## ឯកទេស

# ភូមិវិទ្យា



សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២)

២០២៦

# បុព្វកថា

ទស្សនៈវិស័យអប់រំនាសតវត្សរ៍ទី២១ បានផ្តោតលើការរីកចម្រើនខ្លាំងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឌីជីថល (Digital) ដែលជាមូលដ្ឋានគ្រឹះរឹងមាំមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសគឺការអភិវឌ្ឍធនធានមនុស្សដើម្បីឆ្ពោះទៅរកគំនិតនវានុវត្តន៍ថ្មីៗ សម្រាប់បម្រើឱ្យសេចក្តីត្រូវការរបស់សង្គមជាតិទាំងមូល។ ដោយសារនិន្នាការពិភពលោក ដែលមានការអភិវឌ្ឍឥតឈប់ឈរ ទើបរាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព។

ឈរលើស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ បានដាក់ចេញនូវគោលដៅជាអាទិភាពសម្រាប់ការធ្វើកំណែទម្រង់វិស័យអប់រំដោយផ្អែកលើ សសរស្តម្ភទាំងប្រាំរួមមាន៖ ១. ការអនុវត្តគោលនយោបាយគ្រូបង្រៀន ២.ការវាយតម្លៃ ៣.ការងារអធិការកិច្ច ៤. កម្មវិធីសិក្សា និងបរិស្ថាន ៥.ឧត្តមសិក្សា។ ដោយឡែក កំណែទម្រង់គ្រូបង្រៀន និងកម្មវិធីសិក្សាធានាឱ្យកម្ពុជាមានធនធានមនុស្ស ដែលមានសមត្ថភាពសម្រាប់ដំណើរការអភិវឌ្ឍលើគ្រប់វិស័យ។ ក្រសួងអប់រំ យុវជន និងកីឡាបានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជា នៅគ្រប់កម្រិតគ្រប់ភូមិសិក្សារហូតដល់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា និងកាន់តែធ្វើឱ្យប្រសើរឡើង នូវគុណភាពអប់រំ ក្នុងគោលបំណងឆ្លើយតបទៅនឹងការវិវឌ្ឍរបស់ពិភពលោក និងគោលដៅយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

សៀវភៅសិក្សាគោលនេះ ត្រូវបានកសាងឡើងដោយគ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ ដើម្បីកសាងឧត្តមភាពគុណវុឌ្ឍគ្រូបង្រៀន ទៅតាមទស្សនៈ និងចក្ខុវិស័យថ្មី ជាមួយនឹងខ្លឹមសារបែបវិទ្យាសាស្ត្រ បែបបញ្ញត្តិសិក្សា និងបញ្ចូលគុណសម្បទាសតវត្សរ៍ទី២១ បន្ថែមទៅលើគុណសម្បទាពលរដ្ឋសកល។

វិទ្យាស្ថានជាតិអប់រំសង្ឃឹមថា គ្រប់ស្ថាប័នអប់រំ ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណាប់អារម្មណ៍ទាំងអស់ចូលរួមគាំទ្រ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តលើ កម្មវិធីបណ្តុះបណ្តាលនេះ ដើម្បីពង្រឹងសក្តានុពលរបស់គ្រូបង្រៀននៅគ្រប់កម្រិតសិក្សាទាំងអស់ ដើម្បីអភិវឌ្ឍជំនាញវិជ្ជាជីវៈជាគ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

វិទ្យាស្ថានជាតិអប់រំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះ គណៈកម្មការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាធ្វើឱ្យស្នាដៃដ៏មានសារៈសំខាន់នេះ សម្រេចបានដើម្បីជាប្រយោជន៍ដល់សង្គមជាតិយើង។

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**នាយកវិទ្យាស្ថានជាតិអប់រំ**

# អារម្ភកថា

ឯកសារមុខវិជ្ជាឯកទេសភូមិវិទ្យា សម្រាប់បង្រៀនគរុនិស្សិត បរិញ្ញាបត្រ+២ នេះ គឺបានរៀបចំចងក្រងឡើងដោយក្រុមគ្រូឧទ្ទេសភូមិវិទ្យា សម្រាប់ប្រើប្រាស់ផ្ទៃក្នុងវិទ្យាស្ថានជាតិអប់រំ ដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ខ្លឹមសារនៃឯកសារនេះ ក្រុមគ្រូឧទ្ទេសភូមិវិទ្យាបានរៀបចំជាលំដាប់លំដោយទៅតាមជំពូក និងមេរៀននីមួយៗ។

ខ្លឹមសារមេរៀនដែលមាននៅក្នុងឯកសារចងក្រងនេះ នឹងជួយពង្រឹង និងពង្រីកចំណេះដឹងបន្ថែមដល់គរុនិស្សិតបរិញ្ញាបត្រ+២ ពីសណ្ឋានដីប្រទេសកម្ពុជា អាកាសធាតុប្រទេសកម្ពុជា ផ្លូវទឹកប្រទេសកម្ពុជា ធនធានដីប្រទេសកម្ពុជា ធនធានរ៉ែប្រទេសកម្ពុជា ធនធានសត្វ និងរុក្ខជាតិប្រទេសកម្ពុជា ការរៀបចំរដ្ឋបាលប្រទេសកម្ពុជា ស្ថានភាពប្រជាជនកម្ពុជា សញ្ញាណទូទៅនៃកសិកម្ម មូលដ្ឋានគ្រឹះនៃកសិកម្មពិភពលោក មនុស្សរៀបចំលំហកសិកម្ម កសិកម្មនៅតាមតំបន់ត្រូពិក កសិកម្មនៅប្រទេសឧស្សាហកម្មលូតលាស់ សញ្ញាណទូទៅនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម វិសមភាពនៃការអភិវឌ្ឍនៅលើពិភពលោក វិធីគណនាសន្ទស្សន៍អភិវឌ្ឍមនុស្ស របៀបគណនាផលិតផលជាតិសរុប និងផលិតផលសរុបដុលក្នុងស្រុក ប្រព័ន្ធសេដ្ឋកិច្ច និងរចនាសម្ព័ន្ធសេដ្ឋកិច្ច បរិស្ថាន លក្ខណៈទូទៅនៃប្រជាសាស្ត្រ ប្រជាជន និងការអភិវឌ្ឍនៅប្រទេសកម្ពុជា លក្ខណៈទូទៅនៃទេសចរណ៍ និងសិក្សាស្វែងយល់អំពីកិច្ចអភិវឌ្ឍអេកូ-ទេសចរណ៍ និងពីសមុទ្រ និងមហាសមុទ្រ ប្រភពធនធាន និងផលប៉ះពាល់ផ្សេងសម្រាប់ពេលអនាគត។

ក្រុមគ្រូឧទ្ទេសភូមិវិទ្យាសង្ឃឹមថា ខ្លឹមសារដែលមាននៅក្នុងឯកសារនេះ គរុនិស្សិតភូមិវិទ្យានឹងទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា តាមរយៈការសិក្សាអត្ថបទ សោតទស្សន៍ តារាង រូបភាព ដ្យាក្រាម ការសួរសំណួរ បញ្ចេញមតិយោបល់ ពិភាក្សាក្រុម ស្វ័យសិក្សា និងការសិក្សាស្រាវជ្រាវពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាទំនើបសម័យបច្ចុប្បន្ន ការធ្វើបទបង្ហាញ និងការបង្ហាញស្នាដៃស្រាវជ្រាវ សម្រាប់យកទៅផ្ទេរបន្តដល់សិស្សនៅតាមវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមគ្រូឧទ្ទេសភូមិវិទ្យានៃវិទ្យាស្ថានជាតិអប់រំ មានសេចក្តីសោមនស្សរីករាយនឹងទទួលយកនូវមតិកែលម្អពីគ្រប់មជ្ឈដ្ឋាន។

**ក្រុមគ្រូឧទ្ទេសភូមិវិទ្យានៃវិទ្យាស្ថានជាតិអប់រំ**

ចងក្រង និងបោះពុម្ពដោយ៖ វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២៦
គាំទ្រថវិកាដោយវិទ្យាស្ថានជាតិអប់រំ
© វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៦

## គណៈកម្មការនិពន្ធ

-ញ៉ិល សល្យ
-លោកស្រី ពន់ ជា
-លោក ញ៉ែម ចន្ធា
-លោក មិន សោភ័ណ
-លោកស្រី ឌូ ម៉ារីណែត

## គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

-បណ្ឌិត សោន វណ្ណៈ
-លោក ប៊ុនលី ម៉ារឌី
-លោកស្រី វ៉ា ចំណាន
-លោក ញ៉ិល សល្យ
-លោកស្រី ឌូ ម៉ារីណែត

## គណៈកម្មការរចនា

-លោក ប៊ុនលី ម៉ារឌី
-លោកស្រី វ៉ា ចំណាន
-លោកស្រី វីរៈ ខេងឡា
-កញ្ញា ជា សូជាភា
-កញ្ញា កែវ កញ្ញា

## គណៈកម្មការគ្រប់គ្រង

-ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា
-លោក ម៉ៅ សារឿន
-បណ្ឌិត អាន រ៉ូប្រាវ

# មាតិកា


**បុព្វកថា** ........ i

**អារម្ភកថា** ........ ii

**គណៈកម្មការរៀបចំ** ........ iii

**មាតិកា** ........ iv

**ជំពូកទី១៖ ភូមិវិទ្យាប្រទេសកម្ពុជា** ........ 1

**មេរៀនទី១៖ លក្ខខណ្ឌធម្មជាតិប្រទេសកម្ពុជា** ........ 1

១. សណ្ឋានដីប្រទេសកម្ពុជា ........ 1

១.១. ស្ថានភាពភូមិសាស្ត្រប្រទេសកម្ពុជា ........ 1

១.១. សណ្ឋានដីប្រទេសកម្ពុជា ........ 2

២. ប្រព័ន្ធផ្លូវទឹកនៅប្រទេសកម្ពុជា ........ 30

២.១. ប្រព័ន្ធទន្លេមេគង្គ ........ 31

២.២. ប្រព័ន្ធទន្លេទន្លេសាប ........ 36

២.៣. ប្រព័ន្ធផ្លូវទឹកនៅតំបន់មាត់សមុទ្រ ........ 43

២.៤. សារៈសំខាន់សេដ្ឋកិច្ចប្រព័ន្ធផ្លូវទឹកនៅកម្ពុជា ........ 45

៣. អាកាសធាតុប្រទេសកម្ពុជា លក្ខណៈទូទៅនៃអាកាសធាតុ ........ 47

៣.១. លក្ខណៈទូទៅនៃអាកាសធាតុ ........ 47

៣.២. អាកាសធាតុប្រទេសកម្ពុជា ........ 67

៤. ធនធានរ៉ែនៅកម្ពុជា ........ 74

៤.១. លក្ខណៈទូទៅនៃរ៉ែ ........ 74

៤.២. ធនធានរ៉ែនៅប្រទេសកម្ពុជា ........ 81

៥. ធនធានដីនៅកម្ពុជា ........ 88

៥.១. លក្ខណៈទូទៅនៃធនធានដី ........ 88

៥.២. ធនធានដីនៅប្រទេសកម្ពុជា ........ 101

៦. រុក្ខជាតិ និង សត្វនៅប្រទេសកម្ពុជា ........ 106
៦.១. លក្ខណៈទូទៅ ........ 106
៦.២. រុក្ខជាតិ និងសត្វនៅប្រទេសកម្ពុជា ........ 113
**មេរៀនទី ២៖ លក្ខខណ្ឌសង្គមកម្ពុជា** ........ 119
១. ការរៀបចំរដ្ឋបាលនៅកម្ពុជា ........ 119
១.១. ស្ថាប័នព្រះមហាក្សត្រ ........ 119
១.២. ប្រព័ន្ធនយោបាយ ........ 120
២. ស្ថានភាពប្រជាជនកម្ពុជា ........ 148
២.១. ចំនួន និងរបាយប្រជាជនកម្ពុជា ........ 148
២.២. ដង់ស៊ីតេប្រជាជនកម្ពុជា ........ 150
២.៣. អត្រាកំណើនប្រជាជនកម្ពុជា ........ 151
២.៤. អត្រាមរណៈនៃប្រជាជនកម្ពុជា ........ 152
២.៥. ទម្រង់តាមអាយុនៃប្រជាជនកម្ពុជា ........ 152
២.៦. អត្រាភេទនៃប្រជាជនកម្ពុជា ........ 153
២.៧. លទ្ធភាពបង្កកំណើតនៃប្រជាជនកម្ពុជា ........ 154
២.៨. ដំណុះប្រជាជនកម្ពុជា ........ 155
២.៩. ជាតិសាសន៍នានានៅប្រទេសកម្ពុជា ........ 156
**ជំពូកទី២៖ ភូមិវិទ្យាកសិកម្ម** ........ 159
**មេរៀនទី១៖ លក្ខណៈសំគាល់ទូទៅ និងមូលដ្ឋានគ្រឹះនៃកសិកម្ម** ........ 159
១. លក្ខណៈទូទៅនៃកសិកម្ម ........ 159
១.១. កំណើត និងការវិវត្តន៍នៃទេសភាពជនបទ ........ 159
១.២. ប្រព័ន្ធកសិកម្មនៅលើពិភពលោក ........ 160
១.៣. បដិវត្តន៍កសិកម្ម ........ 162
១.៤. របាយសកម្មភាពកសិកម្មលើពិភពលោក ........ 163

២. មូលដ្ឋានគ្រឹះនៃកសិកម្ម ..... 167
២.១. តួនាទីកសិកម្មក្នុងខឿនសេដ្ឋកិច្ច ..... 167
២.២. ចំនុចពិសេសរួមនិយាយពីការរីកចំរើនកសិកម្មលើពិភពលោក ..... 168
២.៣. ប្រព័ន្ធ និងទ្រង់ទ្រាយផលិតកម្មកសិកម្ម ..... 172
២.៤. កត្តា និងលក្ខខណ្ឌផលិតកម្មក្នុងកសិកម្ម ..... 174
២.៥. ទ្រង់ទ្រាយចាត់តាំងផលិតកម្មកសិកម្មក្នុងតំបន់កសិកម្ម ..... 177
២.៦. ប្រពលវប្បកម្ម ..... 179
២.៧. ពហុផលិតកម្មលើទឹកដីកសិកម្ម ..... 180
**មេរៀនទី២៖ មនុស្សរៀបចំលំហកសិកម្ម** ..... 183
១. លំហកសិកម្មនៅលើពិភពលោក ..... 183
១.១. ភូមិសាស្ត្រនៃផ្ទៃដីដាំដុះ ..... 183
១.២. មធ្យោបាយពង្រីកផ្ទៃដីដាំដុះ ..... 184
២. មនុស្សស្ដាបនាទេសភាពកសិកម្ម ..... 186
២.១. វិភាគទេសភាពកសិកម្ម ..... 186
២.២. ការស្ដាបនាទេសភាពកសិកម្ម ..... 187
៣. ពលករដីធ្លី ..... 188
៣.១. អ្នកស្រែចម្ការនៅលើពិភពលោក ..... 188
៣.២. កម្មសិទ្ធិដីធ្លី ..... 188
៣.៣. ការធ្វើអាជីវកម្មដីធ្លី ..... 188
៤. បដិវត្តន៍បៃតង ..... 189
៤.១. និយមន័យ ..... 189
៤.២. គុណសម្បត្តិ និងគុណវិបត្តិ នៃបដិវត្តន៍បៃតង ..... 190
៥. កសិកម្ម និងបរិស្ថាន ..... 191
**មេរៀនទី៣៖ កសិកម្មនៅតំបន់ត្រូពិក** ..... 193

១. អាកាសធាតុអនុគ្រោះ ប៉ុន្តែដីជាំដុះឆាប់អស់ជីជាតិ ............ 193
២. កសិកម្មប្រពៃណីបែបចិញ្ចឹមពោះ ............ 193
៣. កសិកម្មចម្ការធំៗ ............ 196
**មេរៀនទី៤៖ កសិកម្មនៅបណ្ដាប្រទេសឧស្សាហកម្មលូតលាស់** ............ 198
១. កសិកម្មតាមបែបមូលធន ............ 198
១.១. ពីកសិកម្មទៅកសិ-ពាណិជ្ជកម្ម ............ 198
១.២. លក្ខណៈសម្គាល់ នៃកសិកម្មមូលធន ............ 198
១.៣. គុណសម្បត្តិ នៃកសិកម្មមូលធន ............ 199
១.៤. សិកម្មប្រពៃណីក្នុងបណ្ដាប្រទេសលូតលាស់ ............ 200
២. កសិកម្មនៅបណ្ដាប្រទេសសង្គមនិយម ............ 201
**ជំពូកទី៣៖ ភូមិវិទ្យាអភិវឌ្ឍ** ............ 203
**មេរៀនទី១៖ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម** ............ 203
១. ស្សនៈស្ដីពីការចំរើនឡើង និងទស្សនៈស្ដីពីការអភិវឌ្ឍ ............ 203
១.១. ទស្សនៈស្ដីពីការចម្រើនឡើង ............ 203
១.២. ទស្សនៈស្ដីពីការអភិវឌ្ឍ ............ 204
២. ទំនាក់ទំនងគ្នារវាងការធ្វើអោយចំរើនឡើង និងការអភិវឌ្ឍ ............ 207
៣. ប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ ............ 207
៣.១. ប្រទេសអភិវឌ្ឍ (Developed Countries) ............ 207
៣.២. ប្រទេសកំពុងអភិវឌ្ឍ (Developing Countries) ............ 209
**មេរៀនទី២៖ វិធីគណនាសន្ទស្សន៍អភិវឌ្ឍមនុស្ស** (HDI) ............ 213
១. គណនាសន្ទស្សន៍អាយុកាលជាមធ្យម ............ 213
២. គណនាសន្ទស្សន៍អប់រំ ............ 213
៣. គណនាសន្ទស្សន៍កម្រិតជីវភាព ............ 214
៤. លំហាត់អនុវត្ត ............ 214

**មេរៀនទី៣៖ វិធីគណនាផលិតផលជាតិសរុប និងផលិតផលក្នុងស្រុកសរុប** ............ 218
១. និយមន័យផលិតផលក្នុងស្រុកសរុប (GDP) និងផលិតផលជាតិសរុប (GNP) ........................ 218
១.១. ផលិតផលក្នុងស្រុកសរុប (GDP : Gross Domestic Product) .................................. 218
១.២. ផលិតផលជាតិសរុប (GNP : Gross National Product) ............................................ 218
២. ភាពខុសគ្នារវាង GNP និង GDP ............................................................................ 219
៣. តំលៃនៃការផ្ដោះប្ដូរប្រាក់ ......................................................................................... 220
៤. វិធីគណនា GNP និង GDP ......................................................................................... 220
៤.១. ចំនុចគួរយកចិត្តទុកដាក់ ......................................................................................... 220
៤.២. របៀបគណនា GNP និង GDP របស់អង្គការសហប្រជាជាតិ និងក្រុមសង្គមសេដ្ឋកិច្ច .......... 221
៤.៣. របៀបគណនារួមឱ្យទូទាំងពិភពលោក (តាមអង្គការសហប្រជាជាតិ) ............................. 221
៥. GNP និង GDP គិតជាមធ្យមតាមចំនួនមនុស្សម្នាក់ៗ ................................................. 222
**មេរៀនទី៤៖ វិសមភាពនៃការអភិវឌ្ឍនៅលើពិភពលោក** ................................................ 223
១. ប្រវត្តិនៃការចែកពិភពលោក ....................................................................................... 223
១.១. ការបែងចែកតាមប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយ .......................................................... 223
១.២. ការបែងចែកតាមកម្រិតអភិវឌ្ឍ ................................................................................ 224
២. រង្វាស់វិសមភាពនៃការរីកលូតលាស់ ............................................................................. 226
២.១. គោល ឬសូចនាករប្រជាសាស្ត្រ ................................................................................... 226
២.២. គោល ឬសូចនាករសេវាសង្គម ឬការបំពេញតម្រូវការសំខាន់ៗ ......................................... 227
២.៣. គោល ឬសូចនាករសេដ្ឋកិច្ច ....................................................................................... 228
២.៤. គោល ឬសូចនាករសន្ទស្សន៍អភិវឌ្ឍមនុស្ស .................................................................. 231
៣. លោកខាងត្បូង បានកំនត់សម្គាល់ដោយវិសមភាព ............................................................ 234
៣.១. ប្រទេសក្រីក្រ .......................................................................................................... 235
៣.២. ប្រទេសឧស្សាហកម្មថ្មី ............................................................................................. 236
៣.៣. ប្រទេសនាំចេញអ៊ីដ្រូកាបួរ .......................................................................................... 236

៣.៤. ប្រទេសនៅចន្លោះកណ្តាល (រវាងអ្នកក្រ និងអ្នកមាន) ........ 236
៣.៥. ប្រទេសឥណ្ឌា និងចិន ........ 236
៤. ការកាត់បន្ថយវិសមភាពរវាងលោកខាងជើង និងលោកខាងត្បូង ........ 236
៤.១. ដោយបង្កើតលក្ខខណ្ឌខាងពាណិជ្ជកម្មអន្តរជាតិត្រឹមត្រូវ ........ 236
៤.២. ដោយជំរុញនូវបណ្តូររវាងបណ្តាប្រទេសលោកខាងត្បូង ........ 237
៤.៣. ដោយជួយបណ្តាប្រទេសទន់ខ្សោយ ........ 237
**ជំពូកទី៤៖ ភូមិវិទ្យាតំបន់អឺរ៉ុប** ........ 241
**មេរៀនទី១៖ ស្ថានភាពទូទៅនៃទ្វីបអឺរ៉ុប** ........ 241
១. ទីតាំងភូមិសាស្ត្រ ........ 241
២. ផ្ទៃដី ........ 241
៣. បណ្តាប្រទេសនៅទ្វីបអឺរ៉ុប ........ 243
៤. ប្រជាជនទ្វីបអឺរ៉ុប ........ 244
៥. សេដ្ឋកិច្ចអឺរ៉ុប ........ 247
**មេរៀនទី២៖ សណ្ឋានដីទ្វីបអឺរ៉ុប** ........ 249
១. តំបន់ភ្នំភាគពាយ័ព្យ ........ 249
២. តំបន់ទំនាបធំអឺរ៉ុប ........ 251
៣. តំបន់ខ្ពង់រាបកណ្តាល និងជួរភ្នំភាគខាងត្បូង ........ 252
**មេរៀនទី៣៖ អាកាសធាតុ រុក្ខជាតិ និងសត្វព្រៃនៅទ្វីបអឺរ៉ុប** ........ 255
១. ស្ថានភាពទូទៅនៃអាកាសធាតុទ្វីបអឺរ៉ុប ........ 255
២. អាកាសធាតុអង់គ្លេស ........ 256
៣. អាកាសធាតុទ្វីប ........ 257
៤. អាកាសធាតុមេឌីទែរ៉ាណេ ........ 258
៥. អាកាសធាតុតៃហ្គា ........ 259
៦. អាកាសធាតុទុនត្រា ........ 260

**មេរៀនទី៤៖ ធនធានធម្មជាតិនៅទ្វីបអឺរ៉ុប** ........ 261
១. ធនធានធម្មជាតិ ........ 261
២. ករណីសិក្សាពីបដិវត្តន៍ឧស្សាហកម្មនៅចន្លោះសតវត្សរ៍ទី១៨-១៩ ........ 263
**មេរៀនទី៥៖ សហភាពអឺរ៉ុប** ........ 267
១. ប្រវត្តិនៃការកសាងសហភាពអឺរ៉ុប ........ 267
២. ចំណុចខ្លាំង និងចំណុចខ្សោយរបស់សហភាពអឺរ៉ុប នៅលើពិភពលោក ........ 275
៣. ទំនាក់ទំនងរវាងសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ........ 277
៤. ទំនាក់ទំនងសហភាពអឺរ៉ុប និងអាស៊ាន ........ 278
៥. ទំនាក់ទំនងសហភាពអឺរ៉ុប និងរុស្ស៊ី ........ 280
៦. ករណីសិក្សាអំពីអ្វីទៅជា BRIEXIT? ........ 281
**ជំពូកទី៥ ៖ ភូមិវិទ្យាតំបន់អាស៊ាន** ........ 284
**មេរៀនទី១៖ ប្រវត្តិនៃការកកើតសមាគមអាស៊ាន** ........ 284
១. អាស៊ាន ដូចម្តេចដែលហៅថាអាស៊ាន? WHAT IS ASEAN? ........ 286
២. អត្ថន័យនៃនិមិត្តសញ្ញាអាស៊ាន( ASEAN EMBLEM ) ........ 286
**មេរៀនទី២៖ ធម្មនុញ្ញអាស៊ាន** ........ 288
១. គោលបំណង និងគោលការណ៍ ........ 288
២. សមាជិកភាព ........ 289
៣. កិច្ចប្រជុំកំពូលអាស៊ាន ........ 290
៣.១. កិច្ចប្រជុំកំពូលអាស៊ាន ត្រូវចូលរួមដោយប្រមុខរដ្ឋ / រដ្ឋាភិបាលនៃសមាជិកអាស៊ាន។ ........ 290
៣.២. កិច្ចប្រជុំកំពូលអាស៊ាន៖ ........ 290
៣.៣. កិច្ចប្រជុំកំពូលអាស៊ានត្រូវ៖ ........ 290
៤. អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែករបស់អាស៊ាន៖ ........ 291
៤.១. អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែករបស់អាស៊ានត្រូវ៖ ........ 291
៤.២. អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកនីមួយៗរបស់អាស៊ាន ........ 292

**មេរៀនទី៣៖ បណ្តាប្រទេសអាស៊ាន របបនយោបាយ បញ្ហា និង សេដ្ឋកិច្ច**........296
១. ប្រទេសកម្ពុជា........296
២. ប្រទេសវៀតណាម........302
៣. ប្រទេសឥណ្ឌូនេស៊ី........306
៤. សហព័ន្ធម៉ាឡេស៊ី........313
៥. ប្រទេសប្រ៊ុយណេ........318
៦. ប្រទេសសិង្ហបុរី........322
៧. ប្រទេសថៃ........329
៨. ប្រទេសមីយ៉ាន់ម៉ា........335
៩. ហ្វីលីពីន/ភីលីពីន........342
១០. ប្រទេសឡាវ........348
**មេរៀនទី៤៖ សេដ្ឋកិច្ចអាស៊ាន**........353
១. ទំហំសេដ្ឋកិច្ចអាស៊ាន........353
២. ដៃគូពាណិជ្ជកម្មអាស៊ាន........354
**មេរៀនទី៥៖ ទំនាក់ទំនងអាស៊ាន និងបណ្តាប្រទេសមហាអំណាចក្នុងពិភពលោក**........359
១. ជំនួបកំពូលអាស៊ានបូក៣ ទៅជំនួបកំពូលអាស៊ីបូព៌ា........359
២. ទំនាក់ទំនងអាស៊ាន និងឥណ្ឌា........361
៣. ទំនាក់ទំនងអាស៊ាន និងជប៉ុន៖ ដៃគូចាំបាច់........363
៤. ទំនាក់ទំនងអាស៊ាននិងចិន៖ ទំនាក់ទំនងបង្កប់ទៅដោយការមិនទុកចិត្ត........365
៥. ទំនាក់ទំនងអាស៊ាន និងសហរដ្ឋអាមេរិក........368
៦. ទំនាក់ទំនងអាស៊ាន និងសហភាពអឺរ៉ុប៖ នៅតែស្វែងរកគ្នាមិនទាន់ឃើញ........370
**ជំពូកទី៦៖ ភូមិវិទ្យាទេសចរណ៍ និងអេកូ-ទេសចរណ៍**........376
**មេរៀនទី១៖ សញ្ញាណទូទៅនៃភូមិវិទ្យា ទេសចរណ៍**........376
១. លក្ខណៈទូទៅនៃទេសចរណ៍........376

១.១. បញ្ញាត្តិផ្សេងៗនៃទេសចរណ៍ ........ 376
១.២. ប្រវត្តិទេសចរណ៍ ........ 376
១.៣. អ្នកណាជាទេសចរ? ........ 379
២. ភាពខុសគ្នានៃការធ្វើដំណើរ និងទេសចរណ៍ ........ 379
៣. ប្រភេទទេសចរណ៍ ........ 380
៣.១. ប្រភេទទេសចរណ៍គិតទៅតាមទ្រង់ទ្រាយ ........ 380
៣.២. ប្រភេទទេសចរណ៍គិតទៅតាមគោលបំណង ........ 381
៣.៣. ប្រភេទទេសចរណ៍គិតទៅតាមមធ្យោបាយធ្វើដំណើរ ........ 382
៣.៤. ប្រភេទទេសចរណ៍គិតទៅតាមលទ្ធភាពចំណាយ ........ 382
៤. ហេតុផលនៃការមានភូមិវិទ្យាទេសចរណ៍ ........ 382
៤.១. ហេតុអ្វីបានជាមនុស្សធ្វើដំណើរទេសចរណ៍? ........ 382
៤.២. ហេតុអ្វីបានជាមាន ភូមិវិទ្យា ទេសចរណ៍? ........ 384
៥. កត្តាដែលមានឥទ្ធិពលដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ........ 384
៦. លក្ខណៈពិសេសនៃវិស័យទេសចរណ៍ ........ 385
៧. ផលិតផលទេសចរណ៍ ........ 385
៧.១. ផលិតផលទេសចរណ៍ជាអ្វី? ........ 385
៧.២.ទីផ្សារការធ្វើដំណើរ និងទេសចរណ៍ ........ 387
៨. តម្រូវការលើការធ្វើដំណើរ និងទេសចរណ៍ ........ 388
៨.១. តម្រូវការមុនពេលធ្វើដំណើរ ........ 388
៨.២. តម្រូវការកំឡុងពេលធ្វើដំណើរ ........ 389
៨.៣. តម្រូវការលើការស្នាក់នៅ និងអាហារ ........ 389
៨.៤. តម្រូវការក្នុងតំបន់ទេសចរណ៍ ........ 389
៨.៥. តម្រូវការលើការទិញវត្ថុអនុស្សាវរីយ៍ និងរក្សាចំណាប់អារម្មណ៍ ........ 390
**មេរៀនទី២៖ កម្មវត្ថុ រដ្ឋបាល មុខងារ និងឥទ្ធិពលវិស័យទេសចរណ៍** ........ 392

១. ច្បាប់រដ្ឋបាលទេសចរណ៍ ........ 392
១.១. លិខិតឆ្លងដែន ........ 392
១.២. ទិដ្ឋាការ ........ 393
១.៣. ច្រកចេញ-ចូល ........ 393
១.៤. គយ ........ 393
១.៥. ពន្ធក្រៅប្រទេស ........ 394
១.៦. សម្បទាពន្ធសម្រាប់ទេសចរណ៍ ........ 394
២. មុខងារ និងជាតុផ្សំនៃទីផ្សារទេសចរណ៍ ........ 395
២.១. មុខងារនៃទីផ្សារទេសចរណ៍ ........ 395
២.២. ជាតុផ្សំនៃទីផ្សារទេសចរណ៍ ........ 395
៣. ឥទ្ធិពលទេសចរណ៍ទៅលើវិស័យផ្សេងៗ ........ 396
៣.១. ឥទ្ធិពលទេសចរណ៍ទៅលើវិស័យសេដ្ឋកិច្ច ........ 396
៣.២. ឥទ្ធិពលទេសចរណ៍ទៅលើវិស័យបរិស្ថាន ........ 397
៣.៣. ឥទ្ធិពលទេសចរណ៍ទៅលើសង្គម ........ 398
៣.៤. ឥទ្ធិពលទេសចរណ៍ទៅលើវិស័យវប្បធម៌ ........ 398
៤. កម្មវត្ថុទេសចរណ៍ ........ 399
៤.១. លទ្ធភាពនៃការទទួលទេសចរណ៍ ........ 399
៤.២. តំបន់ទេសចរណ៍ ........ 400
**មេរៀនទី៣៖ សញ្ញាណទូទៅនៃអេកូ-ទេសចរណ៍ និងប្រព័ន្ធតំបន់ការពារធម្មជាតិ នៅព្រះរាជាណាចក្រកម្ពុជានៃអេកូ-ទេសចរណ៍** ........ 403
១.សញ្ញាណទូទៅនៃអេកូ-ទេសចរណ៍ ........ 403
១.១. អ្វីទៅជាអេកូ-ទេសចរណ៍? ........ 403
១.២. អត្ថប្រយោជន៍អេកូទេសចរណ៍ ........ 405
១.៣. ឥទ្ធិពលអេកូ-ទេសចរណ៍ទៅលើវិស័យផ្សេងៗ ........ 406

១.៤. ទស្សនវិស័យនៃអេកូ-ទេសចរណ៍ ........ 410
១.៥. គោលនយោបាយជាតិលើការអភិវឌ្ឍអេកូ-ទេសចរណ៍ ........ 412
២. អេកូ-ទេសចរណ៍កម្ពុជា ........ 413
២.១. គោលនយោបាយសម្រាប់វិស័យ អេកូ-ទេសចរណ៍ ........ 413
២.២. ជម្រើសជាយុទ្ធសាស្ត្រនៃអេកូ-ទេសចរណ៍ ........ 414
២.៣. ការរៀបចំអភិវឌ្ឍអេកូ-ទេសចរណ៍ ........ 415
២.៤. កាលានុវត្តភាព និងការគម្រាមកំហែង ........ 415
៣. ប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជា ........ 417
៣.១. ការកំណត់តំបន់ការពារធម្មជាតិ ........ 417
៣.២. ការធ្វើចំណាត់ថ្នាក់តំបន់ការពារធម្មជាតិ ........ 418
៣.៣. លំនឹងជីវចម្រុះ និង ការបាត់បង់ជីវៈចម្រុះ ........ 432
៣.៤. សត្វ និងរុក្ខជាតិជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ........ 434
**ជំពូកទី៧ ៖ ភូមិវិទ្យា ប្រជាជន ឬប្រជាគណន៍** ........ 436
**មេរៀនទី១ ៖ រំលឹកបញ្ញាត្តិទូទៅ និងកំណើនប្រជាជនពិភពលោកនៅដើម សហស្សវត្សទី៣** ........ 436
១. បញ្ញាត្តិទូទៅនៃភូមិវិទ្យាប្រជាជន ........ 436
២. ប្រវត្តិកំណើនប្រជាជន ........ 440
២.១. ប្រវត្តិកំណើនប្រជាជនមុនឆ្នាំ១៦៥០ ........ 440
២.២. ប្រវត្តិកំណើនប្រជាជនពីឆ្នាំ ១៦៥០ ដល់ឆ្នាំ ១៩៥០ ........ 441
២.៣. ប្រវត្តិកំណើនប្រជាជនពីឆ្នាំ ១៩៥០ មក ........ 441
៣. អន្តរភាពប្រជាសាស្ត្រ ........ 441
៣.១. របបប្រជាសាស្ត្រប្រពៃណី ........ 441
៣.២. អន្តរភាពប្រជាសាស្ត្រវគ្គទី១ ........ 441
៣.៣. អន្តរភាពប្រជាសាស្ត្រវគ្គទី២ ........ 442

៣.៤. អន្តរភាពប្រជាសាស្ត្រទំនើប ........ 442
៤. ពិភពលោកមួយបែងចែក ទៅតាមប្រជាសាស្ត្រ ........ 442
៥. កំណើនប្រជាជន និងភាពក្រីក្រ ........ 442
៥.១. ពេលដំបូងនៃអន្តរភាពប្រជាសាស្ត្រ ........ 442
៥.២. ដំណាក់កាលទី២នៃអន្តរភាពប្រជាសាស្ត្រ ........ 443
៥.៣. ការមានកូនច្រើនជាគុណប្រយោជន៍សម្រាប់គ្រួសារក្រីក្រីដែរឬទេ ? ........ 443
៦. របាយប្រជាជនពិភពលោក ........ 443
៦.១. ការប៉ាន់ស្មានចំនួនប្រជាជនតាមតំបន់ធំៗ ........ 443
៦.២. ប្រទេសដែលមានប្រជាជនច្រើនជាងគេ ........ 444
៦.៣. ការវិវត្តប្រជាសាស្ត្រ ........ 444
៦.៤. ប្រជាជននឹងមាន៩ពាន់លាននាក់នៅឆ្នាំ២០៥០ ........ 445
៧. ការលំបាកក្នុងការវាស់វិសមភាពនៃការអភិវឌ្ឍ ........ 446
៧.១. ផាសុកភាព និង ទុរគ៌តភាព ........ 446
៧.២. បញ្ញាត្តិនានានៃតតិយលោក លោកខាងជើង និងលោកខាងត្បូង ........ 448
៧.៣. វិសមភាពវាស់តាម GDP ឬ HDI ........ 448
៨. ពិភពលោកមួយមានការអភិវឌ្ឍមិនស្មើគ្នា ........ 450
៨.១. ការរៀបចំឡើងវិញនូវប្រព័ន្ធពិភពលោក ........ 451
៨.២. ប្រទេសលោកខាងជើង ........ 451
៨.៣. ប្រទេសលោកខាងត្បូង ........ 452
**មេរៀនទី២ ៖ ប្រជាជន និងការអភិវឌ្ឍនៅកម្ពុជា** ........ 454
១. ទម្រង់ប្រជាសាស្ត្រនៃកម្ពុជា ........ 454
១.១. ទម្រង់ប្រជាសាស្ត្រ ........ 454
១.២. ដង់ស៊ីតេនិងលទ្ធភាពបង្កកំណើតនៃប្រជាជនកម្ពុជា ........ 454
១.៣. កម្រិតលទ្ធភាពបង្កកំណើត ........ 456

២. វិសមភាពនៃការប្រើប្រាស់សេវានៅកម្ពុជា ... 457
៣. អាយុសង្ឃឹមរស់នៃប្រជាជនកម្ពុជា ... 457
៣.១. អាយុសង្ឃឹមរស់ ... 457
៣.២. កត្តាដែលមានឥទ្ធិពលលើ អាយុសង្ឃឹមរស់របស់ប្រជាជនកម្ពុជា ... 458
**ជំពូកទី៨៖ សមុទ្រ និងមហាសមុទ្រ ... 461**
**មេរៀនទី១៖ សមុទ្រ និង មហាសមុទ្រ ... 461**
១. កំណកំណើតភពផែនដី ... 461
១.១. បរិយាកាសអតីតកាលនិងបច្ចុប្បន្នកាល ... 462
២. វដ្តទឹក និងទឹកលើផែនដី ... 463
២.១. វដ្តទឹក ... 463
២.២. របាយទឹកលើភពផែនដី ... 464
៣. របាយមហាសមុទ្រលើពិភពលោក ... 465
៣.១. របាយមហាសមុទ្រ ... 465
៤. សណ្ឋានដីបាតសមុទ្រ ... 466
៤.១. ជាយទ្វីប ... 466
៤.២. តំបន់អាងសមុទ្រ ... 467
៥. ទឹកសមុទ្រ និងមហាសមុទ្រ ... 467
៥.១. ជាតិប្រៃនៃទឹកសមុទ្រ ... 468
៥.២. ដង់ស៊ីតេទឹកសមុទ្រ ... 468
៥.៣. សីតុណ្ហភាពទឹកសមុទ្រ ... 468
៥.៤. កំណកទឹកសមុទ្រ ... 469
៥.៥. តំបន់មហាសមុទ្រ ... 469
**មេរៀនទី២ ៖ សមុទ្រ ជាធនធានធម្មជាតិ ... 472**
១. ការនេសាទ និងបច្ចេកទេសនេសាទ ... 472

១.១. ការនេសាទ ........ 472

១.២. ការវិវត្តន៍បច្ចេកទេសនេសាទ ........ 473

១.៣. របៀបនេសាទ ........ 474

២. អាជីវកម្មធនធានរ៉ែក្នុងសមុទ្រ ........ 474

២.១. រ៉ែប្រេងកាត ........ 475

២.២. ធនធានរ៉ែដ៏ទៃទៀត ........ 475

៣. សកម្មភាពតំបន់ឆ្នេរសមុទ្រ ........ 475

៣.១. តំបន់ឧស្សាហកម្ម ........ 476

៣.២. តំបន់ទេសចរណ៍ ........ 477

៤. បញ្ហាសមុទ្រ ........ 478

៤.១. គ្រោះថ្នាក់បណ្តាលមកពីការនេសាទហួសហេតុ ........ 479

៤.២. គ្រោះថ្នាក់បណ្តាលមកពីកង្វក់បរិស្ថាន ........ 481

# ជំពូកទី១៖ ភូមិវិទ្យាប្រទេសកម្ពុជា
# មេរៀនទី១៖ លក្ខខណ្ឌធម្មជាតិប្រទេសកម្ពុជា

## ១. សណ្ឋានដីប្រទេសកម្ពុជា

### ១.១. ស្ថានភាពភូមិសាស្ត្រប្រទេសកម្ពុជា

### ក. ទីតាំងភូមិសាស្ត្រ

ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ គឺស្ថិតនៅភាគខាងត្បូងឧបទ្វីបឥណ្ឌូចិន។ បើយោងទៅតាមផ្ទៃដី ដែលមានផ្ទៃដីសរុបចំនួន ១៨១ ០៣៥ គ.ម$^{២}$ នោះប្រទេសកម្ពុជា យើងមានទំហំតូចជាងប្រទេសចិន ៥៤ ដង តូចជាងប្រទេសឥណ្ឌា ១៨ ដង និងតូចជាងប្រទេសឥណ្ឌូនេស៊ី ១០ ដង ស្មើនឹង ១/៤ នៃប្រទេសភូមា ស្មើនឹង ១/៣ នៃប្រទេសថៃ ស្មើនឹងពាក់កណ្ដាលនៃប្រទេសវៀតណាម តូចជាងប្រទេសឡាវតែបន្តិចប៉ុណ្ណោះ ក៏ប៉ុន្តែធំជាងប្រទេសណេប៉ាល់ ប្រទេសស្រីលង្កា និងប្រទេសផ្សេងៗទៀតដូចជាប្រទេសព្រុយណេ ប្រទេសសិង្ហបុរី និងប្រទេសទីម័រខាងកើត ពោលបើធៀបទៅនឹងបណ្ដាប្រទេសទាំង ១១ នៅភូមិភាគអាស៊ីអាគ្នេយ៍វិញ គឺប្រទេសកម្ពុជាយើងជាប់ចំណាត់ថ្នាក់លេខ ៨ ក្នុងចំណោមប្រទេសទាំងនេះ។

បើយោងទៅតាមកូអរដោណេភូមិសាស្ត្រ ប្រទេសកម្ពុជាយើងស្ថិតនៅចន្លោះខ្សែស្របទី១០$^{0}$ ដល់ទី ១៥$^{0}$ នៃរយៈទទឹងខាងជើង និងស្ថិតនៅចន្លោះខ្សែបណ្ដោយទី ១០២$^{0}$ ដល់ទី ១០៨$^{0}$ នៃរយៈបណ្ដោយខាងកើត។ កូអរដោណេភូមិសាស្ត្របែបនេះ បញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅក្នុងតំបន់ត្រូពិច នៅក្នុងអឌ្ឍគោលខាងជើង ដែលមានអាកាសធាតុក្ដៅហើយសើម មានសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំ ២៧ អង្សារសេ និងស្ថិតនៅក្នុងតំបន់អាស៊ីមូសុង ដែលទទួលទឹកភ្លៀងគ្រប់គ្រាន់ប្រចាំឆ្នាំសម្រាប់អនុគ្រោះដល់ការលូតលាស់របស់ពពួករុក្ខជាតិ ដំណាំ និងជីវិតសត្វគ្រប់ប្រភេទ។

លើសពីនេះទៅទៀត ដោយសារប្រទេសកម្ពុជាមានទីតាំងជាប់នឹងតំបន់មាត់សមុទ្រ រួមនឹងលក្ខណៈអនុគ្រោះទាំងនេះហើយ បានបង្កឱ្យប្រទេសកម្ពុជាយើងអាចមានលទ្ធភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយនឹងបណ្ដាប្រទេសនានានៅលើពិភពលោក ពិសេសក្នុងវិស័យពាណិជ្ជកម្ម និងមានលក្ខណៈល្អប្រសើរផងដែរ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន ជាពិសេសអភិវឌ្ឍវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យទេសចរណ៍ ពីព្រោះជាតំបន់ ដែលទទួលឥទ្ធិពលអាកាសធាតុក្ដៅ ហើយសើមស្ទើរតែពេញមួយឆ្នាំ។

### ខ. ព្រំប្រទល់

ព្រំប្រទល់ប្រទេសកម្ពុជាយើងទាំងមូល ដោយមិនរាប់បញ្ចូលនូវកោះទាំងឡាយ នៅក្នុងឈូងសមុទ្រ មានប្រវែងសរុប ២ ៦០០ គ.ម ដែលក្នុងនោះព្រំប្រទល់ដីគោកស្មើនឹង ៥/៦ និងព្រំប្រទល់ សមុទ្រស្មើនឹង ១/៦។

#### ១. ព្រំប្រទល់ដីគោក

ប្រទេសកម្ពុជាយើងមានព្រំប្រទល់ដីគោកជាប់ជាមួយប្រទេស៣ដែលស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍គឺ ៖

- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ៖ នៅភាគខាងជើងមួយផ្នែក និងភាគឦសានមួយផ្នែក ដែលមានប្រវែងសរុបចំនួន ៥៤១ គ.ម។

– ព្រះរាជាណាចក្រថៃ ៖ នៅភាគខាងជើងមួយផ្នែក និងនៅភាគខាងលិចមួយផ្នែក ដែលមានប្រវែងសរុបចំនួន ៨០៣ គ.ម។
– សាធារណរដ្ឋសង្គមនិយមវៀតណាម៖ នៅភាគខាងកើតមួយផ្នែក និងនៅភាគខាងត្បូងមួយផ្នែក ដែលមានប្រវែងសរុបចំនួន ១ ២២៨ គ.ម។

**២. ព្រំប្រទល់សមុទ្រ**

ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅជាប់នឹងឈូងសមុទ្រថៃ ដែលស្ថិតនៅក្នុងសមុទ្រចិនភាគខាងត្បូង និងស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីភិច។ ឈូងសមុទ្រនេះមានឆ្នេរដោយទ្វីបធំទូលាយ និងជាសមុទ្ររាក់ពិចដែលមានជម្រៅទឹកជាមធ្យម ៥០ ម៉ែត្រ និងជម្រៅជាអតិបរមា ៧៥ ម៉ែត្រ ហើយសម្បូរផលផលគ្រប់បែបយ៉ាង ដែលបង្កលក្ខណៈងាយស្រួលដល់ការនេសាទសមុទ្រ វារីវប្បកម្ម និងជាកន្លែងទេសចរណ៍ដ៏ប្រណីតលាយឡំជាមួយនឹងខ្សាច់ពណ៌ស កោះ ដើមស្វាវ និងដើមកោងកាងប្រកបដោយខ្យល់អាកាសបរិសុទ្ធ។

**៣. ទ្រង់ទ្រាយ និងទំហំ**

ប្រទេសកម្ពុជាយើងមានផ្ទៃដីសរុបចំនួន ១៨១០៣៥ គ.ម² មានរាងជាពហុកោណ ស្ទើរស្មើជ្រុង ដែលមានចំណុចកណ្តាលនៅចំក្រុងស្ទឹងសែន ក្នុងខេត្តកំពង់ធំ និងមានប្រវែងពីជើងទៅត្បូង ៤៤០ គ.ម និងពីលិចទៅកើតមានប្រវែង ៥៦០ គ.ម។ ដោយសារតែប្រទេសកម្ពុជាយើង មានរាងជាពហុកោណស្ទើរស្មើជ្រុងនេះហើយ បានជាប្រទេសកម្ពុជាយើងពុំមានតំបន់ដាច់ស្រយាលឡើយ លើកលែងតែកោះទាំងឡាយនៅក្នុងឈូងសមុទ្រថៃប៉ុណ្ណោះ និងពុំបង្កឱ្យមានការលំបាកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិយើង ហើយបង្កនូវលក្ខណៈងាយស្រួលដល់ការធ្វើដំណើររបស់ប្រជាជនយើងពីតំបន់មួយ ទៅកាន់តំបន់មួយទៀតបានយ៉ាងងាយស្រួលផងដែរ។

## ១.១. សណ្ឋានដីប្រទេសកម្ពុជា

### ១.២.១ ប្រវត្តិធរណីកាល និងបំណែងចែកធរណីកាល

ធរណីកាល គឺជាការសិក្សាអំពីប្រវត្តិរបស់ផែនដី ចាប់តាំងពីការកកើតឡើងរហូតដល់ពេលបច្ចុប្បន្ន ដោយឆ្លងកាត់នូវព្រឹត្តិការណ៍សំខាន់ៗជាច្រើន។

### ក. បំណែងចែកធរណីកាល

ជាទូទៅ គេបានបែងចែកធរណីកាលជា ២ គឺ បុរេកុំប្រ៊ីយាង ឬមុនស័ក និងស័ក។

**១. ការបែងចែកធរណីកាលតាមរបៀបចាស់**

អ្នកវិទ្យាសាស្ត្រសម័យដើម ជាពិសេសអ្នកធរណីវិទ្យាបានធ្វើការបែងចែកធរណីកាល ដោយពួកគេបានរៀបតាមលំដាប់ស្ទីតពីតូចទៅធំ ឬរាប់តាមលំដាប់ថយក្រោយ។ ផ្អែកលើបំណែកចែកនេះ ធរណីកាលត្រូវបានបែងចែកជា ២ គឺ បុរេកុំប្រ៊ីយាង ឬស័ក និងស័ក។

**ក.១.១ បុរេកុំប្រ៊ីយាង ឬមុនស័ក**

បុរេកុំប្រ៊ីយាង ឬមុនស័កនេះ គឺបានគេគិតចាប់ពី ៤ ៦០០ លានឆ្នាំមុន ដល់ ៥៧០ លានឆ្នាំមុន គឺពេលគឺចាប់ពីពេលដែលភពផែនដីកកើតឡើង រហូតដល់ ៥៧០ លានឆ្នាំមុន។ គេចែកបុរេកុំប្រ៊ីយាង ឬស័កនេះជា ២ ដំណាក់កាលទៀតគឺ ៖

- **ដំណាក់កាលទី ១** ៖ ចាប់ពី ៤ ៦០០ លានឆ្នាំមុន រហូតដល់ ១៥០០ លានឆ្នាំមុន។ នៅក្នុងដំណាក់កាលនេះ គេឃើញមានព្រឹត្តិការណ៍សំខាន់ៗមួយចំនួនបានកកើតឡើងដូចជា ៖

– បរិកាសផែនដីដំបូង (អ៊ីដ្រូសែន និងអេល្យូម)
– បរិយាកាសផែនដីបន្ទាប់ ($CO_2$ $H_2O$ $NH_3$ $CH_4$)
– ព្រះចន្ទរបស់ភពផែនដី (៤៥៥០ លានឆ្នាំមុន)
– មហាសមុទ្រដំបូងរបស់ភពផែនដី (៤៣០០ លានឆ្នាំមុន)
– ការប្រែប្រួលនៃបរិយាកាសផែនដី (ការបំបែកនៃសារធាតុពុលក្នុងបរិយាកាស ពី ៣៨០០ ដល់ ៤០០០ លានឆ្នាំមុន)
– សមាសធាតុសរីរាង្គដំបូង (៣៨០០ ដល់ ៤០០០ លានឆ្នាំមុន)
– ឯកកោសិកាដំបូង (៤០០០ ដល់ ៣១០០ លានឆ្នាំមុន)
– ពហុកោសិកាស៊ាំញាំដំបូង (៣១០០ ដល់ ១៥០០ លានឆ្នាំមុន)។

- **ដំណាក់កាលទី ២** ៖ ដំណាក់កាលនេះ ចាប់ផ្ដើមពី ១៥០០ រហូតដល់ ៥៧០ លានឆ្នាំមុន។ នៅក្នុងដំណាក់កាលទី២នេះ គេឃើញមានព្រឹត្តិការណ៍សំខាន់ៗមួយចំនួនបានកកើតឡើងផងដែរ ដូចជា៖

– សារពាង្គកាយពហុកោសិកា (១៥០០ ដល់ ៧០០ លានឆ្នាំមុន)
– ស្រទាប់អូសូនរបស់ផែនដី (៧០០ ដល់ ៦៥០ លានឆ្នាំមុន)
– សារាយសមុទ្រ ខ្វៃសមុទ្រ និងបាក់តេរីដំបូង (៦៥០ ដល់ ៥៧០ លានឆ្នាំមុន)។

### ១.២. ស័ក

ស័ក គឺជាបំណែងចែកពេលវេលាធំៗនៃធរណីកាល ឬជារង្វាស់នៃពេលវេលា ដែលមានអាយុកាលវែងជាងកាលសម័យ និងសម័យ។ ស័ក នៃធរណីកាលមាន ៤ គឺ ៖

- ***ស័កទី ១*** ៖ ស័កទី ១ នេះ មានឈ្មោះថា ប៉ាលេអូសូអ៊ិច ដែលចាប់ផ្ដើមពី ៥៧០ រហូតដល់ ២២៥ លានឆ្នាំមុន។ ស័កប៉ាលេអូសូអ៊ិចមាន ៦ កាលសម័យគឺ ៖

– កំប្រីយាង (៥៧០ ដល់ ៥០០ លានឆ្នាំមុន)
– អរដូវីស្យាង (៥០០ ដល់ ៤៣០ លានឆ្នាំមុន)
– ស៊ីលុយរ្យាង (៤៣០ ដល់ ៣៩៥ លានឆ្នាំមុន)
– ដេវ៉ូញាង (៣៩៥ ដល់ ៣៤៥ លានឆ្នាំមុន)
– កាបូនីផែ (៣៤៥ ដល់ ២៨០ លានឆ្នាំមុន)
– ពែមីញាង ( ២៨០ ដល់ ២២៥ លានឆ្នាំមុន)។

នៅក្នុងស័កទី ១ ឬស័កប៉ាលេអូសូអ៊ិចនេះ គេឃើញមានព្រឹត្តិការណ៍សំខាន់ៗមួយចំនួនដែលបានកើតមានឡើងដូចជា ៖

– ការរីករាលដាលនៃសារាយសមុទ្រ និងសត្វដែលមានសំបកខ្នងរឹង
– ការលេចឡើងនូវប្រភេទសត្វឆ្អឹងកង (ត្រី ហៅថាអាយុត្រី)

- ការលេចឡើងនូវប្រភេទថនិកសត្វ និងរុក្ខជាតិនៅលើគោក
- ការលេចឡើងនូវប្រភេទសត្វ ដែលរស់នៅលើគោកផង និងក្នុងទឹកផង (អាយុថលជលិក សត្វ)
- ការលេចឡើងនូវពពួកល្មូន
- ចលនាពំនើងផ្នត់កាលេដូញ៉ាង (នៅដើមសក័)
- ការកើតឡើងនូវជួរភ្នំអាល់ និងជួរភ្នំអាប៉ាឡាស
- ការកើតឡើងនូវប៉ង់សៀរ (ពាក់កណ្ដាលស័ក)
- ការកើតឡើងនូវមហាសមុទ្រមួយហៅថា ប៉ង់ថាឡាសា
- ចលនាពំនើងផ្នត់អែរស៊ីញ៉ាង (នៅចុងស័ក)
- ប៉ង់សៀរចាប់ផ្ដើមប្រេះស្រាំ (នៅចុងស័ក) បង្កើតជាទ្វីបពីរ គឺកុងដ្វាណា និងឡូរ៉ាស៊ី។

▪ **ស័កទី ២** ៖ ស័កនេះមានឈ្មោះថា មេសូសូអ៊ិចដែលបានចាប់ផ្ដើមពី ២២៥ លានឆ្នាំមុនដល់ ៦៥ លានឆ្នាំមុន។ ស័កមេសូសូអ៊ិចមាន ៣ កាលសម័យគឺ ៖

- កាលសម័យទ្រីយ៉ាស ( ២២៥ ដល់ ១៩០ លានឆ្នាំមុន)
- កាលសម័យស្សូរ៉ាស៊ិច ( ១៩០ ដល់ ១៣៦ លានឆ្នាំមុន)
- កាលសម័យក្រេតាសេ ( ១៣៦ ដល់ ៦៥ លានឆ្នាំមុន)។

នៅក្នុងស័កទី ២ ឬស័កមេសូសូអ៊ិចនេះ គេសង្កេតឃើញមានព្រឹត្តិការណ៍សំខាន់ៗមួយចំនួនបានកើតមានឡើងនៅក្នុងស័កនេះដូចជា ៖

- ការលេចឡើងនូវថនិកសត្វថ្នាក់ខ្ពស់
- ការលេចឡើងនូវសត្វល្មូនយក្ស (អំបូរដាយណូស័រ)
- ការលេចឡើងនូវប្រភេទបក្សី
- ការលេចឡើងនូវប្រភេទរុក្ខជាតិថ្មីៗ
- ការលេចឡើងនូវប្រភេទសត្វល្អិតទំនើប
- ការផុតពូជសត្វដាយណូស័រ
- ចលនាពំនើងផ្នត់អាំងដូស៊ីញ៉ាង
- ការកើតឡើងនូវជួរភ្នំកូកាសនៅរុស្ស៊ី
- ការកើតឡើងនូវជួរភ្នំថ្ម
- ទ្វីបកុងដ្វាណា និងទ្វីបឡូរ៉ាស៊ីបានបន្តរសាត់បែកចេញពីគ្នា ហើយប្រេះស្រាំបង្កើតបានជាទ្វីបផ្សេងៗទៀតដូចជា ៖
    - **កុងដ្វាណា** បានបំបែកចេញបានជាទ្វីប ៥ ទៀតគឺ ទ្វីបអាមេរិចខាងត្បូង ទ្វីបអាព្រិចទ្វីបអង់តាកទិច ទ្វីអូសេអានី (អូស្ត្រាលី)និងទ្វីបឥណ្ឌា។
    - **ឡូរ៉ាស៊ី** បានបំបែកចេញបានជាទ្វីប៣ ទៀតគឺទ្វីបអាស៊ី ទ្វីបអឺរ៉ុប និងទ្វីបអាមេរិកខាងជើង។

- **ស័កទី ៣ ៖** ស័កនេះមានឈ្មោះថា សេណូសូអ៊ិច ដែលបានចាប់ផ្តើមពី ៦៥ លានឆ្នាំមុនដល់ ២ លានឆ្នាំមុន។ ស័កទី ៣ ឬស័កសេណូសូអ៊ិចនេះ គឺពុំមានកាលសម័យដូចស័កទី ១ និង ស័កទី ២ នោះទេ មានតែសម័យប៉ុណ្ណោះ។ ស័កសេណូសូអ៊ិចនេះមាន ៥ សម័យគឺ ៖

– សម័យប៉ាលេអូសែន ( ៦៥ ដល់ ៥៥ លានឆ្នាំមុន)
– សម័យអេអូសែន ( ៥៥ ដល់ ៣៨ លានឆ្នាំមុន)
– សម័យអូលីកូសែន (៣៨ ដល់ ២៥ លានឆ្នាំមុន)
– សម័យមីអូសែន (២៥ ដល់ ៦ លានឆ្នាំមុន)
– សម័យប្លីអូសែន (៦ ដល់ ២ លានឆ្នាំមុន)។

នៅក្នុងស័កនេះ គេសង្កេតឃើញមានព្រឹត្តិការណ៍សំខាន់ៗជាច្រើនបានកើតមានឡើងនៅលើផែនដីដូចជា ៖

– ការលេចឡើងនូវអេម្បូរពានដំបូង នៅលើផែនដី
– ការលេចឡើងនូវអំបូរសត្វស៊ីសត្វល្អិតជាអាហា (បាណាកសី)
– ការលេចឡើងនូវអំបូរសត្វស៊ីសាច់ជាអាហារ (មំសាសី)
– ការលេចឡើងនូវអំបូរសត្វសេះ និងដំរី
– ការលេចឡើងនូវអំបូរថនិកសត្វថ្នាក់ខ្ពស់សម័យបច្ចុប្បន្ន
– ការលេចឡើងនូវពានរអំបូរស្វា
– ការលេចឡើងនូវថនិកសត្វអំបូរស្វាឌី និងថនិកសត្វថ្នាក់ខ្ពស់ធំៗស៊ីស្មៅ (មីអូសែន)
– ការរីករាលដាលនៃវាលស្មៅបានកើត
– ការលេចឡើងនូវមនុស្សស្វាដំបូងឡើងនៅលើផែនដី (ប្លីអូសែន)
– ការលេចឡើងនូវមនុស្សសម័យដើម
– ទ្វីបទាំងអស់បានរសាត់មកដល់ទីតាំងដូចបច្ចុប្បន្ន
– ចលនាពត់នើងផ្នត់ហិមាល័យ
– ការកកើតឡើងនូវជួរភ្នំថ្មីដូចជា ជួរភ្នំអាល់ ជួរភ្នំអង់ និងជួរភ្នំហិម៉ាល័យ
– ចលនាបន្ទុះភ្នំភ្លើង ដែលបានកើតឡើងជាញឹកញាប់នៅលើផែនដី។

- **ស័កទី ៤ ៖** ស័កនេះមានឈ្មោះថា សេណូសូអ៊ិច ដូចស័កទី ៣ ផងដែរ។ ស័កនេះបានចាប់ផ្តើមពី ២ លានឆ្នាំមុន រហូតមកដល់ពេលបច្ចុប្បន្ននេះ។ ស័កទី ៤ ឬស័កសេណូសូអ៊ិចនេះ ពុំមានកាលសម័យនោះទេ គឺមានតែសម័យដូចស័កទី ៣ ប៉ុណ្ណោះ។ ស័កទី ៤ ឬស័កសេណូ-សូអ៊ិចនេះមាន ២ សម័យគឺ ៖

– សម័យប្លេអ៊ីស្តូសែន (២ ដល់ ០.១ លានឆ្នាំមុន)
– សម័យហូឡូសែន (០.១ ដល់បច្ចុប្បន្ន)។

នៅក្នុងស័កទី ៤ ឬស័កសេណូសូអ៊ិចនេះ គេសង្កេតឃើញមានព្រឹត្តិការណ៍សំខាន់ៗមួយចំនួនបានកើតមានឡើងនៅលើផែនដីដូចជា ៖

- ការលេចឡើងនូវមនុស្សទំនើប
- ការលេចឡើងនូវថនិកសត្វថ្មីៗជាច្រើន ដែលមានលក្ខណៈដូចបច្ចុប្បន្ន
- ការលេចឡើងនូវអរ្យធម៌របស់មនុស្សសម័យទំនើប
- ការបំផ្លាញព្រៃរងទឹកភ្លៀងត្រូពិច
- ការកើតឡើងនូវផ្ទាំងទឹកកកធំៗនៅលើផែនដី (សម័យទឹកកក) (ប្លេអ៊ីស្តូសែន)
- ការរលាយទឹកកកបានកើតឡើង (ហូឡូសែន)
- សកម្មភាពក្នុងផែនដីមានសភាពស្ងប់ និងជាសម័យចាក់បង្គរ ដោយសារសំណឹក។

**២. ការបែងចែកធរណីកាលតាមរបៀបថ្មី**

នៅក្នុងសម័យបច្ចុប្បន្ននេះ អ្នកវិទ្យាសាស្ត្រ ពិសេសអ្នកធរណីវិទ្យាបានធ្វើការបែងចែកធរណីកាលជាថ្មីឡើងវិញ ដោយពួកគេបានរៀបធរណីកាល តាមលំដាប់ស្ទឹតពីធំមកតូច ឬរាប់តាមលំដាប់ពីក្រោយមកមុខវិញម្តង។ ផ្អែកលើបំណែងចែកថ្មីនេះ ធរណីកាលត្រូវបានបានគេបែងចែកជា ២ ធំៗដែរ គឺបុរេកុំប្រីយាង ឬស័ក និងស័ក តែបានរៀបតាមលំដាប់ពីក្រោយមកមុខ។ ចំណែកឯស័កវិញ ត្រូវបានគេបង្រួមមកត្រឹមតែ ៣ ប៉ុណ្ណោះ ដោយគេយកស័កទី៤ (ឈ្មោះសេណូសូអ៊ិច) និងស័កទី៣ (ឈ្មោះសេណូសូអ៊ិច) ដែលមានត្រឹមតែសម័យនោះ មកបញ្ចូលគ្នាធ្វើជាស័កតែមួយ និងថែមទាំងបានបង្កើតជាកាលម័យថែមទៀតផង។

**២.១ ស័ក ៖** ស័ក នៃធរណីកាលមាន ៣ គឺ ៖

- **ស័កទី ១ ៖** ស័កទី ១ មានឈ្មោះថា សេណូសូអ៊ិច ដែលបានចាប់ផ្តើមពីពេលបច្ចុប្បន្នថយ រហូតដល់ ៦៥ លានឆ្នាំមុន។ ស័កទី ១ ឬស័កសេណូសូអ៊ិចនេះមាន ២ កាលសម័យគឺ ៖

- កាលសម័យក្វាទែណារី ៖ សម័យកាលនេះ បានចាប់ផ្តើមពីពេលបច្ចុប្បន្នថយរហូតដល់ ២ លានឆ្នាំមុន និងមាន ២ សម័យគឺ ៖
  - សម័យហូឡូសែន (បច្ចុប្បន្នថយដល់ ០.១ លានឆ្នាំមុន)
  - សម័យព្លេអ៊ីសតូសែន (ពី ០.១ ថយដល់ ២ លានឆ្នាំមុន)។
- កាលសម័យទែត្យារី ៖ បានចាប់ផ្តើមពី ២ លានឆ្នាំមុនថយរហូតដល់ ៦៥ លានឆ្នាំមុន និងមាន ៥ សម័យគឺ ៖
  - សម័យព្លីអូសែន (ពី ២ ថយដល់ ៦ លានឆ្នាំមុន)
  - សម័យមីអូសែន (ពី ៦ ថយដល់ ២៥ លានឆ្នាំមុន)
  - សម័យលីអូកូសែន (ពី ២៥ ថយដល់ ៣៨ លានឆ្នាំមុន)
  - សម័យអេអូសែន (ពី ៣៨ ថយដល់ ៥៥ លានឆ្នាំមុន)
  - សម័យប៉ាលេអូសែន (ពី ៥៥ ថយដល់ ៦៥ លានឆ្នាំមុន)។

- **ស័កទី ២ ៖** ស័កនេះមានឈ្មោះថា មេសូសូអ៊ិច ដែលបានចាប់ផ្តើមពី ៦៥ លានឆ្នាំមុន ថយរហូតដល់ ២២៥ លានឆ្នាំមុន ហើយស័កនេះមាន ៣ កាលសម័យគឺ ៖

- កាលសម័យក្រេតាសេ ៖ ចាប់ពី ៦៥ លានឆ្នាំមុនថយដល់ ១៣៦ លានឆ្នាំមុន
- កាលសម័យស្ហ៊ូរ៉ាស៊ិច ៖ ចាប់ពី ១៣៦ លានឆ្នាំមុនថយដល់ ១៩០ លានឆ្នាំមុន

- កាលសម័យទ្រីយ៉ាស ៖ ចាប់ពី ១៩០ លានឆ្នាំមុនថយដល់ ២២៥ លានឆ្នាំមុន។

▪ **ស័កទី ៣** ៖ ស័កនេះមានឈ្មោះថា ប៉ាលេអូសូអ៊ិច ដែលបានចាប់ផ្តើមពី ២២៥ លានឆ្នាំមុន ថយរហូតដល់ ៥៧០ លានឆ្នាំមុន។ ស័កប៉ាលេអូសូអ៊ិចនេះមាន ៦ កាលសម័យគឺ ៖

- កាលសម័យពែមីញាង ៖ ចាប់ផ្តើមពី ២២៥ លានឆ្នាំមុនថយដល់ ២៨០ លានឆ្នាំមុន
- កាលសម័យកាបូនីផែ ៖ ចាប់ផ្តើមពី ២៨០ លានឆ្នាំមុនថយដល់ ៣៤៥ លានឆ្នាំមុន
- កាលសម័យដេវ៉ូញាង ៖ ចាប់ផ្តើមពី ៣៤៥ លានឆ្នាំមុនថយដល់ ៣៩៥ លានឆ្នាំមុន
- កាលសម័យស៊ីលុយរ្យាង ៖ ចាប់ផ្តើមពី ៣៩៥ លានឆ្នាំមុនថយដល់ ៥០០ លានឆ្នាំមុន
- កាលសម័យកំប្រីយាង ៖ ចាប់ផ្តើមពី ៥០០ លានឆ្នាំមុនថយដល់ ៥៧០ លានឆ្នាំមុន។

**២.២ មុនស័ក ឬបុរេកំប្រីយាង ៖** មុនស័ក ឬបុរេកុំប្រីយាងនេះ បានចាប់ផ្តើមពី ៥៧០ លានឆ្នាំមុនថយរហូតដល់ ៤ ៦០០ លានឆ្នាំមុន។ នៅមុនស័ក ឬបុរេកុំប្រីយាងនេះ ចែកចេញជា ២ ដំណាក់កាលទៀតគឺ ៖

▪ **ដំណាក់កាលទី ២** ៖ ចាប់ផ្តើមពី ៥៧០ លានឆ្នាំមុន ថយរហូតដល់ ១៥០០ លានឆ្នាំមុន

▪ **ដំណាក់កាលទី ១** ៖ ចាប់ផ្តើមពី ១ ៥០០លានឆ្នាំមុន ថយរហូតដល់ ៤ ៦០០លានឆ្នាំមុន។

## ខ. ប្រវត្តិធរណីកាលនៃសណ្ឋានដីប្រទេសកម្ពុជា

### ១. លក្ខណៈទូទៅនៃសណ្ឋានដីប្រទេសកម្ពុជា

សណ្ឋានដីប្រទេសកម្ពុជាយើងមានផ្ទៃផតកណ្តាល មានជាយស្ទើរតែជុំវិញជាភ្នំ ជាកូនភ្នំ និងជាខ្ពង់រាប។ នៅភាគនិរតីនៃប្រទេស ផ្ទៃដីនេះបានចុះទេជាលំដាប់ពីជួរភ្នំក្រវ៉ាញ សំដៅទៅឈូងសមុទ្រ ដែលជាទីសម្បូរទៅដោយកូនកោះ និងកូនភ្នំ។

ប្រសិនបើគេធ្វើពំនុះកាត់ទឹកដីប្រទេសកម្ពុជាពីទិសនិរតីទៅទិសឦសាន គេនឹងសង្កេតឃើញសណ្ឋានដីប្រទេសកម្ពុជា មានរយៈកម្ពស់ទាបនៅតំបន់មាត់សមុទ្រ រយៈកម្ពស់ខ្ពស់ខ្លាំងនៅទីបន្ទាប់ពីតំបន់មានត់សមុទ្រ គឺជួរភ្នំក្រវ៉ាញ និងតំបន់កូនភ្នំ រយៈកម្ពស់ខ្សោយនៅចំកណ្តាលប្រទេស គឺជាទំនាប កណ្តាល និងរយៈកម្ពស់មធ្យមនៅភូមិភាគឦសាន គឺខ្ពង់រាប។

ដោយឆ្លងកាត់ដំណើរការវិវត្ត នៃប្រវត្តិធរណីដ៏យូរលង់ សណ្ឋានដីប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ បានកកើតឡើងដោយកម្លាំងតិចតូនិច ដំណើរសំណឹក និងដំណើរកំទេចកំណដែលតែងតែកកើតមាននៅគ្រប់ស័ក កាលសម័យ និងសម័យនៃធរណីកាលទាំងអស់។ ដូចនេះ ប្រទេសកម្ពុជាជាទឹកដីមួយដែលសម្បូរទៅដោយដំណើរធម្មជាតិច្រើនបែបច្រើនយ៉ាងបំផុត។




*ពំនុះ*

*កាត់ទទឹងសណ្ឋានដីប្រទេសកម្ពុជាពីនីរិទិសរតីទៅទិសឦសាន*

## ២. ប្រវត្តិនៃការកកើតសណ្ឋានដីប្រទេសកម្ពុជា

សណ្ឋានដីប្រទេសកម្ពុជាបច្ចុប្បន្ននេះ បានកើតឡើងដោយបានឆ្លងកាត់នូវប្រវត្តិធរណីកាលមួយដ៏យូរលង់ណាស់មកហើយ ពោលគឺបានកកើតឡើងដោយកម្លាំង នៃចលនារបស់ផ្លាកតិចតូនិច ដំណើរចាក់បង្គរដោយកំទេចកំណា និងដំណើរសំណឹក ដែលតែងតែបានកកើតមានឡើងនូវគ្រប់ស័ក គ្រប់កាលសម័យ និងគ្រប់សម័យទាំងអស់ នៃធរណីកាល។ ដំណើរវិវត្តន៍ នៃសណ្ឋានដីប្រទេសកម្ពុជា ត្រូវបានគេធ្វើកំណត់សម្គាល់ដូចតទៅ ៖

**មុនស័កទី១** ទឹកដីប្រទេសកម្ពុជានៅជាជាយទ្វីប ហើយស្ថិតនៅក្រោមផ្ទៃសមុទ្រនៅឡើយ។ ក្រោយមក ជាយទ្វីបនេះត្រូវបានគ្របដណ្តប់បន្តិចម្តងៗ ដោយសិលាកំទេចកំណទ្រនរទ្វីបចាស់ ដែលមានឈ្មោះ **អាំងដូស៊ីញាង** និងមានរ៉ែជាច្រើនប្រភេទ ប៉ុន្តែរ៉ែដែលសំខាន់ជាងគេ គឺរ៉ែដែក។

**ស័កទី១** ភូមិភាគនេះបានទទួលរងនូវចលនាពំនើងផ្នត់មួយយ៉ាងខ្លាំង នៅតំបន់ជួរភ្នំក្រវាញដែលមានឈ្មោះថា **កាលេដូញាង**។ ដោយសារចលនាពំនើងផ្នត់នេះ គេសង្កេតឃើញថាមានរំលេចចេញនូវសិលាចាស់ៗដូចជា សិលាក្រានីត និងសិលាក្រែលាយស៊ីសនៅតំបន់កំពង់ធំ។ រ៉ែសំខាន់ៗ ក្នុង ស័កនេះមានដូចជា ត្បូងថ្ម ប្រេងកាត និងលោហៈកម្រជាច្រើន។ បន្ទាប់មកទៀត ទឹកដីនេះបានទទួលរងនូវចលនាពំនើងផ្នត់មួយផ្សេងទៀត ដែលមានឈ្មោះថា **អ៊ែស៊ីញាង** ក៏ប៉ុន្តែពំនើងផ្នត់នេះត្រូវបានមេសំណឹកស៊ីផ្តាច់អស់ ហើយបានក្លាយទៅជាទំនាបសំនឹកនៅចុងស័កទី ១ វិញ។

**ស័កទី២** គឺជាសម័យរង្វាតនៃទឹកសមុទ្រ គឺនៅពេលនោះ គេសង្កេតឃើញទឹកដីនៃប្រទេសកម្ពុជាត្រូវបានលិចកប់ចូលទៅក្រោមទឹកសមុទ្រម្តងទៀត។ នៅពេលនោះដែរ កំទេចកំណសិលាបានហូរមកចាក់បង្គរជាមួយផូស៊ីលសត្វ និងរុក្ខជាតិនៅលើផ្ទៃដីនេះ។ ក្រោយមកទៀតគេឃើញមានចលនាពំនើងមួយទៀតបានកើតឡើង គឺចលនាពំនើងផ្នត់ **អាំងដូស៊ីញាង** និងមានបាតុភូតបន្ទុះភ្នំភ្លើងបានកើតមានឡើងផងដែរដែលបង្កើតបានជាសណ្ឋានដីជាច្រើននៅប្រទេសកម្ពុជា ជាពិសេសជួរភ្នំក្រវាញ ជួភ្នំដងរែក និងខ្ពង់រាបឰសាននៃប្រទេសកម្ពុជា។ សំណល់ផូស៊ីលដែលជាប្រភេទថ្មកំបោរមាននៅភ្នំសំពៅ ក្នុងខេត្តបាត់ដំបង នៅភ្នំធំ ក្នុងខេត្តបន្ទាយមានជ័យ នៅទូកមាស ក្នុងកំពត និងមានថ្មក្រៃយ៉ាងក្រាស់គ្របដណ្តប់មួយភាគធំនៃផ្ទៃប្រទេស។ នៅក្នុងស័កនេះ គេឃើញមានរ៉ែសំខាន់ៗជាច្រើន ដែលបានកកើតឡើងដូចជា ត្បូងថ្ម ប្រេងកាត មាស និងសំណ។ល។

**ស័កទី៣** មានចលនាពំនើងផ្នត់មួយទៀតបានកើតឡើងនៅលើផ្ទៃផែនដី គឺចលនាពំនើងផ្នត់**ហិម៉ាល័យ**។ ឥទ្ធិពលនៃចលនាពំនើងផ្នត់នេះ បានបង្កើតឡើងនូវជួរភ្នំក្មេងជាច្រើននៅលើផែនដី និងមានព្រឹត្តការណ៍ភ្នំភ្លើងផងដែរ។ ដោយសារតែឥទ្ធិពលនៃចលនាពំនើងផ្នត់នេះ បានធ្វើឱ្យទឹកដីប្រទេសកម្ពុជាទទួលរងនូវបំណាក់ស្រុតមួយ ដែលបណ្តាលឱ្យមានលំហូរឡើង នៃសិលាបាសាល់មកលើផ្ទៃដី ប្រទេសកម្ពុជាជាច្រើនកន្លែងដូចជាតំបន់ដីក្រហមនៅខ្ពង់រាបខាងកើត និងឰសានជាដើម។ លើសពីនេះទៅទៀត ដោយសារតែឥទ្ធិពលនៃចលនាពំនើងផ្នត់ហិម៉ាល័យនេះខ្លាំងពេក បានធ្វើឱ្យជួរភ្នំក្រវាញ និងជួរភ្នំដងរែក នៃប្រទេសកម្ពុជាយើងបានងើបឡើងខ្ពស់បន្តិច ចំណែកឯទំនាបកណ្តាលវិញត្រូវបាក់ស្រុតចុះ ហើយបានគ្របដណ្តប់ទៅដោយទឹកសមុទ្រ

ម្តងទៀតរហូតដល់ជួរភ្នំដងរែក។ នៅក្នុងស័កទី៣ នេះ គេសង្កេតឃើញមានរ៉ែសំខាន់ៗជាច្រើនប្រភេទបានកកើតឡើងដូចជា ប្រេងកាត ឧស្ម័នធម្មជាតិ និងត្បូងថ្ម។ល។

*ផែនទីធរណីកាលនៃទឹកដីប្រទេសកម្ពុជា*




**ស័កទី៤** ជាសម័យកំទេចកំណ។ នៅក្នុងស័យកនេះ ផ្លូវទឹកទាំងឡាយដែលស្ថិតនៅទីខ្ពស់ព័ទ្ធជុំវិញពិសេសទន្លេមេគង្គបានហូរនាំយកដីល្បាប់មកចាក់បំពេញនៅក្នុងសមុទ្រ។ ស្របពេលជាមួយគ្នានិងចលនារុញដោលឡើងលើយ៉ាងយឺតៗពីក្នុងផែនដីបណ្តាលឱ្យទឹកសមុទ្រចក៏ចាប់ផ្តើមថយចុះបន្តិចម្តងៗ ដែលធ្វើឱ្យគេមើលឃើញល្បាប់ចាស់នៅក្បែរតំបន់ខ្ពស់ៗដូចជា ជួរភ្នំដងរែក និងជួរភ្នំក្រវាញ និងល្បាប់ថ្មីនៅក្បែរផ្លូវទឹកដូចជា ប្រព័ន្ធទន្លេសាប និងប្រព័ន្ធទន្លេមេគង្គជាដើម។ ដីល្បាប់ចាស់ និងល្បាប់ថ្មីនេះ ក៏បានបង្កើតជាសណ្ឋានដីទំនាបកណ្តាលដូចសព្វថ្ងៃនេះ ដែលល្អប្រសើរបំផុតដល់កសិកម្ម។

### ១.២.២. តំបន់ធំៗនៃសណ្ឋានដីប្រទេសកម្ពុជា

យោងទៅតាមសណ្ឋានដីនៃប្រទេសកម្ពុជា គេបែងចែកទឹកដីប្រទេសកម្ពុជាជា ៤ តំបន់ធំៗគឺ តំបន់ទំនាបកណ្តាល តំបន់មាត់សមុទ្រ តំបន់ប្រជុំភ្នំ និងតំបន់ខ្ពង់រាប។

#### ក. តំបន់ទំនាបកណ្តាល

តំបន់ទំនាបកណ្តាលនៃប្រទេសកម្ពុជា គឺជាតំបន់មួយ ដែលមានទីតាំងស្ថិតនៅចំកណ្តាលនៃប្រទេសកម្ពុជា។ តំបន់នេះ គឺជាវាលទំនាបមួយយ៉ាងធំធេង ដែលមានរយៈកម្ពស់ខ្ពស់មធ្យមតិចជាង ៥០ ម៉ែត្រ គឺចន្លោះពី ២០ ម៉ែត្រ ទៅ ៣០ ម៉ែត្រ និងមានចំណោតយ៉ាងខ្សោយបន្តិចម្តងៗ ចាប់ពីទិសពាយ័ព្យសំដៅទៅទិសអាគ្នេយ៍។ តំបន់នេះ ស្ថិតនៅសណ្តូកបន្តពីទំនាបនៃប្រទេសថៃដែលលាតសន្ធឹងពីទិសពាយ័ព្យសំដៅទៅទិសអាគ្នេយ៍ រហូតដល់ព្រំដែនប្រទេសវៀតណាម នៅភាគភាគខាងត្បូង។ ទំនាបកណ្តាលនៃប្រទេសកម្ពុជាមានទំហំស្មើនឹង ១/៣ នៃផ្ទៃប្រទេស ដោយមានរាងរៀវកណ្តាល និងរីកធំឡើងៗសំដៅទៅទិសខាងត្បូង។

ដីនៅតំបន់ទំនាបកណ្តាល ជាប្រភេទដីល្បាប់ ដែលត្រូវបានហូរដឹកជញ្ជូនដោយខ្សែទឹកទន្លេមេគង្គមកចាក់បំពេញជារៀងរាល់ឆ្នាំ។ ហេតុដូច្នេះហើយ ទើបគេឃើញមានដីល្បាប់ចាស់ស្ថិតនៅត្រង់ជាយខាងក្រៅ និងដីល្បាប់ថ្មីស្ថិតនៅត្រង់តំបន់ក្បែរផ្លូវទឹក។ នៅក្នុងភូមិភាគកណ្តាលនេះហើយ ដែលគេឃើញមានបណ្តុំប្រជាជនកម្ពុជារស់នៅច្រើនជាងគេបំផុត និងជាកន្លែងបណ្តុំនៃសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដូចជា វិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យឧស្សាហកម្ម វិស័យគមនាគមន៍ និងវិស័យទេសចរណ៍។

ជាទូទៅ សណ្ឋានដីតំបន់ទំនាបកណ្តាលត្រូវបានគេចែកចេញជា ៣ ភូមិភាគគឺ ៖

- **ភូមិភាគល្បាប់ម៉ដ្ឋ** ៖ ភូមិភាគនេះមានទទឹងប្រវែងចាប់ពី ៤ ម៉ែត្រ ទៅ ១០ ម៉ែត្រ និងដល់ច្រើនរយម៉ែត្រ។ ភូមិភាគនេះ គឺស្ថិតនៅជាប់នឹងច្រាំងទន្លេ មាត់ព្រែក និងជាយកោះ ហើយដីប្រភេទនេះ គឺជាដីដ៏ល្អប្រសើរបំផុត សម្រាប់កសិកម្ម។ នៅក្នុងភូមិភាគនេះ គេឃើញមានប្រជាជនកម្ពុជាបានរស់ នៅយ៉ាងកុះករជាងភូមិភាគផ្សេងៗទៀត និងសម្បូរដោយបណ្តាញផ្លូវគមនាគមន៍។
- **ភូមិភាគលិចទឹក និងវាលភក់** ៖ ភូមិភាគនេះ គឺស្ថិតនៅព័ទ្ធពីក្រៅភូមិភាគល្បាប់ម៉ដ្ឋ គឺជាប្រភេទដីដែលមានដីជាតិល្អគួរសម សម្រាប់កសិកម្ម។ ចំណែកឯប្រជាជនវិញក៏មានច្រើនផងដែរ ដោយសារតែភូមិភាគនេះសម្បូរទៅដោយបឹងបួរ និងសម្បូរត្រី សម្រាប់នេសាទ ជាពិសេសតំបន់នៅជុំវិញបឹងទន្លេសាបដែលសម្បូរទៅដោយព្រៃលិចទឹក សម្រាប់ជាចំណី និងជាជម្រកត្រីពង ជាហេតុធ្វើឱ្យភូមិភាគនេះសម្បូរត្រី ហើយបានក្លាយទៅជាមជ្ឈមណ្ឌលនេសាទមួយយ៉ាងសំខាន់របស់ប្រទេសកម្ពុជា។
- **ភូមិភាគវាលស្រែ** ៖ ភូមិភាគនេះ គឺស្ថិតនៅបន្តពីក្រៅភូមិភាគលិចទឹក និងវាលភក់ ជាភូមិភាគដែលដីមានដីជាតិតិចជាងភូមិភាគល្បាប់ម៉ដ្ឋ និងភូមិភាគវាលភក់ ប៉ុន្តែជាភូមិភាគមានវាលស្រែដ៏ធំល្វឹងល្វើយ ហើយបំពេញមុខងារយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចជាតិ។ ភូមិភាគវាលស្រែមានផ្ទៃដីធំធេង មើលដាច់កន្ទុយភ្នែកដែលស្ថិតនៅក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាម កំពង់ធំ តាកែវ ព្រៃវែង កំពង់ចាម និងខេត្តស្វាយរៀង។

ជាទូទៅ គេចែកតំបន់ទំនាបកណ្តាលនៃប្រទេសកម្ពុជាជា ២ តំបន់ទៀតគឺ តំបន់ទំទន្លេបួនមុខ ឬទំនាបចតុមុខ និងទំនាបបឹងទន្លេសាប។

**១. តំបន់ទំនាបទន្លេចតុមុខ**

តំបន់ទំនាបទន្លេបួនមុខ ឬទំនាបចតុមុខ ជាតំបន់ដែលមានទីតាំងស្ថិតនៅអមសងខាងទន្លេបួនមុខនៃប្រទេសកម្ពុជា។ ទំនាបនេះមានផ្ទៃយ៉ាងធំធេង និងមានចំណោតយ៉ាងខ្សោយនៅផ្នែកខាងកើតនៃទន្លេដូចជា ទំនាបនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង និងមានផ្ទៃតូចចង្អៀត ព្រមទាំងមានចំណោតខ្លាំងហើយងើបយ៉ាងឆាប់រហ័សសំដៅទៅរកជួរភ្នំក្រវ៉ាញនៅផ្នែកខាងលិចដូចជា ទំនាបខាងត្បូងក្រុងតាខ្មៅ ក្នុងខេត្តកណ្តាលជាដើម។

ជាទូទៅ គេបែងចែកសណ្ឋានដីតំបន់ទំនាបទន្លេបួនមុខ ឬទំនាបចតុមុខនេះជា ៣ ផ្នែកទៀត (ប្រសិនបើគេធ្វើពុំនុះកាត់ទទឹងទំនាបនេះ) ដែលរួមមាន ៖

- **ផ្នែកទី ១** ៖ ជាភូមិភាគល្បាប់ម៉ដ្ឋ ដែលស្ថិតនៅជាប់នឹងមាត់ទទន្លេ មាត់ព្រែក មាត់បឹង និងជាយកោះ។ ភូមិភាគនេះ មានទទឹងពី ១០ ម៉ែត្រទៅរាប់រយម៉ែត្រ ដែលជាដីដែលមានជីជាតិបំផុតសម្រាប់ដំណាំចម្ការដូចជា ពោត សណ្តែក កប្បាស មន ត្រុំ ថ្នាំជក់ និងបន្លែគ្រប់មុខ។ នៅក្នុងភូមិភាគនេះ គេឃើញមានប្រជាជនកម្ពុជារស់នៅយ៉ាងច្រើនកុះករ ជាងភូមិភាគដទៃទៀតដោយសារតែលក្ខខណ្ឌអនុគ្រោះនៃធម្មជាតិនៅក្នុងភូមិភាគនេះ។
- **ផ្នែកទី ២** ៖ ជាភូមិភាគវាលភក់ ដែលស្ថិតនៅបន្តពីភូមិភាគល្បាប់ម៉ដ្ឋ និងមួយភាគធំត្រូវបានលិចទឹកនៅរដូវវស្សា ឬរដូវទឹកតំឡើង។ ភូមិភាគនេះ សម្បូរបឹង វាលភក់ ព្រែក និងអូរ រីឯដីវិញគឺជាប្រភេទដីកណ្តោងដែលមានជីជាតិគួរសម សម្រាប់ដំណាំស្រូវ ពិសេសស្រូវប្រាំង និងបន្លែបង្ការ។ នៅក្នុងភូមិភាគនេះ គេសង្កេតឃើញមានប្រជាជនរស់នៅយ៉ាងក្រាស់ក្រែលដែរបន្ទាប់ពីភូមិភាគល្បាប់ម៉ដ្ឋ ព្រោះសម្បូរត្រី សម្រាប់ធ្វើជាអាហារ និងមានកន្លែងប្រកបរបរកសិកម្មផងដែរ។
- **ផ្នែកទី ៣** ៖ ជាភូមិភាគវាលស្រែ ដែលស្ថិតនៅបន្តពីភូមិភាគលិចទឹក និងជាតំបន់វាលស្រែដ៏ធំល្វឹងល្វើយមើលដាច់កន្ទុយភ្នែក សម្បូរដើមត្នោតដុះ ដែលលាតសន្ធឹងរហូតដល់ជើងភ្នំនៃជួរភ្នំដងរែកនៅប៉ែកខាងលិច និងរហូតដល់ប្រទេសវៀតណាម នៅប៉ែកខាងកើត។ ភូមិភាគនេះ គឺជាមណ្ឌលផលិតស្រូវទី ២ របស់ប្រទេសកម្ពុជា។

**២. តំបន់ទំនាបបឹង**

តំបន់ទំនាបបឹង ឬទំនាបបឹងទន្លេសាប ជាទំនាបដែលមានទីតាំងស្ថិតនៅជុំវិញបឹងទន្លេសាប ដោយមានព្រំប្រទល់ខាងជើងទល់នឹងតំបន់ខ្ពង់រាបខាងជើង ដែលលាតសន្ធឹងចាប់ពីរយៈកម្ពស់ពី ២៥ ម៉ែត្រ ដល់ ២០០ ម៉ែត្រ ខាងលិច និងខាងត្បូងទៅទល់នឹងតំបន់កូនភ្នំ ដែលស្ថិតនៅតាមជើងនៃជួរភ្នំក្រវ៉ាញ។ ទំនាបនេះ មានចំណោតមិនសូវទៀងទាត់នោះទេ ដោយគេសង្កេតឃើញមានចំណោតខ្លាំង ចាប់ពីខេត្តសៀមរាបទៅខេត្តពោធិ៍សាត់ ជាងពីខេត្តបាត់ដំបងទៅខេត្តកំពង់ធំ។ ចំណែកឯទទឹងទំនាបវិញ ក៏មានភាពមិនទៀងទាត់ផងដែរ។ នៅទីនេះ គេឃើញមានទំនាបពីរកន្លែងយ៉ាងរាបស្មើ ហើយធំ គឺមួយនៅខាងប៉ែកលិចដែលមានប្រវែងទទឹងជាមធ្យម ៨០ គ.មស្ថិតនៅក្នុងខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យរហូតដល់ស្រុកក្រឡាញ់ ខេត្ត

សៀមរាប និងមួយទៀតនៅប៉ែកខាងកើតដែលមានប្រវែងទទឹងជាមធ្យម ៦០ គ.ម ស្ថិតនៅក្នុងខេត្តកំពង់ធំ ហូតដល់ស្រុកជីក្រែង ខេត្តសៀមរាបផងដែរ។

***ផែនទីសណ្ឋានដីប្រទេសកម្ពុជា***




ក្រៅពីទំនាបពីរកន្លែងនេះ គេឃើញមានទំនាបតូចៗជាច្រើនកន្លែងផ្សេងទៀត ជាពិសេសនៅភាគខាងជើងដែលស្ថិតនៅក្នុងខេត្តសៀមរាបផ្នែកកណ្ដាល ដោយមានប្រវែងទទឹងជាមធ្យម ៣០ គ.ម និងនៅភាគខាងត្បូង ដែលស្ថិតនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ដោយមានប្រវែងទទឹងជាមធ្យម ៣០ គ.ម ផងដែរ។ ក៏ប៉ុន្តែទំនាបនេះ មកដល់ត្រង់កំពង់ហ្លួង (ស្រុកក្រគរ ខេត្តពោធិ៍សាត់) ផ្ទៃរបស់វាបានរួមតូច នៅសល់ប្រវែងទទឹងត្រឹមតែ ១៥ គ.ម ប៉ុណ្ណោះ។

ទំនាបបឹង ឬទំនាបបឹងទន្លេសាបនេះមានផ្ទៃធំធេងហើយរាបស្មើ ដែលលាតសន្ធឹងល្វឹងល្វើយនៅក្នុងខេត្តបាត់ដំបង និងខេត្តកំពង់ធំ ជាភូមិភាគមានរយៈកម្ពស់ទាប ដែលមួយភាគធំស្ថិតនៅក្រោមការគំរាម

កំហែងនៃទឹកជំនន់នៅរដូវវស្សា។ តែទោះជាយ៉ាងណាក្តី តំបន់ទំនាបបឹង ឬទំនាបបឹងទន្លេសាបនេះមានសារៈសំខាន់ជាច្រើននៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

ជាទូទៅ គេចែកសណ្ឋានដីតំបន់ទំនាបបឹងទន្លេសាបជា ៣ ផ្នែកទៀត (ប្រសិនបើគេធ្វើពុំនុះកាត់ទទឹងទំនាប បឹងទន្លេសាប) ដែលរួមមាន ៖

- **ផ្នែកទី១៖** ជាភូមិភាគលិចទឹក ដែលស្ថិតនៅជាប់មាត់បឹង ហើយត្រូវបានលិចទឹកជាប្រចាំទាំងរដូវ ប្រាំងនិងរដូវវស្សា។ ភូមិភាគនេះសម្បូរទៅដោយព្រៃលិចទឹក ដែលជាជម្រកដ៏ប្រសើររបស់មច្ឆាជាតិ និងជាចំណីរបស់ពួកវា ហើយក៏ជាមជ្ឈមណ្ឌលនេសាទដ៏សំខាន់ផងដែររបស់ប្រទេសកម្ពុជាផងដែរ។

***គំនូសបំព្រួញ ៖ ពំនុះកាត់ទទឹងភាគខាងជើងនៃទំនាបបឹងទន្លេសាប***




***គំនូសបំព្រួញ ៖ ពំនុះកាត់ទទឹងផ្នែកភាគគើទំនាបបឹងទន្លេសាប***




- **ផ្នែកទី ២** ៖ ជាភូមិភាគវាលភក់ ដែលស្ថិតនៅបន្តពីភូមិភាគទី ២ ហើយភូមិភាគនេះត្រូវបានលិចទឹកនៅរដូវវស្សា ឬរដូវទឹកតំឡើង។ ភូមិភាគនេះ សម្បូរដោយវាលភក់ និងកូនបឹង ដែលមានសារៈសំខាន់ សម្រាប់វិស័យកសិកម្មខាងដំណាំស្រូវទាំងស្រូវឡើងទឹក និងស្រូវប្រាំង ការដំណាំរួមផ្សំផ្សេងៗ និងការនេសាទ។
- **ផ្នែកទី ៣** ៖ ជាភូមិភាគទំនាបខ្ពស់ដែលមិនត្រូវបានលិចទឹកនោះទេនៅរដូវវស្សា។ ភូមិភាគនេះជាតំបន់វាលស្រែដ៏ធំល្វឹងល្វើយ ដោយលាតសន្ធឹងរហូតដល់ជើងភ្នំជួរភ្នំដងរែក នៅប៉ែកខាងជើង និងជើងជួរភ្នំក្រវាញ នៅប៉ែកខាងត្បូង។ នៅក្នុងភូមិភាគនេះ គឺជាតំបន់ផលិតស្រូវ លេខ១ របស់ប្រទេសកម្ពុជា ដែលស្ថិតនៅក្នុងកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ។




*ផែនទីសណ្ឋានដីតំបន់ទំនាបកណ្តាល នៃប្រទេសកម្ពុជា*

នៅតំបន់ទំនាបកណ្ដាលនៃប្រទេសកម្ពុជា គេឃើញមានភ្នំតូចៗនៅដាច់តែឯងជាច្រើនកន្លែង ដែលសុទ្ធសឹងតែជាភ្នំសិលាក្រែដូចជាភ្នំ នៅស្រុកបាទី ក្នុងខេត្តតាកែវ ភ្នំបាភ្នំនៅស្រុកបាភ្នំ ក្នុងខេត្តព្រៃវែង ភ្នំបាជាយនៅស្រុកបាជាយ ក្នុងខេត្តកំពង់ចាម ភ្នំកង្រីនៅស្រុកកំពង់លែង ក្នុងខេត្តកំពង់ឆ្នាំង និងភ្នំក្រោម នៅក្រុងសៀមរាប ក្នុងខេត្តសៀមរាបជាដើម។

### ៣. សារៈសំខាន់សេដ្ឋកិច្ចនៃតំបន់ទំនាបកណ្ដាល

ការសិក្សាពីតំបន់ទំនាបកណ្ដាល នៃប្រទេសកម្ពុជាយើងបានបញ្ជាក់ឱ្យឃើញថា តំបន់នេះជាមណ្ឌលដែលបំពេញមុខងារសំខាន់ណាស់នៅក្នុងសេដ្ឋកិច្ចជាតិយើង ជាពិសេសវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យពាណិជ្ជកម្ម និងវិស័យគមនាគមន៍ ព្រមទាំងជាមជ្ឈមណ្ឌល ផ្ដល់ត្រីយ៉ាងច្រើនសន្ធឹកសន្ធាប់ទៀតផង។ នៅតំបន់ទំនាបកណ្ដាល គេពុំឃើញមានភ្នំ ឬខ្ពង់រាបអ្វីធំដុំនោះឡើយ គឺមានតែកូនភ្នំតូចៗឯណេះមួយឯណោះមួយដូចជា ភ្នំនៅស្រុកបាទីក្នុងខេត្តតាកែវ ភ្នំបាភ្នំនៅក្នុងខេត្តព្រៃវែង ភ្នំបាជាយនៅខេត្ត កំពង់ចាម ភ្នំក្រោមនៅខេត្តសៀមរាប ភ្នំនាងកង្រីនៅខេត្តកំពង់ឆ្នាំង...-ល-។ តំបន់វាលស្រែដ៏ធំល្វឹងល្វើយភាគច្រើន គឺមាននៅក្នុងខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ កំពង់ធំ តាកែវ កំពង់ចាម កំពង់ឆ្នាំង ព្រៃវែង និងខេត្តស្វាយរៀង។

### ខ. តំបន់មាត់សមុទ្រ

តំបន់មាត់សមុទ្រ គឺជាតំបន់មួយដែលមានទីតាំងស្ថិតនៅប៉ែកនិរតី នៃប្រទេសកម្ពុជាយើង។ តំបន់នេះមានខេត្តចំនួន ៤ ដូចជា ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប។ ជាទូទៅ គេចែកតំបន់មាត់សមុទ្រនៃប្រទេសកម្ពុជាជា ៣ ផ្នែកគឺ ទំនាបឆ្នេរ ឆ្នេរសមុទ្រ និងឈូងសមុទ្រ។

### ១. ទំនាបឆ្នេរ

ជាតំបន់ដែលស្ថិតនៅចន្លោះឆ្នេរសមុទ្រ និងជួរភ្នំក្រវ៉ាញ។ ទំនាបនេះមានរយៈកម្ពស់ងើបឡើងយ៉ាងឆាប់រហ័សពីឆ្នេរសមុទ្រទៅទល់នឹងជើងភ្នំ នៃតំបន់កូនភ្នំ និងជួរភ្នំក្រវ៉ាញ ហើយដែលសម្បូរទៅដោយកូនភ្នំ និងផ្លូវទឹកដែលហូរធ្លាក់ចុះមកពីជួរភ្នំក្រវ៉ាញ។ ទោះបីជាមានរយៈកម្ពស់ងើបឡើងយ៉ាងឆាប់រហ័ស និងទទួលរងនូវសំណឹកយ៉ាងខ្លាំងក្ដី ក៏តំបន់នេះនៅតែមានសារៈសំខាន់ដល់សេដ្ឋកិច្ចជាតិផងដែរ ពីព្រោះគេអាចធ្វើចម្ការដំណាំធំៗដូចជា ចម្ការដូងប្រេង ចម្ការ ធូរេន ចម្ការកៅស៊ូ ចម្ការម្រេច និងចម្ការដំណាំហូបផ្លែផ្សេងៗជាច្រើនទៀត។ ក្រៅពីនេះ ទំនាបឆ្នេរច្រើនតែសម្បូរទៅដោយព្រៃកោងកាង ដែលផ្ដល់ជាជម្រកសត្វព្រៃ និងថាមពលសម្រាប់ចម្អិនម្ហូបអាហារផងដែរ។

### ២. ឆ្នេរសមុទ្រ

ប្រទេសកម្ពុជាមានឆ្នេរសមុទ្រប្រវែង ៤៤០ គ.ម ដែលលាតសន្ធឹងចាប់ពីខេត្តកោះកុង កាត់តាមខេត្តព្រះសីហនុ ខេត្តកំពត រហូតដល់ខេត្តកែប។ ឆ្នេរនេះ មានរាងរវេចរវូចខ្លាំងណាស់ដែរ ដែលមានស្នើរកោះ២ យ៉ាងធំស្ថិតនៅជាប់ពីគ្នា ដោយឆកកំពង់សោម គឺស្នើរកោះស្មាច់ និងមួយទៀត គឺស្នើរកោះវាលរេញ។ ឆ្នេរសមុទ្រប្រទេសកម្ពុជាមានជម្រៅមិនសូវជ្រៅប៉ុន្មាននោះទេ ជម្រៅទឹកជាមធ្យមមិនលើសពី៥៦ ម៉ែត្រនោះឡើយ ដែលអាចបង្កលក្ខណៈងាយស្រួលក្នុងការពង្រីកសកម្មភាពនៅតាមឆ្នេរសមុទ្រ។ នៅតាមឆ្នេរសមុទ្រនេះហើយ ដែលរាជរដ្ឋាភិបាលយើងស្ថាបនាកំពង់ផែជាច្រើន គឺកំពង់ផែម៉ុងឫទ្ធី កំពង់ផែរាម និងកំពង់ផែ

កំពង់សោម រីឯក្រុងកែប ដែលស្ថិតនៅតាមឆ្នេរសមុទ្រនេះដែរ ក៏ជាបុរីទេសចរណ៍ដ៏ទំនើបមួយ ប្រកបដោយសោភ័ណភាពយ៉ាងប្រសើរ ដែលទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិបានយ៉ាងច្រើនកុករ។

ដើម្បីងាយស្រួលដល់ការសិក្សា គេចែកឆ្នេរសមុទ្រប្រទេសកម្ពុជាជា ៥ ផ្នែក ពីទិសពាយ័ព្យទៅទិសអាគ្នេយ៍ ដែលរួមមានដូចជា ៖

- **ពីព្រំប្រទល់ប្រទេសថៃត្រង់ចាំយាមទៅទល់នឹងព្រែកគគីរ ៖** ឆ្នេរតំបន់នេះ មានរយៈកម្ពស់ទាប ហើយសម្បូរវាលភក់ ព្រៃកោងកាង និងមានភូមិអ្នកនេសាទជាច្រើនដូចជា នៅថ្មល់ក្របី កោះកាពិ ពាមក្រសោប និងកោះថៅឡាវជាដើម។ ចំណែកឯនៅលើកោះមូលវិញ កាលពីមុន គឺជាទីតាំងនៃមណ្ឌលស្រុកកោះកុង (បច្ចុប្បន្ននៅត្រពាំងរូង) ដែលជាកោះមួយដុះភ្ជាប់មកដីគោកដោយសារទំនប់ផៃ។
- **ពីព្រែកគគីរទៅទល់នឹងជ្រោយសុរិយាវង្ស ៖** ឆ្នេរសមុទ្រនៅត្រង់នេះ គឺស្ថិតនៅក្បែរជើង នៃជួរភ្នំក្រវ៉ាញ និងស្ថិតនៅចំទិសផ្លូវខ្យល់មូសុង ដែលបណ្តាលឱ្យឆ្នេរនេះមានសភាពរេចរឹលខ្លាំង។ លើសពីនេះទៅទៀត ឆ្នេរនេះសម្បូរទៅដោយផ្ទាំងថ្ម ប៉ុន្តែផ្ទាំងថ្មធំៗ ពុំសូវមាននោះទេ មានតែនៅតាមជ្រោយខ្លះ ដែលជាជម្រកនៃឆកសមុទ្រ ហើយសម្បូរទៅដោយដើមស្វាវ ដែលដុះនៅតាមឆ្នេរដូចជា ជ្រោយយាយសែន ជ្រោយស្មាច់ និងជ្រោយសូរីយាវង្ស ព្រមទាំងមានកោះ និងកូនកោះជាច្រើននៅរាយបន្តពីមុខជ្រោយទាំងនោះ សំដៅចុះទៅឈូងសមុទ្រថៃ។ នៅត្រង់ឆ្នេរនេះ គេពុំឃើញមានមនុស្សរស់នៅច្រើននោះទេ។ បច្ចុប្បន្ន ឆ្នេរនៅត្រង់នេះកំពុង ទទួលបានការអភិវឌ្ឍន៍យ៉ាងខ្លាំងក្លាដោយក្រុមហ៊ុនចិនដូចជា អភិវឌ្ឍលើហេដ្ឋរចនាសម្ព័ន្ធ សំណង់លំនៅស្ថាន សំណង់កំពង់ផែសមុទ្រ និងសំណង់ព្រលានយន្តហោះ។
- **ឆកកំពង់សោម** (ពីជ្រោយសុរិយាវង្សដល់កំពង់ផែក្រុងព្រះសីហនុ) **៖** ឆ្នេរនៅត្រង់នេះ បានព័ទ្ធពីក្រៅដោយកោះភ្នំមួយជួរនៅក្នុងលំហសមុទ្រ។ នៅទីនេះ សម្បូរព្រៃកោងកាង ប៉ុន្តែជាទូទៅពុំសូវមានមនុស្សរស់នៅនោះទេ។ នៅខាងលិចនៃឆកនេះ មានជ្រោយសុរិយាវង្ស និង ជ្រោយថ្មស ដែលមានភូមិអ្នកនេសាទនៅត្រង់ចម្លងគោ។ នៅខាងកើតនេះវិញ គឺមានជ្រោយវាលរេញ ដែលមានកំពង់ផែមុងឫទ្ធី និងកំពង់ផែក្រុងព្រះស៊ីហនុ ហើយមានមនុស្សរស់នៅច្រើនគួរសម។ ឆកកំពង់សោមមានទទឹងប្រវែង ៣០ គ.ម ហើយចាប់ផ្តើមចុះរាក់បន្តិចម្តងៗ ដោយសារតែល្បាប់ដែលផ្លូវទឹក ឬព្រែកទាំងឡាយហូរនាំចូលមក។ នៅខាងលិចឆ្នេរនេះទាប ហើយត្រង់ រីឯនៅខាងកើតឆ្នេរវិញទាប ហើយក៏ត្រង់ផងដែរ។ នៅត្រង់តំបន់ខាងជើងឆ្នេរនេះមានរយៈកម្ពស់ខ្ពស់ និងមានថ្មប៉ប្រ៉ះទឹកនៅត្រង់តំបន់ខាងត្បូង។
- **ពីក្រុងព្រះស៊ីហនុទៅឆកទឹកសាប ៖** ឆ្នេរនេះមានឆ្នេរខ្សាច់ជាច្រើនកន្លែង ប្រកបដោយដើមស្វាវឆ្លាស់គ្នានឹងផ្ទាំងថ្មដុះសម្រាប់បម្រើឱ្យវិស័យទេសចរណ៍។ នៅចំកណ្តាលវាលនៃឆកនេះ គឺមានឆកទឹកសាប និងឆករាមដែលជាជម្រកយ៉ាងល្អប្រសើរ សម្រាប់កំពង់ផែសមុទ្រ ព្រោះអាចគេចផុតពីមុខខ្យល់មូសុង។

- **ពីឆកទឹកសាបដល់ហាទៀង ៖** ឆ្នេរនេះ មានរាងផតចូលក្នុង ដោយសារឆកទឹកសាប និងឆកវាលរេញ។ ឆ្នេរតំបន់នេះមានផ្ទៃរាបស្មើ ហើយសម្បូរដោយវាលភក់។ នៅក្បែរមុខចំណោតភ្នំបូកគោ ឆ្នេរនេះមានរាងជាជងធ្នូរដែលសម្បូរទៅដោយដើមកោងកាង និងវាលភក់។ នៅប៉ែកខាងកើតពាមសមុទ្រនៃស្ទឹងកំពតវិញ គឺមានឆ្នេរខ្សាច់ ដែលជាស្ថានីយ៍ងូតទឹកកែប។

***ផែនទីតំបន់មាត់សមុទ្រ និងកោះនៅក្នុងឈូងសមុទ្រកម្ពុជា***




## ៣. ឈូងសមុទ្រ

ឈូងសមុទ្រប្រទេសកម្ពុជាយើងមានជម្រៅពុំសូវជ្រៅប៉ុន្មាននោះទេ ហើយមានបាតរាបស្មើ។ ជម្រៅទឹកជាមធ្យមមាន ៥០ ម៉ែត្រ ហើយជម្រៅជាអតិបរមារមានមិនលើសពី ៧៥ ម៉ែត្រនោះឡើយ។ ឈូងសមុទ្រនេះបានខណ្ឌប្រទេសកម្ពុជាពីឧបទ្វីបម៉ាឡាកា កោះស៊ូម៉ាត្រា និងកោះជ្វា។

ទឹកឈូងសមុទ្រនេះ មានសភាពស្ងប់នៅរដូវប្រាំង (ពីខែធ្នូដល់ខែមេសា) និងមានការរញ្ជួយដោយរលកធំៗ នៅរដូវវស្សា (ពីខែឧសភាទៅខែវិច្ឆិកា)។ ភាពស្ងប់ ឬភាពរញ្ជួយនៃទឹកនេះ កើតឡើងស្របទៅនឹងរបបខ្យល់មូសុង ដែលបក់មកពីទិសឦសាន ឬមកពីទិសនិរតី។

ព្យុះស៊ីក្លូន ឬព្យុះទីផុងក្នុងសមុទ្រចិនពុំដែលមាននៅលើឈូងសមុទ្រនេះឡើយ គឺមានតែព្យុះភ្លៀងខ្លះៗ នៅពេលប្តូររបបខ្យល់មូសុងតែប៉ុណ្ណោះ ជាហេតុបណ្តាលអោយមានគ្រោះថ្នាក់តិច និងមានថ្មប៉ប្រះទឹកក៏តិចតួចដែរ។

ឈូងសមុទ្រថៃនេះ ស្ថិតនៅក្រោមឥទ្ធិពលជំនោរទឹកដូចជាសមុទ្រដទៃទៀតដែរ គឺក្នុង ១ ថ្ងៃ (២៤ ម៉ោង) មានជំនោរពីរដងឆ្លាស់គ្នា និងមានលំនាចពីរដងឆ្លាស់គ្នាផងដែរ។ ចលនាជំនោរនេះកើតឡើង

ដោយសារតែបម្រែបម្រួល នៃផ្ទៃទឹកសមុទ្រទាំងឡាយ ក្រោមឥទ្ធិពលនៃទំនាញព្រះអាទិត្យ និងព្រះច័ន្ទ។ ក្រៅពីជំនោរទឹក ក៏មានចរន្តទឹកសមុទ្រ ដែលកើតឡើងពីការបក់បោកនៃខ្យល់តំបន់នោះផងដែរ។

**៤. កោះនៅក្នុងសមុទ្រកម្ពុជា**

ទោះបីជាឈូងសមុទ្រយើងមានជម្រៅមិនសូវជ្រៅយ៉ាងណាក្តី ក៏នាវាសមុទ្រធំៗអាចចូលមកដល់កំពង់ផែព្រះសីហនុ និងកំពង់ផែម៉ុងឫទ្ធីបានដោយងាយស្រួលផងដែរ។ ម្យ៉ាងទៀត ក្រៅពីភាពអនុគ្រោះដល់នាវាចរណ៍ ឈូងសមុទ្រប្រទេសកម្ពុជាយើង ក៏សម្បូរដោយកោះច្រើនណាស់ផងដែរ។ កោះទាំងនោះរួមមានដូចជា ៖

- **ក្រុមកោះនៅខាងភាគជើងពាមសមុទ្រព្រែកតាតៃ៖** ជាក្រុមកោះដែលកើតឡើងដោយសារសម្រុតបាតសមុទ្រនៅក្នុងតំបន់នេះដូចជា កោះពរ កោះកាពិ កោះថៅឡាវ កោះស្តេត និងកោះមូល។
- **កោះកុង** ៖ ជាកោះដែលមានផ្ទៃធំជាងគេនៅប្រទេសកម្ពុជាយើង ដោយមានទំហំប្រហែល ៨០ គ.ម២។ កោះនេះ គឺជាកូនភ្នំមួយដែលមានកម្ពស់រហូត ៤១០ ម៉ែត្រ ហើយបាននៅដាច់ចេញពីទ្វីបដោយសារបំណាក់ស្រុតភ្នំភ្លើង។ នៅប៉ែកខាងលិច កោះនេះបែរមុខទៅរកទិសខ្យល់មូសុងនិរតី ដែលបណ្តាលឱ្យឆ្នេរកោះនេះមានរាងរឆេចរឆូច និងប្រកបដោយផ្ទាំងថ្មដែលស្ទើរតែចូលពុំចុះ។ ផ្ទុយទៅវិញ នៅឆ្នេរប៉ែកខាងកើតនៃកោះនេះវិញ គេចផុតពីទិសខ្យល់មូសុង ហើយឆ្នេរមិនរឆេចរឆូចនោះទេ មានប្រជាជនរស់នៅ និងមានចម្ការដំណាំធំៗជាច្រើនថែមទៀតផង។
- **ក្រុមកោះស្ថិតនៅចន្លោះកោះកុង** ៖ ជាកូនកោះមួយជួរ ប្រកបដោយថ្មនៅតាមបណ្តាយជុំវិញជ្រោយស្មាច់។ ក្រុមកោះទាំងនោះរួមមានដូចជា កោះដំបង កោះព្រះ កោះខ្មោច កោះស្មាច់ កោះស្វាយ និងកោះសាមិត។
- **កោះស្ថិតនៅចំពីមុខឆកកំពង់សោម** ៖ កោះទាំងនេះរួមមាន កោះរង់ និងកោះរង់សន្លឹម។ កោះទាំង ២ នេះ ភ្ជាប់មកដីគោកដោយសារកូនកោះមួយជួរ។
- **កោះដែលនៅឯនាយស្ទើរកោះវាលរេញ** ៖ មានកោះ ៤ ក្រុមគឺ ៖
  - **ក្រុមទី ១** ៖ ក្រុមកោះនៅចំពីមុខកំពង់ផែព្រះសីហនុរួមមាន កោះពស់ កោះសង្ហារ និងកូនកោះតូចៗដទៃទៀត។
  - **ក្រុមទី ២** ៖ ក្រុមកោះនៅចំពីមុខរាមរួមមាន កោះតាកៀវ កោះឬស្សី កោះត្រែះ កោះចន្លុះ និងកោះស្រមោច។
  - **ក្រុមទី ៣** ៖ ក្រុមកោះនេះស្ថិតនៅបន្តទៅកោះត្រល់រួមមាន កោះថ្មី និងកោះសេះ។
  - **ក្រុមទី ៤** ៖ ក្រុមកោះនេះស្ថិតនៅក្នុងលំហនៃឈូងសមុទ្រប្រទេសកម្ពុជាយើងមានដូចជា កោះតាង កោះអាគ្នេយ៍ កោះព្រីង កោះរៀ និងកោះពូលូវ៉ៃ។
- **កោះត្រល់** ៖ ជាកោះមួយដែលពីដើមជាកម្មសិទ្ធិរបស់ខ្មែរយើង ប៉ុន្តែឥឡូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសវៀតណាម។ កោះនេះ គឺជាកោះមួយដ៏ធំ ដែលជារបាំងការពារឆ្នេរមិនឱ្យប៉ះជាមួយនឹងខ្យល់មូសុងនិរតី និងជាបាំងការពារជម្រករបស់អ្នកភូមិនេសាទជាច្រើន។

- **ក្រុមកោះនៅខាងត្បូងស្ថានីយ៍ងូតទឹកកែប** ៖ គឺជាក្រុមកោះចុងក្រោយបង្អស់របស់ប្រទេសយើង ដែលមានដូចជា កោះស្វាយ កោះទន្សាយ កោះត្បាល់ កោះដែកគោល កោះពោធិ៍ កោះអង្គញ់ កោះសេះ និងកោះឫស្សី។

កោះនៅក្នុងឈូងសមុទ្ររបស់ប្រទេសយើងភាគច្រើន គឺពុំសូវមានប្រជាជនរស់នោះទេ ព្រមទាំងប្រកបដោយព្រៃស្តុកទៀតផង។ ក៏ប៉ុន្តែសព្វថ្ងៃនេះ កោះមួយចំនួនធំជាមជ្ឈមណ្ឌលនេសាទយ៉ាងសំខាន់នៅរដូវដែលខ្យល់មូសុងបក់មកពីទិសឦសាន និងត្រូវបានគេធ្វើអាជីវកម្មព្រៃឈើខ្លះៗហើយ។ ចំណែកឯកោះមួយចំនួនផ្សេងទៀតដូចជា កោះរង់ កោះរង់សន្លឹម កោះ ទន្សាយ កោះពស់ កោះថាស កោះស្មាច់ កោះឋានសួគ៌ កោះសង្ហរជាដើម កំពុងតែទទួលបានការអភិវឌ្ឍន៍ពីក្រុមហ៊ុនឯកជនមួយចំនួនដែលបានផ្តល់អាជ្ញាប័ណ្ណដោយរដ្ឋាភិបាលកម្ពុជា។

### ៥. សារៈសំខាន់សេដ្ឋកិច្ចនៃតំបន់មាត់សមុទ្រ

យោងទៅតាមការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា តំបន់មាត់សមុទ្រនៃប្រទេសកម្ពុជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជា ជាពិសេសសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចដូចជា អភិវឌ្ឍវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យពាណិជ្ជកម្ម និងវិស័យដឹកជញ្ជូនជាដើម ពីព្រោះតំបន់នេះ ដីសម្បូជីជាតិណាស់ សម្រាប់ដំណាំដូចជា ដំណាំដូងប្រេង ដំណាំដូង ដំណាំម្រេច ដំណាំទុរេន ដំណាំសាវម៉ាវ ដំណាំកោស៊ូ ដំណាំស្រូវ និងដំណាំហូបផ្លែជាច្រើនប្រភេទទៀត។ ជាងនេះទៅទៀត តំបន់នេះមានឆ្នេរខ្សាច់ម៉ដ្ឋសខៃ មានកោះ មានផ្ទាំងថ្ម មានព្រៃឈើ មានទឹកធ្លាក់ មានព្រៃកោងកាងសមុទ្រ មានខ្យល់ជំនោរសមុទ្រដ៏បរិសុទ្ធ មានជួរផ្កាថ្ម ដែលសុទ្ធសឹងតែបានទាក់ទាញដល់ភ្ញៀវទេសចរ និងបម្រើឱ្យវិស័យទេសចរណ៍នៅកម្ពុជា។ ជាងនេះទៅទៀត តំបន់នេះមានឈូងសមុទ្រ ដែលជាសមុទ្រស្ងប់ សម្បូរត្រី និងរ៉ែជាពិសេសឥន្ធនៈផូស៊ីល ដែលអនុគ្រោះដល់ការធ្វើនាវាចររបស់នាវាសមុទ្រតូចធំ ការធ្វើពាណិជ្ជកម្មតាមផ្លូវសមុទ្រ ជម្រកសំណង់កំពង់ផែ ការនេសាទសមុទ្រ និងការធ្វើអាជីវកម្មរុករករ៉ែ ពិសេសប្រេងកាត និងឧស្ម័នធម្មជាតិបានថែមទៀតផង។

ម្យ៉ាងទៀត ឆ្នេរសមុទ្រមានខ្សាច់ រីឯទឹកសមុទ្រវិញមានកម្រិតជាតិប្រៃខ្ពស់ ដែលសុទ្ធតែផ្តល់នូវវត្ថុធាតុដើម សម្រាប់បម្រើឱ្យវិស័យឧស្សាហកម្ម និងផ្តល់នូវអំបិលសម្រាប់បរិភោគថែមទៀតផង។ ក្រៅពីនេះ តំបន់មាត់សមុទ្រសម្បូរទៅដោយផ្លូវទឹក ដែលផ្តល់នូវលក្ខណៈដ៏ល្អប្រសើរ សម្រាប់ស្ថាបនាទំនប់វារីអគ្គិសនី និងជាទីកន្លែងដ៏ល្អប្រសើរ សម្រាប់សំណាងរោងចក្រឧស្សាហកម្ម សំណង់កំពង់ផែ ពីព្រោះនៅទីនេះប្រមូលផ្តុំទៅដោយផ្លូវគមនាគមន៍គ្រប់ប្រភេទទាំងអស់ដូចជា ផ្លូវដែក ផ្លូវអាកាស ផ្លូវថ្នល់ និងផ្លូវទឹក។

## គ. តំបន់ប្រជុំភ្នំ

ដើម្បីងាយស្រួលក្នុងការសិក្សា គេបែងចែកតំបន់ប្រជុំភ្នំនៃប្រទេសកម្ពុជាជាផ្នែកតូចៗទៀតគឺ ជួរភ្នំក្រវាញ ជួរភ្នំដងរែក និងតំបន់កូនភ្នំ។

### ១. ជួរភ្នំក្រវាញ

ជួរភ្នំក្រវាញនៅប្រទេសកម្ពុជា គឺមានទីតាំងស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា ដែលលាតសន្ធឹងចាប់តាំងពីភាគខាងជើង នៃខេត្តច័ន្ទបុរី ក្នុងប្រទេសថៃរហូតដល់ខេត្តកំពត នៃប្រទេសកម្ពុជាយើង ដោយ

លាតសន្ធឹងពីទិសពាយ័ព្យសំដៅទៅទិសអាគ្នេយ៍ស្របតាមបណ្ដោយឆ្នេរសមុទ្រ។ គេអាចសន្និដ្ឋានបានថា ជួរភ្នំក្រវាញមានកំណើតនៅក្នុងស័កទី១ ក្នុងកាលសម័យកុំប្រ៊ីយាង និងនៅក្នុងពេលដែលផែនដីបានទទួលរងនូវចលនាពំនើងផ្នត់មួយមានឈ្មោះថា **អែស៊ីញាង** ហើយជួរភ្នំនេះបានក្លាយ ទៅជាទំនាបសំណឹក ដែលត្រូវគ្របដណ្ដប់ដោយកំទេចកំណានៅស័កទី២។ ហេតុដូច្នេះហើយ បានជាគេសង្កេតឃើញនៅបាតនៃជួរភ្នំនេះសុទ្ធសឹងតែគ្របដណ្ដប់ទៅដោយសិលាក្រានីត ដែលមានសិលាក្រែលាយខ្សាច់បានគ្របដណ្ដប់ពីខាងក្រៅយ៉ាងក្រាស់។

តាមដំណើរវិវត្តន៍ នៃសកម្មភាពសំណឹកបានស៊ីផ្ដាច់ជួរភ្នំនេះ ហើយបានប្រែក្លាយជួរភ្នំនេះទៅជាខ្ពង់រាប ដែលមានមុខចំណោតយ៉ាងចោត គឺភ្នំបូកគោ ឬជាភ្នំដាច់ៗពីគ្នា។

ដើម្បីងាយស្រួលក្នុងការសិក្សា គេចែកជួរភ្នំនេះ ៣ ផ្នែកទៀតគឺ ៖

- **ជួរភ្នំក្រវាញខាងលិច** ៖ លាតសន្ធឹងពីខេត្តប៉ៃលិនរហូតដល់ស្ទឹងពោធិ៍សាត់។ កំពូលភ្នំខ្ពស់ៗ នៅក្នុងតំបន់នេះរួមមាន ភ្នំសពុក (កម្ពស់ ៨៩៣ ម៉ែត្រ) ភ្នំតាជិត (កម្ពស់ ១១១៤ ម៉ែត្រ) ភ្នំទឹកព្រិល (កម្ពស់ ១១២៣ ម៉ែត្រ) ភ្នំមូស (កម្ពស់ ១៣៣៧ ម៉ែត្រ) ភ្នំធំ (កម្ពស់ ១២៥៨ ម៉ែត្រ) ភ្នំខ្មោច (កម្ពស់ ១៤២៥ ម៉ែត្រ) និងភ្នំទំព័រ (កម្ពស់ ១៥៦៣ ម៉ែត្រ) គឺជាភ្នំ ដែលមានកម្ពស់ខ្ពស់ជាងគេ នៅក្នុងតំបន់នេះ។
- **ជួរភ្នំក្រវាញកណ្ដាល** ៖ ជាប្រជុំភ្នំមួយដ៏ធំ ដែលលាតសន្ធឹងចាប់ពីស្ទឹងពោធិ៍សាត់រហូតដល់ព្រែកតាតី ដោយមានផ្ទៃទេរពីមោងសំដៅទៅខេត្តកោះកុង។ នៅប៉ែកខាលិចនៃជួរភ្នំនេះ មានភ្នំសំកុស (កម្ពស់ ១៧៤៤ ម៉ែត្រ) នៅក្បែរឈូងសមុទ្រថៃ។ រីឯនៅប៉ែកខាងកើតនៃជួរភ្នំនេះវិញមានភ្នំជាច្រើនដែលសុទ្ធសឹងជាភ្នំ ដែលមានរយៈកម្ពស់លើសពី ១០០០ ម៉ែត្រឡើងទៅដូចជា ភ្នំបាន (កម្ពស់ ១៤០០ ម៉ែត្រ) ភ្នំបាកាន (កម្ពស់ ១២២០ ម៉ែត្រ) និងភ្នំខ្នងត្រពាំង (កម្ពស់ ១១៧២ ម៉ែត្រ)។
- **ជួរភ្នំក្រវាញខាងកើត ៖** លាតសន្ធឹងចាប់ពីព្រែកតាតីត្រង់ភ្នំតាសីរហូតដល់ភ្នំបូកគោ។ គេចែកជួរភ្នំនេះជា ៣ ក្រុមទៀតគឺ ៖
  - **ប្រជុំភ្នំខ្មោល** ៖ ស្ថិតនៅចន្លោះខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។ គឺនៅទីនេះហើយ គេឃើញមានភ្នំ ដែលមានកំពូលខ្ពស់ជាងគេបំផុតនៅក្នុងប្រទេសកម្ពុជាឈ្មោះ **ភ្នំឱរ៉ាល់** ដែលមានកម្ពស់រហូតដល់ ១៨១៣ ម៉ែត្រ។
  - **ប្រជុំភ្នំអូរម្លូ** ៖ ស្ថិតនៅចន្លោះស្រុកស្រែអំបិល និងខេត្តកំពង់ស្ពឺ ដែលមានរយៈកម្ពស់មិនលើសពី ១ ០០០ ម៉ែត្រនោះឡើយដូចជា ខ្ពង់រាបគីរីរម្យ (កម្ពស់ ៧០០ ម៉ែត្រ) ជាដើម។
  - **ប្រជុំភ្នំដំរី** ៖ នៅដាច់ពីប្រជុំភ្នំអូរម្លូ ដោយច្រកពេជ្រនិល ដែលដាច់ដោយផ្លូវជាតិលេខ ៤ គឺផ្លូវដែលចេញពីរាជធានីភ្នំពេញឆ្ពោះទៅខេត្តព្រះសីហនុ។ នៅប៉ែកខាងត្បូងបំផុត ប្រជុំភ្នំនេះត្រូវបញ្ចប់ដោយភ្នំបូកគោ ដែលមានកម្ពស់ ១០៧៥ ម៉ែត្រ។




ផែនទីជួរភ្នំក្រវាញនៃប្រទេសកម្ពុជា

ជួរភ្នំក្រវាញជាជញ្ជាំងខណ្ឌតំបន់ទំនាបកណ្ដាល និងតំបន់មាត់សមុទ្រនៃប្រទេសកម្ពុជា ប៉ុន្តែ ទោះបីជាដូចនេះក្ដី គេអាចធ្វើការទំនាក់ទំនងពីតំបន់ទំនាបកណ្ដាល និងតំបន់មាត់សមុទ្របាន ដោយឆ្លង កាត់តាមច្រកសំខាន់ៗ ៣ គឺ ៖

- **ច្រកពេជ្រនិល ៖** ពីខេត្តកំពង់ស្ពឺទៅស្រែអំបិល និងខេត្តព្រះសីហនុ
- **ច្រកតាសី ៖** ពីខេត្តពោធិ៍សាត់ទៅខេត្តកោះកុង ឬស្រែអំបិល និងខេត្តព្រះសីហនុ
- **ច្រកវាលវែង ៖** ពីមោង និងពីសំឡូត ខេត្តបាត់ដំបងទៅខេត្តកោះកុង។

ជួរភ្នំក្រវាញពុំទាន់មានការត្រួសត្រាយ ឬការរុករកឱ្យបានដិតដល់នៅឡើយទេ គឺជាតំបន់ព្រៃក្រាស់ ដែលពិបាកចេញចូលដោយសារខ្វះបណ្ដាញគមនាគមន៍។ ព្រៃនៅក្នុងជួរភ្នំនេះមានលក្ខណៈជាព្រៃត្រូពិច ដែលមានរុក្ខជាតិគ្រប់ប្រភេទដុះប្រជ្រៀតគ្នា ព្រមទាំងសម្បូរទៅដោយសត្វតូចធំជាច្រើនរស់នៅផងដែរ។ នៅ ចំហៀង ដែលបែរទៅរកតំបន់មាត់សមុទ្រ គឺសម្បូរទៅដោយព្រៃកោងកាង។ រីឯនៅខ្ពង់រាបគីរីរម្យវិញ គេឃើញ មានសម្បូរទៅដោយព្រៃស្រល់។ ក្រៅពីនេះ សន្ទស្សន៍នៃការស្រាវជ្រាវរុករករ៉ែបានបញ្ជាក់ថា ជួរភ្នំក្រវាញមាន រ៉ែជាច្រើនកន្លែង ពិសេសកំណប់ត្បូងថ្មនៅម្ដុំខ្ពង់រាបគីរីរម្យ។ បច្ចុប្បន្ន នេះមានរ៉ែមួយចំនួនត្រូវបានគេកំពុងធ្វើ អាជីវកម្ម ដើម្បីទាញយកមកប្រើប្រាស់ដូចជា ថ្មម៉ាប និងថ្មកែវជាដើម។

ដូចនេះ ជួរភ្នំក្រវាញជាជួរភ្នំមួយដែលផ្ដល់នូវសារៈសំខាន់បានមួយចំណែកដល់សេដ្ឋកិច្ចជាតិផង ដែរ ប៉ុន្តែដោយខ្វះប្រព័ន្ធគមនាគមន៍ ទើបតំបន់នេះមានប្រជាជនរស់នៅតិចតួច ហើយពុំទាន់បានធ្វើការ ស្រាវជ្រាវឱ្យបានដិតដល់នៅឡើយ។

**២. ជួរភ្នំដងរែក**

ជួរភ្នំដងរែកនៃប្រទេសកម្ពុជា ជាជួរភ្នំមួយ ដែលមានទីតាំងស្ថិតនៅតាមព្រំដែនប៉ែកខាងជើងនៃ ប្រទេស ដែលជាព្រំដែនរួមរវាងប្រទេសកម្ពុជា និងប្រទេសថៃ។ ជួរភ្នំនេះ សណ្ដូកពីកើតទៅលិច គឺចាប់ពី ជ្រលងទន្លេមេគង្គ នៃប្រទេសកម្ពុជាទៅជ្រលងទន្លេមេណាម ឬទន្លេចៅផ្រះយ៉ា នៃប្រទេសថៃ។ តាមពិតជួរភ្នំ ដងរែកមិនមែនជាជួរភ្នំនោះទេ វាគឺជាគែមខាងត្បូងនៃខ្ពង់រាបនគររាជ (កូរ៉ាត) ដែលស្ថិតនៅក្នុងភូមិភាគខាងកើត នៃប្រទេសថៃ។ ជួរភ្នំនេះ ជាជញ្ជាំងសិលាដែលមានមុខចំណោតយ៉ាងខ្លាំងមកខាងប្រទេសកម្ពុជា និងមាន ប្រវែងបណ្ដោយប្រហែល ៣០០ គីឡូម៉ែត្រ និងមានរយៈកម្ពស់ទេចុះជាលំដាប់ពីកើតទៅលិច គឺចុះពីប្រទេស កម្ពុជាសំដៅទៅប្រទេសថៃ ក្នុងរយៈកម្ពស់ពី ៧០០ ម៉ែត្រ ទៅ ២០០ ម៉ែត្រ។ នៅក្នុងជួរភ្នំនេះ គេសង្កេត ឃើញមានភ្នំដែលមានកំពូលខ្ពស់ៗ រាប់ពីកើតទៅលិចដូចជា ភ្នំដងរែកកម្ពស់ ៧៥៦ ម៉ែត្រ ភ្នំព្រះវិហារកម្ពស់ ៦២៥ ម៉ែត្រ ភ្នំអន្លង់ស្វាយកម្ពស់ ៥៥៧ ម៉ែត្រ និងភ្នំម៉ាកែកម្ពស់ ៥៣៧ ម៉ែត្រ។

ទោះបីជាជួរភ្នំដងរែក គឺជាជញ្ជាំងសិលាដែលខណ្ឌប្រទេសកម្ពុជា និងប្រទេសថៃក៏ដោយចុះ ក៏គេ អាចធ្វើដំណើរឆ្លងកាត់បានដោយងាយ តាមច្រកសំខាន់ៗជាច្រើន។ ច្រកសំខាន់ៗដែលអាចឱ្យគេធ្វើដំណើរ ឆ្លងកាត់ជួរភ្នំនេះពីប្រទេសកម្ពុជាទៅប្រទេសថៃចែកចេញជា ២ គឺ ៖

- **ច្រកចាស់** ៖ រួមមាន ៥ គឺ ៖
  - ច្រកអន្សែ

- ប្រកជួនតាប៉ាយ
- ប្រកជួនឱ
- ប្រកតាព្រហ្ម
- ប្រកកូន។

▪ **ប្រកថ្មី** ៖ រួមមានដូចជា ៖

- ប្រកម៉ុបី
- ប្រកអានសេះ
- ប្រកតាថៃវ
- ប្រកដាំ-សាង៉ុំ
- ប្រកអូរស្មាច់
- ប្រកប្រាសាទតាក្របី
- ប្រកដប់គគីរ
- ប្រកអូរបីជាន់។

ជួរភ្នំដងរែកនៃប្រទេសកម្ពុជា ជាតំបន់ព្រៃរបោះ ដែលប្រកបទៅដោយពូជឈើមានតម្លៃល្អៗ និងសម្បូរទៅដោយសត្វព្រៃផងដែរ។ ដូចនេះ ជួរភ្នំដងរែកក៏ដូចជាជួរភ្នំក្រវ៉ាញដែរ សុទ្ធសឹងតែជាតំបន់ដែលមានសារៈសំខាន់ដល់សេដ្ឋកិច្ចជាតិយើង។

**៣. តំបន់កូនភ្នំ**

តំបន់កូនភ្នំ គឺជាតំបន់ដែលមានទីតាំងស្ថិតនៅជុំវិញជួរភ្នំក្រវ៉ាញ ដោយមានកូនភ្នំស្ថិតនៅដាច់ៗពីគ្នា និងមានរយៈកម្ពស់មិនលើសពី ៨០០ ម៉ែត្រនោះឡើយ។ តំនប់នេះ បានភ្ជាប់ជួរភ្នំក្រវ៉ាញទៅកាន់តំបន់មាត់សមុទ្រមួយផ្នែក ហើយមួយផ្នែកទៀតបានភ្ជាប់ជួរភ្នំក្រវ៉ាញទៅទំនាបកណ្តាល។ នៅក្នុងតំបន់នេះ គេសង្កេតឃើញមានអ្នកស្រុករស់នៅតែនៅត្រង់វាលទំនាប និងជ្រលងភ្នំដែលដីមានជីជាតិប៉ុណ្ណោះ។ ជាទូទៅគេចែកតំបន់កូនភ្នំនៅប្រទេសកម្ពុជាយើងជា ៦ ក្រុម ដែលរួមមាន ៖

**៣.១. តំបន់កូនភ្នំខាងលិចខេត្តបាត់ដំបង ៖** កូនភ្នំទាំងនេះលាតសន្ធឹងពីអូរជ្រៅទៅមោង ដែលមានកូនភ្នំប្រកបដោយភាពប្លែកៗ ដែលមានកំណើតពីសិលាច្រើនបែបច្រើនយ៉ាងដូចជា សិលាក្រាមនិងសិលាក្រែ មានភ្នំវែងជាដើម សិលាក្រែ និងសិលាស៊ីសមានភ្នំរទា និងភ្នំម៉ាកហឿន និងថ្មកំបោរមានភ្នំសំពៅ និងភ្នំសេរីសោភ័ណ្ឌជាដើម។

**៣.២. តំបន់កូនភ្នំចន្លោះខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ៖** ជាខ្ពង់រាបល្បាប់ចាស់មួយ ដែលមានកូនភ្នំជាច្រើនដូចជា ភ្នំថ្មក្រែមានភ្នំកំរែង (ខេត្តពោធិសាត់) និងកូនភ្នំថ្មភ្នំភ្លើងមានភ្នំក្រាំងលាវជាដើម (ខេត្តកំពង់ឆ្នាំង)។

**៣.៣. តំបន់ខ្ពង់រាបខេត្តកំពង់ស្ពឺ ៖** តំបន់នេះ មានរយៈកម្ពស់កើនឡើងជាលំដាប់ ចាប់ពីតំបន់ទំនាបកណ្តាលទៅជួរភ្នំក្រវ៉ាញ ហើយមានប្រជុំភ្នំទាំងអស់ចំនួន ៣ ដែលរួមមាន ៖

- ភាគឦសាន ៖ មានប្រជុំកូនភ្នំជំរាយ

– ភាគកណ្តាល ៖ មានភ្នំពិស ភ្នំក្រោល ភ្នំព្រះ
– ភាគនិរតី ៖ មានប្រជុំកូនភ្នំរាជាគង់។

**៣.៤. តំបន់កូនភ្នំចន្លោះកំពង់ស្ពឺ និងខេត្តកំពត ៖** ជាខ្ពង់រាបខ្សាច់ ដែលមានផ្ទៃចេះតែរួមតូចទៅៗ នៅទិសខាងត្បូង និងប្រកបដោយប្រជុំភ្នំសំខាន់ៗ ៣ គឺ ៖

– ភ្នំចង្អោរ (កម្ពស់ ៧២២ ម៉ែត្រ)
– ភ្នំព្រះ (កម្ពស់ ៧៨០ ម្រ៉ែត)
– និងភ្នំទ្វារ។

**៣.៥. តំបន់កូនភ្នំចន្លោះខេត្តកំពត និងខេត្តតាកែវ៖** ជាខ្ពង់រាបមួយដ៏ទាប និងប្រកបដោយកូនភ្នំ ដែលមានកម្ពស់ចាប់ពី ១០០ ម៉ែត្រ ដល់ទៅ ៣០០ ម៉ែត្រ ដែលមានដូចជា កូនភ្នំកែប នៅខេត្តកែប ភ្នំថ្មកំបោរ នៅស្រុកកំពង់ត្រាច និងស្រុកបន្ទាយមាស ខេត្តកំពត និងប្រជុំភ្នំបាក់នឹមនៅតានី ស្រុកអង្គរ-ជ័យ ខេត្តកំពត និងភ្នំជំរីរមៀលនៅស្រុកត្រាំកក់ ខេត្តតាកែវជាដើម។

**៣.៦. តំបន់កូនភ្នំនៅតាមតំបន់មាត់សមុទ្រ៖** តំបន់នេះ សំបូរកូនភ្នំ ដែលជួនកាលជាកូនភ្នំនៅតាមទំនាបឆ្នេរដូចជា ភ្នំទំនាបវាលវេញជាដើម ហើយជួនកាលទៀតជាកូនភ្នំ ដែលលិចចេញពីសមុទ្រ មានលក្ខណៈជាកោះដូចជា កោះកុង ជាដើម ដែលមានកម្ពស់រហូតដល់ទៅ ៤១០ ម៉ែត។

**៤. សារៈសំខាន់សេដ្ឋកិច្ចនៃតំបន់ប្រជុំភ្នំ**

ជាទូទៅតំបន់ភ្នំនៃប្រទេសកម្ពុជាយើង សុទ្ធសឹងតែផ្តល់សារៈសំខាន់ជាច្រើន សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិយើងទាំងវិស័យកសិកម្ម វិស័យទេសចរណ៍ វិស័យថាមពល និងវិស័យឧស្សាហកម្ម។ ប្រជុំភ្នំទាំងនេះសម្បូរព្រៃឈើ ដែលសុទ្ធសឹងតែជាពូជឈើមានតម្លៃ សម្រាប់គ្រឿងសំណង់ ធ្វើតុ ធ្វើទូតាំង និងឧស្សាហកម្មដូចជា ត្រាច ខ្លុង ត្បែង ឈើទាល ធ្នឹក ធ្នង់ កកោះ ស្រឡៅ បេង នាងនួន គគីរ ក្រញូង...-ល-។ ក្រៅពីនេះ តំបន់ប្រជុំភ្នំទាំងនេះ សម្បូរទៅដោយអនុផលព្រៃឈើ និងសត្វព្រៃជាច្រើនប្រភេទដូចជា រមាស ដំរី ខ្ទីង ខ្លាធំ ទន្សោង ប្រើស ក្តាន់ និងជ្រូកព្រៃជាដើម ដែលផ្តល់ដូចជាជ័រ វល្លិ ផ្តៅ ឫស្សី ឃ្មុំ សាច់ ឆ្អឹង ស្បែក ស្នែង ភ្លុក សម្រាប់ទីផ្សារពិភពលោក។

ម្យ៉ាងទៀត ព្រៃឈើ និងសត្វព្រៃទាំងនេះក៏បានចូលរួមចំណែកក្នុងការទាក់ទាញភ្ញៀវទេសចរឱ្យចូលមកទស្សនាប្រទេសយើងផងដែរ ដែលផ្តល់នូវប្រាក់ចំណូលយ៉ាងច្រើន ក្នុងសេដ្ឋកិច្ចជាតិ និងព្រមទាំងបានចូលរួមចំណែកលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនយើងផងដែរ តាមរយៈការបម្រើសេវាកម្មទេសចរណ៍។ លើសពីនេះទៅទៀត តំបន់ប្រជុំភ្នំភ្នំ សម្បូរដោយកំណាប់រ៉ែជាច្រើនប្រភេទដូចជា ត្បូងថ្ម ត្បូងលីញ៉ីត ប្រេងកាត រ៉ែបុកស៊ីត រ៉ែមាស ត្បូងថ្ម និងរ៉ែអែលោហៈ និងរ៉ែលោហៈមានតម្លៃជាច្រើនទៀត ដែលសុទ្ធតែបានចូលរួមចំណែកក្នុងការលើកកម្ពស់ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិយើងឱ្យរីកចម្រើនទៅមុខបាន។ ក្រៅពីនេះ តំបន់ប្រជុំភ្នំនៃប្រទេសកម្ពុជាភាគច្រើន សម្បូរទៅដោយប្រភពនៃផ្លូវទឹក ជាពិសេសទឹកជ្រោះសុទ្ធសឹងតែអនុគ្រោះដល់ការស្ថាបនានូវទំនប់វារីអគ្គិសនី ដែលផ្តល់នូវថាមពលរាប់ពាន់គីឡូវ៉ាត់ សម្រាប់ប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម និងជីវភាពរស់នៅរបស់ប្រជាជនយើង។

*ផែនទីជួរភ្នំដងរែក និងខ្ពង់រាបខាងជើង*




## ឃ. តំបន់ខ្ពង់រាប

តំបន់ខ្ពង់រាបនៃប្រទេសកម្ពុជាយើង ជាតំបន់មួយដែលមានទីតាំងស្ថិតនៅភាគខាងជើង ភាគខាងកើត និងភាគឦសាននៃប្រទេសកម្ពុជា។ ដើម្បីងាយស្រួលក្នុងការសិក្សា គេបែងចែកតំបន់ខ្ពង់រាបនេះជា ២ ក្រុម គឺ ៖

### ១. ខ្ពង់រាបខាងជើង

តំបន់ខ្ពង់រាបខាងជើង គឺជាតំបន់ខ្ពស់ដែលស្ថិតនៅបន្តពីជួរភ្នំដងរែកមកភ្ជាប់នឹងតំបន់ទំនាបកណ្តាល នៃប្រទេសកម្ពុជា ដែលស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តសៀមរាប និងខេត្តកំពង់ធំ។ ខ្ពង់រាបនេះគ្របដណ្តប់ទៅដោយល្បាប់ចាស់ឆ្លាស់គ្នានឹងថ្មបាយក្រៀម ដែលសម្បូរដោយព្រៃរបោះ។ នៅតាមទ្រនុងកណ្តាលនៃខ្ពង់រាបនេះ គេសង្កេតឃើញមានកូនភ្នំមួយចំនួន ដែលស្ថិតនៅដាច់ៗពីគ្នាដូចជា ភ្នំត្បែងនៅក្នុងខេត្តព្រះវិហារ ភ្នំចុងកាល់នៅក្នុងខេត្តឧត្តរមានជ័យ ភ្នំគូលែននៅក្នុងខេត្តសៀមរាប និងភ្នំសន្ទុកនៅក្នុងខេត្តកំពង់ធំ...-ល-។ ក្រៅពីព្រៃរបោះ និងកូនភ្នំ ផ្ទៃដីនៃខ្ពង់រាបនេះមួយភាគធំ ជាដីសម្រាប់ដាំដំណាំ។ ដូចនេះ ខ្ពង់រាបខាងជើង ក៏ជាតំបន់ដែលមានសារៈសំខាន់ដល់សេដ្ឋកិច្ចជាតិយើងផងដែរ ពិសេសវិស័យកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។

**២. ខ្ពង់រាបខាងកើត និងឦសាន**

តំបន់ខ្ពង់រាបខាងកើត និងឦសាននៃប្រទេសកម្ពុជា គឺជាតំបន់ដែលមានទីតាំងស្ថិតនៅបន្តពីជ្រលងទន្លេមេគង្គ ហើយលាតសន្ធឹងរហូតដល់ប្រទេសវៀតណាម។ ជាទូទៅ គេចែកខ្ពង់រាបនេះជា ៤ ផ្នែកទៀត គឺ ៖

**២.១. ខ្ពង់រាបខេត្តក្រចេះ និងស្ទឹងត្រែង**

ខ្ពង់រាបខេត្តក្រចេះ និងខេត្តស្ទឹងត្រែង គឺជាខ្ពង់រាបមួយ ដែលមានលក្ខណៈដូចគ្នានឹងខ្ពង់រាបខាងជើងផងដែរ ប៉ុន្តែស្ថិតនៅដាច់ពីខ្ពង់រាបនេះ ដោយសារទន្លេមេគង្គ។ ខ្ពង់រាបនេះ បានគ្របដណ្តប់ទៅដោយល្បាប់ចាស់ និងប្រកបដោយព្រៃរបោះ ហើយគេសង្កេតឃើញមានកូនភ្នំជាច្រើនស្ថិតនៅជាប់គ្នារដឹកពីខេត្តក្រចេះ រហូតដល់ខេត្តស្ទឹងត្រែង។ កន្លែងខ្លះនៃខ្ពង់រាបនេះ ក៏បានគ្រប់ដណ្តប់ដោយសិលាបាសាល់ផងដែរ ដែលសព្វថ្ងៃបានពុកផុយក្លាយទៅជាដីក្រហម សម្រាប់ដំណាំកៅស៊ូទៅហើយដូចជា នៅត្រង់ស្រុកស្នួល និងសំបូរ ខេត្តក្រចេះ និងអូរពងមាន់ ក្នុងខេត្តស្ទឹងត្រែងជាដើម។

**២.២. ខ្ពង់រាបខេត្តកំពង់ចាម និងត្បូងឃ្មុំ**

ខ្ពង់រាបខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ជាខ្ពង់រាបមួយ ដែលមានផ្ទៃយ៉ាងទេរទៅទិសឦសាន ហើយមានរយៈកម្ពស់ ២០០ម៉ែត្រ។ នៅប៉ែកខាងនិរតី ខ្ពង់រាបនេះលាតសន្ធឹងមកទល់នឹងតំបន់ទំនាបកណ្តាលនៃប្រទេសកម្ពុជា។ ខ្ពង់រាបខេត្តកំពង់ចាម និងត្បូងឃ្មុំនេះមានផ្ទៃរាបស្មើដែលគ្របដណ្តប់ទៅដោយល្បាប់ចាស់ និងសិលាបាសាល់ ដែលមានស្រទាប់ខាងលើបានពុកផុយក្លាយទៅជាដីក្រហមទៅហើយ។ សព្វថ្ងៃនេះគេសង្កេតឃើញមានទួលសិលាបាសាល់ចំនួន ៤ កន្លែង ដែលបានក្លាយទៅជាចម្ការធំៗ ជាពិសេសចម្ការកៅស៊ូគឺ ចម្ការលើ មេមត់ ពាមជញ្ជាំង និងជប់។

**២.៣. ខ្ពង់រាបខេត្តរតនគីរី (ខ្ពង់រាបបរកែវ)**

ខ្ពង់រាបខេត្តរតនគីរី ឬខ្ពង់រាបបរកែវ ស្ថិតនៅបន្តពីខ្ពង់រាបកន្ទុំនៃប្រទេសវៀតណាម។ ខ្ពង់រាប នេះខណ្ឌប្រទេសកម្ពុជាពីប្រទេសឡាវផង និងពីប្រទេសវៀតណាមផង។ ខ្ពង់រាបនេះ ស្ថិតនៅចន្លោះជ្រលងទន្លេសេសាន ទន្លេស្រែពក និងប្រទេសវៀតណាម។ ខ្ពង់រាបខេត្តរតនគីរីនេះ មានលក្ខណៈជាទំនាបសិលាក្រែ និងខ្ពង់រាបសិលាបាសាល់ ដែលមានរយៈកម្ពស់ ៣០០ ម៉ែត្រ ហើយដែលគេនិយមហៅថា **ខ្ពង់រាបបរកែវ**។ ខ្ពង់រាបនេះជាកន្លែងភ្នំភ្លើងចាស់ ព្រោះនៅទីនេះមានកំអែភ្នំភ្លើង មានដីក្រហម មានផេះភ្នំភ្លើង ហើយនិងមានមាត់ភ្នំភ្លើង ដែលមាត់ភ្នំភ្លើងខ្លះបានក្លាយទៅជាបឹងទៅហើយដូចជា បឹងយក្សឡោម និងបឹងកុដ្ឋឡោមជាដើម។ នៅចំលើទ្រនុងកណ្តាលនៃខ្ពង់រាបនេះ គេសង្កេតឃើញមានកំពូលភ្នំខ្លះៗ ដែលរួមមានដូចជា ភ្នំពោងពាយមានកម្ពស់ ៨១៦ ម៉ែត្រ ភ្នំក្រងមានកម្ពស់ ៨១២ ម៉ែត្រ
និងភ្នំរាំងមានកម្ពស់ ៧០១ ម៉ែត្រ។

**២.៤. ខ្ពង់រាបខេត្តមណ្ឌលគីរី (ខ្ពង់រាបឆ្លូងលើ)**

ខ្ពង់រាបខេត្តមណ្ឌលគីរី ឬខ្ពង់រាបឆ្លូងលើ គឺស្ថិតនៅបន្តពីខ្ពង់រាបដាឡាត់នៃប្រទេសវៀតណាម។ ខ្ពង់រាបនេះមានវាលសិលាក្រែ ដែលងើបឡើងពីគែមនៃជ្រលងទន្លេមេគង្គឆ្ពោះទៅកាន់ខ្ពង់រាបឆ្លូងលើ ក្នុងខេត្តមណ្ឌលគីរី ដោយមានរយៈកម្ពស់ប្រហាក់ប្រហែលគ្នានឹងខ្ពង់រាបខេត្តរតនគីរីផងដែរ។ ខ្ពង់រាបនេះបាន

គ្រប់ដណ្តប់ទៅដោយសិលាបាសាល់ ដែលមួយភាគធំបានក្លាយទៅជាដីក្រហម។ ដោយសារតែឥទ្ធិពលនៃសំណឹក បានធ្វើឱ្យខ្ពង់រាបនេះមានផ្ទៃមិនសូវរាបស្មើនោះឡើយ គឺមានកំពូលរាងដូចដងធ្នូ ហើយស្ថិតនៅបន្តបន្ទាប់គ្នា។ ភ្នំដែលស្ថិតនៅលើខ្ពង់រាបនេះ មានតែភ្នំមួយប៉ុណ្ណោះដែលកំពូលខ្ពស់រហូតដល់ទៅ ១១០៣ ម៉ែត្រ គឺភ្នំព្រះបាទ ឬភ្នំណាមលៀ ដែលមានទីតាំងស្ថិតនៅជិតព្រំដែនប្រទេសវៀតណាម។




*ផែនទីតំបន់ខ្ពង់រាបខាងកើត និងខ្ពង់រាបឦសាន*

ខ្ពង់រាបនៅប្រទេសកម្ពុជាយើងភាគច្រើន គឺសុទ្ធសឹងតែគ្រប់ដណ្តប់ដោយព្រៃឈើ និងវាលស្មៅ ហើយខ្ពង់រាបខ្លះ គ្រប់ដណ្តប់ដោយដីក្រហមដែលមានសារៈសំខាន់ណាស់ សម្រាប់វិស័យកសិកម្មជាពិសេសដំណាំកៅស៊ូ និងវិស័យទេសចរណ៍។ លើសពីនេះទៀត ខ្ពង់រាបខ្លះមានកំណប់រ៉ែមានតម្លៃជាច្រើនប្រភេទ ពិសេសរ៉ែមាស និងរ៉ែត្បូងជាដើមដូចជា ខ្ពង់រាបរតនគីរី ឬខ្ពង់រាបបរកែវ ខ្ពង់រាបខាងជើង និងខ្ពង់រាបមណ្ឌលគីរី ឬខ្ពង់រាបឆ្លូងលើជាដើមដែលសុទ្ធតែបានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិយើង។

**៣. សារៈសំខាន់សេដ្ឋកិច្ចនៃតំបន់ខ្ពង់រាប**

ជាទូទៅ តំបន់ខ្ពង់រាបនៃប្រទេសកម្ពុជាយើង សុទ្ធសឹងតែផ្តល់សារៈសំខាន់ជាច្រើន សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងវិស័យកសិកម្ម វិស័យទេសចរណ៍ វិស័យថាមពល និងវិស័យឧស្សាហកម្ម។ ខ្ពង់រាបទាំងនេះ សម្បូរដោយព្រៃរបោះដែលសុទ្ធសឹងតែជាពូជឈើមានតម្លៃ សម្រាប់គ្រឿងសំណង់ ធ្វើតុ ធ្វើទូតាំង និងឧស្សាហកម្មដូចជា ត្រាច ខ្លុង ត្បែង ឈើទាល ធ្នឹក ធ្នង់ កកោះ ស្រឡៅ បេង នាងនួន គគីរ ក្រញូង...-ល-។ ក្រៅពីនេះ តំបន់ខ្ពង់រាបទាំងនេះ សម្បូរទៅដោយអនុផលព្រៃឈើ និងសត្វព្រៃជាច្រើនប្រភេទដូចជា រមាស ដំរី ខ្ទីង ខ្លាធំ ទន្សោង ប្រើស ក្តាន់ និងជ្រូកព្រៃជាដើម ដែលផ្តល់ដូចជាជ័រ វល្លិ៍ ផ្តៅ ឬស្សី ឃ្មុំ សាច់ ឆ្អឹង ស្បែក ស្នែង ភ្លុក សម្រាប់ទីផ្សារពិភពលោក។

ម្យ៉ាងទៀត ព្រៃឈើ និងសត្វព្រៃទាំងនេះក៏បានចូលរួមចំណែកក្នុងការទាក់ទាញភ្ញៀវទេសចរឱ្យចូលមកទស្សនាប្រទេសយើងផងដែរ ដែលផ្តល់នូវប្រាក់ចំណូលយ៉ាងច្រើន ក្នុងសេដ្ឋកិច្ចជាតិ និងព្រមទាំងបានចូលរួមចំណែកលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនយើងផងដែរ តាមរយៈការបម្រើសេវាកម្មទេសចរណ៍។ លើសពីនេះទៅទៀត តំបន់ខ្ពង់រាបប្រទេសយើង សម្បូរដោយកំណប់រ៉ែជាច្រើនប្រភេទដូចជា ត្បូងថ្ម ត្បូងលីញីត រ៉ែបុកស៊ីត រ៉ែមាស ត្បូងថ្ម និងរ៉ែអេលោហៈ និងរ៉ែលោហៈមានតម្លៃជាច្រើនទៀតដែលសុទ្ធតែបានចូលរួមចំណែកក្នុងការលើកកម្ពស់ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិយើងឱ្យរីកចម្រើនទៅមុខបាន។ ក្រៅពីនេះ តំបន់ខ្ពង់រាបនៅប្រទេសកម្ពុជាយើងភាគច្រើនសម្បូរទៅដោយប្រភពនៃផ្លូវទឹក ជាពិសេសទឹកជ្រោះសុទ្ធសឹងតែអនុវគ្រោះដល់ការស្ថាបនានូវទំនប់វារីអគ្គិសនី ដែលផ្តល់នូវថាមពលរាប់ពាន់គីឡូវ៉ាត់ សម្រាប់ប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម និងជីវភាពរស់នៅរបស់ប្រជាជនយើង។

**១.២.៣. សារៈសំខាន់សេដ្ឋកិច្ច នៃសណ្ឋានដីប្រទេសកម្ពុជា**

សណ្ឋានដីប្រទេសកម្ពុជាយើង បង្កនូវលក្ខខណ្ឌអនុគ្រោះយ៉ាងច្រើ ដល់ប្រទេសកម្ពុជាយើងទាំងសង្គម និងសេដ្ឋកិច្ចដូចជា ៖

- ប្រជុំភ្នំ និងខ្ពង់រាបទាំងអស់នៅប្រទេសកម្ពុជា មិនបង្កជាឧបសគ្គធំៗ ដល់ការធ្វើគមនាគមន៍នោះទេ ពោលគឺបង្កភាពងាយស្រួលក្នុងការធ្វើទំនាក់ទំនងគ្នារវាងតំបន់នីមួយៗ
- ជួរភ្នំក្រវាញនៅភាគនិរតី និងខ្ពង់រាបនៅភាគឦសានជាទិសដែលខ្យល់មូសុងបក់ឆ្លងកាត់ទឹកប្រទេសយើង។ ជួរភ្នំក្រវាញការពារមិនឱ្យខ្យល់ព្យុះបក់ឆ្លងកាត់មកតំបន់ទំនាបកណ្តាល និងរាំងឃាត់ទឹកភ្លៀង ដែលលើសពីតម្រូវការនៃកសិកម្ម ព្រមទាំងមិនបង្កឱ្យមានគ្រោះទឹកជំនន់ថែមទៀតផង។ តំបន់ខ្ពង់រាបឦសាន ជារបាំងការពារតំបន់ទំនាបកណ្តាលឱ្យគេចផុតពីគ្រោះមហន្តរាយ

ផ្សេងៗដែលបណ្ដាលមកពីខ្យល់ព្យុះ បោកបក់មកពីទិសខាងកើត ពិសេសបក់មកពីសមុទ្រចិនភាគខាងកើត។

- ប្រជុំភ្នំទាំងអស់នៃប្រទេសកម្ពុជាយើងសម្បូរព្រៃឈើណាស់ ព្រមទាំងជាជម្រករបស់សត្វព្រៃជាច្រើនប្រភេទថែមទៀតផង។ ប្រជុំភ្នំទាំងនេះ ជាឃ្លាំងស្ដុកទឹក សម្រាប់វិស័យកសិកម្ម និងជាប្រភពសម្រាប់ស្ថាបនាទំនប់វារីអគ្គិសនីផងដែរ។
- ប្រជុំភ្នំ និងតំបន់ខ្ពង់រាបទាំងអស់នៅប្រទេសកម្ពុជាយើង សុទ្ធសឹងតែសម្បូរទៅដោយកំណប់រ៉ែជាច្រើនដូចជា រ៉ែលោហៈមានតម្លៃ រ៉ែត្បូងមានតម្លៃ រ៉ែអលោហៈ និងឥន្ធនៈផូលស៊ីល ដែលអាចឱ្យប្រទេសយើងទាញកមកប្រើប្រាស់ សម្រាប់អភិវឌ្ឍប្រទេសជាតិយើងឱ្យរីកចម្រើន។
- តំបន់ខ្ពង់រាបទាំងអស់នៅប្រទេសយើង គឺសម្បូរទៅដោយវាលស្មៅ និងដីមានជីជាតិល្អដែលអាចឱ្យគេអភិវឌ្ឍវិស័យកសិកម្ម ពិសេសការចិញ្ចឹមសត្វ និងការដាំដំណាំចម្ការធំៗជាដើម។
- តំបន់ទំនាបកណ្ដាលនៅប្រទេសកម្ពុជាយើង គឺសុទ្ធសឹងជាទំនាបដែលមានដីសម្បូរជីជាតិល្អជាពិសេសដីល្បាប់ ដែលត្រូវបានហូរនាំមកចាក់បង្គរដោយខ្សែទឹកជារៀងរាល់ឆ្នាំ សម្បូរផ្លូវទឹក សម្បូរត្រី អាចឱ្យគេអភិវឌ្ឍវិស័យកសិកម្ម វិស័យទេសចរណ៍ វិស័យគមនាគមន៍ វិស័យឧស្សាហកម្ម និងវិស័យពាណិជ្ជកម្មបានយ៉ាងល្អប្រសើរ។
- លើពីនេះទៅទៀត តំបន់ទំនាបកណ្ដាលនៅប្រទេសកម្ពុជាយើង គឺជាអាងក្លាំមួយយ៉ាងធំ និងសម្បូរទៅដោយបឹងបួរជាច្រើន ពិសេសបឹងទន្លេសាប ដែលអាចស្រូបយកទឹកជំនន់នានាមកពីតំបន់ភ្នំ និងតំបន់ខ្ពង់រាប ជាពិសេសទឹកជំនន់ទន្លេមេគង្គបានមួយភាគធំ មិនបង្កឱ្យមានការលិចលង់ និងខូចខាតធ្ងន់ធ្ងរដល់តំបន់ទំនាបកណ្ដាលនោះឡើយ។

## សំណួរត្រិះរិះ

1. ចូរពិពណ៌នាពីទីតាំងភូមិសាស្ត្រនៃប្រទេសកម្ពុជា និងសារៈសំខាន់របស់វា។
2. តើសណ្ឋានដីនៃប្រទេសកម្ពុជាបច្ចុប្បន្នមានដំណើរវិវត្តន៍ដោយបានឆ្លងកាត់ប្រវត្តិនៃធរណីកាលយ៉ាងដូចម្ដេចខ្លះ?
3. យោងទៅតាមសណ្ឋានដី តើគេបែងចែកប្រទេសកម្ពុជាជាប៉ុន្មានតំបន់? អ្វីខ្លះ? ក្នុងចំណោមតំបន់ទាំងនេះ តើតំបន់ណាមួយមានប្រជាជនរស់នៅច្រើនជាងគេ? ហេតុអ្វី? ចូរពន្យល់។
4. តើគេចែកតំបន់មាត់សមុទ្រនៃប្រទេសកម្ពុជាប៉ុន្មានតំបន់ទៀត? អ្វីខ្លះ? ចូរពន្យល់។
5. តើគេចែកឆ្នេរសមុទ្រនៃប្រទេសកម្ពុជាជាប៉ុន្មានផ្នែក? អ្វីខ្លះ? ចូរពន្យល់។
6. តើគេចែកតំបន់ប្រជុំភ្នំនៅប្រទេសកម្ពុជាជាប៉ុន្មាន? អ្វីខ្លះ? ចូរពន្យល់។
7. តើអ្វីខ្លះជាតំបន់ខ្ពង់រាបនៅប្រទេសកម្ពុជា? ចូរពិពណ៌នាពីសារៈសំខាន់នៃតំបន់ខ្ពង់រាបនេះ។
8. ចូរពិពណ៌នាអំពីសារៈសំខាន់នៃសណ្ឋានដីប្រទេសកម្ពុជា។

## ២. ប្រព័ន្ធផ្លូវទឹកនៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាយើងសម្បូរផ្លូវទឹកណាស់ ដោយសារប្រទេសយើងមានសណ្ឋានដីរាងជាបាតខ្ទះ ដែលព័ទ្ធជុំវិញដោយជួរភ្នំ កូនភ្នំ និងខ្ពង់រាប ជាហេតុធ្វើឱ្យប្រទេសយើងសម្បូរផ្លូវទឹក។ គេឃើញមានផ្លូវទឹកតូចធំខ្វាត់ខ្វែងជាច្រើន នៅស្ទើរពាសពេញផ្ទៃប្រទេសយើង។ ផ្លូវទឹកទាំងនេះមាន ទន្លេធំៗ មានបឹងបួរតូចធំ មានព្រែក មានស្ទឹង និងជ្រោះគ្រប់ទីកន្លែង។

*ផែនទីបណ្តាញផ្លូវទឹកនៅប្រទេសកម្ពុជា*




នៅប្រទេសកម្ពុជាមានទន្លេដ៏ធំមួយ ហូរកាត់ពីជើងទៅត្បូង គឺទន្លេមេគង្គ។ នៅត្រង់រាជធានីភ្នំពេញ នៅខាងមុខព្រះបរមរាជវាំង ទន្លេដ៏ធំនេះបានបែកខ្វែកជាបួន ដែលគេនិយមហៅថា ទន្លេបួនមុខ ឬទន្លេចតុមុខ។ ទន្លេទាំងបួននេះរួមមាន ទន្លេមេគង្គលើ ឬទន្លេធំ ដែលហូរកាត់ប្រទេសកម្ពុជាពីព្រំដែនឡាវហូតមកដល់រាជធានីភ្នំពេញ ទន្លេមេគង្គក្រោម ឬទន្លេក្រៅ ដែលហូរពីរាជធានីភ្នំពេញទៅដល់ព្រំដែនប្រទេសវៀតណាមភាគខាងត្បូង ត្រង់ក្អមសំណរ ខេត្តកណ្តាល ដោយកាត់តាមអ្នកលឿង ទន្លេបាសាក់ ឬទន្លេក្នុង ដែលហូរស្របនឹងទន្លេមេគង្គក្រោមដែរ សំដៅទៅប្រទេសវៀតណាម ដោយកាត់តាមក្រុងតាខ្មៅ និងទន្លេសាបដែលហូរពីរាជធានីភ្នំពេញទៅភ្ជាប់នឹងបឹងទន្លេសាប ដោយកាត់តាមក្រុងកំពង់ឆ្នាំង។ នៅភាគ

៣យ័ព្យនៃប្រទេសមានអាងក្លាំមួយយ៉ាងធំដែលប្រៀបបានទៅនឹងកូនសមុទ្រ មួយ គឺបឹងទន្លេសាប។ រីឯនៅភាគនិរតីនៃប្រទេសវិញ គឺមានឆ្នេរសមុទ្រ គឺឈូងសមុទ្រថៃ ព្រមទាំងមានស្ទឹង និងព្រែកមួយចំនួន ដែលហូរធ្លាក់ចុះមកពីជួរភ្នំក្រវាញចាក់ចូលទៅក្នុងឈូងសមុទ្រនេះ។

លើសពីនេះទៀត ទាំងទន្លេមេគង្គ ទាំងទន្លេសាប និងទាំងទន្លេបាសាក់ គឺសុទ្ធសឹងតែមានដៃរបស់វាជាច្រើនដែលហូរចុះមកពីតំបន់ទីខ្ពស់ដូចជា ខ្ពង់រាបខាងជើង ខ្ពង់រាបខាងកើត ខ្ពង់រាបឦសាន ជួរភ្នំដងរែក និងជួរភ្នំក្រវាញ និងបានហូរខ្វាត់ខ្វែងស្ទើរតែពាសពេញផ្ទៃប្រទេសរបស់យើង ប្រៀបបានទៅនឹងសរសៃឈាម នៅក្នុងខ្លួនមនុស្ស។

ដូចនេះ ប្រទេសកម្ពុជាយើង ជាប្រទេសមួយដែលសម្បូរទៅដោយបណ្តាញផ្លូវទឹកគ្រប់ទិសទី ងាយស្រួលក្នុងការរស់នៅ ក្នុងកិច្ចការធ្វើស្រែចម្ការ និងធ្វើគមនាគមន៍។

ជាទូទៅ គេចែកបណ្តាញផ្លូវទឹកនៅប្រទេសកម្ពុជាយើងជា ៣ ក្រុមធំៗ ដែលរួមមានដូចជា ប្រព័ន្ធទន្លេមេគង្គ ប្រព័ន្ធទន្លេសាប និងប្រព័ន្ធផ្លូវទឹកនៅតាមមាត់សមុទ្រ។

## ២.១. ប្រព័ន្ធទន្លេមេគង្គ

នៅក្នុងមេរៀននេះ យើងនឹងបែងចែកទន្លេមេគង្គជា ២ ប្រព័ន្ធ គឺប្រព័ន្ធទន្លេមេគង្គអន្តរជាតិ និងប្រព័ន្ធទន្លេមេគង្គកម្ពុជា។

### ក. ទន្លេមេគង្គអន្តរជាតិ

ទន្លេមេគង្គ គឺជាទន្លេដ៏ធំមួយ ក្នុងចំណោមទន្លេធំៗទាំងឡាយនៅលើពិភពលោក។ ទន្លេនេះ ជាប់ចំណាត់ថ្នាក់លេខ ៤ ក្នុងចំណោមទន្លេធំៗនៅទ្វីបអាស៊ី( ទន្លេយ៉ាងសេ ៦ ៣០១ គ.ម ទន្លេលឿង ៥ ៤៦៤ គ.ម និងទន្លេយេនីស៊ី ៥ ៥៣៩ គ.ម)។ ទន្លេមេគង្គមានប្រភពនៅលើខ្ពង់រាបទីបេប៉ែកខាងកើតប្រទេសចិន ដោយស្ថិតនៅលើរយៈកម្ពស់ ៥ ០០០ ម៉ែត្រ ហើយហូរកាត់ប្រទេសចំនួន ៦ នៅទ្វីបអាស៊ីគឺ ប្រទេសចិន ប្រទេសភូមា ប្រទេសឡាវ ប្រទេសថៃ ប្រទេសកម្ពុជា និងប្រទេសវៀតណាម រួចហូរចាក់ចូលទៅក្នុងសមុទ្រចិនភាគខាងត្បូងវិញ ដោយមានប្រវែង ៤ ២០០ គ.ម។ ទន្លេមេគង្គមាន ផ្ទៃអាងទំហំ ៨០០ ០០០ គ.ម$^{២}$ ក៏ប៉ុន្តែទន្លេដ៏វែងនេះ អាចឱ្យនាវាគ្រប់ប្រភេទធ្វើចរាចរបានត្រឹមតែ ចំងាយ ៥១០ គ.ម ប៉ុណ្ណោះពីសមុទ្រ។

ទន្លេមេគង្គអន្តរជាតិចែកចេញជា ៣ ផ្នែក គឺ ៖

- **ដងទន្លេខាងលើ** ៖ ចាប់ពីប្រភពដើមមកដល់ទីក្រុងវៀងច័ន្ទ (ប្រទេសឡាវ)។ នៅត្រង់នេះទន្លេមេគង្គមានរាងបត់បែនយ៉ាងខ្លាំង ដោយសារតែសណ្ឋានដីនៅទីនោះ សម្បូរទៅដោយជួរភ្នំខ្ពស់ៗ ហើយបានទទួលទឹកពីដៃទាំងឡាយរបស់វា ដែលស្ថិតនៅត្រើយខាងឆ្វេង ឬត្រើយខាងកើត ដែលសុទ្ធសឹងតែជាជ្រោះជ្រៅៗ។
- **ដងទន្លេកណ្តាល** ៖ ចាប់ពីវៀងច័ន្ទ ប្រទេសឡាវដល់ខេត្តក្រចេះ ប្រទេសកម្ពុជា។ នៅត្រង់នេះទន្លេមេគង្គសម្បូរដោយទឹកជ្រោះជាច្រើនអន្លើដូចជា នៅសាវ៉ាន់ណាខេត្ត និងនៅចំប៉ាសាក់ប្រទេសឡាវ នៅខោន (១២ គម) ខេត្តស្ទឹងត្រែង ព្រំប្រទល់ប្រទេសឡាវ និងកម្ពុជា និងនៅស្រុកសំបូរ (៥០ គម) ខេត្តក្រចេះជាដើម។ នៅត្រង់នេះដែរ ទន្លេមេគង្គបានទទួលទឹកមកពីដៃទាំងឡាយរបស់វាដែលស្ថិតនៅត្រើយខាងឆ្វេង ឬត្រើយខាងកើត ដែលជាទន្លេ ស្ទឹង ព្រែក អូរ និងជ្រោះ

- **ដងទន្លេខាងក្រោម** ៖ ចាប់ពីខេត្តក្រចេះរហូតដល់សមុទ្រចិនខាងត្បូង។ នៅត្រង់នេះ ពេលគឺ ចាប់ពីខេត្តក្រចេះរហូតដល់សមុទ្រចិនខាងត្បូង ទន្លេមេគង្គអាចឱ្យនាវាធ្វើចរាចរបាន នៅគ្រប់រដូវ ទាំងរដូវប្រាំង និងរដូវវស្សាក្នុងចម្ងាយ ៥១០ គ.ម។ នៅរាជធានីភ្នំពេញ ទន្លេមេគង្គប្រសព្វគ្នា ជាមួយនិងទន្លេសាបបង្កើតជាដងទន្លេបួន ស្របទៅតាមពាក្យខ្មែរថា "ទន្លេបួនមុខ" គឺទន្លេបាសាក់ (ទន្លេក្នុង) ទន្លេមេគង្គលើ ទន្លេមេគង្គក្រោម (ទន្លេក្រៅ) និងទន្លេសាប។ នៅក្បែរនឹងមាត់សមុទ្រ ទន្លេមេគង្គបានបង្កើតជាដីសណ្តជាច្រើនកន្លែង ព្រមទាំងបានចែកចេញជាដៃច្រើនទៀត ដែលមានទទឹងប្រវែងរហូតដល់ទៅ ២ គ.ម និងប្រកបទៅដោយកូនកោះជាច្រើន ឬគំនរខ្សាច់យ៉ាងវែងៗដែលសណ្តូកទៅរកមាត់សមុទ្រ។

*ផែនទីទន្លេមេគង្គអន្តរជាតិ និងដៃរបស់វា*




## ខ. ប្រព័ន្ធទន្លេមេគង្គកម្ពុជា

ផ្លូវទឹកទាំងឡាយដែលត្រូវបានគេចាត់ទុកថាជាប្រព័ន្ធទន្លេមេគង្គរួមមាន តួទន្លេមេគង្គ (ទន្លេមេគង្គលើ និងទន្លេមេគង្គក្រោម) ទន្លេបាសាក់ ទន្លេតូច និងដៃនានារបស់ទន្លេទាំងនោះ។

### ១. ទន្លេមេគង្គ

ទន្លេមេគង្គកម្ពុជា ឬទន្លេធំហូរកាត់ប្រទេសកម្ពុជាពីព្រំដែនឡាវ (ត្រង់ល្បាក់ខោន) រហូតដល់ ព្រំប្រទល់ប្រទេសវៀតណាម មានប្រវែង ៥០០ គ.ម។ ទន្លេនេះ ហូរកាត់ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តកំពង់ចាម

ខេត្តត្បូងឃ្មុំ ខេត្តកណ្តាល និងខេត្តព្រៃវែង រួចហូរចាក់ចូលទៅក្នុងប្រទេសវៀតណាមត្រង់ក្អមសំណរ ខេត្តកណ្តាល។

### ១.១. របបទឹកទន្លេមេគង្គ

នៅរដូវវស្សា ទន្លេមេគង្គមានជារទឹកសរុប ៣៤ ០០០ ម$^៣$ ក្នុងមួយវិនាទី គឺស្មើនឹង ២០ នៃជារទឹករបស់វានៅរដូវប្រាំង។ ទន្លេមេគង្គកម្ពុជា មានរបបទឹកទៀងទាត់ខ្លាំងណាស់។ របបទឹកនេះជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងអាកាសធាតុមូសុង។

- **នៅរដូវវស្សា ៖** នៅរដូវវស្សា គឺជារដូវទឹកឡើង។ រដូវទឹកឡើងនេះ គឺចាប់ផ្តើមពីខែមិថុនាដល់ខែតុលា។ នៅរដូវនេះ ទឹកដែលបានមកពីការរលាយទឹកកកនៅខ្ពង់រាបទីបេ និងពីទឹកភ្លៀងនៅតាមដៃនានារបស់វា បានហូរចាក់ចូលមកក្នុងតួទន្លេមេគង្គ ដោយល្បឿនយ៉ាងលឿន ហើយបង្កើតឱ្យមានទឹកឡើង ដែលហៅថា រដូវទឹកតំឡើង។ នៅរដូវទឹកឡើងនេះ នៅតាមទីកន្លែងខ្លះកម្ពស់ទឹកទន្លេមេគង្គអាចឡើងដល់កម្ពស់ ៣០ ម៉ែត្រ ពិសេសនៅត្រង់ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ។ ទឹកជំនន់ដ៏អស្ចារ្យនេះ មិនត្រឹមតែបានផ្តល់ទឹកឱ្យពោរពេញក្នុងអាងទន្លេមេគង្គប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចាល់ចូលទៅក្នុងបឹងទន្លេសាបទៀតផង។ ទឹកជំនន់នេះ ដំបូងគឺបានចាប់ផ្តើមនៅក្នុងប្រទេសឡាវ នៅក្នុងខែកក្កដា រួចហើយបានហូរចុះមកផ្នែកខាងក្រោមជាលំដាប់ ហើយទឹកជំនន់ជាអតិបរមារមាននៅត្រង់រាជធានីភ្នំពេញ នៅក្នុងដំណាច់ខែកញ្ញា ដែលកម្ពស់ទឹកឡើងដល់ចាប់ពី ៧ ទៅ ៩ ម៉ែត្រ។ បឹង និងកំហូងទាំងឡាយ ដែលស្ថិតនៅអមសងខាងទន្លេមេគង្គ ចាប់ពីខេត្តក្រចេះរហូតដល់ក្អមសំណរ ខេត្តព្រៃវែងមានមុខងារធ្វើឱ្យរបបទឹកទន្លេមេគង្គមានភាពទៀងទាត់។ ទឹកឡើង ឬស្រកនៃបឹងទាំងនេះបានកើតមានឡើងនៅក្រោយទឹកភ្លៀង ឬទឹកស្រកនៃទន្លេជានិច្ច ព្រោះបឹងទាំងនេះជាប់ទាក់ទងជាមួយនឹងទន្លេដោយសារព្រែក។ នៅរដូវទឹកស្រកព្រែកច្រើនតែរីងស្ងួត រីឯបឹងវិញនៅមានសេសសល់ទឹកខ្លះជាអប្បរមា។
- **នៅរដូវប្រាំង ៖** នៅរដូវប្រាំង គឺជារដូវទឹកស្រក។ រដូវទឹកសម្រកនេះ គឺបានចាប់ផ្តើមឡើងពីខែវិច្ឆិកាដល់ខែឧសភា ដែលគេហៅថាជា រដូវទឹកសម្រក។ ការស្រកនៃទឹកទន្លេមេគង្គនេះ គឺ បណ្តាលមកពីទឹកកកនៅលើខ្ពង់រាបទីបេ ប្រទេសចិនឈប់រលាយ និងចាប់ផ្តើមកកឡើងវិញ រួមជាមួយនិងមូសុងវស្សាឈប់ភ្លៀង ហើយក៏ក្លាយទៅជាមូសុងប្រាំងវិញផងដែរ។ នៅរដូវទឹក សម្រកនេះ ទឹកទន្លេមេគង្គ និងទន្លេដទៃទៀតរបស់វា បានហូរមកប្រសព្វគ្នានៅត្រង់ទន្លេបួនមុខ រួចហើយបានហូរចុះទៅតាមទន្លេក្រៅ ឬទន្លេមេគង្គក្រោម និងទន្លេក្នុង ឬទន្លេបាសាក់សំដៅទៅសមុទ្រចិនភាគខាងត្បូង ដោយឆ្លងកាត់ប្រទេសវៀតណាម។

### *ផែនទីប្រព័ន្ធទន្លេមេគង្គ និងប្រព័ន្ធទន្លេសាបនៅប្រទេសកម្ពុជា*




## ១.២. ដៃទន្លេមេគង្គ

ទន្លេមេគង្គកម្ពុជាហូរកាត់ប្រទេសកម្ពុជា ក្នុងប្រវែងសរុប ៥០០ គ.ម ចាប់ពីល្បាក់ខោន ព្រំប្រទល់ប្រទេសឡាវហូតដល់ព្រំប្រទល់ប្រទេសវៀតណាម ត្រង់ក្អមសំណរ ក្នុងខេត្តកណ្ដាល។ ចាប់ពីល្បាក់ខោន ព្រំប្រទល់ប្រទេសឡាវហូតដល់រាជធានីភ្នំពេញ គេសង្កេតឃើញទន្លេមេគង្គមានដៃជាច្រើន ហើយដៃរបស់វាភាគច្រើនបំផុត គឺសុទ្ធសឹងតែនៅត្រើយខាងឆ្វេង ឬត្រើយខាងកើត ដោយសារតែនៅត្រើយខាងកើត គឺជាតំបន់ខ្ពង់រាប និងជួរភ្នំ។ ដៃសំខាន់ៗរបស់ទន្លេមេគង្គទាំងនៅត្រើយខាងស្តាំ ឬត្រើយខាងលិច និងនៅត្រើយខាងឆ្វេង ឬត្រើយខាងកើតរួមមាន ៖

- **ដៃនៅត្រើយខាងស្តាំ** ៖ នៅត្រើយខាងស្តាំ ឬនៅត្រើយខាងលិច គេឃើញទន្លេមេគង្គមានដៃសំខាន់តែមួយគត់ ដែលមានប្រភពនៅលើខ្ពង់រាបកូរ៉ាត់ ភាគឦសានប្រទេសថៃ។ ដៃមួយនេះគឺ ៖
  - ទន្លេរពៅ ៖ ទន្លេនេះ មានទីតាំងស្ថិតនៅតាមព្រំប្រទល់ប្រទេសឡាវ និងប្រទេសកម្ពុជា ដែលជាព្រំដែនធម្មជាតិរួមរវាងប្រទេសឡាវ និងប្រទេសកម្ពុជា។
- **ដៃនៅត្រើយខាងឆ្វេង** ៖ នៅត្រើយខាងឆ្វេង ឬនៅត្រើយខាងកើត គេសង្កេតឃើញទន្លេមេគង្គមានដៃសំខាន់ៗជាច្រើន ហើយដៃសំខាន់ៗទាំងនេះរួមមាន ៖
  - ទន្លេកុង និងដៃទាំងពីររបស់វា គឺទន្លេសេសាន និងទន្លេស្រែពក ៖
    - ទន្លេសេកុង ៖ មានប្រភពនៅលើខ្ពង់រាបបូឡូវ៉ែន ក្នុងខេត្តចំប៉ាសាក់ និងខេត្តសេកុង ប្រទេសឡាវ
    - ទន្លេសេសាន ៖ មានប្រភពនៅខ្ពង់រាបកន្ទុំ ក្នុងខេត្តកន្ទុំ ប្រទេសវៀតណាម
    - ទន្លេស្រែពក ៖ មានប្រភពនៅខ្ពង់រាបដាឡាក់ ក្នុងខេត្តដាក់ឡាក់ ប្រទេសវៀតណាម។
  - ព្រែកក្រៀង ៖ មានប្រភពនៅខ្ពង់រាបខាងកើត និងជាស្ទឹងដែលរីងស្ងួតនៅរដូវប្រាំង

- ព្រែកកាំពី ៖ ជាស្ទឹងដែលរីងស្ងួតនៅរដូវប្រាំង ព្រោះហូរមកពីតំបន់ខ្ពង់រាបខាងកើត។
- ព្រែកទេរ ៖ មានប្រភពនៅលើខ្ពង់រាបឆ្លូងលើ ក្នុងខេត្តមណ្ឌលគីរី។ ព្រែកនេះមានរបបទឹកមិនទៀងទាត់នោះទេ តែចរន្តទឹកហូរលឿននៅរដូវទឹកឡើង ឬនៅរដូវវស្សា
- ព្រែកឆ្លូង ៖ មានប្រភពនៅលើខ្ពង់រាបឆ្លូងលើក្នុងខេត្តមណ្ឌលគីរី គឺស្ទឹងមួយយ៉ាងប្រណីតព្រោះហូរកាត់ព្រៃស្ពុក។

**២. ទន្លេបាសាក់**

ទន្លេបាសាក់ ជាទន្លេដែលបន្តពីទន្លេបួនមុខ រួចហូរចាក់ចូលទៅក្នុងប្រទេសវៀតណាម តាមទិសស្របជាមួយនឹងទន្លេមេគង្គក្រោមដែរ។ របបទឹកទន្លេបាសាក់ គឺមានភាពទៀងទាត់ណាស់ ព្រោះ ទន្លេនេះមានទំនាក់ទំនងជាមួយនឹងរបបទឹកទន្លេមេគង្គដែរ។ ទន្លេបាសាក់មានប្រវែង ១០០គ.ម ចាប់ពីរាជធានីភ្នំពេញរហូតដល់ប្រទេសវៀតណាមនៅត្រង់ជ្រៃធំ ស្រុកកោះធំ ខេត្តកណ្ដាល ដោយហូរកាត់ក្រុងតាខ្មៅនៃខេត្តកណ្ដាល។ ដៃសំខាន់ៗនៃទន្លេនេះរួមមាន ៖

- ស្ទឹង**ព្រែក**ត្នោត ៖ មានប្រភពនៅប្រជុំភ្នំអូរម្លូ ក្នុងជួរភ្នំក្រវាញខាងកើត ហើយហូរកាត់ខេត្តកំពង់ស្ពឺ និងក្រុងតាខ្មៅ។
- ស្ទឹង**តាកែវ** ៖ ជាស្ទឹងដែលមានប្រភពនៅតំបន់កូនភ្នំ និងហូរមកប្រសព្វគ្នាជាមួយនឹងទន្លេបាសាក់នៅត្រង់មាត់ជ្រូក ប្រទេសវៀតណាម។

**៣. ទន្លេមេគង្គតូច**

ទន្លេតូច គឺជាកូនទន្លេដ៏តូចមួយ ដែលហូរបែកចេញពីទន្លេមេគង្គលើនៅត្រង់ពាមជីកង ស្រុកកោះសុទិន ខេត្តកំពង់ចាម និងមកតភ្ជាប់ជាមួយនឹងទន្លមេគង្គក្រោមវិញនៅត្រង់ពាមប្រធ្នស់ ស្រុកពាមរក៍ ខេត្តព្រៃវែង ដែលមានប្រវែង ១០០ គ.ម។ នៅត្រង់ពាមប្រធ្នស់ ស្រុកពាមរក៍ ខេត្តព្រៃវែងនេះ ទន្លេតូចបានបែកចេញជា ២ ផ្នែកទៀត គឺទន្លេតូចដែលហូរស្របនឹងទន្លេមេគង្គ និងព្រែកកំពង់ត្របែក ដែលហូរចាក់ទៅក្នុងប្រទេសវៀតណាមនៅត្រង់ទំនាបវាលភក់។

## គ. សារៈសំខាន់សេដ្ឋកិច្ចប្រព័ន្ធទន្លេមេគង្គ

ប្រព័ន្ធទន្លេមេគង្គកម្ពុជាផ្ដល់ នូវសារៈសំខាន់ជាច្រើនដល់សង្គមកម្ពុជា។ ប្រទេសកម្ពុជាយើងបានសម្បូរសប្បាយហូរហៀរ គឺដោយសារតែភោគទ្រព្យធម្មជាតិដែលផ្ដល់ឱ្យដោយប្រព័ន្ធទន្លេមេគង្គ។ នៅរដូវទឹកជំឡើង ប្រព័ន្ធទន្លេមេគង្គកម្ពុជាផ្ដល់នូវដីល្បាប់ម៉ដ្ឋដ៏មានជីជាតិបំផុតនៅភូមិភាគល្បាប់ម៉ដ្ឋនៅតាមច្រាំងទន្លេ ជាយកោះ មាត់ព្រែក មាត់ស្ទឹង និងភូមិភាគលិចទឹកនានា សម្រាប់ការងារកសិកម្ម ពិសេសដំណាំស្រូវ និងដំណាំចម្ការផ្សេងៗទៀត។

ប្រព័ន្ធទន្លេមេគង្គក៏ជាផ្លូវទឹក សម្រាប់នាវាធ្វើចរាចរបាននៅគ្រប់រដូវផងដែរ ចាប់ពីខេត្តក្រចេះរហូតដល់សមុទ្រចិនភាគខាងត្បូង។ ប៉ុន្តែនៅរដូវប្រាំង កប៉ាល់សមុទ្រធុនមធ្យមចូលបានត្រឹមតែទីក្រុងភ្នំពេញប៉ុណ្ណោះ។ ចំពោះទន្លេតូច និងទន្លេបាសាក់វិញ នាវាចរណ៍អាចប្រព្រឹត្តទៅបានស្រួលនៅតែរដូវទឹកជំឡើងប៉ុណ្ណោះ។

ប្រព័ន្ធទន្លេមេគង្គគឺជាឡូត៍នេសាទមួយយ៉ាងសំខាន់នៅរដូវទឹកសម្រក ពីព្រោះបឹងទាំងឡាយ ដែលភ្ជាប់មកទន្លេមេគង្គ ដោយសារព្រែកនានា គឺជាទីដ៏ល្អប្រសើរ សម្រាប់ការលូតលាស់ និងកំណើនមច្ឆជាតិ។ នៅពេលដែលទឹកស្រកទៅវិញ ពពួកមច្ឆជាតិទាំងនោះតែងតែមកផ្តុំគ្នានៅតាមព្រែក តាមបឹង និងពោះទន្លេ។

ប្រព័ន្ធទន្លេមេគង្គ គឺជាបណ្តាញផ្លូវទឹក សម្រាប់បាចបញ្ចូលស្រែចម្ការនៅពេលណាដែលមានភាពរាំងស្ងួតបានកើតមានឡើងនៅរដូវប្រាំង។

ក្រៅពីនេះ ប្រព័ន្ធទន្លេមេគង្គអាចផ្តល់លទ្ធភាពច្រើន សម្រាប់ការសាងសង់ទំនប់វារីអគ្គិសនី។ តាមការសិក្សាស្រាវជ្រាវរបស់អ្នកបច្ចេកទេសបានបង្ហាញថា ទំនប់វារីអគ្គិសនីនៅសំបូរ ក្នុងខេត្តក្រចេះ អាចផ្តល់ថាមពលអគ្គិសនីចាប់ពី ២ ១៤០ លានគីឡូវ៉ាត់ម៉ោងក្នុងមួយឆ្នាំ ហើយអាចផ្តល់ទឹក សម្រាប់បញ្ចូលស្រែបានពី ១០០ ០០០ ទៅ ២០០ ០០០ ហិចតាទៀត។ ទំនប់អគ្គិសនីនៅល្បាក់ខោន ក្នុងខេត្តស្ទឹងត្រែងមានកម្លាំងប្រហែល ២ លានគីឡូ វ៉ាត់ម៉ោង។ លើសពីនេះទៅទៀត ដៃទន្លេមេគង្គដូចជា ទន្លេសេសាន និងទន្លេស្រែពកត្រូវបានរាជរដ្ឋាភិបាលរៀបចំគម្រោងអភិវឌ្ឍទំនប់វារីអគ្គិសនីនៅលើដងទន្លេទាំងនេះ ដែលអាចផ្តល់ថាមពលអគ្គិសនីរាប់រយគីឡូវ៉ាត់ម៉ោង សម្រាប់ប្រើប្រាស់នៅក្នុងប្រទេស។ ម្យ៉ាងទៀត ដៃទន្លេបាសាក់ជាពិសេសស្ទឹងព្រែកត្នោត ក្រៅពីគមនាគមន៍ ស្ទឹងនេះត្រូវបានគេសង់ទំនប់វារីអគ្គិសនីរួចរាល់ហើយ ប៉ុន្តែត្រូវបានខូចខាតទៅវិញ ដោយសារតែសង្គ្រាម អាចបង្វិលឌីណាម៉ូកម្លាំង ១៥ ០០០ គីឡូវ៉ាត់ ហើយផ្តល់ទឹកបញ្ចូលស្រែបានពី ៧០ ០០០ ទៅ ៩០ ០០០ ហិចតា។

លើសពីនេះទៅទៀត ប្រព័ន្ធទន្លេមេគង្គកម្ពុជាក៏ផ្តល់សារៈប្រយោជន៍ជាច្រើនសម្រាប់វិស័យទេសចរណ៍ផងដែរ ពីព្រោះប្រព័ន្ធទន្លេនេះសម្បូរដោយព្រៃលិចទឹក សម្បូរដោយជីវៈចម្រុះដ៏សម្បូរបែប ជាពិសេស មានត្រីផ្សោត ដែលជាថនិកសត្វដ៏កម្រនៅលើពិភពលោក សម្រាប់ទាក់ទាញអ្នកទេសចរ។

## ២.២. ប្រព័ន្ធទន្លេទន្លេសាប

ផ្លូវទឹកទាំងឡាយ ដែលត្រូវបានគេរាប់បញ្ចូលទៅក្នុងប្រពន័ន្ធទន្លេសាបរួមមាន ទន្លេសាប បឹងទន្លេសាប និងដៃរបស់វាទាំងឡាយរបស់វា។ ប្រព័ន្ធទន្លេសាប ជាបណ្តាញទឹកដែលមានលក្ខណៈប្លែក គេដោយសារតែវាទទួលទឹកពីទំនាមកណ្តាលផង និងទឹកជំនន់ពីទន្លេមេគង្គផង។

### ក. ទន្លេសាប

ទន្លេសាប គឺជាទន្លេមួយដែលបន្តពីទន្លេចតុមុខសំដៅទៅតភ្ជាប់នឹងបឹងទន្លេសាប ដោយកាត់តាមព្រែកក្តាម និងក្រុងកំពង់ឆ្នាំង។ ទន្លេនេះ ស្ថិតនៅចន្លោះទន្លេបួនមុខ ត្រង់មុខព្រះបរមរាជវាំង និងខេត្តកំពង់ឆ្នាំង ដែលមានប្រវែង ១០០ គ.ម។

### ១. របបទឹកទន្លេសាប

របបទឹកទន្លេសាប ដូចគ្នានឹងរបបទឹកទន្លេមេគង្គដែរ ដោយសារទន្លេនេះ មានទំនាក់ទំនងជាមួយនឹងទន្លេមេគង្គ។ នៅរដូវវស្សា គឺជារដូវទឹកឡើង រីឯនៅរដូវប្រាំងវិញ គឺជារដូវទឹកសម្រក។ នៅរដូវទឹកជំឡើង ទឹកទន្លេសាបចាប់ផ្តើមឡើងពីខែមិថុនា រហូតដល់ខែតុលា។ នៅរដូវនេះ ទឹកទន្លេសាបបានហូរពីត្បូងទៅជើង គឺហូរចេញពីទន្លេបួនមុខនៅភ្នំពេញសំដៅទៅចាក់បំពេញបឹងទន្លេសាប ដោយកាត់តាមខេត្តកំពង់ឆ្នាំង។ នៅរដូវទឹកស្រក ទឹកទន្លេសាបបានចាប់ផ្តើមស្រកទៅវិញពីខែវិច្ឆិកា រហូតដល់ខែឧសភា ហើយនៅរដូវនេះ

ទឹកទន្លេសាបបានហូរត្រឡប់ពីជើងមកត្បូងវិញ ដោយបានហូរចេញពីបឹងទន្លេសាបចូលទៅក្នុងទន្លេសាប ហូរកាត់តាមខេត្តកំពង់ឆ្នាំង សំដៅមកទន្លេបួនមុខវិញនៅត្រង់រាជធានីភ្នំពេញ។ នៅទន្លេបួនមុខ ត្រង់រាជធានីភ្នំពេញនេះ ទឹកទន្លេសាបបានហូរមកប្រសព្វគ្នាជាមួយនឹងទន្លេមេគង្គលើ រួចហើយហូរចុះសំដៅទៅសមុទ្រចិនភាគខាងត្បូង តាមទន្លេមេគង្គក្រោម ឬទន្លេក្រៅ និងទន្លេបាសាក់ ឬទន្លេក្នុង។ ចរន្តទឹកម្តងហូរពីត្បូងទៅជើង និងម្តងហូរពីជើងទៅត្បូងវិញបែបនេះ គឺជាបាតុភូតដ៏ចម្លែកមួយ ដែលបានកើតមាននៅក្នុងទន្លេសាប ហើយដែលមានលក្ខណៈខុសប្លែកពីផ្លូវទឹកផ្សេងៗទៀតនៅលើពិភពលោក។

### ២. ដៃទន្លេសាប

ទន្លេសាបក៏មិនខុសគ្នាពីទន្លេមេគង្គ និងទន្លេបាសាក់នោះដែរ គឺសុទ្ធសឹងតែមានដៃ។ ជារួមទន្លេមេគង្គ គេឃើញមានដៃភាគច្រើនបំផុតនៅតែត្រើយខាងកើត ឬនៅត្រើយខាងស្តាំប៉ុណ្ណោះ ក៏ប៉ុន្តែដោយឡែក ទន្លេសាបវិញ គេឃើញមានដៃស្ទើរតែស្មើគ្នា ទាំងនៅត្រើយខាងកើត ឬនៅត្រើយខាងឆ្វេង និងនៅត្រើយខាងលិច ឬនៅត្រើយខាងស្តាំ។ ដៃទន្លេសាបសំខាន់ៗ រួមទាំងនៅត្រើយខាងកើត ឬនៅត្រើយខាងឆ្វេង និងនៅត្រើយខាងលិច ឬនៅត្រើយខាងស្តាំទាំងនោះរួមមាន ៖

- **ដៃនៅត្រើយខាងកើត ឬនៅត្រើយខាងឆ្វេង** ៖ ដៃនៅត្រើយខាងកើត ឬនៅត្រើយខាងឆ្វេងទាំងអស់ គឺសុទ្ធសឹងតែមានប្រភពនៅលើខ្ពង់រាបចម្ការលើ រួចបានហូរធ្លាក់ចុះមកសំដៅចាក់ចូលទៅក្នុងទន្លេសាប។ ដៃទាំងនេះរួមមាន៖
  - ស្ទឹងខ្យា
  - ស្ទឹងជីនិត
  - ស្ទឹងតាំងក្រសាំង
  - និងស្ទឹងស្លាប។
- **ដៃនៅត្រើយខាងលិច ឬនៅត្រើយខាងស្តាំ ៖** ដៃទាំងនេះ គឺសុទ្ធសឹងតែមានប្រភពនៅជើងភ្នំឱរ៉ាល់ ក្នុងជួរភ្នំក្រវាញ និងបានហូរធ្លាក់ចុះមកសំដៅចូលទៅក្នុងទន្លេសាប។ ដៃទាំងនេះគឺសុទ្ធសឹងជាស្ទឹងដែលមានទឹកជាអចិន្ត្រៃយ៍ជានិច្ចដូចជា ៖
  - ស្ទឹងជ្រៃបាក់
  - ស្ទឹងច្រៀវ
  - ស្ទឹងក្រាំងពន្លៃ
  - ស្ទឹងស្រែដៃ
  - ស្ទឹងជ្រោយ។

### ផែនទីប្រព័ន្ធទន្លេសាប




## ខ. បឹងទន្លេសាប

បឹងទន្លេសាប ជាបឹងទឹកសាបដ៏ធំមួយដែលមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជាយើង។ បឹងនេះ តភ្ជាប់មកទន្លេមេគង្គ ដោយទន្លេសាប។ បឹងទន្លេសាបមានខេត្តចំនួន ៦ នៅព័ទ្ធជុំវិញ គឺខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ និងមានផ្លូវជាតិ ២ ខ្សែ អមសងខាងគឺ ផ្លូវជាតិលេខ ៥ និងផ្លូវជាតិលេខ ៦ ដែលតភ្ជាប់រវាងខេត្តនានានៅជុំវិញបឹងទន្លេសាប ហើយបង្កើតបានជាប្រព័ន្ធគមនាគមន៍មួយយ៉ាងសំខាន់ សម្រាប់ប្រជាជនដែលស្ថិតនៅជុំវិញបឹងទន្លេសាប។

បឹងទន្លេសាប ដែលជាបេះដូងនៃប្រទេសកម្ពុជាយើង គឺជាបឹងទឹកសាបដ៏ធំជាងគេបំផុតនៅភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល។ បឹងនេះ មានរាងដូចជាវិយូឡុង ដោយស្ថិតនៅកណ្ដាលអាងមានរាងមូល និងមានបណ្ដោយប្រវែង ១៥០ គ.ម គិតពីព្រែកទ័លមកទល់នឹងក្រុងកំពង់ឆ្នាំង និងទទឹងប្រវែង ៣២ គ.ម ជាមធ្យម ព្រមទាំងមានផ្ទៃក្រឡា ៣ ០០០ គ.ម$^{២}$ នៅរដូវទឹកសម្រក ឬរដូវប្រាំង ហើយទឹកបឹងមានជម្រៅចាប់

ពី ០.៨០ ម៉ែត្រ ទៅ ២ ម៉ែត្រតែប៉ុណ្ណោះ។ នៅរដូវទឹកជំនន់ ឬរដូវវស្សា បឹងនេះមានទិដ្ឋភាពដូចជាសមុទ្រក្នុងមួយដែលមានផ្ទៃប្រមាណ ១០ ០០០ គ.ម² ហើយកម្ពស់ទឹកអាចឡើងដល់ ១៤ ម៉ែត្រ បានពន្លិចព្រៃនោម និងទំនាបដែលស្ថិតនៅជុំវិញបឹង។ ជាទូទៅ បឹងទន្លេសាបត្រូវបាន គេបែងចែកជា ៣ ផ្នែកទៀតគឺ ៖

***ផែនទីទិដ្ឋភាពបឹងទន្លេសាប***




- **បឹងធំ** ៖ ស្ថិតនៅភាគខាងជើង នៅជាប់នឹងខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ដែលមានបណ្តោយប្រវែងពី ៧៥ ទៅ ៨០ គ.ម និងទទឹងប្រវែងពី ៣២ គ.ម ទៅ ៣៥ គ.ម និងជម្រៅទឹកនៅពេលស្រកអស់មិនលើសពី ២ ម៉ែត្រនោះឡើយ។នៅក្បែរបឹងតូច ទទឹងនៃបឹងធំបានរួមតូច ដែលមានប្រវែងត្រឹមតែ ១២ គ.ម ប៉ុណ្ណោះ ព្រោះនៅទីនោះជាដីសណ្តដែលបានកកើតឡើងដោយសារតែការហូរនាំមកជាមួយនូវដីល្បាប់ និងកំទេចកំទីទាំងឡាយមកចាក់បង្គរនៃខ្សែទឹកស្ទឹងដូចជា ស្ទឹងពោធិ៍សាត់នៅភាគខាងត្បូង និងស្ទឹងជីក្រែង និងស្ទឹងស្ទោងនៅភាគខាងជើង។
- **បឹងតូច** ៖ ស្ថិតនៅចំកណ្តាល នៅជាប់នឹងខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ ដែលមានប្រវែងបណ្តោយពី ៣៥ គ.ម ទៅ ៤០ គ.ម និងទទឹងប្រវែង ២៨ គ.ម ជាអតិបរមា។ បឹងនេះ មានចុងខាង

តូចរួមតូច នៅត្រង់ផ្នុកទ្រូ ដោយសារតែការហូរនាំមកចាក់បង្គរនូវដីល្បាប់ និងកំទេចកំទីរបស់ស្ទឹងសែន ដែលជាស្ទឹងដ៏វែង និងធំជាងគេបំផុតនៅប្រទេសកម្ពុជា។ បឹងនេះ តភ្ជាប់ទៅទន្លេសាបដោយវាលភក់។

- **វាលភក់** ៖ ជាវាលដ៏ធំមួយ ដែលស្ថិតនៅចន្លោះផ្នុកទ្រូ និងខេត្តកំពង់ឆ្នាំង។ វាលនេះ គឺជាទីប្រជុំដៃទន្លេយ៉ាងសាំញ៉ាំ ដែលម្តងជួប និងម្តងឃ្លាតបណ្តាលឱ្យកើតបានជាកូនកោះទាបៗជាច្រើន ព្រមទាំងសម្បូរទៀតផង។ វាលភក់នេះ មានទីតាំងស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ ដែលមានប្រវែងបណ្តោយ ៤០ គ.ម និងទទឹងប្រវែង ១២ គ.ម ហើយសម្បូរទៅដោយរុក្ខជាតិក្រិនៗ។

**១. របបទឹកបឹងទន្លេសាប**

បឹងទន្លេសាបនៅប្រទេសកម្ពុជាយើងមានទិដ្ឋភាពដូចកូនសមុទ្រក្នុងមួយយ៉ាងធំនៅរដូវវស្សា ហើយអាចបម្រើឱ្យសកម្មភាពនាវាចរធំៗបាននៅរដូវវស្សា។ នៅរដូវវស្សា ទឹកជំនន់បានកើនឡើងជោរជន់ពេញទំនាប ដែលស្ថិតនៅព័ទ្ធជុំវិញបឹងទន្លេសាប។ ទឹកជំនន់ដ៏សម្បើមអស្ចារ្យនេះ គឺបណ្តាលមកពីទឹកភ្លៀង ដែលហូរចុះមកពីស្ទឹងនានា និងទឹកជំនន់នៅទន្លេមេគង្គ។ ផ្ទុយទៅវិញ នៅរដូវប្រាំង បឹងនេះមានទិដ្ឋភាពមិនខុសពីស្រះដ៏ធំមួយនោះឡើយ ប្រកបដោយភក់ ហើយរាក់ថែមទៀតផង។

នៅរដូវវស្សា ទិដ្ឋភាពទូទៅនៃបឹងទន្លេសាបបានផ្លាស់ប្តូរជាច្រើន ផ្ទៃបឹង ហើយនិងជម្រៅទឹកក៏បានកើនឡើងជាលំដាប់ផងដែរ រហូតដល់ជួនកាលទឹកជំនន់នេះបានហូរចូលពេញទំនាបដែលព័ទ្ធជុំវិញបឹងនោះទៀតផង។ កម្ពស់ទឹកបឹងនេះអាចកើនឡើងរហូតដល់ទៅ ១៤ ម៉ែត្រ គឺខុសគ្នា ១០ ម៉ែត្រ យ៉ាងតិចពីកម្ពស់ទឹកនៅរដូវប្រាំង នៅពេលនេះហើយ ដែលនាវាមានចំណុះច្រើនអាចបើកបរចូលដល់បឹងទន្លេសាបយ៉ាងងាយស្រួល។

នៅរដូវទឹកសម្រកបានចាប់ផ្តើមនៅខែធ្នូ ហើយបានចប់ទៅវិញនៅខែឧសភា។ នៅពេលនោះ កម្ពស់ទឹកបឹងទន្លេសាបមានជាអប្បរមាពី ០.៨០ ម៉ែត្រ ដល់ ២ ម៉ែត្រជាមធ្យម។ ចាប់ពីក្រុងកំពង់ឆ្នាំង ជាពិសេសនៅវាលភក់ ជម្រៅទឹកចុះជាលំដាប់ រហូតដល់នាវាមិនអាចធ្វើចរាចរបាន ហើយត្រូវបានគេហាមឃាត់។

**២. ដៃសំខាន់ៗបឹងទន្លេសាប**

ដៃសំខាន់ៗរបស់បឹងទន្លេសាបសុទ្ធសឹងជាស្ទឹង ដែលហូរធ្លាក់ចុះមកពីកូនភ្នំខាងជើង ពីជួរភ្នំដងរែក និងពីជួរភ្នំក្រវាញ ហើយបានហូរធ្លាក់ចាក់ចូលទៅក្នុងបឹងទន្លេសាប ពោលគឺបានហូរមកពីគ្រប់ទិសទីទាំងអស់ ប្រៀបបានទៅនឹងកាំកង់ទោចក្រយានផងដែរ។ លើសពីនេះទៅទៀត ស្ទឹងដែលជាដៃរបស់បឹងទន្លេសាបទាំងនោះ គឺមានទិសដៅស្ទើរតែស្របគ្នាពីមួយទៅមួយថែមទៀតផង។ ដៃសំខាន់ៗរបស់បឹងទន្លេសាប គឺមាននៅទាំងសងខាង ពោលគឺមាននៅទាំងនៅត្រើយខាងកើត ឬនៅត្រើយខាងឆ្វេង និងមាននៅទាំងនៅត្រើយខាងស្តាំ ឬនៅត្រើយខាងលិច។ ដៃរបស់បឹងទន្លេសាបទាំងសងខាងនេះរួមមានដូចជា ៖

- **ដៃបឹងទន្លេសាបនៅត្រើយខាងកើត ឬត្រើយខាងឆ្វេង** ៖ ដៃទាំងនេះរួមមាន ៖
  - **ស្ទឹងស្រែង** ៖ មានប្រភពនៅជួរភ្នំដងរែក ហើយហូរចុះមកប្រសព្វគ្នានឹងស្ទឹងសង្កែ មុននឹងហូរចាក់ចូលទៅក្នុងបឹងទន្លេសាប។ ស្ទឹងស្រែង គឺជាស្ទឹងមួយ ដែលស្ថិតនៅជាព្រំប្រទល់រវាងខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប។
  - **ស្ទឹងសៀមរាប** ៖ មានប្រភពនៅលើខ្នងភ្នំគូលែន ហើយស្ទឹងនេះហូរកាត់ក្បែរប្រាសាទអង្គរវត្ត ដោយហូរនាំទឹកទៅចាក់បំពេញបារាយណ៍អង្គរ រួចហូរចាក់ចូលទៅក្នុងបឹងទន្លេសាប។
  - **ស្ទឹងរលួស** ៖ ជាស្ទឹងតូចមួយដែលមានប្រភពនៅលើខ្នងភ្នំគូលែន ហើយស្ទឹងនេះហូរកាត់ឃុំរលួស រួចចាក់ចូលទៅក្នុងបឹងទន្លេសាប។
  - **ស្ទឹងជីក្រែង** ៖ មានប្រភពនៅតំបន់ខ្ពង់រាបខាងជើង ហើយស្ទឹងនេះហូរកាត់ស្រុកជីក្រែងខេត្តសៀមរាប រួចចាក់ចូលទៅតំបន់វាលភក់ ឬទន្លេធ្លារ។
  - **ស្ទឹងស្ទោង** ៖ ស្ទឹងនេះ មានប្រភពនៅតំបន់ខ្ពង់រាបខាងជើង និងហូរកាត់ស្រុកស្ទោង ខេត្តកំពង់ធំ រួចហូរចាក់ចូលទៅក្នុងតំបន់វាលភក់ ឬទន្លេធ្លារផងដែរ។

***ផែនទីដៃទន្លេមេគង្គ ទន្លបាសាក់ ទន្លេសាប និងបឹងទន្លេសាប***



- **ស្ទឹងសែន** ៖ ស្ទឹងនេះ មានប្រភពនៅជួរភ្នំដងរែក ហើយមានទឹកជាច្រើន ដោយសារមានអូរជាច្រើនហូរកាត់។ ស្ទឹងនេះ ហូរកាត់ទីរួមខេត្តព្រះវិហារ និងទីរួមខេត្តកំពង់ធំ ដែលមានបណ្តោយប្រវែង ៤៥០ គ.ម គឺជាស្ទឹងដែលវែងជាងគេបំផុតនៅប្រទេសកម្ពុជា។ ស្ទឹងនេះបានបត់បែនជាក្នែនយ៉ាងច្រើន មុននឹងមកដល់ខេត្តកំពង់ធំ រួចហូរចាក់ចូលទៅក្នុងបឹងទន្លេសាបនៅត្រង់ផ្លុកទ្រូ។

▪ **ដៃបឹងទន្លេសាបនៅត្រើយខាងលិច ឬនៅត្រើយខាងស្តាំ** ៖ ដៃទាំងនេះរួមមាន ៖

- **ស្ទឹងសេរីសោភ័ណ្ឌ** ៖ ស្ទឹងនេះ ហូរមកពីប្រទេសថៃ ដែលមានប្រភពនៅភ្នំសាយខាវនៅលើរយៈកម្ពស់ ១៤៧០ ម៉ែត្រ និងហូរកាត់ក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ រួចហូរមកប្រសព្វគ្នាជាមួយនឹងស្ទឹងសង្កែ មុននឹងហូរចាក់ចូលទៅក្នុងបឹងទន្លេសាប។
- **ស្ទឹងមង្គលបុរី** ៖ ស្ទឹងនេះ មានប្រភពនៅជួរភ្នំក្រវាញ នៃប្រទេសកម្ពុជា និងបានហូរកាត់ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ រួចហូរមកប្រសព្វគ្នាជាមួយនឹងស្ទឹងសង្កែ មុននឹងហូរចាក់ចូលទៅក្នុងបឹងទន្លេសាប។
- **ស្ទឹងសង្កែ** ៖ ស្ទឹងនេះ មានប្រភពនៅភ្នំតាល័រដែលមានកម្ពស់ ៧០០ ម៉ែត្រ ហើយស្ទឹងនេះបានហូរកាត់ក្រុងបាត់ដំបង រួចហូរមកប្រសព្វគ្នាជាមួយនឹងស្ទឹងសេរីសោភ័ណ្ឌ និងស្ទឹងមង្គលបុរី មុននឹងហូរចាក់ចូលទៅក្នុងបឹងទន្លេសាបនៅត្រង់ព្រែកទាល់។
- **ស្ទឹងមោង ឬស្ទឹងដូនទ្រី** ៖ ស្ទឹងនេះមានប្រភពនៅលើភ្នំទឹកព្រិល ក្នុងជួរភ្នំក្រវាញ និងបានហូរកាត់ស្រុកមោង ខេត្តបាត់ដំបង រួចហូរទៅប្រសព្វគ្នាជាមួយនឹងស្ទឹងស្វាយដូនកែវ មុននឹងហូរចាក់ចូលទៅក្នុងបឹងទន្លេសាប។
- **ស្ទឹងស្វាយដូនកែវ** ៖ ស្ទឹងនេះមានប្រភពនៅក្នុងភ្នំក្រវាញ ដោយហូរកាត់ភូមិស្វាយដូនកែវ ខេត្តពោធិ៍សាត់ រួចហូរទៅជួបនឹងស្ទឹងមោង មុននឹងហូរចាក់ចូលទៅក្នុងបឹងទន្លេសាប។
- **ស្ទឹងពោធិ៍សាត់** ៖ ស្ទឹងនេះ មានប្រភពនៅលើភ្នំខ្មោច ក្នុងជួរភ្នំក្រវាញខាងលិច ជាស្ទឹងដែលមានរបបទឹកប្រៀបបាននឹងទឹកជ្រោះ ដែលអាចបណ្តាលឱ្យមានទឹកជំនន់។ ស្ទឹងនេះហូរកាត់ក្រុងពោធិ៍សាត់ និងស្រុកកណ្តៀង ខេត្តពោធិ៍ មុននឹងហូរចូលក្នុងបឹងទន្លេសាប។
- **ស្ទឹងបរិបូរ** ៖ ស្ទឹងនេះ មានប្រភពនៅជួរភ្នំក្រវាញ ដែលបានហូរកាត់ទីរួមស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង មុននឹងហូរចាក់ចូលទៅក្នុងបឹងទន្លេសាប នៅត្រង់ផ្លុកទ្រូ។

### គ. សារៈសំខាន់សេដ្ឋកិច្ចប្រព័ន្ធទន្លេសាប

ទន្លេសាប បឹងទន្លេសាប និងដៃទាំងអស់របស់វា រួមគ្នាបង្កើតបានជាផ្លូវនាវាចរមួយដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា។ នៅរដូវវស្សា បឹងទន្លេសាបមានទូក កាណូតតូចធំចេញចូលយ៉ាងច្រើន ដើម្បីបំពេញសកម្មភាពនានា ជាពិសេសសកម្មភាពដឹកទំនិញពីតំបន់ពាយ័ព្យមកកាន់រាជធានីភ្នំពេញ។ នៅរដូវប្រាំង ក្នុងបឹងទន្លេសាប គេអាចធ្វើនាវាចរបាន ដោយសារការប្រើកូនទូកតូចៗតែប៉ុណ្ណោះ ពីព្រោះទឹករាក់ខ្លាំងពេក។

ទន្លេសាប បឹងទន្លេសាប និងដៃរបស់វាសុទ្ធសឹងតែផ្តល់ទឹក សម្រាប់បំណាចបញ្ចូលស្រែចម្ការ និងផលិតថាមពលវារីអគ្គិសនី ដែលគេអាចទាញយកមកប្រើប្រាស់យ៉ាងងាយ។

ប្រព័ន្ធទន្លេសាប ទោះបីជាបឹងក្តី ស្ទឹងក្តី ទន្លេក្តី គឺសុទ្ធសឹងតែផ្តល់នូវអត្ថប្រយោជន៍ដូចប្រព័ន្ធទន្លេមេគង្គផងដែរ គឺផ្តល់នូវដីល្បាប់ដ៏មានជីជាតិដល់ទំនាបទាំងឡាយ ដែលស្ថិតនៅអមសងខាង។

បឹងទន្លេសាប គឺជាមជ្ឈមណ្ឌលនេសាទទឹកសាបមួយយ៉ាងធំនៅប្រទេសកម្ពុជា។ បឹងនេះ គឺជាមជ្ឈមណ្ឌល ដែលសម្បូរត្រីជាងគេនៅលើពិភពលោក ពីព្រោះនៅទីនោះមានព្រៃលិចទឹក ដែលជាជម្រកដ៏សម្បូរអាហារ សម្រាប់មច្ឆាជាតិទាំងអស់នៅក្នុងអាងទាំងមូល។

តាមការសិក្សាស្រាវជ្រាវ បឹងទន្លេសាបគឺមានកំណប់រ៉ែជាច្រើនប្រភេទ ពិសេសកំណប់ឥន្ធនៈផូស៊ីល ដូចជា ប្រេងកាត ឧស្ម័នធម្មជាតិ និងធ្យូងថ្ម ពីព្រោះបឹងទន្លេសាបកាលពីអតីតកាល គឺជាបាតសមុទ្រចាស់កាលពីស័កទី ៣ ដូចនេះ បឹងទន្លេសាបពិតជាមានកំណប់រ៉ែជាច្រើនប្រភេទនៅក្រោមផ្ទៃដីជាក់ជាមិនខាននោះឡើយ។

ម្យ៉ាងទៀត ប្រព័ន្ធទន្លេសាប ពិសេសដៃទាំងឡាយរបស់វា អាចឱ្យគេស្ថាបនាទំនប់វារីអគ្គិសនីដែលផ្តល់នូវថាមពលអគ្គិសនីរាប់ពាន់គីឡូវ៉ាត់ម៉ោង សម្រាប់ប្រើប្រាស់នៅក្នុងឧស្សាហកម្ម និងនៅក្នុងជីវភាពរបស់ប្រជាជនយើងផងដែរ។

ជាងនេះទៅទៀត បឹងទន្លេសាបជាងអាងស្តុំមួយយ៉ាងធំ ដែលអាចស្រូបយកទឹកជំនន់ពីទន្លេមេគង្គអស់មួយភាគធំ ជាហេតុធ្វើឱ្យតំបន់ទំនាបកណ្តាលមិនបានទទួលរង នូវការលិចលង់ខ្លាំងនៅរដូវទឹកជំឡើងនោះឡើយ។

លើសពីនេះទៀត ប្រព័ន្ធទន្លេសាបក៏ផ្តល់សារៈប្រយោជន៍យ៉ាងច្រើន ដល់វិស័យទេសចរណ៍ផងដែរ ពីព្រោះប្រព័ន្ធទន្លេនេះ គឺសម្បូរទៅដោយព្រៃលិចទឹក មានទេសភាពស្រស់ត្រកាល មានខ្យល់អាកាសបរិសុទ្ធ មានផ្ទះអណ្តែតទឹក សម្បូរទៅដោយជីវៈចម្រុះដ៏សម្បូរបែប ពិសេសមានពពួកបក្សីទឹក ដែលប្រភេទបក្សីខ្លះគឺជាសត្វដ៏កម្រនៅលើពិភពលោក សម្រាប់ទាក់ទាញអ្នកទេសចរ។

## ២.៣. ប្រព័ន្ធផ្លូវទឹកនៅតំបន់មាត់សមុទ្រ

នៅភាគនិរតីនៃប្រទេសកម្ពុជាយើងដែលស្ថិតនៅចន្លោះឆ្នេរសមុទ្រ និងជួរភ្នំក្រវាញ មានស្ទឹង និងព្រែកជាច្រើន បានហូរធ្លាក់ចុះមកពីតំបន់កូនភ្នំ និងជួរភ្នំក្រវាញ សំដៅចាក់ចូលទៅក្នុងសមុទ្រ។

ស្ទឹង និងព្រែក ឬផ្លូវទឹកទាំងនោះ ហូរធ្លាក់ពីលើរយៈកម្ពស់ពី ៥០០ ម៉ែត្រ ទៅ ៦០០ ម៉ែត្រ ពោលគឺធ្លាក់ពីល្បាក់មួយទៅកាន់ទំនាបជិតៗ ដោយបត់បែនជាក្បែនយ៉ាងច្រើន មុននឹងទៅដល់សមុទ្រក្នុងចម្ងាយពី ១៥ ទៅ ២០ គ.ម។ នៅត្រង់កន្លែងដីសណ្ត ផ្លូវទឹកទាំងនោះតែងតែចែកជាដៃយ៉ាងច្រើនកប់នៅក្រោមភក់ជ្រាយ ដែលមានប្រភេទព្រៃកោងកាងដុះពាសពេញ។ នៅរដូវវស្សា ព្រែក ឬស្ទឹងទាំងនោះតែងតែមានទឹកច្រើន ហើយហូរយ៉ាងលឿនដោយនាំមកជាមួយនូវដុំថ្ម និងមែកឈើ ដែលជាហេតុធ្វើឱ្យមានទឹកជំនន់ក្នុងរយៈពេលខ្លី។ នៅរដូវប្រាំង ស្ទឹង ឬព្រែកទាំងនេះមានទឹកតិចតួចណាស់ ហើយហូរយ៉ាងសន្សឹមៗ និងជួនកាលមានជ្រោះខ្លះត្រូវរីងស្ងួតផងនៅរដូវប្រាំងនេះ។ នេះបញ្ជាក់ឱ្យឃើញថា របបទឹកស្ទឹង ឬព្រែកនៅតាមតំបន់មាត់សមុទ្រគឺមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងរបបខ្យល់ មូសុង គឺមូសុងវស្សា និងមូសុងប្រាំង។

## ឆ. ដៃសំខាន់ៗ

នៅតំបន់មាត់សមុទ្រ  គេឃើញមានផ្លូវទឹកជាច្រើន  ដែលហូរចាក់ចូលទៅក្នុងសមុទ្រពីតំបន់កូនភ្នំ និងជួរភ្នំក្រវាញនៃប្រទេសកម្ពុជា។ ផ្លូវទឹកដែលជាស្ទឹង ឬជាព្រែកទាំងនោះគឺសុទ្ធសឹងជាដៃនៃឆ្នេរសមុទ្រ ឬសមុទ្ររបស់ប្រទេសយើង។ ផ្លូវទឹកសំខាន់ៗ ដែលជាដៃរបស់ឆ្នេរសមុទ្រ ឬសមុទ្រទាំងនោះរួមមាន ៖

***ផែនទីតំបន់មាត់សមុទ្រ និងផ្លូវទឹកនៅតំបន់មាត់សមុទ្រនៃប្រទេសកម្ពុជា***




- **ស្ទឹងមេទឹក** ៖ មានប្រភពនៅភ្នំធំ (មានកម្ពស់ ១ ២៥៨ ម៉ែត្រ) ក្នុងជួរភ្នំក្រវាញ។ ស្ទឹងនេះហូរស្រប គ្នានៅតាមបណ្តោយព្រំប្រទល់ប្រទេសកម្ពុជា និងថៃ រួចហូរចាក់ចូលទៅក្នុងសមុទ្រ ត្រង់ថ្នល់ក្របី ខេត្តកោះកុង។ ស្ទឹងមេទឹក គឺទទួលបានទឹកពីស្ទឹងឫស្សីជ្រុំ និងព្រែកសំខាន់ៗផ្សេងៗទៀតនៅក្នុង តំបន់នោះ។
- **ស្ទឹងតាតៃ** ៖ ស្ទឹងនេះ ត្រូវបានគេយកតាមឈ្មោះភូមិតាតៃ ដែលស្ថិតនៅជិតប្រភពដើម និងមាន ប្រភពនៅក្នុងជួរភ្នំក្រវាញ។ ស្ទឹងតាតៃ ឬព្រែកតាតៃនេះ គឺទទួលបានទឹកពីដៃខាងស្តាំចំនួនពីរ របស់វាគឺ ស្ទឹងកែប និងស្ទឹងសាលាមនន្ទ។
- **ស្ទឹងជាយអារ៉ែង** (ត្រពាំងរូង) ៖ ស្ទឹងនេះ មានប្រភពនៅក្នុងជួរភ្នំក្រវាញ ហើយមានរាងបត់បែន យ៉ាងខ្លាំង ព្រមទាំងបានហូរទៅប្រសព្វគ្នាជាមួយនឹងស្ទឹងតាតៃ មុននឹងហូរចាក់ចូលទៅក្នុងសមុទ្រ។ ស្ទឹងជាយអារ៉ែងគឺទទួលបានទឹកពីព្រែកយួន ព្រែកស្មោញ និងព្រែកតាចាន់។

- **ព្រែកជីផាត់ (ព្រែកអណ្តូងទឹក)** ៖ ព្រែកនេះ ក៏មានប្រភេតពនៅក្នុងជួរភ្នំក្រវ៉ាញផងដែរ និងបានហូរចាក់ចូលទៅក្នុងឆកកំពង់សោម។ ព្រែកជីផាត់គឺជាផ្លូវធម្មជាតិមួយដ៏សំខាន់ សម្រាប់ឡើងទៅតំបន់ខ្ពស់ ដែលស្ថិតនៅក្នុងជួរភ្នំក្រវ៉ាញ។
- **ព្រែកកំពង់សោម (ព្រែកស្រែអំបិល)** ៖ ព្រែកនេះ មានប្រភពនៅក្នុងជួរភ្នំក្រវ៉ាញ និងបានហូរកាត់ស្រុកស្រែអំបិល ខេត្តកោះកុង មុននឹងហូរចាក់ចូលទៅក្នុងឆកកំពង់សោម។ ព្រែកនេះ គឺបានទទួលទឹកពីដៃខាងស្តាំរបស់វាគឺ ស្ទឹងកំបុត និងស្ទឹងសំរោង។
- **ស្ទឹងកំពត (ព្រែកកំពត)** ៖ ស្ទឹងនេះ មានប្រភពនៅភ្នំដំរីជិតប្រកពេជ្រនិល ហើយបានទទួលទឹកពីខាងស្តាំដៃ និងពីខាងលើខេត្តកំពតពីស្ទឹងមួយដ៏សំខាន់ គឺស្ទឹងកំចាយ ដែលហូរធ្លាក់ចុះមកពីជ្រោះពពកវិល (បូកគោ)។ ស្ទឹងកំពត បានហូរកាត់ក្រុងកំពត មុននឹងហូរចាក់ចូលទៅ ក្នុងសមុទ្រ។
- **ស្ទឹងទូកមាស (ព្រែកទូកមាស)** ៖ ស្ទឹងនេះ មានប្រភពនៅលើភ្នំវល្លិ៍ និងបានហូរកាត់ស្រុកទូកមាស ខេត្តកំពត។ ស្ទឹងទូកមាសបានហូរចូលទៅក្នុងប្រទេសវៀតណាមនៅត្រង់ទាន់ហាន់ រួចហូរចាក់ទៅក្នុងឆកសមុទ្រហាទៀង។ ស្ទឹងនេះ បានហូរមកតភ្ជាប់នឹងទន្លេបាសាក់ ដោយព្រែកវិញតេ នៅត្រង់ព្រំប្រទល់ប្រទេសកម្ពុជា និងវៀតណាម។

ក្រៅពីស្ទឹង និងព្រែកសំខាន់ៗ ដូចបានរៀបរាប់ខាងលើនេះ នៅមានកូនជ្រោះជាច្រើនទៀត ដែលតែងតែបានហូរនាំមកនូវកំទេចកំទីគ្រប់បែបយ៉ាងមកចាក់បំពេញនៅក្នុងឈូងសមុទ្រនៅរៀងរាល់រដូវវស្សា។

### ខ. សារៈសំខាន់សេដ្ឋកិច្ចប្រព័ន្ធផ្លូវទឹកនៅតំបន់មាត់សមុទ្រ

នៅក្នុងពេលបច្ចុប្បន្ននេះ ផ្លូវទឹកនៅតាមតំបន់សមុទ្រនៃប្រទេសកម្ពុជាយើងពុំសូវបានផ្តល់នូវ សារៈសំខាន់ប៉ុន្មាននោះទេ ចំពោះសេដ្ឋកិច្ចជាតិប្រទេសយើង ពីព្រោះផ្លូវទឹកទាំងនេះគឺសុទ្ធសឹងតែជាជ្រោះ ជាព្រែកតូចៗ និងខ្លីៗដែលមានរបបទឹកជាជ្រោះ ហើយមានភាពមិនទៀងទាត់ ឡើង និងស្រកឆាប់រហ័ស ទៅតាមលក្ខណៈនៃទឹកភ្លៀង និងច្រើនមានរបាំងខ្សាច់ ឬរបាំងភក់នៅត្រង់ចំណុចលំនឹងនៃជំនោរសមុទ្រ និងចរន្តស្ទឹង ដែលពេលខ្លះរាំងស្ទះដល់នាវាចរ។ ប៉ុន្តែ បើតាមបច្ចេកទេសទំនើប ផ្លូវទឹកដែលហូរចុះពីលើភ្នំដោយល្បឿនខ្លាំងដូចនេះ គឺគេអាចទាញយកថាមពលវារីអគ្គិសនីបានយ៉ាងងាយបំផុត។ ម្យ៉ាងទៀត ផ្លូវទឹកទាំងនោះមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ប្រជាជនដែលរស់នៅក្នុងតំបន់មាត់សមុទ្រ ព្រោះផ្លូវទឹកទាំងនោះបានផ្តល់នូវទឹកសាប សម្រាប់ប្រជាជនទាំងនោះប្រើប្រាស់ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

## ២.៤. សារៈសំខាន់សេដ្ឋកិច្ចប្រព័ន្ធផ្លូវទឹកនៅកម្ពុជា

ប្រព័ន្ធផ្លូវទឹកនៅប្រទេសកម្ពុជាយើង គឺសុទ្ធសឹងតែងតែបានផ្តល់នូវសារៈសំខាន់ជាច្រើនដល់ប្រទេសកម្ពុជាយើង ពិសេសសម្រាប់ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចជាតិយើង។ សារៈសំខាន់ទាំងនោះរួមមានដូចជា ៖

- ផ្តល់ជាផ្លូវនាវាចរណ៍បាននៅគ្រប់រដូវកាលនៅទូទាំងប្រទេស។
- ផ្តល់ជាឡូត៍នេសាទយ៉ាងសំខាន់នៅរដូវទឹកសម្រក ពីព្រោះនៅរដូវនេះ ត្រីតែងតែមកផ្តុំគ្នានៅតាមព្រែក និងតាមពាមពោះទន្លេនានា ដែលនាំឱ្យងាយស្រួលក្នុងការនេសាទ។
- នៅរដូវទឹកជំឡើង ផ្លូវទឹកនេះតែងតែផ្តល់នូវដីល្បាប់ម៉ដ្ឋដ៏មានជីជាតិ សម្រាប់ទំនាបលិចទឹក

- ទាំងឡាយ ដែលមានសារៈសំខាន់ សម្រាប់ដំណាំគ្រប់ប្រភេទ ពិសេសដំណាំចម្ការផ្សេងៗ។
- នៅជុំវិញបឹង គឺសម្បូរទៅដោយព្រៃលិចទឹក ដែលជាជម្រកសម្រាប់ត្រីពង និងកូន។ ជាងនេះទៅទៀត ព្រៃលិចទឹកទាំងនោះមិនត្រឹមតែផ្តល់នូវជម្រក និងចំណីអាហារ ដល់ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវជម្រក សម្រាប់បក្សីទឹក និងផ្តល់ឧស សម្រាប់ប្រជាជនចម្អិនម្ហូបអាហារទៀតផង។
- ផ្តល់ជាប្រព័ន្ធធារាសាស្ត្រធម្មជាតិ សម្រាប់ស្រោចស្រពដីស្រែចម្ការ នៅពេលណាដែលមានភាពរាំងស្ងួតកើតឡើង។
- បឹងទន្លេសាប ជាអាងភ្លាមួយយ៉ាងធំ ដែលអាចស្រូបយកទឹកជំនន់ពីទន្លេមេគង្គអស់មួយភាគ
- ធំ ជាហេតុបណ្តាលឱ្យទំនាបកណ្តាលគេចផុតពីការលិចលង់ខ្លាំងនៅរដូវទឹកជំឡើង។
- អាចឱ្យគេទាញយកថាមពលវារីអគ្គិសនីបានយ៉ាងងាយបំផុត ពីព្រោះសម្បូរទៅដោយល្បាក់ទឹក ទឹកជ្រោះ និងព្រែក ស្ទឹង អូរ ដែលសុទ្ធសឹងតែជាផ្លូវទឹកមានប្រភពនៅតំបន់ខ្ពស់ ព្រមទាំងមានរបបទឹកហូរខ្លាំង ដែលអាចឱ្យគេស្ថាបនាទំនប់វារីអគ្គិសនីបានយ៉ាងងាយស្រួល។
- ជាប្រភពផ្តល់ទឹកសាបដល់ប្រជាជនកម្ពុជា សម្រាប់ប្រើប្រាស់ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។
- ផ្តល់នូវត្រីទឹកសាប សម្រាប់ភរិភោគ និងធ្វើពាណិជ្ជកម្មផងដែរ។
- សម្បូរទៅដោយព្រៃកោងកាង ដែលជាជម្រករបស់បក្សីទឹក និងមច្ឆជាតិ និងបានផ្តល់នូវអុសសម្រាប់ចម្អិនអាហាររបស់ប្រជាជននៅក្នុងតំបន់ផងដែរ។
- ជួយរក្សានូវលំនឹងសីតុណ្ហភាព និងអាកាសធាតុនៅក្នុងតំបន់។
- ផ្តល់នូវទីកន្លែងទេសចរណ៍ធម្មជាតិដ៏សំខាន់ ពីព្រោះសម្បូរទៅដោយព្រៃលិចទឹកបក្សីទឹក ជាពិសេសសត្វផ្សោតដ៏កម្ររបស់ពិភពលោក សម្រាប់ទាក់ទាញភ្ញៀវទេសចរ។
- ផ្តល់ជាមជ្ឈមណ្ឌលពាណិជ្ជកម្មជាតិ និងអន្តរជាតិ។
- ផ្តល់នូវកំណាប់រ៉ែដ៏សម្បូរបែបនៅក្រោមបាតបឹង និងទន្លេ ជាពិសេសកំណាប់ប្រេងកាត ត្បូងថ្ម និងឧស្ម័នធម្មជាតិ។

## សំណួរត្រិះរិះ

1. ចូរពិពណ៌នាអំពីទន្លេមេគង្គអន្តរជាតិ។
2. តើគេបែងចែកបណ្តាញផ្លូវទឹកនៅប្រទេសកម្ពុជាជាប៉ុន្មានប្រព័ន្ធ? អ្វីខ្លះ? ចូរពិពណ៌នាពីសារៈសំខាន់នៃប្រព័ន្ធផ្លូវទឹកនៅប្រទេសកម្ពុជា។
3. តើផ្លូវទឹកណាខ្លះ ដែលត្រូវបានគេរាប់បញ្ចូលក្នុងប្រព័ន្ធទន្លេមេគង្គ? ចូរពន្យល់នូវផ្លូវទឹកនីមួយៗឱ្យបានច្បាស់លាស់។
4. តើផ្លូវទឹកណាខ្លះ ដែលត្រូវបានគេរាប់បញ្ចូលក្នុងប្រព័ន្ធទន្លេសាប? ចូរពន្យល់។
5. ចូររៀបរាប់ឈ្មោះដៃទន្លេមេគង្គសំខាន់ៗ។
6. ចូររៀបរាប់ឈ្មោះដៃបឹងទន្លេសាបសំខាន់ៗ។
7. ចូរពិពណ៌នាអំពីផ្លូវទឹកនៅតំបន់មាត់សមុទ្រ។

# ៣. អាកាសធាតុប្រទេសកម្ពុជា លក្ខណៈទូទៅនៃអាកាសធាតុ

## ៣.១. លក្ខណៈទូទៅនៃអាកាសធាតុ

### ក.ធាតុអាកាស

**១. និយមន័យធាតុអាកាស**

យើងទាំងអស់គ្នាភាគច្រើនសុទ្ធសឹងធ្លាប់បានស្តាប់នូវការព្យាករណ៍ធាតុអាកាសតាមវិទ្យុ និង ទូរទស្សន៍ជារៀងរាល់ថ្ងៃ។ នៅពេលដែលយើងស្តាប់អំពីការព្យាករណ៍ធាតុអាកាសនេះ យើងប្រាកដជាកត់សម្គាល់ឃើញថា ធាតុអាកាសបានផ្លាស់ប្តូរពីមួយពេលទៅមួយពេល ឬពីមួយថ្ងៃទៅមួយថ្ងៃ។ តាមពិតក្នុងរយៈពេលមួយថ្ងៃ លក្ខខណ្ឌធាតុអាកាសតែងតែមានការប្រែប្រួលខុសៗគ្នា ទៅតាមពេលវេលា ឬម៉ោង។ នៅពេលព្រឹកព្រលឹម អាចត្រជាក់ អាចក្តៅល្មម និងមានពន្លឺថ្ងៃ រីឯនៅពេលរសៀលអាចក្តៅខ្លាំង និងអាចមានពពកច្រើន ព្រមទាំងអាចមានភ្លៀងធ្លាក់ថែមទៀតផង និងនៅពេលយប់អាចមានព្យុះជាដើម។ ការប្រែប្រួលនៃកត្តាទាំងអស់នេះ នៅក្នុងរយៈពេលខ្លីបែបនេះ ត្រូវបានអ្នកឧតុកូតវិទូហៅថា **ធាតុអាកាស**។

ដូចនេះ យើងអាចកំណត់និយមន័យ ធាតុអាកាស បានថាគឺជាលក្ខខណ្ឌ នៃការប្រែប្រួលជាទូទៅនៃសមាសធាតុផ្សំរបស់បរិយាកាស (សីតុណ្ហភាព សម្ពាធ កំណកអាកាស ពន្លឺព្រះអាទិត្យ ពពក និងទិសខ្យល់បក់) ក្នុងរយៈពេលខ្លីនៅទីកន្លែងណាមួយ ឬនៅតំបន់ណាមួយជាក់លាក់។

**២. សមាសធាតុផ្សំនៃធាតុអាកាស**

សមាសធាតុផ្សំ នៃធាតុអាកាសរួមមាន សីតុណ្ហភាព សំណើមអាកាស ពពក កំណកអាកាស សំពាធអាកាស ខ្យល់បក់ ម៉ាសខ្យល់ និងព្រំខ្យល់។ ធាតុទាំងនេះបានដើរតួនាទីសំខាន់ណាស់ ក្នុងការធ្វើឱ្យធាតុអាកាសនៅតំបន់មួយ ឬទីកន្លែងមួយមានការប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ។

**២.១. សីតុណ្ហភាព**

សីតុណ្ហភាពគឺយោងទៅតាមកម្រិតនៃភាពក្តៅ និងភាពត្រជាក់នៅទីតាំងភូមិសាស្ត្រណាមួយ ឬនៅទីកន្លែងមួយ។ សីតុណ្ហភាពនៅទីតាំងមួយ ឬនៅកន្លែងមួយត្រូវបានជះឥទ្ធិពល ដោយបរិមាណនៃកាំរស្មីព្រះអាទិត្យ ឬរំកាយនៃកាំរស្មីព្រះអាទិត្យ ដែលបានធ្វើដំណើរទៅដល់ផ្ទៃផែនដី។ បម្រែបម្រួលនៃសីតុណ្ហភាពនៅតំបន់នានានៅលើផ្ទៃផែនដី ទាក់ទងទៅនឹងមុំចាំងប៉ះនៃកាំរស្មីព្រះអាទិត្យដែលបានចាំងប៉ះមកលើផ្ទៃផែនដីទាំងមូល។ មុំចាំងប៉ះ នៃកាំរស្មីព្រះអាទិត្យដែលចាំងប៉ះមកលើផ្ទៃផែនដី គឺមិនដូចគ្នានៅគ្រប់ទីកន្លែងទាំងអស់នោះទេ។ នៅតំបន់អេក្វាទ័រ កាំរស្មីព្រះអាទិត្យកាត់កែងនឹងផ្ទៃផែនដី។ កំដៅដ៏ខ្លាំងក្លាបានកើតឡើងនៅពេលដែលកាំរស្មីព្រះអាទិត្យកាត់កែងជាមួយផ្ទៃផែនដីបង្កើតជាបានមុំ ៩០$^{0}$ ឬក្បែរ ៩០$^{0}$។ ដូចនេះ តំបន់នៅក្បែរអេក្វាទ័រទទួលបានពន្លឺព្រះអាទិត្យដោយផ្ទាល់ ហើយមានសីតុណ្ហភាពខ្ពស់ជាងតំបន់ផ្សេងៗទៀត។ តំបន់ដែលស្ថិតនៅឆ្ងាយពីអេក្វទ័រទទួលបានពន្លឺព្រះអាទិត្យតិច ពីព្រោះកាំរស្មីព្រះអាទិត្យប៉ះនឹងផ្ទៃដីតូចជាងមុំ ៩០$^{0}$។

មានកត្តាមួយជាច្រើន ដែលជះឥទ្ធិពលទៅលើសីតុណ្ហភាពដូចជា រយៈទទឹង រយៈកម្ពស់ ខ្សែទឹកសមុទ្រ ចម្ងាយពីសមុទ្រ និងគម្របពពក។

**២.១.១. រយៈទទឹង**

រយៈទទឹង គឺជាចម្ងាយដែលត្រូវបានគេវាស់ដោយគិតជាដឺក្រេ ចេញពីអេក្វាទ័រទៅប៉ែកខាងជើង និងប៉ែកខាងត្បូងនៃអ័ក្សគោលទាំងពីរ។ រយៈទទឹងកើនឡើង នៅពេលដែលយើងឃ្លាតចេញពី អេក្វាទ័រទៅកាន់តំបន់ប៉ូល។ ទាំងប៉ូលខាងជើង និងប៉ូលខាងត្បូង គឺមានរយៈទទឹងទី ៩០$^{0}$ ខាងជើង និង ៩០$^{0}$ ខាងត្បូងអេក្វាទ័រ។

នៅតំបន់អេក្វាទ័រ និងតំបន់ត្រូពិច កាំរស្មីព្រះអាទិត្យកាត់កែងលើផ្ទៃផែនដីស្មើនឹងមុំ ៩០$^{0}$ ជាហេតុបង្កឱ្យតំបន់នេះទទួលកម្តៅព្រះអាទិត្យខ្លាំង។ ចំណែកឯនៅតំបន់ត្រជាក់បង្គួរ និងតំបន់ប៉ូលវិញ កាំរស្មីព្រះអាទិត្យចាំងទ្រេតទៅលើផ្ទៃដី ហើយកម្តៅដែលទទួលបានក៏តិចផងដែរ។ ហេតុដូច្នេះហើយបានជាសីតុណ្ហភាពមធ្យមនៅតំបន់អេក្វាទ័រ និងតំបន់ត្រូពិចខ្ពស់ជាងតំបន់ត្រជាក់បង្គួរ និងតំបន់ប៉ូល។

**២.១.២ រយៈកម្ពស់**

រយៈកម្ពស់ គឺជាកម្ពស់នៃចំណុចមួយនៃផ្ទៃដីពីលើកម្រិតផ្ទៃទឹកសមុទ្រ។ ប្រសិនបើយើងវាស់សីតុណ្ហភាពផ្ទៃផែនដីនៅរយៈកម្ពស់ខុសគ្នាៗ យើងនឹងឃើញថា សីតុណ្ហភាពនឹងប្រែប្រួល ហើយមានលក្ខណៈខុសៗគ្នា។ ជាទូទៅ សីតុណ្ហភាពមានការធ្លាក់ចុះ នៅពេលដែលរយៈកម្ពស់កើនឡើងនៅក្នុងមណ្ឌលអាកាសរចល់ ជាទីកន្លែងដែលមានធាតុអាកាសប្រែប្រួលកើតឡើង។ សីតុណ្ហភាពនឹងធ្លាក់ចុះជាមធ្យមប្រហែល ៦.៥ ℃ នៅពេលដែលរយៈកម្ពស់កើនឡើង ១ ០០០ ម៉ែត្រ ឬ ១ គីឡូម៉ែត្រពីផ្ទៃផែនដី។

លើសពីនេះទៅទៀត ខ្យល់នៅរយៈកម្ពស់កាន់តែខ្ពស់ គឺស្តើង និងមានកំហាប់តិច។ នៅរយៈកម្ពស់កាន់តែខ្ពស់ ខ្យល់ផ្សំឡើងពីកំហាប់នៃឧស្ម័ន ធូលី និងចំហាយទឹក ក៏កាន់តែតិចជាងខ្យល់នៅ រយៈកម្ពស់ទាបផងដែរ។ ខ្យល់ដែលមានកំហាប់តិចមិនមានលទ្ធភាពស្រូបយកកម្តៅបានច្រើន ឬមានប្រសិទ្ធភាពដូចខ្យល់ខាប់នោះទេ ពីព្រោះវាមានកំហាប់ឧស្ម័នតិចមិនអាចស្រូប ឬស្ទាក់ទុកនូវថាមពលកម្តៅបានឡើយ។

**២.១.៣. ចរន្តទឹកសមុទ្រ**

ចរន្តទឹកសមុទ្រខ្លះ គឺជាចរន្តទឹកក្តៅ រីឯចរន្តទឹកសមុទ្រខ្លះទៀត ជាចរន្តទឹកត្រជាក់។ ដូចនេះ តំបន់ដែលស្ថិតជិតចរន្តទឹកក្តៅ គឺមានសីតុណ្ហភាពខ្ពស់ជាងតំបន់ ដែលស្ថិតនៅជិតចរន្តទឹកត្រជាក់។ ចរន្តទឹកសមុទ្រដែលហូរចេញពីតំបន់អេក្វាទ័រ គឺជាចរន្តទឹកក្តៅ ហើយតំបន់ដែលស្ថិតនៅជិតនឹងចរន្តទឹកទាំងនេះមានសីតុណ្ហភាពខ្ពស់។

នៅតំបន់រយៈទទឹងមធ្យម និងតំបន់រយៈទទឹងខ្ពស់ដូចជា តំបន់ត្រជាក់បង្គួរ និងតំបន់ប៉ូល ចរន្តទឹកក្តៅគុលស្ទ្រីម និងគូរ៉ូស៊ីវ៉ូហូរមកកម្តៅឆ្នេរខាងលិច ប៉ុន្តែនៅតំបន់រយៈទទឹងដូចខាងលើនេះដែរ ចរន្តទឹកត្រជាក់ឡាប្រាដ័រ និងអូយ៉ាស៊ីវ៉ូធ្វើឱ្យសីតុណ្ហភាពចុះត្រជាក់នៅឆ្នេរខាងកើត។

**២.១.៤. ចម្ងាយពីសមុទ្រ**

ដីមានការដុតកម្តៅ និងចុះត្រជាក់លឿនជាងសមុទ្រ។ ភាពខុសគ្នា នៃអត្រាដុតកម្តៅ និងការចុះត្រជាក់នៃដី ហើយនិងសមុទ្រនេះមានឥទ្ធិពលទៅលើសីតុណ្ហភាពនៅតំបន់ឆ្នេរសមុទ្រ។

- **ឥទ្ធិពលសមុទ្រ**

ឥទ្ធិពលសមុទ្រ ជាឥទ្ធិពលដែលផ្ទៃមហាសមុទ្រ ឬសមុទ្រមានទៅលើអាកាសធាតុនៅតំបន់ឆ្នេរសមុទ្រ។ វាបណ្តាលឱ្យតំបន់ទាំងនេះ មានសីតុណ្ហភាពទាបជាមធ្យមប្រចាំឆ្នាំ។ ក្នុងកំឡុងរដូវក្តៅ ខ្យល់នៅពីលើផ្ទៃដីត្រូវបានកម្តៅយឺតជាងផ្ទៃដី។ ខ្យល់ត្រជាក់នៅពីលើផ្ទៃមហាសមុទ្រ ឬសមុទ្របានជួយបន្ទាបសីតុណ្ហភាពនៅតាមតំបន់មួយចំនួន ដែលស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ។

ម្យ៉ាងវិញទៀត ក្នុងកំឡុងពេលរដូវរំហើយ ខ្យល់នៅពីលើផ្ទៃមហាសមុទ្រ ឬសមុទ្របានរក្សាថាមពលកម្តៅ បើធៀបទៅនឹងខ្យល់នៅពីលើផ្ទៃទ្វីប ព្រោះផ្ទៃមហាសមុទ្ទ ឬសមុទ្រចំណាយពេលវេលាយូរជាងផ្ទៃដី ក្នុងការបាត់បង់ថាមពលកម្តៅ។

- **ឥទ្ធិពលទ្វីប**

ឥទ្ធិពលទ្វីប យោងទៅតាមឥទ្ធិពលដែលផ្ទៃទ្វីបមានឥទ្ធិពលទៅលើអាកាសធាតុនៅលើតំបន់ដីគោកនានា ដែលស្ថិតនៅឆ្ងាយពីសមុទ្រ។ វាបង្កឱ្យទីកន្លែងទាំងនេះ មានសីតុណ្ហភាពខ្ពស់ជាមធ្យមប្រចាំឆ្នាំ។ មិនដូចតំបន់ឆ្នេរសមុទ្រនោះទេ សីតុណ្ហភាពនៅតាមតំបន់ដីគោកមួយចំនួនមិនបានទទួលឥទ្ធិពលពីសមុទ្រនោះឡើយ។ ផ្ទុយទៅវិញ ទីកន្លែងទាំងនេះបានទទួលឥទ្ធិពលពីទ្វីប ដោយនៅរដូវក្តៅ គឺក្តៅខ្លាំង រីឯនៅរដូវត្រជាក់ គឺត្រជាក់ខ្លាំង ហើយគម្លាតសីតុណ្ហភាពរវាងរដូវទាំងពីរនេះ គឺខ្ពស់ខ្លាំងណាស់។

**២.១.៥. គម្របពពក**

គម្របពពក គឺអាស្រ័យទៅលើបរិមាណនៃពពក ដែលបានគ្របដណ្តប់នៅលើតំបន់មួយ។ វាបានជះឥទ្ធិពលលើសីតុណ្ហភាពនៅទីកន្លែងមួយ ឬតំបន់មួយ ដែលត្រូវបានទទួលឥទ្ធិពលនូវបរិមាណនៃថាមពលព្រះអាទិត្យមកដល់ និងត្រឡប់ទៅក្នុងបរិយាកាសវិញ។

ទីកន្លែងទាំងឡាយណា ដែលមានពពកគ្របដណ្តប់ពីលើកាន់តែច្រើន នោះភាពខុសគ្នារវាងសីតុណ្ហភាពពេលថ្ងៃ និងពេលយប់មានគម្លាតពីគ្នាកាន់តែតូច។ ផ្ទុយទៅវិញ ទីកន្លែងទាំងឡាយណាដែលមានពពកគ្របដណ្តប់ពីលើកាន់តែតិចដូចជា នៅតំបន់វាលលំហក្តៅ និងតំបន់វាលលំហត្រជាក់ជាដើម ភាពខុសគ្នារវាងសីតុណ្ហភាពពេលថ្ងៃ និងពេលយប់មានគម្លាតពីគ្នាកាន់តែធំ។ នេះ ដោយសារតែភាពអវត្តមាននៃគម្របពពក ស្ថិតនៅពីលើតំបន់វាលលំហទាំងនេះ ដែលធ្វើឱ្យថាមពលព្រះអាទិត្យមកដល់ផ្ទៃដីនៅពេលថ្ងៃ ហើយនិងកម្តៅ ដែលភាយចេញត្រឡប់ទៅក្នុងបរិយាកាសនៅពេលយប់បានយ៉ាងងាយស្រួល។

**២.២. សំណើមអាកាស**

សំណើមអាកាស គឺយោងទៅតាមបរិមាណនៃចំហាយទឹក ដែលមានវត្តមាននៅក្នុងខ្យល់នៅក្នុងបរិយាកាសរបស់ផែនដី។ ទីកន្លែងនានាដែលស្ថិតនៅក្បែរអេក្វាទ័រ គឺមានសំណើមខ្ពស់ មានន័យថា មានបរិមាណដ៏ច្រើន នៃចំហាយទឹកនៅក្នុងខ្យល់។ បរិយាកាសទទួលបានសំណើម តាមរយៈរំហួតទឹក ដែលបានមកពីមហាសមុទ្រ សមុទ្រ ទន្លេ បឹងបួរ ដី រុក្ខជាតិ សត្វ និងមនុស្ស។ ខ្យល់បានបក់នាំយកសំណើមឱ្យមានពាសពេញបរិយាកាសរបស់ផ្ទៃផែនដី។ នៅពេលខ្លះ មានសំណើមប្រហែល ១៤ លានតោននៅក្នុងបរិយាកាស។ សំណើមអាកាស អាចប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយ និងពីពេលមួយទៅពេលមួយទៀត។ ជាទូទៅសំណើមអាកាសមាន ២ ប្រភេទគឺ សំណើដាច់ខាត និងសំណើមប្រៀបធៀប។

### ២.២.១. សំណើមដាច់ខាត

សំណើមដាច់ខាត គឺជាបរិមាណនៃចំហាយទឹក ដែលអាចមានច្រើនបំផុតនៅក្នុង ១ម$^{៣}$ នៃអាកាស។ នៅក្នុងលក្ខខណ្ឌសីតុណ្ហភាព និងសម្ពាធធម្មតា ទម្ងន់នៃចំហាយទឹកក្នុង ១ម$^{៣}$ នៃអាកាសគឺមានជាមធ្យម ប្រហែល ១៥ ក្រាម។

### ២.២.២. សំណើមប្រៀបធៀប

សំណើមប្រៀបធៀប គឺជាផលធៀបរវាងទម្ងន់ចំហាយទឹក ដែលមាននៅក្នុងអាកាស និងទម្ងន់ចំហាយទឹកដែលមានច្រើនបំផុតនៅក្នុងអាកាសក្នុងចំណុះស្មើគ្នា ហើយនៅក្នុងលក្ខខណ្ឌសីតុណ្ហភាព និងសម្ពាធដូចគ្នា។ យើងអាចដឹងថា ធាតុអាកាសសើម ឬស្ងួត ដោយសារតែបម្រែបម្រួលនៃសំណើមប្រៀបធៀបនេះ។ ជាទូទៅ គេគិតសំណើមប្រៀបធៀបនេះជាភាគរយ។

### ២.៣. ពពក

ពពក គឺម៉ាសនៃតំណក់ទឹករាវតូចៗ ដែលបានកក ហើយរសាត់អណ្តែតនៅក្នុងបរិយាកាស។ ពពក ជាទម្រង់ដើមនៃកំណកអាកាស។ កំណកអាកាស គឺមិនអាចកើតជាទឹកភ្លៀង ឬជាកំណករឹងភ្លាមៗនោះទេ ក៏ប៉ុន្តែដំបូងកំណកអាកាសកកើតជាពពកសិន។ ពពកកើតឡើងពីបណ្តុំនៃតំណក់ទឹកល្អិតតូចៗដែលមានអង្កត់ផ្ចិតពី ៥ ទៅ ៥០ មីក្រុង (១ មីក្រុង = ១០$^{-៣}$ មីលីម៉ែត្រ = ១០$^{-៦}$ ម៉ែត្រ) រាប់លានគ្រាប់ផ្តុំចូលគ្នា ឬពពកកកើតឡើងពីក្រាមទឹកកកតូចៗ ឬពីតំណក់ទឹក និងក្រាមទឹកកកដែលលាយចូលគ្នាតែម្តង។ ដោយសារតែតំណក់ទឹកទាំងនេះល្អិតពេក និងដោយសារតែមានចលនាខ្យល់ស្ទុះឡើងទៅលើផងនោះ ទើបតំណក់ទឹកទាំងនេះអាចអណ្តែតក្នុងបរិយាកាសបាន។ មិនតែប៉ុណ្ណោះ ខ្យល់បក់ ក៏អាចធ្វើមិនឱ្យតំណក់ទឹកតូចៗទាំងនេះ ធ្លាក់ចុះមកដោយងាយបានដែរ។ ពពក ដែលយើងមើលឃើញនៅក្នុងបរិយាកាសមានលក្ខណៈខុសៗគ្នា គឺអាស្រ័យទៅលើអ្វីៗ ដែលបានបង្កើតវាឡើង។ ពពកដែលមានតំណក់ទឹក គឺមានគែមរាងស្រួច។ ប្រសិនបើពពកក្រាស់ មានចំហាយទឹកច្រើន គឺយើងមើលទៅមានពណ៌ប្រផេះ ឬខ្មៅ។ ការណ៍ដែលយើងមើលឃើញដូចនេះ ដោយសារតែពន្លឺព្រះអាទិត្យមិនអាចឆ្លងកាត់បាន។ ពពកដែលមានក្រាមទឹកកក គឺមានគែមរាងដូចជារោមសត្វ ឬស្បៃ ហើយមើលទៅមានពណ៌ស។

ពពកទាំងអស់បានកកើតឡើងនៅក្នុងបរិយាកាស។ ពពកមានច្រើនប្រភេទ តាមរូបរាង និងកម្ពស់របស់វានៅក្នុងបរិយាកាស ក៏ប៉ុន្តែប្រភេទសំខាន់របស់វាមាន ៣ គឺ ពពកផ្កាស្លែ ពពកអន្លាយ និងពពកស្បៃ។

### ២.៣.១. ពពកអន្លាយ

ពពកអន្លាយមានទម្រង់ជាស្រទាប់ពណ៌ប្រផេះ មានទំហំធំ ហើយតែងតែបាំងពន្លឺព្រះអាទិត្យ និងមានរយៈកម្ពស់ប្រហែល ២ ៥០០ ម៉ែត្រ គឺជាពពកជាន់ទាប និងមធ្យម។ ពពកប្រភេទនេះ បានកកើតឡើង ដោយសារការរសាត់យឺតៗនៃខ្យល់ក្នុងបរិយាកាស ហើយតែងតែបង្កើតឱ្យមានភ្លៀងបើកថ្ងៃ ឬភ្លៀងរលឹម។ ពពកអន្លាយដែលមានពណ៌ខ្មៅហៅថា ពពកអន្លាយណាំប៊ូស តែងតែបង្កើតឱ្យមានភ្លៀងធ្លាក់ ឬព្រិល និងរន្ទះខ្លាំងៗ។

ពពកអន្លាយ ដែលកកើតឡើងនៅជិតផ្ទៃដីហៅថា អព្ទ។ អព្ទនេះ កកើតឡើងនៅពេលដែលខ្យល់នៅជិតនឹងផ្ទៃដីចុះត្រជាក់ឆាប់ក្នុងពេលយប់ ឬពេលព្រឹកព្រលឹម។ នៅពេលថ្ងៃ សីតុណ្ហភាពឡើងកម្ដៅ នៅពេលនោះអព្ទក៏ចាប់ផ្ដើមរលាយបាត់អស់ពីបរិយាកាសជិតផ្ទៃដី។

*ពពកជាន់ទាប ពពកមធ្យម និងពពកជាន់ខ្ពស់*




### ២.៣.២. ពពកផ្កាស្ពៃ

ពពកផ្កាស្ពៃមានសណ្ឋានដូចជាគំនរសំឡីអណ្ដែតនៅលើមេឃ ហើយស្ថិតនៅក្នុងរយៈកម្ពស់ប្រហែល ២ ៥០០ ម៉ែត្រ ទៅ ១៣ ៥០០ ម៉ែត្រ។ ពពកប្រភេទនេះ តែងតែកកើតឡើងនៅពេលខ្យល់អណ្ដែតឡើងទៅលើនៅពេលមេឃស្រឡះ ប៉ុន្តែពេលខ្លះវាបង្កើតបានជាផ្ទាំងពពកធំ ដែលបណ្ដាលឱ្យមានព្យុះភ្លៀង ផ្គរ និងរន្ទះ។

### ២.៣.៣. ពពកស្បៃ

ពពកស្បៃមានសណ្ឋានស្ដើង ស្រាល និងស្ថិតនៅរយៈកម្ពស់ខ្ពស់ចាប់ពីចន្លោះប្រហែលជា ៦ ០០០ ម៉ែត្រ ទៅ ១២ ០០០ ម៉ែត្រ។ ពពកប្រភេទនេះ កកើតឡើងពីក្រាមទឹកកក។ គេអាចមើលឃើញពពកស្បៃនេះ នៅពេលមេឃស្រឡះ ប៉ុន្តែពពកនេះអាចបណ្ដាលឱ្យមានភ្លៀងធ្លាក់ ឬព្រិលផងដែរ បន្ទាប់ពីប៉ុន្មានម៉ោងក្រោយមក។

## ២.៤. កំណកអាកាស

កំណកអាកាស គឺជាទម្រង់ផ្សេងៗនៃទឹក ដែលធ្លាក់ចុះពីក្នុងបរិយាកាសមកលើផ្ទៃដី។ តាមធម្មតា កំណកអាកាសអាចកើតមានឡើងបាន លុះត្រាតែសំណើមដាច់ខាតមានលើសពីអត្រាចម្អែត នៃចំហាយទឹក។ ដូចនេះនៅក្នុងបរិយាកាស ម៉ាសខ្យល់ទាំងឡាយណា ដែលមានសីតុណ្ហភាពត្រជាក់ធ្លាក់ចុះហួសពីសីតុណ្ហភាពរបស់អត្រាសំណើមអាកាស នោះចំហាយទឹកមួយភាគនៅក្នុងម៉ាសខ្យល់ទាំងនោះត្រូវកែជាទឹក។

កត្តាសំខាន់មួយ ដែលធ្វើឱ្យម៉ាសខ្យល់ចុះត្រជាក់ គឺសំទុះខ្យល់ឡើងទៅលើ ដែលបណ្តាល មកពីកំដៅដី ចលនាវង្វល់ ឬក៏បណ្តាលមកពីសណ្ឋានដី។ ហេតុនេះ ម៉ាសខ្យល់ណាដែលស្ទុះឡើងទៅលើតែងរីកមាឌ និងមានភាពធូរស្រាល រីឯសីតុណ្ហភាពក៏ចុះត្រជាក់ផងដែរ។ ភាពត្រជាក់នេះ គឺជាដើមហេតុ ដែលបណ្តាលឱ្យកកើតកំណកអាកាសឡើង។ នៅក្នុងបរិយាកាស កំណកអាកាសកើតមានឆាប់រហ័ស លុះត្រាតែនៅក្នុងខ្យល់អាកាសមានគ្រាប់កំណកផងដែរ។ គ្រាប់កំណកទាំងនេះ អាចជាដុំរឹងល្អិតៗទាំងឡាយណាដែលមាននៅក្នុងអាកាសដូចជា ធូលី ផ្សែង តំណក់ទឹកសមុទ្រ ដែលរសាត់តាមខ្យល់ ឬជាអ៊ីយ៉ុងក៏មាន។ ដំបូង កំណកទឹកកកកើតឡើងនៅជុំវិញគ្រាប់កំណកនីមួយៗ រួចទើបកើតមានកំណកបន្ទាប់ៗទៅទៀត។

**២.៤.១. ប្រភេទកំណកអាកាស**

ជាទូទៅ កំណកអាកាសមានទម្រង់សំខាន់ៗ ៤ ប្រភេទ ដែលរួមមាន ទឹកភ្លៀង ភ្លៀងលាយព្រិល ទឹកកក និងព្រិល។

- **ទឹកភ្លៀង**

ទឹកភ្លៀង គឺជាកំណកអាកាសដែលស្ថិតនៅក្នុងទម្រង់រូបភាពរាវ ហើយធ្លាក់ពីពពកនៅក្នុងបរិយាកាសមកលើផ្ទៃផែនដី។ ពពកបង្កើតទឹកភ្លៀងបានលុះត្រាតែតំណក់ទឹកតូចៗរីកកាន់តែធំឡើងៗមិនអាចអណ្តែតក្នុងបរិយាកាសបាន រួចក៏ធ្លាក់មកលើផែនដី។ តំណក់ទឹកតូចៗ ឬកំណជាញើសមួយគ្រាប់ពពកមានទំហំប្រហែល ២០ មីក្រូម៉ែត្រ (១ មីក្រូម៉ែត្រ=0.000១ សងទីម៉ែត្រ=0.00000១ ម៉ែត្រ) ក្លាយជាគ្រាប់ពពកដែលមានទំហំប្រហែល ២០ មីក្រូម៉ែត្រ។ មុនពេលគ្រាប់ពពកធ្លាក់ចុះមកជាគ្រាប់ភ្លៀង វាត្រូវកើនទំហំរបស់វាប្រហែល ២០០០មីក្រូម៉ែត្រ ទើបវាអាចធ្លាក់ចុះមកបាន។ ជាទូទៅ កំណកអាកាស ដែលអាចធ្លាក់មកក្នុងទម្រង់ជាគ្រាប់ទឹកភ្លៀងបាន លុះត្រាណាតែគ្រាប់ក្រាមនៃដុំទឹកកកទាំងនោះបានធ្លាក់ចុះមក ដោយឆ្លងកាត់ខ្យល់ក្តៅនៅក្បែរនឹងផ្ទៃដី។

- **ភ្លៀងលាយព្រិល**

ភ្លៀងលាយព្រិល គឺជាកំណកអាកាស ក្នុងទម្រង់ជាទឹកភ្លៀងលាយព្រិល ឬលាយដុំទឹកកក។ ភ្លៀងលាយព្រិលនេះ បានកកើតឡើងនៅពេលទឹកភ្លៀងធ្លាក់ចុះមកផ្ទៃដី ដោយឆ្លងកាត់ស្រទាប់ខ្យល់ត្រជាក់ខ្លាំង ហើយបានកកជាទឹកកក។ ជាលទ្ធផល គឺមានការកកើតឡើងនូវបំណែករឹង នៃដុំទឹកកក
នេះឡើង។

ភ្លៀងលាយព្រិលធ្វើឱ្យមានដុំទឹកកកធ្លាក់ចុះមកជាមួយនឹងទឹកភ្លៀង។ ជួនកាល ទឹកភ្លៀងធ្លាក់ចុះមកមិនបានកកនោះទេ ក៏ប៉ុន្តែនៅពេលដែលវាធ្លាក់មកជិតដល់ផ្ទៃដី ដោយសារវាបានឆ្លងកាត់នឹងស្រទាប់ខ្យល់ត្រជាក់ខ្លាំង វាក៏ក្លាយទៅជាទឹកកក ដែលមានសណ្ឋានដូចជាកញ្ចក់ទឹកកក។

- **ភ្លៀងទឹកកកសំឡី**

ភ្លៀងទឹកកកសំឡី គឺជាកំណកអាកាសក្នុងទម្រង់រឹង ដែលកកើតឡើងនៅពេលសីតុណ្ហភាពចុះត្រជាក់ខ្លាំងនៅក្នុងបរិយាកាស ហើយចំហាយទឹកបានផ្លាស់ប្តូររូបភាព ពីឧស្ម័នទៅជារឹងដោយផ្ទាល់តែម្តង ដោយមិនបានឆ្លងកាត់តំណាក់កាលជារូបភាពរាវនោះឡើយ។ ទឹកកកអាចធ្លាក់មកជាទឹកកកគ្រីស្តាល់ ឬលាយជាមួយទឹកកកស្តើងៗ ស្រាល ដែលមានសណ្ឋានរាងប្រាំមួយជ្រុង ដោយសារតែវាបានឆ្លងកាត់សីតុណ្ហភាព

ខ្យល់នៅជាប់នឹងផ្ទៃដីត្រជាក់ខ្លាំង។ បន្សុំ នៃរូបសណ្ឋានជាទឹកកកគ្រីស្តាល់ទាំងនេះ បង្កើតឱ្យមានលំនាំដ៏ប្រណីត និងសាំញ៉ាំនៃទឹកកក។

- **ភ្លៀងព្រិល**

ភ្លៀងព្រិល គឺជាទម្រង់នៃកំណកអាកាស ដែលមានសណ្ឋានជាបាល់ ឬជាដុំមូលនៃទឹកកក ដោយមានទំហំពី ៥ ទៅ ៧៥ ម.ម។ វាមានរចនាសម្ព័ន្ធជាស្រទាប់ ដែលជារឿយៗកកើតមានឡើងជាប់ទាក់ទងនឹងចរន្តរង្វល់ដ៏ខ្លាំងនៃពពកផ្គរស្ទែ ឬពពកគុយមុលណាំប៊ុស។

ភ្លៀងព្រិលជាទម្រងនៃកំណកអាកាស ដែលកើតមានឡើងដោយកម្រ បើធៀបទៅនឹងទម្រង់ទាំងបីនៃកំណកអាកាសខាងលើ។ ដុំព្រិលបានកកើតឡើង នៅពេលដែលគ្រាប់ទឹកកកប៉ះនឹងតំណក់ទឹកជាច្រើននៅក្នុងពពក ហើយកក។ បើចលនារបស់ខ្យល់បក់ឡើងលើខ្លាំងគ្រប់គ្រាន់ ដុំព្រិលនឹងស្ថិតនៅពីលើកម្រិតកំណកបានយូរ។ បើមានតំណក់ទឹកកាន់តែច្រើនមកប៉ះនឹងវានោះដូចជាបន្ថែមស្រទាប់ទឹកកកកាន់តែច្រើនឱ្យវា ហើយដុំព្រិលកាន់តែរីកធំ ធ្ងន់ ហើយក៏ធ្លាក់ចុះមកលើផ្ទៃដី។

### ២.៤.២. ប្រភពកំណើតនៃកំណកអាកាស

គេអាចធ្វើចំណែកថ្នាក់នៃប្រភពកំណើតទឹកភ្លៀងជា ៤ ប្រភេទគឺ ភ្លៀងរង្វល់ ភ្លៀងសណ្ឋានដី ភ្លៀងតំបន់ឆ្នេរ និងភ្លៀងព្យុះ ឬភ្លៀងច្របល់បរិយាកាស ឬភ្លៀងព្រំខ្យល់ ដោយផ្អែកទៅលើរបៀប ឬវិធីដែលទឹកភ្លៀងទាំងនោះ កកើតឡើង។

- **ភ្លៀងរង្វល់**

ភ្លៀងរង្វល់បណ្តាលមកពីខ្យល់ក្តៅនៅជិតៗនឹងផ្ទៃដីស្ទុះឡើងទៅលើ គឺចលនាស្ទុះឡើង។ គេអាចសង្កេតឃើញមានភ្លៀងសម្ពាធខ្សោយ ពិសេសនៅតំបន់ត្រូពិច។ ភ្លៀងរង្វល់កកើតឡើង នៅពេលមានការដុតកម្តៅផ្ទៃរបស់ផែនដីដ៏ខ្លាំងក្លា ដែលជាញឹកញាប់បានកកើតមានឡើងនៅពេលថ្ងៃរសៀល។ នៅពេលដែលខ្យល់ពីលើផ្ទៃដីត្រូវបានដុតកម្តៅយ៉ាងខ្លាំងក្លានោះ វាបានស្ទុះឡើងទៅលើ ដោយនាំយកទាំងចំហាយទឹកទៅជាមួយវាផងដែរ ហើយក្រោយមក វាបង្កឱ្យកកើតឡើងជាពពកគុយមុលណាំប៊ុសយ៉ាងក្រាស់ លុះដល់ថ្ងៃជិតលិច អាកាសកាន់តែត្រជាក់ឡើងៗ ក៏បណ្តាលឱ្យមានភ្លៀងធ្លាក់ចុះ។

ជារឿយៗ ភ្លៀងប្រភេទនេះបានធ្លាក់នៅលើតំបន់តូចមួយ ដែលគ្របដណ្តប់ពី ២ ទៅ ៣ គីឡូម៉ែត្រការេតែប៉ុណ្ណោះ។ ជាធម្មតា វាជាប្រភេទភ្លៀងធ្លាក់ខ្លាំង ក៏ប៉ុន្តែបានកើតមានឡើងតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ នៅពេលរសៀល ឬនៅពេលព្រះអាទិត្យរៀបលិច ហើយជាញឹកញាប់ក៏បង្កឱ្យមានជារន្ទះ និងផ្លេកបន្ទោរកើតឡើងជាមួយផងដែរ។

- **ភ្លៀងសណ្ឋានដី**

ភ្លៀងសណ្ឋានដី បានកើតមានឡើងជាសំខាន់នៅទីកន្លែងមួយចំនួន ដែលខ្យល់សើមបក់មកពីសមុទ្រត្រូវបានបានរុញឱ្យងើបឡើងលើតាមជំរាលសណ្ឋានដីខ្ពស់ៗដូចជា ខ្ពង់រាប ជួរភ្នំ និងកូនភ្នំជាដើម។

នៅពេលដែលខ្យល់បក់កាត់ផ្ទៃសមុទ្រ ឬបឹងនានា វាបានប្រមូលយកនូវបរិមាណចំហាយទឹកយ៉ាងច្រើនពីទឹក។ ជាលទ្ធផល សំណើមប្រៀបធៀបនៅក្នុងខ្យល់បានកើនឡើង។ ប្រសិនបើមានជួរភ្នំនៅជិតៗខ្យល់ត្រូវបានរុញឱ្យបក់ងើបឡើងទៅលើតាមជំរាលនៃជួរភ្នំនោះ។ នៅពេលដែលខ្យល់ងើបឡើងទៅលើតាម

ជំរាលនៃសណ្ឋានដីខ្ពស់ៗ សីតុណ្ហភាពក៏ចុះត្រជាក់ រីឯចំហាយទឹកដែលនៅក្នុងខ្យល់ចាប់ផ្តើមកកបន្តិចម្តងៗ រួចបានកកើតជាទឹកភ្លៀងធ្លាក់។ ចំណោត ដែលស្ថិតនៅចំពីមុខខ្យល់ ក៏សើម ហើយបង្កើតឱ្យមានភ្លៀងធ្លាក់ច្រើន។ ចំណែកឯចំណោតម្ខាងទៀត ខ្យល់ខ្សោះអស់ចំហាយទឹកជ្រាលចុះតាមចំណោតមកខាងក្រោម ហើយឡើងក្តៅបន្តិចម្តងៗ រួចក៏ក្លាយទៅជាខ្យល់ក្តៅស្ងួត។

នៅប្រទេសកម្ពុជាយើង គេអាចសង្កេតឃើញបាតុភូតនេះនៅតំបន់ខ្ពស់ៗដូចជា ជួរភ្នំក្រវាញ និងខ្ពង់រាបឦសាន។ នៅតំបន់ជួរភ្នំក្រវាញ ខ្យល់មូសុងវស្សា ដែលបក់ពីទិសនិរតីមកប៉ះនឹងជួរភ្នំនេះបានបង្កឱ្យមានភ្លៀងធ្លាក់ច្រើននៅប៉ែកនិរតីនៃជួរភ្នំនេះ។

- **ភ្លៀងតំបន់ឆ្នេរ**

តំបន់ឆ្នេរសមុទ្រ ទោះបីមិនមែនជាតំបន់ខ្ពស់ក្តី ក៏តំបន់នេះសម្បូរភ្លៀងធ្លាក់ច្រើនដែរ។ ខ្យល់ដែលបក់មកពីសមុទ្រជាខ្យល់ ដែលមានសំណើមខ្ពស់។ នៅពេលដែលខ្យល់នេះ បក់មកប៉ះនឹងផ្ទៃដី វាបានស្ទុះឡើងទៅលើ រួចបានក៏កើតជាភ្លៀងធ្លាក់។ ហេតុដូចនេះហើយ បានជានៅប្រទេសកម្ពុជាយើង នៅតំបន់មាត់សមុទ្រមានខេត្តមួយចំនួនដូចជា ខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពតជាដើមមានភ្លៀងធ្លាក់ច្រើនជាងតំបន់ទំនាបកណ្តាលដូចជា រាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំជាដើម។

- **ភ្លៀងច្របល់បរិយាកាស**

ភ្លៀងព្យុះ ឬភ្លៀងច្របល់បរិយាកាស ឬភ្លៀងព្រំខ្យល់កកើតមានឡើង នៅពេលដែលម៉ាសខ្យល់ពីរបានជួបគ្នា ហើយក៏បង្កើតឱ្យមានច្របល់បរិយាកាសកើតឡើង។ នៅពេលដែលម៉ាសខ្យល់ក្តៅ ដែលមានសំណើមបក់ឆ្លងកាត់លើផ្ទៃដីទៅប៉ះនឹងម៉ាសខ្យល់ត្រជាក់ស្ងួត ខ្យល់ក្តៅក៏អណ្តែតឡើងទៅលើ ហើយបន្ទាប់ទៀតខ្យល់នេះក៏ចុះត្រជាក់ ហើយក៏កកក្លាយទៅជាពពកគុយម៉ុលណាំប៊ុស។ ក្រោយពីមានច្របល់នៃចលនាខ្យល់ឡើង និងចុះ ភ្លៀងក៏បានចាប់ផ្តើមធ្លាក់។

### ២.៥. សម្ពាធអាកាស

សម្ពាធអាកាស គឺជាទម្ងន់នៃអាកាស ដែលសង្កត់មកលើផ្ទៃដី។ ឧស្ម័ន និងភាគល្អិតតូចៗ ដែលរសាត់អណ្តែតនៅក្នុងបរិយាកាសសុទ្ធសឹងតែមានម៉ាស។ ដូច្នេះ ទំនាញផែនដីបានទាញអាកាស ឬបរិយាកាសឱ្យធ្លាក់ចុះមកក្រោម។

សម្ពាធអាកាស តែងតែប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយនៅលើផែនដី។ កាលណាខ្យល់កាន់តែធ្ងន់ ម៉ាសមាឧខ្យល់កាន់តែធំ ហើយសម្ពាធដែលសង្កត់មកលើផ្ទៃផែនដី ក៏កាន់តែខ្លាំងផងដែរ។ សម្ពាធបរិយាកាសធម្មតាគឺស្មើនឹងកម្ពស់បារត ៧៦០ មីលីម៉ែត្រ ឬ ១ ០១៥ មីលីបារ។ ១ មីលីបារស្មើនឹងបារត ០.៧៥ មីលីម៉ែត្រ។ បើសម្ពាធមានលើសពី ១ ០១៥ មីលីបារ ឬខ្ពស់ជាង ៧៦០ មីលីម៉ែត្រ ហៅថាសម្ពាធខ្លាំង ឬសម្ពាធខ្ពស់។ បើសម្ពាធមានទាបជាង ៧៦០ មីលីបារ ហៅថាសម្ពាធខ្សោយ ឬ សម្ពាធទាប។

មានកត្តាជាច្រើនដែលជះឥទ្ធិពលទៅលើសម្ពាធអាកាស។ កត្តាទាំងនោះរួមមានសីតុណ្ហភាព រយៈកម្ពស់ សំណើមអាកាស និងបណ្តុំខ្យល់។

### ២.៥.១. សីតុណ្ហភាព

នៅពេលដែលខ្យល់ក្តៅ ម៉ូលេគុលរបស់វាធ្វើដំណើរលឿន ហើយឃ្លាតឆ្ងាយពីគ្នា ធ្វើឱ្យខ្យល់មានដង់ស៊ីតេទាប។ នៅពេលដែលខ្យល់ត្រជាក់ ម៉ូលេគុលរបស់វារំកិលមកជិតគ្នា ធ្វើឱ្យខ្យល់មានដង់ស៊ីតេខ្ពស់។ អាស្រ័យហេតុនេះ ខ្យល់ត្រជាក់មានដង់ស៊ីតេខ្ពស់ជាងខ្យល់ក្តៅ ហើយសម្ពាធក៏សង្កត់មកលើផែនដីខ្លាំងជាងខ្យល់ក្តៅផងដែរ។ ដូចនេះ ការប្រែប្រួលសីតុណ្ហភាព គឺបណ្តាលឱ្យមានបំលាស់ប្តូរ សម្ពាធអាកាស។

នៅតំបន់ក្តៅ បរិយាកាសស្រទាប់ក្រោមមានសីតុណ្ហភាពខ្ពស់។ ពេលនោះ ខ្យល់ក្តៅអណ្តែតឡើងទៅលើ ហើយក៏ស្រាល ចំណែកឯសម្ពាធក៏ចុះទាបជាងមធ្យមផងដែរ។ តំបន់នេះ ក៏ក្លាយទៅជាតំបន់សម្ពាធខ្សោយ ដែលមានសម្ពាធទាបជាងកម្ពស់បារត ៧៦០ មីលីបារ។

នៅតំបន់ត្រជាក់ បរិយកាសមានសីតុណ្ហភាពទាប។ ពេលនោះ ខ្យល់ត្រជាក់ធ្លាក់ចុះមកលើផ្ទៃដី បណ្តាលឱ្យតំបន់នេះក្លាយទៅជាតំបន់សម្ពាធខ្ពស់ ដែលមានសម្ពាធលើសពី ៧៦០ មីលីបារ។ នៅតំបន់មណ្ឌលសម្ពាធខ្សោយ ខ្យល់មានចលនារួមចូល ហើយអណ្តែតឡើងទៅលើ។ ផ្ទុយទៅវិញ នៅតំបន់មណ្ឌលសម្ពាធខ្លាំង ខ្យល់មានចលនារីកចេញ ហើយធ្លាក់ចុះមកក្រោម។ ជាទូទៅ មណ្ឌលសម្ពាធខ្លាំង តែងតែមានផ្ទៃធំជាងមណ្ឌលសម្ពាធខ្សោយ។

### ២.៥.២. សំណើមអាកាស

នៅក្នុងខ្យល់ ម៉ូលេគុលទឹកមានម៉ាសតិចជាងម៉ូលេគុលឧស្ម័នដទៃទៀត។ ដូចនេះ នៅពេលចំហាយទឹកកើនឡើង ម៉ាសខ្យល់ក៏ថយចុះ ធ្វើឱ្យខ្យល់ស្រាល ហើយមានសម្ពាធខ្សោយ។ ដូច្នេះ ខ្យល់ដែលមានចំហាយទឹកច្រើនមានដង់សីតេទាប និងមានសម្ពាធខ្សោយជាងខ្យល់ស្ងួត។

នៅលើពិភពលោកយើងនេះ តំបន់ដែលមានរំហួតខ្លាំង គឺជាតំបន់សម្ពាធខ្សោយដូចជា តំបន់អេក្វាទ័រជាដើម រីឯតំបន់ដែលមានរំហួតចំហាយទឹកតិច ឬតំបន់ត្រជាក់ គឺជាតំបន់សម្ពាធខ្លាំង។

### ២.៥.៣. បណ្តុំអាកាស

បណ្តុំអាកាស ក៏មានឥទ្ធិពលទៅលើសម្ពាធអាកាសផងដែរ។ ស្រទាប់បរិយាកាសជាន់ទាបទាំងឡាយ តែងតែរលាយចូលគ្នាទាំងស្រុង ដែលបណ្តាលមកពីមានចលនាវង្វិលខ្វាល់ នៃផែនដី។ ពេលខ្លះ ខ្យល់បក់ចុះឡើង ជួនកាលយឺត អាចគរ ឬផ្តុំគ្នានៅកន្លែងណាមួយតាមបណ្តោយខ្សែស្របខ្លះ (ជួនកាលនៅត្រង់តំបន់ត្រូពិច) ហើយក៏បង្កើតជាមណ្ឌលសម្ពាធខ្លាំង ដែលគេហៅថាមណ្ឌលសម្ពាធខ្លាំងសកម្ម (មណ្ឌលសម្ពាធខ្ពស់នៅតាមបណ្តោយខ្សែត្រូពិចទាំងពីរនៃផែនដី)។

### ២.៥.៤. រយៈកម្ពស់

រយៈកម្ពស់ ក៏បានជះឥទ្ធិពលទៅលើសម្ពាធអាកាសផងដែរ។ កាលណារយៈកម្ពស់កើនឡើង ខ្យល់រាវ ហើយស្រាល រួមផ្សំជាមួយនឹងមានវត្ថុមានឧស្ម័នកាន់តែតិចទៅៗផងនោះ បណ្តាលឱ្យសម្ពាធអាកាសក៏ថយចុះផងដែរ។

ប្រសិនបើយើងឡើងលើកំពូលភ្នំ ឬជិះយន្តហោះ នោះយើងនឹងកត់សម្គាល់ឃើញថា សម្ពាធថយចុះជាលំដាប់ ហើយជួនកាលអាធ្វើឱ្យយើងហឹងត្រចៀក ឬឈឺត្រចៀកក៏បាន។ ដោយសារសម្ពាធអាកាសប្រែប្រួល

ទៅតាម សីតុណ្ហភាព ចំហាយទឹក បណ្ដុំខ្យល់បក់ ទើបគេសន្មតយករង្វាស់សម្ពាធអាកាសនៅចំណុច សូន្យអង្សារសេ ពីនីវ៉ូទឹកសមុទ្រ។

### ២.៦. ខ្យល់បក់

ខ្យល់បក់កើតឡើងដោយសារតែសម្ពាធខ្យល់ពីរខុសគ្នា ឬតំបន់ពីរមានសីតុណ្ហភាពខុសគ្នា។ ភាពខុសគ្នានៃសម្ពាធខ្យល់ នៅក្នុងតំបន់ខុសៗគ្នា ឬទីកន្លែងខុសៗគ្នា បណ្ដាលឱ្យខ្យល់បក់ពីតំបន់មួយទៅតំបន់មួយ ឬពីកន្លែងមួយទៅកន្លែងមួយទៀតនៅលើផែនដី។ កាលណាសម្ពាធខុសគ្នាកាន់តែខ្លាំង ខ្យល់ធ្វើចលនា ឬបក់កាន់តែលឿន។ ភាពខុសគ្នានៃសម្ពាធខ្យល់គឺបណ្ដាលមកពីកម្ដៅមិនស្មើគ្នានៅលើផែនដី។

ខ្យល់បក់ គឺជាចលនារបស់ខ្យល់ដែលរសាត់ចេញពីតំបន់ដែលមានសម្ពាធខ្ពស់ទៅកាន់តំបន់ ដែលមានសម្ពាធទាប។ ឧទាហរណ៍ ៖ ខ្យល់នៅតំបន់អេក្វាទ័រក្ដៅ ហើយស្រាលស្ទុះឡើងលើ បណ្ដាឱ្យតំបន់នេះមានសម្ពាធទាប។ រីឯខ្យល់នៅតំបន់ប៉ូលវិញត្រជាក់ និងធ្ងន់ ហើយធ្លាក់ចុះ ធ្វើឱ្យតំបន់នេះមានសម្ពាធខ្លាំង។ ភាពខុសគ្នានៃសម្ពាធ ក្នុងបរិយាកាសនៅតំបន់អេក្វាទ័រ និងតំបន់ប៉ូលជាមូលហេតុធ្វើឱ្យខ្យល់មានចលនា។ ជាទូទៅ ខ្យល់ធ្វើដំណើរចេញពីតំបន់ប៉ូលទៅកាន់តំបន់អេក្វាទ័រ ពោលគឺធ្វើដំណើរពីតំបន់សម្ពាធខ្ពស់ទៅកាន់តំបន់សម្ពាធទាប។

អឌ្ឍគោលខាងជើង និងអឌ្ឍគោលខាងត្បូងនៃផែនដី បានឆ្លងកាត់នូវសិសិររដូវ និងវស្សានរដូវនៅពេលវេលាខុសៗគ្នា ក្នុងរយៈពេលមួយឆ្នាំ។ ភាពខុសគ្នានៃសីតុណ្ហភាពនេះ គឺបណ្ដាលឱ្យមានសម្ពាធខុសគ្នារវាងអឌ្ឍគោលទាំងពីរផងដែរ ដែលជាហេតុបណ្ដាលឱ្យខ្យល់បក់កើតមានឡើង។ នៅពេលដែលខ្យល់បក់ផ្លាស់ទីឆ្លងកាត់នៅលើផ្ទៃផែនដី វាមិនមែនបក់តាមទិសដៅត្រង់នោះទេ គឺវាបានបក់តាមទិសវេរ តាមលំនាំមួយរាងកោង។ ខ្យល់ ដែលបក់តាមទិសដៅវេរនេះ គឺបណ្ដាលមកពីឥទ្ធិពលនៃកម្លាំងកូរីយ៉ូលីស ដែលកើតឡើងដោយសារតែចលនារង្វិលខ្វាល់របស់ផែនដី។ ឥទ្ធិពល នៃកម្លាំងកូរីយ៉ូលីស គឺមិនបានជះឥទ្ធិពលទៅលើខ្យល់បក់នៅតំបន់អេក្វាទ័រនោះទេ ក៏ប៉ុន្តែនៅពេលដែលយើងផ្លាស់ទីឆ្ពោះទៅកាន់តំបន់ប៉ូល ឥទ្ធិពលនៃកម្លាំងកូរីយ៉ូលីសមានសភាពកាន់តែខ្លាំងឡើងៗ ពោលគឺធ្វើឱ្យខ្យល់បក់វេរកាន់តែខ្លាំងឡើងៗ។

ដោយសារតែចលនារង្វិលខ្វាល់របស់ផែនដី បានធ្វើឱ្យខ្យល់នៅលើផែនដីបក់វេរទៅតាមទិសដៅខុសៗគ្នា នៅអឌ្ឍគោលខាងជើង និងអឌ្ឍគោលខាងត្បូង។ ខ្យល់បានបក់វេរទៅទិសខាងស្ដាំនៅអឌ្ឍគោលខាងជើង និងវេរទៅទិសខាងឆ្វេងនៅអឌ្ឍគោលខាងត្បូង។

ខ្យល់បក់អាចកកើតមានឡើងក្នុងទ្រង់តូច ឬធំ។ ខ្យល់ដែលអាចកើតមានក្នុងទ្រង់ទ្រាយតូចត្រូវបានគេហៅថា **ខ្យល់ប្រចាំទី** រីឯខ្យល់ក្នុងទ្រង់ទ្រាយធំត្រូវបានគេហៅថា **ខ្យល់ប្រចាំតំបន់**។ ដូចនេះ ខ្យល់បក់មាន ២ ប្រភេទធំៗ គឺខ្យល់បក់ប្រចាំទី និងខ្យល់តំបន់។

#### ២.៦.១. ខ្យល់បក់ប្រចាំទី

ខ្យល់បក់ប្រចាំទី គឺជាខ្យល់ ដែលមានទំហំ ឬទ្រង់ទ្រាយតូច ហើយធ្វើចលនាក្នុងរយៈចម្ងាយខ្លី និងអាចបក់មកពីគ្រប់ទិសទី។ ខ្យល់បក់ប្រចាំទីទទួលឥទ្ធិពលពីភូមិសាស្ត្ររបស់តំបន់មួយ។ ភូមិសាស្ត្រតំបន់ដូចជា សមុទ្រ ឬភ្នំ ជួនកាលតំបន់ទាំងពីរនេះមានសីតុណ្ហភាពខុសគ្នា ហើយបង្កើតបានជាខ្យល់បក់ប្រចាំទីឡើង។ ខ្យល់បក់ប្រចាំទីរួមមាន ខ្យល់ជំនោរសមុទ្រ ខ្យល់ជំនោរទ្វីប និងខ្យល់មូសុង។

- **ខ្យល់ជំនោរសមុទ្រ**

ខ្យល់ជំនោរសមុទ្រ គឺជាខ្យល់ដែលបក់ចេញពីផ្ទៃសមុទ្រសំដៅមកផ្ទៃទ្វីបនៅពេលថ្ងៃ។ នៅពេលថ្ងៃ ផ្ទៃដីបានស្រូប និងផុតកម្ដៅត្រឡប់ទៅក្នុងបរិយាកាសវិញលឿនជាងផ្ទៃទឹកសមុទ្រ ជាហេតុធ្វើឱ្យខ្យល់នៅពីលើផ្ទៃទ្វីបក្ដៅ ហើយស្រាលអណ្ដែតឡើងលើបង្កើតឱ្យមានជាតំបន់សម្ពាធទាបនៅលើផ្ទៃទ្វីប។ រីឯនៅលើផ្ទៃសមុទ្រវិញ ផ្ទៃទឹកបានស្រូប និងផុតកំដៅត្រឡប់ចូលទៅក្នុងបរិយាកាសវិញមានល្បឿនយឺតជាងផ្ទៃដី ជាហេតុធ្វើឱ្យខ្យល់នៅពីលើផ្ទៃសមុទ្រមានកំហាប់ និងត្រជាក់ជាងផ្ទៃទ្វីប ដែលបង្កើតឱ្យមានជាតំបន់សម្ពាធខ្ពស់នៅពីលើផ្ទៃទឹកសមុទ្រ។

ជាទូទៅ ដោយសារតែខ្យល់បក់តែងតែបក់ពីតំបន់សម្ពាធខ្ពស់សំដៅទៅតំបន់សម្ពាធទាប ជាហេតុធ្វើឱ្យខ្យល់បក់ពីសមុទ្រ សំដៅទៅផ្ទៃទ្វីប ពីព្រោះផ្ទៃទឹកសមុទ្រមានសម្ពាធខ្ពស់ជាងផ្ទៃដីទ្វីប។ ជាទូទៅ ខ្យល់ជំនោរសមុទ្រតែងតែមានឥទ្ធិពលទៅលើតំបន់ឆ្នេរសមុទ្រនានា ពីព្រោះវាបានជួយបន្ទាបនូវសីតុណ្ហភាពពេលថ្ងៃនៅតំបន់ទាំងនោះ។

- **ខ្យល់ជំនោរទ្វីប**

ខ្យល់ជំនោរទ្វីប គឺជាខ្យល់ដែលបានបក់ចេញពីផ្ទៃទ្វីបសំដៅទៅសមុទ្រនៅពេលយប់។ នៅពេលយប់ ផ្ទៃទ្វីបបានបាត់បង់នូវកម្ដៅ ឬចុះត្រជាក់លឿនជាងផ្ទៃសមុទ្រ ដែលជាហេតុធ្វើឱ្យខ្យល់ពីលើផ្ទៃទ្វីបបានចុះត្រជាក់ និងធ្លាក់ចុះ ហើយក៏បង្កើតឱ្យមានជាតំបន់សម្ពាធខ្ពស់នៅលើផ្ទៃទ្វីប។ រីឯនៅលើផ្ទៃសមុទ្រវិញ ផ្ទៃទឹកបានបាត់បង់កម្ដៅ ឬចុះត្រជាក់យឺតៗជាងផ្ទៃទ្វីប ដែលជាហេតុធ្វើឱ្យសម្ពាធខ្យល់នៅពីលើផ្ទៃសមុទ្រមានសីតុណ្ហភាពក្ដៅជាងនៅលើផ្ទៃទ្វីប ហើយក៏បង្កើតឱ្យមានជាតំបន់សម្ពាធទាបពីលើផ្ទៃសមុទ្រ។ ដោយសារតែនៅលើផ្ទៃទ្វីបមានសម្ពាធខ្ពស់ជាងនៅលើផ្ទៃសមុទ្រ ជាហេតុបណ្ដាលឱ្យខ្យល់បក់ចេញពីផ្ទៃទ្វីប ហើយសំដៅទៅកាន់ផ្ទៃសមុទ្រវិញនៅពេលយប់។

- **ខ្យល់មូសុង**

ខ្យល់ជំនោរសមុទ្រ និងខ្យល់ជំនោរទ្វីបដែលមានទំហំធំ គឺខ្យល់មូសុង។ ខ្យល់មូសុង គឺជាខ្យល់រដូវដែល ៦ ខែបក់ចេញពីទ្វីបទៅសមុទ្រ និង ៦ ខែបក់ចេញពីសមុទ្រសំដៅទៅរកទ្វីបវិញ។ នៅពេលដែលខ្យល់នេះបក់ចេញពីសមុទ្រទៅរកទ្វីប វាបាននាំទាំងកម្ដៅ និងសំណើមអាកាសមកជាមួយផងដែរ ធ្វើឱ្យមានភ្លៀងធ្លាក់យ៉ាងច្រើនដែលបង្កើតបានជា រដូវវស្សា។ ខ្យល់មូសុង គឺជាខ្យល់រដូវ ដែលបក់កាត់ផ្ទៃផែនដី ដោយសារតែនៅអឌ្ឍគោលខាងជើង និងនៅអឌ្ឍគោលខាងត្បូងបានឆ្លងកាត់រដូវពីរខុសៗគ្នា គឺរដូវប្រាំង និងរដូវវស្សា ពីព្រោះតែព្រះអាទិត្យមានទីតាំងខុសគ្នានៅលើអឌ្ឍគោលទាំងពីរនេះ ពោលគឺ ៦ ខែនៅស្ថិតនៅអឌ្ឍគោលខាងជើង និង ៦ ខែទៀតស្ថិតនៅអឌ្ឍគោលខាងត្បូង។

ខ្យល់មូសុងបានកើតមានឡើងនៅចន្លោះមហាសមុទ្រឥណ្ឌា និងឧបទ្វីបអឺរ៉ាស៊ីដែលបានគ្របដណ្ដប់ពីអាស៊ីខាងត្បូង រហូតដល់អាស៊ីខាងកើត រួមទាំងអាស៊ីអាគ្នេយ៍ផងដែរ។ ខ្យល់នេះ ត្រូវបានបង្កឡើងដោយសារតែការផុតកម្ដៅ និងការចុះត្រជាក់យ៉ាងខ្លាំងនៃម៉ាសដីដ៏ធំ។ ជាទូទៅ ខ្យល់មូសុងមាន ២ ប្រភេទ គឺ មូសុងនិរតី ឬមូសុងវស្សា និងមូសុងឦសាន ឬមូសុងប្រាំង។

- **ខ្យល់មូសុងនិរតី ឬមូសុងវស្សា**

ខ្យល់មូសុងនិរតី ឬមូសុងវស្សា គឺជាខ្យល់ ដែលបក់ចេញពីទិសនិរតីសំដៅទៅទិសឦសាន។ ចាប់ពីខែឧសភា ដល់ខែតុលា នៅអឌ្ឍគោលខាងជើងបានឆ្លងកាត់នូវរស្សាន្តរដូវ (រដូវវស្សា) រីឯនៅអឌ្ឍគោលខាងត្បូងវិញបានឆ្លងកាត់នូវរដូវរំហើយ (រដូវរងារ) ដោយសារតែពេលវេលានេះ ព្រះអាទិត្យមានទីតាំងស្ថិតនៅក្នុងអឌ្ឍគោលខាងជើង។ នៅអឌ្ឍគោលខាងជើងនៅពេលនេះ គឺទទួលបានពន្លឺព្រះអាទិត្យច្រើន ជាហេតុធ្វើឱ្យខ្យល់ក្លាយទៅជាខ្យល់ក្ដៅ រីឯនៅអឌ្ឍគោលខាងត្បូងវិញ គឺទទួលបានពន្លឺព្រះអាទិត្យតិច ជាហេតុធ្វើឱ្យខ្យល់ក្លាយទៅជាខ្យល់ត្រជាក់។ ដោយសារតែខ្យល់ក្ដៅមានកំហាប់តិច ឬមានទម្ងន់ស្រាលជាងខ្យល់ត្រជាក់ ដូច្នេះក៏បង្កើតឱ្យមានតំបន់សម្ពាធទាបមួយបានគ្រប់ដណ្ដប់នៅលើឧបទ្វីបឥណ្ឌាដែលស្ថិតនៅអឌ្ឍគោលខាជើង និងតំបន់សម្ពាធខ្ពស់មួយបានគ្របដណ្ដប់នៅលើមហាសមុទ្រឥណ្ឌា និងទ្វីបអូស្ត្រាលីដែលស្ថិតនៅអឌ្ឍគោលខាងត្បូង។ ដោយសារតែតំបន់ទាំងពីរនេះមានសម្ពាធខុសគ្នា ពោលគឺនៅឧបទ្វីបឥណ្ឌាមានសម្ពាធទាប និងនៅលើមហាសមុទ្រឥណ្ឌា និងទ្វីបអូស្ត្រាលីមានសម្ពាធខ្ពស់ ជាហេតុធ្វើឱ្យខ្យល់មូសុងបក់ចេញពីមហាសមុទ្រឥណ្ឌា និងពីទ្វីបអូស្ត្រាលី ដែលស្ថិតនៅអឌ្ឍគោលខាងត្បូង សំដៅទៅកាន់ឧបទ្វីបឥណ្ឌាដែលស្ថិតនៅអឌ្ឍគោលខាងជើង។

នៅពេលដែលខ្យល់មូសុងនិរតីបក់ឆ្លងកាត់មហាសមុទ្រឥណ្ឌា វាបានទទួលយកសំណើម ឬចំហាយទឹកទៅជាមួយ ដែលបង្កឱ្យមានភ្លៀងធ្លាក់យ៉ាងជោគជាំនៅទ្វីបអាស៊ីខាងត្បូងដូចជា ប្រទេសឥណ្ឌា និងប្រទេសបង់ក្លាដេសជាដើម និងបណ្ដាប្រទេមួយចំនួនទៀតនៅទ្វីអាស៊ីអាគ្នេយ៍ដូចជាប្រទេសភូមា ប្រទេសឡាវ ប្រទេសវៀតណាម ប្រទេសថៃ ប្រទេសម៉ាលេស៊ីខាងលិច និងប្រទេសកម្ពុជាយើងជាដើម។ ខ្យល់មូសុងនិរតីបានបន្តចាប់ពីខែឧសភា ដល់ខែតុលា។ ក្នុងអំឡុងពេលខែទាំងនេះ ឧបទ្វីបឥណ្ឌា និងបណ្ដាប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍បានទទួលរងនូវធាតុអាកាសក្ដៅ ហើយសើម និងមានភ្លៀងធ្លាក់យ៉ាងជោគជាំ។

- **ខ្យល់មូសុងឦសាន ឬមូសុងប្រាំង**

ខ្យល់មូសុងឦសាន ឬមូសុងប្រាំង គឺខ្យល់ ដែលបក់ចេញពីទិសឦសានសំដៅទៅទិសនិរតី។ ចាប់ពីខែវិច្ឆិកាដល់ខែតុលា នៅអឌ្ឍគោលខាងជើងបានឆ្លងកាត់នូវសិសិររដូវ (រដូវរងារ) ចំណែកឯនៅអឌ្ឍគោលខាងត្បូងវិញ ក៏បានឆ្លងកាត់នូវរស្សាន្តរដូវវិញម្ដង (រដូវវស្សា) ដោយសារនៅពេលវេលានេះ ព្រះអាទិត្យមានទីតាំងស្ថិតនៅក្នុងអឌ្ឍគោលខាងត្បូងវិញម្ដង។ នៅអឌ្ឍគោលខាងត្បូងពេលនេះ គឺទទួលបានពន្លឺព្រះអាទិត្យច្រើន ជាហេតុធ្វើឱ្យខ្យល់ក្លាយទៅជាខ្យល់ក្ដៅ រីឯនៅអឌ្ឍគោលខាងជើងវិញ គឺទទួលបានពន្លឺព្រះអាទិត្យតិច ជាហេតុធ្វើឱ្យខ្យល់ក្លាយទៅជាខ្យល់ត្រជាក់។ ជាលទ្ធផលក៏បង្កើតឱ្យមានជាតំបន់សម្ពាធទាបមួយបានគ្រប់ដណ្ដប់នៅពីលើមហាសមុទ្រឥណ្ឌា និងនៅពីលើទ្វីបអូស្ត្រាលី ដែលស្ថិតនៅអឌ្ឍគោលខាងត្បូង និងបង្កើតឱ្យមានជាតំបន់សម្ពាធខ្ពស់មួយ បានគ្របដណ្ដប់នៅពីលើឧបទ្វីបឥណ្ឌា ដែលស្ថិតនៅអឌ្ឍគោលខាងជើង។ ដោយសារតែតំបន់ទាំងពីរនេះមានសម្ពាធខុសគ្នា ពោលគឺនៅលើឧបទ្វីបឥណ្ឌាមានសម្ពាធខ្ពស់ រីឯនៅលើតំបន់មហាសមុទ្រឥណ្ឌា និងទ្វីបអូស្ត្រាលីមានសម្ពាធទាប ជាហេតុធ្វើឱ្យខ្យល់មូសុងបក់ចេញពីឧបទ្វីបឥណ្ឌាដែលស្ថិតនៅអឌ្ឍគោលខាងជើងសំដៅទៅកាន់មហាសមុទ្រឥណ្ឌា និងទ្វីបអូស្ត្រាលី ដែលស្ថិតនៅអឌ្ឍគោលខាងត្បូងវិញម្ដង។

ក្នុងអំឡុងពេលនេះ ខ្យល់មូសុងឦសានបានបក់កាត់ទ្វីបអាស៊ី ដែលជាហេតុធ្វើឱ្យខ្យល់នេះក្លាយទៅជាខ្យល់ត្រជាក់ស្ងួត ដោយបាននាំមកជាមួយនូវទឹកភ្លៀងដ៏តិចតួចបំផុត ទៅកាន់ប្រទេសមួយចំនួននៅទ្វីបអាស៊ីខាងត្បូងដូចជា ប្រទេសឥណ្ឌា និងប្រទេសបង់ក្លាដេសជាដើម និងបណ្តាប្រទេមួយចំនួនទៀតនៅទ្វីអាស៊ីអាគ្នេយ៍ដូចជាប្រទេសភូមា ប្រទេសឡាវ ប្រទេសថៃ ប្រទេសម៉ាលេស៊ីខាងលិច និងប្រទេសកម្ពុជាយើងជាដើម និងបាននាំយកទឹកភ្លៀងមធ្យមមកជាមួយ សំដៅទៅកាន់ប្រទេសមួយចំនួននៅអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ដូចជា ប្រទេសចិន និងប្រទេសវៀតណាមជាដើម។ នៅក្នុងអំឡុងពេលខែទាំងនេះ នៅលើឧបទ្វីបឥណ្ឌា និងបណ្តាប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍បានទទួលរងនូវធាតុអាកាសត្រជាក់ស្ងួត គឺជារដូវរងារ។

### ២.៦.២. ខ្យល់បក់ប្រចាំតំបន់

ខ្យល់បក់ប្រចាំតំបន់ គឺជាខ្យល់ ដែលបានបក់ចេញពីតំបន់មួយ ទៅកាន់តំបន់មួយផ្សេងទៀតក្នុងរយៈចម្ងាយឆ្ងាយៗ ឬវែង តាមទិសដៅមួយជាក់លាក់។ ជាទូទៅ ខ្យល់បក់ប្រចាំតំបន់ គឺជាផ្នែកមួយនៃគំរូចរន្តខ្យល់បក់ ដែលធ្វើចលនាកាត់តាមផ្ទៃផែនដី។ ប្រព័ន្ធខ្យល់បក់ប្រចាំតំបន់កើតឡើង ដោយសារតែកម្តៅ ឬសីតុណ្ហភាពមិនស្មើគ្នានៅលើផ្ទៃផែនដី។ តំបន់នៅក្បែរអេក្វាទ័រទទួលកម្តៅព្រះអាទិត្យស្ទើរតែពេញមួយឆ្នាំ។ កម្តៅនេះ ធ្វើឱ្យផ្ទៃដីឡើងកម្តៅយ៉ាងឆាប់រហ័ស។ ផ្ទុយទៅវិញ នៅតំបន់ប៉ូលទទួលកម្តៅព្រះអាទិត្យបានតិច ធ្វើឱ្យផ្ទៃដីឡើងកម្តៅយឺត។ ដូចនេះ សីតុណ្ហភាពតំបន់ប៉ូលទាបជាងសីតុណ្ហភាពតំបន់អេក្វាទ័រ ឬក្បែរអេក្វាទ័រ។ នៅអេក្វាទ័រខ្យល់ក្តៅអណ្តែតឡើងលើ ហើយរសាត់អណ្តែតទៅកាន់តំបន់ប៉ូល រីឯខ្យល់ត្រជាក់នៅតំបន់ប៉ូលធ្លាក់ចុះ ហើយរសាត់អណ្តែតសំដៅទៅកាន់តំបន់អេក្វាទ័រវិញ។ ចលនានេះ បង្កើតឱ្យមានជាលំនាំខ្យល់បក់ប្រចាំតំបន់មួយ។

ខ្យល់ប្រចាំតំបន់ ក៏ដូចជាខ្យល់មូសុងផងដែរ គឺវាមិនមែនបក់ត្រង់ពីជើងទៅត្បូង ឬពីត្បូងទៅជើងនោះទេ គឺវាបានបក់រាងវេរ ដោយសារតែឥទ្ធិពលនៃកម្លាំងកូរីយ៉ូលីស ដែលកើតឡើងដោយសារ ចលនារង្វិលខ្វាល់របស់ផែនដី។ ដោយសារតែឥទ្ធិពលនេះហើយ បានធ្វើឱ្យគន្លងខ្យល់បក់បានប្តូរទិសដៅនៅលើផែនដី។ ខ្យល់បក់ប្រចាំតំបន់រួមមាន ខ្យល់ជំនួញ ឬខ្យល់អាលីសេ ខ្យល់បក់ពីទិសខាងលិច និងខ្យល់ពីទិសខាងកើត។

- **ខ្យល់អាលីសេ ឬខ្យល់ជំនួញ**

ខ្យល់អាលីសេ ឬខ្យល់ជំនួញ គឺជាខ្យល់ដែលបក់ចេញពីខ្សែស្របទី ៣០° នៃអឌ្ឍគោលទាំងពីរសំដៅទៅអេក្វាទ័រ។ នៅពេលដែលខ្យល់នេះបក់ទៅដល់អេក្វាទ័រ ខ្យល់នេះបានឡើងកម្តៅ ស្រាល ហើយស្ទុះឡើងលើ ហើយរសាត់អណ្តែតសំដៅត្រឡប់ទៅកាន់ខ្សែស្របទី ៣០° វិញ។ នៅខ្សែស្របទី ៣០° នៃអឌ្ឍគោលទាំងពីរ ខ្យល់នេះបានចាប់ផ្តើមត្រជាក់ ហើយធ្លាក់ចុះ។ ខ្យល់ ដែលធ្លាក់ចុះមួយផ្នែកបានបក់ត្រលប់ទៅរកអេក្វាទ័រវិញ និងមួយផ្នែកទៀតបានបក់សំដៅទៅកាន់តំបន់ប៉ូល។ ខ្យល់ ដែលបក់ត្រលប់ទៅកាន់តំបន់អេក្វាទ័រវិញ គឺជាខ្យល់មិនប្រែប្រួល ហើយបង្កើតបានជាតំបន់សម្ពាធខ្សោយ ដែលលាតសន្ធឹងជាច្រើនគីឡូម៉ែត្រនៅតំបន់ត្រូពិច ជាពិសេសតំបន់អេក្វាទ័រ។ ខ្យល់នេះ ត្រូវបានគេហៅថា ខ្យល់ជំនួញ ឬខ្យល់អាលីសេ។

នៅអឌ្ឍគោលខាងជើង កម្លាំងកូរីយ៉ូលីសធ្វើឱ្យខ្យល់ជំនួញនេះវេរទៅខាងស្តាំ ជាខ្យល់ដែលបក់ពីទិសឦសានទៅទិសនិរតី គេឱ្យឈ្មោះថា ខ្យល់ជំនួញឦសាន។ នៅអឌ្ឍគោលខាងត្បូង ខ្យល់ជំនួញនេះបានវេរទៅឆ្វេង ជាខ្យល់បក់ពីទិសនិរតីទៅឦសាន គេឱ្យឈ្មោះថា ខ្យល់ជំនួញនិរតី។

- **ខ្យល់បក់ពីទិសខាងលិច**

ខ្យល់បក់ពីទិសខាងលិច គឺជាខ្យល់ដែលបក់ចេញពីខ្សែក្រវាត់ខ្យល់នៅត្រង់ខ្សែស្របទី ៣០° សំដៅទៅតំបន់ប៉ូល ឬជាខ្យល់ដែលបក់ពីខ្សែស្របទី ៣០° សំដៅទៅខ្សែស្របទី ៦០° នៃអឌ្ឍគោលទាំងពីរ។ វាគឺជាខ្យល់ ដែលបក់ពីលិចទៅកើតហៅថា ខ្យល់បក់ពីលិចទៅកើត ហើយខ្យល់នេះបានបក់ក្នុងទិសដៅផ្ទុយពីខ្យល់ជំនួញ។

ខ្យល់នេះ មានទីតាំងស្ថិតនៅចន្លោះខ្សែស្របទី ៣០° និង៦០° នៃអឌ្ឍគោលទាំងពីរ ហើយវាបានបក់វេរទៅខាងស្តាំនៅអឌ្ឍគោលខាងជើង និងបក់វេរទៅឆ្វេងនៅអឌ្ឍគោលខាងត្បូង។ ខ្យល់នេះបានជួយអ្នកជំនួញពីសម័យមុន ដើម្បីធ្វើដំណើរពីទ្វីបអាមេរិចទៅទ្វីបអឺរ៉ុបវិញ។

- **ខ្យល់បក់ពីទិសខាងកើត**

ខ្យល់បក់ពីទិសខាងកើត គឺជាខ្យល់ដែលបក់ចេញពីខ្សែក្រវាត់ខ្យល់នៅក្នុងតំបន់ប៉ូល សំដៅមកខ្សែស្របទី ៦០° នៃ អឌ្ឍគោលទាំងពីរ។ ខ្យល់នេះ បានកើតឡើងពីខ្យល់ត្រជាក់ធ្លាក់ចុះ ហើយធ្វើដំណើរចេញពីតំបន់ប៉ូលឆ្ពោះទៅកាន់ខ្សែស្របទី ៦០° នៃអឌ្ឍគោលខាងជើង និងខាងត្បូង។

នៅអឌ្ឍគោលទាំងពីរ ខ្យល់នេះបានបក់មកជួបនឹងខ្យល់ដែលបក់មកពីទិសខាងលិច ឬខ្យល់ដែលបក់មកពីអេក្វាទ័រទៅតំបន់ប៉ូល។ បណ្តាញខ្យល់ត្រជាក់ទាំងនេះ បានបក់វេរទៅខាងលិច ដោយ សារកម្លាំងកូរីយ៉ូលីស។

**២.៧. ម៉ាសខ្យល់**

ម៉ាសខ្យល់ គឺជាបណ្តុំនៃខ្យល់ដែលមានសម្ពាធ សីតុណ្ហភាព សំណើមអាកាស និងទិសខ្យល់បក់។ លក្ខណៈសម្គាល់នៃម៉ាសខ្យល់មួយ គឺសំណើម និងសីតុណ្ហភាពដែលបានមកពីតំបន់ម៉ាសខ្យល់នោះកកើតឡើង។ តំបន់នេះត្រូវបានគេហៅថា តំបន់ប្រភព។ ដូចនេះ បម្រែបម្រួលនៃធាតុអាកាស គឺ អាស្រ័យលើទីកន្លែង ដែលម៉ាសខ្យល់កើតឡើង។ ម៉ាសខ្យល់ បានគ្របដណ្តប់រាប់ពាន់គីឡូម៉ែត្រការេនៅលើផ្ទៃផែនដី។ គេធ្វើការបែងចែកម៉ាសខ្យល់ ដោយផ្អែកទៅលើសីតុណ្ហភាព និងសំណើមរបស់វា ដែលរួមមាន ម៉ាសខ្យល់ត្រជាក់ ម៉ាសខ្យល់ក្តៅ ម៉ាសខ្យល់សើម និងម៉ាសខ្យល់ស្ងួត ដោយផ្អែកលើតំបន់ប្រភព។ ជាទូទៅ នៅលើផែនដីមានម៉ាសខ្យល់សំខាន់ៗ ២ ប្រភេទធំៗដូចជា ម៉ាសខ្យល់ត្រូពិច និងម៉ាសខ្យល់ប៉ូល។

**២.៧.១. ម៉ាសខ្យល់ត្រូពិច**

ម៉ាសខ្យល់ត្រូពិចកកើតឡើងនៅលើមហាសមុទ្រ និងនៅលើទ្វីបក្បែរតំបន់អេក្វាទ័រ។ ម៉ាសខ្យល់ត្រូពិចចែកចេញជា ២ ប្រភេទទៀត គឺម៉ាសខ្យល់ត្រូពិចសមុទ្រ និងម៉ាខ្យល់ត្រូពិចទ្វីប។

- **ម៉ាសខ្យល់សមុទ្រ**

ម៉ាសខ្យល់ត្រូពិចសមុទ្រ គឺជាម៉ាសខ្យល់ដែលកកើតឡើងនៅលើមហាសមុទ្រដូចជា មហាសមុទ្រប៉ាស៊ីភិច (នៅរយៈទទឹងក្បែរអេក្វាទ័រ) មហាសមុទ្រឥណ្ឌា និងសមុទ្រចិនខាងត្បូង។ ម៉ាសខ្យល់នេះមានលក្ខណៈក្តៅ ហើយសើម ដោយសារវាកើតឡើងនៅតំបន់អេក្វាទ័រ និងនៅលើសមុទ្រ។

- **ម៉ាសខ្យល់ទ្វីប**

ម៉ាសខ្យល់ត្រូពិចទ្វីបមានលក្ខណៈក្តៅ ហើយស្ងួត ដោយសារវាបានកកើតឡើងនៅលើទ្វីប។ ម៉ាសខ្យល់ទ្វីប ខ្យល់ក្តៅខ្លាំងអាចមានសីតុណ្ហភាពលើសពី ៤០ អង្សារ នៅរដូវប្រាំង។ បើម៉ាសខ្យល់នោះស្ថិតនៅលើតំបន់ណាមួយក្នុងរយៈពេលវែង វានឹងធ្វើឱ្យតំបន់នោះទទួលរងនូវភាពរាំងស្ងួត។ ប៉ុន្តែនៅរដូវក្តៅ ខ្យល់ក្តៅអាចមានទំនាក់ទំនងជាមួយខ្យល់ត្រជាក់ បង្កើតឱ្យមានភ្លៀងធ្លាក់ ឬធ្លាក់ព្រិល។

**២.៧.២. ម៉ាសខ្យល់ប៉ូល**

ម៉ាសខ្យល់ប៉ូលកកើតឡើងនៅលើតំបន់ប៉ូលដូចជា នៅប្រទេសរុស្ស៊ី ប្រទេសកាណាដា នៅភាគខាងជើងនៃមហាសមុទ្រប៉ាស៊ីភិច និងនៅភាគខាងជើងមហាសមុទ្រអាត្លង់ទិច។ ម៉ាសខ្យល់ប៉ូលក៏មាន ២ ប្រភេទផងដែរ គឺម៉ាសខ្យល់ប៉ូលសមុទ្រ និងម៉ាសខ្យល់ទ្វីប។

- **ម៉ាសខ្យល់ប៉ូលសមុទ្រ**

ម៉ាសខ្យល់ប៉ូលសមុទ្រមានលក្ខណៈត្រជាក់ ហើយសើម ដោយសារវាកើតមានឡើងនៅតំបន់ប៉ូល និងនៅលើផ្ទៃសមុទ្រ។ នៅរដូវវស្សា ម៉ាសខ្យល់នេះបាននាំមកនូវសីតុណ្ហភាពត្រជាក់ បង្កើតឱ្យមានភ្លៀងធ្លាក់ និងអ័ព្ទធ្លាក់យ៉ាងក្រាស់។ នៅរដូវរងារ ម៉ាសខ្យល់នេះបាននាំមកនូវសីតុណ្ហភាពត្រជាក់ខ្លាំង ដោយបង្កើតជាភ្លៀង និងធ្លាក់ព្រិលគ្រាប់ធំៗ។

- **ម៉ាសខ្យល់ប៉ូលទ្វីប**

ម៉ាសខ្យល់ប៉ូលទ្វីប មានលក្ខណៈត្រជាក់ ហើយស្ងួត។ នៅរដូវធ្លាក់ព្រិល សីតុណ្ហភាពនៅលើផ្ទៃដីអាចធ្លាក់ចុះរហូតដល់ -៤០ អង្សារសេ។

ក្រៅពីម៉ាសខ្យល់ទាំងពីរប្រភេទធំៗខាងលើនេះ គឺម៉ាសខ្យល់ត្រូពិច និងម៉ាសខ្យល់ប៉ូល នៅមានម៉ាសខ្យល់ដទៃទៀតដូចជា ម៉ាសខ្យល់អេក្វាទ័រ ម៉ាសខ្យល់អាកទិច និងម៉ាសខ្យល់អង់តាកទិច។ ប្រភេទនៃម៉ាសខ្យល់ទាំងនេះ តែងតែមានសីតុណ្ហភាព សម្ពាធ និងសំណើមខុសៗគ្នា ហើយខណ្ឌចែកដោយព្រំខ្យល់មួយ។

**២.៨. ព្រំខ្យល់**

លក្ខណៈនៃម៉ាសខ្យល់ គឺសំណើម និងសីតុណ្ហភាព ហើយម៉ាសខ្យល់នីមួយៗមិនអាចចូលគ្នាបាននោះទេ។ នៅពេលដែលមានម៉ាសខ្យល់ពីរជួបគ្នា វាបង្កើតបានជាព្រំខ្យល់។ ដូចនេះ ព្រំខ្យល់ គឺជាផ្ទៃខណ្ឌរវាងម៉ាសខ្យល់ពីរ ដែលមានសីតុណ្ហភាព និងសំណើមខុសគ្នា។ ជាតុអាកាសនៅតាមព្រំខ្យល់តែងតែមាន ពពក ភ្លៀង និងព្យុះកើតមានឡើង។ នៅពេលម៉ាសខ្យល់ពីរជួបគ្នា ព្រំខ្យល់បានកើតឡើង ហើយត្រូវបានគេចែកថ្នាក់ទៅតាមជំនួបរបស់វា។ គេអាចចែកព្រំខ្យល់ជា ៤ ប្រភេទ ដែលរួមមាន ព្រំខ្យល់ត្រជាក់ ព្រំខ្យល់ក្តៅ ព្រំខ្យល់គួច និងព្រំខ្យល់នឹង។

**២.៨.១. ព្រំខ្យល់ត្រជាក់**

ព្រំខ្យល់ត្រជាក់ គឺជាផ្ទៃព្រំខណ្ឌ ដែលកើតឡើងនៅពេលដែលម៉ាសខ្យល់ត្រជាក់សម្រុកចូលទៅជំនួសម៉ាសខ្យល់ក្តៅ។ ខ្យល់ត្រជាក់មានចលនារហ័ស ហើយបានរុញច្រានខ្យល់ក្តៅឱ្យឡើងទៅលើ តាមរាងព្រំចោតមួយ។ សកម្មភាពបែបនេះ បានបង្កើតឱ្យមានជាពពកផ្គាស្តែដែលបង្កឱ្យមានភ្លៀង ផ្គរ និងរន្ទះកើតមានឡើង។ បន្ទាប់ពីព្រំត្រជាក់បានឆ្លងកាត់ផុតរួច ខ្យល់ចាប់ផ្តើមប្តូរទិស សីតុណ្ហភាពក៏ធ្លាក់ចុះ មេឃក៏ស្រឡះ ហើយសម្ពាធ ក៏កើនឡើងផងដែរ។

**២.៨.២. ព្រំខ្យល់ក្តៅ**

ព្រំខ្យល់ក្តៅ គឺជាផ្ទៃព្រំខណ្ឌដែលកើតឡើងនៅពេលម៉ាសខ្យល់ក្តៅសម្រុកចូលទៅដណ្តើម ឬជំនួសទីកន្លែងម៉ាសខ្យល់ត្រជាក់។ នៅតាមបណ្តោយព្រំខ្យល់នេះ ខ្យល់ក្តៅបានហោះរអិលពីលើខ្យល់ត្រជាក់ ដោយបាននាំយកសំណើមឡើងទៅលើខ្ពស់ទៅៗ ហើយបង្កើតបានជាផ្ទាំងពពកធំៗ។ បន្ទាប់មក សម្ពាធក៏ចាប់ផ្តើមធ្លាក់ចុះខ្សោយបន្តិចម្តងៗ រហូតទាល់តែមានភ្លៀងធំចាប់ផ្តើមធ្លាក់។ នៅពេលដែលព្រំខ្យល់ក្តៅឆ្លងផុតទៅ ផ្ទៃមេឃក៏ចាប់ផ្តើមស្រឡះ ហើយសម្ពាធក៏ចាប់ផ្តើមឡើងខ្លាំងឡើងវិញ។ ជាទូទៅ សីតុណ្ហភាពមានកម្រិតខ្ពស់ នៅពេលខ្យល់ក្តៅចូលមកជំនួសខ្យល់ត្រជាក់នៅតាមទីកន្លែងណាមួយ។

**២.៨.៣. ព្រំខ្យល់នឹង**

នៅពេលដែលមានម៉ាសខ្យល់ពីរជួបគ្នា ហើយគ្មានចលនាអ្វីសោះកើតមានឡើងនោះ គឺជាព្រំនឹង។ ដូចនេះ ព្រំនឹង គឺជាផ្ទៃខណ្ឌដែលកើតឡើងនៅពេលដែលម៉ាសខ្យល់ពីរជួបគ្នា ដោយគ្មានបង្កើតឱ្យមានចលនាអ្វីកើតឡើង។ ជាតុអាកាស ដែលកើតមកពីព្រំនឹងភាគច្រើនស្រដៀងគ្នានឹងធាតុអាកាសរបស់ព្រំក្តៅដែរ ហើយធ្វើឱ្យមានភ្លៀងធ្លាក់ជាច្រើនថ្ងៃនៅត្រង់ទីកន្លែងនោះ។

**២.៨.៤. ព្រំខ្យល់គួច**

ព្រំខ្យល់គួច គឺជាផ្ទៃខណ្ឌដែលកើតឡើងនៅពេលដែលម៉ាសខ្យល់ពីរ គឺម៉ាសត្រជាក់ ហើយនិងម៉ាសខ្យល់ក្តៅបានជួបគ្នា ហើយបង្កើតឱ្យមានជំនួបគ្នាទៀតរវាងម៉ាសខ្យល់ត្រជាក់ និងម៉ាសខ្យល់ត្រជាក់។ នៅពេលដែលម៉ាសខ្យល់ត្រជាក់ ដែលមានចលនាលឿនបានផ្លាស់ទីចូលទៅនៅពីលើម៉ាសខ្យល់ក្តៅ ហើយវាបានបង្ខំឱ្យម៉ាសខ្យល់ក្តៅអណ្តែតឡើងទៅលើ។ ម៉ាសខ្យល់ត្រជាក់ នៅតែបន្តចលនារហូតទាល់តែបានជួបគ្នាជាមួយនឹងម៉ាសខ្យល់ត្រជាក់មួយទៀត។ នៅមុនពេលដែលព្រំខ្យល់នេះ កើតឡើង ម៉ាសខ្យល់ដែលស្ថិតនៅពីក្រោយព្រំខ្យល់ត្រជាក់ គឺមានសភាពត្រជាក់ រីឯម៉ាសខ្យល់ដែលស្ថិតនៅពីមុខព្រំខ្យល់ក្តៅ ក៏មានសភាពត្រជាក់ផងដែរ។ នៅពេលដែលម៉ាសខ្យល់ត្រជាក់ផ្លាស់ទីចូលទៅ
ជួបម៉ាសខ្យល់ត្រជាក់មួយទៀត វាបានរុញម៉ាសខ្យល់ក្តៅឱ្យអណ្តែតឡើងលើ។ នៅត្រង់ព្រំខ្យល់គួចនេះ សីតុណ្ហភាពក៏បានចុះត្រជាក់ ហើយភ្លៀងធំក៏ចាប់ផ្តើកើតឡើងផងដែរ។

**ខ. អាកាសធាតុ**

**១. និយមន័យអាកាសធាតុ**

ប្រសិនបើយើងប្រមូលយកពត៌មានអំពីធាតុអាកាសជារៀងរាល់ថ្ងៃ នៅក្នុងរយៈពេលមួយវែង យើងនឹងមានលទ្ធភាពអង្កេតឃើញនូវនិន្នាការទាំងឡាយ និងបង្កើតនូវភាពជាទូទៅនានាពីអាកាសធាតុនៅទី

កន្លែងនោះ។ នេះមានន័យថា យើងនឹងដឹងពីលក្ខខណ្ឌជាទូទៅនៃសីតុណ្ហភាព ហើយនិងកំណកអាកាសនៅទីកន្លែង ដែលយើងបានប្រមូលពត៌មាន ឬបានអង្កេតយ៉ាងជាក់លាក់។ ក្នុងលក្ខខណ្ឌទូទៅនៃសីតុណ្ហភាព និងកំណកអាកាសនៅទីកន្លែងមួយ ដែលយើងបានប្រមូល ឬបានអង្កេត ត្រូវបានអ្នកឧកូតវិទូហៅថា **អាកាសធាតុ**។

ដូចនេះ អាកាសធាតុ គឺជាលក្ខខណ្ឌមធ្យមនៃការប្រែប្រួលធាតុអាកាស ឬបរិយាកាសនៅទីកន្លែងណាមួយ ឬតំបន់ណាមួយ នៅក្នុងរយៈពេលវែង ឬរយៈពេលយូរឆ្នាំ ដោយមានរយៈពេលចាប់ពី ៣០ ទៅ ៣៥ ឆ្នាំ។ ឧទាហរណ៍ ៖ អាកាសធាតុនៅប្រទេសសឹង្ហបុរីត្រូវបានកត់សម្គាល់ឃើញថា មានសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំខ្ពស់ និងមានកម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំខ្ពស់។ ចំណែកឯអាកាសធាតុនៅប្រទេសកម្ពុជាយើងវិញ ត្រូវបានគេកត់សម្គាល់ឃើញថា មានសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំគឺ ២៧ អង្សារសេ និងកម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំគឺ ១២០០ ម.ម។

ជាទូទៅ នៅគ្រប់ទីកន្លែងទាំងអស់នៅលើពិភពលោក គឺសុទ្ធសឹងតែមានអាកាសធាតុពិសេសប្រចាំតំបន់របស់ខ្លួន។ អាកាសធាតុតំបន់ណាក៏ដោយនៅលើពិភពលោក តែងតែត្រូវបានកំណត់ដោយកត្តាសំខាន់ ២ ជាមូលដ្ឋានគឺ សីតុណ្ហភាព និងកំណកអាកាស។ គំនួបផ្សំផ្សេងៗគ្នា នៃសីតុណ្ហភាព និងកំណកអាកាសមានសារៈសំខាន់ណាស់នៅលើផែនដី។ សីតុណ្ហភាព និងកំណកអាកាសតែងតែទទួលឥទ្ធិពលពីកត្តាផ្សេងៗជាច្រើនទៀត។

### ២. កត្តាដែលមានឥទ្ធិពលើអាកាសធាតុ

យើងដឹងហើយថា មានកត្តាសំខាន់ពីរដែលបានជះឥទ្ធិពលទៅលើអាកាសធាតុនៅតំបន់ណាឬនៅទីកន្លែងណាមួយនៅលើផែនដី។ តែទន្ទឹមគ្នានេះដែរ ក៏នៅមានកត្តាជាច្រើនផ្សេងទៀតដែលមានឥទ្ធិពលទៅលើរបបអាកាសធាតុនៅក្នុងទីកន្លែងមួយ ឬតំបន់មួយនេះផងដែរដូចជា រយៈទទឹង ផ្ទៃទឹក ខ្យល់បក់ ចរន្ត ឬខ្សែទឹកសមុទ្រ និងរយៈកម្ពស់ ឬសណ្ឋានដី។

### ២.១. រយៈទទឹង

មធ្យោបាយមួយ ដើម្បីពិពណ៌នាពីទីតាំងភូមិសាស្ត្រ គឺត្រូវប្រាប់ពីរយៈទទឹងនៃទីកន្លែងមួយ។ រយៈទទឹងគឺជារង្វាស់គិតជាដឺក្រេ ដែលគេវាស់ចេញពីខ្សែស្របណាមួយ នៃអឌ្ឍគោលទាំងពីរទៅកាន់អេក្វាទ័រ។ នៅលើរយៈទទឹងខុសគ្នា មុំចាំងប៉ះរវាងផែនដី និងពន្លឺព្រះអាទិត្យ ក៏មានភាពខុសៗគ្នាដែរ។ ភាពខុសគ្នានេះ ក៏បានធ្វើឱ្យសីតុណ្ហភាពនៅរយៈទទឹងទាំនោះ ក៏មានភាពខុសៗគ្នាផងដែ។

- **តំបន់ត្រូពិច** ៖ តំបន់នេះ គឺមានទីតាំងស្ថិតនៅក្បែរអេក្វាទ័រ។ ដូច្នេះ តំបន់នេះទទួលបានពន្លឺព្រះអាទិត្យច្រើន និងមានសីតុណ្ហភាពខ្ពស់ពេញមួយឆ្នាំ។ ចំណែកឯទឹកភ្លៀងវិញ តំបន់នេះក៏មានភ្លៀងធ្លាក់យ៉ាងជោគជាំផងដែរ។ នៅប្រហែលជាខ្សែស្របទី ៣០$^{\circ}$ នៃអឌ្ឍគោលទាំងពីរគឺជាវាលលំហ ដែលជាតំបន់មានសីតុណ្ហភាពខ្ពស់ និងកំណកអាកាសទាប។
- **តំបន់ត្រជាក់បង្គួរ** ៖ **តំបន់**នេះ គឺស្ថិតនៅរយៈទទឹងខ្ពស់បង្គួរ។ នៅរស្សាន្តរដូវ តំបន់នេះមានសីតុណ្ហភាពក្តៅល្មម រីឯនៅសិសិររដូវវិញ តំបន់នេះមានសីតុណ្ហភាពត្រជាក់ឬត្រជាក់ខ្លាំង។ នៅតំបន់នេះដែរ គេឃើញមានកំណកអាកាសអាចធ្លាក់ច្រើនសន្ទឹកសន្ធាប់ប្រហាក់ប្រហែលទៅនឹងតំបន់ត្រូពិចដែរ។

- **តំបន់ប៉ូល** ៖ នៅតំបន់នេះ មានទីតាំងស្ថិតនៅលើរយៈទទឹងខ្ពស់។ តំបន់នេះ នៅសិសិររដូវមានរយៈពេលវែង និងមានសីតុណ្ហភាពត្រជាក់ខ្លាំង។ រីឯនៅរដូវក្តៅវិញ តំបន់នេះមានរយៈពេលខ្លី និងមានសីតុណ្ហភាពក្តៅមធ្យម។ នៅតំបន់នេះ កំណកអាកាសទាបពេញមួយឆ្នាំ។

### ២.២. ផ្ទៃទឹក

ប្រសិនបើយើងសំឡឹងមើលទៅលើភូគោលវិញ យើងនឹងឃើញថាផ្ទៃដី និងផ្ទៃទឹកមានរបាយមិនស្មើគ្នានោះឡើយ។ ភាគច្រើននៅលើភូគោល ត្រូវបានគ្របដណ្តប់ទៅដោយផ្ទៃទឹក។ ទោះបីជាដូចនេះក្តី មានទីកន្លែងខ្លះនៅលើទ្វីបអាចមានចម្ងាយច្រើនជាង ១៦០០ គ.ម ពីផ្ទៃទឹកធំៗ។ ដូចយើងដឹងរួចមកហើយថា ផ្ទៃ ដី និងផ្ទៃទឹកបានផុតកម្តៅ និងចុះត្រជាក់នៅអត្រាខុសៗគ្នា។ ផ្ទៃដីបានផុតកំដៅលឿនជាងផ្ទៃទឹក។ ផ្ទៃដីក៏ចុះត្រជាក់លឿនជាងផ្ទៃទឹកផងដែរ។ ជាលទ្ធផល សីតុណ្ហភាពខ្យល់នៅលើផ្ទៃដី គឺមានក្តៅខ្លាំងនៅរដូវក្តៅ និងត្រជាក់ខ្លាំងនៅរដូវរំហើយ ជាងវាស្ថិតនៅពីលើមហាសមុទ្រនៅលើ រយៈទទឹងដូចគ្នា។

### ២.៣. ខ្យល់បក់

យើងដឹងហើយថា ចរន្តខ្យល់បក់បានបក់ជុំវិញភពផ្ទៃផែនដី។ លំនាំបែបនេះ គឺមិនមែនកើតមានឡើងតែពីមួយថ្ងៃទៅមួយថ្ងៃនោះទេ។ តាមពិត ខ្យល់បក់បានបក់ជាអចិន្ត្រៃយ៍ពីលើផ្ទៃភពផែនដីរបស់យើង។ ជាឧទាហរណ៍៖ នៅផ្នែកខាងលើ និងនៅផ្នែកខាងក្រោមខ្សែអេក្វាទ័រ ខ្យល់ជំនួញ ឬខ្យល់អាលីសេបានបក់បោកជាអចិន្ត្រៃយ៍។ នៅតំបន់រយៈទទឹងខ្ពស់បង្គួរមានខ្យល់បក់ពីទិសខាងលិច រីឯនៅតំបន់ប៉ូលវិញមានខ្យល់បក់ពីទិសខាងកើត។ ខ្យល់បក់ពីទិសខាងលិច គឺបានបក់កាត់សហរដ្ឋអាមេរិកពីទិសខាងលិច (ពីមហាសមុទ្រប៉ាស៊ីភិច) ទៅទិសខាងកើត (ពីមហាសមុទ្រអាត្លង់ទិច)។ នៅពេលដែលវាផ្លាស់ទី វាបាននាំយកមកជាមួយនូវខ្យល់ក្តៅសើម និងទឹកភ្លៀងទៅកាន់តំបន់ឆ្នេរភាគខាងលិច និងបានរុញម៉ាសខ្យល់ និងព្រំខ្យល់ឱ្យឆ្លងកាត់សហរដ្ឋអាមេរិកផងដែរ។

### ២.៤. ចរន្តទឹកសមុទ្រ

ខ្យល់បក់ក៏ធ្វើឱ្យទឹកមានចលនាឆ្លងកាត់លើផ្ទៃមហាសមុទ្រផងដែរ។ ចលនារបស់ខ្យល់នៅពីលើផ្ទៃសមុទ្របង្កើតឱ្យមានជាចរន្តទឹកសមុទ្រ។ នៅពេលដែលទឹកមហាសមុទ្រមានចលនា វាក៏បាននាំយកទៅជាមួយនូវខ្យល់ក្តៅ ឬខ្យល់ត្រជាក់ ព្រមទាំងទឹកភ្លៀងផងដែរ។ ចរន្តទឹកក្តៅគុលស្ទ្រីមបានហូរមកកម្តៅតាមបណ្តោយឆ្នេរខាងកើតសហរដ្ឋអាមេរិក ចំណែករីឯចរន្តទឹកត្រជាក់កាលីហ្វូនញ៉ាវិញ ហូរចុះមកតាមបណ្តោយឆ្នេរខាងលិចសហរដ្ឋអាមេរិក ធ្វើឱ្យតំបន់នេះមានសីតុណ្ហភាពត្រជាក់។ ចរន្តទឹកសមុទ្រគូរ៉ូស៊ីវ៉ូហូរមកកម្តៅឆ្នេរខាងលិចទ្វីបអាស៊ី ចំណែកឯចរន្តទឹកត្រជាក់ឡាប្រាដ័រ អូយ៉ាស៊ីវ៉ូហូរមកតាមបណ្តោយឆ្នេរខាងកើត ធ្វើឱ្យឆ្នេរនេះមានសីតុណ្ហភាពត្រជាក់។

### ២.៥. រយៈកម្ពស់

រយៈកម្ពស់ គឺជារង្វាស់នៃកម្ពស់របស់ទីកន្លែងមួយពីលើផ្ទៃផែនដី ដោយធៀបទៅនឹងនីវ៉ូទឹកសមុទ្រ។ កាលណាទីកន្លែងមួយមានរយៈកម្ពស់កាន់តែខ្ពស់ពីលើនីវ៉ូទឹកសមុទ្រ នោះសីតុណ្ហភាពនៅទីកន្លែងនោះក៏កាន់តែមានភាពត្រជាក់ផងដែរ។

នៅតាមបណ្តោយនៃជើងភ្នំខ្ពស់ៗ គេសង្កេតឃើញមានរុក្ខជាតិត្រូពិចជាច្រើនប្រភេទបានដុះប្រជ្រៀតគ្នានៅទីនោះ។ នៅពេលដែលយើងឡើងទៅដល់ពាក់កណ្តាល នៃភ្នំទាំងនេះ គេសង្កេតឃើញថាមានរុក្ខជាតិប្រភេទព្រៃស្រល់ជាច្រើនបានដុះនៅទីនេះ។ ក៏ប៉ុន្តែ នៅពេលដែលគេឡើងដល់កំពូលភ្នំទាំងនេះវិញ គេលែងប្រទះឃើញប្រភេទរុក្ខជាតិទាំងនេះទៀតហើយ ប៉ុន្តែបែរជាប្រទះឃើញនូវទឹកកក និងព្រិលធ្លាក់នៅតំបន់ទាំងនេះជាប្រចាំទៅវិញ។

ភ្នំ និងជួរភ្នំ ក៏មានឥទ្ធិពលទៅលើអាកាសធាតុផងដែរ។ ជួរភ្នំអាល់នៅទ្វីបអឺរ៉ុប បានការពារឆ្នេរសមុទ្រមេឌីទែរ៉ានេពីខ្យល់ត្រជាក់តំបន់ប៉ូល។ ជួរភ្នំហិមាល័យ បានការពារទំនាបប្រទេសឥណ្ឌាពីខ្យល់ត្រជាក់ស៊ីបេរី។ ភ្នំ និងជួរភ្នំ ក៏មានឥទ្ធិពលទៅលើលំនាំភ្លៀងធ្លាក់ផងដែរ។ ជារឿយៗ នៅពីមុខម្ខាងនៃភ្នំតែងតែទទួលបានទឹកភ្លៀងច្រើន ផ្ទុយទៅវិញនៅមុខម្ខាងទៀតនៅផ្នែកខាងក្រោយវិញតែងតែទទួលបានទឹកភ្លៀងតិចតួចបំផុត។

### គ. តំបន់អាកាសធាតុ

គេចែកអាកាសធាតុនៅលើផែនដីជាច្រើនតំបន់ផ្សេងៗគ្នាដោយអាស្រ័យទៅលើសីតុណ្ហភាព និងកំណាកអាកាសជាមធ្យមប្រចាំឆ្នាំ នៃតំបន់ទាំងនោះ។ តំបន់អាកាសធាតុធំៗទាំងនោះ ត្រូវបានគេចែកជាតំបន់តូចៗជាបន្តទៅទៀត ហើយអាកាសធាតុតូចៗទាំងនោះ ក៏ត្រូវបានគេចែកជាតំបន់តូចៗជាបន្តទៅទៀតផងដែរ។

តំបន់អាកាសធាតុធំៗទាំងនេះមាន ៣ គឺ អាកាសធាតុតំបន់ត្រូពិច អាកាសធាតុតំបន់ត្រជាក់បង្គួរ និងអាកាសធាតុតំបន់ប៉ូល។ សីតុណ្ហភាព ហើយនិងកំណាកអាកាសនៅតំបន់ទាំង ៣ នេះ គឺអាស្រ័យដោយទីតាំងតំបន់ និងប្រភេទម៉ាសខ្យល់នៅទីនោះផ្ទាល់តែម្តង។

#### ១. អាកាសធាតុតំបន់ត្រូពិច

តំបន់អាកាសធាតុត្រូពិច គឺលាតសន្ធឹងស្ថិតនៅក្នុងតំបន់រយៈទទឹងទាប ពោលគឺលាតសន្ធឹងចាប់ពីអេក្វាទ័រហូតដល់ខ្សែស្របទី ៣០$^{0}$ នៃអឌ្ឍគោលទាំងពីរ។ តំបន់នេះ មានសីតុណ្ហភាព និងសំណើមអាកាសខ្ពស់ រីឯបរិមាណទឹកភ្លៀងវិញមានច្រើនស្ទើរតែពេញមួយឆ្នាំ។ សីតុណ្ហភាពកម្រនឹងឡើងដល់ ៣៥ អង្សារសេណាស់។ ជាទូទៅ សីតុណ្ហភាពខ្ពស់បំផុតនៅពេលថ្ងៃមានប្រហែលជា ៣២ អង្សារសេ រីឯនៅពេលយប់វិញ សីតុណ្ហភាពជាធម្មតាកម្រនឹងធ្លាក់ចុះហូតដល់ក្រោម ២០ អង្សារសេណាស់។ ការឡើងចុះនៃសីតុណ្ហភាពនៅក្នុងតំបន់នេះ មានភាពខុសគ្នាតិចតួចណាស់ជាប្រចាំឆ្នាំ។ ជាទូទៅ នៅតំបន់ត្រូពិចមានរដូវ ២ ច្បាស់លាស់គឺ រដូវវស្សា ដែលមានរយៈពេល ៦ ខែ និងរដូវប្រាំងក៏មានរយៈពេល ៦ ខែផងដែរ។

អាកាសធាតុនៅតំបន់ត្រូពិចមានសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំ គឺខ្ពស់ជាងនៅតំបន់ផ្សេងៗ ទៀត ហើយសីតុណ្ហភាពនៅខែដែលត្រជាក់បំផុតមិនទាបជាង ១៨ អង្សារនោះឡើយ។ កម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំមានលើសពី ២០០០ ម.ម និងមានរបាយស្មើគ្នាពេញមួយឆ្នាំ ស្ទើរតែនៅគ្រប់ទីកន្លែងទាំងអស់។ នៅតំបន់ត្រូពិច ខ្យល់បក់ចេញពីទ្វីបភាគខាងលិចឆ្ពោះទៅសមុទ្រ។ ជួរភ្នំខ្ពស់ៗនៅតាមបណ្តោយឆ្នេរខាងលិច គឺជានាំងបាំងខ្យល់ទ្វីបមិនឱ្យទៅដល់តំបន់ឆ្នេរសមុទ្រ ជាហេតុធ្វើឱ្យមានភ្លៀងធ្លាក់ច្រើននៅលើជញ្ជាំងភ្នំម្ខាង ដែលស្ថិតនៅចំមុខខ្យល់ រីឯនៅជញ្ជាំងភ្នំម្ខាងទៀត ដែលមិនបានទទួលទឹកភ្លៀង ក៏ក្លាយទៅជាតំបន់

វាលលំហខ្សាច់។ ហេតុដូចនេះហើយ បានជាគេច្រើនតែប្រទះឃើញមានវាលលំហខ្សាច់ជាច្រើនស្ថិតនៅលើផ្នែកភាគខាងលិចទ្វីបនានា។

**២. អាកាសធាតុតំបន់ត្រជាក់បង្គួរ**

តំបន់អាកាសធាតុត្រជាក់បង្គួរ គឺស្ថិតនៅលាតសន្ធឹងនៅក្នុងតំបន់រយៈទទឹងខ្ពស់បង្គួរ ពោលគឺលាតសន្ធឹងចាប់ពីខ្សែស្របទី ៣០$^{0}$ ដល់ ៦០$^{0}$ នៃអឌ្ឍគោលទាំងពីរ។ តំបន់ត្រជាក់បង្គួរមានរដូវ ៤ ច្បាស់លាស់គឺ និទាឃរដូវ (Spring) វស្សាន្តរដូវ (Summer) សរទរដូវ (Autumn) និងសិសិររដូវ (Winter) ហើយរដូវនីមួយៗមានរយៈពេល ៣ ខែស្មើៗគ្នា។ សីតុណ្ហភាព គឺជាកត្តាសំខាន់ សម្រាប់កំណត់ឱ្យមានរដូវខុសៗគ្នា និងឱ្យដាច់ពីគ្នា គឺមិនមែនមានតែទឹកភ្លៀងដូចនៅតំបន់ត្រូពិចនោះទេ។ សីតុណ្ហភាពនៅតំបន់ត្រជាក់បង្គួរ គឺទទួលឥទ្ធិពលពីម៉ាសខ្យល់ប៉ូលផង និងពីម៉ាសខ្យល់ត្រូពិចផង។ សីតុណ្ហភាពមធ្យមនៅតំបន់នេះ ស្ថិតនៅចន្លោះរវាងសីតុណ្ហភាពមធ្យមនៅតំបន់ប៉ូល និងសីតុណ្ហភាពមធ្យមនៅតំបន់ត្រូពិច។

សីតុណ្ហភាពជាមធ្យមនៅតំបន់នេះមាន ៦ អង្សារសេ នៅខែត្រជាក់បំផុត និងប្រហែល ២៨ អង្សារសេ នៅខែក្តៅបំផុត។ នៅវស្សាន្តរដូវ សីតុណ្ហភាពអតិបរមាអាចឡើងដល់ ៣៤ អង្សារសេ រីឯនៅសិសិររដូវវិញ សីតុណ្ហភាពអប្បមារអាចធ្លាក់ចុះរហូតដល់ក្រោម ០ អង្សារសេ។ នៅតំបន់ត្រជាក់បង្គួរ កំណកអាកាសអាចស្ថិតនៅក្នុងទម្រង់ជាទឹកភ្លៀង និងព្រិល ហើយអាចមានកម្ពស់ចន្លោះចាប់ពី ៥០០ ម.ម ទៅ ១២០០ ម.ម។

**៣. អាកាសធាតុតំបន់ប៉ូល**

អាកាសធាតុតំបន់ប៉ូលគឺលាតសន្ធឹងនៅក្នុងតំបន់រយៈទទឹងខ្ពស់ ដោយលាតសន្ធឹងចាប់ពីខ្សែស្របទី ៦០$^{0}$ ពោលគឺចាប់ពីខ្សែរង្វង់អាកទិចទៅប៉ូលខាងជើង និងចាប់ពីខ្សែស្របទី ៦០$^{0}$ ពោលគឺពីខ្សែរង្វង់អង់តាក់ទិចទៅប៉ូលខាងត្បូង។ អាកាសធាតុតំបន់នេះ មានសីតុណ្ហភាពត្រជាក់ជាងគេបំផុត។ សីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំ គឺក្រោមសូន្យអង្សារសេជានិច្ច ទោះបីជាស្ថិតនៅក្នុងខែដែលក្តៅបំផុតក្តី ក៏សីតុណ្ហភាពជាមធ្យមនៅតំបន់នេះ មិនលើសពី ១០ អង្សារសេនោះឡើយ។ នៅរដូវក្តៅក្នុងតំបន់នេះមានរយៈពេលខ្លី រីឯរដូវរំហើយមានរយៈពេលវែង និងត្រជាក់ខ្លាំង គឺជារាត្រីប៉ូល (៦ ខែ)។ តំបន់នេះ មានកំណកអាកាសជាមធ្យមប្រចាំឆ្នាំតិចតួចណាស់ គឺមានចាប់ពីចន្លោះ ២៥០ មីលីម៉ែត្ររហូតដល់ ៤០០ មីលីម៉ែត្រ ហើយជាសំខាន់ក្នុងទម្រង់ជាព្រិល។

បណ្តាប្រទេស ដែលទទួលរងនូវអាកាសធាតុតំបន់ប៉ូលរួមមានដូចជា ប្រទេសរុស្សីភាគខាងជើង ប្រទេសអ៊ីស្លង់ ទ្វីបអង់តាកទិច និងប្រទេសកាដាណាភាគខាងជើង។

នៅក្នុងតំបន់អាកាសធាតុធំៗទាំង ៣ ខាងលើនេះ អាចមានអាកាសធាតុសមុទ្រ ហើយនិងអាកាសធាតុទ្វីបទៀត។ អាកាសធាតុសមុទ្រមាននៅតំបន់ជិតមាត់សមុទ្រ រីឯអាកាសធាតុទ្វីបវិញ គឺ មាននៅតាមតំបន់នានា ដែលស្ថិតនៅក្នុងទ្វីប។

តំបន់អាកាសធាតុសមុទ្រ គឺទទួលបានបរិមាណទឹកភ្លៀងច្រើនជាងតំបន់អាកាសធាតុទ្វីប។ សីតុណ្ហភាពនៅតំបន់ ដែលមានអាកាសធាតុសមុទ្រមិនសូវប្រែប្រួលខ្លាំងដូចអាកាសធាតុទ្វីបទេ។ នៅខែក្តៅ តំបន់សមុទ្រមានសីតុណ្ហភាពត្រជាក់ជាងទ្វីប ចំណែកឯនៅខែត្រជាក់វិញ សីតុណ្ហភាពបែរជាត្រជាក់ជាងទ្វីប។ ផ្ទុយទៅវិញ អាកាសធាតុទ្វីបមានលក្ខណៈស្ងួតជាងអាកាសធាតុសមុទ្រ ហើយបម្រែបម្រួលសីតុណ្ហភាពមានកម្រិតខ្ពស់។

តំបន់អាកាសធាតុទ្វីបនៅរដូវក្តៅ មានសីតុណ្ហភាពខ្ពស់ និងក្តៅខ្លាំង ចំណែកឯនៅរដូវត្រជាក់វិញ គឺមានសីតុណ្ហភាពទាប និងត្រជាក់ខ្លាំង។ វាលលំហខ្សាច់ភាគច្រើននៅលើពិភពលោក មានទីតាំងស្ថិតនៅចន្លោះខ្សែស្របទី ៣០$^{0}$ នៃអឌ្ឍគោលខាងជើង និងអឌ្ឍគោលខាងត្បូង។ វាលលំហខ្សាច់ទាំងនេះ គឺទទួលរងនូវអាកាសធាតុទ្វីប។

## ៣.២. អាកាសធាតុប្រទេសកម្ពុជា

### ក. ស្ថានភាពទូទៅនៃអាកាសធាតុប្រទេសកម្ពុជា

ប្រទេសកម្ពុជាយើងទទួលរងនូវអាកាសធាតុត្រូពិចមូសុង ដែលមានលក្ខណៈក្តៅហើយសើម និងទទួលបានទឹកភ្លៀងដោតជាំកន្លះឆ្នាំ និងខ្សត់ភ្លៀងកន្លះឆ្នាំ។ ក៏ប៉ុន្តែ សំណើម និងកម្តៅមានតិច ឬច្រើនអាស្រ័យទៅតាមភូមិភាគ និងទៅតាមរដូវ។ អាកាសធាតុបែបនេះ កើតមកពីមូលហេតុសំខាន់ៗ ២ យ៉ាងគឺ ៖

- ប្រទេសកម្ពុជាយើងមានទីតាំងភូមិសាស្ត្រស្ថិតនៅក្បែរអេក្វាទ័រ គឺស្ថិតនៅចន្លោះខ្សែស្របពីទី១០$^{0}$ ដល់ខ្សែស្របទី១៥$^{0}$ នៃរយៈទទឹងខាងជើង ឬស្ថិតនៅក្នុងតំបន់ត្រូពិច។
- ប្រទេសកម្ពុជាមានទីតាំងភូមិសាស្ត្រស្ថិតនៅក្នុងអាស៊ីមូសុងដែលមានអាកាសធាតុនៅក្រោមឥទ្ធិពលជាចិន្រ្តៃយ៍នៃរបបខ្យល់មូសុង។ ខ្យល់នេះ បង្កើតឱ្យមានរដូវ ២ យ៉ាងច្បាស់លាស់គឺ រដូវវស្សា និងរដូវប្រាំង។

### ខ. កត្តាដែលមានឥទ្ធិពលលើអាសកាសធាតុប្រទេសកម្ពុជា

កត្តាសំខាន់ៗ ដែលជះឥទ្ធិពលលើអាកាសធាតុនៅប្រទេសកម្ពុជាយើងរួមមាន សីតុណ្ហភាព ខ្យល់បក់ របបទឹកភ្លៀង និងសំណើមអាកាស។

#### ១. របបខ្យល់បក់

ដោយសារតែប្រទេសកម្ពុជាយើង មានទីតាំងស្ថិតនៅក្នុងតំបន់ភូមិភាគអាស៊ីមូសុង ជាហេតុធ្វើឱ្យខ្យល់ដែលបក់ឆ្លងកាត់ប្រទេសកម្ពុជាយើងមានរបបទៀតទាត់ ហើយបង្កើតឱ្យមានរដូវ ២ យ៉ាងច្បាស់លាស់ គឺរដូវប្រាំង និងរដូវវស្សា។

នៅរដូវប្រាំង គឺចាប់ផ្តើមពីខែវិច្ឆិកា រហូតដល់ខែមេសា។ នៅរដូវនេះ ខ្យល់មូសុងបានបក់មកពីទិសឦសានសំដៅទៅទិសនិរតី ដែលគេនិយមហៅថា ខ្យល់មូសុងប្រាំង។ ខ្យល់មូសុងប្រាំងនេះ គឺបានបក់ចេញពីមណ្ឌលសម្ពាធខ្ពស់នៅស៊ីបេរីសំដៅទៅកាន់មណ្ឌលសម្ពាធទាប ដែលគ្រប់ដណ្តប់នៅលើមហាសមុទ្រឥណ្ឌា។ ខ្យល់នេះ គឺជាខ្យល់ត្រជាក់ស្ងួត ហើយខ្សត់ទឹកភ្លៀង ពីព្រោះវាបក់កាត់ទ្វីប។ រដូវប្រាំងនេះ ត្រូវបានចែកចេញជា ២ ទៀតគឺ រដូវរងា ឬរដូវរំហើយ ដែលមានរយៈពេលចាប់ពីខែវិច្ឆិកាដល់ខែមករា និងរដូវប្រាំងពិតប្រាកដ ដែលមានរយៈពេលចាប់ពីខែកម្ភៈដល់ខែមេសា។ ក៏ប៉ុន្តែ នៅក្នុងរយៈពេលនៃរដូវប្រាំងនេះ ក៏មានភ្លៀងធ្លាក់ខ្លះៗដែរ ដែលគេនិយមហៅថា ភ្លៀងកក់ខែ។

រដូវវស្សា គឺចាប់ផ្តើមពីខែឧសភា រហូតដល់ខែតុលា។ នៅរដូវនេះ ខ្យល់មូសុងបក់ពីទិសនិរតី សំដៅទៅទិសឦសានវិញ ដែលគេនិយមហៅថា ខ្យល់មូសុងវស្សា។ ខ្យល់មូសុងវស្សានេះ បក់ចេញពីមណ្ឌលសម្ពាធខ្ពស់ដែលគ្រប់ដណ្តប់ពីលើមហាសមុទ្រឥណ្ឌាសំដៅទៅកាន់មណ្ឌលសម្ពាធទាប ដែលគ្រប់ដណ្តប់ពី

លើតំបន់ស៊ីបេរី។ ខ្យល់នេះ គឺជាខ្យល់ក្តៅ ហើយសើម ដែលសម្បូរសំណើម និងសម្បូរទឹកភ្លៀង ពីព្រោះវាបក់កាត់មហាសមុទ្រឥណ្ឌា និងសមុទ្រនានាសំដៅទៅទ្វីប ពោលគឺតំបន់ស៊ីបេរី។

## ២. របបទឹកភ្លៀង

គេអាចនិយាយបានថា ប្រទេសកម្ពុជាយើង គឺជាប្រទេសសើម ដោយសារតែប្រទេសកម្ពុជាយើងទទួលបានទឹកភ្លៀងលើសពី ១២០០ មីលីម៉ែត្រ ក្នុងមួយឆ្នាំនៅគ្រប់ទីកន្លែងទាំងអស់។ ទឹកភ្លៀងបានចាប់ផ្តើមធ្លាក់ពីពាក់កណ្តាលខែឧសភា រហូតទៅដល់ខែតុលា។ នេះឱ្យឃើញបញ្ជាក់ថា របបទឹកភ្លៀង គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងរបបខ្យល់មូសុង។ នៅរដូវមូសុងវស្សា ប្រទេសកម្ពុជាយើងទទួលបានទឹកភ្លៀងយ៉ាងជោគជាំជាទីបំផុត ព្រោះខ្យល់មូសុវស្សាងនេះបានបក់កាត់មហាសមុទ្រឥណ្ឌា ដោយបាននាំយកមកជាមួយនូវទឹកភ្លៀងយ៉ាងច្រើនសន្ធឹកសន្ធាប់ មកឱ្យប្រទេសកម្ពុជាយើងផងដែរ។ ផ្ទុយទៅវិញ នៅរដូវមូសុងប្រាំង ប្រទេសកម្ពុជាយើងទទួលបានទឹកភ្លៀងតិចតួចបំផុត ហើយ ទឹកភ្លៀងបានយ៉ាងកម្រ ដោយសារតែខ្យល់មូសុងប្រាំងនេះបក់កាត់ទ្វីប។

*តំនូសតាងស្តីពីកម្ពស់ទឹកភ្លៀង និងសីតុណ្ហភាពនៅស្ថានីយ៍ផ្ទេរ ទំនាប និងខ្ពង់រាប*

| ខែ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កំរិតទឹកភ្លៀង | 0 | 0 | 0.4 | 20.3 | 80.2 | 149.8 | 98.9 | 183.9 | 236.1 | 302.3 | 193 | 58.2 | 1323.1 |
| សី.ភាព | 26.5 | 27.7 | 29.8 | 30.7 | 30.7 | 30.1 | 30.1 | 28.5 | 28.5 | 28.1 | 27.6 | 27.9 | 28.9 |




*ប្រភព ៖ នាយកដ្ឋានឧត្តុនិយម ២០១៥ ស្ថានីយ៍ពោធិ៍ចិនតុង*

*តំនូសតាងបង្ហាញពីកម្ពស់ទឹកភ្លៀង និងសីតុណ្ហភាពនៅតំបន់ខ្ពង់រាបប្រទេសកម្ពុជា*

| ខែ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| កំរិតទឹកភ្លៀង | 27.8 | N/A | 34.4 | 71.8 | 283.8 | 178.5 | 292.8 | 119.2 | 274.1 | 221.3 | 52.4 | N/A |
| សី.ភាព | 26.9 | 27.8 | 29.1 | 29.2 | 28.7 | 29 | 27.9 | 27.7 | 28.1 | 26.7 | 25.3 | 25.1 |




*ប្រភព ៖ នាយកដ្ឋានឧត្តុនិយម ២០១៥ ស្ថានីយ៍ខេត្តកំពង់ចាម*

## *គំនូសតាងកម្ពស់ទឹកភ្លៀង និងសីតុណ្ហភាពនៅស្ថានីយ៍ខេត្តកោះកុង ២០១៥*

| ខែ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **កំរិតទឹកភ្លៀង** | 66 | 32 | 47.8 | 238.2 | 337.1 | 390.4 | 882.1 | 801.3 | 686.3 | 337.6 | 46.6 | 19.1 |
| **សីតុណ្ហភាព** | 27.9 | 27.2 | 28.9 | 29.2 | 28.6 | 29.2 | 27.6 | 27.7 | 27.8 | 28.3 | 27.8 | 27.6 |




*ប្រភព ៖ នាយកដ្ឋានឧត្តុនិយម (តំបន់ឆ្នេរសមុទ្រក្នុងប្រទេសកម្ពុជា)*

ខ្សែគំនូសកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំបញ្ជាក់ឱ្យឃើញថា របបទឹកភ្លៀងនៅប្រទេសកម្ពុជាយើងមានអតិបរមាពីរ និងអប្បរមាពីរដូចជាសីតុណ្ហភាពផងដែរ។ អតិបរមាពីរនេះ គឺមួយមាននៅខែតុលា(២៥២ ម.ម) និងមួយទៀត គឺមាននៅខែកក្កដា (១៦៥ ម.ម)និងអប្បបរមាពីរ គឺមួយមាននៅខែមករា(៧ ម.ម) និងមួយទៀតនៅខែសីហា (១៥៧ ម.ម)។ ម្យ៉ាងវិញទៀត គេតែងតែសង្កេតឃើញថា នៅក្នុងរដូវវស្សា ប្រជាជនកម្ពុជាតែងតែបានជួបប្រទះនូវឧបសគ្គមួយ គឺភាពខ្យត់ទឹកភ្លៀងដែលតែងតែកើតមានឡើងនៅចុងខែកក្កដា និងដើមខែសីហាជារៀងរាល់ឆ្នាំដែលខ្មែរយើងឱ្យឈ្មោះថា កូនរដូវប្រាំង។ រយៈពេលអត់មានភ្លៀងធ្លាក់នេះ គឺចាប់ពី ១០ ថ្ងៃ ទៅទល់នឹង ២ សប្ដាហ៍ ឬច្រើនជាងនេះទៀត ជាហេតុធ្វើឱ្យមានការលំបាកក្នុងការប្រកបរបរកសិកម្មរបស់ប្រជាជនកម្ពុជា។

ចំពោះរបាយទឹកភ្លៀងនៅប្រទេសកម្ពុជាយើងវិញ គឺមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងសណ្ឋានដី។ តំបន់ជួរភ្នំក្រវាញ និងតំបន់ឆ្នេរសមុទ្រ គឺទទួលបានភ្លៀងច្រើនជាងគេប្រចាំឆ្នាំ។ រីឯតំបន់ទំនាបកណ្ដាលវិញ ដែលមានជួរភ្នំក្រវាញបាំងជាជញ្ជាំង គឺទទួលទឹកភ្លៀងតិចជាងគេ។ នៅតំបន់ខ្ពង់រាបខាងជើង និងឦសានទឹកភ្លៀងធ្លាក់មកច្រើនជាងទំនាបកណ្ដាល ដោយសារតែតំបន់ទាំងនេះ
រយៈកម្ពស់ខ្ពស់ជាងតំបន់ទំនាបកណ្ដាល បន្ទាប់ពីជួរភ្នំក្រវាញ។

### ៣. សីតុណ្ហភាព

ដោយសារប្រទេសកម្ពុជាយើងស្ថិតនៅចន្លោះខ្សែអេក្វាទ័រ និងខ្សែត្រូពិចខាងជើង បានធ្វើឱ្យសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំនៅគ្រប់ទីកន្លែងទាំងអស់ទូទាំងប្រទេសមានកម្រិតខ្ពស់ គឺស្ថិតនៅជុំវិញ ២៧ អង្សារសេ ដោយសារដំណើរគោចរណ៍នៃព្រះអាទិត្យ បានស្ថិតនៅចំពីលើក្បាលរបស់យើងពីរដង ក្នុងរយៈពេល ១ ឆ្នាំ គឺនៅដើមខែឧសភាម្ដង ក្នុងដំណើរគោចរណ៍របស់ព្រះអាទិត្យទៅត្រូពិចខាងជើង និងម្ដងទៀត គឺនៅដើមខែសីហា ក្នុងដំណើរគោចរណ៍របស់ព្រះអាទិត្យវិលត្រឡប់មកកាន់ត្រូពិចខាងត្បូងវិញ។ ចន្លោះកម្ដៅរវាងខែដែលក្ដៅបំផុត និងខែដែលត្រជាក់បំផុតមានកម្រិតទាប គឺមានប្រមាណ ត្រឹមតែ ៤ អង្សារសេប៉ុណ្ណោះ។

ខ្សែគំនូសសីតុណ្ហភាពមធ្យមប្រចាំឆ្នាំនៅប្រទេសកម្ពុជាយើងបង្ហាញឱ្យឃើញថាសីតុណ្ហភាពនៅប្រទេសកម្ពុជាយើងមានចំណុចអតិបរមា ២ គឺមួយនៅខែមេសា និងមួយទៀតនៅខែនៅខែសីហា។ ខែដែលក្ដៅជាងគេ គឺខែមេសាដែលមានសីតុណ្ហភាពជាមធ្យម ២៩ អង្សារសេ។ រីឯចំណុចអប្បរមាវិញក៏មាន ២ ផងដែរ គឺមួយនៅខែធ្នូ និងមួយទៀត គឺនៅខែកក្កដា។ ខែដែលត្រជាក់ជាងគេបំផុត គឺខែធ្នូ ដែលមានសីតុណ្ហភាពជាមធ្យមប្រចាំខែគឺ ២៥ អង្សារសេ។

### ៤. សំណើមអាកាស

សំណើមអាកាស គឺជាវត្តមាននៃចំហាយទឹក ដែលមាននៅក្នុងអាកាស ឬនៅក្នុងខ្យល់។ សំណើមអាកាស ជាប្រភពនៃបាតុភូតឧត្តុភូតជាច្រើនយ៉ាង ដែលរួមមានដូចជា ពពក ទឹកភ្លៀង និងទឹកសន្សើម។ ក្នុងមួយឆ្នាំៗ សំណើមអាកាសនៅប្រទេសកម្ពុជាយើងតែងតែមានការប្រែប្រួលទៅតាមរដូវ។ រយៈពេលដែលមានសំណើមខ្ពស់ ឬសើមខ្លាំង គឺស្របទៅតាមកម្ពស់ទឹកភ្លៀងជាអតិបរមា (ពីខែកក្កដាដល់ខែតុលា)។ នៅរដូវប្រាំង (ពីខែមករាដល់ខែកុម្ភៈ) សំណើមអាកាសមានទាបបំផុត គឺជារយៈពេលដែលសភាវៈរស់ទាំងឡាយពិបាក ក្នុងការរស់នៅជាទីបំផុត។

## គ. មណ្ឌលអាកាសធាតុនៅប្រទេសកម្ពុជា

ដោយយោងទៅតាមសីតុណ្ហភាព និងរបាយទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំ គេចែកអាកាសធាតុនៅប្រទេសកម្ពុជាយើងជា ៣ មណ្ឌល គឺមណ្ឌលនិរតី មណ្ឌលទំនាបកណ្ដាល និងមណ្ឌលខ្ពង់រាប។

### ១. មណ្ឌលនិរតី ឬមណ្ឌលមាត់សមុទ្រ

មណ្ឌលនេះ មានអាកាសធាតុក្ដៅហើយសើមនៅត្រង់ឆ្នេរសមុទ្រ ត្រជាក់ស្រួល និងសើមនៅត្រង់តំបន់ខ្ពស់ ឬកំពូលភ្នំ។ ដោយសារតែតំបន់នេះ បែរមុខទៅរកចំទិសខ្យល់មូសុងវស្សា ហើយនិងដោយសារមានជួរភ្នំក្រវាញបាំងជាជញ្ជាំងខណ្ឌផងនោះ ទើបបានជាតំបន់នេះមានភ្លៀងធ្លាក់ច្រើនជាងតំបន់ផ្សេងៗទៀត ក្នុងប្រទេសកម្ពុជា។ នៅលើកោះមូល ក្នុងខេត្តកោះកុងមានភ្លៀងធ្លាក់រហូតដល់ទៅ ៤ ម៉ែត្រ ក្នុងមួយឆ្នាំៗ។ រីឯក្រុងកំពតវិញ ដែលស្ថិតនៅពីក្រោយជួរភ្នំ និងដោយសារតែមានកោះត្រល់នៅបាំងពីមុខផងនោះ គឺបានទទួលទឹកភ្លៀងមិនលើសពី ២.៥០ ម៉ែត្រនោះឡើយ ក្នុងមួយឆ្នាំៗ។ ដូចនេះ មណ្ឌលនិរតី គឺជាមណ្ឌលដែលមានសំណើមខ្ពស់ និងជាតំបន់ព្រៃស្អុក ដែលមានពណ៌បៃតងជានិច្ចពេញមួយឆ្នាំ។ ថ្វីត្បិតតែនៅតាមឆ្នេរសមុទ្រមានបរិយកាសក្ដៅក៏ដោយ ក៏សភាវៈទាំងឡាយនៅក្នុងតំបន់នេះ តែងតែទទួលឥទ្ធិពលដ៏ធូរស្រាលពីសមុទ្រផងដែរ គឺខ្យល់ជំនោរសមុទ្រដ៏ត្រជាក់ស្រួល។

*របាយ និងកម្ពស់ទឹកភ្លៀងតាមមណ្ឌលនីមួយៗនៅប្រទេសកម្ពុជា*




### ២. មណ្ឌលឦសាន ឬមណ្ឌលខ្ពង់រាប

មណ្ឌលឦសាន ឬតំបន់ខ្ពង់រាបទាំងអស់នៅក្នុងប្រទេសកម្ពុជាយើងច្រើនមានលក្ខណៈក្ដៅហើយសើម។ ក៏ប៉ុន្តែជាទូទៅ គេសង្កេតឃើញថា មណ្ឌលនេះមានអាកាសធាតុក្ដៅនៅពេលថ្ងៃ និងត្រជាក់នៅពេលយប់។ នៅរដូវប្រាំង អាកាសធាតុនៅក្នុងមណ្ឌលនេះ គឺមានលក្ខណៈស្រួលរស់នៅ រហូតដល់ខែមីនា។ រីឯនៅលើកំពូលភ្នំវិញ សីតុណ្ហភាពមានលក្ខណៈជាទីមនោរម្យ គឺត្រជាក់ស្រួលពេញមួយឆ្នាំ។ ដោយសារតែមណ្ឌលនេះ មានរយៈកម្ពស់ខ្ពស់មធ្យម និងសម្បូរទៅដោយព្រៃឈើ ទើបបានជាមណ្ឌលនេះ មានភ្លៀងធ្លាក់ច្រើនជាងនៅតំបន់ទំនាបកណ្ដាល។ កម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំនៅមណ្ឌលនេះ មានលើសពី ២ ម៉ែត្រ បន្ទាប់ពីមណ្ឌលនិរតី ដែលជាមណ្ឌលទទួលបានទឹកភ្លៀងខ្ពស់ជាងគេបំផុតនៅប្រទេសកម្ពុជា។

### ៣. មណ្ឌលទំនាបកណ្ដាល

មណ្ឌលទំនាបកណ្ដាល ជាតំបន់វាលទំនាបនៃទន្លេមេគង្គ និងវាលទំនាបនៃទន្លេសាប (ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តតាកែវ និងរាជធានីភ្នំពេញ)។ មណ្ឌលនេះ មិនបានទទួលនូវរបបខ្យល់មូសុងពីទិសនិរតីនោះទេ ដោយសារតែមានជួរភ្នំក្រវាញបាំងជាជញ្ជាំង ដែលជាឧបសគ្គដល់ការជ្រៀតចូលនៃខ្យល់មូសុងវស្សាទៅក្នុងតំបន់ទំនាបកណ្ដាល ជាហេតុធ្វើឱ្យមណ្ឌលនេះមានអាកាសធាតុក្ដៅជាង និងស្ងួតជាងមណ្ឌលដទៃទៀតនៅប្រទេសកម្ពុជា។ ចាប់ពីខែកុម្ភៈរហូតដល់ខែមេសា អាកាសធាតុនៅក្នុងមណ្ឌលនេះ គឺមានលក្ខណៈក្ដៅខ្លាំង ដែលពិបាកទ្រាំទ្របន្តិច។

ប៉ុន្តែទោះបីជាយ៉ាងដូចនេះក្ដី តំបន់ទំនាបកណ្ដាលតែងតែទទួលបានទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំលើសពី ១ ម៉ែត្រ ស្ទើរតែនៅគ្រប់ទីកន្លែងទាំងអស់ ក្នុង ១ ឆ្នាំ។ រាជធានីភ្នំពេញបានទទួលទឹកភ្លៀង ១.៤០ ម៉ែត្រ ក្នុងមួយឆ្នាំ។ ក្នុងមណ្ឌលទំនាបកណ្ដាលនេះ មានតំបន់តិចតួចណាស់ដែលបានទទួលទឹកភ្លៀងតិចជាង ១ ម៉ែត្រ ក្នុង ១ ឆ្នាំ ជាពិសេសតំបន់ ដែលស្ថិតនៅពីក្រោយជួរភ្នំក្រវាញដូចជា កំពង់កន្ទួត និងចំបក់ក្នុងខេត្តកណ្ដាល និងតំបន់ខ្លះៗទៀតនៅក្នុងខេត្តតាកែវ និងខេត្តកំពត។

***ផែនទីកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំតាមតំបន់នានានៃប្រទេសកម្ពុជា***




## ឃ. សារៈសំខាន់សេដ្ឋកិច្ចនៃអាសធាតុប្រទេសកម្ពុជា

អាកាសធាតុនៅប្រទេសកម្ពុជាបង្កលក្ខណៈអនុគ្រោះយ៉ាងខ្លាំងដល់ប្រទេសកម្ពុជាយើងទាំង សេដ្ឋកិច្ច សង្គម មនុស្ស សត្វ និងរុក្ខជាតិដូចជា ៖

- ចំពោះវិស័យកសិកម្ម ៖ ប្រទេសកម្ពុជាយើងស្ថិតនៅក្នុងតំបន់ត្រូពិច ហេតុដូចនេះ ប្រទេសយើង គឺទទួលបានបរិមាណកម្តៅជាមធ្យមប្រចាំឆ្នាំខ្ពស់។ ការទទួលបាននូវបរិមាណកម្តៅដ៏ខ្ពស់នេះ អាចឱ្យរុក្ខជាតិស្រូបសយក ដើម្បីធ្វើរស្មីសំយោគផលិតអាហារ សម្រាប់ទ្រទ្រង់ដល់ការដុះលូត លាស់របស់វាបានយ៉ាងល្អប្រសើរ។ ជាមួយនឹងបរិមាណកម្តៅនេះដែរ ដំណាំទាំង ឡាយអាចដុះ លូតលាស់បានយ៉ាងងាយស្រួល។ ការដុះលូតលាស់ នៃដំណាំគ្រប់ប្រភេទទាំងអស់មិនមានការ បង្កភាពអាក់ខាន ហើយព្រមទាំងផ្តល់នូវភោគផលយ៉ាងជាទីគាប់ចិត្តដល់កសិករថែមទៀតផង។ ស្ថានភាពបែបនេះ គឺខុសគ្នាពីបណ្តាប្រទេស ដែលមានអាកាសធាតុត្រជាក់ ដែលអនុគ្រោះដល់ ការធ្វើកសិកម្មបានត្រឹមតែប៉ុន្មានខែប៉ុណ្ណោះ ក្នុងមួយឆ្នាំៗ។
- ចំពោះវិស័យឧស្សាហកម្ម ៖ ក្នុងវិស័យឧស្សាហកម្ម អាកាសធាតុនៅប្រទេសកម្ពុជាក៏បានបង្កនូវ លក្ខណៈល្អប្រសើរផងដែរ។ អាកាសធាតុមិនក្តៅពេក មិនត្រជាក់ពេក និងមានភ្លៀងធ្លាក់ទៅ តាមរដូវបែបនេះ គឺបង្កនូវលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍន៍វិស័យឧស្សាហកម្មដូចជា សម្បូរ រូបធាតុដើមពីកសិកម្ម សម្បូរថាមពលពីវារីអគ្គិសនី ងាយស្រួលស្ថាបនារោងចក្រ ងាយស្រួលដឹក ជញ្ជូនរូបធាតុដើម និងងាយស្រួលដឹកជញ្ជូនផលិតផលសម្រេចទៅកាន់ទីផ្សារ។
- ចំពោះវិស័យទេសចរណ៍ ៖ ភ្លៀងធ្លាក់ច្រើនបង្កលក្ខណៈឱ្យសម្បូរទឹកធ្លាក់ សម្បូរព្រៃឈើ និង សម្បូរសត្វព្រៃ ដែលសុទ្ធសឹងតែបម្រើឱ្យដល់វិស័យទេសចរណ៍។ ធាតុអាកាសមិនក្តៅពេក មិន ត្រជាក់ពេក និងមានភ្លៀងធ្លាក់ទៅតាមរដូវបែបនេះ គឺបង្កលក្ខណៈងាយស្រួលដល់ការធ្វើ ដំណើរកំសាន្តរបស់អ្នកទេសចរទាំងភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ ដើរបានសព្វទីកន្លែង។

- ចំពោះវិស័យទំនាក់ទំនងផ្នែកផ្សេងៗទៀតនៃសេដ្ឋកិច្ច ៖ ក្នុងវិស័យទំនាក់ទំនងផ្នែកផ្សេងៗទៀតនៃសេដ្ឋកិច្ច អាកាសធាតុនៅប្រទេសកម្ពុជាបាននាំមក នូវផលវិជ្ជមានគួរជាទីមោទនៈ និងគួរឱ្យកត់សម្គាល់។ បើនិយាយអំពីថាមពលវិញ កម្ពស់ទឹកភ្លៀងខ្ពស់បង្កនូវភាពអនុគ្រោះដល់ការស្តាបនាទំនប់វារីអគ្គិសនីនៅតាមដងទន្លេ ដៃទន្លេ និងទឹកធ្លាក់ជាច្រើនកន្លែង។ បើនិយាយពីបណ្តាញគមនាគមន៍វិញ កម្ពស់ទឹកភ្លៀងខ្ពស់បង្កលក្ខណៈងាយស្រួលដល់ការធ្វើចរាចរបស់នាវាគ្រប់ប្រភេទនៅតាមប្រព័ន្ធផ្លូវទឹក។
- ចំពោះជីវិតមនុស្ស និងសត្វ ៖ អាកាសធាតុនៅប្រទេសកម្ពុជា ពុំបង្កឱ្យមានឥទ្ធិពលអវិជ្ជមានអ្វីជាធំដុំដែលបណ្តាលឱ្យមានគ្រោះមហន្តរាយ ឬគ្រោះកាចចង្រៃដល់ជីវិតមនុស្ស និងសត្វប៉ុន្មាននោះទេ។

## ង. ឥទ្ធិពលនៃអាកាសធាតុ និងបញ្ហាចោទនៅប្រទេសកម្ពុជា

អាកាសធាតុនៅប្រទេសកម្ពុជាបង្កភាពអនុគ្រោះដល់ដុះការលូតលាស់ នៃប្រភេទរុក្ខជាតិគ្រប់បែបយ៉ាង។ ហេតុដូចនេះហើយ បានជាគេឃើញប្រទេសកម្ពុជាយើងសម្បូរទៅដោយព្រៃឈើ ដែលគ្របដណ្តប់យ៉ាងក្រាស់នៅតំបន់ភ្នំ និងតំបន់ខ្ពង់រាប។ ប៉ុន្តែដោយសារតែរដូវប្រាំងមានរយៈពេលវែងពេក ទើបព្រៃឈើទាំងនោះច្រើនតែជាព្រៃរបោះដូចជានៅតំបន់ទំនាបកណ្តាល និងតំបន់ខ្ពស់ភាគខាងជើងជាដើម។ ក្រៅពីនេះដំណាំដាំដុះផ្សេងៗទៀត ក៏មានលទ្ធភាពដុះលូតលាស់បានយ៉ាងងាយស្រួលផងដែរ រីឯជីវិតសត្វ និងមនុស្សវិញ ក៏ពុំមានឥទ្ធិពលអ្វីជាធំដុំនោះដែរ។

ប៉ុន្តែទោះបីជាយ៉ាងណាក្តី អាកាសធាតុប្រទេសកម្ពុជាបាននាំមកនូវគ្រោះមហន្តរាយខ្លះៗដែរដល់មនុស្ស សត្វ និងរុក្ខជាតិនៅប្រទេសកម្ពុជាយើដូចជា ៖

- កម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំខែ និងប្រចាំឆ្នាំ តែងតែមានការប្រែប្រួលយ៉ាងខ្លាំង ដែលគួរឱ្យ
- កត់សម្គាល់ សម្រាប់ផ្នែកសេដ្ឋកិច្ចជាតិ ពិសេសក្នុងវិស័យកសិកម្ម។
- ទឹកភ្លៀងមានរបាយមិនស្មើគ្នាទៅតាមតំបន់នោះទេ។ គេឃើញតំបន់ទំនាបកណ្តាល ដែលជាតំបន់កសិកម្មយ៉ាងប្រសើរនោះ បែរជាមានភ្លៀងធ្លាក់តិច ហើយមិនទៀងទាត់។ មានកន្លែងខ្លះរយៈពេលរាំងស្ងួតមានវែងអន្លាយ ហើយកន្លែងខ្លះទៀតមានភ្លៀងធ្លាក់ជោគជាំពេក។
- ភ្លៀងខ្លាំងហើយច្រើនអាចបណ្តាលឱ្យមានទឹកជំនន់ធំ ក្នុងផ្លូវទឹកទាំងឡាយ និងអាចបង្កើតសំណឹកខ្លាំងនៅលើផ្ទៃដីទាំងនេះដែលជាមូលហេតុនៃគ្រោះថ្នាក់ដល់បណ្តាជន និងបណ្តាញផ្លូវគមនាគមន៍។ ហេតុនេះហើយ ទើបគេឃើញអ្នកនៅជនបទនៅប្រទេសកម្ពុជាស្ថិតនៅក្នុងការគំរាមកំហែងនៃមហន្តរាយពីរធំៗគឺ ភាពរាំងស្ងួតជៀសមិនផុតរាល់ឆ្នាំ និងគ្រោះទឹកជំនន់នៅរដូវវស្សា។
- អាកាសធាតុប្រទេសកម្ពុជាយើង គឺពុំសូវមានការអនុគ្រោះឡើយ។ ទំនាបវាលភក់ និងតំបន់កំពូលភ្នំជាតំបន់ជំងឺគ្រុនចាញ់។ ប្រជាជនច្រើនតែជួបប្រទះនូវរោគរាតត្បាតផ្សេងៗដូចជា ជំងឺអុត ជំងឺអាសន្នរោគ និងជំងឺប៉េសជាដើម។ ប៉ុន្តែទោះបីជាគ្មានរោគទាំងនេះ ក៏មានកម្តៅដែលបណ្តាលឱ្យមានភាពខ្សោយកម្លាំងកាយ និងកម្លាំងប្រាជ្ញាដែរ មានតែស្ថានីយ៍អាកាសធាតុនោះទេ ដែលមានការអនុគ្រោះដល់ស្ថានភាពនៃការរស់នៅដូចជា ឆ្នេរខ្សាច់ មាត់សមុទ្រ ឬស្ថានីយ៍កំពូលភ្នំបូកគោ និងគីរីរម្យជាដើម។

សរុបសេចក្តីទៅ អាកាសធាតុប្រទេសកម្ពុជាមានលក្ខណៈល្អប្រសើរណាស់ ដល់ការដុះលូតលាស់នៃរុក្ខជាតិ និងដំណាំ ក៏ប៉ុន្តែពុំអាចាត់ទុកថាប្រសើរដល់កសិកម្មទាំងស្រុងនៅឡើយ ពីព្រោះមានឧបសគ្គដូចបានរៀបរាប់ខាងលើនេះ។

ដើម្បីដោះស្រាយបញ្ហានេះ គេត្រូវអនុវត្តនូវនយោបាយទឹក គឺជីកព្រែក ធ្វើប្រឡាយ ស្ថាបនាទំនប់ទឹក និងអាងទឹកឱ្យបានច្រើន និងគ្រប់ទិសទី។ នយោបាយនេះ អាចបំបាត់នូវកង្វះទឹក សម្រាប់ធ្វើស្រែចម្ការផង និងអាចបន្ថយឥទ្ធិពលទឹកជំនន់ពីទន្លេផង។

**សំណួរត្រិះរិះ**

1. អ្វីជាធាតុអាកាស? តើធាតុអាកាសមានធាតុផ្សំអ្វីខ្លះ?
2. អ្វីជាអាកាសធាតុ? តើមានកត្តាអ្វីខ្លះដែលជះឥទ្ធិពលលើអកាសធាតុ? ចូរពន្យល់។
3. តើអាកាសធាតុនៅប្រទេសកម្ពុជាមានលក្ខណៈដូចម្តេចខ្លះ? ចូរពិពណ៌នាពីឥទ្ធិពលនៃអាកាសធាតុនៅប្រទេសកម្ពុជាទៅលើជីវិតមនុស្ស សត្វ និងរុក្ខជាតិ។
4. តើគេចែកអាកាសធាតុនៅប្រទេសកម្ពុជាជាប៉ុន្មានមណ្ឌល? អ្វីខ្លះ? ចូរពន្យល់។

## ៤. ធនធានរ៉ែនៅកម្ពុជា

### ៤.១. លក្ខណៈទូទៅនៃរ៉ែ

#### ក. និយមន័យ

រ៉ែ គឺជារូបធាតុ ឬជាអង្គធាតុ ឬជាសមាសធាតុរឹងអសរីរាង្គ ដែលកើតឡើងដោយធម្មជាតិនៅលើ និងក្នុងសំបកផែនដី ក្នុងទម្រង់ជាក្រាម។ សម្បកផែនដីរបស់យើងផ្សំពីរ៉ែ ដែលជាអង្គធាតុ ឬសមាសធាតុសរីរាង្គលើកលែងតែមួយផ្នែកតូចដែលមានអង្គធាតុសរីរាង្គ ឬសមាសធាតុសរីរាង្គ។ រ៉ែខ្លះផ្សំឡើងពីធាតុតែមួយមុខដូចជា មាស (Au) ប្រាក់ (Ag) ពេជ្រ (Zr) ទង់ដែង (Cu) ស្ពាន់ធ័រ (S) និងអាលុយមីញ៉ូម (Al) ជាដើម។ ចំណែកឯរ៉ែខ្លះទៀត គឺជាសមាសធាតុអសរីរាង្គ ដែលផ្សំឡើងពីធាតុ អុកស៊ីសែន ($O_2$) ស៊ីលីស្យូម (Si) កាល់ស្យូម (Ca) អាលុយមីញ៉ូម (Al) សូដ្យូម (Na) ប៉ូតាស្យូម (K) ដែក (Fe) និងម៉ាញ៉េស្យូម (Mg) ដូចជា អំបិលសម្ល (សូដ្យូមក្លរ - NaCl) ថ្មកំបោរ ($CaCO_3$ - កាល់ស្យូមកាបូណាត និងក្វាត ($SO_2$ - ស៊ីលីស្យូមឌីអុកស៊ីត) ជាដើម។

កំណាប់រ៉ែ គឺជាបណ្តុំនៃរូបធាតុ ឬអង្គធាតុ ឬសមាសធាតុរឹងអសរីរាង្គ ដែលកើតឡើងដោយធម្មជាតិនៅលើ និងក្នុងសម្បកកផែនដី ដែលមានតម្លៃសេដ្ឋកិច្ច ហើយអាចឱ្យគេធ្វើអាជីវកម្មបាន។

សន្ទស្សន៍រ៉ែ គឺប្រភេទរ៉ែទាំងឡាយណា ដែលត្រូវបានគេសិក្សាស្រាវជ្រាវរកឃើញនៅទីកន្លែងណាមួយ ឬតំបន់ណាមួយនៅលើ និងនៅក្នុងសម្បកផែនដី ប៉ុន្តែគេមិនទាន់បានធ្វើអាជីវកម្ម ដើម្បីទាញយកវាមកប្រើប្រាស់នៅឡើយ។

## ខ. លក្ខណៈសម្គាល់នៃរ៉ែ

រ៉ែនៅលើផែនដីរបស់យើងមានច្រើនប្រភេទណាស់។ គេអាចស្គាល់ ឬកំណត់ពីប្រភេទរបស់រ៉ែទាំងនោះបាន ដោយសារគេប្រើប្រាស់នូវវិធីមួយចំនួន ដែលជាគោលការណ៍វិទ្យាសាស្ត្រ។ តាមរយៈវិធីទាំងនេះ គឺគេអាចសង្កេតមើលទៅលើ ពណ៌ ស្នាមពណ៌ ផ្លេកលោហៈ ភាពរឹង ស្នាមប្រេះ បំណែក និង ប្រព័ន្ធក្រាមរបស់រ៉ែ។

### ១. ពណ៌ (Color)

ពណ៌របស់រ៉ែ គឺជាលក្ខណៈសម្គាល់ដំបូង និងសាមញ្ញបំផុតរបស់រ៉ែ ប៉ុន្តែជារឿយៗវាមិនមានសារៈប្រយោជន៍ណាស់ណានោះទេ ដើម្បីស្គាល់ពីប្រភេទរបស់រ៉ែនោះឱ្យបានច្បាស់លាស់។ ពណ៌របស់រ៉ែ គឺមានភាពងាយស្រួល ក្នុងការសម្គាល់លក្ខណៈរូបរបស់រ៉ែ ក៏ប៉ុន្តែពណ៌តែមួយអាចផ្តល់ពត៌មានអំពីប្រភេទរបស់រ៉ែបានតិចតួចតែប៉ុណ្ណោះដូចជា រ៉ែមាស រ៉ែពីរីត រ៉ែកាល់ពីរីត ដែលរ៉ែ ៣ ប្រភេទមានពណ៌មាសដូចគ្នា ប៉ុន្តែមានតែរ៉ែមួយប្រភេទប៉ុណ្ណោះដែលជារ៉ែមាសពិតប្រាកដ នោះគឺរ៉ែមាស។ ពណ៌របស់រ៉ែអាចប្រើប្រាស់ ដើម្បីសម្គាល់រ៉ែបានតែមួយចំនួនតូច ដែលមានលក្ខណៈផ្ទាល់របស់វាតែប៉ុណ្ណោះដូចជា រ៉ែម៉ាឡារីតតែងតែមាន ពណ៌បៃតង រីឯអាស៊ូរីតមានពណ៌ខៀវ។

### ២. ស្នាមពណ៌ (Steak)

ស្នាមពណ៌ គឺជាពណ៌នៃម្សៅរបស់រ៉ែ នៅពេលដែលគេឆូត ឬឆ្កូតវានៅលើចានប៉សឺឡែន។ ស្នាមពណ៌របស់រ៉ែ គឺជាវិធីមួយទៀត ដែលគេប្រើប្រាស់ សម្រាប់សម្គាល់អំពីលក្ខណៈរបស់រ៉ែ។ ការធ្វើស្នាមពណ៌រ៉ែអាចផ្តល់នូវស្លាកស្នាមមួយ ដើម្បីកំណត់ពីអត្តសញ្ញាណរ៉ែមួយប្រភេទបាន។ ស្នាមពណ៌របស់រ៉ែ គឺជាពណ៌នៃម្សៅរបស់វា ហើយស្នាមពណ៌ និងពណ៌របស់រ៉ែតែងតែខុសគ្នាដូចជា រ៉ែពីរីតជាដើម គឺមានពណ៌មាស ប៉ុន្តែម្សៅរបស់វា គឺមានពណ៌បៃតងក្រម៉ៅទៅវិញ។

### ៣. ផ្លេកលោហៈ (Luster)

ផ្លេកលោហៈ គឺជាគុណភាព ហើយនិងកម្រិតសកម្មនៃពន្លឺដែលបានចាំងផ្លាតចេញពីផ្ទៃរបស់រ៉ែ។ ការធ្វើតេស្តជម្មតាមួយបែបផ្សេងទៀត ដើម្បីកំណត់អត្តសញ្ញាណរ៉ែ គឺការពិនិត្យមើលទៅលើផ្លេកលោហៈរបស់រ៉ែ។ ផ្លេកលោហៈពិពណ៌នាអំពីពន្លឺដែលចាំងផ្លាតពីផ្ទៃរបស់រ៉ែ។ រ៉ែដែលមានផ្ទុកទៅដោយលោហៈតែងតែមានភាពភ្លឺចែងចាំងជានិច្ច រីឯរ៉ែដែលផ្ទុកទៅដោយអលោហៈតែងតែមានផ្ទៃរលោង និងស្រអាប់ជានិច្ច។ ក៏ប៉ុន្តែការប្រើប្រាស់វិធីបែបនេះ ដើម្បីកំណត់សម្គាល់ប្រភេទរ៉ែនោះអាចឱ្យគេសម្គាល់បានតែរ៉ែពីប្រភេទប៉ុណ្ណោះ គឺរ៉ែលោហៈ និងរ៉ែអលោហៈ។

### ៤. ភាពរឹង (Hardness)

ភាពរឹង គឺជាភាពធន់នៃផ្ទៃរបស់រ៉ែ ក្នុងការទប់ទល់ទៅនឹងការឆ្កូត ឬឆូតលើផ្ទៃរបស់វា។ ការពិនិត្យមើលទៅលើភាពរឹងរបស់រ៉ែ គឺជាវិធីមួយផ្សេងទៀត ដែលអាចឱ្យគេសម្គាល់អំពីប្រភេទរ៉ែបានផងដែរ។ ស្លាកស្នាម ដែលជាក់លាក់ជាងគេមួយ ដើម្បីកំណត់អត្តសញ្ញាណរ៉ែ គឺការធ្វើតេស្តភាពរឹងរបស់រ៉ែនេះឯង។ ភាពរឹងនៃរ៉ែមួយប្រភេទ គឺការធន់ទៅនឹងស្នាមឆ្កូតលើផ្ទៃរបស់វា។ ជាទូទៅ អ្នកវិទ្យាសាស្ត្របានកំណត់យកសំណាក នៃភាពរឹងពី ១ ដល់ ១០ ដោយផ្អែកលើមាត្រដ្ឋានម៉ូស (Mohs Hardness Scale)។ ខាងក្រោម

នេះ គឺជាភាពរឹងរបស់ប្រភេទរ៉ែ ដែលមានលំដាប់ពី ១ ដល់ ១០។ រ៉ែដែលទន់ជាងគេ គឺរ៉ែថក ដែលមានលំដាប់លេខ ១ និងរ៉ែ ដែលរឹងជាងគេ គឺរ៉ែពេជ្រ ដែលមានលំដាប់លេខ ១០។

- **ថក** (Talc) ៖ ជារ៉ែ ដែលមានសភាពទន់ជាងគេ ហើយអាចឆ្កូតនឹងក្រចកដៃបាន
- **ម្នាងសិលា** (Gypsum) ៖ ងាយឆ្កូតនឹងក្រចកដៃ
- **កាលស៊ីត** (Calcite) ៖ អាចឆ្កូតនឹងកាក់ទង់ដែងបាន
- **ភ្លុយអរីត** (Fluorite) ៖ ងាយឆ្កូតនឹងកាំបិតដែកថែប
- **អាប៉ាទីត** (Apatite) ៖ អាចឆ្កូតនឹងកាំបិតដែកថែបបាន
- **ផែលស្បាត** (Feldspar) ៖ មិនអាចឆ្កូតនឹងកាំបិតដែកថែបបាននោះទេ ក៏ប៉ុន្តែគេអាចឆ្កូតនឹងកញ្ចក់បង្អួចបាន
- **ក្វាត** (Quartz) ៖ អាចឆ្កូតនឹងកាំបិតដែកថែប និងកញ្ចក់រឹងបាន
- **ពេជ្រពណ៌លឿង** (Topaz) ៖ អាចឆ្កូតក្វាតបាន
- **កូរ៉ានដិម** (Corundum) ៖ អាចឆ្កូតពេជ្រពណ៌លឿងបាន
- **ពេជ្រ** (Diamond/ Zircon) ៖ អាចឆ្កូតគ្រប់សារធាតុទាំងអស់បាន

**៥. ប្រព័ន្ធក្រាម ឬទម្រង់លក្រាម (Crystal Form)**

ប្រព័ន្ធក្រាម ឬទម្រង់ក្រាម គឺជាការតម្រៀបគ្នារាងជ្រុងនៃអាតូម នៅក្នុងរូបធាតុ ដែលបង្កើតបានជាទម្រង់របស់អង្គធាតុ ឬសមាសធាតុមួយ។ ប្រព័ន្ធក្រាម ឬទម្រង់ក្រាម គឺជាវិធីមួយទៀត ដែលគេអាចប្រើប្រាស់ សម្រាប់សម្គាល់ពីប្រភេទរបស់រ៉ែបាន។ ប្រភេទរ៉ែខុសគ្នា គឺមានប្រព័ន្ធក្រាម ឬទម្រង់ក្រាមខុសគ្នា។ ប្រព័ន្ធក្រាម ឬទម្រង់ក្រាមនៃប្រភេទរ៉ែនីមួយៗ មានអាតូមតម្រៀបគ្នារាងជ្រុង ទៅតាមលំដាប់លំដោយដ៏ទៀងទាត់។ ទម្រង់ក្រាមនៃប្រភេទរ៉ែទាំងនេះ កើនឡើងពីអាតូមមួយទៅអាតូមមួយទៀត ដើម្បីបង្កើតទម្រង់ក្រាមរបស់វា។ អ្នកធរណីវិទូបានធ្វើចំណាត់ថ្នាក់ទម្រង់នេះជា ៧ ក្រុម ដោយផ្អែកទៅលើចំនួនជ្រុង និងមុំនៃក្រាមដែលហៅថា ប្រព័ន្ធគ្រាប់ក្រាម។ ទម្រង់ក្រាមទាំងនេះមានដូចជា ទ្រីកូណាល់ (ក្វាត) តេត្រាកូណាល់ (វ៉ុលផេនីត) អូតូរ៉ូមបិច (អារ៉ាកូនីត) ទ្រីគ្លីនិច (ផែលស្ប៉ាត) គូប (ពីរីត) អេសាកូណាល់ (បេរីល) និងម៉ូណូគ្លីនិច (អរតូក្លាស)។

**៦. ស្នាមប្រេះ (Cleavage)**

លក្ខណៈសម្គាល់មួយទៀតនៃប្រភេទរ៉ែ គឺស្នាមប្រេះរបស់រ៉ែ។ ស្នាមប្រេះនៃរ៉ែ គឺជានិន្នាការនៃរ៉ែ នៅពេលដែលមានការប្រេះស្រាំ។ ស្នាមប្រេះរបស់រ៉ែ គឺជាវិធីមួយផ្សេងទៀត ដែលអាចឱ្យគេសម្គាល់បានអំពីប្រភេទរ៉ែផងដែរ។ ស្នាមប្រេះនៃរ៉ែ តែងតែកើតមានឡើងនៅតាមបណ្តោយប្លង់ស្របនៃការចងសម្ព័ន្ធគីមីខ្សោយរបស់រ៉ែជានិច្ច។ ស្នាមប្រេះរបស់រ៉ែ គឺអាស្រ័យលើការតម្រៀបគ្នានៃអាតូមនៅក្នុងគ្រាប់ក្រាមរបស់វាដែលធ្វើឱ្យវាងាយបែកជាផ្នែកៗ ទៅតាមទិសដៅតែមួយ។ ទីកន្លែងដែលស្នាមប្រេះនេះកើតឡើង គឺអាស្រ័យទៅលើតំបន់នៃភាពខ្សោយនៅក្នុងទម្រង់ក្រាមនៃរ៉ែ។ ឧទាហរណ៍ ៖ រ៉ែមីកានឹងប្រេះស្រាំតាមបណ្តោយស្នាមប្រេះនៃភាពខ្សោយ ហើយក្លាយទៅជាបន្ទះតូចៗ។ រីឯរ៉ែកាល់ស៊ីត និងរ៉ែហាលីតនឹងប្រេះបែក

តាមទិសដៅបីបែបខុសៗគ្នា ហើយប្រសិនបើយើងវាយរ៉ែនីមួយៗនឹងញញួរវិញ រ៉ែទាំងនេះនឹងប្រេះបែកជាបន្ទះតូចៗ ដោយមានជ្រុងមិនផ្លាស់ប្តូរនឹងទ្រង់ទ្រាយដើមរបស់វានោះឡើយ។

**៧. បំណែក (Fracture)**

មធ្យោបាយមួយទៀត ដើម្បីស្គាល់ពីប្រភេទរបស់រ៉ែ គឺការពិនិត្យមើលទៅលើបំណែករបស់រ៉ែ។ បំណែករបស់រ៉ែ គឺជាចំណិត ឬភាគរបស់រ៉ែ ដែលបានបែកដាច់ចេញពីគ្នា។ បំណែករបស់រ៉ែ គឺអាស្រ័យទៅលើផ្ទៃបែកមិនទៀងទាត់របស់ប្រភេទរ៉ែនីមួយៗ ដែលមិនបង្ហាញនូវស្នាមប្រេះស្រាំ នៅពេលដែលរ៉ែទាំងនោះបាក់បែក។ ប្រភេទរ៉ែខុសគ្នា គឺមានស្លាកស្នាមនៅលើផ្ទៃដែលបែកបាក់ខុសគ្នា។ ប្រភេទរ៉ែខ្លះ នៅពេលដែលបែកបាក់ចេញពីគ្នា មានស្នាមបំណែកនៅលើផ្ទៃរបស់វារាបស្មើ រីឯប្រភេទរ៉ែខ្លះទៀតមានស្នាមបំណែកគគ្រើម និងរេចរឆូចៗ។

## គ. កំណកំណើតនៃរ៉ែ

សំបកផែនដីរបស់យើងកើតឡើងពីសិលា ហើយសិលាទាំងនោះគឺផ្សំឡើងពីរូបធាតុអសរីរាង្គ ជាច្រើនប្រភេទ គឺរ៉ែ។ សំណាករ៉ែដែលល្អជាងគេ តែងតែកើតឡើងនៅក្នុងសូលុយស្យុងទឹកក្តៅក្រោមដី។ ស្នាមប្រេះ ឬស្នាមបាក់បែកនៅក្នុងសំបកផែនដីអាចឱ្យរូបធាតុរាវ ហើយក្តៅហូរកាត់បាន។ រូបធាតុរាវទាំងនេះមានផ្ទុកនូវអង្គធាតុ និងសមាសធាតុដែលបង្កើតបានជារ៉ែជាច្រើនប្រភេទ។ សំណាករ៉ែដែលកើតឡើងពីសិលាភ្នំភ្លើងមានកំណក្រាមដោយផ្ទាល់ពីការចុះត្រជាក់នៃម៉ាក់ម៉ា (សិលាដែលរលាយនៅក្បែរ ឬនៅក្នុងផ្ទៃផែនដី) ឬកំអែភ្នំភ្លើង (សិលារលាយដែលហៀរមកលើផ្ទៃផែនដី)។ នៅក្នុងសិលាប្រែ កំណើត កំណក្រាមរ៉ែបានកកើតឡើង នៅពេលដែលសិលាទទួលរងលំនាំប្រែកំណើត។ នៅក្នុងសិលាកំទេចកំណ កំណក្រាមរ៉ែបានកើតឡើងពីសូលុយស្យុងមានសីតុណ្ហភាពទាប ដែលតែងតែនៅក្បែរផ្ទៃផែនដី។ ដូចនេះ ជាទូទៅ រ៉ែបានកកើតឡើងពីមធ្យោបាយ ៤ ប្រភេទ ដែលរួមមាន ៖

- រ៉ែកើតឡើងពីការឡើងក្រាមនៃសិលាភ្នំភ្លើង (ម៉ាក់ម៉ា និងកំអែភ្នំភ្លើង)
- រ៉ែកើតឡើងពីរំហួតសូលុយស្យុងទឹក (របេច)
- រ៉ែកើតឡើងពីសូលុយស្យុងទឹកក្តៅ
- រ៉ែកើតឡើងពីការប្រែកំណើតរបស់សិលា

**១. រ៉ែកើតពីការឡើងក្រាមនៃសិលាភ្នំភ្លើង (ម៉ាក់ម៉ា និកំអែភ្នំភ្លើង)**

មានរ៉ែជាច្រើនប្រភេទបានកើតឡើងពីម៉ាក់ម៉ា និងកំអែភ្នំភ្លើង។ ម៉ាក់ម៉ាជារូបធាតុរលាយបានមកពីស្រទាប់ម៉ង់តូនៅក្នុងផែនដី ដែលកករឹងបង្កើតបានជាសិលា។ កំអែភ្នំភ្លើង គឺជាម៉ាក់ម៉ាដែលឡើងមកខាងលើនៃផ្ទៃផែនដី។ កំអែភ្នំភ្លើង ក៏បង្កើតបានជាសិលាផងដែរ នៅពេលដែលវាចុះត្រជាក់ ហើយបានកករឹង។ មានរ៉ែជាច្រើនប្រភេទបានកកើតឡើងពីម៉ាក់ម៉ា និងកំអែភ្នំភ្លើង នៅពេលវាចុះត្រជាក់។ រ៉ែទាំងនេះបានកើតឡើងពីម៉ាក់ម៉ាក្តៅ ហើយបានចុះត្រជាក់ក្នុងជម្រៅផែនដី ឬកកើតឡើងពីកំអែភ្នំភ្លើង ដែលកករឹងលើផ្ទៃផែនដី។ ជាទូទៅ រ៉ែបានកកើតឡើងនៅពេលដែលសិលារាវក្តៅ ឬម៉ាក់ម៉ាចុះត្រជាក់ និងបានកករឹងក្លាយទៅជារូបធាតុរឹង។ ម៉ាក់ម៉ាក្តៅខ្លាំងណាស់ ហើយម៉ូលេគុលរបស់វាបានផ្លាស់ទី ឬមានចលនាយ៉ាងលឿន។ នៅពេលដែលម៉ាក់ម៉ាចុះត្រជាក់ ម៉ូលេគុលរបស់វាក៏មានចលនាយ៉ាងយឺតៗ ហើយកាន់តែខិតជិតចូលមករកគ្នា។ បន្ទាប់

មកទៀត ម៉ូលេគុលទាំងនេះបានចងភ្ជាប់គ្នាតាមលំនាំគីមីមួយ ហើយក៏បង្កើតបានជាក្រាមឡើង។ ទំហំក្រាមនៃរ៉ែ គឺអាស្រ័យទៅលើអត្រាចុះត្រជាក់ នៃម៉ាក់ម៉ា។ នេះមានន័យថា ប្រសិនបើម៉ាក់ម៉ាចុះត្រជាក់កាន់តែយឺត នោះរ៉ែដែលកើតឡើងមានគ្រាប់ក្រាមកាន់ធំ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើម៉ាក់ម៉ាចុះត្រជាក់កាន់តែលឿន នោះរ៉ែដែលបានកើតឡើងមានគ្រាប់ក្រាមកាន់តែតូច។

ម៉ាក់ម៉ាដែលមាននៅសល់នៅក្នុងជម្រៅនៃផែនដីបានចុះត្រជាក់យឺតៗ ហើយបង្កើតបានជារ៉ែ ដែលមានគ្រាប់ក្រាមធំៗ។ ចំណែកឯម៉ាក់ម៉ា ដែលស្ថិតនៅក្បែរនឹងផ្ទៃផែនដីវិញ បានចុះត្រជាក់យ៉ាងលឿន ហើយបង្កើតបានជារ៉ែដែលមានគ្រាប់ក្រាមតូចៗ។ ចំណែកឯម៉ាក់ម៉ា ដែលចេញមកដល់នៅលើផ្ទៃផែនដី ហើយបានក្លាយជាកំអែភ្នំភ្លើងវិញ បានចុះត្រជាក់យ៉ាងឆាប់រហ័ស ហើយក៏បានក្លាយទៅជារ៉ែ ដែលមានគ្រាប់ក្រាមរឹតតែតូចៗទៅទៀត។

**២. រ៉ែកើតឡើងពីរំហួតសូលុយស្យុងទឹកសមុទ្រ (របេច)**

មានប្រភេទរ៉ែខ្លះទៀត បានកើតឡើងពីរំហួតនៃសូលុយស្យុងទឹកផងដែរ ពិសេសរំហួតនៃទឹកសមុទ្រ។ ប្រសិនបើយើងដាក់គ្រាប់អំបិលចូលទៅក្នុងចានទឹកមួយ គ្រាប់អំបិលទាំងនោះនឹងរលាយនៅក្នុងទឹកនោះ ហើយបង្កើតបានជាសូលុយស្យុងឡើង។ ក៏ប៉ុន្តែប្រសិនបើយើងទុកឱ្យសូលុយស្យុងទឹកនោះហួតឡើងអស់ វានឹងបន្សល់ទុកនូវគ្រាប់ក្រាមអំបិលនៅបាតចាននោះ។ ដូចគ្នានេះនឹងមជ្ឈបាយនេះដែរ ពំនូកគ្រាប់ក្រាមអំបិលបានកើតឡើងរាប់លានឆ្នាំ នៅពេលដែលមានរំហួតនៃទឹកសូលុយស្យុងសមុទ្រចាស់ៗ។ នៅក្នុងសូលុយស្យុងទឹកសមុទ្រមានផ្ទុកនូវសារធាតុរ៉ែរលាយជាច្រើន។ នៅពេលដែលសូលុយស្យុងទឹកសមុទ្រនេះបានហួតឡើង សារធាតុរ៉ែរលាយទាំងនេះ បានបង្កើតឡើងនូវគ្រាប់ក្រាមរ៉ែ ឡើង។ អំបិលសម្លត្រូវបានគេជីករកឃើញនៅក្នុងតំបន់នានានៅលើពិភពលោកដែលធ្លាប់ត្រូវបានគ្រប់ដណ្តប់ដោយទឹកសមុទ្រកាលពីរាប់លានឆ្នាំមុន។ អំបិលជារ៉ែមួយប្រភេទដែលមានឈ្មោះថា ហាលីត។ វាបានបន្សល់ទុកនៅក្រោមដី នៅពេលដែលទឹកសមុទ្របុរាណបានហួតអស់។ រ៉ែសំខាន់ផ្សេងៗទៀត ដែលបានកកើតឡើងពីរំហួតសូលុយស្យុងទឹកនេះដែររួមមានដូចជា ម្នាងសិលា និងកាល់ស៊ីត។

**៣. រ៉ែកើតឡើងពីសូលុយស្យុងទឹកក្តៅ**

នៅក្នុងជម្រៅនៃផែនដី ម៉ាក់ម៉ារលាយអាចធ្វើឱ្យទឹកឡើងកម្តៅនៅសីតុណ្ហភាពមួយយ៉ាងខ្ពស់។ ជួនកាលអង្គធាតុ និងសមាសធាតុដែលកកើតបានជារ៉ែរលាយក្នុងទឹកក្តៅនោះ។ នៅពេលដែលសូលុយស្យុងទឹកក្តៅនោះចាប់ផ្តើមចុះត្រជាក់ អង្គធាតុ និងសមាសធាតុទាំងនោះ ដែលស្ថិតនៅក្នុងសូលុយស្យុងក៏ចាប់ផ្តើចុះត្រជាក់ រួចកបង្កើតបានជាគ្រាប់ក្រាមរ៉ែឡើង។

គ្រាប់ក្រាមរ៉ែអាចកកើតឡើងពីការចុះត្រជាក់ នៃសូលុយស្យុងទឹកក្តៅ។ ទឹកដែលត្រូវបានដុតកម្តៅដោយម៉ាក់ម៉ា ក្នុងជម្រៅនៃសំបកផែនដីមានផ្ទុកនូវសារធាតុរ៉ែរលាយ។ ជាទូទៅ ទឹកក្តៅអាចផ្ទុកនូវសារធាតុរ៉ែរលាយបានច្រើនជាងទឹកត្រជាក់។ នៅពេលដែលទឹកក្តៅបានចុះត្រជាក់ វាមានលទ្ធភាពផ្ទុកនូវសារធាតុរ៉ែរលាយបានតិចតួចបំផុត។ គ្រប់លោហៈសុទ្ធទាំងអស់ ដែលបានកើតពីសូលុយស្យុងទឹកក្តៅនៅក្នុងផែនដី តែងតែកកើតឡើងពីវ៉ែន។ វ៉ែន គឺជាបំពង់តូចមួយ ដែលអនុញ្ញាតឱ្យម៉ាក់ម៉ាងើបឡើងមកកាន់ផ្ទៃផែនដី។ រ៉ែ ដែលកើតឡើងតាមលំនាំបែបនេះរួមមាន រ៉ែក្វាត រ៉ែផែលស្ប៉ាត និងរ៉ែមីកាជាដើម។

**៤. រ៉ែកើតឡើងពីការប្រែកំណើតរបស់សិលា (សម្ពាធ និងសីតុណ្ហភាព)**

មានរ៉ែខ្លះទៀតបានកកើតឡើងនៅក្នុងជម្រៅដ៏ជ្រៅក្នុងផែនដី។ ដោយសារតែទទួលរងនូវការផ្លាស់ប្តូរ និងការប្រែប្រួលនៃសម្ពាធ និងសីតុណ្ហភាពនៅក្នុងជម្រៅនៃផែនដី បានធ្វើឱ្យសិលាប្រែរូបរាងរបស់វា។ ទន្ទឹមគ្នានោះដែរ រ៉ែខ្លះដែលស្ថិតនៅក្នុងសិលាទាំងនោះបានផ្លាស់ប្តូរនូវលក្ខណៈគីមី ឬទម្រង់គ្រាប់ក្រាម និងលក្ខណៈរូបរបស់វា នៅពេលដែលសម្ពាធ និងសីតុណ្ហភាពចេះតែកើនឡើងខ្ពស់ ហើយក៏បង្កើតបានជាប្រភេទគ្រាប់ក្រាមរ៉ែថ្មីផ្សេងទៀត ដោយមានលក្ខណៈគីមី និងលក្ខណៈរូបខុសគ្នាទាំង ស្រុងពីប្រភេទរ៉ែដើម។ ប្រភេទរ៉ែដែលបានទទួលរង នូវលំនាំបែបប្រែកំណើតទាំងនេះមានដូចជា ពេជ្រ (Diamond) កាណេត (Garnet) កាល់ស៊ីត (Calcite) ក្រាភីត (Graphite) ហេម៉ាទីត (Hematite) ម៉ាញ៉េទីត (Magnetite) អេពីដូត (Epidote) និង ថក (Talc)។

បន្ទាប់មក ដោយសារតែចលនានៃសំបកផែនដី រ៉ែទាំងនោះត្រូវបាននាំយកមកក្បែរផ្ទៃផែនដី ដែលជាកន្លែងគេអាចធ្វើអាជីវកម្ម ដើម្បីទាញយករ៉ែទាំងនេះមកប្រើប្រាស់នៅក្នុងសេដ្ឋកិច្ចបាន។

**ឃ. ប្រភេទរ៉ែសំខាន់ៗ**

នៅលើភពផែនដីយើងនេះ រ៉ែមានច្រើនប្រភេទណាស់។ ក៏ប៉ុន្តែប្រភេទទាំងនេះ ត្រូវបានបែងចែកជា ៣ ក្រុមសំខាន់ៗដូចខាងក្រោម ៖

**១. រ៉ែត្បូង**

រ៉ែត្បូង គឺជាប្រភេទរ៉ែដែលកម្របំផុតនៅលើភពផែនដី។ រ៉ែត្បូងមានរបឹង និងសោភ័ណភាពល្អជាងរ៉ែផ្សេងៗទៀត។ រ៉ែទាំងអស់ ដែលគេប្រទះឃើញនៅលើភពផែនដី មិនមែនសុទ្ធតែមានគុណភាពល្អនោះទេ ចំណែកឯរ៉ែត្បូងវិញក៏ដូច្នេះដែរ។ ប្រភេទត្បូងខ្លះមានតម្លៃខ្ពស់ រីឯត្បូងខ្លះទៀតជាត្បូងមានតម្លៃខ្ពស់បង្គួរ និងមានត្បូងខ្លះទៀតមានតម្លៃមធ្យម។ ពេជ្រ គឺជាប្រភេទត្បូង ដែលមានសោភ័ណភាព និងមានតម្លៃខ្ពស់ជាងគេបំផុត ហើយគេកម្រនឹងជួបប្រទះវាណាស់នៅលើផែនដី។ ចំពោះត្បូងដែលមានតម្លៃខ្ពស់បង្គួរ និងមធ្យមវិញ គេតែងតែប្រទះឃើញជាញឹកញាប់ ហើយក៏មានច្រើនណាស់ដែរនៅលើផែនដូចជា ត្បូងទទឹម ត្បូងកណ្តៀង ត្បូងមរកត និងពេជ្រខ្មែរជាដើម។ ប្រភេទត្បូងទាំងនេះ ក៏ជាត្បូង ដែលមានរបឹង និងសោភ័ណភាពល្អដែរ ក៏ប៉ុន្តែវាមានលក្ខណៈសាមញ្ញ។ នៅប្រទេសកម្ពុជាយើង ប្រភេទត្បូងដែលមានតម្លៃថ្លៃគឺ ត្បូងទទឹម និងត្បូងកណ្តៀងនៅប៉ៃលិន រីឯត្បូងដែលមានតម្លៃមធ្យមគឺ ត្បូងទទឹម និងត្បូងកណ្តៀងនៅបរកែវ ខេត្តរតនគិរី ត្បូងមរកត និងពេជ្រខ្មែរ។

**២. រ៉ែលោហៈ**

រ៉ែលោហៈ ជារូបធាតុ ដែលមានលក្ខណៈពិសេសរបស់វាដូចជា មានផ្លេកលោហៈ ចម្លងកម្តៅ និងអគ្គិសនីបានល្អ អាចផែបាន និងអាចហូតជាលួសបានដោយគ្មានការបាក់បែកអ្វីឡើយ។ រ៉ែលោហៈរួមមានដូចជា រ៉ែដែក រ៉ែសំណ រ៉ែអាលុយមីញ៉ូម រ៉ែទង់ដែង រ៉ែប្រាក់ រ៉ែស័ង្កសី និងរ៉ែមាស។ ក្រៅពីនេះ គេឃើញមានរ៉ែជាច្រើនប្រភេទផ្សេងៗទៀតដែលនៅលាយជាមួយនឹងសារធាតុផ្សេងៗ ហើយនៅពេលដែលគេធ្វើអាជីវកម្មទាញយកវាពីក្នុងដីមក គេចាំបាច់ត្រូវតែបន្សុទ្ធវាជាមុនសិន ដោយគេយកវាទៅធ្វើលោហៈកម្មតាមវិធីមួយ ដើម្បីញែកលោហៈចេញ។ លំនាំកែច្នៃបែបនេះត្រូវបានគេហៅថា ការរំលាយ។ ដែកត្រូវបានគេទាញយកចេញពីរ៉ែអាលីម៉ូញីត

និងអេម៉ាទីត សំណត្រូវបានគេយកចេញពីរ៉ែកាឡែន ស៊ីលីស្យូមត្រូវបានគេទាញយកចេញពីរ៉ែក្វាត និង អាលុយមីញ៉ូមត្រូវបានគេយកចេញពីរ៉ែបុកស៊ីត។

**៣. រ៉ែអលោហៈ**

រ៉ែអលោហៈ គឺជារូបធាតុដែលគ្មានផ្នែកលោហៈ ហើយចម្លងកម្ដៅ និងអគ្គិសនីមិនបានល្អ ឬ ខ្សោយ។ លើសពីនេះទៅទៀត រ៉ែប្រភេទនេះ គឺគេមិនអាចផែ ឬហូតវាធ្វើជាលួសបាននោះទេ។ ប្រភេទរ៉ែអលោហៈរួម មាន ស្ពាន់ធ័រ ក្លរ កាបូន ប្រូម អ៊ីយ៉ូត -ល-។ ប្រភេទរ៉ែអលោហៈខ្លះ គេទាញយកវាពីក្នុងដីមកប្រើប្រាស់បាន ដោយផ្ទាល់តែម្តង ប៉ុន្តែមានរ៉ែអលោហៈខ្លះទៀតគេត្រូវកែច្នៃ ដើម្បីបន្សុទ្ធវាចេញពីរ៉ែដទៃទៀត មុននឹងយកវា ទៅប្រើប្រាស់។

## ខ. អត្ថប្រយោជន៍នៃរ៉ែ

ការប្រើប្រាស់រ៉ែមានលក្ខណៈខុសៗគ្នា ទៅតាមប្រទេសនីមួយៗនៅលើពិភពលោក។ ប្រទេស អភិវឌ្ឍនៃលោកខាងជើងបានប្រើប្រាស់រ៉ែយ៉ាងច្រើនក្រៃលែង។ ដូចធនធានដទៃទៀតដែរ ធនធានរ៉ែមាន របាយមិនស្មើគ្នានោះទេនៅលើផែនដី។ ប្រទេសខ្លះសម្បូរទៅដោយធនធានរ៉ែ រីឯប្រទេសខ្លះទៀតពុំសូវសម្បូរ ធនធានរ៉ែនោះទេ។ ការប្រើប្រាស់រ៉ែអាស្រ័យទៅនឹងលក្ខណៈរបស់វា។ ឧទាហរណ៍ដូចជា រ៉ែអាលុយមីញ៉ូម ដែលជាធាតុស្វិត ហើយជាប់បានយូរត្រូវបានគេយកទៅប្រើប្រាស់នៅក្នុងឧស្សាហកម្ម ផលិតយន្តហោះ ឧស្សាហកម្មផលិតយានអវកាស ឧស្សាហកម្មផលិតរថយន្ត និងឧស្សាហកម្មផលិត នាវា -ល-។ ដូចនេះ រ៉ែ ត្រូវបានគេយកទៅប្រើប្រាស់នៅក្នុងវិស័យឧស្សាហកម្ម សម្រាប់ផលិតចេញនូវសម្ភារៈប្រើប្រាស់ជាច្រើន ប្រភេទនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សដូចជា ៖

- ខ្សាច់ ក្រួស ដីឥដ្ឋ ថ្ម ដែកថែប កែវ អាលុយមីញ៉ូម សំណល់ប្រេងកាត ត្រូវបានគេយកទៅប្រើ ប្រាស់ សម្រាប់ធ្វើសំណង់ផ្សេងៗ។
- ដែក ដែកថែប ទង់ដែង សណ ស្ពាន់ធ័រ កែវ ត្រូវបានយកទៅប្រើប្រាស់ សម្រាប់ធ្វើបំពង់ និងខ្សែ ភ្លើង ខ្សែលួស -ល-។
- ដែក ដែកថែប អាលុយមីញ៉ូម ផ្លាទីន ជ័រប្លាស្ទិច ត្រូវបានគេយកទៅប្រើប្រាស់ សម្រាប់ផលិតយន្ត ហោះ យានអវកាស រថយន្ត និងនាវា។
- ដែក ដែកថែប អាលុយមីញ៉ូម ទង់ដែង សំណ កែវ ជ័រប្លាស្ទិច ត្រូវបានគេយកទៅប្រើប្រាស់ សម្រាប់ផលិតសម្ភារៈអេឡិចត្រូនិច និងសម្ភារៈបរិក្ខារផ្សេងៗ។
- ជាតិពណ៌រ៉ែដូចជា ដែក ស័ង្កសី និងសារធាតុភ្និត ត្រូវបានគេយកទៅប្រើប្រាស់ សម្រាប់ធ្វើជាថ្នាំ លាបផ្សេងៗ។
- ផូស្វាត និងហាលីត (អំបិល) ត្រូវបានគេយកទៅប្រើប្រាស់ សម្រាប់ផលិតជីកសិកម្ម និង អំបិល សម្រាប់បរិភោគ។
- ម៉ាស ត្បូង និងប្រាក់ ត្រូវបានគេយកទៅប្រើប្រាស់ក្នុងសិប្បកម្ម ដើម្បីផលិតគ្រឿងអលង្ការ គ្រឿងលំអ្អ និងវត្ថុសិល្បៈផ្សេងៗ -ល-។

### ៤.២. ធនធានរ៉ែនៅប្រទេសកម្ពុជា

ដោយសារតែប្រទេសកម្ពុជាយើងធ្លាប់បានឆ្លងកាត់ នូវប្រវត្តិធរណីកាលដ៏យូរលង់មកហើយពោល គឺប្រទេសកម្ពុជាយើងធ្លាប់បានទទួលរង នូវចលនាពំនើងផ្នត់ទាំងនៅក្នុងស័កទី១ ទី២ និងទី៣ ចលនាបំណាក់ស្រុត និងបាតុភូតបន្ទុះភ្នំភ្លើងនៅស័កទី៣ ជាពិសេសប្រទេសកម្ពុជាយើងធ្លាប់ជាបាតសមុទ្រចាស់ និងមានមានទីតាំងស្ថិតនៅលើទ្វីបចាស់អាំដូស៊ីញាងផងនោះ អាចនិយាយបានថា ប្រទេសកម្ពុជាយើងពិតជាមានធនធាននៅក្រោមដីយ៉ាងច្រើនក្រាស់ក្រែលជាក់ជាមិនខាន ដែលជាទុនដ៏សំខាន់ សម្រាប់កសាង និងអភិវឌ្ឍឧស្សាហកម្មរបស់ខ្លួន។

### ក. ប្រវត្តិនៃការសិក្សាស្រាវជ្រាវធនធានរ៉ែនៅកម្ពុជា

#### ១. ការស្រាវជ្រាវពីឆ្នាំ១៨៦៦ ដល់ឆ្នាំ១៨៧៣

ការសិក្សាពីប្រវត្តិធរណីប្រទេសកម្ពុជា និងការស្រាវជ្រាវធនធានរ៉ែ និងដីបានចាប់ផ្តើមឡើងតាំងពីឆ្នាំ១៨៦៦ រហូតដល់ឆ្នាំ១៨៧៣ មកម្លេះ ដោយអ្នកធរណីវិទ្យាជនជាតិបារាំងឈ្មោះ Joubert, J.Gubler និង Mamsoy E.Saurin បន្ទាប់ពីប្រទេសបារាំងបានដាក់អាណានិគមលើប្រទេសកម្ពុជាយើងបានរយៈពេល ៣ ឆ្នាំរួចមក។ យោងតាមការស្រាវជ្រាវនេះបានបញ្ជាក់អោយឃើញថា ប្រទេសកម្ពុជាមានដីនៅគ្រប់ស័ក ៖ ស័កទី៤ មានដីល្បាប់សម្រាប់កសិកម្ម ស័កទី៣ មានដីបាសាល់ ដែលល្អប្រសើរបំផុតសម្រាប់ដំណាំឧស្សាហកម្ម រីឯស័កទី២ និងទី១ ដែលធ្លាប់ទទួលរងនូវចលនាពំនើងផ្នត់ពិតជាមានកំណប់រ៉ែសំខាន់ៗពុំខានឡើយ។ ក៏ប៉ុន្តែ ដោយសារប្រទេសយើងខ្វះទុន ខ្វះបច្ចេកទេស ខ្វះឧបករណ៍ទំនើប សម្រាប់ស្រាវជ្រាវ និងធ្វើអាជីវកម្មបានជាប្រទេសយើងពុំទាន់ធ្វើអាជីវកម្មឱ្យបានត្រឹមត្រូវ និងពុំទាន់ដំណើរការរោងចក្រឧស្សាហកម្មគ្រប់ផ្នែកនៅឡើយ។

#### ២. ការស្រាវជ្រាវពីឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៧០

ការស្រាវជ្រាវអំពីផ្នែកធរណី និងរ៉ែនៃប្រទេសកម្ពុជាយើងបានចាប់ផ្តើមធ្វើឡើងបន្តទៀតចាប់ពីឆ្នាំ ១៩៦១ រហូតដល់ឆ្នាំ១៩៧០ ដោយការិយាល័យស្រាវជ្រាវផ្នែកធរណីនៃប្រទេសកម្ពុជា។ តាម រយៈការស្រាវជ្រាវនេះបានរកឃើញកំណប់រ៉ែជាច្រើនប្រភេទដែលស្ថិតនៅក្រោមទឹកដីនៃប្រទេសកម្ពុជាយើង។ ក្នុងចំណោមរ៉ែទាំងនោះ មានរ៉ែខ្លះត្រូវបានគេធ្វើអាជីវកម្មទាញយកមកប្រើប្រាស់ជាហូរហែនៅក្នុងសម័យនោះ និងហូតមកដល់បច្ចុប្បន្ន រីឯរ៉ែខ្លះទៀតគឺនៅមិនទាន់ត្រូវបានគេធ្វើអាជីវកម្មនៅឡើយនោះទេ គឺវាស្ថិតនៅជាសន្ទស្សន៍នៅឡើយ។

#### ៣. ការស្រាវជ្រាវពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩៣

ពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៩៣ ការស្រាវជ្រាវអំពីផ្នែកធរណី និងរ៉ែនៅប្រទេសកម្ពុជាយើងត្រូវបានផ្អាកដំណើរការ ដោយសារប្រទេសកម្ពុជាយើងបានជួបប្រទះនូវវិបត្តិសង្គម និងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃអស់រយៈពេលជាច្រើនឆ្នាំ។

#### ៤. ការស្រាវជ្រាវពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន

ចាប់តាំងពីឆ្នាំ១៩៩៣ រហូតមកដល់ពេលបច្ចុប្បន្ននេះ គេឃើញការស្រាវជ្រាវផ្នែកធរណី និង

រ៉ែនៅប្រទេសកម្ពុជាបានចាប់ផ្តើមធ្វើសកម្មភាពរបស់ខ្លួនឡើងវិញដោយគេឃើញមានក្រុមហ៊ុនបរទេសជាច្រើនបានចូលមកបណ្តាក់ទុនរកស៊ីនៅក្នុងប្រទេសកម្ពុជាយើងខាងរុករក និងទាញយកធនធានរ៉ែទាំងនោះ។ យោងតាមកាសិក្សារបស់អង្គការ ESCAP ដែលបានស្រាវជ្រាវពីធនធានរ៉ែនៅកម្ពុជានៅឆ្នាំ១៩៩៣ បានបង្ហាញថា ប្រទេសកម្ពុជាយើងសម្បូរធនធានរ៉ែ ហើយអង្គការនេះបានបែងចែកធនធានរ៉ែទាំងនោះជា ៤ ក្រុមធំៗគឺ រ៉ែឧស្សាហកម្ម និងសំណង់ លោហៈ ត្បូងមានតម្លៃ និងថ្មរចនា។

## ខ. មណ្ឌលរ៉ែ និងសន្ទស្សន៍រ៉ែនៅប្រទេសកម្ពុជា

### ១. មណ្ឌលរ៉ែ

នៅប្រទេសកម្ពុជាយើង រ៉ែដែលត្រូវបានគេធ្វើអាជីវកម្មរួចមកហើយនោះ ត្រូវបានគេបែងចែកទៅជា ៦ មណ្ឌលដូចខាងក្រោម ៖

- **មណ្ឌលប៉ៃលិន** ៖ មណ្ឌលនេះមានកំណប់ត្បូងដែលមានតម្លៃជាច្រើនដូចជា ត្បូងទទឹម ត្បូងកណ្តៀង និងត្បូងមានតម្លៃជាច្រើនទៀត។ ប្រភេទត្បូងទាំងនេះ ត្រូវបានគេជីកគាស់រែងយក ដោយជនជាតិភូមា ដែលបានមករស់នៅជាឈ្មួញឯកទេសខាងត្បូងតាំងពីចុងសតវត្សទី ១៩ មកម្លេះ។ បច្ចុប្បន្នេះ ប្រភេទរ៉ែត្បូងដែលមានតម្លៃទាំងនេះ ស្ទើរតែវិនាសហិនហោចអស់ទៅហើយ ដោយសារតែការធ្វើអាជីវកម្មទ្រង់ទ្រាយធំនៅចុងសម័យសង្គ្រាមស៊ីវិល។
- **មណ្ឌលបរកែវ** ៖ មណ្ឌលនេះ មានទីតាំងស្ថិតនៅក្នុងខេត្តរតនគីរី ដែលមានកំណប់រ៉ែត្បូងទទឹម ត្បូងកណ្តៀង ត្បូងមរកត ពេជ្រខ្មែរ និងរ៉ែមាស។ មណ្ឌលទាំងពីរខាងលើនេះបានផ្តល់នូវត្បូងយ៉ាងមានតំលៃ សម្រាប់នាំយកទៅលក់នៅក្រៅប្រទេស ហើយអាចផ្តល់នូវរូបិយប័ណ្ណយ៉ាងច្រើនសន្ធឹកសន្ធាប់ដល់ប្រទេសយើង។ សព្វថ្ងៃនៅមណ្ឌលនេះ មានក្រុមហ៊ុនអូស្រ្តាលីឈ្មោះសាវធឺនហ្គោលលីមីតធីត ( Southern Gold Limited ) ទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាឱ្យរុករករ៉ែមាស និងលោហធាតុក្នុងមូលដ្ឋានចំនួន ៧ កន្លែង។
- **មណ្ឌលកំពង់ធំ** ៖ មណ្ឌលនេះ មានរ៉ែដែកនៅភ្នំដែកដែលប្រជាជនកម្ពុជា ជាពិសេសជនជាតិកួយបានស្គាល់ និងចេះយកមកប្រើប្រាស់ជាយូរយារណាស់មកហើយដូចជា ធ្វើកាំបិត ពូថៅ និងអាវុធផ្សេងៗ ដោយមានកម្រិតផលិតកម្មជាសិប្បកម្មប្រពៃណីនៅឡើយ។ រ៉ែដែកនៅក្នុងមណ្ឌលនេះ មានទម្រង់ជាម៉ាញ៉េទីត លីម៉ូនីត និងស៊ីដេរីត។ រ៉ែមាសមាននៅកប់ក្នុងដីល្បាប់ រ៉ែសំណបាហាំងមាននៅជុំវិញភ្នំដី និងភ្នំលឿង។ លើសពីនេះទៀត មណ្ឌលនេះក៏មានរ៉ែត្បូងសម្រាប់ធ្វើអលង្ការផងដែរ។ សព្វថ្ងៃ នៅក្នុងមណ្ឌលនេះ មានក្រុមហ៊ុនចិនកំពុងតែរុករក និងធ្វើអាជីវកម្ម។
- **មណ្ឌលពោធិ៍សាត់** ៖ មណ្ឌលនេះ មានរ៉ែថ្មម៉ាប និងរ៉ែថ្មកែវនៅភ្នំតាសាយ។ ថ្មម៉ាបត្រូវបានគេទាញយកមកប្រើប្រាស់ សម្រាប់ធ្វើឥដ្ឋការូ រីឯថ្មកែវវិញមានច្រើនពណ៌ដូចជា ពណ៌បៃតងខ្ចី ពណ៌ក្រហម ពណ៌ខ្មៅ និងពណ៌ត្នោតចាស់ និងត្រូវបានគេនាំយកមកប្រើប្រាស់ សម្រាប់រចនាវត្ថុសិល្បៈដូចជា រូបអប្សរា ក្បាលព្រហ្មណ៍ប្រាសាទអង្គរវត្ត រូបបដិមាករ កោដិដាក់ធាតុជាដើម។

- **មណ្ឌលបាត់ដំបង** ៖ មណ្ឌលនេះ មានថ្មកំបោរ និងផូស្វាតនៅភ្នំសំពៅ។ ប្រជាជនយើងបានប្រើប្រាស់ថ្មកំបោរយកមកដុតធ្វើជាកំបោរ សម្រាប់លាបផ្ទះសំបែង។ រីឯផូស្វាតវិញ ប្រជាជនយើងគ្រាន់តែយកមកកិនធ្វើជាជី សម្រាប់ប្រើប្រាស់ក្នុងកសិកម្មតែប៉ុណ្ណោះ។
- **មណ្ឌលកំពត** ៖ មណ្ឌលនេះ មានថ្មកំបោរ និងផូស្វាតនៅទូកមាស និងនៅចក្រីទីង។ កាលពីមុនឆ្នាំ១៩៧០ ប្រទេសកម្ពុជាយើងមានរោងចក្រស៊ីម៉ង់ត៍មួយនៅចក្រីទីង និងមានរោងចក្រជីផូស្វាតនៅទូកមាស ប៉ុន្តែរោងចក្រទាំងនោះត្រូវបានខកខានលែងមានដំណើរការ ក្នុងពេលមានសង្គ្រាម និងមានវិបត្តិនយោបាយអស់រយៈពេលជាង ២ ទសវត្សរ៍នៅកម្ពុជា។ សព្វថ្ងៃនេះមានក្រុមហ៊ុនផលិតស៊ីម៉ង់ត៍ចំនួន ៥ បានមកធ្វើអាជីវកម្មនៅលើទឹកដីខេត្តកំពត ដោយប្រើប្រាស់ថ្មកំបោរនៅទីនោះ។

### ២. សន្និស្សន៍រ៉ែ

ក្រៅពីមណ្ឌលរ៉ែទាំង ៦ ខាងលើនេះ ប្រទេសកម្ពុជាយើងនៅមានសន្និស្សន៍រ៉ែជាច្រើនប្រភេទទៀតផងដែរដូចជា ៖

- **រ៉ែដែក** ៖ មាននៅខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង។ នៅប្រទេសកម្ពុជា រ៉ែដែកមានច្រើនជាងគេគឺមាននៅខ្ពង់រាបខាងជើង ត្រង់ភ្នំដែក។ បើតាមការប៉ាន់ស្មានរបស់អ្នកធរណីវិទ្យាថា រ៉ែដែកមានប្រហែល ៦ លានតោន និងមានចំណុះដែកពី ៥១% ទៅ ៥៦%។ នៅខេត្តព្រះវិហារ រ៉ែដែកពីរកន្លែងទៀតពុំអាចធ្វើអាជីវកម្មបានងាយស្រួល និងបានចំណេញទេ។ នៅខេត្តស្ទឹងត្រែង រ៉ែដែកមាននៅអន្លង់ជ័យ កំពង់ពុទ្រា និងជិតក្រុងស្ទឹងត្រែង ត្រង់ភ្នំបាក់សៀ។ នៅខេត្តឧត្តរមានជ័យ រ៉ែដែកមានចំណុះដែកច្រើន តែរ៉ែនេះនៅប៉ាត់រប៉ាយឆ្ងាយពីគ្នានៅជុំវិញភ្នំរ៉ុំដែក។ នៅខេត្តសៀមរាបនៅត្រង់ភ្នំក្បាលស្ទឹង ក៏មានរ៉ែដែកដែរ តែមានចំនួនតិច រីឯនៅខេត្តតាកែវវិញ នៅត្រង់ម្តុំជងទង់ រ៉ែដែកមានច្រើនប៉ុន្តែនៅរ៉ាយប៉ាយពីគ្នា និងមានចំណុះដែកសុទ្ធតិច និងមិនសូវចំណេញដល់ការធ្វើអាជីវកម្ម។
- **រ៉ែប្រាក់** ៖ មាននៅតាមជើងភ្នំក្រវ៉ាញ ខាងលិចខេត្តកំពង់ឆ្នាំង នៅភ្នំថ្មកំបោរ និងសំរោង ក្នុងខេត្តឧត្តរមានជ័យ និងតំបន់កូនភ្នំក្នុងខេត្តសៀមរាប។
- **រ៉ែមាស** ៖ មាននៅក្នុងខេត្តរតនគីរី "ប៉ូខប" រកឃើញនៅឆ្នាំ១៨៩៨។ នៅភ្នំដែក ភ្នំលុង ភ្នំជី ភ្នំលឿង ក្នុងខេត្តកំពង់ធំ ភ្នំថ្មមាស ក្នុងខេត្តបាត់ដំបង ជិតព្រំប្រទល់ដែនថៃ និងកម្ពុជា និងភ្នំថ្មកំបោរបូស៊ុបទ្រុប ក្នុងខេត្តឧត្តរមានជ័យ ដែលតាមការគណនាក្នុងឆ្នាំ១៩២៩ បានបង្ហាញថា រ៉ែនេះមាន ៤៤០ ០០០ តោន ដែលមានចំណុះមាស ១៥ ក្រាមក្នុងមួយតោន។ ដូចនេះ នៅបូស៊ុបទ្រុប គេអាចរែងយកសាច់មាសសុទ្ធប្រមាណ ៦,៦ តោន។
- **រ៉ែទង់ដែង** ៖ មាននៅក្រូចឆ្មារ ក្នុងខេត្តត្បូងឃ្មុំ នៅឡុំផាត់ ក្នុងខេត្តរតនគិរី នៅអន្លង់ជ័យក្នុងខេត្តស្ទឹងត្រែង និងនៅខ្ពង់រាប ក្នុងខេត្តព្រះវិហារ។
- **រ៉ែបុកស៊ីត** ៖ រ៉ែនេះ សម្រាប់យកទៅធ្វើជាអាលុយមីញ៉ូមមាននៅខេត្តបាត់ដំបងត្រង់ម្តុំភ្នំសំពៅប្រមាណ ៣ លានតោន ដែលមានចំណុះអាលុយមីញ៉ូមចាប់ពី ៥៦% ទៅ ៦១%។ នៅ

ខ្ពង់រាបឆ្លូងលើ ក្នុងខេត្តមណ្ឌលគិរី រ៉ែបុកស៊ីតមានចំណុះអាលុយមីញ៉ូមចាប់ពី ២៥% ទៅ ៣៦%។

- **រ៉ែម៉ង់កាណែស** ៖ មាននៅឆែប ក្នុងខេត្តព្រះវិហារប្រមាណ ១២០ ០០០ តោន ដែលមានចំណុះពី ២២% ទៅ ២៦%។ ម៉ង់កាណែស គឺជារូបធាតុដើមយ៉ាងសំខាន់ ដែលប្រើជាមួយនឹងដែកជាលក្ខខណ្ឌងាយស្រួល សម្រាប់កសាងឧស្សាហកម្មលោហៈប្រទេសយើង។
- **ស្ពាន់ធ័រ** ៖ មាននៅសំរោង ក្នុងខេត្តកំពង់ស្ពឺ នៅបាម៉ៃ ក្នុងខេត្តរតនគិរី នៅអូរធុង ក្នុងខេត្តមណ្ឌលគិរី និងនៅភូមិព្រីង ក្នុងខេត្តព្រះវិហារ។
- **ម៉ាញេស្យូម** ៖ មាននៅភូមិខ្សាង ក្នុងខេត្តស្ទឹងត្រែងមានបរិមាណច្រើនបង្គួរ ៤០ ០០០ តោន ដោយមានចំណុះពី ២០% ទៅ ២៤% នៃម៉ាញេស្យូម។ កាលពីមុនឆ្នាំ១៩៧០ រ៉ែប្រភេទនេះត្រូវបានដឹកមកបម្រើរោងចក្រធ្វើកែវនៅជើងឯក ក្នុងទីក្រុងភ្នំពេញ។
- **ស៊ីលីស្យូម** ៖ មាននៅត្រាំខ្នារ ក្នុងខេត្តតាកែវ នៅឆ្នេរសមុទ្រកំពង់សោម ក្នុងខេត្តព្រះសីហនុនិងនៅតាមផ្លូវទឹកសាប ដែលសុទ្ធតែមានខ្សាច់ម៉ត់សល្អ មានជាតិស៊ីលីស្យូមច្រើន គុណភាពល្អសម្រាប់ធ្វើកែវ ហើយប្រើប្រាស់ពុំចេះរីងស្ងួត។
- **ផូស្វាត** ៖ មាននៅទូកមាស ក្នុងខេត្តកំពត ចំនួនប្រមាណ ៣២០០០០ តោន ដែលមានចំណុះផូស្វាត ២០%។ នៅឆ្នាំ១៩៦៨ រោងចក្រជីផូស្វាតនៅកន្លែងនោះផលិតបានជីផូស្វាតចំនួន ១១ ៣២០ តោន។ កន្លែងយករ៉ែផូស្វាតមួយទៀត គឺនៅខេត្តបាត់ដំបង នៅភ្នំសំពៅ ភ្នំក្រពើ និងភ្នំបាណន់ ដែលមានចំនួន ៣០០ ០០ តោន។
- **ពេជ្រ** ៖ ពេជ្រថៃមាននៅបរកែវ នៅអណ្ដូងពេជ្រ ក្នុងខេត្តរតនគិរី និងនៅខេត្តប៉ៃលិន ដែលផលិតជាមធ្យមក្នុងមួយឆ្នាំៗបានចំនួន ១ ២០០ ទៅ ១ ៥០០ គីឡូក្រាម។
- **ត្បូងកណ្ដៀង** និង **ត្បូងទទឹម** ៖ ជាធនធានរ៉ែក្រោមដី ដែលសំខាន់ជាងគេនៅក្នុងប្រទេស។ អណ្ដូងរ៉ែ ដែលសំខាន់មាននៅសំឡូត ក្នុងខេត្តបាត់ដំបង និងនៅខេត្តប៉ៃលិន ខេត្តកោះកុង និងនៅភូមិថ្មី ក្នុងខេត្តព្រះវិហារ។
- **ថ្មកែវ** ៖ ថ្មកែវ ដែលមានគុណភាពល្អ សម្រាប់ចម្លាក់រូបសិល្បៈផ្សេងៗគឺថ្មកែវពោធិសាត់មាននៅភ្នំតាសាយ ក្នុងខេត្តពោធិសាត់ចំនួនប្រមាណ ៦៥ ០០០ ម៉ែតគីប។ ថ្មកែវនេះ មានច្រើនពណ៌ដូចជា ព៌ណក្រហម ខ្មៅ ប្រផេះ បៃតងខ្ចី ត្នោតចាស់ ឬពណ៌ឆ្នូត -ល-។ ថ្មកែវផ្សេងៗទៀតដែលមានគ្រាប់ធំៗ មាននៅស្ទឹងឃ្លៀច រលាក់កងជើង ក្នុងខេត្តកំពង់ស្ពឺ នៅខ្សាងជិតល្បាក់ខោន ក្នុងខេត្តស្ទឹងត្រែង និងភ្នំជី ក្នុងខេត្តកំពង់ធំ។
- **ថ្មថ្លើមអណ្ដើក** ៖ ពណ៌ខ្មៅមាននៅខេត្តកោះកុង ដោយទទួលផលិតផលជាមធ្យមក្នុងមួយឆ្នាំពី ៤០០ ទៅ ១ ០០០ គីឡូក្រាម នៅក្នុងចន្លោះឆ្នាំ១៩១៦ និង១៩២៥ នៅអន្លង់ច័ន្ទ ក្នុងខេត្តព្រះវិហារ និងនៅខោន ក្នុងខេត្តស្ទឹងត្រែង។
- **ត្បូងថ្ម** និង **ត្បូងលីញីត** ៖ មាននៅខេត្តកោះកុង ខេត្តព្រះសីហនុ ខ្ពង់រាបខេត្តកំពង់ចាម និងខេត្តរតនគីរី។

- **ប្រេងកាត** ៖ តាមរយៈការស្រាវជ្រាវខ្លះ ដែលបានធ្វើរួចមកហើយនោះ កំណប់ប្រេងកាតនៅប្រទេសកម្ពុជាមាននៅក្នុងឈូងសមុទ្ររបស់ខ្លួន ដោយមានទំហំយ៉ាងធំដែលអាចប្រៀបបានទៅនឹងកំណប់ប្រេងកាតនៃប្រទេសប្រេងកាតនានាដែរ។ កំណប់នេះគឺស្ថិតនៅតាមបណ្តោយជាយទ្វីបប្រទេសកម្ពុជា ចាប់ពីខេត្តកំពតរហូតដល់ខេត្តកោះកុង ប្រវែងប្រមាណ ៤៤០ គ.ម ពិសេសត្រង់ម្តុំកោះអាចម៍សេះ តែការគណនាចំណុះ និងការធ្វើអាជីវកម្មនៅជាចោទជាបញ្ហាដែលទាមទារពេលវេលា និងទុនសម្រាប់ដំណើរការ។ ការជីកយកប្រេងកាតនេះ អាចប្រព្រឹត្តទៅបានស្រួលជាងគេ ដោយសារតែតំបន់នេះមានលក្ខណៈល្អប្រសើរ ជម្រៅទឹកមធ្យមមាន ៣២ ម៉ែត្រ សមុទ្រមានសភាពស្ងប់ ព្យុះស៊ីក្លូនសឹងតែពុំដែលកើតមានរលករំជួយដល់កម្ពស់ ៥ ម៉ែត្រណាស់។ ទឹកសមុទ្រជោរពីរដង ក្នុងរយៈពេល ២៤ ម៉ោង ក៏ប៉ុន្តែចន្លោះជំនោរមានតិចតួចណាស់។ ឯកំណប់ប្រេងកាតកន្លែងដទៃទៀត ប្រហែលមាននៅក្រោមដីនៃតំបន់ភូមិភាគឦសាន និងភាគពាយ័ព្យនៃប្រទេស ប៉ុន្តែមានចំនួនតិចតួច។ ហើយម្យ៉ាងទៀត បើផ្អែកទៅលើទស្សនៈគោលការណ៍ភូមិវិទ្យា ទំនាបកណ្តាលនៃប្រទេសកម្ពុជា ដែលកាលពីអតីតជាឈូងសមុទ្រចាស់នោះនឹងមានកំណប់ប្រេងកាតសន្ទឹកសន្ធាប់ទៅអនាគតពុំខានឡើយ។

ក្រៅពីនេះ ប្រទេសយើងក៏សម្បូរទៅដោយថ្ម សម្រាប់សំណង់ខ្លាំងណាស់ដូចជា ថ្មបាសាល់ និងថ្មបាយក្រៀមជាដើម ដែលមាននៅក្នុងខេត្តដូចជា ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តពោធិសាត់ និងខេត្តសៀមរាប ហើយថ្មទាំងនេះ ត្រូវបានបុព្វបុរសខ្មែរយើងយកមកកសាងប្រាសាទបង្កើតស្នាដៃល្អឯកជាច្រើននៅសម័យមហានគរ។ កន្លែងយកថ្មសំខាន់ជាងគេ គឺនៅភ្នំគូលែនចំងាយប្រមាណ ៤០ គ.មពីក្រុងសៀមរាប។

ចំណែកឯដីឥដ្ឋ គ្រួស និងខ្សាច់វិញ គឺមាននៅគ្រប់ទីកន្លែងតាមមាត់ស្ទឹងទន្លេ... សម្រាប់ធ្វើផ្ទាំងក្អម ចាន កែវ និងបាយអរ -ល-។ ដូចនេះ ធនធានរ៉ែក្រោមដី ដែលយើងស្រាវជ្រាវរកឃើញមានមួយចំនួនយើងដឹងចំនួនរ៉ែ និងមួយចំនួនទៀត ដែលយើងគណនាពុំទាន់បាន ហើយប្រហែលជាអាចមានរ៉ែមួយចំនួនធំផ្សេងទៀតដែលអ្នកធរណីវិទ្យា និងអ្នកឯកទេសខាងរ៉ែពុំទាន់ស្រាវជ្រាវរកឃើញនៅឡើយ។ រ៉ែដែលរកឃើញជាទុនធម្មជាតិដ៏សំខាន់ សម្រាប់ធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាជនយើង។

### គ. ប្រភេទធនធានរ៉ែនៅប្រទេសកម្ពុជា

យោងតាមកាសិក្សាស្រាវជ្រាវរបស់អង្គការ ESCAP នៅឆ្នាំ១៩៩៣ បានស្រាវជ្រាវពីធនធានរ៉ែនៅកម្ពុជា។ ធនធានរ៉ែទាំងអស់នោះត្រូវបានអង្គការនេះបែងចែកជា ៤ ក្រុមធំៗគឺ រ៉ែឧស្សាហកម្ម និងសំណង់ លោហៈ ត្បូងមានតម្លៃ និងថ្មរចនា។

#### ១. រ៉ែឧស្សាហកម្ម និងសំណង់

តាមរបាយការណ៍របស់អង្គការ ESCAP បានបញ្ជាក់យ៉ាងច្បាស់ថា នៅប្រទេសកម្ពុជាយើងសម្បូរវត្ថុធាតុដើម សម្រាប់ឧស្សាហកម្មសំណង់ណាស់។ គេបានជីកយករ៉ែមួយចំនួន សម្រាប់យកទៅប្រើប្រាស់ក្នុងសំណង់អាគារ និងផ្លូវថ្នល់ដូចជា ៖

- សិលាបាសាល់ នៅខេត្តកំពង់ចាម និងស្រុកស្នួល ខេត្តក្រចេះ
- សិលាក្រានីត នៅភ្នំបាសិត ស្រុកពញាឮ ខេត្តកណ្តាល និងខេត្តកំពង់ឆ្នាំង
- ថ្មកំបោរ នៅសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ នៅខេត្តបាត់ដំបង និងខេត្តកំពត
- រីយ៉ូលីត នៅតំបន់កូនភ្នំមួយចំនួនស្ថិតនៅជុំវិញរាជធានីភ្នំពេញ
- ក្វាត នៅខេត្តតាកែវ ខេត្តព្រះសីហនុ កែប និងខេត្តកំពង់ស្ពឺ
- ម៉ាប មាននៅពោធិ៍សាត់ ខេត្តស្ទឹងត្រែង ខេត្តកំពង់ស្ពឺ និងខេត្តក្រចេះ។

គេជីកយកថ្មកំបោរ និងដូឡូមីតនៅខេត្តកំពត សម្រាប់យកទៅប្រើប្រាស់នៅក្នុងឧស្សាហកម្មស៊ីម៉ង់ត៍។ រ៉ែផូស្វាតនៅខេត្តបាត់ដំបង និងកំពតត្រូវគេជីកយកទៅធ្វើជីផូស្វាត។

**២. រ៉ែលោហះ**

គេបានរកឃើញ និងបានជីកយករ៉ែលោហៈជាច្រើនប្រភេទ ក្នុងទឹកដីនៃប្រទេសកម្ពុជាយើងដូចជា ៖

- រ៉ែដែកនៅភ្នំដែក ក្នុងខេត្តព្រះវិហារ
- រ៉ែសំណបាហាំងនៅភ្នំជី និងភ្នំលឿង ក្នុងខេត្តកំពង់ធំ
- រ៉ែមាសនៅកប់ក្នុងដីល្បាប់ ក្នុងខេត្តកំពង់ធំ នៅម៉េងម៉ង់ ស្រុកស្នួល និងនៅស្រុកកែវសីម៉ា
- ខេត្តមណ្ឌលគីរី និងនៅស្រុកបរកែវ ខេត្តរតនគីរី។

**៣. រ៉ែត្បូងមានតម្លៃ**

គេបានរកឃើញត្បូងមានតម្លៃនៅប្រទេសកម្ពុជាយើងនៅកន្លែងសំខាន់ៗ ២ កន្លែង និងបានជីកយករ៉ែត្បូងទាំងនោះមកប្រើប្រាស់ជាហូរហែរមកហើយ។ ទី១ នៅខេត្តប៉ៃលិន ដែលមានត្បូងទទឹម ត្បូងកណ្តៀង ត្បូងមរកត និងពេជ្រខ្មែរ (Zircon) ហើយត្បូងទាំងនេះត្រូវទទួលរងការធ្វើអាជីវកម្មយ៉ាងធ្ងន់ធ្ងរ។ ទី២ នៅខេត្តរតនគីរី ដែលគេជីកយកពេជ្រខ្មែរ និងត្បូងកណ្តៀង នៅក្នុងអាជីវកម្មទ្រង់ទ្រាយតូចតែប៉ុណ្ណោះកាលពីមុន ក៏ប៉ុន្តែសព្វថ្ងៃនេះ គឺស្ថិតក្នុងអាជីវកម្មទ្រង់ទ្រាយធំ។

**៤. រ៉ែថ្មរចនា**

គេបានរកឃើញរ៉ែថ្មកែវនៅភ្នំតាសាយ នៅក្នុងខេត្តពោធិ៍សាត់ ហើយគេបានទាញយករ៉ែថ្មកែវនេះមកប្រើប្រាស់ ដើម្បីផលិតជាគ្រឿងចម្លាក់សិល្បៈខ្មែរនានា។

## ឃ. ការសិក្សាស្រាវជ្រាវ និងរុករកឥន្ធនៈផូស៊ីលនៅប្រទេសកម្ពុជា

ការស្រាវជ្រាវរុករកឥន្ធនៈផូស៊ីលនៅក្នុងតំបន់ជាយទ្វីបនៃសមុទ្រប្រទេសកម្ពុជាយើងត្រូវបានធ្វើឡើងនៅក្នុងរបបសាធារណរដ្ឋខ្មែររួចម្តងមកហើយ ប៉ុន្តែការស្រាវជ្រាវរុករកនេះត្រូវបានអាក់ខានទៅវិញ ដោយសារតែសង្គ្រាមស៊ីវិលបានផាបផេះឡើងនៅប្រទេសយើង។ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ មក គេឃើញមានក្រុមហ៊ុនបរទេសចំនួន ៣ បានចូលមកបណ្តាក់ទុនរកស៊ីនៅប្រទេសកម្ពុជាយើង លើផ្នែករុករកឥន្ធនៈផូស៊ីលក្នុងដែនទឹកសមុទ្រប្រទេសកម្ពុជា។ ក្រុមហ៊ុនទាំង ៣ នេះរួមមាន ៖

- **ក្រុមហ៊ុនអ៊ិនធ័រប្រាយអយ** (Inter Bright Oil) ៖ បានធ្វើសកម្មភាពរុករកនៅក្នុងប្លុកទី១ មានទំហំ ៤ ៧០០ គម.$^{២}$ និងប្លុកទី២ មានទំហំ ៤ ៩០០ ម$^{២}$។ ក្រុមហ៊ុននេះ បានខួងក្នុងប្លុកទី១. ដំបូង ក្នុងជម្រៅ ៣ ៩៥២ ម៉ែត្រ និងមានចម្ងាយពីខេត្តព្រះសីហនុប្រហែល ១៧០គ.មពីឆ្នេរ។

- **ក្រុមហ៊ុនកាំប៉ិច** (Kampex) ៖ ក្រុមហ៊ុននេះបានធ្វើសកម្មភាពរុករកនៅប្លុកទី៣ ដែលមានទំហំ ៣ ៦៦០ គម.²។ ក្រុមហ៊ុននេះបានខួងនៅអណ្តូងអប្សរា១ ក្នុងជម្រៅ ៣ ៣០៨ ម៉ែត្រ និងបានខួងនៅអណ្តូងទេវតា១ នៅក្នុងជម្រៅ ៣ ២០៧ ម៉ែត្រ ប៉ុន្តែជាលទ្ធផល គឺមិនមានប្រេងនោះទេ។
- **ក្រុមហ៊ុនព្រីមីញ៉ែរអេយ** (Primier Oil) ៖ ក្រុមហ៊ុននេះបានធ្វើសកម្មភាពរុករកនៅក្នុងប្លុកទី៤ ដែលមានទំហំ ៤០១៥ គម.²។ ក្រុមហ៊ុននេះ បានខួងនៅអណ្តូងកោះតាង១ នៅក្នុងជម្រៅ ៣៨៦៧ ម៉ែត្រ។

នៅឆ្នាំ១៩៩៧ ក្រុមហ៊ុន**អាយដេមមីតស៊ូ** (Idemitsu) បានចុះកិច្ចព្រមព្រៀងជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើសកម្មភាពរុករកឥន្ទនៈផូស៊ីលបន្តទៅទៀត ដោយសារក្រុមហ៊ុនទាំងបីនោះបានបញ្ឈប់សកម្មភាពរុករករបស់ពួកគេ។ ក្រុមហ៊ុន**អាយដេមមីតស៊ូនេះ** បានធ្វើសកម្មភាពរុករកនៅក្នុងប្លុកទី១ និងប្លុកទី៤ ហើយបានខួងអណ្តូងកោះព្រីង១ ប៉ុន្តែដោយសារគ្មានប្រេង ក្រុមហ៊ុននេះក៏បានបោះបង់ចោលនូវសកម្មភាពរុករករបស់ខ្លួនទៀត។

នៅឆ្នាំ១៩៩៩ មានក្រុមហ៊ុនអូស្ត្រាលីមួយដែលមានឈ្មោះថា **វូតសាយ** (Woodside) បានចុះកិច្ចព្រមព្រៀងជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការសិក្សាស្រាវជ្រាវឡើងវិញនៅលើទិន្នន័យ ដែលមានស្រាប់នៅក្នុងប្លុកទី១ ទី២ ទី៣ ទី៤ និងទី៧ ហើយថែមទាំងបានខួងនូវអណ្តូងចំនួន ៨ កន្លែងបន្ថែមទៀត ប៉ុន្តែលទ្ធផលវិញហាក់បីដូចនៅឆ្ងាយនៅឡើយ។

នៅឆ្នាំ២០០៥ មានក្រុមហ៊ុនអាមេរិកមួយដែលមានឈ្មោះថា **ប្រេងយក្សឆែវ្រ៉ុន** (Oil Giant Chevron) បានចូលមកបណ្តាក់ទុនរកស៊ីលើផ្នែកឥន្ទនៈផូស៊ីលនេះនៅកម្ពុជា ហើយបន្ទាប់ពីការរុករករួចមក ក្រុមហ៊ុននេះបានប្រកាសរកឃើញកំណប់ឥន្ទនៈផូស៊ីលដ៏ធំ នៅក្នុងដែនសមុទ្រប្រទេសយើង។ នៅពេលនោះ រាជរដ្ឋាភិបាលយើងបានប្រកាសសាទរពីការរកឃើញនេះ និងបានប្រកាសថា តំណក់ប្រេងដំបូងបំផុតនៅកម្ពុជានឹងត្រូវបានទាញចេញយកមកនៅថ្ងៃទី១២ ខែ១២ ឆ្នាំ២០១២ វេលាម៉ោង១២ ម៉ោងនៅប្រទេសកម្ពុជា ក៏ប៉ុន្តែលុះមកដល់ថ្ងៃខែឆ្នាំ និងវេលានេះ គឺគេពុំឃើញមានតំណក់ប្រេងដូចអ្វី ដែលរាជរដ្ឋាភិបាលយើងបានប្រកាសនោះឡើយ។

នៅឆ្នាំ២០១៤ មានក្រុមហ៊ុនមួយដែលមានឈ្មោះថា **គ្រីសអ៊ែណឺជី** ( Krish Energy) បានទិញយកភាគហ៊ុនខ្លះពីក្រុមហ៊ុន **ប្រេងយក្សឆែវ្រ៉ុន** រួមនឹងភាគហ៊ុនរបស់ខ្លួនមានស្រាប់ផងនោះបានធ្វើឱ្យក្រុមហ៊ុននេះ មានសិទ្ធិពេញលេញក្នុងការធ្វើសកម្មភាពរុករកប្រេងនៅក្នុងដែនសមុទ្រកម្ពុជា។ ចាប់ពីឆ្នាំ២០១៤ មក អណ្តូងប្រេងនៅក្នុងដែនសមុទ្រប្រទេសកម្ពុជាយើង ត្រូវបានគេបែងចែកជាប្លុកតាមលំដាប់នៃអក្សរឡាតាំង ដោយមាន ៦ ប្លុក គឺប្លុកអា ប្លុកបេ ប្លុកសេ ប្លុកដេ ប្លុកអឺ និងប្លុកអែហ្វ។ មកដល់ឆ្នាំ២០១៥ ក្រុមហ៊ុន **គ្រីសអ៊ែណឺជី** បានចុះកិច្ចព្រមព្រៀងធ្វើសកម្មភាពរុករកឥន្ទនៈផូស៊ីលនៅក្នុងប្លុកអា ដែលគ្របដណ្តប់នៅលើផ្ទៃសមុទ្រទំហំ ៦ ២៧៨ គ.ម² ក៏ប៉ុន្តែរហូតមកដល់ឆ្នាំ២០២០ ក្រុមហ៊ុន**គ្រីសអ៊ែណឺជី** (Krish Energy) ដែលបានធ្វើសកម្មភាពរុករកប្រេងនៅក្នុងប្លុកអា បានពន្យាពេលបូមប្រេងនៅក្នុងអណ្តូងរបស់ខ្លួន រហូតដល់ខែធ្នូ ឆ្នាំ២០២០ ដោយសារតែបញ្ហានៃការរីករាលដាលនៃជំងឺកូវីដ១៩។

**សំណួរត្រិះរិះ**

1. ចូរកំណត់និយមន័យ រ៉ែ កំណាប់រ៉ែ និងសន្ទស្សន៍រ៉ែ។
2. តើគេប្រើវិធីអ្វីខ្លះ ដើម្បីសម្គាល់អំពីអត្តសញ្ញាណរបស់រ៉ែ? ចូរពន្យល់។
3. តើធនធានរ៉ែផ្តល់នូវអត្ថប្រយោជន៍អ្វីខ្លះដល់សង្គមមនុស្ស?
4. តើរ៉ែមានប្រភពកំណើតយ៉ាងដូចម្តេចខ្លះ? ចូរពន្យល់។
5. តើមណ្ឌលរ៉ែនៅកម្ពុជាមានប៉ុន្មានមណ្ឌល? អ្វីខ្លះ? ចូររៀបរាប់។
6. ចូររៀបរាប់អំពីសន្ទស្សន៍រ៉ែនៅកម្ពុជា។
7. ចូរពិណ៌នាអំពីប្រវត្តិនៃការសិក្សាស្រាវជ្រាវធនធានរ៉ែនៅកម្ពុជា។

## ៥. ធនធានដីនៅកម្ពុជា

### ៥.១. លក្ខណៈទូទៅនៃធនធានដី

ដីជាធនធានមូលដ្ឋានមួយ នៃភពផែនដី។ ភាគច្រើននៃជីវិតនៅលើភពផែនដីអាចមានអត្ថិភាពបាន ដោយពុំអាចគ្មានវត្តមាននៃដីបាននោះឡើយ។ ផែនដីទាំងមូលរបស់យើងបានគ្របដណ្តប់ទៅដោយដី គោកចំនួនប្រហែល ៣០% និងផ្ទៃទឹកសមុទ្រចំនួនប្រហែល ៧០%។

**ក. និយមន័យ**

**ដី** គឺជាស្រទាប់ខាងលើបង្អស់នៃសម្បកផែនដី ដែលស្ថិតនៅជាមុខកណ្តាលរវាងមណ្ឌលជីវៈ និងមណ្ឌលថ្ម ដោយមានកម្រាស់ពី ២ សង់ទីម៉ែត្រ ដល់ ៣ ម៉ែត្រ។ ដី គឺជាល្បាយនៃខ្យល់ ទឹក អំបិលខនិជ សារធាតុខនិជ ដែលបានមកពីសំណឹករូបធាតុសរីរាង្គ និងសារពាង្គកាយរបស់ភាវរស់។

**ដីវិទ្យា** គឺជាវិទ្យាសាស្ត្រ ដែលសិក្សាអំពីលក្ខណៈ និងសមត្ថភាពចិញ្ចឹមរបស់ដីដូចជា ទម្រង់ វាយភាព ប្រភពកំណើត ការវិវត្តន៍ និងភាពអាស៊ីតជាដើម។

**ដីក្រាម ឬដីប៉ុតសុល** គឺជាប្រភេទដី ដែលកកើតឡើងមកពីការបំបែកធាតុ នៃសិលាក្រានីត និងស៊ីស មានកម្រាស់ស្តើង សម្បូរជាតិអាស៊ីត មានជីជាតិតិច ជាប្រភេទដីព៌ណប្រផេះ ដែលគេនិយមហៅថា ដីប៉ុតសុល។ នៅលើដីប្រភេទនេះ ច្រើនជាប្រភេទព្រៃធំៗនៃតំបន់ត្រជាក់ ដែលមានដុះប្រភេទដើមឈើរាងសាជីដូចជានៅអាមេរិកខាងជើង ស៊ីបេរី និងឡាប៉ូនី (ភាគខាងជើងរុស្ស៊ី និងអឺរ៉ុប និងភាគខាងជើងស្កង់ឌីណាវ)។

**ដីកំទេចកំណ ឬដីឈៃរណូស្យូម** គឺជាប្រភេទដីក្រាស់ សម្បូរជីជាតិដែលកកើតឡើងដោយសារការបំបែកធាតុនៃពពួករុក្ខជាតិ និងសត្វ។ វា គឺជាដីដែលស្ថិតនៅក្នុងតំបន់វាលស្មៅ និងព្រៃសម្បូស្លឹកនៅតំបន់ត្រជាក់បង្គួរ។ ដីប្រភេទនេះ គេឃើញមាននៅទំនាបអាមេរិកខាងជើង អឺរ៉ុបខាងលិច ភាគខាងលិចរុស្ស៊ី និងប្រទេសអ៊ុយក្រែន។

**ដីល្បាប់** គឺជាប្រភេទដីក្រាស់ សម្បូរជីជាតិ ដែលកកើតឡើងដោយសារការហូរទៅចាក់បង្ករបស់ខ្សែទឹកហូរនៅត្រង់ទីកន្លែងណាមួយ។ ដីប្រភេទនេះ គេប្រទះឃើញមាននៅតាមតំបន់ទំនាបដែលមានទន្លេហូរកាត់ ដូចជាមាននៅតាមអាងទន្លេមេគង្គ អាងទន្លេអាម៉ាសូន អាងទន្លេមីស៊ីស៊ីពី អាងទន្លេយ៉ាងសេ អាងទន្លេហួងហ៊ី អាងទន្លេលឿង អាងទន្លេឥណ្ឌូង អាងទន្លេគង្គារ អាងទន្លេចៅផ្រះយ៉ា អាងទន្លេអ៊ីយ៉ារ៉ាទីជាដើម។

**ដីមមោក** គឺជាប្រភេទដីពណ៌ខ្មៅ សម្បូរដីជាតិដែលកកើតឡើងដោយសារការបំបែកជាតុនៃសំណល់សារពាង្គកាយមានជីវិត។ វា ជាប្រភេទដីធូរ សម្បូរទៅដោយអុកស៊ីសែនខ្ពស់ មានកម្រិតជាតិអាស៊ីតទាប ហើយច្រើនគេប្រទះឃើញដីប្រភេទនេះមាននៅតាមបាតុបឹង និងបាតត្រពាំងជាដើម។

**ដីឡឺស** គឺជាប្រភេទដីពណ៌លឿង សម្បូរដីជាតិដែលកើតឡើងពីការចាក់បង្គរនៅត្រង់កន្លែងណាមួយ ដោយចរន្តខ្យល់បក់នៅតំបន់វាលលំហក្តៅ។ ដីប្រភេទនេះ ត្រូវបានគេប្រទេះឃើញមានច្រើបំផុតនៅប្រទេសចិន នៅក្បែរតំបន់វាលលំហហ្គោប៊ី ដែលស្ថិតនៅតាមបណ្តោយព្រំប្រទល់ប្រទេសចិន និងប្រទេសម៉ុងហ្គោលី។

## ខ. របេច ឬដំណើរពុកផុយនៃដី

របេច ឬដំណើរពុកផុយ គឺជាដំណើរនៃការបំផ្លាញសិលា ឬរូបធាតុទាំងឡាយ ដោយធម្មជាតិនិងមានល្បឿនយឺតៗ ហើយដែលបានធ្វើឱ្យសិលា ឬរូបធាតុទាំងនោះឈានទៅរកការបាក់បែក ប្រេះស្រាំ និងការសឹករេចរិល។ ឬគេអាចឱ្យនិយមន័យម្យ៉ាងទៀតថា របេច ឬដំណើរពុកផុយ គឺជាដំណើរនៃការប្រេះស្រាំ ការបាក់បែកជាបំណែកៗនៃសិលា ដី និងខនិជរបស់ផែនដី ដោយធម្មជាតិ តាមរយៈទំនាក់ទំនងដោយផ្ទាល់ជាមួយនិងបរិយាកាស។ របេច ឬដំណើរពុកផុយដែលកើតឡើងពីអាកាសធាតុមានល្បឿនយឺត ហើយដំណើរនេះមានឥទ្ធិពលទៅលើរូបធាតុទាំងឡាយក្នុងបរិយាកាស។

ប្រសិនបើយើងធ្វើការកត់សម្គាល់លើជញ្ជាំងផ្ទះមួយ យើងនឹងឃើញកំបោរដែលគេបានលាបលើជញ្ជាំងនោះរបក។ ឥដ្ឋថ្មីមានពណ៌ក្រហមភ្លឺ និងមានជ្រុងស្រួចៗប្រែទៅជាមានពណ៌ស្រអាប់ និងមានជ្រុងទាល ហើយដុំឥដ្ឋទាំងនោះក៏អាចមានស្នាមប្រេះស្រាំផងដែរ។ របេច ឬដំណើរពុកផុយមិនត្រឹមតែមានអំពើទៅលើសំណង់ផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានឥទ្ធិពលទៅលើអង្គធាតុលោហៈ និងផ្ទាំងសិលានៅក្នុងបរិយាកាសផងដែរ។

ក្នុងរយៈពេលដ៏វែងនៅតាមជញ្ជាំងភ្នំ ឬតាមជ្រលងភ្នំ សិលាត្រូវបានប្រេះស្រាំ បែកបាក់ និងពុកផុយ ហើយធ្លាក់ចុះមកគរគ្នានៅតាមជើងភ្នំ និងនៅតាមជ្រលងភ្នំ ដែលបង្កើតបានជាច្រាំងជំរាល។ ជាទូទៅរបេច ឬដំណើរពុកផុយមាន ២ ប្រភេទសំខាន់ៗគឺ របេចរូប ឬរបេចមេកានិច (ដំណើរពុកផុយរូប ឬដំណើរពុកផុយមេកានិច និងរបេចគីមី (ដំណើរពុកផុយគីមី)។ ទន្ទឹមគ្នានោះដែរ របេចរូប ឬរបេចមេកានិច (ដំណើរពុកផុយរូប ឬដំណើរពុកផុយមេកានិច) និងរបេចគីមី (ដំណើរពុកផុយគីមី)តែងតែធ្វើសកម្មភាពរួមគ្នា។

### ១. របេចរូប ឬរបេចមេកានិច

របេចរូប ឬដំណើរពុកផុយរូប គឺជាលំនាំនៃការបំផ្លាញផ្ទាំងសិលា ឬបំបែកផ្ទាំងសិលាឱ្យក្លាយទៅជាបំណែកតូចៗ ឬដុំតូចៗ ដោយមិនបានផ្លាស់ប្តូរនូវសមាសធាតុគីមីនៅក្នុងផ្ទាំងសិលា។ បំណែកតូចៗ ឬដុំតូចៗរបស់សិលា ឬរូបធាតុផ្សេងៗ មានសមាសភាពដូចសិលា ឬរូបធាតុដើមផងដែរ។ របេចរូបមានចលនាយឺតៗ ហើយប្រើរយៈពេលយូរ ក៏ប៉ុន្តែធ្វើឱ្យសិលា ឬរូបធាតុប្រេះស្រាំ បាក់បែក និងសឹករេចរឹលបាន។

ក្នុងរបេចរូប ឬដំណើរពុកផុយរូប ផ្ទាំងសិលា ឬរូបធាតុត្រូវបានបំបែកជាបំណែកៗ ឬដុំតូចៗ និងមានរូបសណ្ឋានផ្សេងៗគ្នា។ ផ្ទាំងសិលា ឬផ្ទាំងរូបធាតុតូចៗ ដែលទើបនឹងបានបែកបាក់ថ្មីៗនេះមានជ្រុងស្រួចៗជាច្រើន ប៉ុន្តែដោយសារដំណើរពុកផុយនោះចេះតែបន្តរហូត ទើបដុំសិលា ឬរូបធាតុ តូចៗនោះក៏

រលុបជ្រុងបាត់អស់រហូតមានរាងមូល ហើយរលោង។ មានកត្តាផ្សេងៗជាច្រើនទៀត ដែលបណ្ដាលឱ្យមានរបេច ឬដំណើរពុកផុយរូបកើតមានឡើងដូចជា កត្តាសីតុណ្ហភាព កត្តាដំណើរបង្កក-រលាយ កត្តាភាវៈរស់ កត្តាទំនាញផែនដី និងកត្តាសំណឹក។

- **កត្តាសីតុណ្ហភាព**

សិលា ឬរូបធាតុអាចប្រេះស្រាំ និងបាក់បែកបាន ដោយសារតែការប្រែប្រួលនៃសីតុណ្ហភាព។ នៅពេលថ្ងៃផ្នែកខាងក្រៅនៃផ្ទាំងសិលាធំៗ ឬរូបធាតុទទួលរងកម្ដៅខ្លាំងពីព្រះអាទិត្យ ហើយចាប់ផ្ដើមរីកមាឌ ក៏ប៉ុន្តែផ្នែកខាងក្នុងនៃផ្ទាំងសិលា រូបធាតុទាំងនោះនៅតែត្រជាក់ និងមិនរីកមាឌទេ។ នៅពេលយប់ នៅពេលដែលសីតុណ្ហភាពធ្លាក់ចុះបានធ្វើឱ្យផ្នែកខាងក្រៅនៃផ្ទាំងសិលា ឬរូបធាតុបានចុះត្រជាក់ ហើយក៏រួមមាឌវិញ។ ដំណើរវិលចុះ វិលឡើងនៃសីតុណ្ហភាពជារៀងរាល់ថ្ងៃនេះបានធ្វើឱ្យដុំសិលា ឬរូបធាតុប្រេះស្រាំរហូតដល់បាក់បែកជាបំណែកៗផ្សេងៗគ្នា។ នៅតំបន់អាកាសធាតុក្ដៅ កម្លាំងនៃរបេចរូប ឬដំណើរពុកផុយរូបសំខាន់ជាងគេគឺសីតុណ្ហភាពនេះឯងដូចជា នៅតំបន់ត្រូពិច និងតំបន់វាលលំហក្ដៅជាដើម។

- **កត្តាដំណើរបង្កក-រលាយ**

ទឹកខុសប្លែកពីអង្គធាតុរាវដទៃទៀតគឺ វារីកមាឌនៅពេលវាកក។ កំណក និងរលាយនៃទឹក គឺជាមូលហេតុរួមមួយដែលនាំឱ្យមានរបេចរូប ឬដំណើរពុកផុយមេកានិច។ នៅតំបន់អាកាសធាតុត្រជាក់ កម្លាំងនៃរបេចរូបសំខាន់ជាងគេ គឺកំណក និងការរលាយនៃទឹក។ បាតុភូតនេះ កើតមានឡើងនៅពេលដែលទឹកជ្រាបចូលទៅក្នុងស្នាមប្រេះរបស់សិលា ឬរូបធាតុ។ នៅពេលដែលសីតុណ្ហភាពធ្លាក់ចុះក្រោមសូន្យអង្សារសេ ទឹកត្រូវកកហើយរីកមាឌ។ ការរីកមាឌនៃទឹក ដែលកកបានធ្វើឱ្យស្នាមប្រេះនេះកាន់តែធំឡើងៗ។ ក្នុងពេលកំណត់មួយ កំណក និងការរលាយនៃទឹកបានធ្វើឱ្យសិលាបែកជាបំណែកតូចៗ បាតុភូតនេះហៅថា **របេច ឬដំណើរពុកដោយកំណក**។

នៅតំបន់ត្រជាក់ដូចជា បណ្ដាប្រទេសនៅអឺរ៉ុប ឬអាមេរិក តាមផ្លូវក្រាលស៊ីម៉ង់ត៍ គេឃើញមានស្នាមប្រេះ និងគ្រលុកដែលកើតឡើងពីដំណើរពុកផុយដោយកំណក។ ផ្ទុយទៅវិញ របេចបែបនេះមិនអាចកើតមានបានទេសដែលមានអាកាសធាតុក្ដៅដូចនៅប្រទេសកម្ពុជាយើងទេជាដើម។

- **កត្តាភាវរស់**

សិលា ឬរូបធាតុក៏អាចប្រេះស្រាំ និងបាក់បែកបាន ដោយសារតែភាវរស់ផងដែរ។ ក្នុងការរស់នៅប្រចាំថ្ងៃ ភាវរស់បានធ្វើសកម្មភាពជាច្រើន ដែលបង្កឱ្យសិលា ឬរូបធាតុរងនូវការប្រេះស្រាំ និងបាក់បែកទៅជាបំណែកៗ។ របេច ឬដំណើរពុកផុយ ដែលទាក់ទងនឹងភាវរស់ទាំងនេះរួមមាន ៖

- **របេច ឬដំណើរពុកផុយដោយរុក្ខជាតិ** ៖ រុក្ខជាតិក៏អាចបង្កឱ្យមានរបេច ឬដំណើរពុកផុយរូបផងដែរ។ រុក្ខជាតិអាចធ្វើឱ្យសិលារបេះចេញពីគ្នាបាន ដោយសារការដុះរបស់រុក្ខជាតិនៅតាមស្នាមប្រេះរបស់សិលា ឬរូបធាតុ ហើយនៅពេលដែលរុក្ខជាតិទាំងនោះដុះលូតលាស់ វាបានធ្វើឱ្យស្នាមប្រេះរបស់សិលាកាន់តែរីកធំឡើងៗ។

- **របេច ឬដំណើរពុកផុយដោយមនុស្ស** ៖ មនុស្សក៏ជាមូលហេតុដែលនាំឱ្យមានដំណើរពុកផុយ ឬ របេចរូបផងដែរ ដូចជាមនុស្សប្រើប្រាស់ឧបករណ៍ទំនើបៗទៅបំផ្លាញផ្ទាំងថ្មធំៗ ដើម្បីយកកំទេចថ្មមកប្រើប្រាស់ សម្រាប់ក្រាលថ្នល់ និងគ្រឿងសំណង់ផ្សេងៗជាដើម។
- **របេច ឬដំណើរពុកផុយដោយសត្វ** ៖ សត្វក៏ជាមូលហេតុមួយផ្សេងទៀត ដែលនាំឱ្យមានរបេច ឬ ដំណើរពុកផុយមេកានិចផងដែរដូចជា ជន្លេន ស្រមោច សត្វល្អិត និងសត្វផ្សេងៗទៀតបានជីករូងនៅក្នុងដី និងជញ្ជូនដីម៉ដ្ឋៗនៅជុំវិញដែលការណ៍នេះបានធ្វើឱ្យដីធូរ និងសិលានៅក្នុងដីបាក់បែក ក្លាយទៅជាបំណែកតូចៗ។

▪ **កត្តាសំណឹក**

សិលា ឬរូបធាតុអាចប្រេះស្រាំ និងបាក់បែកបាន ដោយសារកម្លាំងសំណឹកផងដែរ។ សំណឹកបង្កឡើងដោយភ្នាក់ងារសំខាន់ ២ ប្រភេទគឺ ខ្យល់ និងទឹក។

- **របេច ឬដំណើរពុកផុយដោយសារកម្លាំងខ្យល់** ៖ នៅតំបន់វាលលំហក្តៅ ខ្យល់អាចនាំឱ្យខ្សាច់តូចៗមានជ្រុងស្រួចៗទៅបោកផ្ទប់លើផ្ទាំងសិលា ឬរូបធាតុ និងធ្វើឱ្យសិលារងសំណឹកក្នុង រយៈពេលយូរអង្វែង។ សកម្មភាពគ្រាប់ខ្សាច់ ដែលមានអំពើលើផ្ទាំងសិលា ឬរូបធាតុ បានធ្វើឱ្យសិលា ឬរូបធាតុទាំងនោះមានទ្រង់ទ្រាយប្លែកៗជាច្រើននៅតំបន់វាលលំហក្តៅ។
- **របេច ឬដំណើរពុកផុយដោយកម្លាំងទឹកហូរ** ៖ ទឹកក៏ជាមូលហេតុ ដែលធ្វើឱ្យសិលាទទួលរងនូវសំណឹកផងដែរ។ ទឹកហូរនៅតាមស្ទឹង ឬនៅតាមទន្លេបាននាំយកដុំសិលា និងកំទេចតូចៗទៅជាមួយ។ ក្នុងអំឡុងពេលដែលទឹកកំពុងហូរនេះ ការប៉ះទង្គិច ឬការកកិតគ្នាទៅវិញទៅមកតែងតែកើតមាន។ សកម្មភាពនេះបានធ្វើឱ្យសិលា ឬរូបធាតុទាំងនោះប្រេះស្រាំ និងបាក់បែកថែមទៀត។ ម្យ៉ាងទៀត ដុំសិលា ឬរូបធាតុដែលរមៀលតាមចរន្ត ទឹកហូរទៅកកិតជាមួយនឹងសិលា ឬរូបធាតុនៅតាមពោះទន្លេ ឬស្ទឹង ធ្វើឱ្យបាតទន្លេ ឬស្ទឹងទាំងនោះមានភាពកាន់តែរាបស្មើ។

▪ **កត្តាទំនាញផែនដី**

ទំនាញផែនដី គឺជាភ្នាក់ងារមួយដែលទាញយកបំណែកសិលា ឬរូបធាតុដែលកំពុងប្រេះស្រាំឱ្យធ្លាក់ចុះមកតាមចំណោតជើងភ្នំ។ នៅពេលបំណែកសិលា ឬរូបធាតុដែលប្រេះស្រាំធ្លាក់ចុះពីលើភ្នំ វារមៀលមកប៉ះទង្គិចគ្នា ដែលជាហេតុធ្វើឱ្យបំណែកទាំងនោះកាន់តែតូចទៅៗ ឬបាក់បែកទៅជាបំណែកផ្សេងៗទៀត។

**២. របេចគីមី ឬដំណើរពុកផុយគីមី**

របេច ឬដំណើរពុកផុយគីមី គឺជាលំនាំនៃការបំផ្លាញសិលា ឬរូបធាតុ តាមរយៈការធ្វើឱ្យមានបំលាស់ប្តូរសមាសធាតុគីមី ដែលមាននៅក្នុងផ្ទាំងសិលា ឬរូបធាតុ។ របេច ឬដំណើរពុកផុយនេះ បានធ្វើឱ្យសមាសធាតុខនិជនៃសិលាត្រូវផ្លាស់ប្តូរ។ ខនិជ គឺជាសារធាតុរឹង ដែលមាននៅក្នុងធម្មជាតិ។ នៅពេលដែលមានបំលាស់ប្តូរលក្ខណៈគីមី ខនិជអាចចាប់យក ឬផ្តាច់ចេញពីសិលា ឬរូបធាតុ។ ម្យ៉ាងវិញ ទៀត ខនិជដែលមាននៅក្នុងសិលា ឬរូបធាតុអាចមានប្រតិកម្មជាមួយនឹងសារធាតុដទៃទៀតនៅក្នុងបរិយាកាស ដែលបង្កើតបានជាផលិតផលថ្មីមួយផ្សេងទៀត។ នៅក្នុងលំនាំបែបនេះ ត្រូវបានគេហៅថា **ការបំបែកជាតុ** មានន័យថា សារជាតុទាំងឡាយនោះធ្វើប្រតិកម្មគីមី ដើម្បីបំបែកសិលា ឬរូបធាតុ។ មានកត្តាជាច្រើនដែលធ្វើឱ្យមានរបេច ឬ

ដំណើរពុកផុយគីមីកើតឡើងដូចជា កត្តាទឹក កត្តាអុកស៊ីតកម្ម កត្តាកាបូនកម្ម កត្តាភ្លៀងអាស៊ីត និងកត្តាអាស៊ីតរុក្ខជាតិ។

- **កត្តាទឹក**

របេច ឬដំណើរពុកផុយគីមីភាគច្រើនបណ្តាលមកពីទឹក។ ទឹកអាចរំលាយខនិជដែលមាននៅក្នុងសិលា ឬរូបធាតុបាន។ ដំណើរនេះត្រូវបានគេហៅថា **ការរំលាយ**។ ទឹកអាចចូលរួមប្រតិកម្មគីមីជា មួយនឹងធាតុគីមី ដែលជាសមាសធាតុផ្សំរបស់សិលា ឬរូបធាតុ ហើយបង្កើតបានជាផលិតផលថ្មីមួយផ្សេងទៀតដែលរលាយក្នុងទឹកដូចជា អ៊ីដ្រុកស៊ីត ដែលកើតឡើងពីប្រតិកម្មគីមីរវាងសិលា ឬរូបធាតុដែលផ្ទុកទៅដោយរ៉ែលោហៈជាមួយនឹងទឹក និងដីឥដ្ឋដែលកើតឡើងពីប្រតិកម្មគីមីរវាងសិលាឬរូបធាតុដែលមានផ្ទុកដោយរ៉ែផែលស្ប៉ាតជាដើម។ ទឹកក៏អាចបង្កើតបានជាសារធាតុអាស៊ីតផងដែរ នៅពេលវាចូលរួមប្រតិកម្មគីមីជាមួយនឹងឧស្ម័នផ្សេងៗទៀតដែលមាននៅក្នុងបរិយាកាស។ អាស៊ីតទាំងនោះបានជួយបង្កើនល្បឿនប្រតិកម្មក្នុងការបំបែកធាតុសិលា ឬរូបធាតុ។

- **កត្តាអ៊ុកស៊ីតកម្ម**

របេច ឬដំណើរពុកផុយគីមីអាចបណ្តាលមកពីអុកស៊ីតកម្មផងដែរ។ អុកស៊ីសែននៅក្នុងខ្យល់គឺជាមូលមូលហេតុដែលនាំឱ្យមានអុកស៊ីតកម្មកើតឡើង។ អុកស៊ីតកម្ម គឺជាដំណើរនៃប្រតិកម្មគីមីរវាងអុកស៊ីសែនជាមួយនិងសារធាតុផ្សេងៗទៀត។ លទ្ធផលនៃអុកស៊ីតកម្ម គឺផលិតផលថ្មីមួយផ្សេងទៀតបានកើតមានឡើង។ ប្រសិនបើយើងដាក់លោហៈដូចជា ដែកនៅហាលខ្យល់ យើងនឹងសង្កេតឃើញថា អុកស៊ីសែនអាចធ្វើឱ្យដែកពុកផុយបាន។ ដែកបានចូលរួមប្រតិកម្មជាមួយនិងអុកស៊ីសែននៅក្នុងខ្យល់ តាមលំនាំមួយដែលគេហៅថា **អុកស៊ីតកម្ម**។ លទ្ធផល នៃអុកស៊ីតកម្មគឺ **ច្រែះ**។ សិលា ដែលមានផ្ទុកនូវសារធាតុដែក និងសារធាតុផ្សេងៗទៀតក៏ទទួលរងនូវអុកស៊ីតកម្មឬច្រែះនេះផងដែរ។ ច្រែះធ្វើឱ្យសិលាទន់ ហើយជ្រុះកម្ទេច និងមានពណ៌ក្រហមត្នោត។

- **កត្តាកាបូនកម្ម**

ឧស្ម័នផ្សេងៗទៀតនៅក្នុងខ្យល់ដូចជា កាបូនឌីអុកស៊ីតក៏ជាមូលហេតុ ដែលបណ្តាលឱ្យមានរបេចគីមី ឬដំណើរពុកផុយគីមីកើតឡើងផងដែរ។ ឧស្ម័នកាបូនិច ឬកាបូនឌីអុកស៊ីតនៅក្នុងខ្យល់បានចូលរួមប្រតិកម្មគីមីជាមួយនិងសំណើមអាកាស ឬទឹកភ្លៀងនៅក្នុងបរិយាកាស និងទឹកនៅក្នុងបឹងទន្លេ ឬត្រពាំង ឬប្រភពទឹកនៅក្នុងដី។ ជាលទ្ធផលនៃប្រតិកម្មគីមីនេះ អាស៊ីតខ្សោយមួយប្រភេទបានកកើតមានឡើងហៅថា **អាស៊ីតកាបូនិច**។ អាស៊ីតកាបូនិចបានចូលរួមប្រតិកម្មគីមីជាមួយនិងសារធាតុដទៃទៀតដែលបង្កើតបានជាលំនាំកាបូនកម្ម។ អាស៊ីតដែលមាននៅក្នុងទឹកភ្លៀងនេះបានធ្លាក់ចុះមកលើផ្ទៃដី ហើយបានជ្រាបចូលទៅក្នុងដី។ អាស៊ីតកាបូនិចអាចធ្វើឱ្យសិលា ជាពិសេសថ្មកំបោរពុកផុយនៅផ្នែកខាងលើ និងនៅផ្នែកខាងក្រោមផ្ទៃដី។ ជាសំណាងល្អ អាស៊ីតកាបូនិចជាអាស៊ីតខ្សោយបំផុត វាពុំអាចបង្កឱ្យមានមហន្តរាយដល់រុក្ខជាតិ មនុស្ស និងសត្វនោះឡើយ។ ប៉ុន្តែវាបានធ្វើឱ្យផែលស្ប៉ាត ថ្មកំបោរ និងថ្មម៉ាបទទួលរងនូវភាពពុកផុយយឺតៗផងដែរ។ ហេតុដូចនេះហើយ ទើបគេសង្កេតឃើញមានគុហា ឬរូង ឬល្អាងតែងតែកើតមាននៅពីក្រោមភ្នំ ឬនៅក្នុងភ្នំ

ដែលភាគច្រើនគ្រប់ដណ្តប់ដោយថ្មកំបោរដូចជាដូចជានៅភ្នំកំពង់ត្រាច ខេត្តកំពត និងនៅភ្នំសំពៅ ខេត្តបាត់ដំបង ជាដើម។

- **កត្តាអាស៊ីតស៊ុលផួរិច**

អាស៊ីតស៊ុលផួរិច ជាកត្តាមួយដ៏សំខាន់ផងដែរ ដែលបានធ្វើឱ្យមានរបេចគីមីកើតមានឡើង។ នៅតំបន់ដែលមានការរីកចម្រើនផ្នែកឧស្សាហកម្ម ខ្យល់អាកាសអាចក្លាយទៅជាកខ្វក់បាន ដោយសារមានវត្តមាននៃឧស្ម័នស៊ុលផួរ និងឧស្ម័ននីដ្រូសែនឌីអុកស៊ីត។ សមាសធាតុនៃឧស្ម័នទាំងនេះបានចូលរួមប្រតិកម្មគីមីជាមួយនឹងចំហាយទឹក ឬទឹកភ្លៀងនៅក្នុងបរិយាកាស។ ជាលទ្ធផលនៃប្រតិកម្មគីមីនេះ មានអាស៊ីតខ្លាំង ២ ប្រភេទបានកើតឡើង គឺអាស៊ីតស៊ុលផួរិច និងអាស៊ីតនីទ្រិច។ ទឹកភ្លៀង ដែលមានជាតិអាស៊ីតទាំង ២ ប្រភេទនេះហៅថា ភ្លៀងអាស៊ីត ហើយបានធ្លាក់មកលើផ្ទៃដី។ នៅលើផ្ទៃដី ភ្លៀងអាស៊ីតទាំងនេះមួយផ្នែកបានជ្រាបចូលក្នុងដី និងមួយផ្នែកទៀតបានដក់នៅផ្ទៃលើសិលា។ នៅលើផ្ទៃសិលា ឬនៅក្នុងដី អាស៊ីតភ្លៀងទាំងពីរប្រភេទនេះ បានចូលរួមប្រតិកម្មជាមួយនិងសារធាតុគីមីផ្សេងៗទៀតដែលជាសមាសធាតុផ្សំរបស់សិលា ឬរូបធាតុនានា ហើយបានផ្តាច់យកសារធាតុគីមីទាំងនោះឱ្យចេញពីសិលា ឬរូបធាតុ ដែលធ្វើឱ្យសិលារងការពុកផុយ ឬរលាយបង្កើតបានជាផលិតផលថ្មីមួយផ្សេងទៀត។ ដោយសារតែអាស៊ីតទាំងពីរប្រភេទនេះគឺជាអាស៊ីតដែលខ្លាំងជាងអាស៊ីតកាបូនិច ដូច្នេះភ្លៀងអាស៊ីតនេះ គឺជាមូលហេតុដ៏លឿនបំផុតនៃដំណើរពុកផុយគីមី ឬរបេចគីមី ពីព្រោះវាអាចស៊ីផ្តាច់សិលា លោហៈ និងវត្ថុដទៃទៀតបានយ៉ាងឆាប់រហ័សបំផុត។

- **កត្តាអាស៊ីតរុក្ខជាតិ**

យើងបានដឹងរួចមកហើយថា រុក្ខជាតិអាចបង្កឱ្យមានរបេចមេកានិច ឬដំណើរពុកផុយមេកានិចបាន។ តែទន្ទឹមនឹងនោះដែរ រុក្ខជាតិក៏អាចបង្កឱ្យមានរបេចគីមី ឬដំណើរពុកផុយគីមីបានផងដែរ។ ជាទូទៅ គ្រាប់រុក្ខជាតិដែលធ្លាក់មកលើផ្ទៃដី ឬលើផ្ទៃសិលា នៅពេលដែលវាដុះពន្លក ឬសរបស់វាបានចាក់ចូលទៅក្នុងស្នាមប្រេះនៃសិលា ឬរូបធាតុ។ នៅពេលដែលឫសរុក្ខជាតិដុះលូតលាស់ វាបង្កើតបានជាអាស៊ីតខ្សោយមួយប្រភេទ ដែលអាចរំលាយខនិជនៅក្នុងសិលាបាន។ ក្នុងពេលមួយ សិលាត្រូវបានសឹករេចរឹលបន្តិចម្តងៗ លំនាំបែបនេះមានលក្ខណៈសំខាន់ណាស់នៅក្នុងការបង្កើតដី។ ស្លែ ហើយនិងលីកែនជាប្រភេទរុក្ខជាតិ ដែលបង្កើតឡើងនូវអាស៊ីតខ្សោយ ហើយច្រើនដុះនៅលើសិលា។

ស្ថិតនៅក្រោមអាកាសធាតុត្រូពិចក្តៅ ហើយសើម ថ្មនៅតាមប្រាសាទនានាក្នុងប្រទេសកម្ពុជាយើងមានដុះស្លែពាសពេញ។ បច្ចុប្បន្ននេះ អាជ្ញាធរអប្សរា ដោយមានការជួយឧបត្ថម្ភពីអង្គការយូណេស្កូបាននឹងកំពុងកំចាត់ស្លែទាំងនោះចេញ។ បើដូច្នេះទេ វានឹងបណ្តាលឱ្យថ្មទាំងនោះមានសារធាតុអាស៊ីត ដែលធ្វើឱ្យថ្មប្រាសាទត្រូវទទួលរងនូវការពុកផុយ។

### គ. ល្បឿននៃរបេច ឬដំណើរពុកផុយ

ល្បឿននៃរបេច ឬដំណើរពុកផុយគឺទាក់ទងទៅនឹងកត្តារួមផ្សំមួយចំនួន។ ជាតុផ្សំនៃសិលាពីរប្រភេទដែលស្ថិតនៅក្នុងអាកាសធាតុដូចគ្នា អាចទទួលរងនូវដំណើរពុកផុយខុសៗគ្នា អាស្រ័យទៅលើប្រភេទខនិជដែលបង្កើតប្រភេទសិលានីមួយៗ។ ប្រសិនបើខនិជ នៅក្នុងសិលាធន់នឹងដំណើរពុកផុយគីមីបាន សិលានោះត្រូវបានគេហៅថា **សិលាស្ថិតស្ថេរ**។

សិលាស្ថិតស្ថេរមានលក្ខណៈខុសៗគ្នា អាស្រ័យទៅលើសិលា ដែលទទួលរងនូវអាកាសធាតុតាមទីកន្លែងផ្សេងៗគ្នា។ ឧទាហរណ៍ ៖ ថ្មកំបោររងការពុកផុយតិចតួចបំផុតនៅតំបន់អាកាសធាតុស្ងួតហែង។ ក៏ប៉ុន្តែនៅតំបន់ដែលមានអាកាសធាតុក្តៅ ហើយសើម សំណើមអាចរំលាយថ្មកំបោរបានទាំងស្រុង។ ឧទាហរណ៍ ៖ ភ្នំសំពៅនៅក្នុងខេត្តបាត់ដំបង គឺជាភ្នំថ្មកំបោរ មានល្អាងធំមួយ ដែលកើតឡើងដោយសារការរលាយថ្មកំបោរ។ សិលាក្រានីតធន់នឹងអាកាសធាតុត្រជាក់ និងអាកាសធាតុក្តៅស្ងួត ក៏ប៉ុន្តែបើវាស្ថិតនៅក្នុងអាកាសធាតុត្រូពិចក្តៅ ហើយសើមវិញ វាអាចប្រេះស្រាំ។

ផែលស្ប៉ាតជាខនិជ សម្រាប់ភ្ជាប់គ្រាប់ក្រោមសិលាក្រានីត។ កាលណាបើមានភ្លៀងធ្លាក់ច្រើន ផែលស្ប៉ាតរលាយក្លាយទៅជាដីឥដ្ឋ ដែលធ្វើឱ្យសិលាងាយប្រេះស្រាំដាច់ចេញពីគ្នា។ ដូច្នេះ សិលានៅតំបន់ដែលមានសំណើមខ្ពស់អាចទទួលរងនូវការពុកផុយ ឬរបេចយ៉ាងឆាប់រហ័ស។

កង្វក់អាកាសក៏ជួយបង្កើនល្បឿនពុកផុយ ឬរបេចផងដែរ។ ចំហេះផូស៊ីលឥន្ទនៈដូចជា ប្រេងកាតធ្យូងថ្ម និងឧស្ម័នធម្មជាតិបង្កើតឱ្យមានឧស្ម័នកាបូនិច និងឧស្ម័នដទៃទៀតនៅក្នុងបរិយាកាស។ ឧស្ម័នទាំងនោះបានចូលរួមប្រតិកម្មគីមីជាមួយនឹងទឹកក្នុងបរិយាកាស ដើម្បីបង្កើតជាអាស៊ីតឡើង។

នៅបណ្តាទីក្រុងដែលមានការបំពុលបរិយាកាសខ្លាំង ល្បឿននៃរបេចឬដំណើរពុកផុយក៏មានកម្រិតខ្លាំងផងដែរ។ គេអាចឃើញឥទ្ធិពលនៃការបំពុលបរិយាកាសនេះទៅលើសំណង់រូបសំណាក និងវិមានទាំងឡាយបានដូចជា សសរស្តម្ភមួយដែលមានឈ្មោះថា **ក្លេអូប៉ាត** មានអាយុ ៣ ៥០០ឆ្នាំ ដែលគេបានតម្កល់ទុកនៅប្រទេសអេស៊្សីបក្នុងតំបន់វាលលំហាក្តៅ មានបម្រែបម្រួលតែបន្តិចបន្តួចប៉ុណ្ណោះ។ ប៉ុន្តែ ក្រោយពីគេលើកយកទៅតម្កល់នៅក្នុងសួនសាធារណៈនៅទីក្រុងញូវយ៉ក សសរស្តម្ភនោះត្រូវរងនូវការពុកផុយដោយសារកាបំពុលបរិយាកាស ក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ។

សិលាចាស់ៗដែលមិនរងនូវកម្លាំងផ្សេងៗនៃរបេច ឬដំណើរពុកផុយស្ទើរតែគ្មានបំលាស់ប្តូរ។ ក៏ប៉ុន្តែសិលាដែលកកើតឡើងដោយសារការចាក់បង្គរថ្មីៗនៅលើផ្ទៃដីនឹងត្រូវទទួលរងនូវសំណឹកយ៉ាងឆាប់រហ័ស។

### ឃ. កំណកំណើរបស់ដី

#### ១. ការវិវត្តន៍របស់ដី

ដូចយើងបានដឹងរួចមកហើយថា ដីបានកកើតឡើង ដោយសារតែអន្តរកម្មរវាងសិលាជាមួយអាកាសធាតុ កត្តាជីវៈ និងវដ្តធារាសាស្រ្តនៅតំបន់មួយ។ ជំហានទីមួយនៃកំណកំណើតដី គឺការបំបែកសិលាតាមបាតុភូតរូប និងបាតុភូតគីមី ដែលត្រូវគេហៅថារបេច ឬដំណើរពុកផុយ (Weathering)។ របេចរូប ឬរបេចមេកានិច (Physical weathering ឬ Mechanical weathering) គឺបានកើតឡើងដោយសារឥទ្ធិពលនៃចលនាទឹក ខ្យល់ កំដៅ និងកត្តាជីវៈ ទៅលើសិលាមេ ដំណើរបង្កក-រលាយ និងទំនាញផែនដី។ របេចគីមី (Chemical weathering) បានកកើតឡើងនៅពេលដែលទឹកមានអន្តរកម្មជាមួយនិងខនិជផ្សេងៗ ដែលជាធាតុផ្សំរបស់សិលា ហើយបង្កើតបានជាផលិតផលថ្មីមួយផ្សេងទៀត។ រូបធាតុមេដែលជាប្រភពសមាសធាតុផ្សំនៃដី អាចជាសិលានៅក្រោមស្រទាប់ដី ឬកំទេចកំណដែលត្រូវបាននាំពីទីផ្សេងៗ ក្រោមអំពើនៃទឹក និងកំលាំងទំនាញផនដី។ ដំណឹកជញ្ជូនកំទេចកំណ ឬដីនៅតាមចរន្តទឹក (ឧទាហរណ៍ ៖ ទឹកទន្លេមេគង្គ ទឹកទន្លេបាសាក់ ឬទឹកទន្លេសាប) ត្រូវបានគេហៅថា ដំណុះល្បាប់ (Alluviation)។ ដំណើរដឹកជញ្ជូនកំទេចកំណនៅត្រង់

កន្លែងណាមួយ ឬដីដោយកម្លាំងទំនាញផែនដីត្រូវបានគេហៅថា ដីល្បាប់ (Colluviation)។ ដីកដែលកើតឡើងនៅនឹងកន្លែងដែលមានសិលាមេ (ពោលគឺកើតឡើងនៅត្រង់កន្លែង ឬនៅមិនឆ្ងាយពីរូបជាតុមេ) ដូចជាសិលាក្រៃលាយស៊ីស សិលាបាសាល់ និងថ្មកំបោរអាចឃើញមាននៅក្នុងប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ។ ដីច្រើនប្រភេទនៅភូមិភាគឦសានកើតពីរបេចនៃសារជាតុកំអែភ្នំភ្លើង។ ដីនៅតំបន់វាលទំនាបនៃប្រទេសកម្ពុជាបានកកើតឡើង (និងកំពុងតែបន្តកកើតឡើង) ដោយសារដីល្បាប់ ដែលត្រូវបានហូរដឹកជញ្ជូនតាមទឹកទន្លេមេគង្គ និងទន្លេសាប។

## ២. ស្រទាប់របស់ដី

ដីមានលក្ខណៈសម្គាល់ដូចជា កម្រាស់ ភាពម៉ដ្ឋ កម្រិតជាតិអាស៊ីត (pH របស់ដី) សមាសភាពរ៉ែ និងស្រទាប់របស់វា។ ជាតុទាំងអស់នេះ កំណត់នូវកម្រាស់ និងកម្រិតមមោកផ្នែកខាងលើ ដែលសម្រាប់ទ្រទ្រង់ដល់ជីវិតរុក្ខជាតិ។

ដីមានភាពខុសគ្នា គឺអាស្រ័យទៅដោយអាកាសធាតុ សណ្ឋានដី សិលាមេ ពេលវេលា និងសកម្មភាពរបស់ភាវៈរស់។ ចលនាតាមខ្សែឈរ និងតាមខ្សែដេកនៃរូបជាតុផ្សំក្នុងប្រព័ន្ធដីបង្កើតឱ្យមានស្រទាប់ដីខុសៗគ្នាជាច្រើន។ មុខខ្នាត់ដីទូទៅមួយបង្ហាញពីស្រទាប់លើ (ស្រទាប់ O) ដែលជាស្រទាប់សម្បូរទៅដោយសារជាតុសរីរាង្គ។ សំណល់របស់រុក្ខជាតិរួមមានដូចជា ស្លឹក មែក ឬសំបកងាប់បានបន្សល់ទុកនៅក្នុងស្រទាប់ O ហើយរលួយបន្តិចម្តងៗ។ ខាងក្រោមស្រទាប់ O មានដីស្រទាប់ A ដែលមានពណ៌ខ្មៅ និងសម្បូរដោយសារជាតុសរីរាង្គរលួយ។ ដីស្រទាប់ A អាចខ្សោះជីជាតិ ព្រោះតែការលេចចេញនូវសារជាតុចិញ្ចឹមទៅស្រទាប់ដីជ្រៅខាងក្រោមទៀត។ ក្រោមស្រទាប់ A មានដីស្រទាប់ Bដែលសម្បូរដោយសារជាតុចិញ្ចឹម ដែលជ្រាបលេចចេញពីស្រទាប់លើៗ។ ស្រទាប់នេះ ច្រើនសម្បូរទៅដោយសារជាតុដែក និងអាលុយមីញ៉ូម។ នៅខាងក្រោមស្រទាប់ B មានស្រទាប់ C ជាស្រទាប់ដែលផ្សំឡើងដោយកំទេចកំទីបានមកពីសំណឹកនៃសិលាមេដោយភាគ។ ដីស្រទាប់ C ស្ថិតនៅជ្រៅ បណ្តាលឱ្យឫសរុក្ខជាតិភាគច្រើនមិនអាចចាក់ចូលដល់ ហើយដីស្រទាប់នេះច្រើនតែឆ្អែតទឹក និងមិនសូវសម្បូរទៅដោយសារជាតុចិញ្ចឹម។







*ស្រទាប់របស់ដី*

### ៣. វាយភាពរបស់ដី

វាយភាពរបស់ដី គឺអាស្រ័យទៅនឹងសមាមាត្រធៀបនៃចុណ្ណភាគខ្សាច់ ល្បាប់ម៉ដ្ឋ និងដីឥដ្ឋ។ ចុណ្ណភាគទាំងនេះមានទំហំផ្សេងៗគ្នា។ វាយភាពរបស់ដីមានសារៈសំខាន់ណាស់ ព្រោះវាមានឥទ្ធិពលទៅលើទម្រង់វត្តមានសារធាតុចិញ្ចឹម និងទឹកក្នុងដី។ ដីខ្សាច់មានរន្ធប្រហោងធំៗ ដែលអាចឱ្យទឹកជ្រាបឆ្លងកាត់រហ័សជាងដីឥដ្ឋ។ ដីខ្សាច់មានសភាពគ្រោតគ្រាត និងមិនស្អិតជាប់គ្នានោះទេ នៅពេលដែលគេច្របាច់វា។ ដីឥដ្ឋស្អិត និងងាយលុញឱ្យមូលបាន។ វាយភាពដីល្បាប់ម៉ដ្ឋស្ថិតនៅចន្លោះដីឥដ្ឋ និងដីខ្សាច់ ហើយវាអាចស្អិតជាប់គ្នាជាបង្គួរ។ វាយភាពរបស់ដីមានសារៈសំខាន់ណាស់ក្នុងការកំណត់ភាពសមស្របសម្រាប់ការប្រើប្រាស់ណាមួយជាក់លាក់ ក្នុងសកម្មភាពសេដ្ឋកិច្ច។

*តារាងវាយភាពរបស់ដី*

| ប្រភេទចុណ្ណភាគ | ទំហំចុណ្ណភាគ (mm) |
|---|---|
| គ្រួស | > 2,0 |
| ខ្សាច់ | 0,02-2,0 |
| ល្បាប់ម៉ដ្ឋ | 0,002-0,02 |
| ឥដ្ឋ | < 0,002 |

### ៤. ទម្រង់របស់ដី

ទម្រង់របស់ដីបង្ហាញពីលំដាប់តម្រៀបគ្នានៃចុណ្ណភាគដី។ វាមានឥទ្ធិពលលើជម្រាបទឹក និងលទ្ធភាពដែលអាចឱ្យឫសរបស់រុក្ខជាតិជ្រៀតចូលទៅក្នុងដីបាន។ ការប្រើប្រាស់ដីមានឥទ្ធិពលទៅលើទម្រង់ដីដូចជាការដាំដំនាំអតិផលបែបឯកវប្បកម្មនាំឱ្យបាត់បង់សារធាតុចិញ្ចឹម ឬសារធាតុសរីរាង្គនៅក្នុងដី។ ការបាត់បង់សារធាតុចិញ្ចឹម ឬសារធាតុសរីរាង្គបែបនេះ ជាហេតុនាំឱ្យទទួលបានទិន្នផលទាប និងបន្ថយនូវប្រសិទ្ធភាពដីមួយចំនួន ដែលប្រើសម្រាប់ដំណាំ។ គម្របដំណាំជួយការពារទម្រង់ដី និងកាត់បន្ថយនូវសំណឹកដីដូចជាតាមរយៈការកាត់បន្ថយលំហូរលើផ្ទៃ នៅក្រោយពេលមានភ្លៀងធ្លាក់ធំ។

### ៥. សារពាង្គកាយក្នុងដី

នៅក្នុងដីមានសារពាង្គកាយមានជីវិតជាច្រើនប្រភេទរស់នៅ។ ដីមួយស្លាបព្រាបាយអាចមានសារពាង្គកាយរាប់លានរស់នៅ។ ចំនួនសារពាង្គកាយនេះ គឺអាស្រ័យទៅតាមភាពមានជីជាតិរបស់ដី។ ស្ថានប្រព័ន្ធដីមានសភាពប្លែកពីគ្នាខ្លាំង ហើយអាចមានបាក់តេរី ផ្សិត សត្វល្អិត ឬសរុក្ខជាតិ រហូតដល់សត្វខ្លះដូចជា កណ្ដុរ និងពស់ជាដើម។ សារពាង្គកាយមានជីវិតទាំងនេះ មានអន្តរកម្មនៅក្នុងបណ្ដាញអាហារដ៏សាំញ៉ាំ ដែលត្រូវបានគេហៅថា ខ្សែអាហារ ឬបណ្ដាញអាហារ។ នៅពេលដែលសារពាង្គកាយទាំងនេះងាប់ វាក៏រលួយបំបែកជាតុ ហើយរួមចំណែកទៅក្នុងវដ្តសារធាតុចិញ្ចឹមនៃស្ថានប្រព័ន្ធ។ ពពួកមីក្រូសារពាង្គកាយក្នុងដីបានបំបែកសំណល់រុក្ខជាតិបង្កើតបានជាមមោក ដែលជួយបង្កើនសមត្ថភាពដី ក្នុងការស្រូបយកទឹក និង សារធាតុចិញ្ចឹម។

នៅក្នុងស្ថានប្រព័ន្ធដីដែលមានតុល្យភាព ទំនាក់ទំនងរវាងដីជាមួយនិងសារពាង្គកាយ ដែលរស់នៅក្នុងដី និងលើដី គឺជួយធានាឱ្យដីមានជីជាតិ។ វដ្តនៃសារធាតុចិញ្ចឹមនៃដី គឺជាដំណើរវិលជុំនៃសារធាតុចិញ្ចឹមដូចជា អាសូត ផូស្វរ និងប៉ូតាស ដែលធ្វើដំណើរពីដីទៅសារពាង្គកាយមានជីវិត និងពីសារពាង្គកាយមានជីវិតវិលត្រឡប់ចូលទៅក្នុងដីវិញ។ ពួកមីក្រូសារពាង្គកាយដូចជា បាក់តេរី និងផ្សិតបានបំបែកសំណល់កំទេចកំទី និងសាកសពសត្វ និងរុក្ខជាតិ ដោយបញ្ចេញសារជាតុចិញ្ចឹមទៅក្នុងដី សម្រាប់ការប្រើប្រាស់ឡើងវិញ។ ទោះបីជាមានការលេចចេញ ដែលធ្វើឱ្យបាត់បង់សារជាតុចិញ្ចឹមខ្លះៗ ពីស្ថានប្រព័ន្ធចូលទៅតាមទឹកក្នុងដីក៏ដោយ ក៏សំណឹកសិលាមេបានមកជំនួសផ្នែក ដែលបាត់បង់មួយភាគធំ ឬទាំងស្រុង។

***ប្រភេទសារពាង្គកាយមានជីវិតនៅក្នុងដី***



ដីភាគច្រើនគឺមានកម្រិតប៉េហាស់ (pH) នៅក្នុងចន្លោះពី ៤ ទៅ ៨។ កម្រិតប៉េហាស់ (pH) របស់ដីមានឥទ្ធិពលទៅលើទិន្នផលដំណាំ និងសារពាង្គកាយមានជីវិតផ្សេងៗទៀតនៅក្នុងដី។ រុក្ខជាតិរងឥទ្ធិពលពីអន្តរកម្មរវាងសារជាតុចិញ្ចឹមនានា ដែលអាស្រ័យទៅនឹងអត្រា នៃកម្រិតប៉េហាស់ (pH)។ ឧទាហរណ៍ ៖ នៅកម្រិតប៉េហាស់ (pH) ទាប (ដីជូ) សមាសធាតុដែក និងអាលុយមីញ៉ូមងាយនឹងរលាយ ក៏ប៉ុន្តែសមាសធាតុផូស្វរ និងប៉ូតាស្យូម ដែលជាសារជាតុចិញ្ចឹមដ៏សំខាន់ សម្រាប់ដំណាំបែរជាមិនសូវរលាយ ដែលធ្វើឱ្យដីខ្វះជាតិផូស្វរ និងប៉ូតាស្យូម ហើយបណ្តាលឱ្យរុក្ខជាតិមិនសូវលូតលាស់។ នៅកម្រិតប៉េហាស់ (pH) ខ្ពស់ (ដីប្រៃនិងល្វីង) ទាំងសមាសជាតុដែក អាលុយមីញ៉ូម និងសមាសជាតុផូស្វរ និងប៉ូតាស្យូម មិនសូវរលាយដែលធ្វើឱ្យដីខ្វះជាតិផូស្វរ និងប៉ូតាស្យូម ហើយបង្កឱ្យរុក្ខជាតិមិនសូវលូតលាស់។ នៅប្រទេសកម្ពុជាយើងមានករណីដីជូ និងប្រៃជាច្រើនដែលជាដីខ្វះសារជាតុផូស្វរ និងប៉ូតាស្យូម ជាហេតុនាំឲ្យដំណាំផ្តល់ទិន្នផលទាប។ កម្រិតប៉េហាស់ (pH) សមស្របសម្រាប់ដំណាំភាគច្រើនលូតលាស់បានល្អគឺពីចន្លោះ ៦.៥ ទៅ ៧.៥ ពីព្រោះនៅចន្លោះនេះ សារជាតុចិញ្ចឹមចាំបាច់ភាគច្រើនអាចឱ្យដំណាំស្រូបយកបាន។

### ខ. បញ្ហាគុណភាពដី

បញ្ហាចំបងចំពោះដីនៅពាសពេញពិភពលោកគឺ សំណឹកដី ការបាត់បង់សារធាតុចិញ្ចឹម កំណថ្ម បាយក្រៀម និងកង្វក់ដីដោយសារវត្ថុមានអំបិល ទឹក និងសារធាតុគីមីច្រើនហួសកម្រិត។ សកម្មភាពមនុស្ស ជាមូលហេតុចំបងក្នុងការបង្កឱ្យមានបញ្ហាទាំងនេះ។

### ១. សំណឹកដី

ទឹក ទឹកកក ខ្យល់ និងភ្នាក់ងារអាកាសធាតុផ្សេងៗទៀតជំរុញឱ្យមានសំណឹក ឬការបាត់បង់ដីពីប្រភពដើម។ សំណឹកកើតឡើងនៅពេលភ្លៀងធ្លាក់ជោគជាំ ដែលធ្វើឱ្យចុណ្ណភាគដីងាយដាច់ចេញពីគ្នា និងអាចហូរតាមទឹកនាំទៅកាន់ទីឆ្ងាយ។ សំណឹកនាំឱ្យបាត់បង់ដីជាតិដោយសារតែការហូរនាំធាតុខនិជទៅកន្លែងផ្សេង។ ការបាត់បង់ដីជាតិដីធ្វើឱ្យទិន្នផលកសិកម្មថយចុះ ហេតុនេះគេត្រូវបន្ថែមជីគីមី អសរីរាង្គ ឬជីសរីរាង្គដើម្បីបំពេញកង្វះខាតសារធាតុចិញ្ចឹម។ ការគ្រប់គ្រងដីមិនបានត្រឹមត្រូវក៏បង្កឱ្យមានសំណឹកដីដែរ។ ដោយសារគម្របរុក្ខជាតិការពារដីពីកម្ដៅព្រះអាទិត្យ ទឹកភ្លៀង ខ្យល់ និងទឹកហូរ នោះការបាត់បង់ព្រៃឈើដែលបណ្ដាលមកពីការកាប់ឈើ ការសាងសង់ និងសកម្មភាពផ្សេងៗទៀត ជាមូលហេតុនៃសំណឹកដី។ សារពើរុក្ខជាតិនៅលើដី គឺជួយកាត់បន្ថយកម្លាំងទង្គិចនៃទឹកភ្លៀងទៅលើដី ហើយវាក៏ជួយពង្រឹងដីមិនឱ្យមានការហូរនាំទៅកាន់ទីកន្លែងផ្សេង បានដោយងាយដែរ។ សំណឹកដីនាំឱ្យមានកំណើនកម្ទេចកំណនៅតាមទន្លេ និងបឹងជាហេតុបង្កឱ្យមានការប៉ះពាល់ដល់គុណភាពទឹក និងសារពាង្គកាយរស់នៅក្នុងទឹក ដូចជាត្រីជាដើម។

### ២. ការបាត់បង់សាធាតុចិញ្ចឹមនៃដី

នៅក្នុងស្ថានប្រព័ន្ធធម្មជាតិ សារធាតុចិញ្ចឹម និងសារធាតុខនិជសំខាន់ៗបានធ្វើចលនាពីដីទៅសារពាង្គកាយមានជីវិត និងបន្ទាប់មកចេញពីសារពាង្គកាយមានជីវិតចូលមកក្នុងដីវិញ នៅពេលដែលសារពាង្គកាយទាំងអស់នោះងាប់។ ប្រពន្ធ័កផលិតកម្មសិកម្មបានបង្អាក់ដំណើរនៃវដ្ដធម្មជាតិបែបនេះ។ ឧទាហរណ៍ ៖ នៅប្រទេសកម្ពុជាមានដីស្រែតិចជាង ២០០ ០០០ហិចតា។ នៅក្នុងប្រព័ន្ធនេះ រូបធាតុរុក្ខជាតិភាគច្រើន (ចំបើង និងគ្រាប់ធញ្ញជាតិ) ដែលមានផ្ទុកនូវសារធាតុខនិជ និងសារធាតុសរីរាង្គត្រូវបានគេដកយកចេញនៅពេលប្រមូលផល។ ជាលទ្ធផល ពុំមានការផ្ដល់នូវសារធាតុចិញ្ចឹមត្រឡប់ទៅឱ្យដីវិញឡើយ។ ដំណើរបែបនេះ យូរៗទៅនឹងធ្វើឱ្យដីបាត់បង់ដីជាតិអស់មួយចំណែកធំ។

ដីនៅក្នុងព្រៃតំបន់ត្រូពិចគឺមិនសូវសម្បូរសារធាតុចិញ្ចឹមនោះទេ ពីព្រោះភាគច្រើននៃសារធាតុចិញ្ចឹមមាននៅតែក្នុងសារពើរុក្ខជាតិ ដែលដុះនៅលើដីនោះប៉ុណ្ណោះ។ សារធាតុខនិជ ដែលត្រូវបញ្ចេញទៅឱ្យដី ក្នុងទម្រង់នៃសាកសពសារពាង្គកាយស្អុយរលួយ ត្រូវឫសរុក្ខជាតិ និងផ្សិតស្រូបយកវិញយ៉ាងឆាប់រហ័ស។ ប្រសិនបើគ្មានការស្រូបយកយ៉ាងឆាប់រហ័សបែបនេះទេ សារធាតុចិញ្ចឹមទាំងនោះក៏នឹងត្រូវច្រោះបាត់យ៉ាងឆាប់រហ័ស ក្រោមអំពើនៃទឹកភ្លៀង។ ប្រសិនបើគេកាប់ឆ្ការព្រៃអស់ ប្រសិទ្ធភាពនៃកំណៃច្នៃសារធាតុចិញ្ចឹមក៏ត្រូវអាក់ខានផងដែរ។ ការដកយកគម្របព្រៃចេញនាំឱ្យសារធាតុខនិជច្រោះចេញបាត់ពីប្រព័ន្ធដីកន្លែងនោះ ព្រោះសារធាតុខនិជទាំងនោះមិនអាចនៅជាប់លាប់ក្នុងដីនោះទេ។ គេអាចដាំដំណាំនៅលើដីនេះបានល្អ នៅក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ គឺនៅមុនពេលដែលសារធាតុខនិជទាំងនោះបាត់បង់អស់ទៅ។ ប្រសិនបើគេបោះបង់ដីនោះចោល ដោយឈប់ដាំដំណាំលើដីនោះ ព្រៃអាចដុះឡើងវិញ ក៏ប៉ុន្តែព្រៃបែបនេះមានលក្ខណៈ

ដីរបម្រុះមិនសម្បូរបែប ដូចព្រៃស្ដុកនោះឡើយ។ ប្រសិនបើគេកាប់ឆ្ការព្រៃដុះឡើងវិញនេះ សម្រាប់ដាំដំណាំម្ដងទៀត ដីនឹងកាន់តែបាត់បង់ជីជាតិ។ នៅដំណាក់កាលណាមួយ ដីកាន់តែខ្សោះជីជាតិមែនទែន ហើយមានតែរុក្ខជាតិតិចប្រភេទប៉ុណ្ណោះ ដែលអាចដុះលើដីនោះបាន។

### ៣. កំណាថ្មបាយក្រៀម

កំណាថ្មបាយក្រៀម គឺជាដំណើរដែលធ្វើឱ្យដីក្លាយជារឹងដូចសិលា មិនអាចធ្វើកសិកម្មបាន។ ដីថ្មបាយក្រៀមរឹងខ្លាំង រហូតដល់គេអាចកាត់ជាដុំបាន សម្រាប់ប្រើប្រាស់ក្នុងសំណង់ ក្រោយពេលគេហាលវាឱ្យស្ងួត។ ដីថ្មបាយក្រៀមមានពណ៌ក្រហម ឬលឿង ដោយសារវត្តមាននៃសមាសធាតុលោហៈដូចដែក និងអាលុយមីញ៉ូម ដែលមិនងាយហូរច្រោះដូចសារធាតុខនិជដទៃទៀតនោះឡើយ។ តំបន់ដីថ្មបាយក្រៀម ដែលគេច្រើនតែនិយមហៅថា វាលលំហក្រហម មានច្រើននៅប្រទេសឥណ្ឌា និងបណ្ដាប្រទេសមួយចំនួនទៀតនៅភូមិភាគអាស៊ីអាគ្នេយ៍។

### ៤. អំបិលកម្ម

អំបិលកម្ម គឺជាដំណើរនៃការកកើតឡើងនូវសារធាតុអំបិលនៅក្នុងដី នៅពេលដែលទឹកមានផ្ទុកទៅដោយសារធាតុអំបិលត្រូវបានគេបញ្ចូលទៅក្នុងដីស្រែចម្ការ ឬស្រោចលើដំណាំបានហួតចេញពីដីដោយសារកម្ដៅព្រះអាទិត្យ។ ទឹកដែលយើងប្រើប្រាស់ សម្រាប់ស្រោចស្រពដំណាំតែងតែមានអំបិលផ្សេងៗរលាយនៅក្នុងនោះ។ នៅក្នុងលក្ខខណ្ឌអាកាសធាតុស្ងួត ទឹកស្រោចស្រពភាគច្រើនហួតឡើងជាចំហាយទឹក ហើយបន្សល់ទុកនូវកំហាប់អំបិលខ្ពស់ដូចជា អំបិលសូដ្យូមក្លរួ អំបិលម៉ាញ៉េស្យូមក្លរួ ឬអំបិលសូដ្យូមស៊ុលផាត ជាដើម នៅក្នុងដីស្រទាប់លើ។ ដំណើរបង្គរអំបិលនៅក្នុងដីស្រទាប់លើនេះហៅថា **អំបិលកម្ម**។

## ច. ការថែរក្សាគុណភាពដី

ការថែរក្សាគុណភាពដីរួមមានវិធីជាច្រើនដែលត្រូវបានគេប្រើ ដើម្បីកាត់បន្ថយសំណឹកដី ទប់ស្កាត់នូវការបាត់បង់សារធាតុចិញ្ចឹមរបស់ដី និងស្ដារសារធាតុចិញ្ចឹមរបស់ដី ដែលបាត់បង់ដោយសារតែសំណឹកដី អំបិលកម្ម ចម្រោះ និងដោយសារការប្រមូលផលច្រើនហួសហេតុ។ វិធីភាគច្រើន ដែលគេប្រើប្រាស់ សម្រាប់កាត់បន្ថយសំណឹកដីទាក់ទងនឹងការថែរក្សាឱ្យមានគម្របរុក្ខជាតិនៅលើដី។ ខាងក្រោមនេះ យើងនឹងលើកយកវិធីទាំងនោះមកបរិយាយជូន។

### ១. បន្លាស់ដំណាំ

រុក្ខជាតិប្រភេទខុសគ្នាចាក់ឫសក្នុងជម្រៅដីក៏ខុសៗគ្នាដែរ ហេតុនេះវាអាចស្រូបយកសារធាតុចិញ្ចឹមពីទីតាំងផ្សេងៗគ្នានៅក្នុងស្រទាប់ដី។ ដោយសារវត្តមានបាក់តេរីដែលរស់នៅតាមឫស រុក្ខជាតិខ្លះអាចស្រូបយកសារធាតុចិញ្ចឹមខុសគ្នា នៅក្នុងកម្រិតខុសគ្នា។ ការដាំដំណាំប្រភេទផ្សេងៗគ្នានៅលើដីមួយកន្លែងនៅរដូវខុសៗគ្នាមិនបង្កជាបន្ទុកធ្ងន់ធ្ងរ សម្រាប់ដីទេ។ រុក្ខជាតិប្រភេទនីមួយៗ ស្រូបយកសារធាតុចិញ្ចឹមមួយចំនួនពីដី ក៏ប៉ុន្តែការធ្វើបន្លាស់ដំណាំសមស្រប ធ្វើឱ្យមានការផ្ដល់សារធាតុចិញ្ចឹមត្រឡប់ទៅឱ្យដីវិញ។ ដំណាំខ្លះផ្ដល់នូវសារធាតុចិញ្ចឹមឱ្យដី (ពពួកសណ្ដែក) រីឯដំណាំខ្លះទៀតស្រូបយកសារធាតុចិញ្ចឹមពីដីមកវិញ (ពោត ស្រូវ)។ ដោយការផ្លាស់ប្ដូរនូវប្រភេទដំណាំទៅតាមរដូវ ដីអាចសម្រាកពីដំណាំមួយបែប និងអាចទទួលប្រយោជន៍ពីប្រភេទដំណាំផ្សេងៗទៀត។ បន្លាស់ដំណាំអាចឱ្យដីសម្រាក ដោយពុំចាំបាច់ទុកឱ្យវានៅទំនេរ។

**២. ចម្ការល្បាក់ ឬដំណាំតាមទីជម្រាល**

ចម្ការល្បាក់ គឺជាការរានដីលើចំណោត ឬជម្រាលមួយឲ្យទៅជាល្បាក់ៗ ឬថ្នាក់ៗតាមលំដាប់សម្រាប់ដាំដំណាំ។ ដំណាំតាមទីជម្រាលគឺជាការរានដី ឬភ្ជួរដីលើជម្រាល ដើម្បីដាំដំណាំ។ វិធីទាំងនេះ អាចកាត់បន្ថយល្បឿនទឹកហូរពីលើភ្នំបាន ក្រោយពេលមានភ្លៀងធ្លាក់ខ្លាំង ឬពេលព្រិលរលាយនៅលើកំពូលភ្នំ ដើម្បីកុំឱ្យទឹកនាំយកដីមានប្រយោជន៍ទៅជាមួយ។

**៣. កសិករុក្ខកម្ម**

ដើមឈើ ចុល្លព្រឹក្ស និងដំណាំផ្សេងៗទៀតអាចដាំបានតាមរូបភាពមួយ ដែលបង្កើតទម្រង់ជាដំណាំចម្រុះជាច្រើនជាន់។ វិធីនេះ អាចឱ្យដំណាំច្រើនប្រភេទដុះជាមួយគ្នា ដោយគ្មានការប្រជែង គ្នានៅក្នុងទីកន្លែងតែមួយ។ រុក្ខជាតិនៅស្រទាប់ខាងលើបង្កើតបានជាគម្របការពារទប់ទល់ទៅនឹងកម្តៅព្រះអាទិត្យ និងភ្លៀងធំ។ ស្លឹកឈើធ្លាក់ពីដើមឈើមាននាទីជាជីបៃតងសរីរាង្គ។ គម្របស្រទាប់លើបង្កើតជាម្លប់ការពារមិនឱ្យស្មៅចង្រៃដុះបាន។ ប្រព័ន្ធដំណាំចម្រុះបែបនេះហៅថា **កសិរុក្ខកម្ម**។

**៤. ការដាក់ជី**

ជាទូទៅ ជីមាន ២ ប្រភេទគឺ ជីសរីរាង្គ និងជីអសរីរាង្គ។ ជីសរីរាង្គកើតឡើងពីការពុកផុយនៃសំណល់សារពាង្គកាយមានជីវិត។ ជីសរីរាង្គមានសារធាតុធម្មជាតិដូចជា លាមកសត្វ សំណល់ដំណាំ និងកំប៉ុស្ត។ សមាសធាតុជីសរីរាង្គខុសប្លែកៗគ្នា ហើយអាចផ្តល់នូវសារធាតុចិញ្ចឹម សម្រាប់រុក្ខជាតិតែនៅពេលណាដែលសារធាតុសរីរាង្គទាំងនោះរលួយតែប៉ុណ្ណោះ ហេតុនេះវាមានឥទ្ធិពលយឺតៗ។ ចំពោះជីអសរីរាង្គវិញត្រូវបានគេផលិតចេញពីសមាសធាតុគីមី ហើយគេអាចស្គាល់ពីសមាសភាពរបស់វាបានយ៉ាងច្បាស់លាស់។ ជីបែបនេះអាចផ្តល់សារធាតុចិញ្ចឹមភ្លាមៗដល់រុក្ខជាតិប្រសិនបើពុំមានការបាត់បង់ ដោយសារការលេចចេញទេនោះ។

ការប្រើប្រាស់ជីអសរីរាង្គពុំបង្កើតលក្ខខណ្ឌនិរន្តរភាពអេកូឡូស៊ីល្អ ដូចការប្រើជីសរីរាង្គឡើយ នោះឡើយ ពីព្រោះថាវាងាយលេចចូលទៅក្នុងទឹក ក្នុងដី ឬអាចហូរចេញតាមលំហូរលើផ្ទៃដី ជាហេតុបង្កឱ្យមានការបំពុលនៅកន្លែងផ្សេងទៀត។ ទម្រង់ជីសរីរាង្គអាចជួយបង្កើនសមត្ថភាពស្រូបទឹករបស់ដី ដែលករណីបែបនេះពុំមាននោះទេ សម្រាប់ជីអសរីរាង្គ។ លាមកសត្វ សំណល់រុក្ខជាតិ និងកំប៉ុស្តមានឥទ្ធិពលលើសារពាង្គកាយជាច្រើនបែប ដែលរស់នៅក្នុងដី។ ភាគច្រើននៃសារពាង្គកាយទាំងនេះ មានប្រតិកម្មជាវិជ្ជមានទៅលើដី។

**ឆ. ប្រភេទដី**

លក្ខណៈខុសប្លែកគ្នា នៃអាកាសធាតុ សារពើរុក្ខជាតិ សិលាមេ សណ្ឋានដី និងអាយុដីធ្វើឱ្យដីមានច្រើនបែបច្រើនយ៉ាង ដែលមានលក្ខណៈខុសគ្នាទាំងពណ៌ ជម្រៅ ប៉េហាស់ និងលក្ខណៈផ្សេងៗទៀត។ តាមការសិក្សាស្រាវជ្រាវ គេអាចដឹងបានថា មានប្រភេទដីជាច្រើនប្រភេទខុសៗគ្នា អាស្រ័យនឹងមជ្ឈដ្ឋាននីមួយៗ។ អ្នកធរណីវិទ្យាបានធ្វើចំណែកថ្នាក់ដី ដោយផ្អែកលើសមាសធាតុផ្សំ និងតំបន់នីមួយៗ ដែលដីកកើតឡើង។ ការធ្វើចំណែកថ្នាក់ដីជាប្រភេទ ឬក្រុមមានសារៈសំខាន់ណាស់ សម្រាប់ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងដីឱ្យបានសមស្របនៅ ក្នុងផលិតកម្មកសិកម្ម។ ការធ្វើចំណែកថ្នាក់ដីគឺមានភាពសាំញ៉ាំ ដោយសារមានប្រព័ន្ធចំណែកថ្នាក់ជាច្រើន ត្រូវបានគេលើកយកមកប្រើប្រាស់។

## ៥.២. ធនធានដីនៅប្រទេសកម្ពុជា

### ក. ស្ថានភាពដីនៅកម្ពុជា

នៅប្រទេសកម្ពុជា ដីមានលក្ខណៈជាដីតំបន់ត្រូពិច។ ដីតំបន់ត្រូពិចនេះកកើតឡើងនៅតំបន់អាកាសធាតុក្តៅ ហើយសើមខ្លាំង។ កម្តៅ និងបរិមាណទឹកភ្លៀងដ៏លើសលប់ គឺជាមូលហេតុនាំឱ្យរូបធាតុផ្សេងៗដូចជា សត្វ និងរុក្ខជាតិ ដែលបាត់បង់ជីវិតបានបំបែកធាតុយ៉ាងឆាប់រហ័ស។ រូបធាតុទាំងនោះមិនអាចបង្កើតឱ្យមានស្រទាប់មមោកក្រាស់បាននោះឡើយ ពីព្រោះភ្លៀងធ្លាក់ច្រើនធ្វើឱ្យមានការហូរច្រោះយកសារធាតុចិញ្ចឹមមួយផ្នែកទៅជាមួយ និងសារធាតុចិញ្ចឹមមួយផ្នែកទៀត ត្រូវបានជ្រាបចូលទៅក្នុងដី។ មិនតែប៉ុណ្ណោះ វាបានធ្វើឱ្យបាត់បង់នូវស្រទាប់មមោកទៀតផង។ ក៏ប៉ុន្តែដោយសារសម្បូររុក្ខជាតិ និងសត្វរស់នៅច្រើននាំឱ្យមានការកើតឡើងវិញនូវមមោកយ៉ាងឆាប់រហ័ស។

### ខ. ប្រភេទដីនៅកម្ពុជា

យើងដឹងរួចមកហើយថា ការធ្វើចំណែកថ្នាក់ដីជាប្រភេទ ឬក្រុម គឺមានភាពសាំញ៉ាំណាស់ ដោយសារមានប្រព័ន្ធចំណែកថ្នាក់ជាច្រើនត្រូវបានគេលើកយកមកប្រើប្រាស់។ ជាមួយគ្នានេះដែរ ការធ្វើចំណែកថ្នាក់ដីនៅប្រទេសកម្ពុជាយើងក៏មានលក្ខណៈមិនខុសគ្នាផងដែរ។ ខាងក្រោមនេះ យើងនឹងលើកយកប្រព័ន្ធចំណែកថ្នាក់ដី ២ ប្រភេទ ដែលត្រូវបានគេប្រើប្រាស់ សម្រាប់ធ្វើការបែងចែកប្រភេទដីនៅប្រទេសកម្ពុជាយើងមកបរិយាយគឺ ការបែងចែកតាមសណ្ឋានដី និងការបែងចែកតាមសមាសធាតុផ្សំនៃដី។

**១. ការបែងចែកតាមសណ្ឋានដី**

ដោយយោងទៅតាមសណ្ឋានដី គេចែកប្រភេទដីនៅប្រទេសកម្ពុជាជា ៤ ប្រភេទគឺ ដីភ្នំ ដីខ្ពង់រាប ដីមាត់សមុទ្រ និងដីទំនាបកណ្តាល។

- **ដីភ្នំ**

ភ្នំនៅប្រទេសកម្ពុជា គឺនៅមានលក្ខណៈជាភ្នំក្មេងនៅឡើយ ដោយសារភ្នំទាំងនេះមានកំពូលស្រួច ហើយពុំទាន់បានទទួលរងនូវសំណឹកខ្លាំងក្លាប៉ុន្មាននោះឡើយ។ ភ្នំមួយភាគបានគ្រប់ដណ្តប់ទៅ ដោយសិលាក្រែលាយខ្សាច់យ៉ាងក្រាស់ រីឯភ្នំត្រង់ិលវិញ ដែលគ្របដណ្តប់ដោយផ្ទាំងថ្ម ឬសិលាក្រានីតគឺពុំសូវមាននោះទេ។ ហេតុដូច្នេះហើយ បានជាតំបន់ភ្នំនៅប្រទេសកម្ពុជាយើងសម្បូរទៅដោយព្រៃឈើ ក្រាស់ៗ។ នេះសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា នៅតំបន់ភ្នំមានដីល្អៗ សម្រាប់ទ្រទ្រង់ដល់រុក្ខជាតិឱ្យដុះលូតលាស់បានយ៉ាងទ្រុបទ្រល់។ នេះ គឺបណ្តាលមកពីប្រទេសកម្ពុជាយើងមានអាកាសធាតុត្រូពិចក្តៅហើយសើម ដែលធ្វើឱ្យសិលាមេទាំងឡាយងាយពុកផុយក្លាយទៅជាដី។ ម្យ៉ាងវិញទៀត រុក្ខជាតិនិងសត្វក៏ជាកត្តាមួយផងដែរ ក្នុងការចូលរួមបង្កើតដី និងទប់ទល់ទៅនឹងសំណឹកដីនៅតំបន់ភ្នំ។

- **ដីខ្ពង់រាប**

ខ្ពង់រាបនៅប្រទេសម្ពុជាយើង សុទ្ធសឹងតែជាខ្ពង់រាបដែលគ្រប់ដណ្តប់ទៅដោយសិលាក្រែ និងជាខ្ពង់រាប ដែលគ្រប់ដណ្តប់ទៅដោយសិលាបាសាល់។ ក្រោមឥទ្ធិពលនៃអាកាសធាតុត្រូពិច ក្តៅហើយសើម បានធ្វើឱ្យសិលាទាំងនេះពុកផុយ ហើយក្លាយទៅជាដីច្រើនប្រភេទខុសៗគ្នាដូច ដីបាយក្រៀម ដីឥដ្ឋល្បាយ

ស៊ីលីស និងដីក្រហមជាដើម...។ ដូចនេះ ដីតំបន់ខ្ពង់រាបក៏សុទ្ធសឹងតែជាដី ដែលមានសារៈសំខាន់ដល់សេដ្ឋកិច្ចខ្លាំងណាស់ផងដែរ។ ខ្ពង់រាបខ្លះដែលគ្រប់ដណ្ដប់ទៅដោយដីបាយក្រៀម ឬដីឥដ្ឋល្បាយស៊ីលីស គឺជាតំបន់ព្រៃរបោះ ដែលផ្ដល់នូវប្រភេទឈើប្រណីតដ៏មានតម្លៃ សម្រាប់បំពេញតម្រូវការក្នុងប្រទេសផង និងសម្រាប់នាំចេញទៅលក់នៅប្រទេសក្រៅផង។ ខ្ពង់រាបណា ដែលគ្រប់ដណ្ដប់ទៅដោយសិលាបាសាល់ សម្បូរដីក្រហម គឺជាតំបន់ចម្ការធំៗ ពិសេសចម្ការកៅស៊ូ ចម្ការទុរេន និងចម្ការសាវម៉ាវដូចជានៅ ពាមជាំង ជប់ មេមត់ ស្នួល និងរតនគីរីជាដើម។

- **ដីតំបន់មាត់សមុទ្រ**

តាមធម្មតានៅលើដីតំបន់មាត់សមុទ្រ ដែលជាវាលភក់លាយនិងទឹកប្រៃទៀតនោះ បានធ្វើឱ្យសារជាតុអាស៊ីតបានកកើតឡើងយ៉ាងឆាប់រហ័សខ្លាំងណាស។ ក៏ប៉ុន្តែដោយសារតំបន់មាត់សមុទ្រមានភ្លៀងធ្លាក់ច្រើនជោគជាំ បានធ្វើឱ្យសារជាតុអាស៊ីតទាំងនោះហូរច្រោះអស់មួយភាគធំទៅតាមទឹកភ្លៀង បណ្ដាលឱ្យដីនៅតំបន់មាត់សមុទ្រសម្បូរទៅដោយជាតុអាសូត សូដ្យូម និងប៉ូតាស្យូម ហើយខ្សត់ជាតិកំបោរ និងអាស៊ីតផូស្វរិច។ ដូចនេះ ដីតំបន់មាត់សមុទ្រនៅប្រទេសកម្ពុជា ក៏មានលក្ខណៈល្អប្រសើរគួរសមផងដែរចំពោះកសិកម្ម ជាពិសេសដំណាំដូង។ តាមការប៉ាន់ស្មាន តំបន់នេះមានផ្ទៃដីពី ៤០ ០០០ ទៅ ៥០ ០០០ ហិចតា ដែលអាចធ្វើការដាំដុះបាន។

- **ដីតំបន់ទំនាបកណ្ដាល**

ដូចយើងបានសិក្សារួចមកហើយថា តំបន់ទំនាបកណ្ដាល នៃប្រទេសកម្ពុជាយើងធ្លាប់ជាបាតសមុទ្រចាស់ ហើយដែលត្រូវចាក់លុបបំពេញបន្តិចម្ដងៗ ដោយដីល្បាប់នៃខ្សែទឹកទន្លេមេគង្គ។ ដូច្នេះហើយ បានជាគេឃើញដីទំនាបកណ្ដាលនៃប្រទេសកម្ពុជាមួយភាគធំ ជាដីល្បាប់ដ៏មានជីជាតិ ចំពោះដំណាំ។ គេសង្កេតឃើញមានល្បាប់ចាស់ស្ថិតនៅជាយក្រៅ និងល្បាប់ថ្មីស្ថិតនៅក្បែរផ្លូវទឹក។ ជាទូទៅ គេចែកដីទំនាបកណ្ដាលជា ៣ ប្រភេទគឺ ៖

- **ប្រភេទទី១** ៖ ជាប្រភេទដីល្បាប់ម៉ត់ ដែលស្ថិតនៅជាប់នឹងមាត់ទន្លេ មាត់ព្រែក មាត់ស្ទឹង និងជាយកោះ។ ដីប្រភេទនេះ គឺមានជីជាតិខ្លាំងណាស់ សម្រាប់ដំណាំគ្រប់ប្រភេទ ហើយដែលប្រជាជនយើងនិយមធ្វើចម្ការដំណាំផ្សេងៗនៅលើដីប្រភេទនេះ។
- **ប្រភេទទី២** ៖ ជាប្រភេទដីកណ្ដោង ឬដីល្បាយឥដ្ឋដែលជាវាលភក់ និងត្រូវបានលេចទឹកនៅរដូវវស្សា។ ដីប្រភេទនេះ មានលក្ខណៈល្អប្រសើចំពោះដំណាំស្រូវផង និងដំណាំចម្ការផង។
- **ប្រភេទទី៣** ៖ ជាប្រភេទដីខ្សាច់ និងដីល្បាយខ្សាច់ ដែលជាល្បាប់ចាស់ តែមានកន្លែងខ្លះនៅមានជីជាតិនៅឡើយ រីឯកន្លែងខ្លះទៀតខ្សោះជីជាតិ។ ដីប្រភេទនេះ គឺជាតំបន់វាលស្រែដែលជាមជ្ឈមណ្ឌលផលិតស្រូវដ៏សំខាន់បំផុតរបស់ប្រទេសកម្ពុជាយើង។

**២. ការបែងចែកតាមសមាសធាតុផ្សំនៃដី**

បើយោងទៅតាមសមាសធាតុផ្សំរបស់ដី គេចែកប្រភេទដីនៅប្រទេសកម្ពុជាជា ៥ ប្រភេទគឺ ដីសិលាក្រែលាយខ្សាច់ ដីក្រហម ឬដីសិលាបាសាល់ ដីខ្សាច់ ដីល្បាយដីឥដ្ឋ និងដីល្បាប់។

- **ដីសិលាក្រែលាយខ្សាច់**

ដីល្បាយលាយខ្សាច់ ភាគច្រើនស្ថិតនៅតំបន់ភ្នំនៃប្រទេសកម្ពុជា។ ភ្នំនៅប្រទេសកម្ពុជាភាគច្រើនគ្របដណ្តប់ដោយសិលាក្រៃលាយខ្សាច់យ៉ាងក្រាស់ (កម្រាស់ជាង ១ ០០០ ម៉ែត្រ នៅបូកគោ) ដែលជាពំនូកទ្វីបកើតឡើងនៅក្នុងស័កទី ២។ ដីសិលាក្រៃលាយខ្សាច់គ្របដណ្តប់ប្រជុំភ្នំទាំងអស់ នៅប្រទេសកម្ពុជាដូចជា ជួរភ្នំក្រវាញ ជួរភ្នំដងរែក និងកូនភ្នំទាំងឡាយនៅតំបន់ទំនាបកណ្តាល តំបន់មាត់សមុទ្រ និងតំបន់ខ្ពង់រាបភាគខាងជើង ភាគខាងកើត និងភាគឦសាន។

- **ដីខ្សាច់**

ដីខ្សាច់នៅប្រទេសកម្ពុជាយើងភាគច្រើនជាដី ដែលបានវិវត្តមកពីល្បាប់ចាស់ ហើយច្រើនតែគ្របដណ្តប់នៅលើទំនាបខ្ពស់ៗ និងខ្ពង់រាបជិតជើងភ្នំ។ ដីប្រភេទនេះ មានរយៈកម្ពស់ខ្ពស់ជាងនីវូទឹកស្ទឹង បឹងបួរនារដូវទឹកតម្លើង (រយៈកម្ពស់ ២០ ម៉ែត្រ ឬលើសពីនេះ)។ ក៏ប៉ុន្តែវាអាចលិចទឹកក្នុងរយៈពេលខ្លី កាលណាមានជំនន់ខុសប្រក្រតី។

ដីខ្សាច់ ច្រើនមាននៅជុំវិញខេត្តសៀមរាប ខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងផ្នែកខាងត្បូងនៃខេត្តកំពង់ចាម។ ដីនេះជ្រៅ និងបឺតទឹក ដែលមានកម្រិតជាតិអាស៊ីត ៥.៥ មិនសម្បូរជីជាតិ ប៉ុន្តែស្រួលធ្វើការ។ តម្លៃដីខ្សាច់ទាក់ទងទៅនឹងជម្រៅជង្ហើមទឹក។ ដីប្រភេទនេះ ភាគច្រើនជាវាលស្រែ ដែលមានទំហំពី ១០ ទៅ ១២% នៃផ្ទៃដាំស្រូវសរុប។ ក្រៅពីនេះ វាត្រូវបានប្រជាជនទុកចោលឱ្យព្រៃដុះ ហើយនៅកន្លែងខ្លះ ព្រៃដុះល្អថែមទៀតផង ដូចជាព្រៃនៅស្រុកតំបែរ ខេត្តត្បូងឃ្មុំជាដើម។

- **ដីបាសាល់ ឬដីក្រហម**

ដីក្រហម ឬដីសិលាបាសាល់ជាប្រភេទដី ដែលទទួលរងការពុកផុយពីសិលាបាសាល់នៅក្នុងស័កទី ៣ នៅក្រោមឥទ្ធិពលអាកាសធាតុត្រូពិច ក្តៅហើយសើម។ ដីប្រភេទនេះ មានជីជាតិល្អណាស់ សម្រាប់ដំណាំគ្រប់ប្រភេទដូចជា កៅស៊ូ កប្បាស កាផេ តែ សណ្តែក ដំឡូងមី និងដំណាំហូបផ្លែ។ ដីក្រហមស្ថិតនៅខ្ពង់រាបទាបៗ ក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ក្រៅពីនេះគេឃើញមាននៅខេត្តប៉ៃលិន នៅខ្ពង់រាបបរកែវ ខេត្តរតនគិរី និងនៅខ្ពង់រាបឆ្លូងលើ ខេត្តមណ្ឌលគិរី។

ដីក្រហមនៅប្រទេសកម្ពុជាយើង មានលក្ខណៈដូចខាងក្រោមនេះ ៖

- មានពណ៌ក្រហមពិសេស
- មានកម្រាស់មធ្យមពី ២៥ ទៅ ២០ ម៉ែត្រ
- មានសមាសធាតុល្អ ប៉ុន្តែបើគ្មានគម្របទេ ដីនេះនឹងទទួលរងពីបន្សោះ ពីសំណឹក និងពីការរាតត្បាតនៃដើមទន្រ្ទានខេត្ត។
- ជ្រាបទឹក ក៏ប៉ុន្តែនៅរដូវប្រាំងដីនេះអាចធ្វើឱ្យរុក្ខជាតិធន់នឹងភាពរាំងស្ងួតបាន ដោយសារតែដីនេះងាយធ្វើឱ្យរុក្ខជាតិចាក់ឫសបានយ៉ាងជ្រៅ។
- ជង្ហើមទឹកនៅជ្រៅ ៖ ដូចនេះដីនេះមិនល្អ សម្រាប់ដំណាំស្រូវនោះទេ។
- ជាដីសឹងតែណឹត ៖ កម្រិតប៉េហាស់ (pH) របស់វាមានពីចន្លោះ ៦ ទៅ ៦.៥។
- មានជីជាតិល្អ ជាពិសេសសម្បូរផូស្វាត។

ជារួម ដីក្រហម គឺជាដីដែលមានដីជាតិល្អបំផុត សម្រាប់ដំណាំគ្រប់ប្រភេទ ជាពិសេសដំណាំកៅស៊ូ។ ប្រជាជនយើងភាគច្រើនដាំជាចម្ការកៅស៊ូ ចម្ការចេក ចម្ការពោត សណ្តែក ម្នាស់ ដំឡូង និងចម្ការដំណាំហូបផ្លែជាច្រើនប្រភេទ។

ក្រៅពីខ្ពង់រាបទាបៗដែលមានចម្ការកៅស៊ូធំៗនៅខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តរតនគីរី និងខេត្តមណ្ឌលគីរីនោះ គេឃើញមានដីក្រហមជាតំបន់តូចៗ នៅឯណេះខ្លះ នៅឯណោះខ្លះដូចជានៅខេត្តប៉ៃលិន និងខេត្តព្រះសីហនុជាដើម។ ខាងក្រោមនេះ ជាតារាងដីក្រហម ឬដីបាសាល់របស់ប្រទេសយើង។

- ខ្ពង់រាបទាបៗនៃទន្លេមេគង្គ ៖
- – តំបន់ជប់ តាប៉ាវ ក្រែក ៖ ៥៨ ៤៤៤ ហិចតា
- – តំបន់ឆ្លូងលើ មេមត់ ៖ ៥៧ ៤០០ ហិចតា
- – តំបន់ស្នួល ៖ ៨ ៥០០ ហិចតា
- – តំបន់ចម្ការលើ (ត្រើយស្តាំ)៖ ៣២ ៩០០ ហិចតា
- – តំបន់ព្រៃកកក់ (ត្រើយស្តាំ)៖ ២៤ ៤០០ ហិចតា
- ខ្ពង់រាបខ្ពស់ៗនៅខាងកើត ៖
- – តំបន់បរកែវរតនគីរី ៖ ១៨០ ០០០ ហិចតា
- – តំបន់ឆ្លូងលើ ៖ ៣២០ ០០០ ហិចតា
- – ប្រជុំភ្នំជាច់ពីគេ (ក្រចេះ) ៖ ២០ ០០០ ហិចតា
- – ប្រជុំភ្នំនៅក្នុងជួរភ្នំក្រវាញ ៖ ១០ ០០០ ហិចតា
- – **សរុប ៖ ៧១៦ ៦០០ ហិចតា**

ក្នុងតារាងខាងលើនេះ យើងគិតទាំងដីក្រហម ទាំងដីថ្ម ដីសម្បុរត្នោត ឬដីខ្មៅដែលមានដើមកំណើតពីសិលាបាសាល់ ហើយដែលស្ថិតនៅតាមជើងខ្ពង់រាបដីក្រហម។ ដីថ្មសម្បូរទៅដោយកំអែភ្នំភ្លើង មានសារៈសំខាន់តិចតួច សម្រាប់កសិកម្ម (ខ្ពង់រាបត្រើង និងខ្ពង់រាបស្រែសៀមនៅសង់ខាងខេត្តកំពង់ចាម)។

ដីសម្បុរត្នោត ច្រើនតែស្ថិតនៅទីខ្ពស់មានពណ៌សុកូឡា ដែលជាអន្តរភាពរវាងដីក្រហម និងដីខ្មៅ។ បើធៀបទៅនឹងដីក្រហម ដីសម្បុរត្នោតជាដីធ្ងន់ ស្រួលធ្វើការ ហើយប្រកបនឹងដំណាំស្រូវ។

នៅទីកន្លែងទាបជាងនេះទៀត នៅក្នុងអាងភ្លាទាំងឡាយ ឬនៅកន្លែងដែលជាប់ជាមួយទំនាបល្បាប់ គេឃើញមានដីខ្មៅ ដែលប្រហែលជាបានមកពីការបំបែកជាតុ នៃសិលាបាសាល់ ឬពីដីក្រហមនៅក្នុងមជ្ឈដ្ឋានសើមខ្លាំង (អាងភ្លាំស្តី បារាយណ៍ ទំនាបសួង)។ ដោយសារមានស្រទាប់មិនជ្រាបទឹកនៅរាក់ៗនោះ ដីប្រភេទនេះមានច្រើន ហើយអាចធ្វើស្រែល្អៗបាន។ ដីសម្បុរត្នោត និងដីខ្មៅសម្បូរជីជាតិណាស់ និងមានកម្រិត pH ប្រហាក់ប្រហែលនឹងដីក្រហមដែរ។

- **ដីល្បាយដីឥដ្ឋ**

ដីល្បាយដីឥដ្ឋនៅប្រទេសកម្ពុជាយើង មាននៅតាមទំនាបទាបៗដូចជា នៅក្នុងខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកណ្តាល ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ (ពីស្រុកមោងទៅស្រុកមង្គលបុរី) ដែលជាដីស្រែ។ ដីប្រភេទនេះ ជាដីល្អ ប្រសិនបើស្រទាប់មិនជ្រាបទឹកស្ថិតនៅមិនសូវជ្រៅ។

ដីល្បាយដីឥដ្ឋក្នុងទំនាបនានា នៃខេត្តបាត់ដំបង ជាដីដ៏ល្អបំផុតនៃប្រទេសយើង ពីព្រោះវា គឺជាដីណឹត សម្បូរកំបោរ និងប៉ូតាស ហើយងាយស្រួលធ្វើការ។ ដីប្រភេទនេះ ល្អសម្រាប់ដំណាំស្រូវ ឬដំណាំផ្សេងៗទៀតជាច្រើន។ តំបន់ធំៗនៃដំណាំស្រូវក្នុងខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តតាកែវ និងខេត្តកណ្ដាលមានដីប្រភេទនេះ។

- **ដីល្បាប់**

ដីល្បាប់ ជាប្រភេទដីល្បាយ ឬដីពណ៌ត្នោតដែលមានទម្រង់ស្រទាប់វិវត្តន៍ខ្សោយនៅលើច្រាំងទន្លេ និងជម្រាលនៃច្រាំង។ ដីប្រភេទនេះ កកើតនៅតាមមាត់ទន្លេ និងខ្នងជម្រាលទំនាបខាងក្រោយតំបន់មាត់ទន្លេ។ តំបន់ក្រោយទន្លេ ដែលជាកន្លែងដាំស្រូវដ៏សំខាន់មួយតែងតែលិចទឹក និងទទួលនូវល្បាប់ថ្មីនៅរដូវវស្សារាល់ឆ្នាំ ហើយតែងតែទទួលនូវល្បាប់ថ្មីៗ។ នៅតាមមាត់ទន្លេមេគង្គ ទន្លេបាសាក់ ទន្លេតូច ទន្លេសាប គេឃើញមានដីល្អៗសម្បូរជីជាតិ ដោយសារទឹកជំនន់ទន្លេមេគង្គ។ ប្រជាជនយើង
បានហៅដីប្រភេទនេះថា ដីល្បាយ ដែលលាតសន្ធឹងលើផ្ទៃដីប្រហែល ៥០០ ០០០ ហិចតា។

ដីល្បាប់មានសមាសជាតុល្អប្រពៃ គឺជាដីជ្រៅ ស្មើសាច់ ជ្រាបទឹក ហើយសម្បូរជីជាតិ។ គេអាចដាំដំណាំបានគ្រប់រដូវ ដោយរាប់ទាំងរដូវប្រាំងផង ពីព្រោះដីប្រភេទនេះអាចឲ្យរុក្ខជាតិធន់នឹងភាពរាំងស្ងួតបាននៅរដូវប្រាំង។ គេអាចដាំដំណាំពោត សណ្ដែក ល្ង ថ្នាំជក់ ក្រចៅ ដើមគរ អំពៅ និងបន្លែគ្រប់មុខ។ ដីប្រភេទនេះ គេឃើញមានភាគច្រើននៅក្នុងខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តកំពង់ចាម
ខេត្តស្ទឹងត្រែង និងរាជធានីភ្នំពេញ។

ជាទូទៅ ប្រភេទដីនៅប្រទេសកម្ពុជាយើងជាដីអាសុីត មិនសូវសម្បូរជីជាតិ។ ក្នុងចំណោមដី ១០០% ដែលយើងដាំដុះ ដីល្អមានប្រហែលជា ៣០% ប៉ុណ្ណោះ (ដីក្រហម ដីខ្មៅ ដីល្បាយដីឥដ្ឋ និងដីល្បាប់)។ នៅក្នុងតំបន់ទំនាប ដែលមានមនុស្សរស់នៅច្រើន គេបានដាំដុះលើដីខ្សាច់។ ខ្ពង់រាបដីក្រហមទាបៗ ទើបនឹងត្រូវធ្វើអាជីវកម្មក្រោយឆ្នាំ ១៩២០ តែប៉ុណ្ណោះ។ ដីបម្រុងល្អៗមានច្រើននៅក្នុងទំនាបខេត្តបាត់ដំបង និងនៅកន្លែងដាច់ស្រយាល (ខ្ពង់រាបបាសាល់ក្នុងខេត្តរតនគិរី និងមណ្ឌលគិរី និងខេត្តកោះកុង)។ ក៏ប៉ុន្តែ ដើម្បីធ្វើឱ្យមានតម្លៃត្រូវតែពឹងផ្អែកទៅលើបច្ចេកទេសថ្មីៗ និងទំនើបៗ។

ដីនៅប្រទេសកម្ពុជាយើងមានលក្ខណៈខុសៗគ្នា នៅទូទាំងប្រទេស។ ការធ្វើចំណែកថ្នាក់ដីពឹងផ្អែកយ៉ាងច្រើនទៅលើលក្ខណៈធនធានដីស្រទាប់លើដែលមានឥទ្ធិពលទៅលើការបង្កបង្កើនផល។ បច្ចុប្បន្ននេះ អ្នកជំនាញផ្នែកកសិកម្មជាច្រើន នៅកម្ពុជាបានទទួលពត៌មានពីប្រភេទដីនេះជាបណ្ដើរៗ ដើម្បីជាមូលដ្ឋានក្នុងការសិក្សា។

**សំណួរត្រិះរិះ**

1. ចូរកំណត់និយមន័យ ដីវិទ្យា ដី ដីឈៃរណ្ឌស្បូម ដីប៉ុតស៊ុល ដីល្បាប់ និងដីឡឺស។
2. ដូចម្ដេចដែលហៅថា របេច ឬដំណើរពុកផុយ? តើរបេច ឬដំណើរពុកផុកមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់។
3. តើមានកត្តាអ្វីខ្លះ ដែលបណ្ដាលឱ្យរបេចរូប និងរបេចគីមីកើតឡើង? ចូរពន្យល់ពីកត្តានីមួយៗ។

4. ចូរពិពណ៌នាអំពីសារៈសំខាន់នៃដី។
5. តើមានកត្តាអ្វីខ្លះ ដែលបណ្តាលឱ្យដីខូចគុណភាព?
6. តើត្រូវធ្វើដូចម្តេចខ្លះ ដើម្បីថែរក្សាគុណភាពដី? ចូរពន្យល់។
7. យោងទៅតាមសណ្ឋានដី តើគេចែកដីនៅប្រទេសកម្ពុជាជាប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់។
8. យោងទៅតាមសមាជាតុផ្សំរបស់ដី តើគេចែកដីនៅប្រទេសកម្ពុជាជាប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់អំពីប្រភេទនីមួយៗ។

## ៦. រុក្ខជាតិ និង សត្វនៅប្រទេសកម្ពុជា

### ៦.១. លក្ខណៈទូទៅ

ប្រហែលជា ១/៣ នៃផ្ទៃផែនដីសរុបរបស់ភពផែនដីត្រូវបានគ្របដណ្តប់ដោយព្រៃឈើ។ ព្រៃឈើបានកើតឡើង ដោយធម្មជាតិនៅតំបន់នានានៃពិភពលោកយើងដែលជាកន្លែងមានការផ្តល់នូវទឹកភ្លៀងខ្ពស់បំផុត។ ក្នុងអំឡុង ៤០ ឆ្នាំ ចុងក្រោយនេះ ១/៣ នៃព្រៃឈើពិភពលើកយើង ត្រូវបានគេកាប់បំផ្លាញ និងប្រែក្លាយឱ្យទៅជាកន្លែងប្រើប្រាស់ផ្សេងៗ។

ជាទូទៅ ប្រភេទព្រៃឈើនៅពិភពលោកមានការប្រែប្រួលទៅតាម សីតុណ្ហភាព របបទឹកភ្លៀង និងទៅតាមរយៈទទឹងនៃផ្ទៃផែនដី។ យោងទៅតាម សីតុណ្ហភាព កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំ និងរយៈទទឹងនៃផែនដី គេចែកព្រៃឈើនៅលើពិភពលោកជា ៣ ប្រភេទគឺ ព្រៃរងទឹកភ្លៀងតំបន់ត្រូពិច ព្រៃតំបន់ត្រជាក់បង្គួរ និងព្រៃតៃកា ឬព្រៃកូនីផែ។

### ក. ព្រៃឈើតំបន់ត្រូពិច

ព្រៃតំបន់ត្រូពិច គឺជាប្រភេទព្រៃក្រាស់ ដែលដុះនៅក្នុងតំបន់ត្រូពិច។ ព្រៃប្រភេទនេះត្រូវបានសម្គាល់ដោយមានប្រភេទឈើខុសគ្នាៗជាច្រើនប្រភេទដែលដុះប្រជ្រៀតគ្នាយ៉ាងញឹកស្អេក។ ព្រៃតំបន់ត្រូពិចបានគ្រប់ដណ្តប់នៅលើផ្ទៃដីប្រហែល ១២ លានគីឡូម៉ែត្រការេ ដែលស្មើនឹង ៧% នៃផ្ទៃផែនដីទាំងមូល។ ព្រៃឈើទាំងនេះបានដុះនៅចន្លោះខ្សែស្របទី ២៣$^{0}$ នៃអឌ្ឍគោលទាំងពីរ ដែលជាទីកន្លែងមានសំណើមខ្ពស់ និងសីតុណ្ហភាពជាមធ្យម ២៦ អង្សាសេពេញមួយឆ្នាំ។ ព្រៃត្រូពិចនេះមានដើមឈើ ដែលមានស្លឹកបៃតងជានិច្ច ហើយនៅតំបន់ក្បែរត្រូពិចជាព្រៃជ្រុះស្លឹក ពីព្រោះវាបានដុះនៅក្នុងតំបន់ដែលមានរដូវ ២ គឺរដូវប្រាំង និងរដូវវស្សា។ ជាទូទៅ គេបែងចែកប្រភេទព្រៃនៅតំបន់ត្រូពិចនេះជា ៣ ប្រភេទទៀតគឺ ព្រៃរងទឹកភ្លៀងត្រូពិច ព្រៃត្រូពិចមូសុង ឬព្រៃជ្រុះស្លឹក និងព្រៃកោងកាង។

- **ព្រៃរងទឹកភ្លៀងត្រូពិច**

ព្រៃរងទឹកភ្លៀងតំបន់ត្រូពិច គឺជាប្រភេទព្រៃឈើ ដែលត្រូវបានគេប្រទះឃើញមានដុះនៅក្នុងតំបន់អាកាសធាតុអេក្វាទ័រនៃតំបន់ត្រូពិច ដែលស្ថិតនៅចន្លោះខ្សែស្របទី ១០$^{0}$ ខាងជើង និងខាងត្បូងខ្សែអេក្វាទ័រ។

តំបន់អាកាសធាតុអេក្វាទ័រ គឺជាតំបន់អាកាធាតុតូចមួយ ដែលស្ថិតនៅក្នុងតំបន់អាកាសធាតុត្រូពិច និងមានទីតាំងស្ថិតនៅក្នុងតំបន់អេក្វាទ័រ។ តំបន់នេះ មានសីតុណ្ហភាពខ្ពស់ ជាមធ្យមប្រហែល ២៧ អង្សាសេ

និងមានភ្លៀងធ្លាក់ជាមធ្យមលើស ១ ៥០០ ម.ម ក្នុងមួយឆ្នាំ។ ព្រៃនេះ មានដើមឈើ ដែលមានស្លឹកបៃតងជានិច្ច ពីព្រោះវាបានដុះនៅក្នុងតំបន់ ដែលមានមភ្លៀងធ្លាក់ស្ទើរតែពេញមួយឆ្នាំ។

ដោយសារវានៅក្បែរតំបន់អេក្វាទ័រ ទើបតំបន់នេះទទួលពន្លឺពេញមួយឆ្នាំ ហើយអាកាសធាតុមិនសូវផ្លាស់ប្តូរខ្លាំងឡើយទៅតាមរដូវនីមួយៗ។ អាកាសធាតុបែបនេះ មានអំណោយផលល្អណាស់ សម្រាប់ការលូតលាស់នៃរុក្ខជាតិ និងសត្វគ្រប់ប្រភេទ។

នៅក្នុងតំបន់នេះ មានប្រភេទរុក្ខជាតិប្លែកៗជាច្រើនបានដុះលូតលាស់ ច្រើនជាងនៅតំបន់ដទៃទៀតនៅលើផែនដី។ ព្រៃរងទឹកភ្លៀងត្រូពិចមួយហិចតា មានឈើដុះរហូតដល់ ៧៥០ ប្រភេទ និងរុក្ខជាតិដុះចំនួន ១ ៥០០ ប្រភេទ ចំណែករីឯនៅតំបន់ត្រជាក់បង្គួរវិញមានតែ ១០ ប្រភេទប៉ុណ្ណោះ។ ឈើភាគច្រើនដែលបានដុះនៅក្នុងព្រៃរងទឹកភ្លៀងត្រូពិច គឺជាឈើដែលពុំសូវមានតម្លៃសេដ្ឋកិច្ច ប៉ុន្តែគេអាចយកវាទៅប្រើប្រាស់ សម្រាប់ធ្វើគ្រឿងសង្ហារឹម និងវត្ថុផ្សេងៗទៀតបាន។ ព្រៃរងទឹកភ្លៀងត្រូពិច មានដុះនៅក្នុងទ្វីប និងប្រទេសមួយចំនួនដូចជា ៖

- **នៅទ្វីបអាមេរិចខាងត្បូង** ៖ ព្រៃនេះមានដុះយ៉ាងធំនៅក្នុងអាងអាម៉ាសូន ដែលគេនិយមហៅថា **ព្រៃអាម៉ាសូន** នៃប្រទេសប្រេស៊ីល និងប្រទេសអេក្វាឌ័រ។
- **នៅទ្វីបអាព្រិច** ៖ ព្រៃប្រភេទនេះ មានដុះភាគច្រើនបំផុតតែនៅក្នុងអាងកុងហ្គោនៃប្រទេសកុងហ្គោ និងប្រទេសហ្សាអៀរប៉ុណ្ណោះ។
- **នៅទ្វីបអាស៊ី** ៖ នៅទ្វីបអាស៊ី ព្រៃប្រភេទនេះ មានដុះនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ គឺមានដុះភាគច្រើនបំផុតនៅក្នុងប្រទេសម៉ាលេស្យ៉ា និងប្រទេសឥណ្ឌូនេស៊ី។

ជាទូទៅ ព្រៃរងទឹកភ្លៀងត្រូពិច មិនត្រូវបានគេរកឃើញថាមានដុះនៅគ្រប់ទីកន្លែងដែលមានអាកាសធាតុអេក្វាទ័រនោះទេ។ ប្រភេទព្រៃឈើផ្សេងៗទៀតដូចជាព្រៃកោងកាងជាដើម ក៏គេឃើញមានដុះនៅក្នុងតំបន់អាកាសធាតុអេក្វាទ័រនេះដែរ ប៉ុន្តែទីកន្លែងដែលវាដុះ មិនបានគ្របណ្តប់ទៅដោយព្រៃរងទឹកភ្លៀងត្រូពិចនោះទេ។

***ព្រៃរងទឹកភ្លៀងត្រូពិច***




- **ព្រៃត្រូពិចមុសុង**

ដូចព្រៃរងទឹកភ្លៀងត្រូពិចផងដែរ ព្រៃត្រូពិចមូសុងត្រូវបានគេឃើញមានដុះនៅក្នុងតំបន់ក្បែរត្រូពិច ដែលស្ថិតនៅចន្លោះខ្សែស្របទី ១០$^{0}$ ទៅ ២៥$^{0}$ នៃអឌ្ឍគោលទាំងពីរ។ ក៏ប៉ុន្តែទោះបីជាយ៉ាងដូចនេះក្តី

ព្រៃឈើប្រភេទនេះ មានដុះនៅតែទីកន្លែងណា ដែលបានទទួលនូវអាកាសធាតុត្រូពិចមូសុងតែប៉ុណ្ណោះ។ អាកាសធាតុត្រូពិចមូសុងមានលក្ខណៈសម្គាល់ ដោយមានសីតុណ្ហភាពខ្ពស់ជាមធ្យមប្រហែល ២០ អង្សាសេ និងមានភ្លៀងធ្លាក់ជាមធ្យមលើសពី ១ ៥០០ ម.ម នោះឡើយ ក្នុងមួយឆ្នាំ ហើយមានរដូវ ២ ច្បាស់លាស់គឺ រដូវវស្សា និងរដូវប្រាំង។

ព្រៃឈើត្រូពិចមូសុងមានដុះនៅក្នុងទ្វីបអាស៊ីដូចជា អាស៊ីខាងត្បូង អាស៊ីអាគ្នេយ៍ និងប្រទេសចិនភាគខាងត្បូង និងទ្វីបអូស្ត្រាលីភាគខាងជើង ពោលគឺដុះនៅចន្លោះខ្សែស្របទី ១០$^{0}$ និងទី ២៥$^{0}$ នៃអឌ្ឍគោលខាងជើង និងខាងត្បូង។

ព្រៃឈើត្រូពិចមូសុង ជាប្រភេទព្រៃជ្រុះស្លឹក ពីព្រោះវាបានដុះនៅទីកន្លែង ដែលមានរដូវពីរច្បាស់លាស់គឺ រដូវវស្សា និងរដូវប្រាំង។ នៅរដូវវស្សា ព្រៃប្រភេទនេះមានស្លឹកពណ៌ខៀវស្រងាត់ ក៏ប៉ុន្តែនៅរដូវប្រាំងវិញ ព្រៃប្រភេទនេះមានពណ៌ក្រហម ឬលឿងទុំ ហើយចាប់ផ្តើមជ្រុះស្លឹក។ គេឃើញមានប្រភេទរុក្ខជាតិតិចតួចប៉ុណ្ណោះ ពោលគឺមានរុក្ខជាតិត្រឹមតែ ២០០ ប្រភេទប៉ុណ្ណោះ ដែលដុះនៅក្នុងព្រៃត្រូពិចមូសុង បើធៀបទៅនឹងព្រៃរងទឹកភ្លៀងត្រូពិច ដោយសារមានភ្លៀងធ្លាក់មិនទៀងទាត់។ ប្រភេទឈើភាគច្រើនដែលដុះក្នុងព្រៃត្រូពិចមូសុងជាឈើ ដែលមានតម្លៃដូចជា ម៉ៃសាក់ នាងនួន បេង កកោះ និងធ្នង់ជាដើម ដែលអាចប្រើប្រាស់ សម្រាប់គ្រឿងសំណង់ និងនៅក្នុងឧស្សាហកម្ម។

***ព្រៃត្រូពិចមូសុង***





- **ព្រៃកោងកាង**

ព្រៃកោងកាង ត្រូវបានគេប្រទះឃើញមានដុះជាសំខាន់នៅក្នុងតំបន់ ដែលមានអាកាសធាតុត្រូពិចដែលស្ថិតនៅចន្លោះខ្សែស្របទី ២៣$^{0}$ នៃអឌ្ឍគោលខាងជើង និងខាងត្បូង ពិសេសតំបន់តាមបណ្តោយឆ្នេរសមុទ្រ និងទីកន្លែងនានាដែលទន្លេនានាហូរមកចាក់បង្ហូរជាអចិន្ត្រៃយ៍នូវល្បាប់ម៉ដ្ឋ។ ព្រៃប្រភេទនេះមានដុះលូតលាស់នៅតំបន់ដីសណ្ត តំបន់ពាមសមុទ្រ និងខាងក្រោយផ្នូកខ្សាច់ដែលកម្លាំងរលកមានកម្រិតខ្សោយ។ ទឹកតំបន់នេះប្រៃតិចៗ ឬប្រៃដូចទឹកសមុទ្រ។ ប្រភេទដើមកោងកាង ដែលដុះនៅតំបន់ណាមួយត្រូវបានកំណត់ដោយវាយភាពដី កម្រិតជាតិប្រៃរបស់ដី និងកម្រិតទឹកជោរ និងនាច។

*ព្រៃកោងកាង*





ព្រៃកោងកាង គឺជាសហគមន៍ដើមឈើ ហើយដើមកោងកាង ដែលមានកម្ពស់រហូតដល់ ៤៦ ម៉ែត្រ ត្រូវបានគេឃើញមានដុះនៅក្នុងតំបន់ដីសណ្ដ នៃទន្លេនីស្សេនៅទ្វីបអាព្រិច។ រុក្ខជាតិនៅស្រទាប់ក្រោមពុំសូវសម្បូរ ហើយជាទូទៅមានតែកូនកោងកាងដុះ។ លំនាំនៃការចាក់ឫសនៃដើមកោងកាងមានភាពខុសប្លែកពីគេ និងស្មុគ្រស្មាញ។

ជាទូទៅ រុក្ខជាតិនានានៅក្នុងព្រៃកោងកាងផ្ដល់នូវធនធានដ៏មានតម្លៃជាច្រើនដូចជា ផ្ដល់នូវអាហារ ថ្នាំ ឧសសម្រាប់ដុត ធ្យូង និងសម្ភារៈសំណង់ផ្សេងៗ។

## ខ. ព្រៃតំបន់ត្រជាក់បង្គួរ

ព្រៃឈើនៅតំបន់ត្រជាក់បង្គួរ គឺមានទីតាំងស្ថិតនៅចន្លោះតំបន់ប៉ូល និងតំបន់ត្រូពិច គឺស្ថិតនៅចន្លោះខ្សែស្របទី ៤០° ខាងជើង និងទី ៥០° ខាងត្បូងអេក្វាទ័រដែលមានអាកាសធាតុត្រជាក់ខ្លាំងពិបាកទ្រាំ។ ព្រៃឈើប្រភេទនេះមានដុះជាទូទៅនៅក្នុងប្រទេសមួយចំនួនដូចជា បណ្ដាប្រទេសនៅទ្វីបអឺរ៉ុប បណ្ដាប្រទេសនៅទ្វីបអាមេរិកខាងជើង ប្រទេសណូវែលសេឡង់ ប្រទេសកូរ៉េជើង ប្រទេសកូរ៉េខាងត្បូង ប្រទេសចិន ប្រទេសជប៉ុន និងប្រទេសតាស្មានី។ ព្រៃឈើនៅតំបន់ត្រជាក់បង្គួរមាន ២ ប្រភេទគឺ ព្រៃបៃតងជានិច្ច និងព្រៃជ្រុះស្លឹក។

- **ព្រៃបៃតងជានិច្ច**

ព្រៃបៃតងជានិច្ចនៅតំបន់ត្រជាក់បង្គួរ មានដុះលូតលាស់នៅតំបន់ ដែលសម្បូរទឹកភ្លៀង និងមានសីតុណ្ហភាពក្ដៅនៅនិទាឃរដូវ ហើយត្រជាក់នៅសិសិររដូវ។ ដើមឈើមិនជ្រុះស្លឹកនោះទេ ហើយប្រភេទឈើសំខាន់ៗរួមមាន ដើមសែន ដើមស្រល់ និងដើមសែត។ ព្រៃបៃតងជានិច្ចតំបន់ត្រជាក់បង្គួរជាច្រើនត្រូវរងការកាប់បំផ្លាញយ៉ាងដំណំ ដើម្បីយកឈើមានតម្លៃ ហើយត្រូវជំនួសដោយព្រៃដាំវិញ។

*ព្រៃបៃតងជានិច្ច*




- **ព្រៃជ្រុះស្លឹក**

ព្រៃជ្រុះស្លឹកនៅតំបន់ត្រជាក់បង្គួរ មានដុះលូតលាស់នៅតំបន់ ដែលមានសីតុណ្ហភាពមធ្យមល្មម ហើយដែលប្រែប្រួលទៅតាមរដូវទាំងបួន។ នៅនិទាឃរដូវ ឬរដូវផ្ការីក សីតុណ្ហភាពខ្ពស់ ចំណែកឯនៅសិសិររដូវវិញ សីតុណ្ហភាពទាប។ ដើមឈើជ្រុះស្លឹកនៅតំបន់ត្រជាក់បង្គួរ បានជ្រុះស្លឹកនៅសិសិររដូវ ហើយបានចាប់ផ្ដើមដុះស្លឹកលូតលាស់ឡើងវិញនៅនិទាឃរដូវ។ ប្រភេទឈើសំខាន់ៗ ដែលដុះក្នុងតំបន់នេះរួមមាន ដើមសែន ដើមប៊ុព្លីយេ ដើមស៊ីកាម័រ និងដើមអែតជាដើម។ ព្រៃជ្រុះស្លឹកតំបន់ត្រជាក់បង្គួរត្រូវបានគេកាប់ ដើម្បីយកឈើមានតម្លៃ និងដោយសារតែដីមានជីជាតិល្អ គេកាប់ឆ្ការព្រៃទាំងនេះ ដើម្បីយកដីធ្វើកសិកម្មចិញ្ចឹមសត្វ និងចម្ការដំណាំហូបផ្លែ។

*ព្រៃឈើជ្រុះស្លឹក*




- **ព្រៃតៃកា ឬព្រៃកូនីផៃ**

ព្រៃកូនីផៃ ឬព្រៃតៃកាត្រូវបានគេប្រទះឃើញមានដុះជាសំខាន់នៅទីកន្លែងមួយចំនួន ដែលមានអាកាសធាតុទឹបត្រជាក់ខ្លាំង។ អាកាសធាតុបែបនេះ គឺស្ថិតនៅក្នុងអាកាសធាតុតំបន់ត្រជាក់បង្គួរ ដែលស្ថិតនៅទីកន្លែងមួយចំនួន នៃអឌ្ឍគោលខាងជើង ចន្លោះខ្សែស្របទី ៦០$^{0}$ និង ៧០$^{0}$ នៃអេក្វាទ័រ។ ទីកន្លែងទាំងនេះ

គឺមាន ៤ រដូវគឺ និទាឃរដូវ វស្សាន្តរដូវ សរទរដូវ និងសិសិររដូវ។ សិសិររដូវ គឺជារដូវត្រជាក់បំផុត ហើយសីតុណ្ហភាពអាចធ្លាក់ចុះរហូតដល់ -៤០ អង្សារសេ។ វស្សាន្តរដូវ គឺជារដូវដែលក្តៅបំផុត មានសីតុណ្ហភាពជាមធ្យមរហូតដល់ ២១ អង្សារសេ។ កំណកអាកាសនៅតំបន់ទាំងនេះ មានកម្ពស់ជាមធ្យមទាបប្រហែលពី ៣០០ ទៅ ៦៣៥ ម.ម ក្នុងមួយឆ្នាំ ហើយជាញឹកញាប់កំណកអាកាសទាំងនេះបានធ្លាក់មក ក្នុងទម្រង់ជាព្រិលទឹកកក។

ព្រៃប្រភេទនេះ មានដុះជាសំខាន់នៅក្នុងតំបន់មួយចំនួនដូចជា អាឡាស្កា ប្រទេសកាណាដាភាគខាងជើង សហរដ្ឋអាមេរិចភាគខាងជើង តំបន់ស្កង់ឌីណាវភាគខាងជើង (ដូចជានៅប្រទេសហ្វាំងឡង់ ប្រទេសន័រវេសន៍ ប្រទេសស៊ុយអែដ) និងប្រទេសរុស្សីជាដើម។ ព្រៃប្រភេទនេះ ក៏មានដុះផងដែរនៅក្នុងផ្នែកផ្សេងៗនៃពិភពលោក ជាពិសេសនៅក្នុងតំបន់ដែលមានរយៈទទឹងខ្ពស់ ឬខ្ពង់រាបខ្ពស់ៗ ប្រកបដោយអាកាសធាតុត្រជាក់ខ្លាំងពិបាកទ្រាំ។

ព្រៃកូនីផៃ គឺជាប្រភេទព្រៃ ដែលមិនក្រាស់ ពីព្រោះសីតុណ្ហភាព និងកំណកអាកាសមិនអាចទ្រទ្រង់ឱ្យមានកំណើនរុក្ខជាតិក្រាស់បានទេ។ ព្រៃនេះភាគច្រើន គឺជាប្រភេទដើមឈើមានរាងដូចសាជី ដូចជាពពួកអម្បូរស្រល់ ដែលដុះលាយឡំគ្នាជាមួយរុក្ខជាតិសម្បូរស្លឹកដែលហៅថា **ព្រៃឈើចម្រុះ**។

*ព្រៃតៃកា*





## គ. តួនាទី និងសារៈសំខាន់នៃព្រៃឈើ

ការគ្រប់គ្រង និងការការពារព្រៃឈើដែលនៅសេសសល់ គឺសំខាន់ណាស់ ពីព្រោះព្រៃឈើដើរតួនាទី និងមានសារៈប្រយោជន៍ខ្លាំងណាស់ សម្រាប់សង្គម និងបរិស្ថានរបស់យើង។

- **ព្រៃឈើធ្វើឱ្យមានវដ្តភូគព្ភគីមី** ៖ ព្រៃឈើមានតួនាទីសំខាន់ណាស់ នៅក្នុងវដ្តនៃសារជាតុគីមី ឬវដ្តភូគព្ភគីមីក្នុងពិភពលោក ពិសេសនៅក្នុងវដ្តអាស៊ូត វដ្តកាបូន និងវដ្តអុកស៊ីសែន។ រស្មីសំយោគរបស់រុក្ខជាតិបៃតង ទាញយកនូវបរិមាណកាបូនឌីអុកស៊ីតពីបរិយាកាសបានយ៉ាងច្រើន ហើយបានបម្លែងឱ្យទៅជាសមាសធាតុសរីរាង្គ ឬគ្លុយស៊ីត។ ក្នុងពេលជាមួយគ្នានោះដែរ រុក្ខជាតិក៏បានបញ្ចេញនូវអុកស៊ីសែនទៅក្នុងបរិយាកាសវិញ ហើយថាមពលព្រះអាទិត្យបានបំប្លែងទៅជាទម្រង់មួយ ដែលអាចប្រើប្រាស់បាន។
- **ព្រៃឈើធ្វើឱ្យមាននិយ័តកម្មអាកាសធាតុ** ៖ ក្រៅពីធ្វើឱ្យមានវដ្តភូគព្ភគីមី ព្រៃឈើក៏បានចូលរួមចំណែក ក្នុងការធ្វើឱ្យមាននិយ័តកម្មអាកាសធាតុផងដែរ។ ការធ្វើរស្មីសំយោគរបស់រុក្ខជាតិបៃតងមិនត្រឹមតែបានធ្វើឱ្យមានវដ្តភូគព្ភគីមីប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានចូលរួមយ៉ាងសំខាន់ ក្នុងការសម្អាតបរិយាកាសមិនឱ្យរងការកខ្វក់ និងមិនឱ្យផែនដីឡើងកម្ដៅ តាមរយៈការស្រូបយកឧស្ម័នកាបូនិចពីបរិយាកាស ព្រោះប្រសិនបើមានវត្តមាន នៃបរិមាណឧស្ម័នកាបូនិចច្រើននៅក្នុងបរិយាកាស វាបង្កឱ្យមានកខ្វក់អាកាស និងកំណើនផលផ្ទះកញ្ចក់នៅក្នុងបរិយាកាសដែលជាមូលហេតុបណ្ដាលឱ្យផែនដីឡើងកម្ដៅ។
- **ព្រៃឈើធ្វើឱ្យមាននិយ័កម្មប្រភពទឹក** ៖ ព្រៃឈើបានទាក់ទាញទឹកភ្លៀង និងជាផ្លូវទឹកដ៏មានប្រសិទ្ធភាពមួយ ព្រោះវាបានស្រូបយកទឹកភ្លៀងយ៉ាងច្រើនចូលទៅក្នុងដី ផ្ទុក និងបានបញ្ចេញទឹកទាំងនោះមកវិញបន្តិចម្ដងៗ ដែលធ្វើឱ្យលំហូរនៃទឹកនោះមានភាពទៀងទាត់ បើទោះបីជាស្ថិតនៅក្នុងរដូវរាំងស្ងួតក៏ដោយក្ដី និងបានជួយការពារគ្រោះទឹកជំនន់យ៉ាងគំហុក បញ្ចៀសនូវគ្រោះរាំងស្ងួត ការពារសំណឹកដី ថែរក្សាគុណភាពដី ការពារការបេះដី និងអាចទប់ទល់នឹងការពារខ្យល់ព្យុះបានទៀតផង។
- **ព្រៃឈើជាប្រភពផ្ដល់ និងទាក់ទាញនូវទឹកភ្លៀង** ៖ ព្រៃឈើក៏មានឥទ្ធិពលផងដែរទៅលើលក្ខខណ្ឌអាកាសធាតុ។ ខ្យល់នៅក្នុងព្រៃឈើត្រជាក់ និងមានសំណើមជាងខ្យល់នៅផ្នែកខាងក្រៅព្រៃឈើ ដោយសារតែដំណើរធ្វើឱ្យត្រជាក់ប្រព្រឹត្តទៅ តាមបែបបាតុភូតជីវៈហៅថា **រំភាយចំហាយទឹក** ដែលក្នុងនោះទឹកបាន ដែលបានមកពីដីតាមរយៈការស្រូបដោយប្រព័ន្ធឫសឈើ ហើយដែលបានដឹកជញ្ជូនកាត់តាមដើមឈើ និងបន្ទាប់មកបានរំហួតចេញពីស្លឹក និងទងរបស់វាទៅក្នុងបរិយាកាសវិញ។ រំភាយចំហាយទឹកនេះ ក៏បានផ្ដល់នូវសំណើមនៅក្នុងពពកផងដែរ ហើយដែលនឹងក្លាយទៅជាទឹកភ្លៀងធ្លាក់មកលើផែនដី។ ម្យ៉ាងទៀត ព្រៃឈើ ក៏បានចូលរួមចំណែកក្នុងការទាក់ទាញទឹកភ្លៀងផងដែរ ព្រោះខ្យល់នៅពីលើព្រៃឈើជាខ្យល់ត្រជាក់ ហើយនៅពេលដែលខ្យល់ក្ដៅសើមបក់កាត់តំបន់ ដែលមានព្រៃឈើ ខ្យល់ត្រជាក់ ដែលស្ថិតនៅពីលើព្រៃឈើបាន

ជ្រមុជចុះទៅនៅពីក្រោមខ្យល់ក្តៅហើយសើម ហើយបានធ្វើឱ្យខ្យល់ក្តៅសើមទាំងនេះបានចុះត្រជាក់ និងកកើតជាទឹកភ្លៀងធ្លាក់មកលើផ្ទៃផែនដីតែម្តង។

- **ព្រៃឈើរក្សាទុកនូវជីវៈមណ្ឌលសម្បូរបែប** ៖ នៅក្នុងព្រៃត្រូពិច គេសង្កេតឃើញមានសត្វ និងរុក្ខជាតិជាច្រើនប្រភេទ។ ៧០% នៃរុក្ខជាតិ និងសត្វ គឺមាននៅទីនេះ។ ព្រៃត្រូពិចមានឈើច្រើនប្រភេទណាស់ គឺមានច្រើនជាង ២០០ ប្រភេទ នៅក្នុងមួយហិចតា រីឯព្រៃឈើនៅតំបន់ត្រជាក់បង្គួរវិញមានឈើត្រឹមតែ ១០ ប្រភេទប៉ុណ្ណោះ នៅក្នុងមួយហិចតា។ លើសពីនេះទៅទៀត ព្រៃត្រូពិចបានផ្តល់នូវសែនបម្រុងដ៏សម្បូរបែប សម្រាប់រក្សាទុកក្នុងការប្រើប្រាស់នាពេលទៅអនាគតខាងមុខ។
- **ព្រៃឈើផ្តល់នូវវូបជាតុដើម សម្រាប់ឧស្សាហកម្ម និងលើកស្ទួចសេដ្ឋកិច្ច** ៖ ព្រៃឈើបានដើរតួជាផ្នែកមួយនៅក្នុងសកម្មភាពផ្សេងៗ ក្នុងសេដ្ឋកិច្ចទំនើប ច្រើនជាងរបស់ប្រើប្រាស់ផ្សេងៗទៀត ពីព្រោះស្ទើរតែគ្រប់ឧស្សាហកម្មសំខាន់ៗទាំងអស់ គឺពឹងផ្អែកទៅលើវូបជាតុដើមព្រៃឈើ ដែលយ៉ាងហោចណាស់មានមួយនៅក្នុងដំណើរការរបស់វា។ ឈើ ដែលត្រូវបានគេប្រមូលមកពីព្រៃ ត្រូវគេប្រើប្រាស់ជាថាមពល សម្រាប់ចម្អិនម្ហូបអាហារ និងឧបករណ៍សំណង់ផ្សេងៗ។ ឈើក៏ត្រូវបានគេយកមកកែច្នៃនៅក្នុងឧស្សាហកម្ម ដើម្បីបង្កើតក្តារបន្ទះ ផ័រមីកា ក្តារង្សឿ ក្តារធ្វើអំពីកំទេចឈើ ក្តារធ្វើអំពីចំនាំង ឈើជាដើម និងធ្វើក្រដាស។
- **ផ្តល់អនុផលព្រៃឈើ** ៖ ក្រៅពីផ្តល់ឈើ ព្រៃឈើក៏បានផ្តល់ផងដែរនូវរុក្ខជាតិសរសៃ ផ្តល់ជ័រ ផ្តល់វល្លិ ផ្តល់ផ្តៅ ផ្តល់ឫស្សី ផ្តល់ផ្លែឈើ ផ្តល់ឃ្មុំ និងផលិតផលអាហារ សម្រាប់មនុស្សប្រើប្រាស់ដោយផ្ទាល់។
- **សម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ** ៖ ក្រៅពីផ្តល់នូវអនុផលព្រៃឈើ ព្រៃឈើក៏មានសារៈសំខាន់ផងដែរ សម្រាប់ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រដូចជា ខាងផ្នែកក្សេត្រសាស្ត្រ ខាងផ្នែកឱសថសាស្ត្រ និងឱសថបុរាណ សម្រាប់ព្យាបាលជម្ងឺផ្សេងៗ។ តាមរយៈការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា មានសហគ្រាសផលិតឱសថបានប្រើប្រាស់ធនធានព្រៃត្រូពិច ក្នុងការផលិតឱសថរបស់ខ្លួន។
- **ទ្រទ្រង់នូវជីវៈចម្រុះ** ៖ ព្រៃឈើបានផ្តល់នូវជម្រកសត្វព្រៃគ្រប់ប្រភេទទាំងអស់ និងជាកន្លែងដ៏សំខាន់មួយ សម្រាប់ការកកើតនូវប្រភេទថ្មី។

## ៦.២. រុក្ខជាតិ និងសត្វនៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាសម្បូរទៅដោយរុក្ខជាតិ និងសត្វព្រៃណាស់។ ភាពសម្បូរទៅដោយរុក្ខជាតិ និងសត្វនេះ គឺអាស្រ័យទៅដោយលក្ខខណ្ឌអនុគ្រោះនៃសណ្ឋានដី និងអាកាសធាតុ និងផ្លូវទឹកនៃប្រទេសកម្ពុជាយើង។ រុក្ខជាតិ និងសត្វព្រៃ គឺមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធបំផុតជាមួយនឹងអាកាសធាតុ និងសណ្ឋានដី។ ព្រៃឈើអាចដុះ និងលូតលាស់យ៉ាងទ្រុបទ្រុលបាន អាស្រ័យដោយមានអាកាសធាតុក្តៅហើយសើម និងសម្បូរដោយភ្នំ និងខ្ពង់រាបដែលមានដីប្រកបទៅដោយជីជាតិល្អ។ ចំណែកឯសត្វអាចរស់នៅបាន ក៏អាស្រ័យទៅដោយមានព្រៃឈើធ្វើជាជម្រក មានវាលស្មៅ និងទឹក សម្រាប់ជាចំណីអាហាររបស់ពួកវាផងដែរ។

### ក. ព្រៃឈើនៅកម្ពុជា

## ១. ស្ថានភាពព្រៃឈើនៅកម្ពុជា

ព្រៃឈើ គឺជាភោគទ្រព្យធម្មជាតិដែលកើតឡើងវិញ។ ភោគទ្រព្យនេះ ត្រូវទទួលការគ្រប់គ្រងប្រកបដោយគតិបណ្ឌិត ដើម្បីជាប្រយោជន៍ សម្រាប់មនុស្សជំនាន់ក្រោយ និងអនាគតនៃប្រជាជនកម្ពុជា។ ប្រសិនបើមានការគ្រប់គ្រងប្រកបដោយគតិបណ្ឌិតនោះ ព្រៃឈើអាចបន្តផ្គត់ផ្គង់តម្រូវការរបស់ប្រជាជននៅមូលដ្ឋាន ក៏ដូចជាតម្រូវការរបស់ប្រទេស ក្នុងការទទួលបាននូវប្រាក់ចំណូល សម្រាប់ការអភិវឌ្ឍន៍ផងដែរ។ ប៉ុន្តែប្រសិនបើការគ្រប់គ្រងព្រៃឈើមិនបានល្អវិញនោះ ភោគទ្រព្យនេះនឹងឈានទៅរកការបាត់បង់ ហើយកាលានុវត្តភាព ឬឱកាសសម្រាប់មនុស្សជំនាន់ក្រោយ ក៏នឹងត្រូវបាត់បង់ទៅតាមនឹងផងដែរ។

ប្រទេសកម្ពុជាសម្បូរព្រៃឈើ ដោយសារកត្តាធម្មជាតិដូចជា សណ្ឋានដី និងលក្ខខណ្ឌអាកាសធាតុអនុគ្រោះ។ ក៏ប៉ុន្តែក្នុងរយៈពេល ៣ ទសវត្សរ៍ចុងក្រោយនេះ ព្រៃឈើរបស់យើងត្រូវបានបាត់បង់ជាបន្តបន្ទាប់គួរឱ្យព្រួយបារម្ភ ដោយសារតែការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់ដី សម្បទានសេដ្ឋកិច្ចឱ្យទៅក្រុមហ៊ុនអភិវឌ្ឍដំណាំឧស្សាហកម្មនានា។

រហូតមកដល់ឆ្នាំ ១៩០០ ផ្ទៃដីព្រៃឈើប្រទេសកម្ពុជាមានទំហំស្មើនឹង ៧៥% នៃផ្ទៃប្រទេស នៅឆ្នាំ ១៩៦០ ផ្ទៃដីព្រៃឈើនេះនៅសល់ ៧៣% នៅឆ្នាំ ១៩៨០ ផ្ទៃដីព្រៃឈើនៅសល់ត្រឹម ៥០% (តាមតារាងណបឥណ្ឌាថតពីលើអាកាស) នៅឆ្នាំ ១៩៨៩ ផ្ទៃដីព្រៃឈើនៅសល់តែ ៤១.៧% (តាមទីភ្នាក់ងារសារពត៌មាន **For Eastern Economic Review** ចេញផ្សាយថ្ងៃទី១២ ខែមករា ឆ្នាំ១៩៨៩) និងបច្ចុប្បន្ន ផ្ទៃដីព្រៃឈើនៅសល់ប្រហែលជា ៣២% នៃផ្ទៃប្រទេសតែប៉ុណ្ណោះ ហើយនឹងកំពុងតែបន្តថយចុះជាលំដាប់ ដោយសារការផ្តល់ដីសម្បទានសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលទៅឱ្យក្រុមហ៊ុនឯកជន។

## ២. ប្រភេទព្រៃឈើនៅកម្ពុជា

ប្រទេសកម្ពុជាមានព្រៃឈើប្លែកៗគ្នាជាច្រើន ដោយសារតែលក្ខណៈដី និងអាកាសធាតុដែលមានការអនុគ្រោះដល់ការដុះលូតលាស់នៃជីវិតរុក្ខជាតិទាំងនេះ។ ហេតុដូចនេះហើយ បានជាប្រទេសកម្ពុជាយើងសម្បូរព្រៃឈើច្រើនម្លេះ។ ខេត្ត ដែលសម្បូរព្រៃឈើច្រើនជាងនៅកម្ពុជាគេគឺ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគីរី ខេត្តមណ្ឌលគីរី ខេត្តកំពង់ធំ ខេត្តខេត្តពោធិ៍សាត់ ខេត្តព្រះវិហារ ខេត្តកំពតខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន និងខេត្តកោះកុង។ ក្រៅពីខេត្តទាំងនេះ ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តសៀមរាប គឺជាខេត្ត ដែលមានព្រៃឈើមធ្យម។ រីឯខេត្តក្រៅពីនេះ មានព្រៃឈើតិចតួចណាស់។ ព្រៃឈើនៅប្រទេសកម្ពុជាច្រើនជាព្រៃធំៗ ហើយភាគច្រើនសម្បូរដោយឈើដែលមានតម្លៃដូចជា កកោះ បេងគគីរ សុក្រម នាងនួន ក្រញូង ចំបក់ ស្រឡៅ ធ្នង់ ឥន្ទ្រទេយ ត្របែកព្រៃ ឈើទាល-ល-។ ជាទូទៅ ព្រៃឈើនៅប្រទេសកម្ពុជាយើងត្រូវបានគេចែកជា ៣ ប្រភេទធំៗ ដែលរួមមាន ៖

### ២.១. ព្រៃតំបន់ខ្ពស់

ព្រៃតំបន់ខ្ពស់ គឺជាព្រៃដែលដុះនៅតំបន់ភ្នំ និងខ្ពង់រាបនៃប្រទេសកម្ពុជា។ ព្រៃតំបន់ខ្ពស់លាតសន្ធឹងយ៉ាងធំធេង ហើយមានឈើល្អៗ មានផលប្រយោជន៍តិច ឬច្រើនគឺអាស្រ័យទៅលើប្រភេទដី និងអាកាសធាតុ។ លក្ខណៈពិសេស នៃព្រៃឈើទាំងនេះ គឺមានល្បាយដ៏ស្មុគ្រស្មាញនៃពូជឈើច្រើនយ៉ាង។ ក៏ប៉ុន្តែគេអាចសង្កេតឃើញថា ព្រៃឈើទាំង នេះមានលក្ខណៈផ្សេងៗគ្នាទៅតាមប្រភេទដី និងអាកាសធាតុ។

- **ព្រៃឈើតាមជួរភ្នំក្រវាញ**

ព្រៃឈើនៅតាមជួរភ្នំក្រវាញ គឺជាប្រភេទព្រៃស្អុក មានលក្ខណៈជាព្រៃត្រូពិច ពីព្រោះដើមឈើពុំសូវត្រង់ល្អនោះទេ ក៏ប៉ុន្តែដុះញឹកប្រជ្រៀតគ្នា ហើយមានច្រើនស្រទាប់អាចមានកម្ពស់រហូតដល់ ៤០ ម៉ែត្រ។ ឯព្រៃក្រោមវិញ មានបណ្ណង្គជាតិ រំពាក់ ផ្តៅ វល្លិធំៗ រុក្ខជាតិធ្មើប្រាណ និងអម្បូរត្នោតតឿដុះជាច្រើន។ ចំណែកឯនៅខ្ពង់រាបគីរីរម្យវិញ សម្បូរទៅដោយដើមស្រល់ ដែលគេចាត់ទុកថាជាឈើមានតម្លៃមធ្យម។

- **ព្រៃឈើនៅតំបន់ខ្ពង់រាបខាងជើង និងខ្ពង់រាបឦសាន**

ព្រៃឈើទាំងនេះ មានដុះនៅតាមជួរភ្នំដងរែក និងនៅតាមកូនភ្នំ នៃតំបន់ខ្ពង់រាបមួយចំនួនដូចជា ភ្នំគូលេន ភ្នំត្បែង ភ្នំចុងកាល ភ្នំពេងពាយ ភ្នំក្រង់ និងភ្នំរាំងជាដើម។ ព្រៃឈើនៅតំបន់នេះ ជាប្រភេទព្រៃក្រាស់ៗ និងធំៗ ហើយសម្បូរទៅដោយពូជឈើល្អៗ សម្រាប់សំណង់នានា និងគ្រឿងបរិក្ខារផ្សេងៗ។ ម្យ៉ាងទៀត ពូជឈើនៅប្រទេសកម្ពុជាយើង ក៏ដូចជាពូជឈើប្រទេសត្រូពិចផ្សេងៗទៀតដែរ គឺតែងតែដុះលាយឡំគ្នាច្រើនមុខ ដូចជា ធ្នង់ នាងនួន បេង កកោះ ស្រឡៅ ឈើទាល ខ្នុរព្រៃ គគីរ ផ្ចឿកជាដើម។

- **ព្រៃឈើដុះនៅលើសិលាក្រែលាយខ្សាច់**

ព្រៃឈើប្រភេទនេះ គឺជាប្រភេទព្រៃរបោះ ដែលមានពូជឈើសំខាន់តិចតួចដូចជា ខ្លុង ត្បែង ត្រាច និងពពេលជាដើម ដែលដុះនៅលើដីប្រភេទនេះ។ លក្ខណៈពិសេសនៃព្រៃរបោះ គឺព្រៃក្រោមដែលមានស្បូវ ហើយច្រើនតែឆាបឆេះនៅរដូវប្រាំង ដែលជាឧបសគ្គដល់ការលូតលាស់ ឬដុះឡើងវិញ នៃដើមឈើនាន។ ព្រៃប្រភេទនេះ ពុំសូវមានសារៈសំខាន់សេដ្ឋកិច្ចធំដុំប៉ុន្មានទេ។

- **ព្រៃឈើនៅលើសិលាបាសាល់**

ព្រៃឈើប្រភេទនេះ គឺមានដើមឈើដុះដោយរង្វើលៗ ហើយភាគច្រើនសម្បូរទៅដោយឈើមានតម្លៃដូចជា ធ្នង់ នាងនួន កកោះ ស្រឡៅ គរគី ក្រញូង និងឈើទាលជាដើម។

- **ព្រៃឈើនៅលើដីឥដ្ឋល្បាយស៊ីលីស**

ព្រៃឈើប្រភេទនេះ ជាប្រភេទព្រៃក្រាស់ល្មម ដែលសម្បូរដោយឈើមានតម្លៃដូចជា ឈើទាល គគីរ ផ្ចឿក ជ័រចុង និងខ្នុរព្រៃ។

ជាទូទៅ នៅលើភ្នំទាំងឡាយណា ដែលគេចផុតពីខ្យល់សើម ច្រើនតែមានដុះនូវប្រភេទឈើដែលមានតម្លៃដូចជា នៅជួរភ្នំដំរីខាងត្បូង និងតំបន់ខ្ពង់រាបខាងជើង និងឥសាន្តជាដើម។

**២.២. ព្រៃលិចទឹក**

ព្រៃលិចទឹក គឺជាព្រៃ ដែលដុះនៅតាមតំបន់ទំនាប នាមាត់បឹង មាត់ទន្លេ និងមាត់សមុទ្រ។ ព្រៃលិចទឹកនៅប្រទេសកម្ពុជាយើងគ្របដណ្តប់លើផ្ទៃដីប្រហែល ៦៨០ ០០០ ហិចតា។ ព្រៃប្រភេទនេះ អាចជាព្រៃបឹងពិសេសបឹងទន្លេសាប ក្នុងប្រវែងប្រហែល ៨០ គ.ម ព្រៃទន្លេ ដែលគ្របដណ្តប់លើផ្នែកទាបៗក្រោយមាត់ទន្លេ និងព្រៃកោងកាង ដែលលាតសន្ធឹងតាមបណ្តោយឆ្នេរសមុទ្រ និងមាត់ព្រែកនានានៅក្នុងតំបន់ឆ្នេរសមុទ្រ។ ជាទូទៅ គេចែកព្រៃលិចទឹកជា ២ ប្រភេទ គឺព្រៃលិចទឹកសាប ឬព្រៃរនាម និងព្រៃលិចទឹកប្រៃ ឬព្រៃកោងកា។

- **ព្រៃលិចទឹសាប ឬព្រៃរនាម**

ព្រៃលិចទឹកបឹងភាគច្រើនស្ថិតនៅព័ទ្ធជុំវិញបឹងទន្លេសាប និងតាមមាត់បឹងនៅអមសងខាងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់។ ព្រៃបឹងសម្បូរនៅខេត្តបាត់ដំបង និងខេត្តកំពង់ធំ។ ព្រៃបឹង ជាប្រភេទឈើតូចៗ ដែលមានលក្ខណៈជារុក្ខជាតិក្រិន ឬព្រៃរនាម ប៉ុន្តែគេក៏ប្រទះឃើញមានដើមឈើខ្ពស់ៗខ្លះៗដែរ ដែលអាច ធន់នឹងជម្រៅទឹកពី ២ ទៅ ៦ ម៉ែត្រដូចជា រាំងទឹក ក្របៅ រទាំង សាអួ ត្រស់ ភ្នំភ្លើង-ល-។ ព្រៃបឹងមានសារៈ សំខាន់ណាស់ ពីព្រោះវាជាជ្រកត្រីពង និងជាចំណីរបស់ត្រីនៅរដូវវស្សា។

បច្ចុប្បន្ននេះ ព្រៃបឹង ឬព្រៃរនាមទាំងនេះបានទទួលរង នូវការកាប់បំផ្លាញយ៉ាងខ្លាំងពីសំណាក់ប្រជាជន របស់យើង ដើម្បីយកដីសម្រាប់ធ្វើកសិកម្ម។

- **ព្រៃលិចទឹកប្រៃ ឬព្រៃកោងកាង**

ព្រៃលិចទឹក ឬព្រៃកោងកាងជាបពពួកដើមឈើ និងចុល្លព្រឹក ដែលធន់ទៅនឹងទឹកប្រៃ ហើយដែល ដុះនៅតាមតំបន់ចន្លោះទឹកជោរ និងនាចនៃទន្លេ ស្ទឹង ឆកសមុទ្រ ពាមសមុទ្រ ដែលមានរបាំងការពារ។ ព្រៃលិច ទឹកប្រៃ ឬព្រៃកោងកាងនៅប្រទេសកម្ពុជាយើងមានដុះនៅក្នុងខេត្តកោះកុង ខេត្តកំពត ខេត្តព្រះសីហនុ និង ខេត្តកែប។ ជាទូទៅ គេចែកព្រៃកោងកាងជា ២ ប្រភេទ គឺ ៖

- **ព្រៃកោងកាងពិត**

ព្រៃកោងកាងពិត គឺជាប្រភេទព្រៃលិចទឹកប្រៃជាប្រចាំ និងលិចទឹកប្រៃនៅពេលដែលមានទឹកជោរ។ ព្រៃកោងកាងប្រភេទនេះ មានប្រហែលជា ៣៨ ០០០ ហិចតា ហើយលាតសន្ធឹងនៅលើវាល់ភក់លិចទឹកប្រៃនៃ ខេត្តកោះកុង និងនៅតាមពាមសមុទ្រផ្សេងៗទៀត។ គេឃើញមានប្រភេទរុក្ខជាតិជាច្រើន ដែលដុះនៅក្នុងព្រៃ កោងកាងពិតនេះដូចជា ដើមកោងកាង ដើមតាឱន និងដើមចាកជាដើម។

- **ព្រៃកោងកាងក្រោយ**

ព្រៃកោងកាងក្រោយ គឺជាប្រភេទព្រៃកោងកាងម្យ៉ាង ដែលដុះលាតសន្ធឹងនៅលើវាលទំនាបខ្សាច់ ទាបៗ ដែលទឹកជំនោរសមុទ្រពុំអាចហូរចូលទៅដល់។ ដើមឈើសំខាន់ៗ ដែលដុះនៅក្នុងព្រៃកោងកាង ប្រភេទនេះរួមមានដូចជា ដើមស្មាច់ជាដើម ដែលមានកម្ពស់មធ្យម និងដុះយ៉ាងក្រាស់។ ភ្លើងឆេះព្រៃ ដែលឆាប ឆេះជាញឹកញាប់ ពុំរំខានដល់ដំណុះនៃគ្រាប់ស្មាច់នោះទេ។ ជាទូទៅ ព្រៃកោងកាងផ្តល់នូវសារៈសំខាន់ជា ច្រើន ដល់សេដ្ឋកិច្ច និងបរិស្ថាន ជាពិសេសផ្តល់នូវជម្រក និងចំណីអាហាររបស់ មច្ឆជាតិនៅតំបន់ឆ្នេរសមុទ្រ។

- **ព្រៃឬស្សី**

នៅប្រទេសកម្ពុជា ព្រៃឬស្សីមានដុះលាតសន្ធឹងលើផ្ទៃដីដ៏ធំល្វឹងល្វើយ ក៏ប៉ុន្តែភាគច្រើនដុះនៅជាយ ព្រៃលិចទឹក (ជុំវិញបឹង) នៅតាមដៃនៃបឹងទន្លេសាបនៅលើដីក្រហម។ គេប្រទះឃើញព្រៃប្រភេទនេះមាន ច្រើនណាស់។ ខាងក្រោមនេះ ជាប្រភេទឫស្សីសំខាន់ៗ ដែលរៀបរាប់តាមលំដាប់ឡើងនៃទំហំរបស់ឫស្សី។

- ឫស្សីព្រេច ៖ ដើមតូចៗ មានកម្ពស់ទាបៗ និងមានស្លឹកល្អិតៗ
- ឫស្សីរលាក ៖ ដើមតូច ហើយសម្បូរបន្លា
- ឫស្សីពីងពង់ ៖ ដើមធំល្មម ហើយសឹងតែតាន់ និងគ្មានបន្លា
- ឫស្សីកែវ ៖ មានដើមពណ៌លឿង ហើយសម្បូរជាងគេក្នុងចំណោមប្រភេទឫស្សីទាំងអស់

- ឫស្សីស្រុក ៖ មានដើមពណ៌បៃតង និងមានដើមធំ
- ឫស្សីព្រៃ ៖ មានដើមធំៗ សម្បូរបន្លា និងដុះនៅក្នុងព្រៃ
- ឫស្សីចិន ៖ មានដើមពណ៌ខៀវ ហើយធំជាងគេទាំងអស់ ក្នុងចំណោមប្រភេទឫស្សី។

ឫស្សីស្រុក និងឫស្សីចិនត្រូវបានគេដាំដោយកន្លែងៗ នៅក្បែរផ្ទះ និងក្បែរភូមិភាគច្រើននៅប៉ែកអាគ្នេយ៍នៃរាជធានីភ្នំពេញ។ ដើមឫស្សីមានប្រយោជន៍ណាស់ បន្ទាប់ពីដើមឈើ។ គេយកដើម ឫស្សីទៅធ្វើក្រដាស គ្រឿងសំណង់ និងឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ក្រៅពីនេះ ទំពាំងឫស្សីត្រូវបានគេយកទៅប្រើប្រាស់ធ្វើជាបន្លែ សម្រាប់ធ្វើជាម្ហូបអាហារបានថែមទៀតផង។

## ខ. សត្វព្រៃនៅប្រទេសកម្ពុជា

អាកាសធាតុ សណ្ឋានដី និងផ្លូវទឹកនៅប្រទេសកម្ពុជាយើងផ្តល់នូវអំណោយផលយ៉ាងល្អប្រសើរ សម្រាប់កំណកំណើតនៃពពួកសត្វព្រៃជាច្រើនប្រភេទ។ សណ្ឋានដីនៃប្រទេសកម្ពុជាផ្នែកខាងកើតគឺជាចំណោតខាងលិចនៃជួរភ្នំអណ្ណាម ផ្នែកខាងនិរតីជាជួរភ្នំក្រវាញ និងនៅផ្នែកខាងជើងជាជួរភ្នំដងរែកដែលជាចំណោតនៃខ្ពង់រាបនគររាជនៃប្រទេសថៃ។ ផ្ទៃដីប្រទេសកម្ពុជាភាគច្រើនគ្របដណ្តប់ទៅដោយព្រៃឈើ និងព្រៃដីសើមដែលជាជម្រកដ៏សំខាន់របស់សត្វព្រៃជាច្រើនប្រភេទ។

### ១. ប្រភេទសត្វលើគោក

សត្វលើគោកនៅប្រទេសកម្ពុជា ក្រៅពីសត្វពាហនៈគឺមានសត្វព្រៃជាច្រើនប្រភេទដែលកំពុងរស់នៅ។ គេជឿថា ប្រភេទសត្វលើគោកនៅប្រទេសកម្ពុជាមានថនិកសត្វចំនួន ២១២ ប្រភេទ បក្សីចំនួន ៧២០ ប្រភេទ និងល្មូនចំនួន ២៤០ ប្រភេទ។ ពពួកសត្វលើគោកទាំងនេះរួមមាន ៖

- **ថនិកសត្វ** ៖ មាន ដំរី ក្របីព្រៃ ទន្សោង ខ្ទីង ដំរី ខ្លាធំ ខ្លាដំបង ស្វា ខ្លាឃ្មុំ ក្តាន់ ប្រើស ជ្រូកព្រៃ រមាំង និងទន្សាយ -ល-។
- **បក្សី** ៖ មាន មាន់ព្រៃ មាន់ទោ ក្ងោក ទទា ត្បាត ក្រសា ត្រយង អក ក្រៀល ទង់ ត្រដក់ ក្រសា ក្អែកទឹក ប្រវឹក លលក ចាប និងសារិកាកែវ -ល-។
- **ល្មូន** ៖ មាន ពស់ តុកកែ ត្រកួត ថ្លែន និងបង្កួយ-ល-។

### ២. ប្រភេទសត្វក្នុងទឹក

ប្រភេទសត្វក្នុងទឹកនៅប្រទេសកម្ពុជាយើង ក៏មានច្រើនប្រភេទណាស់ដែរ។ ជាទូទៅ គេចែកសត្វនៅក្នុងទឹកនៃប្រទេសកម្ពុជាជា ២ ប្រភេទ គឺសត្វរស់នៅក្នុងទឹកសាប និងសត្វរស់នៅក្នុងទឹកប្រៃ។

- **សត្វរស់នៅក្នុងទឹកសាប**

សត្វដែលរស់នៅក្នុងទឹកសាប នៃប្រទេសកម្ពុជារួមមាន ប្រភេទត្រី ប្រភេទថនិកសត្វ ប្រភេទសិប្បីសត្វ ប្រភេទល្មូន និងប្រភេទគ្រុស្តាសេ។ បឹងទន្លេសាប ទន្លេមេគង្គ ទន្លេបាសាក់ និងវាលទំនាបលិចទឹករបស់វា គឺជាជម្រកដ៏សំខាន់របស់ប្រភេទសត្វទាំងនេះ។ ប្រភេទសត្វទាំងនេះរួមមាន ៖

- **ប្រភេទត្រី** ៖ មានចំនួនប្រមាណ ៨៥០ ប្រភេទ ដែលរួមមានដូចជា ត្រីឆ្តោរ ត្រីរស់ ត្រីក្រាយ ត្រីគ្រំ ត្រីព្រួល ត្រីគល់រាំង ត្រីរាជ ត្រីត្រសក់ ត្រីពោរ ត្រីខ្យា ត្រីក្រាញ់ ត្រីទ្រប់ ត្រីឆ្លូញ ត្រីឆ្តោក ត្រីកាហែ ត្រីផ្ទិន ត្រីប្រកែង និងត្រីខ្ទឹង -ល-។

- **ថនិកសត្វ** ៖ ត្រីដូហ្វាំង ឬត្រីផ្សោតជាដើម។
- **សិប្បីសត្វ** ៖ មាន ខ្ចៅ ខ្យង គ្រំ និងលៀស -ល-។
- **ល្មូន** ៖ ក្រពើ អណ្តើក កន្ធាយ និងអន្សង -ល-។
- **គ្រួស្តាសេ** ៖ មាន កំពិស បង្គារ និងបង្កង -ល-។

▪ **សត្វរស់នៅក្នុងទឹកប្រៃ**

សត្វ ដែលរស់នៅក្នុងទឹកសមុទ្រនៃប្រទេសកម្ពុជាយើងមានដូចជា ប្រភេទត្រី ប្រសប្បីសត្វ ប្រភេទគ្រួស្តាសេ ប្រភេទល្មូន និងប្រភេទថនិកសត្វលើសពីចំនួន ៤០០ ប្រភេទ។ ប្រភេទសត្វសមុទ្រទាំងនេះ រួមមានដូចជា ៖

- **ប្រភេទត្រី** ៖ មានត្រីសូមុង ត្រីប្លាធូ ត្រីអណ្តាតឆ្កែ ត្រីតុកកែ ត្រីផ្ទោង ត្រីអណ្តែង ត្រីឆ្លាម ត្រីកន្ទុយរឹង និងត្រីឆ្លង់ -ល-។
- **ប្រភេទសិប្បីសត្វ** ៖ ខ្យង លៀស គ្រែង ងាវ និង និងមឹក -ល-។
- **ប្រភេទល្មូន** ៖ មាន កន្ធាយ ពស់ និងអណ្តើក -ល-។
- **ប្រភេទគ្រួស្តាសេ** ៖ មានគីរ បង្គារ ក្តាម និងបង្កង -ល-។
- **ប្រភេទថនិកសត្វ** ៖ មាន ត្រីដូហ្វាំង ត្រីបាឡែន និងជ្រូកសមុទ្រ-ល-។

## សំណួរត្រិះរិះ

1. តើព្រៃឈើនៅលើពិភពលោកមានប៉ុន្មានប្រភេទ? អ្វីខ្លះ?
2. តើព្រៃឈើនៅតំបន់ត្រូពិចមានប៉ុន្មានប្រភេទ? អ្វីខ្លះ?
3. តើព្រៃរងទឹកភ្លៀងត្រូពិចសំខាន់ៗនៅលើពិភពលោកមាននៅក្នុងទ្វីប និងប្រទេសណាខ្លះ?
4. តើព្រៃតំបន់ត្រជាក់បង្គួរមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់នូវប្រភេទនីមួយៗ។
5. តើព្រៃតៃកាមានលក្ខណៈដូចម្តេច? តើព្រៃប្រភេទនេះមានដុះនៅទីកន្លែងណាខ្លះ?
6. តើព្រៃឈើមានតួនាទី និងសារៈសំខាន់អ្វីខ្លះ?
7. តើព្រៃឈើនៅប្រទេសកម្ពុជាមានស្ថានភាពដូចម្តេចខ្លះ? ចូរពន្យល់។
8. តើគេបែងចែកព្រៃឈើនៅប្រទេសកម្ពុជាជាប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់។
9. តើព្រៃលិចទឹកនៅប្រទេសកម្ពុជាមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់។
10. ចូររៀបរាប់អំពីព្រៃឫស្សីនៅប្រទេសកម្ពុជា។
11. តើសត្វលើគោក និងសត្វក្នុងទឹកនៅប្រទេសកម្ពុជាមានអ្វីខ្លះ? ចូររៀបរាប់។

# មេរៀនទី ២៖ លក្ខខណ្ឌសង្គមកម្ពុជា

## ១. ការរៀបចំរដ្ឋបាលនៅកម្ពុជា

### ១.១. ស្ថាប័នព្រះមហាក្សត្រ

ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ មក ប្រទេសកម្ពុជាបានផ្លាស់ប្តូរនាមផ្លូវការប្រទេសរបស់ខ្លួនពី «រដ្ឋកម្ពុជា» មកជា «ព្រះរាជាណាចក្រកម្ពុជា» វិញ ដោយប្រកាន់យករបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ និងគោរពលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយផ្អែកលើគោលការណ៍បែងចែកអំណាចដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

ព្រះមហាក្សត្រសោយរាជ្យសម្បត្តិ ក៏ប៉ុន្តែព្រះអង្គមិនកាន់អំណាចនោះទេ ព្រះអង្គគង់ជាម្លប់ និងជានិមិត្តរូបនៃសាមគ្គីភាព និងឯកភាពជាតិខ្មែរ។ ព្រះមហាក្សត្រទ្រង់គង់ជាព្រះប្រមុខរដ្ឋអស់មួយជីវិត ហើយគ្មានបុគ្គលណាម្នាក់ ហ៊ានរំលោភបំពានលើព្រះអង្គបាននោះឡើយ។

### ក. ការជ្រើសតាំងព្រះមហាក្សត្រ

របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញនៅព្រះរាជាណាចក្រកម្ពុជាយើង គឺជារបបជ្រើសតាំង។ ព្រះមហាក្សត្រទ្រង់មិនមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទ សម្រាប់គ្រងរាជសម្បត្តិឡើយ។ ការជ្រើសរើស ឬជ្រើសតាំងព្រះមហាក្សត្រថ្មី នៃព្រះរាជាណាចក្រកម្ពុជាត្រូវបានសម្រេចឡើង ដោយក្រុមប្រឹក្សារាជសម្បត្តិ ដែលមានសមាសភាពដូចជា ៖

- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និង គណៈធម្មយុត្តិកនិកាយ
- អនុប្រធានទី១ និង អនុប្រធានទី២ ព្រឹទ្ធសភា
- អនុប្រធានទី១ និង អនុប្រធានទី២ រដ្ឋសភា។

បុគ្គលដែលត្រូវបានជ្រើសរើសជាព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាសមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មយ៉ាងតិច ៣០ ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រអង្គឌួង ឬព្រះមហាក្សត្រនរោត្តម ឬក៏ព្រះមហាក្សត្រស៊ីសុវត្ថិ ហើយត្រូវបានក្រុមប្រឹក្សារាជសម្បត្តិចំនួនមួយ ១/៣ ស្នើសុំជាបេក្ខជន ទើបរាជវង្សអង្គនោះមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រះមហាក្សត្រ ដើម្បីឱ្យក្រុមប្រឹក្សារាជសម្បត្តិបោះឆ្នោត។ ការបោះឆ្នោតជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាផ្លូវការ ត្រូវសម្រេចទៅតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាសភាពក្រុមប្រឹក្សារាជសម្បត្តិទាំងអស់នោះ។

### ខ. រាជកិច្ច និងតួនាទីព្រះមហាក្សត្រ

ព្រះមហាក្សត្រមានរាជកិច្ច និងតួនាទីជាច្រើនដូចជា ៖

- ទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។

- ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់។
- ទ្រង់ទទួលធ្វើសវនាការជាផ្លូវការពីរដងក្នុងមួយខែឱ្យនាយកមន្ត្រី និងគណៈរដ្ឋមន្ត្រីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាបអំពីសភាពការណ៍ នៃប្រទេសជាតិ។
- ទ្រង់គង់ជាអធិបតី នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
- ទ្រង់គង់ជាអគ្គមេបញ្ជាការកំពូល នៃកងយោធពលខេមរភូមិន្ទ។
- ទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រី ក្រោយពីរដ្ឋសភាបានបោះឆ្នោតទុកចិត្ត តាមមតិភាគច្រើនដាច់ខាត(៥០%+១)។
- ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ ស៊ីវិល និងយោធា ឯកអគ្គរាជទូត តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី។
- ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់។
- ទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំព្រះរាជាណាចក្រកម្ពុជា។

ចំណែកឯព្រះជាយានៃព្រះមហាក្សត្រមានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះមហេសីពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំក្នុងរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ។ ព្រះមហេសីទុកព្រះរាជកាយពលបំពេញព្រះរាជភារៈបម្រើប្រយោជន៍សង្គម មនុស្សធម៌ សាសនា និងជួយព្រះមហាក្សត្រ ក្នុងព្រះរាជកាតព្វកិច្ចផ្នែកពិធីការ និងការទូត។

## ១.២. ប្រព័ន្ធនយោបាយ

ស្ថាប័ននយោបាយនៅព្រះរាជាណាកម្ពុជាយើងត្រូវបានបែងចែកជា ៣ អំណាចដាច់ដោយឡែកពីគ្នាគឺ ៖

### ក. អំណាចនីតិប្បញ្ញត្តិ

អំណាចនេះត្រូវបានអមដោយស្ថាប័ន ២ ទៀតគឺ ស្ថាប័នព្រឹទ្ធសភា និងស្ថាប័នរដ្ឋសភាដែលជាស្ថាប័នកំពូលនៃប្រទេសជាតិ និងជាតំណាងជាន់ខ្ពស់របស់ប្រជារាស្ត្រកម្ពុជា។

**១. ព្រឹទ្ធសភា**

**១.១. ការរៀបចំព្រឹទ្ធសភា**

ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាមានប្រធាន ១រូប អនុប្រធាន ២រូប និងសមាជិកជាច្រើនរូប។ ចំនួនសមាជិកព្រឹទ្ធសភាមានយ៉ាងច្រើនស្មើនឹងពាក់កណ្តាល នៃសមាជិករដ្ឋសភាទាំមូល។ សមាជិកព្រឹទ្ធសភាខ្លះត្រូវបានតែងតាំង និងខ្លះទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។ សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និងជ្រើសរើសសារជាថ្មីបាន។ នីតិកាលរបស់ព្រឹទ្ធសភាមានមានរយៈពេល ៦ ឆ្នាំ ប៉ុន្តែនីតិកាលទី១ មានមានរយៈពេលកំណត់ត្រឹមតែ ៥ ឆ្នាំប៉ុណ្ណោះ។ ការរៀបចំជ្រើសតាំង នៃសមាជិកព្រឹទ្ធសភាមានដូចខាងក្រោម ៖

- សមាជិកព្រឹទ្ធសភាចំនួន ២ រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ
- សមាជិកព្រឹទ្ធសភាចំនួន ២ រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើន
- សមាជិកព្រឹទ្ធសភាឯទៀតត្រូវបានជ្រើសតាំង ដោយការបោះឆ្នោតអសកល។

បុគ្គល ដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភាបាន គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត ត្រូវមានអាយុយ៉ាងតិច ៤០ ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត។

**១.២. តួនាទីរបស់ព្រឹទ្ធសភា**

ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាមានតួនាទីសំខាន់ៗដូចជា ៖

- **តួនាទីក្នុងការផ្ដល់មតិយោបល់លើនីតិកម្ម**

នៅក្នុងតួនាទីនេះ ព្រឹទ្ធសភាជាអ្នកពិនិត្យ និងផ្ដល់មតិយោបល់លើអត្ថបទច្បាប់ដែលអនុម័តដោយរដ្ឋសភា និងផ្ដួចផ្ដើមធ្វើសេចក្ដីស្នើច្បាប់។ តួនាទីសំខាន់របស់ព្រឹទ្ធសភា គឺការពិនិត្យឡើងវិញរាល់អត្ថបទច្បាប់ទាំងឡាយដែលរដ្ឋសភាបានអនុម័តរួចហើយ។

- **តួនាទីត្រួតពិនិត្យលើសកម្មភាពនានារបស់រដ្ឋាភិបាល**

ព្រឹទ្ធសភាអាចតាមដាន ត្រួតពិនិត្យមើលការងារ និងការអនុវត្តន៍គោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាល ពិសេសត្រួតពិនិត្យការប្រើប្រាស់ថវិកាជាតិរបស់រាជរដ្ឋាភិបាល។ ព្រឹទ្ធសភាក៏មានតួនាទីត្រួតពិនិត្យយ៉ាងទៀតទាត់ផងដែរ នូវការអនុវត្តន៍ច្បាប់របស់ស្ថាប័ននីតិប្រតិបត្តិ និងត្រួតពិនិត្យការអនុវត្តន៍កម្មវិធី និងផែនការរបស់រាជរដ្ឋាភិបាលលើការងារប្រជាធិបតេយ្យ នីតិរដ្ឋ ការងារកែទម្រង់រដ្ឋ ការងារកាត់បន្ថយភាពក្រីក្រ ការងារអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច។

- **តួនាទីជាតំណាង**

នៅក្នុងតួនាទីនេះ ព្រឹទ្ធសភាមានតួនាតំណាងឱ្យ ៖

- តំណាងសមូហភាពដែនដី(ក្រុមប្រឹក្សាឃុំ-សង្កាត់)
- តំណាងស្ថាប័នជាតិ (តំណាងព្រះមហាក្សត្រ និងរដ្ឋសភា)។

**២. រដ្ឋសភា**

**២.១. ការរៀបចំរដ្ឋសភា**

រដ្ឋសភា គឺជាអង្គការកំពូលតំណាងឱ្យប្រជាពលរដ្ឋ ដែលមានអំណាចនីតិប្បញ្ញត្តិ។ តំណាងរាស្ត្រនៅក្នុងរដ្ឋសភាជាតំណាងឱ្យប្រជាជាតិខ្មែរទាំងមូលដែលកើតចេញពីការបោះឆ្នោតជាតិជាសកលដោយសេរី និងជាសម្ងាត់ពីប្រជាពលរដ្ឋខ្មែរ។ នីតិកាលរបស់រដ្ឋសភាមានរយៈពេល ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។

**២.២. តួនាទីរបស់រដ្ឋសភា**

រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាមានតួនាទីសំខាន់ៗដូចជា ៖

- **ការអនុម័តផ្សេងៗ**

នៅក្នុងតួនាទីនេះ រដ្ឋសភាមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ អនុម័តលើថវិកាជាតិ ផែនការរដ្ឋការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចីការ សន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោល

ពន្ធដារជាដើម។ លើសពីនេះទៅទៀត រដ្ឋសភាក៏មានតួនាទីផ្តល់នូវសេចក្តីយល់ព្រម ចំពោះគណនីរដ្ឋបាល និងអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ព្រមទាំងមានសិទ្ធិអនុម័តលើច្បាប់ស្តីពីការប្រកាសសង្គ្រាមផងដែរ។

- **តួនាទីទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល**

នៅក្នុងតួនាទីនេះរដ្ឋសភាមានសិទ្ធិបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកសភាទាំងមូល និងមានសិទ្ធិអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយ ឱ្យមកបំភ្លឺរដ្ឋសភាអំពីបញ្ហា ដែលមានសារៈសំខាន់ពិសេស។ រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិស្តីបន្ទោសតាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិកទាំងមូល។ ញត្តិស្តីបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រយ៉ាងតិច ៣០នាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។ លើសពីនេះទៀត រដ្ឋសភាមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាលដោយសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។

- **តួនាទីទំនាក់ទំនងជាមួយប្រជាពលរដ្ឋ**

នៅក្នុងតួនាទីនេះ សមាជិករដ្ឋសភាត្រូវចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋ ជួយដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋនៅតាមមណ្ឌលរៀងៗខ្លួន ឬតាមខេត្តទាំងឡាយនៅទូទាំងប្រទេស ឱ្យអស់លទ្ធភាព និងត្រូវទាក់ទងជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

### ២.៣. វិសមភាព និងអភ័យឯកសិទ្ធិរដ្ឋសភា

តំណាងរាស្ត្រ មិនអាចបំពេញមុខងារជាសមាជិករដ្ឋសភាផង និងជាសមាជិកព្រឹទ្ធសភាផងស្របពេលតែមួយបានឡើយ។ សមាជិកសភា មានវិសមតិភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ វៀរលែងតែបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរដ្ឋាភិបាល។ ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា។

ដើម្បីឱ្យសមាជិកសភាបំពេញ នូវតួនាទីជាតំណាងប្រជាពលរដ្ឋ និងប្រជាជាតិបានល្អប្រសើរ រដ្ឋធម្មនុញ្ញ បានផ្តល់អភ័យឯកសិទ្ធិសភាជូនសមាជិកសភា។ តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ អភ័យឯកសិទ្ធិនេះ ជានាឯករាជ្យភាពរបស់សមាជិកសភា។ តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុអំពីបានសំដែងយោបល់ ឬបញ្ចេញមតិ នៅក្នុងការបំពេញមុខងាររបស់ខ្លួននោះឡើយ។

- **គណៈកម្មាធិការអចិន្ត្រៃយ៍**

គណៈកម្មាធិការអចិន្ត្រៃយ៍ នៃរដ្ឋសភាត្រូវបានបង្កើតឡើង ដើម្បីធានាដំណើរការរដ្ឋសភាក្នុងចន្លោះសម័យប្រជុំ និងសម្រេចអំពីរបៀបវារៈប្រជុំពេញអង្គ និងកិច្ចការធំៗរបស់រដ្ឋសភា។ ខាងក្រោមនេះគឺសមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍មានដូចតទៅ៖

- ប្រធានរដ្ឋសភា
- អនុប្រធានទាំងពីរ

- ប្រធានគណៈកម្មការនានានៃរដ្ឋសភា។

រដ្ឋសភាបង្កើតគណៈកម្មការជំនាញនានាចំនួន ១០ ដើម្បីទទួលពិនិត្យមើលសេចក្ដីស្នើច្បាប់ ឬសេចក្ដីព្រាងច្បាប់នានា និងជាពិសេសទទួលបន្ទុកទៅតាមមុខជំនាញរបស់ខ្លួន ក្នុងការត្រួតមើលទៅលើកិច្ចការរបស់រាជរដ្ឋាភិបាល។ សមាសភាព នៃគណៈកម្មការជំនាញនីមួយៗមានសមាជិក ៧ រូបយ៉ាងតិច។

- **គណៈកម្មាធិការអចិន្ត្រៃយ៍**

គណៈកម្មការជំនាញទាំង ១០ របស់រដ្ឋសភាមានដូចខាងក្រោម ៖

- គណៈកម្មការការពារសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា
- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
- គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
- គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ
- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
- គណៈកម្មការនីតិកម្ម និងយុត្តិធម៌
- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍
- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី
- គណៈកម្មការសាធារណៈការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ និងថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគររូបនីយកម្ម និងសំណង់
- គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ។

## ខ. អំណាចនីតិប្រតិបត្តិ

អំណាចនេះ គឺជាស្ថាប័ន ដែលជាអ្នកអនុវត្តនូវច្បាប់គ្រប់គ្រងសង្គមជាតិដោយផ្ទាល់ ពោលគឺជារាជរដ្ឋាភិបាល។ រដ្ឋបាលដែនដីរបស់ប្រទេសមាននៅថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន។ រដ្ឋបាលថ្នាក់កណ្ដាល ឬថ្នាក់ជាតិ គឺនៅទីស្ដីការគណៈរដ្ឋមន្ត្រី ទីស្ដីការក្រសួង ទីស្ដីការរដ្ឋលេខាធិការដ្ឋាន និងទីស្ដីការស្ថាប័នរដ្ឋដទៃទៀត ដែលភាគច្រើនស្ថិតនៅរាជធានីភ្នំពេញ។ រដ្ឋបាលថ្នាក់មូលដ្ឋាន ឬថ្នាក់ក្រោមជាតិ គឺនៅតាមទីតំបន់ដូចជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

### ១. រដ្ឋបាលថ្នាក់ជាតិ

### ១.១. រាជរដ្ឋាបាល

គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលជាអ្នកគ្រប់គ្រងប្រទេសដោយផ្ទាល់ ដឹកនាំការកសាង និងពង្រឹងសេដ្ឋកិច្ចជាតិសំដៅអភិវឌ្ឍប្រទេសជាតិទាំងមូលលើគ្រប់វិស័យ។ រាជរដ្ឋាភិបាលមានសិទ្ធិដឹកនាំការងារនយោបាយផង និងការងាររនៅស្ថាប័នរដ្ឋបាលផង។

### ១.២. បែបបទនៃការរៀបចំរាជរដ្ឋាភិបាល

ក្រោយពេលបោះឆ្នោតជាតិជ្រើសតាំងតំណាងរាស្ត្រ ដោយប្រជាពលរដ្ឋខ្មែរជាសកល ដោយសេរី ស្មើភាព និងជាសម្ងាត់រួចមក មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធានអនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា។

បន្ទាប់មក តាមសេចក្តីស្នើសុំរបស់ប្រធានរដ្ឋសភា ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់បានចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត ដើម្បីឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះបាននាំសហការី ដែលជាតំណាងរាស្ត្រជាសមាជិកគណបក្សនៅក្នុងរដ្ឋសភាឱ្យផ្គូរផ្គងកាន់តំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាលទៅស្នើសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបោះឆ្នោតទុកចិត្ត តាមមតិភាគច្រើនដាច់ដាច់ (៥០%+១)នៃចំនួនសមាជិករដ្ឋសភាទាំងមូលរួចហើយ ព្រះមហាក្សត្រទ្រង់បានចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ ប្រសិនបើធ្វើតាមនីតិវិធីខាងលើនេះ មិនបានទៅតាមសំណើរបស់គណបក្ស ដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភានោះទេ អាចមានដំណើរការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នាផងដែរ និងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល។

### ១.៣. សមាសភាពរាជរដ្ឋាភិបាល

ក្នុងជួររាជរដ្ឋាភិបាលមានសមាសភាពដូចជា នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីជាប្រមុខនៃរាជរដ្ឋាភិបាល រីឯឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី គឺជាសមាជិករបស់រាជរដ្ឋាភិបាល។ ឧបនាយករដ្ឋមន្ត្រីមានអាសនានុក្រមលើសមាជិកដទៃទៀត។ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមិនមែនជាសមាជិករាជរដ្ឋាភិបាលទេ ហើយក៏មិនមែនជាភ្នាក់ងាររដ្ឋបាលអចិន្ត្រៃយ៍ផងដែរ។

### ១.៤. មុខងារ និងតួនាទីសំខាន់ៗរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលមានតួនាទី និងមុខងារសំខាន់ៗដូចជា ៖

- កំណត់ និងអនុវត្តនយោបាយ ព្រមទាំងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ តាមកម្មវិធីនយោបាយ និងផែនការរដ្ឋដែលបានអនុម័តស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ។
- ធានាការអនុវត្តន៍ច្បាប់ ដែលស្ថាប័ននីតិប្បញ្ញត្តិបានអនុម័តឱ្យមានប្រសិទ្ធភាព ដើម្បីធ្វើឱ្យសង្គមមានភាពសុខសាន្ត និងរីកចម្រើន ក្លាយទៅជាប្រទេសមាននីតិរដ្ឋ។
- គ្រប់គ្រងបញ្ជា ប្រើប្រាស់យោធា នគរបាល កម្លាំងប្រដាប់អាវុធផ្សេងៗទៀត និងរដ្ឋបាលក្នុងការធ្វើសកម្មភាពរបស់ខ្លួន។

### ១.៥. ការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល

សមាជិកទាំងឡាយ នៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នា ចំពោះរដ្ឋសភាអំពីនយោបាយទូទៅរបស់រដ្ឋាភិបាល។ សមាជិកមួយរូបៗ ទទួលខុសត្រូវរៀងៗខ្លួន ចំពោះនាយករដ្ឋមន្ត្រីនិង ចំពោះរដ្ឋសភាអំពី

ការ ដែលខ្លួនបានប្រព្រឹត្ត។ សមាជិកទាំងឡាយ នៃរាជរដ្ឋាភិបាលមិនអាចយកសំអាង នៃសេចក្ដីបង្គាប់ជាលាយលក្ខណ៍អក្សរ ឬដោយវាចាអំពីនរណាមួយ ដើម្បីដោះសាឱ្យរួចពីការទទួលខុសត្រូវរបស់ខ្លួនបាននោះឡើយ។

**២. រដ្ឋបាលថ្នាក់ក្រោមជាតិ**

**២.១. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានរាជធានីចំនួន១ ខេត្តចំនួន២៤ ក្រុងចំណួន២៧ ស្រុកចំនួន១៦២ ខណ្ឌចំនួន១៤ និងឃុំ សង្កាត់សរុបទាំងអស់ចំនួន ១៦៤៦។

**២.១.១ រចនាសម្ព័ន្ធរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈអភិបាល ហើយមាននាយករដ្ឋបាល ដែលមានតួនាទីជាជំនួយការឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការចាត់ចែងកិច្ចការរដ្ឋបាលនិងធានានិរន្តរភាពកិច្ចការរដ្ឋបា លប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។

សាលារាជធានី ខេត្ត មានទីចាត់ការមួយចំនួនជាចំណុះ ដែលស្ថិតនៅក្រោមការដឹកនាំគ្រប់គ្រងផ្ទាល់ដោយនាយករដ្ឋបាល។ ទីចាត់ការនីមួយៗ មាននាយកទីចាត់ការមួយរូប និងនាយករងទីចាត់ការ ២ រូប ដែលទទួលខុសត្រូវដោយផ្ទាល់ចំពោះនាយករដ្ឋបាល។ ទីចាត់ការនីមួយៗ មានការិយាល័យមួយចំនួនចំណុះ ដែលដឹកនាំដោយប្រធាន ១ រូប និងអនុប្រធាន ២ រូប។ ការិយាល័យនីមួយៗ មានតួនាទីធ្វើជាសេនាធិការឱ្យនាយកទីចាត់ការ និងមានការទទួលខុសត្រូវដោយផ្ទាល់ចំពោះនាយកទីចាត់ការរបស់ខ្លួន និងចំពោះនាយករដ្ឋបាល នៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។

**២.១.២. គណៈអភិបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានគណៈអភិបាលរៀងៗខ្លួន។ គណៈអភិបាលរួមមានដូចជាអភិបាល និងអភិបាលរងមួយចំនួន។ រាជធានីភ្នំពេញមានគណៈអភិបាលយ៉ាងច្រើនចំនួន ៧ រូប ខេត្តមានចំនួនពី ៣ រូបទៅ ៧ រូប ចំណែកឯក្រុង ស្រុក ខណ្ឌវិញមានចំនួនចាប់ពី ៣ រូបទៅ ៥ រូប។

អភិបាលរាជធានី និងខេត្តត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី និងតាមសេចក្ដីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រីឯអភិបាលរងរាជធានី ខេត្តអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ចំពោះអាណត្តិរបស់អភិបាល និងអភិបាលរងមិនលើសពី ៤ ឆ្នាំ ក៏ប៉ុន្តែអាចតែងតាំង ៤ ឆ្នាំទៀត សម្រាប់អាណត្តិទី ២ នៅដែនសមត្ថកិច្ចដដែល។

គណៈអភិបាលជាសេនាធិការ ជាអ្នកអនុវត្តសេចក្ដីលើសម្រេច និងជាអ្នកផ្ដល់យោបល់ដល់ក្រុមប្រឹក្សា ដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវការអនុវត្តមុខងារសិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន
ស្របទៅតាមច្បាប់។

**២.២. ឃុំ សង្កាត់**

**២.២.១. រចនាសម្ព័ន្ធរដ្ឋបាល ឃុំ សង្កាត់**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ជាចៅសង្កាត់។ មេឃុំ ចៅសង្កាត់មានជំនួយការពីររូប គឺជំទប់ទី១ មួយរូប និងជំទប់ទី២ មួយរូប ឬចៅសង្កាត់រងទី១ មួយរូប និងចៅសង្កាត់រងទី២ មួយរូប ហើយមានសិទ្ធិចាត់តាំងគណៈកម្មាធិការនានា ដែលអាចយកសមាជិកក្រុមប្រឹក្សា ឬអាចយកប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួនឱ្យធ្វើជាប្រធានក៏បាន ដើម្បីផ្តល់យោបល់ និងជួយកិច្ចការផ្សេងៗ ព្រមទាំងអាចជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងអាណត្តិ ដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការចាំបាច់។ ឃុំ សង្កាត់មានស្មៀនដែលត្រូវបានតែងតាំងឡើង ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ឃុំ សង្កាត់នីមួយៗ មានមេភូមិដែលជ្រើសរើសដោយក្រុមប្រឹក្សាឃុំសង្កាត់។

### ២.២.២. តួនាទី សិទ្ធិអំណាចនៃរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយបានចាត់ចែងប្រើប្រាស់ធនធាននានា ដែលមានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការនៅក្នុងឃុំ សង្កាត់របស់ខ្លួនបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងផលប្រយោជន៍របស់ជាតិ តាមនយោបាយទូទៅរបស់ រដ្ឋាភិបាល។

ឃុំ សង្កាត់មានតួនាទី ២ ប្រភេទគឺ ៖

- **មុខងារមូលដ្ឋាន ៖** មុខងារនេះ ជាមុខងារដែលបម្រើកិច្ចការមូលដ្ឋាន សម្រាប់ផលប្រយោជន៍ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន។
- **មុខងារតំណាងរដ្ឋ** ៖ មុខងារនេះ ជាមុខងា ដែលដើរតួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

### ២.២.៣. ផែនការអភិវឌ្ឍឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័ត និងអនុវត្តផែនការអភិវឌ្ឍ ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍឃុំ សង្កត់របស់ខ្លួន ហើយត្រូវស្របទៅនឹងផែនការអភិវឌ្ឍ សេដ្ឋកិច្ចសង្គមរបស់ជាតិ។

## គ. អំណាចតុលាការ

អំណាចនេះ គឺជាអំណាចឯករាជ្យដែលមានតួនាទីធានារក្សា និងការពារនូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យ នៃតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាអ្នកជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។ ការជំនុំជម្រះក្តី ដែលផ្តល់យុត្តិធម៌ត្រូវធ្វើឡើងនៅក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ មានតែអង្គចៅក្រមប៉ុណ្ណោះដែលមានសិទ្ធិធ្វើការជំនុំជម្រះក្តីបាន។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ជាទីបំផុត អស់ពីដួងចិត្ត និងប្រកបដោយសម្បជញ្ញៈរបស់ខ្លួន។

អំណាចតុលាការគ្រប់ដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។ អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ មានតែអង្គការអយ្យការប៉ុណ្ណោះទើបមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជារួមមាន សាលាដំបូងរាជធានី ខេត្ត តុលាការ

យោធា សាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ត្រូវជំនុំជម្រះដោយផ្អែកទៅលើច្បាប់ជាធរមាន។

នៅសាលាជម្រះក្តីជាន់ទាបនីមួយៗ មានអយ្យការនៅអម ចំណែកឯនៅសាលាជម្រះក្តីជាន់ខ្ពស់នីមួយៗវិញ មានមហាអយ្យការនៅអម។ ក្នុងរឿងព្រហ្មទណ្ឌ ក្រុមអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា និងធ្វើសេចក្តីសន្និដ្ឋានទោស ដោយតាំងខ្លួនជាគូក្តីដើមជាដរាប។ នៅក្នុងរឿងរដ្ឋប្បវេណី និងរឿងក្តីផ្សេងៗទៀត ក្រុមអយ្យការជាគូក្តីវណបគឺគ្រាន់តែជាអ្នកផ្តល់យោបល់ បើយល់ថាជាការគួរ។ ក៏ប៉ុន្តែ នៅក្នុងរឿងខ្លះដែលទាក់ទងរបៀបរៀបរយសាធារណៈ ក្រុមអយ្យការត្រូវតាំងខ្លួនជាគូក្តីដើម។

អំណាចតុលាការនៅព្រះរាជាណាចក្រកម្ពុជាយើងមាន ២ ថ្នាក់គឺ តុលាការជាន់ទាប និងតុលាការជាន់ខ្ពស់។

### ១. តុលាការជាន់ទាប (សាលាជំនុំជម្រះក្តីជាន់ទាប)

តុលាការជាន់ទាបនៅប្រទេសកម្ពុជារួមមាន សាលាដំបូងរាជធានី ខេត្ត និងតុលាការយោធា។ សាលាដំបូងរាជធានី ខេត្ត តាំងនៅរាជធានី ខេត្តនីមួយៗមានសមត្ថកិច្ចលាតសន្ធឹងលើដែនដី នៃរាជធានី ខេត្តទាំងនោះ។ តុលាការយោធា ដែលត្រូវតាំងនៅរាជធានីភ្នំពេញ មានសមត្ថកិច្ចលាតសន្ធឹងលើដែនដី នៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។

### ១.១. សាលាដំបូងរាជធានី ខេត្ត

សាលាដំបូងរាជធានី ខេត្ត មានសមត្ថកិច្ចជំនុំជម្រះបើកផ្លូវឧទ្ធរណ៍នូវរឿងក្តីព្រហ្មទណ្ឌ រឿងក្តីរដ្ឋប្បវេណី រឿងក្តីពាណិជ្ជកម្ម រឿងក្តីវិវាទរដ្ឋបាល និងរឿងក្តីវិវាទការងារ។ នៅក្នុងរឿងក្តីព្រហ្មទណ្ឌ សាលាដំបូងរាជធានី ខេត្ត មានសមត្ថកិច្ចជំនុំជម្រះជាក្រុមប្រឹក្សាជំនុំជម្រះ ដែលមានចៅក្រម ៣ រូបចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង ក៏ប៉ុន្តែសាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទមជ្ឈិម និងបទលហុ។

### ១.២. តុលាការយោធា

តុលាការយោធា មានសមត្ថកិច្ចជំនុំជម្រះបើកផ្លូវឧទ្ធរណ៍នូវបទល្មើសយោធា។ បទល្មើសយោធាគឺជាបទល្មើស ដែលប្រព្រឹត្តឡើងដោយយោធិននៅក្នុងជួរកងទ័ព ហើយដែលពាក់ពន្ធ័នឹងវិន័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ។ នៅក្នុងករណីយោធិនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌសាមញ្ញត្រូវសាលាដំបូងរាជធានី ខេត្តជំនុំជម្រះ។ នីតិវិធីរបស់តុលាការយោធាដូចគ្នាទៅនឹងនីតិវិធីរបស់សាលាដំបូងរាជធានី ខេត្តដែរ។

### ២. តុលាការជាន់ខ្ពស់ (សាលាជំនុំជម្រះក្តីជាន់ខ្ពស់)

សាលាឧទ្ធរណ៍ និងតុលាការកំពូលជាសាលាជម្រះក្តីជាន់ខ្ពស់។ សាលាឧទ្ធរណ៍មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីតាមតំបន់នៃប្រទេសកម្ពុជា ចំណែកឯតុលាការកំពូលមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។

### ២.១. សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះក្តីលើបណ្តឹងឧទ្ធរណ៍ ពីសាលក្រមរបស់សាលាដំបូងរាជធានីខេត្ត និងតុលាការយោធា ដោយបើកផ្លូវឱ្យប្តឹងសារទុក្ខព្រមទាំងមានសមាសភាពចៅក្រម ៣ រូប ក្រុម) (ប្រឹក្សាជំនុំជម្រះ ដែលមានម្នាក់ធ្វើជាប្រធាន និងអមដោយអគ្គព្រះរាជអាជ្ញាម្នាក់ ឬអគ្គព្រះរាជអាជ្ញារងម្នាក់ និងក្រឡាបញ្ជីម្នាក់។

បច្ចុប្បន្ននេះ យើងមានសាលាឧទ្ធរណ៍ចំនួន ៤ ដែលរួមមានដូចជា សាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍ត្បូងឃ្មុំ សាលាឧទ្ធរណ៍បាត់ដំបង និងសាលាឧទ្ធរណ៍ព្រះសីហនុ។

### ២.២. តុលាការកំពូល

តុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើរឿងបណ្តឹងសារទុក្ខ អំពីសាលដីការបស់សាលាឧទ្ធរណ៍ដោយជំនុំជម្រះតែលើអង្គច្បាប់ មិនជំនុំជម្រះលើអង្គហេតុនោះឡើយ ហើយមានសមាសភាពចៅក្រម ៥ រូប (ក្រុមប្រឹក្សាជំនុំជម្រះ) ដែលមានម្នាក់ធ្វើជាប្រធាន និងអមដោយព្រះអគ្គព្រះរាជអាជ្ញាម្នាក់ ឬអគ្គព្រះរាជអាជ្ញារងម្នាក់ និងក្រឡាបញ្ជីម្នាក់។ ក៏ប៉ុន្តែតុលាការកំពូលជំនុំជម្រះទាំងអង្គច្បាប់ និងអង្គហេតុ ដោយមានសមាសភាពចៅក្រមប្រាំបួន ៩ រូប ដែលមានម្នាក់ធ្វើជាប្រធាន និងអមដោយអគ្គព្រះរាជអាជ្ញាម្នាក់ ឬអគ្គព្រះរាជអាជ្ញារងម្នាក់ និងក្រឡាបញ្ជីម្នាក់នៅក្នុងករណីមាន បណ្តឹងសារទុក្ខលើកទី២។ សេចក្តីសម្រេចរបស់តុលាការកំពូលហៅថា **សាលដីកា** ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

តុលាការកំពូលមានសមត្ថកិច្ចពិសេសមួយទៀត គឺជំនុំជម្រះលើបណ្តឹងសើរើ។ បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម និងសាលដីកាដែលស្ថាពរ ដែលមានអាជ្ញាអស់ជំនុំ។ សភាពេញអង្គនៃតុលាការកំពូលមានសមត្ថកិច្ចលើបណ្តឹងសើរើ។ បណ្តឹងសើរើអាចត្រូវធ្វើបានក្នុងរឿងព្រហ្មទណ្ឌទោះបីតុលាការដែលបានសម្រេចនោះជាតុលាការណាក៏ដោយ និងទោះបីទោសដែលប្រកាសនោះជាទោសអ្វីក៏ដោយ។

### ១.៣. ការរៀបចំរដ្ឋបាល

បច្ចុប្បន្ននេះ តំបន់រដ្ឋបាលនៃប្រទេសកម្ពុជាត្រូវបានបែងចែកជា រាជធានី ១ ខេត្តចំនួន ២៤ ក្រុងចំនួន ២៨ ស្រុកចំនួន ១៦២ ឃុំ-សង្កាត់ចំនួន ១៦៤៦ (សង្កាត់ ២៤១) និងភូមិទាំងអស់ចំនួន ១៤ ៣៩៤។ ខេត្តទាំង ២៤ នៅប្រទេសកម្ពុជាត្រូវបានបែងចែកទៅជា ក្រុង ស្រុក ខណ្ឌ ចំណែកឯ ក្រុង ស្រុក ខណ្ឌទាំងនេះត្រូវបានបែងចែកបន្តទៅជាឃុំ សង្កាត់។ ចុងក្រោយ ឃុំ សង្កាត់ត្រូវបានបែងចែកបន្តជាភូមិតទៅទៀត។ នៅក្នុងខេត្តនីមួយៗមានទីរួមខេត្តមួយដែលគេឱ្យឈ្មោះថា ក្រុង។ ខេត្តខ្លះ ក្រុង ហើយនិងខេត្តមានឈ្មោះដូចគ្នា ចំណែកឯខេត្តខ្លះទៀត ក្រុង និងខេត្តមានឈ្មោះផ្សេងគ្នា។ ទន្ទឹមគ្នានេះដែរ នៅប្រទេសកម្ពុជា ខេត្តខ្លះមានស្រុកច្រើន តែមានក្រុងមួយប៉ុណ្ណោះ រីឯខេត្តខ្លះទៀតមានស្រុកច្រើន តែមានក្រុងចំនួន ៣។ ខេត្តខ្លះ មានស្រុកមិនច្រើននោះទេ តែមានក្រុងចំនួន ២ និងខេត្តខ្លះទៀតមានស្រុកតិច តែក៏មានក្រុងចំនួនមួយដែរ។

### ក. រាជធានីភ្នំពេញ

ភ្នំពេញ គឺជាតំបន់រដ្ឋបាលពិសេសរបស់ប្រទេសកម្ពុជាដែលគេឱ្យឈ្មោះថា រាជធានីភ្នំពេញ។ ភ្នំពេញ គឺជាទីក្រុង ដែលមានទំហំធំជាងគេបំផុតនៅប្រទេសកម្ពុជា និងមានប្រជាជនរស់នៅច្រើនជាងគេផងដែរ។ រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលនយោបាយ វប្បធម៌ និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

រាជធានីភ្នំពេញ គឺជាបណ្ដុំ នៃសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាដូចជា ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ ធនាគារ និងគមនាគមន៍ជាដើម។

រាជធានីភ្នំពេញមានខណ្ឌសរុបទាំងអស់ចំនួន ១៤ មានសង្កាត់ចំនួន ១០៥ និងមានភូមិសរុបទាំងអស់ចំនួន ៩៥៣។ ខណ្ឌ និងសង្កាត់នៅរាជធានីភ្នំពេញរួមមានដូចខាងក្រោម ៖

- **ខណ្ឌដូនពេញ** ៖ ខណ្ឌនេះមាន ១១ សង្កាត់ដូចជា សង្កាត់ផ្សារថ្មីទី១ សង្កាត់ផ្សារថ្មីទី២ សង្កាត់ផ្សារថ្មីទី៣ សង្កាត់បឹងរាំង សង្កាត់ផ្សារកណ្ដាលទី១ សង្កាត់ផ្សារកណ្ដាលទី២ សង្កាត់ចតុមុខ សង្កាត់ជ័យជំនះ សង្កាត់ផ្សារចាស់ សង្កាត់ស្រះចក និងសង្កាត់វត្តភ្នំ។
- **ខណ្ឌចម្ការមន** ៖ ខណ្ឌនេះមាន ៥ សង្កាត់ដូចជា សង្កាត់ទន្លេបាសាក់ សង្កាត់ទួលទំពូងទី១ សង្កាត់ទួលទំពូងទី២ សង្កាត់បឹងត្របែក និងសង្កាត់ផ្សារដើមថ្កូវ។
- **ខណ្ឌ ៧ មករា** ៖ ខណ្ឌនេះមាន ៨ សង្កាត់គឺ សង្កាត់ផ្សារអូរឬស្សីទី១ សង្កាត់ផ្សារអូរឬស្សីទី២ សង្កាត់ផ្សារអូរឬស្សីទី៣ សង្កាត់ផ្សារអូរឬស្សីទី៤ សង្កាត់មនោរម្យ សង្កាត់មិត្តភាព សង្កាត់វាលវង់ និងសង្កាត់បឹងព្រលឹត។
- **ខណ្ឌទួលគោក** ៖ ខណ្ឌនេះមាន ១០ សង្កាត់គឺ សង្កាត់ផ្សារដេប៉ូទី១ សង្កាត់ផ្សារដេប៉ូទី២ សង្កាត់ផ្សារដេប៉ូទី៣ សង្កាត់ទឹកល្អក់ទី១ សង្កាត់ទឹកល្អក់ទី២ សង្កាត់ទឹកល្អក់ទី៣ សង្កាត់បឹងកក់ទី១ សង្កាត់បឹងកក់ទី២ សង្កាត់ផ្សារដើមគរ និងសង្កាត់បឹងសាឡាង។
- **ខណ្ឌដង្កោ** ៖ ខណ្ឌនេះមាន ១២ សង្កាត់ដូចជា សង្កាត់ដង្កោ សង្កាត់ពងទឹក សង្កាត់ព្រៃវែង សង្កាត់ព្រៃស សង្កាត់ក្រាំងពង្រ សង្កាត់សាក់សំពៅ សង្កាត់ជើងឯក សង្កាត់គងនយ សង្កាត់ព្រែកកំពឹស សង្កាត់ទៀន សង្កាត់រលួស និងសង្កាត់ស្ពានថ្ម។
- **ខណ្ឌមានជ័យ** ៖ ខណ្ឌនេះមាន ៧ សង្កាត់មានដូចជា សង្កាត់ចាក់អង្រែលើ សង្កាត់ចាក់អង្រែក្រោម សង្កាត់ស្ទឹងមានជ័យទី១ សង្កាត់ស្ទឹងមានជ័យទី២ សង្កាត់ស្ទឹងមានជ័យទី៣ សង្កាត់បឹងទំពន់ទី១ និងសង្កាត់បឹងទំពន់ទី២។
- **ខណ្ឌឫស្សីកែវ** ៖ ខណ្ឌនេះមាន ៧ សង្កាត់មានដូចជា សង្កាត់ស្វាយប៉ាក សង្កាត់គីឡូលេខ៦ សង្កាត់ឫស្សីកែវ សង្កាត់ច្រាំងចំរេះទី១ សង្កាត់ច្រាំងចំរេះទី២ សង្កាត់ទួលសង្កែទី១ និងសង្កាត់ទួលសង្កែទី២។
- **ខណ្ឌសែនសុខ** ៖ ខណ្ឌនេះមានចំនួន ៦ សង្កាត់មានដូចជា សង្កាត់ភ្នំពេញថ្មី សង្កាត់ទឹកថ្លា សង្កាត់ឃ្មួញ សង្កាត់ក្រាំងធ្នង់ សង្កាត់អូរបែកក្អម និងសង្កាត់គោកឃ្លាង។
- **ខណ្ឌពោធិ៍សែនជ័យ** ៖ ខណ្ឌនេះ មានចំនួន ៧ សង្កាត់មានដូចជា សង្កាត់ត្រពាំងក្រសាំង សង្កាត់សំរោងក្រោម សង្កាត់ចោមចៅទី១ សង្កាត់ចោមចៅទី២ សង្កាត់ចោមចៅទី៣ សង្កាត់កាកាបទី១ និងសង្កាត់កាកាបទី២។
- **ខណ្ឌច្បារអំពៅ** ៖ ខណ្ឌនេះមានចំនួន ៨ សង្កាត់មានដូចជា សង្កាត់និរោធ សង្កាត់ព្រែកប្រា សង្កាត់វាលស្បូវ សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ សង្កាត់ផ្សារច្បារអំពៅទី១ សង្កាត់ផ្សារច្បារអំពៅទី២ និងសង្កាត់ព្រៃថ្មី។

- **ខណ្ឌជ្រោយចង្វារ** ៖ ខណ្ឌនេះមានចំនួន ៥ សង្កាត់មានដូចជា សង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក សង្កាត់កោះដាច់ និងសង្កាត់បាក់ខែង។
- **ខណ្ឌព្រែកព្នៅ** ៖ ខណ្ឌនេះមានចំនួន ៥ សង្កាត់រួមមាន សង្កាត់ព្រែកព្នៅ សង្កាត់ពញាពន់ សង្កាត់សំរោង សង្កាត់គោករកា និងសង្កាតពន្សាំង។
- **ខណ្ឌបឹងកេងកង** ៖ ខណ្ឌនេះមានចំនួន ៧ សង្កាត់រួមមានដូចជា សង្កាត់បឹងកេងកងទី១ សង្កាត់បឹងកេងកងទី២ សង្កាត់បឹងកេងកងទី៣ សង្កាត់អូរឡាំពិក សង្កាត់ទំនប់ទឹក សង្កាត់ទួលស្វាយព្រៃទី១ និងសង្កាត់ទួលស្វាយព្រៃទី២។
- **ខណ្ឌកំបូល** ៖ ខណ្ឌនេះមានចំនួន ៧ សង្កាត់រួមមានដូចជា សង្កាត់កំបូល សង្កាត់កន្ទោក សង្កាត់ឪឡោក សង្កាត់ស្នោរ សង្កាត់ភ្លើងឆេះរទេះ សង្កាត់បឹងធំ និងសង្កាត់ប្រទះឡាង។

**ខ. ខេត្ត**

ក្រៅពីរាជធានីភ្នំពេញ ប្រទេសកម្ពុជាមានខេត្តទាំងអស់ចំនួន ២៤ មានក្រុង និងស្រុកសរុបទាំងអស់ចំនួន ១៩០ (ក្រុងចំនួន ២៨ និងស្រុកចំនួន ១៦២) មានឃុំ និងសង្កាត់សរុបទាំងអស់ចំនួន ១ ៥៤១ (សង្កាត់ចំនួន ១៣៦ និងឃុំចំនួន ១៤០៥) និងមានភូមិទាំងអស់ចំនួន ១៣ ៤៤១។ ខេត្ត ក្រុង ស្រុក និងសង្កាត់ និងឃុំទាំងនេះ រួមមានដូចខាងក្រោម ៖

**១. ខេត្តដែលមានក្រុងពីរ**

នៅព្រះរាជាណាចក្រកម្ពុជាយើង ខេត្តដែលមានក្រុង២មានចំនួន៤ខេត្តដែលរួមមានដូចខាងក្រោម ៖

**១.១. ខេត្តបន្ទាយមានជ័យ**

ខេត្តបន្ទាយមានជ័យ ជាខេត្តមួយ ដែលស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល (តំបន់ទន្លេសាប) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ២ ស្រុកចំនួន ៧ ឃុំចំនួន ៥៥ សង្កាត់ចំនួន ១០ និងភូមិចំនួន ៦៥៨។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តនេះ មានដូចខាងក្រោម ៖

- **ក្រុងសិរីសោភ័ណ** ៖ ក្រុងសិរីសោភ័ណ ជាទីរួមខេត្តរបស់ខេត្តបន្ទាយមានជ័យ។ ក្រុងនេះមាន ៧ សង្កាត់គឺ សង្កាត់កំពង់ស្វាយ សង្កាត់កោះពងសត្វ សង្កាត់ម្កាក់ សង្កាត់ភ្នៀត សង្កាត់អូរអំបិល សង្កាត់ព្រះពន្លា និងសង្កាត់ទឹកថ្លា។
- **ក្រុងប៉ោយប៉ែត** ៖ ក្រុងនេះមាន ៣ សង្កាត់រួមមាន សង្កាត់ប៉ោយប៉ែត សង្កាត់ផ្សារកណ្ដាល និងសង្កាត់និមិត្ត។
- **ស្រុកមង្គលបុរី** ៖ ស្រុកនេះមាន ១៣ ឃុំដែលរួមមាន ឃុំបន្ទាយនាង ឃុំបត់ត្រង់ ឃុំចំណោម ឃុំគោកបល្ល័ង្គ ឃុំគយម៉ែង ឃុំអូរប្រាសាទ ឃុំភ្នំតូច ឃុំរហាត់ទឹក ឃុំឫស្សីក្រោក ឃុំសម្បួរ ឃុំស្រះរាំង ឃុំសឿ និងឃុំតាឡំ។
- **ស្រុកព្រះនេត្រព្រះ** ៖ ស្រុកនេះមាន ៩ ឃុំដែលរួមមាន ឃុំឈ្នូរមានជ័យ ឃុំជប់វ៉ារី ឃុំភ្នំលៀប ឃុំប្រសាទ ឃុំព្រះនេត្រព្រះ ឃុំរហាល ឃុំទានកាំ ឃុំទឹកជោរ និងឃុំបុស្បូវ។
- **ស្រុកអូរជ្រៅ** ៖ ស្រុកនេះមាន ៧ ឃុំ ដែលរួមមាន ឃុំចង្ហារ ឃុំកូប ឃុំគុត្តសត ឃុំសំរោង ឃុំសូភី ឃុំសឹង្ហ និងឃុំអូរបីជាន់។

- **ស្រុកថ្មពួក** ៖ ស្រុកនេះមានចំនួន ៦ ឃុំ ដែលរួមមាន ឃុំបន្ទាយឆ្មារ ឃុំគោករមៀត ឃុំភូមិថ្មី ឃុំថ្មពួក ឃុំគោកកឋិន និងឃុំគំរូ។
- **ស្រុកស្វាយចេក** ៖ ស្រុកនេះមានចំនួន ៨ ឃុំ ដែលរួមមាន ឃុំផ្គាំ ឃុំសារង្គ ឃុំស្លាក្រាម ឃុំស្វាយចេក ឃុំតាបែន ឃុំតាផូ ឃុំទ្រាស និងឃុំរលួស។
- **ស្រុកម៉ាឡៃ** ៖ ស្រុកនេះមានចំនួន ៦ ឃុំ ដែលរួមមាន ឃុំបឹងបេង ឃុំម៉ាឡៃ ឃុំអូរសំព័រ ឃុំអូរស្រឡៅ ឃុំទួលពង្រ និងឃុំតាគង់។

### ១.២. ខេត្តស្វាយរៀង

ខេត្តស្វាយរៀង គឺជាខេត្តមួយដែលស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល (តំបន់វាលរាប) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ២ ស្រុកចំនួន ៦ សង្កាត់ចំនួន ១២ ឃុំចំនួន ៦៨ និងភូមិទាំងអស់មានចំនួន៦៩០។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តនេះមានដូចជា ៖

- **ក្រុងស្វាយរៀង** ៖ ក្រុងនេះ ជាទីរួមខេត្តរបស់ខេត្តស្វាយរៀង។ ក្រុងនេះ មានសង្កាត់ចំនួន ៧ ដែលរួមមានដូចជា សង្កាត់ស្វាយរៀង សង្កាត់ព្រៃឆ្លាក់ សង្កាត់គយត្របែក សង្កាត់ពោធិ៍តាហោរ សង្កាត់ចេក សង្កាត់ស្វាយតឿ និងសង្កាត់សង្ឃ័រ។
- **ក្រុងបាវិត** ៖ ក្រុងនេះមានសង្កាត់ចំនួន ៥ ដូចជា សង្កាត់បាវិត សង្កាត់បាទី សង្កាត់ច្រកម្ទេស សង្កាត់ប្រាសាទ និងព្រៃអង្គញ់។
- **ស្រុកចន្ទ្រា** ៖ ស្រុកនេះមាន ៦ ឃុំ ដែលរួមមាន ឃុំចន្ទ្រា ឃុំច្រេស ឃុំមេសរថ្ងក ឃុំព្រៃគគីរ ឃុំសំរោង និងឃុំទួលស្ដី។
- **ស្រុកកំពង់រោទ៍** ៖ ស្រុកនេះមាន ១១ ឃុំ ដែលរួមមាន ឃុំបន្ទាយក្រាំង ឃុំញរ ឃុំខ្សែត្រ ឃុំព្រៃធំឃុំព្រះពន្លា ឃុំរាជមន្ទីរ ឃុំសំឡី ឃុំសំយ៉ោង ឃុំស្វាយតាយាន ឃុំថ្មី និងឃុំត្នោត។
- **ស្រុករំដួល** ៖ ស្រុកនេះមានចំនួន ១០ ឃុំ ដែលរួមមាន ឃុំបុសមន ឃុំធ្មា ឃុំកំពង់ចក ឃុំជ្រុងពពេល ឃុំកំពង់អំពិល ឃុំម៉ឺនជ័យ ឃុំពងទឹក ឃុំសង្កែ ឃុំស្វាយចេក និងឃុំថ្នាធ្នង់។
- **ស្រុករមាសហែក** ៖ ស្រុកនេះមាន ១៦ ឃុំ ដែលរួមមាន ឃុំអំពិល ឃុំអណ្ដូងពោធិ៍ ឃុំអណ្ដូងត្របែក ឃុំអង្គប្រស្រែ ឃុំចន្ទ្រី ឃុំជ្រៃធំ ឃុំដូង ឃុំកំពង់ត្រាច ឃុំគគីរ ឃុំក្រសាំង ឃុំមុខដា ឃុំម្រាម ឃុំសម្បួរ ឃុំសម្បត្តិមានជ័យ ឃុំត្រពាំងស្ដៅ និងឃុំត្រស់។
- **ស្រុកស្វាយជ្រុំ** ៖ ស្រុកនេះមានចំនួន ១៦ ឃុំ ដែលរួមមាន ឃុំអង្គតាសូរ ឃុំបាសាក់ ឃុំចំបក់ ឃុំកំពង់ចម្លង ឃុំតាសួស ឃុំឈើទាល ឃុំដូនស ឃុំគោកព្រីង ឃុំក្រោលគោ ឃុំគ្រួស ឃុំពោធិ៍រាជ ឃុំស្វាយអង្គ ឃុំស្វាយជ្រុំ ឃុំស្វាយធំ ឃុំស្វាយយា និងឃុំធ្លក។
- **ស្រុកស្វាយទាប** ៖ ស្រុកនេះមានចំនួន ៩ ឃុំ ដែលរួមមាន ឃុំគគីរសោម ឃុំកណ្ដៀងរាយ ឃុំមនោរម្យ ឃុំពពែត ឃុំព្រៃតាអី ឃុំប្រសូត្រ ឃុំរមាំងថ្កោល ឃុំសម្បួរ និងឃុំស្វាយរំពារ។

### ១.៣. ខេត្តព្រះសីហនុ

ខេត្តព្រះសីហនុ ជាខេត្តមួយដែលមានទីតាំងស្ថិតនៅក្នុងតំបន់មាត់សមុទ្រនៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ២ ស្រុកចំនួន ៣ សង្កាត់ចំនួន ៦ ឃុំចំនួន ២៣ និងមានភូមិសរុបចំនួន ១១០។ ក្រុង សង្កាត់

ស្រុក និងឃុំនៅក្នុងខេត្តនេះមានដូចជា ៖

- **ក្រុងព្រះសីហនុ** ៖ ក្រុងនេះ ជាទីរួមខេត្តរបស់ខេត្តព្រះសីហនុ។ ក្រុងនេះ មានសង្កាត់ចំនួន ៤ ដែលរួមមាន សង្កាត់លេខ១ សង្កាត់លេខ២ សង្កាត់លេខ៣ និងសង្កាត់លេខ៤។
- **ក្រុងកោះរ៉ុង** ៖ ក្រុងនេះ មានសង្កាត់ចំនួន ២ ដែលរួមមានដូចជា សង្កាត់កោះរ៉ុងសន្លឹម និង សង្កាត់កោះរ៉ុង។
- **ស្រុកព្រៃនប់** ៖ ស្រុកនេះ មានចំនួន ១៥ ឃុំរួមមាន ឃុំអណ្ដូងថ្ម ឃុំតាព្រហ្ម ឃុំបិតត្រាង ឃុំជើងគោ ឃុំអូរជ្រៅ ឃុំអូរឧកញ៉ាហេង ឃុំព្រនប់ ឃុំរាម ឃុំសាមគ្គី ឃុំសំរុង ឃុំទឹកល្អក់ ឃុំទឹកថ្លា ឃុំទួលទទឹង ឃុំវាលរេញ និងឃុំតានៃ។
- **ស្រុកស្ទឹងហាវ** ៖ ស្រុកនេះមានចំនួន ៤ ឃុំដែលរួមមាន ឃុំកំពេញ ឃុំអូរត្រេះ ឃុំទំនប់រលក និងឃុំកែវផុស។
- **ស្រុកកំពង់សិលា** ៖ ស្រុកនេះមានចំនួន ៤ ឃុំ ដែលរួមមាន ឃុំចម្ការហ្លួង ឃុំកំពង់សិលា ឃុំអូរបាក់រទេះ និងឃុំស្ទឹងឆាយ។

### ១.៤. ខេត្តកំពត

ខេត្តកំពត គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់មាត់សមុទ្រនៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ២ ស្រុកចំនួន ៧ សង្កាត់ចំនួន ៥ ឃុំចំនួន ៨៨ និងមានភូមិសរុបទាំងអស់ចំនួន ៤៨៨។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តនេះ មានដូចជា ៖

- **ក្រុងកំពត** ៖ ក្រុងនេះ ជាទីរួមខេត្តរបស់ខេត្តកំពត។ ក្រុងនេះ មានសង្កាត់ចំនួន ៥ ដែលរួមមាន សង្កាត់កំពង់កណ្ដាល សង្កាត់ក្រាំងអំពិល សង្កាត់កំពង់បាយ សង្កាត់អណ្ដូងខ្មែរ និង សង្កាត់ត្រើយកោះ។
- **ក្រុងកោះបូកគោ** ៖ ក្រុងនេះ មានសង្កាត់ចំនួន ៣ ដែលរួមមានដូចជា សង្កាត់បឹងទូក សង្កាត់កោះតូច និងសង្កាត់ព្រែកត្នោត។
- **ស្រុកអង្គរជ័យ** ៖ ស្រុកនេះ មានចំនួន ១១ ឃុំរួមមាន ឃុំអង្គភ្នំតូច ឃុំដានគោម ឃុំអង្គរជ័យ ឃុំចំប៉ី ឃុំដំបូកខ្ពស់ ឃុំដើមដូង ឃុំម្រោម ឃុំភ្នំកុង ឃុំប្រភ្នំ ឃុំសម្លាញ និងឃុំតានី។
- **ស្រុកបន្ទាយមាស** ៖ ស្រុកនេះមានចំនួន ១៥ ឃុំ ដែលមានដូចជា ឃុំមន្ទាយមាសខាងកើត ឃុំបន្ទាយមាសខាងលិច ឃុំព្រៃទន្លេ ឃុំសំរោងក្រោម ឃុំសំរោងលើ ឃុំស្ដេចគង់ខាងជើង ឃុំស្ដេចគង់ខាងលិច ឃុំស្ដេចគង់ខាងត្បូង ឃុំត្នោតចុងស្រង់ ឃុំត្រពាំងសាលាខាងកើត ឃុំត្រពាំងសាលាខាងលិច ឃុំទូកមាសខាងកើត ឃុំទូកមាសខាងលិច ឃុំវត្តអង្គខាងជើង និងឃុំវត្តអង្គខាងត្បូង។
- **ស្រុកឈូក** ៖ ស្រុកនេះមានចំនួន ១៥ ឃុំ ដែលរួមមាន ឃុំបានៀវ ឃុំតាកែន ឃុំបឹងនិមល ឃុំឈូក ឃុំដូនយ៉យ ឃុំក្រាំងស្បូវ ឃុំក្រាំងស្នាយ ឃុំល្បើក ឃុំត្រពាំងភ្លាំង ឃុំមានជ័យ ឃុំនរាយណ៍ ឃុំសត្វពង ឃុំត្រពាំងបី ឃុំត្រមែង និងឃុំតេជោអភិវឌ្ឍន៍។
- **ស្រុកជុំគីរី** ៖ ស្រុកនេះមានចំនួន ៧ ឃុំ ដែលរួមមាន ឃុំច្រេស ឃុំជំពូវន្ត ឃុំស្នាយអញ្ជិត ឃុំស្រែចែង ឃុំស្រែក្នុង ឃុំស្រែសំរោង និងឃុំត្រពាំងរាំង។

- **ស្រុកជងទង់** ៖ ស្រុកនេះមានចំនួន ១០ ឃុំ ដែលរួមមានដូចជា ឃុំដំណាក់សុក្រំ ឃុំជងទង់ ឃុំខ្នាយខាងជើង ឃុំខ្នាយខាងត្បូង ឃុំមានរិទ្ធិ ឃុំស្រែជាខាងជើង ឃុំស្រែជាខាងត្បូង ឃុំទទង់ ឃុំអង្គរមាស និងឃុំល្អាង។
- **ស្រុកកំពង់ត្រាច** ៖ ស្រុកនេះមានចំនួន ១៤ ឃុំ ដែលរួមមានដូចជា ឃុំបឹងសាលាខាងជើង ឃុំបឹងសាលាខាងត្បូង ឃុំដំណាក់កន្ទួតខាងជើង ឃុំដំណាក់កន្ទួតខាងត្បូង ឃុំកំពង់ត្រាចខាងកើត ឃុំកំពង់ត្រាចលិច ឃុំប្រាសាទភ្នំខ្យង ឃុំភ្នំប្រាសាទ ឃុំអង្គសុរភី ឃុំព្រែកក្រឹស ឃុំឫស្សីស្រុកខាងកើត ឃុំឫស្សីស្រុកខាងលិច ឃុំស្វាយទងខាងជើង និងឃុំស្វាយទងខាងត្បូង។
- **ស្រុកទឹកឈូ** ៖ ស្រុកនេះមានចំនួន ១៣ ឃុំ ដែលរួមមានដូចជា ឃុំជុំក្រៀល ឃុំកំពង់ក្រែង ឃុំកំពង់សំរោង ឃុំកណ្ដោល ឃុំកូនសត្វ ឃុំម៉ាក់ប្រាង ឃុំព្រៃឃ្មុំ ឃុំព្រៃថ្នង ឃុំស្ទឹងកែវ ឃុំថ្មី ឃុំត្រពាំងព្រីង ឃុំត្រពាំងសង្កែ និងត្រពាំងធំ។

**២. ខេត្តដែលមានក្រុងមួយ**

ខេត្តដែលមានក្រុងចំនួនមួយនៅព្រះរាជាណាចក្រកម្ពុជាយើងមានចំនួន២០ខេត្ត ដែលរួមមានដូចខាងក្រោម ៖

**២.១. ខេត្តបាត់ដំបង**

បាត់ដំបង ជាខេត្តមួយដែលស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល (តំបន់ទន្លេសាប) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ១ ស្រុកចំនួន ១៣ ឃុំចំនួន ៩២ សង្កាត់ចំនួន ១០ និងភូមិមានសរុបចំនួន ៨២៩។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តនេះ មានដូចខាងក្រោម ៖

- **ក្រុងបាត់ដំបង** ៖ ក្រុងបាត់ដំបង គឺជាទីរួមខេត្តរបស់ខេត្តបាត់ដំបង។ ក្រុងនេះមានសង្កាត់ចំនួន ១០ ដែលរួមមាន សង្កាត់ទួលតាឯក សង្កាត់ព្រែកព្រះស្ដេច សង្កាត់រតនៈ សង្កាត់ចម្ការសំរោង សង្កាត់ស្លាកែត សង្កាត់ក្ដុលដូនទាវ សង្កាត់អូរម៉ាល់ សង្កាត់វត្តគរ សង្កាត់អូរចារ និងសង្កាត់ស្វាយប៉ោ។
- **ស្រុកបាណន់** ៖ ស្រុកនេះមានចំនួន ៨ ឃុំ ដែលរួមមាន ឃុំកន្ទឺ១ ឃុំកន្ទឺ២ ឃុំបាយដំរាំ ឃុំឈើទាល ឃុំចែងមានជ័យ ឃុំភ្នំសំពៅ ឃុំស្នឹង និងឃុំតាក្រាម។
- **ស្រុកថ្មគោល** ៖ ស្រុកនេះមាន ១០ ឃុំ ដែលរួមមាន ឃុំតាពូង ឃុំតាម៉ឺន ឃុំអូរតាគី ឃុំជ្រៃ ឃុំអន្លង់រុន ឃុំជ្រោយស្ដៅ ឃុំបឹងព្រីង ឃុំគោកឃ្មុំ ឃុំបន្សាយត្រែង និងឃុំរូងជ្រៃ។
- **ស្រុកទឹកបវេល** ៖ ស្រុកនេះមានចំនួន ៨ ឃុំ ដែលរួមមាន ឃុំបវេល ឃុំខ្នាចរមាស ឃុំល្វា ឃុំព្រៃខ្ពស់ ឃុំអំពិលប្រាំដើម ឃុំក្ដុលតាហែន ឃុំឃ្លាំងមាស និងឃុំបឹងប្រាំ។
- **ស្រុកឯកភ្នំ** ៖ ស្រុកនេះមាន ៧ ឃុំ ដែលរួមមាន ឃុំព្រែកនរិន្ទ ឃុំសំរោងក្នុង ឃុំព្រែកខ្ពប ឃុំព្រែកហ្លួង ឃុំពាមឯក ឃុំព្រៃចាស់ និងឃុំកោះជីវាំង។
- **ស្រុកមោងឫស្សី** ៖ ស្រុកនេះមានចំនួន ៩ ឃុំ ដែលរួមមាន ឃុំមោង ឃុំគារ ឃុំព្រៃស្វាយ ឃុំឫស្សីក្រាំង ឃុំជ្រៃ ឃុំតាលាស់ ឃុំកកោះ ឃុំព្រៃតូច និងឃុំរបស់មង្គល។
- **ស្រុករតនមណ្ឌល** ៖ ស្រុកនេះមាន ៥ ឃុំ ដែលរួមមាន ឃុំស្ដៅ ឃុំអណ្ដើកហែប ឃុំផ្លូវមាស ឃុំ

ត្រែង និងឃុំស្មើសង្ការ។

- **ស្រុកសង្កែ** ៖ ស្រុកនេះមានចំនួន ១០ ឃុំដែលរួមមាន ឃុំអន្លង់វិល ឃុំនរា ឃុំតាប៉ុន ឃុំកា ឃុំកំពង់ព្រះ ឃុំកំពង់ព្រៀង ឃុំរាំងកេសី ឃុំអូរដំបង១ ឃុំអូរដំបង២ និងឃុំវត្តតាមិម។
- **ស្រុកសំឡូត** ៖ ស្រុកនេះ មានចំនួន ៧ ឃុំ ដែលរួមមានដូចជា ឃុំតាតោក ឃុំកំពង់ល្ពៅ ឃុំអូរសំរិល ឃុំស៊ុងឃុំសំឡូត ឃុំមានជ័យ និងឃុំតាសាញ។
- **ស្រុកសំពៅលូន** ៖ ស្រុកនេះមាន ៦ ឃុំ ដែលរួមមាន ឃុំសំពៅលូន ឃុំអង្គរបាន ឃុំតាស្ដា ឃុំសន្តិភាព ឃុំសិរីមានជ័យ និងឃុំជ្រៃសីមា។
- **ស្រុកភ្នំព្រឹក** ៖ ស្រុកនេះមានចំនួន ៥ ឃុំ ដែលរួមមានដូចជា ឃុំភ្នំព្រឹក ឃុំពេជ្រចិន្ដា ឃុំបួរ ឃុំបារាំងធ្លាក់ និងឃុំអូររំដួល។
- **ស្រុកកំរៀង** ៖ ស្រុកនេះមាន ៦ ឃុំ ដែលរួមមាន ឃុំកំរៀង ឃុំបឹងរាំង ឃុំអូរដា ឃុំតាសែន ឃុំត្រាង និងឃុំតាក្រី។
- **ស្រុកគាស់ក្រឡ** ៖ ស្រុកនេះមានចំនួន ៦ ឃុំ ដែលរួមមាន ឃុំធិបតី ឃុំគាស់ក្រឡ ឃុំហប់ ឃុំព្រះផុស ឃុំដូនបា និងឆ្នាល់មាន់។
- **ស្រុករុក្ខគីរី** ៖ ស្រុកនេះមាន ៥ ឃុំ ដែលរួមមាន ឃុំព្រែកជីក ឃុំព្រៃត្រឡាច ឃុំមុខរាហ៍ ឃុំស្តុកប្រវឹក និងឃុំបាសាក់។

### ២.២. ខេត្តកំពង់ចាម

កំពង់ចាម គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល (តំបន់វាលរាប) នៃប្រទេសកម្ពុជា។ ខេត្តនេះមានក្រុងចំនួន ១ ស្រុកចំនួន ៩ ឃុំចំនួន ១០៥ សង្កាត់ចំនួន ៤ និងមានភូមិសរុបចំនួន ៩១៦។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តកំពង់ចាម រួមមានដូចខាងក្រោម ៖

- **ក្រុងកំពង់ចាម** ៖ ក្រុងកំពង់ចាម គឺជាទីរួមខេត្តរបស់ខេត្តកំពង់ចាម។ ក្រុងនេះ មានសង្កាត់ចំនួន ៤ ដែលរួមមានដូចជា សង្កាត់បឹងកុក សង្កាត់កំពង់ចាម សង្កាត់សំបួរមាស និងសង្កាត់វាលវង់។
- **ស្រុកបាធាយ** ៖ ស្រុកនេះមាន ១២ ឃុំ ដែលរួមមាន ឃុំបាធាយ ឃុំច្បារអំពៅ ឃុំជាលា ឃុំផ្អាវ ឃុំជើងព្រៃ ឃុំមេព្រីង ឃុំសម្បូរ ឃុំសណ្ដែក ឃុំតាំងក្រាំង ឃុំតាំងក្រសាំង ឃុំត្រប់ និងឃុំទំនប់។
- **ស្រុកចម្ការលើ** ៖ ស្រុកនេះមាន ៧ ឃុំ ដែលរួមមាន ឃុំបុសខ្នុរ ឃុំជយោ ឃុំល្វាលើ ឃុំតាអុង ឃុំស្វាយទាប ឃុំស្ពឺ និងឃុំតាប្រុក។
- **ស្រុកជើព្រៃ** ៖ ស្រុកនេះមានចំនួន ១០ ឃុំ ដែលរួមមាន ឃុំខ្នុរដំបង ឃុំគោករវៀង ឃុំផ្ដៅជុំ ឃុំព្រៃចារ ឃុំព្រីងជ្រុំ ឃុំសំពងជ័យ ឃុំស្ដើងជ័យ ឃុំសូទិប ឃុំស្រម៉រ និងឃុំត្រពាំងគរ។
- **ស្រុកកំពង់សៀម** ៖ ស្រុកនេះមាន ១៥ ឃុំ ដែលរួមមាន ឃុំអំពិល ឃុំហាន់ជ័យ ឃុំកៀនជ្រៃ ឃុំគគរ ឃុំកោះមិត្ត ឃុំកោះរកា ឃុំកោះសំរោង ឃុំកោះទទឹម ឃុំក្រឡា ឃុំអូរស្វាយ ឃុំរអាង ឃុំរំចេក ឃុំស្រក ឃុំទ្រាន និងវិហារធំ។
- **ស្រុកកងមាស** ៖ ស្រុកនេះមានចំនួន ១១ ឃុំ ដែលរួមមាន ឃុំអង្គរបាន ឃុំកងតាណឹង ឃុំពាមជី

កង ឃុំខ្ញៅ ឃុំព្រែកកុយ ឃុំព្រែកក្របៅ ឃុំរាយប៉ាយ ឃុំរកាអារ ឃុំរកាគយ ឃុំស្ដៅ និងឃុំសូរគង។

- **ស្រុកកោះសូទិន** ៖ ស្រុកនេះមានចំនួន ៨ ឃុំ ដែលរួមមាន ឃុំកំពង់រាប ឃុំកោះសូទិន ឃុំមហាលាភ ឃុំល្វេ ឃុំមហាខ្ញូង ឃុំពាមប្រធ្នស់ ឃុំពង្រ និងឃុំព្រែកតានន់។
- **ស្រុកព្រៃឈរ** ៖ ស្រុកនេះមាន ១៥ ឃុំ ដែលរួមមាន ឃុំបារាយណ៍ ឃុំជ្រៃវៀន ឃុំបឹងណាយ ឃុំខ្វិតធំ ឃុំគរ ឃុំក្រូច ឃុំល្វា ឃុំមៀន ឃុំព្រៃឈរ ឃុំសូរ្យសែន ឃុំសំរោង ឃុំស្រង៉ែ ឃុំថ្មពូន ឃុំតុងរ៉ុង និងឃុំត្រពាំងព្រះ។
- **ស្រុកស្រីសន្ធរ** ៖ ស្រុកនេះមានចំនួន ១៤ ឃុំ ដែលរួមមាន ឃុំបារាយណ៍ ឃុំជីបាល ឃុំកោះអណ្ដែត ឃុំខ្នារស ឃុំមានជ័យ ឃុំផ្ទះកណ្ដាល ឃុំប្រាំយ៉ាម ឃុំព្រែកដំបូក ឃុំព្រែកពោធិ៍ ឃុំព្រែករំដេង ឃុំឫស្សីស្រុក ឃុំស្វាយពោធិ៍ ឃុំស្វាយខ្សាច់ភ្នំ និងឃុំទងត្រឡាច។
- **ស្រុកស្ទឹងត្រង់** ៖ ស្រុកនេះមាន ១២ ឃុំ ដែលរួមមាន ឃុំអារក្សត្នោត ឃុំដងក្ដារ ឃុំខ្ពបតាងួន ឃុំមេសរជ្រៃ ឃុំអូរម្លូ ឃុំពាមកោះស្នា ឃុំព្រះអណ្ដូង ឃុំព្រែកបាក់ ឃុំព្រែកកក់ ឃុំទួលព្រះឃ្លាំង ឃុំសូភាស និងឃុំទួលសម្បូរ។

### ២.៣. ខេត្តកំពង់ឆ្នាំង

កំពង់ឆ្នាំង ជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល (តំបន់ទន្លេសាប) នៃប្រទេសកម្ពុជា។ ខេត្តនេះមានក្រុងចំនួន ១ ស្រុកចំនួន ៧ ឃុំចំនួន ៦៦ សង្កាត់ចំនួន ៤ និងមានភូមិសរុបចំនួន ៥៦៩។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តកំពង់ឆ្នាំង រួមមានដូចខាងក្រោម ៖

- **ក្រុងកំពង់ឆ្នាំង** ៖ ក្រុងកំពង់ឆ្នាំង គឺជាទីរួមខេត្តរបស់ខេត្តកំពង់ឆ្នាំង។ ក្រុងនេះ មានសង្កាត់ចំនួន ៤ រួមមានដូចជា សង្កាត់ផ្សារឆ្នាំង សង្កាត់កំពង់ឆ្នាំង សង្កាត់ផ្អេរ និងសង្កាត់ខ្សាម។
- **ស្រុកបរិបូណ៌** ៖ ស្រុកនេះមាន ១១ ឃុំ ដែលរួមមាន ឃុំអញ្ចាញរូង ឃុំច្នុកទ្រូ ឃុំចក ឃុំខុនរ៉ង ឃុំកំពង់ព្រះគគីរ ឃុំមេលំ ឃុំផ្សារ ឃុំពេជ្រចង្វារ ឃុំពពេល ឃុំពន្លៃ និងឃុំត្រពាំងចាន់។
- **ស្រុកជលគីរី** ៖ ស្រុកនេះមានចំនួន ៥ ឃុំ ដែលរួមមាន ឃុំជលសា ឃុំកោះថ្កូវ ឃុំកំពង់ឧស ឃុំព្រៃគ្រី និងឃុំពាមឆ្កោក។
- **ស្រុកកំពង់លែង** ៖ ស្រុកនេះមានចំនួន ៩ ឃុំ ដែលរួមមាន ឃុំច្រណូក ឃុំដារ ឃុំកំពង់ហៅ ឃុំផ្លូវទូកឃុំពោធិ៍ ឃុំប្រឡាយមាស ឃុំសំរោងសែន ឃុំស្វាយរំពារ និងឃុំត្រងិល។
- **ស្រុកកំពង់ត្រឡាច** ៖ ស្រុកនេះមានចំនួន ១០ ឃុំ ដែលរួមមាន ឃុំអំពិលទឹក ឃុំឈូកស ឃុំច្រេស ឃុំកំពង់ត្រឡាច ឃុំលង្វែក ឃុំអូរឫស្សី ឃុំពានី ឃុំសែប ឃុំតាជេស និងឃុំថ្មឥដ្ឋ។
- **ស្រុករលាប្អៀរ** ៖ ស្រុកនេះមាន ១៣ ឃុំ ដែលរួមមានដូចជា ឃុំអណ្ដូងស្នាយ ឃុំបន្ទាយព្រាល ឃុំពង្រឃុំជើងគ្រាវ ឃុំជ្រៃបាក់ ឃុំគោលបន្ទាយ ឃុំក្រាំងលាវ ឃុំស្វាយជ្រុំ ឃុំព្រៃមូល ឃុំរលាប្អៀរ ឃុំស្រែថ្មី ឃុំប្រស្នឹប និងឃុំទឹកហូត។
- **ស្រុកសាមគ្គីមានជ័យ** ៖ ស្រុកនេះមានចំនួន ៩ ឃុំ ដែលរួមមាន ឃុំឈានឡើង ឃុំខ្នារឆ្មារ ឃុំពាម ឃុំក្រាំងល្វា ឃុំសេដ្ឋី ឃុំស្វាយ ឃុំស្វាយជុក ឃុំត្បែងខ្ពស់ និងឃុំធ្លាកវៀន។
- **ស្រុកទឹកផុស** ៖ ស្រុកនេះមានចំនួន ៩ ឃុំ ដែលរួមមាន ឃុំអភិវឌ្ឍន៍ ឃុំក្ដុលសែនជ័យ ឃុំចោង

ម៉ោង ឃុំជ្រៀប ឃុំក្បាលទឹក ឃុំខ្លុងពពក ឃុំក្រាំងស្គារ ឃុំតាំងក្រសាំង និងឃុំទួលខ្ពស់។

**២.៤. ខេត្តកំពង់ស្ពឺ**

កំពង់ស្ពឺ គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ភ្នំនៃប្រទេសកម្ពុជា។ ខេត្តនេះមាន ក្រុងចំនួន ១ ស្រុកចំនួន ៧ ឃុំចំនួន ៨២ សង្កាត់ចំនួន ៥ និងមានភូមិសរុបទាំងអស់ចំនួន ១៣៦៨។ ក្រុង សង្កាត់ស្រុក និងឃុំនៅក្នុងខេត្តកំពង់ស្ពឺ រួមមានដូចខាងក្រោម ៖

- **ក្រុងច្បារមន** ៖ ក្រុងច្បារមន គឺជាទីរួមខេត្តរបស់ខេត្តកំពង់ស្ពឺ។ ក្រុងនេះ មានសង្កាត់ចំនួន ៥ ដែលរួមមាន សង្កាត់ច្បារមន សង្កាត់កណ្តាលជ្រុំ សង្កាត់រការធំ សង្កាត់សុពរ័ទេព និងសង្កាត់ស្វាយក្រវ៉ាន់។
- **ស្រុកបរសេដ្ឋ** ៖ ស្រុកនេះមាន ១៥ ឃុំ ដែលរួមមាន ឃុំបរសេដ្ឋ ឃុំកាត់ភ្លុក ឃុំនិទាន ឃុំព្រះខែ ឃុំភក្តី ឃុំភារីមានជ័យ ឃុំផុង ឃុំពោធិ៍អង្រ្កង ឃុំពោធិ៍ចម្រើន ឃុំពោធិ៍ម្រាល ឃុំកក់ ឃុំស្វាយចចិប ឃុំទួលសាលា និងឃុំស្វាយរំពារ។
- **ស្រុកគងពិសី** ៖ ស្រុកនេះមាន ១៣ ឃុំ ដែលរួមមាន ឃុំអង្គពពេល ឃុំជង្រុក ឃុំមហាឫស្សី ឃុំពេជ្រមុនី ឃុំព្រះនិព្វាន ឃុំព្រៃញាតិ ឃុំព្រៃវិហារ ឃុំរកាកោះ ឃុំស្តុក ឃុំស្នំក្រពើ ឃុំវាំងចាស់ ឃុំទឹកល្អក់ និងឃុំស្រង់។
- **ស្រុកឱរ៉ាល់** ៖ ស្រុកនេះមានចំនួប ៥ ឃុំ ដែលរួមមានដូចជា ឃុំហោងសំណំ ឃុំរស្មីសាមគ្គី ឃុំត្រពាំងជោរ ឃុំសង្កែសាទប និងឃុំតាសាល។
- **ស្រុកឧត្តុង្គ** ៖ ស្រុកនេះមាន ១៥ ឃុំដែលរួមមាន ឃុំចាន់សែន ឃុំដំណាក់រាំង ឃុំយុទ្ធសាមគ្គី ឃុំជើងរាស់ ឃុំជំពូព្រឹក្ស ឃុំក្សេមក្សាន្ត ឃុំក្រាំងចេក ឃុំមានជ័យ ឃុំព្រះស្រែ ឃុំព្រៃក្រសាំង ឃុំត្រាចទង ឃុំវាលពង់ ឃុំវាំងចាស់ ឃុំពាំងល្វា និងឃុំភ្នំតូច។

❖ **ស្រុកភ្នំស្រួច** ៖ ស្រុកនេះមាន ១២ ឃុំ ដែលរួមមាន ឃុំចំបក់ ឃុំជាំសង្កែ ឃុំដំបូករូង ឃុំព្រៃក្មេង ឃុំគីរីវន្ត ឃុំក្រាំងដីវ៉ាយ ឃុំមហាសាំង ឃុំអូរ ឃុំព្រៃរំដួល ឃុំតាំងសំរោង ឃុំតាំងស្យា និងឃុំត្រែងត្រយឹង។

- **ស្រុកសំរោងទង** ៖ ស្រុកនេះមាន ១៥ ឃុំ ដែលរួមមាន ឃុំរលាំងចេក ឃុំកាហែង ឃុំខ្ទុំក្រាំង ឃុំក្រាំងអំពិល ឃុំញ្ញាយ ឃុំរលាំងគ្រើល ឃុំសំរោងទង ឃុំសម្បូរ ឃុំសែងដី ឃុំស្គុះ ឃុំតាំងក្រូច ឃុំធម្មតាអរ ឃុំត្រពាំងគង ឃុំទំព័រមាស និងឃុំវល្លិ៍សរ។
- **ស្រុកថ្ពង** ៖ ស្រុកនេះមានចំនួន ៧ ឃុំ ដែលរួមមាន ឃុំអមលាំង ឃុំមនោរម្យ ឃុំប្រាំបីមុម ឃុំរុងរឿងឃុំទ័ពមានជ័យ ឃុំវាលពន់ និងឃុំយាអង្គ។

**២.៥. ខេត្តកំពង់ធំ**

កំពង់ធំ គឺជាខេត្តមួយដែលមានទីតាំងស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល (តំបន់ទន្លេសាប) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ១ ស្រុកចំនួន ៨ ឃុំចំនួន ៧៣ សង្កាត់ចំនួន ៨ និងភូមិសរុបមានចំនួន ៧៦៥។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តកំពង់ធំ រួមមានដូចខាងក្រោម ៖

- **ក្រុងស្ទឹងសែន** ៖ ក្រុងស្ទឹងសែន គឺជាទីរួមខេត្តរបស់ខេត្តកំពង់ធំ។ ក្រុងនេះ មានសង្កាត់ចំនួន ៨

ដែលរួមមានដូចជា សង្កាត់ដំរីជាន់ខ្លា សង្កាត់កំពង់ធំ សង្កាត់កំពង់រទេះ សង្កាត់អូរកន្ធរ សង្កាត់កំពង់ក្របៅ សង្កាត់ព្រៃកតាហ៊ូ សង្កាត់អាចារ្យលាក់ និងសង្កាត់ស្រយ៉ូវ។

- **ស្រុកបារាយណ៍** ៖ ស្រុកនេះមាន ១០ ឃុំដែលរួមមាន ឃុំបារាយណ៍ ឃុំបាក់ស្នា ឃុំចើងដើង ឃុំបល្ល័ង្គ ឃុំបឹង ឃុំឈូកខ្សាច់ ឃុំចុងដូង ឃុំគគីរធំ ឃុំក្រវ៉ា និងឃុំត្នោតជ្រុំ។
- **ស្រុកតាំងគោក** ៖ ស្រុកនេះមាន ៨ ឃុំ ដែលរួមមាន ឃុំពង្រ ឃុំច្រនាង ឃុំជ្រលង ឃុំទ្រៀល ឃុំសូយោង ឃុំស្រឡៅ ឃុំស្វាយលើ និងឃុំអណ្ដូងពោធិ៍។
- **ស្រុកកំពង់ស្វាយ** ៖ ស្រុកនេះ មានចំនួន ១១ ឃុំ ដែលរួមមានដូចជា ឃុំកំពង់គោ ឃុំដំរីស្លាប់ ឃុំផាត់សណ្ដាយ ឃុំជ័យ ឃុំត្បែង ឃុំនីពេជ ឃុំកំពង់ស្វាយ ឃុំសានគរ ឃុំត្រពាំងឫស្សី ឃុំក្ដីដូង និងឃុំព្រៃគុយ។
- **ស្រុកប្រាសាទបល្ល័ង្គ** ៖ ស្រុកនេះមាន ៧ ឃុំ ដែលរួមមាន ឃុំសាលាវិស័យ ឃុំដូង ឃុំក្រយា ឃុំផាន់ញើម ឃុំសាក្រាម ឃុំសាមគ្គី និងឃុំទួលគ្រើល។
- **ស្រុកប្រាសាទសម្បូរ** ៖ ស្រុកនេះមាន ៥ ឃុំដែលរួមមាន ឃុំឈូក ឃុំតាំងក្រសៅ ឃុំសំបូរណ៍ ឃុំស្រើង និងឃុំគោល។
- **ស្រុកសណ្ដាន់** ៖ ស្រុកនេះមានចំនួន ៩ ឃុំ ដែលរួមមាន ឃុំឈើទាល ឃុំដងកាំបិត ឃុំក្លែង ឃុំមានរិទ្ធិ ឃុំមានជ័យ ឃុំងន ឃុំសណ្ដាន់ ឃុំសុចិត្រ និងឃុំទំរីង។
- **ស្រុកសន្ទុក** ៖ ស្រុកនេះមាន ១០ ឃុំ ដែលរួមមាន ឃុំបឹងល្វា ឃុំជ្រាប់ ឃុំកំពង់ថ្ម ឃុំកកោះ ឃុំក្រយា ឃុំពៅ ឃុំប្រសាទ ឃុំតាំងក្រសាំង ឃុំទីពោ និងឃុំត្បូងក្រពើ។
- **ស្រុកស្ទោង** ៖ ស្រុកនេះមាន ១៣ ឃុំដែលរួមមាន ឃុំបន្ទាយស្ទោង ឃុំព្រោជ ឃុំចំណាក្រោម ឃុំចំណាលើ ឃុំកំពង់ចិនខាងជើង ឃុំកំពង់ចិនខាងត្បូង ឃុំម្សាក្រង ឃុំពាមបាង ឃុំពពក ឃុំប្រឡាយ ឃុំព្រះដំរី ឃុំរុងរឿង និងឃុំទ្រា។

## ២.៦. ខេត្តកណ្ដាល

កណ្ដាល គឺជាខេត្តមួយដែលមានទីតាំងស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល (តំបន់វាលរាប) នៃប្រទេសកម្ពុជា។ ខេត្តនេះមានក្រុងចំនួន ១ ស្រុកចំនួន ១០ ឃុំចំនួន ១១៧ សង្កាត់ចំនួន ១០ និងភូមិសរុបចំនួន ១០០៥។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តកណ្ដាល រួមមានដូចខាងក្រោម ៖

- **ក្រុងតាខ្មៅ** ៖ ក្រុងតាខ្មៅ គឺជាទីរួមខេត្តរបស់ខេត្តកណ្ដាល។ ក្រុងនេះ មានសង្កាត់ចំនួន ១០ ដែលរួមមានដូចជា សង្កាត់តាក្ដុល សង្កាត់ព្រែកឫស្សី សង្កាត់ដើមមៀន សង្កាត់តាខ្មៅ សង្កាត់ព្រែកហូរ សង្កាត់កំពង់សំណាញ់ សង្កាត់ស្វាយរលំ សង្កាត់កោះអន្លង់ចិន សង្កាត់សិត្បូ និងសង្កាត់កោះខ្ពស់។
- **ស្រុកកណ្ដាលស្ទឹង** ៖ ស្រុកនេះមានចំនួន ១៨ ឃុំ ដែលរួមមាន ឃុំអំពៅព្រៃ ឃុំអន្លង់រមៀត ឃុំបារគូ ឃុំបឹងខ្យាង ឃុំជើងកើប ឃុំដើមឫស ឃុំកណ្ដោក ឃុំថ្មី ឃុំគោកត្រប់ ឃុំព្រះពុទ្ធ ឃុំព្រែករកា ឃុំព្រែកស្លែង ឃុំរកា ឃុំរលាំងកែន ឃុំសៀមរាប ឃុំត្បែង ឃុំត្រពាំងវែង និងឃុំទ្រា។
- **ស្រុកកៀនស្វាយ** ៖ ស្រុកនេះមាន ៨ ឃុំ ដែលរួមមាន ឃុំបន្ទាយដែក ឃុំឈើទាល ឃុំដីឥដ្ឋ ឃុំកំពង់ស្វាយ ឃុំគគីរ ឃុំគគីរធំ ឃុំភូមិធំ និងឃុំសំរោងធំ។

- **ស្រុកខ្សាច់កណ្ដាល** ៖ ស្រុកនេះមានចំនួន ១៨ ឃុំ ដែល រួមមាន ឃុំបាក់ដាវ ឃុំជ័យធំ ឃុំកំពង់ចំលង ឃុំកោះចូរ៉ាម ឃុំកោះឧកញ៉ាតី ឃុំព្រះប្រសប់ ឃុំព្រែកអំពិល ឃុំព្រែកលួង ឃុំព្រែកតាកូវ ឃុំព្រែកតាមាក់ ឃុំពុកឫស្សី ឃុំរកាជន្លឹង ឃុំសន្លុង ឃុំស៊ីធរ ឃុំស្វាយជ្រុំ ឃុំស្វាយរមៀត ឃុំតាឯក និងឃុំវិហារសួគ៌។
- **ស្រុកកោះធំ** ៖ ស្រុកនេះមាន ១១ ឃុំ ដែលរួមមាន ឃុំឈើខ្មៅ ឃុំជ្រោយតាកែវ ឃុំកំពង់កុង ឃុំកោះធំ១ ឃុំកោះធំ២ ឃុំលើកដែក ឃុំពោធិ៍បាន ឃុំព្រែកជ្រៃ ឃុំព្រែកស្ដី ឃុំព្រែកថ្មី និងឃុំសំពៅពូន។
- **ស្រុកលើកដែក** ៖ ស្រុកនេះមាន ៧ ឃុំដែលរួមមាន ឃុំកំពង់ភ្នំ ឃុំក្អមសំណរ ឃុំខ្ពបអាទាវ ឃុំពាមរាំង ឃុំព្រែកដាច់ ឃុំព្រែកទន្លាប និងឃុំសណ្ដារ។
- **ស្រុកល្វាឯម** ៖ ស្រុកនេះមានចំនួន ១៥ ឃុំ ដែលរួមមាន ឃុំអរិយក្សត្រ ឃុំបារុង ឃុំបឹងគ្រំ ឃុំកោះកែវ ឃុំកោះរះ ឃុំល្វាសរ ឃុំពាមឧកញ៉ាអុង ឃុំភូមិធំ ឃុំព្រែកក្មេង ឃុំព្រែករៃ ឃុំព្រែកឫស្សី ឃុំសម្បួរ ឃុំសារិកាកែវ ឃុំថ្មគរ និងឃុំទឹកឃ្លាំង។
- **ស្រុកមុខកំពូល** ៖ ស្រុកនេះមានចំនួន ៧ ឃុំ ដែលរួមមាន ឃុំព្រែកអញ្ចាញ ឃុំព្រែកដំបង ឃុំរកាកោងទី១ ឃុំរកាកោងទី២ ឃុំឫស្សីជ្រោយ ឃុំសំបួរមាស និងឃុំស្វាយអំពារ។
- **ស្រុកអង្គស្នួល** ៖ ស្រុកនេះមានចំនួន ១០ ឃុំ ដែលរួមមាន ឃុំបែកចាន ឃុំឆក់ឈើនាង ឃុំដំណាក់អំពិល ឃុំក្រាំងម្កាក់ ឃុំលំហាច ឃុំម្កាក់ ឃុំពើក ឃុំព្រៃពួច ឃុំសំរោងលើ និងឃុំទួលពេជ្រ។
- **ស្រុកពញាឮ** ៖ ស្រុកនេះមានចំនួន ១១ ឃុំ មានដូចជា ឃុំពញាឮ ឃុំជ្រៃលាស់ ឃុំកំពង់ហ្លួង ឃុំកោះចិន ឃុំឈ្វាំង ឃុំកំពង់ឧស ឃុំភ្នំបាត ឃុំព្រែកតាទែន ឃុំផ្សារដែក ឃុំទំនប់ធំ និងឃុំវិហារហ្លួង។
- **ស្រុកស្អាង** ៖ ស្រុកនេះមានចំនួន ១២ ឃុំ មានដូចជា ឃុំខ្ពប ឃុំកោះខែល ឃុំកោះខ្សាច់ទន្លា ឃុំក្រាំងយ៉ូវ ឃុំប្រសាទ ឃុំព្រែកអំបិល ឃុំព្រែកគយ ឃុំស្អាងភ្នំ ឃុំស្វាយប្រទាល ឃុំតាលន់ ឃុំត្រើយស្លា និងឃុំទឹកវិល។

## ២.៧. ខេត្តកោះកុង

កោះកុង ជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់មាត់សមុទ្រនៃប្រទេសកម្ពុជា។ ខេត្តនេះមានក្រុងចំនួន ១ ស្រុកចំនួន ៦ ឃុំចំនួន ២៦ សង្កាត់ចំនួន ៣ និងភូមិសរុបទាំងអស់មានចំនួន ១២០។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តកោះកុង រួមមានដូចខាងក្រោម ៖

- **ក្រុងខេមរភូមិន្ទ** ៖ ក្រុងខេមរភូមិន្ទ គឺជាទីរួមខេត្តរបស់ខេត្តកោះកុង។ ក្រុងនេះ មានសង្កាត់ចំនួន ៣ ដែលរួមមានដូចជា សង្កាត់ស្មាច់មានជ័យ សង្កាត់ដងទង់ និងសង្កាត់ស្ទឹងវែង។
- **ស្រុកបុទុមសាគរ** ៖ ស្រុកនេះមានចំនួន ៤ ឃុំ ដែលមានដូចជា ឃុំអណ្ដូងទឹក ឃុំកណ្ដោល ឃុំតានួន និងឃុំថ្ម-ស។
- **ស្រុកគីរីសាគរ** ៖ ស្រុកនេះមានចំនួន ៣ ឃុំ ដែលរួមមានដូចជា ឃុំកោះស្ដេច ឃុំភ្ញីមាស និងឃុំព្រែកខ្សាច់។
- **ស្រុកកោះកុង** ៖ ស្រុកនេះមានចំនួន ៤ ឃុំ ដែលរួមមានដូចជា ឃុំជ្រោយប្រស់ ឃុំកោះកាពិ ឃុំ

តាតៃក្រោម និងឃុំត្រពាំងរូង។

- **ស្រុកមណ្ឌលសីមា** ៖ ស្រុកនេះមានចំនួន ៣ ឃុំ ដែលរួមមាន ឃុំប៉ាក់ខ្លង ឃុំពាមក្រសោប និងឃុំទួលគគីរ។
- **ស្រុកស្រែអំបិល** ៖ ស្រុកនេះមាន ៦ ឃុំ ដែលរួមមាន ឃុំបឹងព្រាវ ឃុំដី-ខក្រោម ឃុំដី-ខលើ ឃុំជ្រោយស្វាយ ឃុំដងពែង និងស្រែអំបិល។
- **ស្រុកថ្មបាំង** ៖ ស្រុកនេះមានចំនួន ៦ ឃុំ ដែលមានដូចជា ឃុំតាតៃលើ ឃុំប្រឡាយ ឃុំជំនាប់ ឃុំឫស្សីជ្រុំ ឃុំជីផាត់ និងថ្មដូនពៅ។

### ២.៨. ខេត្តក្រចេះ

ក្រចេះ គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ខ្ពង់រាប នៃប្រទេសកម្ពុជា។ ខេត្តនេះមានក្រុងចំនួន ១ ស្រុកចំនួន ៥ ឃុំចំនួន ៤២ សង្កាត់ចំនួន ៥ និងមានភូមិសរុបទាំងអស់ចំនួន ២៥៨។ ក្រុង សង្កាត់ស្រុក និងឃុំនៅក្នុងខេត្តក្រចេះ រួមមានដូចខាងក្រោម ៖

- **ក្រុងក្រចេះ** ៖ ក្រុងក្រចេះ គឺជាទីរួមខេត្តរបស់ខេត្តក្រចេះ។ ក្រុងនេះ មានសង្កាត់ចំនួន ៥ ដែលរួមមានដូចជា សង្កាត់កោះទ្រង់ សង្កាត់ក្រគរ សង្កាត់ក្រចេះ សង្កាត់អូរឫស្សី និងសង្កាត់រកាកណ្ដាល។
- **ស្រុកឆ្លូង** ៖ ស្រុកនេះមាន ៨ ឃុំដែលរួមមាន ឃុំឆ្លូង ឃុំដំរីផុង ឃុំហាន់ជ័យ ឃុំខ្សាច់អណ្ដែត ឃុំកំពង់ដំរី ឃុំកញ្ជរ ឃុំពង្រ និងឃុំព្រែកសាម៉ាន់។
- **ស្រុកព្រែកប្រសព្វ** ៖ ស្រុកនេះមាន ៨ ឃុំដែលរួមមាន ឃុំចំបក់ ឃុំជ្រោយបន្ទាយ ឃុំកំពង់គរ ឃុំកោះតាស៊ុយ ឃុំព្រែកប្រសព្វ ឃុំឫស្សីកែវ ឃុំសោប និងឃុំតាម៉ៅ។
- **ស្រុកសំបូរ** ៖ ស្រុកនេះមានចំនួន ៩ ឃុំ ដែលរួមមាន ឃុំបឹងចារ ឃុំកំពង់ចាម ឃុំក្បាលដំរី ឃុំកោះខ្ញែរ ឃុំអូរគ្រៀង ឃុំរលួសមានជ័យ ឃុំសំបូរ ឃុំសណ្ដាន់ ឃុំស្រែជិះ និងឃុំវឌ្ឍនៈ។
- **ស្រុកស្នួល** ៖ ស្រុកនេះមាន ៦ ឃុំ ដែលរួមមានដូចជា ឃុំឃ្សឹម ឃុំ២ធ្នូ ឃុំស្នួល ឃុំស្រែចារ ឃុំស្វាយជ្រះ ឃុំក្រញូងសែនជ័យ។
- **ស្រុកចិត្របុរី** ៖ ស្រុកនេះមានចំនួន ១០ ឃុំ ដែលរួមមានដូចជា ឃុំបុសលាវ ឃុំចង្រ្កង ឃុំដារ ឃុំកន្ទួត ឃុំគោលាប់ ឃុំកោះច្រែង ឃុំសំបុក ឃុំថ្មអណ្ដើក ឃុំថ្មគ្រែ និងឃុំថ្មី។

### ២.៩. ខេត្តមណ្ឌលគីរី

មណ្ឌលគីរី គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ខ្ពង់រាប នៃប្រទេសកម្ពុជា។ ខេត្តនេះមានក្រុងចំនួន ១ ស្រុកចំនួន ៤ ឃុំចំនួន ១៧ សង្កាត់ចំនួន ៤ និងមានភូមិសរុបចំនួន ៩២។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តមណ្ឌលគីរី រួមមានដូចខាងក្រោម ៖

- **ក្រុងសែនមនោរម្យ** ៖ ក្រុងសែនមនោរម្យ គឺជាទីរួមខេត្តរបស់ខេត្តមណ្ឌលគីរី។ ក្រុងនេះ មានសង្កាត់ចំនួន ៤ ដែលរួមមាន សង្កាត់មនោរម្យ សង្កាត់សុខដុម សង្កាត់ស្ពានមានជ័យ និងសង្កាត់រមនា។
- **ស្រុកកែវសីម៉ា** ៖ ស្រុកនេះមាន ៥ ឃុំដែលរួមមានដូចជា ឃុំចុងផ្លាស់ ឃុំមេម៉ង់ ឃុំស្រែឈូក ឃុំស្រែខ្ទុម និងឃុំស្រែព្រះ។
- **ស្រុកកោះញែក** ៖ ស្រុកនេះមាន ៦ ឃុំ ដែលរួមមានដូចជា ឃុំណាងឃីលិក ឃុំអបួន ឃុំរយ៉ ឃុំ

សុខសាន្ត ឃុំស្រែហ៊ុយ និងឃុំស្រែសង្គម។

- **ស្រុកអន្លង់វែង** ៖ ស្រុកនេះមានឃុំចំនួនតែ ២ ប៉ុណ្ណោះ ដែលរួមមានដូចជា ឃុំដាក់ដាំ និងឃុំសែនមនោរម្យ។
- **ស្រុកពេជ្រាដា** ៖ ស្រុកនេះមានឃុំចំនួន ៤ រួមមានដូចជា ឃុំក្រង់តេះ ឃុំពូជ្រៃ ឃុំស្រែអំពូម និងឃុំប៊ូស្រា។

## ២.១០. ខេត្តព្រះវិហារ

ព្រះវិហារ គឺជាខេត្តមួយដែលមានទីតាំងស្ថិតនៅក្នុងតំបន់ខ្ពង់រាបខាងជើង នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ១ ស្រុកចំនួន ៧ ឃុំចំនួន ៤៩ សង្កាត់ចំនួន ២ និងមានភូមិសរុបទាំងអស់ចំនួន ២៣២។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តព្រះវិហារ រួមមានដូចខាងក្រោម ៖

- **ក្រុងព្រះវិហារ** ៖ ក្រុងព្រះវិហារ (កាលពីខេត្តនេះមានក្រុងឈ្មោះថា ក្រុងត្បែងមានជ័យ)គឺជាទីរួមខេត្តរបស់ខេត្តព្រះវិហារ។ ក្រុងនេះ មានសង្កាត់តែចំនួន ២ ប៉ុណ្ណោះ ដែលរួមមានដូចជា សង្កាត់កំពង់ប្រណាក និងសង្កាត់ប៉ាលហាល។
- **ស្រុកជ័យសែន** ៖ ស្រុកនេះមាន ៦ ឃុំ ដែលរួមមានដូចជា ឃុំស្អាង ឃុំតស៊ូ ឃុំខ្យង ឃុំច្រាច់ ឃុំធ្មា និងឃុំពុទ្រា។
- **ស្រុកឆែប** ៖ ស្រុកនេះមានចំនួន ៨ ឃុំ ដែលមានដូចជា ឃុំឆែបមួយ ឃុំឆែបពីរ ឃុំសង្កែមួយ ឃុំសង្កែពីរ ឃុំម្លូព្រៃមួយ ឃុំម្លូព្រៃពីរ ឃុំកំពង់ស្រឡៅមួយ និងឃុំកំពង់ស្រឡៅពីរ។
- **ស្រុកជាំក្សាន្ត** ៖ ស្រុកនេះមាន ៧ ឃុំ ដែលមានដូចជា ឃុំជាំក្សាន្ត ឃុំទឹកក្រហម ឃុំព្រីងធំ ឃុំរំដោះស្រែ ឃុំយាង ឃុំកន្ទួត ឃុំស្រអែម និងឃុំមរកត។
- **ស្រុកគូលែន** ៖ ស្រុកនេះមាន ៦ ឃុំ ដែលមានដូចជា ឃុំគូលែនខាងត្បូង ឃុំគូលែនខាងជើង ឃុំថ្មី ឃុំភ្នំពេញ ឃុំភ្នំត្បែងទីពីរ និងឃុំស្រយ៉ង់។
- **ស្រុករវៀង** ៖ ស្រុកនេះមានចំនួន ១២ ឃុំ ដែលរួមមានដូចជា ឃុំរបៀប ឃុំរស្មី ឃុំរហ័ស ឃុំរុងរឿង ឃុំរីករាយ ឃុំរួសរាន់ ឃុំរតនៈ ឃុំរៀបរយ ឃុំរក្សា ឃុំរំដោះ ឃុំរមទម និងរមណី។
- **ស្រុកសង្គមថ្មី** ៖ ស្រុកនេះមាន ៥ ឃុំ ដែលមានដូចជា ឃុំចម្រើន ឃុំរអាង ឃុំភ្នំត្បែងទីមួយ ឃុំស្ដៅ និងឃុំរណសិរ្ស។
- **ស្រុកត្បែងមានជ័យ** ៖ ស្រុកនេះមានចំនួន ៤ ឃុំ ដែលមានដូចជា ឃុំឈានមុខ ឃុំព្រះឃ្លាំង ឃុំពោធិ៍ និងប្រមេរុ។

## ២.១១. ខេត្តព្រៃវែង

ព្រៃវែង គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល (តំបន់វាលរាប) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ១ ស្រុកចំនួន ១២ ឃុំចំនួន ១១២ សង្កាត់ចំនួន ៤ និងភូមិសរុបមានចំនួន ១១៤៩។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តព្រៃវែង រួមមានដូចខាងក្រោម ៖

- **ក្រុងព្រៃវែង** ៖ ក្រុងព្រៃវែង គឺជាទីរួមខេត្តរបស់ខេត្តព្រៃវែង។ ក្រុងនេះ មានសង្កាត់ចំនួន ០៤ ដែលរួមមាន សង្កាត់បារាយណ៍ សង្កាត់ជើងទឹក សង្កាត់កំពង់លាវ និងសង្កាត់តាកោ។

- **ស្រុកបាភ្នំ** ៖ ស្រុកនេះ មានចំនួន ០៩ ឃុំ ដែលមានដូចជា ឃុំបឹងព្រះ ឃុំជើងភ្នំ ឃុំឈើកាច់ ឃុំរក្សជ័យ ឃុំរោងដំរី ឃុំស្ដៅកោង ឃុំស្ពឺ-ក ឃុំស្ពឺ-ខ និងឃុំជាយ។
- **ស្រុកកំចាយមារ** ៖ ស្រុកនេះមានចំនួន ០៨ ឃុំ ដែលរួមមាន ឃុំជាប ឃុំដូនកឹង ឃុំក្រញូង ឃុំក្របៅ ឃុំស៊ាងឃ្វាង ឃុំស្មោងខាងជើង ឃុំស្មោងខាងត្បូង និងឃុំត្របែក។
- **ស្រុកកំពង់ត្របែក** ៖ ស្រុកនេះមានចំនួន ១៣ ឃុំ ដែលរួមមានដូចជា ឃុំអន្សោង ឃុំចាម ឃុំជ្រៃ ឃុំជាងដែក ឃុំកន្សោមអក ឃុំគោខ្ចក ឃុំកំពង់ត្របែក ឃុំពាមមន្ទារ ឃុំប្រាសាទ ឃុំថ្កូវ ឃុំប្រធាតុ ឃុំព្រៃឈរ និងឃុំព្រៃពោន។
- **ស្រុកកញ្ជ្រៀច** ៖ ស្រុកនេះមានចំនួន ០៨ ឃុំ ដែលរួមមានដូចជា ឃុំចុងអំពិល ឃុំកញ្ជ្រៀច ឃុំក្អៀងរាយ ឃុំគោកគង់ខាងកើត ឃុំគោកគង់ខាងលិច ឃុំព្រាល ឃុំថ្មពូន និងត្នោត។
- **ស្រុកមេសាង** ៖ ស្រុកនេះមានចំនួន ០៨ ឃុំ ដែលមានដូចជា ឃុំអង្គសរ ឃុំប្រសេស ឃុំជីផុចឃុំព្រៃឃ្នេស ឃុំព្រៃរំដេង ឃុំព្រៃទទឹង ឃុំស្វាយជ្រុំ និងឃុំត្រពាំងស្រែ។
- **ស្រុកពាមជរ** ៖ ស្រុកនេះមានចំនួន ១០ ឃុំ ដែលមានដូចជា ឃុំអង្គរអង្គ ឃុំកំពង់ប្រាសាទ ឃុំកោះចេក ឃុំកោះរកា ឃុំកោះសំពៅ ឃុំក្រាំងតាយ៉ង ឃុំព្រែកក្របៅ ឃុំព្រែកសម្បួរ ឃុំឫស្សីស្រុក និងឃុំស្វាយភ្លោះ។
- **ស្រុកពាមរក៍** ៖ ស្រុកនេះមានចំនួន ០៨ ឃុំ ដែលរួមមានដូចជា ឃុំបាបោង ឃុំព្រែកខ្សាយ-ក ឃុំព្រែកខ្សាយ-ខ ឃុំបន្ទិចប្រាសាទ ឃុំអ្នកលឿង ឃុំពាមមានជ័យ ឃុំព្រែកកណ្ដៀង និងឃុំពាមរក៍។
- **ស្រុកពារាំង** ៖ ស្រុកនេះមានចំនួន ០៩ ឃុំ ដែលរួមមានដូចជា ឃុំកំពង់ពពិល ឃុំកញ្ចំ ឃុំរាប ឃុំកំពង់ប្រាំង ឃុំមេសរប្រចាន់ ឃុំព្រៃញ្ញា ឃុំព្រៃស្នៀត ឃុំព្រៃស្រឡិត និងឃុំរកា។
- **ស្រុកព្រះស្ដេច** ៖ ស្រុកនេះមានចំនួន ១១ ឃុំ ដែលរួមមានដូចជា ឃុំអង្គររាជ ឃុំបន្ទាយចក្រី ឃុំបឹងដោល ឃុំដែកំពក ឃុំកំពង់សឹង ឃុំក្រាំងស្វាយ ឃុំល្វា ឃុំព្រះស្ដេច ឃុំរាធរ ឃុំរំចេក និងឃុំសេនារាជឧត្ដម។
- **ស្រុកពោធិ៍រៀង** ៖ ស្រុកនេះមានចំនួន ០៦ ឃុំ ដែលមានដូចជា ឃុំពោធិ៍រៀង ឃុំព្រែកអន្ទះ ឃុំព្រែកជ្រៃ ឃុំព្រែកកន្លោង ឃុំព្រែកតាសរ និងឃុំកំពង់ឫស្សី។
- **ស្រុកស៊ីធរកណ្ដាល** ៖ ស្រុកនេះមានចំនួន ១១ ឃុំ ដែលមានដូចជា ឃុំអំពិលក្រៅ ឃុំជ្រៃឃ្មុំ ឃុំល្វេ ឃុំញ្ញៅទី១ ឃុំញ្ញៅទី២ ឃុំពោធិ៍ទី ឃុំព្រែកចង្ក្រាន ឃុំព្រៃដើមថ្នឹង ឃុំព្រៃទឹង ឃុំរំលេច និងឃុំឫស្សីសាញ់។
- **ស្រុកស្វាយអន្ទរ** ៖ ស្រុកនេះមានចំនួន ១១ ឃុំ ដែលរួមមានដូចជា ឃុំអង្គរទ្រេត ឃុំជាខ្លាង ឃុំជ្រៃ ឃុំដំរីពួន ឃុំមេបុណ្យ ឃុំពានរោង ឃុំពពឺស ឃុំព្រៃខ្លា ឃុំសំរោង ឃុំស្វាយអន្ទរ និងឃុំទឹកថ្លា។

### ២.១២. ខេត្តពោធិ៍សាត់

ពោធិ៍សាត់ ជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល (តំបន់ទន្លេសាប) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ០១ ស្រុកចំនួន ០៦ ឃុំចំនួន ៤២ សង្កាត់ចំនួន ០៧ និងភូមិសរុបចំនួន ៥១១។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តពោធិ៍សាត់ រួមមានដូចខាងក្រោម ៖

- **ក្រុងពោធិ៍សាត់** ៖ ក្រុងពោធិ៍សាត់ គឺជាទីរួមខេត្តរបស់ខេត្តពោធិ៍សាត់។ ក្រុងនេះ មានសង្កាត់ចំនួន ០៧ ដែលរួមមានដូចជា សង្កាត់ចម្រើនផល សង្កាត់លលកស សង្កាត់ផ្ទះព្រៃ សង្កាត់ព្រៃញី សង្កាត់រលាប សង្កាត់ស្វាយអាត់ និងសង្កាត់បន្ទាយដី។
- **ស្រុកបាកាន** ៖ ស្រុកនេះមានចំនួន ០៩ ឃុំ មានដូចជា ឃុំបឹងបត់កណ្ដាល ឃុំបឹងខ្នារ ឃុំខ្នារទទឹង ឃុំមេទឹក ឃុំអូរតាប៉ោង ឃុំរំលេច ឃុំស្នាមព្រះ ឃុំស្វាយដូនកែវ និងឃុំត្រពាំងជង។
- **ស្រុកកណ្ដៀង** ៖ ស្រុកនេះមានចំនួន ០៩ ឃុំ ដែលរួមមានដូចជា ឃុំអន្លង់វិល ឃុំកណ្ដៀង ឃុំកញ្ជរ ឃុំរាំងទិល ឃុំស្រែស្ដុក ឃុំស្វាយលួង ឃុំស្យា ឃុំវាល និងឃុំកោះជុំ។
- **ស្រុកក្រគរ** ៖ ស្រុកនេះមានចំនួន ១១ ឃុំ ដែលរួមមានដូចជា ឃុំអន្លង់ត្នោត ឃុំអន្សាចំបក់ ឃុំបឹងកន្ទួត ឃុំឈើតុំ ឃុំកំពង់ហ្លួង ឃុំកំពង់ពោធិ៍ ឃុំក្បាលត្រាច ឃុំអូរសណ្ដាន់ ឃុំស្នាអន្សា ឃុំស្វាយស និងឃុំត្នោតជុំ។
- **ស្រុកក្រវាញ** ៖ ស្រុកនេះមានចំនួន ០៦ ឃុំ មានដូចជា ឃុំបាក់ចិញ្ចៀន ឃុំសន្ទ្រែ ឃុំលាច ឃុំរកាត ឃុំព្រងិល និងឃុំសំពោង។
- **ស្រុកវាលវែង** ៖ ស្រុកនេះមានចំនួន ០៥ ឃុំ ដែលរួមមានដូចជា ឃុំអូរសោម ឃុំក្រពើពីរ ឃុំថ្មដា ឃុំអន្លង់រាប និងឃុំប្រមោយ។
- **ស្រុកតាលោសែនជ័យ** ៖ ស្រុកនេះមានឃុំចំនួនតែ ២ ប៉ុណ្ណោះ ដែលរួមមានដូចជា ឃុំតាលោ និងឃុំផ្ទះរុង។

### ២.១៣. ខេត្តរតនគីរី

រតនគីរី គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ខ្ពង់រាប (តំបន់ឦសាន) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ០១ ស្រុកចំនួន ០៨ ឃុំចំនួន ៤៦ សង្កាត់ចំនួន ០៤ និងភូមិសរុបមានចំនួន ២៤៣។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តរតនគីរី រួមមានដូចខាងក្រោម ៖

- **ក្រុងបានលុង** ៖ ក្រុងបានលុង គឺជាទីរួមខេត្តរបស់ខេត្តរតនគីរី។ ក្រុងនេះ មានសង្កាត់ចំនួន ០៤ ដែលរួមមានដូចជា សង្កាត់កាចាញ សង្កាត់ឡាបានសៀក សង្កាត់យក្ខឡោម និងសង្កាត់បឹងកន្សែង។
- **ស្រុកអណ្ដូងមាស** ៖ ស្រុកនេះមានចំនួន ០៣ ឃុំ ដែលរួមមានដូចជា ឃុំម៉ាលិក ឃុំញ៉ាង និងឃុំតាឡាវ។
- **ស្រុកបរកែវ** ៖ ស្រុកនេះមានចំនួន ០៦ ឃុំ ដែលរួមមានដូចជា ឃុំកក់ ឃុំកិះចុង ឃុំឡាមីញ ឃុំលុងឃុង ឃុំស៊ើង និងឃុំទីងចាក់។
- **ស្រុកកូនមុំ** ៖ ស្រុកនេះមានចំនួន ០៦ ឃុំ ដែលមានដូចជា ឃុំសិរីមង្គល ឃុំស្រែអង្គ្រង ឃុំតឺនឃុំតាអង ឃុំត្រពាំងច្រេស និងឃុំត្រពាំងក្រហម។
- **ស្រុកលំផាត់** ៖ ស្រុកនេះមានចំនួន ០៦ ឃុំ ដែលរួមមានដូចជា ឃុំជ័យឧត្ដម ឃុំកាឡែង ឃុំល្បាំងទី១ ឃុំល្បាំងទី២ ឃុំតាប៉ោង និងឃុំសេដា។
- **ស្រុកអូរជុំ** ៖ ស្រុកនេះមានចំនួន ០៧ ឃុំ ដែលរួមមានដូចជា ឃុំចាអ៊ុង ឃុំប៉ូយ ឃុំឯកភាព ឃុំ

កាឡៃ ឃុំអូរជុំ ឃុំសាមគ្គី និងឃុំល្អក់។

- **ស្រុកអូរយ៉ាដាវ** ៖ ស្រុកនេះមានចំនួន ០៧ ឃុំ ដែលមានដូចជា ឃុំបរខាំ ឃុំលំជ័រ ឃុំប៉ក់ញៃ ឃុំប៉ាតេ ឃុំសេសាន ឃុំសោមធំ និងឃុំសាទុង។
- **ស្រុកតាវែង** ៖ ស្រុកនេះ មានឃុំចំនួនតែ ០២ ប៉ុណ្ណោះ ដែលរួមមានដូចជា ឃុំតាវែងលើ និងឃុំតាវែងក្រោម។
- **ស្រុកវើនសៃ** ៖ ស្រុកនេះ មានចំនួន ០៩ ឃុំ ដែលមានដូចជា ឃុំប៉ុង ឃុំហាត់ប៉ក់ ឃុំកាចូន ឃុំកោះប៉ុង ឃុំកោះពាក្យ ឃុំកុកឡាក់ ឃុំប៉ាកាឡាន់ ឃុំភ្នំកុក និងឃុំវើនសៃ។

**២.១៤. ខេត្តសៀមរាប**

សៀមរាប គឺជាខេត្តមួយដែលមានទីតាំងស្ថិតនៅក្នុងតំបន់ទំនាបកណ្តាល (តំបន់ទន្លេសាប) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ០១ ស្រុកចំនួន ១១ ឃុំចំនួន ៨៨ សង្កាត់ចំនួន ១២ និងភូមិសរុបចំនួន ៩១០។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តសៀមរាប រួមមានដូចខាងក្រោម ៖

- **ក្រុងសៀមរាប** ៖ ក្រុងសៀមរាប គឺជាទីរួមខេត្តរបស់ខេត្តសៀមរាប។ ក្រុងនេះ មានសង្កាត់ចំនួន ១២ ដែលរួមមានដូចជា សង្កាត់ស្លាក្រាម សង្កាត់ស្វាយដង្គំ សង្កាត់គោកចក សង្កាត់សាលាកំរើក សង្កាត់នគរធំ សង្កាត់ជ្រាវ សង្កាត់សម្បួរ សង្កាត់សៀមរាប សង្កាត់ស្រង៉ែ សង្កាត់ក្របីរៀល និងសង្កាត់ទឹកវិល។
- **ស្រុកអង្គរជុំ** ៖ ស្រុកនេះ មានចំនួន ០៧ ឃុំ ដែលរួមមានដូចជា ឃុំចារឈូក ឃុំដូនពេង ឃុំគោកដូង ឃុំគោល ឃុំនគរភាស ឃុំស្រែខ្វាវ និងឃុំតាសោម។
- **ស្រុកអង្គរធំ** ៖ ស្រុកនេះ មានចំនួន ០៤ ឃុំ ដែលរួមមានដូចជា ឃុំជប់តាត្រាវ ឃុំលាងដៃ ឃុំពាក់ស្នែង និងឃុំស្វាយចេក។
- **ស្រុកបន្ទាយស្រី** ៖ ស្រុកនេះ មានចំនួន ០៦ ឃុំ ដែលមានដូចជា ឃុំខ្នារសណ្តាយ ឃុំរំចេក ឃុំឃុនរាម ឃុំព្រះដាក់ ឃុំរុនតាឯក និងឃុំត្បែង។
- **ស្រុកជីក្រែង** ៖ ស្រុកនេះ មានចំនួន ១២ ឃុំ ដែលរួមមានដូចជា ឃុំអន្លង់សំណរ ឃុំជីក្រែង ឃុំកំពង់ក្ដី ឃុំខ្វាវ ឃុំគោកធ្លកក្រោម ឃុំគោកធ្លកលើ ឃុំល្វែងឫស្សី ឃុំពង្រក្រោម ឃុំពង្រលើ ឃុំឫស្សីលក ឃុំសង្វើយ និងឃុំស្ពានត្នោត។
- **ស្រុកក្រឡាញ់** ៖ ស្រុកនេះមានចំនួន ១០ ឃុំ មានដូចជា ឃុំចន្លាសដៃ ឃុំកំពង់ថ្កូវ ឃុំក្រូចគរ ឃុំរោងគោ ឃុំសំបួរ ឃុំសែនសុង ឃុំស្នួល ឃុំស្រណោល ឃុំក្រឡាញ់ និងឃុំតាអាន។
- **ស្រុកពួក** ៖ ស្រុកនេះ មានចំនួន ១៤ ឃុំ ដែលមានដូចជា ឃុំសសរស្តម្ភ ឃុំដូនកែវ ឃុំក្តីរុន ឃុំកែវពណ៌ ឃុំខ្នាត ឃុំល្វា ឃុំសុខប៉ែន ឃុំពោធិ៍ទ្រាយ ឃុំពួក ឃុំព្រៃជ្រូក ឃុំរើល ឃុំយាង ឃុំសំរោងយា និងឃុំត្រីញ័រ។
- **ស្រុកប្រាសាទបាគង** ៖ ស្រុកនេះ មានចំនួន ០៩ ឃុំ ដែលរួមមានដូចជា ឃុំបាគង ឃុំបល្ល័ង្គ ឃុំកំពង់ភ្លុក ឃុំកន្ទ្រាំង ឃុំកណ្តែក ឃុំមានជ័យ ឃុំរលួស ឃុំត្រពាំងធំ និងឃុំអំពិល។
- **ស្រុកសូទ្រនិគម** ៖ ស្រុកនេះ មានចំនួន ១០ ឃុំ មានដូចជា ឃុំចាន់ស ឃុំដំដែក ឃុំដានរុន ឃុំ

កំពង់ឃ្លាំង ឃុំកៀនសង្កែ ឃុំខ្វាស់ ឃុំខ្នារពោធិ៍ ឃុំពពេល ឃុំសំរោង និងឃុំតាយ៉ែក។

- **ស្រុកស្រីស្នំ** ៖ ស្រុកនេះមានចំនួន ០៦ ឃុំ ដែលមានដូចជា ឃុំជ្រោយនាងងួន ឃុំក្លាំងហាយ ឃុំត្រាំសសរ ឃុំមោង ឃុំប្រីយ៍ និងឃុំស្លែងស្ពាន។
- **ស្រុកស្វាយលើ** ៖ ស្រុកនេះ មានចំនួន ០៥ ឃុំ ដែលរួមមានដូចជា ឃុំបឹងមាលា ឃុំកន្ទួត ឃុំខ្នងភ្នំ ឃុំស្វាយលើ និងឃុំតាសៀម។
- **ស្រុកវ៉ារិន្ទ** ៖ ស្រុកនេះ មានចំនួន ០៥ ឃុំ ដែលមានដូចជា ឃុំប្រាសាទ ឃុំល្វាក្រាំង ឃុំវ៉ារិន្ទ ឃុំស្រែណយ និងឃុំស្វាយស។

### ២.១៥. ខេត្តស្ទឹងត្រែង

ស្ទឹងត្រែង គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ខ្ពង់រាប (តំបន់ខ្ពង់រាបឦសាន្ត) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ០១ ស្រុកចំនួន ០៥ ឃុំចំនួន ៣០ សង្កាត់ចំនួន ០៤ និងភូមិសរុបចំនួន ១២៨។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តស្ទឹងត្រែង រួមមានដូចខាងក្រោម ៖

- **ក្រុងស្ទឹងត្រែង** ៖ ក្រុងស្ទឹងត្រែង គឺជាទីរួមខេត្តរបស់ខេត្តស្ទឹងត្រែង។ ក្រុងនេះ មានសង្កាទាំងអស់ចំនួន ០៤ ដែលរួមមានដូចជា សង្កាត់ស្ទឹងត្រែង សង្កាត់ស្រះឫស្សី សង្កាត់ព្រះបាទ និងសង្កាត់សាមគ្គី។
- **ស្រុកសេសាន** ៖ ស្រុកនេះ មានចំនួន ០៧ ឃុំ ដែលរួមមានដូចជា ឃុំកំភុន ឃុំក្បាលរមាស ឃុំភ្លុក ឃុំសាមឃួយ ឃុំស្ដៅ ឃុំស្រែគរ និងឃុំតាឡាត។
- **ស្រុកសៀមបូក** ៖ ស្រុកនេះ មានចំនួន ០៧ ឃុំ ដែលរួមមាន ឃុំកោះព្រះ ឃុំកោះសំពាយ ឃុំកោះស្រឡាយ ឃុំអូរម្រះ ឃុំអូរឫស្សីកណ្ដាល ឃុំសៀមបូក និងឃុំស្រែក្រសាំង។
- **ស្រុកសៀមបាង** ៖ ស្រុកនេះ មានចំនួន ០៥ ឃុំ ដែលរួមមានដូចជា ឃុំព្រែកមាស ឃុំសេកុង ឃុំសន្តិភាព ឃុំស្រែសំបូរ និងឃុំថ្មកែវ។
- **ស្រុកថាឡាបរិវ៉ាត់** ៖ ស្រុកនេះ មានចំនួន ០៨ ឃុំ ដែលមានដូចជា ឃុំអន្លង់ភេ ឃុំចម្ការលើ ឃុំកាំងចាម ឃុំអន្លង់ជ្រៃ ឃុំអូររ៉ៃ ឃុំសម្អាង ឃុំស្រែឫស្សី និងឃុំថាឡាបរិវ៉ាត់។
- **ស្រុកបុរីអូរស្វាយសែនជ័យ** ៖ ស្រុកនេះ មានចំនួន ០៣ ឃុំ ដែលរួមមានដូចជា ឃុំអូរស្វាយ ឃុំកោះស្នែង និងឃុំព្រះរំកិល។

### ២.១៦. ខេត្តតាកែវ

តាកែវ គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល (តំបន់វាលរាប) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ០១ ស្រុកចំនួន ០៩ ឃុំចំនួន ៩៧ សង្កាត់ចំនួន ០៣ និងភូមិសរុបចំនួន ១១១៩។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តតាកែវ រួមមានដូចខាងក្រោម ៖

- **ក្រុងដូនកែវ** ៖ ក្រុងដូនកែវ គឺជាទីរួមខេត្តរបស់ខេត្តតាកែវ។ ក្រុងនេះ មានសង្កាត់ចំនួន ០៣ ដែលរួមមានដូចជា សង្កាត់បារាយណ៍ សង្កាត់រកាក្នុង និងសង្កាត់រការក្រៅ។
- **ស្រុកអង្គរបុរី** ៖ ស្រុកនេះ មានចំនួន ០៦ ឃុំ ដែលមានដូចជា ឃុំអង្គរបុរី ឃុំបាស្រែ ឃុំពន្លៃ ឃុំគោកធ្លក ឃុំព្រែកផ្ទោល និងឃុំព្រែកផ្កាំ។

- **ស្រុកបាទី** ៖ ស្រុកនេះ មានចំនួន ១៥ ឃុំ ដែលរួមមាន ឃុំចំបក់ ឃុំចំប៉ី ឃុំដូង ឃុំកណ្ដឹង ឃុំកុមារាជា ឃុំក្រាំងលាវ ឃុំក្រាំងធ្នង់ ឃុំលំពង់ ឃុំរាម ឃុំពត់សរ ឃុំសូរភី ឃុំតាំងដូង ឃុំត្នោត ឃុំត្រពាំងក្រសាំង និងឃុំត្រពាំងសាប។
- **ស្រុកបុរីជលសារ** ៖ ស្រុកនេះ មានចំនួន ០៥ ឃុំ ដែលមានដូចជា ឃុំបុរីជលសារ ឃុំដូងខ្ពស់ ឃុំដោគជ័យ ឃុំកំពង់ក្រសាំង និងឃុំគោកពោធិ៍។
- **ស្រុកគីរីវង្ស** ៖ ស្រុកនេះ មានចំនួន ១២ ឃុំ ដែលមានដូចជា ឃុំអង្គប្រាសាទ ឃុំគីរីចុងកោះ ឃុំព្រះបាទជាន់ជុំ ឃុំកំណប់ ឃុំកំពែង ឃុំគោកព្រេច ឃុំភ្នំដិន ឃុំព្រែកអំពក ឃុំព្រៃរំដេង ឃុំរាមអណ្ដើក ឃុំសោម និងឃុំតាអូរ។
- **ស្រុកបុរីជលសារ** ៖ ស្រុកនេះ មានចំនួន ០៦ ឃុំ ដែលមានដូចជា ឃុំក្រពុំឈូក ឃុំពេជសារ ឃុំព្រៃខ្លា ឃុំព្រៃយុថ្កា ឃុំរមេញ និងឃុំធ្លាប្រជុំ។
- **ស្រុកព្រៃកប្បាស** ៖ ស្រុកនេះ មានចំនួន ១៣ ឃុំ ដែលរួមមានដូចជា ឃុំអង្កាញ់ ឃុំបានកាម ឃុំចំប៉ា ឃុំចារ ឃុំកំពែង ឃុំកំពង់រាប ឃុំក្តាញ់ ឃុំពោធិ៍រំចាក ឃុំព្រៃកប្បាស ឃុំព្រៃល្វា ឃុំព្រៃផ្ដៅ ឃុំស្នោ និងឃុំតាំងយ៉ាប។
- **ស្រុកសំរោង** ៖ ស្រុកនេះមានចំនួន១១ ឃុំ ដែលមានដូចជា ឃុំជើងគួន ឃុំជំរះពេន ឃុំខ្វាវ ឃុំបឹងត្រាញ់ខាងជើង ឃុំបឹងត្រាញ់ខាងត្បូង ឃុំលំចង់ ឃុំរវៀង ឃុំសំរោង ឃុំសឹង្ហ ឃុំស្លា និងឃុំទ្រា។
- **ស្រុកត្រាំកក់** ៖ ស្រុកនេះ មានចំនួន១៥ ឃុំ ដែលរួមមានដូចជា ឃុំអង្គតាសោម ឃុំជាងទង ឃុំលាយបូរ ឃុំគុស ឃុំញ៉ែងញ៉ង ឃុំអូរសារាយ ឃុំត្រពាំងក្រញូង ឃុំឧត្ដមសុរិយា ឃុំត្រាំកក់ ឃុំស្រែននោង ឃុំពពេល ឃុំសំរោង ឃុំតាភេម ឃុំត្រពាំងធំខាងជើង និងឃុំត្រពាំងធំខាងត្បូង។
- **ស្រុកទ្រាំង** ៖ ស្រុកនេះ មានចំនួន ១៤ ឃុំ ដែលមានដូចជា ឃុំអង្កាញ់ ឃុំអង្គខ្នុរ ឃុំអង្គកែវ ឃុំជីខ្មា ឃុំខ្វាវ ឃុំប្រាំបីមុម ឃុំព្រៃស្លឹក ឃុំនាម ឃុំសម្បួរ ឃុំសន្លុង ឃុំស្មោង ឃុំស្រង៉ែ ឃុំធ្លក និងឃុំត្រឡាច។

## ២.១៧. ខេត្តឧត្តរមានជ័យ

ឧត្តរមានជ័យ គឺជាខេត្តមួយ ដែលមានទីតាំងស្ថិតនៅភាគខាងជើង ជាប់នឹងជួរភ្នំដងរែក និងស្ថិតនៅក្នុងតំបន់ទន្លេសាប (បែងចែកតាមរបាយប្រជាជន) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ០១ ស្រុកចំនួន ០៤ ឃុំចំនួន ១៩ សង្កាត់ចំនួន ០៥ និងភូមិសរុបមានចំនួន ៣០៤។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តឧត្តរមានជ័យ រួមមានដូចខាងក្រោម ៖

- **ក្រុងសំរោង** ៖ ក្រុងសំរោង គឺជាទីរួមខេត្តរបស់ខេត្តឧត្តរមានជ័យ។ ក្រុងនេះ មានសង្កាត់សរុបចំនួន ០៥ ដែលរួមមានដូចជា សង្កាត់បន្សាយរាក់ សង្កាត់បុស្សបូវ សង្កាត់កូនក្រៀល សង្កាត់សំរោង និងសង្កាត់អូរស្មាច់។
- **ស្រុកអន្លង់វែង** ៖ ស្រុកនេះ មានចំនួន ០៥ ឃុំ ដែលរួមមានដូចជា ឃុំអន្លង់វែង ឃុំត្រពាំងតាវ ឃុំត្រពាំងប្រីយ៍ ឃុំថ្លាត និងឃុំលំទង។
- **ស្រុកបន្ទាយអំពិល** ៖ ស្រុកនេះ មានចំនួន ០៤ ឃុំ ដែលមានដូចជា ឃុំអំពិល ឃុំគោកខ្ពស់ ឃុំ

បេង និងឃុំគោកមន។

- **ស្រុកចុងកាល់** ៖ ស្រុកនេះ មានចំនួន ០៤ ឃុំ ដែលរួមមានដូចជា ឃុំជើងទាន ឃុំចុងកាល់ ឃុំក្រសាំង និងឃុំពង្រ។
- **ស្រុកត្រពាំងប្រាសាទ** ៖ ស្រុកនេះ មានចំនួន ០៦ ឃុំ ដែលមានដូចជា ឃុំបាក់អន្លង់ ឃុំផ្អាវ ឃុំអូរស្វាយ ឃុំព្រះប្រឡាយ ឃុំទំនប់ដាច់ និងត្រពាំងប្រាសាទ។

### ២.១៨. ខេត្តកែប

កែប ជាខេត្តតូចជាងគេបំផុត ក្នុងចំណោមខេត្តទាំង ២៤ នៅប្រទេសកម្ពុជា។ ខេត្តនេះ មានទីតាំងស្ថិតនៅតំបន់មាត់សមុទ្រ នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ០១ ស្រុកចំនួន ០១ ឃុំចំនួន ០២ សង្កាត់ចំនួន ០៣ និងមានភូមិសរុបចំនួន ១៨។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តកែប មានដូចខាងក្រោម ៖

- **ក្រុងកែប** ៖ ក្រុងកែប គឺជាទីរួមខេត្តរបស់ខេត្តកែប។ ក្រុងនេះ មានសង្កាត់ចំនួន ០៣ ដែលរួមមានដូចជា សង្កាត់កែប សង្កាត់ព្រៃធំ និងសង្កាត់អូរក្រសារ។
- **ស្រុកដំណាក់ចង្អើរ** ៖ ស្រុកនេះ មានឃុំតែចំនួន ០២ ប៉ុណ្ណោះ ដែលមានដូចជា ឃុំ អង្កោល និងឃុំពងទឹក។

### ២.១៩. ខេត្តប៉ៃលិន

ប៉ៃលិន គឺជាខេត្តតូចមួយផងដែរ ដែលមានទីតាំងស្ថិតនៅក្នុងជួរភ្នំក្រវាញ (បែងចែកតាមរបាយប្រជាជនស្ថិតនៅក្នុងតំបន់ទន្លេសាប) នៃប្រទេសកម្ពុជា។ ខេត្តនេះ មានក្រុងចំនួន ០១ ស្រុកចំនួន ០១ ឃុំចំនួន ០៤ សង្កាត់ចំនួន ០៤ និងភូមិសរុបមានចំនួន ៩០។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តប៉ៃលិន មានដូចខាងក្រោម ៖

- **ក្រុងប៉ៃលិន** ៖ ក្រុងប៉ៃលិន គឺជាទីរួមខេត្តរបស់ខេត្តប៉ៃលិន។ ក្រុងនេះ មានសង្កាត់ចំនួន ០៤ ដែលមានដូចជា សង្កាត់ប៉ៃលិន សង្កាត់អូរតាវៅ សង្កាត់ទួលល្វា និងសង្កាត់បរយ៉ាខា។
- **ស្រុកសាលាក្រៅ** ៖ ស្រុកនេះ មានចំនួន ០៤ ឃុំ ដែលរួមមាន ឃុំសាលាក្រៅ ឃុំស្ទឹងត្រង់ ឃុំស្ទឹងកាច់ និងឃុំអូរអណ្តូង។

### ២.២០. ខេត្តត្បូងឃ្មុំ

ត្បូងឃ្មុំ គឺជាខេត្តដែលទើបតែបង្កើតថ្មី ដោយបំបែកចេញពីខេត្តកំពង់ចាម។ ខេត្តនេះ មានទីតាំងស្ថិតនៅក្នុងតំបន់ខ្ពង់រាប (ខ្ពង់រាបភាគខាងកើត) នៃប្រទេសកម្ពុជា។ ខេត្តត្បូងឃ្មុំ មានក្រុងចំនួន ០១ ស្រុកចំនួន ០៦ ឃុំចំនួន ៦២ សង្កាត់ចំនួន ០២ និងភូមិសរុបមានចំនួន ៨៧៣។ ក្រុង សង្កាត់ ស្រុក និងឃុំនៅក្នុងខេត្តប៉ៃលិន មានដូចខាងក្រោម ៖

- **ក្រុងសួង** ៖ ក្រុងសួង គឺជាទីរួមខេត្តរបស់ខេត្តត្បូងឃ្មុំ។ ក្រុងនេះ មានសង្កាត់ចំនួន ០២ ដែលរួមមានដូចជា សង្កាត់សួង និងសង្កាត់វិហារហ្លួង។
- **ស្រុកតំបែរ**៖ ស្រុកនេះ មានចំនួន ០៧ ឃុំ ដែលមានដូចជា ឃុំចុងជាច ឃុំតំបែរ ឃុំនាងទើត ឃុំគោកស្រុក ឃុំសេដា ឃុំត្រពាំងព្រីង និងទឹកជ្រៅ។
- **ស្រុកក្រូចឆ្មារ** ៖ ស្រុកនេះ មានចំនួន ១២ ឃុំ ដែលមានដូចជា ឃុំឈូក ឃុំដំរិល ឃុំកោះពីរ ឃុំ

កំពង់ទ្រាស ឃុំក្រូចឆ្មារ ឃុំប៉ើសទី១ ឃុំប៉ើសទី២ ឃុំព្រែកអាជី ឃុំទួលស្នួល ឃុំទ្រា ឃុំស្វាយឃ្លាំង និងឃុំរកាខ្នុរ។

- **ស្រុកមេមត់** ៖ ស្រុកនេះ មានចំនួន ១៤ ឃុំ ដែលមានដូចជា ឃុំចាន់មូល ឃុំជាំ ឃុំជាំក្រវៀន ឃុំជាំតាម៉ៅ ឃុំដារ ឃុំកំពាន់ ឃុំគគីរ ឃុំមេមង ឃុំមេមត់ ឃុំរំចេក ឃុំរូង ឃុំទន្លូង ឃុំត្រមូង និងឃុំទ្រៀក។
- **ស្រុកអូររាំងឪ** ៖ ស្រុកនេះ មានចំនួន ០៧ ឃុំ ដែលមានដូចជា ឃុំអំពិលតាពក ឃុំគងជ័យ ឃុំដំរិល ឃុំចក ឃុំមៀន ឃុំព្រះធាតុ និងឃុំទួលសូភី។
- **ស្រុកពញាក្រែក** ៖ ស្រុកនេះ មានចំនួន ០៨ ឃុំ ដែលរួមមានដូចជា ឃុំដូនតី ឃុំកណ្ដោលជ្រុំ ឃុំកក់ ឃុំកោងកាង ឃុំក្រែក ឃុំពពេល ឃុំត្រពាំងផ្លុង និងឃុំវាលម្លូរ។
- **ស្រុកត្បូងឃ្មុំ** ៖ ស្រុកនេះ មានចំនួន ១៤ ឃុំ ដែលមានដូចជា ឃុំអញ្ចើម ឃុំបឹងព្រួល ឃុំជីគរ ឃុំជីរោទ៍ទី១ ឃុំជីរោទ៍ទី២ ឃុំជប់ ឃុំថ្មពេជ្រ ឃុំល្ងៀង ឃុំមងរៀវ ឃុំពាមជីលាំង ឃុំគរ ឃុំកាពប្រាំ ឃុំស្រឡប់ និងឃុំទន្លេបិទ។

*ផែនទីរដ្ឋបាលប្រទេសកម្ពុជា*



# ២. ស្ថានភាពប្រជាជនកម្ពុជា

## ២.១. ចំនួន និងរបាយប្រជាជនកម្ពុជា

យោងតាមជំរឿនឆ្នាំ២០០៨ ប្រជាជនកម្ពុជាទាំងអស់មានចំនួន ១៣ ៣៩៥ ៦៨២ នាក់ ដែលក្នុងនោះ បុរសមានចំនួន ៦ ៥១៦ ០៥៤ នាក់ និងស្ត្រីចំនួន ៦ ៨៧៩ ៦២៨ នាក់ (៥១.៣៦%) ហើយអត្រាកំណើនប្រជាជនប្រចាំឆ្នាំមាន ១.៤៥%។ ប៉ុន្តែបើយោងទៅតាមជំរឿនប្រជាជនកម្ពុជាក្នុងឆ្នាំ២០១៩ វិញ ប្រជាជនកម្ពុជាទាំងអស់មានចំនួន ១៥ ២៨៨ ៤៨៩ នាក់ ដែលនៅក្នុងនោះ បុរសមានចំនួន ៧ ៤១៨ ៥៧៧ នាក់ (៤៨.៥%) និងស្ត្រីមានចំនួន ៧ ៨៦៩ ៩១២នាក់ (៥១.៥%) ហើយនិងអត្រាកំណើនប្រជាជនប្រចាំឆ្នាំមាន ១.២%។

***តារាងស្តីអំពីចំនួនប្រជាជនសរុបតាមតំបន់ និងតាមភេទ ឆ្នាំ២០១៩***

| តំបន់ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| វាលរាប | ៣ ៦០៨ ៤៤៨ | ៣ ៨៦៨ ៩៩៦ | ៧ ៤៧៧ ៤៤៤ |
| ទន្លេសាប | ៣ ២២៦ ៣៧៥ | ២ ៤៧៤ ៨៨៥ | ៤ ៨០១ ២៦០ |
| មាត់សមុទ្រ | ៥១៦ ៧១១ | ៥៤ ៤៤៣៧ | ១ ០៦១ ១៤៨ |
| ភ្នំ និងខ្ពង់រាប | ៩៦៧ ០៤៣ | ៩៨១ ៥៩៤ | ១ ៩៤៨ ៦៣៧ |
| **សរុប** | **៧ ៤១៨ ៥៧៧** | **៧ ៨៦៩ ៩១២** | **១៥ ២៨៨ ៤៨៩** |

*ប្រភព ៖ សៀវភៅជំរឿនប្រជាជនកម្ពុជាឆ្នាំ២០១៩*

តាមរយៈទិន្នន័យខាងលើនេះ បានបង្ហាញឱ្យឃើញថា អត្រាកំណើនប្រជាជនកម្ពុជាប្រចាំឆ្នាំមានការធ្លាក់ចុះយ៉ាងខ្លាំង បើធៀបទៅនឹងលទ្ធផលជំរឿនឆ្នាំ ២០០៨។ យោងតាមលទ្ធផល នៃជំរឿនប្រជាជនកម្ពុជាក្នុងឆ្នាំ២០១៩ នេះផងដែរ ក៏បានបង្ហាញឱ្យឃើញថា ប្រជាជនកម្ពុជាមានរបាយមិនស្មើគ្នាទៅតាមតំបន់នោះទេ ពោលគឺតំបន់វាលរាបមានប្រជាជនរស់នៅច្រើនជាងគេបំផុត ក្នុងលំដាប់ទី១ និងបន្ទាប់មកទៀត គឺតំបន់ទន្លេសាបមានប្រជាជនរស់នៅច្រើន នៅក្នុងលំដាប់ទី២។

បើយោងទៅតាមរបាយនៃប្រជាជនកម្ពុជា គេបែងចែកប្រទេសកម្ពុជាជា ៤ តំបន់ធំៗ ដែលរួមមានដូចខាងក្រោមនេះ ៖

- **តំបន់វាលរាប** ៖ តមបន់នេះ មានរាជធានីភ្នំពេញ ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ប្រមូលផ្តុំទៅដោយប្រជាជនរស់នៅចំនួន ៧ ៤៧៧ ៤៤៤នាក់ ដែលស្មើនឹង ៤៨.៩%។
- **តំបន់ទន្លេសាប** ៖ តំបន់នេះ រួមមានខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ ប្រមូលផ្តុំទៅដោយប្រជាជនរស់នៅសរុបចំនួន ៤ ៨០១ ២៦០ នាក់ ដែលស្មើនឹង ៣១.៤%។
- **តំបន់មាត់សមុទ្រ** ៖ តំបន់នេះ មានខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកោះកុង ប្រមូលផ្តុំទៅដោយប្រជាជនរស់នៅសរុបចំនួន ១ ០៦១ ១៤៨ នាក់ ដែលស្មើនឹង ៦.៩។

- **តំបន់ភ្នំ និងខ្ពង់រាប** ៖ តំបន់នេះ រួមមានខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ និងខេត្តកំពង់ស្ពឺ ដែលប្រមូលផ្ដុំទៅដោយប្រជាជនរស់នៅសរុបចំនួន ១ ៩៤៨ ៦៣៧ នាក់ ដែលស្មើនឹង ១២.៧%។

ប៉ុន្តែក្នុងចំណោមរាជធានី និងខេត្តទាំង ២៥ គឺរាជធានីភ្នំពេញមានប្រជាជនរស់នៅខ្ពស់ជាងគេ គឺចំនួន ២ ១២៩ ៣៧១នាក់ ដែលស្មើនឹង ១៣.៩% បន្ទាប់មក គឺខេត្តកណ្ដាលដែលមានចំនួន ១ ១៩៥ ៥៤៧នាក់ ស្មើនឹង ៧.៨% ខេត្តព្រៃវែងមានចំនួន ១ ០៥៧ ៤៣៨នាក់ ស្មើនឹង ៦.៩% ខេត្តសៀមរាប មានចំនួន ១ ០០៦ ៥១២នាក់ ស្មើនឹង ៦.៦% ខេត្តបាត់ដំបងចំនួន ៩៨៧ ៤០០នាក់ ស្មើនឹង ៦.៥% ខេត្តតាកែវចំនួន ៨៩៩ ៤៨៥នាក់ ស្មើនឹង ៥.៩% និងចុងខេត្តកំពង់ចាមដែលមានចំនួន ៨៩៥ ៧៦៣ នាក់ ស្មើនឹង ៥.៨៩% ចំណែកឯខេត្តកែបវិញមានចំនួនប្រជាជនរស់នៅតិចជាង គេបំផុតគឺ ៤១ ៧៩៨ នាក់ ស្មើនឹង ០.៣%។

***ផែនទីស្ដីពីចំនួនប្រជាជនកម្ពុជាសរុប តាមរាជធានី ខេត្ត និងភេទ ឆ្នាំ២០១៩***




*ប្រភព ៖ សៀវភៅជំរឿនប្រជាជនកម្ពុជាឆ្នាំ២០១៩*

## ២.២. ដង់ស៊ីតេប្រជាជនកម្ពុជា

ដង់ស៊ីតេប្រជាជន គឺជាផលធៀបរវាងចំនួនប្រជាជន និងផ្ទៃដី ដោយគិតជាចំនួននាក់ ក្នុងមួយគីឡូម៉ែត្រការេ។ ប្រសិនបើចំនួនប្រជាជនមានការកើនឡើងនៅក្នុងអំឡុងពេលមួយ ប៉ុន្តែទំហំផ្ទៃដីនៅដដែល នោះដង់ស៊ីតេប្រជាជននឹងកើនឡើងជាសមាមាត្រ។ ដង់ស៊ីតេប្រជាជនកម្ពុជាបានចាប់ផ្ដើមកើនឡើងពី ៦៤ នាក់ ក្នុង ១ គ.ម² នៅឆ្នាំ១៩៩៨ ទៅ ៧៥នាក់ ក្នុង ១ គ.ម² នៅឆ្នាំ២០០៨ គឺកើនឡើងចំនួន ១១នាក់ និងទៅ ៨៦នាក់ ក្នុង ១ គ.ម² (មិនគិតអំពីផ្ទៃបឹងទន្លេសាប) នៅឆ្នាំ២០១៩ គឺកើនឡើង ១១នាក់ ផងដែរ តែនៅក្នុងរយៈពេលមួយទស្សវត្សរ៍ប៉ុណ្ណោះ បើធៀបទៅនឹងឆ្នាំ២០០៨។

យោងទៅតាមតួលេខជំរឿនឆ្នាំ ២០១៩ បានបង្ហាញថា ដង់ស៊ីតេប្រជាជនកម្ពុជាមានការប្រែប្រួលយ៉ាងខ្លាំង ទៅតាមតំបន់នានានៃប្រទេសកម្ពុជា។ ជាទូទៅ តំបន់ដែលមានផ្ទៃដីធំ គឺមានដង់ស៊ីតេប្រជាជនទាបជាង ផ្ទុយពីតំបន់ដែលមានផ្ទៃដីតូច គឺមានដង់ស៊ីតេប្រជាជនខ្ពស់ជាង។ ដង់ស៊ីតេប្រជាជននៅតំបន់វាលរាបមានចំនួនខ្ពស់ជាងគេគឺ ២៩៨នាក់ ក្នុង ១ គ.ម² បន្ទាប់មកទៀត គឺតំបន់ទន្លេសាបមានដង់ស៊ីតេប្រជាជន ៧១នាក់ ក្នុង ១ គ.ម² តំបន់មាត់សមុទ្រមានដង់ស៊ីតេប្រជាជន ៦២នាក់ ក្នុង ១ គ.ម² ខណៈដែលនៅក្នុងតំបន់ភ្នំ និងខ្ពង់រាបវិញមានដង់ស៊ីតេប្រជាជនទាបជាងគេបំផុត គឺមាន ២៩នាក់ ក្នុង ១ គ.ម²។

*ផែនទីស្ដីអំពីដង់ស៊ីតេប្រជាជនកម្ពុជាតាមរាជធានី និងខេត្តនៃប្រទេសកម្ពុជា ឆ្នាំ២០១៩*




*ប្រភព ៖ សៀវភៅជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៩*

*តារាងដង់ស៊ីតេប្រជាជនកម្ពុជាតាមតំបន់ ឆ្នាំ២០០៨-២០១៩*

| តំបន់ | ផ្ទៃដីគិតជា គ.ម² | ដង់ស៊ីតេប្រជាជនគិតក្នុង ១ គ.ម² | |
|---|---|---|---|
| | | ២០០៨ | ២០១៩ |
| វាលរាប | ២៥ ០៦៩ | ២៦១ | ២៩៨ |
| ទន្លេសាប | ៦៧ ៦៦៨ | ៥៧ | ៧១ |
| មាត់សមុទ្រ | ១៧ ២៣៧ | ៥៦ | ៦២ |
| ភ្នំ និងខ្ពង់រាប | ៦៨ ០៦១ | ២២ | ២៩ |
| **សរុប** | **១៨១០៣៥** | **៧៥** | **៨៦** |

*ប្រភព ៖ សៀវភៅជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៩*

បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៨ ដង់ស៊ីតេប្រជាជនគ្រប់តំបន់ទាំងអស់ ជាពិសេសតំបន់ទំនាបវាលរាបបានកើនឡើងពី ២៦១នាក់ ក្នុង ១ គ.ម² ដល់ទៅ ២៩៨នាក់ ក្នុង ១ គ.ម² ឬបានកើនឡើងចំនួន ៣៧នាក់ ក្នុង ១ គ.ម² តំបន់ទន្លេសាបបានកើនឡើងចំនួន ១៤នាក់ ក្នុង ១ គ.ម² រីឯតំបន់មាត់សមុទ្រវិញបានកើនឡើងចំនួន ៦នាក់ ក្នុង ១ គ.ម² និងតំបន់ភ្នំ និងខ្ពង់រាបបានកើនឡើងដល់ចំនួន ៧ នាក់ ក្នុង ១ គ.ម²។

តាមបណ្ដារាជធានី ខេត្ត ឆ្នាំ២០១៩ បានបង្ហាញឱ្យឃើញថា ដង់ស៊ីតេប្រជាជនកម្ពុជាមានការប្រែប្រួលពីកម្រិត ៣ ១៣៦នាក់ ក្នុង ១ គ.ម² នៅរាជធានីភ្នំពេញដែលខ្ពស់ជាងគេបំផុត បន្ទាប់មកទៀត គឺខេត្តកណ្ដាល ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តព្រះសីហនុ ខេត្តត្បូងឃ្មុំ ខេត្តបន្ទាយមានជ័យ ខេត្តកែប ខេត្តកំពង់ស្ពឺ និងខេត្តកំពត តាមលំដាប់លេខរៀង។ ចំណែក ឯខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង ខេត្តប៉ៃលិន ខេត្តបាត់ដំបង និងខេត្តកំពង់ធំ មានដង់ស៊ីតេប្រជាជនចន្លោះពី ៤៩នាក់ ដល់ ៩៧នាក់ ក្នុង ១ គ.ម²។ ខេត្តកោះកុង និងខេត្តមណ្ឌលគិរី គឺជាខេត្តដែលមានដង់ស៊ីតេប្រជាជនទាបជាងគេបំផុតគឺចំនួន ១២ នាក់ ក្នុង ១ គ.ម² សម្រាប់ខេត្តកោះកុង និងចំនួន ៦ នាក់ ក្នុង ១ គ.ម² សម្រាប់ខេត្តមណ្ឌលគីរី។ ដង់ស៊ីតេប្រជាជនកម្ពុជាបានកើនឡើងនៅគ្រប់ខេត្ត និងរាជធានី នៅក្នុងអត្រាតិច ឬច្រើន គឺអាស្រ័យទៅលើការរីកចម្រើននៃវិស័យកសិកម្ម វិស័យពាណិជ្ជកម្ម វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ សង្គម និងវប្បធម៌។

## ២.៣. អត្រាកំណើនប្រជាជនកម្ពុជា

អត្រកំណើនប្រជាជន គឺជាភាគរយ ដែលបានមកពីផលសងរវាងអត្រាជាតិប្រមាណ និង អត្រាមរណប្រមាណរបស់ប្រជាជននៅក្នុងតំបន់មួយ ឬនៅក្នុងប្រទេសមួយ។ យោងតាមតួលេខជំរឿនប្រជាជនកម្ពុជាឆ្នាំ២០១៩ បានបង្ហាញថា ចំនួនប្រជាជនកម្ពុជាសរុបកើនឡើងត្រឹមតែ ១ ៨៩២ ៨០៧នាក់ប៉ុណ្ណោះ ដែលត្រូវជា ១៤.១% ក្នុងរយៈពេល ១១ ឆ្នាំ គឺចន្លោះពីឆ្នាំ២០០៨ និងឆ្នាំ២០១៩ នៅក្នុងអត្រាកំណើនប្រចាំឆ្នាំ ១.២%។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំបានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារតែ អត្រាលទ្ធភាពបង្កកំណើតធ្លាក់ចុះ និងចលនាចំណាកស្រុករបស់ប្រជាជនកម្ពុជា ទៅកាន់បណ្ដាប្រទេសផ្សេងៗនៅលើពិភពលោក។

អត្រាកំណើនប្រជាជនប្រចាំឆ្នាំខ្ពស់បំផុត គឺត្រឹម ២.២% មាននៅតំបន់ភ្នំ និងខ្ពង់រាប ដែលមានខេត្តភាគច្រើននៅភូមិភាគភាគឦសាន និងបន្ទាប់មកទៀត គឺតំបន់វាលរាបដែលមានអត្រាកំណើនប្រចាំឆ្នាំ ១.២% ។ ដោយឡែកតំបន់មាត់សមុទ្រ និងតំបន់ទន្លេសាបវិញ មានអត្រាកំណើនប្រជាជនប្រចាំឆ្នាំត្រឹមតែ ០.៩% ប៉ុណ្ណោះ។ មានតែតំបន់វាលរាប និងតំបន់មាត់សមុទ្រប៉ុណ្ណោះ ដែលមានអត្រាកំណើនប្រជាជនប្រចាំឆ្នាំកើនឡើង ចំណែកឯតំបន់ទន្លេសាបវិញ មានអត្រាកំណើនប្រជាជនប្រចាំឆ្នាំធ្លាក់ចុះ បើធៀបទៅនឹងឆ្នាំ២០០៨ ហើយតំបន់ខ្ពង់រាប និងភ្នំមានអត្រាកំណើនហាក់ស្ថិតនៅថេរ គឺនៅក្នុងរង្វង់ ២.២%។

***តារាងស្តីអំពីអត្រាកំណើនប្រជាជនកម្ពុជាប្រចាំឆ្នាំ តាមតំបន់ ឆ្នាំ២០០៨-២០១៩***

| តំបន់ | ឆ្នាំ២០០៨ | ឆ្នាំ២០១៩ | ឆ្នាំ១៩៩៨-២០០៨ | ឆ្នាំ២០០៨-២០១៩ |
|---|---|---|---|---|
| វាលរាប | ៦៥៤ ៧៩៥៣ | ៧ ៤៧៧ ៤៤៤ | ១.០ | ១.២ |
| ទន្លេសាប | ៤ ៣៥៦ ៧០៥ | ៤ ៨០១ ២៦០ | ២.១ | ០.៩ |
| មាត់សមុទ្រ | ៩៦០ ៤៨០ | ១ ០៦១ ១៤៨ | ០.៨ | ០.៩ |
| ភ្នំ និងខ្ពង់រាប | ១ ៥៣០ ៥៤៤ | ១ ៩៤៨ ៦៣៧ | ២.២ | ២.២ |
| **សរុប** | **១៣៣៩៥៦៨២** | **១៥ ២៨៨ ៤៨៩** | **១.៥** | **១.២** |

*ប្រភព ៖ សៀវភៅជំរឿនប្រជាជនកម្ពុជាឆ្នាំ២០១៩*

## ២.៤. អត្រាមរណៈនៃប្រជាជនកម្ពុជា

អត្រាមរណប្រមាណ គឺជាភាគពាន់ នៃចំនួនប្រជាជន ដែលបានកើតហើយស្លាប់នៅក្នុងតំបន់ណាមួយ ឬនៅក្នុងប្រទេសណាមួយ នៅក្នុងឆ្នាំណាមួយ ដែលបានមកផលធៀបរវាងប្រជាជន ដែលបានកើតហើយស្លាប់សរុបនៅក្នុងតំបន់ ឬប្រទេសនោះនៅលើប្រជាជនសរុប រួចគុណនឹង ១០០០។

យោងតាមលទ្ធផលជំរឿនប្រជាជនកម្ពុជាឆ្នាំ២០១៩ បានបង្ហាញថា អត្រាមរណប្រមាណនៅប្រទេសកម្ពុជាយើង គឺមានភាពល្អប្រសើរឡើងគួរឱ្យកត់សម្គាល់ ពោលគឺមានការធ្លាក់ចុះជាលំដាប់។ តាមលទ្ធផលនេះ បានបង្ហាញថា នៅឆ្នាំ២០១៩ ប្រជាជនកម្ពុជាមានអត្រាមរណប្រមាណ ១៨ ‰ គឺមានការធ្លាក់ចុះចំនួន ៨‰ បើធៀបទៅនឹងលទ្ធផលជំរឿនប្រជាជនកម្ពុជាឆ្នាំ២០០៨ ដែលមានអត្រាមរណប្រមាណរហូតដល់ចំនួន ២៦‰។ ដោយឡែក ចំពោះអត្រាមរណៈមាតាវិញ គេក៏សង្កេតឃើញមានការធ្លាក់ចុះផងដែរ បើធៀបទៅនឹងលទ្ធផលជំរឿនឆ្នាំ២០០៨។ តាមរយៈលទ្ធផលជំរឿនប្រជាជនកម្ពុជាទាំងពីរលើកនេះ បានបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជាមានអត្រាមរណៈមាតាធ្លាក់ចុះពីចំនួន ៤៦១ នាក់ នៅក្នុងឆ្នាំ២០០៨ មកនៅត្រឹមចំនួន ១៤១ នាក់ នៅក្នុងឆ្នាំ២០១៩។

## ២.៥. ទម្រង់តាមអាយុនៃប្រជាជនកម្ពុជា

យោងតាមលទ្ធផលជំរឿនប្រជាជនកម្ពុជាឆ្នាំ ២០០៨ និងឆ្នាំ២០១៩ បានបង្ហាញថា ប្រទេសកម្ពុជាមានទម្រង់ប្រជាជនក្មេង (០-១៤ ឆ្នាំ) បានធ្លាក់ចុះពី ៣៣% ដល់ទៅ ២៩.៤% ទម្រង់ប្រជាជនសកម្ម (១៥-៥៩ ឆ្នាំ) បានកើនឡើងពី ៦០% ទៅ ៦១.៧% និងទម្រង់មនុស្សចាស់ (៦០ ឆ្នាំឡើង) បានកើនឡើងពី ៦.៣% ទៅ ៨%។ តាមរយៈលទ្ធផលនេះ បានបង្ហាញថា ប្រជាជនកម្ពុជាកំពុងតែមានការវិវត្តន៍ទៅតាមអាយុ មានន័យថា ប្រទេសកម្ពុជានឹងមានទម្រង់ប្រជាជនចាស់ច្រើននៅពេលអនាគត។ មូលហេតុដែលធ្វើឱ្យប្រទេសកម្ពុជា

យើងមានទម្រង់មនុស្សចាស់ច្រើនទៅពេលអនាគតនេះ គឺបណ្ដាល មកពីការធ្លាក់ចុះនៃអត្រាលទ្ធភាពបង្កកំណើតស្ត្រី ការធ្លាក់ចុះនូវអត្រាជាតិប្រមាណ និងការធ្លាក់ចុះនូវ អត្រាមរណប្រមាណនៃប្រជាជនកម្ពុជា។

## ២.៦. អត្រាភេទនៃប្រជាជនកម្ពុជា

អត្រាភេទ គឺជាចំនួនបុរសធៀបទៅនឹងចំនួនមនុស្សស្រី ១០០ នក់ នៅទីកន្លែងមួយ ឬតំបន់មួយ ឬខេត្តមួយ ឬនៅប្រទេសមួយ។ ផលធៀបនេះ បើលទ្ធផលលើសពី ១០០ មានន័យថា ចំនួនបុរសច្រើនជាងចំនួនស្ត្រី តែបើលទ្ធផលស្មើ ១០០ នោះមានន័យថា ចំនួនបុរស និងចំនួនស្ត្រី គឺមានចំនួនស្មើគ្នា ក៏ប៉ុន្តែបើលទ្ធផលនេះតិចជាង ១០០ វិញ នោះមានន័យថា ចំនួនបុរសតិចជាងចំនួនស្ត្រី។

យោងទៅតាមលទ្ធផលជំរឿនឆ្នាំ ២០១៩ បានបង្ហាញថា ប្រទេសកម្ពុជាមានប្រជាជនសរុបទាំងអស់ចំនួន ១៥ ២៨៨ ៤៨៩ នាក់ នៅក្នុងនោះ ៤៨.៥% ជាបុរស និង ៥១.៥% ជាស្ត្រី។ ជាទូទៅ ចំនួនកំណើតបុរស និងចំនួនកំណើតស្ត្រី គឺមិនមានសមភាពនឹងគ្នានោះទេ នៅលើពិភពលោក។ ចំនួនកំណើតបុរស តែងតែច្រើនជាងចំនួនកំណើតស្ត្រីជានិច្ច។ តាមការសិក្សាអំពីការផ្តល់កំណើតកូន បានបង្ហាញឱ្យឃើញថា ផលធៀបភេទពីធម្មជាតិនៃកំណើតជិត ១១០នាក់ ឬ ១១០នាក់ ទារកប្រុសបានចាប់កំណើតក្នុងផ្ទៃ ក្នុង ១០០នាក់ទារកស្ត្រី។ ផលធៀបភេទពីកំណើតប្រែប្រួល នៅក្នុងរង្វង់ពី ១០២ ទៅ ១១០ នៅប្រទេសភាគច្រើន ចំណែកឯផលធៀបភេទ ឬអត្រាភេទនៅកម្ពុជាយើង គឺមានប្រមាណ ១០៥ នៅឆ្នាំ២០១៩។

ផលធៀបភេទ ឬអត្រាភេទនៅប្រទេសកម្ពុជាយើងមាន ៩៤.៣ បើយោងទៅតាមតួលេខ នៃការធ្វើជំរឿនឆ្នាំ២០១៩។ នេះបញ្ជាក់ឱ្យឃើញថា នៅប្រទេសកម្ពុជាស្ត្រីមានចំនួនច្រើនជាងចំនួនបុរស ក្នុងចំណោមប្រជាជនកម្ពុជាយើង។ នៅក្នុងបណ្ដាប្រទេសជាច្រើនមានអត្រាភេទស្ថិតនៅក្នុងចន្លោះចាប់ពី ៩៥ ទៅ ១០៥។ ផលធៀបភេទ ឬអត្រាភេទនៅប្រទេសកម្ពុជាយើងហាក់បានស្ថិតនៅថេរ ចាប់តាំងពីឆ្នាំ២០០៨ មក។

យោងតាមលទ្ធផល នៃជំរឿនប្រជាជនកម្ពុជាឆ្នាំ២០១៩ បានបង្ហាញឱ្យឃើញថា អត្រាភេទ ឬផលធៀបភេទនៅប្រទេសកម្ពុជាយើង មានភាពខុសគ្នាពីខេត្តមួយទៅខេត្តមួយទៀត។ ខេត្តចំនួន ៨ ដែលមានផលធៀបភេទ ឬអត្រាភេទខ្ពស់លើសពី ១០០ គឺមានខេត្តស្ទឹងត្រែង (១០៨.៧) ខេត្តឧត្តរ-មានជ័យ (១០៥.៩) ខេត្តមណ្ឌលគីរី (១០៥.៦) ខេត្តព្រះសីហនុ (១០២.៤) ខេត្តប៉ៃលិន (១០២) ខេត្តកោះកុង (១០១.៦) ខេត្តព្រះវិហារ (១០១.៥) និងខេត្តរតនគីរី (១០០.៦)។ ផលធៀបភេទ ឬ អត្រាភេទនៅក្នុងរាជធានីភ្នំពេញមានត្រឹមតែ ៩៥.៣ តែប៉ុណ្ណោះ។ ខេត្តដែលមានផលធៀបភេទ ឬអត្រាភេទទាបជាងគេ គឺខេត្តបាត់ដំបងដោយសារតែបុរសពេញវ័យភាគច្រើនទៅធ្វើការនៅក្នុងរោងចក្រ ឬនៅក្នុងវិស័យសេដ្ឋកិច្ចផ្សេងៗ ឬផ្លាស់ប្ដូរទៅកន្លែងផ្សេង នៅក្នុងប្រទេសកម្ពុជា ឬធ្វើចំណាកស្រុកទៅកាន់ប្រទេសជិតខាង។

*តារាងស្តីអំពីអត្រាភេទ តាមរាជធានី ខេត្ត ឆ្នាំ២០០៨-២០១៩*

| រាជធានី/ខេត្ត | ចំនួនប្រជាជនឆ្នាំ ២០១៩ | | ផលធៀបភេទ | |
|---|---|---|---|---|
| | ប្រុស | ស្រី | ឆ្នាំ ២០០៨ | ឆ្នាំ ២០១៩ |
| បន្ទាយមានជ័យ | ៤២៦ ១០៤ | ៤៣៣ ៤៤១ | ៩៥.៨ | ៩៨.៣ |
| បាត់ដំបង | ៤៥៨ ៩០២ | ៥២៨ ៤៩៨ | ៩៧.៦ | ៨៦.៨ |

| រាជធានី/ខេត្ត | ចំនួនប្រជាជនឆ្នាំ ២០១៩ | | ផលធៀបភេទ | |
|---|---|---|---|---|
| | ប្រុស | ស្រី | ឆ្នាំ ២០០៨ | ឆ្នាំ ២០១៩ |
| កំពង់ចាម | ៤២៨ ៤៨១ | ៤៦៧ ២៨២ | ៩១.៧ | ៩១.៧ |
| កំពង់ឆ្នាំង | ២៥១ ៨៩៥ | ២៧៤ ០៣៧ | ៩២.៥ | ៩១.៩ |
| កំពង់ស្ពឺ | ៤២៤ ០៣៩ | ៤៤៨ ១៨០ | ៩៤.៦ | ៩៤.៦ |
| កំពង់ធំ | ៣២៧ ០១៣ | ៣៥០ ២៤៧ | ៩៥.១ | ៩៣.៤ |
| កំពត | ២៨០ ៥៣៧ | ៣១២ ៣០៨ | ៩៤.២ | ៨៩.៨ |
| កណ្ដាល | ៥៨០ ១២៩ | ៦១៥ ៤១៨ | ៩៤.២ | ៩៤.៣ |
| កោះកុង | ៦២ ៣០៤ | ៦១ ៣១៤ | ១០២.០ | ១០១.៦ |
| ក្រចេះ | ១៨៥ ៤២៩ | ១៨៧ ៣៩៦ | ៩៩.៤ | ៩៩.០ |
| មណ្ឌលគីរី | ៤៥ ៥៣៣ | ៤៣ ១១៦ | ១០៥.៥ | ១០៥.៦ |
| ភ្នំពេញ | ១ ០៣៩ ១៩២ | ១ ០៩០ ១៧៩ | ៨៩.៤ | ៨៥.៣ |
| ព្រះវិហារ | ១២៦ ៦២៤ | ១២៤ ៧២៨ | ៩៩.៤ | ១០១.៥ |
| ព្រៃវែង | ៥០១ ៣៤៦ | ៥៥៦ ០៨២ | ៩១.៧ | ៩០.២ |
| ពោធិ៍សាត់ | ២០០ ៣៩២ | ២១១ ៣៦៧ | ៩៤.៥ | ៩៤.៨ |
| រតនគីរី | ១០២ ៣២៥ | ១០១ ៧០២ | ១០២.៤ | ១០០.៦ |
| សៀមរាប | ៤៩១ ៥៦៨ | ៥១៤ ៩៤៤ | ៩៦.៤ | ៩៥.៥ |
| ព្រះសីហនុ | ១៥៣ ២៥៥ | ១៤៩ ៦៣២ | ១០០.១ | ១០២.៤ |
| ស្ទឹងត្រែង | ៨៣ ០៩៣ | ៧៦ ៤៧២ | ៩៩.៣ | ១០៨.៧ |
| ស្វាយរៀង | ២៤៩ ៤៤៦ | ២៧៥ ១០៨ | ៩២.២ | ៩០.៧ |
| តាកែវ | ៤២៣ ៦៤៩ | ៤៦៦ ៨៣៦ | ៩៤.៦ | ៩២.៧ |
| ឧត្ដរមានជ័យ | ១៣៤ ៣៥០ | ១២៦ ៩០២ | ១០១.៦ | ១០៥.៩ |
| កែប | ២០ ៦១៥ | ២១ ១៨៣ | ៩៧.៨ | ៩៧.៣ |
| ប៉ៃលិន | ៣៦ ១៥១ | ៣៥ ៤៤៩ | ១០៦.៤ | ១០២.០ |
| ត្បូងឃ្មុំ | ៣៧៧ ២០៥ | ៣៩៨ ០៩១ | ៩៤.៦ | ៩៤.៨ |
| **សរុប** | **៧ ៤១៨ ៥៧៧** | **៧ ៨៦៩ ៩១២** | **៩៤.៥** | **៩៤.៣** |

*ប្រភព ៖ សៀវភៅជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៩*

## ២.៧. លទ្ធភាពបង្កកំណើតនៃប្រជាជនកម្ពុជា

អត្រាលទ្ធភាពបង្កកំណើតស្ត្រី គឺជាចំនួនកូនជាមធ្យម ដែលស្ត្រីម្នាក់អាចបង្កើតបាននៅក្នុងដំណាក់កាលបន្តពូជ ចាប់ពីអាយុ ១៤ ឆ្នាំ ដល់អាយុ ៤៤ឆ្នាំ នៅតំបន់ណាមួយ ឬប្រទេសណាមួយ។

យោងតាមជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៩ បានបង្ហាញថា អត្រាលទ្ធភាពបង្កកំណើតស្ត្រីនៅប្រទេសកម្ពុជាបានថយចុះពីចំនួនកូនគិតជាមធ្យម ដែលស្ត្រីមានពី ៥.២ នាក់ នៅឆ្នាំ១៩៩៨ មកនៅត្រឹម

៣.១ នាក់ នៅក្នុងឆ្នាំ២០០៨ និងបានបន្តធ្លាក់ចុះមកនៅត្រឹម ២.៥ នាក់ នៅក្នុងឆ្នាំ២០១៩។ ទោះបីជាអត្រានេះ បានធ្លាក់ចុះក៏ដោយ ប៉ុន្តែបើធៀបទៅនឹងបណ្តាប្រទេសនៅក្នុងតំបន់ អត្រានេះនៅតែមានកម្រិតខ្ពស់ជាងគេនៅឡើយ។ ជាទូទៅ អត្រាលទ្ធភាពបង្កកំណើតស្ត្រីនៅប្រទេសកម្ពុជាមានការប្រែប្រួលទៅតាមកត្តាមួយចំនួនដូចជា កត្តាភូមិសាស្ត្រ កត្តាសេដ្ឋកិច្ច កត្តាទំនៀមទំលាប់ និងកត្តាកម្រិតវប្បធម៌។ ស្ត្រីកម្ពុជា ដែលមិនបានចូលរៀនមានកូនច្រើនជាងស្ត្រីកម្ពុជា ដែលបានចូលរៀនត្រឹមកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ រីឯស្ត្រីកម្ពុជាដែលបានរៀនចប់កម្រិតមធ្យមសិក្សាទុតិយភូមិ និងខ្ពស់ជាងនេះ លទ្ធភាពបង្កកំណើតរបស់ពួកគេក៏ថយចុះជាងនឹងនោះផងដែរ។

លទ្ធភាពបង្កកំណើតស្ត្រី គឺជាកត្តាមួយដ៏សំខាន់ សម្រាប់កំណត់អំពីសន្ទស្សន៍អភិវឌ្ឍមនុស្សនៅក្នុងប្រទេសមួយ។ នេះ មានន័យថា ប្រសិនបើប្រទេសមួយមានសន្ទស្សន៍អភិវឌ្ឍមនុស្សទាប នោះលទ្ធភាពបង្កកំណើតស្ត្រី គឺមានកម្រិតខ្ពស់។ ក៏ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើប្រទេសមួយមានសន្ទស្សន៍អភិវឌ្ឍមនុស្សខ្ពស់វិញ នោះលទ្ធផាពបង្កកំណើតស្ត្រីរបស់ប្រទេសនោះ គឺមានកម្រិតទាបទៅវិញ។

## ២.៨. ជំណុះប្រជាជនកម្ពុជា

ប្រទេសកម្ពុជាយើង គឺស្ថិតនៅចំទីប្រសព្វផ្លូវជំនួញនៃប្រទេសពីរ គឺប្រទេសឥណ្ឌា និងចិន។ ដូចនេះហើយ បានជាអរិយធម៌របស់ប្រទេសយើងទទួលឥទ្ធិពលពីអរិយធម៌របស់ប្រទេសទាំងនេះ។

អស់រយៈពេលជាច្រើនសតវត្សនៅមុនគ.ស ជនជាតិជាម្ចាស់ស្រុកដើមដែលបានចូលមករស់នៅតាំងពីយូរយាណាស់មកហើយ (Australoides) និងពួកមេឡាណេស៊ី (Melanesiens)។ ពួកគេទាំងពីរក្រុមនេះ គឺជាជាតិសាសន៍ស្បែកខ្មៅ។ ក្រោយមកទៀត គឺនៅសតវត្សទី ១០ មុនគ.ស មានពួកឥណ្ឌូនេស៊ីជាតិសាសន៍ស្បែកលឿង បានចូលមករស់នៅលាយឡំជាមួយជាតិសាសន៍ខ្មែរ-មន។

នាសតវត្សទី ៣ មុនគ.ស មានចលនាចំណាកស្រុកឥណ្ឌា បានកើតមានឡើងជាប់គ្នារដឹក។ ពួកនេះបានចូលទៅធ្វើនិគមកម្មមកលើទឹកដីនៃភូមិភាគអាស៊ីអាគ្នេយ៍ ទាំងនៅលើដីកោះ និងទនៅលើដីគោក។ ពួកព្រាហ្មណ៍ និងអ្នកជំនួញបាននាំចូលមកនូវអរិយធម៌ និងសាសនា ព្រមទាំងភាសាសំស្ក្រឹតផងដែរ។ នៅឥណ្ឌូចិន គេប្រទះឃើញមានជនជាតិនានា ដែលបានរស់នៅជាសង្គមមានរបៀបរៀបចំច្បាស់លាស់ គឺជាជនជាតិចាមនៅវៀតណាមកណ្តាល ខ្មែរនៅជ្រលងទន្លេមេគង្គ និងពួកមននៅភូមា។

ក្រោយមកទៀត ក៏មានការលុកលុយនៃជនជាតិថ្មីៗជាច្រើន មកលើភូមិភាគអាស៊ីអាគ្នេយ៍។ នៅសតវត្សទី ៨ ពួកឥណ្ឌា ពួកម៉ាឡាយូនៅកោះជ្វាបានចូលមកលុកលុយប្រទេសខ្មែរយើង។ ខ្មែរបានឱ្យឈ្មោះពួកនេះថា ជ្វាព្រាហ្មណ៍។ អ្នកស្រុកទំនាបបានចុះចូលជាមួយនឹងពួកជ្វាព្រាហ្មណ៍។ ចំណែកឯពួកកុលសម្ព័ន្ធតំបន់ភ្នំវិញ នៅតែរក្សាបូរណភាពជាតិសាសន៍របស់ខ្លួនជាប់ជានិច្ច។ រហូតមកដល់សព្វថ្ងៃនេះ ក៏ដោយក៏ពួកនេះនៅតែរស់នៅដាច់ដោយឡែកពីគេជាដដែល។

ក្នុងចំណោមពពួកជនជាតិ ដែលបានរស់នៅដាច់ពីគេ គឺពួកនេះមានលក្ខណៈជាពួកឥណ្ឌូនេស៊ី (ស្ទៀង ខា សំរែ ព័រ កួយ)។ ផ្ទុយទៅវិញ ពួកខ្លះ ដែលបានកាត់ពូជជាមួយនឹងពួកនេគ្រីតូ ហើយមិនមានជាប់ទាក់ទងនឹងពួកជ្វាព្រាហ្មណ៍វិញ មានស្បែកខ្មៅ មានលក្ខណៈនេគ្រីតូសុទ្ធ (ស្អូច)។

នៅសតវត្សទី ១៣ មានការលុកលុយនៃពួកម៉ុងហ្គោលលនៅទ្វីបអាស៊ី។ ដោយសារតែការ វង្វាយយក នៃពួកម៉ុងហ្គោលនេះហើយ បានជាពួកកុលសម្ព័ន្ធនៅប្រទេសចិនភាគខាងត្បូងបានភៀសខ្លួនចូលមកលុកលុយនៅឥណ្ឌូចិន។ ពួកថៃ និងពួកយួនបានចូលមករស់នៅតាមជ្រលងទន្លេចៅផ្រះយ៉ា (ទន្លេមេណាម) និងតាមឆ្នេរសមុទ្រឥណ្ឌូចិន ដោយនាំមកនូវអរិយធម៌ចិនមកជាមួយ។

ទំនាក់ទំនងគ្នារវាងខ្មែរ និងជនជាតិចិនបានចាប់ផ្ដើមឡើងតាំងពីសតវត្សដំបូង នៃគ.ស មកម្លេះ។ ប្រតិភូចិនជាច្រើននាក់បានចូលមកទស្សនានៅក្នុងប្រទេសខ្មែរដំបូងបំផុត នៅសតវត្សទី ១៣។ ជំនួញរវាងជាតិសាសន៍ទាំងពីរនេះបានប្រព្រឹត្តទៅតាមផ្លូវគោក និងផ្លូវសមុទ្រ។ បើកាត់តាមជ្រលងទន្លេមេគង្គ ក្បួនទូកចរត្រូវធ្វើដំណើរអស់រយៈពេល ១២ ថ្ងៃ។ នៅតាមផ្លូវសមុទ្រ សំពៅដែលចេញពីគួន់ទុង (Kanton) បើកសំដៅទៅដល់ទន្លេមេគង្គរយៈពេល ១៥ ថ្ងៃ។

ការចូលមកលុកលុយរបស់ជនជាតិម៉ុងហ្គោលនៅឥណ្ឌា និងសាសនាអ៊ីស្លាមនៅឥណ្ឌូណេស៊ីនាសតវត្សទី ១៣ បានធ្វើឱ្យអរិយធម៌នៅអាស៊ីអាគ្នេយ៍រុះរោយ។ នៅឆ្នាំ១២៩៥ ពួកចិនបានមកធ្វើជំនួញនៅប្រទេសខ្មែរ។ ឆូវតាគ្វាន់ បាននិយាយថា ពួកនេះច្រើនយកប្រពន្ធនៅស្រុកខ្មែរ នៅពេលដែលពួកគេបានចូលមកតាំងនៅ។ សព្វថ្ងៃ ពួកចិនដែលធ្វើជំនួញនៅក្នុងប្រទេសខ្មែរភាគច្រើន គឺសុទ្ធសឹងតែមានប្រពន្ធ។ ចិនជាអ្នកបង្កាត់ពូជខ្មែរយ៉ាងទៀងទាត់ និងឆាប់រហ័សបំផុត ដែលជាហេតុធ្វើឱ្យសក់ខ្មែរលែងរួញ និងមានស្បែកជ្រះថ្លា។ ក្រោយមកទៀត ចាប់តាំងពីសតវត្សទី ១៧ មក មានជនជាតិខ្លះបានចូលមករស់នៅប្រទេសខ្មែរ ដើម្បីគេចពីសង្គ្រាមដូចជា ជនជាតិចាម ជនជាតិយួន និងជនជាតិលាវ និងដើម្បីធ្វើជំនួញដូចជា ជនជាតិភូមា ឥណ្ឌា ចិន និងជនជាតិអឺរ៉ុបជាដើម។

## ២.៩. ជាតិសាសន៍នានានៅប្រទេសកម្ពុជា

បច្ចុប្បន្ន ប្រទេសកម្ពុជាមានប្រជាជនសរុបមានចំនួន ១៥ ២៨៨ ៤៨៩នាក់ (ឆ្នាំ២០១៩)។ ក្នុងចំណោមប្រជាជន ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាយើង មានជនជាតិប្លែកៗគ្នាជាច្រើន ដែលគេសម្គាល់ឃើញមានដូចជា ជនជាតិខ្មែរសុទ្ធ ខ្មែរចូលជាតិ ខ្មែរលើ ឬពួកកុលសម្ព័ន្ធជនជាតិដើម និងជនបរទេស។ មានពួកចំណូលស្រុកខ្លះ បានចូលមករស់នៅក្នុងស្រុកខ្មែរជាប់តែម្ដង និងពួកចំណូលស្រុកខ្លះទៀត បានចូលមករស់នៅក្នុងស្រុកខ្មែរយើងមិនបានជាប់ស្ថិតស្ថេរនោះឡើយ។

### ក. ខ្មែរសុទ្ធ

ជនជាតិខ្មែរសុទ្ធ ជាជនជាតិភាគច្រើន ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាយើង។ ជនជាតិខ្មែរសុទ្ធ គឺមានមាឌខ្ពស់ល្មម (កម្ពស់ជាមធ្យមសរុប ១.៦២ ម៉ែត្រ និងស្ត្រីកម្ពស់ ១.៥០ ម៉ែត្រ) ប៉ុន្តែ ខ្ពស់ជាងជនជាតិវៀតណាម ហើយខ្មែរសុទ្ធមានស្បែកសម្បុរស្រអែម ច្រមុះធំ ថ្ពាស់ត្រដើល បបូរមាត់ក្រាស់ សក់ខ្មៅ និងរឹងមាំ។ ចំណែកចិត្តគំនិតវិញ យោងទៅតាមការអប់រំខាងផ្លូវព្រះពុទ្ធសាសនា និងមួយទៀតយោងទៅតាមជីវភាពសុខស្រួល ខ្មែរមានចរឹតនឹង ស្ងាត់ស្ងៀម ប្រកបដោយជំនឿ ព្រមទាំងជាមនុស្សឧស្សាហ៍ព្យាយាមធ្វើកាងារ។

## ខ. ខ្មែរចូលជាតិ

ខ្មែរចូលជាតិ គឺជាប្រជាជនដែលបានចូលមកតាំងទី នៅប្រទេសខ្មែរតាំងពីយូរយារណាស់មកហើយ មានសិទ្ធិ និងកាតព្វកិច្ចដូចជនជាតិខ្មែរសុទ្ធដែរ។ ជនជាតិទាំងនេះមានដូចជា ជ្វា អ៊ីស្លាម លាវ និងភូមា។

- **ខ្មែរឥស្លាម** ៖ ក្រុមនេះរួមមានពួកចាម និងពួកជ្វា។ ពួកចាមបានរស់នៅឥណ្ឌូចិនតាំងពីយូរយារណាស់មកហើយ។ រាជាណាចក្រចាម គឺជានគរចម្បាដែលរីកលូតលាស់យ៉ាងខ្លាំងនៅមុនសតវត្សទី១០ ហើយត្រូវបាត់បង់ទឹកដីបន្តិចម្តងៗ រហូតដល់អស់រលីង។ ពួកជ្វាមានដើមកំណើតមកពីលើកោះស៊ូម៉ាត្រា និងកោះជ្វាដែលមានដើមកំណើតពីជាតិម៉ាឡាយូប៉ូលីនេស៊ី។ ជនជាតិចាម និងជនជាតិជ្វាជាបងប្អូននឹងគ្នាយ៉ាងជិតណាស់។ ខ្មែរឥស្លាមច្រើនតែរស់នៅក្នុងខេត្តកំពង់ស្ពឺ នៅតាមដងទន្លេធំ និងនៅដងទន្លេសាប ហើយពួកគេប្រកបរបរនេសាទ។
- **ពួកលាវ** ៖ មានចំនួនច្រើនគួរសម និងច្រើនរស់នៅខេត្តស្ទឹងត្រែង កំពង់ធំ បាត់ដំបង។ ពួកលាវមិនមែនជាអ្នកចំណូលស្រុកទេ គេជាអ្នកតំណវង្សត្រកូលពួកឈ្លើយសង្គ្រាម ដែលគេនាំយកមកនៅប្រទេសខ្មែរ។ ដោយសារភាសា សាសនា ទំនៀមទំលាប់ស្រដៀងគ្នានឹងខ្មែរដែរ ទើបពួកគេរស់នៅលាយឡំជាមួយខ្មែ រហើយប្រកាន់យករបៀបរបបរស់ដូចខ្មែរដែរ។
- **ពួកភូមា** ៖ ពួកនេះមាននៅក្នុងតំបន់ប៉ៃលិនតាំងពីសតវត្សទី ១៩ មកម្លេះ ហើយពួកគេច្រើនប្រកបរបរជាអ្នកជីករកត្បូង។ ភូមាមានការរីកចម្រើនខ្លាំងនៅឆ្នាំ១៩០០ ដោយមានឯកទេសក្នុងការធ្វើការជួញត្បូង។

## គ. ខ្មែរលើ

ខ្មែរលើ គឺជាពួកកុលសម្ព័ន្ធជនម្ចាស់ស្រុកដើម ដែលមានអរិយធម៌មិនសូវជឿនលឿន ហើយពួកនេះគឺជាសំណល់ជនជាតិជនជាតិដើម ឬពួកលុកលុយចាស់ៗ ដែលអ្នកឈ្នះជំនាន់ក្រោយៗបានដេញទៅនៅតំបន់ព្រៃភ្នំ ឬនៅជាយប្រទេស។

- នៅតំបន់ខាងលិចនៅលើភ្នំក្រវ៉ាញ តំបន់វាលរេញ (ខាងលិចកំពត) ខាងជើងខេត្តកំពង់ធំ និងខេត្តសៀមរាប ៖ មានពួកកុលសម្ព័ន្ធខ្មែរជាច្រើនដូចជា ពួកព័រដែលរស់នៅក្នុងតំបន់ខាងលើនៃស្ទឹងពោធិ៍សាត់ ពួកសំរែដែលរស់នៅខាងជើងខេត្តសៀមរាប ពួកកួយដែលរស់នៅខាងជើងខេត្តកំពង់ធំ និងពួកស្អូច ដែលរស់នៅខាងវាលរេញ (ក្រុងព្រះសីហនុ)។ ពួកកុលសម្ព័ន្ធ មានដើមកំណើតមកពីមនខ្មែរ លើកលែងតែពួកស្អូចដែលមានដើមកំណើតមកពី-ពួកនេគ្រីតូគឺមានមាឌតូច ច្រមុះសំប៉ែត ស្បែកខ្មៅ និងសក់ក្រញាញ់។
- នៅតំបន់ខ្ពង់រាបខាងកើត ៖ មានកុលសម្ព័ន្ធជាច្រើនដូចជា ពួកខា ពួកស្មៀង និងពួកពូនង។ ពួកនេះ មានមាឌមធ្យម សម្បុរសសណ្តែកបាយ ក្បាលតូចពយ ថ្ងាសធ្លាក់ ភ្នែកខ្មៅ រាងមាំទន់ភ្លន់ សក់ក្រាស់វែងត្រង់ សរសៃធំៗ និងសង្ហាដូចជា ពួកព័រ សំរែ និងកួយ នៅតំបន់ខាងលិចផងដែរ។ ពួកនេះ ច្រើនតែប្រកបអាជីវកម្មដូចជា ប្រមាញ់ នេសាទ ដំណាំព្រៃដុត គោរពបាតុភូតធម្មជាតិ ហើយមានជំនឿច្រើនណាស់។

### ឃ. ជនបរទេស

ជនបរទេស គឺជាក្រុមជនជាតិ ដែលបានចូលមករកស៊ីលក់ដូរធ្វើជំនួញ ឬមកវិនិយោគទុន ដោយបើកជាក្រុមហ៊ុន ឬសហគ្រាសនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ គេឃើញមានជនបរទេសជាច្រើននៅក្នុងប្រទេសកម្ពុជាដូចជា ជនជាតិចិន ជនជាតិវៀតណាម ជនជាតិថៃ ជនជាតិកូរ៉េ ជនជាតិជប៉ុន និងពួកស្បែកសមួយចំនួនដូចជា ជនជាតិអាមេរិក ជនជាតិបារាំង ជនជាតិអង់គ្លេសជាដើម...។

## សំណួរត្រិះរិះ

1. ចូរពិពណ៌នាអំពីរបៀប នៃការជ្រើសតាំងព្រះមហាក្សត្រថ្មីនៅព្រះរាជាណាចក្រកម្ពុជា។
2. តើព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាព្រះរាជតួនាទី និងភារកិច្ចយ៉ាងដូចម្ដេចខ្លះ?
3. តើស្ថាប័ននយោបាយ នៃប្រទេសកម្ពុជាចែកចេញជាប៉ុន្មានអំណាច? អ្វីខ្លះ? ចូរពន្យល់។
4. ចូរពិពណ៌នាអំពីរបៀប នៃការរៀបចំព្រឹទ្ធសភានៅប្រទេសកម្ពុជា។
5. តើព្រឹទ្ធសភានៅប្រទេសកម្ពុជាមានតួនាទី និងភាកិច្ចអ្វីខ្លះ?
6. ចូរពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់រដ្ឋសភានៅប្រទេសកម្ពុជា។
7. តើរដ្ឋសភាមានអនុគណៈកម្មការអ្វីខ្លះ? ចូរបង្ហាញ។
8. តើរដ្ឋបាលនៃប្រទេសកម្ពុជាចែកចេញជាប៉ុន្មានថ្នាក់? អ្វីខ្លះ?
9. ចូរពិពណ៌នាអំពីរបៀប នៃការរៀបចំរាជរដ្ឋាភិបាលកម្ពុជា។
10. តើប្រទេសកម្ពុជាមានប៉ុន្មានរាជធានី ខេត្ត? អ្វីខ្លះ? ចូររៀបរាប់។
11. តើខេត្តណាខ្លះ ដែលមានក្រុងពីរ? ចូររៀបរាប់។
12. យោងទៅតាមរបាយប្រជាជនកម្ពុជា តើគេបែងចែកប្រទេសកម្ពុជាជាប៉ុន្មានតំបន់? អ្វីខ្លះ? ក្នុងចំណោមតំបន់ទាំងនេះ តើតំបន់ណាមួយ ដែលមានប្រជាជនរស់នៅច្រើនជាងគេ? ហេតុអ្វី? ចូរពន្យល់។
13. អ្វីជាដង់ស៊ីតេប្រជាជន? ចូរបង្ហាញអំពីដង់ស៊ីតេប្រជាជនកម្ពុជានៅតាមតំបន់នីមួយៗ។
14. អ្វីជាលទ្ធភាពបង្កកំណើតស្ត្រី? តើមានកត្តាអ្វីខ្លះ ដែលជះឥទ្ធិពលទៅលើលទ្ធភាពបង្កកំណើត ស្ត្រីនៅប្រទេសកម្ពុជា? ចូរពន្យល់។
15. អ្វីជាអត្រាភេទ? នៅប្រទេសកម្ពុជា តើអត្រាភេទមានតុល្យភាពគ្នាដែរឬទេ? ហេតុអ្វី? ចូរពន្យល់។
16. តើជាតិសាសន៍ណាខ្លះ ដែលរស់នៅក្នុងប្រទេសកម្ពុជា?
17. តើជាតិសាសន៍ដែលបានចូលមករស់នៅក្នុងប្រទេសកម្ពុជាចែកចេញជាប៉ុន្មានក្រុម? អ្វីខ្លះ? ចូរពន្យល់។

# ជំពូកទី២៖ ភូមិវិទ្យាកសិកម្ម
# មេរៀនទី១៖ លក្ខណៈសំគាល់ទូទៅ និងមូលដ្ឋានគ្រឹះនៃកសិកម្ម

## ១. លក្ខណៈទូទៅនៃកសិកម្ម

### ១.១. កំណើត និងការវិវត្តន៍នៃទេសភាពជនបទ

កសិកម្ម គឺជាដំណាក់កាលដែលឆ្លងកាត់ពីសេដ្ឋកិច្ចបេះផ្លែឈើ ទៅជាកសិកម្មព្រៃដុត។ ដំណាំស្រូវតម្រូវឱ្យមានការងារមមាញឹកដូចជា ការរៀបចំដីដាំដំណាំជាថ្នាក់ៗនៅតាមចង្កេះភ្នំ ការលើក និងការថែរក្សាទំនប់ទឹក ភ្លឺស្រែ និងបំណាចទឹក។ ការងារទាំងអស់នេះ ទាមទារឱ្យមានកំលាំងមនុស្សច្រើនកុះករ ដើម្បីសំរេចបានលទ្ធផល។ ការធ្វើដីជាថ្នាក់ៗ គឺដើម្បីងាយស្រួលក្នុងការទប់ និងបង្ហូរទឹកដាក់ស្រែចម្ការ។ គេបង្កើតដីជាថ្នាក់ៗ បែបនេះ ដោយសារមានដង់ស៊ីតេប្រជាជនខ្ពស់ និងដោយសារមិនសូវសំបូរដីទំនាប សម្រាប់ដាំដំណាំ។ ការរៀបចំដីកសិកម្មតូចៗ គឺជាទេសភាពជនបទ ដែលត្រូវបានច្នៃប្រឌិត ដោយសារសកម្មភាពរបស់មនុស្សមាន លំនៅដ្ឋាន ផ្លូវគមនាគមន៍ និងទុកដីអោយព្រៃដុះ។

ទេសភាពជនបទមានភាពខុសប្លែកៗគ្នាដូចជា ៖

– ទេសភាពជនបទដ៏ធំធេង ហើយគ្មានសណ្តាប់ធ្នាប់នៅអាហ្វ្រិកតំបន់ត្រូពិចសួត។
– ទេសភាពជនបទដែលរៀបចំបានល្អ ឧទាហរណ៍ទេសភាពវាលស្រែនៅអាស៊ី
– ទេសភាពជនបទនៅអឺរ៉ុប ដែលចែកចេញជា ២ ប្រភេទគឺ ៖
  - ចំការចំហរ ឬស្រែវាល (Open field)៖មានផ្ទៃដីដ៏ធំល្វឹងល្វើយ គ្មានដើមឈើ ហើយលំនៅដ្ឋានស្ថិតនៅផ្តុំគ្នា ដែលផ្តុំបានជាភូមិ។
  - ចំការបិទ ឬស្រែចំណារ ៖ មានផ្ទៃដីជួនកាលតូច ជួនកាលធំ ដែលហ៊ុំព័ទ្ធទៅដោយដើមឈើ ហើយផ្ទះសំបែងស្ថិតនៅរាយប៉ាយដាច់ៗពីគ្នា។

ចំការទាំង ២ ប្រភេខាងលើនេះ គឺទាក់ទងទៅនឹងប្រភេទសិលា គឺ ៖ សិលាជ្រាបទឹក គឺជាចំការចំហរ និងសិលាមិនជ្រាបទឹក គឺជាចំការបិទឬចំការចំនារ។

គេប្រមូលផ្តុំដីចំការ ដើម្បីងាយស្រួល ក្នុងការប្រើប្រាស់គ្រឿងម៉ាស៊ីន នៅក្នុងការដាំដំណាំស្រូវ ដូចជានៅប្រទេសជប៉ុន គេបានប្រមូលផ្តុំដីស្រែតូចៗឱ្យបានជាដីស្រែធំៗ ងាយស្រួល ក្នុងការប្រើប្រាស់ត្រាក់ទ័រនៅក្នុងផលិតកម្ម។

**ការរុករានដីថ្មី ៖** ការរុករានដីថ្មីមាន ៖

– ការគាស់រានដីថ្មីសព្វថ្ងៃ ដែលគេហៅថា "រណសិរ្សឈានមុខ" ឧទាហរណ៍ដូចជានៅប្រទេសប្រេស៊ីល ប្រទេសចិន និងការរុករានដីឆ្ពោះទៅទិសខាងលិច នៅអាមេរិកខាងជើងនាសតវត្សរ៍ទី ១៩។
– ប៉ុលឌែ គឺជាដំណើរនៃការរុករានដីថ្មីចូលទៅក្នុងសមុទ្រ ឬតំបន់វាលភក់។ ឧទាហរណ៍ ៖ ការធ្វើប៉ុលឌែនៅប្រទេសហូឡង់ ប្រទេសសិង្ហាបុរី និងប្រទេសជប៉ុនជាដើម។
– ការអភិវឌ្ឍខាងបំណាចទឹក ៖ ដីស្រែបំណាចទឹកថ្មីៗ កាន់តែមានទំហំធំឡើងៗ នៅលើពិភពលោកយើងសព្វថ្ងៃនេះ ដោយមានការលើកទំនប់ ហើយនិងការជីកអណ្តូងយ៉ាងជ្រៅលើសពី ១០០ ម៉ែត្រ។

ឧទាហរណ៍ ៖ គេដាំស្រូវសាលីនៅវាលលំហ នៃប្រទេសលីប៊ី ប្រទេសអារ៉ាប៊ី ប្រទេសអ៊ីស្រាអែល ហើយជាពិសេសគេដាំកប្បាស ឈើហូបផ្លែ និងបន្លែ នៅកាលីហ្វូញ៉ាសហរដ្ឋអាមេរិក (ដំណាំបន្លែមានតំលៃខ្ពស់ សំរាប់ផ្គត់ផ្គង់ដល់ទីក្រុង)។

ទំនាស់ដណ្តើមធនធានទឹកបានកើតមានឡើងកាន់តែខ្លាំងឡើងៗ។ តើទំនាស់នេះ វាជាទំនាស់នៅសតវត្សរ៍ទី ២១ នេះ ឬយ៉ាងណា? ឧទាហរណ៍៖ ដូចជានៅក្បែរបូព៌ា ទំនាស់ទឹកបានកើតមានបន្ថែមទៅលើទំនាស់ដីធ្លី។ បញ្ហានេះ អាចមានលក្ខណៈកាន់តែធ្ងន់ធ្ងរ សម្រាប់មនុស្សជំនាន់ក្រោយៗទៀត។ ឧទាហរណ៍ ៖ កាលណាមានទន្លេមួយហូរកាត់ប្រទេសជាច្រើន គេចាំបាច់ត្រូវតែបង្កើតគណៈកម្មការអន្តរប្រទេស ដើម្បីធ្វើសុវត្ថិកម្មផ្លូវទឹកនេះ ដូចជាទន្លេមេគង្គ ទន្លេសេនេកាល់ជាដើម។

គេប្រើប្រាស់ធនធានទឹក ដោយមធ្យោបាយ ២ បែបគឺ ៖

- ការធ្វើប្រឡាយបង្ហូរទឹកចេញ
- បំនាចទឹក (ការបូបយកទឹកចេញពីក្នុងដី គឺបានមកពីព្រែកជីក។ ឧទាហរណ៍ ៖ ដូចជានៅប្រទេសចិន ប្រទេសអេហ្ស៊ីប ដែលបានមកពីទឹកបំរុងទុក និងបានមកពីធ្វើទំនប់ទឹកដោយគេប្រើរហាត់ទឹក ដើម្បី នាំយកទឹកមកបញ្ចូលស្រែ)។

## ១.២. ប្រព័ន្ធកសិកម្មនៅលើពិភពលោក

យោងតាមការងារអនុវត្តជាក់ស្តែងប្រចាំថ្ងៃនៅក្នុងវិស័យកសិកម្ម គេចែកប្រព័ន្ធកសិកម្មជា ២ ប្រភេទធំៗ ដែលរួមមាន ៖

### ក. ប្រព័ន្ធកសិកម្មបែបយថាផល

ប្រព័ន្ធកសិកម្មបែបយថាផល គឺជាការអនុវត្តផ្នែកកសិកម្ម ដែលឱ្យផលតិច ក្នុងមួយឯកតានៃផ្ទៃដី។ គេប្រើប្រាស់មធ្យោបាយដ៏សាមញ្ញ ចំនាយទុនតិច ហើយប្រើកំលាំងពលកម្មក៏តិច។

ឧទាហរណ៍ ៖

- កសិកម្មព្រៃដុតបែបប្រពៃណីនៅអាស៊ីតំបន់ភ្នំ និងនៅអាហ្វ្រិក
- ការចិញ្ចឹមសត្វបែបយថាផលនៅអាមេរិក (Ranching)
- កសិដ្ឋានយ៉ាងទំនើប (Hancienda) ធំៗ នៅអាមេរិកឡាទីន ១០ ០០០ ហិចតា
- ការចិញ្ចឹមសត្វបែបពនេចរ នៅតំបន់ស្ងួតហែង

នៅក្នុងនោះគេសង្កេតឃើញកសិកម្មបែបយថាផលមានលក្ខណៈវិនិច្ឆ័យ ២ បែបទៀតគឺ ៖

**១. កសិកម្មបែបយថាផល និងផលិតផលទាប**

កសិករមានផ្ទៃដីធ្វើកសិកម្មច្រើន ប៉ុន្តែក្នុងមួយឆ្នាំៗ កសិករមិនអាចដាំដុះលើផ្ទៃដីទាំងអស់បាននោះទេ។ កំលាំងពលកម្ម ដែលគេប្រើសំរាប់ធ្វើកសិកម្មមានចំនួនតិច គេប្រើវិធីដាំដុះ និងវិធីចិញ្ចឹមសត្វយ៉ាងសាមញ្ញ ហើយទិន្នផលដែលទទួលបានទាប ក៏ប៉ុន្តែកិច្ចប្រឹងប្រែងរបស់គេ មានតែមួយរយៈពេលប៉ុណ្ណោះ ក្នុងមួយឆ្នាំៗ។ កសិកម្មបែបនេះ គេសង្កេតឃើញមានអនុវត្តនៅទ្វីបអាហ្វ្រិក នៅក្នុងតំបន់ដាច់ស្រយាល នៃទ្វីបអាស៊ីដូចជា តំបន់មជ្ឈឹមបូព៌ា អាស៊ីកណ្តាល និងអាស៊ីខាងជើង នៅតំបន់ ត្រជាក់ខ្លាំងនៅអាមេរិកខាងជើង និងនៅតំបន់ត្រូពិកដាច់ស្រយាល នៃទ្វីបអាមេរិកខាងត្បូង និងទ្វីបអាហ្វ្រិក។

**២. កសិកម្មបែបយថាផល និងផលិតភាពខ្ពស់**

កសិករមិនចាំបាច់ដាំដុះលើផ្ទៃដីទាំងអស់នោះទេ ពីព្រោះគេអាចផលិតបានច្រើនបង្គួរហើយ។ ទិន្នផលដែលទទួលបាន គឺពុំសូវខ្ពស់ណាស់ណានោះឡើយ ក៏ប៉ុន្តែកសិករម្នាក់ៗមានដីច្រើន ហើយប្រព័ន្ធកសិកម្មបែបនេះ ភាគច្រើនទាក់ទងទៅនឹងកសិ-ពាណិជ្ជកម្មជាបង្គួរ សម្រាប់ទីផ្សារ ពិសេសមានផលិតផលលើស និងមានការកើនឡើងនូវដំណាំមាសប្រាក់សម្រាប់នាំចេញ។ ជាទូទៅ កសិកម្មប្រភេទនេះ គេសង្កេតឃើញមាននៅតំបន់ត្រូពិក ដែលជាច់ស្រយាលតិចតួច នៃទ្វីបអាមេរិកឡាទីន អាហ្វ្រិក (ចំការធំៗ) ហើយនិងអាស៊ីអាគ្នេយ៍ និងកំពុងតែគ្របដណ្តប់នៅលើផ្ទៃដីមួយភាគធំ ក្នុងនៅទ្វីបអឺរ៉ុប អាមេរិកខាងជើង និងទ្វីបអូសេអានី។

**ខ. ប្រព័ន្ធកសិកម្មបែបអតិផល**

ជាប្រភេទកសិកម្ម ដែលផ្តល់ផលច្រើនក្នុងមួយឯកតាផ្ទៃដី ដែលធ្វើដោយផ្ចិតផ្ចង់ និងចំណាយដើមទុនច្រើន ហើយភាគច្រើនបំផុតមានផលិតផលលើស សម្រាបនាំចេញទៅទៅលើទីផ្សារអន្តរជាតិ។ គ្មានប្រព័ន្ធណាមួយផ្សេងទៀត នៅក្នុងពិភពលោក ដែលផលិតនៅលើមួយឯកតា នៃផ្ទៃដីជាមូលដ្ឋានបានច្រើនជាងប្រព័ន្ធបែបនេះនោះឡើយ។ វា គឺជាប្រព័ន្ធមួយ ដែលគោលដៅសំខាន់របស់កសិករ គឺដើម្បីបង្កើននូវទិន្នផលនៅលើផ្ទៃដីកសិកម្ម។

ឧទាហរណ៍ ៖

- ការធ្វើស្រែបែបប្រពៃណីនៅអាស៊ី
- ដំណាំក្រោមស៊ែរ ៖ ជាដំណាំ ដែលគេដាំនៅលើរងធំ ហើយវែងៗគ្របពីលើដោយកញ្ចក់ ឬផ្លាស្ទិកដើម្បីថែរក្សាកម្តៅ និងការពារកំណក។
- ការចិញ្ចឹមសត្វនៅក្នុងក្រោលដូចជាការចិញ្ចឹមមាន់ ទា ជ្រូក គោ ក្របី ដែលបង្ខាំងនៅក្នុងទ្រុងក្នុងក្រោលជាប់រហូត។
- ដំនាំធញ្ញជាតិនៅអឺរ៉ុប សហរដ្ឋអាមេរិកផ្តល់នូវទិន្នផលខ្ពស់ ៨ តោន ក្នុងមួយហិចតា នៅក្នុងនោះគេសង្កេតឃើញកសិកម្មបែបអតិផលនេះ ក៏មានលក្ខណៈវិនិច្ឆ័យ ២ បែបទៀតដែរគឺ ៖

**១. កសិកម្មបែបអតិផល និងផលិតផលទាប**

កសិករមួយចំនួនធំធ្វើការអស់ពីសមត្ថភាពនៅលើផ្ទៃដីដាំដុះ ប៉ុន្តែទទួលបានផលតិច បើប្រៀបធៀបទៅនឹងកំលាំងពលកម្ម ដែលគេបញ្ចេញ។ គ្រប់ប្រព័ន្ធកសិកម្មទាំងអស់នៅលើពិភពលោកថ្ងៃនេះ ប្រហែលជាកញ្ចប់មួយដ៏ធំបំផុត ដែលត្រូវបានគេដាក់នៅលើប្រព័ន្ធមួយ ដែលបានផ្គត់ផ្គង់នៅក្នុងតំបន់ ដែលមានប្រជាជនច្រើនបំផុត និងមានកំណើនយ៉ាងលឿនបំផុតនៅលើពិភពលោក។ នៅក្នុងតំបន់ភូមិភាគអាស៊ីភាគខាងត្បូង និងអាស៊ីខាងកើត កសិកម្មបែបអតិផលនៅតែស្ថិតនៅនឹងថ្កល់ ហើយនៅតែជាប្រព័ន្ធផលិតកម្មចំណីអាហារដ៏សំខាន់ សម្រាប់តំបន់។ វា គឺជាប្រព័ន្ធមួយ ដែលគោលដៅសំខាន់របស់កសិករ គឺដើម្បីបង្កើននូវទិន្នផលដោយគ្មានគិតពីតំលៃ ក៏ប៉ុន្តែដើម្បីផ្គត់ផ្គង់តែជីវភាពប្រជាជននៅក្នុងតំបន់។ កសិកម្មបែបនេះ គេសង្កេតឃើញមាននៅក្នុងតំបន់ដែលមានកំនើនប្រជាជនខ្ពស់ នៅទ្វីបអាស៊ី ក្នុងតំបន់ជនបទដូចជា នៅតាមតំបន់ប្រព័ន្ធទន្លេសំខាន់ៗ (ជ្រលងទន្លេយ៉ាងសេ ទន្លេមេគង្គ ទន្លេគង្គា ទន្លេឥណ្ឌូ ទន្លេលឿង...) និងតំបន់

ទំនាបលិចទឹករបស់ពួកគេ។ វាគឺជាប្រព័ន្ធមួយដែលអាចជួយចញ្ចឹម ប្រជាជនពិភពលោកបានប្រហែលជា ៦០%។ ប្រព័ន្ធកសិកម្មបែបនេះ គេសង្កេតឃើញមានផលិតផល លើសតិចតួចណាស់ ឬគ្មានផលិតផលលើសនោះទេ ហើយភាគច្រើនផលិត សម្រាប់ប្រើប្រាស់នៅក្នុងតំបន់តែប៉ុណ្ណោះ។

**២. កសិកម្មបែបអតិផល និងផលិតភាពខ្ពស់**

កសិករមួយចំនួនតូចបានធ្វើការងារអស់ពីសមត្ថភាពនៅលើផ្ទៃដីដាំដុះរបស់ពួកគេ ប៉ុន្តែម្នាក់ៗទទួលបានផលច្រើន អាស្រ័យដោយអនុភាពនៃមធ្យោបាយដែលគេមាន និងការប្រើប្រាស់ក្នុងវិស័យ កសិកម្ម។ កសិកម្មបែបនេះភាគច្រើនបំផុត មានផលិតផលលើសដែលអាចនាំចេញ ហើយទិន្នផលមួយភាគធំ ត្រូវបានគេនាំយកទៅលក់ឱ្យអ្នកប្រើប្រាស់នៅខាងក្រៅតំបន់នៃផលិតកម្ម។ ការអនុវត្តន៍នូវកសិកម្មបែបនេះ គេសង្កេតឃើញមានអនុវត្តនៅទ្វីបអឺរ៉ុបភាគខាងលិច និងកណ្តាល ព្រមទាំងនៅទ្វីបអាមេរិកខាងជើង។

***បែបផែនផ្សេងៗ នៃដំណាំក្នុងពិភពលោក***

| | | |
|---|---|---|
| ដំណាំអតិផល | ទិន្នផលខ្ពស់<br>ទិន្នផលទាប | កសិកម្មអឺរ៉ុប ដំណាំក្រោមស៊ែរ<br>ការធ្វើស្រែតាមបែបប្រពៃណី |
| ដំណាំយថាផល | ទិន្នផលខ្ពស់<br><br>ទិន្នផលទាប | ដំណាំធញ្ញជាតិនៅអាមេរិក<br>ចំការដំណាំធំៗនៅតំបន់ត្រូពិច<br>កសិកម្ម និងការចិញ្ចឹមសត្វនៅ សាហែល (តំបន់ជាយវាលលំហ សាហារ៉ា) |

*ប្រភព ៖ សៀវភៅឯកសារស្រាវជ្រាវរបស់នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ*

## ១.៣. បដិវត្តន៍កសិកម្ម

### ក. បដិវត្តន៍កសិកម្មលើកទី ១ នៅទ្វីបអឺរ៉ុបនាសតវត្សរ៍ទី ១៨

បដិវត្តន៍កសិកម្មលើកទី១ នេះបានកើតមានឡើងដោយសារតែ ៖

- ការអភិវឌ្ឍដំណាំស្មៅ សំរាប់ចិញ្ចឹមសត្វ
- ការប្រើប្រាស់ជីលាមកសត្វ
- ការប្រើកំបោរលើដីសំបូរអាស៊ីត
- ការលេចឡើងនូវដំណាំដែលទាមទារការជម្រះស្មៅដូចជា ដំឡូង សណ្តែក ល្ង ពោត ជាដើម។

### ខ. បដិវត្តន៍លើកទី ២

បដិវត្តន៍កសិកម្មលើកទី២ នេះបានកើតមានឡើងនៅបណ្តាប្រទេសមួយចំនួនដូចជា ៖

- ១៩១៨ - ១៩៣៩ កើតមានឡើងនៅសហរដ្ឋអាមេរិក
- ១៩៥០ កើតមានឡើងនៅបណ្តាប្រទេសក្នុងទ្វីបអឺរ៉ុប
- ១៩៦០ ដែលគេហៅថា បដិវត្តន៍បៃតង ដែលកើតមានឡើងនៅបណ្តាប្រទេសតតីយលោកដូចជា នៅប្រទេសឥណ្ឌា ប្រទេសឥណ្ឌូនេស៊ី ប្រទេសហ្វីលីពីន ប្រទេសចិនជាដើម។

- **បុព្វហេតុ ៖** ដោយសារតែមានការប្រើប្រាស់គ្រឿងយន្ត និងម៉ូទ័រ។ ជាដំបូង គឺការប្រើប្រាស់ត្រាក់ទ័រ ដែលបង្កើនដល់ផលិតភាព។ ការងាររបស់មនុស្សបានថយចុះ។ ប្រភេទដំណាំថ្មីៗ ត្រូវបានបង្កើតឡើងដូចជា ពោតបង្កាត់ពូជ ពូជសត្វជម្រើសថ្មីៗជាដើម។ មានការប្រើប្រាស់ផលិតផលគីមីដូចជា ជី ថ្នាំ សំលាប់សត្វល្អិតជាដើម ដូចជានៅសហរដ្ឋអាមេរិក។

### គ. បដិវត្តន៍កសិកម្មលើកទី ៣

បដិវត្តន៍កសិកម្មលើកទី៣ បានចាប់កំណើតឡើងនៅឆ្នាំ១៩៧០។ ដំណាំក្រៅដី ដែលដុះនៅក្នុងវត្ថុធាតុដីវសាស្រ្ត ដាំលើអេប៉ុងដូចជាដំណាំ ផ្កា បន្លែ សាឡាត់ ប៉េងប៉ោះ ម្ទេស ត្រប់ ត្រសក់ជាដើម។ វា គឺជារុក្ខជាតិដែល ផលិតចេញពីមន្ទីរពិសោធន៍។ ក្នុងនោះ មានការប្រើប្រាស់កុំព្យូទ័រច្រើន ដើម្បីគណនា និងកំណត់បរិមាណរ បបចំណីអាហារសត្វ និងការគ្រប់គ្រងចាត់ចែងលើមនុស្សយន្ត។ ឧទាហរណ៍ ៖ ដូចជា ប្រដាប់រឹតទឹកដោះគោ ដែលដើរដោយអគ្គិសនី។ ពិសេសវិទ្យាសាស្រ្តតំណពូជបានធ្វើឱ្យសម្រេចប្រែក្លាយសែនរុក្ខជាតិដោយបណ្តុះនូវកោសិកាថ្មីៗ។ ឧទាហរណ៍ ៖ ដូចជា OGM សរីរាង្គតំណពូជ ដែលទទួលកំណែប្រែរួចមក ហើយត្រូវបានគេបញ្ចូលទៅក្នុងដំណាំពោត សណ្តែកសៀង ហើយនិងត្រីសូម៉ុងចិញ្ចឹម។

នៅក្នុងបណ្តាប្រទេសអ្នកមាន គេបានចំណាយលុយកាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីធ្វើការស្រាវជ្រាវ និងផលិតឱសថថ្មីៗ សម្រាប់ម្រើឱ្យកសិកម្មទំនើប។ ឧទាហរណ៍ ៖ ដូចក្រុមហ៊ុនស៊ែល និងក្រុមហ៊ុនមុងតេសង់តូជាដើម។

## ១.៤. របាយសកម្មភាពកសិកម្មលើពិភពលោក

នៅលើពិភពលោកយើងនេះ កសិកម្មមានរបាយមិនស្មើគ្នានោះទេ។ ទាំងនេះ គឺវាអាស្រ័យទៅលើលក្ខខណ្ឌធម្មជាតិ។

### ក. លក្ខខណ្ឌធម្មជាតិកំណត់ពីរបាយកសិកម្ម

- សណ្ឋានដី ៖ ភ្នំ វាលទំនាប ជ្រលង
- អាកាសធាតុ ៖ សំណើម កំណកអាកាស កម្តៅ
- ដី ៖ ស្រទាប់លើ ដែលអាចដំដុះបាន ហើយដែលមានកំរាស់មិនស្មើគ្នា ប្រែប្រួលមិនស្មើគ្នា និងមានជីជាតិ មិនដូចគ្នា។
- ផ្លូវទឹក ៖ មានប្រភពទឹក ប្រឡាយ ស្ទឹង ត្រពាំង បឹងបួរ...។ ដោយសារកត្តាទាំងនេះហើយ ទើបគេឃើញមានតំបន់កសិកម្មខុសៗគ្នាជាច្រើន នៅលើពិភពលោកដូចជាកសិកម្មនៅ ៖

#### ១. មជ្ឈដ្ឋានត្រជាក់បង្គួរសើម

- មជ្ឈដ្ឋានត្រជាក់បង្គួរសើមហើយត្រជាក់ ៖ ដីខ្សត់ជីជាតិដូចជា ដីប៉ុតសុលជាដើម ប៉ុន្តែគេអាចចិញ្ចឹមសត្វតាមបែបបុរាណ។
- មជ្ឈដ្ឋានត្រជាក់បង្គួរទ្វីប ៖ អនុគ្រោះច្រើនដល់ដំណាំធញ្ញជាតិ ហើយកន្លែងខ្លះគេប្រទះឃើញដីមានជីជាតិខ្លាំងដូចជាដី ឈែណូស្យូមនៅប្រទេសរុស្សី អនុគ្រោះដល់ដំណាំស្រូវសាលី។
- មជ្ឈដ្ឋានត្រជាក់បង្គួរសើម ឬត្រជាក់បង្គួរសមុទ្រ ៖ ជាមជ្ឈដ្ឋាន ដែលអនុគ្រោះដល់ការចិញ្ចឹមសត្វ និងដំណាំពោត។

- មជ្ឈដ្ឋានជ្រាក់បង្គួរមេឌីទែរ៉ានេ ៖ ដីប្រភេទនេះ គឺទទួលរងនូវភាពរាំងស្ងួតនៅរដូវក្ដៅ។ គេសង្កេតឃើញមានដំណាំធម្មជាតិដែលមិនពឹងអាស្រ័យទៅលើបំនាចទឹកដូចជា ស្រូវសាលីបែបយថាផល ដំណាំទំពាំងបាយជូ និងដំណាំអូលីវ។ ក៏ប៉ុន្តែនៅទីណា ដែលអាចធ្វើបំនាចទឹកបាននោះគេអាចដាំដំណាំបន្លែពពួកក្រូច និងផ្កា។

**២. កសិកម្មនៅមជ្ឈដ្ឋានត្រជាក់បង្គួរស្ងួត**

វាគឺជាវាលស្ដិបដែលលាតសន្ធឹងយ៉ាងធំល្វឹងល្វើយ ហើយដែលស្ថិតនៅទ្វីបឆ្ងាយពីសមុទ្រ។ ឧទាហរណ៍ដូចជានៅ ៖

- វង់ស្រូវសាលីនៅសហរដ្ឋអាមេរិក
- ស្រូវសាលីនៅរុស្ស៊ី
- នៅប្រទេសកាហ្សាក់ស្ថានដែលត្រូវរៀបចំប្រព័ន្ធធារាសាស្ត្រយ៉ាងលំបាក និងចំនាយថវិកាច្រើនសម្រាប់ដំណាំកប្បាស ។

**៣. កសិកម្មមជ្ឈដ្ឋានត្រូពិចស្ងួត**

គេសង្កេតឃើញមានវាលលំហយ៉ាងធំធេងដូចជាវាលលំហសាហារ៉ានៅអាហ្វ្រិក និងនៅឧបទ្វីបអារ៉ាប់ជាដើម។ នៅទីនោះមានការចិញ្ចឹមសត្វបែបពនេចរ នៅតាមជាយនៃតំបន់សាហែល និងនៅក្នុងអាស៊ីស។ នៅតំបន់ត្រូពិចស្ងួតនេះ ដីងាយស្រួលប្រែប្រួលបំផុត ភ្លៀងមិនទៀងទាត់ រដូវស្ងួតមានរយៈពេលវែង។ គេចិញ្ចឹមសត្វ និងដំណាំបែបយថាផលបំផុត។ កំណើនប្រជាជនខ្ពស់ បានធ្វើឱ្យវាលលំហកាន់តែរីករាលដាលធំ (សកម្មភាពរបស់មនុស្សកាប់ដើមឈើ)។

**៤. កសិកម្មក្នុងមជ្ឈដ្ឋានត្រូពិចសើម**

កម្ដៅ និងសំណើម គឺជាកត្តាអនុគ្រោះដល់ការលូតលាស់ នៃរុក្ខជាតិ។ ប៉ុន្តែដីងាយស្រួលខ្សោះជីជាតិបំផុត ពីព្រោះទឹកជ្រាបនាំយកជីជាតិទៅផ្នែកខាងក្រោម នៃជំរៅដី។ ដីនោះក្លាយទៅជាដីអាស៊ីត ហើយជាចុងក្រោយ កាលណារដូវប្រាំងមានរយៈពេលវែង ដីនោះអាចក្លាយទៅជាស្រទាប់ក្ដាំងរឹងនៃដីបាយក្រៀម។ ដីនេះមានពណ៌ក្រហមរឹងដូចឥដ្ឋ គ្មានជីជាតិសោះឡើយ។ ប៉ុន្តែសកម្មភាពរបស់មនុស្ស អាចធ្វើឱ្យដីមានជីជាតិ។ ឧទាហរណ៍ដូចជា ៖

- ដីស្រែនៅទ្វីបអាស៊ីមួយចំនួនធំបានត្រូវកែច្នៃឱ្យមានជីជាតិ ដែលអាចយកផលពី ២ ទៅ ២ ដងក្នុង ១ ឆ្នាំ។
- ដំណាំចម្ការធំៗទំនើបនៅតំបន់ត្រូពិក លើដីមានជីជាតិល្អ។

*រូបភាពទី ១ ៖ កត្តាធម្មជាតិ នៃរបាយសកម្មភាពកសិកម្ម*




*ប្រភព ៖ សៀវភៅឯកសារស្រាវជ្រាវរបស់នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ*

## ខ. ការកើតឡើងនៃទំនើបកម្មក្នុងកសិកម្ម

### ១. សេដ្ឋកិច្ច

ការធ្វើទំនើបកម្ម នៅក្នុងសិកម្ម គឺមានការពឹងផ្អែកយ៉ាងសំខាន់ទៅលើកម្រិត នៃការវិវត្តន៍ផ្នែកសេដ្ឋកិច្ច។ នេះមានន័យថា នៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើនលូតលាស់ នាំឱ្យគេឈានទៅរកការប្រើប្រាស់បច្ចេកទេសទំនើបនៅក្នុងកសិកម្ម។

### ២. ប្រជាគណន៍ ឬប្រជាសាស្ត្រ

ប្រជាគណន៍ ឬប្រជាសាស្ត្រ ក៏បានជះឥទ្ធិពលយ៉ាងខ្លាំងក្លាផងដែរទៅលើកសិកម្ម។ កាលណាប្រជាជនមានការកើនឡើងច្រើន នោះតម្រូវការស្បៀងអាហារក៏មានការកើនឡើងផងដែរ ដូច្នេះវាតម្រូវឱ្យគេអនុវត្តនូវកសិកម្មទំនើបបែបអតិផល។

## គ. សង្គមបែបបុរាណ ឬពាណិជ្ជកម្ម

កសិកម្មក្នុងសង្គមបុរាណ គឺជាផលិតកម្មចិញ្ចឹមពោះ ឬផលិតកម្មស្បៀងអាហារ។ វាមិនអាចបង្កើនឱ្យមានជាចរន្តពាណិជ្ជកម្មបានឡើយ ពីព្រោះពុំមានផលិតផលនៅសល់ សម្រាប់ធ្វើពាណិជកម្មនោះឡើយ។ សកម្មភាពនេះ កើតមានដំបូងឡើងនៅទ្វីបអឺរ៉ុបរហូតដល់សតវត្សរ៍ទី១៨ និងមានរហូតដល់សព្វថ្ងៃ នៅក្នុងបណ្តាប្រទេសក្រីក្រជាច្រើននៅលើពិភពលោក។ កសិករដាំគ្រប់ដំណាំ ដែលគេត្រូវការ គឺជាពហុវប្បកម្ម គឺផ្ទុយពីឯកវប្បកម្ម។ ឧទាហរណ៍ដូចជា ៖

- នៅទ្វីបអាហ្វ្រិក គេដាំពោត សកហ្គោ មីល បន្លែ និងចិញ្ចឹមបក្សីស្រុក
- នៅទ្វីបអាស៊ី គេដាំស្រូវ បន្លែ ផ្លែឈើ ចិញ្ចឹមជ្រូក និងបក្សីស្រុក
- នៅទ្វីបអឺរ៉ុប គេដាំដំណាំស្រូវសាលី ដំឡូងបារាំង បន្លែ ចិញ្ចឹមគោ និងបក្សីស្រុក
- នៅទ្វីបអាមេរិកឡាទីន គេដាំពោត សណ្តែក និងចិញ្ចឹមមាន់

បច្ចុប្បន្ននេះ កសិកម្មបែបនេះ ភាគច្រើនត្រូវបានផ្លាស់ប្តូរហើយ ភាគច្រើនបានប្រែក្លាយទៅជាកសិកម្មបែបពាណិជ្ជកម្ម ដោយសារតែមានទំនាក់ទំនងជាមួយនឹងពិភពខាងក្រៅដ៏សែនទំនើប។

### ឃ. បដិវត្តន៍ឧស្សាហកម្ម

បដិវត្តន៍ឧស្សាហកម្មបានជះឥទ្ធិពលទៅលើកសិកម្ម។ សំណង់ផ្លូវដែកនៅក្នុងទ្វីបអឺរ៉ុប និងនៅអាមេរិកនាសតវត្សរ៍ទី ១៩ សំណង់ផ្លូវថ្នល់នៅអាហ្វ្រិក និងនៅអាស៊ីនាសតវត្សរ៍ទី ២០ បាននាំឱ្យកើតមាននូវកសិកម្មដើម្បីធ្វើពាណិជ្ជកម្ម គឺគេដាំដើម្បីលក់នៅលើទីផ្សារ។ សកម្មភាពកសិកម្មបែបនេះ គឺកើតមាននៅតាមតំបន់ឯកទេសកម្មថ្នាក់ជាតិ និងជាឯកវប្បកម្ម។

ឧទាហរណ៍ដូចជា ៖

- ដំណាំបន្លែនៅជិតទីក្រុងធំៗ និងនៅជិតទីប្រជុំជនក្រុងធំៗ ៖ ចំការព័រ សាឡាត់ ការ៉ុត ខ្ទឹម ដំណាំផ្តល់ផលមុនគេ ដោយដាំក្រោមស៊ែរ ដើម្បីការពារកំណក។
- ដំណាំផ្កានៅតាខ្មៅ ស្រូវ និងក្រូចនៅបាត់ដំបង

### ខ.. ឯកទេសកម្មលំដាប់ថ្នាក់ពិភពលោក

បច្ចុប្បន្ននេះ ឯកទេសកម្ម គឺស្ថិតនៅក្នុងលំដាប់ថ្នាក់ពិភពលោក ដោយសារតែការរីកចម្រើនដ៏ធំធេងនៃបណ្តូរនៅតាមផ្លូវសមុទ្រ (នាវាពិសេសធំៗ) និងនៅតាមផ្លូវអាកាស (ដំណឹកនាំផ្លែឈើ និងផលិតផលនៃសាទដូចជា បង្គា បង្កងត្រាំទឹកកក)។

បណ្តាប្រទេស ដែលស្ថិតនៅតំបន់ត្រជាក់បង្គួរដូចជា សហរដ្ឋអាមេរិក កាណាដា អឺរ៉ុប អូស្ត្រាលី អាហ្សង់ទីន សុទ្ធសឹងតែជាប្រទេសផលិតករស្រូវសាលីដ៏សំខាន់។ ដើម្បីចៀសវាងកុំឱ្យមានផលិតផលលើសដែលបណ្តាលមកពីទិន្នផលខ្ពស់ សហរដ្ឋអាមេរិកមានបំណង ហើយបានធ្វើឱ្យសម្រេចបានក្នុងការកែប្រែទម្លាប់ហូបចុកនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ឧទាហរណ៍ ៖ ដូចជាវត្តមានរបស់នំប៉័ងនៅក្នុងភូមិតាមប្រទេសទាំងឡាយនៅទ្វីបអាស៊ី និងនៅអាហ្វ្រិក។ នៅទ្វីបអាហ្វ្រិក ឡដុតនំប៉័ងបែបឧស្សាហកម្មជាច្រើនបានប្រកួតប្រជែងឈ្នះលើចំណីអាហារជាតិ ដែលមានតំលៃខ្ពស់។ លក្ខណៈនេះ បានធ្វើឱ្យផលិតករក្នុងស្រុករលំរលាយ។ កសិកម្ម បានក្លាយទៅជាកសិកម្មបែបពាណិជ្ជកម្ម មានន័យថា កសិកម្មផលិត ដើម្បីឱ្យបានប្រាក់កាក់ច្រើន និងទៅតាមតំលៃកំនត់ នៃផលិតកម្មក្នុងពិភពលោក។

ជនជាតិអាមេរិកបានបង្កើតបណ្តាញតារារណប ដើម្បីឃ្លាំមើលផលដំណាំក្នុងពិភពលោក និងធ្វើការសម្រេចចិត្តថា តើត្រូវបង្កើនផលិតកម្ម ឬក៏ត្រូវទុកដីឱ្យទំនេរ ឬក៏ត្រូវកាត់បន្ថយស្តុក ឬក៏លក់ក្នុងពេលដែលតំលៃឡើងខ្ពស់។ បណ្តាប្រទេសអ្នកមាន គឺជាអ្នកកំណត់នូវតំលៃទំនិញនៅក្នុងពិភពលោក រីឯបណ្តាប្រទេសក្រីក្រមិនអាចធ្វើផលិតកម្មឱ្យបានស្មើនឹងប្រទេសអ្នកមានទាំងនោះបានឡើយ។

## ២. មូលដ្ឋានគ្រឹះនៃកសិកម្ម

### ២.១. តួនាទីកសិកម្មក្នុងខឿនសេដ្ឋកិច្ច

#### ក. កសិកម្មផ្តល់ស្បៀងអាហារ

កសិកម្ម គឺជាផ្នែកមួយយ៉ាងសំខាន់ ចំពោះប្រជាជនពិភពលោក ម្យ៉ាងវិញទៀត កសិកម្មបានកើតមានតាំងពីយូរយាណាស់មកហើយ។ ក្នុងបណ្តាផ្នែកផលិតកម្មរបស់សង្គម នៅពេល ដែលសង្គមមនុស្សទើបនឹងកកើតមនុស្សចេះបេះរុក្ខផល ចេះបរបាញ់ ដើម្បីទាញយកផលទាំងនោះមកចិញ្ចឹមខ្លួន ហើយនៅពេលណាដែលមនុស្សចាប់សត្វបានច្រើន មនុស្សចេះចិញ្ចឹមឡើងវិញទៀតផង។

យ៉ាងណាមិញ កសិកម្មបានក្លាយជារចនាសម្ព័ន្ធ នៃមូលដ្ឋានរបស់ខឿនសេដ្ឋកិច្ចសង្គម វាពិតជាបានផ្តល់នូវស្បៀង សម្រាប់ចិញ្ចឹមជីវិតមនុស្ស និងសត្វនៅក្នុងសង្គមមនុស្ស។ អ្នកប្រាជ្ញម្នាក់ឈ្មោះ អង់ហ្គែលបានឱ្យនិយមន័យថា កសិកម្ម គឺជាផ្នែកមួយនៃផលិតកម្មយ៉ាងសំខាន់ ដែលពិភពលោកទាំងមូលបានចែងទាំងក្នុងបុរាណសម័យ និងទាំងបច្ចុប្បន្នសម័យ ទៅអនាគតកសិកម្ម ក៏នៅតែមានអត្ថន័យយ៉ាងដូច្នេះដែរ៉។

សព្វថ្ងៃនេះ មានផ្នែកជាច្រើនទើបនឹងកកើតឡើង ប៉ុន្តែកសិកម្មនៅតែរក្សាតួនាទីចំបងក្នុងផ្នែកខឿនសេដ្ឋកិច្ចជាតិរបស់បណ្តាប្រទេសមួយចំនួនធំ ពិសេសបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ចំនួនពលករនៅក្នុងផ្នែកកសិកម្មមានជាងពាក់កណ្តាល នៃចំនួនពលករនៅលើពិភពលោក។ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍកម្លាំងផលិតកម្មផ្នែកកសិកម្មមានអត្រាខ្ពស់ជាងគេ ពី ៦៥% ទៅ ៧០% នៃចំនួនពលករសរុប។ នៅក្នុងបណ្តាប្រទេសអភិវឌ្ឍ ឬបណ្តាប្រទេសមូលធននិយម ចំនួនកសិករមានតែពី ៥% ទៅ១៥% នៃចំនួនពលករសរុបតែប៉ុណ្ណោះ។ កសិកម្ម នៅតែជាផ្នែកមួយដ៏សំខាន់ នៅក្នុងចំណោមផ្នែកនានាទៀត នៃខឿនសេដ្ឋកិច្ចពិភពលោកដែលបានជានាសំណួមពរស្បៀង សម្រាប់ប្រជាជនដែលកំពុងតែកើនឡើងនាពេលបច្ចុប្បន្ន។

#### ខ. កសិកម្មផ្តល់វត្ថុធាតុដើម សំរាប់នាំចេញ និងជំរុញឱ្យវិស័យឧស្សាហកម្ម

តាមទស្សនៈរបស់អ្នកប្រាជ្ញមួយចំនួនបានឱ្យនិយមន័យថា ៉ចង់អភិវឌ្ឍឧស្សាហកម្មឱ្យព្រមគ្នាជាមួយនឹងកសិកម្ម គឺត្រូវធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ចរីកចំរើនជាមុនសិន ទើបយើងអាចជំរុញទាំងពីរផ្នែកនេះទៅមុខបាន៉។ ផ្នែកកសិកម្ម គឺជាភារកិច្ចមួយដ៏ចម្បង ដែលផ្តល់វត្ថុធាតុដើមដល់ឧស្សាហកម្ម ផ្ទុយមកវិញ វិស័យឧស្សាហកម្មពិតជាជំរុញឱ្យវិស័យកសិកម្មរីកចម្រើន។ បើវិស័យឧស្សាហកម្មរីកចម្រើនហើយ ក៏ប៉ុន្តែផ្ទុយទៅវិញ បើវិស័យកសិកម្មមិនរីកចម្រើន នោះសេដ្ឋកិច្ចជាតិប្រៀបបីដូចជាមនុស្សដើរខ្វើចជើងម្ខាងអញ្ចឹងដែរ។ ដូចនេះ កសិកម្ម និងឧស្សាហកម្មមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ជំរុញគ្នាទៅវិញទៅមក ដើម្បីរីកចម្រើនទាំងអស់គ្នា។ ក្នុងនោះ កសិកម្មមានតួនាទីដ៏សំខាន់ ក្នុងការផ្តល់វត្ថុធាតុដើមឱ្យឧស្សាហកម្មធុនស្រាល។ ផ្នែកឧស្សាហកម្មធុនស្រាលប្រើប្រាស់វត្ថុធាតុដើម ៨០% ដែលបានមកពីកសិកម្មផ្តល់ឱ្យ។ ដូចនេះ ល្បឿននៃការរីកចម្រើនផ្នែកឧស្សាហកម្មធុនស្រាល អាស្រ័យយ៉ាងណាទៅលើបរិមាណ និងគុណភាពរបស់កសិផល។

ចំពោះបណ្តាប្រទេសទាំងអស់នៅលើសកលលោក ជាពិសេសបណ្តាប្រទេសអភិវឌ្ឍ (បណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើន កសិកម្មជាផ្នែកមួយដែលស្ថិតនៅក្រោមឥទ្ធិពលរបស់វិទ្យាសាស្រ្តបច្ចេកទេស)។ ពលកម្មបានថយចុះ ពីព្រោះផ្ទៃដីសំរាប់ធ្វើកសិកម្មមិនកើន ឬកើនយឺតពេក ហើយមានយន្តកម្មរីកចម្រើនផង បានជាកម្លាំងពលកម្មមនុស្សត្រូវថយចុះ។ ហេតុនេះ កម្លាំងមនុស្សនៅក្នុងវិស័យកសិកម្មបានផ្តល់ឱ្យវិស័យឧស្សាហកម្ម។

**គ. កសិកម្មផ្តល់ផលិតផលនាំចេញ ដើម្បីបង្កើនរូបិយប័ណ្ណក្នុងសេដ្ឋកិច្ច**

កសិកម្មមានសារៈសំខាន់ណាស់ សម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍ ពិសេសបណ្តាប្រទេស ដែលមានលក្ខខណ្ឌអនុគ្រោះចំពោះវិស័យនេះ។ កសិកម្មបានផ្តល់នូវផលិតផលទៅលក់នៅឯបរទេស ដើម្បីស្រូបយករូបិយប័ណ្ណពីបណ្តាប្រទេសជាច្រើនលើសកលលោក។ បច្ចុប្បន្ននេះ មានបណ្តាប្រទេសជាច្រើន ដែលបាននាំចេញនូវផលិតផលកសិកម្មរបស់ខ្លួនទៅលក់ក្រៅបរទេស ដូចជាប្រទេសប្រេស៊ីលបាននាំចេញកាហ្វេ ៧១% ប្រទេសកាណាដានាំចេញកាការ ៨០% ប្រទេសថៃបាននាំចេញស្រូវ ៣៣% អាមេរិកនាំចេញស្រូវ ១៧ នៅលើពិភពលោក។ នេះមានន័យថាកាហ្វេ ៧១% កាការ ៨០ និងស្រូវ ៣៣ និង១៧% នៅក្នុងទីផ្សារអន្តរជាតិរបស់ប្រទេសប្រេស៊ីល ប្រទេសកាណាដា ប្រទេសថៃ និងសហរដ្ឋអា-មេរិក។

កសិកម្មមានឥទ្ធិពលយ៉ាងខ្លាំងទៅលើល្បឿន នៃការរីកចម្រើននៃសេដ្ឋកិច្ចរបស់បណ្តាប្រទេសនីមួយៗលើពិភពលោក ពិសេសបណ្តាប្រទេសកំពុងអភិវឌ្ឍ។ បណ្តាប្រទេសដែលមានខឿនសេដ្ឋកិច្ចរីកចម្រើន ល្បឿនកើនឡើងនៃចំណូលជារៀងរាល់ឆ្នាំរបស់ខឿនសេដ្ឋកិច្ចជាតិ ក៏អាស្រ័យទៅលើកម្រិតនៃការរីកចម្រើនខាងវិស័យកសិកម្មផងដែរ ពីព្រោះទិន្នផល និងផលិតផលឧស្សាហកម្មមានលំនឹង បានជាគេអាចអភិវឌ្ឍបន្ថែមតាមផែនការឡើងវិញខាងផ្នែកកសិកម្ម ដែលមានលក្ខណៈប្រមូលផលឃ្លេងឃ្លោងតាមរដូវ ហើយផលិតផលខាងផ្នែកកសិកម្ម អាស្រ័យដោយលក្ខខណ្ឌធម្មជាតិ។ លើសពីនេះទៅទៀត ផលិតផលកសិកម្មមួយផ្នែក ក៏បានក្លាយទៅជាផលិតផលប្រើប្រាស់ជាបន្ទាន់ គឺមិនមែនដូចផលិតផលឧស្សាហកម្មនោះឡើយ។ ហេតុដូចនេះ ល្បឿនរីកម្រើននៃកសិផលមានឥទ្ធិពលខ្លាំងក្លា។

**ឃ. កសិផលមានតួនាទីសំខាន់សំខាន់បំផុតដល់វិស័យការពារជាតិ**

ក្រៅពីការហូបចុក និងនាំចេញ កសិផលផ្តល់ស្បៀងអាហារអោយកងទ័ពបានគ្រប់គ្រាន់ ហើយវាយខ្មាំងសត្រូវបានឈ្នះទៀតផង។ កសិកម្ម ជាប្រភពកម្លាំងត្រៀមស្បៀងយ៉ាងសំខាន់ សម្រាប់ខឿនការពារជាតិជាមូលដ្ឋានដ៏រឹងមាំ សម្រាប់បណ្តាប្រទេសទាំងអស់នៅលើពិភពលោក។ ចំពោះបញ្ហានេះ មានអ្នកប្រាជ្ញមួយចំនួនបានអះអាងថា "មូលដ្ឋានពិតរបស់ខឿនសេដ្ឋកិច្ច គឺស្បៀងបម្រុង បើគ្មានរដ្ឋអំណាច គឺប្រទេសជាតិគ្មានអ្វីៗទាំងអស់"។

**២.២. ចំនុចពិសេសរួមនិយាយពីការរីកចំរើនកសិកម្មលើពិភពលោក**

ផលិតផលកសិកម្មនៅលើពិភពលោកបច្ចុប្បន្ននេះ មានការរីកចម្រើនឥតឈប់ឈរ ប៉ុន្តែសង្វាក់នៃការរីកចម្រើនផលិតផលកសិកម្ម គឺនៅតែមានល្បឿនយឺតជាងផលិតផលឧស្សាហកម្មនៅឡើយ។ ដោយហេតុនេះ សមាមាត្ររបស់ផលិតផលកសិកម្ម នៅក្នុងចំណូលថវិការជាតិសរុបមាននិន្នាការថយចុះ។ ដោយទិន្នផលនៃពលកម្មចេះតែកើនដោយសារតែការអនុវត្តបច្ចេកទេសវិទ្យាសាស្រ្តទំនើបនៅក្នុងផ្នែកផលិតកម្ម បង្កើន

យន្តកម្ម អគ្គីសនីកម្ម គីមីកម្ម វារីកម្ម ក្នុងវិស័យកសិកម្ម បានធ្វើឱ្យកើនឡើងឥតឈប់ឈរនូវកសិផល គឺជាមូលដ្ឋាន ហើយចំនួនផលិតផលគិតតាមចំនួនមនុស្សម្នាក់ៗ ក៏ចេះកើនឥតឈប់ឈរផងដែរ។ ផលិតផលកសិកម្ម មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងចំនួនប្រជាជន ផ្នែកកសិកម្ម មិនគ្រាន់តែជាមូលដ្ឋានក្នុងការផ្តល់កម្លាំងពលកម្មឱ្យដល់វិស័យឧស្សាហកម្ម និងផ្នែកផ្សេងៗទៀតប៉ុណ្ណោះទេ តែក៏បានផ្តល់នូវចំណីអាហារ សម្រាប់ទ្រទ្រង់ជីវិតប្រជាជននៅលើពិភពលោកផងដែរ។ កំណើនប្រជាជនពិភពលោកជាប្រចាំនៅតែខ្ពស់ បើយោងតាមការគណនាប្រជាជនពិភពលោកនៅឆ្នាំ ២០០០ បានកើនឡើងដល់ ៦ ពាន់លាននាក់ ហើយនៅឆ្នាំ 2005 នឹងកើនឡើងដល់ 68 ពាន់លាននាក់ និងនៅឆ្នាំ២០២២ នឹងកើនឡើងដល់ជាង ៧០ ពាន់លាននាក់។ អត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំមាន ២.២% ក្នុងពេលជាមួយគ្នានោះដែរ អត្រាកំណើនស្បៀងប្រចាំឆ្នាំគិតជាមធ្យមកើនឡើងនៅក្រោម ២ % តែប៉ុណ្ណោះ។

តាមអ្នកប្រាជ្ញខាងកសិកម្មជនជាតិបារាំងម្នាក់ឈ្មោះ **ហ្សង់ក្លាសឺម៉ាន់** ក្រោយពីបានធ្វើនិទស្សន៍គុណភាព និងបរិមាណសំណូមពរបរិភោគរបស់មនុស្ស ដែលបានពិនិត្យនៅក្នុងអំឡុងចុងឆ្នាំ ១៩៧៦ ដែលមាន ៣៩៧៨ លាននាក់ ឃើញថាបរិមាណស្បៀងនៅក្នុងអំឡុងពេលនោះ មិនជានាបានគ្រប់គ្រាន់ តាមសំណូមពរកំណើនចំនួនប្រជាជនពិភពលោកនៅសម័យនោះទេ។ ពាក់កណ្តាល នៃមនុស្សជាតិនៅពេលនោះ គឺបរិភោគមិនបានគ្រប់គ្រាន់នោះឡើយ ហើយដែលនៅក្នុងនោះមាន ១៥% មានអាហារបរិភោគបានបរិបូរ ១០% មានអាហារបរិភោគបានសមរម្យ ១៥% ទៀតមានអាហារបរិភោគបានមធ្យម និងចំនួន ៥០% មានអាហារបរិភោគមិនគ្រប់គ្រាន់ រីឯ ១០% ទៀត គ្មានអាហារបរិភោគនោះឡើយ។ នៅក្នុងពេលបច្ចុប្បន្ននេះ មានចំនួនប្រជាជននៅលើពិភពលោករាប់លាននាក់ ដែលមានអាហារបរិភោគមិនបានគ្រប់គ្រាន់ពេញមួយឆ្នាំ។ បើយោងទៅតាមលោក Malthus បានលើកឡើងថា ពិភពលោករបស់យើងនាពេលនេះ បានប្រឈមនឹងវិបត្តិដែលនឹងកើតមានឡើង នៅពេលពេលផលិត ផលស្បៀងអាហារមិនបានដើរទាន់ជាមួយនឹងកំនើនប្រជាជននោះ។ លោកបានទស្សន៍ទាយដែលគួរឱ្យភ្ញាក់ផ្អើលជាច្រើនអំពីអនាគតនៃពិភពលោក ដែលយើងរស់នៅ។ លោកបានព្យាករណ៍ថា កំណើនប្រជាជនពិភពលោក ប្រសិនបើយើងមិនបានត្រួតពិនិត្យនោះទេ វានឹងផ្តល់ឱ្យនូវសង្គ្រាមភាពចលាចល ភាពអត់ឃ្លាន ជំងឺដង្កាត់ ហើយនិងភាពក្រខ្សត់។ លទ្ធផលនេះ កើតលេចចេញឡើងមកពីការកើន ឡើងនូវភាពខ្វះខាតខាងស្បៀងអាហារ។ លោកបានសន្និដ្ឋានថា ឥទ្ធិពលបង្កកំណើតរបស់មនុស្សខ្លាំងជាងលទ្ធភាពរបស់ផែនដី ក្នុងការផលិតនូវស្បៀងអាហារ។

អាចនិយាយបានថា ធម្មជាតិមានលទ្ធភាពដ៏សម្បូរបែបនៅក្នុងការផ្តល់ប្រភពចំណីអាហារដល់មនុស្ស តែក្នុងលក្ខខណ្ឌមួយដែលកំណើនប្រជាជនស្ថិតនៅតែក្នុងកម្រិតមួយដ៏សមស្របតែប៉ុណ្ណោះ។ កម្រិតប្រើប្រាស់ចំណីអាហារទាំងអស់ បើតាមលោក **ហ្សង់ក្លួសឺម៉ាន់** បានឱ្យដឹងថា នាដើមសតវត្សរ៍នេះ ប្រជាជនពិភពលោកអាចនឹងឡើងដល់កម្រិតមួយដ៏សមស្រប គឺ ៧០០០ លាននាក់។ ដោយហេតុនេះហើយបរិមាណផលិតផល កសិកម្មត្រូវបង្កើនរៀងរាល់ឆ្នាំពី ៤ ទៅ ៥%។ ស្ថានភាពកសិកម្មនាពេលបច្ចុប្បន្ននេះ ពិបាកជានាកម្រិតកំណើនដូចនេះណាស់។ សភាពការណ៍ដែលកំពុងវិវត្តន៍ គឺផលិតផលកសិកម្មកើនបានតែ ២.២% តាមសំណូមពរស្បៀងចាំបាច់ត្រូវកើនឡើងបាន ៣%។

### *តារាងទី ១ ៖ អត្រាកំនើនធម្មជាតិនៃប្រជាជននៅលើពិភពលោក*

| ឆ្នាំ | ចំនួនប្រជាជនពាន់លាននាក់ | កំនើនធម្មជាតិពាន់លាននាក់ | កំនើនធម្មជាតិរាល់ឆ្នាំគិតជាលាននាក់ គិតជាភាគរយ | |
|---|---|---|---|---|
| 1880 | 1.5 | 0.3 | 13 | 0.8% |
| 1913 | 1.8 | 0.3 | 14 | 0.7% |
| 1935 | 2.1 | 0.7 | 30 | 1.3% |
| 1958 | 2.8 | 0.6 | | 2.1% |
| 1967 | 3.4 | 0.7 | 67 | 2.1% |
| 1976 | 4.0 | 0.7 | 75 | 2.0% |
| 2008 | 6 | 0.7 | 84 | 1.9% |
| 2022 | 7 | 0.6 | 85 | 1.9% |

*ប្រភព ៖ សៀវភៅភូមិវិទ្យាអភិវឌ្ឍន៍សេដ្ឋកិច្ចឆ្នាំ 2022*

ក្នុងចំណោម ១៥០ ប្រទេស មាន ១៤០ ប្រទេសដែលមានស្បៀងអាហារ សំរាប់បរិភោគមិនគ្រប់ គ្រាន់។ មានតែ ២២ ប្រទេសប៉ុណ្ណោះ ដែលផលិតស្បៀងបានលើសសំណូមពរ ដោយគ្មានគ្រោះមហន្តរាយ នោះឡើយ។ បណ្តាប្រទេសទាំងនោះរួមមានដូចជា ប្រទេសអាមេរិក ប្រទេសកាណាដា ប្រទេសថៃ ប្រទេស អាហ្សង់ទីន ប្រទេសរូម៉ានី ប្រទេសរុស្សី ប្រទេសស៊ុយអែដ ប្រទេសហុងគ្រី ប្រទេសបារាំង ប្រទេសកេនយ៉ា ប្រទេសអ៊ុយរ៉ាហ្គាយ ប្រទេសអាព្រិចខាងត្បូង ប្រទេសភូមា ប្រទេសប៊ូតង់ ប្រទេសន័រវេស ប្រទេសឥណ្ឌា ប្រទេសហ្វីលីពីន ប្រទេសនេបាល់ ប្រទេសឥណ្ឌូនេស៊ី អូស្ត្រាលី ប្រទេសវៀតណាម និងប្រទេសចិន។ ក្នុងចំណោមបណ្តាប្រទេសទាំងនេះ មានតែប្រទេសអាមេរិក ប្រទេសបារាំង ប្រទេសកាណាដា និងប្រទេស អាហ្សង់ទីនទេ ដែលមានអំណោយផលពីធម្មជាតិ ដីស្រែមានដីជាតិ មានដីស្រែច្រើន សម្រាប់មនុស្សម្នាក់ៗ (កាណាដាមាន ១.៩ ហិចតា/ម្នាក់) ហើយថែមទាំងមានមូលដ្ឋានបច្ចេកទេសទំនើប មានធនធានបំរុងច្រើន មានលទ្ធភាពនាំចេញច្រើនគឺមានចាប់ពី ១០ លានតោនឡើងទៅ។ ផ្ទុយទៅវិញប្រទេស ជប៉ុនខ្វះស្បៀង ២០ លានតោនឡើងទៅជារៀងរាល់ឆ្នាំ គឺជាងពាក់កណ្តាលសំណូមពរ។ តែមានផលិតផលឧស្សាហកម្មនាំចេញច្រើន ទើបបានមានលទ្ធភាពនាំស្បៀងចូលគ្រប់តាមសំណូមពររបស់ប្រជាជាតិ។ ពេលបច្ចុប្បន្ននេះ គេបានស្វែងរកប្រភពស្បៀង ដែលមិនមែនចេញពីប្រភពកសិកម្ម ដូចជាចំណីអាហារសប្បនិម្មិត ដែលបានមកពីការដាំសារាយបង្កើតបាក់តេរីបង្កើតផ្សិតនៅលើប៉ារ៉ាហ្វីនសុទ្ធ ក៏ប៉ុន្តែនៅពុំទាន់មានលទ្ធភាពអាចផ្តល់បានធំធេងនៅឡើយនោះទេ។ ប្រសិនបើជាអាចធ្វើបាននៅក្នុងឆ្នាំ ២០២២ មនុស្សម្នាក់ៗអាចទទួលបានក្នុងមួយថ្ងៃតែ ១ គីឡូក្រាមស្បៀងប្រភេទនេះតែប៉ុណ្ណោះ។

ដូចនេះ កសិកម្មនៅស្ថិតនៅតែជាផ្នែកមួយ ដែលផ្តល់ស្បៀងសំខាន់បំផុតនៅលើពិភពលោក ហើយមានចំនួនមនុស្សតែ ១/៤ នៃចំនួនមនុស្សជាតិទាំងអស់ ដែលជារៀងរាល់ឆ្នាំនៅតែជួបប្រទះនូវគ្រោះទុរ្ភិក្សអត់ឃ្លាន។ ប្រការនេះ គឺបណ្តាលមកពីមូលហេតុជាច្រើន ដែលបានធ្វើឱ្យមនុស្សជាតិនៅក្នុងបណ្តាប្រទេសនីមួយៗជួបប្រទះ នូវគ្រោះទុរ្ភិក្សអត់ឃ្លាននេះ។ ដូច្នេះ លទ្ធភាព និងលក្ខខណ្ឌទៅអនាគត តើត្រូវការពង្រីក

កសិកម្មយ៉ាងដូចម្ដេចខ្លះ? តើត្រូវធ្វើដូចម្ដេច ដើម្បីចិញ្ចឹមមនុស្សជាតិនៅលើផែនដីអោយបានល្អប្រសើរ? នៅលើពិភពលោកទាំងមូល ផ្ទៃដីដោយមិនគិតប៉ូលទាំងសងខាងមានចំនួន ១៣៥០០ លានហិចតា។ បច្ចុប្បន្ននេះ ផ្ទៃដីដែលគេអាចភ្ជួររាស់ដាំដុះបានមានតែ 11% នៃផ្ទៃដីទាំងអស់ប៉ុណ្ណោះ នៅក្នុងនោះមានដីដាំដុះនៅតាម តំបន់ទំនាប ដីដាំដំណាំជាថ្នាក់ៗនៅតាមតំបន់ភូនភ្នំ ឬដីបាចបញ្ចូលទឹក។ ដីដាំដុះបានទាំងនោះគេអាចដាំរុក្ខជាតិដែលផ្ដល់នូវគ្រាប់ធញ្ញជាតិ ដាំដើមឈើ និងដីសំរាប់ធ្វើច្បារដំណាំ។ ផ្ទៃដីដាំដុះមួយភាគធំស្ថិតនៅអឺរ៉ុបខាងលិចអាស៊ីមូសុង និងអាមេរិកខាងជើង និងខាងត្បូង។ បើគេបន្ថែមវាលស្មៅ វាលស្ទិប វាលស្មោងសម្រាប់ហ្វូងគោ និងចៀមចំនួន ១០% ទៀត នោះដីកសិកម្មនឹងកើនឡើងដល់ទៅ ២១%។ ប៉ុន្តែដោយសារមានការវិវត្តផែកបច្ចេកវិទ្យា និងសំពាធប្រជាសាស្ត្រលើផលិតកម្មអាហារ គេអាចបង្កើនដីដាំដុះបាន ១៤ % និងវាលស្មៅ ១៤%។ លទ្ធផលបន្ថែមនេះ ភាគច្រើនស្ថិតនៅក្នុងតំបន់ត្រូពិក តំបន់ស្ងួតហែង និងស្ទើរស្ងួតហែង ដោយប្រើវិធីបាចទឹកបញ្ចូលជាចាំបាច់។ និយាយរួម ដីដាំដំណាំបាននៅលើពិភពលោក គឺប្រមូលផ្ដុំគ្នានៅក្នុងតំបន់ទំនាប និងនៅតាមជ្រលងភ្នំ ហើយជាដីដែលមានដីជាតិល្អ។ ដូចនេះ នៅសល់ផ្ទៃដី ៥១% ទៀតដែលមិនអាចដាំដុះកើត។

វិធានការបើកទូលាយផលិតកម្មកសិកម្មនៅលើសាកលលោកគឺ ៖

- អនុវត្តបច្ចេកទេសថ្មីនៅក្នុងកសិកម្ម
- ផ្ទេរពីដំណាំយថាផលទៅដំណាំអតិផល

ដូច្នេះ ទិសដៅដែលត្រូវធ្វើមានដូចតទៅ ៖

- មានដីធម្មជាតិទាំងអស់នៅក្នុងបណ្ដាតំបន់ប្រទេសលើទ្វីបសំខាន់ៗគឺនៅបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ និងប្រទេសឥណ្ឌា។
- បង្កើនការដាក់ទុនច្រើនជាងគេបំផុតទៅលើការរុករានដីធ្វើកសិកម្ម ដីអន់គុណភាពត្រូវដាក់ជីបង្កើនគុណភាព។ បណ្ដាតំបន់ណាដែលកាប់ឆ្ការធ្វើអាជីវកម្ម ដំណាំអតិផលយូរមកហើយ ក៏ត្រូវបង្កលក្ខខ័ណ្ឌអនុគ្រោះ ដោយមានប្រព័ន្ធធារាសាស្ត្រ កែច្នៃដី ដាក់ជីដែលចាំបាច់តាំងលំនៅដ្ឋានបើកទូលាយផ្លូវគមនាគមន៍ អភិវឌ្ឍឧស្សាហកម្ម ដែលបម្រើផ្ទាល់ឱ្យតំបន់កសិកម្មទាំងអស់។

ការបើកទូលាយនូវផ្ទៃដីដាំដុះ គឺប្រព្រឹត្តទៅតាមទិសដៅ ២ គឺ ៖ ការកាប់គាស់រានដីបន្ថែម និងបង្កើនទិន្នផលភ្ជួររាស់ក្នុងរដូវនីមួយៗ។ បច្ចុប្បន្ននេះ កសិកម្មមានការរីកចំរើនខ្ពស់ (នៅបណ្ដាប្រទេសនៅអឺរ៉ុប និងបណ្ដាប្រទេសដែលមានដីធ្វើកសិកម្មច្រើនដូចជា សហរដ្ឋអាមេរិក ប្រទេសកាណាដា ដែលបានបើកទូលាយផ្ទៃដីដាំដំណាំ តាមរបៀបបង្កើនទិន្នផលភ្ជួររាស់នៅក្នុងរដូវនីមួយៗ ចំណែករីឯ បណ្ដាប្រទេសកំពុងអភិវឌ្ឍ បានយកចិត្តទុកដាក់លើការរុករានដីថ្មីជាការសំខាន់។ នៅដើមសតវត្សរ៍ទី ២០ ប្រព័ន្ធធារាសាស្ត្រត្រូវបានគេអនុវត្តទាំងនៅក្នុងបណ្ដាប្រទេសអភិវឌ្ឍ និងបណ្ដាប្រទេសកំពុងអភិវឌ្ឍ ហើយក្រោយមកមិនយូរប៉ុន្មាន ក៏ចាប់ផ្ដើមមានការធ្វើគីមីកម្ម វារីកម្ម និងយន្តកម្មកសិកម្ម។ បណ្ដាលំនាំទាំងនោះ បានបង្កើនជាបណ្ដើរៗនូវបរិមាណកសិផល។ ការផ្គត់ផ្គង់នូវម៉ាស៊ីនកសិកម្ម និងការប្រើប្រាស់ជីគីមីគឺមានកំរិតខ្ពស់បំផុតនៅក្នុងបណ្ដាប្រទេសអភិវឌ្ឍ និងបណ្ដាប្រទេសកំពុងអភិវឌ្ឍ។ សរុមសេចក្ដីមក បណ្ដាប្រទេសដែលមាន

ខឿនសេដ្ឋកិច្ចរីកចម្រើននខ្លាំង ចំនួនកសិករមាននិន្នាការចេះតែចុះថយទៅៗយ៉ាងលឿន។ រីឯនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍខ្លះវិញ ចំនួនកសិករក៏មាននិន្នាការចុះថយជាបណ្តើរៗហើយផងដែរ។

*តារាងទី ២ ៖ សមាមាត្រចំនួនកសិករ និងចំនួនប្រជាជនសរុប (គិតជាភាគរយ)*

| ប្រទេស | 1950 | 1960 | 1968 | 1978 | 1998 | 2018 |
|---|---|---|---|---|---|---|
| - បណ្តាប្រទេសអភិវឌ្ឍ | 31 | 23 | 15 | 12 | 3 | 2 |
| - បណ្តាប្រទេសកំពុងអភិវឌ្ឍ | | | | | | |
| - អាមេរិកឡាទីន | 54 | 50 | 47 | 44 | 39 | 36 |
| - អាស៊ីអាគ្នេយ៍ | 75 | 73 | 71 | 68 | 29 | 21 |
| - អាព្រិចខាងជើង | 73 | 70 | 66 | 63 | 62 | 50 |

*ប្រភព ៖ សៀវភៅភូមិវិទ្យាអភិវឌ្ឍន៍សេដ្ឋកិច្ចឆ្នាំ 2018*

នៅបណ្តាប្រទេសទាំងឡាយនៅអាមេរិកឡាទីន ក្នុងនោះមានបណ្តាប្រទេស ដែលមានទំនាក់ទំនងកសិកម្មជាមួយនឹងបណ្តាប្រទេសអភិវឌ្ឍ (អាហ្សង់ទីន វ៉េណេស៊ុយអេឡា) បានបញ្ចូលកម្មករជាច្រើនទៅក្នុងកសិកម្ម។ មានបណ្តាប្រទេសជាច្រើន ដែលមាននិន្នាការប្រមូលផ្តុំ និងរៀបចំសហគ្រាសឧស្សាហកម្មធំៗ ប្រើបច្ចេកទេសដាំដុះទំនើប បានបញ្ចូលទុនយ៉ាងច្រើនទាមទារការកែច្នៃដីធ្លី ប្រែក្លាយកសិកម្មជាផ្នែកផលិតកម្ម ដែលមានទ្រង់ទ្រាយធំ។ បណ្តាលំនាំអភិវឌ្ឍកសិកម្មមូលធននិយមបែបនោះ គឺប្រព្រឹត្តទៅមានសង្វាក់ខុសៗគ្នានៅក្នុងបណ្តាប្រទេសអភិវឌ្ឍ។ ប្រទេសកាណាដា និងសហរដ្ឋអាមេរិកបានអនុវត្តនូវកសិកម្មរបៀបចាស់នៅឡើយ ធ្វើដំណាំអតិផលលើស្រែចំការតូចៗ មានកសិករ និងអ្នកស៊ីឈ្នួល។ ជួនកាល នៅបណ្តាប្រទេសដែលមានកសិកម្មបែបចាស់មួយចំនួន មានផលិតផលកសិកម្មមួយផ្នែកនាំចេញ ក្នុងលក្ខខណ្ឌផលិតកម្មទ្រង់ទ្រាយធំរបស់មូលធននិយម។ បណ្តាប្រទេសមួយចំនួននៅចុងបូព៌ា និងនៅអាមេរិកកណ្តាល ប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍មួយផ្នែកធំ គឺបណ្តាប្រទេសកំពុងអភិវឌ្ឍមានមូលដ្ឋានសំភារៈបច្ចេកទេសមិនគ្រប់គ្រាន់ ដើម្បីធ្វើកសិកម្មខ្លួនឱ្យរីកចម្រើន។ ខឿនកសិកម្មសង្គមមានជំហរយ៉ាងរឹងមាំ ព្រោះត្រូវបានកសាងឡើងពីទំនាក់ទំនងបែបផែនផលិតកម្មសង្គម អនុវត្តតាមវិទ្យាសាស្ត្រ និងបច្ចេកទេសទំនើប ក្នុងការចាត់តាំងផលិតកម្ម ឯកទេសកម្ម និងប្រពលវប្ប-កម្មតាមតំបន់ធំៗ។ ខឿនសេដ្ឋកិច្ច គឺជានិច្ចកាលត្រូវជានាពីផែនការកម្មរីកចម្រើនន មានតុល្យភាព ហើយគ្រប់ជ្រុងជ្រោយនៅទូទាំងប្រទេស ឈរលើមូលដ្ឋានបែងចែកកម្លាំងពលកម្មជាក់ស្តែង សម្រាប់តំបន់សេដ្ឋកិច្ចនីមួយៗ ក្នុងនោះមានបណ្តាប្រទេសរុស្ស៊ី រូម៉ានី ប៊ុលការី បានជួយគ្នាទៅវិញទៅមកខាងសេដ្ឋកិច្ច។

## ២.៣. ប្រព័ន្ធ និងទ្រង់ទ្រាយផលិតកម្មកសិកម្ម

ប្រព័ន្ធកផលិតកម្មសិកម្ម គឺជាចំណែកទាំងឡាយណា ដែលមានទំនាក់ទំនងជាមួយគ្នាក្នុងវិស័យកសកម្ម ក្នុងនោះរួមមានប្រព័ន្ធដាំដុះ ការនេសាទ ការចិញ្ចឹមសត្វ និងអាជីវកម្មព្រៃឈើ។ នៅក្នុងប្រព័ន្ធអេកូឡូស៊ីកសិកម្មមានការផ្លាស់ប្តូររូបធាតុ និងថាមពលដូចតទៅ ៖

– រុក្ខជាតិផ្លាស់ប្តូរថាមពលជាមួយនិងបរិយាកាស ដោយទទួលថាមពលពីព្រះអាទិត្យ ស្រូបយកឧស្ម័ន កាបូនិច និងទឹក ដែលគេហៅថា រស្មីសំយោគ។ ក្នុងដំណើរនេះ ស្លឹកបៃតងរបស់រុក្ខជាតិបង្កើតបានជាសមាសធាតុសរីរាង្គ ដែលស្រូបយកជាតិអាស៊ូត និងខនិជរបស់ដី ហើយបង្កើតបានជាផលិតផលដើមឈើ ដែលមានជាតិប្រូតេអ៊ីន និងរូបធាតុខនិជផ្សេងៗទៀត។
– ថាមពល និងរូបធាតុ ដែលមាននៅក្នុងរុក្ខជាតិស្បៀងបានផ្តល់មកឱ្យមនុស្ស ហើយមនុស្សក៏ ផ្តល់ថាមពលមកឱ្យរុក្ខជាតិវិញ តាមរយៈការធ្វើពលកម្ម។ កាកសំណល់ ដែលនៅសេសសល់អំពីលំនាំរំលាយអាហារត្រូវបានផ្តល់ទៅអោយរុក្ខជាតិវិញ តាមរយៈកំលាំងអូសទាញ និងជីដាក់ដីស្រែ ហើយនៅទីបំផុត គឺទទួលបានទិន្នផលខ្ពស់ ដោយមិនបាច់ចំណាយថវិកា។
– មនុស្សធ្វើពលកម្ម និងការចិញ្ចឹមសត្វ មានទំនាក់ទំនងគ្នាខាងពលកម្ម និងម្ហូបអាហារ។ មនុស្សធ្វើពលកម្ម សម្រាប់ការចិញ្ចឹមសត្វ ការចិញ្ចឹមសត្វផ្តល់ផលិតផលឱ្យទៅមនុស្សវិញ។ ទំនាក់ទំនងគ្នារវាងប្រព័ន្ធទាំង២នេះ គឺប្រព័ន្ធអេកូឡូស៊ីកសិកម្មបុរាណ និងប្រព័ន្ធអេកូឡូស៊ីកសិកម្មទំនើបមានភាពខុសគ្នាបន្តិច។
  - ប្រព័ន្ធអេកូឡូស៊ីកសិកម្មបុរាណ មិនកែប្រែធម្មជាតិ អាស្រ័យទៅលើលក្ខខណ្ឌធម្មជាតិជាអ្នកកំណត់ គឺជាប្រព័ន្ធដាំដុះស្មុគស្មាញ គួបផ្សំនឹងការដាំដុះ និងការចិញ្ចឹមសត្វ ការចំណាយលើពលកម្មខ្ពស់ កម្លាំងពលកម្មដែលប្រើនៅក្នុងកសិកម្ម គឺកម្លាំងមនុស្ស និងសត្វពាហនៈ។
  - ប្រព័ន្ធអេកូឡូស៊ីកសិកម្មជឿនលឿនគឺធ្វើអាជីវកម្មទៅលើលក្ខខណ្ឌធម្មជាតិ កែប្រែធម្មជាតិ ប្រើប្រព័ន្ធដាំដុះសាមញ្ញ បង្កើតបានជាដំណាំឯកវប្បកម្មផ្តាច់ចេញពីការចិញ្ចឹមសត្វ ចំណាយលើពលកម្មតិច សំខាន់ធ្វើយន្តកម្មដែលមានទិន្នផលខ្ពស់។
  - នៅក្នុងប្រព័ន្ធអេកូឡូស៊ីកសិកម្មត្រូវការមានទំនាក់ទំនងទៅនឹងទម្រង់ដំណាំដាំដុះ និងការចិញ្ចឹម សត្វសមស្រប ដើម្បីធ្វើឱ្យទិន្នផលខ្ពស់ ឆ្លើយតបទៅនឹងសំណូមពរ។
  - ក្នុងទម្រង់ដាំដុះ គឺជាតុល្យភាពរវាងដើមឈើ ដែលប្រើការបានរបស់ដីតិច ឬច្រើន និងប្រភេទដើមឈើ ដែលធ្វើឱ្យដីសម្បូរជាតិកាបូន និងអាសូត។
  - ក្នុងទម្រង់ចិញ្ចឹមសត្វ គឺជាតុល្យភាពរវាងប្រភេទសត្វពាហនៈ ដែលមានតួនាទីពិសេសសម្រាប់ផ្ទេររូបធាតុសរីរាង្គឱ្យទៅដីវិញ។

*រូបភាពទី ២ ៖ ប្រព័ន្ធអេកូឡូស៊ីកសិកម្ម*




## ២.៤. កត្តា និងលក្ខខណ្ឌផលិតកម្មក្នុងកសិកម្ម

ទំនាក់ទំនងគ្នារវាងទិន្នផលពលកម្មកសិកម្ម និងទិន្នផលកសិកម្ម...។ល។ សុទ្ធបានតែឆ្លងកាត់តាមឥទ្ធិពលសង្គម និងធម្មជាតិ។ បណ្តាកត្តាដែលមានឥទ្ធិពលទៅលើកសិកម្ម ទោះបីទៅលើលទ្ធភាពនៃលទ្ធផល ឬទៅលើទិន្នផលពលកម្ម ក៏ត្រូវបានស្រាវជ្រាវវាយតម្លៃមូលដ្ឋាន នៃការរីកចំរើនវិទ្យាសាស្ត្រ បច្ចេកទេសផលិតកម្ម កសិកម្មផងដែរ។

### ក. កត្តាសង្គម និងសេដ្ឋកិច្ច

យើងធ្លាប់បានឃើញច្បាស់ហើយ នៅក្នុងលំនាំឧស្សាហូបនីយកម្មកសិកម្មប្រទេសមូលធននិយម ហើយការប្រមូលផ្តុំធនធានធម្មជាតិ ប្រើប្រាស់ដីធ្លីឱ្យអស់លទ្ធភាពហើយ និងសមស្របក្នុងប្រពលវប្បកម្មនៃការដាំដុះ និងការចិញ្ចឹមសត្វ។ ប្រមូលផ្តុំផលិតកម្មកសិកម្ម គឺជាទ្រង់ទ្រាយធំធេងក្នុងតំបន់កសិកម្ម គឺបង្កើនគុណភាព និងបរិមាណកសិផល គឺធ្វើឱ្យផលិតផលរាល់ឆ្នាំមានស្ថេរភាព ធ្វើឱ្យប្រព័ន្ធដាំដុះ ចិញ្ចឹមសត្វសមស្របជាជំហានៗ។ ប្រការនេះ ចាំបាច់ត្រូវឱ្យអទិភាពទៅលើការអភិវឌ្ឍនៃការចិញ្ចឹមសត្វ បើកទូលាយប្រពលវប្បកម្មស្បៀងអាហារ ដំណាំឧស្សាហកម្ម ធានាពីផលិតកម្មកសិផលឱ្យបានអតិបរមារ ប្រើប្រាស់ដីធ្លីដាំដុះឱ្យបានអស់លទ្ធភាពខ្ពស់បំផុត។ លទ្ធផលនោះ ធ្វើឱ្យការផ្លាស់ប្តូរទំនាក់ទំនងផលិតកម្ម តម្លៃរបស់កសិផលសំភារៈផលិតកម្ម និងផលិតផលផ្នែកផ្សេងៗទៀត ធ្វើឱ្យការផ្លាស់ប្តូពេលវេលាផ្គត់ផ្គង់ និងតំរូវការក្នុងតំបន់

សេដ្ឋកិច្ចរីកចំរើននៅក្នុងបណ្តាតំបន់កសិកម្ម ក្នុងបណ្តាមូលដ្ឋានឧស្សាហកម្ម និងផ្នែកសេដ្ឋកិច្ចជាតិផ្សេងៗទៀត។ ចង់អភិវឌ្ឍកសិកម្មនៅក្នុងតំបន់សេដ្ឋកិច្ច ត្រូវតែកំណត់ និងសម្រួលតម្លៃឱ្យបានសមស្រប មិនគប្បីអត្តនោម័តតម្លៃ មិនគួរគប្បីបង្កើតការផ្តោះប្តូរមិនសមគ្នារវាងតំលៃពលកម្មផលិតយូរឆ្នាំ និងផលិតផលឧស្សាហកម្ម។ ការបង្កើតផែនការផលិតកម្ម ក៏ត្រូវពឹងផ្អែកលើមូលដ្ឋាននោះដែរ។ យកចិត្តទុកដាក់ឱ្យមានតុល្យភាព រវាងមូលដ្ឋានសំភារៈបច្ចេកទេសកសិកម្ម និងផ្នែកផ្សេងៗទៀត រវាងសំណូមពរផលិតផលកសិកម្មជាមួយផ្នែកផ្សេងៗទៀត ជាមួយនិងសំណូមពររបស់សង្គម និងផលប្រយោជន៍សង្គម ដែលរដ្ឋជានាឱ្យដល់ប្រជាកសិករ។

## ខ. កត្តាធម្មជាតិ

ស្ថានភាពធម្មជាតិ បានបញ្ជាក់យ៉ាងច្បាស់ចាប់ពីការកកើតផលិតផលកសិកម្ម ហើយនៅតែបន្តរហូត នៅពេលណាដែលកសិកម្មពុំទាន់អាចចៀសផុតពីលក្ខខណ្ឌរបស់ទិដ្ឋភាពខាងក្រៅបាន។ តែ នៅពេលណា ដែលមនុស្សមានលទ្ធភាពអាចចៀសផុតពីលក្ខខណ្ឌធម្មជាតិបាន ប្រការនេះនៅមានបញ្ហាយូរអង្វែង ហើយត្រូវពឹងផ្អែកលើការរីកចម្រើនរបស់វិទ្យាសាស្ត្រ និងបច្ចេកទេសរបស់ផលិតកម្ម កសិកម្ម។ លក្ខខណ្ឌធម្មជាតិ ជាកត្តាមួយដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លាដល់កសិកម្ម ព្រោះមុខសញ្ញាផលិតកម្មកសិកម្ម គឺជាភាវរស់ដែលបានទ្រទ្រង់យ៉ាងខ្លាំងក្លាទៅនឹងកត្តាធម្មជាតិ។

- **ដី**

ដី គឺជាសំភារៈផលិតកម្មយ៉ាងសំខាន់បំផុតរបស់ផ្នែកកសិកម្ម។ ដីផ្តល់នូវសារជាតុចិញ្ចឹមដល់រុក្ខជាតិដើម្បីលូតលាស់។ ប្រភេទដីនីមួយៗត្រូវនឹងប្រភេទរុក្ខជាតិនីមួយៗ ជាកំណត់។ ដី ជាកត្តាមួយដ៏សំខាន់បំផុតចំពោះទិន្នផលរុក្ខជាតិ។ ហេតុនេះហើយ ដើម្បីជួយសម្រួលដល់ដំណើរការផលិតកម្មកសិកម្មឱ្យទទួលបានទិន្នផលខ្ពស់ គេត្រូវធ្វើការអង្កេត ត្រួតពិនិត្យ និងវាយតម្លៃប្រភេទដី ដើម្បីដាំដុះរុក្ខជាតិឱ្យសមស្រប ព្រមជាមួយគ្នានោះ ត្រូវមានវិធានការកែច្នៃ និងការពារដីឱ្យបានល្អប្រសើរ។

- **អាកាសធាតុ**

អាកាសធាតុ ក៏មានឥទ្ធិពលផ្ទាល់ទៅលើទិន្នផលបរិមាណគុណភាពនៃផលិតផលផងដែរ។ នៅក្នុងនោះ បណ្តាកត្តាធម្មជាតិ អាកាសធាតុជាកត្តាបែងចែករុក្ខជាតិយ៉ាងច្បាស់លាស់។ ប្រភេទរុក្ខជាតិ និងសត្វចិញ្ចឹមខុសប្លែកគ្នាទៅតាមតំបន់ ដែលមានអាកាសធាតុផ្សេងៗគ្នា ដោយសារតែប្រភេទរុក្ខជាតិ នីមួយៗសមស្របជាមួយនឹងលក្ខខណ្ឌធម្មជាតិមួយជាកំណត់។ អាកាសធាតុសមស្រប មិនងាយផ្លាស់ប្តូរធ្វើឱ្យរុក្ខជាតិ និងសត្វរីកចម្រើនឆាប់បានរហ័ស ហើយនិងទទួលបានទិន្នផលខ្ពស់។ អាស្រ័យដោយហេតុនេះហើយ ទើបនៅពេលដែលគេរៀបចំដាំដុះរុក្ខជាតិ ឬចិញ្ចឹមសត្វនៅតាមតំបន់នីមួយៗ គេត្រូវយកចិត្តទុកដាក់ដល់ចំណុចពិសេស នៃអាកាសធាតុរបស់តំបន់នោះ។

- **ធារាសាស្ត្រ**

ធារាសាស្ត្រ គឺជាកត្តាសំខាន់ក្នុងកសិកម្ម ពីព្រោះរុក្ខជាតិ និងសត្វត្រូវការជាចាំបាច់បំផុត ក្នុងលំនាំនៃការរីកលូតលាស់របស់វា តំបន់ទាំងឡាយណាដែលមានទឹកគ្រប់គ្រាន់តែងតែអនុគ្រោះដល់ការរីកចម្រើននៃ

វិស័យកសិកម្ម ដល់ការធ្វើប្រពលវប្បកម្ម និងបង្កើនរដូវដាំដុះ។ ផ្ទុយទៅវិញ នៅតំបន់ដែលហួតហែង ឆ្ងាយពីប្រភពទឹក គឺមានការលំបាកចំពោះការរីកចម្រើនផ្នែកកសិកម្ម។

- **សណ្ឋានដី**

សណ្ឋានដីមានឥទ្ធិពលដល់កសិកម្មដូចតទៅ ៖

- សណ្ឋានដីផ្លាស់ប្តូរខ្លាំង ធ្វើឱ្យអាកាសធាតុផ្លាស់ប្តូរតាម ធ្វើឱ្យកសិកម្មផ្លាស់ប្តូរផងដែរ។
- លក្ខណៈសណ្ឋានដីខុសគ្នា ធ្វើអោយកសិកម្មមានការរីកចម្រើនខុសគ្នា ។

តំបន់ភ្នំខ្ពស់ចោទពិបាកដាំដុះ ពិបាកប្រើម៉ាស៊ីន ទឹកភ្លៀងតែងតែហូរច្រោះនាំយកដី ដែលមានជីជាតិពិបាករក្សាទឹកឱ្យនៅបានល្អ ពោលគឺមិនអាចអភិវឌ្ឍកសិកម្មបានល្អដូចជានៅវាលទំនាបនោះឡើយ។ បណ្តាលក្ខខណ្ឌធម្មជាតិ គឺមានឥទ្ធិពលយ៉ាងខ្លាំងដល់ការរីកចម្រើន និងការចាត់ចែងក្នុងការធ្វើកសិកម្ម។ ស្ថានភាពធម្មជាតិគ្រាន់តែផ្តល់លក្ខខណ្ឌ និងលទ្ធភាពឱ្យកសិកម្មតាមសំណូមពរ និងកម្រិតផលិតកម្មរបស់សង្គម នឹងត្រូវកែប្រែលទ្ធភាពទាំងនោះ។ សង្គមមួយ ដែលមានបច្ចេកទេសនៅមានកម្រិតទាបនៅឡើយ ត្រូវនឹងលក្ខខណ្ឌធម្មជាតិបញ្ជាយ៉ាងខ្លាំងក្លាបំផុត គឺពិបាកក្នុងការទាញយកផលប្រយោជន៍ពីធម្មជាតិណាស់ ក៏ប៉ុន្តែ ផ្ទុយទៅវិញ សង្គមមួយដែលមានកម្រិតផលិតកម្មខ្ពស់ មានវិទ្យាសាស្ត្រ និងបច្ចេកទេសរីកចម្រើនវិញ គឺអាចទាញយកផលប្រយោជន៍ពីធម្មជាតិយ៉ាងច្រើន។

## គ. កត្តាមូលដ្ឋានសំភារៈបច្ចេកទេស

បច្ចុប្បន្ននេះ ល្បឿនផលិតកម្មកសិកម្មបានស្ថិតនៅក្នុងសតវត្សរ៍ថ្មីមួយ គឺជាសតវត្សរ៍ ដែលមានការផ្លាស់ប្តូរនូវមូលដ្ឋានសំភារៈបច្ចេកទេស ទទួលយកវិធីសាស្ត្រ និងសំភារៈផលិតកម្មបែបថ្មី និងទំនើបនាំឱ្យមានទិន្នផលខ្ពស់ ពលកម្មខ្ពស់។ ប្រព័ន្ធម៉ាស៊ីនកសិកម្មបានកកើតឡើង ហើយបានកែច្នៃជាច្រើនលើកមកហើយ បញ្ចូលគ្នាជាបណ្តើរៗ ម៉ាស៊ីនកាន់តែស្វ័យប្រវត្តិ ហើយសុក្រិតជំនួសឱ្យឧបករណ៍សាមញ្ញ ជំនួសនូវកម្លាំងអូសទាញ ដោយសត្វពាហនៈ បង្កើតឱ្យបានទិន្នផលខ្ពស់។ ពលកម្មកសិកម្មកើនឡើងរាប់រយដង ដេញទាន់ពលកម្មឧស្សាហកម្ម ធ្វើឱ្យមានតម្លៃពលកម្មខ្ពស់ បើធៀបនឹងពេលវេលាពលកម្មឧស្សាហកម្មផ្សេងៗទៀត យន្តកម្មក្នុងវិស័យកសិកម្ម កាត់បន្ថយនូវភាពអាស្រ័យទៅដោយលក្ខខណ្ឌធម្មជាតិ ទៅដោយអេកូឡូស៊ីរុក្ខជាតិ និងសត្វពាហនៈ។ ទិន្នផលពលកម្មត្រូវបានលើកកម្ពស់ ជំរុញឱ្យប្រពលវប្បកម្មក្នុងតំបន់ឯកវប្បកម្មធំៗ ដោយមានបច្ចេកទេសទំនើប។ ផលិតកម្មដោយគ្រឿងយន្ត គឺបន្ថយពេលវេលាពលកម្ម ជំនះបានមជ្ឈដ្ឋានធម្មជាតិជុំវិញ ដែលបង្កភាពអាក្រក់។

## ឃ. កត្តាស្ថានភាពចាត់ចែងរៀបចំឧស្សាហកម្ម

ឧស្សាហកម្ម និងកសិកម្ម ជាផ្នែកពីរដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធរវាងគ្នានឹងគ្នា។ ការចាត់ចែងរៀបចំឧស្សាហកម្ម ច្រើនតែមានឥទ្ធិពលទៅលើការរៀបចំកសិកម្ម ពិសេសនៅបណ្តាប្រទេសអភិវឌ្ឍ ការគួបផ្សំផ្នែកទាំងពីរនេះ ត្រូវទាមទារស្ថាបនាឧស្សាហកម្មនៅតំបន់ ដែលមានវត្ថុធាតុដើមកសិកម្ម។ ផ្នែកខ្លះទាមទារឱ្យមានការធ្វើឯកទេសកម្មកសិកម្ម ផលិតផលណាជាវត្ថុធាតុដើមសម្រាប់ផ្តល់ឱ្យឧស្សាហកម្មតំបន់នោះ។ ឧទាហរណ៍ ៖ នៅខេត្តបាត់ដំបងមានដំណាំក្រចៅ ហេតុដូច្នេះ គេតាំងរោងចក្រធ្វើបាវនៅទីនោះ។ នៅ

ភូមិភាគឦសាននៃប្រទេសកម្ពុជាមានដំណាំកៅស៊ូដែលមាននៅជប់ មេមត់ ក្រែក ស្នួល ចំការអណ្តូង។ល។ ដូចនេះ រោងចក្រចម្រាញ់ជ័រកៅស៊ូ ក៏ត្រូវតែសាងសង់នៅតំបន់នោះផងដែរ។

**ខ. កត្តាស្ថានភាពរៀបចំផ្លូវគមនាគមន៍**

ការធ្វើឯកទេសកម្មផលិតកម្មកសិកម្ម ត្រូវបានជំរុញយ៉ាងខ្លាំងក្លា ដោយសារមានការរីកចម្រើននូវប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន។ តំបន់កសិកម្មមួយ ដែលធ្វើឯកទេសកម្ម នឹងត្រូវផលិតវត្ថុធាតុដើមកសិកម្មច្រើន ដូច្នេះត្រូវការដឹកជញ្ជូនផលិតផលទាំងនោះទៅដល់ទីកន្លែងប្រើប្រាស់។ ជួនកាលត្រូវការដឹកជញ្ជូនស្បៀងពីកន្លែងផ្សេងៗទៀតមកកាន់តំបន់នេះវិញ។ បើផ្គត់ផ្គង់មិនទាន់ពេលវេលានោះ គឺមិនអាចធ្វើឯកទេសកម្មតាមតំបន់នីមួយៗបានឡើយ។ ដូច្នេះ ត្រូវតែស្ថាបនាបណ្តាញគមនាគមន៍ឱ្យបានគ្រប់គ្រាន់ ដើម្បីធានាការដឹកជញ្ជូនបានល្អ។

**ច. កត្តាតម្លៃទំនិញ និងសំណូមពរតាមទីផ្សារ**

តម្លៃកសិកម្មខ្ពស់ សំណូមពរទីផ្សារជំធេង ទើបផលិតផលកសិកម្មត្រូវបានអភិវឌ្ឍយ៉ាងខ្លាំងក្លា បង្កើនទុនវិនិយោគ និងបើកទូលាយផលិតកម្មកសិកម្ម។ ចំពោះប្រទេសមូលធននិយមត្រូវបានគេក្រិត្យក្រមនូវតម្លៃបញ្ហាខ្លាំងក្លា វាមានឥទ្ធិពលទៅលើការកើនឡើង ឬថយចុះនៃផលិតផលកសិកម្ម។ ក្នុងខឿនកសិកម្ម បញ្ហាតម្លៃកសិផល ក៏មានឥទ្ធិពលជំធេងទៅលើល្បឿន នៃការរីកចម្រើននផលិតផលផងដែរ។ តម្លៃសមស្របគឺជំរុញឱ្យផលិតកម្មរីកចម្រើន ក៏ប៉ុន្តែផ្ទុយទៅវិញ តម្លៃមិនសមស្របធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើនផលិតកម្ម។ ដោយមូលហេតុដូចនេះ រដ្ឋត្រូវធ្វើម្ចាស់ការជួយសម្រួលដល់តម្លៃឲ្យបានត្រឹមត្រូវ បង្កឱ្យមានការផ្លាស់ប្តូរសមស្រប ជាមួយនឹងតម្លៃពលកម្មលើផលិតកម្មកសិកម្ម និងឧស្សាហកម្ម ហើយជំរុញឱ្យផលិតកម្មកសិកម្មរីកចម្រើន។

**២.៥. ទ្រង់ទ្រាយចាត់តាំងផលិតកម្មកសិកម្មក្នុងតំបន់កសិកម្ម**

ផ្នែកឧស្សាហកម្មមានទ្រង់ទ្រាយផលិតកម្មសំខាន់ ៤ រួមមាន បណ្តុំកម្ម សហការកម្ម កំបីណា និងឯកទេសកម្ម។ ក្នុងផ្នែកកសិកម្ម ក៏មានទ្រង់ទ្រាយផលិតកម្ម ៤ ផងដែរ ក៏ប៉ុន្តែនៅក្នុងផលិតកម្មកសិកម្ម មានលក្ខណៈខុសប្លែកពីឧស្សាហកម្ម។

**ក. បណ្តុំកម្មផលិតកម្ម**

បណ្តុំផលិតកម្ម គឺជាបណ្តុំនៃផលិតកម្ម ដែលមានទ្រង់ទ្រាយធំ ក្នុងការអភិវឌ្ឍតាមក្រិតក្រមសេដ្ឋកិច្ច ដែលជំរុញកម្លាំងផលិតកម្មយ៉ាងខ្លាំងក្លា។

ឧទាហរណ៍ ៖ នៅសហរដ្ឋអាមេរិកបានធ្វើបណ្តុំកម្មផលិតកម្មកសិកម្មយ៉ាងធំមួយ ដោយគេបានធ្វើការប្រមូលផ្តុំ ៥៤០០០ កសិដ្ឋាន មកដាល់បញ្ចូលគ្នា ក្នុងនោះកសិដ្ឋាននីមួយៗមានដីប្រហែលជា ២០០០ ហិចតា គោ ២០០០០ក្បាល ជ្រូក ២៨៦០ក្បាល ចៀម និងពពែ ៥៦០០ក្បាល ម៉ាស៊ីនអូសទាញកម្លាំង ១៥ សេសចំនួន ៨៩០គ្រឿង ក្នុងពេលដែលកើតកសិដ្ឋាននេះឡើង គឺនៅសល់តែ ១២០០០កសិដ្ឋានប៉ុណ្ណោះ ហើយមានកម្លាំងផលិតកម្មកសិកម្មដ៏ធំមួយ ដែលជំរុញយ៉ាងខ្លាំងក្លាបំផុត នូវឯកទេសកម្មផលិតកម្មកសិកម្មធុនធំ។ ប្រពលវប្បកម្មដោយមានយន្តកម្មខ្ពស់នេះ បានឈានឡើងដល់ផលិតកម្មកសិកម្មទ្រង់ទ្រាយធំ និងទំនើប។

### ខ. សហការកម្មផលិតកម្មកសិកម្ម

សហការកម្មផលិតកម្មកសិកម្ម គឺជាផលិតកម្មកសិកម្មមានរូបរាង ដែលគេហៅថា សហការកម្មនោះមានដូចតទៅ ៖

- សហកាកម្ម គឺជាបណ្តុំផ្នែកកសិកម្មផ្សេងៗគ្នា (ចិញ្ចឹមសត្វ និងការដាំដុះ ) ឧទាហរណ៍ ៖ ដូចជាកសិដ្ឋាន ចិញ្ចឹមសត្វ គោ ជ្រូក... ដោយធ្វើសហការជាមួយការដាំដុះការហ្វេ ស្រូវ ពោត...។
- សហការកម្មបណ្តាសហគ្រាសឧស្សាហកម្មជាមួយនឹងសហគ្រាសនីមួយៗរបស់កសិកម្ម។
- ឧទាហរណ៍ ៖ សហគ្រាសកិនស្រូវ ផលិតស្រា សហការជាមួយកសិដ្ឋានស្រូវ។ សហគ្រាសសាច់សហការជាមួយនឹងកសិដ្ឋានចិញ្ចឹមគោ ជ្រូក មាន់...។
- ឧស្សាហកម្មប្លែងភាពកសិផលក្នុងតំបន់កសិកម្ម ដែលមានវត្ថុជាតុដើមដូចជា រោងចក្រក្រណាត់ នំ កាកសំណល់របស់ឧស្សាហកម្មប្លែងភាពទាំងនេះ ធ្វើសហការគ្នាជាមួយកសិដ្ឋានកសិកម្មដាំដំណាំ អំពៅ ស្រូវ សាលី និងចិញ្ចឹមសត្វ។
- នៅសហរដ្ឋអាមេរិក កសិដ្ឋានចិញ្ចឹមសត្វយកសាច់ និងទឹកដោះធ្វើការសហការជាមួយសហគ្រាសសម្លាប់សត្វយកសាច់។ ការធ្វើសហការកម្មឧស្សាហកម្មកសិកម្ម តែងតែឱ្យលទ្ធផលខ្ពស់ក្នុងពេលដែលមានការប្រើប្រាស់ទាំងគមនាគមន៍ និងទាំងថាមពល។

### គ. កំបីណាផលិតកម្មកសិកម្ម

នៅក្នុងឧស្សាហកម្ម ដោយផលិតកម្មបែងចែកជាផ្នែកៗ (គ្រឿងបន្លាស់បំបែកម៉ាស៊ីន...) ទើបបណ្តាសហគ្រាសផលិតផ្នែកបន្សំទាំងនោះងាយស្រួល។ នៅក្នុងផ្នែកកសិកម្ម ផ្នែកផលិតកម្ម គឺមិនអាចបែងចែកជាផ្នែកតូចៗបានដូចសហគ្រាសឧស្សាហកម្មនោះឡើយ ទើបកំបីណាអនុវត្តបានតែនៅក្នុងផ្នែកចិញ្ចឹមសត្វយកសាច់យកទឹកដោះ និងចិញ្ចឹមបក្សីប៉ុណ្ណោះ។ ឧទាហរណ៍ ៖ កសិដ្ឋានចិញ្ចឹមគោចែកចេញជា ៖

- កសិដ្ឋានចិញ្ចឹមគោយកកំលាំងអូសទាញ
- កសិដ្ឋានចិញ្ចឹមគោយកខ្លាញ់ យកសាច់ យកស្បែក
- កសិដ្ឋានចិញ្ចឹមគោយកទឹកដោះ

កសិដ្ឋានទាំងនេះ អាចរួមបញ្ចូលគ្នា ដើម្បីយកសាច់ សន្សំទឹកដោះ ចិញ្ចឹមកូនគោ។

### ឃ. ឯកទេសកម្មកសិកម្ម

ឯកទេសកម្មផលិតកម្មកសិកម្ម ជាទម្រង់ចាត់តាំងផលិតកម្ម ទម្រង់បែងចែកពលកម្មទៅតាមតំបន់អនុវត្តក្នុងតំបន់កសិកម្ម សំដៅចាត់តាំងផលិតកម្មកសិកម្មអោយទទួលបានទិន្នផលខ្ពស់។ បណ្តាអង្គភាពផលិតកម្មកសិកម្ម ត្រូវដាក់ទិសដៅទៅរកឯកទេសកម្មផលិតកម្ម ហើយវាក៏អាស្រ័យទៅតាមលក្ខខណ្ឌធម្មជាតិប្រពៃណី ផលិតកម្ម ប្រជាជន និងជីវភាពរស់នៅប្លែកៗគ្នា។ បញ្ហាដែលចោទ គឺថា តើឯកទេសកម្មកសិកម្មត្រូវធ្វើតាមវិធីបែបណាខ្លះ? តើត្រូវបង្ហាញពីរបាយផលិតកម្មកសិកម្មយ៉ាងដូចម្តេចខ្លះ?

ការធ្វើឯកទេសកម្មកសិកម្មតាមតំបន់មានការរីកចំរើនយ៉ាងខ្លាំងក្លា ព្រោះវាត្រូវប្រមូលផ្តុំផ្ទៃដីដាំដុះធំៗជាច្រើន សម្រាប់ប្រភេទរុក្ខជាតិតែមួយមុខៗ ហើយផលិតផលកសិកម្មត្រូវតែប្រមូលផ្តុំច្រើននៅក្នុងតំបន់មួយចំនួន។ ឧទាហរណ៍ ៖ នៅតំបន់ខ្ពង់រាបភាគខាងកើតប្រទេសវៀតណាមត្រូវប្រមូលផ្តុំនូវផលិតផល

ដំណាំជាច្រើនប្រភេទ ហើយនៅក្នុងតំបន់ទាំងនោះមានដូចជា ផលិតផលកៅស៊ូ កាហ្វេ ថ្នាំជក់ តែ និងម្រេច ជាដើម។ ទំនាក់ទំនងទម្រង់ចាត់តាំងផលិតកម្មកសិកម្មទាំងបួន មានឥទ្ធិពលលើគ្នាទៅវិញទៅមក ហើយជិតស្និទ្ធបំផុតដែលបង្កើតបានជាពហុផលិតកម្មកសិកម្ម នៅតំបន់មានលទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងធានាពីការផលិតបានច្រើន ហើយទំនើបទៀតផង។ ទំរង់ចាត់តាំងផលិតកម្មកសិកម្មទាំងនោះ ធ្វើសកម្មភាពដូចជា ធនាគារដែលផ្តោះប្តូរផលិតផលកសិកម្ម នៅក្នុងតំបន់កសិកម្ម។ អាចនិយាយបានម៉្យាងទៀតថា ឯកទេសកម្មបង្កើតបានជាទំនាក់ទំនងផលិតកម្ម ទំនាក់ទំនងបច្ចេកទេសរវាងបណ្តាតំបន់កសិកម្មឯកវប្បកម្ម និងរវាងបណ្តាសហគ្រាស ឧស្សាហកម្ម បណ្តាកសិដ្ឋានដែលប្រើប្រាស់ហើយ និងផលិតទំនិញឧស្សាហកម្ម។ សកម្មភាពទាំងអស់នេះ បង្ហាញឡើងដោយការប្រមូលផ្តុំនូវប្រភេទដំណាំ ឬសត្វតែមួយមុខ ហើយបានផ្សារភ្ជាប់ជាមួយនឹងលក្ខខណ្ឌអេកូឡូស៊ីរបស់សត្វ និងរុក្ខជាតិទាំងនោះ។

### ២.៦. ប្រពលវប្បកម្ម

ប្រពលវប្បកម្ម គឺជាដំណើរការ ឬនិន្នាការផលិតកម្មសំខាន់ ក្នុងខឿនកសិកម្មទំនើប ដោយមានការប្រើបច្ចេកទេស ទំនើប ដើម្បីធានាឆ្លើយតបទៅនឹងសំណូមពរស្បៀង សម្រាប់មនុស្សជាតិ ក្នុងពេលដែលផ្ទៃដីកសិកម្មមានកំរិត ប៉ុន្តែចំនួនប្រជាជនចេះតែកើនឡើងឥតឈប់ឈរ។

តាមមតិរបស់អ្នកប្រាជ្ញជាច្រើនបានឱ្យនិយមន័យថា "ប្រពលវប្បកម្ម គឺជាការប្រមូលផ្តុំមូលធន លើស្រែតែមួយជាមួយគ្នា គឺមិនមែនបែកខ្ញែក ដោយប្រការណាមួយនោះទេ"។ ដូច្នេះ ប្រពលវប្បកម្មកសិកម្ម គឺជាការបង្កើនផលិតផលលើមូលដ្ឋានបង្កើនទុនទៅលើផ្ទៃដី។ ទិសដៅ ដើម្បីធ្វើបានសម្រេចខាងប្រពលវប្បកម្មត្រូវបានគិតគូរដល់តម្លៃធនធាន ធ្វើតម្លៃសំភារៈឱ្យមានស្ថេរភាព (ទុនខាងសំភារៈផលិតកម្ម គិតជាទឹកប្រាក់ និងពេលវេលា ដែលខាតបង់លើពលកម្ម ក្នុងមួយឯកតានៃផ្ទៃដីដាំដុះ) ។ កាលណាគេចំណាយតិច ប៉ុន្តែទទួលបានទិន្នផលខ្ពស់ គេថាកម្រិតប្រពលវប្បកម្មខ្ពស់។ លទ្ធផល នៃប្រពលវប្បកម្ម គឺត្រូវគិតតាមកំរិតកើននៃចំណូលលើមួយឯកតានៃផ្ទៃដី កម្រិតកើនទិន្នផលកសិកម្ម ហើយគិតតាមការប្រែប្រួលគុណភាពដីពីមួយឆ្នាំទៅមួយឆ្នាំ។ ដើម្បីធ្វើប្រពលវប្បកម្ម គេត្រូវប្រើប្រាស់នូវបច្ចេកទេសកសិកម្មទំនើបៗដូចជា ៖ វារីកម្ម គីមីកម្ម យន្តកម្ម និង អគ្គិសនីកម្ម។

- **វារីកម្ម ៖** ជាវិធានការឈានមុខ ក្នុងចំណោមវិធានការបច្ចេកទេសកសិកម្ម។ ដំណាំដាំដុះ និងសត្វដែលគេចិញ្ចឹម ត្រូវការបរិមាណទឹកមួយចំនួនជាកំណត់ក្នុងលំនាំរីកចំរើនរបស់វា។ វារីកម្មបង្កលក្ខខណ្ឌឱ្យមានការស្ថាបនាប្រព័ន្ធជាពសាស្ត្រ ដើម្បីធានាទឹកឱ្យបានគ្រប់គ្រាន់សម្រាប់ស្រោចដំណាំក្នុងកសិកម្ម។ វារីកម្ម បង្កលក្ខខណ្ឌរីកចម្រើនខាងផលិតកម្មកសិកម្ម បង្កើនទិន្នផលកសិកម្ម ដែលនាំកសិកម្មឯកប្បកម្មឱ្យទៅជាឯកទេសកម្មកសិកម្ម។ ប្រពលវប្បកម្ម គឺវាជួយបង្កើនរដូវប្រមូលផលបង្កើតបានផលិតផលដ៏ធំធេងក្នុងមួយឯកតាដី។
- **គីមីកម្ម ៖** ជាការបង្កើនការប្រើប្រាស់ជីគីមីនៅក្នុងផលិតផលកសិកម្មដូចជា ថ្នាំកំចាត់សត្វល្អិត ថ្នាំកំចាត់ស្មៅ ថ្នាំបង្កើតការធំធាត់...។ល។ សំដៅលើកកំពស់ទិន្នផលកសិកម្ម។ ដើម្បីគិតពីកម្រិតគីមីកម្មនៅក្នុងកសិកម្ម គេត្រូវតែគិតកម្រិតប្រើជីគីមីក្នុងមួយឯកតាដី។ កម្រិតប្រើប្រាស់ជីគីមី ក្នុងដីមួយហិកតាខុសគ្នាៗ ទៅតាមបណ្តាប្រទេសនីមួយៗដែលមានភាពជឿនលឿន ហើយ

មានដីស្រែតិចកម្រិតប្រពលវប្បកម្មខ្ពស់ដូចជា ប្រទេសហូឡង់ ប្រទេសជប៉ុនដែលប្រើជីគីមីពី ៣០០-៥០០ គ.ក ក្នុងមួយហិកតា។ បណ្តាប្រទេសជឿនលឿន ដែលមានដីស្រែច្រើន ប្រើជីគីមីប្រហែលជា ១០០ គ.ក ក្នុងមួយហិកតាដូចជា នៅសហរដ្ឋអាមេរិក និងប្រទេសកាណាដាជាដើម។ រីឯនៅបណ្តាប្រទេសកំពុងអភិវឌ្ឍវិញ ដែលមានខឿនកសិកម្មយថាផល ហើយគេប្រើប្រាស់ជីគីមីប្រហែលជាចាប់ពី ៣០-៥០ គ.ក ក្នុងមួយហិកតា។

- **យន្តកម្ម ៖** គឺជាដំណើរនៃការបង្កើនការប្រើប្រាស់គ្រឿងម៉ាស៊ីននៅក្នុងផលិតកម្មកសិកម្ម។ គឺជាដំណើរការធ្វើឧស្សាហូបនីយកម្មកសិកម្ម។ យន្តកម្ម គឺមានសកម្មភាពរំដោះពលកម្ម ដែលប្រើដៃជើងរបស់មនុស្ស បន្ថយពលកម្មរបស់សត្វ ប្រែក្លាយការចិញ្ចឹមសត្វ ដើម្បីយកកម្លាំងអូសទាញឱ្យទៅជាកា ចិញ្ចឹមសត្វ ដើម្បីយកសាច់ យកទឹកដោះ និងជី។ កម្រិតយន្តកម្មកសិកម្ម អាស្រ័យទៅដោយកម្រិតបច្ចេកទេស និងសារៈសំខាន់នៃសេដ្ឋកិច្ចរបស់បណ្តាប្រទេសនីមួយៗ។ ក្នុងបណ្តាទសវត្សរ៍ទី៨០ និង ៩០ បណ្តាប្រទេសអភិវឌ្ឍមានផ្ទៃដីកសិកម្មសរុប ២៧% នៃផ្ទៃដីភ្ជួររាស់ដាំដុះបាននៅលើពិភពលោកតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ បណ្តាប្រទេសដែលកំពុងអភិវឌ្ឍមានផ្ទៃដីរហូតដល់ទៅ ៤៥% ប៉ុន្តែមានម៉ាស៊ីនអូសទាញភ្ជួររាស់តែ ៨% នៃចំនួនម៉ាស៊ីនអូសទាញលើសាកលលោក។
- **អគ្គីសនីកម្ម ៖** គឺជាដំណើរនៃលំនាំក្នុងការផ្តល់អគ្គិសនី ពីមួយថ្ងៃទៅមួយថ្ងៃឱ្យបានច្រើនសម្រាប់ផលិតកម្មកសិកម្ម សំដៅលើកកំពស់នូវទិន្នផលកសិកម្ម។ អគ្គិសនីកម្មមានតួនាទីសំខាន់ វាបង្កលក្ខខណ្ឌអនុគ្រោះដល់ដំណើរការវារីកម្ម គីមីកម្ម យន្តកម្ម និងជាពិសេសនៅក្នុងការចិញ្ចឹមសត្វ ហើយព្រមជាមួយគ្នានោះ វាបំរើដល់ជីវភាពរស់នៅរបស់ប្រជាជន។ បណ្តាប្រទេសទាំងឡាយនៅលើសកលលោក សុទ្ធតែបានបង្កើនអគ្គិសនីឱ្យកសិកម្មដូចជា សហរដ្ឋអាមេរិក បារាំង អង់គ្លេស រុស្ស៊ី កាណាដា និងប្រទេសអាឡឺម៉ង់ជាដើម។

## ២.៧. ពហុផលិតកម្មលើទឹកដីកសិកម្ម

### ក. ស្ថានភាពផលិតកម្មកសិកម្មទ្រង់ទ្រាយធំ បង្កើតជាពហុផលិតកម្មលើទឹកដី

ចំណាត់តាំងផលិតកម្មកសិកម្មទំនើប នៅក្នុងតំបន់កសិកម្មកាលពីមុននេះ គឺគ្មានស្ថានភាពផលិតកម្មទ្រង់ទ្រាយធំទំនើប ដើម្បីចាត់តាំងផលិតកម្មតាមទឹកដីនោះឡើយ ព្រោះវាពុំទាន់បានអនុវត្តនូវវិទ្យាសាស្ត្រ និងបច្ចេកទេសជឿនលឿននៅក្នុងតំបន់កសិកម្មនៅឡើយ។ បែបផែនផលិតកម្មសក្តិភូមិបានរាំងស្ទះកសិកម្មមិនឱ្យរីកចម្រើនអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ។ នៅពេលនោះដែរ គឺខឿនផលិតកម្មមានទ្រង់ទ្រាយតូច គ្មានតុល្យភាព មិនគ្រាន់តែមិនបានធានាឱ្យដល់ផលិតផលនាំចេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្គត់ផ្គង់ក្នុងតំបន់ពុំបានល្អទៀតផង។ របបមូលធនមានបច្ចេកទេសកសិកម្មទំនើប ខឿនកសិកម្មផលិតកម្មកាន់តែបាត់បង់តុល្យភាព កាន់តែមានទំនាស់ធ្ងន់ធ្ងររវាងផ្នែកសេដ្ឋកិច្ចផ្សេងៗរបស់តំបន់កសិកម្មផ្សេងៗ។

កាលពី ៣០ ទៅ ៤០ ឆ្នាំមុននេះ ខឿនកសិកម្មមូធននិយមបានឈានឡើងពង្រឹងទំនាក់ទំនងផលិតកម្មកសិកម្មជឿនលឿនឈរលើមូលដ្ឋានពាណិជ្ជកម្មឯកជន និងបានអនុវត្តយ៉ាងឆាប់រហ័សនូវបច្ចេកទេសទំនើបៗ

ដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅពីបដិវត្តន៍កសិកម្ម ហើយបានធ្វើអោយកសិកម្មមានលក្ខណៈវិសេសវិសាល ដើរតាមទិសដៅផលិតកម្មកសិ-ឧស្សាហកម្ម ដែលជាផលិតកម្មមានទ្រង់ទ្រាយធំទំនើប។

នាពេលបច្ចុប្បន្ននេះ មានផ្ទៃដីថ្មីៗជាច្រើនបានកើតឡើង ហើយបានបង្កើតឡើងនូវផ្នែកចិញ្ចឹមបក្សី តាមរបៀបឧស្សាហកម្មប្លែងភាពចំណីអាហារចម្រុះ ផ្នែកមីក្រូសារពាង្គកាយ និងផ្នែកចំណីអាហារសត្វ។ល។ ចំណាត់តាំងផលិតកម្មផ្នែកទាំងនេះ ធ្វើទៅតាមទិសដៅឧស្សាហកម្ម ដែលបានធ្វើឱ្យពួកវាទាំងនោះមានទំនាក់ទំនងផ្ទាល់ជាមួយនឹងដីធ្លី ជាមួយលក្ខខណ្ឌពីខាងក្រៅ។ គមនាគមន៍ដឹកជញ្ជូនជឿនលឿន ក៏ធ្វើឱ្យមានការផ្លាស់ប្ដូរនូវបច្ចេកទេសផលិតកម្មកសិកម្មថ្មី ដែលជាជំនួយដល់កសិកម្មឱ្យមានទំនាក់ទំនងគ្នារវាងផលិតកម្មថ្មី ធ្វើឱ្យកើតឡើងនូវពហុផលិតកម្មលើទឹកដី ធ្វើឱ្យអង្គភាពផលិតកម្មកសិកម្មនីមួយៗ មានទំនាក់ទំនងជាមួយនឹងបណ្ដាអង្គភាពសេដ្ឋកិច្ច និងផលិតកម្មក្នុងតំបន់។ តំបន់កសិកម្មរីកចម្រើនហើយមានសុក្រិតភាពជាបណ្ដើរៗឆ្ពោះទៅ រកឯកទេសកម្ម ហើយមានឧស្សាហកម្មផ្គត់ផ្គង់យ៉ាងសកម្មឱ្យកសិកម្ម ដែលផលិតតាមផ្នែកនីមួយៗដូចជា ស្លឹក មើម ផ្លែ ទឹកដោះ សាច់ ស្បែក រោម...។ ឆ្លងតាមទំនាក់ទំនងនូវបច្ចេកទេសបណ្ដារោងចក្រ ឧស្សាហកម្មបង្កើតបានជាការផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ រវាងសហគ្រាសឧស្សាហកម្ម ជាមួយនឹងសហគ្រាស កសិកម្មជានាបានពីការកកើតជារូបរាងពហុផលិតកម្មកសិកម្មលើទឹកដី។

## ខ. លក្ខណៈសំគាល់ពិសេសនៃការកកើតពហុផលិតកម្មកសិកម្មលើទឹកដី

ពហុផលិតកម្មកសិកម្មលើទឹកដី មិនគ្រាន់តែខុសប្លែកគ្នាខាងគុណភាពគោលការណ៍ចាត់តាំងប្រមូលផ្ដុំចម្រុះសហគ្រាសប៉ុណ្ណោះទេ តែថែមទាំងខុសប្លែកគ្នាពីលំនាំបច្ចេកទេស និងកំរិតទំនាក់ទំនងផលិតកម្មចាប់ពីផលិតផលកសិផល រហូតដល់ប្លែងភាពទៀតផង ពីព្រោះថាដីធ្លី គឺជាកម្មវត្ថុផលិតកម្មផង និងជាមធ្យោបាយផលិតកម្មផង ហើយធ្វើឱ្យកសិកម្មអាស្រ័យទៅដោយធម្មជាតិ ទើបបានជានៅក្នុងរបាយតំបន់កសិកម្ម ត្រូវតែកំណត់លក្ខណៈរបស់តំបន់។ នៅក្នុងឧស្សាហកម្ម មានផលិតផលមួយចំនួន ដែលដូចគ្នានៅក្នុងតំបន់ផ្សេងៗគ្នា ប្រការនេះ វាគ្មានអ្វីគួរឱ្យចំឡែកនោះទេ។ ឧទាហរណ៍ ៖ ដែកស្និតដែលផលិតនៅក្នុងដុំបាស អ៊ួរាល់ គួសបាស...។ មិនខុសគ្នានោះទេ ព្រោះថាបច្ចេកទេសផលិតដូចគ្នា ប៉ុន្តែនៅក្នុងផ្នែកកសិកម្ម តើផលិតផលមួយចំនួននៅក្នុងតំបន់ខុសគ្នាអាចដូចគ្នាដែរ ឬទេ?

គ្មានគំរូបច្ចេកទេសណាមួយ ដែលត្រូវពិតប្រាកដនោះទេ ពីព្រោះថាភាពខុសគ្នាទៅតាមតំបន់បង្ហាញឡើងច្បាស់លាស់ ទៅតាមភូមិសាស្ត្រ ឬទៅតាមតំបន់កសិកម្មនីមួយៗ ផលិតផលអាចខុសគ្នាទាំងបរិមាណ និងទាំងគុណភាព ប៉ុន្តែក៏មានករណីខ្លះដូចគ្នាដែរ នោះជាករណីលើកលែង។

## គ. ពហុផលិតកម្មកសិកម្ម និងបំណែងចែកជាប្រភេទ

តាមទស្សនៈរបស់អ្នកប្រាជ្ញជាច្រើនបានកំណត់និយមន័យ ពហុផលិតកម្មឧស្សាហកម្ម ក៏ប៉ុន្តែវាមិនបានបង្ហាញឃើញពីភាពខុសគ្នារវាងកសិកម្ម និងឧស្សាហកម្មនៅក្នុងពហុផលិតកម្មនោះទេ។ បើតាមលោក **ហ្សហ្វមុយកូមែល** យល់ថា តំបន់ឧស្សាហកម្ម គឺជាពហុផលិតកម្មនៅលើទឹកដីរបស់តំបន់ កសិដ្ឋានដែលមានលក្ខណៈពិសេស គឺចម្រុះផ្នែកសំខាន់ៗ និងផ្នែកបន្ទាប់បន្សំក្នុងផ្នែកកសិកម្ម ដែលមានប្រភេទដូចគ្នា។

តាមពិត នៅក្នុងពហុផលិតកម្មកសិកម្មមានបញ្ហាចោទដូចតទៅ ៖

- របរាងចម្រុះគ្នាទៅវិញទៅមកយ៉ាងរឹងមាំត្រូវបានកំណត់យ៉ាងច្បាស់ដោយលក្ខខណ្ឌធម្មជាតិ សេដ្ឋកិច្ច គមនាគមន៍ ដឹកជញ្ជូន ដោយមានផលិតផលទៅតាមឯកទេសកម្ម មានភាពជឿនលឿនបច្ចេកទេស ផលិតកម្ម និងដោយសារទំនាក់ទំនងទៅវិញទៅមក។
- មាននិន្នាការរៀបចំសហគ្រាសក្នុងតំបន់ដែលនៅជិតគ្នាដើម្បីឱ្យទទួលបានលទ្ធផលសេដ្ឋកិច្ចខ្ពស់។
- ទម្រង់ពហុផលិតកម្មលើទឹកដី គឺដោយសារសហគ្រាសដែលមានផលិតផលសំខាន់ៗ គួបផ្សំជាមួយ សហគ្រាសបន្ទាប់បន្សំ ដែលផលិតផលិតផលប្លែងភាព។

  **ឧទាហរណ៍ ៖** តំបន់វាលទំនាប ដែលមានទំរង់ពហុផលិតកម្ម សហគ្រាសសំខាន់ គឺកសិដ្ឋានស្រូវ រោងចក្រកិនស្រូវ ហើយបន្ទាប់បន្សំ គឺកសិដ្ឋានចិញ្ចឹមសត្វមាន មាន់ ជ្រូក គោ ក្របី និងបក្សីស្រុក ហើយមានឧស្សាហកម្មប្លែងភាពយកសាច់។

យោងលើគោលការណ៍កសិកម្មខាងលើ វាពិតជាផ្តល់អត្ថប្រយោជន៍ច្រើន ដល់ពហុផលិតកម្ម ដែលអ្នកប្រាជ្ញជាច្រើនបានចងក្រងទុក នៅក្នុងឯកសារតាំងពីទំនាក់ទំនងគោលការណ៍ធំៗ រហូតដល់រចនាសម្ព័ន្ធផលិតកម្ម។ បើនិយាយពីឧស្សាហកម្មប្លែងភាពវិញ គឺវាមានរចនាសម្ព័ន្ធចាប់ពីសហគ្រិចតូចៗ រហូតដល់សហគ្រាសធំៗ ហើយនៅក្នុងនោះ បើយើងនិយាយពីគោលការណ៍ចិញ្ចឹមសត្វ គឺចាប់តាំងពីបែបបុរាណរហូតដល់បែបទំនើប ដែលមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកទេស គឺធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ចរស់រវើកដើរទាន់សម័យ។

## សំណួររំលឹកមេរៀន

1. ចូរពិពណ៌នាអំពីកំណើត និងការវិវត្តន៍នៃទេសភាពជនបទ។
2. តើគេចែកប្រព័ន្ធកសិកម្មនៅលើពិភពលោកជាប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់។
3. ដូចម្តេចដែលហៅថា បដិវត្តកសិកម្ម? រហូតមកដល់ពេលនេះ តើបដិវត្តន៍កសិកម្មបានកើតឡើងចំនួនប៉ុន្មានលើក? អ្វីខ្លះ? ក្នុងបដិវត្តន៍កសិកម្មនីមួយៗបានកើតឡើងដោយសារមូលហេតុអ្វីខ្លះ?
4. ចូរពិពណ៌នាអំពីតួនាទី និងសារៈសំខាន់នៃកសិកម្ម។
5. នៅមានទ្រង់ទ្រាយអ្វីខ្លះនៅក្នុងផ្នែកកសិកម្ម? ចូរពន្យល់។
6. ចូរពិពណ៌នាអំពីប្រព័ន្ធអេកូឡូស៊ីកសិកម្មបុរាណ និងប្រព័ន្ធអេកូឡូស៊ីកសិកម្មទំនើប។
7. ដូចម្តេចដែលហៅថា ប្រពលវប្បកម្ម? ដើម្បីធ្វើប្រពលវប្បកម្ម តើគេត្រូវប្រើប្រាស់បច្ចេកទេសអ្វីខ្លះ? ចូរពន្យល់។
8. តើកត្តាអ្វីខ្លះ ដែលជះឥទ្ធិពលលើរបាយកសិកម្មនៅលើពិភពលោក?

# មេរៀនទី២៖ មនុស្សរៀបចំលំហកសិកម្ម

## ១. លំហកសិកម្មនៅលើពិភពលោក

ភពផែនដីរបស់យើងទាំងមូលគ្រប់ដណ្តប់ដោយផ្ទៃទឹក និងផ្ទៃដីផុស។ ផ្ទៃទឹកមានប្រហែល ៧០% នៃផ្ទៃផែនដីទាំងមូល រីឯផ្ទៃដីមានប្រហែលត្រឹមតែ ៣០% ប៉ុណ្ណោះ។

### ១.១. ភូមិសាស្ត្រនៃផ្ទៃដីដាំដុះ

៣០ លានគ.ម² ឬ ២១% នៃផ្ទៃដីដំណាំសាបព្រួស ដាំដុះ មិនមែនមានត្រឹមតែផ្ទៃដី ដែលភ្ជួររាស់ដាំដុះនោះទេ គឺរាប់ទាំងផ្ទៃដី ដែលមានដំណាំបន្លែ សម្រាប់អាហារសត្វផងដែរ។ ផ្ទៃដីមួយផ្នែកធំ ដែលដកលម្អកសិកម្មចេញ មានដីមានជម្រកអចិន្ត្រៃយ៍ ដីស្ងួតហែង ដីតំបន់ភ្នំខ្ពស់ៗ ដីដែលទុកចោល និងដីព្រៃឈើ។

ដីដែលអាចភ្ជួររាស់ដាំដុះបានពិតប្រាកដមាននៅតាមតំបន់ជ្រលងទំនាបទន្លេ ជ្រលងភ្នំ តំបន់ទំនាប តំបន់ឆ្នេរសមុទ្រ និងតំបន់ដែលបញ្ចូលទឹកមាន ១១% នៃផ្ទៃដីទ្វីប។ ផ្ទៃដី ដែលអាចដាំដុះបានទាំងនេះស្ថិតនៅក្នុងទ្វីបអាស៊ី ទ្វីបអាមេរិកខាងជើង ទ្វីបអាមេរិកខាងត្បូង ទ្វីបអឺរ៉ុប ទ្វីបអាហ្វ្រិក និងទ្វីបអូសេអានី។ ក៏ប៉ុន្តែ ២/៣ នៃផ្ទៃដីទាំងនេះ ប្រមូលផ្តុំនៅតំបន់ត្រជាក់បង្គួរ នៃទ្វីបអឺរ៉ុប និងទ្វីបអាមេរិកខាងជើង និងតំបន់ត្រូពិកមូសុងនៃទ្វីបអាស៊ី។ បើរាប់បញ្ចូលទាំងផ្ទៃដី សម្រាប់ចិញ្ចឹមសត្វផងចំនួន ១០% ទៀត នោះផ្ទៃដីកសិកម្មនឹងកើនឡើងដល់ ២១%។ សមាមាត្រ នៃផ្ទៃដីដាំដុះមិនលើសពី ១៧% នៅប្រទេសជប៉ុន ៥០% នៅសហរដ្ឋអាមេរិក និងមានរហូតដល់ ៦០% ស្ថិតនៅក្នុងបណ្តាប្រទេសមួយចំនួននៅទ្វីបអឺរ៉ុបដូចជា នៅប្រទេសបារាំងជាដើម។

បច្ចុប្បន្ន ដោយសារសម្ពាធប្រជាសាស្ត្រ និងការវិវត្តនៃបច្ចេកទេសកសិកម្ម គេអាចពង្រីកផ្ទៃដីដាំដុះបានចំនួន ១៤% និងដីចិញ្ចឹមសត្វបានចំនួន ១៤% ទៀត ដែលធ្វើឱ្យផ្ទៃដីកសិកម្មនឹងកើនឡើងរហូតដល់ ៤៩%។ គេអាចពង្រីកផ្ទៃដីទាំងនេះបាន នៅតាមតំបន់មួយចំនួនដូចជា តំបន់ព្រៃរងទឹកភ្លៀងត្រូពិក តំបន់ស្ងួតហែង តំបន់ស្ទើរស្ងួតហែង និងតំបន់វាលស្មៅ...-ល-។ ចំណែកឯផ្ទៃដី ដែលនៅសេសសល់ទាំងប៉ុន្មានមិនអាចដាំដុះបានទេ ពីព្រោះវាស្ថិតនៅក្នុងតំបន់វាលលហក្តៅ វាលលំហាត្រជាក់តំបន់ប៉ូល និងតំបន់ជួរភ្នំធំៗ ឬខ្ពស់ៗនៅលើផែនដី។

*លំហកសិកម្ម (គិតជាលានគីឡូម៉ែត្រការ៉េ)*

- ផ្ទៃដីសរុបទាំងអស់នៅលើពិភពលោក.................................. ១៤០ (១០០%)
- ផ្ទៃដី ដែលគ្មានតម្លៃ សម្រាប់កសិកម្ម.................................. ៧១ (៥១%)
- ផ្ទៃដីព្រៃឈើ និងតំបន់ស្ទើរស្ងួតហែង.................................. ៣៩ (២៨%)
- ផ្ទៃដីវាលស្មៅ សម្រាប់សត្វ.................................................. ១៤ (១០%)
- ផ្ទៃដីដាំដុះពិតប្រាកដ.......................................................... ១៦ (១១%)
  - តំបន់ត្រជាកបង្គួរ.................................. ................... ១០ (៦២.៥%)
  - តំបន់ត្រូពិច............................................................ ៦% (៣៧.៥%)

## ១.២. មធ្យោបាយពង្រីកផ្ទៃដីដាំដុះ

បច្ចុប្បន្ននេះ ប្រជាជននៅលើពិភពលោកមានការកើនឡើងឥតឈប់ឈរ រីឯផ្ទៃដីដែលអាច ដាំដុះបានពិតប្រាកដមានត្រឹមតែ ១១% នៃផ្ទៃទ្វីបសរុបប៉ុណ្ណោះ។ ដូចនេះ ផ្ទៃដីដាំដុះនេះ គឺពិតជាមិនអាចផលិតស្បៀងអាហារ សម្រាប់ចិញ្ចឹមមនុស្សនៅលើភពផែនដីបានគ្រប់គ្រាន់នោះឡើយ។ ដូច្នេះ ការពង្រីកផ្ទៃដីដាំដុះ គឺជាមធ្យោបាយមួយដ៏ចាំបាច់បំផុត ដែលគេគួរតែយកចិត្តទុកដាក់ និងអនុវត្ត តាម។ ជាទូទៅ គេមានមធ្យោយបាយ ៤ យ៉ាង ដើម្បីពង្រីក ឬបង្កើនផ្ទៃដីដាំដុះ ឬផ្ទៃដីកសិកម្ម ដែលរួមមាន ៖

### ក. ការរុករានដីព្រៃ

ការរុករានដីព្រៃសព្វថ្ងៃនេះ ត្រូវបានគេហៅថា រណសិរ្សឈានមុខ ដូចជានៅប្រទេសប្រេស៊ីល ប្រទេសចិន និងការរុករានដីព្រៃឆ្ពោះទៅទិសខាងលិច នៅអាមេរិកខាងជើងនាសតវត្សរ៍ទី១៩ ជាដើម។ ការរុករានដីព្រៃថ្មី គឺជាមធ្យោបាយពង្រីកផ្ទៃដីដាំដុះមួយ ដែលគេសង្កេតឃើញមានជាទូទៅ នៅបណ្ដាប្រទេសលោកខាងត្បូងមួយចំនួនធំ ក្នុងគោលបំណងអភិវឌ្ឍសេដ្ឋកិច្ចជាតិខ្លួន ក៏ដូចជាការលើកស្ទួយកម្រិតជីវភាពរបស់នៅរបស់ប្រជាជនផងដែរ។ អស់រយៈពេលជាយូរយាមកហើយ ការបង្កើនផលិតកម្មកសិកម្មតែងតែប្រព្រឹត្តទៅ ដោយផ្អែកទៅលើការគាស់រានព្រៃឈើ និងដាំដុះនៅលើដីថ្មីៗ។

ជារៀងរាល់ឆ្នាំ ដីព្រៃប្រហែល១៥ លានហិកតាត្រូវបានគេគាស់រាន ពិសេសនៅក្នុងតំបន់ត្រូពិក ប៉ុន្តែការត្រួសត្រាយជួរមុខទាំងនេះនាំមកនូវវិនាសកម្មព្រៃឈើយ៉ាងធំធេងបំផុតដូចជា នៅព្រៃអាម៉ាសូន ប្រទេសប្រេស៊ីល និងនៅប្រទេសឥណ្ឌូនេស៊ីជាដើម។ ជាក់ស្ដែង កម្មវិធីអភិវឌ្ឍន៍របស់រដ្ឋាភិបាលប្រទេសប្រេស៊ីលនៅបណ្ដាឆ្នាំ ១៩៧០ បានធ្វើឱ្យបាត់បង់ព្រៃអាម៉ាសូនអស់យ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីកសាងផ្លូវថ្នល់ និងផ្លូវដែកជាច្រើនខ្សែ ដែលឆ្លងកាត់ទៅកាន់តំបន់អភិវឌ្ឍន៍ដំណាំចម្ការធំៗ និងទៅកាន់តំបន់អាជីវកម្មរ៉ែនានា។ លើសពីនេះទៅទៀត គេឃើញប្រជាជនប្រេស៊ីល ដែលជាអ្នកអត់មានដីធ្លីបានចូលទៅគាស់រុករានព្រៃអមសងខាងផ្លូវទាំងនោះ ដើម្បីយកដីដាំដំណាំ និងចិញ្ចឹមសត្វ។

### ខ. ការបញ្ចូលទឹក

ការបញ្ចូលទឹក គឺជាមធ្យោបាយពង្រីកផ្ទៃដីដាំដុះមួយបែបផ្សេងទៀត ហើយវាគឺជាបច្ចេកទេសកសិកម្មដ៏ចំណាស់មួយ ដែលអាចឱ្យគេពង្រីកផ្ទៃដីដាំដុះបាន។ មធ្យោបាយបែបនេះ ត្រូវបានគេអនុវត្តនៅតាមតំបន់មួយចំនួនដូចជា តំបន់ស្ងួតហែង តំបន់ស្ទើរស្ងួតហែង តំបន់វាលស្ពឹប និងតំបន់វាលស្មៅ។ ប្រជាជនដែលរស់នៅក្នុងតំបន់ទាំងនេះ ចេះប្រើប្រាស់ប្រភពទឹកដូចជា លើកទំនប់ ជីកប្រឡាយ និងជីកអណ្ដូងជាជួរហៅថា **ផុកការ៉ា** ពីជើងភ្នំរហូតដល់ភូមិ ដើម្បីនាំយកទឹកទៅស្តុកទុក សម្រាប់ស្រោចដំណាំបានយ៉ាងល្អប្រសើរ ដោយបានប្រែក្លាយតំបន់ទាំងនោះឱ្យក្លាយទៅជាកោះបៃតងនៅចំកណ្ដាលវាលលំហហៅថា **អូាស៊ីស**។ អូាស៊ីសខ្លះមានភាពជឿនលឿន ដោយបានទទួលការបញ្ចូលទឹក តាមរយៈប្រមោយស្រោចស្រពវិលជុំវិញអ័ក្សទម្រមួយដើរដោយស្វ័យប្រវត្តិ។ ផ្ទៃដីស្រោចស្រពនីមួយៗមានរាងជារង្វង់ ដែលមានអង្កត់ផ្ចិតដល់ទៅ ១០០ ម៉ែត្រ។ ប្រព័ន្ធស្រោចស្រពបែបនេះ គេឃើញមានអនុវត្តក្នុងតំបន់វាលលំហក្ដៅនៃបណ្ដាប្រទេសប្រេងកាតខ្លះៗនៃទ្វីបអាហ្វ្រិក និងតំបន់វាលលំហក្ដៅភាគខាងលិច នៃសហរដ្ឋអាមេរិក។

នៅលើពិភពលោក ផ្ទៃដីដាំដុះប្រហែល ១/៥ ជាដីបញ្ចូលទឹក។ ជាទូទៅ តំបន់ដែលទទួលបានទឹកភ្លៀងប្រចាំឆ្នាំតិចជាង ៥០០ ម.ម. ត្រូវការបញ្ចូលទឹកដូចជា នៅក្នុងតំបន់វាលលំហ និងតំបន់ស្ទើរវាលលំហ (តំបន់ស្ទើរស្ងួតហែង) នៃតំបន់មជ្ឈឹមបូព៌ា និងតំបន់ភាគខាងលិចសហរដ្ឋអាមេរិកជាដើម។ រីឯនៅបណ្តាប្រទេស ដែលទទួលបានទឹកភ្លៀងគ្រប់គ្រាន់ (ពី ៥០០ ទៅ ១៥០០ ម.ម ក្នុងមួយឆ្នាំ) ក៏ត្រូវការបញ្ចូលទឹកដែរ ពីព្រោះភ្លៀងធ្លាក់មិនទៀងទាត់ ឬក៏ធ្លាក់មកមិនចំពេល ដែលដំណាំកំពុងត្រូវការទឹកច្រើនដូចជា នៅប្រទេសឥណ្ឌា ប្រទេសប៉ាគីស្ថាន ប្រទេសចិន និងប្រទេសអូស្ត្រាលីជាដើម។

ជាទូទៅ វិធីបញ្ចូលទឹកទៀតទាត់ផ្តល់លទ្ធភាពឱ្យការដាំដុះប្រព្រឹត្តទៅបានពេញមួយឆ្នាំ ក៏ប៉ុន្តែចាំបាច់ត្រូវមានប្រព័ន្ធបញ្ចេញទឹកមួយ ដើម្បីកុំឱ្យទឹកនៅនឹង។ បើការបញ្ចេញទឹកមិនបានល្អ ពោលគឺបើទឹកមិនហូរទេ នោះវានឹងបង្កើននូវជាតិអំបិលទៅឱ្យដី ដែលនាំឱ្យដីខូចគុណភាព និងម្យ៉ាងទៀត វាក៏បណ្តាលឱ្យមានមេរោគគ្រុនចាញ់ផងដែរ ក៏ប៉ុន្តែប្រសិនបើទុកឱ្យដីនៅស្ងួតពេក នោះវានឹងធ្វើឱ្យដីក្លាយទៅជារឹងឡើងក្តាំងបង្កើតជាថ្ម បាយក្រៀម។

### គ. ការពង្រាតដីវាលភក់

វាលភក់ គឺជាតំបន់ដីសើម ដែលមានព្រៃលិចទឹក មានដីឆ្អែតទឹក និងត្រូវបានលិចទឹកជាអចិន្ត្រៃយ៍ ឬលិចទឹកទៅតាមរដូវ។ នៅលើពិភពលោក គេឃើញមានវាលភក់ជាច្រើនដូចជា វាលភក់នៅតាមឆ្នេរភាគខាងត្បូងសហរដ្ឋអាមេរិក វាលភក់នៅតាមឆ្នេរខាងជើងប្រទេសម៉ិចស៊ិច វាលភក់នៅតាមឆ្នេរប្រទេសគុយបា វាលភក់នៅតាមឆ្នេរទ្វីបអាមេរិកខាងត្បូង វាលភក់នៅតាមឆ្នេរនៃទ្វីបអាហ្វ្រិក វាលភក់នៅតាមឆ្នេរនៃទ្វីបអាស៊ី និងវាលភក់នៅតាមឆ្នេរនៃប្រទេសអូស្ត្រាលីជាដើម។ ជាទូទៅ ការពង្រីកផ្ទៃដីដាំដុះនៅតាមតំបន់វាលភក់ ត្រូវបានគេអនុវត្តនៅតាមបណ្តាប្រទេសមួយចំនួន ដែលសម្បូរវាលភក់ ជាពិសេសបណ្តាប្រទេសដែលមានផ្ទៃដីទំនាបតូចចង្អៀត ឬមានផ្ទៃដីតូចចង្អៀតនៅលើពិភពលោក។ ការរុករានដីថ្មីចូលទៅក្នុងតំបន់វាលភក់នៅក្នុងតំបន់ឆ្នេរសមុទ្រមាន ២ ប្រភេទគឺ ៖

#### ១. ប៉ុលឌែកម្ម

ប៉ុលឌែកម្ម គឺជាដំណើរ នៃការពង្រីកផ្ទៃដីថ្មីចូលទៅក្នុងទឹកសមុទ្ររាក់ៗ តាមរយៈការលើកទំនប់ ការបញ្ចេញទឹកប្រៃ ការបញ្ចូល ហើយនិងការបញ្ចេញទឹកសាប។

ប៉ុលឌែកម្ម វាគឺជាមធ្យោបាយមួយផ្សេងទៀត ដែលគេសង្កេតឃើញមានអនុវត្តន៍ជាទូទៅ នៅក្នុងបណ្តាប្រទេសចំនួន ដែលមានផ្ទៃដីទំនាបតូចចង្អៀត ឬផ្ទៃដីតូចៗចង្អៀតដូចជា នៅប្រទេសហូឡង់ ប្រទេសសិង្ហបុរី និងប្រទេសជប៉ុនជាដើម។

#### ២. ដីចំណាក់បំពេញ ឬដីខឿន

ដីចំណាក់បំពេញ ឬដីខឿន គឺជាដំណើរនៃការពង្រីកផ្ទៃដីថ្មីចូលទៅក្នុងសមុទ្ររាក់ៗតាមរយៈការចាក់ដីបំពេញ ឬចាក់លុប។ ដីខឿន ឬដីចំណាក់បំពេញត្រូវបានគេអនុវត្តជាទូទៅ នៅក្នុងបណ្តាប្រទេសមួយចំនួន ដែលមានផ្ទៃដីតូចចង្អៀត ឬមានដីទំនាបតូចចង្អៀតដូចជា នៅប្រទេសហូឡង់ ប្រទេសសិង្ហបុរី ទីក្រុងហុងកុង និងប្រទេសជប៉ុនជាដើម។

### ឃ. ស្រែថ្នាក់ៗ ឬចម្ការល្បាក់

នៅតាមតំបន់ភ្នំ ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ ឬនៅតាមបណ្តាប្រទេស ដែលសម្បូរដោយភ្នំ និងមានដីទំនាបតូចចង្អៀតដូចជា នៅប្រទេសឥណ្ឌូណេស៊ី ប្រទេសចិន ប្រទេសហ្វីលីពីន ប្រទេសម៉ាលេស៊ី ជាដើម មនុស្សបានរចនាជម្រាលភ្នំឱ្យក្លាយទៅជាស្រែថ្នាក់ៗ ឬចម្ការល្បាក់ រាងជាកាំជណ្តើរ ដែលជាវិធីសាស្ត្រមួយផងដែរ ក្នុងការពង្រីកផ្ទៃដីដាំដុះផង និងថែរក្សានូវគុណភាពដីផង។ ការរៀបចំដីបែបនេះ មានតាំងពីយូរយារណាស់មកហើយ ហើយទាមទារការងារមួយដ៏ធំធេង ដើម្បីទទួលបានដី ស្រែចម្ការដ៏តូចចង្អៀត។

គេកាប់ជម្រាលភ្នំជាថ្នាក់ៗដូចជា កាំជណ្តើរខណ្ឌដោយជញ្ជាំងទប់ដី។ បច្ចេកទេសបែបនេះ អាចជួយកាត់បន្ថយនូវផលប៉ះពាល់ទៅលើដី ដែលបណ្តាលមកពីភ្លៀងធ្លាក់ធំៗ និងអាចបញ្ចៀសបាននូវសំណឹកដីដ៏ខ្លាំងក្លា ឬអាចរក្សាទឹកទុកឱ្យបានយូរនៅតាមតំបន់ខ្សត់ភ្លៀងដូចជា នៅប្រទេសម៉ិចស៊ិច និងតំបន់ខ្លះ នៃប្រទេសឥណ្ឌា។ ការធ្វើស្រែ ឬចម្ការបែបនេះទាមទារឱ្យមានការថែទាំយ៉ាងជិតដល់ខ្លាំងណាស់។

*ស្រែថ្នាក់ៗនៅប្រទេសឥណ្ឌូណេស៊ី*



## ២. មនុស្សស្ថាបនាទេសភាពកសិកម្ម

### ២.១. វិភាគទេសភាពកសិកម្ម

ទេសភាពកសិកម្ម សុទ្ធតែជាស្នាដៃជាក់ស្តែងនៃការរៀបចំលំហកសិកម្ម។ វា គឺជាស្នាដៃរបស់មនុស្សដែលប្រកបដោយពណ៌ប្លែកៗ ដោយពេលខ្លះមានពន្លឺស្រស់បំព្រង នៃផ្ទៃដីដាំដុះ។ ទេសភាពកសិកម្មរួមផ្សំដោយលំនៅឋាននៅតាមតំបន់ជនបទ ចម្ការដាំដំណាំតូចធំ ផ្លូវដើរដែលភ្ជាប់ពីលំនៅឋានទៅចម្ការតូចៗ ពេលខ្លះគេឃើញមានព្រៃឈើ ដោយសារតែចម្ការទាំងនោះត្រូវបានគេទុកចោលយូរមកហើយ។ លំនៅដ្ឋាននៅតំបន់ជនបទ គឺជាកន្លែងមនុស្សរស់នៅផង និងជាកន្លែងប្រកបការងារផង ដែលជារបស់មួយដ៏ល្អប្រសើររបស់អ្នកស្រែចម្ការ។ ជាទូទៅ មនុស្សសង់វាដោយប្រើសម្ភារៈដែលមាននៅក្នុងតំបន់ (ផ្ទះធ្វើពីដី ឬបាយអរឈើ ថ្ម) ពេលខ្លះ សត្វ និងមនុស្សរស់នៅក្រោមដំបូលតែមួយជាមួយគ្នា និងពេលខ្លះ គេឃើញមានអាគារជាច្រើននៅជុំវិញទីធ្លាមួយ ដែលបើកចំហ ឬបិទ។ ជម្រកនៅតំបន់ជនបទ ពេលខ្លះស្ថិតនៅប្រមូលផ្តុំគ្នាបង្កើតបានជាភូមិ និងពេលខ្លះស្ថិតនៅដាច់ៗ ឬរាយប៉ាយពីគ្នា។

ដីដែលធ្វើអាជីវកម្ម ដោយសហគមន៍អ្នកស្រែត្រូវគេបានកំណត់តាមទំនៀមទំលាប់ ដោយគតិយុត្តិ ដែលគេហៅថា ដីសហគមន៍។ ផែនទីមាត្រដ្ឋានធំ ដែលតាងចម្ការទាំងនោះហៅថា ប្លង់ដី។ ការរៀបចំដីកសិកម្ម តូចៗ គឺជាទេសភាពជនបទ ដែលត្រូវបានច្នៃប្រឌិតដោយមនុស្ស មានលំនៅឋាន ផ្លូវគមនាគមន៍ និងទុកដី ចោលឱ្យព្រៃដុះ។ ទេសភាពកសិកម្មនៅលើពិភពលោកមានលក្ខណៈខុសប្លែកៗពីគ្នាដូចជា ៖

- ទេសភាពកសិកម្មគ្មានសណ្ដាប់ធ្នាប់នៅទ្វីបអាព្រិច ក្នុងតំបន់ត្រូពិចស្ងួត
- ទេសភាពកសិកម្មមានសណ្ដាប់ធ្នាប់នៅទ្វីបអាស៊ី (ទេសភាពវាលស្រែនៅអាស៊ី) ទ្វីបអាមេរិក ខាងជើង ទ្វីបអាមេរិកខាងត្បូង ទ្វីបអូស្ត្រាលី និងទ្វីបអឺរ៉ុប។

ទេសភាពកសិកម្មនៅទ្វីបអឺរ៉ុបមាន ២ ប្រភេទ គឺ ៖

- **ចំហការចំហ ឬស្រែវាល** ៖ គឺជាប្រភេទដីស្រែ ឬដីចម្ការមួយ ដែលក្នុងនោះដីស្រែ ឬចម្ការទាំង នោះ មានផ្ទៃធំល្វឹងល្វើយ ដោយមានលំនៅឋានស្ថិតនៅប្រមូលផ្ដុំគ្នាបង្កើតបានជាភូមិ។
- **ស្រែចំណារ ឬចម្ការបិទ** ៖ គឺជាប្រភេទដីស្រែ ឬចម្ការមួយ ដែលក្នុងនោះដីស្រែ ឬចម្ការទាំងនោះ មានផ្ទៃជួនកាលតូច ជួនកាលធំ ដែលហ៊ុំពទ្ធ័ដោយដើមឈើ ឬខណ្ឌគ្នាដោយដើមឈើ និងមាន លំនៅឋាននៅរាយប៉ាយដាច់ៗពីគ្នា នៅឯណោះមួយ ឯណោះមួយ។

## ២.២. ការស្ថាបនាទេសភាពកសិកម្ម

ទេសភាពកសិកម្ម គឺត្រូវបានស្ថាបនាឡើងដោយសារកត្តាធម្មជាតិផង និងកត្តាមនុស្សនៅក្នុងតំបន់ ជនបទផង។ អាកាសធាតុនៅក្នុងតំបន់នីមួយៗ អាចឱ្យគេមើលឃើញពីស្លាកស្នាមនៃកសិកម្មនៅក្នុងតំបន់ នោះ ដែលអាចជាដំណាំស្រូវសាលី ដំណាំស្រូវ ដំណាំពោត ឬស្រូវមីយេជាដើម។ នៅតំបន់ភ្នំ ផ្ទៃដីដាំដុះមាន ការថយចុះ ដោយសារតែការរីករាលដាលនៃវាលស្មៅ សម្រាប់ចិញ្ចឹមសត្វ។ នៅក្នុងតំបន់សើមជានិច្ចកាល លំនៅឋានតែងតែប្រមូលផ្ដុំនៅតាមទីកន្លែងដែលមានប្រភពទឹក។ ប៉ុន្តែ ឥទ្ធិពលរបស់ទឹក មិនបានបកស្រាយ អំពីការរស់នៅបែបប្រមូលផ្ដុំ ឬជាការរស់នៅបែបរាយប៉ាយត្រង់នេះបន្តិច ត្រង់នោះបន្តិចរបស់ប្រជាជន ជនបទនោះឡើយ។ ឧទាហរណ៍ ៖ សន្តិសុខរបស់តំបន់ ដែលជំរុញឱ្យអ្នកស្រែចម្ការនៅតាមតំបន់មេឌីទែរ៉ា នេរស់នៅប្រមូលផ្ដុំគ្នានៅតាមទីស្ថិត ដែលមានលក្ខណៈការពារនៅក្នុងភូមិទាំងឡាយ ដោយមានលំនៅឋាន នៅលាយឡំជាមួយផ្ទាំងថ្មធំៗ។

ទេសភាពកសិកម្មនៅតំបន់ជនបទ គឺជាលទ្ធផលរបស់សង្គមមនុស្ស ច្រើនជាងការបកស្រាយរបស់ ប្រព័ន្ធអេកូឡូស៊ី។ ទេសភាពចម្ការចំហ ឬស្រែវាលបញ្ជាក់ពីចរិតលក្ខណៈរបស់សង្គមមនុស្សដែលរស់នៅ ជាសហគមន៍ ដោយសមាជិកទាំងអស់រស់នៅក្នុងសង្គមមួយ ព្រមទាំងមានចំណងទាក់ទងគ្នាយ៉ាងតឹងរ៉ឹង។ រីឯទេសភាពចម្ការបិទ ឬស្រែចំណារវិញបញ្ជាក់ពីចរិតលក្ខណៈនៃការរស់នៅតាមលក្ខណៈបែបជាបុគ្គលម្នាក់ៗ ឬបែបជាគ្រួសារនីមួយៗ។ នៅក្នុងបណ្ដាប្រទេស ដែលមានអរិយធម៌ចាស់បុរាណ ទេសភាពកសិកម្ម គឺជា វិមានប្រវត្តិសាស្ត្រយ៉ាងពិតប្រាកដ ដែលបានរៀបចំកែលម្អអស់ជាច្រើនសតវត្សរ៍មកហើយ។ ប្រព័ន្ធនៃការដាំ ដំណាំនីមួយៗបណ្ដាលមកពីការជ្រើសរើសរបស់មនុស្សជាតិ។ គេជ្រើសរើសយកប្រព័ន្ធពហុវប្បកម្ម គឺដើម្បី បង្គ្រប់តម្រូវការរបស់ពួកគេ។ គេជ្រើសរើសយកប្រព័ន្ធឯកវប្បកម្ម គឺដើម្បីឆ្លើយតបទៅនឹងទីផ្សាររបស់គេ។ ចំនួនប្រជាជនក៏មានឥទ្ធិពលទៅលើទេសភាពកសិកម្មផងដែរ។ នេះមានន័យថា វិស័យកសិកម្មវាតទីយ៉ាងធំ

ផេង ហើយមានការបែងចែកជាចម្ការ ឬស្រែតូចៗ នៅពេលណាដែលមានសម្ពាធប្រជាសាស្ត្រខ្លាំង។ ចម្ការ ឬដីស្រែដែលត្រូវគេបោះបង់ចោល កាន់តែរីកធំឡើងៗ នៅក្នុងចម្ការ ឬស្រែសហគមន៍ នៅពេលណា ដែលចំនួនប្រជាកសិករមានការថយចុះ។

## ៣. ពលករដីធ្លី

### ៣.១. អ្នកស្រែចម្ការនៅលើពិភពលោក

២/៣ នៃអ្នកស្រែចម្ការនៅលើពិភពលោក គឺប្រមូលផ្តុំនៅចន្លោះខ្សែស្របទី ៤០$^{0}$ នៃអឌ្ឍគោលខាងជើង និងទី ៣០$^{0}$ នៃអឌ្ឍគោលខាងត្បូង ដែលស្ថិតនៅក្នុងទ្វីបអាមេរិកខាងជើង និងខាងត្បូងក្នុងតំបន់ត្រូពិកនៃទ្វីបអាហ្វ្រិក ទ្វីបអាស៊ី និងតំបន់ដែលទទួលរបបខ្យល់មូសុង។ ការចំណេញនៅលើផ្នែកផលិតភាព បានកាត់បន្ថយនូវចំនួនអ្នកស្រែចម្ការយ៉ាងច្រើនសន្ធឹកសន្ធាប់ នៅក្នុងបណ្តាប្រទេសដែលមានឧស្សាហកម្មរីកចម្រើន។

### ៣.២. កម្មសិទ្ធិដីធ្លី

ពីមុន លំហកសិកម្មហាក់ដូចជាកម្មសិទ្ធិរបស់សមូហភាព។ នេះមានន័យថា ទាល់តែមនុស្សរស់នៅជាច្រើនក្រុម ទើបអាចមានសមត្ថភាពកាប់ឆ្ការព្រៃដើម្បីធ្វើអាជីវកម្ម និងការពារដីដាំដុះបាន។ តែបច្ចុប្បន្ននេះ ដីធ្លី មួយភាគធំនៅជារបស់សហគមន៍នៅឡើយ នៅទ្វីបអាមេរិកខាងត្បូងតំបន់ជួរភ្នំអង់ និងវាលលំហសាហារ៉ានៅទ្វីបអាហ្វ្រិក។ នៅក្នុងគ្រប់សង្គមជនបទ ដែលបានរក្សាទុកការរួបរួមគ្នាយ៉ាងខ្លាំងក្លា គេបានបែងចែកគ្នាជារៀងរាល់ឆ្នាំនូវដីធ្លីទៅតាមសមាជិក នៃគ្រួសារនីមួយៗ។

នៅទ្វីបអឺរ៉ុប កម្មសិទ្ធិតូចតាចរបស់អ្នកស្រែចម្ការកើតមានឡើង ដោយសារការតស៊ូរាប់សតវត្សរ៍ ដើម្បីដណ្តើមយកមកពីវណ្ណៈអភិជន ព្រះវិហារ និងពួកគហបតី។ វាមិនដាច់ចេញពីមូលដ្ឋានភូមិឃុំនោះឡើយ វិស័យសហគមន៍ជនបទផ្តល់ឱ្យគេនូវតម្រូវការព្រៃឈើ និងវាលចិញ្ចឹមសត្វ។ កម្មសិទ្ធិអ្នកស្រែចម្ការបែបនេះបានបែងចែកទៅតាមកេរ្តិ៍មរតកតៗគ្នារហូតមក ក៏ប៉ុន្តែកម្មសិទ្ធិគ្រួសារតូចៗពុំសមស្របទៅតាមនិយាមរបស់សង្គមឧស្សាហកម្មនោះឡើយ។ ហេតុដូចនេះហើយ ទើបនៅបច្ចុប្បន្ននេះ មានការប្រមូលផ្តុំចម្ការតូចៗឡើងវិញឱ្យទៅជាចម្ការធំមួយ ឬច្រើន។

កម្មសិទ្ធិដីធ្លីធំៗទាំងឡាយ ( ឡាទីនផានឌីយ៉ា ៖ Latinundia) បានអនុញ្ញាតឱ្យមានប្រាក់ចំណេញ និងកិត្យានុភាព។ ជានិច្ចកាល វាជាទ្រព្យសម្បត្តិរបស់មហាសេដ្ឋី គហបតីនៅក្នុងទីក្រុង ឬជនបទ។ កម្មសិទ្ធិដីធ្លីធំៗ បង្ហាញពីចរឹតលក្ខណៈផងដែរ របស់ប្រទេសដែលធ្លាប់បានទទួលអាណានិគមពីបណ្តាប្រទេសនានានៅទ្វីបអឺរ៉ុប ឬទីកន្លែងដែលទើបមានមនុស្សមករស់នៅដូចជា នៅប្រទេសអូស្ត្រាលី នៅអាមេរិកឡាទីន និងនៅអាមេរិកខាងជើងជាដើម។

ដើម្បីធ្វើការកែលម្អការបែងចែកដីធ្លី ដែលមិនស្មើភាពគ្នា ការកែទម្រង់ជាច្រើនបានកើតមានឡើងក្រោយសង្គ្រាមលោកលើកទាំងពីរលើក និងមានការរំដោះពីអាណានិគម។ គេបានធ្វើការរឹបអូស ឬប្រមូលទិញដីពីម្ចាស់កម្មសិទ្ធិធំៗ ហើយធ្វើការបែងចែក ឬប្រគល់ប្រយោជន៍ឲ្យទៅកសិករក្រីក្រ។

### ៣.៣. ការធ្វើអាជីវកម្មដីធ្លី

កាលណាម្ចាស់ដីធ្វើអាជីវកម្មលើដី ដែលខ្លួនឯងមាន គេនិយាយថា ការធ្វើឱ្យបានផលដោយផ្ទាល់។ ការជួលដី កាលណាម្ចាស់ដីផ្ទេរអាជីវកម្មទៅឱ្យកសិករ លុះត្រាតែមានឱ្យបំណុលប្រចាំឆ្នាំ គិតជាលុយកាក់។

ការប្រវាស់ដី ដែលម្ចាស់ដីត្រូវផ្តល់ដី និងមធ្យោបាយធ្វើអាជីវកម្មមួយចំនួន ហើយអ្នកដែលប្រវាស់ដីត្រូវបែងចែកកសិផលជាមួយនឹងម្ចាស់ដី។ និយោជិតកសិកម្ម ដែលបច្ចុប្បន្នមានការថយចុះយ៉ាងច្រើននៅក្នុងប្រទេសដែលអនុវត្តនូវយន្តកម្មកសិកម្មធំៗ មិនចូលរួមជាមួយនឹងប្រាក់ចំណេញ ដែលបានមកពីអាជីវកម្មនោះឡើយ ពីព្រោះគេមានប្រាក់បៀវត្សរ៍។

នៅបណ្តាប្រទេសប្រជាធិបតេយ្យប្រជាមានិត ឬប្រទេសសង្គមនិយមមួយចំនួននៅលើពិភពលោក សហករណ៍ភាវូបនីយកម្មបានទទួលបន្តពីការធ្វើកំណែទម្រង់ដីធ្លី ពោលគឺរដ្ឋជាម្ចាស់ដីធ្លី ដែលធ្វើអាជីវកម្មដោយប្រើកម្មកររបស់រដ្ឋ ឬដោយក្រុមអ្នកស្រែចម្ការ ដែលចងក្រងគ្នាជាក្រុមសហករណ៍ ហើយស្ថិតនៅក្រោមអាណាព្យាបាលរបស់រដ្ឋ។

បែបផែនធ្វើឱ្យបានផលពីដី ញែកឱ្យឃើញអំពីភាពខុសគ្នា នៃអាជីវកម្មកសិកម្ម ៖ គុណភាព និងបរិមាណនៃពលករ សម្ភារៈបរិក្ខារជាម៉ាស៊ីន ប្រភេទ និងគោលបំណងនៃផលិតកម្ម។ អាជីវកម្មតូចតាចនៅតែជាអាជីវកម្មចិញ្ចឹមតែពោះ សម្រាប់តែបំពេញតម្រូវការក្នុងគ្រួសារតែប៉ុណ្ណោះ ប៉ុន្តែពេលណាសេដ្ឋកិច្ចដូរដូររីករាលដាលដល់តំបន់ជនបទ គេត្រូវការផលិត ដើម្បីលក់ដូរ។ កសិកម្មកេងកម្រៃ គឺការធ្វើឯកទេសកម្មទៅលើកសិផលមួយចំនួនតូច សម្រាប់ធ្វើជំនួញនៅលើទីផ្សារ ដើម្បីបានប្រាក់កម្រៃច្រើន។ ប្រព័ន្ធកសិកម្មយថាផលទទួលបានផលទាប ក្នុងមួយឯកតាដី ដោយប្រើលំហាធំធេង។ កសិកម្មអតិផលទទួលបានផលច្រើន ក្នុងមួយឯកតាដី ដោយប្រើលំហាដ៏តូចចង្អៀត ដោយសារតែពលកម្មយ៉ាងខ្លាំងក្លារបស់ប្រជាកសិករ និងប្រើបច្ចេកទេសទំនើប។

## ៤. បដិវត្តន៍បៃតង

### ៤.១. និយមន័យ

បដិវត្តន៍បៃតង គឺជាដំណើរនៃការបំលែងលក្ខខណ្ឌផលិតកម្មកសិកម្ម ក្នុងន័យធ្វើអតិផលកម្ម ដែលកើតមានឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍនៅបណ្តាឆ្នាំ១៩៦០ និងឆ្នាំ១៩៧០ ឬយើងអាចោឱ្យនិយមន័យតាមបែបម្យ៉ាងទៀតថា គឺជាដំណើរ នៃការធ្វើឱ្យគ្រាប់ធុញ្ញជាតិទទួលបានទិន្នផលខ្ពស់ តាមរយៈការប្រើបច្ចេកទេសទំនើប ឬការធ្វើប្រពលវប្បកម្ម។

ស្នាដៃនេះ ត្រូវបានសម្រេចឡើងដោយវិទ្យាស្ថានស្រាវជ្រាវពូជស្រូវអន្តរជាតិហៅកាត់ថា IRRI ( International Rice Research Institute ) នៅតំបន់ឡូបាណូសជិតទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ដែលដឹកនាំដោយបណ្ឌិត **ស្វាមីណាថាន** ជនជាតិឥណ្ឌា។ IRRI បានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៦១ ក្រោមគំនិតផ្តួចផ្តើមរបស់អង្គការចំណីអាហារ និងកសិកម្មពិភពលោកហៅកាត់ថា FAO (Food and Agricultural Organization) ដែលមានភារកិច្ចអភិរក្សនានាភាពនៃប្រភេទស្រូវ ដែលមាននៅគ្រប់ទ្វីប ដើម្បីចៀសវាងភាពខ្សត់ទៅៗ នៃពូជស្រូវ។ ពូជស្រូវបង្កាត់ IR36 របស់វិទ្យាស្ថាននេះ គ្មានសោះឡើយកាលពីមុនឆ្នាំ ១៩៦៦ ហើយត្រូវបានគេបានយកទៅសាបព្រួសនៅលើផ្ទៃដី ១២ លានហិកតា នៅក្នុងទ្វីបអាស៊ី ក្នុងនោះ ២/៣ នៅប្រទេសឥណ្ឌា។ IR36 ជាប្រភេទស្រូវលូតលាស់ឆាប់ហ័ស មានដើមខ្លី គួរស្រូវធ្ងន់ ឈ្មះជម្ងឺ ធននឹងសត្វចង្រៃបំផ្លាញ ត្រូវការទឹកតិច និងទទួលបានទិន្នផលខ្ពស់។

ទន្ទឹមគ្នានេះដែរ ប្រភេទពូជស្រូវសាលីឈ្មោះ **សូណារ៉ា** និងពោតរបស់មជ្ឈមណ្ឌលស្រាវជ្រាវមួយកន្លែងនៅក្បែរទីក្រុងម៉ិចស៊ិចកូ ដែលបានដឹកនាំដោយក្សេតសាស្ត្រវិទូ ឬអ្នកវិទ្យាសាស្ត្រផ្នែកដំណាំអាមេរិកឈ្មោះ **ណរម៉ិន បរឡុក** (Norman Borlaug) ជាសមិទ្ធិផលពិសេសមួយទៀតផ្នែកកសិកម្ម។

## ៤.២. គុណសម្បត្តិ និងគុណវិបត្តិ នៃបដិវត្តន៍បៃតង

### ក. គុណសម្បត្តិ នៃបដិវត្តន៍បៃតង

ជាទូទៅ បដិវត្តន៍បៃតងតែងតែនាំមកនូវផលវិជ្ជមានជាច្រើន សម្រាប់មនុស្សលោកដូចជា ៖

- បង្កើនផលិតកម្មស្បៀងអាហារ ក្នុងកម្រិតមួយខ្ពស់ អាចបំពេញតម្រូវការស្រូវនៅលើពិភពលោក អាចរត់ទាន់ល្បឿនកំណើនប្រជាជន។
- អាចលុបបំបាត់បញ្ហាគ្រោះទុរ្ភិក្សបាន។ ឧទាហរណ៍ ៖ នៅឆ្នាំ១៩៤៧ ចក្រភពឥណ្ឌា ដែលទើបទទួលបានឯករាជ្យពីចក្រភពអង់គ្លេសនោះ មានប្រជាជនសរុបមិនដល់ ៥០០ លាននាក់ផង ត្រូវទទួលរងនូវគ្រោះទុរ្ភិក្ស ប៉ុន្តែនៅឆ្នាំ១៩៦០ ដោយសារតែការអនុវត្តន៍បដិវត្តន៍បៃតង ប្រទេសឥណ្ឌាដែលមានប្រជាជនកើនឡើងយ៉ាងច្រើននោះ លែងជួបប្រទះគ្រោះទុរ្ភិក្សដូចមុនទៀតហើយ។
- បង្កើននូវផលិតផលនាំចេញ។ ឧទាហរណ៍ ៖ នៅឆ្នាំ ១៩៨៨ ប្រទេសឥណ្ឌាផលិតស្រូវបានបីដងលើសឆ្នាំ ១៩៦៦ ដែលក្នុងរយៈពេលនោះ កំណើនប្រជាជនមានត្រឹមតែ ១០០ លាននាក់ប៉ុណ្ណោះ។ ប្រទេស ដែលធ្លាប់តែទទួលរងគ្រោះទុរ្ភិក្ស ដោយសារខ្វះខាតស្បៀងបានក្លាយទៅជាអ្នកនាំចេញនូវស្រូវសាលីមួយយ៉ាងចម្លែកនៅលើពិភពលោក។
- រួមចំណែកក្នុងការកាត់បន្ថយនូវអត្រាអត់ការងារធ្វើរបស់ប្រជាជន។
- លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។
- បង្កើនប្រាក់ចំណូល ក្នុងថវិកាជាតិ (GDP)។
- ជួយលើស្ទួយ និងរក្សាលំនឹងជញ្ជីងពាណិជ្ជកម្ម។

### ខ. គុណវិបត្តិ នៃបដិវត្តន៍បៃតង

ទន្ទឹមនឹងគុណសម្បត្តិ បដិវត្តន៍បៃតងក៏ផ្តល់នូវគុណវិបត្តិមួយចំនួនផងដែរដូចជា ៖

- បង្កើតឱ្យមានវិសមភាពរវាងកសិករក្រីក្រ និងកសិករអ្នកមាន។
- បង្កឱ្យកសិករក្រីក្របាត់បង់ដីកសិកម្ម ដោយហេតុថា កសិករក្រីក្រគឺពុំមានលទ្ធភាពអាចទិញគ្រឿងយន្ត ទិញជី និងថ្នាំគីមីថ្លៃៗបាន ដូចនេះកសិកក្រីក្របង្ខំចិត្តលក់ដីស្រែកសិកម្មរបស់ខ្លួន។
- បង្កឱ្យកសិករមួយចំនួនបាត់បង់ការងារធ្វើ ដោយសារតែការធ្វើបដិវត្តន៍បៃតង មានការប្រើប្រាស់គ្រឿងយន្តជំនួសកម្លាំងមនុស្ស ជាហេតុនាំបាត់បងការងាររបស់ប្រជាកសិករក្រីក្រ។
- បណ្តាលឱ្យមានចំណោលស្រុកស្រែកើតមានឡើង ដោយសារតែកសិករក្រីក្រគ្មានការងារធ្វើ បង្ខំចិត្តឱ្យពួកគេធ្វើចំណាកស្រុក។

- បង្កើនឱ្យមានផលប៉ះពាល់ទៅដល់តុល្យភាពនៃការចំណាយ ពីព្រោះថា ដើម្បីទទួលបានទិន្នផលខ្ពស់ជាប្រចាំនោះ ពួកកសិករត្រូវប្រើប្រាស់ជី ដើម្បីរក្សាគុណភាពដី ទោះបីជាជីមាននៅក្នុងស្រុក ឬ នាំចូលក៏ដោយ។
- បង្កឱ្យមានការបំពុលទឹក បំពុលដី និងបំពុលខ្យល់ ដោយសារការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតជាប្រចាំ។
- បង្កឱ្យដីខូចគុណភាព ដោយសារការប្រើប្រាស់ជីគីមី ថ្នាំសម្លាប់សត្វល្អិត និងការបញ្ចូលទឹកជាប្រចាំ ព្រោះថា កាលណាកសិករប្រើប្រាស់ជីគីមី ថ្នាំសម្លាប់សត្វល្អិត និងបញ្ចូលទឹកជាប្រចាំ ធ្វើឱ្យដីឡើងរឹងក្តាំង និងធ្វើឱ្យដីមានកំហាប់កម្រិតជាតិអំបិលខ្ពស់ ដែលនាំឱ្យដីខូចគុណភាព។
- បង្កឱ្យបាត់បង់ប្រភេទរុក្ខជាតិមួយចំនួន ដោយសារតែការបង្កាត់ពូជរុក្ខជាតិ និងការជ្រើសរើសពូជរុក្ខជាតិល្អៗច្រើនពេក ធ្វើឱ្យពូជរុក្ខជាតិអន់មួយចំនួនបាត់បង់ ដោយសារតែប្រជាកសិករឈប់ប្រើប្រាស់។

## ៥. កសិកម្ម និងបរិស្ថាន

ជាទូទៅ កសិកម្មតែងតែធ្វើឲ្យខូចបរិស្ថាន ដោយធ្វើឲ្យមានការប្រែប្រួលមជ្ឈដ្ឋានធម្មជាតិ។ វាបានធ្វើឱ្យបាត់បង់ព្រៃឈើ កូនឈើតូចៗដែលបង្កើតជារបាំការពារដី និងផ្តល់កំទេចកំទីដែលពុកផុយ សម្រាប់រក្សាបរិមាណទឹក ហើយធ្វើឱ្យដីមិនសូវហូរច្រោះ ដោយសារប្រព័ន្ធឫសរបស់រុក្ខជាតិ កូនតូចៗមានលទ្ធភាពបន្ថយល្បឿនខ្យល់ និងសកម្មភាពសំណឹក។ វាជួយសម្រួលសំណើមក្នុងបរិយាកាស និងសំណើមដី ការពារទប់ទល់ទៅនឹងកំណកក្នុងដី។ កូនឈើផ្តល់ជាជម្រកដល់សត្វព្រៃ និងសត្វពាហនៈ ដែលស៊ីស្មៅនៅតាមវាលស្មៅក្នុងរបង និងជាជម្រកផងដែរដល់សត្វបក្សី ដែលរស់នៅដោយសារសត្វល្អិត និងពពួកសត្វកកេរតូចៗ។

ហ្វូងចៀម និងពពែរបស់អ្នកចិញ្ចឹមសត្វអាចជាកន្ត្រៃតុងជីរស់ ដែលធ្វើឱ្យប្រែប្រួលតំបន់មេឌីទែរ៉ានេដែលមានពណ៌បៃតងឲ្យក្លាយទៅជាវាលលំហាថ្មីយ៉ាងពិតប្រាកដ។ កសិកម្ម និងការចិញ្ចឹមសត្វ ដោយធ្វើការជ្រើសរើសពូជ ឬប្រភេទរុក្ខជាតិ និងសត្វគ្មានស្ថេរភាពបានធ្វើឱ្យបាត់បង់ប្រភេទសត្វ និង រុក្ខជាតិខ្លះ និងលក្ខណៈប្លែកៗរបស់វា ហើយធ្វើឲ្យទុនជីវសាស្ត្រដ៏មានតម្លៃចុះក្រទៅៗ ដោយមិនអាចស្តារឡើងវិញបាន។

កសិកម្មធ្វើឱ្យមានការបំពុលបរិស្ថាន ដោយធ្វើឱ្យមានការបំពុលខ្យល់ បំពុលទឹក និងបំពុលដី។ នៅក្រោមផល នៃការចង់បានកម្រៃខ្ពស់ ឬដំណុះប្រជាសាស្ត្រ (សម្ពាធប្រជាសាស្ត្រ) ដើម្បីបង្គ្រប់តម្រូវការរបស់មនុស្សជាតិ ដែលមានចំនួនកាន់តែច្រើនឡើងៗ កសិករចង់បង្កើនទិន្នផលកសិកម្មរបស់ពួកគេពួក គេបានប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិតចង្រៃយ៉ាងច្រើនទៅលើដីធ្លី ដែលគេធ្វើអាជីវកម្ម និងបំបាត់សកម្មភាពរបស់សត្វទាំងនោះ។ ជីគីមី និងថ្នាំសម្លាប់សត្វល្អិតចង្រៃបានហូរចូលទៅតាមខ្សែទឹក ហើយបានជ្រាបចូលទៅក្នុងស្រទាប់ទឹកក្រោមដីដែលជាមូលហេតុនាំឲ្យមានការបំពុលកើតឡើង។ កសិករប្រាស់សម្ភារៈធុនធ្ងន់ដើម្បីតម្រូវទៅនឹងផ្ទៃដីដ៏ធំធេង ដែលធ្វើឱ្យខូចដី និងបង្កនូវលក្ខណៈងាយស្រួលដល់ចម្រោះដី។ ពេលខ្លះកសិករអនុវត្តឯកវប្បកម្មនៃការដាំដុះ ដែលធ្វើឱ្យដីធាប់អស់ជីជាតិ និងជួយសម្រួលដល់សំណឹកដីផងដែរ។ ការធ្វើកសិកម្ម ដោយការបញ្ចូលទឹកជាប្រចាំ ធ្វើឱ្យដីខូចគុណភាព ដោយសារតែវត្តមាននៃសារធាតុអំបិលបានកកើតឡើងនៅលើដីស្រទាប់លើ។

ដូចនេះក្នុងការធ្វើកសិកម្ម កសិករត្រូវតែរៀបចំធម្មជាតិឱ្យមានតុល្យភាព។ កសិករត្រូវតែមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីផលវិបាកដ៏យូរអង្វែងរបស់ដំណាំ។ រីឯការចិញ្ចឹមសត្វវិញ កសិករត្រូវគិតពីចំណងទំនាក់ទំនងដ៏សម្បូរបែប និងរឹងមាំរបស់ស្ថេរភាពបរិស្ថានធម្មជាតិ យកចិត្តទុកដាក់ទៅលើធនធានធម្មជាតិដែលមិនចេះរីងស្ងួត និងសមត្ថភាព នៃដំណើរកើតឡើងវិញរបស់ធម្មជាតិ។

## សំណួរត្រិះរិះ

1. ចូរពិពណ៌នាអំពីលំហកសិកម្មនៅលើពិភពលោក។
2. តើគេប្រើមធ្យោបាយអ្វីខ្លះ ដើម្បីពង្រីកផ្ទៃដីកសិកម្ម? ចូរពន្យល់។
3. តើមនុស្សបានស្ថាបនាទេសភាពកសិកម្មយ៉ាងដូចម្តេចខ្លះ?
4. តើទេសភាពកសិកម្មនៅទ្វីបអឺរ៉ុបមានប៉ុន្មានប្រភេទ? អ្វីខ្លះ?
5. ចូរបង្ហាញអំពីភាពខុសគ្នារវាងទេសភាពចម្ការបិទ ឬស្រែចំណារ និងទេសភាពចម្ការបើក ឬស្រែវាល។
6. ដូចម្តេចដែលហៅថា បដិវត្តបដិវត្តន៍បៃតង? តើការធ្វើបដិវត្តន៍បៃតងនាំមកនូវផលវិជ្ជមាន និងផលអវិជ្ជមានអ្វីខ្លះ?
7. តើការធ្វើកសិកម្មកបង្កឱ្យមានផលប៉ះពាល់អ្វីខ្លះដល់បរិស្ថាន?

# មេរៀនទី៣៖ កសិកម្មនៅតំបន់ត្រូពិក

## ១. អាកាសធាតុអនុគ្រោះ ប៉ុន្តែដីដាំដុះឆាប់អស់ជីជាតិ

ត្រូពិក គឺជាតំបន់មួយ ដែលអាកាសធាតុមានលក្ខណៈអនុគ្រោះបំផុត ដល់សកម្មភាពកសិកម្ម ដោយសារតែតំបន់នេះសម្បូរដោយកម្តៅ និងសំណើមគ្រប់គ្រាន់ដែលបង្កលក្ខណៈងាយស្រួលដល់ការដុះ និងលូតលាស់នៃពពួកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ។ បន្សោះដី គឺជាមូលហេតុមួយដែលបណ្តាលឱ្យដីទាំងនោះខូចគុណភាព លែងប្រើការកើតជារៀងរហូត (សំណឹកដី ដីបាយក្រៀម ខ្សោះជីជាតិ)។ ក៏ប៉ុន្តែនៅក្នុងតំបន់ត្រូពិកដីនៅតាមជ្រលងភ្នំ ដីល្បាប់តាមដងទន្លេ ដីកំអែលភ្នំភ្លើង និងដីថ្មកំបោរមានលទ្ធភាពគឺអាចអភិវឌ្ឍដំណាំអតិផលបាន។ ថ្វីត្បិតបើដីនៅតំបន់ត្រូពិក ឆាប់ទទួលរងនូវការខូចខាតក្តី ប៉ុន្តែមានបណ្តាប្រទេសមួយចំនួននៅតំបន់ត្រូពិកនេះ មានកម្រិតជីវភាពរស់នៅខ្ពស់ និងរស់នៅយ៉ាងសម្បូរសប្បាយ។ គេដាំដុះនៅលើដី ដែលមានលក្ខណៈអំណោយផលបំផុត។ ដូចជាករណីដែលគេជួបប្រទះនៅរដ្ឋហ្វ្លរីដា នៃសហរដ្ឋអាមេរិក (តំបន់ក្បែរត្រូពិក) នៅប្រទេសអូស្ត្រាលី។ នៅទីនោះ ដំណាំអតិផលមានទិន្នផលខ្ពស់ ព្រោះតំបន់ទាំងនោះ គឺស្ថិតនៅក្នុងប្រទេស ដែលមានសេដ្ឋកិច្ចរីកចំរើនខ្លាំង (ចំការក្រូចធំៗនៅរដ្ឋហ្វ្លរីដា ចម្ការអំពៅធំៗនៅអូស្ត្រាលី)។

ក្នុងតំបន់ត្រូពិក គេសង្កេតឃើញមានកសិកម្ម ២ បែបខុសៗគ្នាគឺ កសិកម្មប្រពៃណីបែបចិញ្ចឹមពោះ និងកសិកម្មចម្ការធំៗ។

## ២. កសិកម្មប្រពៃណីបែបចិញ្ចឹមពោះ

កសិកម្មបែបប្រពៃណីសំរាប់ចិញ្ចឹមពោះ គឺជាប្រភេទកសិកម្ម ដែលមានលក្ខណៈតាមបែបពហុវប្បកម្មយថាផលដូចជា នៅទ្វីបអាហ្វ្រិក និងតាមបែបឯកវប្បកម្មយ៉ាងខ្លាំងក្លា ហើយបានផ្តល់ផលតិចដូចជា នៅទ្វីបអាស៊ី (ធ្វើពលកម្មច្រើន ប៉ុន្តែទទួលផលតិច ដោយសារមូលហេតុកង្វះខាតគ្រឿងម៉ាស៊ីន ជីគីមី និងថ្នាំសម្លាប់សត្វល្អិត) នៅក្នុងផ្នែកដំណាំស្រូវ។

- នៅទ្វីបអាព្រិច ៖ គេដាំដំណាំមីល សកគោ ដីគ្រប់មុខ ឈើហូបផ្លែ ចិញ្ចឹមគោ ចៀម និងបក្សី ស្រុក។ ហើយជួនកាលសកម្មភាពកសិកម្ម ច្រើនតែនៅដាច់ពីការចិញ្ចឹមសត្វ ដែលបណ្តាលអោយកើតមានទំនាស់ជាញឹកញាប់រវាងអ្នកដាំដុះ និងអ្នកចិញ្ចឹមសត្វ។ ឧទាហរណ៍ដូចជា នៅសាហែលដែលជាតំបន់ជាយវាលលំហសាហារ៉ា ដែលនៅទីនោះភាពរាំងស្ងួតកាន់តែធ្វើឱ្យបញ្ហានេះធ្ងន់ធ្ងរថែមទៀត។
- នៅអាមេរិក ៖ គេដាំដំណាំពោត សណ្តែកបាយ សណ្តែកសៀង ឈើហូបផ្លែ និងការចិញ្ចឹមបក្សីស្រុក ហើយភាគច្រើនគេដាំនៅលើផ្ទៃដីតូចៗ ដូចជានៅអាមេរិកឡាទីនជាដើម។
- នៅអាស៊ី ៖ គេដាំដំណាំស្រូវ និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ (ជ្រូក មាន់ ទា គោ ក្របី)។ ឧទាហរណ៍ដូចជា ៖
  - នៅប្រទេសចិនភាគខាងត្បូង

- នៅប្រទេសកម្ពុជាយើង ៖ ការដាំដំណាំស្រូវដោយខ្វះការប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត គ្រឿងម៉ាស៊ីន ហើយពឹងផ្អែកតែទៅលើទឹកភ្លៀង។ នៅតាមដងទន្លេ គេដាំឈើហូបផ្លែ បន្លែ...។ ការចិញ្ចឹមសត្វមានលក្ខណៈជាគ្រួសារដូចជា ការចិញ្ចឹមជ្រូក មាន់ ទា គោ ក្របី ជាដើម។

នៅតំបន់អាកាសធាតុត្រូពិកស្ងួត ឬវាលលំហចាប់ពីតំបន់សាហារ៉ា រហូតដល់អាស៊ីកណ្ដាលគេនិយមចិញ្ចឹមសត្វទៅតាមបែបពនេចរយថាផល ដែលផ្សារភ្ជាប់ទៅនឹងបណ្ដូរផ្សេងៗដូចជា អំបិល ផ្លែល្មើ សំភារៈសិប្បកម្ម និងកាលពីសម័យដើម ក៏ផ្សារភ្ជាប់នៅនឹងការធ្វើជំនួញទាសករផងដែរ។ កសិកម្មព្រពៃណីត្រូវបានគេមើលស្រាល ដោយពួកនិគមកម្ម។ មិនត្រឹមតែមិនបានទទួល នូវការរីកចម្រើនផ្នែកបច្ចេកទេសប៉ុណ្ណោះទេ តែកសិកម្មប្រពៃណីនេះ ថែមទាំងត្រូវបានទទួលរងនូវសំពាធពីកសិកម្មទំនើប ដែលបានមកតាំងទីនៅទីជិតៗ នោះធ្វើឱ្យកសិកម្មព្រពៃណីបាត់បង់ នូវចំនួនកំលាំងពលកម្ម និងមានបន្ទុះប្រជាសាស្ត្រខ្ពស់ (ពួកនិគមជនអភិវឌ្ឍតែលើផ្នែកសុខភាព ដើម្បីបានកំលាំងពលកម្ម គេពុំបានអភិវឌ្ឍខាងផ្នែកដំណាំស្បៀងសោះឡើយ។

*រូបភាពទី ៤ ៖ កសិកម្មនៅតំបន់ត្រូពិក*



*ការប្រៀបធៀបកសិកម្មតំបន់ត្រូពិក (ផ្នែកទំនើប និងផ្នែកប្រពៃណី)*

| *ប្រៀបធៀប* | ផ្នែកទំនើប "ចំការធំៗ" | ផ្នែកប្រពៃណី |
|---|---|---|
| *ទីតាំង* | ជិតឆ្នេរ កំពង់ផែ ដីមានជីជាតិល្អ អាជីវកម្មធំៗ | ឆ្ងាយពីឆ្នេរ ពីផ្លូវថ្នល់ អាជីវកម្មធុនតូច |
| *ការរៀបចំ* | ទំរង់ជាម្ចាស់កម្មសិទ្ធិឯកជន ជាក្រុមហ៊ុន ជាកម្មសិទ្ធិរបស់រដ្ឋ ប្រើប្រាស់កម្មករច្រើន | កសិករតូចតាច ឬជាក្រុមរបស់ភូមិ |
| *ផលិតកម្ម* | ឯកវប្បកម្ម ដែលមានតំលៃពាណិជ្ជកម្មខ្ពស់ សំរាប់នាំចេញ | ពហុវប្បកម្ម សំរាប់ហូបចុក ក្នុងគ្រួសារ |
| *ទំនើបកម្ម* | គ្រឿងយន្ត ជី ថ្នាំសំលាប់សត្វល្អិត | ឧបករណ៍បែបបុរាណ |
| *ទិន្នផល* | ខ្ពស់ រូបីយប័ណ្ណ | ទាប លើ្បសប្រជាជន គ្រោះទុរ្ភិក្ស |

*ប្រភព ៖ សៀវភៅឯកសារស្រាវជ្រាវរបស់នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ*

កសិកម្មប្រពៃណីខ្លះ ត្រូវបានប្រែប្រួលដោយសារបដិវត្តបៃតងដូចជានៅប្រទេសឥណ្ឌា និងចិន ចាប់ពីឆ្នាំ ១៩៦០ មក ដែលមានការផ្សព្វផ្សាយអំពីពូជដំណាំធញ្ញជាតិថ្មីៗ ដែលផ្តល់នូវទិន្នផលខ្ពស់ ៖ ស្រូវសាលី និងស្រូវនៅប្រទេសឥណ្ឌា ផ្ទៃដីដាំដុះកើនដល់ទៅ ៦៥% ពូជធញ្ញជាតិត្រូវបានកែច្នៃ ក៏ប៉ុន្តែកសិកម្មប្រភេទនេះ ត្រូវការទឹកច្រើន ងាយស្រួលទទួលរងនូវជំងឺឆ្លងផ្សេងៗ ដែលទាមទារឱ្យមានការចំណាយប្រាក់ជាច្រើន និងមានជំនួយពីរដ្ឋផង។ តំបន់ខ្លះ ងាយក្នុងការធ្វើបំនាចទឹក ដោយសារតែមានលក្ខណៈអនុគ្រោះច្រើន ក៏ប៉ុន្តែគេសង្កេតឃើញមានប្រជាជនឥណ្ឌាជាង ២០% នៅតែហូបមិនទាន់គ្រប់គ្រាន់នៅឡើយ។

**កសិកម្មព្រៃដុត ៖** ក្នុងករណីនេះ កសិករដុតព្រៃយកដីដាំដំណាំ។ ប៉ុន្តែដោយដឹងថា ដីធាប់អស់ជីជាតិ ឆ្នាំបន្ទាប់មកទៀត គេនាំគ្នាទៅរានព្រៃនៅកន្លែងថ្មីទៀត ហើយបោះបង់កន្លែងចាស់ចោលដើម្បីទុកអោយព្រៃដុះឡើងវិញ។ ច្រើនឆ្នាំក្រោយមក គេក៏មករានកន្លែងដើមជាថ្មី រួចក៏បោះបង់ចោលវាម្តង ទៀត។ ប្រព័ន្ធបែបនេះ ធានាបានលំនឹងខ្លះ លុះត្រាណាតែចំនួនប្រជាជនមានតិច។ ពេលណាចំនួនប្រជាជនកើនឡើង គេត្រូវការដាំដំណាំបន្ថែម រីឯរុក្ខជាតិមិនអាចដុះឡើងវិញបានគ្រប់គ្រាន់បានឡើយ ហើយផេះដែលជាប្រភពជីជាតិចាំបាច់ មិនអាចមានគ្រប់គ្រាន់ ដីក៏ក្លាយជាហិរ។ នេះ គឺជាបាតុភូតមួយធ្ងន់ធ្ងរកំពុងកើតមាននៅតំបន់ត្រូពិក ចាប់ពីពេលដែលប្រជាជនមានកំណើននយ៉ាងឆាប់រហ័ស ហើយបញ្ហាកាន់តែធ្ងន់ធ្ងរឡើងៗ នៅពេលដែលគេបានបន្ថែមដំណាំសម្រាប់នាំចេញទៅលើដំណាំចិញ្ចឹមពោះ ដែលលេបផ្ទៃដីដាំដុះកាន់តែរីកធំឡើងៗ។ គេឃើញមានការធ្វើកសិកម្មបែបនេះ នៅអាមេរិកឡាទីន អាហ្វ្រិក (លើកលែងចំការធំៗ) និងតំបន់មួយចំនួនទៀតនៅក្នុងទ្វីបអាស៊ី ដែលមានចំនួនប្រជាជនរស់នៅតិច។

## ៣. កសិកម្មចម្ការធំៗ

ចម្ការធំៗ ជាលំហដីដែលអនុវត្តន៍នូវឯកវប្បកម្មដំណាំប្រកបដោយប្រព័ន្ធផលិតកម្ម ហើយផ្ដល់ទិន្នផលខ្ពស់។ គេសង្កេតឃើញមានចំការធំៗ នៅក្នុងតំបន់ឆ្នេរភូមិភាគត្រូពិចសើមដូចជា នៅប្រទេសប្រេស៊ីល នៅឈូងគីណេ (អាហ្វ្រិក) នៅប្រទេសឥណ្ឌូណេស៊ី និងនៅប្រទេសអាមេរិកកណ្ដាល។

ដំណាំចម្ការពឹងពាក់ទៅលើបរទេស ព្រោះចំការទាំងនោះបង្កើតឡើង ដោយជនបរទេស ដើម្បីទីផ្សារពិភពលោក។ ឧទាហរណ៍ដូចជា នៅប្រទេសប្រេស៊ីល មានចំការអំពៅ កាហ្វេ និងចំការក្រូច។ ដំណាំទាំងនោះសុទ្ធសឹងតែជាដំណាំ សម្រាប់ពាណិជ្ជកម្ម ដែលត្រូវចំណាយដើមទុនយ៉ាងច្រើនសន្ធឹកសន្ធាប់ រាប់តាំងពីការរុករានដី ការដាំដុះ និងតំហែទាំ។ ចម្ការធំៗទាំងនោះ ស្ថិតនៅក្នុងកណ្ដាប់ដៃរបស់ក្រុមហ៊ុនពហុជាតិធំៗដូចជា៖

- ខាសថល អេន យុក (Castl and Cook) នៅហាវ៉ៃ និងប្រទេសហ្វីលីពីន។
- យូណាយធីត ហ្វ្រូត ខំផេនី (United Fruit Company) នៅអាមេរិកកណ្ដាល
- ជាក្រុមហ៊ុនរបស់រដ្ឋដូចជា នៅប្រទេសកូតឌីវ័រ (Cote d'ivoire) ឬជាម្ចាស់កម្មសិទ្ធិតូចៗ នៅកូតឌីវ័រ ៖ ចម្ការកាកាវ ចម្ការកាហ្វេ ចម្ការតែ ចម្ការចេក ដែលត្រូវបានគេធ្វើទំនើបកម្មនៅប្រទេសប្រេស៊ីល និងការអភិវឌ្ឍនៅភូមិភាគអាគ្នេយ៍របស់ពួកកសិករថ្នាក់មធ្យម បានទទួលជោគជ័យយ៉ាងធំធេង។

▪ **លក្ខណៈសម្គាល់ចម្ការធំៗ**

- ស្ថិតនៅក្បែរឆ្នេរមានផ្ទៃដីធំៗ
- ប្រើប្រាស់កម្មករ ដែលទទួលបៀវត្សទាប ដូចជានៅអាមេរិកឡាទីន
- ត្រូវបានធ្វើទំនើបកម្ម ប្រើប្រាស់ដី ជ្រើសរើសពូជ និងប្រើប្រាស់គ្រឿងយន្ត
- ច្រើនជាឯកវប្បកម្ម ដូចជាដំណាំដូងប្រេង កាកាវ កាហ្វេជាដើម...
- មានលក្ខណៈជាពាណិជ្ជកម្ម សំរាប់នាំចេញទៅកាន់ទីផ្សារអឺរ៉ុប និងអាមេរិក
- មានទំនាក់ទំនងជាមួយបរទេសដូចជាតម្លៃ(ហាងឆេង) ទីផ្សារពិភពលោក និងក្រុមហ៊ុនពហុជាតិ

▪ **អត្ថប្រយោជន៍ ៖** ផ្ដល់នូវរូបិយប័ណ្ណដល់រដ្ឋ(ឯករាជ) និងកំណើនកម្រិតជីវភាពរស់នៅរបស់ប្រជាជនមួយចំនួន។

▪ **គុណវិបត្តិ**

- កេងប្រវ័ញ្ចកម្លាំងពលកម្ម (បៀវត្សរ៍ទាប)
- ផ្នែកប្រពៃណីត្រូវបាត់បង់
- បង្កើតបាននូវបុព្វសិទ្ធិដល់ជនមួយភាគតូច (ពួកនិគមជនបរទេស)
- ការប្រើប្រាស់គ្រឿងយន្តច្រើន ធ្វើឱ្យកម្មករបាត់បង់អាជីព
- បាត់បង់ព្រៃឈើ និងសត្វព្រៃ
- ប្រែប្រួលមជ្ឈដ្ឋានធម្មជាតិ
- បាត់បង់ជីវចម្រុះ និងលំនឹងអេកូឡូស៊ី...។

## សំណួរត្រិះរិះ

1. តើលក្ខខណ្ឌធម្មជាតិតំបន់ត្រូពិកមានលក្ខណៈអនុគ្រោះយ៉ាងដូចម្ដេចខ្លះដល់កសិកម្ម?
2. តើលក្ខខណ្ឌអាកាសធាតុតំបន់ត្រូពិកបង្កលក្ខណៈមិនអនុគ្រោះយ៉ាងដូចម្ដេចខ្លះដល់កសិកម្ម?
3. តើកសិកម្មតំបន់ត្រូពិកមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរពន្យល់។
4. តើកសិកម្មបែបចិញ្ចឹមពោះនៅតំបន់ត្រូពិកមាននៅក្នុងទ្វីបណាខ្លះ? ចូរបង្ហាញ។
5. តើកសិកម្មតំបន់ត្រូពិកនៅទ្វីបណាខ្លះ ដែលមានលក្ខណៈជឿនលឿន? ហេតុអ្វី? ចូរពន្យល់។
6. តើកសិកម្មចម្ការធំៗនៅតំបន់ត្រូពិកមានលក្ខណៈបែបណាខ្លះ? ចូរពន្យល់។
7. តើកសិកម្មចម្ការធំនៅតំបន់ត្រូពិកមានលក្ខណៈសម្គាល់ដូចម្ដេចខ្លះ?
8. ចូរពិពណ៌នាអំពីគុណសម្បត្តិ និងគុណវិបត្តិនៃកសិកម្មចម្ការធំៗនៅតំបន់ត្រូពិក។

# មេរៀនទី៤៖ កសិកម្មនៅបណ្តាប្រទេសឧស្សាហកម្មលូតលាស់

## ១. កសិកម្មតាមបែបមូលធន

### ១.១. ពីកសិកម្មទៅកសិ-ពាណិជ្ជកម្ម

កសិ-ពាណិជ្ជកម្មមូលធននិយម គឺជាពហុវប្បកម្មបែបអតិផលមួយប្រកបដោយទិន្នផលខ្ពស់។ បម្រើបម្រាស់គ្រឿងយន្តច្រើន ដែលប្រកបដោយលក្ខណៈពាណិជ្ជកម្ម និងត្រូវបានធ្វើសមាហរណកម្មនៅផ្នែកខាងលើ និងផ្នែកខាងក្រោម នៃឧស្សាហកម្មកសិ-ស្បៀងអាហារ។ ម្ចាស់សហគ្រាសកសិកម្ម ច្រើនតែធ្វើការទៅតាមកិច្ចសន្យា និងផ្នែកកែសម្រួលផលិតកម្មរបស់ខ្លួន ទៅតាមតម្លៃទីផ្សារពិភពលោក និងទៅតាមនយោបាយកសិកម្ម ដែលបម្រើឱ្យសាខាកសិស្បៀងអាហារ។

### ១.២. លក្ខណៈសម្គាល់ នៃកសិកម្មមូលធន

មានលក្ខណៈវិនិច្ឆ័យជាច្រើន សម្រាប់សម្គាល់កសិកម្មមូលធន ដែលរួមមាន ៖

- ទិន្នផលខ្ពស់ ៖ ស្រូវសាលី ៩ តោន ក្នុងមួយហិកតា
- ផលិតភាពខ្ពស់ ៖ កសិករម្នាក់ៗធ្វើស្រែ ១៥០ ហិចតា (ប្រើគ្រឿងម៉ាស៊ីន )។
  - ៥% នៃផ្ទៃដីដាំដុះ អាចចិញ្ចឹមប្រជាជនអាមេរិកបានគ្រប់គ្រាន់
  - កសិករអាមេរិកម្នាក់អាចចិញ្ចឹមមនុស្សបាន 80 នាក់ រីឯកសិករនៅអាព្រិចម្នាក់ស្ទើរតែមិនអាចចិញ្ចឹម គ្រួសារមួយបានផង។
- កសិកម្មជំពាក់បំណុលគេច្រើន ៖ (ខ្ចីពីធានាគារ) ដើម្បីយកមកទិញគ្រឿងម៉ាស៊ីន ជី គ្រាប់ពូជ ថ្នាំ សម្លាប់សត្វល្អិត.....។
- ទទួលជំនួយឧបត្ថម្ភពីរដ្ឋយ៉ាងច្រើន ៖ ដូចជានៅសហរដ្ឋអាមេរិក ជំនួយឧបត្ថម្ភឡើងដល់ ៣៥% នៃប្រាក់ចំណូលឡើងដល់ ៣៥% នៃប្រាក់ចំណូល។
- ពំនឹងពំនាក់លើទីផ្សារបរទេស ៖ នៅសហរដ្ឋអាមេរិក ១/៣ នៃផលិតកម្មត្រូវបានគេនាំចេញទៅបរទេស ដោយមានតម្លៃទាបបំផុត (Dumping) ដើម្បីដណ្តើមកាន់កាប់ទីផ្សារ។ ការប្រណាំងប្រជែងនេះ ជះឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើប្រជាកសិករនៅក្នុងប្រទេសក្រីក្រ។ ឧទាហរណ៍ដូចជា ប្រភេទស្រូវសាលីរបស់សហរដ្ឋអាមេរិកនាំចូលទៅកាន់អាហ្វ្រិក គឺមានតម្លៃទាបជាងស្រូវមីលដែលកសិករផលិតក្នុងស្រុក។
- ប្រមូលផ្តុំនៅតែក្នុងតំបន់ដីមានជីជាតិល្អ។
- ធ្វើឯកទេសកម្មលើផលិតផលមានតម្លៃខ្ពស់ ហើយភាគច្រើនគេអនុវត្តតាមបែបឯកវប្បកម្ម។ ឧទាហរណ៍ ៖
- ដំណាំផ្កានៅប្រទេសហូឡង់
- ចម្ការទំពាំងបាយជូ
- ដំណាំបន្លែ។

## ១.៣. គុណសម្បត្តិ នៃកសិកម្មមូលធន

កសិកម្មមូលធននាំមកនូវគុណសម្បត្តិ និងគុណវិបត្តដូចជា ៖

### ក. គុណសម្បត្តិ

- កំណើនផលិតកម្មខ្ពស់ រំលែងមានកង្វះខាតស្បៀង
- បញ្ឈប់ភាពខ្វះខាតស្បៀងអាហារ
- មានការរីកចម្រើនយ៉ាងខ្លាំងនៅក្នុងបណ្តាប្រទេសអ្នកមាន
- មានសមាហរណកម្ម ដ៏សំខាន់ដល់សេដ្ឋកិច្ចពិភពលោក
- មានកំណើនសេដ្ឋកិច្ចជាតិក្នុងបណ្តាប្រទេសអ្នកមាន
- មានកំណើនផលិតផលនាំចេញ
- ជួយរក្សាលំនឹងជញ្ជាំងពាណិជ្ជកម្មជាតិរបស់ខ្លួន...។

### ខ. គុណវិបត្តិ

- វិបត្តិផលិតកម្ម ៖ តែងតែមានវិបត្តផលិតកម្មលើសជានិច្ច ហើយត្រូវទាមទារអន្តរាគមន៍ពីរដ្ឋ ដូចជា ការបំផ្លាញផលិតផលដំណាំចោល ឬទុកដីឱ្យនៅទំនេរដូចជា នៅអឺរ៉ុប និងនៅសហរដ្ឋអាមេរិកជាដើម។
- បញ្ហាកង្វក់ ៖ កង្វក់ខ្លាំងក្លា ដោយសារតែការប្រើប្រាស់ជីគីមី ថ្នាំសម្លាប់ជាដើមដែលសុទ្ធតែបណ្តាលឱ្យមានកង្វក់ទឹកក្រោមដីដូចជា នៅតំបន់ប្រឺតាញប្រទេសបារាំង នាំឱ្យមានកំណើនជាតិអំបិល ស្លែកាន់តែច្រើន ដែលអាចបំផ្លាញជីវិតទាំងអស់នៅតាមតំបន់ឆ្នេរ។
- សំនឹកដី ៖ ការធ្វើការដាំដំណាំខ្លាំងពេក នាំឱ្យអន្តរាយដល់រុក្ខជាតិ ដែលការពារដី
- បញ្ហាលំបាក ៖ កសិករតូចតាច នៅបណ្តាប្រទេសក្រីក្រ និងកសិករមធ្យម នៃបណ្តាប្រទេស អ្នកមានក៏បានជួបការលំបាកដូចគ្នា។ ឧទាហរណ៍ ៖ ការខូចខាតរបស់កសិករបារាំងបាននាំមកនូវការប្រយុទ្ធដ៏ខ្លាំងក្លា ហើយជួនកាលប្រកបដោយហឹង្សាទៀតផង។
- បញ្ហាទឹក ៖ បានចោទយ៉ាងធ្ងន់ធ្ងរ។ សកម្មភាពកសិកកម្មអបែបតិផល គឺពឹងផ្អែកកាន់តែច្រើនទៅលើបំនាចទឹក សម្រាប់ដំណាំបន្លែ ផ្កា ពោត ល្ង សណ្តែកនៅសហរដ្ឋអាមេរិក នៅប្រទេសអេស្ប៉ាញ និងតំបន់មជ្ឈឹមបូព៌ា។ កសិកម្មទំនើបប្រើប្រាស់ទឹកអស់ប្រមាណ ៧០% នៃទឹកដែលប្រើប្រាស់ក្នុងពិភពលោក (៩៣% នៅប្រទេសអេស្ប៉ាញ)។ នៅមជ្ឈឹមបូព៌ាទឹកទន្លេស្ងួរដង់ ជាប្រភពជម្លោះរវាងប្រទេសអ៊ីស្រអែល និងបណ្តាប្រទេសអារ៉ាប់មួយចំនួន សម្រាប់ដំណាំបំណាចទឹកដូចជា ក្រូច និងបន្លែ។
- បញ្ហាកាប់បំផ្លាញព្រៃឈើ ៖ ប្រទេសប្រេស៊ីលជាប្រទេសទីមួយដែលមានការកាប់បំផ្លាញព្រៃឈើយ៉ាងខ្លាំងក្លា។ ប្រទេសនេះ គឺមានព្រៃឈើរហូតដល់ ៣០% នៃភោគទ្រព្យព្រៃឈើនៅក្នុងពិភពលោក។ ប្រទេសឥណ្ឌូនេស៊ីមាន ៩% ប្រទេសហ្សាអៀរមាន ៩%។ ព្រៃឈើជាប្រភពធនធានខាងអុសដុត ម្សៅក្រដាស ឈើសំណង់ និងក៏ជាបេតិកណ្ឌរបស់មនុស្សជាតិផងដែរ។ ក្រៅពីនេះ ព្រៃឈើមានតួនាទីខាងសម្រួលដល់អាកាសធាតុ ទាក់ទាញទឹកភ្លៀង រក្សាបម្រុងទុក

អុកស៊ីសែន និងបញ្ចេញនូវឧស្ម័នការបូនិជ រក្សាបម្រុងទុកផ្នែកជីវសាស្ត្រដូចជា សម្រាប់ផលិតឱសថ។ ភាពចាំបាច់នៃការការពារព្រៃឈើនៅក្នុងពិភពលោក គឺជាប្រធានបទនៃសន្និសីទនៅរីយ៉ូដឺសែនណេរ៉ូ នាឆ្នាំ១៩៩២ ដែលនៅពេលនោះ ផលប្រយោជន៍ នៃប្រទេសលោកខាងជើង និងលោកខាងត្បូងបានត្រូវប្រឈមមុខនឹងគ្នា គឺប្រទេសលោកខាងជើងទាមទារឱ្យបញ្ឈប់ការកាប់ព្រៃឈើ ដើម្បីការពារបរិយាកាសឱ្យបានស្អាតល្អ រីឯបណ្តាប្រទេសលោកខាងត្បូងវិញ គឺនៅតែជម្នះធ្វើអាជីវកម្ម ទាញយកផលប្រយោជន៍ពីព្រៃឈើ។ ទាក់ទងនឹងការកាប់បំផ្លាញព្រៃឈើនេះ ទើបមានសន្និសីទនៅទីក្រុង តូក្យូ នាឆ្នាំ២០០០ ស្តីអំពីបញ្ហាបរិស្ថាន។

- បញ្ហាគុណភាព នៃផលិតផលម្ហូបអាហារ ៖ ផលិតផលកសិកម្មយ៉ាងច្រើន បានមកពីការប្រើប្រាស់ជីយ៉ាងច្រើនសន្ធឹកសន្ធាប់ ការប្រើប្រាស់ថ្នាំព្យាបាលជំងឺដំណាំ (Pesticide) និងជាពិសេសការប្រើប្រាស់ម្សៅចំណីអាហារសត្វ (យោងប្រវត្តិគោឆ្កួត ១៩៩០-២០០០ នៅទ្វីបអឺរ៉ុប) ។ សព្វថ្ងៃនេះ ការចិញ្ចឹមមាន់ ទា គោ ជ្រូក ចៀម ពពែ ដោយចាក់បញ្ចូលជាតិអ័រម៉ូនត្រូវបានគេហាមឃាត់ មិនឱ្យមានការអនុវត្ត។ ការចិញ្ចឹមសត្វដោយប្រើជាតិអង់ទីប៊ីយ៉ូទិចច្រើន ក៏បានធ្វើឱ្យមនុស្សដែលបានបរិភោគនូវសាច់សត្វទាំងនោះ មានកម្រិតជាតិរេស៊ីស្តង់ (Resistant) នឹងត្រូវថ្នាំព្យាបាល។ គ្រោះ ថ្នាក់ទាំងអស់ខាងលើនេះ បានត្រូវគេឱ្យឈ្មោះថា "ម៉ាល់ប៊ូហ្វ" (Malbouffe) គឺជាការបរិភោគនូវចំណីអាហារដែលគ្មានគុណភាព និងមានតម្លៃថោក។

## ១.៤. កសិកម្មប្រពៃណីក្នុងបណ្តាប្រទេសលូតលាស់

ក្នុងបណ្តាប្រទេសលូតលាស់ ជាពិសេសនៅទ្វីបអឺរ៉ុប កសិកម្មបែបគ្រួសារបានត្រូវគំរាមគំហែង ក៏ប៉ុន្តែកសិកម្មប្រភេទនេះ បានខិតខំទល់ទល់ដើម្បីរស់រានតទៅទៀត រហូតមកដល់សព្វថ្ងៃនេះ។

- កសិកម្មបែបនេះ មានលក្ខណៈសម្គាល់ដូចជា ៖
  - ស្ថិតនៅតំបន់ភ្នំ ឆ្ងាយពីទីក្រុង
  - ដីធ្វើកសិកម្មច្រើនតែផ្តល់ផលតិច ហើយច្រើនតែជាពហុវប្បកម្ម
  - កសិកម្មធ្វើសកម្មភាពច្រើនបែបច្រើនយ៉ាង
  - កសិករវ័យចំណាស់ មិនសូវចាប់អារម្មណ៍ពីការធ្វើទំនើបកម្មទេ
- ទង្វើដើម្បីឱ្យកាន់តែប្រសើរឡើង ៖
  - ពង្រីកផ្លូវគមនាគមន៍
  - ជំណុះប្រជាជននៅតំបន់ជនបទដោយប្រជាជនក្រុង ៖ ការរៀបចំភូមិឋានឱ្យមានសកម្មភាពឡើងវិញ និងការរៀបចំជួសជុលផ្ទះចាស់ៗឡើងវិញ។
  - ជំនួយឧបត្ថម្ភពីរដ្ឋដូចជានៅសហរដ្ឋអាមេរិក និងនៅទ្វីបអឺរ៉ុប
  - ជំនួយសំរាប់ធ្វើទំនើបកម្ម ៖ បណ្តុះបណ្តាលអ្នកបច្ចេកទេស និងការធ្វើកម្មសិក្សា
  - ការអភិវឌ្ឍ "ទេសចរណ៍បៃតង" ដោយបង្កើតនូវផ្ទះសំណាក់នៅតាមតំបន់ជនបទ ដែលធ្វើឱ្យកសិករបានទទួលកម្រៃ។
  - កែច្នៃផលិតផលកសិកម្ម ៖ អាហារកំប៉ុងជាដើម...

- ផលិតកម្មប្រកបដោយគុណភាព ៖ ប្រូម៉ា សាច់ ប៉ាតេធ្វើអំពីថ្លើមមាន់ ទា ក្ងាន...។

## ២. កសិកម្មនៅបណ្តាប្រទេសសង្គមនិយម

កសិកម្មនៅបណ្ដាប្រទេសសង្គមនិយម ឬបណ្ដាប្រទេសសេដ្ឋកិច្ចផែនការ គឺជាប្រភេទកសិកម្មដែលទទួលបរាជ័យជាទូទៅ នៅសហភាពសូវៀត និងនៅបណ្ដាប្រទេសទាំងឡាយនៅអឺរ៉ុបខាងកើត។

- លក្ខណៈសម្គាល់ ៖ កសិកម្មប្រភេទនេះមានលក្ខណៈសម្គាល់ដូចជា ៖
  - សមូហកម្មដីធ្លី ៖ កម្មសិទ្ធិរបស់រដ្ឋ ឬរបស់សហករណ៍ កម្មសិទ្ធិឯកជនមានតិចតួច។
  - ផែនការកម្មធ្ងន់ធ្ងរ និងគ្មានភាពពិតប្រាកដ។
  - កម្លាំងជំរុញកម្មករមានកម្រិតខ្សោយ ៖ ប្រាក់បៀវត្សរ៍ទាប ប្រងើយកន្តើយនឹងការងារ កម្មករមានចំនួនច្រើនពេក។
  - ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ ទាំងផ្នែកខាងលើ និងផ្នែកខាងក្រោម។ ការគ្រប់គ្រងថែទាំគ្រឿងម៉ាស៊ីនមិនបានល្អ និងដំណឹកជញ្ជូនមិនបានត្រឹមត្រូវ បង្កឱ្យមានការខាតបង់នូវផលដំណាំរហូតដល់ទៅ ៤០%។
- គុណវិបត្តិ
  - គោលបំណង នៃការបំពេញតំរូវការឱ្យគ្រប់គ្រាន់ ដោយខ្លួនឯង គឺពុំបានសម្រេចឡើយ។ នៅបណ្ដាប្រទេសកុំមុយនីស្តភាគច្រើនបានក្លាយជាប្រទេសអ្នកនាំចូលដូចជា សហភាពសូវៀត ដែលបាននាំចូលនូវស្រូវសាលីពីសហរដ្ឋអាមេរិកតាំងពីឆ្នាំ ១៩៧៧ មកម្លេះ។
  - មានការប៉ះពាល់យ៉ាងខ្លាំងទៅលើបរិស្ថាន។ កង្វល់របស់គេ ការផលិត គឺជាអាទិភាព ព្រោះគេគិតតែពីផលិត ដោយមិនចាប់អារម្មណ៍ពីបញ្ហាបរិស្ថានឡើយដូចជា សមុទ្រអូរ៉ាល់ត្រូវរីងស្ងួតដោយសារតែដំណាំកប្បាស បំណាចទឹកក្នុងទ្រង់ទ្រាយធំ នៅប្រទេសកាសាក់ស្ថាន។ ទាំងនេះ គឺជាបរាជ័យខាងកសិកម្ម។

ចាប់តាំងពីរបបកុំមុយនីស្តបានរលំរលាយទៅ មានការជួបប្រទះនូវវិបត្តិយ៉ាងស្រួចស្រាវ ដោយមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សដូចជា នៅអ៊ុយក្រែន ផលិតផលធញ្ញជាតិបានធ្លាក់ចុះ ៤០% ចាប់ពីឆ្នាំ ១៩៩០ ដល់ ១៩៩៥។ ការរំសាយសមូហកម្មបានធ្វើឱ្យប៉ះពាល់ដល់ទំលាប់របស់ពួកកសិករ ដែលគេចូលចិត្តធ្វើអាជីវកម្មលើដីតូចៗផ្ទាល់ខ្លួន។ សហករណ៍រដ្ឋ និងសហករណ៍ប្រជាជនមួយចំនួនបានត្រូវសហគ្រិនអឺរ៉ុបទិញយកដូចជា នៅប្រទេសប៉ូឡូញជាដើម។ ប្រទេសចិនមានលក្ខណៈពិសេសដាច់ដោយឡែក។ នៅក្នុងឆ្នាំ ១៩៥៨ នយោបាយ "មហាលោតផ្លោះ" ត្រូវទទួលបរាជ័យ។ នៅពេលនោះ ប្រជាជនបានស្លាប់ ដោយសារគ្រោះទុរ្ភិក្សអស់ ២០ លាននាក់។ នៅឆ្នាំ ១៩៨៨ ការរំសាយសមូហកម្មត្រូវទទួលជោគជ័យ។ កសិករបានក្លាយទៅ ជាម្ចាស់កម្មសិទ្ធិលើដីធ្លីរបស់ពួកគេ ដែលធ្វើឱ្យផលិតផលកើនលើសពីកម្រិតកង្វះអាហារ គឺផលិតធញ្ញជាតិបាន ៤០០ លានតោន នៅឆ្នាំ ១៩៨៨ ហើយនៅឆ្នាំ ២០០០ បានរហូតដល់ ៤៥៧ លានតោន។

**សំណួរត្រិះរិះ**

1. តើអ្វីជាកសិ-ពាណិជ្ជកម្ម? អ្វីជាកសិ-ឧស្សាហកម្ម?
2. តើអ្វីជាកសិកម្មមូលធន? តើកសិកម្មមូលធនមានលក្ខណៈសម្គាល់យ៉ាងដូចម្តេចខ្លះ?
3. ចូរបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃកសិកម្មមូលធន។
4. តើកសិកម្មប្រពៃណីនៅក្នុងបណ្តាប្រទេសលូតលាស់មានលក្ខណៈសម្គាល់ដូចម្តេចខ្លះ?
5. តើគេមានវិធានការអ្វីខ្លះ ដើម្បីអភិវឌ្ឍកសិកម្មប្រពៃណីនៅបណ្តាប្រទេសលូតលាស់ឱ្យមានភាពប្រសើរឡើង?
6. តើកសិកម្មនៅបណ្តាប្រទេសសង្គមនិយមមានលក្ខណៈសម្គាល់ដូចម្តេចខ្លះ?
7. តើកសិកម្មនៅបណ្តាប្រទេសសង្គមនិយមមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?

# ជំពូកទី៣៖ ភូមិវិទ្យាអភិវឌ្ឍ
# មេរៀនទី១៖ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម

## ១. ទស្សនៈស្ដីពីការចំរើនឡើង និងទស្សនៈស្ដីពីការអភិវឌ្ឍ

ក្នុងការអភិវឌ្ឍខឿនសេដ្ឋកិច្ចពិភពលោកជិត ៥ ទសវត្សរ៍កន្លងមកនេះ បានលេចចេញនូវការផ្លាស់ប្ដូរមួយដែលគួរឱ្យមានសេចក្ដីសង្ឃឹមនោះ គឺបណ្ដាប្រទេសកំពុងអភិវឌ្ឍ។ នៅបណ្ដាប្រទេសមួយចំនួន មានការរីកចម្រើនសេដ្ឋកិច្ចយ៉ាងល្អប្រសើរដូចជាករណី ប្រទេសកូរ៉េខាងត្បូង ទីក្រុងហុងកុង ប្រទេសសឹង្ហបុរី ប្រទេសថៃ ប្រទេសតៃវ៉ាន់ ប្រទេសម៉ាលេស៊ី ប្រទេសឥណ្ឌូណេស៊ី ប្រទេសប្រេស៊ីល ប្រទេសម៉ិចសិចជាដើម។

ការជ្រើសរើសយក ឬការដើរតាមទំរង់អភិវឌ្ឍន៍ទស្សនៈ និងយុទ្ធនាការពង្រីកខឿនសេដ្ឋកិច្ច-សង្គម គឺជាជម្រើសដែលយកចិត្តទុកដាក់បំផុតរបស់បណ្ដាប្រទេសនីមួយៗ មិនថាឡើយប្រទេសនោះ គឺជាប្រទេសអភិវឌ្ឍនោះឡើយ។ បណ្ដាប្រទេសដែលបានជ្រើសរើសយក ឬដើរតាមទម្រង់ ឬអនុវត្តន៍តាមទស្សនៈស្ដីពីការអភិវឌ្ឍ និងយុទ្ធនាការពង្រីកខឿនសេដ្ឋកិច្ច-សង្គមសមស្រប គឺជាបណ្ដាប្រទេសដែលមានខឿនសេដ្ឋកិច្ចរីកចម្រើនខ្លាំង និងមានថាមពលនៃចលនាខ្ពស់ខ្លាំងជាងគេ ក្នុងទម្រង់នៃខឿនសេដ្ឋកិច្ច មានខឿនឧស្សាហកម្ម និងសេវាកម្មខ្លាំងឬខ្លាំងបង្គួរ។ រីឯបណ្ដាប្រទេសដែលមិនទាន់ដើរតាមទស្សនៈអភិវឌ្ឍន៍សេដ្ឋកិច្ច និងមានយុទ្ធនាការសេដ្ឋកិច្ចមិនច្បាស់លាស់ គឺបណ្ដាប្រទេសទាំងនោះមានខឿនសេដ្ឋកិច្ចពុំសូវរីកចម្រើន ជាពិសេស មានខឿនឧស្សាហកម្ម និងសេវាកម្មអន់ថយ ឬមានការរីកចម្រើនតិចតួច។ បណ្ដាប្រទេស ដែលមានសេដ្ឋកិច្ចអន់ថយ ភាគច្រើន គឺបណ្ដាលមកពីបណ្ដាប្រទេសទាំងនោះ ជួបប្រទះនូវគ្រោះអត់ឃ្លាន គ្រោះអនក្ខរជន ខ្វះដើមទុន ខ្វះបច្ចេកទេស មានភាពអន់ថយជាប់គ្នារាប់សិបសតវត្សរ៍កន្លងមក ឬជាប្រទេសដែលទើបតែរំដោះខ្លួនផុតពីនឹមអាណានិគមនានា...។

កាលណាបើគេធ្វើការវិភាគទៅលើទស្សនៈស្ដីអំពីការអភិវឌ្ឍ និងថាមពល នៃចលនាសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ក្នុងសេដ្ឋកិច្ច នយោបាយ នៃបណ្ដាប្រទេសកំពុងអភិវឌ្ឍបច្ចុប្បន្ន គេឃើញមានការលេចចេញឡើងនូវទស្សនៈ ២ ដែលមានលក្ខណៈខុសគ្នា គឺទស្សនៈស្ដីពីការចម្រើនឡើង និងទស្សនៈ ស្ដីអំពីការអភិវឌ្ឍ។ ការស្រាវជ្រាវនូវទស្សនៈនីមួយៗ ពិសេសគឺទស្សនៈស្ដីពីការចម្រើនឡើង និងទស្សនៈស្ដីពីការអភិវឌ្ឍ នឹងធ្វើឱ្យយើងមើលឃើញយ៉ាងច្បាស់នូវផ្នែក ដែលខុសគ្នានៅក្នុងបណ្ដាទស្សនៈទាំងនេះ ហើយនិងជាមូលដ្ឋានចាំបាច់ ដើម្បីឱ្យអ្នកស្រាវជ្រាវអាចជ្រើសរើស និងសម្រេចទិសដៅរបស់ខ្លួនបានកាន់តែល្អប្រសើរឡើង ។

### ១.១. ទស្សនៈស្ដីពីការចម្រើនឡើង

ក្នុងពេលវិភាគអំពីការជ្រើសរើស និងការអនុវត្តនូវយុទ្ធនាការសេដ្ឋកិច្ច នៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍ អ្នកនិពន្ធជាច្រើនដូចជា Gerard Grillet, Malcolm Gillis, Dwight H Perkins, Michel Roemer, Donald R Snodgras, Harry T-Oshima... ហាក់បីដូចជាបានឯកភាពគ្នាពីទស្សនៈ នៃការរីកចម្រើនឡើង។ នេះ មានន័យថា វាគឺជាការកើនឡើងនូវផលិតផលជាតិសរុបដុល (PNB : Produit National Brut, GNP: Gross National Product) ឬផលិតផលសរុបក្នុងស្រុកដុល (PIB: Produit Brut, GDP: Gross Domestic Product) ដោយគិតតាមមនុស្សម្នាក់ៗក្នុងប្រទេសមួយ។ ដូច្នេះ បើបរិមាណផលិតផលទំនិញ និងសេវាកម្ម

ក្នុងប្រទេសមួយ ក្នុងរយៈពេលមួយឆ្នាំក្រោយមក មានការកើនឡើងជាង បើប្រៀបធៀបទៅនឹងឆ្នាំមុន គឺប្រទេសនោះត្រូវបានចាត់ទុកថា មានការចម្រើនឡើងខាងសេដ្ឋកិច្ច។

ឧទាហរណ៍ ៖ ផលិតផលដុលនៃប្រទេសហុងកុងនៅក្នុងឆ្នាំ ២០១០ មាន ៣៨ ២២០ លានដុល្លាសហរដ្ឋអាមេរិក ដល់ឆ្នាំ ២០១២ មានការកើនឡើងដល់ ៥២៣៨០ លានដុល្លាសហរដ្ឋអាមេរិក រីឯបរិមាណផលិតផលជាតិដុលគិតជាមធ្យមតាមចំនួនមនុស្សម្នាក់ៗមាន ២ ៦៩១០ និង ២ ៩២៣០ ដុល្លាអាមេរិក។ ដូចនេះ អត្រាកំនើនឡើងនៃសេដ្ឋកិច្ចពីឆ្នាំ ២០១០-២០១២ គឺមាន ៨.៩%។ ឆ្លងតាមតួលេខនេះ យើងអាចមើលឃើញថា កម្មវត្ថុនៃទ្រឹស្តីការរីកចម្រើនឡើង គឺបកស្រាយបានពីទ្រង់ទ្រាយចលនា នៃផលិតផលជាតិសរុបដុល (GNP) ឬផលិតផលសរុបក្នុងស្រុកដុល (GDP) គិតជាមធ្យមតាមមនុស្សម្នាក់ៗ។

មានប្រទេសជាច្រើន នៅលើពិភពលោកច្រើនទសវត្សរ៍កន្លងមក បានសម្រេចនូវការចម្រើនឡើងខ្ពស់ ហើយមានប្រទេសជាច្រើនទៀត ដែលមានស្រទាប់ប្រជាជនត្រូវទទួលរងនូវការថយចុះ នៃកម្រិតជីវភាព និងតម្រូវការជាមូលដ្ឋាន។ ជាការពិតណាស់ហើយ សង្គមទាំងអស់ ប្រទេសទាំងអស់ គឺមិនអាចដូចគ្នាបាននោះឡើយ មានប្រទេសខ្លះចាត់ទុកការរីកចម្រើនឡើង នៃបរិមាណចំនូលថវិកា និងផលិតផលជាងការផ្លាស់ប្តូរពីគុណភាព ទម្រង់សេដ្ឋកិច្ច-សង្គម និងគុណភាពរស់នៅនោះ គឺជាទស្សនៈចម្រើនឡើងសុទ្ធសាធ។ ឧទាហរណ៍ ៖ បណ្តាប្រទេសនៅមជ្ឈឹមបូព៌ា ដែលត្រូវបានធម្មជាតិផ្តល់ឱ្យនូវប្រភពប្រេងឥន្ធនៈដ៏សំបើប អាស្រ័យដោយប្រភពប្រេងឥន្ធនៈនាំចេញចេញ ដ៏ច្រើនសន្ធឹកសន្ធាប់របស់ប្រទេសគេនេះ បានធ្វើឱ្យបណ្តាប្រទេសទាំងនេះក្លាយទៅជាប្រទេសអ្នកមានជាបន្តបន្ទាប់។ រដ្ឋាភិបាលប្រទេសទាំងនោះ បានយកចិត្តទុកដាក់តែទៅលើចំណូលថវិកា ក៏ប៉ុន្តែគេឥតបានគិតគូរដល់ការអភិវឌ្ឍយូរអង្វែង និងផលវិបាកទៅថ្ងៃមុខរបស់ប្រទេសគេនោះទេ។

ផ្ទុយទៅវិញ មានប្រទេសខ្លះទៀតបានចាត់ទុកខឿនឯករាជ្យជនជាតិ និងសង្គមស្មើភាព ជាជាងការបង្កើតចេញនូវសំភារៈប្រើប្រាស់ដល់សង្គម។ ចំណូលថវិកាជាតិនៃបណ្តាប្រទេសទាំងនោះ គិតតាមចំនួនមនុស្សម្នាក់ៗ គឺក្រោម ១៨០០ ទៅ ២០០០ដុល្លាអាមេរិកតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះដែរ ក៏នៅមានប្រទេសមួយចំនួនទៀត បានប្រមូលកម្លាំងទុន តាមរយៈការលក់ធនធានធម្មជាតិ ដើម្បីអនុវត្តការរីកចម្រើនយ៉ាងលឿនពីបរិមាណដើមទុន បន្ទាប់មកទើបគេងាកមកធ្វើការអភិវឌ្ឍឧស្សាហនីយកម្ម និងធ្វើឧស្សាហូបនីយកម្ម និងគុណភាពសង្គមជាក្រោយ។ ឧទាហរណ៍ ៖ ករណីដូចជាប្រទេសកូរ៉េខាងត្បូង ប្រទេសសឹង្ហបុរី ក្រុងហុងកុង និងប្រទេសតៃវ៉ាន់ជាដើម....។ល។

អត្រាចម្រើនឡើង (GNP) (GDP) GNP-GDP គិតជាមធ្យមតាមមនុស្សម្នាក់ៗ គឺវាមិនឆ្លុះបញ្ចាំងពីចលនាឈានឡើងនៃសង្គម មិនអាចដឹងបានពីស្ថានភាពបែងចែកនូវចំណូលថវិកាជាតិ ទម្រង់សេដ្ឋកិច្ច-សង្គម ថាមពលឧស្សាហកម្ម និងស្ថានភាពដែលមានប្រយោជន៍ នៃស្រទាប់ប្រជាជននោះទេ។ បើនិយាយតាមបែបផ្សេងទៀត ទស្សនៈស្តីពីការរីកចម្រើនឡើងនៃសេដ្ឋកិច្ចសុទ្ធសាធ គេយកចិត្តទុកដាក់ទៅលើបរិមាណ។ បន្ទាប់មកគេ អាចដាក់ចេញបាន នូវទស្សនៈសរុបមានលក្ខណៈសុក្រិតជាងនោះ គឺទស្សនៈនៃការអភិវឌ្ឍ។

### ១.២. ទស្សនៈស្តីពីការអភិវឌ្ឍ

អ្នកសេដ្ឋកិច្ចនយោបាយដែលបានសិក្សាអំពីទស្សនៈនេះបានឱ្យនិយមន័យថា ការលូតលាស់ចម្រើន គឺជាដំណើរនៃសង្គមមួយ ដែលអាចសម្រេចបានតាមសេចក្តីត្រូវការជាមូលដ្ឋានរបស់ប្រជាជនក្នុងសង្គមនោះ។ ទស្សនៈការអភិវឌ្ឍរួមមានអត្ថន័យធំធេង ២ ចំនុចសំខាន់ៗ គឺ ៖

- ការអភិវឌ្ឍជាដំណើរមួយ
- ការអភិវឌ្ឍត្រូវបានវាយតម្លៃ ដោយប្រៀបធៀបជាមួយនឹងតម្លៃណាមួយ ឬតម្លៃនៃឆ្នាំណាមួយ ឬប្រទេសណាមួយ។

អភិវឌ្ឍសេដ្ឋកិច្ច គឺជាការធ្វើឱ្យចម្រើនឡើង (បង្កើនចំណូលជាមធ្យមក្នុងចំនួនមនុស្សម្នាក់) បូកជាមួយការផ្លាស់ប្តូរជាមូលដ្ឋាននៅក្នុងទម្រង់នៃខឿនសេដ្ឋកិច្ច ការចូលរួមនៃបណ្តាជនជាតិប្រទេសមួយ ក្នុងដំណើរការបង្កើតចេញនូវការផ្លាស់ប្តូរដូចដែលបាននិយាយខាងលើ ការប្រែប្រួលគួរឱ្យកត់សម្គាល់ពីកម្រិតនៃការប្រើប្រាស់លក្ខខណ្ឌសុខាភិបាល ការថែរទាំសុខភាព ការអប់រំ និងសុភមង្គល។

លក្ខណៈពិសេសនៃការផ្លាស់ប្តូរជាមូលដ្ឋានក្នុងទម្រង់នៃខឿនសេដ្ឋកិច្ចគឺ ៖ កំណើនដង់ស៊ីតេវិស័យឧស្សាហកម្ម កំណើននេះត្រូវបានគិតផ្នែកចំនួលទុកឱ្យផលិតកម្ម និងផ្នែកចំនួលទុកឱ្យពលករក្នុងតំបន់ឧស្សាហកម្ម។ ទន្ទឹមគ្នានេះដែរ គេឃើញមានតំហយចុះដង់ស៊ីតេកសិកម្ម ក្នុងបរិមាណផលិផលជាតិសរុប និងបន្ថយកំណើនអត្រាអ្នករស់នៅក្នុងទីក្រុង ជាងអត្រាអ្នករស់នៅតំបន់ជនបទ។ លក្ខណៈពិសេសនេះ បានលេចឡើងផ្សេងៗគ្នានៅបណ្តាប្រទេស និងបណ្តាតំបន់តាមកម្រិតចំណូលនៃមនុស្សម្នាក់ៗ។ នៅបណ្តាប្រទេស ដែលមានចំណូលថវិកាទាបជាមធ្យម ចំនួនមនុស្សនៅអាយុធ្វើការ (ប្រជាជនសកម្ម) នៅក្នុងតំបន់កសិកម្មមានចំនួន ៧៣%។ នៅបណ្តាប្រទេស ដែលមានចំណូលថវិកាមធ្យមមានប្រមាណ ៤៤%។ ផ្ទុយទៅវិញ ចំពោះបណ្តាប្រទេស ដែលមានខឿនឧស្សាហកម្មរីកចម្រើន ចំនួនមនុស្សដែលនៅធ្វើការនៅក្នុងតំបន់កសិកម្មមានតែ ៦% ប៉ុណ្ណោះ។ រចនាសម្ព័ន្ធបណ្តាវិស័យផ្សេងៗទៀត GDP នៅក្នុងចំណូថវិកាជាតិ ក៏មានភាពផ្សេងៗគ្នាដែរ។ បណ្តាប្រទេស ដែលមានខឿនសេដ្ឋកិច្ចរីកចម្រើន ផ្នែកដែលចូលរួមក្នុងតំបន់ពីរ គឺឧស្សាហកម្ម និងសេវាកម្ម (Service) ក្នុង GDP គឺសំខាន់ណាស់។ ឧទាហរណ៍ នៅក្នុងទម្រង់ GDP របស់ប្រទេសជប៉ុននៅឆ្នាំ ២០០៨ ផ្នែកឧស្សាហកម្មមាន ៤០,៧% សេវាកម្មមាន ៥៦,៤% ចំណែកឯកសិកម្មមានត្រឹមតែ ២,៩% ប៉ុណ្ណោះ។ នៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់វិញ ទម្រង់នេះប្រហែលនឹង ៤១,៨% ៥៦,៣% និង១,៩%។ ចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍ ដង់ស៊ីតេកសិកម្មក្នុងទំរង់ GDP មានតួនាទីសំខាន់ណាស់នៅក្នុងខឿនសេដ្ឋកិច្ចជាតិ។ រីឯដង់ស៊ីតេឧស្សាហកម្មវិញ និងសេវាកម្មនៅអន់ថយយ៉ាងខ្លាំង(មានបណ្តាប្រទេសមួយចំនួនមានការរីកចម្រើនល្អជាខ្លំងដូចជា ប្រទេសកូរ៉េខាងត្បូង ទីក្រុងហុងកុង កោះតៃវ៉ាន ប្រទេសម៉ិចស៊ិច និងប្រទេសប្រេស៊ីលជាដើម)។ ឧទាហរណ៍ ៖ នៅឆ្នាំ ២០០៨ វិស័យកសិកម្មរបស់ប្រទេសអាហ្គានីស្ថាន នៅក្នុងទម្រង់ GDP មាន ៥២.៣% ចំណែកឯឧស្សាហកម្មមាន ៣៣.៧% និងសេវាកម្មមានត្រឹមតែ ១៤.0% ប៉ុណ្ណោះ។

កត្តាជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច គឺប្រជាជននៃប្រទេសនោះត្រូវជាសមាជិកដ៏សំខាន់នៅក្នុងដំណើរការ នៃការផ្លាស់ប្តូរទម្រង់សេដ្ឋកិច្ចនេះ។ ការចូលរួមនៅក្នុងដំណើរអភិវឌ្ឍន៍ មានន័យថាជាការចូលរួមដោយរីករាយ នៅក្នុងផលប្រយោជន៍នៃការរីកចម្រើន ក៏ដូចជាការបង្កើតបាននូវផលនោះ។ ជនបរទេសអាច

ចូលរួមនៅក្នុងដំណើរការនេះបាន ប៉ុន្តែគេមិនអាចជាអ្នកអនុវត្តកិច្ចការនោះទាំងស្រុងបាននោះឡើយដូចជាធ្វើឱ្យបានចំណេញបន្តិច ឬក៏អាចធ្វើឱ្យក្រុមមនុស្សណាមួយនោះប្រែក្លាយទៅជាអ្នកមាន (ទោះបីមនុស្សនោះជាអ្នកម្ចាស់ស្រុកដើម ឬជនបរទេស) ក៏មិនអាចចាត់ទុកថាជាការរីកចម្រើនលូតលាស់បានឡើយ។

ឧទាហរណ៍ ៖ ចាប់ពីបណ្តាឆ្នាំ ១៩៦០ មកដល់ពេលនេះ ប្រទេសលីប៊ីសម្រេចបាននូវថវិកាគិតតាមមនុស្សម្នាក់ៗខ្ពស់បំផុត ដែលអាស្រ័យដោយការរកឃើញប្រេងឥន្ទនៈ ហើយក្រុមហ៊ុនបរទេសបានប្រមូលផ្តុំទុន ដើម្បីធ្វើអាជីវកម្ម និងនាំប្រេងចេញទៅក្រៅប្រទេស (ចំណូលថវិកាជាមធ្យមគិតតាមមនុស្សម្នាក់នាឆ្នាំ ១៩៨៧ គឺមាន ៥ ៤៦០ ដុល្លាអាមេរិក គឺខ្ពស់បំផុតនៅទ្វីបអាហ្រិក ហើយនៅក្នុងឆ្នាំ ២០០០ គឺ ៧៥៧០ ដុល្លាអាមេរិក គឺឈរនៅលំដាប់ទី២ បន្ទាប់ពីប្រទេសអាហ្វ្រិកខាងត្បូង) និងនៅឆ្នាំ ២០០៨ គឺកើនឡើងរហូតដល់ ១៣៣៦២ ដុល្លាអាមេរិក ដោយសារជនបរទេសផ្តល់ឱ្យរដ្ឋជាពន្ធដា (ប្រជាជនមិនបានចូលរួម)។ ទោះបីជារដ្ឋាភិបាល និងប្រជាជនលីប៊ីទទួលបានថវិកាដ៏ច្រើន អាស្រ័យដោយការលក់ប្រេងកាតយ៉ាងណាក្តី គេនៅតែមិនត្រូវបានចូលរួម ឬចូលរួមយ៉ាងតិចតួចបំផុត ក្នុងការបង្កើតបានចំណូលទាំងនោះ។ លទ្ធផលនៃការពង្រីកអាជីវកម្មប្រេងឥន្ទនៈដ៏ធំដូច្នេះ គឺអាស្រ័យដោយបណ្តាប្រទេសអ្នកមាន បានជួយជ្រោមជ្រែងយ៉ាងខ្លាំងដល់ប្រទេសលីប៊ី។ ការអនុវត្តន៍នៅប្រទេសនេះ មិនអាចពិពណ៌នាបានពីការរីកចម្រើនសេដ្ឋកិច្ចជាអចិន្ត្រៃយ៍នោះឡើយ។ ចំណែកឯការប្រែប្រួលដែលបានលេចឡើងនៅប្រទេសកូរ៉េខាងត្បូង ក្នុងពេលវេលាទន្ទឹមគ្នានេះដែរ គឺខុសគ្នាពីការលេចចេញឡើងនៅប្រទេសលីប៊ី។ ប្រទេសកូរ៉េខាងត្បូងត្រូវបានគេទទួលស្គាល់ថាជាប្រទេសឧស្សាហកម្មថ្មី ដែលមានសេដ្ឋកិច្ចរីកចម្រើនយ៉ាងខ្លាំងក្លាបំផុត រហូតក្លាយជាប្រទេសអភិវឌ្ឍ ក្នុងចំណោមបណ្តាប្រទេសអភិវឌ្ឍនានានៅលើពិភពលោកយើងនេះនាពេលបច្ចុប្បន្ន។ ទាំងនេះដោយសារផ្នែកនៃការបង្កើនចំនូលថវិកាគិតជាមធ្យមតាមចំនួនមនុស្សម្នាក់ៗពី ២៦០ ដុល្លាអាមេរិកនៅឆ្នាំ ១៩៧០ និងកើនដល់ ១៦២០ ដុល្លាអាមេរិកនៅឆ្នាំ ១៩៨០។ នៅឆ្នាំ ១៩៨៨ ចំនួននេះបានកើនឡើងដល់ ៣៥៣០ ដុល្លាអាមេរិក និងនៅឆ្នាំ ២០០០ ចំនួននេះបានកើនឡើងដល់ ១៧ ៣៨០ ដុល្លាអាមេរិក។ ជាងនេះទៅទៀត គឺនៅឆ្នាំ ២០០៨ ផលិតផលសរុបរបស់ប្រទេសនេះបានកើនឡើងរហូតដល់ ២២ ៩៨៥ ដុល្លាអាមេរិក។ ទម្រង់ នៃខឿនសេដ្ឋកិច្ចជាតិរបស់ប្រទេសនេះបានផ្លាស់ប្តូរយ៉ាងខ្លាំង ៖ ដង់ស៊ីតេក្នុងវិស័យឧស្សាហកម្មកើនឡើងគួរឱ្យកត់សម្គាល់ពី ២៩,២% ឡើងទៅដល់ ៤៧,១%។ ទន្ទឹមគ្នានេះដែរ ដង់ស៊ីតេក្នុងវិស័យកសិកម្មត្រូវបានថយចុះនៅក្នុង GDP ពី ២៦,០% ចុះទៅ៩% នៅឆ្នាំ ២០០០។ អត្រាប្រជាជនក្រុងនៅប្រទេសកូរ៉េខាងត្បូងបានកើនឡើងពី ៤៣,៦% ឆ្នាំ ១៩៧០ ទៅ ៦៨,៨% នៅ ឆ្នាំ ២០០៨។

កំណើនចំនូលថវិកា មិនមែនជាគោលដៅតែមួយនៃការអភិវឌ្ឍនោះឡើយ។ មនុស្សលោកមានការបែងចែកទុកដាក់ ដើម្បីឱ្យជីវិតរស់នៅរបស់គេរស់នៅប្រកបដោយសុភមង្គល ហើយដើម្បីប្រែក្លាយខ្លួនគេឱ្យទៅជាមនុស្សមានវប្បធម៌ មានសុខភាពល្អ ធានាបាននូវការអប់រំ និងប្រកបដោយកម្រិតជីវភាពខ្ពស់។ បណ្តាប្រទេសដែលមានចំណូលថវិកាទាប ឬមធ្យមកំពុងតែថយចុះជាបណ្តើរៗនូវអត្រាមរណៈ ដោយបង្កើនឡើងជាបង្គួរនូវចំនួនវេជ្ជបណ្ឌិត គិលានុប្បដ្ឋាក ប្រៀបជាមួយនឹងចំនួនប្រជាជននៅទូទាំងប្រទេស ពង្រីកនិងយកចិត្តទុកដាក់ផ្គត់ផ្គង់ដល់វិស័យអប់រំចំនេះដឹងជាមូលដ្ឋាន...។

## ២. ទំនាក់ទំនងរវាងការធ្វើអោយចំរើនឡើង និងការអភិវឌ្ឍ

ទស្សនៈ និងលក្ខណៈពិសេស នៃទស្សនៈស្តីពីការចម្រើនឡើង និងការអភិវឌ្ឍដែលបានលើកឡើងនៅផ្នែកខាងលើ បានបង្ហាញឱ្យយើងឃើញថា ៖

- បើពិនិត្យលើភាពជាក់ស្តែង មានបណ្តាប្រទេសមួយចំនួនអាចសម្រេចបាននូវការចម្រើនឡើង តែគ្មានការរីកលូតលាស់នោះឡើយ។ នោះ គឺបណ្តាលមកពីប្រទេសទាំងនោះជ្រើសរើសយក ឬដើរតាមទម្រង់ធ្វើឱ្យចម្រើនឡើងសុទ្ធសាធ ដោយគិតតែទៅលើការកើនឡើងពីបរិមាណ។
- មានករណីជាច្រើន ដែលប្រទេសមួយចំនួនមានចំនូលថវិកា ក្នុងប្រទេស GDP គិតតាមមនុស្សម្នាក់ៗមិនកើនឡើងនោះទេ ក៏ប៉ុន្តែគេអនុវត្តបាននូវការស្មើភាពសង្គមល្អជាង ហើយបន្ថយចុះនូវការចំណាយ ដើម្បីនាំមកនូវផលប្រយោជន៍ឱ្យដល់តំរូវការចំបាច់ នៃប្រជាជនប្រទេសនោះ។ នោះ គឺបណ្តាលមកពីបណ្តាប្រទេសទាំងនោះជ្រើសរើសយក ឬដើតាមទស្សនៈហៅថា "សង្គមស្មើភាព" ដែលជាធាតុពិត គឺ "មជ្ឈមនិយម" ។
- មានបណ្តាប្រទេសមួយចំនួនផ្សេងទៀត បានសម្រេចឡើងនូវការចម្រើនឡើង ដោយមានការកើនឡើងនូវប្រាក់ចំណូលប្រចាំឆ្នាំ ហើយបន្ទាប់មក គេបានងាកមកអភិវឌ្ឍវិស័យឧស្សាហកម្ម និងសេវាកម្មឱ្យមានការរីកចម្រើនជឿនលឿនដែលជាមូលដ្ឋានគ្រឹះ នៃខឿនសេដ្ឋកិច្ចជាតិរបស់គេ។ នោះ គឺបណ្តាលមកពីប្រទេសទាំងនោះ ដើរតាម ឬជ្រើសរើសយកតាមទម្រង់ទស្សនៈនៃការចម្រើនឡើងឆ្ពោះទៅរកការអភិវឌ្ឍ។
- ក៏ប៉ុន្តែតាមធម្មតា ការចម្រើនឡើង និងការអភិវឌ្ឍតែងតែដើរទន្ទឹមគ្នាជានិច្ច។ គ្មានការអភិវឌ្ឍណាមួយ ដែលមិនឆ្លងកាត់នូវការចម្រើនឡើងនោះឡើយ។ កាលណាមានកំណើនចំនូលថវិកា និងកំណើនផលិតផលតាមចំនួនមនុស្សម្នាក់ៗ គឺដើរទន្ទឹមគ្នាជាមួយនឹងកំណើន ដែលជាផលប្រយោជន៍របស់ប្រជាជន មិនអាចមានការអភិវឌ្ឍ ដោយខ្វះការរីកចម្រើនឡើងបានឡើយ។

## ៣. ប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ

ប្រទេសនានានៅលើពិភពលោក តែងតែមានការបែងចែកយ៉ាងច្បាស់លាស់ពីកម្រិតប្រាក់ចំណូល កម្រិតជីវភាពរស់នៅ ទម្រង់សេដ្ឋកិច្ច-សង្គម និងរបបនយោបាយ។ គេអាចមើលឃើញពីភាពខុសគ្នានេះ ដោយការប្រើពាក្យបច្ចេកទេសពីរ គឺបណ្តាប្រទេសអភិវឌ្ឍ និងបណ្តាប្រទេសកំពុងអភិវឌ្ឍ ដើម្បីមើលឃើញពីការផ្លាស់ប្តូរ ដែលកំពុងកើតមាននៅបណ្តាប្រទេសនានានៅទូទាំងពិភពលោក។

### ៣.១. ប្រទេសអភិវឌ្ឍ (Developed Countries)

គេតែងតែហៅបណ្តាប្រទេសទាំងនេះថា បណ្តាប្រទេសឧស្សាហកម្ម ដើម្បីស្តែងចេញនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងការរីកចម្រើន និងឧស្សាហូបនីយកម្ម។ បណ្តាប្រទេសដែលមានខឿនសេដ្ឋកិច្ចឧស្សាហកម្ម ត្រូវបានបែងចែកជាខឿនសេដ្ឋកិច្ចទីផ្សារ ដែលត្រូវមានការប្រកួតប្រជែង និងស្វែងរកគុណភាព (បណ្តាប្រទេសមូលធននិយម)។ ក្រុមប្រទេសទាំងនេះ រួមមានបណ្តាប្រទេសនៅទ្វីបអឺរ៉ុបខាងលិច អាមេរិកខាងជើង បណ្តាប្រទេសមួយចំនួន ដែលស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក និងបណ្តាប្រទេសមួយចំនួនទៀត ដែលមានខឿនសេដ្ឋកិច្ចមិនមែនទីផ្សារ (សេដ្ឋកិច្ចបិទ ឬសេដ្ឋកិច្ចផែនការ ប៉ុន្តែសព្វថ្ងៃនេះ មាន

បណ្តាប្រទេសមួយចំនួនបានធ្វើកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនពីសេដ្ឋកិច្ចផែនការ ទៅជាសេដ្ឋកិច្ចទីផ្សារសេរីស្ទើរតែទូទាំងពិភពលោកទៅហើយ) ដូចជា ប្រទេសអតីតសហភាពសូវៀត និងបណ្តាប្រទេសអតីតកុំមុយនីស្តនៅអឺរ៉ុបខាងកើត។

**ក. និយមន័យ**

**ប្រទេសអភិវឌ្ឍ** គឺជាកន្សោមនៃពាក្យដែលគេប្រើ សម្រាប់សម្គាល់ទៅលើបណ្តាប្រទេសទាំងឡាយណា ដែលអាចឆ្លើយតបបាន ឬអាចបំពេញបានទាំងស្រុងនូវតម្រូវការជាមូលដ្ឋានរបស់ប្រជាជននៅក្នុងប្រទេសរបស់ខ្លួន។ បណ្តាប្រទេសអភិវឌ្ឍរួមមាន ៖

- ទ្វីបអឺរ៉ុបខាងលិច ៖ មានប្រទេសបារាំង អាឡឺម៉ង់ អង់គ្លេស ណ័រវេសន៍ ស៊ុយអែត ស្វីស...
- ទ្វីបអាមេរិកខាងជើង ៖ មានប្រទេសកាណាដា និងសហរដ្ឋអាមេរិក
- ទ្វីបអាស៊ី ៖ មានប្រទេសជប៉ុន ប្រទេសសិង្ហបុរី និងប្រទេសកូរ៉េខាងត្បូង
- ទ្វីបអូសេអានី ៖ មានប្រទេសអូស្រ្តាលី និងប្រទេសញូសឺឡែន។

**ខ. តួនាទីប្រទេសអភិវឌ្ឍ**

ប្រទេសអភិវឌ្ឍមានតួនាទីដូចជា ៖

- បន្តលើកកម្ពស់កម្រិតជីវភាពរបស់នៅរបស់ប្រជាជន និងលុបបំបាត់នូវភាពក្រីក្រ ដែលនៅសេសសល់ដូចជា គ្មានទីជម្រក អ្នកខ្វះហូបចុក អ្នកគ្មានការងារធ្វើ អ្នកបាត់បង់ដីធ្លី...។
- បន្តលើកកម្ពស់សេវាសុខភាពប្រជាជន តាមរយៈការសិក្សាស្រាវជ្រាវលើផ្នែកវេជ្ជសាស្ត្រ សំដៅបង្កើនប្រសិទ្ធភាពសេវាព្យាបាលជំងឺ តាំងពីប្រភេទជំងឺ ដែលកើតមានឡើងតាំងពីយូរមកហើយ និងប្រភេទជំងឺដែលទើបកើតមានថ្មីៗ ពីព្រោះថាមានតែបណ្តាប្រទេសអភិវឌ្ឍទេ ទើបមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍ការងារនេះ។
- បន្តលើកកម្ពស់ និងដោះស្រាយបញ្ហាប្រជាសាស្ត្រដែលនៅសេសសល់ដូចជា បញ្ហាចំណាក ស្រុក អាយុសង្ឃឹមរស់ មនុស្សចំណាស់ច្រើន លទ្ធភាពបង្កកំណើតរបស់ស្ត្រី អត្រាកំណើនជាដើម និងបន្តដោះស្រាយបញ្ហាប្រជាសាស្ត្រនេះឱ្យកាន់តែមានភាពល្អប្រសើរឡើងឡើង។
- បន្តលើកកម្ពស់វិស័យអប់រំ តាមរយៈការសិក្សាស្រាវជ្រាវបង្កើតឡើងកម្មវិធីសិក្សាថ្មីៗ ឱ្យកាន់តែមានភាពសុក្រឹតខ្លាំងឡើងថែមទៀត។
- បន្តលើកកម្ពស់ប្រសិទ្ធភាពច្បាប់ ទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ សំដៅធ្វើឱ្យសង្គមមានសណ្តាប់ធ្នាប់ មានរបៀបរៀបរយ មានសុខសុវត្ថិភាពកាន់តែប្រសើរឡើង សំដៅធ្វើឱ្យមានកិច្ចសហការអន្តរជាតិ ក្នុងការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ គ្មានការកាប់សម្លាប់ដោយរង្គាល គ្មានបទឧក្រិដ្ឋ សង្គ្រាម គ្មានអំពើភេរវកម្មកើតមានឡើយ។

ទាំងនេះ បង្ហាញឱ្យឃើញថាបើគ្មានការអភិវឌ្ឍនោះទេ សង្គមជាតិមិនអាចវិវត្តន៍ទៅមុខទាន់សម័យកាលឡើយ ព្រោះថាបច្ចុប្បន្ននេះជាសតវត្សរ៍ទី ២១ អ្វីៗមានការប្រែប្រួលផ្លាស់ប្តូរមិនឈប់ឈរ តាមបែបវិជ្ជមានផង និងតាមបែបអវិជ្ជមានផង។

### គ. ចំណុចពិសេសនៃបណ្តាប្រទេសអភិវឌ្ឍ

បណ្តាប្រទេសអភិវឌ្ឍមានចំណុចពិសេសមួយចំនួនដូចជា ៖

- មានកម្រិតជីវភាពរស់នៅខ្ពស់
- មានកម្រិតប្រាក់ចំណូលខ្ពស់
- ការផ្គត់ផ្គង់សេវាសង្គមមានកម្រិតខ្ពស់
- មានសេដ្ឋកិច្ចឯករាជ្យ
- មានបំណុលបរទេសទាប (ជាទូទៅ)
- ពុំសូវចោទចំពោះបញ្ហាបរិស្ថាន
- មានរបបអាហារគ្រប់គ្រាន់ (៣ ៤៥៩ កាឡូរី លើសការកំណត់ ២ ៧០០ កាឡូរី)
- ការគោរពច្បាប់នានាមានកម្រិតខ្ពស់
- មានបញ្ហាផ្នែកប្រជាសាស្ត្រ...។

### ៣.២. ប្រទេសកំពុងអភិវឌ្ឍ (Developing Countries)

កាលពីមុន គេតែងតែហៅក្រុមប្រទេសទាំងនេះថាជា ប្រទេសតតិយលោក ដែលរួមមានបណ្តាប្រទេសនៅទ្វីបអាស៊ីមួយចំនួនដូចជា ប្រទេសកូរ៉េខាងត្បូង កោះតៃវ៉ាន់ ក្រុងហុងកុង ប្រទេសសិង្ហបុរី... បណ្តាប្រទេសនៅទ្វីបអាមេរិកខាងត្បូងដូចជា ប្រទេសប្រេស៊ីល ប្រទេសវេនេស៊ុយអេឡា ប្រទេសម៉ិចស៊ិច... និងបណ្តាប្រទេសនៅទ្វីបអាហ្វ្រិកដូចជា ប្រទេសអាហ្វ្រិកខាងត្បូង ដែលគេអាចហៅថា ប្រទេសកំពុងអភិវឌ្ឍកំពុងជឿនលឿន។ ផ្នែកដែលនៅសេសសល់ គឺបណ្តាប្រទេសដែលស្ថិតនៅក្នុងពិភពទី ៤ ដែលរួមមានប្រទេសទាំងឡាយនៅទ្វីបអាស៊ី (លើកលែងប្រទេសជប៉ុន និងបណ្តាប្រទេសឧស្សាហកម្មថ្មីមួយចំនួន) ទ្វីបអាហ្វ្រិក តំបន់មជ្ឈឹមបូព៌ា បណ្តាប្រទេសអាមេរិកឡាទីន និងតំបន់ការ៉ាអ៊ីប (លើកលែងប្រទេសមួយចំនួនចេញ)។ បច្ចុប្បន្ននេះ ក្រុមប្រទេសទាំងអស់ខាងលើនេះ ត្រូវបានគេហៅរួម ថា លោកខាងត្បូង។

ប្រទេសកំពុងអភិវឌ្ឍ គឺជាក្រុមប្រទេស ដែលពុំទាន់អាចសំរេចបានទាំងស្រុងនូវគោលការណ៍ណាមួយ (ការធ្វើឱ្យចម្រើនឡើងនូវគោលការណ៍ប្រើមនុស្ស...) ឬមិនអាចធានាបានតាមសំណូមពរណាមួយនោះត្រូវបានចាត់ទុកជាភាពទន់ខ្សោយ (គ្រឿងឧបភោគ អក្ខរកម្ម សង្គមកិច្ច) ឬការប្រើប្រាស់ក្រោមកម្រិត (ប្រើប្រាស់តិច) ប្រភពធនធាននៃប្រទេស។ បណ្តាប្រទេសកំពុងអភិវឌ្ឍ និយាយរួម គឺមានចំណូលថវិកាមធ្យមតាមមនុស្សម្នាក់ទាប និងមានល្បឿនសេដ្ឋកិច្ចពុំសូវរីកចម្រើន (លើកលែង ប្រទេសមួយចំនួនតូចចេញ)។ ក្រុមប្រទេសទាំងនេះ មានចំនុចពិសេសរួមមួយចំនួនដូចខាងក្រោម ៖

- កម្រិតជីវភាពនៅទាប បើធៀបទៅនឹងបណ្តាប្រទេសនៅទ្វីបអឺរ៉ុបខាងលិច អាមេរិកខាងជើង។ ចំណូលថវិកាតាមមនុស្សម្នាក់ៗ គឺក្រោម ១៥០០ ដុល្លាអាមេរិក។
- តម្រូវការមួយចំនួននៅទន់ខ្សោយ មិនអាចធានាបានតាមសេចក្តីត្រូវការរបស់ប្រជាជនបានទេ ដូចជា គ្រឿងឧបភោគ សិទ្ធិចូលរៀនសូត្រ ឬការថែទាំថ្នាំសង្កូវ...។
- មិនទាន់មានល្បឿនសេដ្ឋកិច្ចឯករាជ្យ និងម្ចាស់ការ មួយផ្នែកនៃល្បឿនសេដ្ឋកិច្ចត្រូវស្ថិតនៅចំណុះប្រទេសក្រៅ ឬជាផ្នែកដែលមានល្បឿនសេដ្ឋកិច្ចមិនមានទំនាក់ទំនងស្អិតរមួត...។ ក្រុមប្រទេស

លោកខាងត្បូង ក៏មានការបែងចែកច្បាស់លាស់ដែរ។ មានបណ្ដាប្រទេសខ្លះ ដែលទទួលបានចំណូលថវិកាជាមធ្យមគិតតាមមនុស្សម្នាក់ៗលើសពី ៨ ៥០០ ដុល្លាអាមេរិក ហើយសម្រេចបាននូវតម្រូវការចាំបាច់របស់ប្រជាជន ប៉ុន្តែមានទំរង់សេដ្ឋកិច្ចគ្មានប្រព័ន្ធផលិតកម្ម នោះគឺក្រុមប្រទេសនាំចេញនូវប្រេងឥន្ធនៈដូចជា ប្រទេសលីប៊ី ប្រទេសអារ៉ាប៊ីសាអូឌីត ប្រទេសគុយវ៉ែត ប្រទេសអ៊ីរ៉ង់ ប្រទេសអ៊ីរ៉ាក់ ប្រទេសកាតា...។ បណ្ដាប្រទេសទាំងនេះ មានកម្រិតចំណូលថវិកាគិតតាមចំនួនមនុស្សម្នាក់ៗច្រើនជាង ៥ ០០០ ដុល្លាអាមេរិកនៅឆ្នាំ ២០០៨។ ចក្រភពអារ៉ាប់មាន ១៧ ៩៣៥ ដុល្លាអាមេរិក ប្រទេសគុយវ៉ែត ១៥ ៧៩៩ ដុល្លាអាមេរិក ប្រទេសអារ៉ាប៊ីសាអ៊ូឌីត ១១ ៣៦៧ ដុល្លាអាមេរិក ប្រទេសអូម៉ង់ ១៣ ៣៥៦ ដុល្លាអាមេរិក ប្រទេសលីប៊ី ៧៥៧០ ដុល្លាអាមេរិក។ មានប្រទេសមួយចំនួនទៀត មានប្រព័ន្ធផលិតកម្មទាក់ទងគ្នាល្អ ឯករាជ្យ និងមានការបើកទូលាយពិភពខាងក្រៅ ប៉ុន្តែទន្ទឹមនឹងនេះដែរ ក៏មានចំនូលថវិកាទាប ប្រជាជននៅក្រខ្សត់ កម្រិតជីវភាពប្រជាជនត្រឹមតែមួយគ្រប់គ្រាន់សម្រាប់ជីវិតតែប៉ុណ្ណោះ។ បណ្ដាប្រទេសទាំងនេះត្រូវបានគេរាប់បញ្ចូលក្នុងបណ្ដាប្រទេសសេដ្ឋកិច្ចអន់ថយ (The least developed countries sresrkat, LDC)។ តាមឯកសាររបស់អង្គការសហប្រជាជាតិ នៅលើពិភពលោកយើងនេះ មាន ២៤ ប្រទេសដូចជា ប្រទេសអេត្យូពី ប្រទេសអ៊ូហ្គាន់ដា ប្រទេសបង់ក្លាដេស...។ នោះ គឺជាបណ្ដាប្រទេសទាន់ខ្សោយផ្នែកសេដ្ឋកិច្ច ទិន្នផលពលកម្មទាបបំផុត និងមានហេដ្ឋា-រចនាសម្ព័ន្ធអន់ថយហួសសម័យ ហើយមាន GNP តាមមនុស្សម្នាក់ៗទាបបំផុត គឺ ២១៩ ដុល្លាអាមេរិក។

នៅមានបណ្ដាប្រទេសមួយចំនួនទៀត ដែលជ្រើសរើសយកនូវយុទ្ធនាការឧស្សាហូបនីយកម្ម ហៅថា បណ្ដាប្រទេសប្រទេសឧស្សាហកម្មថ្មី (Newly Industrializing Countries-NIC) គេសម្រេចបាននូវការធ្វើឱ្យចម្រើនឡើងខ្ពស់ មានខឿនឧស្សាហកម្មលូតលាស់ខ្លាំងបង្គួរ ដោយមានកម្រិតវប្បធម៌ និងបច្ចេកទេសខ្ពស់ មានចំណូលថវិកាជាតិតាមមនុស្សម្នាក់ៗខ្ពស់ដូចជា ទីក្រុងហុងកុង ២៥ ១៥៣ ដុល្លាអាមេរិក កោះតៃវ៉ាន់ ២៣ ៣៥៦ ដុល្លាអាមេរិក ប្រទេសអាហ្សង់ទីន ១២ ៣៧៧ ដុល្លាអាមេរិក ប្រទេសម៉ិចស៊ិច ៩០២៣ ដុល្លាអាមេរិក...នៅឆ្នាំ ២០០៨ (យុទ្ធសាស្ត្រឧស្សាហូបនីយកម្មនាំចេញ) ប៉ុន្តែគេនៅតែរាប់បញ្ចូលប្រទេសទាំងនេះថាជា ប្រទេសកំពុងអភិវឌ្ឍផងដែរ ឬប្រទេសលោកខាងត្បូង ឬប្រទេកំពុងអភិវឌ្ឍកំពុងជឿនលឿន។

### ក. និយមន័យ

**ប្រទេសកំពុងអភិវឌ្ឍ** គឺជាកន្សោមនៃពាក្យដែលគេប្រើ សម្រាប់សម្គាល់សំដៅទៅលើបណ្ដាប្រទេសទាំងឡាយណា ដែលមិនទាន់អាចឆ្លើយតបបាន ឬមិនទាន់អាចបំពេញបានទាំងស្រុងនូវតម្រូវការជាមូលដ្ឋានរបស់ប្រជាជន នៅក្នុងប្រទេសរបស់ខ្លួន។ បណ្ដាប្រទេសអភិវឌ្ឍរួមមាន ៖

- ទ្វីបអឺរ៉ុបខាងកើត ៖ លើកលែងរុស្ស៊ី
- ទ្វីបអាមេរិកខាងជើង ៖ លើកលែងប្រទេសកាណាដា និងសហរដ្ឋអាមេរិក
- ទ្វីបអាមេរិចខាងត្បូង ៖ បណ្ដាប្រទេសទាំងអស់នៅអាមេរិកខាងត្បូង
- ទ្វីបអាព្រិច ៖ បណ្ដាប្រទេសទាំងអស់នៅទ្វីបអាព្រិច
- ទ្វីបអាស៊ី ៖ លើកលែងមានប្រទេសជប៉ុន ប្រទេសសិង្ហបុរី និងប្រទេសកូរ៉េខាងត្បូង

- ទ្វីបអូសេអានី ៖ លើកលែងប្រទេសអូស្ត្រាលី និងប្រទេសញូសឺឡែន។

## ខ. តួនាទីប្រទេសកំពុងអភិវឌ្ឍ

បណ្ដាប្រទេសអភិវឌ្ឍមានតួនាទីដូចជា ៖

- លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន សំដៅធ្វើយ៉ាងណាឱ្យប្រជាជនមានជីវភាពរស់នៅធូរធារ ហូបចុកគ្រប់គ្រាន់ និងរស់នៅសមរម្យ។ ចំពោះបញ្ហានេះ រដ្ឋាភិបាលនៃបណ្ដាប្រទេសកំពុងអភិវឌ្ឍតែងតែរិះរកគ្រប់មធ្យោបាយ ដើម្បីដោះស្រាយ។
- លើកកម្ពស់សេវាថែទាំសុខភាពប្រជាជន សំដៅធ្វើយ៉ាងណាឱ្យសេវាសុខាភិបាលកាន់តែមានលក្ខណៈល្អប្រសើរឡើង ដោយបង្កើនចំនួនគ្រូពេទ្យ មន្ទីរពេទ្យ គិលានុបដ្ឋាន បរិក្ខារពេទ្យ ជំនាញគ្រូពេទ្យ...ឱ្យបានគ្រប់គ្រាន់ និងល្អប្រសើរ។
- លើកកម្ពស់ និងដោះស្រាយនូវបញ្ហាប្រជាសាស្ត្រឱ្យមានភាពកាន់តែល្អប្រសើរឡើងដូចជា បញ្ហាចំណាកស្រុក អាយុសង្ឃឹមរស់ មនុស្សចំណាស់ច្រើន លទ្ធភាពបង្កកំណើតរបស់ស្ត្រី អត្រាកំណើនជាដើម និងដោះស្រាយបញ្ហាប្រជាសាស្ត្រនេះ ឱ្យកាន់តែមានភាពល្អប្រសើរឡើង...។
- លើកកម្ពស់ការសិក្សាអប់រំ សំដៅបណ្ដុះបណ្ដាលក្របខណ្ឌជំនាញដូចជា កម្មករជំនាញ អ្នកឯកទេស អ្នកបច្ចេកទេស វិស្វករ គ្រូបង្រៀនឱ្យបានគ្រប់គ្រាន់ និងគ្រប់ផ្នែកជំនាញ កាត់បន្ថយអត្រាអនក្ខរភាព ដែលសព្វថ្ងៃមានការកែលម្អច្រើនគួរសម តែនៅតែស្ថិតនៅក្នុងកម្រិតមួយខ្ពស់នៅឡើយ។
- លើកកម្ពស់ និងបង្កើនការយល់ដឹងពីច្បាប់ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ការប្រើប្រាស់ច្បាប់ ការអនុវត្តសិទ្ធិសេរីភាពក្នុងក្របខណ្ឌច្បាប់ សំដៅកាត់បន្ថយការរំលោភបំពាន អំពើហិង្សា ភាពអនាធិបតេយ្យ...ក្នុងសង្គមជាតិ និងក្នុងក្រុមគ្រួសារ។

និយាយរួម ការអភិវឌ្ឍមានតួនាទីសំខាន់ណាស់ បើទោះបីជាស្ថិតនៅក្នុងសង្គមអភិវឌ្ឍក្ដី ឬកំពុងអភិវឌ្ឍក្ដី ព្រោះវាជាគន្លឹះមួយសម្រាប់ទ្រទ្រង់ស្ថិរភាពសង្គម និងសម្រាប់រុញច្រានសង្គមឱ្យចេញផុតពីភាពអន់ថយឆ្ពោះទៅកាន់ភាពរីកចម្រើនរុងរឿងបាន។

## គ. ចំណុចពិសេសនៃបណ្ដាប្រទេសកំពុងអភិវឌ្ឍ

បណ្ដាប្រទេសកំពុងអភិវឌ្ឍមានចំណុចពិសេសមួយចំនួនដូចជា ៖

- មានកម្រិតជីវភាពរស់នៅទាប
- មានកម្រិតប្រាក់ចំណូលទាប
- មានការផ្គត់ផ្គង់សេវាសង្គមទាប
- មានរបបអាហារមិនគ្រប់គ្រាន់ (ក្រោមការកំណត់ ២ ៧០០ កាឡូរី)
- មានសេដ្ឋកិច្ចមិនឯករាជ្យ
- មានបំណុលបរទេសច្រើន
- មានបញ្ហាបរិស្ថានខ្ពស់
- ការគោរពច្បាប់នានាមានកម្រិតទាប
- មានបញ្ហាផ្នែកប្រជាសាស្ត្រ...។

**សំណួរត្រិះរិះ**

1. អ្វីជាការចម្រើនឡើង? អ្វីជាការអភិវឌ្ឍ?
2. ប្រសិនបើគេធ្វើការវិភាគទៅលើទស្សនៈស្តីពីការចម្រើនឡើង តើគេឃើញមានការលេចឡើងនូវ ទស្សនៈអ្វីខ្លះផ្សេងទៀត? ចូរពន្យល់នូវទស្សនៈនីមួយៗ។
3. ចូរបង្ហាញពីទំនាក់ទំនងរវាងការចម្រើនឡើង និងការអភិវឌ្ឍ។
4. អ្វីជាប្រទេសកំពុងអភិវឌ្ឍ? តើប្រទេសកំពុងអភិវឌ្ឍមានលក្ខណៈសម្គាល់អ្វីខ្លះ?
5. ហេតុអ្វីបានជាបណ្តាប្រទេសកំពុងអភិវឌ្ឍមានខឿនសេដ្ឋកិច្ចមិនសូវរីកចម្រើន?
6. អ្វីជាប្រទេសអភិវឌ្ឍ? តើប្រទេសអភិវឌ្ឍមានលក្ខណៈសម្គាល់អ្វីខ្លះ?
7. ហេតុអ្វីបានជាបណ្តាប្រទេសអភិវឌ្ឍមានខឿនសេដ្ឋកិច្ចរីកចម្រើនខ្លាំងម្លេះ?
8. ចូរនិយាអំពីតួនាទីរបស់ប្រទេសកំពុងអភិវឌ្ឍ ក្នុងការអភិវឌ្ឍប្រទេសជាតិរបស់ខ្លួន។
9. ចូរនិយាយអំពីតួនាទីរបស់ប្រទេសអភិវឌ្ឍ ក្នុងការអភិវឌ្ឍប្រទេសជាតិរបស់ខ្លួន។

# មេរៀនទី២៖ វិធីគណនាសន្ទស្សន៍អភិវឌ្ឍមនុស្ស (HDI)

រូបមន្តទូទៅនៃសន្ទស្សន៍អភិវឌ្ឍមនុស្សគឺ ៖

$$\text{HDI} = \frac{\text{សន្ទ.អាយុកាលមធ្យម} + \text{សន្ទ.អប់រំ} + \text{សន្ទ.កម្រិតជីវភាព (GDP)}}{៣}$$

ដើម្បីគណនាសន្ទស្សន៍អភិវឌ្ឍមនុស្ស គេត្រូវគណនាសន្ទស្សន៍នីមួយៗ តាមរូបមន្តសំខាន់ៗ មួយចំនួនដូចខាងក្រោម ៖

## ១. គណនាសន្ទស្សន៍អាយុកាលជាមធ្យម

ដើម្បីគណនាសន្ទស្សន៍អាយុកាលជាមធ្យមរបស់ប្រជាជននៅក្នុងប្រទេសមួយ គេត្រូវគណនាតាមរូបមន្តសន្ទស្សន៍អាយុកាលជាមធ្យមដូចខាងក្រោម ៖

$$\text{សន្ទស្សន៍} = \frac{\text{តម្លៃអង្កេត - តម្លៃអប្បរមា}}{\text{តម្លៃអតិបរមា - តម្លៃអប្បរមា}} \quad \text{(ដែនកំណត់ពី 0 - ១)}$$

- អាយុកាលមធ្យម
  - តម្លៃអតិបរមា = ៨៥ ឆ្នាំ
  - តម្លៃអប្បរមា = ២៥ ឆ្នាំ

## ២. គណនាសន្ទស្សន៍អប់រំ

ដើម្បីគណនាសន្ទស្សន៍អប់រំរបស់ប្រជាជននៅក្នុងប្រទេសមួយ គេត្រូវគណនាតាមរូបមន្តសន្ទស្សន៍អប់រំជាមធ្យម តាមរូបមន្តដូចខាងក្រោម ៖

$$\text{សន្ទ.អប់រំ} = \frac{\text{២(សន្ទ.អត្រាចេះអក្សរពេញវ័យ)+(សន្ទ.អត្រាចូលរៀន)}}{៣} \quad \text{(ដែនកំណត់ពី 0 - ១)}$$

- ការអប់រំ
  - ២/៣ អត្រាចេះអក្សរមនុស្សពេញវ័យ
    - តម្លៃអតិបរមា = ១០០
    - តម្លៃអប្បរមា = 0%
  - ១/៣ អត្រាចូលរៀនតាមកម្រិតសិក្សា
    - តម្លៃអតិបរមា = ១០០
    - តម្លៃអប្បរមា = 0%

ដើម្បីគណនាសន្ទស្សន៍អត្រាចេះអក្សររបស់មនុស្សពេញវ័យ និងសន្ទស្សន៍អត្រាចូលរៀនតាមកម្រិតសិក្សានៃប្រជាជននៅក្នុងប្រទេសមួយ គេត្រូវគណនាតាមរូបមន្តសន្ទស្សន៍ដូចខាងក្រោម ៖

$$\text{សន្ទស្សន៍} = \frac{\text{តម្លៃអង្កេត} - \text{តម្លៃអប្បរមា}}{\text{តម្លៃអតិបរមា} - \text{តម្លៃអប្បរមា}} \quad (\text{ដែនកំណត់ពី } 0 - ១)$$

## ៣. គណនាសន្ទស្សន៍កម្រិតជីវភាព

ដើម្បីគណនាសន្ទស្សន៍កម្រិតជីវភាព នៃប្រជាជននៅក្នុងប្រទេសមួយ គេត្រូវគណនាតាមរូបមន្តសន្ទស្សន៍ដូចខាងក្រោម ៖

$$\text{សន្ទស្សន៍} = \frac{\text{Log}(\text{តម្លៃអង្កេត}) - \text{Log}(\text{តម្លៃអប្បរមា})}{\text{Log}(\text{តម្លៃអតិបរមា}) - \text{Log}(\text{តម្លៃអប្បរមា})} \quad (\text{ដែនកំណត់ពី } 0 - ១)$$

- កម្រិតជីវភាព (GDP)
  - តម្លៃអតិបរមា = ៤0 000$
  - តម្លៃអប្បរមា = ១ 000$

## ៤. លំហាត់អនុវត្ត

១. នៅប្រទេសកាណាដា ក្នុងឆ្នាំ២០០៨ អាយុកាលជាមធ្យមរបស់ប្រជាជនមាន ៧៨.៨ ឆ្នាំ ហើយនិងអត្រាចូលរៀនតាមកម្រិតសិក្សារបស់ប្រទេសនេះមាន ៩៧ % និងអត្រាចេះអក្សរមនុស្សពេញវ័យមាន ១០០% រីឯ GDP សម្រាប់មនុស្សម្នាក់ៗវិញគឺមាន ២ ៧៨៤០ ដុល្លាអាមេរិក។ ចូរគណនាសន្ទស្សន៍អភិវឌ្ឍមនុស្សរបស់ប្រទេសកាណាដា។

២- នៅក្នុងឆ្នាំ២០០៨ ប្រទេសន័រវេសមាន GDP សម្រាប់មនុស្សម្នាក់គឺ ២ ៩៩១៨ ដុល្លាអាមេរិក ហើយគេឃើញអត្រាចេះអក្សរមនុស្សពេញវ័យរបស់ប្រទេសនេះវិញមាន ១០០% និងមានអត្រាអ្នកចូលរៀនតាមកម្រិតសិក្សា ៩៧ % រីឯអាយុសង្ឃឹមរស់ជាមធ្យមរបស់គេមាន ៧៨.៥ ឆ្នាំ។ ចូររកសន្ទស្សន៍អភិវឌ្ឍមនុស្សរបស់ប្រទេសនេះ។

៣- អត្រាចូលរៀនមនុស្សពេញវ័យរបស់ប្រទេសកម្ពុជាយើងនៅក្នុងឆ្នាំ២០០៨ គឺមាន ៦៧.៨% និងអត្រាចូលរៀនតាមកម្រិតសិក្សាមាន ៦២%។ នៅក្នុងនោះដែរ គេឃើញ GDP សម្រាប់មនុស្សម្នាក់មាន ១៤៤៦ ដុល្លារអាមេរិក រីឯអាយុសង្ឃឹមរស់ជាមធ្យម គឺមានរយៈពេល ៥៦.៤ ឆ្នាំ។ ផ្អែកលើតួលេខនេះចូរគណនាសន្ទស្សន៍អភិវឌ្ឍមនុស្សរបស់ប្រទេសកម្ពុជាយើង។

៤- ចូរគណនាសន្ទស្សន៍អភិវឌ្ឍមនុស្សរបស់បណ្តាប្រទេសមួយចំនួនក្នុងឆ្នាំ ២០១៨ ដូចខាងក្រោមនេះ ៖

| ឈ្មោះប្រទេស | អាយុកាលមធ្យម | អត្រាចេះអក្សរមនុស្សពេញវ័យ (%) | អត្រាចូលរៀនតាម កំរិតសិក្សា (%) | GDP ក្នុងមនុស្សម្នាក់ | សន្ទស្សន៍ HDI ? |
|---|---|---|---|---|---|
| ប្រទេសស៊ុយអែត | ៧៩,៧ | ១០០ | ១០១ | ២៤២៧៧ | |
| ប៊ែលហ្ស៊ិក | ៧៨,៤ | ១០០ | ១០៩ | ២៧១៧៨ | |
| អូស្ត្រាលី | ៧៨,៩ | ១០០ | ១១៦ | ២៥៦៩៣ | |
| សហរដ្ឋអាមេរិច | ៧៧,0 | ១០០ | ៩៥ | ៣៤១៤២ | |
| អ៊ីស្លង់ | ៧៩,២ | ១០០ | ៨៩ | ២៩៥៨១ | |
| ហូឡង់ | ៧៨,១ | ១០០ | ១០២ | ២៥៦៥៧ | |
| ជប៉ុន | ៨១,0 | ១០០ | ៨២ | ២៦៧៥៥ | |
| ហ្វាំងឡង់ | ៧៧,៦ | ១០០ | ១០៣ | ២៤៩៩៦ | |
| ស្វីស | ៧៨,៩ | ១០០ | ៨៤ | ២៨៧៦៩ | |
| បារាំង | ៧៨,៦ | ១០០ | ៩៤ | ២៤២២៣ | |
| អង់គ្លេស | ៧៧,៧ | ១០០ | ១០៦ | ២៣៥០៩ | |
| ដាណឺម៉ាក | ៧៦,២ | ១០០ | ៩៧ | ២៧៦២៧ | |
| អូស្ទ្រីស | ៧៨,១ | ១០០ | ៩០ | ២៦៧៦៥ | |
| លុចហ្សំបួ | ៧៧,៤ | ១០០ | ៧២ | ៥០០៦១ | |
| អាឡឺម៉ង់ | ៧៧,៧ | ១០០ | ៩៤ | ២៥១០៣ | |
| អៀរឡង់ | ៧៦,៦ | ១០០ | ៩១ | ២៩៨៦៦ | |
| ណូវែលហ្សេឡង់ | ៧៧,៦ | ១០០ | ៩៩ | ២០០៧០ | |
| អ៊ីតាលី | ៧៨,៥ | ៩៨,៤ | ៨៤ | ២៣៦២៦ | |
| អេស្ប៉ាញ | ៧៨,៥ | ៩៧,៦ | ៩៥ | ១៩៤៧២ | |
| អ៊ីស្រាអែល | ៧៨,៧ | ៩៤,៦ | ៨៣ | ២០១៣១ | |

| ឈ្មោះប្រទេស | អាយុកាលមធ្យម | អត្រាចេះអក្សរមនុស្សពេញវ័យ (%) | អត្រាចូលរៀនតាម កំរិតសិក្សា (%) | GDP ក្នុងមនុស្សម្នាក់ | សន្ទស្សន៍ HDI ? |
|---|---|---|---|---|---|
| ហុងកុង | ៧៩,៥ | ៩៣,៥ | ៦៣ | ២៥១៥៣ | |
| ក្រិច | ៧៨,២ | ៩៧,២ | ៨១ | ១៦៥០១ | |
| សឹង្ហបុរី | ៧៧,៦ | ៩២,៣ | ៧៥ | ២៣៣៥៦ | |
| ស៊ីប្រ៊ីស | ៧៨,០ | ៩៧,១ | ៦៨ | ២០៨២៤ | |
| កូរ៉េខាងត្បូង | ៧៤,៩ | ៩៧,៨ | ៩០ | ១៧៣៨០ | |
| ប៉ទុយហ្កាល់ | ៧៥,៧ | ៩២,២ | ៩៦ | ១៧២៩០ | |
| ស្លូវិនា | ៧៥,៥ | ៩៩,៦ | ៨៣ | ១៧៣៦៧ | |
| ព្រុយណេ | ៧៥,៩ | ៩១,៥ | ៧៦ | ១៦៧៧៩ | |
| មិចស៊ីច | ៧២,៦ | ៩១,៤ | ៧១ | ៩០២៣ | |
| កុយបា | ៧៦,០ | ៩៦,៧ | ៧៦ | ៩០២៣ | |
| ប៊ែលឡារ៉ូស | ៦៨,៥ | ៩៩,៦ | ៧៧ | ៧៥៤៤ | |
| ប៉ាណាម៉ា | ៧៤,០ | ៩១,៩ | ៧៤ | ៦០០០ | |
| ម៉ាឡេស៊ី | ៧២,៥ | ៨៧,៥ | ៦៦ | ៩០៦៨ | |
| សហព័ន្ធរុស្ស៊ី | ៦៦,១ | ៩៩,៦ | ៧៨ | ៨៣៧៧ | |
| កូលំប៉ៀរ | ៧១,២ | ៩១,៧ | ៧៣ | ៦២៤៨ | |
| វេណឺហ្សូអ៊ីឡា | ៧២,៩ | ៩២,៦ | ៦៥ | ៥៧៩៤ | |
| ថៃឡង់ | ៧០,២ | ៩៥,៥ | ៦០ | ៦៤០២ | |
| ឥណ្ឌូនេស៊ី | ៦៦,២ | ៨៦,៩ | ៦៥ | ៣០៤៣ | |
| វៀតណាម | ៦៨,២ | ៩៣,៤ | ៦៧ | ១៩៩៦ | |
| អ៊ុយក្រែន | ៦៨,១ | ៩៩,៦ | ៧៧ | ៣៨១៦ | |
| ហ្វីលីពីន | ៦៩,៣ | ៩៥,៥ | ៨៣ | ៣៩៧១ | |
| ម៉ាឡៀវ | ៦៦,៥ | ៩៦,៧ | ៧៧ | ៤៤៨៥ | |
| ប៉ាគីស្ថាន | ៦០,០ | ៤៣,២ | ៤០ | ១៩២៨ | |
| ប៊ូតាន | ៦២,០ | ៤៧,០ | ៣៣ | ១៤១២ | |
| នេប៉ាល់ | ៥៨,៦ | ៤១,៨ | ៦០ | ១៣២៧ | |
| ឡាវ | ៥៣,៣ | ៤៨,៧ | ៥៨ | ១៥៧៥ | |
| យេមែន | ៦០,៦ | ៤៦,៣ | ៥១ | ៨៩៣ | |
| ប៉ង់ក្លាដែស | ៥៩,៨ | ៤១,៣ | ៣៧ | ១៦០២ | |
| ម៉ាដាកាស្កា | ៥២,៦ | ៦៦,៥ | ៤៤ | ៨៤០ | |

| ឈ្មោះប្រទេស | អាយុកាលមធ្យម | អត្រាចេះអក្សរមនុស្សពេញវ័យ (%) | អត្រាចូលរៀនតាម កំរិតសិក្សា (%) | GDP ក្នុងមនុស្សម្នាក់ | សន្ទស្សន៍ HDI ? |
|---|---|---|---|---|---|
| អ៊ុយហ្កាន់ដា | ៤៤,០ | ៦៧,១ | ៤៥ | ១២០៨ | |
| តាន់ហ្សានី | ៥១,១ | ៧៥,១ | ៣២ | ៥២៣ | |
| ហ្សំប៊ី | ៤១,៤ | ៤១,១ | ៤៩ | ៧៨០ | |
| សេនីហ្កាល់ | ៥៣,៣ | ៣៧,៣ | ៣៦ | ១៥១០ | |
| កុងហ្គោ | ៥១,៣ | ៦១,៤ | ៣១ | ៧៦៥ | |
| អង់ហ្គោឡា | ៤៥,២ | ៤២,០ | ២៣ | ២១៨៧ | |
| រ៉វ៉ាន់ដា | ៤០,២ | ៦៦,៨ | ៤០ | ៩៤៣ | |
| ម៉ាឡាវី | ៤០,០ | ៦០,១ | ៧៣ | ៦១៥ | |
| ម៉ាលី | ៥១,៥ | ៤១,៥ | ២៨ | ៧៩៧ | |
| អាហ្វ្រិចកណ្តាល | ៤៤,៣ | ៤៦,៧ | ២៤ | ១១៧២ | |
| អេត្យូពី | ៤៣,៩ | ៣៩,១ | ២៧ | ៦៦៨ | |
| មូហ្សំប៊ិច | ៣៩,៣ | ៤៤,០ | ២៣ | ៨៥៤ | |
| នីហ្សែ | ៤៥,២ | ១៥,៩ | ១៦ | ៧៤៦ | |
| សូម៉ាលីអូន | ៣៨,៩ | ៣៦,០ | ២៧ | ៤៩០ | |

*ប្រភព ៖ UNDP Reports ឆ្នាំ 2006 -2007*

# មេរៀនទី៣៖ វិធីគណនាផលិតផលជាតិសរុប និងផលិតផលក្នុងស្រុកសរុប

## ១. និយមន័យផលិតផលក្នុងស្រុកសរុប (GDP) និងផលិតផលជាតិសរុប (GNP)

ការផលិត និងការប្រើប្រាស់ វាគឺជាសកម្មភាពអចិន្ត្រៃយ៍ ដែលហាក់បីដូចជាប្រព័ន្ធវដ្តមួយ នៃខឿនសេដ្ឋកិច្ចក្នុងប្រទេសទាំងអស់នៅលើពិភពលោកទាំងមូល។ នៅក្នុងខឿនសេដ្ឋកិច្ចជាតិនៃប្រទេសនីមួយៗមានសកម្មភាពចំណាត់ចែងនៅក្នុងរដ្ឋាភិបាល សហគ្រាសឯកជន និងបរទេស។ លទ្ធផលសកម្មភាពនៃខឿនសេដ្ឋកិច្ចក្នុងរយៈពេលមួយ (ជាធម្មតា គឺមួយឆ្នាំពេញ) ត្រូវបានស្តែងចេញឡើងនូវបរិមាណផលិតផលទំនិញ និងសេវាកម្ម (អ្នកលក់ផលិតផល) ដែលគេតែងតែហៅថា ផលិតផលជាតិសរុប ដើម្បីវាស់វែងនូវខឿនសេដ្ឋកិច្ចផលិតចេញបានប៉ុន្មាន ក្នុងកំឡុងពេលមួយឆ្នាំ និងដើម្បីគណនាបានផលិតផលសរុប ដែលមានឈ្មោះផ្សេងៗគ្នាដូចជា ស្រូវ អង្ករ ពោត សណ្តែក លូ សម្លៀកបំពាក់ ស្បែកជើង របស់របរផ្សេងៗ សេវាកម្មបម្រើផ្នែកអប់រំ ផ្នែកសុខាភិបាល ទំនិញសព្វសារពើ និងសេវាកម្មផ្សេងៗទៀត។

អាស្រ័យដោយខឿនសេដ្ឋកិច្ចដែលបានបង្កើតចេញ គេត្រូវប្រើប្រាស់នូវតម្លៃរូបិយវត្ថុជាតិ និងអន្តរជាតិ។ នោះ គឺជាតម្លៃដែលត្រូវសងឱ្យនូវរាល់ទំនិញ ឬសេវាកម្មដែលត្រូវបានផលិតចេញក្នុងខឿនសេដ្ឋកិច្ច អាស្រ័យដោយអ្នកទិញចុងក្រោយ គឺជាទំនិញឯកជន សហគ្រាសរដ្ឋាភិបាល និងជនបរទេស ដែលចូលមក បណ្តាក់ទុន។

### ១.១. ផលិតផលក្នុងស្រុកសរុប (GDP : Gross Domestic Product)

ផលិតផលក្នុងស្រុកសរុប (GDP) គឺជាផ្នែកមួយ សម្រាប់វាស់វែងអំពីតម្លៃនៃផលិតផល ដែលរួមមានទាំងតម្លៃទំនិញ និងសេវាកម្មដែលត្រូវផលិតបាននៅក្នុងប្រទេសមួយ មិនថាអ្នកណាមួយនោះទេដែលបានចំណូល ប៉ុន្តែមិនធ្វើការគណនាដល់ចំណូលនៃអ្នកដែលស្ថិតនៅក្នុងប្រទេសនោះ ប៉ុន្តែរស់នៅ និងប្រកបរបររកស៊ីនៅក្រៅប្រទេ។ និយាយឱ្យងាយយល់ វាគឺជាបណ្តុំនៃធនធានសរុបទាំងអស់ក្នុងរយៈពេលមួយឆ្នាំនៅលើផែនដីជាតិមួយ ឬប្រទេសមួយ ដោយរាប់បញ្ចូលនូវទ្រព្យធន ឬផលិតផលទាំងអស់នៃសហគ្រាសឧស្សាហកម្ម សេវាកម្ម កសិកម្ម ដែលផលិតបានដោយជនជាតិនោះ និងជនបរទេសដែលបានបណ្តាក់ទុននៅក្នុងប្រទេសនោះផងដែរ។

តាមខ្លឹមសារខាងលើនេះ គេអាចធ្វើការបំព្រួញនូវអត្ថន័យនៃពាក្យផលិតផលក្នុងសរុប(GDP)នេះបានគឺ ៖

| |
|---|
| ផលិតផលសរុបក្នុងស្រុកដុល = ផលទុនសរុបរបស់ម្ចាស់ស្រុក + ផលទុនសរុបរបស់បរទេសនៅក្នុងស្រុក - ផលទុនសរុបម្ចាស់ស្រុកនៅបរទេស |

### ១.២. ផលិតផលជាតិសរុប (GNP : Gross National Product)

ផលិតផលជាតិសរុបដុល គឺជាតំលៃទីផ្សារ នៃទំនិញនីមួយៗ និងជាសេវាកម្ម ដែលត្រូវបង្កើតឡើងដោយប្រទេសមួយក្នុងរយៈពេលមួយជាកំណត់ (តាមធម្មតា គឺមួយឆ្នាំ) ឬជាផលិតផលផ្ទៃក្នុងដើម ដែលជាតម្លៃបន្ថែម ដោយក្នុងនោះ គេត្រូវរាប់បញ្ចូលផងដែរ នូវទ្រព្យធនទាំងអស់ នៃសហគ្រាសឧស្សាហកម្ម ដែលរកបានដោយជនជាតិប្រទេសនោះ ដែលធ្វើការនៅឯបរទេស ហើយត្រូវបានបញ្ជូនចូលមកក្នុងប្រទេសនោះ

រួចគេត្រូវដកចេញនូវទ្រព្យធនទាំងអស់ នៃសហគ្រាសឧស្សាហកម្ម ដែលរកបាននៅក្នុងប្រទេសនេះ ដោយជនជាតិបរទេសដែលត្រូវបញ្ជូនទៅក្រៅប្រទេសវិញ។

តាមរយៈខ្លឹមសារខាងលើនេះ គេអាចធ្វើការបំពេញនូវអត្ថន័យ នៃពាក្យផលិតផលជាតិសរុប (GDP) នេះបានគឺ ៖

| ផលិតផលជាតិសរុបដុល = ផលទុនសរុបរបស់ម្ចាស់ស្រុក + ផលទុនសរុបម្ចាស់ស្រុកនៅបរទេស - ផលទុនសរុបរបស់បរទេសនៅក្នុងស្រុក |
| --- |

នៅក្នុងស្ថិតិ និងការគណនាផលិតផលជាតិដើម ឬផលិតផលក្នុងស្រុកសរុបនៃប្រទេសណាមួយ ជាចាំបាច់ត្រូវយកចិត្តទុកដាក់ទៅលើ ៖

- ការគណនាតំលៃទំនិញ និងសេវាកម្មចុងក្រោយ។ ឧទាហរណ៍ ៖ តម្លៃទីផ្សារនៃនំប៉័ងត្រូវបានគេគិតចូល GNP ឬ GDP ពីព្រោះវាជាតម្លៃទំនិញចុងក្រោយ ដែលមិនបូកបញ្ចូលទៅក្នុងតម្លៃអង្ករភោគសាលី រួមនិងសេវាកម្មកិនម្សៅ និងធ្វើនំ ដើម្បីផលិតចេញជានំប៉័ង។ ចំណែកឯដែកថែប ដែលប្រើក្នុងរថយន្ត និងបណ្តាផ្នែកផ្សេងៗទៀត ដែលតំឡើងជាម៉ាស៊ីនស្វ័យប្រវត្តិត្រូវ បានចាត់ទុកថាជាផលិតផលកណ្តាល ហើយមិនត្រូវគិតចូលក្នុង GNP ឬ GDP នោះទេ។ ការកំណត់ដូចនេះ គឺដើម្បីចៀសវាងនូវការគណនាត្រួតគ្នា។
- GNP ឬ GDP មិនត្រឹមតែរួមបញ្ចូលដោយផលិតផលចុងក្រោយនៃទំនិញ និងសេវាកម្ម ដែលត្រូវផលិតបានខាងក្នុងប្រទេសនោះទេ ក៏ប៉ុន្តែថែមទាំងរួមបញ្ចូល ដោយខ្ទង់ចំណូលអាស្រ័យដោយទុននៅក្រៅប្រទេស និងខ្ទង់ប្រាក់របស់កម្មករដែលទៅធ្វើការនៅក្រៅប្រទេសផ្ញើមកផងដែរ តែត្រូវដកចេញនូវតម្លៃផលិតផល ដែលខឿនសេដ្ឋកិច្ចជាតិនោះត្រូវសងឱ្យទៅជនបរទេសដែលចូលមកបណ្តាក់ទុន ក្រោមទម្រង់ជាប្រាក់ចំណេញ ដោយគេបានបណ្តាក់ទុនក្នុងខឿនសេដ្ឋកិច្ច។

ឧទាហរណ៍ ៖ ពេលគណនា GNP ឬ GDP នៃប្រទេសកម្ពុជាយើង គេត្រូវដកចេញនូវប្រាក់បំណាច់កម្មកររបស់ជនបរទេស ឬដើមទុនរបស់ជនបរទេស ដែលចូលមកដាក់ទុនរកស៊ី និងធ្វើការនៅក្នុងប្រទេសយើងចេញ ប៉ុន្តែគេត្រូវបូកបញ្ចូលនូវប្រាក់បំណាច់កម្មកររបស់ប្រទេសកម្ពុជា ដែលទៅធ្វើពលកម្មនៅបរទេស ឬដើមទុនរបស់ជនជាតិយើង ដែលបានបណ្តាក់ទុននៅឯបរទេសចេញ។

សន្ទស្សន៍ GNP និងGDP គឺស្ថិតនៅលើប្រទេសនីមួយៗជាអ្នកអនុវត្ត និងដូរជាប្រាក់ដុល្លាអាមេរិក ដើម្បីអាចធ្វើការប្រៀបធៀបរវាងបណ្តាប្រទេសនៅលើពិភពលោកបាន។

## ២. ភាពខុសគ្នារវាង GNP និង GDP

រវាងផលិតផលជាតិសរុប GNP និងផលិតផលក្នុងស្រុក GDP គឺមានការខុសគ្នា។ GNP ត្រូវបានគេគណនាដោយយកGDPបូកជាមួយខ្ទង់ប្រាក់ចំណូលនៃកម្មករទាំងអស់ និងអ្នកចាត់ចែងកិច្ចការសេដ្ឋកិច្ចនានានៃប្រទេសនោះ នៅឯក្រៅប្រទេស តែត្រូវដកចេញនូវខ្ទង់ចំណូលថវិការបស់ជនបរទេសនៅប្រទេសនោះ។

ចំពោះបណ្តាប្រទេស ដែលមានអ្នកចេញទៅធ្វើការងារនៅឯក្រៅប្រទេស បណ្តាខ្ទង់ប្រាក់ផ្ញើទៅប្រទេសរបស់ជននោះច្រើនជាបង្គួរ ក្នុងខណៈពេលដែលខ្ទង់ប្រាក់ដែលត្រូវបានបង្វិលប្តូរឱ្យទៅជនបរទេស

នោះតិចជាងយ៉ាងណាក្តី ក៏ GNP ត្រូវតែធំជាង GDP យ៉ាងច្បាស់។ ឧទាហរណ៍ដូចជាករណីប្រទេសប៉ាគីស្ថាន និងប្រទេស ហុងគ្រី ទួរគី...។

ប្រទេសមួយចំនួន បែរជាមានការដាក់ទុនបរទេសច្រើនបង្គួរ ដូច្នេះការងារប្រគល់ប្រាក់ចំណូលថវិកាមួយចំនួនឱ្យទៅជនបរទេសនៅឯក្រៅប្រទេស ក៏ច្រើនណាស់ដែរ គឺប្រទេសទាំងនោះពិតជាមានGDPធំជាងបើប្រៀបធៀបជាមួយនឹងGNPដូចជាករណីនៃប្រទេសស៊ីឡេប៊ី ប្រទេសឥណ្ឌូណេស៊ី ប្រទេសកម្ពុជា។ល។

### ៣. តំលៃនៃការផ្តោះប្តូរប្រាក់

គោលការណ៍ផលិតផលជាតិសរុប និងផលិតផលក្នុងស្រុកសរុប ឬ GNP និង GDP គិតជាមធ្យមតាមចំនួនមនុស្សម្នាក់ៗត្រូវបានបណ្តាប្រទេសទាំងអស់នៅលើពិភពលោកបានយកចិត្តទុកដាក់យ៉ាងខ្លាំងព្រោះវាជាគោលការណ៍មួយសំខាន់បំផុត ដើម្បីវាយតម្លៃពីកម្រិតរីកចម្រើននៃសេដ្ឋកិច្ចរបស់ប្រទេសមួយធ្វើជាមូលដ្ឋាន ដើម្បីកំណត់ទំនាក់ទំនងសេដ្ឋកិច្ច រវាងបណ្តាប្រទេសនីមួយៗ និងជាមួយចំណាត់ថែងអន្តរជាតិ។ ដើម្បីធ្វើការប្រៀបធៀបបានពីគោលការណ៍នេះ រវាងបណ្តាប្រទេសនានានៅលើសកលោក ក្រៅពីរបៀបគណនាតាមប្រាក់បណ្តាប្រទេសនីមួយៗ (ប្រាក់ សម្រាប់ចាយក្នុងប្រទេសនីមួយៗឧទាហរណ៍ប្រាក់រៀល)។ អង្គការសហប្រជាជាតិបានកំណត់ប្រើប្រាក់ដុល្លាអាមេរិករួមឱ្យដល់ពិភពលោកទាំងមូល។ ដូច្នេះ វាត្រូវមានការផ្តោះប្តូររវាងប្រាក់បណ្តាប្រទេសនីមួយៗ មកជាប្រាក់ដុល្លាអាមេរិក។ ការផ្តោះប្តូរជាផ្លូវការ គឺជាមូលដ្ឋានដើម្បីគណនាដូរ GNP ឬ GDP ពីប្រាក់រៀល តាមប្រទេសនីមួយៗ មកជាប្រាក់ដុល្លាអាមេរិក។ លក្ខខណ្ឌ ដែលចាំបាច់ត្រូវប្រយ័ត្ន គឺការផ្តោះប្តូរប្រាក់ ពិសេសនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ តែងតែមានការគៀបសង្កត់យ៉ាងខ្លាំងក្លា វាមិនឆ្លុះបញ្ចាំងបាននូវតម្លៃស្មើនៃការទិញនោះទេ ព្រោះខឿនសេដ្ឋកិច្ចរបស់ខ្លួនវាអន់ថយ ទំនាក់ទំនងពាណិជកម្មក្រៅប្រទេស នៅមានតម្លៃទាបទំនិញជាច្រើន និងសេវាកម្មដែលមិនមែនជាពាណិជ្ជកម្មមិនអាចនាំចេញទៅលក់នៅអន្តរជាតិបាន ហើយតម្លៃប្រភេទទាំងនេះខុសគ្នាយ៉ាងខ្លាំងក្លារវាងបណ្តាប្រទេសទាំងនោះ។

ក្រៅពីនេះ ចំពោះប្រទេសយើង និងបណ្តាប្រទេសជាច្រើនទៀត ដែលមានសេដ្ឋកិច្ចអន់ថយ តម្លៃផ្តោះប្តូរនៅតែត្រូវស្ថិតនៅក្នុងទំនាក់ទំនងផ្គត់ផ្គង់រូបិយវត្ថុយ៉ាងខ្លាំង គឺមិនគ្រាន់តែអាស្រ័យដោយការបាត់បង់តម្លៃប្រាក់រៀលក្នុងប្រទេសរបស់ខ្លួននេះទេ។ តម្លៃផ្តោះប្តូរជាផ្លូវការខុសគ្នានឹងតំលៃផ្តោះប្តូរទីផ្សារសេរី។

### ៤. វិធីគណនា GNP និង GDP

#### ៤.១. ចំនុចគួរយកចិត្តទុកដាក់

ចំណុចមួយ ដែលគួរឱ្យយកចិត្តទុកដាក់ពីទស្សនៈ GNP និង GDP គឺតម្លៃទីផ្សារនៃទំនិញ និង សេវាកម្មចុងក្រោយ បានសេចក្តីថា វារួមទាំងទំនិញ និងសេវាកម្មដែលត្រូវបាននាំចេញ ទិញ និងលក់។ នៅក្នុងបណ្តាប្រទេសជាច្រើនមានផ្នែកមួយ ដែលគួរឱ្យកត់សម្គាល់ គឺបរិមាណផលិតផលមិនត្រូវបាននាំចេញទៅដួញដូរដូចជា បរិមាណផលិតផលនៃគ្រឿឧបភោគបរិភោគ អាស្រ័យដោយកសិករផលិតបាន សំដៅ ដោយការហូបចុកប្រើប្រាស់នៅក្នុងគ្រួសារ។ គ្រឿងដុត បើអាស្រ័យដោយគ្រួសារជាអ្នករកបាន ដើម្បីប្រើ គឺមិនត្រូវគេគណនាចូលទៅក្នុង GNP ឬ GDP នោះទេ ក៏ប៉ុន្តែបើគ្រួសារទាំងឡាយណាត្រូវចំណាយអស់ប្រាក់ទិញនោះគឺទើបគិត។ ការងាររបស់អ្នកមេផ្ទះ ដើម្បីផលប្រយោជន៍គ្រួសារ គឺមិនត្រូវគិតចូលក្នុង GNP ឬ GDP នោះដែរ ប៉ុន្តែបើមានការទិញលក់សេវាកម្មនោះ ទើបត្រូវបានគិតវិញ ។

បណ្ដាឧទាហរណ៍ដូចខាងលើ គឺអាចឱ្យយើងមើលឃើញពីការងារស្ថិតិតួលេខមួយចំនួនសរុប GNP ដើម្បីវាស់ពីលទ្ធផលរាប់លានសកម្មភាពក្នុងខឿនសេដ្ឋកិច្ច ដែលអាចចៀសផុតពីការខុសឆ្គងជាកំណត់ ។

## ៤.២. របៀបគណនា GNP និង GDP របស់អង្គការសហប្រជាជាតិ និងក្រុមសង្គមសេដ្ឋកិច្ច

ពីមុននេះនៅលើពិភពលោកបានលេចចេញប្រព័ន្ធស្ថិតិពីរត្រូវនឹងក្រុមសេដ្ឋកិច្ចបែបសហគ្រាស ទីផ្សាសេរី គឺប្រព័ន្ធគណនេយ្យជាតិ (System of National Account - SNA)។ ប្រព័ន្ធនេះ ត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ និងអនុវត្តនៅបណ្ដាប្រទេសមូលធននិយមទាំងអស់ និងនៅបណ្ដាប្រទេសកំពុងអភិវឌ្ឍមួយចំនួន។ គោលការណ៍ក្នុងប្រព័ន្ធ (SNA) វាឆ្លុះបញ្ចាំងជាសរុបស្ថានភាពសេដ្ឋកិច្ច នៃប្រទេសមួយនូវរាល់សកម្មភាពសេដ្ឋកិច្ចសង្គម និងត្រូវបានវាស់ដោយតម្លៃ។ ក្នុង SNA គោលការណ៍ GNP ឬ GDP មានទីតាំងសំខាន់បំផុតចំពោះប្រព័ន្ធគោលការណ៍សេដ្ឋកិច្ចប្រទេសមួយ។ SNA គណនាបានគោលការណ៍ពី GNP ឬ GDP នៅតំបន់ផលិត និងសេវាកម្ម។ ស្របជាមួយនឹងក្រុមសេដ្ឋកិច្ចផែនការ គឺប្រព័ន្ធផលិតកម្មសំភារៈ (Material Product System-MPS)។ ប្រព័ន្ធនេះ ត្រូវបានគេប្រើប្រាស់នៅអតីតសហភាពសូវៀត បណ្ដាប្រទេសអឺរ៉ុបខាងកើត។ ក្នុង MPS គឺមានបណ្ដាសកម្មភាពនៃតំបន់ផលិតសំភារៈ ហើយដែលត្រូវបានឆ្លុះបញ្ចាំង ក្នុងគោលការណ៍សេដ្ឋកិច្ចសរុប ស្ដីពីបរិមាណផលិតផលសង្គម និងចំណូលថវិកាជាតិ។ ផ្នែក GNP និង GDP ក្នុង PMS វាឆ្លុះបញ្ចាំងពីផលិតផលសំភារៈសុទ្ធ (Net Material Product - NMP)។

នោះ វាគឺជាភាពខុសគ្នារវាងប្រព័ន្ធ ២ គឺប្រព័ន្ធគណនេយ្យជាតិ SNA និងប្រព័ន្ធផលិតកម្មសំភារៈ MPS។ របៀបគណនា NMP ក្នុង MPS ដែលប្រទេសវៀតណាមកំពុងអនុវត្តប្រៀបជាមួយរបៀបគណនារបស់អង្គការសហប្រជាជាតិ (SNA) ទាបជាងប្រមាណ ២៣% ទៅ ២៧% ក្នុងនោះរួមមាន ៥ - ៧ % និង ១៨ - ២០% ចំណូលថវិកានៃវិស័យសេវាកម្ម។

ក្នុងសម័យកាលធ្វើកំណែទម្រង់សេដ្ឋកិច្ច ពីសេដ្ឋកិច្ចផែនការមកសេដ្ឋកិច្ចទីផ្សារសេរី ប្រទេសកម្ពុជា និងបណ្ដាប្រទេស ដែលយកតាមលំនាំខឿនសេដ្ឋកិច្ចបែបផែនការកាលពីមុន កំពុងតែឈានទៅរកនូវការអនុវត្តន៍តាមប្រព័ន្ធ SNA និងគណនាគោលការណ៍ GNP និង GDP តាមប្រព័ន្ធនេះ។

## ៤.៣. របៀបគណនារួមឱ្យទូទាំងពិភពលោក (តាមអង្គការសហប្រជាជាតិ)

ដើម្បីគណនាផលិតផលជាតិសរុប យើងត្រូវគណនាឱ្យផ្នែកផលិតសំភារៈទាំងអស់ និងផ្នែកផលិតមិនមែនជាសំភារៈទាំងអស់ (សេវាកម្ម)។ បញ្ញតិកម្មប្រព័ន្ធតុល្យភាពហិរញ្ញវត្ថុ (SNA) បានចាត់ទុកក្របខណ្ឌផលិតកម្ម រួមទាំងសកម្មភាពសេដ្ឋកិច្ចសំដៅបង្កើតបានទំនិញ និងសេវាកម្ម (ទាំងសេវាកម្មផលិតទាំងមិនផលិត) ដើម្បីបំពេញតាមតតម្រូវការបុគ្គល ឬសង្គម។ តាមពិត SNA មិនបែងចែកផលិតផលជាសំភារៈ និងមិនមែនជាសំភារៈនោះទេ។ នៅក្នុងការគណនានីមួយៗ ឬគោលការណ៍សេដ្ឋកិច្ចរួម សុទ្ធតែត្រូវបានគណនាសរុបទាំង ២ តំបន់។ វិធីមួយ ដើម្បីគណនាសរុបតម្លៃទំនិញ និងសេវាកម្ម ដែលបានផលិតចេញពីខឿន សេដ្ឋកិច្ចមួយ គឺត្រូវសរុបតម្លៃសេដ្ឋកិច្ច ដែលបានបង្កើតឡើង ដោយអង្គភាពនីមួយៗ កំពុងផលិតនៅក្នុងខឿនសេដ្ឋកិច្ច ៖ បុគ្គល គ្រសារ សហគ្រាស និងរដ្ឋ។ នេះ គឺជាតម្លៃកំណើនដែលត្រូវបានបង្កើតចេញនៃខឿនសេដ្ឋកិច្ច GDP ទាំងអស់។

វិធីមួយទៀត សម្រាប់គណនាផលិតផលជាតិសរុបដុល ឬផលិតផលសរុបដុលក្នុងស្រុក គឺផ្អែកលើការចំណាយរបស់អង្គភាពផលិតនីមួយៗ នៅក្នុងតំបន់ ក្នុងរយៈពេលមួយឆ្នាំ។ អាស្រ័យដោយ GDP ឆ្លុះបញ្ចាំងចំណូលថវិការបស់ប្រជាជនម្នាក់ៗក្នុងរយៈពេលឆ្នាំ ថវិកានេះរួមមានប្រាក់កម្រៃការងារ ប្រាក់ចំណេញ ប្រាក់ឈ្នួលផ្ទះ និងប្រាក់របស់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ។ ចំណូលថវិកាពីកត្តាផលិតកម្មដូចជាដីធ្លី ពលកម្ម និងទុនចំណាយ ដើម្បីផលិតចេញនូវផលិតផល។ ផលិតផល GNP ក៏មានន័យជាសរុបចំណូលថវិកាពីកត្តាផលិតកម្ម (ប្រាក់បំណាច់ ប្រាក់ចំណេញ ប្រាក់ឈ្នួលផ្ទះ...) ប្រើធ្វើជាប្រាក់ចំណាយ ដើម្បីផលិតចេញជាផលិតផលចុងក្រោយរបស់សង្គម។

**៥. GNP និង GDP គិតជាមធ្យមតាមចំនួនមនុស្សម្នាក់ៗ**

គោលការណ៍គណនា GNP ឬ GDP ជាមធ្យមក្នុងមនុស្សម្នាក់នៃប្រទេសមួយ ត្រូវបានគេគិតដោយផលិតផលជាតិសរុប (ឬផលិតផលក្នុងប្រទេស) ចែកឱ្យចំនួនប្រជាជនសរុប នៃប្រទេសនោះ។

ការគណនា GNP ឬ GDP ជាមធ្យមតាមមនុស្សម្នាក់ ក្នុងប្រទេសមួយមានអត្ថន័យធំធេងខ្លាំងណាស់។ ឆ្លងកាត់តាមគោលការណ៍គណនានេះ គេអាចវាយតម្លៃបាននូវកម្រិតរីកចម្រើននៃសេដ្ឋកិច្ច កម្រិតប្រសើរឡើង នៃជីភាពរស់នៅ (ជាទ្រឹស្តី) របស់ប្រជាជននៅក្នុងប្រទេសនីមួយៗ។ ឆ្លងកាត់តាមគោលការណ៍នេះ បណ្តាប្រទេសនានានៅលើពិភពលោកត្រូវបានបែងចែកតាមប្រភេទខុសៗគ្នា។

ខាងក្រោមនេះ គឺជារូបមន្ត សម្រាប់គណនាផលិតផលជាតិសរុប (GNP) ឬផលិតផលសរុបដុលក្នុងស្រុក (GDP) របស់ប្រទេសនីមួយៗ។

រូបមន្ត ដើម្បីគណនាផលិតផលជាតិសរុបដុល គិតជាមធ្យម សម្រាប់មនុស្សម្នាក់ គឺ ៖

❖ $$\text{GNP} = \frac{\text{GNP សរុបក្នុងឆ្នាំ x}}{\text{ប្រជាជនសរុបក្នុងឆ្នាំ x}}$$

រូបមន្ត ដើម្បីគណនាផលិតសរុបក្នុងស្រុកដុល គិតជាមធ្យម សម្រាប់មនុស្សម្នាក់ គឺ ៖

❖ $$\text{GNP} = \frac{\text{GDP សរុបក្នុងឆ្នាំ x}}{\text{ប្រជាជនសរុបក្នុងឆ្នាំ x}}$$

**សំណួរត្រិះរិះ**

1. អ្វីជាផលិតផលជាតិសរុប (GNP)? អ្វីជាផលិតផលក្នុងស្រុកសរុប (GDP)?
2. តើផលិតផលជាតិសរុប និងផលិតផលក្នុងស្រុកសរុបមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ?
3. តើគេប្រើប្រព័ន្ធអ្វីខ្លះ ដើម្បីគណនាផលិតផលជាតិសរុប និងផលិតផលសរុបក្នុងស្រុកសរុប? ចូរពន្យល់។
4. ដើម្បីគណនាផលិតផលជាតិសរុប និងផលិតផលក្នុងស្រុកសរុប គេប្រើរូបមន្តអ្វីខ្លះ?
5. តើការប្រើប្រាស់ផលិតផលជាតិសរុប ឬផលិតផលក្នុងស្រុកសរុប ដើម្បីវាយតម្លៃពីកម្រិតមាន ឬក្រ របស់ប្រទេសមួយជាការត្រឹមត្រូវហើយឬនៅ? ហេតុអ្វី? ចូរពន្យល់។

# មេរៀនទី៤៖ វិសមភាពនៃការអភិវឌ្ឍនៅលើពិភពលោក

## ១. ប្រវត្តិនៃការចែកពិភពលោក

បន្ទាប់ពីសង្គ្រាមលោកទាំង ២ បានបញ្ចប់មក ពិភពលោកទាំងមូលត្រូវបានគេបែងចែកជាជាក្រុមៗ ជាប្លុកជាបន្តបន្ទាប់។ ការបែងចែកនេះត្រូវបានគេសំអាងលើលក្ខណៈវិនិច្ឆ័យខុសៗគ្នាជាច្រើន។ លក្ខណៈវិនិច្ឆ័យទាំងនោះរួមមានដូចជា ប្រព័ន្ធសេដ្ឋកិច្ច ប្រព័ន្ធនយោបាយ និងកម្រិតអភិវឌ្ឍរបស់បណ្តាប្រទេសនីមួយៗ។

### ១.១. ការបែងចែកតាមប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយ

ការបែងចែកនេះត្រូវបានធ្វើឡើង បន្ទាប់ពីសង្គ្រាមលោកលើកទី ២ ត្រូវបានបញ្ចប់ និងជាការចាប់ផ្តើមកើតមានឡើងនូវសង្គ្រាមត្រជាក់។ នៅឆ្នាំ១៩៥០ បណ្តាប្រទេសធំៗនៅលើពិភពលោកទាំង មូលត្រូវគេបានបែងចែក ដោយសំអាងទៅលើប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយរបស់ពិភពលោកនាពេលនោះ។ យោងទៅតាមប្រព័ន្ធនេះ ពិភពលោកត្រូវបានគេបែងចែកជា ២ ក្រុមធំៗ គឺ ៖

**ក. ពិភពទី ១**

ពិភពនេះ ត្រូវបានគេពិពណ៌នា ដោយសំដៅដល់បណ្តាប្រទេសទាំងឡាយណា ដែលអនុវត្ត នូវរបបនយោបាយបែបប្រជាធិបតេយ្យសេរី និងអនុវត្តសេដ្ឋកិច្ចតាមបែបប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី មានខឿនសេដ្ឋកិច្ចរីកចម្រើនខ្លាំង ជាពិសេសវិស័យឧស្សាហកម្ម។ ក្រុមនេះរួមមានបណ្តាប្រទេសមួយចំនួននៅអឺរ៉ុបខាងលិច អាមេរិកខាងជើង ប្រទេសជប៉ុន ប្រទេសអូស្ត្រាលី និងប្រទេសណូវែលសេឡង់។

**ខ. ពិភពទី ២**

ពិភពទី ២ នេះ ត្រូវបានគេពិពណ៌នា ដោយសំដៅដល់ប្រទេសទាំងឡាយណាដែលមានខឿនសេដ្ឋកិច្ចរីកចម្រើនខ្លាំង ជាពិសេសវិស័យឧស្សាហកម្មរីកចម្រើនខ្លាំងផងដែរ ប៉ុន្តែបានអនុវត្តតាមរបប នយោបាយបែបសង្គមនិយម និងអនុវត្តសេដ្ឋកិច្ចតាមបែបសេដ្ឋកិច្ចផែនការ ឬសេដ្ឋកិច្ចបិទ។ ក្រុមនេះរួមមានដូចជាសហភាពសូវៀត និងអតីតបណ្តាប្រទេសនៅអឺរ៉ុបខាងកើតមួយចំនួន។

ប៉ុន្តែមកដល់ឆ្នាំ **១៩៦០** មានលេចឡើងនូវ ២ ពិភពផ្សេងទៀត តែការបែងចែកនេះមិនបានផ្អែកទៅលើប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធនយោបាយដូចពិភពទី ១ និងពិភពទី ២ នោះឡើយ កត្តាសំខាន់ គឺផ្អែកលើកម្រិតរីកលូតលាស់ នៃសេដ្ឋកិច្ចរបស់បណ្តាប្រទេសទាំងនោះ និងជាការបង្ហាញពីឯករាជ្យភាពការមិនចូលបក្សសម្ព័ន្ធរបស់ពួកគេ នៅក្នុងក្រុមនៃពិភពទាំង ២ នោះតែប៉ុណ្ណោះ។

**គ. ពិភពទី ៣**

ពិភពនេះ គឺសំដៅទៅលើបណ្តាប្រទេសទាំងឡាយណាដែលទើបតែទទួលបាននូវឯករាជ្យពីបណ្តាប្រទេសអាណានិគម ហើយមានសេដ្ឋកិច្ចចាប់ផ្តើមរីកលូតលាស់ខ្លាំង និងខ្លាំងបង្គួរ ពោលគឺមានឧស្សាហកម្មរីកចម្រើនខ្លាំង និងខ្លាំងបង្គួរ។ ក្រុម ឬប្លុកនេះរួមមានដូចជា ប្រទេសចិន ប្រទេសឥណ្ឌា កោះតៃវ៉ាន់ ប្រទេសសិង្ហបុរី ប្រទេសម៉ាលេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសអាហ្វ្រិកខាងត្បូង និងបណ្តាប្រទេសនៅអាមេរិកខាងត្បូងមួយចំនួនទៀត។

**ឃ. ពិភពទី ៤**

ពិភពនេះ គឺត្រូវបានពិពណ៌នាសំដៅដល់បណ្ដាប្រទេសទាំងឡាយណា ដែលមានសេដ្ឋកិច្ចទន់ខ្សោយ ពុំសូវមានការអភិវឌ្ឍ ពោលគឺកង្វះខាតនូវមធ្យោបាយនានា ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមរបស់ខ្លួន ដោយសារតែបញ្ហាធនធានធម្មជាតិរបស់ខ្លួន ឬកង្វះខាងគ្រឿងផលិតកម្ម។ ក្រុម ឬ ប្លុកនៃពិភពនេះរួមមាន បណ្ដាប្រទេសក្រីក្រទាំងអស់នៅជុំវិញពិភពលោក។

## ១.២. ការបែងចែកតាមកម្រិតអភិវឌ្ឍ

### ក. ប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍ

នៅឆ្នាំ ១៩៥៧ ពិភពលោកត្រូវគេបានបែងចែកសារជាថ្មីឡើងវិញ ក៏ប៉ុន្តែការបែងចែកនេះគឺផ្អែកតែទៅលើកម្រិតរីកលូតលាស់ ឬកម្រិតអភិវឌ្ឍរបស់បណ្ដាប្រទេសនីមួយៗប៉ុណ្ណោះ។ អ្នកដែលបាន ផ្ដួចផ្ដើមឱ្យមានការបែងចែកពិភពលោកសារជាថ្មីឡើងវិញនេះ គឺជាអង្គការមួយដែលមានឈ្មោះថា អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍដែលត្រូវបានហៅកាត់ជាភាសាអង់គ្លេសថា (OECD : Organization of Economic Corporation Development) ក្នុងនោះរួមមានសហភាពអឺរ៉ុប ប្រទេសតួរគី សហរដ្ឋអាមេរិក ប្រទេសកាណាដា ប្រទេសជប៉ុន ប្រទេសអូស្ត្រាលី និងប្រទេសណូវែលសេឡង់ជាសមាជិក។ កម្រិតអភិវឌ្ឍដែលជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់ នៅក្នុងការបែងចែកនេះរួមមាន ភាពល្អប្រសើរផ្នែកប្រជាសាស្ត្រ ភាពល្អប្រសើរផ្នែកសេដ្ឋកិច្ច និងភាពល្អប្រសើរផ្នែក ការផ្ដត់ផ្គង់សេវាសង្គមដល់ប្រជាពលរដ្ឋរបស់ខ្លួន។

- **ប្រទេសអភិវឌ្ឍ**

ក្រុមនេះត្រូវបានគេពិពណ៌នាសំដៅដល់ក្រុមប្រទេសទាំងឡាយណាដែលមានខឿនសេដ្ឋកិច្ចរីកចម្រើនខ្លាំង ជាក្រុមប្រទេសដែលមានឧស្សាហកម្ម និងសេវាកម្មរីកចំរើនខ្លាំង ពោលគឺអាចឆ្លើយតបបានទាំងស្រុងទៅនឹងតម្រូវការជាមូលដ្ឋាននៃប្រជាជននៅក្នុងប្រទេសរបស់ខ្លួន។ ក្រុមនេះរួមមានបណ្ដាប្រទេសទាំងឡាយនៅអឺរ៉ុបខាងខាងលិច អាមេរិកខាងជើង ប្រទេសអូស្ត្រាលី ប្រទេសណូវែលសេឡង់ និងប្រទេសជប៉ុន។

- **ប្រទេសកំពុងអភិវឌ្ឍ**

ក្រុមនេះ ត្រូវបានគេពិពណ៌នាដោយសំដៅដល់បណ្ដាប្រទេសទាំងឡាយណាដែលមានខឿនសេដ្ឋកិច្ចរីកចម្រើនជាបង្គួរ ជាមធ្យម និងអន់ថយ ពោលគឺជាបណ្ដាប្រទេស ដែលមានឧស្សហកម្ម និងសេវាកម្មមិនសូវរីកចម្រើន និងរីកចម្រើនខ្លាំងបង្គួរ។ ក្រុមបណ្ដាប្រទេសទាំងនេះរួមមាន បណ្ដាប្រទេសឧស្សាហកម្មថ្មីមួយចំនួនដូចជា ប្រទេសចិន ប្រទេសឥណ្ឌា ប្រទេសកូរ៉េខាងត្បូង កោះតៃវ៉ាន់ ប្រទេសសិង្ហបុរី ទៅក្រុងហុងកុង ប្រទេសម៉ាលេស៊ី ប្រទេសឥណ្ឌូណេស៊ី បណ្ដាប្រទេសនៅទ្វីបអាមេរិកខាងត្បូង បណ្ដាប្រទេសនៅទ្វីបអាហ្វ្រិក បណ្ដាប្រទេសអឺរ៉ុបខាងកើត និងបណ្ដាប្រទេសអាស៊ី លើកលែងតែប្រទេសជប៉ុនចេញ។

### ខ. លោកខាងជើង និងលោកខាងត្បូង

មកដល់ទសវត្សរ៍ឆ្នាំ ១៩៧០ ពិភពលោកត្រូវបានបែងចែកសារជាថ្មីម្ដងទៀត តែការបែងចែកនេះមានលក្ខណៈវិនិច្ឆ័យ ដោយផ្អែកលើកម្រិតអភិវឌ្ឍរបស់ប្រទេសនីមួយៗ ដូចការបែងចែករបស់អង្គការ **OECD** ដែរ ពោលគឺភាពប្រសើរផ្នែកប្រជាសាស្ត្រ ភាពប្រសើរផ្នែកសេដ្ឋកិច្ច និងភាពប្រសើផ្នែកសេវាសង្គម។ អ្នកដែលបានផ្ដួចផ្ដើមគំនិតនាំឱ្យមានការបែងចែកពិភពលោកសារជាថ្មីឡើងវិញនេះ គឺលោក **Willy Brandt**

ដែលជាអ្នកសេដ្ឋកិច្ចផង និងជាអធិការវតីរបស់ប្រទេសអាឡឺម៉ង់ផង។ ការបែងចែកនេះ ត្រូវបានធ្វើឡើងនៅដើមឆ្នាំ១៩៧០ ក្នុងសម័យកាលសង្គ្រាមត្រជាក់ បន្ទាប់ពីសង្គ្រាមលោកលើកទី ២។

- **លោកខាងជើង** (The North)

ជាទូទៅ លោកខាងជើងត្រូវបានគេពិពណ៌នាដល់បណ្តាប្រទេសទាំងឡាយណា ដែលមានខឿនសេដ្ឋកិច្ចរីកចម្រើនខ្លាំងនៅលើពិភពលោក ពោលមានការរីកចម្រើនលើគ្រប់ផ្នែកទាំងអស់ ហើយអាចឆ្លើយតបនឹងតម្រូវការសង្គមជាមូលដ្ឋាន នៃប្រជាជនរបស់ខ្លួនបានដូចជា តម្រូវការផ្នែកសេដ្ឋកិច្ច តម្រូវការផ្នែកប្រជាសាស្ត្រ តម្រូវការផ្នែកសេវាសង្គម និងផ្នែកបរិស្ថានជាដើម។ ក្រុមប្រទេសទាំងនេះជាបណ្តាប្រទេសអភិវឌ្ឍ ដែលមានសន្ទស្សន៍អភិវឌ្ឍមនុស្សខ្ពស់។

***រូបភាពលោកខាងជើង និងលោកខាងត្បូង***




ប្រទេសអភិវឌ្ឍ (ប្រទេសឧស្សាហកម្ម) ប្រទេសកំពុងអភិវឌ្ឍ (លំដាប់ខ្ពស់ បង្គួរ និងមធ្យម) ប្រទេសក្រីក្រ

*ប្រភព ៖ សៀវភៅភូមិវិទ្យាមនុស្ស និងការអភិវឌ្ឍឆ្នាំ ២០១៨*

- **លោកខាងត្បូង** (The South)

ជាទូទៅ លោកខាងជើងត្រូវបានគេពិពណ៌នាដល់បណ្តាប្រទេសទាំងឡាយណា ដែលមានខឿនសេដ្ឋកិច្ចរីកចម្រើនជាបង្គួរ ឬមធ្យម ឬអន់ថយ ពោលជាក្រុមប្រទេសដែលមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការជាមូលដ្ឋាននៃប្រជាជនរបស់ខ្លួន។ បណ្តាប្រទេសទាំងនេះ គឺជាបណ្តាប្រទេស កំពុងអភិវឌ្ឍ ដែលរួមមានដូចជាប្រទេសឧស្សាហកម្មថ្មីមួយចំនួន ប្រទេសនាំប្រេងកាតចេញមួយចំនួន និងបណ្តាប្រទេសក្រីក្រនានានៅលើពិភពលោក ។

តាមពិតទៅ ការបែងចែកនេះបានបង្ហាញនូវស្ថានភាពមួយដ៏សាំញ៉ាំ និងមានការវិវត្តន៍យ៉ាងលឿន។ ក៏ប៉ុន្តែគេនៅតែបន្តប្រើសញ្ញាណ ៖ "លោកខាងជើង និងលោកខាងត្បូង" ដោយបញ្ជាក់យ៉ាងច្បាស់ថា ខ្សែវណ្ឌវាងលោកទាំងពីរនេះ ពុំមែនជាខ្សែអេក្វាទ័រភូមិសាស្ត្រនោះទេ។ វាគ្រាន់តែជាខ្សែសន្មត់មួយ ដែលបានគូសឡើងដោយលោក Willy Brandt (Brandt Map Line) សម្រាប់សម្គាល់លោកខាងជើង និងលោកខាងត្បូងតែប៉ុណ្ណោះ។

សញ្ញាណ ៖ ការអភិវឌ្ឍ (The Development) ដែលគេប្រើជាញឹកញាប់មានន័យខុសគ្នាពីភោគទ្រព្យ "Asset" ឬកំណើនសេដ្ឋកិច្ច។ បើតាមភូមិវិទូ **ស៊ីលវី ប្រ៊ុយណែល** «Sylvie Brunel» ពាក្យការអភិវឌ្ឍ គឺជាសមត្ថភាពនៃសង្គមមួយដែលបំពេញបានតាមសេចក្តីត្រូវការសំខាន់ៗនៃប្រជាជនរបស់ខ្លួន ហើយដែលនាំឱ្យគេទទួលបាននូវភាពរីកចម្រើន និងភាពល្អប្រសើរណៃនៃសុខភាព ដែលចាំបាច់ដល់ការរីកមុខមាត់របស់គេ។

## ២. រង្វាស់វិសមភាពនៃការរីកលូតលាស់

គេអាចវាស់វែងពីវិសមភាពនេះបាន ដោយគេប្រើនូវគោលសំខាន់ៗ ឬសូចនាករជាច្រើនផ្សេងៗគ្នា ដើម្បីឱ្យដឹងពីប្រទេសលោកខាង "ជើង" និងលោកខាង "ត្បូង" ឬប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ។ គោល ឬសូចនាករសំខាន់ៗទាំងនោះរួមមានដូចខាងក្រោម ៖

### ២.១. គោល ឬសូចនាករប្រជាសាស្ត្រ

ដើម្បីវាស់វែងឱ្យដឹងពីកម្រិតរីកលូតលាស់របស់បណ្តាប្រទេសនីមួយៗនៅលើពិភពលោក គេបានប្រើគោល ឬសូចនាករជាច្រើនខុសគ្នា ក៏ប៉ុន្តែនៅក្នុងនោះក៏រួមមានគោល ឬសូចនាករប្រជាគណន៍ឬប្រជាសាស្ត្រផងដែរ។ នៅក្នុងគោល ឬសូចនាករនេះ គេបានធ្វើការអង្កេតទៅលើ ៖

- អាយុសង្ឃឹមរស់
- អត្រាជាតិប្រមាណ
- អត្រាមរណប្រមាណ
- អត្រាមរណៈកុមារ
- អត្រាមរណៈមាតា
- អត្រាកំណើនធម្មជាតិ
- ទំរង់តាមអាយុ និតាមភេទ
- អត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រី
- អត្រារបេកក្រុង
- អត្រាចំណាកស្រុក។

តាមរយៈការសង្កេតមើលលើគោល ឬសូចនាករប្រជាសាស្ត្រនេះ អាចឱ្យគេដឹងបានពីកម្រិតរីកលូតលាស់របស់បណ្តាប្រទេសនីមួយៗនៅលើពិភពលោកបាន។

### ២.២. គោល ឬសូចនាករសេវាសង្គម ឬការបំពេញតម្រូវការសំខាន់ៗ

ក្រៅពីគោល ឬសូចនាករខាងលើ គេអាចវាស់វែង ឬពិនិត្យមើលពីកម្រិតអភិវឌ្ឍរបស់ប្រទេសនីមួយៗបាន តាមរយៈការអង្កេតមើលលើការផ្គត់ផ្គង់សេវាសង្គម ឬការបំពេញតម្រូវការសំខាន់ៗរបស់ប្រទេសទាំងនោះ។ គោល ឬសូចនាករសេវាសង្គម ឬការបំពេញតម្រូវការទាំងនោះរួមមានដូចជា ៖

**ក. ស្បៀងអាហារ**

នៅបណ្តាប្រទេសលោកខាង "ជើង" ស្បៀងអាហារសម្រាប់មនុស្សបរិភោគមានបរិបូណ៌ និងសម្បូរបែប ហើយមានគុណភាព។ នៅក្នុងបណ្តាប្រទេសខាង "ត្បូង" មានមនុស្ស ៤៥០ លាននាក់ បានជួបប្រទះនូវការខ្វះខាតស្បៀងជារៀងរាល់ឆ្នាំ (កង្វះជាតិប្រូតេអ៊ីន ខ្វះជីជាតិ)។ ក៏ប៉ុន្តែ គ្រោះទុរ្ភិក្សបានផុតរលត់ស្ទើរតែអស់ ឬអស់ លើកលែងតែក្នុងករណីពិសេសខ្លះៗដែលទាក់ទងទៅនឹងព្រឹត្តិការណ៍នយោបាយ ប៉ុណ្ណោះ (សង្គ្រាមនៅអាហ្វ្រិក) ឬគ្រោះធម្មជាតិ។

**ខ. ការថែទាំផ្នែកវេជ្ជសាស្ត្រ**

ផ្នែកវេជ្ជសាស្ត្រនៅក្នុងបណ្តាប្រទេសលោកខាងត្បូង នៅមានកម្រិតទាបនៅឡើយ ទាំងបរិមាណ និងគុណភាព។ ផ្ទុយទៅវិញ ផ្នែកវេជ្ជសាស្ត្រនៅបណ្តាប្រទេសអភិវឌ្ឍមានការរីកចម្រើនយ៉ាងខ្លាំងក្លាទាំងបរិមាណ និងគុណភាព។ មន្ទីរពេទ្យ និងមណ្ឌលថែទាំសុខភាពនានាត្រូវបានគេស្ថាបនាឡើងស្ទើរតែគ្រប់ទីកន្លែងទាំងអស់នៅទូទាំងប្រទេស រីឯចំនួនគ្រូពេទ្យវិញក៏មានចំនួនកើនឡើងច្រើន លើសលប់ផងដែរ។ ប្រសិនបើគេធ្វើផលធៀបចំនួនគ្រូពេទ្យជាមួយនឹងចំនួនប្រជាជន នៅក្នុងបណ្តាប្រទេសទាំងនេះវិញ គេនឹងសង្កេតឃើញថាមានចំនួនគ្រូពេទ្យជាមធ្យមចាប់ពី ២ ទៅ ៣នាក់ នៅលើចំនួនប្រជាជន ១០០០ នាក់។ រីឯនៅក្នុងបណ្តាប្រទេសលោកខាងត្បូងវិញ ចំនួននេះបានធ្លាក់ចុះមកដល់រហូតត្រឹមពីចន្លោះ ០.៣ ទៅ ០.៥ នាក់ នៅលើចំនួនប្រជាជន ១០០០ នាក់។

**គ. ការថែទាំផ្នែកវេជ្ជសាស្ត្រ**

អនក្ខរជននៅមានចំនួនច្រើនលើសលប់ នៅក្នុងបណ្តាប្រទេសលោកខាងត្បូង លើកលែងតែប្រទេសគុយបាចេញ។ រីឯការសិក្សានៅមធ្យមសិក្សា និងឧត្តមសិក្សាវិញ ក៏នៅមានកម្រិតទាបណាស់ផងដែរ។ ចំនួនកាសែត និងសៀវភៅប្រហែល ៣/៤ គឺបានមកពីបណ្តាប្រទេសលោកខាងជើង ដែល នៅទីនោះចំនួនអនក្ខរជនស្ទើរតែគ្មានសោះ។ រីឯសាលារៀនវិញចាប់ពីបឋមសិក្សារហូតដល់ថ្នាក់ឧត្តម សិក្សាត្រូវបានគេស្ថាបនាឡើងច្រើនឥតគណនា ជាពិសេសចំនួនសាកលវិទ្យាល័យ និងវិទ្យាស្ថាននានាបានរីកដុះដាលដូចផ្សិត ដែលមានលក្ខណៈផ្ទុយគ្នាស្រឡះពីបណ្តាប្រទេសលោកខាងត្បូង។ ចំពោះឧបករណ៍ និងសម្ភារៈសិក្សាទៀតសោត នៅបណ្តាប្រទេសលើកខាងជើង ក៏មានលក្ខណៈទំនើប និងសម្បូរបែបជាងបណ្តាប្រទេសលោកខាងត្បូងផងដែរ។

**ឃ. ផ្នែកសេវាមូលដ្ឋាន**

ផ្នែកសេវាមូលដ្ឋាននេះ នៅមានភាពអន់ថយច្រើននៅក្នុងបណ្តាប្រទេសលោកខាងត្បូង តែក៏មានបណ្តាប្រទេសខ្លះ ផ្គត់ផ្គង់លើផ្នែកនេះបានយ៉ាងល្អប្រសើរផងដែរនាពេលបច្ចុប្បន្ន។ ផ្ទុយទៅវិញនៅលោក

ខាងជើង ផ្នែកនេះគឺត្រូវបានគេផ្តត់ផ្គង់បានយ៉ាងល្អប្រសើរខ្លាំងណាស់ ពោលគឺប្រជាជននៅក្នុងលោកខាងជើង បានទទួលនូវសេវាទាំងនេះយ៉ាងសម្បូរបែបបំផុត។

### ២.៣. គោល ឬសូចនាករសេដ្ឋកិច្ច

បណ្តាប្រទេសលោកខាងត្បូង មានអត្រាអ្នកអត់ការងារធ្វើខ្ពស់ ហើយប្រជាជនសកម្មត្រូវបានកត់សម្គាល់ គឺកសិករនៅជនបទមានចំនួនច្រើនលើសលប់ ក៏ប៉ុន្តែផលិតផលបានតិច រីឯនៅក្នុងបណ្តាប្រទេសលោកខាងជើងវិញ មានបាតុភូតផ្ទុយពីនេះទៅវិញ។ ឧទាហរណ៍ ៖ នៅប្រទេសអង់គ្លេស ផ្នែកសកម្មភាពទី ១ (The first Section) មាន ២% នៃប្រជាជនសកម្ម ចំណែកឯនៅប្រទេសឥណ្ឌាវិញមានរហូតដល់ ៦១,៦%។ ផ្នែកសកម្មភាពទី ២ (The Second Section) ប្រជាជនសកម្មធ្វើការនៅក្នុងរោងចក្រឧស្សាហកម្មតិចតួចណាស់ គឺមានចំនួនលើសពី ១៥% នៅក្នុងបណ្តាប្រទេសលោកខាងត្បូង (ឥណ្ឌាមាន ១៧,១%) ចំណែករីឯនៅក្នុងបណ្តាប្រទេសលោកខាងជើងវិញ ចំនួននេះស្ថិតនៅចន្លោះចាប់ពី ២៥ ទៅ ៣០% (ប្រទេសអង់គ្លេសមាន ២៧.៣%)។

តម្លៃបន្ថែមនៃឧស្សាហកម្ម សម្រាប់មនុស្សម្នាក់ៗនៅក្នុងបណ្តាប្រទេសលោកខាងជើង គឺមានកម្រិតខ្ពស់ជាងបណ្តាប្រទេសលោកខាងត្បូងឆ្ងាយណាស់។ បើមានរោងចក្រឧស្សាហកម្ម គឺបានផ្តល់ផលិតផលទៅតាមបច្ចេកវិទ្យាទាប (ឧទាហរណ៍ដូចជា ខាងវាយនភ័ណ្ឌជាដើម)។ ប៉ុន្តែក៏មានប្រទេសខ្លះនៃលោកខាងត្បូងបានក្លាយទៅជាមហាអំណាចនុយក្លេអ៊ែរ មហាអំណាចសេដ្ឋកិច្ច និងមហាអំណាចបច្ចេកវិទ្យាផងដែរដូចជា ប្រទេសឥណ្ឌា ប្រទេសប៉ាគីស្ថាន និងប្រទេសចិនជាដើម។ ផ្នែកសកម្មភាពទី ៣ ដែលមានភាពទំនើប (ពាណិជ្ជកម្ម ធនាគារ ទូរគមនាគមន៍) ក៏ពុំសូវជាសំខាន់ប៉ុន្មានដែរ គឺមានភាពផ្ទុយគ្នាពីនៅលោកខាងជើង។

ម៉្យាងទៀត បើនិយាយអំពីទ្រព្យសម្បត្តិប្រើប្រាស់ប្រចាំគ្រួសារនីមួយៗវិញ ក្រុមបណ្តាប្រទេសលោកខាងជើង តែងតែមានទ្រព្យសម្បត្តិប្រើប្រាស់នៅក្នុងគ្រួសាររបស់ខ្លួន ច្រើនជាងគ្រួសារនៃក្រុមបណ្តាប្រទេសខាងត្បូង។ យោងទៅតាមការប្រៀបធៀបពីសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនក្នុងគ្រួសារ នៃក្រុមបណ្តាប្រទេសលោកខាងជើង និងលោកខាងត្បូង ដែលរួមមានដូចជា រថយន្ត ទូរទស្សន៍ វិទ្យុ ទូរស័ព្ទ និងកុំព្យូទ័របានបង្ហាញថា គ្រួសារនៃក្រុមបណ្តាប្រទេសលោកខាងជើង មានការប្រើប្រាស់ឈានមុខជាងក្រុមគ្រួសារនៃបណ្តាប្រទេសលោកខាងត្បូង។

ថ្វីត្បិតតែមានការរីកចម្រើន ដែលមិនអាចប្រកែកបានទាក់ទងទៅនឹងកំណើនសេដ្ឋកិច្ច ដែលជួនកាលមានសំទុះយ៉ាងលឿន នៅក្នុងបណ្តាប្រទេសលោកខាងត្បូងក៏ដោយ ប៉ុន្តែនៅមានភាពខុសគ្នាយ៉ាងច្រើនរវាងបណ្តាប្រទេសលោកខាងត្បូង និងបណ្តាប្រទេសលោកខាងជើងផងដែរ។ បើគេធ្វើការពិនិត្យ និងវិភាគទៅលើផលិតផលក្នុងស្រុកសរុបដុល (GDP) ឬផលិតផលជាតិសរុបដុល (GNP) របស់បណ្តាប្រទេសលោកខាងជើង និងបណ្តាប្រទេសលោកត្បូងវិញវិញ តាមរយៈរង្វាស់ផងដែរនេះគេសង្កេតឃើញមានភាពខុសគ្នាឆ្ងាយណាស់។ បណ្តាប្រទេសលោកខាងជើង គឺតែងតែឈានមុខបណ្តាប្រទេសលោកខាងត្បូងជានិច្ច ពោលគឺបណ្តាប្រទេសលោកខាងជើងមានផលិតផលសរុប ឬផលិតផលជាតិសរុប ខ្ពស់ជាងបណ្តាប្រទេសលោកខាងត្បូង។ នេះបញ្ជាក់ឱ្យឃើញថា ល្បឿនសេដ្ឋកិច្ចរបស់បណ្តាប្រទេសលោកខាងជើង មានការ

រីកចម្រើនខ្លាំង ហើយមានលំនឹង រីឯល្បឿនសេដ្ឋកិច្ចរបស់បណ្ដាប្រទេសលោកខាងត្បូងវិញពុំសូវមានការរីកចម្រើនឡើយ ហើយគ្មានលំនឹង ជាពិសេសតែងតែទទួលរងនូវវិបត្តិសេដ្ឋកិច្ចជាញឹកញាប់ថែមទៀតផង។

ទោះបីជាវង្វាស់ ដោយប្រើគោលសេដ្ឋកិច្ច (គិតលើ GDP ឬ GNP) អាចអោយគេដឹងពីកម្រិតរីកលូតលាស់របស់បណ្ដាប្រទេសលោកខាងជើង និងលោកខាងត្បូងក៏ដោយ ក៏គោល ឬសូចនាករនេះពុំទាន់មានភាពពេញលេញ និងភាពសុក្រិត ចំពោះកម្រិតជីវភាពនៃប្រជាជននៃបណ្ដាប្រទេសនីមួយៗនោះឡើយ ពីព្រោះវាគ្រាន់តែមធ្យមភាគ ដែលមិនបានយកវិសមភាពផ្ទៃក្នុង ភាពខុសគ្នានៃតម្លៃទំនិញ និងភាពខុសគ្នារវាង GDP និង GNP របស់បណ្ដាប្រទេសលោកខាងជើង និងលោកខាងត្បូងមកបង្ហាញនោះឡើយ។ ហេតុដូចនេះហើយ ទើបអង្គការសហប្រជាជាតិហៅកាត់ថា (UN : United Nation) បានបង្កើតឡើងនូវសន្ទស្សន៍មួយទៀតហៅថា កម្លាំងការទិញ (Product Power Parity) ដែលបានគិតគូរយ៉ាងជិតដល់លើផលិតផលសរុបក្នុងស្រុកពិតប្រាកដ (Real GDP ឬ GNP) សម្រាប់ប្រទេសនីមួយៗ និងប្រជាជនម្នាក់ៗ។ ឧទាហរណ៍ ៖ ប្រជាជនកម្ពុជាម្នាក់ អាចរស់នៅបានយ៉ាងសមរម្យបំផុតជាមួយនឹងទឹកប្រាក់ ៤០០០ ដុល្លាអាមេរិក ក្នុងរយៈពេលមួយឆ្នាំ ប៉ុន្តែសម្រាប់ប្រជាជនអាមេរិកវិញ គឺមិនអាចរស់នៅបានឡើយជាមួយនឹងទឹកប្រាក់ប៉ុណ្ណឹងសម្រាប់រយៈពេលមួយឆ្នាំ។

ខាងក្រោមនេះ គឺជាការប្រៀបធៀបផលិតផលសរុបក្នុងស្រុកដុល សម្រាប់មនុស្សម្នាក់ៗ រវាងក្រុមប្រទេសលោកខាងជើង និងក្រុមប្រទេសលោកខាងត្បូងមួយចំនួន។ តាមរយៈតារាងប្រៀបធៀបនេះ បានបង្ហាញឱ្យឃើញថា មួយភាគធំ នៃផលិតផលសរុបក្នុងស្រុកដុលនៅលើពិភពលោក គឺបានមកពីបណ្ដាប្រទេសលោកខាងជើង ចំណែកឯផលិតផលសរុបក្នុងស្រុករបស់បណ្ដាប្រទេសលោកខាងត្បូងវិញ គឺបានចូលរួមចំណែកតែមួយផ្នែកតូចប៉ុណ្ណោះ។

នៅក្នុងឆ្នាំ ២០០៨ ភោគទ្រព្យនៅក្នុងពិភពលោកកើនដល់ ៦៤ ៩០៩ ៧០០ កោដិដុល្លាសហរដ្ឋអាមេរិក ប៉ុន្តែភោគទ្រព្យទាំងនេះមានរបាយពុំស្មើគ្នានោះឡើយ។ ៧៣,៥៨% នៃភោគទ្រព្យពិភពលោកទាំងមូល បានប្រមូលផ្ដុំនៅក្នុងប្រទេសមួយចំនួនដែលជាប្រទេសអ្នកមាននៅលើពិភពលោក រួមមានដូចជាអាមេរិកខាងជើង ទ្វីបអឺរ៉ុប (ខាងជើងខាងលិច និងខាងត្បូង និងបណ្ដាប្រទេសអឺរ៉ុបខាងកើតមួយចំនួន) ទ្វីបអូស្ត្រាលី ប្រទេសជប៉ុន ប្រទេសនាំប្រេងកាតចេញ និងបណ្ដាប្រទេសឧស្សាហកម្មថ្មីមួយចំនួននៅទ្វីបអាស៊ី (កូរ៉េខាង ត្បូង សឹង្ហបុរី តៃវ៉ាន់ ក្រុងហុងកុង ម៉ាឡេស៊ី) និងអាមេរិចខាងត្បូង (ម៉ិចស៊ិចកូ វេនុយហ្សេអូឡា ប្រេស៊ីល...) ដែលមានប្រជាជនសរុបត្រឹមតែ ៣៥% នៃចំនួនប្រជាជនពិភពលោកប៉ុណ្ណោះ។ ចំពោះបណ្ដាប្រទេសក្រីក្រដែលមានចំនួនរហូត ៦៥% នៃប្រជាជនពិភពលោក សរុបមានធនធានសរុបទាំងអស់ត្រឹមតែ ២៦.៤២% នៃធនធានពិភពលោកប៉ុណ្ណោះ។ ក្នុងចំណោមធនធានសរុបទាំងនេះ បើគិតជាមធ្យមក្នុងមនុស្សម្នាក់ៗ ធនធាននេះមានចាប់ពី ៨៦២ ដុល្លារសហរដ្ឋអាមេរិក (ប្រទេសក្រក្រី) ទៅ ៣៧ ១២២ ដុល្លារសហរដ្ឋអាមេរិក (ប្រទេសអ្នកមាន)។

## *តារាងប្រៀបធៀប GDP សម្រាប់មនុស្សម្នាក់រវាងបណ្តាប្រទេសនីមួយៗនៅឆ្នាំ ២០០៨*

| ឈ្មោះ | GDP ក្នុងមនុស្សម្នាក់ គិតជា $ | ចំនាត់ថ្នាក់ក្នុងពិភពលោក | GDP សរុបគិតជាលាន | ភាគរយនៃពិភពលោក | ធនធានក្នុងមនុស្សម្នាក់គិតជា $ | ចំនាត់ថ្នាក់ក្នុងពិភពលោក |
|---|---|---|---|---|---|---|
| អាល្លឺម៉ង់ | ២៥៥ ៨០ | ៧ | ២០៧៥៤៥ | ៨,១% | ៣៩៩,០០០ | ១៥ |
| ប៊ុលហ្គារី | ១១៦០ | | ១០២៥៥ | | ២៣,០០០ | ១១៦ |
| បារាំង | ២៣៤៧០ | ១០ | ១៣៥៥០៤ | ៥,៣% | ៤១៣,០០០ | ១៣ |
| ប៉ូឡូញ | ២៤៧០ | ៥១ | ៩៤៦១៣ | | ៥០,០០០ | ៧៧ |
| អង់គ្លេស | ១៨៤១០ | ១៩ | ១០៦៩៤៦ | ៤,២% | ៣២៤,០០០ | ២២ |
| ឆេក | ៣២១០ | ៤៤ | ៣៣០៥១ | | ៥០,០០០ | ៧៦ |
| សហរដ្ឋអាមេរិក | ២៥៨៦០ | ៦ | ៦៧៣៧៣៧ | ២៦,៣% | ៤២១,០០០ | ១២ |
| ជប៉ុន | ៣៤៦៣០ | ៣ | ៤៣២១១៤ | ១៦,៩% | ៥៦៦,០០០ | ៥ |
| អេហ្ស៊ីប | ៧១០ | ៨៣ | ៤០៩៥០ | | ១០,៦០០ | ១៤៦ |
| ម៉ាដាកាស្កា | ២៣០ | ១១៦ | ៣០៩៨ | | ៤,៥០០ | ១៧២ |
| ម៉ាលី | ២៥០ | ១១៣ | | | ៤,០០០ | ១៧៥ |
| ម៉ូរីស | ៣១៨០ | ៤៥ | | | ៤៨,០០០ | ៧៩ |
| ទុយនីស៊ី | ១៨០០ | ៦០ | ១៥៨៧៣ | | ៣១,០០០ | ១០០ |
| អាហ្សង់ទីន | ៨០៦០ | ៣០ | ២៧៥៦៦ | ១,១% | ១២០,០០០ | ៤៦ |
| ប្រេស៊ីល | ៣៣៧០ | ៤៣ | ៥៣៦៣១ | ២,១% | ៤៧,០០០ | ៨១ |
| គុយបា | | | | | ៣៥,០០០ | ៩៥ |
| ក្វាតេម៉ាឡា | ១១៩០ | ៧១ | | | ១៨,០០០ | ១២៧ |
| ម៉ិចស៊ិច | ៤០១០ | ៣៧ | ៣៦៨៦៨ | ១,៤% | ៧៤,០០០ | ៦២ |
| ចិន | ៥៣០ | | ៦៣០២០២ | | ៦,៦០០ | ១៦២ |
| ឥណ្ឌា | ៣១០ | ១០៩ | ២៧៥៧៤ | ១,១% | ៤,៣០០ | ១៧៣ |
| ប៉ាគីស្ថាន | ៤៤០ | ៩៩ | ៥៥៥៦៥ | | ៦,៨០០ | ១៦០ |
| ហុងកុង | ២១៦៥០ | ១៤ | ១២៦២៨៦ | | ៣០២,០០០ | ២៤ |

*ប្រភព ៖ របាយការណ៍របស់អង្គការ UND 2007*

- **ធនធានក្នុងមនុស្សម្នាក់ ៖** សន្ទស្សន៍នេះ បានប្រមូលផ្តុំដោយកត្តា ៣ សំខាន់ៗ គឺ ៖
  - ទ្រព្យធនផលិតផល
  - ទុនធម្មជាតិ
  - ធនធានមនុស្ស។

*តារាងប្រៀបធៀប GDP សំរាប់មនុស្សម្នាក់រវាងបណ្តាប្រទេសនីមួយៗនៅឆ្នាំ ២០១៨*

| ឈ្មោះ | GDP ក្នុងមនុស្សម្នាក់ គិតជា $ | ចំនាត់ថ្នាក់ ក្នុងពិភពលោក | GDP សរុបគិតជាកោដិ | ចំនាត់ថ្នាក់ក្នុង ពិភពលោក |
|---|---|---|---|---|
| អាល្លឺម៉ង់ | ៣៤៤០១ | ៧ | ២៨៣០,១ | ១៥ |
| ប៊ុលហ្គារី | ១១២២២ | | ៨៦០ | ១១៦ |
| បារាំង | ៣៣៦៧៤ | ១០ | ២០៧៨ | ១៣ |
| ប៉ូឡូញ | ១៥៩៨៧ | ៥១ | ៦០៩,៤ | ៧៧ |
| អង់គ្លេស | ៣៥១៣០ | ១៩ | ២៨៣០,១ | ២២ |
| ឆេក | ២៤១៤៤ | ៤៤ | ២៤៩,៥ | ៧៦ |
| សហរដ្ឋអាមេរិច | ៤៥៥៩២ | ៦ | ១៣៧៥១,៤ | ១២ |
| ជប៉ុន | ៣៣៦៣២ | ៣ | ៤២៩៧,២ | ៥ |
| អេហ្ស៊ីប | ៥៣៤៩ | ៨៣ | ៤០៣,៧ | ១៤៦ |
| ម៉ាដាកាស្កា | ៩៣២ | ១១៦ | ១៨,៣ | ១៧២ |
| ម៉ាលី | ១០៨៣ | ១១៣ | ១៣,៤ | ១៧៥ |
| ម៉ូរីស | ១១២៩៦ | ៤៥ | ១៤,២ | ៧៩ |
| ទុយនីស៊ី | ៧៥២០ | ៦០ | ៧៦,៩ | ១០០ |
| អាហ្សង់ទីន | ១៣២៣៨ | ៣០ | ៥២២,៩ | ៤៦ |
| ប្រេស៊ីល | ៩៥៦៧ | ៤៣ | ១៨៣៣ | ៨១ |
| គុយបា | | | | ៩៥ |
| ក្វាតេម៉ាឡា | ៤៥៦២ | ៧១ | ៦០,៩ | ១២៧ |
| ម៉ិចសិច | ១៤១០៤ | ៣៧ | ១៤៨៤,៩ | ៦២ |
| ចិន | ៥៣៨៣ | | ៧០៩៦,៧ | ១៦២ |
| ឥណ្ឌា | ២៧៥៣ | ១០៩ | ៣០៩៦,៩ | ១៧៣ |
| ប៉ាគីស្ថាន | ២៤៩៦ | ៩៩ | ៤០៥,៦ | ១៦០ |
| ហុងកុង | ៤២៣០៦ | ១៤ | ២៩៣ | ២៤ |

*ប្រភព ៖ របាយការណ៍របស់អង្គការ UND 2008*

## ២.៤. គោល ឬសូចនាករសន្ទស្សន៍អភិវឌ្ឍមនុស្ស

ដោយពិនិត្យឃើញថា ការលើកយកតែសូចនាករ ឬគោលណាមួយ មកវាស់អំពីកម្រិតអភិវឌ្ឍរបស់ប្រទេសនីមួយៗនៅលើពិភពលោក មិនបានឆ្លុះបញ្ចាំងពីភាពពិតប្រាកដ នៃកម្រិតអភិវឌ្ឍជាទូទៅរបស់

បណ្ដាប្រទេសទាំងនោះបាន ពោលគឺពុំមានភាពត្រឹមត្រូវ និងសុក្រិតបាននោះ ទើបនៅឆ្នាំ១៩៩០ អង្គការសហប្រជាជាតិ សម្រាប់ការអភិវឌ្ឍដែលហៅកាត់ថា UNDP (United Nation Development Program) បានបង្កើតឡើងនូវសូចនាករ ឬគោលថ្មីមួយផ្សេងទៀតឡើង គឺសូចនាករ ឬគោលអភិវឌ្ឍមនុស្ស : Human Development Index (HDI) ដោយបានទាញយកសូចនាករ ឬគោលសំខាន់ៗទាំង ៣ មកបូកបញ្ចូលគ្នា គឺសូចនាករប្រជាសាស្ត្រ សូចនាករសេដ្ឋកិច្ច និងសូចនាករសេវាសង្គម។ តាមរយៈសូចនាករថ្មីនេះ ឬតាមរយៈសូចនាករសន្ទស្សន៍អភិវឌ្ឍមនុស្សនេះបានបង្ហាញថា ៖

- នៅឆ្នាំ ១៩៩៧ គឺ ៖
  - ប្រទេសដែលមាន HDI ខ្ពស់ជាងគេបំផុត គឺប្រទេសកាណាដា ៖ ០.៩៤៨
  - ប្រទេសដែលមាន HDI ទាបជាងគេបំផុត គឺប្រទេសនីស្សេរ ៖ ០.២០៤។
- នៅឆ្នាំ ២០០០ គឺ ៖
  - ប្រទេសដែលមាន HDI ខ្ពស់ជាងគេបំផុត គឺប្រទេសណ័រវេស ៖ ០.៩៥៦
  - ប្រទេសដែលមាន HDI ទាបជាងគេបំផុត គឺប្រទេសសេរ៉ាលេអូន ៖ ០.២៧៥។
- នៅឆ្នាំ ២០០៨ គឺ ៖
  - ប្រទេសដែលមាន HDI ខ្ពស់ជាងគេបំផុត គឺប្រទេសណ័រវេស ៖ ០.៩៧២
  - ប្រទេសដែលមាន HDI ទាបជាងគេបំផុត គឺប្រទេសនីស្សេរ ៖ ០.៣២៩។

តាមរយៈ HDI នេះដែរបានបង្ហាញថា នៅឆ្នាំ ២០០៨ ក្នុងចំណោមប្រទេស ១៨២ គឺ ៖

- ប្រទេសដែលមាន HDI ខ្ពស់ជាងគេបំផុត គឺចាប់ពី ០.៩០០ ដល់ ០.៩៧១ មាន ៣៨ ប្រទេស
- ប្រទេសដែលមាន HDI ខ្ពស់បង្គួរ ចាប់ពី ០.៧០០ ដល់ ០.៨៩៩ មាន ៨៥ ប្រទេស
- ប្រទេសដែលមាន HDI មធ្យម ចាប់ពី ០.៥០០ ដល់ ០.៦៩៩ មាន ៣៥ ប្រទេស
- ប្រទេសដែលមាន HDI ទាប ចាប់ពី ០.៣២៩ ដល់ ០.៤៩៩ មាន ២៤ ប្រទេស។

- នៅឆ្នាំ ២០១៧
  - ប្រទេសដែលមាន HDI ខ្ពស់ជាងគេបំផុត គឺប្រទេសណ័រវេស ៖ ០.៩៧៨
  - ប្រទេសដែលមាន HDI ទាបជាងគេបំផុត គឺប្រទេសនីស្សេរ ៖ ០.៣៥៤។

តាមរយៈ HDI នេះដែរបានបង្ហាញថា នៅឆ្នាំ ២០១៧ ក្នុងចំណោមប្រទេស ១៨៩ គឺ ៖

- ប្រទេសដែលមាន HDI ខ្ពស់ជាងគេបំផុត គឺចាប់ពី ០.៩០០ ដល់ ០.៩៧៨ មាន ២៤ ប្រទេស
- ប្រទេសដែលមាន HDI ខ្ពស់បង្គួរ គឺចាប់ពី ០.៧០០ ដល់ ០.៨៩៩ មាន ៨៨ ប្រទេស
- ប្រទេសដែលមាន HDI មធ្យម ចាប់ពី ០.៥០០ ដល់ ០.៦៩៩ មាន ៥៥ ប្រទេស
- ប្រទេសដែលមាន HDI ទាប គឺចាប់ពី ០.៣៥៤ ដល់ ០.៤៩៩ មាន ២២ ប្រទេស។

ប៉ុន្តែប្រទេសដែលមានសន្ទស្សន៍អភិវឌ្ឍមនុស្សខ្ពស់ ភាគច្រើនគឺជាបណ្ដាប្រទេស ដែលមានកម្រិតប្រាក់ចំណូលខ្ពស់ (ភាគច្រើនប្រាក់ចំនូលទាំងនោះបានមកពីវិស័យឧស្សាហកម្ម និងសេវាកម្ម) មានកម្រិត

អប់រំខ្ពស់ អាចដោះស្រាយបាននូវបញ្ហាប្រជាសាស្ត្រ និងការបំពេញនូវតម្រូវការសំខាន់ៗ (សេវាសង្គម) របស់ប្រជាជននៃប្រទេសរបស់ពួកគេបាន។ ចំណែកឯបណ្តាប្រទេសដែលមានសន្ទស្សន៍អភិវឌ្ឍមនុស្សខ្ពស់បង្គួរ ទោះបីជាមានកម្រិតជីវភាពខ្ពស់ពិតមែន ប៉ុន្តែនៅមានបញ្ហាសង្គមខ្លះ មិនទាន់បានដោះស្រាយបានទាំងស្រុងនៅឡើយដូចជាករណី បញ្ហាប្រជាសាស្ត្រ និងបញ្ហាសេវាសង្គមជាដើម។ រីបណ្តាប្រទេសដែលមានសន្ទស្សន៍អភិវឌ្ឍមនុស្សមធ្យម និងទាបភាគច្រើនជាបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប នៅមានបញ្ហាសង្គម ជាច្រើនដែលមិនអាចដោះស្រាយបាន។

*តារាងបង្ហាញពីភាពខុសគ្នារវាងរង្វាស់សូចនាករ* ***HDI*** និងផលិតផលសរុបដុល ***GDP***




*ឧទាហរណ៍នៃភាពខ្វែងគ្នារវាង HDI & GDP នៅឆ្នាំ* 2008

*តារាងនេះ បង្ហាញឱ្យឃើញពីភាពខុសគ្នារវាង HDI និង GDP (សន្ទស្សន៍អភិវឌ្ឍមនុស្ស និងផលិតលសរុបដុល) សន្ទស្សន៍នេះមិនរាប់បញ្ចូលផងទេនូវភាពខុសគ្នាតាមតំបន់ និងសង្គមនៅក្នុងប្រទេសមួយ។ តែករណីនេះ មានភាពខុសគ្នាច្រើននៅក្នុងប្រទេសលោកខាងត្បូង ដែលមានវណ្ណៈមធ្យម មិនសូវរីកលូតលាស់។*

*តាមអ្នកជំនាញថា បណ្តាប្រទេសទាំងនេះ អ្នកមានគឺកាន់តែមានខ្លាំង រីឯអ្នកក្រវិញ គឺកាន់តែក្រខ្លាំងថែមទៀត។*

តាមរយៈតារាងខាងក្រោមនេះ បង្ហាញឱ្យឃើញពីភាពខុសគ្នារវាងការប្រើរង្វាស់តាមគោល ឬសូចនាករសេដ្ឋកិច្ច (GDP ឬ GNP) និងរង្វាស់សន្ទស្សន៍អភិវឌ្ឍមនុស្ស (HDI)។ តាមរយៈរង្វាស់ទាំងពីរនេះដែរ ប្រទេសខ្លះមានកម្រិតប្រាក់ចំណូលខ្ពស់ខ្លាំងណាស់ (បណ្តាប្រទេសនាំប្រេងកាតចេញ ប្រទេសឧស្សាហកម្មថ្មី) ប៉ុន្តែផ្ទុយទៅវិញមានសន្ទស្សន៍អភិវឌ្ឍមនុស្សមិនសូវខ្ពស់ទៅវិញ។ រីឯប្រទេសខ្លះទៀតបែរជា មានសន្ទស្សន៍

អភិវឌ្ឍមនុស្សខ្ពស់បំផុត ក៏ប៉ុន្តែមានកម្រិតប្រាក់ចំណូលមិនសូវខ្ពស់ខ្លាំងណាស់ណានោះទេករណីដូចជាប្រទេសអភិវឌ្ឍមួយចំនួន។

### ៣. លោកខាងត្បូង បានកំនត់សម្គាល់ដោយវិសមតាព

វិសមភាពដែលគេតែងតែសង្កេតឃើញកើតមានឡើង នៅក្នុងលោកខាងត្បូង គឺស្ថិតនៅក្នុងបណ្តាប្រទេសនីមួយៗ។ បណ្តាប្រទេសលោកខាងត្បូង គឺជាពិភពមួយប្លែកៗ ដោយពុំមានឯកភាពគ្នារវាងទំហំផ្ទៃដីពោលគឺខុសៗគ្នាទៅតាមបណ្តាប្រទេសតូចធំ។ លក្ខខណ្ឌធម្មជាតិនៃបណ្តាប្រទេសទាំងនេះ ក៏មានភាពខុសគ្នាដែរ រីឯប្រជាជន ការរៀបចំទីក្រុងក៏មានកម្រិតខុសគ្នា ហើយក៏មានកម្រិតខុសគ្នាទាំងខាងឧស្សាហកម្ម ការសិក្សារៀនសូត្រ និងសេវាថែទាំសុខភាពផងដែរ។ រីឯខាងផ្នែកវប្បធម៌ និងសាសនាវិញ ក៏ពុំមានភាពឯកភាពគ្នាផងដែរ ៖ ពុទ្ធសាសនា សាសនាអ៊ីស្លាម សាសនាអានីមីស គ្រឹស្តសាសនា។ ចំណែកឯរបបនយោបាយវិញក៏មានភាពខុសប្លែកៗគ្នាជាច្រើនផងដែរ។ ប្រទេសខ្លះប្រកាន់យករបបរាជាណាចក្រ សាធារណរដ្ឋ ឬរបបកុំមុយនីស្ត រីឯប្រទេសខ្លះទៀតប្រកាន់យករបបផ្តាច់ការយោធា ឬរបបប្រជាធិបតេយ្យ។

***ផែនទីបង្ហាញពីវិសមភាពនៃការអភិវឌ្ឍរវាងលោកខាងជើង និងលោកខាងត្បូង***




បច្ចុប្បន្ន តួនាទីនៃបណ្តាប្រទេសលោកខាងត្បូងនៅលើឆាកអន្តរជាតិ មានភាពប្លែកៗគ្នាទៅតាមប្រទេស ៖ ប្រទេសខ្លះបានក្លាយទៅជាប្រទេសមហាអំណាចពិតៗខាងនយោបាយ និងសេដ្ឋកិច្ច នុយក្លេអ៊ែរ និងបច្ចេកវិទ្យា (ចិន និងឥណ្ឌា)។ ជាចុងក្រោយ បណ្តាប្រទេសលោកខាងត្បូង ជួនកាលត្រូវបែងចែកដោយទំនាស់រវាងប្រទេសនីមួយៗ ឬជាទំនាស់ផ្ទៃក្នុង ៖ សង្គ្រាមនៅក្នុងស្រុកតែងកើតមានយ៉ាងសាហាវដូចជាករណី ប្រទេស Rwanda ជាដើម។

*តារាងប្រៀបធៀបពីភាពខុសគ្នានៃកម្រិតអភិវឌ្ឍរបស់ប្រទេសមួយចំនួននៅលើពិភពលោក ២០០៧*

| ប្រទេស | អាយុខ័យ | | ចំនួនគ្រូពេទ្យ ក្នុង ១០០០ ន | អនក្ខរជនគិតជាភាគរយ | សន្ទស្សអភិវឌ្ឍមនុស្ស IDH | សន្ទស្សនៃភាពមានកូន | កំនើនធម្មជាតិគិតជាភាគរយ |
|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | | | | | |
| អាឡឺម៉ង់ | ៧២ | ៧៩ | ២,៧២ | | ០,៩២៤ | ១,៣ | ០,៥៣ |
| ប៊ុលហ្គារី | ៦៨ | ៧៥ | ៣,១៧ | | ០,៧៨០ | ១,៤ | -០,៥ |
| បារាំង | ៧៤ | ៨២ | ២,៩៥ | | ០,៩៤៦ | ១,៧ | ០,៤៧ |
| ប៉ូឡូញ | ៦៨ | ៧៦ | ២,២៨ | | ០,៨៣៤ | ១,៧ | ០,៥ |
| រាជាណាចក្ររ៉ូម | ៧៤ | ៧៩ | ១,៥០ | | ០,៩៣១ | ១,៧ | ០,២ |
| ឆេក | ៧០ | ៧៧ | ៣,៦៦ | | ០,៨៨២ | ១,៤ | -០,១ |
| សហរដ្ឋអាមេរិច | ៧២ | ៧៩ | ២,៣៨ | | ០,៩៤២ | ២ | ០,៩៨ |
| ជប៉ុន | ៧៧ | ៨៣ | ១,៦៤ | | ០,៩៤០ | ១,៥ | ០,២ |
| អេស៊្សីប | ៦២ | ៦៥ | ០,៧៦ | ៤៨,៦ | ០,៦១៤ | ៣,៦ | ២ |
| ម៉ាដាកាស្កា | ៥៥ | ៥៨ | ០,១២ | ១៩,៨ | ០,៣៥០ | ៦,១ | ៣,៣ |
| ម៉ាលី | ៤៤ | ៤៨ | ០,០៥ | ៦៩ | ០,២២៩ | ៧,៣ | ៣,២ |
| ម៉ូរីស | ៦៥ | ៧៣ | ០,៨៥ | ១៧,១ | ០,៨៣១ | ២,៤ | ១,១ |
| ទុយនីស៊ី | ៦៧ | ៦៩ | ០,៥៧ | ៣៣,៣ | ០,៧៤៨ | ៣,៤ | ១,៩ |
| អាហ្សង់ទីន | ៦៩ | ៧៦ | ៣,០៣ | ៣,៨ | ០,៨៩៤ | ២,៧ | ១,៣ |
| ប្រេស៊ីល | ៦៤ | ៦៩ | ១,១៨ | ៧,៧ | ០,៧៨៣ | ២,៨ | ១,៤១ |
| គុយបា | ៧៣ | ៧៧ | ៥,១៩ | ៤,៣ | ០៧២៣ | ១,៥ | ០,៦ |
| ក្វាតេម៉ាឡា | ៦៤,៨ | ៦៤, | ០,២៥ | ៤៤,៤ | ០,៥៧២ | ៥,៣៦ | ១,២ |
| ម៉ិចស៊ិច | ៧០ | ៨ | ១,៦៤ | | ០,៨៤៣ | ៣,១ | ១,៨ |
| កម្ពុជា | ៤៨ | ៧៦ | | ៣៤,៧ | ០,៣៤៨ | ៤,៨៩ | ២,៨ |
| ចិន | ៦៨ | ៥១ | ០,៩៤ | ១៨,៥ | ០,៦២៦ | ១,៨ | ១,១ |
| ហុងកុង | ៧៥ | ៧២ | ០,៩៣ | ៧,៨ | ០,៩១៤ | ១,២ | ១,៤ |
| ឥណ្ឌា | ៥៨ | ៨១ | ០,៤១ | ៤,៨ | ០,៤៤៦ | ៣,៤ | ១៧៦ |
| ប៉ាគីស្ថាន | ៦១ | ៥៩ | ០,៥២ | | ០,៤៤៥ | ៥,៦ | ២,៧ |
| | | ៦១ | | | | | |

*ប្រភព ៖ របាយការណ៍របស់អង្គការ UND 2008*

ជាទូទៅ គេអាចបែងចែកប្រទេសទាំងនេះជា ៥ ក្រុមគឺ ៖

### ៣.១. ប្រទេសក្រីក្រ

បណ្តាប្រទេសទាំងនេះ ភាគច្រើនគឺស្ថិតនៅទ្វីបអាព្រិច និងអាស៊ី។ ផលិតផល និងលំនាំចេញរបស់គេ គឺភាគច្រើនបានមកពីផ្នែកសកម្មភាពទី១ ជាពិសេសផ្នែកកសិផល និងធនធានរ៉ែ។ សព្វថ្ងៃ ផលិតផលទាំងនេះ មានតួនាទីកាន់តែពុំសូវសំខាន់ប៉ុន្មាននោះទេនៅលើទីផ្សារពិភពលោក។ កំណើន សេដ្ឋកិច្ចរបស់បណ្តាប្រទេសទាំងនេះមានភាពយឺតយ៉ាវ ហើយជំពាក់បំណុលបរទេសក៏ច្រើន។ ប្រទេសទាំងនេះ បានជួបប្រទះ នូវគ្រប់លក្ខខណសង្គមនៃភាពអន់ថយ។

### ៣.២. ប្រទេសឧស្សាហកម្មថ្មី

បណ្តាប្រទេសទាំងនេះមានប្រហែល ២០ ហើយមានទីតាំងស្ថិតនៅទ្វីបអាមេរិក ដូចជា ប្រទេសម៉ិចស៊ិច និងប្រទេសប្រេស៊ីល។ នៅទ្វីបអាស៊ីមានដូចជា ប្រទេសសិង្ហបុរី ប្រទេស កូរ៉េខាងត្បូង ប្រទេសម៉ាលេស៊ី កោះហុងកុង ប្រទេសថៃ ប្រទេសតៃវ៉ាន់ ប្រទេសឥណ្ឌូនេស៊ី ប្រទេសអារ៉ាប់រួម និងប្រទេសហ្វីលីពីនជាដើម។ កំណើនសេដ្ឋកិច្ចរបស់បណ្តាប្រទេសទាំងនេះលឿនណាស់ ប៉ុន្តែជួនកាលមានមិនស្ថិតស្ថេរ (ឆ្នាំ១៩៩៨ មានវិបត្តិយ៉ាងធ្ងន់ធ្ងរដូចជាប្រទេសថៃ ប្រទេសកូរ៉េខាងត្បូង ប្រទេសម៉ាលេស៊ី)។ សកម្មភាពសេដ្ឋកិច្ចរបស់បណ្តាប្រទេសទាំងនេះបានបើកទ្វារយ៉ាងធំទូលាយ សំដៅទៅលើពាណិជ្ជកម្មក្រៅប្រទេស ហើយនាំចេញជាពិសេសនូវផលិតផលប្រើប្រាស់សម្រេច។ ប៉ុន្តែ នៅមានគោលលក្ខខណ្ឌសង្គមជាច្រើនទៀតដែលបានដាក់បណ្តាប្រទេសទាំងនេះ ឱ្យស្ថិតនៅឆ្ងាយពីបណ្តាប្រទេសឧស្សហកម្មចាស់នៃលោកខាងជើង។

### ៣.៣. ប្រទេសនាំចេញអ៊ីដ្រូកាបួរ

បណ្តាប្រទេសទាំងនេះ គឺជាក្រុមប្រទេសដែលទាញយកកម្រៃបានយ៉ាងខ្ពស់ពីការលក់ប្រេងកាត និងឧស្ម័នធម្មជាតិរបស់ខ្លួន។ កំណើនសេដ្ឋកិច្ច បានកើតមានឡើងយ៉ាងគំហុក ជាពិសេសចាប់ពីឆ្នាំ១៩៧០ មក។ បណ្តាប្រទេសទាំងនេះ ជួនកាលបង្កើតបាននូវឧស្សាហកម្ម និងការរៀបចំទីក្រុងបានយ៉ាងប្រណីតដូចជាករណី នៅប្រទេសវេណេយអេឡា ប្រទេសនីសេរីយ៉ា ប្រទេសស៊ុលតាណា ប្រទេសអារ៉ាប់រួម ប្រទេសកាតា ប្រទេសអៀរ៉ង់ ប្រទេសអារ៉ាប៊ីសាអ៊ូឌីត...។ ក៏ប៉ុន្តែ ក្នុងចំណោមបណ្តាប្រទេសទាំងនេះមានប្រទេសខ្លះ ដែលមានផលិតផលជាតិសរុប GNP ឬផលិតផលសរុបផុល GDP សម្រាប់មនុស្សម្នាក់ៗឡើងខ្ពស់នោះ នៅតែរក្សាទុកនូវទម្រង់សង្គមតាមបែបប្រពៃណីនៅឡើយ រហូតដល់សព្វថ្ងៃនេះ (បណ្តាប្រទេសមួយចំនួននៅតំបន់មជ្ឈឹមបូព៌ា)។

### ៣.៤. ប្រទេសនៅចន្លោះកណ្តាល (រវាងអ្នកក្រ និងអ្នកមាន)

ក្រុមប្រទេសទាំងនេះមានស្ថានភាពប្លែកៗទាក់ទងទៅនឹងសក្តានុពលភាព និងមានប្រវត្តិសាស្ត្រប្លែកៗនៃប្រទេសនីមួយៗ។ កំណើនសេដ្ឋកិច្ច និងកម្រិតជីវភាពប្រជាជនខុសគ្នាច្រើនណាស់ទៅតាមកាលៈទេសៈ។

### ៣.៥. ប្រទេសឥណ្ឌា និងចិន

ប្រទេសទាំងពីរនេះ មានស្ថានភាពពិសេស ដោយសំអាងទៅលើទំហំដ៏ធំធេងនៃផ្ទៃដី ចំនួនច្រើននៃប្រជាជន វិធីអភិវឌ្ឍលើភោគទ្រព្យយ៉ាងស្មុកស្មាញរបស់ខ្លួន និងលើសមត្ថភាពទីផ្សារក្នុងប្រទេស។ ប្រទេសចិនជាប្រទេសប្រជាធិបតេយ្យប្រជាមានិត (របបកុំមុយនីស្ត) ដែលមានការកែប្រែ និងផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចតាមបែបសហគ្រាសទីផ្សារសេរី និងបើកទ្វារចំហទៅក្រៅប្រទេស។ ប្រទេសឥណ្ឌាជាប្រទេសប្រជាធិបតេយ្យ (ប្រទេសទី១ នៃបណ្តាប្រទេសលោកខាងត្បូង) ដែលបន្ទាប់ពីបានអនុវត្តសេដ្ឋកិច្ចតាមបែបសង្គមនិយម (ផែនការកម្ម សមូហកម្មរដ្ឋ) ក៏បានផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ខ្លួនមកតាមបែបទីផ្សារសេរីវិញ។

## ៤. ការកាត់បន្ថយវិសមតាពរវាងលោកខាងជើង និងលោកខាងត្បូង

### ៤.១. ដោយបង្កើតលក្ខខណ្ឌខាងពាណិជ្ជកម្មអន្តរជាតិត្រឹមត្រូវ

បច្ចុប្បន្ន ការធ្វើពាណិជ្ជកម្មនៅលើពិភពលោក ជារឿយៗ គឺជាកត្តាមួយធ្វើឱ្យរិតតែមានភាព កាន់តែក្រីក្រឡើងៗ ដល់បណ្តាប្រទេសលោកខាងត្បូង លើកលែងតែបណ្តាប្រទេសសម្បូរប្រេងកាត ឬប្រទេស

ឧស្សាហកម្មថ្មីៗខ្លះចេញតែប៉ុណ្ណោះ ដែលគេមានលទ្ធភាពនាំចេញ នូវផលិតផលកម្មមន្តសាលរបស់ខ្លួន។ បណ្ដាប្រទេសលោកខាងត្បូងភាគច្រើន នៅតែជាប្រទេសអ្នកនាំចេញនូវផលិតផលដើម ឬរូបធាតុដើម (កសិផល និងធនធានរ៉ែ) ដែលមិនទាន់មានការផ្លាស់ប្ដូរពីសភាពដើមនៅឡើយ។ ឯតម្លៃវិញទៀតសោតក៏មិនបានខ្ពស់ ហើយត្រូវបានកំណត់ដោយអ្នកទិញដែលដាក់តម្លៃយ៉ាងទាបបំផុត តាមអ្វីដែលគេអាចធ្វើទៅបាន។ ជាមួយគ្នានេះដែរ បណ្ដាប្រទេសអ្នកមានគេក៏មានផលប្រយោជន៍ផងដែរ ដោយសារតែការលក់ទៅឱ្យបណ្ដាប្រទេសពុំមានឧស្សាហកម្មជឿនលឿនវិញនូវផលិតផលឧស្សាហកម្មយ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយលក់ក្នុងតម្លៃខ្ពស់។

រយៈពេល ២៥ ឆ្នាំកន្លងមកនេះ អង្គការសហប្រជាជាតិបានខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យបាននូវតារាងតម្លៃទំនិញមួយយ៉ាងត្រឹមត្រូវ សម្រាប់ទំនិញជាវត្ថុធាតុដើមដែលលក់ដោយក្រុមប្រទេសលោកខាងត្បូង និងផ្ដល់ជំនួយឧស្សាហូបនីយកម្មដល់បណ្ដាប្រទេសទាំងនោះ។

នៅក្នុងក្របខណ្ឌសហភាពសេដ្ឋកិច្ចអឺរ៉ុប កិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខានៅឆ្នាំ១៩៧៥ នៅក្រុងឡូម៉េ (ប្រទេសតូហ្គោ) ដែលមានប្រទេសចំនួន ៦៦ នៃទ្វីបអាហ្វ្រិក ប្រទេសតំបន់ការ៉ាអ៊ីប និងតំបន់ប៉ាស៊ីភិច អនុញ្ញាតិដល់លំនាំចេញនូវផលិតផលនៃបណ្ដាប្រទេសទាំងនោះ ទៅកាន់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប ដោយពុំចាំបាច់មានការបង់ពន្ធគយឡើយ។

មានការជឿនលឿនជាច្រើន ដែលសម្រេចបាន ប៉ុន្តែអាស្រ័យដោយកង្វះសាមគ្គីភាព នៃបណ្ដាប្រទេសលោកខាងត្បូង ដែលជាផលិតករផលិតវត្ថុធាតុដើម បានធ្វើឱ្យមានភាពទន់ខ្សោយ បើធៀបទៅនឹងតម្រូវការទិញយ៉ាងច្រើនពីបណ្ដាប្រទេសលោកខាងជើង។

### ៤.២. ដោយជំរុញនូវបណ្ដូររវាងបណ្ដាប្រទេសលោកខាងត្បូង

បណ្ដាប្រទេសលោកខាងត្បូងខ្លះ ដែលមានឧស្សាហកម្ម សេវាកម្ម និងបច្ចេកវិទ្យាជឿនលឿនគួរតែលក់នូវផលិតផលរបស់ខ្លួនទៅឱ្យបណ្ដាប្រទេសលោកខាងត្បូងដទៃទៀត ដែលមានឧស្សាហកម្ម សេវាកម្ម និងបច្ចេកវិទ្យាមិនសូវជឿនលឿន ពីព្រោះការធ្វើដូចនេះវាមិនត្រឹមតែអាចជួយសម្រួលទីផ្សារដល់បណ្ដាលោកខាងត្បូងដូចគ្នាប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចអោយតម្លៃផលិតផលដើមមានតម្លៃ និងជួយកាត់បន្ថយលើតម្លៃនាំចេញ និងនាំចូលផងដែរ។ នៅក្នុងឆ្នាំ ១៩២៥ មួយភាគបួន នៃលំនាំចេញរបស់ប្រទេសកំពុងអភិវឌ្ឍបានធ្វើជាមួយបណ្ដាប្រទេសកំពុងអភិវឌ្ឍដទៃទៀត។

### ៤.៣. ដោយជួយបណ្ដាប្រទេសទន់ខ្សោយ

បណ្ដាប្រទេសលោកខាងជើង ដែលមានឧស្សាហកម្ម សេវាកម្ម និងបច្ចេកវិទ្យារីកចម្រើនខ្លាំង គួរតែផ្ដល់ជាជំនួយដល់ប្រទេសលោកខាងត្បូង ដើម្បីឱ្យបណ្ដាប្រទេសលោកខាងត្បូងមានទុន និងមានកម្លាំងក្នុងការអភិវឌ្ឍប្រទេសរបស់ខ្លួនបាន។

ជាទូទៅជំនួយត្រូវបានគេធ្វើឡើងតាមរូបភាពជាច្រើនដូចជា ៖

- **អង្គការក្រៅរដ្ឋាភិបាល ៖**

អង្គការក្រៅរដ្ឋាភិបាលនៅលើពិភពលោកមានចំនួនច្រើន (រាប់ពាន់ក្នុងពិភពលោក) ហើយបានធ្វើអន្តរាគមន៍ផ្នែកមនុស្សធម៌ ផ្នែកសិក្សាអប់រំក្នុងការអភិវឌ្ឍជនបទ...។ល។ ជំនួយនេះជាជំនួយឯកជន និងមិនទាមទារផលអ្វីមកវិញទេ។

- **ជំនួយសាធារណៈ សម្រាប់ការអភិវឌ្ឍ**

ចាប់តាំងពីឆ្នាំ ១៩៩៤ មក អង្គការសហប្រជាជាតិមានកង្វល់ពីការបាត់តុល្យភាពរវាងបណ្តាប្រទេសអ្នកមាន និងបណ្តាប្រទេសអ្នកក្រីក្រ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ អង្គការសហប្រជាជាតិ ក៏បានរៀបចំនូវកម្មវិធី នៃអង្គការសហប្រជាជាតិ សម្រាប់ការអភិវឌ្ឍហៅកាត់ថា (UNDP)។ ជំនួយបែបនេះ គឺជាជំនួយដែលប្រទេសឧស្សាហកម្មផ្តល់ឱ្យទៅប្រទេសកំពុងអភិវឌ្ឍ តាមរយៈអង្គការអន្តរជាតិនានា។ ជំនួយបែបនេះមិនសំខាន់ចំពោះទំនាក់ទំនងពីប្រទេសទៅប្រទេសមួយទៀតនោះទេ។ នៅមានជំនួយមួយបែបទៀតដែលត្រូវបានគេធ្វើឡើងដោយប្រទេសមួយបានផ្តល់ឱ្យប្រទេសមួយទៀតដោយផ្ទាល់តែម្តង។ ជំនួយបែបនេះហៅថា ជំនួយឯកតោភាគី។ បច្ចុប្បន្ននេះ ជំនួយបែបនេះមានចំនួនបីភាគបួន នៃជំនួយទាំងអស់។ ជំនួយបែបនេះរួមមានដូចជាការផ្តល់ប្រាក់ឱ្យខ្ចី ការបញ្ជូនប្រាក់ដើមទុន ឬបញ្ជូនអ្នកបច្ចេកទេសជាដើម។ ជាទូទៅ ជំនួយនេះមានប្រសិទ្ធភាព ក៏ប៉ុន្តែអាចជាមធ្យោបាយមួយសម្រាប់កៀបសង្កត់ ឬធ្វើអន្តរាគមន៍។ ជំនួយបែបនេះទាក់ទងជាញឹកញាប់ចំពោះប្រទេស ដែលធ្លាប់ធ្វើអាណានិគម និងនៅក្រោមអាណានិគមរបស់គេ។

ជាទូទៅ មានតែជំនួយតាមរយៈអង្គការអន្តរជាតិនានាប៉ុណ្ណោះ ដែលជាការល្អប្រពៃ ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់នៅឡើយនោះទេ។ ប្រទេសអ្នកមានបានផ្តល់ជំនួយបែបនេះ តែបន្តិចបន្តួចប៉ុណ្ណោះ ពោលគឺមួយភាគតូចនៃ GDP របស់គេ ដែលជាចំនួនទាបបំផុត បើធៀបនឹងសំណូមពររបស់អង្គការសហប្រជាជាតិ។

- **ជំនួយជាស្បៀងអាហារ**

ការផ្តល់ជំនួយជាស្បៀងអាហារ ក៏ជាការល្អប្រសើរមួយផងដែរ ប៉ុន្តែជំនួយនេះក៏បានផ្តល់ផលវិបាកផងដែរ។ ជាឧទាហរណ៍ ការបញ្ជូននូវស្រូវសាលី ដោយសហរដ្ឋអាមេរិក ដែលបានធ្វើឡើងដោយញឹកញាប់នោះ បានផ្តល់នូវអត្ថទោសច្រើនជាងអត្ថប្រយោជន៍ ជាពិសេសគឺធ្វើឱ្យតម្លៃកសិផលចុះថោកក្នុងប្រទេសដែលទទួលជំនួយ ហើយមិនបានលើកទឹកចិត្តកសិករក្នុងការផលិតឡើយ។ ប្រទេសទទួលជំនួយចូលចិត្តចង់បានការលើកទឹកចិត្តកសិករក្នុងផលិតកម្ម ជាជាងការផ្តល់ជំនួយតាមបែបការបញ្ជូនផលិតផល ពីព្រោះជំនួយទាំងនោះមិនមែនសុទ្ធតែធ្លាក់ដល់ដៃអ្នកទទួលនោះទេ ពេលខ្លះត្រូវគេបំបែក ឬគេបំបាត់តែម្តង។ ជំនួយជាស្បៀងអាហារនេះចាំបាច់ សម្រាប់តែដោះស្រាយវិបត្តិបន្ទាន់ៗតែប៉ុណ្ណោះដូចជា គ្រោះទុរ្ភិក្ស គ្រោះធម្មជាតិ និងសង្គ្រាមជាដើម។

## សំណួរត្រិះរិះ

1. ចូរពិពណ៌នាអំពីប្រវត្តិនៃការបែងចែកពិភពលោក។
2. ផ្អែកលើប្រព័ន្ធនយោបាយ និងប្រព័ន្ធសេដ្ឋកិច្ច តើគេបែងចែកពិភពលោកជាអ្វីខ្លះ? ចូរពន្យល់។
3. ផ្អែកលើកម្រិតអភិវឌ្ឍនៃប្រទេសនីមួយៗ តើគេបែងចែកពិភពលោកជាអ្វីខ្លះ? ចូរពន្យល់?
4. តើគេប្រើសូចនាករសំខាន់ៗអ្វីខ្លះ ដើម្បីវាស់វែងពីកម្រិតរីកលូតលាស់របស់ប្រទេសនីមួយៗនៅលើពិភពលោក? ចូរបង្ហាញ។
5. តើការប្រើប្រាស់សូចនាករសេដ្ឋកិច្ច សម្រាប់វាស់វែងពីកម្រិតអភិវឌ្ឍរបស់ប្រទេសនីមួយៗនៅលើពិភពលោក ជាការត្រឹមត្រូវហើយ ឬនៅ? ចូរពន្យល់។

6. តើគេបែងចែកលោកខាងត្បូងជាប៉ុន្មានក្រុម? អ្វីខ្លះ? ចូរពន្យល់។
7. តើបណ្ដាប្រទេសលោកខាងត្បូងមានលក្ខណៈខុសគ្នាដូចម្ដេចខ្លះ?
8. តើគេមានវិធានការអ្វីខ្លះ ដើម្បីកាត់បន្ថយវិសមភាពរវាងលោកខាងជើង និងលោកខាងត្បូង?

## ឯកសារពិគ្រោះ


1. ក្រសួងអប់រំ សៀវភៅភូមវិទ្យា ថ្នាក់ទី ៥ បោះពុម្ពឆ្នាំ ១៩៨៤
2. ក្រសួងអប់រំ សៀវភៅភូមិវិទ្យា ថ្នាក់ទី ៥ បោះពុម្ពឆ្នាំ ១៩៩៤
3. ក្រសួងអប់រំ សៀវភៅភូមិវិទ្យា ថ្នាក់ទី ៧ បោះពុម្ពឆ្នាំ ១៩៨៣
4. ក្រសួងអប់រំ សៀវភៅសិក្សាសង្គម ផ្នែកភូមិវិទ្យា ថ្នាក់ទី ៨ បោះពុម្ពឆ្នាំ ២០១១
5. ក្រសួងអប់រំ សៀវភៅសិក្សាសង្គម ផ្នែកភូមិវិទ្យា ថ្នាក់ទី ៩ បោះពុម្ពឆ្នាំ ២០១១
6. ក្រសួងអប់រំ សៀវភៅភូមិវិទ្យា ថ្នាក់ទី ១១ ភាគ១ និងភាគ២ បោះពុម្ពឆ្នាំ១៩៨៧
7. ក្រសួងអប់រំ សៀវភៅភូមិវិទ្យា ថ្នាក់ទី ១១ បោះពុម្ពឆ្នាំ ២០០៥
8. ក្រសួងអប់រំ សៀវភៅភូមិវិទ្យា ថ្នាក់ទី ១១ បោះពុម្ពឆ្នាំ ២០១៨
9. ក្រសួងអប់រំ សៀវភៅភូមិវិទ្យា ថ្នាក់ទី ១២ បោះពុម្ពឆ្នាំ ២០១១
10. ក្រសួងអប់រំ សៀវភៅភូមិវិទ្យា ថ្នាក់ទី ១២ បោះពុម្ពឆ្នាំ ២០១៨
11. ក្រសួងអប់រំ សៀវភៅផែនដីវិទ្យា ថ្នាក់ទី ១០ បោះពុម្ពឆ្នាំ ១៩៩៩
12. ក្រសួងអប់រំ សៀវភៅផែនដីវិទ្យា ថ្នាក់ទី ១១ បោះពុម្ពឆ្នាំ ១៩៩៩
13. ក្រសួងអប់រំ សៀវភៅផែនដីវិទ្យា ថ្នាក់ទី ១២ បោះពុម្ពឆ្នាំ ១៩៩៩
14. ក្រសួងអប់រំ សៀវភៅផែនដីវិទ្យា ថ្នាក់ទី ១១ បោះពុម្ពឆ្នាំ ២០១១
15. ក្រសួងអប់រំ សៀវភៅផែនដីវិទ្យា ថ្នាក់ទី ១២ បោះពុម្ពឆ្នាំ ២០១១
16. ក្រសួងអប់រំ សៀវភៅខេមរយានកម្ម ថ្នាក់ទី១ ទី២ និងទី ៣
17. ឯកសារភូមិវិទ្យារូបប្រទេសកម្ពុជា ចងក្រងដោយក្រុមសាស្ត្រាចារ្យ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដេប៉ាតឺម៉ង់ភូមិវិទ្យា និងការរៀបចំដែនដី
18. ឯកសារវិទ្យុបារាំងអន្តរជាតិ ដោយសេង ឪណា ឆ្នាំ២០១៣
19. ឯកសារ World Book ឆ្នាំ១៩៩៩
20. ក្រសួងបរិស្ថាន សៀវភៅជំនួយស្មារតី បោះពុម្ពឆ្នាំ ២០១១
21. ឯកសារភូមិវិទ្យាអភិវឌ្ឍសេដ្ឋកិច្ច ចងក្រងដោយក្រុមសាស្ត្រាចារ្យភូមិវិទ្យា វិទ្យាស្ថានជាតិអប់រំ ដេប៉ាតឺម៉ង់ភូមិវិទ្យា
22. ឯកសារជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៩ របស់ក្រសួងផែនការ និងស្ថិតិ
23. សៀវភៅកម្រងទិន្នន័យឈ្មោះ និងចំនួនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ នៃព្រះរាជាណាចក្រកម្ពុជា របស់ក្រសួងមហាផ្ទៃ បោះពុម្ពឆ្នាំ២០២១
24. សៀវភៅប្រព័ន្ធរដ្ឋបាលកម្ពុជា របស់សាលាភូមិន្ទរដ្ឋបាល បោះពុម្ពឆ្នាំ ២០២០

25. Richard G. Boehm, David G. Armstrong and Francis P. Humkins, Geography: The world and its people, New York 2012.
26. Andy Koh and Valerie Koh, Earth our home: Full Geography, Secondary 1, Singapore 2013.
27. Cho Wing Cheong, explore 1: Geography, Singapore 2013.
28. Khoo Ming Ghee and Tan Say Pin, Earth our home: Full Geography, Seconary 3, Singapore 2013.
29. Khoo Ming Ghee and Tan Say Pin, Earth our home: Full Geography, Seconary 4, Singapore 2013.
30. Amstrong Boehm Humkins, Geography of Economic Development, New York 2008.
31. Jerome D. Fellmann, Human Geography, Landscape of Human Activities, New York 2009.
32. Arthur Getis and Judith Getis, Regional Geography, Oxford 2012.
33. James S. Fisher, Geography and Development, A World Regional Approach, Oxford 2011.
34. www.google.com / Physical Geography
35. www.google.com / Geography in the world

# ជំពូកទី៤៖ ភូមិវិទ្យាតំបន់អឺរ៉ុប
# មេរៀនទី១៖ ស្ថានភាពទូទៅនៃទ្វីបអឺរ៉ុប

## ១. ទីតាំងភូមិសាស្ត្រ

ទ្វីបអឺរ៉ុបស្ថិតនៅអឌ្ឍគោលខាងជើង។ វាស្ថិតនៅចន្លោះរយៈទទឹងទី៣៥ទៅ៧៥ដឺក្រេខាងជើង និងនៅចន្លោះរយៈបណ្តោយទី២៥ខាងលិចទៅ៦៥ដឺក្រេខាងកើត។ អឺរ៉ុប គឺជាទ្វីបមួយក្នុងចំណោមទ្វីបទាំង ៧ នៅលើពិភពលោក ដែលស្ថិតនៅចុងខាងលិចបំផុតនៃអឺរ៉ាស៊ី។ នៅភាគខាងកើត ទ្វីបអឺរ៉ុបខណ្ឌពីអាស៊ីដោយជួរភ្នំអ៊ូរ៉ាល់។ ព្រំប្រទល់ភាគខាងអាគ្នេយ៍ខណ្ឌពីទ្វីបអាស៊ីដោយជួរភ្នំកូកាស និងសមុទ្រកាសព្យែន។ ទ្វីបអឺរ៉ុបត្រូវបានព័ទ្ធជុំវិញដោយមហាសមុទ្រអាកទិកនៅខាងជើង។មហាសមុទ្រអាត្លង់ទិកនៅខាងលិច។ សមុទ្រមេឌីទែរ៉ានេ និងសមុទ្រខ្មៅនៅខាងត្បូង។



## ២. ផ្ទៃដី

| | | |
|---|---|---|
| ផ្ទៃដី | 1.02×10^7 km² (គីឡូម៉ែត្រការ៉េ) | |
| ផ្ទៃដីសរុប | សរុប | 2.306×10^7 km²(គីឡូម៉ែត្រការ៉េ) |
| | ប្រទេសធំជាងគេ | 1.71×10^7 km²(គីឡូម៉ែត្រការ៉េ) (ជាប់ចំ ថ្នាក់លើពិភពលោកលេខ1) (ប្រទេសរុស្ស៊ី) |
| | ប្រទេសតូចជាងគេ | 0.44 km² (គីឡូម៉ែត្រការ៉េ) (ជាប់ចំណាត់ថ្នាក់លើពិភពលោកលេខ 249) (បុរីវ៉ាទីកង់) |





# ៣. បណ្តាប្រទេសនៅទ្វីបអឺរ៉ុប

| ល.រ | ឈ្មោះប្រទេស | ផ្ទៃក្រឡា |
|---|---|---|
| ១ | រុស្ស៊ី | 17 098 242 km$^2$ |
| ២ | បារាំង | 643 801 km$^2$ |
| ៣ | អ៊ុយក្រែន | 603 550 km$^2$ |
| ៤ | អេស្ប៉ាញ | 505 992 km$^2$ |
| ៥ | ស៊ុយអែត | 450 295 km$^2$ |
| ៦ | អាល្លឺម៉ង់ | 357 022 km$^2$ |
| ៧ | ហ្វាំងឡង់ | 338 145 km$^2$ |
| ៨ | ន័រវេស | 323 802 km$^2$ |
| ៩ | ប៉ូឡូញ | 312 685 km$^2$ |
| ១០ | អ៊ីតាលី | 301 340 km$^2$ |
| ១១ | ចក្រភពអង់គ្លេស | 243 610 km$^2$ |
| ១២ | រូម៉ានី | 238 391 km$^2$ |
| ១៣ | បេឡារុស្ស | 207 600 km$^2$ |
| ១៤ | ក្រិក | 131 940 km$^2$ |
| ១៥ | ប៊ុលហ្គារី | 110 879 km$^2$ |
| ១៦ | អ៊ីស្លង់ | 103 000 km$^2$ |
| ១៧ | ហុងគ្រី | 93 028 km$^2$ |
| ១៨ | ព័រទុយហ្គាល់ | 92 090 km$^2$ |
| ១៩ | អូទ្រីស | 83 871 km$^2$ |
| ២០ | ឆែក | 78 867 km$^2$ |
| ២១ | ស៊ែប៊ី | 77 474 km$^2$ |
| ២២ | អៀរឡង់ | 70 273 km$^2$ |
| ២៣ | លីទុយអានី | 65 300 km$^2$ |
| ២៤ | ឡាតវី | 64 589 km$^2$ |
| ២៥ | ស្វាលបាត( Svalbard ) | 62 045 km$^2$ |
| ២៦ | ក្រូអាត | 56 594 km$^2$ |
| ២៧ | បូស្នៀ និងហឺហ្សេហ្គោវីណា | 51 197 km$^2$ |
| ២៨ | ស្លូវ៉ាគី | 49 035 km$^2$ |
| ២៩ | អេស្តូនី | 45 228 km$^2$ |

| | | |
|---|---|---|
| ៣០ | ដាណឺម៉ាក | 43 094 km$^2$ |
| ៣១ | ហូឡង់ | 41 543 km$^2$ |
| ៣២ | ស្វីស | 41 277 km$^2$ |
| ៣៣ | ម៉ុលដាវី | 33 851 km$^2$ |
| ៣៤ | បែលហ្ស៊ិក | 30 528 km$^2$ |
| ៣៥ | អាល់បានី | 28 748 km$^2$ |
| ៣៦ | ម៉ាសេដូនៀ | 25 713 km$^2$ |
| ៣៧ | ស្លូវេនី | 20 273 km$^2$ |
| ៣៨ | ម៉ុងតេណេហ្គ្រោ | 13 812 km$^2$ |
| ៣៩ | កូសូវ៉ូ | 10 887 km$^2$ |
| ៤០ | លុចសំបួរ | 2586 km$^2$ |
| ៤១ | កោះហ្វារ៉ូ | 1393 km$^2$ |
| ៤២ | កោះម៉ាន់ | 572 km$^2$ |
| ៤៣ | អង់ដូរ៉ា | 468 km$^2$ |
| ៤៤ | ម៉ាល់តា | 316 km$^2$ |
| ៤៥ | លីចតេនស្ទីន | 160 km$^2$ |
| ៤៦ | ជឺស៊ី ( Jersey ) | 116 km$^2$ |
| ៤៧ | ហ្គេនស៊ី | 78 km$^2$ |
| ៤៨ | សាន់ម៉ារីណូ | 61 km$^2$ |
| ៤៩ | ជីប្រាល់តា ( Gibraltar ) | 6.5 km$^2$ |
| ៥០ | ម៉ូណាកូ | 2 km$^2$ |
| ៥១ | បុរីវ៉ាទីកង់ | 0.44 km$^2$ |

## ៤. ប្រជាជនទ្វីបអឺរ៉ុប

| ល.រ | ឈ្មោះប្រទេស | ចំនួនប្រជាជន |
|---|---|---|
| ១ | អាល្លឺម៉ង់ | 83.3 លាននាក់ |
| ២ | ចក្រភពអង់គ្លេស | 67.7 លាននាក់ |
| ៣ | បារាំង | 64.8 លាននាក់ |
| ៤ | អ៊ីតាលី | 58.9 លាននាក់ |
| ៥ | អេស្ប៉ាញ | 47.5 លាននាក់ |
| ៦ | ប៉ូឡូញ | 41 លាននាក់ |

| | | |
|---|---|---|
| ៧ | អ៊ុយក្រែន | 36.7 លាននាក់ |
| ៨ | រូម៉ានី | 19.9 លាននាក់ |
| ៩ | ហូឡង់ | 17.6 លាននាក់ |
| ១០ | បែលហ្សិក | 11.7 លាននាក់ |
| ១១ | ស៊ុយអែត | 10.6 លាននាក់ |
| ១២ | សាធារណរដ្ឋឆេក | 10.5 លាននាក់ |
| ១៣ | ប្រទេសក្រិក | 10.3 លាននាក់ |
| ១៤ | ព័រទុយហ្គាល់ | 10.2 លាននាក់ |
| ១៥ | ហុងគ្រី | 10.2 លាននាក់ |
| ១៦ | បេឡារុស្ស | 9.5 លាននាក់ |
| ១៧ | អូទ្រីស | 9 លាននាក់ |
| ១៨ | ស្វីស | 8.8 លាននាក់ |
| ១៩ | ស៊ែប៊ី | 7.1 លាននាក់ |
| ២០ | ប៊ុលហ្គារី | 6.7 លាននាក់ |
| ២១ | ដាណឺម៉ាក | 5.9 លាននាក់ |
| ២២ | ស្លូវ៉ាគី | 5.8 លាននាក់ |
| ២៣ | ន័រវេស | 5.5 លាននាក់ |
| ២៤ | ហ្វាំងឡង់ | 5.5 លាននាក់ |
| ២៥ | អៀរឡង់ | 5.1 លាននាក់ |
| ២៦ | ក្រូអាត | 4 លាននាក់ |
| ២៧ | ម៉ុលដាវី | 3.4 លាននាក់ |
| ២៨ | បូស្នៀ និងហឺហ្សេហ្គោវីណា | 3.2 លាននាក់ |
| ២៩ | អាល់បានី | 2.8 លាននាក់ |
| ៣០ | លីទុយអានី | 2.7 លាននាក់ |
| ៣១ | ស្លូវេនី | 2.1 លាននាក់ |
| ៣២ | ម៉ាសេដូនខាងជើង | 2.1 លាននាក់ |
| ៣៣ | កូសូវ៉ូ | 1.86 លាននាក់ |
| ៣៤ | ឡាតវី | 1.8 លាននាក់ |
| ៣៥ | អេស្តូនី | 1.3 លាននាក់ |
| ៣៦ | ស៊ីប | 1.3 លាននាក់ |
| ៣៧ | លុចសំបួរ | 700 000 នាក់ |
| ៣៨ | ម៉ុងតេណេហ្គ្រោ | 600 000 នាក់ |

| | | |
|---|---|---|
| ៣៩ | ម៉ាល់តា | 500 000 នាក់ |
| ៤០ | អ៊ីស្លង់ | 400 000 នាក់ |
| ៤១ | ជឺស៊ី | 111 284 នាក់ |
| ៤២ | កោះម៉ាន់ | 84 605 នាក់ |
| ៤៣ | អង់ដូរ៉ា | 79 960 នាក់ |
| ៤៤ | ហ្គេនស៊ី | 53 184 នាក់ |
| ៤៥ | កោះហ្វារ៉ូ | 53 184 នាក់ |
| ៤៦ | លីចតេនស្ទីន | 39 458 នាក់ |
| ៤៧ | ម៉ូណាកូ | 36 377 នាក់ |
| ៤៨ | សាន់ម៉ារីណូ | 33 652 នាក់ |
| ៤៩ | ជីប្រាល់តា ( Gibraltar ) | 32 673 នាក់ |
| ៥០ | ស្វាបាដ | 2637 នាក់ |
| ៥១ | បុរីវ៉ាទីកង់ | 513 នាក់ |

| | | |
|---|---|---|
| ប្រជាជន | ប្រជាជនសរុប | ៥៩៩លាននាក់ |
| | ប្រជាជនច្រើនជាងគេ | ៨៣.៣លាននាក់ ( អាល្លឺម៉ង់ ) |
| | ប្រជាជនតិចជាងគេ | ៥១៣នាក់ ( បុរីវ៉ាទីកង់ ) |
| ដង់ស៊ីតេប្រជាជន | មធ្យម | ១០៤ នាក់/km² |
| | ខ្ពស់បំផុត | ២៤៦២១ នាក់/km² ( ម៉ូណាកូ ) |
| | ទាបបំផុត | ០.០៤២៥ នាក់/km² ( ស្វាលបាត ) |
| កំណើនប្រជាជន | មធ្យម | ០.០៨៨២%/ឆ្នាំ |
| | ខ្ពស់បំផុត | ២.១៤%/ឆ្នាំ ( ម៉ាល់តា ) |
| | ទាបបំផុត | ១.៥២%/ឆ្នាំ ( បូស្នៀ និងហឺហ្សេហ្គោវីណា ) |
| អាយុសង្ឃឹមរស់ | មធ្យម | ៨០.១ឆ្នាំ |
| | ខ្ពស់បំផុត | ៨៥.៤ឆ្នាំ ( ម៉ូណាកូ ) |
| | ទាបបំផុត | ៧១.៦ឆ្នាំ ( កូសូវ៉ូ ) |

ការចែកចាយអាយុ




## ៥. សេដ្ឋកិច្ចអឺរ៉ុប

| | | |
|---|---|---|
| GDP | សរុប | $21.9 ទ្រីលានក្នុងមួយឆ្នាំ |
| | មធ្យម | $65.13 ប៊ីលានក្នុងមួយឆ្នាំ |
| | ខ្ពស់បំផុត | $3.997 ទ្រីលានក្នុងមួយឆ្នាំ (អាល្លឺម៉ង់) |
| | ទាបបំផុត | $1.106 ប៊ីលានក្នុងមួយឆ្នាំ (ជីប្រាល់តា) |
| GDP សម្រាប់មនុស្សម្នាក់ | មធ្យម | $30 524 ក្នុងមួយឆ្នាំសម្រាប់មនុស្សម្នាក់ |
| | ខ្ពស់បំផុត | $166 726 ក្នុងមួយឆ្នាំសម្រាប់មនុស្សម្នាក់ (ម៉ូណាកូ) |
| | ទាបបំផុត | $3095 ក្នុងមួយឆ្នាំសម្រាប់មនុស្សម្នាក់(អ៊ុយក្រែន) |
| អត្រាគ្មានការងារធ្វើ | មធ្យម | 7.77% |
| | ខ្ពស់បំផុត | 30.9% (កូសូវ៉ូ) |
| | ទាបបំផុត | 2.4% (ឆែក) |
| កម្លាំងពលកម្ម | ខ្ពស់បំផុត | 73.61 លាននាក់ (52.39% នៃប្រជាជន) (រុស្ស៊ី) |

| | | |
|---|---|---|
| | ទាបបំផុត | 215 769នាក់ (59% នៃចំនួនប្រជាជន) (អ៊ីស្លង់) |
| កសិកម្ម | មធ្យម | 3.283 ពាន់លានដុល្លារក្នុងមួយឆ្នាំ |
| | ខ្ពស់បំផុត | $45.06 ពាន់លានដុល្លារក្នុងមួយឆ្នាំ (ប្រទេសបារាំង) |
| | ទាបបំផុត | $14.57 លានដុល្លារក្នុងមួយឆ្នាំ (អង់ដូរ៉ា) |
| ឧស្សាហកម្ម | មធ្យម | $18.79 ពាន់លានដុល្លារក្នុងមួយឆ្នាំ |
| | ខ្ពស់បំផុត | $1.118 ពាន់ពាន់លានដុល្លារក្នុងមួយឆ្នាំ (ប្រទេសអាល្លឺម៉ង់) |
| | ទាបបំផុត | $299.5 លានដុល្លារក្នុងមួយឆ្នាំ (អង់ដូរ៉ា) |
| ការផលិត | មធ្យម | $15.07 ពាន់លានដុល្លារក្នុងមួយឆ្នាំ |
| | ខ្ពស់បំផុត | $832.4 ពាន់លានដុល្លារក្នុងមួយឆ្នាំ (ប្រទេសអាល្លឺម៉ង់) |
| | ទាបបំផុត | $94.31 លានដុល្លារក្នុងមួយឆ្នាំ (អង់ដូរ៉ា) |
| សេវាកម្មជាដើម | មធ្យម | $48.36 ពាន់លានដុល្លារក្នុងមួយឆ្នាំ |
| | ខ្ពស់បំផុត | $ 2.158 លានលានក្នុងមួយឆ្នាំ (ប្រទេសអាល្លឺម៉ង់) |
| | ទាបបំផុត | $1.53 ពាន់លានដុល្លារក្នុងមួយឆ្នាំ (កោះហ្វារ៉ូ) |

**សំណួរត្រិះរិះ**

១. តើទ្វីបអឺរ៉ុបមានទីតាំងស្ថិតនៅត្រង់ណា? មានផ្ទៃដីប៉ុន្មានគីឡូម៉ែត្រការេ? មានប្រជាជនប៉ុន្មានលាននាក់?

២. តើនៅទ្វីបអឺរ៉ុបមានប៉ុន្មានប្រទេស? តើប្រទេសនីមួយៗមានទីតាំងនៅកន្លែងណា? ចូររកព័ត៌មានប្រទេសនីមួយៗតាម ដែលអ្នកចង់បាន?

៣. តើទ្វីបអឺរ៉ុបមានព្រំប្រទល់ជាប់ជាមួយប្រទេសណាខ្លះ?

៤. តើវិស័យសេដ្ឋកិច្ចសំខាន់ៗប្រទេសនៅអឺរ៉ុបមានអ្វីខ្លះ? រកចំណូលបានប៉ុន្មានជាមធ្យមសម្រាប់ប្រទេសនីមួយៗ?

# មេរៀនទី២៖ សណ្ឋានដីទ្វីបអឺរ៉ុប

សណ្ឋានដីទ្វីបអឺរ៉ុប គេអាចចែកចេញជាបីតំបន់ គឺតំបន់ភ្នំភាគពាយ័ព្យ តំបន់ទំនាបធំអឺរ៉ុប និងខ្ពង់រាបកណ្តាលនិងតំបន់ភ្នំភាគខាងត្បូង។

## ១. តំបន់ភ្នំភាគពាយ័ព្យ

តំបន់ភ្នំភាគពាយ័ព្យរាប់បញ្ចូលទាំងភ្នំនានា និងខ្ពង់រាប ក្នុងប្រទេសន័រវេស និងស៊ុយអែត ហើយលាតសន្ធឹងរហូតដល់ភាគខាងជើងនៃប្រទេសស្កុតឡែន ប្រទេសវ៉ែល និងប្រទេសអៀរឡង់។ តំបន់ភ្នំទាំងនេះ ស្ថិតនៅក្នុងចំណោមភ្នំដែលចាស់ជាងគេបំផុត នៅក្នុងទ្វីបអឺរ៉ុប ពួកវាជាផ្ទាំងថ្មចាស់រឹង លាតសន្ធឹងជាប់នឹងឆ្នេរសមុទ្រ និងមានចំណោទខ្លាំង ស្ថិតនៅតាមបណ្តោយឆ្នេរមហាសមុទ្រអាត្លង់ទិក។






ផ្នែកផ្សេងទៀតនៃតំបន់ភ្នំ ស្ថិតនៅតាមឆ្នេរមហាសមុទ្រអាត្លង់ទិកលយចូលជ្រៅសមុទ្របង្កើតបានជាឆ្នេរចោទខ្លាំងនិងរឆេករឆូចរដិបរដុប។ភាគច្រើននៃតំបន់ភ្នំទាំងនេះ ទាបនិងមានជំរាល សម្រាប់កន្លែងដែលស្ថិតនៅឆ្ងាយពីសមុទ្រ។ ដៃសមុទ្រតូចចង្អៀតហើយលយចូលជ្រៅ(នៃឧបទ្វីប) ស្ថិតនៅចន្លោះជំរាល និងចំណោទត្រូវបានគេហៅថា ឈូងសមុទ្រចង្អៀត(Fiords)។ ឆ្នេរសមុទ្រនៃប្រទេសន័រវេស គឺជាឈូងសមុទ្រចង្អៀតដ៏ល្បីល្បាញ។





## ២. តំបន់ទំនាបធំអឺរ៉ុប

ទំនាបធំអឺរ៉ុបលាតសន្ធឹងពីឆ្នេរសមុទ្រអាត្លង់ទិកខាងលិចរហូតដល់ ជួរភ្នំអ៊ូរ៉ាល(Ural)ដែលស្ថិតនៅភាគខាងកើត។ មានសមុទ្រស ហើយនិងតំបន់ភ្នំភាគពាយ័ព្យស្ថិតនៅភាគខាងជើង។ នៅភាគខាងត្បូង(នៃទ្វីប)មានតំបន់ភ្នំភាគខាងត្បូង។ មានទន្លេមួយចំនួន ហូរក្នុងតំបន់ទំនាបធំ។




ទន្លេទាំងនេះភាគច្រើនមានទំហំតូច ប៉ុន្តែមានសារៈសំខាន់ខ្លាំងមែនទែន សម្រាប់ប្រទេសដែលមានវិស័យឧស្សាហកម្មមាញឹក ដែលទន្លេទាំងនោះហូរកាត់។ ទម្រង់នៃទន្លេមានសណ្ឋានរាបស្មើ ដែលវាជាអំណោយផលដល់ការអភិវឌ្ឍផ្លូវទឹកនៅលើផ្ទៃដី។ ទំនាបធំអឺរ៉ុប មិនមែនជាទំនាបរាបស្មើនោះទេ ប៉ុន្តែវាជាដីទួលទាបៗជាមួយនឹងកូនភ្នំតូចៗ ស្ថិតនៅរាយប៉ាយក្នុងតំបន់ខ្លះនៃតំបន់ទំនាបនេះ។ ឧទាហរណ៍តំបន់កូនភ្នំទាបៗវ៉ាលដា(Valda) ស្ថិតក្នុងប្រទេសរុស្ស៊ី ដែលជាប្រភពនៃទន្លេវ៉ុលហ្គា(Volga)។

នៅពេលដែលមានបាតុភូតខ្សែភ្នំភ្លើងក្នុងសំបកផែនដី។ នៅពេលមានចលនាខ្សែភ្នំភ្លើងស្របពីរប៉ះទង្គិចគ្នាកើតឡើងនៅលើសំបកផែនដី បង្កើតបានជាទម្រង់ជ្រលងខ្សែភ្នំភ្លើងដែលលិចចុះបានជាជំរាលតូចចង្អៀត ដែលគេហៅថា ជ្រលងស្នាមប្រេះ។ ជ្រលងទន្លេរ៉ាញ(Rhine) ស្ថិតនៅចន្លោះភ្នំវ៉ូសស៍(Vosges) ហើយនឹងតំបន់ព្រៃខ្មៅ(Black forests) គឺជាឧទាហរណ៍មួយនៃជ្រលងស្នាមប្រេះ។

ក្នុងចំណោមនៃតំបន់កូនភ្នំនានានៅទីនេះ គឺកើតឡើងដោយថ្មភ្នំភ្លើងដូចជាតំបន់ប្រីតានី(Brittany) ក្នុងប្រទេសបារាំង អាដិននេស(Ardennes)ស្ថិតក្នុងប្រទេសប៊ែលស៊ិក ហើយនិងតំបន់ ហាតស៍ (Hartz) នៅប្រទេសអាឡឺម៉ង់។

កូនភ្នំខ្លះកើតឡើងពីសិលាកំទេចកំណនៃថ្មកំបោរ និងសិលាខ្សាច់។ ភាគច្រើននៃទំនាបធំអឺរ៉ុបគ្របដណ្តប់ដោយកំណប់ដីឥដ្ឋល្បាយខ្សាច់ និងដីកើតពីខ្យល់បក់។

## ៣. តំបន់ខ្ពង់រាបកណ្តាល និងជួរភ្នំភាគខាងត្បូង

ក្រឡេកទៅមើលខ្ពង់រាបកណ្តាល និងជួរភ្នំភាគខាងត្បូងដែលបង្កើតបានជាខ្សែក្រវាត់នៃខ្ពង់រាបនិងជួរភ្នំ។




នៅភាគខាងត្បូងនៃតំបន់ទំនាបធំ មានខ្ពង់រាបកណ្តាល ដែលកើតមកដោយប្រព័ន្ធភ្នំចាស់រិចរឹល និងមានរយៈកម្ពស់មិនខ្ពស់។ កម្ពស់ខ្ពស់បំផុតនៃភ្នំទាំងនេះ គឺមិនលើសពី១៦០០ម៉ែត្រទេ។ វារាប់បញ្ចូលទាំងខ្ពង់រាបអេស្ប៉ាញ(the plateau Spain), ម៉ាស៊ីវកណ្តាល(the Central Massif), វ៉ូសស៍(Vosges)ក្នុងប្រទេសបារាំង, ព្រៃខ្មៅ(Black forests)ក្នុងប្រទេសអាឡឺម៉ង់ ហើយនិងខ្ពង់រាបបូហ៊ីមា។

ជួរភ្នំអ៊ូរាលនៅក្នុងប្រទេសរុស្ស៊ីគឺជាផ្នែកមួយប្រព័ន្ធភ្នំចាស់នេះផងដែរ។ នៅភាគខាងត្បូងនៃភ្នំចាស់ៗទាំងនេះ មានខ្សែជួរភ្នំវ័យក្មេងដែលបង្កើតជារបាំងរវាងអឺរ៉ុបភាគខាងជើងនិងតំបន់មេឌីទែរ៉ាណេ ដែលមានប្រព័ន្ធអាល់ផាញ់ (Alpine) ក៏ជាផ្នែកខ្សែក្រវាត់មួយ ចំក ណ្តាលនៃពិភពភ្នំ ដែលលាតសន្ធឹងពីតំបន់ភីរីនេស៍ក្នុងប្រទេសអេស្ប៉ាញ រហូតដល់តំបន់ផាមាខ្នត់(Pamir knot) នៅក្នុងអាស៊ីកណ្តាល ហើយនិងផ្នែកដ៏ទៃទៀត។

អាល់ស៍គឺជាចំណុចកណ្តាលនៃប្រព័ន្ធភ្នំនេះ និងបង្កើតជាជួរភ្នំកោងដែលគ្របដណ្តប់ភាគច្រើនបំផុតនៃប្រទេសស្វីស និងផ្នែកខ្លះនៃប្រទេសអូទ្រីស បារាំង អាឡឺម៉ង់ និងអ៊ីតាលី។ ភ្នំក្មេងទាំងនេះ មានកម្ពស់ខ្ពស់ចំណោទខ្លាំង និងមានជ្រលងជ្រៅៗ ដែលស្ថិតនៅស្របៗគ្នា។ ភ្នំស( Blanc) គឺជាភ្នំដែលមានកំពូលខ្ពស់បំផុត នៅជួរភ្នំអាល់ កម្ពស់មានរហូតដល់បួនពាន់ប្រាំបីរយម៉ែត្រ និងប្រាំពីរម៉ែត្រ(៤៨០៧ម៉ែត្រ)។ ពីភ្នំអាល់ដែលជាជួរភ្នំចំកណ្តាល មានរបស់វាសាខាសណ្តូកតាមទិសផ្សេងៗគ្នា។ នៅភាគខាងលិច មានសាខាមួយទៀតនៃភ្នំបន្តកាត់តាមសមុទ្រមេឌីទែរ៉ានេ និងលេចចេញជា ពីរ៉េនី(Pyrenees)ដែលបានបង្កើតជាព្រំដែនរវាងអេស្ប៉ាញនិងបារាំង។

នៅឆ្ងាយទៅចុងខាងលិចទៀត វាបង្កើតជាជួរភ្នំខាន់តាប្រៀនCantabrain នៅភាគខាងជើងប្រទេសអេស្ប៉ាញ។

ជួរភ្នំអាភិនណាញស៍(Apennine)រត់ឆ្ពោះទៅភាគខាងត្បូងតាមឧបទ្វីបអ៊ីតាលីឆ្លងកាត់ក្រុងស៊ីស៊ីលី (Sicily) ហើយលេចឡើងម្តងទៀត នៅក្នុងទ្វីបអាហ្វ្រិក ជាភ្នំអាតាឡាស(Atlas)។

នៅចុងភាគខាងកើតនៃភ្នំអាល់ ជួរភ្នំត្រូវបានបែងចែកជាពីរផ្នែក ដែលជួរភ្នំមួយរត់តាមទិសអាគ្នេយ៍ វាជាជួរភ្នំអាល់ឌីណារីក (the Dinaric Alps) ចំណែកឯជួរភ្នំទី២ស្ថិតនៅចុងភាគខាងកើតនៃភ្នំអាល់ ជាខ្សែភ្នំកាច់កោងចុះទៅរកសមុទ្រខ្មៅ បង្កើតបានជាជួរភ្នំខាប៉ាស្យែន(Carpathian Mountains) ជួរភ្នំអាល់ត្រែនស៊ីលវ៉ានៀន(Transylvanian Alps) និងជួរភ្នំបាល់កន(Balkan Mountains)។

នៅចន្លោះសមុទ្រខ្មៅ និងសមុទ្រកាសព្យែនមានជួរភ្នំកូកាស។ ភ្នំអែលប្រ្ុស៍ជាភ្នំភ្លើងងាប់ ហើយវាជាភ្នំដែលមានកំពូលខ្ពស់ជាគេបំផុតនៅទ្វីបអឺរ៉ុប ក៏ស្ថិតនៅលើជួរភ្នំកូកាសនេះដែរ។ ម៉ាធើហន គឺស្គាល់ច្បាស់ជាកំពូលភ្នំអាល់។

វាមានកម្ពស់៤៤៨៤ម៉ែត្រស្ថិតនៅប្រទេសស្វីស ជាប់នឹងព្រំប្រទល់ប្រទេសអ៊ីតាលី។ វាជាកំពូលភ្នំមួយក្នុងចំណោមភ្នំនានាដែលមានទេសភាពស្អាតល្បីល្បាញបំផុតក្នុងលោក។

ទន្លេវ៉ុលហ្គា គឺជាទន្លេដែលវែងជាងគេបង្អស់នៅទ្វីបអឺរ៉ុបដែលមានប្រភពពីបឹងតូចមួយនៅក្នុងតំបន់វាលដៃហៀល(Valdai hills)និងហូរកាត់ប្រទេសរុស្ស៊ីមុនពេលហូរចាក់ចូលក្នុងសមុទ្រកាសព្យែន។ វាមានប្រវែង៣៦៨៥គីឡូម៉ែត្រ។ ម៉ូស្គូ គឺជាទីក្រុងដ៏សំខាន់មួយស្ថិតនៅលើដងទន្លេនេះ។

ទន្លេដានូប គឺជាទន្លេដែលវែងជាងគេទីពីររបស់ទ្វីបអឺរ៉ុប។ វាមានប្រវែង២៨៥៧គីឡូម៉ែត្រ។ វាមានប្រភពពីនៅតំបន់ព្រៃខ្មៅនៃប្រទេសអាល្លឺម៉ង់ហើយហូរកាត់ប្រទេសមួយចំនួនធំ ពីតំបន់ភ្នំអាល់ត៍ឆ្ពោះទៅសមុទ្រខ្មៅ។ វាគឺជាទន្លេតែមួយគត់នៅទ្វីបអ៊ឺរ៉ុបដែលហូរទៅខាងកើត និងជាផ្លូវទឹកដឹកជញ្ជូនដ៏សំខាន់មួយនៃទ្វីបអឺរ៉ុប។ ទីក្រុងវៀនណានៅក្នុងប្រទេសអូទ្រីស ទីក្រុងប៊ុយដាប៉េក្នុងប្រទេសហុងគ្រី និងទីក្រុងប៊ែលក្រាដនៅក្នុងប្រទេសស៊ែរប៊ី គឺជាទីក្រុងសំខាន់ៗនៅតាមដងទន្លេ។

ទន្លេរាញ(Rhine) គឺជាទន្លេដ៏មមាញឹកបំផុតនៃទ្វីបអឺរ៉ុប។ វាហូរឆ្ពោះទៅទិសខាងជើង មានពីប្រភពពីភ្នំអាល់ស៍ មាត់របស់វានៅឆ្នេរសមុទ្រខាងជើង ដែលវាបង្កើតជាតំបន់ដីសណ្តទន្លេមួយ។ វាក៏មានភាពល្បីល្បាញ ខាងទេសភាពស្រស់បំព្រងនៃជ្រលងរីហ្វត៍របស់ខ្លួនផងដែរ (Rift Valley)។ ទន្លេរួ(Ruhr)គឺជាទន្លេតូចមួយ ប៉ុន្តែជាដៃទន្លេដ៏សំខាន់របស់ទន្លេរាញ(Rhine)។ រូធើដែម(Rotterdam)ជាកំពង់ផែនាំមុខគេនៅអឺរ៉ុប ស្ថិតនៅមាត់ទន្លេរាញ(Rhine)។

ទន្លេសេម(Thames) គឺជាទន្លេដ៏សំខាន់បំផុតរបស់ប្រទេសអង់គ្លេស។ វាក៏ជាទន្លេវែងបំផុតនៅក្នុងប្រទេសអង់គ្លេសផងដែរ។ វាមានប្រវែង346គីឡូម៉ែត្រ មានប្រភពពីភ្នំCotswold នៅភាគខាងត្បូងផ្នែកកណ្ដាលប្រទេសអង់គ្លេស ទៅភាគអាគ្នេយ៍ ជាកន្លែងដែលវាហូរចាក់ចូលទៅក្នុងសមុទ្រខាងជើង។

ទន្លេនីភើ(Dnieper) គឺជាទន្លេដែលវែងជាងគេទីបីនៃទ្វីបអឺរ៉ុប។ វាបានកើនឡើងនៅជិតប្រភពនៃតំបន់វ៉ុលហ្គានិងហូរតាមប្រទេសរុស្ស៊ីនិងអ៊ុយក្រែនមុនពេលហូរចូលទៅក្នុងសមុទ្រខ្មៅ ខណៈទន្លេដុនបានហូរកាត់ប្រទេសរុស្ស៊ី។ វាបែកចេញជាដៃទន្លេបី បង្កើតបានជាដីសណ្ដរដ៏ធំនៅតាមឆ្នេរសមុទ្រអាហ្សូវ នៅភាគខាងជើងនៃសមុទ្រខ្មៅ។

ទន្លេវីស្ទូឡា (Vistula) គឺជាទន្លេដែលហូរនៅភាគខាងជើងដែលហូរកាត់ប្រទេសប៉ូឡូញនិងហូរចាក់ចូលទៅក្នុងសមុទ្របាល់ទិក(Baltic)។ វ៉ស គឺជារដ្ឋធានីរបស់ប្រទេសប៉ូឡូញ ជាទីក្រុងដ៏សំខាន់មួយ នៅតាមមាត់ទន្លេនេះ។

អូឌ័រ(Oder)គឺជាទន្លេនៃប្រទេសអាល្លឺម៉ង់ដែលហូរចូលទៅក្នុងសមុទ្របាល់ទិក។

ទន្លេអែលប៍ (Elbe) ហូរឆ្ពោះទៅទិសខាងជើងកាត់តាមអាឡឺម៉ង់ហើយហូរចាក់ចូលទៅក្នុងសមុទ្រខាងជើង។ ហាំប៊ឺម(Hamburg)នៅលើមាត់ទន្លេនេះ គឺជាកំពង់ផែឈានមុខគេមួយរបស់អាល្លឺម៉ង់។

ទន្លេសែន(Seine) និងទន្លេល័រ(Loire) និងទន្លេហ្គារូន(Garonne) គឺជាទន្លេដែលហូរនៅទិសខាងលិចប្រទេសនៃប្រទេសបារាំង។ ទន្លេសែន(Seine) បានហូរចាក់ចូលទៅក្នុងឈូងសមុទ្រអង់គ្លេស។ ទីក្រុងប៉ារីសស្ថិតនៅលើច្រាំងទន្លេសែននេះ ហើយនិងឡឺហាវ្រ( Le Havre) គឺជាកំពង់ផែសមុទ្រឈានមុខគេរបស់ប្រទេសបារាំងដែលមានទីតាំងនៅមាត់ទន្លេនេះ។ ទន្លេល័រ(Loire) និងទន្លេ(Garonne) ហូរចូលទៅក្នុងឆកសមុទ្របឺស្កាយ(Biscay Bay)។ ទន្លេល័រ(Loire) គឺជាទន្លេដែលវែងបំផុតរបស់ប្រទេសបារាំង។ រ៉ូន (Rhone)គឺជាទន្លេដែលហូរកាត់ឆ្ពោះទៅទិសភាគខាងត្បូងនៃប្រទេសបារាំង ដែលហូរចាក់ចូលទៅក្នុងសមុទ្រមេឌីទែរ៉ាណេ(Mediterranean)។ ម៉ាសី(Marseille) គឺជាកំពង់ផែដ៏សំខាន់មួយនៅមាត់នេះ។

ទន្លេឌួរ៉ូ(Douro)និងទន្លេតាគីស(Tagus) ជាទន្លេពីរហូរកាត់ប្រទេសអេស្ប៉ាញនិងប្រទេសព័រទុយហ្គាល់ ហូរចាក់ចូលទៅក្នុងមហាសមុទ្រអាត្លង់ទិច។ ទីក្រុងលីស្បូន(Lisbon) រដ្ឋធានីព័រទុយហ្គាល់មានទីតាំងស្ថិតនៅមាត់តាគីសនេះ។

ទន្លេប៉ូ(PO)គឺជាទន្លេវែងជាងគេបំផុតរបស់ប្រទេសអ៊ីតាលី។ វាមានប្រភពមកពីតំបន់ភ្នំអាល់ស៍ជិតព្រំប្រទល់ប្រទេសបារាំង នៅតាមដងទន្លេមានទំនាបមានដីជាតិឡំបាឌី(Lombardy) ទន្លេនេះវាហូរចាក់ចូលទៅក្នុងសមុទ្រអាដ្រៀទិក(Adriatic Sea)។ ទីក្រុងទូរីន(Turin)ជាទីក្រុងល្បីល្បាញជាងគេស្ថិតនៅតាមដងទន្លេនេះ។

## សំណួរត្រិះរិះ

១. តើគេអាចចែកចេញជាបីតំបន់សណ្ឋានដីទ្វីបអឺរ៉ុប? អ្វីខ្លះ? ចូរបង្ហាញ។

២. តើទន្លេសំខាន់នៅទ្វីបអឺរ៉ុបមានឈ្មោះអ្វីខ្លះ?

៣. តើនៅទ្វីបអឺរ៉ុបមានសារសំខាន់អ្វីខ្លះ?

# មេរៀនទី៣៖ អាកាសធាតុ រុក្ខជាតិ និងសត្វព្រៃនៅទ្វីបអឺរ៉ុប

## ១. ស្ថានភាពទូទៅនៃអាកាសធាតុទ្វីបអឺរ៉ុប

លក្ខណៈសំខាន់មួយទៀតរបស់អឺរ៉ុបគឺអាកាសធាតុល្អ។ កត្តាដែលកំពុងជះឥទ្ធិពលដល់អាកាសធាតុនៃទ្វីបអឺរ៉ុបគឺៈ

- រយៈទទឹងរបស់ទ្វីប ដែលធ្វើឱ្យទ្វីបមានអាកាសធាតុត្រជាក់បង្គួរ។
- មានចរន្តទឹកក្តៅមហាសមុទ្រអាត្លង់ទិចខាងជើងនៅជិតទ្វីប ដែលនាំទៅកាន់ឆ្នេរអាត្លង់ទិចនៃទ្វីបអឺរ៉ុប ធ្វើឱ្យឆ្នេរភាគខាងលិចអឺរ៉ុបមានភាពកក់ក្តៅជាងកន្លែងដទៃ ដែលមានរយៈទទឹងដូចគ្នា។
- ហើយនិងមានចរន្តខ្យល់ក្តៅ( Westerlies ខ្យល់បកពីត្រូពិច ) ដែលបក់ចូលទៅក្នុងទ្វីបអឺរ៉ុបធ្វើឱ្យមានសីតុណ្ហភាពកក់ក្តៅ ប្រសិនមិនដូច្នេះទេវានឹងមានអាកាសធាតុត្រជាកជាងនេះ។






គេចែកអាកាសធាតុទ្វីបអឺរ៉ុបជាប្រាំតំបន់សំខាន់ៗគឺៈ ប្រភេទអង់គ្លេស(The British type) ប្រភេទអាកាសធាតុទ្វីប(the Continental type) ប្រភេទមេឌីទែរ៉ាណេ(The Mediterranean type) ប្រភេទតៃហ្គា(Taiga) និងប្រភេទទុន្ដ្រា(Tundra type)។

អាកាសធាតុអឺរ៉ុបត្រជាក់បង្គួរស្ទើរតែគ្រប់កន្លែងទាំងអស់ លើកលែងតែនៅក្នុងប្រទេសរុស្ស៊ី។ ហើយស្ទើរគ្រប់កន្លែងទាំងអស់មានទឹកភ្លៀងច្រើន លើកលែងតែតំបន់អឺរ៉ុបខាងកើតប៉ុណ្ណោះ។

## ២. អាកាសធាតុអង់គ្លេស

ប្រភេទអាកាសធាតុអង់គ្លេសត្រូវបានរកឃើញនៅអឺរ៉ុបខាងលិច។ វារាប់បញ្ចូលទាំងភាគខាងជើងប្រទេសអេស្ប៉ាញ ភាគពាយ័ព្យប្រទេសបារាំង បែលហ្ស៊ិក ហូឡង់ ដាណឺម៉ាក ន័រវែសខាងលិច កោះអង់គ្លេស និងប្រទេសអាយឡិនដ៍។ ឥទ្ធិពលអាកាសធាតុមធ្យមនៃសមុទ្រ ចរន្តទឹកក្តៅអាត្លង់ទិចខាងជើង និងចរន្តខ្យល់ក្តៅ(Westerlies) ធ្វើឱ្យតំបន់មានអាកាសធាតុមធ្យម។ រដូវក្តៅមានភាពកក់ក្តៅមិនក្តៅ ហើយរដូវរងាត្រជាក់តែមិនត្រជាក់ខ្លាំង។ ចរន្តខ្យល់ក្តៅ( Westerlies) នាំមកនូវទឹកភ្លៀងយ៉ាងច្រើនពេញមួយឆ្នាំ។ ទោះយ៉ាងណាក៏ដោយមានភ្លៀងធ្លាក់ច្រើនក្នុងរដូវរងារ នៅពេលដែលសមត្ថភាពនៃខ្យល់ត្រជាក់ផ្ទុកសំណើមធ្លាក់ចុះ(កើនកំដៅ។ ព្យុះភ្លៀងក៏កើតមានច្រើនផងដែរនៅក្នុងរដូវរងា។

លក្ខណៈមួយនៃអាកាសធាតុអង់គ្លេស គឺសំណើមច្រើននិងពពកច្រើន និងការផ្លាស់ប្ដូរជាញឹកញាប់ ដែលបណ្ដាលមកពីសម្ពាធខ្យល់(វិសម្ពាធ)។ ប្រភេទអាកាសធាតុនេះ ត្រូវបានគេស្គាល់ផងដែរថា ជាប្រភេទអាកាសធាតុ សមុទ្រ មហាសមុទ្រ និងប្រភេទអាកាសអឺរ៉ុបខាងលិច។

លក្ខណៈចម្បងនៃអាកាសធាតុអង់គ្លេស គឺនៅរដូវរងាសីតុណ្ហភាពមធ្យម ទោះបីជាស្ថិតនៅក្នុងតំបន់ដែលមានរយៈទទឹងខ្ពស់ក៏ដោយ ហើយនិងមានបរិមាណទឹកភ្លៀងគ្រប់គ្រាន់រាយប៉ាយពេញតំបន់ពេញមួយឆ្នាំ។

ព្រៃជ្រុះស្លឹកសម្របតាមអាកាសធាតុត្រជាក់បង្គួរ គឺជារុក្ខជាតិដុះនៅតំបន់ប្រភេទអាកាសធាតុអង់គ្លេស។ ដើមឈើដែលមានដើមក្រាស និងស្លឹកធំៗ ដូចជាដើមអូក(oak) អេល(elm) មែបភល(maple) ប៊ីច(beech) និងដើមប៊ើច(birch) ជាដើមឈើឃើញមានជាទូទៅនៅទីនេះ។ ឈើទាំងនេះជ្រុះស្លឹកស្លឹកនៅក្នុងរដូវសរទរដូវ(២២កញ្ញា ដល់២១ធ្នូ) ដែលត្រូវបានគេស្គាល់ផងដែរថាជារដូវស្លឹកឈើជ្រុះ។

Oak Elm Maple Beech Birch







មិនមានសត្វព្រៃច្រើនទេនៅអឺរ៉ុបខាងលិច ក្រៅពីសត្វកញ្ជ្រោង សត្វក្ដាន់ សត្វចចក សត្វទន្សាយ ប៊ីវើ(beavers)និងសត្វកាំប្រមា។



## ៣. អាកាសធាតុទ្វីប

ប្រភេទអាកាសធាតុទ្វីបមានតំបន់នៅអឺរ៉ុបកណ្ដាល អឺរ៉ុបខាងកើត និងរុស្ស៊ី។ ដោយសារតំបន់នេះនៅឆ្ងាយពីឥទ្ធិពលនៃអាកាសធាតុមធ្យម ដែលទទួលឥទ្ធិពលពីសមុទ្រ អាកាសធាតុគឺអាក្រក់ខ្លាំង។ រដូវក្ដៅ គឺក្ដៅខ្លាំង ហើយនៅរដូវរងាគឺត្រជាក់ខ្លាំង។

កម្រិតសីតុណ្ហភាពប្រចាំឆ្នាំ គឺមានគម្លាតពីគ្នាខ្លាំង និងគម្លាតកាន់តែខ្លាំងជាងនេះ កាលឃ្លាតកាន់តែឆ្ងាយពីខាងលិចទៅកើត ហើយគម្លាតខុសគ្នាខ្លាំងជាអតិបរមានៅរុស្ស៊ី ដោយសារតែឥទ្ធិពលអាកាសធាតុសមុទ្រធ្លាក់ចុះខ្សោយ។

ទឹកភ្លៀងក៏ថយចុះដែរពីលិចទៅខាងកើត។ ទឹកភ្លៀងនៅរដូវក្តៅ មានកម្រិតចាប់ពីមធ្យមថយចុះរហូតទៅដល់កម្រិតតិចតួច។ តំបន់នេះស្ថិតនៅក្នុងតំបន់ចរន្តខ្យល់ក្តៅ(Westerlies) តែតំបន់នេះ (Westerlies)មិននាំមកនូវភ្លៀងច្រើនពេកទេ ព្រោះវាជាខ្យល់ក្តៅ មានភាពស្ងួតនៅពេលដែលវាចូលទៅក្នុងទ្វីប។ តំបន់នេះត្រូវបានគេហៅថាអាកាសធាតុអឺរ៉ុបកណ្តាលផងដែរ។

ដោយសារទឹកភ្លៀងមិនគ្រប់គ្រាន់គ្រប់គ្រាន់ ដើម្បីទ្រទ្រង់ការលូតលាស់របស់ដើមឈើ រុក្ខជាតិ នៅទីនេះមានស្មៅលូតលាស់ទាបជាង និងមិនល្អជាស្មៅតំបន់ត្រូពិច។ ទោះជាយ៉ាងណាក៏ដោយ ដីភាគច្រើនត្រូវបានគេកាប់ឆ្ការសម្រាប់យកដីធ្វើកសិកម្ម ហើយដំណាំដូចជាស្រូវសាលី ស្រូវសាលីរាយ ស្រូវសាលីបាលី និងធញ្ញជាតិផ្សេងទៀតត្រូវបានដាំនៅទីនេះ។

សត្វដូចជាសត្វឈ្លូស (antelopes ) សេះ និងចចក មានរស់នៅក្នុងតំបន់នេះ។

## ៤. អាកាសធាតុមេឌីទែរ៉ាណេ

អាកាសធាតុមេឌីទែរ៉ាណេត្រូវបានរកឃើញនៅក្នុងតំបន់នេះ ដែលមានព្រំប្រទល់ជាមួយសមុទ្រមេឌីទែរ៉ាណេរួមមានប្រទេសអេស្ប៉ាញ ព័រទុយហ្គាល់ ខាងត្បូងបារាំង អ៊ីតាលី ក្រូអាត បូស្នៀនិងហឺហ្ស៊ីហ្គោវីណា យូហ្គូស្លាវី អាល់បានី និងក្រិក។

រដូវក្តៅមានអាកាសធាតុក្តៅ ហើយរដូវរងាមានអាកាសធាតុមធ្យម និងមានភ្លៀងមធ្យមនៅរដូវរងា។

នៅក្នុងខែរដូវក្តៅ តំបន់នេះស្ថិតនៅក្រោមឥទ្ធិពលនៃអាកាសធាតុខ្យល់ជំនួញឆ្ងាយពីឆ្នេរសមុទ្រ។ ចាប់តាំងពីខ្សែក្រវ៉ាត់សម្ពាធខ្ពស់អនុតំបន់ត្រូពិចធ្វើចលនាឆ្ពោះភាគខាងជើង។ ខ្យល់ទាំងនេះស្ងួតហើយមិនមានទឹកភ្លៀងទេ។

ក្នុងរដូវរងា នៅពេលដែលខ្សែក្រវ៉ាត់សម្ពាធខ្ពស់អនុតំបន់ត្រូពិច បក់ឆ្ពោះទៅទិសត្បូង តំបន់នេះស្ថិតនៅក្រោមឥទ្ធិពលនៃចរន្តខ្យល់ក្តៅ(Westerlies)តាមឆ្នេរសមុទ្រ។

រុក្ខជាតិធន់ទៅនឹងអាកាសធាតុតាមរបៀបផ្សេងៗ ដើម្បីទប់ទល់នឹងរដូវក្តៅនិងរាំងស្ងួត។ ដើមឈើខ្ពស់ គឺកម្រមានណាស់។ អូក(Oak), វាលណាត់(Walnut), អាល់ម៉ុង(almond), ល្វា(fig), ក៏ដូចជាដើមឈើសេដា(Cedar)និងដើមឈើត្រូវបានគេរកឃើញមានដុះនៅទីនេះ។

Cedar Tree



Oak Tree



Walnut



Almond



Fig tree



Firs tree



ដើមឈើដូចជាដើមអូកមានរាងកោងសំបកក្រាស់ដែលការពារមិនឱ្យបាត់បង់សំណើម។ ទំពាំងបាយជូរមានឫសវែងសម្រាប់ស្រូបទឹកពីក្នុងដី។ រុក្ខជាតិដូចជាក្រូចឆ្មារ ក្រូចពោធិ៍សាត់ និងឡារ៉ែល(Laurel)មានស្លឹកតូចៗ ដើម្បីកាត់បន្ថយការបាត់បង់ទឹកតាមរយៈការបែកញើស។ ដើមអូលីវមានស្លឹកមានជាតិក្រមួនដើម្បីការពារកុំឱ្យបាត់បង់ទឹក។

សត្វព្រៃនៅទីនេះមិនមានច្រើនទេ ដោយសារគេកាប់ឆ្ការព្រៃ ដើម្បីយកដីសម្រាប់ធ្វើកសិកម្ម។

## ៥. អាកាសធាតុតៃហ្គា

តំបន់អាកាសធាតុតៃហ្គា(Taiga) លាតសន្ធឹងបន្តពីប្រទេសន័រវែសនៅភាគខាងលិច ប្រទេសរុស្ស៊ី និងស៊ីបេរីនៅខាងកើត។ រដូវរងាមានអាកាសធាតុត្រជាក់ខ្លាំងមែនទែន និងមានរយៈពេលប្រហែល៧ខែ។ រដូវក្ដៅមានអាកាសធាតុកក់ក្ដៅ ហើយខ្លី។ ទឹកភ្លៀងប្រែប្រួលចាប់ពីតិចតួចទៅកម្រិតមធ្យម ភាគច្រើនភ្លៀងធ្លាក់នៅរដូវក្ដៅ។ បរិមាណទឹកភ្លៀងមានច្រើនជិតឆ្នេរ និងថយចុះបន្តិចម្ដងៗឆ្ពោះទៅក្នុងទ្វីប។ ភាគច្រើននៃភ្លៀងមានលក្ខណៈជាព្រិល។ រុក្ខជាតិរួមមាន ព្រៃបៃតងដែលមានដើមឈើដែលមិនជ្រុះស្លឹក ហេតុដូច្នេះហើយ ព្រៃឈើទាំងនេះមានពណ៌បៃតងពេញមួយឆ្នាំ មិនដូចព្រៃឈើដែលជ្រុះស្លឹកទេ។ ដើមឈើធម្មតា ដែលមាននៅទីនេះ មានដើមស្រល់, fir, spruce និង cedar។

សត្វនៅទីនេះ មានតិចតួច ហើយភាគច្រើនតូចៗ។ សត្វដែលមានរោមក្រាស ដូចជា ឆ្មាទឹកកក (Lynx), មីង(mink), សេប៊ិល(sable) និងកំប្រុក(squirrel) មានរស់នៅទីនេះ។

Lynx



Mink



Sable



## ៦. អាកាសធាតុទុនដ្រា

តំបន់អាកាសធាតុទុនដ្រា(Tundra) ស្ថិតនៅក្នុងតំបន់អាកទិក។ វាស្ថិតនៅភាគខាងជើងនៃប្រទេសន័រវេ ស៊ុយអែត ហ្វាំងឡង់ និងរុស្ស៊ី។ រដូវរងាមានរយៈពេលយូរ ហើយត្រជាក់ខ្លាំងមែនទែន ហើយរដូវក្ដៅមានរយៈពេលខ្លីនិងមានអាកាសធាតុត្រជាក់។

ទឹកភ្លៀងមានតិចតួច ភាគច្រើនមានទម្រង់ជាព្រិល។

រុក្ខជាតិនៅទីនេះ មានដុះរ៉ុយៗ ដោយសារដីកកនៅពេញមួយឆ្នាំ។ ស្លែ និងលីកែន lichens មានដុះនៅទីនេះ។ រុក្ខជាតិប្រភេទនេះអាចទប់ទល់ជាមួយនឹងអាកាសធាតុត្រជាក់យ៉ាងខ្លាំង ហើយអាចរស់បានដោយសារមានសំណើមតិចតួច។ វាអាចរស់ក្រោមព្រិលទឹកកក។

ក្នុងអំឡុងរដូវក្ដៅខ្លី ដីមានទេសភាពស្រស់ស្អាត ដោយសារមានផ្ការីកស្គុះស្គាយ។ ដើមឈើមិនអាចដុះនៅទីនេះបានទេ ពីព្រោះខាងលើផ្ទៃដីកកនៅរដូវរងា ហើយដីស្រទាប់ក្រោមកកជាអចិន្ត្រៃយ៍។

សត្វមាំង គឺជាសត្វសំខាន់បំផុត នៅក្នុងតំបន់អាកាសធាតុទុនដ្រានេះ ជាមួយនេះដែរក៏មានត្រីបាឡែន គេសមុទ្រ តោសមុទ្រ កញ្ជ្រោងអាទិក ខ្លាឃ្មុំប៉ូល គោតំបន់ទឹកកក និងខ្លាតំបន់ទឹកកក។

ភាគខាងជើងនៃប្រទេសន័រវែស ស៊ុយអែត ហ្វាំងឡង់ និងភាគខាងជើងនៃប្រទេសរុស្ស៊ី អ័ក្សផែនដីផ្អៀងឆ្ពោះទៅរកព្រះអាទិត្យនៅរដូវក្ដៅ ធ្វើឱ្យមានពន្លឺមិនពេញលេញ24ម៉ោង។ ដូច្នេះនៅរដូវក្ដៅព្រះអាទិត្យអាចមើលឃើញ សូម្បីតែនៅពាក់ កណ្ដាលអធ្រាត្រ។ ក្នុងរដូវរងារតំបន់នេះ ស្ថិតក្នុងភាពងងឹត។ មិនមានពន្លឺព្រះអាទិត្យរយៈពេល 6 ខែ។

### សំណួរត្រិះរិះ

១. តើទ្វីបអឺរ៉ុបមានអាកាសធាតុយ៉ាងដូចម្ដេច? ដោយសារកត្តាអ្វីខ្លះ ដែលធ្វើឱ្យអឺរ៉ុបមានអាកាសធាតុបែបនេះ?

២. តើគេចែកអាកាសធាតុទ្វីបអឺរ៉ុបជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

៣. ចូរបង្ហាញពីលក្ខណៈអាកាសធាតុ រុក្ខជាតិ និងសត្វព្រៃនៅអឺរ៉ុប។

# មេរៀនទី៤៖ ធនធានធម្មជាតិនៅទ្វីបអឺរ៉ុប

## ១. ធនធានធម្មជាតិ

អឺរ៉ុបសម្បូរទៅដោយធនធានធម្មជាតិ។ អឺរ៉ុបមានភាពរុងរឿងអាស្រ័យប្រើប្រាស់ដោយបញ្ញានូវធនធានធម្មជាតិ មានមនុស្សខ្លាំង មានការអប់រំ និងស្ទិតស្វាញក្នុងការងារ។ ជាទូទៅ ផ្ទៃដីភាគច្រើន នៅក្នុងទ្វីបអឺរ៉ុបមានលក្ខណៈសមស្របសម្រាប់ការដាំដុះដោយមានការប្រើប្រាស់វិធីសាស្ត្រវិទ្យាសាស្ត្រ និងបច្ចេកទេស។ នៅលើភ្នំដែលដីមិនសមរម្យសម្រាប់ការដាំដុះ វាត្រូវបានប្រើជាវាលស្មៅសម្រាប់ចិញ្ចឹមសត្វ ឬធ្វើជាកន្លែងទេសភាពដែលមានលក្ខណៈជាធម្មជាតិឱ្យមានភាពស្រស់ស្អាតដើម្បីជំរុញវិស័យទេសចរណ៍។

សម្បូរកំណាប់រ៉ែ ជាពិសេសរ៉ែធ្យូងថ្ម និងដែកត្រូវបានប្រើប្រាស់ ដើម្បីអភិវឌ្ឍវិស័យឧស្សាហកម្ម។

អឺរ៉ុបសម្បូរទៅដោយធនធានទឹក។ ន័រវែគឺជាប្រទេសដំបូងគេនៅលើពិភពលោក ដែលបានអភិវឌ្ឍវារីអគ្គិសនី។

នៅប្រទេសដែលដីមិនសមស្របសម្រាប់ធ្វើកសិកម្ម ឬក៏មានតូចពេកប្រជាជន បានងាកទៅរកស៊ីតាមសមុទ្រ ពួកគេចិញ្ចឹមជីវិត ដោយធ្វើការនេសាទ ដើរកប៉ាល់ និងការធ្វើពាណិជ្ជកម្មក្រៅប្រទេស។

ឧស្សាហកម្មផលិតផលិតផលសម្រេច។ ឧទាហរណ៍ប្រទេសស្វ៊ីស ត្រូវបានគេស្គាល់ថា ជាប្រទេសផលិតនាឡិកា។

ប្រហែលជា 1/ 3 នៃផ្ទៃដីនៅទ្វីបអឺរ៉ុបត្រូវបានដាំដុះ។ ដំណាំផ្សេងៗ ជាច្រើនត្រូវបានដាំដុះនៅទីនេះអាស្រ័យទៅលើដី អាកាសធាតុ និងកំលាំងពលកម្មគ្រប់គ្រាន់។ ការធ្វើកសិកម្ម ជាទូទៅនៃទ្វីបអឺរ៉ុប គឺធ្វើកសិកម្មចំរុះ កសិកម្មមានទំហំធំៗ និងកសិកម្មប្រពលវប្បកម្ម(អតិផល)។ ការដាំដុះត្រូវបានធ្វើតាមបែបវិទ្យាសាស្ត្រ។

ការងារជាច្រើននៅទីនេះត្រូវបានគេធ្វើដោយដៃ ដោយសារតែប្រភេទនៃដំណាំ។ ដំណាំអាហារសំខាន់ៗមួយចំនួនរបស់ទ្វីបអឺរ៉ុប រួមមានស្រូវសាលី ដែលជាអាហារមូលដ្ឋាន និងដំណាំសំខាន់បំផុតរបស់ទ្វីបអឺរ៉ុប។ វាត្រូវបានគេដាំដុះនៅតំបន់ទំនាបធំអឺរ៉ុប ប្រទេសអ៊ុយក្រែន ប្រទេសរុស្ស៊ី ជ្រលងភ្នំប៉ូ(PO)ក្នុងប្រទេសអ៊ីតាលី អាងប៉ារីសនៅបារាំង និងតំបន់ទំនាបនៃប្រទេសហុងគ្រីនិង រ៉ូម៉ានី។

ដំណាំដ៏សំខាន់ផ្សេងទៀតនៃទ្វីបអឺរ៉ុបគឺbarley, rye, oats និងដំឡូងបារាំង។

ដំឡូងបារាំងត្រូវបានដាំដុះយ៉ាងច្រើន នៅប្រទេសបារាំង អាឡឺម៉ង់ ហូឡង់ ប៉ូឡូញ និងអៀរឡង់។

បាលី(ស្រូវសាលីម្យ៉ាង) Barley     រាយRye(ស្រូវសាលីម្យ៉ាង)     អូតស៍Oats(ស្រូវសាលីម្យ៉ាង)





Suger Beet និង Flax គឺជាដំណាំរកចំណូលដ៏សំខាន់នៃទ្វីបអឺរ៉ុប។

Sugar beet



Flax





Flax ដុះលូតលាស់បានយ៉ាងល្អ នៅក្នុងបណ្ដាប្រទេសដែលមានព្រំប្រទល់ជាមួយសមុទ្របាល់ទិកខាងជើងប្រទេសរុស្ស៊ី បារាំង និងបែលហ្ស៊ិក។

ផ្លែក្រូចដូចជាក្រូចពោធិ៍សាត់ ទំពាំងបាយជូរ ក្រូចឆ្មា ក្រូចថ្លុងនិងផ្លែឈើដទៃទៀតដូចជាអូលីវ ផ្លែល្វា និងPeaches ក៏បានដាំដុះផងដែរ។ ប្រទេសហូឡង់ដាំផ្កា និងបន្លែ នៅលើដីដែលដណ្ដើមបានពីសមុទ្រ។ ការធ្វើប្រពលវប្បកម្មប្រើប្រាស់ដី ដើម្បីដាំផ្កានិងបន្លែសម្រាប់លក់ ត្រូវបានគេស្គាល់ថាជាផ្សារសួនបន្លែ។ បែលហ្ស៊ិកក៏ដាំដុះផ្លែឈើនិងបន្លែផងដែរ។

ប្រហែលមួយភាគប្រាំនៃដីនៅទ្វីបអឺរ៉ុបត្រូវបានគ្របដណ្ដប់ដោយវាលស្មៅ ដែលត្រូវបានប្រើជាវាលស្មៅសម្រាប់ចិញ្ចឹមសត្វ។ អាកាសធាតុត្រជាក់និងមានសំណើម គឺល្អខ្លាំងណាស់សម្រាប់ការចិញ្ចឹមសត្វយកទឹកដោះ។ ការចិញ្ចឹមសត្វយកទឹកដោះ ត្រូវបានគេធ្វើនៅក្នុងតំបន់ជុំវិញសមុទ្រខាងជើង និងប្រទេសដាណឺម៉ាក។

ប្រទេសហូឡង់ គឺមានឈ្មោះល្បីល្បាញលើពិភពលោកខាងផលិតប្រហុក(អឺរ៉ុបឈីស)។

ជ្រូកត្រូវបានចិញ្ចឹមសម្រាប់យកសាច់ និងបសុបក្សីសម្រាប់យកសាច់និងស៊ុត។ ការចិញ្ចឹមសត្វចៀមរាយប៉ាយពេញចក្រភពអង់គ្លេស បារាំង និងតំបន់មេឌីទែរ៉ាណេ។ សត្វពពែត្រូវបានចិញ្ចឹមនៅតំបន់មានអាកាសធាតុស្ងួតក្នុងតំបន់មេឌីទែរ៉ាណេ។

ព្រៃឈើនិងការនេសាទក៏ជាផ្នែកសំខាន់មួយនៃអាជីពរបស់អឺរ៉ុបផងដែរ។ ប្រហែល 1/4 នៃដីត្រូវបានគ្របដណ្ដប់ដោយព្រៃឈើ។

ដើមឈើសាច់ទុនដូចជា spruce, willow, Beech, oak និងស្រល់ ត្រូវបានគេឃើញមានដុះនៅទូទាំងប្រទេសន័រវេ ស្វីស ហ្វាំងឡង់ និងរុស្ស៊ី។

ដើមឈើទាំងនេះត្រូវបានប្រើសម្រាប់ផលិតគ្រឿងសង្ហារឹម និងការផលិតជ័រ ក្រដាស សរសៃសំយោគ និងប្រេង(ដូចជាវ៉ានី ថ្នាំ។ល។)។

កន្លែងនេសាទដ៏ល្អបំផុតពីរនៅលើពិភពលោក មានទីតាំងនៅក្នុងទ្វីបអឺរ៉ុប គឺនៅតាមឆ្នេរ Dogger ក្នុងតំបន់សមុទ្រខាងជើង និងឆ្នេរ The Great Fisher នៅតាមតំបន់ជាយទ្វីបនៃប្រទេសអាយឡែនដ៍។ ប្រទេសតាមឆ្នេរសមុទ្រទាំងអស់នៃទ្វីបអឺរ៉ុបធ្វើជំនួយនេសាទត្រី។ ប្រទេសន័រវែសនិងដាណឺម៉ាកគឺជាប្រទេសនាំមុខគេនៅអឺរ៉ុប។ អេស្ប៉ាញ, រុស្ស៊ី, ចក្រភពអង់គ្លេសនិងប៉ូឡូញក៏ជាប្រទេសធ្វើជំនួយដ៏សំខាន់ផងដែរ។

Spruce Willow Oak










Pine



ក្រៅពីដែក អឺរ៉ុបក៏ត្រូវបានរកឃើញថា មានសម្បូរបែបរ៉ែមួយចំនួនទៀតផងដែរ។ ធ្យូងថ្មត្រូវបានគេរកឃើញនៅក្នុងចក្រភពអង់គ្លេស ខ្សែធ្យូងថ្មមួយលាតសន្ធឹងពីភាគឦសានប្រទេសបារាំងឆ្ពោះទៅទៅប្រទេសបែលហ្សិក អាល្លឺម៉ង់ និងប៉ូឡូញ។ កំណប់ធ្យូងថ្មធំៗ ត្រូវបានគេរកឃើញនៅអ៊ុយក្រែននិងរុស្ស៊ី ខណៈដែលកំណាត់ធ្យូងថ្មតូចៗត្រូវបានគេរកឃើញនៅក្នុងប្រទេសអេស្ប៉ាញ និងហុងគ្រី។

កំណប់ប្រេងកាតត្រូវបានគេរកឃើញនៅសមុទ្រខាងជើង កំណប់រ៉ែប្រេងចក្រភពអង់គ្លេស និងន័រវែស។ បរិមាណកំណប់រ៉ែប្រេងដ៏ច្រើនត្រូវបានគេរកឃើញនៅក្នុងប្រទេសរុស្ស៊ី និងរូម៉ានី។

អឺរ៉ុបផលិតបុកស៊ីតក្នុងបរិមាណដ៏ច្រើន ដែលមានផ្ទុកអាលុយមីញ៉ូម។ រ៉ែអាលុយមីញ៉ូមត្រូវបានគេធ្វើអាជីវកម្ម នៅប្រទេសអាល្លឺម៉ង់ បារាំង ន័រវែស ស៊ុីស អូទ្រីស ចក្រភពអង់គ្លេស រុស្ស៊ី និងអ៊ីតាលី។

ស័ង្កសីនិងសំណក៏ត្រូវបានគេរកឃើញផងដែរនៅក្នុងបរិមាណច្រើននៅប្រទេសបែលហ្សិក បារាំង ប៉ូឡូញ អេស្ប៉ាញ និងអាល្លឺម៉ង់។ ក្រៅពីរ៉ែទាំងនេះរ៉ែស្ពាន់ធ័រ និងប៉ូតាស្យូម ត្រូវបានគេរកឃើញផងដែរនៅក្នុងទ្វីបអឺរ៉ុប។

## ២. ការណើសិក្សាពីបដិវត្តន៍ឧស្សាហកម្មនៅចន្លោះសតវត្សរ៍ទី១៨-១៩

ការរកឃើញបច្ចេកវិទ្យាផលិតម៉ាស៊ីនដើរដោយចំហាយទឹក គឺជាគន្លឹះដ៏សំខាន់មួយក្នុងបដិវត្តន៍ឧស្សាហកម្ម នៅចន្លោះសតវត្សរ៍ទី១៨ និងសតវត្សរ៍ទី១៩។

គិតមកត្រឹមសតវត្សរ៍ទី១៨ ប្រជាជនទូទៅនៅលើពិភពលោក ភាគច្រើនលើសលុបរស់នៅក្នុងភូមិតូចៗនៅតាមទីជនបទ ហើយប្រកបរបរចិញ្ចឹមជីវិត ដោយការដាំដុះ ចិញ្ចឹមសត្វ ឬសកម្មភាពសិប្បកម្មផ្សេងទៀត។ ប្រជាជនបរិភោគចំណីអាហារ ដែលបានមកពីដំណាំដែលគេដាំដោយខ្លួនឯង ស្លៀកសម្លៀកបំពាក់ និងប្រើប្រាស់សម្ភារៈ ដែលគេផលិតដោយខ្លួនឯង ហើយសកម្មភាពទិញដូរកើតមានយ៉ាងតិចតួចបំផុត។

នៅពេលនោះអ្វីៗទាំងអស់ត្រូវធ្វើឡើងដោយដៃ ដោយកម្លាំងមនុស្ស ឬសត្វចិញ្ចឹម ដូចជា គោ ក្របី ឬសេះជាដើម ហើយសកម្មភាពផលិតភាគច្រើនធ្វើឡើងតែតាមផ្ទះជាលក្ខណៈគ្រួសារ ដែលផ្តល់ផលក្នុងកម្រិតទាបប្រាក់ចំណូលតិចតួចហើយប្រជាជនភាគច្រើនមានជីវភាពខ្សត់ខ្សោយ។

ក៏ប៉ុន្តែ នៅចុងសតវត្សរ៍ទី១៨ ពិភពលោកបានស្គាល់នូវការវិវឌ្ឍដ៏សំខាន់បំផុតមួយ ដែលគេឲ្យឈ្មោះថា "បដិវត្តន៍ឧស្សាហកម្ម" ជាចំណុចរបត់នៃការផ្លាស់ប្តូររបៀបរស់នៅរបស់មនុស្សជាតិ ពីការពឹងផ្អែកជាចម្បងលើសកម្មភាពកសិកម្មទៅជាការប្រកបរបរចិញ្ចឹមជីវិតដោយសកម្មភាពឧស្សាហកម្ម។

អ្វីៗបានចាប់ផ្តើមឡើង ជាដំបូង នៅក្នុងចក្រភពអង់គ្លេស។ បដិវត្តន៍ឧស្សាហកម្មចាប់ផ្តើមចេញពីអង់គ្លេស ដោយសារកត្តាច្រើនយ៉ាង។ កត្តាសំខាន់ទីមួយ គឺវត្ថុធាតុដើម។ អង់គ្លេស គឺជាប្រទេសដែលសម្បូរទៅដោយរ៉ែធ្យូងថ្ម និងរ៉ែដែក ដែលជាវត្ថុធាតុដើមសំខាន់បំផុត ក្នុងវិស័យឧស្សាហកម្ម។ កត្តាសំខាន់ទីពីរ គឺចំណេះដឹង។ នៅក្នុងអំឡុងសតវត្សរ៍ទី១៨ អង់គ្លេសមានអ្នកប្រាជ្ញល្បីៗជាច្រើន។ អ៊ីសាក់ ញូវតុន (Isaac Newton) ដែលជា អ្នកប្រាជ្ញមានឈ្មោះល្បីល្បាញបំផុតរហូតមកទល់នឹងពេលបច្ចុប្បន្ន នេះ គឺជាអ្នកប្រាជ្ញអង់គ្លេស។ ក្រៅពីញូវតុន អង់គ្លេសនៅមានអ្នកប្រាជ្ញជាច្រើនទៀត ជាពិសេស ខាងផ្នែករូបវិទ្យា និងវិស្វកម្ម។ ចំណេះដឹងរបស់អ្នកប្រាជ្ញទាំងនេះបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបង្កើតបច្ចេកវិទ្យាថ្មីៗជាច្រើន ដូចជាការបង្កើនប្រសិទ្ធភាពក្នុងការប្រើថាមពលទឹក, ការប្រើធ្យូងថ្មជាប្រភពថាមពលជំនួសអុស, ការបង្កើតម៉ាស៊ីនដើរដោយចំហាយទឹក, បច្ចេកទេសក្នុងការផលិតដែកជាលក្ខណៈឧស្សាហកម្ម ព្រមទាំងបច្ចេកទេសខាងផ្នែកមេកានិក ក្នុងការបង្កើតគ្រឿងម៉ាស៊ីនផ្សេងទៀត សម្រាប់ប្រើក្នុងវិស័យផលិតកម្មជំនួសដោយការផលិតដោយដៃ។ ការផលិតដោយប្រើម៉ាស៊ីនទាំងនេះធ្វើឲ្យគេទទួលបានទិន្នផលច្រើន ជាងការផលិតដោយដៃរាប់រយឬរហូតដល់រាប់ពាន់ដង។

កត្តាដ៏សំខាន់មួយទៀតដែលនាំឲ្យមានបដិវត្តន៍ឧស្សាហកម្ម នៅអង់គ្លេស គឺកត្តានយោបាយ និងសង្គម។ ចាប់តាំងពីមានបដិវត្តន៍បង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ នៅចុងសតវត្សរ៍ទី១៧ អង់គ្លេសគឺជាប្រទេសមួយ ដែលមានស្ថិរភាពទាំងផ្នែកនយោបាយ និងសង្គម។ម្យ៉ាងទៀត រដ្ឋាភិបាលអង់គ្លេសតែងតែប្រកាន់យកនូវនយោបាយបើកចំហក្នុងវិស័យ ឯកជន។ ជានយោបាយដែលលើកទឹកចិត្តដល់អ្នកបង្កើតសហគ្រាសឯកជន និងអ្នកបង្កើតទ្រឹស្តី ឬបច្ចេកវិទ្យាថ្មីៗ ដែលអាចបង្កើនប្រសិទ្ធភាពក្នុងការផលិត។

លើសពីនេះទៅទៀត អង់គ្លេស នៅពេលនោះ គឺជាមហាអំណាច ដែលមានដែនដីអាណានិគមយ៉ាងធំធេង នៅទូទាំងពិភពលោក។ ដែនដីអាណានិគមទាំងនេះ គឺជាប្រភពវត្ថុធាតុដើមដ៏សំខាន់មួយផង ហើយវាក៏ជាទីផ្សារដ៏ចម្បងមួយដែរ សម្រាប់លក់ផលិតផលរបស់អង់គ្លេស។ នៅពេលដែលទីផ្សារកើនឡើង វាធ្វើឲ្យសហគ្រាសអង់គ្លេសកាន់តែនាំគ្នាខិតខំប្រឹងប្រែង ដើម្បីរកវិធីផលិតទំនិញឲ្យបានកាន់តែច្រើននិងកាន់តែលឿន។

ទាំងអស់នេះហើយដែលនាំឲ្យវិស័យ ឧស្សាហកម្ម នៅអង់គ្លេសស្គាល់នូវភាព ជឿនលឿនជាងគេ នៅអំឡុងចុងសតវត្សរ៍ទី១៨ និងដើមសតវត្សរ៍ទី១៩។ នៅពេលនោះ រដ្ឋាភិបាលអង់គ្លេសបានព្យាយាមទប់ស្កាត់មិនឲ្យបច្ចេកវិទ្យា ឧស្សាហកម្មរបស់ខ្លួនត្រូវរីកសាយ ភាយទៅកាន់ប្រទេសផ្សេង។ ក៏ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងនេះត្រូវទទួលបរាជ័យ ដោយសារ តែមានវិស្វករ ឬកម្មករជំនាញ ព្រមទាំងសហគ្រិនអង់គ្លេសខ្លះ បាននាំគ្នាធ្វើចំណាកស្រុក ដើម្បីទៅស្វែងរកឱកាសការងារ ឬឱកាសធ្វើជំនួញនៅបរទេស។

បដិវត្តន៍ឧស្សាហកម្មក៏បានរីកសាយភាយចេញពីអង់គ្លេស ទៅកាន់ប្រទេសផ្សេងទៀតនៅអឺរ៉ុប ដោយចាប់ផ្តើមពីបែលហ្ស៊ិក បន្តទៅដល់បារាំង អាល្លឺម៉ង់ និងស៊ុយអែដ ហើយបន្ទាប់មកទៀតចេញពីអឺរ៉ុបទៅដល់សហរដ្ឋអាមេរិក។

គិតត្រឹមពាក់កណ្តាលសតវត្សរ៍ទី១៩ បដិវត្តន៍ឧស្សាហកម្មបានចាក់គ្រឹះយ៉ាងមាំ នៅទូទាំងតំបន់អឺរ៉ុបខាងលិច និងនៅឆ្នេរប៉ែកខាងកើតនៃសហរដ្ឋអាមេរិក។ វិស័យដែលមានការជឿនលឿនខ្លាំងជាងគេ នៅពេលនោះ គឺវិស័យវាយនភ័ណ្ឌ ការផលិតដែក និងបច្ចេកវិទ្យាក្នុងការផលិតម៉ាស៊ីន ជាពិសេសម៉ាស៊ីនដើរដោយចំហាយទឹក។

នៅតាមបណ្តាប្រទេស ដែលឆ្លងកាត់នូវបដិវត្តន៍ឧស្សាហកម្ម គេសង្កេតឃើញមានរោងចក្រថ្មីៗរីកដុះដាលដូចផ្សិតនៅគ្រប់ទីកន្លែង ហើយហេដ្ឋារចនាសម្ព័ន្ធខាងផ្នែកដឹកជញ្ជូនក៏មានការរីកចម្រើនមិនធ្លាប់មាន។

កាលពីមុន មនុស្សធ្វើដំណើរ ឬដឹកជញ្ជូនទំនិញ ពីកន្លែងមួយទៅកន្លែងមួយ ដោយថ្មើរជើង ឬដោយរទេះសេះ។ ការធ្វើដំណើរតាមផ្លូវទឹកវិញ ត្រូវធ្វើឡើងតាមទូកដោយប្រើក្តោង ឬចែវ។ ក៏ប៉ុន្តែ បដិវត្តន៍ឧស្សាហកម្មបាននាំទៅរកការបង្កើតមធ្យោបាយដឹកជញ្ជូនថ្មី ដែលអាចដឹកទំនិញបានច្រើន បានលឿននិងក្នុងរយៈចម្ងាយឆ្ងាយជាងមុន។

នៅដើមសតវត្សរ៍ទី១៩ វិស្វករអាមេរិកបានសាងសង់កប៉ាល់ពាណិជ្ជកម្មដើរដោយម៉ាស៊ីនប្រើចំហាយទឹកជាលើកដំបូង ហើយក្រោយមកទៀត នៅពាក់កណ្តាលសតវត្សរ៍ទី១៩ កប៉ាល់ដើរដោយចំហាយទឹកបានក្លាយជាមធ្យោបាយដឹកជញ្ជូនឆ្លងកាត់មហាសមុទ្រអាត្លង់ទិក។

នៅដើមសតវត្សរ៍ទី១៩នោះដែរ បច្ចេកវិទ្យានៃម៉ាស៊ីនដើរដោយចំហាយទឹកក៏ត្រូវបានវិស្វករយកទៅប្រើនៅក្នុងវិស័យដឹកជញ្ជូនតាមផ្លូវដែកផងដែរ តាមរយៈការផលិតក្បាលរថភ្លើងដើរដោយចំហាយទឹក។ នៅឆ្នាំ១៨៣០ ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវដែកត្រូវបានដាក់ឲ្យដំណើរការជាលើកដំបូង ដោយតភ្ជាប់ពីទីក្រុង Liverpoolទៅទីក្រុងManchester។

ប្រព័ន្ធទូរគមនាគមន៍វិញក៏ស្គាល់នូវភាពជឿនលឿនដ៏គួរឲ្យកត់សម្គាល់ ដែរ នៅក្នុងសម័យកាលបដិវត្តន៍ឧស្សាហកម្ម ជាពិសេស តាមរយៈការបង្កើតតេឡេហ្គ្រាហ្វ (Télégraphe)ដោយវិស្វករអង់គ្លេសនៅអំឡុងឆ្នាំ១៨៣០។

បើនិយាយខាងផ្នែកសង្គមវិញ បដិវត្តន៍ឧស្សាហកម្មបានធ្វើឲ្យប្រជាជន ដែលកាលពីមុនរស់នៅតាមទីជនបទ នាំគ្នាមករស់នៅប្រមូលផ្តុំគ្នា នៅតាមទីក្រុង ដែលជាកន្លែងសម្បូររោងចក្រ និងសម្បូរការងារធ្វើ។ ការកើនឡើងនៃសមត្ថភាពផលិតបានធ្វើឲ្យថ្លៃសម្ភារៈប្រើប្រាស់ ជាពិសេស ក្រណាត់ និងសម្លៀកបំពាក់មានការធ្លាក់ចុះ។ប្រជាជនទូទៅមានប្រាក់ចំណូលច្រើននិងមានជីវភាពធូរធារជាងមុន។

ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា មានអ្នកខ្លះបានរិះគន់ថា បដិវត្តន៍ឧស្សាហកម្មក៏បានបង្កជាបញ្ហាយ៉ាងច្រើនផងដែរ ទាក់ទងនឹងលក្ខខណ្ឌការងាររបស់កម្មករ។ កម្មករត្រូវធ្វើចំណាកស្រុក ឃ្លាតឆ្ងាយពីក្រុមគ្រួសារ និងភូមិកំណើត ដើម្បីទៅធ្វើការនៅតាមទីក្រុង។ កម្មករនីមួយៗត្រូវធ្វើការពី១២ម៉ោង ទៅ១៤ម៉ោងក្នុងមួយថ្ងៃ ហើយរោងចក្រត្រូវបានសាងសង់ដោយមិនបានគិតគូរម៉ត់ចត់អំពីសន្តិសុខនិងសុខមាលភាពរបស់កម្មករ។

នៅសហរដ្ឋអាមេរិកវិញ ការកើនឡើងនៃសកម្មភាពផលិតនៅក្នុងវិស័យវាយនភ័ណ្ឌបានធ្វើឲ្យតម្រូវ

ការកប្បាសមានការកើនឡើងខ្លាំង ហើយការទិញដូរទាសករស្បែកខ្មៅ ដើម្បីយកទៅធ្វើការក្នុងចម្ការកប្បាស ក៏មានការកើនឡើងខ្លាំង។ បញ្ហាទាសករ ដែលធ្លាប់ជាបញ្ហាចម្រូងចម្រាសស្រាប់ ចាប់តាំងពីពេលកកើតសហរដ្ឋអាមេរិក ក៏បានក្លាយជាបញ្ហាកាន់តែធំ រហូតរាលដាលទៅជាសង្គ្រាមស៊ីវិល រវាងរដ្ឋរបស់អាមេរិកនៅឆ្នាំ១៨៦១។

**សំណួរត្រិះរិះ**

១. តើអឺរ៉ុបមានភាពរុងរឿងអាស្រ័យទៅលើអ្វី?

២. តើនៅទ្វីបអឺរ៉ុបមានធនធានធម្មជាតិអ្វីខ្លះ? ចូរបង្ហាញ។

៣. តើកត្តាអ្វីដែលធ្វើឱ្យមានបដិវត្តឧស្សាហកម្មនៅអឺរ៉ុប?

# មេរៀនទី៥៖ សហភាពអឺរ៉ុប

## ១. ប្រវត្តិនៃការកសាងសហភាពអឺរ៉ុប

នៅក្រោយសង្គ្រាមលោកលើកទីពីរ ទ្វីបអឺរ៉ុបទាំងមូលខូចខាតខ្ទេចខ្ទី សហភាពសូវៀត គិតតែពីវាតទីពង្រីកទឹកដី និងបង្កើនឥទ្ធិពល ជាហេតុធ្វើឲ្យអឺរ៉ុបខាងលិចអ្នកស្នេហាលទ្ធិប្រជាធិបតេយ្យភិតភ័យ។

គឺនៅក្នុងបរិបទបែបនេះហើយ ដែលបណ្ដាប្រទេសអឺរ៉ុបប្រជាធិបតេយ្យ ផ្ដើមមានគំនិតចង់រួបរួមគ្នាដើម្បីការពារខ្លួន ដើម្បីកសាងអឺរ៉ុបខាងលិចឡើងវិញ និងជាពិសេសដើម្បីបង្កើតសន្តិភាព ចៀសវាងកុំឲ្យសង្គ្រាម ដូចសង្គ្រាមលោកលើកទីមួយ និងសង្គ្រាមលោកលើកទីពីរ កើតឡើងទៀត។ បានន័យថា កាលនោះនៅសម័យឆ្នាំ១៩៤៥ ១៩៤៦ មូលហេតុសំខាន់ៗដែលជម្រុញឲ្យបណ្ដាប្រទេសអឺរ៉ុបខាងលិច ចង់ប្រមូលផ្ដុំគ្នាជ្រកក្រោមដំបូលតែមួយ គឺសុទ្ធសឹងជាមូលហេតុនយោបាយ។

ប៉ុន្តែ នៅទីបំផុត នៅឆ្នាំ១៩៤៨ នាពេលដែលបណ្ដាប្រទេសអឺរ៉ុបប្រជាធិបតេយ្យចំនួន១៩ រួមប្រជុំគ្នានៅទីក្រុងLa Haye ប្រទេសHollande ដើម្បីជជែកគ្នាអំពីការផ្ដួចផ្ដើមបង្កើតអង្គការតំបន់រួមមួយ ស្រាប់តែបដិវាទកម្មកើតឡើង។ គឺការប្រឈមមុខដាក់គ្នារវាងចក្ខុនិមិត្តពីរ។

នៅម្ខាងប្រទេសអឺរ៉ុបមួយក្រុម ដឹកមុខដោយប្រទេសអង់គ្លេស ចង់បានត្រឹមតែសហប្រតិបត្តិការរវាងគ្នា និងចង់បានតែអង្គការអឺរ៉ុបមួយដែលមិនធ្វើឲ្យបាត់បង់សោះ ឡើយអធិបតេយ្យនៃប្រទេសសមាជិកនីមួយៗ។ នៅម្ខាងទៀត មានប្រទេសអឺរ៉ុបមួយចំនួនផ្សេង ដឹកនាំដោយប្រទេសបារាំង និងប្រទេសBelgique ដែលចង់ឲ្យអភិក្រមនៃការបង្រួបបង្រួមអឺរ៉ុបនេះ បោះជំហានទៅរកសហព័ន្ធមួយ តាមគំរូនៃសហរដ្ឋអាមេរិក ដូចអ្វីដែលអ្នកនិពន្ធបារាំងសម័យសតវត្សរ៍ទី១៩ Victor Hugoដាក់នាមឲ្យថា Les Etats-Unis d'Europe ឬសហរដ្ឋអឺរ៉ុប។

ចក្ខុនិមិត្តទាំងពីរខុសគ្នានេះ មួយជាចក្ខុនិមិត្តអឺរ៉ុបសមាគមប្រជាជាតិ(Europe des Nations) និងមួយទៀតជាចក្ខុនិមិត្តអឺរ៉ុបសហព័ន្ធ (Europe fédérale) បន្តប្រឆាំងគ្នាមកទល់សព្វថ្ងៃ ជាង៦០ប្លាយឆ្នាំក្រោយមក។

នៅឆ្នាំ១៩៥០ លោក Robert Schuman រដ្ឋមន្ត្រីការបរទេសបារាំងសម័យនោះ មានគំនិតល្អមួយ នោះគឺឈប់និយាយពីអឺរ៉ុបនយោបាយ តែនិយាយពីអឺរ៉ុបសេដ្ឋកិច្ចវិញម្ដង។ លោកស្នើឲ្យដាក់ចូលជាសម្ភូហភាពអឺរ៉ុប ធ្យូងថ្មនិងដែកថែប។ ពីព្រោះ ធ្យូងថ្ម ជាថាមពលចាំបាច់ សម្រាប់ឧស្សាហកម្ម និងការកសាងអឺរ៉ុបឡើងវិញ រីឯដែកថែបវិញ ជាលោហធាតុ យុទ្ធសាស្ត្រ សម្រាប់ផលិតអាវុធ។ នៅក្នុងស្មារតីរបស់លោកSchuman ការដាក់ធ្យូងថ្ម និង ដែកថែប នៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអឺរ៉ុបតែមួយរួមគ្នា មានគោលដៅនយោបាយ និងសន្តិភាព ពីព្រោះ ធ្វើបែបនេះ វត្ថុធាតុទាំងពីរមុខនេះ នឹងមិនអាចត្រូវគេយកទៅផលិត អាវុធអ្វីផ្ដេសផ្ដាស ដើម្បីធ្វើសង្គ្រាមបានទៀតឡើយ។ អ៊ីចឹងហើយ បានជានៅឆ្នាំ១៩៥១ បណ្ដាប្រទេសអឺរ៉ុបចំនួន ៦ គឺបារាំង អាល្លឺម៉ង់ខាងលិច Belgique, Luxembourg, Hollande និង Italie សុខចិត្តបង្កើតសហគមន៍ធ្យូងថ្មនិងដែកថែបអឺរ៉ុប La Communauté Européenne du Charbon et de l'Acier ហៅកាត់ថាCECA ។

តាមរយៈសហគមន៍CECA នេះ អឺរ៉ុបរួមចាប់បដិសន្ធិកើតចេញជារូបរាងឡើង នៅតូចកូនរង៉េតមែនពិត តែនឹងរីកធំធាត់ម្តងបន្តិចៗ ចាប់ពីដើមទសវត្សរ៍ទី៥០ទៅ។

នៅក្នុងសម័យទសវត្សរ៍ទី៥០ ទ្វីបអឺរ៉ុបជាទីកន្លែងដែលសង្គ្រាមត្រជាក់រវាង Blocខាងកើត កុម្មុយនីស្ត និងBlocខាងលិចសេរី បង្កឲ្យមានភាពតានតឹងខ្លាំងជាងគេ។ នៅក្នុងកាលៈទេសៈបែបនេះ ប្រទេសបារាំងមានគំនិតស្នើឲ្យបង្កើត កងទ័ពអឺរ៉ុបរួមមួយ រវាងបណ្តាប្រទេសសមាជិកទាំង៦។ គំនិតនេះលិចចេញជារូបរាងឡើង តាមរយៈសន្ធិសញ្ញាទីក្រុងប៉ារីសឆ្នាំ១៩៥២ តែរលត់សាបសូន្យទៅវិញ នៅឆ្នាំ១៩៥៤។ ពីព្រោះកាលនោះ រដ្ឋសភាបារាំងដែលខ្លាចប្រទេសបារាំងបាត់បង់អធិបតេយ្យរបស់ខ្លួន មិនព្រមឲ្យសច្ចាប័នទៅលើសន្ធិសញ្ញានេះទេ ខុសផ្ទុយពីរដ្ឋសភាBelgique អាល្លឺម៉ង់ខាងលិច Hollande Luxembourg និងItalie។

សព្វថ្ងៃនេះ ៦០ឆ្នាំក្រោយមក ក្រុមប្រវត្តិវិទូ នៅតែបន្តអះអាងថា បើសិនជារដ្ឋសភា បារាំង មិនប្រានចោលសន្ធិសញ្ញាបង្កើតកងទ័ពអឺរ៉ុបរួមនៅឆ្នាំ១៩៥៤នោះទេ ប្រហែលជាមានសហរដ្ឋអឺរ៉ុបមួយរួចស្រេចបាត់ទៅហើយ នៅថ្ងៃនេះ។ នៅត្រង់នេះ គេគួរបើកវង់ក្រចកពិនិត្យមើលឥរិយាបថរបស់ប្រទេសបារាំងបន្តិចសិន។ ពីព្រោះ នៅក្នុងអភិក្រមនៃការកសាងអឺរ៉ុប ម្តងជាពីរដង បារាំងអស់ពីក្លាហានក្លាយជាកំសាក អស់ពីជម្រុញឲ្យទៅមុខ ក្លាយជាអ្នកយកជើងរាទឹក។ ជាក់ស្តែងជាងគេ គឺនៅឆ្នាំ២០០៥ ជាថ្មីម្តងទៀត ប្រទេសបារាំងប្រានចោលរដ្ឋធម្មនុញ្ញអឺរ៉ុប ដែលខ្លួនជាអ្នកផ្តួចផ្តើមជម្រុញឲ្យតុបតែងឡើង។

យ៉ាងណាក៏ដោយ នៅក្នុងទសវត្សរ៍ទី៥០ ប្រទេសសមាជិកទាំង៦នៃសហគមន៍ធ្យូងថ្ម និងដែកថែបអឺរ៉ុប បន្តជម្រុញឲ្យទៅមុខកាន់តែលឿន គំនិតដែលថាត្រូវតែដើរ ទៅឲ្យដល់ គោលដៅអឺរ៉ុបនយោបាយ។ នៅក្នុងន័យនេះ នៅឆ្នាំ១៩៥៧ បណ្តាប្រទេសអឺរ៉ុបទាំង៦ មូលមតិគ្នា បង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប La Communauté Economique Européenne ហៅកាត់ថា CEE តាមរយៈសន្ធិសញ្ញាទីក្រុងRome។ គោលដៅនៃសន្ធិសញ្ញានេះ គឺបង្កើតឲ្យមានទីផ្សាររួមមួយ និងអនុញ្ញាតឲ្យមានដោយសេរី ចរាចរណ៍មនុស្ស ចរាចរណ៍ផលិតផល និងចរាចរណ៍មូលធន នៅក្នុងព្រំដែននៃបណ្តាប្រទេសសមាជិកទាំង៦ របស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប CEE។ ដោយសារតែសហគមន៍សេដ្ឋកិច្ចអឺរ៉ុប ការផ្លាស់ប្តូរពាណិជ្ជកម្មរវាងបណ្តាប្រទេសសមាជិកទាំង៦ កើនឡើងខ្លាំង កើនមួយជាប្រាំ ក្នុងចន្លោះឆ្នាំ១៩៥៧ និងឆ្នាំ១៩៧០។ រីឯផលិតផលដែលសហគមន៍លក់ចេញទៅក្រៅវិញក៏កើនឡើងបានមួយជាបី។ និយាយរួម សហគមន៍សេដ្ឋកិច្ចអឺរ៉ុប គឺជាជ័យជំនះសេដ្ឋកិច្ចមួយប្រកែកមិនបាន។

ជាមួយនឹងការបង្កើតឡើងនៃសហគមន៍សេដ្ឋកិច្ចអឺរ៉ុបCEE នៅឆ្នាំ១៩៥៧ អឺរ៉ុបនយោបាយហាក់ដូចជាស្លាប់កប់ចោលនិងគ្របបាត់ដោយអឺរ៉ុបសេដ្ឋកិច្ច។ គឺជាជ័យជំនះនៃចក្ខុនិមិត្តអឺរ៉ុបសមាគមប្រជាជាតិ (Europe des Nations) ទៅលើចក្ខុនិមិត្តអឺរ៉ុបសហព័ន្ធ(Europe fédérale)។

ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៦៩ ក្នុងរយៈពេល១២ឆ្នាំ អឺរ៉ុបរួមគ្នានៅលើតែវិស័យសេដ្ឋកិច្ចនេះបោះជំហានទៅមុខ យ៉ាងយឺតជាទីបំផុត។ ពីព្រោះ ឧត្តមសេនីយ៍ de Gaulle ដែលបានវិលត្រឡប់មកកាន់អំណាចវិញនៅឆ្នាំ ១៩៥៨ នៅប្រទេសបារាំង មិនសូវរវល់ពីការកសាងអឺរ៉ុបទេ គិតតែពីធ្វើឲ្យប្រទេសបារាំងខ្លាំង ឯករាជ្យ និងក្លាយជាមហាអំណាចបរមាណូ។

ក៏ប៉ុន្តែ ទន្ទឹមនឹងនេះ សហគមន៍CEE ក្លាយជាអង្គការសេដ្ឋកិច្ចមួយមាំ ប្រកបដោយឥទ្ធិពលខ្លាំង ហួតដល់ជម្រុញប្រទេសអង់គ្លេស ឲ្យសុំចូលជាសមាជិកនៅឆ្នាំ ១៩៦៨។

តែ ឧត្តមសេនីយ៍ de Gaulle មិនព្រម ពីព្រោះអង់គ្លេសស្និទ្ធនឹងសហរដ្ឋអាមេរិកខ្លាំងពេក។

គេត្រូវរង់ចាំដល់ឆ្នាំ ១៩៦៩ ក្រោយពេលដែល de Gaulle បានលាចេញពីអំណាច ទើបឃើញប្រទេសបារាំងយល់ព្រមផ្តល់សន្ទុះថ្មីដល់អឺរ៉ុបនយោបាយ។ គឺជាការវិលត្រឡប់មកវិញនៃចក្ខុនិមិត្តអឺរ៉ុបសហព័ន្ធ (Europe fédérale)។ នៅក្នុងន័យនេះ ប្រទេសសមាជិកទាំង៦នៃសហគមន៍សេដ្ឋកិច្ចអឺរ៉ុប CEE ដែលរួមប្រជុំគ្នាក្នុងទីក្រុង La Haye ប្រទេស Hollande នៅឆ្នាំ១៩៦៩ ប្តេជ្ញាចិត្តសម្រេចឲ្យបាននូវគោលដៅបីនាអនាគតកាល។

ទីមួយ បង្កើតរូបិយវត្ថុរួមមួយ ទីពីរ ធ្វើការចរចាដើម្បីបើកផ្លូវឲ្យប្រទេស Anglais Danemark Irlande និង Norvège ចូលជាសមាជិក និងទីបី រិះរកមធ្យោបាយដែលនាំទៅរកអឺរ៉ុបនយោបាយ ឲ្យបានលឿនរហ័ស។

ហេតុអ្វីបានជានៅទីបំផុត បារាំងព្រមឲ្យអង់គ្លេសចូលជាសមាជិករបស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប CEE?

បារាំងដឹង ដឹងជាមុនថា អង់គ្លេសដែលស្និទ្ធនឹងអាមេរិក និងដែលប្រឆាំងនឹងចក្ខុនិមិត្តអឺរ៉ុបសហព័ន្ធ ច្បាស់ជាខ្ទប់នៅថ្ងៃមុខ មិនឲ្យអឺរ៉ុបនយោបាយ រីកលូតលាស់ទៅមុខបាន។

តែបារាំងអត់ជម្រើស ពីព្រោះប្រទេសសមាជិកអឺរ៉ុបដទៃដាក់សម្ពាធមកលើខ្លួនខ្លាំងពេក ទាមទារឲ្យទីក្រុង Paris ដក Veto បើកទ្វារឲ្យអង់គ្លេសចូលមកក្នុងសហគមន៍ CEE។

អ៊ីចឹងហើយបាន ជាសហគមន៍សេដ្ឋកិច្ចអឺរ៉ុបរីកធំ ចាប់ពីឆ្នាំ១៩៧៣ទៅ ដោយមានសមាជិកបីបន្ថែមនោះគឺ Anglais Irlande និង Danemark។ ប្រទេស Grèce ក្លាយជាសមាជិក នៅឆ្នាំ ១៩៨១ Espagne និង Portugal នៅឆ្នាំ ១៩៨៦។ ទន្ទឹមនឹងនេះ នៅឆ្នាំ ១៩៧៩ សហគមន៍ CEE សម្រេចឲ្យរៀបចំបោះឆ្នោតសភាអឺរ៉ុបជាសាកល ជាលើកទីមួយបង្អស់ និងឲ្យបង្កើតប្រព័ន្ធរូបិយវត្ថុរួមមួយ ដែលជាប្រភពដើមនៃប្រាក់អឺរ៉ូ សព្វថ្ងៃ។

នៅឆ្នាំ ១៩៨៦ សន្ធិសញ្ញាមួយថ្មីដែលភាសាបារាំងគេហៅថា Acte Unique គ្រោងលុបបំបាត់ចោលទាំងស្រុង ឧបសគ្គនៅសេសសល់ទាំងប៉ុន្មាន ដែលបង្កជាបញ្ហាមិនឲ្យទីផ្សាររួមតែមួយកើតចេញជារូបរាងបាន។

តែ អ្វីដែលសំខាន់ គឺការមូលមតិគ្នារវាងបណ្តាប្រទេសសមាជិកទាំងអស់ ថានឹងធ្វើឲ្យសហគមន៍សេដ្ឋកិច្ចអឺរ៉ុប ក្លាយទៅជាសហភាពអឺរ៉ុប នាពេលខាងមុខ។ គោលដៅ នៃឯកសារ Acte uniqueនេះ គឺធ្វើឲ្យអឺរ៉ុបរួមដើរតួនាទីកាន់តែសំខាន់ នៅលើឆាកអន្តរជាតិ ដើម្បីជួយសម្រួលឲ្យពិភពលោកមានតុល្យភាពភូមិសាស្ត្រនយោបាយល្អ។

អ៊ីចឹង ហើយបានជាចាប់ពីឆ្នាំ ១៩៨៦មក បណ្តាប្រមុខរដ្ឋ និងបណ្តាប្រមុខរដ្ឋាភិបាលសមាជិកអឺរ៉ុបទាំងអស់ ចាប់ផ្តើមរួមប្រជុំគ្នាជាច្រើនដង ក្នុងមួយឆ្នាំៗ។ គឺជាការចាប់កំណើតឡើងនៃ ស្ថាប័នក្រុមប្រឹក្សាអឺរ៉ុប (Le Conseil d'Europe ) ដែលគេអាចចាត់ទុកថា ជាអំណាចនីតិប្រតិបត្តិរបស់អឺរ៉ុប។ តាមរយៈស្ថាប័នក្រុមប្រឹក្សាអឺរ៉ុប បណ្តាប្រទេសសមាជិក ត្រួតពិនិត្យនិងក្តាប់យ៉ាងជាប់អភិក្រមនៃការបន្តកសាងអឺរ៉ុប ឲ្យក្លាយទៅដូចអ្វីដែលពួកគេចង់បាន ពោលគឺទុកឲ្យនៅជាអឺរ៉ុបសមាគមប្រជាជាតិ(Europe des Nations) សិន។

ក៏ប៉ុន្តែទន្ទឹមជាមួយគ្នានេះ វត្តមាននៃស្ថាប័នសហភាពអឺរ៉ុប ដែលប្រជាពលរដ្ឋអឺរ៉ុប នៅតាមប្រទេសសមាជិកនីមួយៗ ជាអ្នកបោះឆ្នោតតែងតាំងពួកអ្នកតំណាងរាស្ត្រ ជាសញ្ញាមួយដែលស្តែងឲ្យឃើញថា អឺរ៉ុបសហព័ន្ធន៍ ក៏កំពុងបោះជំហានទៅមុខសន្សឹមៗដែរ។ បានន័យថា ចាប់ពីឆ្នាំ ១៩៧៩ទៅ អឺរ៉ុបរួមមិនមែនជាអង្គការសេដ្ឋកិច្ចមួយសុទ្ធសាធ ដូចពីពេលមុនទៀតទេ។ ពីអំណើះតទៅ អឺរ៉ុបរួម មានលក្ខណៈនយោបាយកាន់តែច្បាស់ឡើងៗ ជាលំដាប់។

យ៉ាងណាក៏ដោយ នៅឆ្នាំ ១៩៨៩ អឺរ៉ុបរួមដើរមកដល់របត់មួយថ្មី។ ឆ្នាំ ១៩៨៩ ជាឆ្នាំដែលសេរីភាពបោកបក់ខ្លាំងទៅលើសហភាពសូវៀត និងទៅលើបណ្តាប្រទេស រណបសហភាពសូវៀត នៅអឺរ៉ុបខាងកើត។ រដ្ឋអំណាចនៅ Moscou បន្តអនុវត្តនយោបាយកែទម្រង់ Perestroïka បក្សប្រឆាំងឈ្នះឆ្នោតនៅ Pologne Hongrie បើកច្រកព្រំដែននៅខាងលិចប្រទេស។

តែហេតុការណ៍សំខាន់ គឺការដួលរលំនៃជញ្ជាំង Berlin។ ជញ្ជាំងBerlin រលំ សង្គ្រាមត្រជាក់ត្រូវចប់ មនោគមវិជ្ជាកុម្មុយនិស្តរលាយ សហភាពសូវៀត ចាប់ផ្តើមត្រដរខ្យល់។

ព្រឹត្តិការណ៍លោតប្លោះលឿនរហ័សទាំងនេះ បង្កជាបញ្ហាដល់ការកសាងអឺរ៉ុប។ ជញ្ជាំង Berlin រលំ បានន័យថា មិនយូរមិនឆាប់ អាល្លឺម៉ង់ខាងលិចនិងអាល្លឺម៉ង់ខាងកើត ត្រូវតែរួបរួមគ្នាជាប្រទេសតែមួយវិញ។ ប្រធានាធិបតីបារាំង François Mitterrand យល់ដឹងភ្លាមថា ប្រទេសអាល្លឺម៉ង់តែមួយ ធំជាងមុន និងខ្លាំងជាងមុន អាចធ្វើឲ្យអឺរ៉ុបរួមបាត់បង់តុល្យភាព និងអាចធ្វើឲ្យការកសាងអឺរ៉ុបគាំងដំណើរ នៅមួយកន្លែង។

នៅក្នុងបរិបទនេះ បារាំងនិងអាល្លឺម៉ង់យល់ឃើញថា មានតែការបង្កើនល្បឿនសមាហរណៈកម្មនយោបាយទេ ដែលអាចជួយស្រោចស្រង់អឺរ៉ុបរួមឲ្យរួចពីគ្រោះថ្នាក់បាន។ គឺចាប់ពីឆ្នាំ ១៩៨៩នោះហើយ ដែលថ្នាក់ដឹកនាំអឺរ៉ុប ផ្តើមគិតគូរអំពីការបង្កើតប្រាក់អឺរ៉ូរួមមួយ។ គំនិតនេះក្លាយចេញជារូបរាង តាមរយៈសន្ធិសញ្ញា Maastricht នៅឆ្នាំ១៩៩២ ។ គឺជាសន្ធិសញ្ញាដែលចែងពីសហភាពអឺរ៉ុបក្នុងនាមជាអឺរ៉ុបរួមនយោបាយ សេដ្ឋកិច្ច និងរូបិយវត្ថុ។

ក្រោយពីសង្គ្រាមត្រជាក់បានរលត់បាត់ទៅ ប្រទេសបារាំងនិងប្រទេសអាល្លឺម៉ង់ ដែលជាក្បាលរទេះភ្លើងនៃអឺរ៉ុប សម្រេចបង្កើនល្បឿនសមាហរណៈកម្ម ដើម្បីស្រោចស្រង់អឺរ៉ុបរួមឲ្យរួចពីគ្រោះថ្នាក់។ នៅក្នុងន័យនេះ តាមរយៈសន្ធិសញ្ញាMaastricht ឆ្នាំ១៩៩២ សហគមន៍សេដ្ឋកិច្ចអឺរ៉ុបCEE ដូរឈ្មោះជាសហភាពអឺរ៉ុប។

ក៏ប៉ុន្តែ ជញ្ជាំងBerlinដែលបានរលំ និងពីរឆ្នាំក្រោយមក សហភាពសូវៀតដែលបានរលាយក៏នាំបញ្ហាពីក្រៅមកបញ្ជេះនៅខាងក្នុង សហភាពអឺរ៉ុបដែរ។ បញ្ហាពីក្រៅនេះ គឺសង្គ្រាមនៅYougoslavie។ អាល្លឺម៉ង់កាន់ជើងពួកCroates រីឯបារាំងវិញមិនព្រមគាបសង្កត់ពួកSerbes តាមការស្នើសុំរបស់អាល្លឺម៉ង់។ មែនទែនទៅ អឺរ៉ុបរួមគ្មានជំហររួម នៅចំពោះមុខវិបត្តិYougoslavie។ ធ្ងន់ធ្ងរជាងនេះទៅទៀត អឺរ៉ុបរួមគ្មានទំពធ្វើអន្តរាគមន៍នៅក្នុងសង្គ្រាមមួយ ដែលកើតឡើង នៅចំមាត់ទ្វារផ្ទះរបស់ខ្លួនតែម្តង។ ហើយជាថ្មីម្តងទៀត គឺសហរដ្ឋអាមេរិកទេតើ ដែលនៅទីបំផុត បានមកពន្លត់ភ្លើងសង្គ្រាមYougoslavieនេះ។

គឺនៅក្នុងបរិបទ បែបនេះហើយ បានជាចាប់ពីដើមទសវត្សរ៍ទី៩០ទៅ ចាប់ផ្តើមមាន នៅក្នុងសហភាពអឺរ៉ុប អ្នកដែលមិនទុកចិត្ត មិនគាំទ្រ និងមាក់ងាយសហភាពអឺរ៉ុបច្រើនឡើងៗ ជាភាសាបារាំងគេហៅថា ពួក Eurosceptiques។

នៅក្រៅព្រំដែននៃសហភាពអឺរ៉ុបវិញ អ្វីៗក៏ផ្តើមប្រែប្រួលអស់រលីងៈ សហភាពសូវៀតរលាយ សហរដ្ឋអាមេរិកក្លាយជាមហាអំណាចផ្តាច់មុខ ប្រទេសចិនអនុវត្តសេដ្ឋកិច្ចទីផ្សារដែលសឹងមានលក្ខណៈជាមូលធននិយម ព្រៃផ្សៃ។ បណ្តាប្រទេសអឺរ៉ុបខាងកើតដែលទើបបានរួចខ្លួនពីក្រញាំកុម្មុយនិស្ត និងពីឥទ្ធិពលសូវៀតមើលឃើញតែគំរូសហរដ្ឋអាមេរិក និងស្រឡាញ់តែសេរីនិយមរបៀបអាមេរិកាំង។ សេដ្ឋកិច្ចសង្គមទីផ្សារ Economie sociale du marché របស់សហភាពអឺរ៉ុបមិនទាក់ទាញចិត្តរបស់ពួកគេឡើយ។

ក៏ប៉ុន្តែ សហរដ្ឋអាមេរិកនៅឆ្ងាយពេក ជាហេតុធ្វើឲ្យបណ្តាប្រទេសអឺរ៉ុបខាងកើតអត់ជម្រើស ត្រូវតែមកគោះទ្វារសហភាពអឺរ៉ុប ដើម្បីសុំចូលជាសមាជិក។ អឺរ៉ុបខាងកើតដែលមកគោះទ្វារអឺរ៉ុបខាងលិច ជាប្អូនជីដូនមួយក្រីក្រ មានប្រវត្តិផ្សេងនិងចិត្តគំនិតផ្សេង។ សូម្បីតែអាល្លឺម៉ង់ខាងកើតក៏ប្លែកដែរ មិនដូចអាល្លឺម៉ង់ខាងលិចទេ។

យ៉ាងម៉េចក៏ដោយ សហភាពអឺរ៉ុបគ្មានជម្រើសអ្វីក្រៅពីបើកទ្វារ និងបើកដៃទទួលបណ្តាប្រទេសទាំងនេះតែប៉ុណ្ណោះ។ ពីព្រោះម្យ៉ាង សហភាពអឺរ៉ុបមិនស្រួលចិត្ត មានអារម្មណ៍មិនល្អ ដោយបានបោះបង់ចោលបណ្តាប្រទេសអឺរ៉ុបខាងកើតទាំងនេះឲ្យនៅរងទុក្ខ ក្រោមនឹមកុម្មុយនិស្តរបស់សហភាពសូវៀត ជិតកន្លះសតវត្សរ៍។ ពីព្រោះម្យ៉ាងទៀត សន្ធិសញ្ញាទាំងប៉ុន្មានដែលស្តីពីការកសាងអឺរ៉ុបរួម សុទ្ធតែបានគ្រោងទុកកន្លែងរង់ចាំទទួលបណ្តាប្រទេសអឺរ៉ុបខាងកើត ពេលណាដែលប្រទេសទាំងអស់នេះរើបម្រះចេញរួចពីរបបផ្តាច់ការ។ និងពីព្រោះម្យ៉ាងចុងក្រោយ ដើម្បីសន្តិភាពនៅក្នុងទ្វីបអឺរ៉ុប សហភាពអឺរ៉ុបត្រូវតែដាច់ចិត្តទទួលបណ្តាប្រទេសអឺរ៉ុបខាងកើត មកធ្វើជាសមាជិក។

អឺរ៉ុបខាងកើត ជាពិសេសអឺរ៉ុបកណ្តាល ជាតំបន់ពោរពេញទៅដោយអស្ថិរភាព ពីព្រោះព្រំដែននៃប្រទេសទាំងនេះ ត្រូវបានកាត់បែងចែកដោយសន្ធិសញ្ញាVersailles ក្រោយសង្គ្រាមលោកលើកទីមួយ ត្រូវបានសើរើមើលឡើងវិញ ដោយកតិកាសញ្ញាអាល្លឺម៉ង់-រុស្ស៊ី នៅសម័យដើមដំបូងនៃសង្គ្រាមលោកលើកទីពីរ និងក្រោយមក ត្រូវបានទុកឲ្យនៅជាStatu quo តាំងពីចប់សង្គ្រាមលោកលើកទីពីរមកម្ល៉េះ។ បានន័យថា សង្គ្រាម ដូចជាសង្គ្រាមនៅYougoslavieជាដើម អាចនឹងផ្ទុះឡើងគ្រប់ពេលវេលា និងនៅគ្រប់ទីកន្លែងក្នុងតំបន់អឺរ៉ុបខាងកើត។ ម្ល៉ោះហើយ តាមរយៈការទទួលបណ្តាប្រទេសទាំងនេះឲ្យចូលជាសមាជិក សហភាពអឺរ៉ុបមានបំណងចង់ខ្ទប់កុំឲ្យសង្គ្រាមជាយថាហេតុ កើតឡើងទៀតបាន។

ក៏ប៉ុន្តែ ជាមួយនឹងបណ្តាសមាជិកថ្មីមកពីអឺរ៉ុបខាងកើត បញ្ហាថ្មីក៏កើតមានដែរនៅក្នុងសហភាពអឺរ៉ុប។ ទីមួយ ដូចបានលើកឡើងអំបាញ់មិញរួចហើយថា ប្រទេសទាំងនេះដែលទើបតែបានឈានជើងចេញពីរបបកុម្មុយនិស្ត ចង់បានណាស់សេដ្ឋកិច្ចសេរីនិយមបែបអាមេរិកាំង មិនយកទេ មិនចង់បានទេសេដ្ឋកិច្ចសង្គមទីផ្សារបែបសហភាពអឺរ៉ុប។ ទីពីរ ប្រទេសទាំងនេះ មិនចង់បានទេអឺរ៉ុបរួមនយោបាយ ពីព្រោះ ពួកគេដែលទើបតែបានចេញរួចពីកុម្មុយនិស្ត មានស្មារតីជាតិនិយមខ្លាំង ស្រឡាញ់បូរណភាពទឹកដី និងមិនចង់បាត់បង់អធិបតេយ្យ សោះឡើយ។ ទីបី ប្រទេសទាំងនេះនៅភ័យ នៅខ្លាចរុស្ស៊ី ត្រូវការឲ្យសហរដ្ឋអាមេរិកការពារ ចង់ឋិតនៅក្រោមឆត្រសន្តិសុខអាមេរិកាំង ពីព្រោះសហភាពអឺរ៉ុបគ្មានកងទ័ពរួម គ្មានក្រសួងការពារអឺរ៉ុបរួម។

ម្ល៉ោះហើយ សមាជិកថ្មីមកពីអឺរ៉ុបខាងកើតនាំគ្នាងាកទៅរកអង្គការសន្ធិសញ្ញា Atlantique ខាងជើង ហៅកាត់ថាOTAN។

គឺនៅក្នុងបរិបទនៃបញ្ហា ទាំងបីខាងលើនេះហើយ ដែលសហភាពអឺរ៉ុបបង្កើនចំនួនប្រទេសសមាជិក ពង្រីកព្រំដែនសំដៅទៅទិសខាងកើត។

ជញ្ជាំង Berlin រលំ និងសហភាពសូវៀតរលាយ នាំមកនូវបញ្ហាជាច្រើនដល់ការកសាងអឺរ៉ុបរួម ធ្វើឲ្យថ្នាក់ដឹកនាំអឺរ៉ុប ជាពិសេសថ្នាក់ដឹកនាំបារាំងនិងអាល្លឺម៉ង់ល្វឹងមុខ។ ក៏ប៉ុន្តែ នៅទីបំផុត ព្រឹត្តិការណ៍ធំៗទាំងនេះ បែរជាជួយផ្តល់សន្ទុះថ្មីដល់ដំណើរសមាហរណ៍កម្មនយោបាយអឺរ៉ុប ទៅវិញ។ សន្ធិសញ្ញាចំនួនពីរបន្ថែម គឺសន្ធិសញ្ញា Maastricht នៅឆ្នាំ ១៩៩២ និងសន្ធិសញ្ញា Amsterdam នៅឆ្នាំ១៩៩៧ ជម្រុញអឺរ៉ុបរួម ឲ្យបោះជើងដើរទៅមុខយ៉ាងលឿន។ សហគមន៍សេដ្ឋកិច្ចអឺរ៉ុប ដូរឈ្មោះជាសហភាពអឺរ៉ុប។

មិនតែប៉ុណ្ណោះ ពីអំណើះតទៅ សហភាពអឺរ៉ុបទទួលស្គាល់លក្ខន្តិកៈរបស់ពលរដ្ឋអឺរ៉ុប។ បានន័យថា ពលរដ្ឋអឺរ៉ុបគ្រប់រូបមានសិទ្ធិចូលរួមបោះឆ្នោតជ្រើសរើសតំណាង រាស្ត្រអឺរ៉ុបនិងជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ នៅក្នុងប្រទេសអឺរ៉ុបណាដែលខ្លួនរស់នៅ។ ឧទាហរណ៍ ជនជាតិអង់គ្លេសដែលរស់នៅក្នុងប្រទេសបារាំង មានសិទ្ធិចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និងជ្រើសរើសអ្នកតំណាងរាស្ត្រអឺរ៉ុបនៅលើទឹកដីបារាំងផ្ទាល់តែម្តង។

តែអ្វីដែលមានលក្ខណៈបដិវត្តន៍ខ្លាំងនោះ គឺសហភាពអឺរ៉ុប ជាអឺរ៉ុបរួមសេដ្ឋកិច្ច រូបិយវត្ថុ និងនយោបាយ។ នៅក្នុងន័យនេះ នៅថ្ងៃទី១មករាឆ្នាំ២០០២ សមាជិកអឺរ៉ុបចំនួន១២ប្រទេស មូលមតិគ្នាទទួលយកប្រាក់អឺរ៉ូមកប្រើប្រាស់។ ទន្ទឹមជាមួយគ្នានេះ សហភាពអឺរ៉ុបក៏ផ្តើមចាក់គ្រឹះនយោបាយការបរទេសរួមមួយ និងផ្តើមពង្រីកអំណាចរបស់ខ្លួនដែរ។

សហភាពក៏ត្រូវការសើរើមើល ឡើងវិញដែរ បែបបទនៃដំណើរការស្ថាប័នអឺរ៉ុប ពីព្រោះជាមួយការបើកទ្វារទទួលបណ្តាប្រទេសអឺរ៉ុបខាងកើត ចំនួនសមាជិករបស់សហភាពកើនឡើងពី១៥ ទៅ២៥ និង រួចហើយពី២៥ទៅ២៧។ អ៊ីចឹងហើយ បានជានៅខែកុម្ភៈឆ្នាំ ២០០១ បារាំងរៀបចំសន្និសីទអន្តររដ្ឋាភិបាលមួយនៅទីក្រុង Nice និងតុបតែងសន្ធិសញ្ញាមួយឡើង ដែលនៅទីបំផុតត្រូវសមាជិកសំខាន់ៗច្រានចោល។ មូលហេតុគឺមកពីសន្ធិសញ្ញាទីក្រុង Nice ផ្តល់អំណាចខ្លាំងពេកដល់ប្រទេសសមាជិកមួយចំនួនដែលមានទំហំធំ និងប្រជាជនច្រើនដូចយ៉ាង Pologne និង Espagne។ នៅពេលនោះហើយ ដែលជាលើកទីមួយបង្អស់ សភាអឺរ៉ុបចេញមុខស្នើ រដ្ឋាភិបាលប្រទេសសមាជិកទាំងអស់ ឲ្យស្រុះស្រួលគ្នាបង្កើតក្រុមការងារមួយទទួលបន្ទុកខាងតាក់តែង រដ្ឋធម្មនុញ្ញអឺរ៉ុប រដ្ឋធម្មនុញ្ញអឺរ៉ុបដែលនឹងត្រូវអនុញ្ញាតឲ្យសហភាពមានដំណើររលូនទៅមុខល្អ។

ឆ្នាំ២០០៥ ជាឆ្នាំនៃការតស៊ូមតិយ៉ាងផុសផុលនៅក្នុងសហភាពអឺរ៉ុប ជុំវិញរដ្ឋធម្មនុញ្ញអឺរ៉ុប។ ពីព្រោះក្រោយពីបានតាក់តែងរួចហើយ រដ្ឋធម្មនុញ្ញនេះត្រូវទទួលសច្ចាប័នពីសំណាក់ប្រទេសសមាជិកនីមួយៗសិន មុននឹងអាចចូលជាធរមានបាន។ ប្រទេសបារាំងស្នើឲ្យប្រជាពលរដ្ឋរបស់ខ្លួនធ្វើសច្ចាប័ន តាមរយៈការបោះឆ្នោតប្រជាមតិ។ ក៏ប៉ុន្តែ ស្រាប់តែនៅខែឧសភាឆ្នាំ២០០៥ ប្រជាពលរដ្ឋបារាំងច្រានចោលរដ្ឋធម្មនុញ្ញអឺរ៉ុប ជាហេតុធ្វើឲ្យអភិក្រមនៃការបន្តកសាងសហភាពអឺរ៉ុបគាំងដំណើរនៅមួយ កន្លែង សាជាថ្មីម្តងទៀត។

ជារួម ប្រវត្តិនៃការកសាងសហភាពអឺរ៉ុប តាំងពីចប់សង្គ្រាមលោកលើកទីពីរ មកទល់ពេលនេះ គឺជាប្រវត្តិនៃការប្រឈមមុខដាក់គ្នារវាងអ្នកគាំទ្រចក្ខុនិមិត្ត នៃអឺរ៉ុបសហព័ន្ធ Europe fédérale និងអ្នកគាំទ្រចក្ខុនិមិត្តនៃអឺរ៉ុបសមាគមប្រជាជាតិ Europe des Nations។ នៅត្រង់នេះ គេអាចនិយាយបានថា ៥០ឆ្នាំក្រោយ

សន្ធិសញ្ញាទីក្រុង Rome សហភាពអឺរ៉ុបមិនមែនជាសហរដ្ឋអឺរ៉ុប ដូចគំរូនៃសហរដ្ឋអាមេរិកនៅឡើយទេ។ ហើយវាក៏មិនមែនជាសហព័ន្ធន៍មួយ ដូចសហព័ន្ធន៍ Suisse ឯណា។ សហភាពអឺរ៉ុប គ្រាន់តែជាសហភាពនៃបណ្តារដ្ឋឯករាជ្យចំនួន២៧ ដែលមកទល់ពេលនេះ នៅមិនទាន់ដាច់ចិត្តបង្កើតអធិបតេយ្យនិងលទ្ធិប្រជាធិបតេយ្យរួមគ្នាមួយនៅឡើយ។

គេក៏មិនត្រូវបំភ្លេចទេ មូលហេតុដើមដែលបានជម្រុញថ្នាក់ដឹកនាំទាំងអស់ ឲ្យចាប់ដៃគ្នាបង្កើតអឺរ៉ុបរួម។ មូលហេតុនោះ គឺចៀសវាងកុំឲ្យសង្គ្រាម ដូចសង្គ្រាមលោកលើកទីមួយ និងសង្គ្រាមលោកលើកទីពីរកើតឡើងនៅទ្វីបអឺរ៉ុបទៀត។ ចំណុចមួយទៀត ដែលគួរចងចាំ គឺបារាំងនិងអាល្លឺម៉ង់ ជាក្បាលរទេះភ្លើងដែលអូសទាញឲ្យអភិក្រមនៃការកសាងសហភាពអឺរ៉ុប បោះពួយទៅមុខ។

តទៅថ្ងៃមុខ សហភាពអឺរ៉ុប ប្រហែលជាគ្មានជម្រើសអ្វីក្រៅពីបង្កើនល្បឿនសមាហរណ៍កម្ម ផ្នែកនយោបាយរួមនិងផ្នែកការពារអឺរ៉ុបរួមនោះទេ។ ពីព្រោះប្រទេសអឺរ៉ុបមួយណាក៏ដោយដែលនៅដាច់តែឯង ទោះជាបារាំង អង់គ្លេសឬអាល្លឺម៉ង់ក៏ដោយ គ្មានទម្ងន់ទេ ទឹកមាត់មិនប្រៃទេ នៅចំពោះមុខសហរដ្ឋអាមេរិកឬប្រទេសចិន។ ក៏ប៉ុន្តែ គេក៏ត្រូវដឹងដែរថា ចាប់ពីពេលនេះទៅ ការបន្តកសាងអឺរ៉ុបរួម ជាការមួយពិបាកឡើងៗ។ ពីព្រោះ ពី៦ប្រទេសនៅក្នុងអតីតកាល អឺរ៉ុបបានកើនដល់ទៅ២៧ប្រទេស ក្នុងបច្ចុប្បន្នកាលនិងប្រហែលដល់ទៅ៣០ប្លាយប្រទេស នៅអនាគតកាល។

សមាជិកកើនឡើងជាលំដាប់ តែគោលការណ៍ដើមនៅដដែល បានន័យថាចង់សម្រេចអ្វី ក៏ដោយសហភាពអឺរ៉ុបត្រូវការ ការយល់ព្រមជាឯកច្ឆ័ន្ទពីសំណាក់សមាជិកទាំងអស់។ ឲ្យតែមាន Veto ប្រឆាំងពីប្រទេសណាមួយបរាជ័យនឹងមកដល់ភ្លាម។

២០០៧ ជាឆ្នាំដែលអភិក្រមនៃការកសាងអឺរ៉ុបរួម ត្រូវរាំងស្ទះនៅមួយកន្លែង។ ក៏ប៉ុន្តែ ផ្ទៃមេឃនៃសហភាពអឺរ៉ុបចាប់ផ្តើមស្រឡះឡើងវិញ បន្តិចម្តងៗ តាំងពីឆ្នាំ២០០៨មក។ តើហេតុអ្វី?

ឆ្នាំ២០០៧ ជាឆ្នាំមួយសែនពិបាកសម្រាប់សហភាពអឺរ៉ុប ដែលត្រូវគាំងដំណើរ នៅមួយកន្លែង។ រដ្ឋធម្មនុញ្ញអឺរ៉ុបមិនអាចចូលជាធរមានបាន ពីព្រោះមិនបានទទួលសច្ចាប័ន ពីសំណាក់បណ្តាសមាជិកទាំងអស់។ ១៥ប្រទេសបានទទួលច្បាប់កំពូលនេះ ប្រទេស ២បានច្រានចោល រីឯសមាជិកដទៃទៀតមិនបានចាត់ចែងកោះប្រជុំសភា ឬរៀបចំធ្វើប្រជាមតិដើម្បីឲ្យសច្ចាប័នអ្វីឡើយ ពីព្រោះចង់ឬមិនចង់ រដ្ឋធម្មនុញ្ញអឺរ៉ុបបានស្លាប់បាត់ទៅហើយ។

ក៏ប៉ុន្តែ យ៉ាងណាក៏ដោយសហភាពអឺរ៉ុបបន្តគ្រងរស់។ Roumanie និង Bulgarie បានចូលជាសមាជិក ធ្វើឲ្យអឺរ៉ុប ២៥ប្រទេសក្លាយជាអឺរ៉ុប ២៧ប្រទេស។ អឺរ៉ុបបន្តរស់ តែដើរអូសជើងតាំងពីឆ្នាំ ២០០៥មក ម្ល៉េះ។ ពីព្រោះ ក្បាលរទេះភ្លើងអឺរ៉ុប គឺប្រទេសអាល្លឺម៉ង់និងប្រទេសបារាំងឈប់ដំណើរការ។

នៅអាល្លឺម៉ង់ លោកស្រីAngela Merkel ដែលបានជាប់ឆ្នោតជានាយករដ្ឋមន្ត្រី ជាប់រវល់សម្រួលទំនាក់ទំនងជាមួយសហរដ្ឋអាមេរិកឡើងវិញ ក្រោយពីប្រទេសទាំងពីរបានបែរខ្នងដាក់គ្នាអស់ពីរបីឆ្នាំ ព្រោះតែសង្គ្រាមIrak។ បារាំងវិញ ក្រពុលមុខខ្លាំង ដោយហេតុតែប្រជាពលរដ្ឋរបស់ខ្លួនបានច្រានចោលរដ្ឋធមនុញ្ញអឺរ៉ុប នៅឆ្នាំ២០០៥ ហើយដោយហេតុតែនៅឆ្នាំ២០០៧ ប្រទេសបារាំងត្រូវជាប់រវល់បោះឆ្នោតប្រធានាធិបតីថែមទៀត ម្ល៉េះហើយគ្មានពេលគិតគូរពីសហភាពអឺរ៉ុបឡើយ។

នៅឆ្នាំ២០០៧ ដដែលនោះ ក៏មានវិបត្តិបញ្ហានៅក្នុងបណ្ដាប្រទេសសមាជិកដែលចេញពីអឺរ៉ុបខាងកើត។ ប្រទេសPologne ដែលដឹកនាំដោយបងប្អូនបង្កើតពីរនាក់ ម្នាក់ជាប្រធានាធិបតី ម្នាក់ទៀតជានាយករដ្ឋមន្ត្រី ខ្លាចRussie និងមិនទុកចិត្តAllemand ហើយចង់ស្និតស្នាលជាមួយសហរដ្ឋអាមេរិក។ ប្រទេសTchèqueវិញ ក៏មានជំហរដូចប្រទេសPologneអ៊ីចឹងដែរ។ ការពិតប្រទេសទាំងពីរនេះប្រកាន់ឫកពាជាអ្នកជាតិនិយម មិនចង់បានទេសមាហរណកម្មខ្លាំងពេកទៅក្នុងសហភាពអឺរ៉ុប។ ក្រៅពីនេះកិច្ចចរចាជាមួយប្រទេសTurquie ដែលចង់ចូលជាសមាជិកសហភាពអឺរ៉ុបចោទជាបញ្ហា ពីព្រោះមានការប្រឆាំងពីសំណាក់សមាជិកខ្លះ និងការគាំទ្រពីសំណាក់សមាជិកខ្លះទៀត។ ទន្ទឹមជាមួយគ្នានេះ Pologne និង Lituanie ចេះតែជម្រុញឲ្យសហភាពអឺរ៉ុបទទួលប្រទេសUkraineមកធ្វើជាសមាជិក។ ក៏ប៉ុន្តែ សហភាពអឺរ៉ុបស្ទាក់ស្ទើរ ព្រោះខ្លាចRussie អន់ចិត្ត។ ប្រទេសUkraineខ្លួនឯង ក៏អល់អែកដែរ ម្ដងចង់ម្ដងមិនចង់ចូលជ្រកក្រោមដំបូលអឺរ៉ុបរួម។ ទាំងនេះ ស្ដែងឲ្យឃើញថា ពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៧ សហភាពអឺរ៉ុបទៅមុខមិនរួច គ្មានជំហររួម និងអត់ទម្ងន់នៅលើឆាកអន្តរជាតិ។

យ៉ាងណាក៏ដោយ ចាប់ពីឆ្នាំចុងឆ្នាំ២០០៨ទៅ ផ្ទៃមេឃនៃសហភាពអឺរ៉ុបចាប់ផ្ដើមស្រឡះឡើងវិញបន្តិចម្ដងៗ ដោយសារតែប្រទេសបារាំង។ ប្រទេសបារាំង ក្រោមការដឹកនាំរបស់លោកប្រធានាធិបតីថ្មី Nicolas Sarkozy ផ្ដួចផ្ដើមតាក់តែងសន្ធិសញ្ញាមួយថ្មី ដើម្បីជំនួសរដ្ឋធម្មនុញ្ញអឺរ៉ុបឆ្នាំ២០០៥ដែលត្រូវបានបោះបង់ចោល ដោយហេតុតែពលរដ្ឋ ឬសភានៃប្រទេសសមាជិកខ្លះមិនព្រមឲ្យសច្ចាប័ន។

សន្ធិសញ្ញា ថ្មីនេះ អនុម័តនៅទីក្រុងLisbonne នៅថ្ងៃទី១៣ធ្នូឆ្នាំ២០០៧ និងចូលជាធរមាននៅថ្ងៃទី១ធ្នូឆ្នាំ២០០៩ មានគោលដៅផ្ដល់សន្ទុះថ្មីដល់ការបន្តកសាងអឺរ៉ុបរួម។ ជាក់ស្ដែង សិទ្ធិប្រើVéto ពីសំណាក់បណ្ដាប្រទេសសមាជិកដើម្បីខ្ទប់សេចក្ដីសម្រេចចិត្តរួមផ្សេងៗត្រូវបានកាត់បន្ថយ ហើយពីអំណើះតទៅ ប្រទេសមួយណាក៏ដោយមានសិទ្ធិដកខ្លួនគ្រប់ពេលវេលា ចេញពីសហភាពអឺរ៉ុប។

សន្ធិសញ្ញាទីក្រុងLisbonne ក៏មានគោលដៅពង្រឹងអំណាចរបស់សហភាពអឺរ៉ុប នៅលើឆាកអន្តរជាតិដែរ ដោយចង់ឲ្យអឺរ៉ុបមានសំឡេងរួមគ្នាតែមួយនៅក្នុងពិភពលោក តាមរយៈការបង្កើតតំណែងប្រធានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាអឺរ៉ុប និងការបង្កើតតំណែងឧត្តមតំណាងនៃសហភាពអឺរ៉ុបទទួលបន្ទុកកិច្ចការ បរទេស និងសន្តិសុខ។

ក៏ប៉ុន្តែ តាំងពីចុងឆ្នាំ២០០៨មកទល់ត្រឹមខែទី១នៃឆ្នាំ២០១០នេះ ពួកអ្នកមិនទុកចិត្ត និងមើលស្រាលអឺរ៉ុប គឺពួកEurosceptiques ចាប់ផ្ដើមស្ដីបន្ទោសសហភាពអឺរ៉ុបជាថ្មីឡើងវិញ។ម្យ៉ាង គឺមកអំពីក្នុងឱកាសសន្និសីទអន្តរជាតិ ស្ដីពីការប្រែប្រួលអាកាសធាតុ នៅទីក្រុងCopenhague ក្នុងខែធ្នូឆ្នាំ២០០៩ទឹកមាត់របស់អឺរ៉ុបមិនប្រៃ នៅចំពោះមុខសហរដ្ឋអាមេរិក និងប្រទេសចិន។ ម្យ៉ាងទៀត គឺមកអំពីតំណែងប្រធានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាអឺរ៉ុបត្រូវបាន ប្រគល់ទៅឲ្យជនជាតិBelgique Herman Van Rompuy ដែលគ្មានបុគ្គលិកលក្ខណៈខ្លាំង និងដែលគ្មានកិត្តិនាម នៅលើឆាកអន្តរជាតិ។ រីឯមូលហេតុចុងក្រោយដែលធ្វើឲ្យគេពិបាកជឿទៅលើឥទ្ធិពលរបស់អឺរ៉ុប គឺអវត្តមាននៃសកម្មភាពរួមរបស់អឺរ៉ុប ដើម្បីជួយសង្គ្រោះប្រជាជនHaïti ក្រោយគ្រោះរញ្ជួយដី នៅខែមករាកន្លងទៅនេះ។

ចង់ឬមិនចង់ ទ្វីបអឺរ៉ុបទាំងមូល និងសហភាពអឺរ៉ុបដាច់ដោយឡែក លែងជាដង្ហើមនៃពិភពលោកទៀត ហើយ។ ពាក្យស្លោកដែលថា អ្នកណាក្ដាប់អឺរ៉ុប អ្នកនោះក្ដាប់ពិភពលោក មានន័យត្រឹមត្រូវល្អ រហូតដល់សម័យសង្គ្រាមលោកលើកទីពីរ។ វាក៏នៅមានន័យដែរ ក្នុងសម័យសង្គ្រាមត្រជាក់ នាពេលដែលសហរដ្ឋអាមេរិក និងសហភាពសូវៀត ដណ្ដើមឥទ្ធិពលគ្នានៅគ្រប់ជ្រុងជ្រោយក្នុងពិភពលោក ពិសេសនៅលើទ្វីបអឺរ៉ុបតែម្ដង។

ក៏ប៉ុន្តែ ក្រោយសង្គ្រាមត្រជាក់ ពិភពលោកបែកចេញជាច្រើនPôles មិនមែនមានPôlesភូមិសាស្ត្រនយោបាយតែពីរ ដូចពីពេលមុនទៀតទេ។ នៅក្នុងបរិបទនេះ សហភាពអឺរ៉ុបចោទសួរខ្លួនឯងថា តើត្រូវបន្តពឹងពាក់ឲ្យអាមេរិកជួយការពារខ្លួន ដូចក្នុងសម័យសង្គ្រាមត្រជាក់ ឬក៏ត្រូវគិតគូរបង្កើតកងទ័ពអឺរ៉ុបរួមមួយដើម្បីការពារខ្លួនឯង និងដើម្បីចេញទៅធ្វើអន្តរាគមន៍នៅលើទីសមរភូមិនានា ក្នុងពិភពលោក ក្នុងនាមជាមហាអំណាចមួយនឹងគេដែរឬទេ ?

តើត្រូវបង្កើតអឺរ៉ុប សហព័ន្ធEurope fédérale ឬអឺរ៉ុបសមាគមប្រជាជាតិ Europe des Nations?

ចក្ខុនិមិត្ត ទាំងពីរនេះ នាំមកនូវការយល់ឃើញផ្សេងគ្នាអំពីតួនាទីរបស់សហភាពអឺរ៉ុប នៅក្នុងលោក។ នៅម្ខាង អឺរ៉ុបសហព័ន្ធ មានមហិច្ឆតាក្លាយជាមហាប្រទេសអឺរ៉ុបតែមួយ ដែលចាំបាច់ត្រូវតែដើតួនាទីជាមហាអំណាច ដូចសហរដ្ឋអាមេរិក ឬក៏ប្រទេសចិនសព្វថ្ងៃ។ នៅម្ខាងទៀត អឺរ៉ុបសមាគមប្រជាជាតិ គ្រាន់តែចង់ឲ្យបណ្ដាប្រទេសសមាជិកសាមគ្គីគ្នាដើម្បីការពារ អារ្យធម៌អឺរ៉ុប ការពារគំរូអភិវឌ្ឍន៍មួយ ដោយមិនចាំបាច់យកចិត្តទុកដាក់ ទៅលើការប្រែប្រួលនយោបាយឬភូមិសាស្ត្រនយោបាយនៅក្នុងពិភពលោកអ្វីទេ ពីព្រោះគិតគូរអំពីរឿងទាំងអស់នេះ គឺជាភារកិច្ចផ្ទាល់របស់ប្រទេសសមាជិកនីមួយៗរៀងៗខ្លួន។

នៅ សប្ដាហ៍ក្រោយ ខ្ញុំនឹងវិភាគមើលថា តើអ្វីទៅចំណុចខ្លាំង និងថា តើអ្វីទៅចំណុចខ្សោយរបស់សហភាពអឺរ៉ុប នៅក្នុងពិភពលោក សព្វថ្ងៃ។

## ២. ចំណុចខ្លាំង និងចំណុចខ្សោយរបស់សហភាពអឺរ៉ុប នៅលើពិភពលោក

ឆ្នាំ២០០៣ ជាឆ្នាំដែលសហភាពអឺរ៉ុប ចាប់ផ្ដើមជួបប្រទះនឹងវិបត្តិធ្ងន់ធ្ងរ។ សង្គ្រាមអាមេរិកាំងនៅ Irak ធ្វើឲ្យអឺរ៉ុបរួមប្រេះឆា។ អង់គ្លេស អេស្ប៉ាញ និងអ៊ីតាលី គាំទ្រអន្តរាគមន៍យោធារបស់អាមេរិក។ រីឯបារាំង និងអាល្លឺម៉ង់វិញប្រឆាំង។ ម្យ៉ាងវិញទៀត គឺនៅឆ្នាំ ២០០៣នោះហើយ ដែលសហភាពអឺរ៉ុបចាប់ផ្ដើមទទួលបណ្ដាប្រទេសអឺរ៉ុបខាងកើត ជាហេតុធ្វើឲ្យចំនួនសមាជិកកើនពី ១៥ ទៅ២៥ប្រទេស នៅឆ្នាំ២០០៤ និងក្រោយមកទៀតពី ២៥ទៅ ២៧ប្រទេស។

វត្តមាននៃសមាជិកថ្មីទាំងអស់នេះ ធ្វើឲ្យសហភាពអឺរ៉ុបបែកបាក់គ្នាកាន់តែខ្លាំង នៅចំពោះមុខសង្គ្រាមIrak ពីព្រោះបណ្ដាសមាជិកថ្មីចេញពីអឺរ៉ុបខាងកើតទាំងនេះ ដែលបានឋិតនៅក្នុងក្រញាំរបស់សហភាពសូវៀតជាច្រើនទសវត្សរ៍ បែរភ្លាមភ្លែតទៅស្និទ្ធស្នាលជាមួយអាមេរិក ដោយហេតុតែពួកគេនៅខ្លាចរុស្ស៊ី និងនៅមិនទុកចិត្តអាល្លឺម៉ង់។

អ៊ីចឹងហើយ បានជាចាប់ពីឆ្នាំ២០០៣នោះមក សហភាពអឺរ៉ុបចោទសួរខ្លួនឯងខ្លាំងឡើងៗថា តើអ្វីទៅតួនាទីរបស់ខ្លួននៅក្នុងពិភពលោក។

មែនទែនទៅ សហភាពអឺរ៉ុបជាមហាអំណាចពាណិជ្ជកម្មនិងសេដ្ឋកិច្ច។ មានប្រជាជនប្រមាណតែ ៥០០លាននាក់ប៉ុណ្ណោះ ក៏ប៉ុន្តែ សហភាពអឺរ៉ុបបង្កើតបាន២៥%នៃផលិតផលក្នុងដុលរបស់ពិភពលោកទាំងមូល និងតំណាង២០%នៃពាណិជ្ជកម្មពិភពលោក។ មិនតែប៉ុណ្ណោះ តាំងពីឆ្នាំ២០០២មក ប្រាក់អឺរ៉ូរបស់សហភាពអឺរ៉ុបថ្លៃជាងប្រាក់ដុល្លាររបស់អាមេរិក។ ម្ល៉ោះហើយ ក៏ដូចសហរដ្ឋអាមេរិកដែរ សហភាពអឺរ៉ុបមានមធ្យោបាយគ្រប់គ្រាន់ក្នុងការអនុវត្តមហិច្ឆតានយោបាយ ធំធេងនៅក្នុងពិភពលោក ឬយ៉ាងហោចណាស់ក៏នៅក្នុងតំបន់Balkan និងនៅក្នុងតំបន់ជុំវិញសមុទ្រMéditerranéeដែរ។

ប្រសើរជាងនេះ ទៅទៀត មតិអន្តរជាតិចង់ឃើញសហភាពអឺរ៉ុបដើរតួនាទីកាន់តែសំខាន់នៅក្នុងពិភពលោក ពីព្រោះសហភាពអឺរ៉ុបមានរូបភាពល្អ ត្រូវគេចាត់ទុកជាមហាអំណាចត្រជាក់ Soft power ដែលការពារពហុភាគីនិយម នៅក្នុងប្រព័ន្ធទំនាក់ទំនងអន្តរជាតិ និងដែលឲ្យតម្លៃទៅលើសន្តិភាព ស្ថិរភាព លទ្ធិប្រជាធិបតេយ្យ យុត្តិធម៌ និងសាមគ្គីធម៌ ព្រមទាំងអភិក្រមនៃការចរចា ដើម្បីដោះស្រាយបញ្ហាផ្សេងៗ។

សហភាពអឺរ៉ុបមិនខ្វះទេ សមត្ថភាព និងមធ្យោបាយ តែខ្វះឆន្ទៈនយោបាយ។ បានន័យថា បណ្តាសមាជិក នៅតែគិតពីប្រយោជន៍របស់ប្រទេសគេរៀងៗខ្លួន ខ្លាំងជាងប្រយោជន៍របស់អឺរ៉ុបរួម។ ម្ល៉ោះហើយ នៅក្នុងសហភាពអឺរ៉ុប មិនទាន់អាចមានទៅកើតទេ ទីបញ្ជាការរួមតែមួយ។ ប្រទេសសមាជិកនីមួយៗជាអ្នកសម្រេចកិច្ចការនយោបាយរៀងៗខ្លួន ហើយរដ្ឋធានីបី មានទឹកមាត់ប្រៃជាងគេ និងទម្ងន់ខ្លាំងជាងគេ គឺទីក្រុងParisនៃប្រទេសបារាំង ទីក្រុងLondresនៃប្រទេសអង់គ្លេសនិងទីក្រុងBerlinនៃប្រទេសអាល្លឺម៉ង់។

កង្វះឆន្ទៈនយោបាយរួម បណ្តាលឲ្យសហភាពអឺរ៉ុបខ្វះយុទ្ធសាស្ត្ររួម។ ជាច្រើនទសវត្សរ៍កន្លងមកហើយ ដែលគេបាន និងកំពុងបន្តនិយាយពីការបង្កើតកងទ័ពអឺរ៉ុបរួមមួយដែលអាចខ្លាំង ស្មើនឹងទ័ពអាមេរិកាំង។ ក៏ប៉ុន្តែ ដរាបណាបណ្តាប្រទេសសមាជិកទាំងអស់ នៅតែមិនទាន់ដាច់ចិត្តបោះបង់ចោលអធិបតេយ្យរៀងៗខ្លួនរបស់គេទេ ដរាបនោះនឹងនៅតែមិនអាចមានទៅកើតទេកងទ័ពអឺរ៉ុបរួម។ មិនតែប៉ុណ្ណោះ ប្រទេសសមាជិកអឺរ៉ុបនីមួយៗ ចាយប្រាក់តិចជាងសហរដ្ឋអាមេរិក នៅក្នុងវិស័យការពារជាតិ គឺប្រមាណ២,៥% នៃផលិតផលដុលក្នុងស្រុកសម្រាប់ប្រទេសបារាំង ក៏ដូចសម្រាប់ប្រទេសអង់គ្លេស និង១,៥%នៃផលិតផលដុលក្នុងស្រុកសម្រាប់ប្រទេសអាល្លឺម៉ង់ ទល់នឹង៤%នៃផលិតផលដុលក្នុងស្រុកសម្រាប់សហរដ្ឋអាមេរិក។

គ្មានកងទ័ពរួម សហភាពអឺរ៉ុបគ្មានអំណាចនៅលើឆាកអន្តរជាតិ។ ម្ល៉ោះហើយ ដើម្បីមានទឹកមាត់ប្រៃនៅក្នុងពិភពលោក សហភាពអឺរ៉ុបក៏សម្រេចបង្កើតមុខតំណែងពីរសែនសំខាន់ តាមរយៈសន្ធិសញ្ញាទីក្រុងLisbonne ឆ្នាំ២០០៧ នោះគឺតំណែងប្រធានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាអឺរ៉ុប និងតំណែងឧត្តមតំណាងអឺរ៉ុបទទួលបន្ទុកកិច្ចការបរទេស និងសន្តិសុខ។

ក៏ប៉ុន្តែសម្រេចសម្រួចទៅ ស្រាប់តែបណ្តាប្រទេសសមាជិកអឺរ៉ុបទាំង២៧ ត្រូវរ៉ូវគ្នាតែងតាំងជាប្រធានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាអឺរ៉ុប ជនជាតិBelgiqueម្នាក់ គឺលោកVan Rompuy។ គាត់មិនគ្រាន់តែជាមនុស្សម្នាក់ដែលគ្មានបុគ្គលិកលក្ខណៈប៉ុណ្ណោះទេ ដើម្បីអាចអង្គុយចរចាបានជាមួយលោកប្រធានាធិបតីអាមេរិកាំង ឬលោកប្រមុខរដ្ឋចិន ជាងនេះទៅទៀត គាត់ជាមនុស្សម្នាក់ដែលគ្មានអ្នកណាស្គាល់ឈ្មោះទៅទៀត នៅលើឆាកអន្តរជាតិ។ បានន័យថា នៅទីបំផុត បណ្តាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលអឺរ៉ុបនៅតែមិនព្រមប្រគល់អំណាចទៅឲ្យអ្នកណា ម្នាក់ដើម្បីនិយាយជំនួស ឬចរចាជំនួសពួកគេទេ នៅលើឆាកអន្តរជាតិ។

ចំណុចខ្សោយមួយទៀតរបស់សហភាពអឺរ៉ុប គឺសន្ទុះសេដ្ឋកិច្ចមិនខ្លាំងនិងមិនលឿនហ័សតាំងពីទសវត្សរ៍ទី៩០ មកម្ល៉េះ បើប្រៀបធៀបទៅនឹងសន្ទុះសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក និងរបស់ចិន។ សេដ្ឋកិច្ចរបស់អឺរ៉ុបរឹងរឹតតែខ្សោយ តាំងពីមានវិបត្តិសេដ្ឋកិច្ចសកលក្នុងឆ្នាំ២០០៨មក។

បើនិយាយ ពីប្រជាសាស្ត្រវិញ ប្រជាជនអឺរ៉ុបដែលមានវ័យកាន់តែចាស់ ចោទជាបញ្ហាជុំវិញការរកប្រាក់មកចិញ្ចឹមអ្នកចូលនិវត្តន៍ ចោទជាបញ្ហាជុំវិញតុល្យភាពនៅក្នុងសង្គម និងអាចធ្វើឲ្យគ្រោះនៃភាពចំរុងចម្រើន ព្រមទាំងគ្រោះនៃអារ្យធម៌អឺរ៉ុបរង្គោះរង្គើ។

និយាយសរុបមកវិញ ដើម្បីពង្រឹងពង្រីកសមត្ថភាព និងសកម្មភាពរួមរបស់ខ្លួន នៅលើឆាកអន្តរជាតិទៅបាន អឺរ៉ុបត្រូវកំណត់ឲ្យច្បាស់លាស់ជាមុនសិនមហិច្ឆតារួមរបស់ខ្លួន។ តើបណ្តាប្រទេសអឺរ៉ុបចង់ក្លាយជាសហព័ន្ធ ក្នុងគោលដៅដើរតួនាទីជាមហាអំណាចនយោបាយ និងយោធាដូចសហរដ្ឋអាមេរិកដែរឬទេ ឬមួយក៏គ្រាន់តែចង់រួបរួមគ្នាជាសមាគមប្រជាជាតិមួយដើម្បីបង្កើន ប្រយោជន៍សេដ្ឋកិច្ចតែប៉ុណ្ណោះ?

នៅសប្តាហ៍ក្រោយ ខ្ញុំនឹងចាប់ផ្តើមវិភាគមើលថា តើនៅក្នុងពិភពលោកសព្វថ្ងៃ ផលប្រយោជន៍របស់សហភាពអឺរ៉ុបឋិតនៅឯណា និងថា តើសហភាពអឺរ៉ុបត្រូវប្រកាន់យកឥរិយាបថបែបណា នៅចំពោះមុខអាមេរិក អាស៊ី ឬអាហ្វ្រិក?

## ៣. ទំនាក់ទំនងរវាងសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក

ដូចដែលធ្លាប់បានលើកឡើងរួចហើយថានៅឆ្នាំ២០០៣ សហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិក មើលមុខគ្នាមិនចំ។ មូលហេតុ គឺមកពីអាមេរិកធ្វើសង្គ្រាមនៅIrak ហើយធ្វើឲ្យអឺរ៉ុបប្រេះឆាគ្នា។ Anglais Espagne និង Italie គាំទ្រអន្តរាគមន៍យោធារបស់អាមេរិក រីឯបារាំងនិងAllemand វិញប្រឆាំង។ ម្យ៉ាងវិញទៀត គឺនៅឆ្នាំ២០០៣នោះហើយ ដែលសហភាពអឺរ៉ុប ត្រៀមខ្លួនទទួលបណ្តាប្រទេសអឺរ៉ុបខាងកើតឲ្យចូលជាសមាជិក។ បណ្តាប្រទេសសមាជិកថ្មីថ្មោងទាំងនេះ ដែលបានឋិតនៅក្រោមក្រញាំសហភាពសូវៀតជាច្រើនទសវត្សរ៍នៅមិនទុកចិត្តរុស្ស៊ី ត្រូវការឲ្យអាមេរិកការពារពួកគេ ម្ល៉េះហើយពួកគេនាំគ្នាទៅគាំទ្រភ្លាមភ្លែតសង្គ្រាមអាមេរិក នៅ Irak។ ទាំងនេះធ្វើឲ្យសហភាពអឺរ៉ុបបែកបាក់ប្រេះឆាគ្នាកាន់តែខ្លាំងនិង ធ្វើឲ្យអឺរ៉ុបនិងអាមេរិក កាន់តែមិនចុះសម្រុងគ្នា។

ប៉ុន្មានឆ្នាំក្រោយមក គឺនៅចុងឆ្នាំ២០០៨ សហរដ្ឋអាមេរិករបស់លោកBush លែងអុងអាត់លែងប្រកាន់យកជំហរឯកតោភាគីនិយម នៅលើឆាកអន្តរជាតិដូចពេលមុន ទៀតហើយ។ ពីព្រោះស្ថានភាពនៅ Irak មិនប្រព្រឹត្តទៅ ដូចទីក្រុងWashington បានគ្រោងទុកទេ ពីព្រោះជ័យជំនះ តាមរយៈការបោះឆ្នោតប្រជាធិបតេយ្យរបស់ចលនាអ៊ីស្លាមជ្រុលនិយមHamas នៅដែនដីPalestine បានបើកភ្នែកលោកBush ឲ្យយល់ថា គេមិនអាចបង្ខំភូមិភាគដើមបូព៌ាឲ្យទទួលយកលទ្ធិប្រជាធិបតេយ្យងាយៗ បានទេ។ អ៊ីចឹងហើយបានជាអាមេរិករបស់លោកBush មានចរិតស្លូតវិញ ស្លូតជាងនៅឆ្នាំ២០០៣ ដោយបានងាកមកឲ្យតម្លៃដល់ អ.ស.ប ជាអាទិ៍ក្នុងសំណុំរឿងនុយក្លេអ៊ែររបស់កូរ៉េខាងជើងនិងរបស់Iran។ នៅក្នុងបរិបទបែបនេះ អឺរ៉ុបនិងអាមេរិកក៏ខិតចូលជិតគ្នាវិញ។

ប៉ុន្តែ នៅឆ្នាំ២០០៨ ឆ្នាំដែលលោកBushជិតអស់អាណត្តិប្រធានាធិបតី ទោះជាទំនាក់ទំនងរវាងអាមេរិកនិងអឺរ៉ុបល្អប្រសើរជាងមុនក្តី ក៏នៅមានសល់ច្រើនណាស់មូលហេតុស្មុគស្មាញដែលបន្តធ្វើឲ្យភាគីទាំង

ពីរមិនអាចស្និទ្ធស្នាលគ្នាបាន ដូចកាលសម័យសង្គ្រាមត្រជាក់បានឡើយ។ ជាបឋម នៅខាងសហភាពអឺរ៉ុប អឺរ៉ុបមិនយល់ឃើញនិងមិនធ្វើតាមអាមេរិកទេ នៅចំពោះមុខចលនាភេរវនិយម។ រដ្ឋការលោកBush ធ្វើសង្គ្រាមប្រឆាំងភេរវកម្ម ដូចខ្លួនបានធ្វើសង្គ្រាមកំចាត់ពួកNazi Allemand កាលសម័យសង្គ្រាមលោកលើកទីពីរ។ បានន័យថា ចំពោះអាមេរិករបស់លោកBush ឲ្យតែជាភេរវជន គឺសុទ្ធតែជាពួកតំណាងសភាវៈអាក្រក់ទាំងអស់ ទោះជាអ្នកនោះជាអ្នកទាមទារផ្តាច់ទឹកដីនិយម ដូចពួកTchéchènes ឬក៏ជាពួកសកម្មជន AlQaïda តាងនាមឲ្យសាសនាអ៊ីស្លាមជ្រុលនិយមក៏ដោយ។ ម្យ៉ាងវិញទៀត អឺរ៉ុបក្តៅចិត្ត ដោយហេតុតែអាមេរិកដែលជាជើងឯកនៃពិភពភាវូបនីយកម្ម ចេះតែបង្ខិតបង្ខំគេឯង ឲ្យទទួលចក្ខុនិមិត្តនៃទីផ្សារសេរីរបស់ខ្លួន ជាពិសេស នៅពេលចរចាក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោកOMCម្តងៗ។

ចំណុចមួយទៀត ដែលអឺរ៉ុបមិនចុះសម្រុងជាមួយអាមេរិក គឺសុបិនរបស់លោកBushក្នុងការធ្វើឲ្យសន្តិភាពកើតឡើង នៅក្នុងភូមិភាគដើមបូព៌ា តាមរយៈការដាក់បន្ទុបលទ្ធិប្រជាធិបតេយ្យឲ្យបណ្តាប្រទេសក្នុងតំបន់ នេះយកទៅអនុវត្ត គឺថាធ្វើហាក់បីដូចជាប្រទេសប្រជាធិបតេយ្យមិនចេះធ្វើសង្គ្រាម និងមានតែប្រទេសកាន់អំណាចផ្តាច់ការទេដែលចេះឈ្លោះប្រកែកគ្នា។

ក្រោយ មកទៀត អាមេរិករបស់លោកObama ចាប់ពីខែមករាឆ្នាំ២០០៩មក និងអឺរ៉ុបក៏នៅតែមិនអាចវិលមកស្និទ្ធស្នាលគ្នាខ្លាំងវិញ ដូចសម័យសង្គ្រាមត្រជាក់បានឡើយ។ ពីព្រោះ អាមេរិកនៅសតវត្សរ៍ទី២១នេះ លែងចាត់ទុកអឺរ៉ុបថា ជាតំបន់ភូមិសាស្ត្រនយោបាយមួយសំខាន់ទៀតហើយ។ រហូតមកដល់ឆ្នាំ១៩៩១ឆ្នាំដែលសហភាពសូវៀតរលាយនិងសង្គ្រាមត្រជាក់ត្រូវចប់ អឺរ៉ុបជាដង្ហើមរបស់អាមេរិក។ ចូរកុំភ្លេចថា អាមេរិកបានមកជួយស្រោចស្រង់អឺរ៉ុបប្រជាធិបតេយ្យឲ្យរួចពីអំណាច ផ្តាច់ការនៃចក្រភពអឺរ៉ុបកណ្តាល មកជួយរំដោះអឺរ៉ុបឲ្យរួចពីក្រញាំAllemand nazi និងមកជួយការពារអឺរ៉ុបប្រជាធិបតេយ្យប្រឆាំងនឹងសហភាពសូវៀតកុម្មុយនិស្ត។

ឥឡូវនេះ នៅឆ្នាំ២០១០ អាមេរិករបស់លោកObama បែរជាឲ្យតម្លៃទៅលើភូមិភាគដើមបូព៌ា និងអាស៊ី ជាងទៅលើអឺរ៉ុបទៅវិញ។ ឲ្យតម្លៃទៅលើអាស៊ី ដោយហេតុតែការលេចត្រដែតឡើងលឿនរហ័សនៃប្រទេសចិន។ ឲ្យតម្លៃទៅលើភូមិភាគដើមបូព៌ា ដោយហេតុតែជាជង្រុកនៃភេរវកម្ម និងជាចំណុចក្តៅគគុកជាងគេ នៃអស្ថិរភាពពិភពលោកសព្វថ្ងៃ។ ម្យ៉ាងវិញទៀត អាមេរិករបស់Obama បែបមិនសង្ឃឹម មិនសង្ឃឹមថា សហភាពអឺរ៉ុបអាចក្លាយទៅជាមហាប្រទេសរួមគ្នាតែមួយ ដែលមានឥទ្ធិពលនយោបាយខ្លាំងក្លា អាចក្លាយជាគូប្រជែងឬជាដៃគូរបស់ខ្លួនបាន។

## ៤. ទំនាក់ទំនងសហភាពអឺរ៉ុប និងអាស៊ាន

រហូតមកដល់ចុងទសវត្សរ៍ទី៩០ អាស៊ានមិនដែលត្រូវបានសហភាពអឺរ៉ុបយកចិត្តទុកដាក់ខ្លាំងឡើយ។ នយោបាយការបរទេសរួមរបស់ទីក្រុងBruxelles បានឲ្យតម្លៃជាពិសេសទៅលើតែបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅទ្វីបអាហ្វ្រិក នៅតំបន់ការ៉ាអ៊ីប(Caraïbes) និងនៅតំបន់ប៉ាស៊ីហ្វិក(Pacifique)។ រីឯនៅអាស៊ីវិញ សហភាពអឺរ៉ុបបានត្រឹមតែពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ជាមួយប្រទេសធំៗឬជាមួយប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ ដូចជាចិនឥណ្ឌា និងកូរ៉េខាងត្បូងតែប៉ុណ្ណោះ។

ក៏ប៉ុន្តែ នារយៈពេលជិតដប់ឆ្នាំចុងក្រោយនេះ នៅក្នុងពេលមួយដែលការផ្លាស់ប្តូរពាណិជ្ជកម្មរវាងអឺរ៉ុប

និងអាស៊ីចេះតែកើនឡើងជាលំដាប់ ស្រាប់តែអាស៊ានក្លាយដោយស្វ័យប្រវត្តជាដៃគូសេដ្ឋកិច្ចមួយដ៏ធំរបស់សហភាពអឺរ៉ុប។ សព្វថ្ងៃនេះ អឺរ៉ុបជាទីផ្សារសំខាន់លំដាប់ថ្នាក់ទីពីរ សំរាប់ផលិតផលរបស់អាស៊ាន នៅក្រោយសហរដ្ឋអាមេរិកដែលជាទីផ្សារធំទីមួយ ហើយអឺរ៉ុបជាដៃគូពាណិជ្ជកម្មទីបីរបស់អាស៊ាន បន្ទាប់ពីអាមេរិក និងជប៉ុន។

នៅឆ្នាំ២០០០-២០០១ ទីក្រុងBruxelles ផ្តើមភ្ញាក់ខ្លួន ហើយផ្តើមយល់ដឹងពីសក្តានុពលសេដ្ឋកិច្ចរបស់អាស៊ាន ដោយហេតុតែឱនភាពរហូតទៅដល់ជាងបីម៉ឺនលានដុល្លារនៃជញ្ជីងពាណិជ្ជកម្មរបស់អឺរ៉ុបនៅចំពោះមុខអាស៊ាន បានន័យថា បណ្តាប្រទេសសមាជិកសហភាពអឺរ៉ុបទិញទំនិញពីបណ្តាសមាជិកអាស៊ានច្រើនជាងលក់ទំនិញទៅឲ្យបណ្តាប្រទេសទាំងនេះ។ អ៊ីចឹងហើយ បានជាតាំងពីពេលនោះមក ទីក្រុង Bruxelles បានផ្លាស់ប្តូរនយោបាយ ក្នុងគោលដៅពង្រឹងវត្តមានរបស់អឺរ៉ុបនៅអាស៊ីអាគ្នេយ៍។ នៅក្នុងន័យនេះ គណៈកម្មការអឺរ៉ុបបាន និងកំពុងបន្តជម្រុញឲ្យក្រុមហ៊ុនអឺរ៉ុប ទៅដាក់ទុនរកស៊ី នៅក្នុងបណ្តាប្រទេសសមាជិកអាស៊ាន។ នៅក្នុងន័យដូចគ្នានេះដែរ សហភាពអឺរ៉ុបបានចុះហត្ថលេខាទទួលយកសន្ធិសញ្ញាស្តីពីមិត្រភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ហៅកាត់ថា TAC ហើយសហភាពអឺរ៉ុបក៏កំពុងបន្តចរចាជាមួយអាស៊ានដើម្បីបង្កើតតំបន់ផ្លោះប្តូរពាណិជ្ជកម្មដោយសេរីមួយដែរ។

យ៉ាងណាក៏ដោយ មកទល់សព្វថ្ងៃ សហភាពអឺរ៉ុប និងអាស៊ាន ដូចជានៅតែមិនទាន់ព្រមឲ្យតម្លៃខ្ពស់ដល់ភាពជាដៃគូនេះរបស់ពួកគេនៅឡើយ។ ជាក់ស្តែង កិច្ចប្រជុំពីរឆ្នាំម្តងរវាងប្លុកទាំងពីរ នៅតែប្រព្រឹត្តទៅត្រឹមថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេសនៅឡើយ មិនទាន់មានទេជំនួបកំពូល រវាងបណ្តាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលរបស់សហភាពអឺរ៉ុប និងរបស់អាស៊ាន។ ពិបាកយល់ជាងនេះទៅទៀត គឺរដ្ឋមន្ត្រីការបរទេសប្រទេសអឺរ៉ុបខ្លះមិនទាំងទៅចូលរួមក្នុងកិច្ចប្រជុំនេះទៅទៀត ច្រើនតែបញ្ជូនរដ្ឋលេខាធិការទៅជំនួសខ្លួនទៅវិញ។

យ៉ាងណាមិញ សហភាពអឺរ៉ុបនិងអាស៊ានដូចជាមិនសូវស៊ីចង្វាក់គ្នា។ ជាទូទៅអឺរ៉ុបមានឥរិយាបថរឹងរូសឧទាហរណ៍នៅចំពោះមុខការរំលោភសិទ្ធិមនុស្សនៅប្រទេសភូមាជាដើម។ ចំណែកអាស៊ានវិញ មិនសូវចង់ជ្រៀតជ្រែកទេក្នុងបញ្ហាផ្ទៃក្នុងនៃប្រទេសណាមួយចូលចិត្តសាច់ការនិងគិតតែពីប្រយោជន៍សេដ្ឋកិច្ច។

មែនទែនទៅ មានច្រើនណាស់ចំណុចរួមរវាងសហភាពអឺរ៉ុបនិងអាស៊ាន ចំណុចរួមដែលអាចជួយឲ្យប្លុកទាំងពីរខិតចូលជិតគ្នា។ មានជាបឋមប្រវត្តិសាស្ត្ររួមគ្នា។ ប្រវត្តិសាស្ត្រដែលទាក់ទងទៅនឹង សម័យអាណានិគមនិយម ពីព្រោះចូរកុំភ្លេចថា បារាំង អង់គ្លេស អេស្ប៉ាញ ព័រទុយហ្គ័ល ឬក៏ហុល្លង់ សុទ្ធសឹងជាប្រទេសដែលបានកាន់កាប់ប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនធំអស់រយៈពេលជាច្រើនសិបឆ្នាំ។ ដោយឡែកសហភាពអឺរ៉ុបជាគំរូសមាហរណកម្មតំបន់មួយសំរាប់អាស៊ាន។ អាស៊ានដែលចង់ប្រែក្លាយឲ្យដូចសហភាពអឺរ៉ុបយ៉ាងយូរនៅឆ្នាំ២០២០។

ម្យ៉ាងទៀត ការពង្រឹងភាពជាដៃគូរវាងតំបន់ទាំងពីរនឹងនាំមកនូវអត្ថប្រយោជន៍ធំ។ អត្ថប្រយោជន៍សំរាប់សហភាពអឺរ៉ុប គឺបទពិសោធន៍នៅក្នុងទំនាក់ទំនងរវាងអង្គការតំបន់មួយ និងអង្គការតំបន់មួយទៀត។ ឯអត្ថប្រយោជន៍សំរាប់អាស៊ានវិញ គឺអឺរ៉ុបអាចជួយធ្វើឲ្យមានតុល្យភាពភូមិសាស្ត្រនយោបាយមួយល្អ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលឋិតនៅក្រោមឥទ្ធិពលខ្លាំងពេករបស់ប្រទេសចិននិងរបស់សហរដ្ឋអាមេរិក។

## ៥. ទំនាក់ទំនងសហភាពអឺរ៉ុប និងរុស្ស៊ី

មានច្រើនណាស់ទំនាស់នយោបាយ និងមនោគមវិជ្ជា រវាងសហភាពអឺរ៉ុបនិងរុស្ស៊ី។ រុស្ស៊ីមិនភ្លេចទេថា នៅសម័យសង្គ្រាមត្រជាក់ អឺរ៉ុបខាងលិចជាសត្រូវរបស់ខ្លួន។ រុស្ស៊ីនៅគុំសហភាពអឺរ៉ុបខ្លាំង ពីព្រោះក្រោយពីសហភាពសូវៀតបានរលាយបាត់ទៅ សហភាពអឺរ៉ុបមិនបានជួយបញ្ចូលរុស្ស៊ីមកក្នុងដែនសន្តិសុខអឺរ៉ុបឡើយ។ ផ្ទុយទៅវិញ អឺរ៉ុបបានព្យាយាមកាត់បន្ថយឥទ្ធិពលរបស់រុស្ស៊ី បានខិតកាន់តែជិតមកដល់ព្រំដែនរុស្ស៊ីតាមរយៈការទទួលឲ្យចូលជាសមាជិករបស់សហភាព បណ្ដាប្រទេសអឺរ៉ុបខាងកើត និងអតីតសាធារណរដ្ឋបាល្ទ (Baltes)ជាដើម។

រុស្ស៊ីក៏បារម្ភខ្លាំង នៅចំពោះមុខអង្គការសន្ធិសញ្ញាអាត្លង់តិកហៅកាត់ថា OTAN ដែលជាសម្ព័ន្ធភាពយោធារវាងអាមេរិក និងអឺរ៉ុប បង្កើតឡើងនៅឆ្នាំ១៩៤៩ ដើម្បីទប់ទល់នឹងការគំរាមកំហែងពីសំណាក់សហភាពសូវៀត។ រុស្ស៊ីបារម្ភ ពីព្រោះពេលដែលសង្គ្រាមត្រជាក់បានចប់បាត់ទៅហើយ អឺរ៉ុបបែរជាចូលដៃជាមួយអាមេរិកដើម្បីពង្រីក OTAN ដោយបានទទួលបណ្ដាប្រទេសអឺរ៉ុបខាងកើតឲ្យចូលជាសមាជិក និងដោយគ្រោងចង់ទទួលបណ្ដាអតីតសាធារណរដ្ឋនៃសហភាពសូវៀតដូចជាអ៊ុយក្រែន( Ukraine ) និងហ្សកហ្ស៊ី ( Géorgie )ឲ្យចូលជាសមាជិកទៀតផង។

មិនតែប៉ុណ្ណោះសហភាពអឺរ៉ុបក៏តែងតែដើរតួនាទីជាគូប្រជែងឬជាសត្រូវរបស់រុស្ស៊ីដែរ។ ជាក់ស្ដែង ប្រទេសអង់គ្លេសបានផ្ដល់សិទ្ធិជ្រកកោនឲ្យសត្រូវនយោបាយនៃរបបទីក្រុងម៉ូស្គូ( Moscou )។ ដូចគ្នាអ៊ីចឹងដែរ រហូតដល់ឆ្នាំ២០០១ សហភាពអឺរ៉ុបបានរិះគន់យ៉ាងចាស់ដៃនយោបាយរបស់រុស្ស៊ីនៅឆេចឆេនី ( Tchétchénie )។ ក្រោយមក នៅឆ្នាំ២០០៣ សហភាពអឺរ៉ុបបានគាំទ្ររដ្ឋអំណាចថ្មីរបស់ហ្សកហ្ស៊ី ដែលមិនព្រមរណបទីក្រុងម៉ូស្គូ ហើយនៅឆ្នាំ២០០៤ អឺរ៉ុបក៏បានសម្ដែងនូវសម្ពានចិត្តរបស់ខ្លួន ចំពោះបដិវត្តន៍ពណ៌លឿងទុំរំលំរដ្ឋអំណាចអ៊ុយក្រែនដែលរណបរុស្ស៊ី។

អ៊ីចឹងហើយ បានជាក្រោយមក ជម្លោះឧស្ម័នរវាងរុស្ស៊ីនិងអ៊ុយក្រែនបស្ចិមលោកនិយមបានជះឥទ្ធិពលមកដល់សហភាពអឺរ៉ុប។ នៅឆ្នាំ២០០៦ និងនៅឆ្នាំ២០០៩ រុស្ស៊ីបិទក្បាលរ៉ូប៊ីនេឈប់បង្ហូរឧស្ម័នទៅឲ្យអ៊ុយក្រែនដែលចេះតែរករឿងមិនព្រមបង់លុយ។ ក៏ប៉ុន្តែ ទង្វើបែបនេះរបស់រុស្ស៊ីក៏ប៉ះពាល់ដល់អឺរ៉ុបដែរ ពីព្រោះអឺរ៉ុបទទួលឧស្ម័នពីរុស្ស៊ីតាមបំពង់ដែលលូនកាត់តាមប្រទេសអ៊ុយក្រែន។

លោកអតីតរដ្ឋមន្ត្រីការបរទេសបារាំងHubert Védrine ធ្លាប់បានពោលថា សម្រាប់ប្រទេសបារាំង រុស្ស៊ីជាដៃគូសំខាន់មួយនៅលើវិស័យទូត សម្រាប់អាល្លឺម៉ង់ រុស្ស៊ីជាដៃគូសេដ្ឋកិច្ច ចំណែកសម្រាប់ប្រទេសសមាជិកអឺរ៉ុបដទៃខ្លះទៀតវិញ រុស្ស៊ីជាគ្រោះថ្នាក់មួយធំ។ សំដីទាំងនេះរបស់លោកVédrine ស្ដែងឲ្យឃើញថាសហភាពអឺរ៉ុបគ្មានគោលនយោបាយរួមទេនៅចំពោះមុខរុស្ស៊ី។

យ៉ាងណាមិញ បន្តិចម្ដងៗ សហភាពអឺរ៉ុបនិងរុស្ស៊ីផ្ដើមយល់ចិត្តគ្នាទៅវិញទៅមក។ ជំនួបកំពូលចុងក្រោយរវាងភាគីទាំងពីរ ក្នុងទីក្រុងStockholm នៅខែវិច្ឆិកាឆ្នាំ២០០៩បានប្រព្រឹត្តទៅក្នុងបរិយាកាសមួយស្ងប់ និងធូរស្រាលល្អ បើទោះបីជាត្រូវនិយាយពីទំនាស់ច្រើនរាប់មិនអស់ក្ដី។ ទំនាស់អស់ទាំងនោះរួមមានឯករាជ្យរបស់កូសូវ៉ូ( Kosovo ) សង្គ្រាមហ្សកហ្ស៊ី វិបត្តិឧស្ម័ន ការពង្រីកOTAN ខែលមីស៊ីលប្រឆាំងមីស៊ីលរបស់អាមេរិក បញ្ហានុយក្លេអ៊ែររបស់អៀរ៉ង់( Iran ) និងបញ្ហាសិទ្ធិមនុស្សនៅរុស្ស៊ី។ល។និង។ល។

ដើម្បីទាញប្រយោជន៍ពីគ្នាបានរៀងៗខ្លួន សហភាពអឺរ៉ុបនិងរុស្ស៊ីគួរតែយោគយល់គ្នា។ សហភាពអឺរ៉ុបគួរតែយល់ថា រុស្ស៊ីនិងប្រជាជនរុស្ស៊ីភាគច្រើនចង់បានសន្តិភាពនៅធេចធេនី ចង់ឲ្យបណ្តាប្រទេសអឺរ៉ុបខាងកើតនិងបណ្តាប្រទេសបាល្ទបំភ្លេចរឿងចាស់ និងប្តូរចិត្តគំនិត ដោយយល់ព្រមចាត់ទុករុស្ស៊ីជាមិត្ត។ សហភាពអឺរ៉ុបគួរតែបញ្ចុះបញ្ចូលរុស្ស៊ី ដូចដែលខ្លួនបានធ្វើចំពោះអឺរ៉ុបខាងកើត ថាត្រូវតែទទួលយកសេរីកម្មសេដ្ឋកិច្ចនិងនយោបាយ ទទួលយកនូវអ្វីដែលបានជួយអឺរ៉ុបខាងលិច ឲ្យស្គាល់សន្តិភាពនិងកំណើនសេដ្ឋកិច្ចអស់រយៈពេលជាង៦០ឆ្នាំកន្លងមកហើយ។

រីឯរុស្ស៊ីវិញ គួរតែឈប់មន្ទិលសង្ស័យថាសហភាពអឺរ៉ុបមានបំណងអាក្រក់មកលើខ្លួន។ រុស្ស៊ីគួរតែឈប់ចោទអឺរ៉ុបថាចូលដៃជាមួយសហរដ្ឋអាមេរិក ដើម្បីជម្រុញបណ្តាប្រទេសនៅក្នុងអតីតដែនដីសហភាពសូវៀតឲ្យរើបម្រះចេញពីឥទ្ធិពលរបស់ខ្លួន។

**៦. ករណីសិក្សាអំពីអ្វីទៅជា** BRIEXIT?

សូមមើលវីដេអូដែលមានតំណភ្ជាប់ដូចខាងក្រោម(បញ្ហា_Brexit_និងវិបត្តិទំនុកចិត្តនៅក្នុងសហភាពអឺរ៉ុប)៖
https://www.youtube.com/watch?v=XIX85pAiHUA

**សំណួរត្រិះរិះ**

១. តើស្ថានភាពអឺរ៉ុបរួមពីឆ្នាំ១៩៥៧ ដល់១៩៦៩ មានលក្ខណៈដូចម្តេច?
២. តើសមាជិកទាំង៦នៃសហគមន៍សេដ្ឋកិច្ចអឺរ៉ុប CEE ប្រជុំគ្នាក្នុងទីក្រុង La Haye ប្រទេសហូឡង់ នៅឆ្នាំ ១៩៦៩ ប្តេជ្ញាសម្រេចឱ្យបានអ្វីខ្លះ សម្រាប់អនាគត?
៣. ហេតុអ្វី បានជានៅទីបំផុត បារាំងព្រមឲ្យអង់គ្លេសចូលជាសមាជិករបស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប CEE?
៤. តើប្រទេសអង់គ្លេសចូលជាសមាជិកនៃសហគមន៍សេដ្ឋកិច្ចអឺរ៉ុបនៅឆ្នាំណា?
៥. តើសហភាពអឺរ៉ុបមានចំណុចខ្លាំង និងចំណុចខ្សោយអ្វីខ្លះ?
៦. តើសហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិកមានទំនាក់ទំនងយ៉ាងដូចម្តេចដែរ?
៧. តើសហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិកមានទំនាក់ទំនងយ៉ាងដូចម្តេចដែរ?
៨. តើសហភាពអឺរ៉ុបនិងអាស៊ានមានទំនាក់ទំនងយ៉ាងដូចម្តេចដែរ?

**ឯកសារពិគ្រោះ**


1. Jean-François TAIN(11/01/2010).ប្រវត្តិនៃការកសាងសហភាពអឺរ៉ុប(ភាគទី១).RFI. Retrieve from: https://shorturl.at/C530i.
2. Jean-François TAIN(18/01/2010).ប្រវត្តិនៃការកសាងសហភាពអឺរ៉ុប(ភាគទី២).RFI. Retrieve from: https://shorturl.at/NkpQz
3. Jean-François TAIN(25/01/2010).ប្រវត្តិនៃការកសាងសហភាពអឺរ៉ុប(ភាគទី៣).RFI. Retrieve from: https://shorturl.at/PJINY

4. Jean-François TAIN(01/02/2010).ប្រវត្តិនៃការកសាងសហភាពអឺរ៉ុប(ភាគទី៤).RFI. Retrieve from: https://shorturl.at/vAUOB
5. Jean-François TAIN(08/02/2010).ប្រវត្តិនៃការកសាងសហភាពអឺរ៉ុប(ភាគទី៥).RFI. Retrieve from: https://shorturl.at/j6E7K
6. Jean-François TAIN(22/02/2010).អឺរ៉ុបកំពុងស្វែងរកចក្ខុនិមិត្តភូមិសាស្ត្រនយោបាយរួមគ្នាមួយ. RFI. Retrieve from: http://km.rfi.fr/europe/eu-members-search-common-geopolitical-vision
7. Jean-François TAIN(01/03/2010).ចំណុចខ្លាំង និងចំណុចខ្សោយរបស់សហភាពអឺរ៉ុប នៅលើពិភពលោក. RFI. Retrieve from: http://km.rfi.fr/europe/strength-weakness-eu-world
8. Jean-François TAIN(15/03/2010).ទំនាក់ទំនងរវាងសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក.RFI. Retrieve from: http://km.rfi.fr/europe/relationship-usa-eu
9. ឈាង បុប្ផា(13/11/2018).ហេតុអ្វីបានជាគេមិនសូវឮនិយាយពីការចូលរួមរបស់ទាហានខ្មែរក្នុងសង្គ្រាមលោកលើកទី១ ?. RFI. Retrieve from: http://km.rfi.fr/cambodia/20181111-Why-cambodian-participation-WWI-not-clearly-known
10. ឈាង បុប្ផា(06/11/2018).ហេតុអ្វីបានជាប្រធានាធិបតីបារាំងចង់ឲ្យមានកងទ័ពអឺរ៉ុបរួមមួយ?. RFI. ភ្នំពេញ។
11. Jean-François TAIN(10/05/2010).សហភាពអឺរ៉ុប និងអាស៊ាននៅតែស្វែងរកគ្នាមិនទាន់ឃើញ.RFI. ភ្នំពេញ
12. Jean-François TAIN(17/05/2010).សហភាពអឺរ៉ុប និងរុស្ស៊ីជាដៃគូចាំបាច់ តែមិនទាន់យល់ចិត្តគ្នា .RFI. ភ្នំពេញ
13. Wolfram Alpha (2024). European Union land area. Retrieve from: https://www.wolframalpha.com/input?i2d=true&i=EU+land+area
14. Wolfram Alpha (2023). European Union. Retrieve from: https://www.wolframalpha.com/input?i2d=true&i=EU+countries
15. Wolfram Alpha (2023). European Union Population. Retrieve from: https://www.wolframalpha.com/input?i2d=true&i=EU+population
16. Wolfram Alpha (2024). European Union Economy Properties. Retrieve from: https://www.wolframalpha.com/input?i2d=true&i=EU+economy
17. iKen Edu(2024). Europe Physical Features. Retrieve from: https://www.youtube.com/watch?v=375u8HKUbKY

18. iKen Edu( 2024 ). Europe Climate Vegetation and Wildlife. Retrieve from: https://www.youtube.com/watch?v=hYczqHGjhYw
19. Josiah Ruhl( 2024 ). Europe Geography Introduction. Retrieve from: https://www.youtube.com/watch?v=-OXtE4zE6XQ
20. National Geographic( 2024 ). Europe: Resources. Retrieve from: https://education.nationalgeographic.org/resource/europe-resources/

# ជំពូកទី៥ ៖ ភូមិវិទ្យាតំបន់អាស៊ាន

## មេរៀនទី១៖ ប្រវត្តិនៃការកកើតសមាគមអាស៊ាន

កាលពី៤៥ឆ្នាំមុន គឺនៅឆ្នាំ១៩៦៧ អាស៊ានត្រូវបានបង្កើតឡើង ដើម្បីជាខែលទប់ទល់នឹងមនោគមវិជ្ជាកុម្មុយនិស្ត។

បើងាកក្រោយ ពិនិត្យមើលប្រវត្តិ៤៥ឆ្នាំរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ាន គេនឹងយល់ច្បាស់ភ្លាមថា ការចាប់បដិសន្ធិឡើងនៃអង្គការតំបន់មួយនេះនៅឆ្នាំ១៩៦៧ ស្តែងឱ្យឃើញនូវភាពប្រេះឆាខ្លាំងមែនទែននៃភូមិភាគអាស៊ីអាគ្នេយ៍សម័យនោះ។

នៅក្នុងទសវត្សរ៍ទី៦០ មានអធិករណ៍ស្មុគស្មាញខ្លាំងណាស់ រវាងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ដែលជាកោះ។ ជាក់ស្តែង ប្រទេសម៉ាឡេស៊ីមានទំនាស់ជាមួយប្រទេសឥណ្ឌូណេស៊ី ជុំវិញកោះបូណេអូ( Bornéo) ហើយនៅឆ្នាំ១៩៦៣ដែនដីប៉ែកខាងជើងនៃកោះនេះ គឺដែនដីកាលីម៉ង់តង់( Kalimantan) បានប្រកាសផ្តាច់ខ្លួនទៅនៅក្រោមការគ្រប់គ្រងនៃប្រទេសម៉ាឡេស៊ី ជាហេតុបានធ្វើឲ្យប្រទេសឥណ្ឌូណេស៊ីខឹងច្រឡោតតោតតូងនិងជាហេតុបានធ្វើឱ្យសង្គ្រាមហៀបតែនឹងផ្ទុះឡើងម្តងៗ រវាងប្រទេសភាគីជម្លោះទាំងពីរទៀតផង។

ម៉្យាងវិញទៀត កាលសម័យនោះ ក៏មានដែរភាពតានតឹងរវាងម៉ាឡេស៊ីនិងសិង្ហបុរី ពីព្រោះសិង្ហបុរីក្រោមការដឹកនាំរបស់លី គាន់យូ (Lee Kuan Yew) បានសម្រេចដើរចេញពីសហព័ន្ធរួមម៉ាឡេស៊ី។ ក្រៅពីនេះ ម៉ាឡេស៊ីក៏មានទំនាស់ជាមួយហ្វីលីពីនដែរជុំវិញដែនដីសាបាហ៍( Sabah)ដែលឋិតនៅប៉ែកខាងជើងនៃកោះបូណេអូពីព្រោះសាបាហ៍បានប្រកាសដាក់ខ្លួនឱ្យនៅក្រោមការគ្រប់គ្រងរបស់ប្រទេសម៉ាឡេស៊ី។

ទន្ទឹមនេះ កាលសម័យនោះ អាស៊ីអាគ្នេយ៍ជាសមរភូមិនៃសង្គ្រាមត្រជាក់ មានន័យថា វាជាទីកន្លែងដ៏ក្តៅគគុកជាងគេបង្អស់មួយនៃជម្លោះមនោគមវិជ្ជា រវាងសហរដ្ឋអាមេរិក សហភាពសូវៀត និងចិន ជម្លោះមនោគមវិជ្ជាដែលស្តែងឡើងតាមរយៈសង្គ្រាមនៅវៀតណាម។ សង្គ្រាមវៀតណាម ដែលកាលណោះបានផ្តើមរីករាលដាលចូលទៅដល់ប្រទេសកម្ពុជានិងឡាវ ពោលគឺពាសពេញឥណ្ឌូចិនតែម្តង។ មិនតែប៉ុណ្ណោះ ទ័ពព្រៃកុម្មុយនិស្តក៏មានសកម្មភាពខ្លាំងក្លាណាស់ដែរនៅប្រទេសភូមា ថៃ ហ្វីលីពីននិងឥណ្ឌូណេស៊ី ឥណ្ឌូណេស៊ីជាទីដែលឧត្តមសេនីយ៍ស៊ូហារតូ(Suharto) បានវាយបង្ក្រាបក្នុងថ្លុកឈាមពួកសកម្មជនបក្សកុម្មុយនិស្ត ជាហេតុបានបណ្តាលឱ្យមានស្លាប់យ៉ាងតិច៥០០០០០នាក់។

នៅក្នុងស្ថានភាពមួយដ៏អាសន្នបែបនេះ បណ្តាប្រទេសអាស៊ីអាគ្នេយ៍ដែលឋិតនៅក្រោមឥទ្ធិពលអាមេរិកាំង រួមមានថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី និងហ្វីលីពីន ដែលមានជម្លោះទឹកដីរវាងគ្នាត្រូវប្រឈមមុខនឹងដំណោះស្រាយបញ្ហាពីរ៖ ទីមួយ គឺត្រូវធ្វើយ៉ាងណាកុំឱ្យសង្គ្រាមកើតឡើងរវាងពួកគេ រីឯទីពីរគឺត្រូវពឹងពាក់សហរដ្ឋអាមេរិកដើម្បីខ្ទប់កុំឥទ្ធិពលកុម្មុយនិស្តរីកធំធាត់នៅក្នុងប្រទេសពួកគេបាន។ អ៊ីចឹងហើយបានជា បណ្តាប្រទេសសម្ព័ន្ធមិត្តទាំង៥របស់អាមេរិកនៅអាស៊ីអាគ្នេយ៍ គឺថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ីនិងហ្វីលីពីនបានសម្រេចចិត្តបង្កើតអាស៊ានឡើងនៅឆ្នាំ១៩៦៧។

មែនទែនទៅ នៅឆ្នាំ១៩៦៧នោះ ការទប់ទល់នឹងមនោគមវិជ្ជាកុម្មុយនិស្ត មិនមែនជាគោលដៅផ្លូវការដែលចែងនៅក្នុងសេចក្តីថ្លែងការណ៍រួមរបស់ប្រទេសស្ថាបនិកអាស៊ានទាំង៥ទេ។ គោលដៅជាផ្លូវការដែលបាន

ចែង គឺបង្កើនសហប្រតិបត្តិការសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌រវាងបណ្តាប្រទេសសមាជិកនិង «បង្កើតតំបន់សន្តិភាពមួយដែលមានមូលដ្ឋាននៅលើសេរីភាពនិងអព្យាក្រិតភាព»។

ទោះជាយ៉ាងណាក៏ដោយ គេត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៧៦ ទើបឃើញបណ្តាប្រទេសសមាជិកអាស៊ានប្រញាប់រួសរាន់ផ្តល់សន្ទុះថ្មីដល់អង្គការតំបន់មួយនេះ។ ជាក់ស្តែង នាឱកាសជំនួបកំពូលអាស៊ាននៅបាលី(Bali)ឆ្នាំ១៩៧៦ ប្រទេសថៃ ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន និងឥណ្ឌូណេស៊ីបានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការមួយ ដើម្បីពង្រឹងសាមគ្គីភាពរវាងគ្នា នៅចំពោះមុខការគំរាមកំហែងនៃ បណ្តាប្រទេសកុម្មុយនិស្តនៅឥណ្ឌូចិន។ នៅឆ្នាំ១៩៧៦ដដែលនោះ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយរបស់អាស៊ានត្រូវបានបង្កើតឡើងនៅយ៉ាការតា(Jakarta)ប្រទេសឥណ្ឌូណេស៊ី។

មានមូលហេតុមួយសំខាន់ដែលបានជំរុញឱ្យប្រទេសស្ថាបនិកទាំងប្រាំ ផ្តល់សន្ទុះថ្មីដល់អង្គការអាស៊ាន នោះគឺនៅខែមេសាឆ្នាំ១៩៧៥ កងទ័ពកុម្មុយនិស្តវៀតណាមខាងជើងបានចូលកាន់កាប់ទីក្រុងសៃហ្គុង(Saigon) កងយោធាកុម្មុយនិស្តខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ និងចលនាកុម្មុយនិស្តប៉ាថេតឡាវ(Pathet-Lao)បានឈ្នះសង្គ្រាមនៅប្រទេសឡាវ។

បន្ទាប់មកទៀតនៅឆ្នាំ១៩៧៩ អាស៊ានបានប្រកាន់ជំហរនយោបាយច្បាស់ជាងមុន ក្រោយពីប្រទេសវៀតណាមគាំទ្រដោយសហភាពសូវៀត បានចូលឈ្លានពានប្រទេសកម្ពុជា ផ្តួលរំលំរបបខ្មែរក្រហមដែលរណបចិនកុម្មុយនិស្ត។ ជំហរនយោបាយរបស់អាស៊ានកាលណោះ គឺឋិតនៅខាងសហរដ្ឋអាមេរិក និងនៅខាងចិនដែលបានជួយគាំទ្រខ្មែរក្រហមក្នុងសង្គ្រាមប្រឆាំងនឹងរបបហេង សំរិននៅកម្ពុជាដែលទ្រទ្រង់ដោយវៀតណាម និងសហភាពសូវៀត។ គឺនៅក្នុងបរិបទនេះហើយ ដែលប្រទេសថៃបានបើកដៃឱ្យខ្មែរក្រហមប្រើប្រាស់ទឹកដីរបស់គេទុកធ្វើជាសមរភូមិក្រោយ។ ទន្ទឹមនេះ អាស៊ានបានធ្វើការគាបសង្កត់តាមផ្លូវទូតដើម្បីបង្ខំឱ្យវៀតណាមដកទ័ពចេញពីកម្ពុជា ។ គឺនៅក្នុងបរិបទនៃអ្វីដែលគេហៅថា សង្គ្រាមឥណ្ឌូចិនលើកទី៣នេះហើយ ដែលអាស៊ានបានទទួលប្រទេសព្រុយណេឱ្យចូលជាសមាជិកនៅឆ្នាំ១៩៨៤៕

អាស៊ាន ឬ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ បង្កើតឡើងនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧ ដោយប្រទេសចំនួន៥ រួមមាន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន សិង្ហបុរី និងប្រទេសថៃ នាទីក្រុងបាងកក ប្រទេសថៃ។ ប្រទេសស្ថាបនិកទាំងនោះ លើកលែងប្រទេសថៃ សុទ្ធសឹងតែជាដែនដីដែលទើបទទួលបានអធិបតេយ្យភាពថ្មីថ្មោងពីនឹមអាណានិគមក្នុងសម័យនោះ។ គួបផ្សំនឹងការចាប់ផ្តើមនៃសង្គ្រាមត្រជាក់ផង ទើបជំរុញឲ្យប្រទេសទាំងប្រាំប្រកៀកស្មាគ្នាបង្កើតសមាគមនេះឡើង ដោយមានគោលដៅរួម ជំរុញឲ្យមានសន្តិភាព ស្ថិរភាព កំណើនសេដ្ឋកិច្ច រួមទាំងការអភិវឌ្ឍសង្គម និងវប្បធម៌ ក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល។

ចាប់ពីឆ្នាំ១៩៨៤ មក ទើបបណ្តាប្រទេសដទៃប្រាំទៀតចូលជាសមាជិក ជាបន្តបន្ទាប់ រួមមានប្រទេសប្រ៊ុយណេ ចូលជាសមាជិកនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៨៤, ប្រទេសវៀតណាមនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៥, ប្រទេសឡាវ និងប្រទេសភូមា ចូលជាសមាជិកនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧ និងប្រទេសកម្ពុជាចូលជាសមាជិកនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។

## ១. អាស៊ាន ដូចម្ដេចដែលហៅថាអាស៊ាន? WHAT IS ASEAN?

អាស៊ានមានពាក្យពេញហៅថាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ASEAN (Association of South East Asian Nation)។ អាស៊ានជាអង្គការអន្តរជាតិរដ្ឋាភិបាលដែលមានលក្ខណៈជាបុគ្គលភាពគតិយុត្តិ។

ប្រវត្តិអាស៊ាន ក្រោយពីសង្គ្រាមលោកលើកទី២បានរលំរលាយ ពិភពលោកទាំងមូលបានជួបនូវ ការលំបាកលំបិនម្ដងទៀតដោយសង្គ្រាមត្រជាក់ ដែលបង្កឡើងដោយឥទ្ធិពល មនោគមវិជ្ជាបស់ប្លុកប្រទេសកុំម្មុយនិស្ត និងប្លុកប្រទេសសេរី។ គ្រប់ប្រទេសមហាអំណាចធំៗដែលប្រកាន់យកមនោគមវិជ្ជាបានប្រជែងដណ្ដើមគ្នាសាបព្រោះគោលនយោបាយមនោគមវិជ្ជារបស់ខ្លួនលើប្រទេសទាំងឡាយណាដែលក្រីក្រទន់ខ្សោយ។ ជាងនេះទៅទៀតឈរលើគោលបំណងពង្រឹងអំណាច និងបង្ការការរីកដុះដាលរបស់ភាគីបដិបក្ខ ប្រទេសទាំងឡាយស្ថិតនៅលើពិភពលោកបានរួមគ្នាជាសម្ព័ន្ធមិត្តបង្កើតជាអង្គការ ឬសមាគមអន្តរជាតិនានាក្នុងតំបន់ដើម្បីការពារប្រទេសខ្លួន មិនឱ្យធ្លាក់ចូលមនោគមវិជ្ជាណាមួយ ដែលអាចហៅបានថា (ប្លុកមិនចូលបក្សសម្ព័ន្ធ)។ ដោយសារកត្តាទាំងនេះអំឡុងក្រោមកដោយមានគំនិតផ្ដួចផ្ដើមរបស់លោកនាយករដ្ឋមន្ត្រីម៉ាឡេស៊ីទុន គូ អាប់ឌុល រ៉ាម៉ាន់ (Tun Ku Abdul Rahman) នៅខែមករាឆ្នាំ១៩៥៩ ក្នុងនោះលោកបានសម្លឹងឃើញថា ពិភពលោក អនាគតនឹងឆ្ពោះទៅរកសាកលភាវូបនីយកម្មលើគ្រប់វិស័យមានដូចជានយោបាយបច្ចេកទេស សិល្បៈវប្បធម៌ ពាណិជ្ជកម្ម និងសេដ្ឋកិច្ចជាដើម។ បន្ថែមពីលើនេះលោកក៏បានធ្វើទស្សនៈកិច្ចទៅប្រទេសនានានៅ អាស៊ីអាគ្នេយ៍ ដូចជាហ្វីលីពីន ក្នុងគោលបំណងបង្កើត សមាគមអាស៊ាននេះ។

## ២. អត្ថន័យនៃនិមិត្តសញ្ញាអាស៊ាន(ASEAN EMBLEM)





បាវចនាអាស៊ាន(ASEAN Matto) គឺចក្ខុវិស័យមួយ អត្តសញ្ញាណមួយ សហគមន៍មួយ។ ទិវាអាស៊ាន (ASEAN day ) ត្រូវបានកំណត់ប្រារព្ធឡើងនៅថ្ងៃទី០៨ ខែសីហា។ ភ្លេងអាស៊ាន (ASEAN Anthem) អាស៊ានមានភ្លេងរបស់ខ្លួន។ ភាសាផ្លូវការរបស់អាស៊ាន (Working Language of ASEAN) គឺមានភាសាអង់គ្លេសតែមួយគត់។ ទង់ជាតិ: ទង់អាស៊ានតំណាងឲ្យអាស៊ានមួយមានស្ថិរភាព សន្តិភាពរួបរួម និងថាមពល។

អត្ថន័យពណ៌ទង់អាស៊ាន: អាស៊ានមានទង់ពណ៌ខៀវ ក្រហម ស និងលឿង ដែលតំណាងឲ្យពណ៌សំខាន់ៗនៃគ្រប់ទង់ជាតិរបស់សមាជិកគ្រប់ប្រទេសរបស់អាស៊ាន។

- ពណ៌ខៀវ តំណាងឲ្យសន្តិភាព និងស្ថិរភាព ពណ៌ក្រហមបង្កប់នៃ ភាពក្លាហាននិងថាមពល ពណ៌សបង្ហាញនូវភាពស្អាតស្អំ និងពណ៌លឿងជា និមិត្តរូបនៃវិបុលភាព។

- រូបគួរស្រូវ តំណាងឲ្យសុបិន្តរបស់បិតាស្ថាបនិកអាស៊ាន ដែលចង់បានអាស៊ានមួយ មានគ្រប់ប្រទេសទាំងអស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រួបរួមគ្នាក្នុងមិត្តភាព និងសាមគ្គីភាព។
- សញ្ញារង្វង់: តំណាងឲ្យការឯកភាពរបស់អាស៊ាន។
- អត្តសញ្ញាណអាស៊ាន(ASEAN Identity) អាស៊ានត្រូវលើកកម្ពស់អត្តសញ្ញាណរួមរបស់ខ្លួន និងក្នុងន័យជា ប្រជាជនដើម្បីធ្វើឲ្យសំរេចនូវតំលៃ គោលដៅ និងជោគវាសនារួមគ្នា របស់អាស៊ាន៕

**សំណួរត្រិះរិះ**

១. តើអាស៊ានបង្កើតឡើងមានគោលបំណងយ៉ាងដូចម្តេចខ្លះ?
២. តើសមាគមអាស៊ានមានគោលការណ៍យ៉ាងណាខ្លះ?
៣. តើរដ្ឋនៃសមាជិកអាស៊ានមានឈ្មោះអ្វីខ្លះ?
៤. តើរដ្ឋជាសមាជិកសមាគមអាស៊ានមានសិទ្ធិ និងកាតព្វកិច្ចអ្វីខ្លះ?
៥. តើល័ក្ខខ័ណ្ឌដើម្បីចូលជាសមាជិកអាស៊ាបានត្រូវមានអ្វីខ្លះ?
៦. តើអ្វីជាកិច្ចប្រជុំកំពូលអាស៊ាន?
៧. តើគេរៀបចំកិច្ចប្រជុំកំពូលអាស៊ានដើម្បីអ្វី?
៨. តើអ្វីជាក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន?
៩. តើក្រុមប្រឹក្សាសម្របសម្រួលអាស៊ានមានភារកិច្ចធ្វើអ្វីខ្លះ?

# មេរៀនទី២៖ ធម្មនុញ្ញអាស៊ាន

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ជាអង្គការតំបន់មួយដែលមានដប់ប្រទេស។ សមាគមនេះបង្កើតឡើង ដើម្បីបង្កើនល្បឿននៃការលូតលាស់នៃសេដ្ឋកិច្ច ការវិវត្តនៃសង្គមជាតិ ការអភិវឌ្ឍវប្បធម៌ ជំរុញសន្តិភាព និងស្ថេរភាពក្នុងតំបន់។ ដូច្នេះដើម្បីដំណើរការងារសមាគមអាស៊ានត្រូវមានក្រមសម្រាប់ប្រតិបត្តិ នោះគឺធម្ម នុញ្ញអាស៊ាន។ ធម្មនុញ្ញអាស៊ានមាន១៣ជំពូក។ ជំពូកទី១ចែងពីគោលបំណងនិងគោលការណ៍ ជំពូកទី២ចែងពីបុគ្គលភាពគតិយុត្តនៃសមាគមអាស៊ាន ជំពូកទី៣ចែងពីសមាជិកភាព ជំពូកទី៤ចែងពីអង្គការចាត់តាំងជំពូកទី៥ចែងពីអង្គភាពពាក់ព័ន្ធអាស៊ាន ជំពូកទី៦ចែងពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ជំពូកទី៧ចែងការធ្វើសេចក្តីសម្រេច ជំពូកទី៨ចែងពីការដោះស្រាយជម្លោះ ជំពូកទី៩ចែងពីថវិកានិងហិរញ្ញវត្ថុ ជំពូកទី១០ចែងពីរដ្ឋបាលនិងនីតិវិធី ជំពូកទី១១ចែងពីអត្តសញ្ញាណ និងនិមិត្តសញ្ញា ជំពូកទី១២ចែងពីទំនាក់ទំនងក្រៅតំបន់ ជំពូកទី១៣ចែងពីបទបញ្ញត្តិទូទៅនិងអវសានបញ្ញត្តិ។ ខាងក្រោមនេះ យើងនឹងលើកឡើងពីជំពូកមួយចំនួនមកបង្ហាញ៖

## ១. គោលបំណង និងគោលការណ៍

**មាត្រា ១ ពីគោលបំណងរបស់អាស៊ានគឺ** :

1. ដើម្បីថែរក្សា និងលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថេរភាព និងពង្រឹងបន្ថែមទៀតនូវគុណតម្លៃផ្នែកសន្តិភាពក្នុងភូមិភាគថែមទៀតឆ្ពោះទៅរកសន្តិភាពក្នុងតំបន់។
2. លើកកម្ពស់ភាពរឹងមាំងនៃតំបន់ តាមរយៈការជំរុញឱ្យកាន់តែខ្លាំងថែមទៀតនូវកិច្ចសហប្រតិបត្តិការ ផ្នែកនយោបាយ-សន្តិសុខ សេដ្ឋកិច្ច និងសង្គម-វប្បធម៌។
3. រក្សាតំបន់អាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ( នូឃ្លារ ) និងគ្មានអាវុធប្រល័យលោកផ្សេងទៀត។
4. ធានាថាប្រជាជន និងរដ្ឋសមាជិករបស់អាស៊ានរស់នៅប្រកបដោយសន្តិភាពជាមួយពិភពលោកទាំងមូល ក្នុងបរិយាកាសយុត្តិធម៌ ប្រជាធិបតេយ្យ និងភាពសុខដុមរមនា។
5. ដើម្បីបង្កើតទីផ្សារ និង មូលដ្ឋានផលិតកម្មរួម ដែលមានស្ថេរភាព វិបុលភាព មានការប្រជែងខ្ពស់ និង សមាហរកម្មសេដ្ឋកិច្ចជាមួយនឹងការសម្របសម្រួលសេដ្ឋកិច្ច បង្កលក្ខណៈងាយស្រួលផ្នែកពាណិជ្ជកម្ម និង វិនិយោគទុនយ៉ាងមានប្រសិទ្ធិភាព ដែលមាន លំហូរទំនិញ សេវាកម្ម និង វិនិយោគទុនដោយសេរី ដែលមានការបង្កលក្ខណៈងាយស្រួលក្នុង ការផ្លាស់ផ្ទេរពាណិជ្ជករ អ្នកប្រកបវិជ្ជាជីវៈ សមត្ថជន និង ពលកម្ម និង មានលំហូរមូលធនដោយ សេរី ។
6. ដើម្បីកាត់បន្ថយទុគ្គតភាព( ភាពក្រីក្រ ) និង ពង្រួញពង្រៀវគម្លាតវឌ្ឍនកម្មខាងក្នុងអាស៊ាន តាមរយៈជំនួយ និង សហប្រតិបត្តិការទៅវិញទៅមក ។
7. ដើម្បីពង្រីកពង្រឹងលទ្ធិប្រជាធិបតេយ្យ បង្កបង្កើនធម្មាភិបាល និង នីតិវិធាន និង ដើម្បីលើកស្ទួយព្រមទាំងការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ដោយគិតគូរដល់សិទ្ធិ និង តួនាទីទទួលខុសត្រូវនៃរដ្ឋសមាជិករបស់អាស៊ាន ។

8. ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពតាមគោលការណ៍សន្តិសុខគ្រប់មជ្ឈដ្ឋានទៅនឹងអំពើគំរាមកំហែង ឧក្រិដ្ឋកម្មអន្តរជាតិ និង អភិយោគអន្តរសីមាគ្រប់រូបបែប ។
9. ដើម្បីលើកស្ទួយនិរន្តរភាពអភិវឌ្ឍនភាពសំដៅធានាឲ្យបាននូវការការពារបរិដ្ឋានរបស់ភូមិភាគ និរន្តរភាពនៃធនធានធម្មជាតិរបស់ភូមិភាគ សម្បូររក្សាបេតិកភណ្ឌវប្បធម៌របស់ភូមិភាគ និង គុណភាពជីវិតខ្ពស់នៃប្រជាជនរបស់ភូមិភាគ ។
10. ដើម្បីអភិវឌ្ឍធនធានមនុស្សតាមរយៈសហប្រតិបត្តិការដ៏ជិតស្និទ្ធថែមទៀតក្នុងវិស័យអប់រំ និង ការសិក្សារហូតអាយុកាលទាំងក្នុងវិស័យវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ដើម្បីបង្កើនសក្តានុពលប្រជាពលរដ្ឋអាស៊ាន និង ដើម្បីពង្រីកពង្រឹងសហគមអាស៊ាន ។
11. ដើម្បីបង្កបង្កើនសុជីវធម៌និងជីវភាពរបស់ប្រជាជនអាស៊ានដោយការផ្តល់ឲ្យប្រជាជនមាឱកាសស្មើៗគ្នាក្នុងការអភិវឌ្ឍមនុស្ស សុខុមាលភាពសង្គម និងយុត្តិធម៌ ។
12. ដើម្បីពង្រីកពង្រឹងសហប្រតិបត្តិការក្នុងការកសាងបរិដ្ឋានដែលមានសុវត្ថិភាព ស្ថេរភាព និង ប្រាសចាកគ្រឿងញៀនដល់ប្រជាជនអាស៊ាន ។
13. ដើម្បីលើកស្ទួយអាស៊ានដែលមានប្រជាជនជាទិសដៅដែលសង្គមគ្រប់ជាន់ថ្នាក់ទាំងអស់ត្រូវលើកទឹកចិត្តឲ្យចូលរួមចំណែក និង ទទួលផលប្រយោជន៍ពីដំណើរការសមាហរណកម្ម និង នវកម្មសហគមអាស៊ាន ។
14. ដើម្បីលើកស្ទួយអត្តសញ្ញាណអាស៊ានតាមរយៈការផ្សំបណ្តុះស្មារតីភ្ញាក់រលឹកវប្បធម៌ និង បេតិកភណ្ឌចម្រុះឆ្លុះឆ្លាស់របស់ភូមិភាគខ្លាំងថែមទៀត និង
15. ដើម្បីថែរក្សាចំណុចរួម និងតួនាទីសម្រុកសម្រួលរបស់អាស៊ានឲ្យជាកម្លាំងចលករចម្បងក្នុងទំនាក់ទំនង និង សហប្រតិបត្តិការជាមួយនឹងភាគីក្រៅភូមិភាគក្នុងនិម្មាបនកម្មភូមិភាគដែលបើកចំហ មានតម្លាភាព និងមិនបិទបាំង ។

## ២. សមាជិកភាព

### មាត្រា ៦ ៖ អំពីការទទួលយកសមាជិកថ្មី៖

១. នីតិវិធីនៃការដាក់ពាក្យសុំ និងទទួលចូលជាសមាជិកអាស៊ាន ត្រូវបញ្ញត្តិដោយក្រុមប្រឹក្សា សម្របសម្រួលអាស៊ាន ។
២. ការទទួលយកសមាជិកថ្មី ត្រូវផ្អែកទៅលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖
ក.ទីតាំងភូមិសាស្ត្រដែលត្រូវបានទទួលស្គាល់ថាស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍
ខ. មានការទទួលស្គាល់ពីបណ្តារដ្ឋសមាជិកអាស៊ានទាំងអស់
គ. ឯកភាពគោរពនិងប្រតិបត្តិតាមធម្មនុញ្ញអាស៊ាននិង
ឃ. មានលទ្ធភាពនិងឆន្ទៈអនុវត្តន៍នូវកាតព្វកិច្ចទាំងអស់នៃសមាជិកភាព
៣. ការទទួលយកជាសមាជិកថ្មី ត្រូវសម្រេចដោយកុងសង់ស៊ីស នៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន បន្ទាប់ពី បាន ទទួលអនុសាសន៍ពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន។

៤. រដ្ឋស្នើសុំត្រូវទទួលបានសមាជិកភាពបន្ទាប់ពីការចុះហត្ថលេខាលើលិខិតុបករណ៍នៃការយល់ព្រមចំពោះធម្មនុញ្ញអាស៊ាន។

**៣. កិច្ចប្រជុំកំពូលអាស៊ាន**

**៣.១. កិច្ចប្រជុំកំពូលអាស៊ាន ត្រូវចូលរួមដោយប្រមុខរដ្ឋ / រដ្ឋាភិបាលនៃសមាជិកអាស៊ាន។**

**៣.២. កិច្ចប្រជុំកំពូលអាស៊ាន៖**

ក. ជាអង្គភាពរៀបចំគោលនយោបាយកំពូលអាស៊ាន

ខ. ពិគ្រោះយោបល់ផ្តល់មាគ៌ានយោបាយ និងធ្វើការសម្រេចចិត្តលើបញ្ហាជាគន្លឹះដែលទាក់ទង ទៅនឹងសមិទ្ធផលនៃគោលដៅរបស់អាស៊ាន បញ្ហាសំខាន់ៗដែលជាផលប្រយោជន៍របស់រដ្ឋសមាជិក និងរាល់ បញ្ហាដែលពាក់ព័ន្ធតាមរយៈក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ក្រុមប្រឹក្សាសហគមន៍អាស៊ាន និងអង្គភាព ថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកអាស៊ាន

គ. ណែនាំរដ្ឋមន្ត្រីពាក់ព័ន្ធក្នុងក្រុមប្រឹក្សានីមួយៗឲ្យរៀបចំកិច្ចប្រជុំអាត់ហុកថ្នាក់អន្តររដ្ឋមន្ត្រី និង ដោះស្រាយ បញ្ហាសំខាន់ៗ ដែលកើតមានឡើងក្នុងក្រុមប្រឹក្សាសហគមន៍។ វិធាននៃនីតិវិធីដំណើរការកិច្ច ប្រជុំនេះ ត្រូវអនុម័តដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន

ឃ. ដោះស្រាយស្ថានភាពបន្ទាន់ដែលប៉ះពាល់អាស៊ាន តាមរយៈប្រើប្រាស់សកម្មភាពសមស្រប

ង. សម្រេចបញ្ហាផ្សេងៗដោយអនុវត្តន៍តាមជំពូក ៧ និង ៨ នៃធម្មនុញ្ញនេះ

ច. អាចបង្កើត និងរំលាយចោលនូវអង្គភាពរដ្ឋមន្ត្រីជំនាញតាមផ្នែកនិងស្ថាប័នអាស៊ានដទៃទៀត និង

ឆ. តែងតាំងអគ្គលេខាធិការអាស៊ាន ដែលមានតំណែងនិងឋានៈស្មើរដ្ឋមន្ត្រីដែលត្រូវបម្រើការងារ ដោយទំនុកចិត្ត និងទទួលបានការពេញចិត្តពីប្រមុខរដ្ឋ / រដ្ឋាភិបាល តាមការស្នើឡើង ដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន។

**៣.៣. កិច្ចប្រជុំកំពូលអាស៊ានត្រូវ៖**

ក. រៀបចំឡើង ២ដង ក្នុងមួយឆ្នាំ ក្នុងរដ្ឋសមាជិកដែលទទួលបន្ទុកជាប្រធានអាស៊ាននិង

ខ. ក្នុងករណីចាំបាច់ ត្រូវរៀបចំកិច្ចប្រជុំពិសេស ឬកិច្ចប្រជុំអាត់ហុក ក្រោមអធិបតីភាពនៃរដ្ឋ សមាជិកដែលទទួលបន្ទុកជាប្រធានអាស៊ាន នៅទីកន្លែងនៃកិច្ចប្រជុំដែលកំណត់តាមការឯកភាពពីរដ្ឋសមាជិកអាស៊ានទាំងអស់។

**អំពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន:**

១. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន រួមមានសមាសភាពរដ្ឋមន្ត្រីការបរទេសអាស៊ាន និងត្រូវជួបប្រជុំយ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ។

២. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ានត្រូវ៖

ក. រៀបចំកិច្ចប្រជុំកំពូលអាស៊ាន

ខ. សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង និងសេចក្តីសម្រេចរបស់កិច្ចប្រជុំកំពូល អាស៊ាន

គ. សម្របសម្រួលជាមួយក្រុមប្រឹក្សាសហគមន៍អាស៊ាន ដើម្បីលើកកម្ពស់ភាពរលូននៃគោលនយោបាយ ប្រសិទ្ធភាព និងសហប្រតិបត្តិការក្នុងចំណោមគ្នានិងគ្នា

ឃ.សម្របសម្រួលរបាយការណ៍នានារបស់ក្រុមប្រឹក្សាសហគមន៍អាស៊ាន ជូនកិច្ចប្រជុំ កំពូលអាស៊ាន

ង. ពិនិត្យពិចារណាលើរបាយការណ៍ប្រចាំឆ្នាំរបស់អគ្គលេខាធិការ ស្តីពីការងារអាស៊ាន

ច. ពិនិត្យពិចារណាលើរបាយការណ៍របស់អគ្គលេខាធិការ ស្តីពីមុខងារ និងប្រតិបត្តិការនៃអគ្គលេខាធិការដ្ឋានអាស៊ាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត

ឆ. ឯកភាពចំពោះការតែងតាំងនិងការបញ្ចប់អាណត្តិអគ្គលេខាធិការរងបន្ទាប់ពីបានទទួល អនុសាសន៍របស់អគ្គលេខាធិការនិង

ជ. អនុវត្តន៍ការងារផ្សេងៗទៀត ដែលកំណត់ឡើងក្នុងធម្មនុញ្ញនេះ ឬមុខនាទីផ្សេងទៀត ដែលអាចកំណត់ឡើងដោយកិច្ចប្រជុំកំពូលអាស៊ាន

៣. ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន គាំទ្រដោយឧត្តមមន្ត្រីពាក់ព័ន្ធ។

**អំពីក្រុមប្រឹក្សាសហគមន៍អាស៊ាន**

១. ក្រុមប្រឹក្សាសហគមន៍អាស៊ាន រួមមានក្រុមប្រឹក្សាសហគមន៍សន្តិសុខនយោបាយអាស៊ាន ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និងក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន។

២. ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ មានអង្គភាពរដ្ឋមន្ត្រីជំនាញតាមផ្នែក នៅក្រោមសមត្ថកិច្ចរបស់ខ្លួន។

៣. រដ្ឋសមាជិកនីមួយៗ ត្រូវតែងតាំងតំណាងជាតិរបស់ខ្លួនសម្រាប់ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នីមួយៗ។

៤. ដើម្បីសម្រេចគោលដៅនីមួយៗនៃសសរគ្រឹះទាំងបីរបស់សហគមន៍ ក្រុមប្រឹក្សាសហកមន៍អាស៊ាននីមួយៗត្រូវៈ

ក. ជានាអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់កិច្ចប្រជុំកំពូលអាស៊ាន

ខ. សម្របសម្រួលការងារផ្នែកផ្សេងៗក្រោមសមត្ថកិច្ចរបស់ខ្លួន និងលើបញ្ហាដែលកើតមានឡើងក្នុងក្រុមប្រឹក្សាសហគមន៍ដទៃទៀតនិង

គ. ដាក់របាយការណ៍និងអនុសាសន៍ផ្សេងៗជូនកិច្ចប្រជុំកំពូលអាស៊ានលើបញ្ហាដែលស្ថិតនៅក្រោមវង្វង់ សមត្ថកិច្ចរបស់ខ្លួន។

៥. ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ ត្រូវប្រជុំយ៉ាងតិច ២ ដងក្នុងមួយឆ្នាំ។ កិច្ចប្រជុំនេះត្រូវដឹកនាំដោយ រដ្ឋមន្ត្រីពីរដ្ឋសមាជិកដែលទទួលបន្ទុកជាប្រធានអាស៊ាន។

៦. ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ ត្រូវបានគាំទ្រដោយឧត្តមមន្ត្រីពាក់ព័ន្ធទៅនឹងសហគមន៍នីមួយៗ។

## ៤. អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែករបស់អាស៊ានៈ

### ៤.១. អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែករបស់អាស៊ានត្រូវៈ

ក. ដំណើរការមុខងារស្របតាមអាណត្តិរបស់ខ្លួន

ខ. អនុវត្តន៍កិច្ចព្រមព្រៀង និងសេចក្ដីសម្រេចនៃកិច្ចប្រជុំកំពូលអាស៊ានដែលស្ថិតនៅ ក្រោមសមត្ថកិច្ចរបស់ខ្លួន

គ.ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងផ្នែករបស់ខ្លួននីមួយៗ ដើម្បីទ្រទ្រង់សមាហរណកម្មអាស៊ាន និងការ កសាងសហគមន៍និង

ឃ. ដាក់របាយការណ៍និងអនុសាសន៍ជូនក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ។

## ៤.២. អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកនីមួយៗរបស់អាស៊ាន

អង្គកភាពនេះអាចមានឧត្តមមន្ត្រីពាក់ព័ន្ធនៅក្រោមសមត្ថកិច្ចរបស់ខ្លួននិងអង្គភាពក្រោមឱវាទ ដើម្បីបំពេញមុខងារដូចមានក្នុងឧបសម្ព័ន្ធទី១។ ឧប សម្ព័ន្ធនេះ អាច ធ្វើបច្ចុប្បន្នភាព ដោយអគ្គលេខាធិការអាស៊ាន បន្ទាប់ពីមានអនុសាសន៍ពីគណៈកម្មា ធិការតំណាង អចិ ន្ត្រៃយ៍ដោយមិនចាំបាច់មានការធ្វើវិសោធនកម្មនៃធម្មនុញ្ញនេះឡើយ។

## អំពីអគ្គលេខាធិការអាស៊ាន និងលេខាធិការដ្ឋានអាស៊ាន:

១. អគ្គលេខាធិការអាស៊ាន ត្រូវបានតែងតាំងដោយកិច្ចប្រជុំកំពូលអាស៊ាន សម្រាប់អាណត្តិប្រាំឆ្នាំ ដែលអាណត្តិនេះមិនអាចបន្តទៀតបានទេ ហើយត្រូវជ្រើសរើសចេញពីក្នុងចំណោមជនជាតិនៃរដ្ឋសមាជិកអាស៊ាន ផ្អែកទៅលើការប្ដូរវេនគ្នាតាមលំដាប់អក្ខរក្រមនៃឈ្មោះរដ្ឋសមាជិក ដោយពិចារណាល្អិតល្អន់ទៅសុច្ចរិតធម៌ សមត្ថភាព បទពិសោធន៍វិជ្ជាជីវៈ និងសមភាពយេនឌ័រ។

២. អគ្គលេខាធិការអាស៊ានត្រូវៈ

ក.អនុវត្តភារកិច្ច និងការទទួលខុសត្រូវនៃការិយាល័យជាន់ខ្ពស់នេះ ដោយយោងទៅតាមបទប្បញ្ញត្តិនៃធម្មនុញ្ញនេះ និងលិខិតតុបករណ៍ ពិធីសារ និងកិច្ចពាក់ព័ន្ធទាំងឡាយរបស់អាស៊ាន

ខ. សម្រួល និងពិនិត្យមើលការរីកចម្រើននៃការអនុវត្តកិច្ចព្រមព្រៀង និងសេចក្ដីសំរេចរបស់អាស៊ាន និងដាក់របាយការណ៍ប្រចាំឆ្នាំស្ដីពីការងារអាស៊ាន ជូនកិច្ចប្រជុំកំពូល

គ. ចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំរបស់ក្រុមប្រឹក្សាសហគមន៍អាស៊ាន កិច្ចប្រជុំក្រុមប្រឹក្សាសម្រប សម្រួលអាស៊ាន កិច្ចប្រជុំរបស់អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែករបស់អាស៊ាន និងកិច្ចពាក់ព័ន្ធដទៃទៀតរបស់អាស៊ាន

ឃ. បង្ហាញអំពីទស្សនៈរបស់អាស៊ាន និងចូលរួមក្នុងកិច្ចប្រជុំជាមួយភាគីក្រៅតំបន់ ដោយអនុលោមទៅតាមគោលមាគ៌ានយោបាយ ដែលបានឯកភាព និងអាណត្តិដែលបានប្រគល់ជូនអគ្គលេខាធិការនិង

ង. ស្នើសុំអនុម័តពីក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន តែងតាំង និងបញ្ចប់អាណត្តិរបស់អគ្គលេខាធិការរង

៣. អគ្គលេខាធិការ ក៏ត្រូវទទួលនាទីជាប្រធានរដ្ឋបាលអាស៊ាន ។

៤. អគ្គលេខាធិការ មានអគ្គលេខាធិការរង៤រូប ដែលមានតំណែង និងឋានៈស្មើនឹងអនុរដ្ឋមន្ត្រីជាជំនួយការ ។ អគ្គលេខាធិការរង ត្រូវទទួលខុសត្រូវចំពោះ មុខអគ្គលេខាធិការ ក្នុងការអនុវត្តមុខងាររបស់ខ្លួន ។

៥. អគ្គលេខាធិការរងទាំង៤ ត្រូវមានសញ្ជាតិខុសពីអគ្គលេខាធិការ និងមកពីរដ្ឋសមាជិក៤ផ្សេងៗគ្នា ។

៦ អគ្គលេខាធិការរងទាំង៤ មានសមាសភាពៈ

ក. អគ្គលេខាធិការរង២រូប ដែលមានអាណត្តិកំណត់៣ឆ្នាំ ដែលអាណត្តិនេះមិនអាចបន្តបាន និង ដែលបាន ជ្រើសរើសចេញពីជនជាតិ នៃរដ្ឋសមាជិកអាស៊ាន ដោយផ្អែកទៅលើការប្តូរវេនគ្នា តាមលំដាប់អក្ខរក្រម និងដោយពិចារណាល្អិតល្អន់ទៅលើសុច្ចរិតធ៌ម លក្ខណៈសម្បត្តិ សមាសភាព បទពិសោធន៍ និងសមភាពយេនឌ័រ ។

ខ. អគ្គលេខាធិការរង២រូប មានអាណត្តិ៣ឆ្នាំដូចគ្នា ប៉ុន្តែអាណត្តិនេះ អាចបន្តបាន១អាណត្តិទៀត ។ អគ្គលេខាធិការរងទាំង២រូបនេះ ត្រូវជ្រើសរើសជាចំហ ដោយផ្អែកទៅលើលក្ខណៈសម្បត្តិដែលសមនឹងទទួលបានតួនាទីនេះ ។

៧. លេខាធិការដ្ឋានអាស៊ាន មានអគ្គលេខាធិការ និងបុគ្គលិកតាមចំនួនដែលអាចត្រូវការ ។

៨. អគ្គលេខាធិការ និងបុគ្គលិកត្រូវៈ

ក. ប្រកាន់ឲ្យបានខ្ពង់ខ្ពស់ បំផុត នូវសុច្ចរិតភាព ប្រសិទ្ធភាព និងសមត្ថភាព ក្នុងការបំពេញការងាររបស់ខ្លួន។

ខ. មិនស្វែងរក ឬទទួលបញ្ជាពីរដ្ឋាភិបាលណាមួយ ឬភាគីខាងក្រៅអាស៊ាន និង

គ. ទប់ស្កាត់សកម្មភាពណាមួយដែលអាចឆ្លុះបញ្ចាំង លើគោលជំហររបស់ខ្លួនជាមន្ត្រីលេខាធិការដ្ឋានអាស៊ាន ដែលមានការទទួលខុសត្រូវចំពោះតែអាស៊ានប៉ុណ្ណោះ ។

៩. រដ្ឋសមាជិកអាស៊ាននីមួយៗ ត្រូវគោរពលក្ខណៈទទួលខុសត្រូវទាំងស្រុងរបស់អគ្គលេខាធិការ និងបុគ្គលិក និងមិនត្រូវប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនទៅលើពួកគេ ដែលធ្វើឲ្យបាត់ការទទួលខុសត្រូវ ។

**អំពីគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំតំបន់អាស៊ាន**

១. រដ្ឋសមាជិកអាស៊ាននីមួយៗ ត្រូវតែងតាំងតំណាងអចិន្ត្រៃយ៍របស់ខ្លួនមួយរូបប្រចាំអាស៊ាន ដែលមានឋានៈជាឯកអគ្គរដ្ឋទូត រាជទូត មានទីតាំងនៅទីក្រុងហ្សាការតា ។

២. តំណាងអចិន្ត្រៃយ៍ទាំងនេះ រួមគ្នាបង្កើត ជាគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍មួយដែលត្រូវៈ

ក. ទ្រទ្រង់ការងារក្រុមប្រឹក្សាសហគមន៍អាស៊ាន និងអង្គការថ្នាក់រដ្ឋមន្ត្រីជំនាញអាស៊ានតាមផ្នែក

ខ. សម្របសម្រួលជាមួយលេខាធិការដ្ឋានជាតិអាស៊ាន និងអង្គការថ្នាក់រដ្ឋមន្ត្រីជំនាញ តាមផ្នែកដទៃទៀតរបស់អាស៊ាន

គ.ធ្វើការងារយ៉ាងជិតស្និតជាមួយអគ្គលេខាធិការអាស៊ាន និងលេខាធិការដ្ឋានអាស៊ាន លើគ្រប់វិស័យពាក់ព័ន្ធទាំងឡាយដល់ការងាររបស់ខ្លួន

ឃ.សម្របសម្រួលសហប្រតិបត្តិការអាស៊ាន ជាមួយដៃគូក្រៅតំបន់

ង. បំពេញការងារដទៃទៀត ដែលអាចកំណត់ឡើងដោយក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ។

**អំពីលេខាធិការដ្ឋានជាតិអាស៊ាន**

រដ្ឋសមាជិកអាស៊ាននីមួយៗ ត្រូវបង្កើតលេខាធិការដ្ឋានជាតិអាស៊ានមួយរបស់ខ្លួន ដែលត្រូវៈ

ក. ដើរតួនាទីជាចំណុចទំនាក់ទំនងគ្នាថ្នាក់ជាតិ

ខ. ជាកន្លែងតម្កល់ព័ត៌មានទាំងអស់នៃកិច្ចការរបស់អាស៊ានថ្នាក់ជាតិ

គ. សម្របសម្រួលការអនុវត្តន៍សេចក្តីរបស់អាស៊ានថ្នាក់ជាតិ

ឃ. សម្របសម្រួលនិងជួយរៀបចំកិច្ចប្រជុំអាស៊ានថ្នាក់ជាតិ

ង. លើកស្ទួយអត្តសញ្ញាណ និងការយល់ដឹងអំពីអាស៊ានថ្នាក់ជាតិ

ច. រួមចំណែកកសាងសហគមន៍អាស៊ាន។

**អំពីអង្គភាពសិទ្ធិមនុស្សអាស៊ាន**

១. ដោយអនុលោមតាមគោលបំណង និងគោលការណ៍របស់រដ្ឋធម្មនុញ្ញអាស៊ាន ដែលទាក់ទង ទៅនឹងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន អាស៊ានត្រូវបង្កើត អង្គភាព សិទ្ធិមនុស្សអាស៊ានមួយ ។

២. អង្គភាពសិទ្ធិមនុស្សអាស៊ាននេះ ត្រូវធ្វើការដោយអនុលោមទៅតាមឯកសារគោល ដែលនឹង កំណត់ដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ។

**អំពីគ្រឹះស្ថានអាស៊ាន**

១. គ្រឹះស្ថានអាស៊ាន ត្រូវគាំទ្រដល់អគ្គលេខាធិការអាស៊ាន នឹងសហការជាមួយអង្គភាពអាស៊ាន ពាក់ព័ន្ធ ដើម្បីទ្រទ្រង់ការកសាងសហគមន៍អាស៊ាន តាមរយៈការជំរុញការយល់ដឹងឲ្យកាន់តែច្បាស់ អំពីអត្តសញ្ញាណអាស៊ាន អន្តរទំនាក់ទំនងរវាងប្រជាជន និងប្រជាជននិងសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធជាមួយ ផ្នែកធុរកិច្ច សង្គមស៊ីវិល គ្រឹះស្ថានសិក្សានិងផ្នែកពាក់ព័ន្ធដទៃទៀត ។

២. គ្រឹះស្ថានអាស៊ាន ទទួលខុសត្រូវចំពោះមុខ អគ្គលេខាធិការអាស៊ាន តាមរយៈក្រុមប្រឹក្សា សម្របសម្រួល ។

**អង្គភាពចំណុះអាស៊ាន**

១. អាស៊ានអាចបំពេញការងារជាមួយអង្គភាពនានា ដែលគាំទ្រធម្មនុញអាស៊ាននេះ ជាពិសេស ចំពោះគោលបំណង និងគោលការណ៍របស់ធម្មនុញ្ញអាស៊ាន ។ អង្គភាពដែលចំ ណុះអាស៊ានមានរាយនាមក្នុងឧបសម្ព័ន្ធ ទី២នៃធម្មនុញ្ញនេះ ។

២. វិធាននៃនីតិវិធី និងលក្ខណៈវិនិច្ឆ័យសម្រាប់ការចូលរួមជាមួយអង្គភាពទាំងនេះ ត្រូវកំណត់ដោយគណៈកម្មាធិកាតំណាងអចិន្ត្រៃយ៍ នៅពេលដែលបានទទួលអនុសាសន៍ពីអគ្គលេខាធិការអាស៊ាន។

៣. ឧបសម្ព័ន្ធទី២ អាចត្រូវធ្វើបច្ចុប្បន្នភាព ដោយអគ្គលេខាធិការអាស៊ាន នៅពេលមានអនុសាសន៍ពីគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ ដោយពុំចាំបាច់ធ្វើវិសោធនកម្មនៃធម្មនុញ្ញនេះ ។

**សំណួរត្រិះរិះ**

១. តើអ្វីជាក្រុមប្រឹក្សាសហគមន៍អាស៊ាន?

២. តើប្រឹក្សាសហគមន៍អាស៊ានមានភារកិច្ចធ្វើអ្វីខ្លះ?

៣. តើអង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែកអាស៊ានមានភារកិច្ចធ្វើអ្វីខ្លះ?

៤. តើអគ្គលេខាធិការអាស៊ាន គេជ្រើសរើសយ៉ាងដូចម្ដេច? មានអាណត្តិប៉ុន្មានឆ្នាំ? តើមានល័ក្ខខ័ណ្ឌអ្វីខ្លះ?

៥. តើអគ្គលេខាធិការអាស៊ាន មានភារកិច្ចធ្វើអ្វីខ្លះ?

៦. តើគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ានជាអ្វី?

៧. តើគណៈកម្មាធិការតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន មានភារកិច្ចធ្វើអ្វីខ្លះ?

៨. តើលេខាធិការដ្ឋានជាតិអាស៊ានមានភារកិច្ចអ្វីខ្លះ?

៩. តើអាស៊ាធ្វើការសម្រេចចិត្តយ៉ាងដូចម្តេច?

១០. តើអាស៊ានធ្វើការដោះស្រាយជម្លោះយ៉ាងដូចម្តេច?

១១. តើប្រធានអាស៊ាមានអាណត្តិប៉ុន្មានឆ្នាំ?

១២. តើប្រធានអាស៊ាមានតួនាទី និងភារកិច្ចធ្វើអ្វីខ្លះ?

១៣. តើអគ្គលេខាធិការអាស៊ាន គេជ្រើសរើសយ៉ាងដូចម្តេច? មានអាណត្តិប៉ុន្មានឆ្នាំ? តើមានល័ក្ខខ័ណ្ឌអ្វីខ្លះ?

១៤. តើអគ្គលេខាធិការអាស៊ាន មានភារកិច្ចធ្វើអ្វីខ្លះ?

១៥. តើអាស៊ាធ្វើការដោះស្រាយជម្លោះយ៉ាងដូចម្តេច?

# មេរៀនទី៣៖ បណ្តាប្រទេសអាស៊ាន របបនយោបាយ បញ្ហា និង សេដ្ឋកិច្ច

## ១. ប្រទេសកម្ពុជា





**ឈ្មោះប្រទេស៖** ព្រះរាជាណាចក្រកម្ពុជា

**រាជធានី៖** ភ្នំពេញ

**ភាសាជាតិ៖** ខ្មែរ

**ថ្ងៃដែលចូលជាសមាជិកអាសស៊ាន៖** ៣០ មេសា ១៩៩៩

**ថ្ងៃឯករាជ្យ៖** ៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ពីបារាំង

**ទង់ជាតិ**

ទង់ជាតិប្រទេសកម្ពុជា មានរូបប្រាសាទកំពូលបីពណ៌សស្ថិតនៅចំកណ្តាល៖

- ពណ៌ក្រហម តំណាងឱ្យជាតិ
- ពណ៌ខៀវតំណាងឱ្យស្ថាប័នព្រះមហាក្សត្រ
- ប្រាសាទអង្គរវត្តពណ៌ស តំណាងឱ្យសន្តិភាព និងសាសនា ដែលកាលពីសម័យដើមមានការគោរព ព្រាហ្មណ៍ ហិណ្ឌូហើយប្តូរមកគោរពព្រះពុទ្ធសាសនារហូតដល់បច្ចុប្បន្ន។

**ទីតាំងភូមិសាស្ត្រ**



ប្រទេសកម្ពុជាស្ថិតនៅភាគខាងត្បូងឧបទ្វីបឥណ្ឌូចិនក្នុងតំបន់អាស៊ីអាគ្នេយ៍។មានផ្ទៃ 181.035 គីឡូម៉ែត្រការ៉េ។ នៅប៉ែកពាយ័ព្យជាប់ប្រទេសថៃ ភាគឦសានជាប់ប្រទេសឡាវ ខាងកើតជាប់ប្រទេសវៀតណាម និងឈូងសមុទ្រថៃនៅភាគនិរតី។ ប្រទេសកម្ពុជាមាន ២៥ខេត្ត ១៥៦ស្រុក ២៦ក្រុង។

**ប្រជាជន៖**

ប្រជាជនមានចំនួន ១៥ ៩៥៧ ២២៣នាក់ ក្នុងខែកក្កដា ឆ្នាំ ២០១៦។ ជំរឿនឆ្នាំ២០១៣ មានចំនួន ១៣ ៣៩៥ ៨៨២នាក់។ ដង់ស៊ីតេមានចំនួន៨១,៨នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។ ប្រជាជនរស់នៅប្រទេសកម្ពុជារួមមាន៖ ជនជាតិខ្មែរចំនួន៩៧,៦% ចាមចំនួន១,២% វៀតណាមចំនួន០,១% ចិនចំនួន០,១% ជនជាតិដើម៣០ផ្សេងៗទៀតមានចំនួន០,៩%( ទិន្នន័យពីក្រុមជនជាតិដែលរស់នៅក្នុងប្រទេស កម្ពុជាឆ្នាំ២០១៣ wikipedia)។ សាសនាព្រះពុទ្ធ អ៊ីស្លាម គ្រឹះសាសនា និងផ្សេងៗទៀត

**របបនយោបាយ**

ជាប្រទេសប្រកាន់របបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ និងគោរពលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សផ្អែកលើគោលការណ៍នៃការបែងចែកដាក់ពីគ្នា រវាងអំណាចស្ថាប័ននីតិបញ្ញត្តិ ប្រតិបត្តិ និងតុលាការ។ ស្ថាប័ននីតិបញ្ញត្តិតំណាងដោយសភា និងព្រឹទ្ធសភា។ ស្ថាប័នប្រតិបត្តិតំណាងដោយនាយករដ្ឋមន្ត្រី និងស្ថាប័នតុលាការជាស្ថាប័នឯករាជ្យជាអ្នកបកស្រាយច្បាប់។

**សេដ្ឋកិច្ចៈ**

ប្រទេសកម្ពុជាមានGDP ចំនួន$18.05 billion ក្នុងឆ្នាំ២០១៥ ជាប់លំដាប់ថ្នាក់ទី១១៧ និងមានកំណើនសេដ្ឋកិច្ច7.3%។ វិស័យសេដ្ឋកិច្ចសំខាន់ៗមានរួមមានវិស័យសំណង់ កាស៊ីណូ ស៊ីម៉ង់ត៍ សំលៀកបំពាក់ វាយនភ័ណ្ឌ នេសាទ អាជីវកម្មត្បូង ម៉ាស៊ីនកិន ស្រូវ កៅស៊ូ ទេសចរណ៍ និងផលិតផលពីឈើ។ វិស័យកសិកម្មរកចំណូលបានចំនួន34.7%នៃថវិកាជាតិ, វិស័យឧស្សាហកម្មមានពីរដែលសសំខាន់ជាងគេ គឺវាយនភ័ណ្ឌ និងទេសចរណ៍ វិស័យនេះរកចំណូលបាន24.3%នៃថវិកាជាតិ និងវិស័យសេវាកម្មរកចំណូល41.0%នៃថវិកាជាតិ[1]។

ប្រជាជនសកម្មមានចំនួន 8.8លាននាក់ ក្នុងឆ្នាំ២០១០។ កម្លាំងពលកម្មធ្វើការនៅក្នុងវិស័យកសិកម្មមានចំនួន57.6% ក្នុងវិស័យឧស្សហកម្មមានចំនួន15.9% និងក្នុងវិស័យសេវាកម្មមានចំនួន26.5%(ឆ្នាំ២០១០)។ អ្នកអត់ការងារធ្វើមានចំនួន3.5%។

ពាណិជ្ជកម្មៈ ប្រទេសកម្ពុជាមានតម្លៃទំនិញនាំចេញចំនួន $8.433 billion (2012)។ ផលិតផលនាំចេញរួមមាន សំលៀកបំពាក់ ឈើ កៅស៊ូ ស្រូវ ត្រី ថ្នាំជក់ និងស្បែកជើង។ ដៃគូពាណិជ្ជកម្មនាំចេញរួមមានសហរដ្ឋអាមេរិកមានចំនួន23.1% អង់គ្លេស8.8% អាឡឺម៉ង់8.2% ជប៉ុន7.4% កាណាដា6.7% ចិន5.1% វៀតណាម5.0% ថៃ4.9% និងNetherlands4.1%(2015.)។

ប្រទេសកម្ពុជាមានតម្លៃនាំចូលទំនិញចំនួន $8.840 billion (2012) ផលិតផលនាំចូលរួមមាន ប្រេង ថ្នាំជក់ មាស សម្ភារសំណង់ ម៉ាស៊ីន យានយន្ត និងផលិតផលឱសថ។ ថៃ28.7% ចិន22.2% វៀតណាម16.4% ហុងកុង6.1% និងសិង្ហបូរី5.7%(2015)។

**បញ្ហាសំខាន់ៗ**

ទម្រាំបានស្គាល់សន្តិភាព ស្ថិរភាពនិងការអភិវឌ្ឍន៍ដូចពេលបច្ចុប្បន្ន កម្ពុជាបានឆ្លងកាត់មហាសោកនាដកម្មមួយពាន់ជំពូក ដែលគេកម្រប្រទះឃើញនៅក្នុងប្រវត្តិមនុស្សជាតិ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចសីហនុនៅថ្ងៃទី១៨មីនាឆ្នាំ១៩៧០ កម្ពុជាបានក្លាយជាសមរភូមិនៃសង្គ្រាមជាច្រើន និងច្រើនប្រភេទក្នុងអំឡុងពេល២០ឆ្នាំ រួមមានជាអាទិ៍សង្គ្រាមស៊ីវិលនៅដើមទសវត្សរ៍ទី៧០ដែលបានជរចេញពីសង្គ្រាមត្រជាក់រវាងលោកខាងលិច និងលោកខាងកើត និងសង្គ្រាមនៅក្នុងទសវត្សរ៍ទី៨០ ដែលបានជរចេញពីអធិករណ៍រវាងកុម្មុយនីស្តចិន និងកុម្មុយនីស្តសូវៀត។ នៅចន្លោះសង្គ្រាមទាំងពីរ កម្ពុជាបានឋិតនៅក្រោមនឹមនៃរបបខ្មែរក្រហមសែនសាហាវយង់ឃ្នង។ គឺជារបបកុម្មុយនីស្តជាតិនិយមជ្រុល ប្រកាន់ពូជសាសន៍ និងប្រល័យពូជសាសន៍ ដែលបានយកការសម្លាប់រង្គាលមកធ្វើជារបៀបដឹកនាំប្រទេស។

សោកនាដកម្មទាំងអស់នេះ រួមមានសង្គ្រាមស៊ីវិលឆ្នាំ១៩៧០-១៩៧៥ របបខ្មែរក្រហមឆ្កួតលីលា ព្រមទាំងសង្គ្រាមក្នុងទសវត្សរ៍ទី៨០រវាងរដ្ឋកម្ពុជាគាំទ្រដោយវៀតណាមរណបសូវៀត និងចលនាខ្មែរតស៊ូរបស់សម្តេចសីហនុ និងលោកតាស៊ីន សាន ព្រមទាំងខ្មែរក្រហមដែលទ្រទ្រង់ដោយចិន និងសហរដ្ឋអាមេរិក បានធ្វើឱ្យប្រទេសជាតិបាត់បង់មនុស្សអស់ជាង៣លាននាក់ក្នុងរយៈពេលប្រមាណតែ២០ឆ្នាំប៉ុណ្ណោះ។

---

[1] https://en.wikipedia.org/wiki/Economy_of_Cambodia 2012

សង្គ្រាមក៏យូរ ផ្លូវទៅរកសន្តិភាពក៏វែងឆ្ងាយ។ សន្តិភាពនៅលើក្រដាសតាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីសខែតុលាឆ្នាំ១៩៩១ និងនៅលើសាច់ការជាក់ស្តែងតាមរយៈបេសកកម្មរបស់អង្គការសហប្រជាជាតិនៅកម្ពុជា មិនបានគ្របដណ្តប់ភ្លាមៗទៅលើប្រទេសទេ។ ជាការពិត សហគមន៍អន្តរជាតិបានជួយបង្ខំកងទ័ពវៀតណាមឱ្យចាកចេញពីទឹកដីកម្ពុជានិងបានទទួលជោគជ័យក្នុងការរៀបចំបោះឆ្នោត និងក្នុងការបង្កើតរបបនយោបាយមួយថ្មីសេរីនិងពហុបក្ស។ ក៏ប៉ុន្តែ សហគមន៍អន្តរជាតិបានទទួលបរាជ័យក្នុងការនាំមកនូវសន្តិភាព។ នៅទីបំផុត គឺកម្ពុជាខ្លួនឯងទេតើក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែនជាអ្នកដែលបានបញ្ចប់សង្គ្រាមជាមួយខ្មែរក្រហមនៅចុងឆ្នាំ១៩៩៨។ ម្ល៉ោះហើយ ម្នាក់ៗគួរចងចាំថា ទម្រាំមកដល់ថ្ងៃនេះ កម្ពុជាបានធេះរលេះរលួយ បានហែលឆ្លងនរក និងបានដើរអូសជើងចេញរួចយ៉ាងវេទនាជាទីបំផុតពីសករាជសូន្យ។

ក្នុងរយៈពេលជិត២០ឆ្នាំចុងក្រោយនេះ ពោលគឺរាប់ពីឆ្នាំ១៩៩៨មក ប្រទេសកម្ពុជាដែលបានឈានជើងចេញរួចពីរបបផ្តាច់ការបាននឹងកំពុងបន្តដើរឆ្ពោះទៅរករបបប្រជាធិបតេយ្យទោះបីជាដំណើរទៅរកគោលដៅលទ្ធិប្រជាធិបតេយ្យនេះមានលក្ខណៈរប៉ាក់របើក ហើយជួនកាលទៀតទៅមុខមួយជំហាន និងថយក្រោយមកវិញពីរជំហានក៏ដោយ។

ជាក់ស្តែង កម្ពុជាដែលគ្មានវប្បធម៌និងទំនៀមទម្លាប់ប្រជាធិបតេយ្យបានបោះបង់ចោលលទ្ធិកុម្មុយនីស្តដើម្បីក្រសោបយករបបប្រជាធិបតេយ្យសេរីពហុបក្ស។ ជាក់ស្តែង កម្ពុជា ក្នុងគ្រាបច្ចុប្បន្នមានសេរីភាពសារព័ត៌មានប្រសើរគ្រាន់បើ រហូតដល់ត្រូវបានអង្គការអ្នក កាសែតគ្មានព្រំដែនចាត់ទុកថាមានសេរីភាពសារព័ត៌មានល្អជាងគេនៅក្នុងចំណោម បណ្តាប្រទេសសមាជិកអាស៊ានទាំង១០។ ការរីកចម្រើន និងវិជ្ជាជីវៈកាន់តែល្អឡើងជាលំដាប់នៃវិស័យសារព័ត៌មានក៏បាននិងកំពុងបន្តជួយកាត់បន្ថយមិនតិចដែរភាពតានតឹងនយោបាយនិងសង្គម។ មិនសូវមានច្រើនដូចមុនទៀតទេ សារព័ត៌មានដែលជេរប្រមាថ បង្អាប់បង្អោនកិត្តិយស និងកេរ្តិ៍ឈ្មោះ។ ទន្ទឹមនេះ វិទ្យុនិងទូរទស្សន៍អន្តរជាតិ ជាពិសេសវិទ្យុអន្តរជាតិនិយាយភាសាខ្មែរ ដែលរដ្ឋាភិបាលបានបើកដៃឱ្យផ្សព្វផ្សាយឬចាក់ផ្សាយបន្តតាមរលកអាកាសFMសឹងនៅទូទាំងប្រទេស បានធ្វើឱ្យលេចឡើងនូវសម្លេងថ្មីមួយអព្យាក្រឹត ឯករាជ្យនិងសត្យានុម័ត។ ជាក់ស្តែងដូចគ្នា កម្ពុជាមានសង្គមស៊ីវិលមួយខ្លាំងដែលស្តែងឡើងតាមរយៈវត្តមាននៃអង្គការក្រៅរដ្ឋាភិបាលចំនួនជាង៤០០០។ ដោយឡែក កម្ពុជាបច្ចុប្បន្នមានសន្តិភាពរឹងមាំជាងកាលសម័យទសវត្សរ៍ទី៩០។ សន្តិភាពមាំទាំ និងស្ថិរភាពល្អគ្រាន់បើដែលគេសង្កេតឃើញនៅក្នុងប្រទេសនារយៈពេលជាង១០ចុងក្រោយនេះ ក៏ជាលទ្ធផលបានមកពីនិរន្តភាពនៃស្ថាប័នរាជាធិបតេយ្យដែរ។ នេះក៏ដោយសារតែព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហមុនី ដែលទ្រង់បានឡើងសោយរាជ្យនៅឆ្នាំ២០០៤ ទ្រង់បាននឹងកំពុងបន្តផ្ចិតផ្ចង់មិនឱ្យព្រះរាជ្យសកម្មភាពរបស់ព្រះអង្គឧសភ្លាត់ឬឃ្លាតចាកពីការថែងរបស់រដ្ឋធម្មនុញ្ញឡើយ។

យ៉ាងណាមិញ ពីឆ្នាំ១៩៩៨រហូតមកដល់ឥឡូវនេះ អំណាចរដ្ឋនៅកម្ពុជាឋិតនៅក្រោមឥទ្ធិពលសឹងផ្តាច់មុខតែឯកឯងរបស់គណបក្សប្រជាជន និងនៅក្នុងដៃរបស់លោកនាយកហ៊ុន សែនដែលត្រូវគេចាត់ទុកថាជាបុរសខ្លាំងនៅកម្ពុជា។

ឥទ្ធិពលខ្លាំងក្លានៃគណបក្សប្រជាជន បានស្តែងឡើងជាពិសេស តាមរយៈការបោះឆ្នោតសភានៅខែកក្កដាឆ្នាំ២០០៨។ កាលនោះ គណបក្សប្រជាជនកម្ពុជាបានទទួលអាសនៈចំនួន៩០ក្នុងចំណោមអាសនៈ

ទាំង១២៣នៅក្នុងរដ្ឋសភា។ ទន្ទឹមនេះ ការបោះឆ្នោតសភាឆ្នាំ២០០៨ ក៏បានបង្ហាញឱ្យឃើញដែរនូវការប្រែប្រួលស៊ីជម្រៅនៃតុល្យភាពនយោបាយនៅខាងពួកអ្នកប្រឆាំង។ ចលនារាជានិយមបានរលាយដូចអំបិលត្រូវទឹក ដ្បិតបក្សហ៊្វុនស៊ីនប៉ិច ក៏ដូចបក្សនរោត្តម រណឫទ្ធិដែរ បានទទួលតែ២អាសនៈប៉ុណ្ណោះ ទល់នឹង២៦ សម្រាប់គណបក្សសម រង្ស៊ី និង៣សម្រាប់គណបក្សប្រឆាំងមួយថ្មី នោះគឺគណបក្សសិទ្ធិមនុស្សរបស់លោក កឹម សុខា។ ការរៀបចំបោះឆ្នោតទាំងថ្នាក់ជាតិនិងទាំងថ្នាក់មូលដ្ឋានជាបន្តបន្ទាប់តាំងពីឆ្នាំ១៩៩៣មក ជាភស្តុតាងប្រកែកមិនបានដែលបញ្ជាក់ថាលទ្ធិប្រជាធិបតេយ្យបាននឹងកំពុងបន្តចាក់ឫសនៅក្នុងប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះ លើកលែងតែការបោះឆ្នោតសភាខែកក្កដាឆ្នាំ២០១៣មួយចេញដែលនៅតែជាសង្គ្រាមប៉ាកកា ការបោះឆ្នោតមុនៗទាំងអម្បាលម៉ានសុទ្ធតែត្រូវបានក្រុមអ្នកសង្កេតការណ៍អន្តរជាតិវាយតម្លៃថា ជាទូទៅមានលក្ខណៈសេរី យុត្តិធម៌ និងត្រឹមត្រូវ។

ក្រៅតែពីការបោះឆ្នោតសភានៅឆ្នាំ១៩៩៣ដែលខ្លួនបានទទួលបរាជ័យ និងក្រៅតែពីការបោះឆ្នោតសភាខែកក្កដាឆ្នាំ២០១៣កន្លងទៅថ្មីៗនេះដែលប្រជាប្រិយភាពរបស់ខ្លួនបានធ្លាក់ស្រុតចុះខ្លាំង បក្សប្រជាជនបានឈ្នះឆ្នោតរហូត។ ប៉ុន្តែ សម្រាប់ពួកអ្នកប្រឆាំង ជ័យជំនះម្តងហើយម្តងទៀតនៃបក្សកាន់អំណាច គឺវាបានមកពីការលួចបន្លំសន្លឹកឆ្នោត។ យ៉ាងណាក៏ដោយ ការឈ្នះឆ្នោតបន្តបន្ទាប់គ្នានេះរបស់បក្សប្រជាជនកម្ពុជា ពិសេស ជ័យជំនះ នៅឆ្នាំ២០០៨ ចង់ឬមិនចង់ វាក៏អាចជាលទ្ធផលនៃការទុកចិត្តមួយប្រកែកមិនបានពីសំណាក់ប្រជាពលរដ្ឋទៅលើគណបក្សរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែនដែរ។...មានកត្តាធំៗចំនួន៤ យ៉ាងតិចដែលអាចពន្យល់បំភ្លឺថាហេតុអ្វីបានជា នៅឆ្នាំ១៩៩៨ ឆ្នាំ២០០៣ និងឆ្នាំ២០០៨ ពលរដ្ឋខ្មែរសុខចិត្តបោះឆ្នោតគាំទ្របក្សប្រជាជនកម្ពុជា។ ទីមួយ គឺមកពីថ្នាក់ដឹកនៃគណបក្សនេះ ជាអ្នកដែលបានទប់ស្កាត់កុំឱ្យពួកខ្មែរក្រហមវិលត្រឡប់មកកាន់អំណាចវិញពីឆ្នាំ១៩៧៩រហូតដល់ឆ្នាំ១៩៩៨។ ទីពីរ គឺមកពីថ្នាក់ដឹកនាំនៃគណបក្សនេះ ជាអ្នកដែលបាននាំសន្តិភាពមកឱ្យប្រទេសជាតិវិញ ក្រោយពីមានសង្គ្រាមរ៉ាំរ៉ៃអស់រយៈពេលជាងពីរទសវត្សរ៍។ ទីបី គឺការបែកខ្ញែកសំឡេងគាំទ្រគណបក្សប្រឆាំង និងការហែកហួរឈ្លោះប្រកែកគ្នាអស់រយៈពេលជាង១៥ឆ្នាំនៅក្នុងជួរបណ្តាគណបក្សប្រឆាំង។ ទីបួន គឺមកពីប្រទេសជាតិក្រោមការដឹកនាំរបស់រដ្ឋាភិបាលលោកហ៊ុន សែននារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានផ្តើមស្គាល់ការលូតលាស់សេដ្ឋកិច្ច។ កំណើនសេដ្ឋកិច្ចខ្លាំង ជាពិសេសនៅឆ្នាំ២០០៥-២០០៦ ទោះបីជាវាបានស្ទុះឡើងក្នុងភាពអនាធិបតេយ្យ ទោះបីជាវាបានបណ្តាលឱ្យមានគម្លាតកាន់តែធំរវាងអ្នកមាននិងអ្នកក្រ និងទោះបីជាវាបានបង្កើនអំពើពុករលួយនៅក្នុងសង្គមក៏ដោយក្តី ក៏វាបានធ្វើឱ្យជីវភាពរបស់ប្រជាពលរដ្ឋទូទៅស្គាល់ការរីកចម្រើនមិនតិចដែរ។

ក៏ប៉ុន្តែ កម្លាំងខ្លាំងសឹងផ្តាច់មុខតែឯកឯងរបស់គណបក្សប្រជាជនក្នុងអំឡុងពេលជិត២០ ឆ្នាំចុងក្រោយនេះ មិនមែនជាសញ្ញាល្អទេសម្រាប់ដំណើរការប្រជាធិបតេយ្យ ដ្បិតបាតុភាពនយោបាយបែបនេះ បានធ្វើឱ្យអំណាចពីរទៀត នោះគឺនីតិបញ្ញត្តិ និងតុលាការបាត់បង់សឹងអស់រលីងឥទ្ធិពលនិងឯករាជភាព។

ដោយអាងថាខ្លួនខ្លាំង ដោយអាងថាខ្លួនគង់តែបន្តឈ្នះឆ្នោត គណបក្សប្រជាជនកម្ពុជាដែលដឹកនាំប្រទេស ជាពិសេសក្នុងអំឡុងឆ្នាំ២០០៨-២០១៣ មិនបានឱ្យតម្លៃសោះឡើយទៅលើកំណែទម្រង់ ដែលជាកត្តាចាំបាច់បំផុតសម្រាប់ការបន្តអភិវឌ្ឍន៍ប្រទេសជាតិ។ មិនតែប៉ុណ្ណោះ ក្នុងអំឡុងពេលដដែលនេះ គណបក្ស

កាន់អំណាចក៏បានបណ្តោយឱ្យចំណុចអសកម្ម និងបញ្ហាធ្ងន់ធ្ងរជាច្រើនកើតឡើងនិងកើនឡើងដែរ។ មានតាំងពីវប្បធម៌និទណ្ឌភាព ជម្លោះដីធ្លីដែលមានលក្ខណៈកាន់តែស្រួចស្រាល់ អំពើពុករលួយ បញ្ហាអសន្តិសុខសង្គមមួយចំនួនដែលបង្កឡើងដោយក្រុមគ្រួសារអ្នកមាន និងអ្នកមានអំណាច រហូតដល់បញ្ហាអយុត្តិធម៌សង្គម ដូចជាការបណ្តេញប្រជាជនចេញដោយបង្ខំពីដីធ្លីរបស់ ពួកគេ និងការប្រើប្រាស់អំពើហិង្សានានា។

គឺសកម្មភាពអវិជ្ជមាននិងចំណុចអសកម្មទាំងនេះហើយ ដែលត្រូវបានគណបក្សប្រឆាំងឈ្មោះសង្គ្រោះជាតិរបស់លោក សម រង្ស៊ី និងលោក កឹម សុខា ជួយជ្រោមជ្រែងដោយសង្គមស៊ីវិល លើកយកមកនិយាយបរិហារយ៉ាងចាស់ដៃ ក្នុងពេលបោះឆ្នោតខែកក្កដាឆ្នាំ២០១៣។ អយុត្តិធម៌ក្នុងសង្គម ផ្គួបផ្សំជាមួយរឿងរ៉ាវច្រំដែលនៃប្រវត្តិសាស្ត្រជុំវិញបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម...ទាំងនេះហើយគឺជាថាមពលដែលសង្គ្រោះជាតិបានយកមកបំប៉នម៉ាស៊ីនឃោសនា ដើម្បីទាក់ទាញ និងពូនជ្រុំការគាំទ្រពីសំណាក់ពួក"អ្នកឈឺចាប់"និយាយជាទូទៅ និងពីសំណាក់យុវវ័យអ្នកនិយមលេងFacebook និយាយដាច់ដោយឡែក។ មិនតែប៉ុណ្ណោះ ពាក្យសន្យារបស់សង្គ្រោះជាតិដែលក្នុងនោះរួមមាន៤ ០០០០រៀលក្នុងមួយខែសម្រាប់មនុស្សចាស់ជរា ១៥០ដុល្លារក្នុងមួយខែសម្រាប់កម្មករ និង២៥០ដុល្លារក្នុងមួយខែសម្រាប់មន្ត្រីរាជការ បានធ្វើឱ្យអ្នកជនបទ ពួកអ្នកក្រនៅក្នុងទីក្រុង និងពួកមន្ត្រីរាជការចាប់អារម្មណ៍ជាខ្លាំង។

ទន្ទឹមនេះ ក្នុងពេលបោះឆ្នោតខែកក្កដាឆ្នាំ២០១៣ គណបក្សប្រជាជនកម្ពុជារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបន្តរបៀបធ្វើការឃោសនាដែលក្រុមអ្នកសង្កេតការណ៍វាយតម្លៃថា មានលក្ខណៈបែបចាស់គំរឹលមិនទាន់សម័យ។ គណបក្សកាន់អំណាចមួយនេះ បានលើកឡើងដដែលជាដដែលពីព្រឹត្តិការណ៍ថ្ងៃទី៧មករាឆ្នាំ១៩៧៩ ដែលក្មេងជំនាន់ក្រោយភាគច្រើនស្តាប់មិនឮឬស្តាប់មិនយល់។ ក្មេងជំនាន់ក្រោយនិយាយបែបផ្សេងយុវជននិងយុវនារីបច្ចុប្បន្នដែលមានចំនួនកាន់តែច្រើនឡើង ត្រូវការសារមួយច្បាស់ពីអ្នកនយោ បាយ សារនៃក្តីសង្ឃឹមចំពោះការរៀនសូត្រ ការងារ និយាយរួមសារនៃក្តីសង្ឃឹម ចំពោះអនាគតរបស់ពួកគេ។ ដូចគ្នាអ៊ីចឹងដែរ គណបក្សប្រជាជនបានលើកឡើងដដែលជាដដែលពីសមិទ្ធិផលរបស់ខ្លួនរួមមានជាពិសេសហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។ ប៉ុន្តែការកសាងផ្លូវថ្នល់ សាលារៀន និងមន្ទីរពេទ្យ។ល។និង។ល។ គឺជាភារកិច្ចរបស់រដ្ឋចំពោះសមូហភាព។ រីឯពលរដ្ឋម្នាក់ៗវិញ ក្នុងនាមជាអ្នកចូលនិវត្តន៍ ក្នុងនាមជាមន្ត្រីរាជការ និងក្នុងនាមជាយុវជនទំពាំងស្នងឫស្សី ត្រូវការប្រយោជន៍ផ្ទាល់ខ្លួន ត្រូវការឱ្យរដ្ឋគិតគូរពីជីវភាពនិងពីអនាគតរបស់ពួកគេ។

ទាំងអស់នេះ គឺសុទ្ធសឹងជាមូលហេតុសំខាន់ៗនៃការធ្លាក់ស្រុតចុះខ្លាំងរបស់គណបក្សប្រជាជនកម្ពុជា និងនៃការកើនសន្ទុះខ្លាំងទន្ទឹមគ្នារបស់គណបក្សសង្គ្រោះជាតិក្នុងពេលបោះឆ្នោតខែកក្កដាឆ្នាំ២០១៣។

ការបោះឆ្នោតខែកក្កដាឆ្នាំ២០១៣ គឺជារលកយក្សស៊ូណាមិនយោបាយមួយ សម្រាប់គណបក្សប្រជាជនកម្ពុជារបស់លោកហ៊ុន សែន។ គណបក្សនេះបានធ្លាក់ចំនួនអាសនៈពី៩០មកនៅត្រឹម៦៨ រីឯគណបក្សសង្គ្រោះជាតិបានទទួលរហូតដល់ទៅ៥៥អាសនៈ។

តាំងពីឆ្នាំ២០១៣មក ដូចដែលធ្លាប់បានកើតឡើងញឹកញយក្រោយការបោះឆ្នោតសំខាន់ៗម្តងៗ កម្ពុជាត្រូវហែលឆ្លងកាត់វិបត្តិ ក្នុងបរិយាកាសនៃការទាស់ទែងគ្នាឥតឈប់ឈរ ក្នុងអតីតកាលរវាងបក្សប្រជាជនកម្ពុជានិងបក្សFUNCINPEC ហើយឥឡូវនេះរវាងបក្សប្រជាជនកម្ពុជានិងបក្សសង្គ្រោះជាតិវិញម្តង។

ដើមដំបូង សង្គ្រោះជាតិមិនព្រមទទួលស្គាល់លទ្ធផលបោះឆ្នោត មិនព្រមចូលរដ្ឋសភា បន្តដឹកនាំបាតុកម្មទន្ទឹមគ្នានឹងបាតុកម្មបន្តបន្ទាប់គ្នារបស់កម្មករដែលទាមទារឡើងប្រាក់ខែ។
អាជ្ញាធរវិញដាក់ពង្រាយទ័ព សម្ដែងអំណាចនិងវាយបង្ក្រាប។ គេត្រូវរង់ចាំដល់ខែកក្កដាឆ្នាំ២០១៤ គឺមួយឆ្នាំក្រោយការបោះឆ្នោត ទើបឃើញគូបដិបក្ខទាំងពីរត្រូវរ៉ូវគ្នា ទើបឃើញតំណាងរាស្ត្រទាំង៥៥នាក់នៃបក្សប្រឆាំងសុខចិត្តចូលធ្វើការនៅក្នុងរដ្ឋសភា និងឃើញរដ្ឋាភិបាលថ្មីនីតិកាលទី៥ប្រសូត្រឡើង។ ដំបូង ភាពល្អកល្អិនមានលក្ខណៈដូចរាត្រីទឹកឃ្មុំ។ ទាំងសងខាងនាំគ្នានិយាយពី**វប្បធម៌សន្ទនា**ដែលមេបក្សប្រឆាំងហ៊ានរហូតដល់ទៅអះអាងថាមិនដែលមានក្នុងប្រវត្តិសាស្ត្រ កម្ពុជាសម័យថ្មីទៀតផង។ មេដឹកនាំកំពូលនៃបក្សប្រជាជនកម្ពុជានិងនៃបក្សសង្គ្រោះជាតិព្រមទាំងក្រុមគ្រួសារទាំងសងខាងថែមទាំងបានទទួលទានអាហាររួមគ្នាទៀតផង។ ប៉ុន្តែមិនយូរឡើយ គឺជាការវិលមកវិញនៃរាត្រីទឹកខ្មេះ គឺជាការវិលមកវិញនៃការប្រកួតប្រជែងដើម្បីទាក់ទាញប្រជាប្រិយភាពនិងដើម្បីបំពេញចិត្តពលរដ្ឋម្ចាស់ឆ្នោត។ បក្សប្រឆាំងលើកជ្រោងខ្ពស់ឡើងជាថ្មីរឿងរ៉ាវច្រំដែលនៃប្រវត្តិសាស្ត្រជុំវិញបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម បក្សប្រឆាំងត្រូវបានបក្សកាន់អំណាចសង្ស័យថានៅពីក្រោយបាតុកម្មជាបន្តបន្ទាប់ប្រឆាំងនឹងវត្តមានរបស់លោកនាយករដ្ឋមន្ត្រីកម្ពុជានៅបរទេស។ ទន្ទឹមនេះ សង្គ្រាមពាក្យសំដីក៏ផ្ដើមឡើងដែរ។ មេដឹកនាំបក្សប្រឆាំងប្រៀបធៀបលោកនាយករដ្ឋមន្ត្រីកម្ពុជាទៅនឹងហ្កាដាហ្វី (Kadhafi) ដែលជាអតីតមេដឹកនាំផ្ដាច់ការនៃប្រទេសលីប៊ី(Libye) និងប្រៀបធៀបគណបក្សខ្លួនទៅនឹងចលនារបស់លោកស្រីអ៊ុង សានស៊ូជី(Aung San Suu Kyi) ជ័យលាភីរង្វាន់ណូបែលផ្នែកសន្តិភាពដែលឈ្នះឆ្នោតសភានៅភូមាក្នុងខែវិច្ឆិកាឆ្នាំ២០១៥។

ប្រមុខរដ្ឋាភិបាលវិញ ជេរប្រធានសង្គ្រោះជាតិថាជា **កូនអាក្បត់ជាតិ** ។ រីឯអាជ្ញាធរមិនបង្អង់យូរឡើយ ចាត់វិធានការធម៌ក្ដៅបែបចង់ប្រដៅបក្សប្រឆាំង ដោយអះអាងថាសុទ្ធសឹងជារឿងរ៉ាវច្បាប់ សុទ្ធសឹងជាបញ្ហារបស់តុលាការ។ សម្រេចសម្រួចទៅ វិធានការអស់ទាំងនេះ សម្រាប់សហគមន៍អន្តរជាតិនិងអង្គការសិទ្ធិមនុស្សនានា គឺជាការធ្វើទុក្ខបុកម្នេញទៅលើបក្សប្រឆាំង។ ពីព្រោះជាលទ្ធផលជាក់ស្ដែង សមាជិកព្រឹទ្ធសភាម្នាក់ និងសមាជិករដ្ឋសភាម្នាក់របស់បក្សប្រឆាំងត្រូវជាប់ពន្ធនាគារ ប្រធានបក្សប្រឆាំងនិរទេសខ្លួនឯងទៅរស់នៅប្រទេសបារាំងជាថ្មី រីឯអនុប្រធានរបស់បក្សប្រឆាំងវិញកំពុងជាប់ក្ដីក្ដាំតុលាការ ក្រោយពីផ្ទុះរឿងរ៉ាវអាស្រូវស្នេហាលួចលាក់។

យ៉ាងណាក៏ដោយ ពីការបោះឆ្នោតខែកក្កដាឆ្នាំ២០១៣ និងពីស្ថានភាពនយោបាយបច្ចុប្បន្ន គេអាចទាញយកមេរៀនមួយចំនួន៖

- <u>មេរៀនទីមួយ</u> គឺលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាលែងខ្ចីស្រគាលទៀតហើយ តែផ្ដើមទុំ ដ្បិតពលរដ្ឋនៃប្រទេសមួយនេះមានចំណេះដឹងខ្ពស់ឡើងជាលំដាប់ ចេះប្រើសន្លឹកឆ្នោតរបស់ខ្លួន ដើម្បីធ្វើឱ្យគណបក្សកាន់អំណាចប៉ិះចាញ់ និងធ្វើឱ្យគណបក្សប្រឆាំងប៉ិះឈ្នះនៅឆ្នាំ ២០១៣។ និយាយរួមពលរដ្ឋខ្មែរចេះគិតគូរជាងមុន ចេះជំរុញឱ្យគណបក្សកាន់អំណាចឆ្លុះកញ្ចក់និងដុះក្អែលសម្អាតខ្លួន និងចេះលើកទឹកចិត្តឱ្យគណបក្សប្រឆាំងត្រៀមយុទ្ធសាស្ត្រ រចនាសម្ព័ន្ធនិងធនធានមនុស្សដើម្បីឡើងគ្រប់គ្រងអំណាចរដ្ឋជាយថាហេតុ។

- មេរៀនទីពីរ គឺពីអំណឹះតទៅ នៅប្រទេសកម្ពុជា អ្នកបោះឆ្នោតឱ្យគណបក្សសង្គ្រោះជាតិភាគច្រើន ជាយុវជន ជាអ្នករស់នៅទីក្រុង រីឯអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជាភាគច្រើនជាមនុស្សចាស់ ជាអ្នករស់នៅជនបទ។ ចំនួនពួកយុវជនដែលកើនឡើងជាលំដាប់ អាចនឹងធ្វើឱ្យក្រឡាប់ចាក់ឆាកនយោបាយកម្ពុជានាពេលខាងមុខ។
- មេរៀនទីបី គឺស្ថានភាពនៅទីបំផុតមានលក្ខណៈច្រំដែលដូចពេលមុនៗតទៅទៀតនោះគឺអំណាចប្រមូលផ្តុំរបស់លោកនាយករដ្ឋមន្ត្រី អំណាចពេញដៃរបស់បក្សប្រជាជនកម្ពុជា។ រីឯបក្សប្រឆាំងវិញគ្មានជម្រើសអ្វីផ្សេងក្រៅពីបន្តពឹងពាក់សហគមន៍អន្តរជាតិដើម្បីស្រាយចំណងច្បាប់និងនយោបាយដែលកំពុងវ័ណ្ឌកបស់ខ្លួន។ នៅក្នុងកាលៈទេសៈបែបនេះ ក្តីបារម្ភគ្របដណ្តប់ម្តងបន្តិចៗទៅលើស្មារតីរបស់ប្រជាពល រដ្ឋ នាពេលដែលការបោះឆ្នោតសភាឆ្នាំ២០១៨កាន់តែខិតជិតចូលមកដល់៕

**សំណួរត្រិះរិះ**

១. តើប្រទេសកម្ពុជាមានឈ្មោះផ្លូវការអ្វី?
២. តើប្រទេសកម្ពុជាមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?
៣. តើប្រទេសកម្ពុជាមានប្រជាជនប៉ុន្មានលាននាក់?
៤. តើប្រទេសកម្ពុជាមានរបបនយោបាយយ៉ាងដូចម្តេច?
៥. តើរដ្ឋាភិបាលកម្ពុជាមានអាណត្តិប៉ុន្មានឆ្នាំ?
៦. តើវិស័យសេដ្ឋកិច្ចកម្ពុជា មានប្រភពចំណូលពីវិស័យអ្វីខ្លះ?
៧. តើដៃគូពាណិជ្ជកម្មសំខាន់របស់កម្ពុជា មានប្រទេសណាខ្លះ?
៨. តើប្រទេសកម្ពុជា មានបញ្ហាអ្វីខ្លះ?

## ២. ប្រទេសវៀតណាម






**ឈ្មោះប្រទេស៖** សាធារណរដ្ឋសង្គមនិយមវៀតណាម
**ភាសា៖** វៀតណាម
**ចូលជាសមាជិកអាស៊ាន** ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៥
**ថ្ងៃឯករាជ្យជាតិ៖** ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ ពីប្រទេសបារាំង
**ទង់ជាតិ៖**

- ពណ៌ក្រហមនៅលើផ្ទៃទង់ តំណាងឱ្យឈាមរបស់ប្រជាជនដែលបាត់បង់ទៅក្នុងការតស៊ូទាមទារឯករាជ្យ។
- ផ្កាយពណ៌លឿង តំណាងឱ្យជនជាតិវៀតណាម។
- ជ្រុងទាំងប្រាំរបស់ផ្កាយ តំណាងឱ្យវណ្ណៈទាំងប្រាំនៅក្នុងសង្គម គឺកសិករ បញ្ញវន្ត ពលករ យុវជន និងទាហាន។

## ទីតាំងភូមិសាស្ត្រ

វៀតណាមជាប្រទេសដែលស្ថិតចុងខាងកើតឧបទ្វីបឥណ្ឌូចិននៃតំបន់អាសុីអាគ្នេយ៍។ ព្រំប្រទល់ភាគខាងជើងជាប់និងប្រទេសចិន ភាគពាយព្យជាប់នឹងប្រទេសឡាវ ខាងលិចជាប់ប្រទេសកម្ពុជា និងខាងកើតជាប់នឹងសមុទ្រចិនខាងត្បូង។



ផ្ទៃដីទំហំ ៣៣១ ២១០គីឡូម៉ែតការ៉េ មានព្រំប្រទល់ប្រវែង៤៦៣៩គីឡូម៉ែត្រ និងមានឆ្នេរប្រវែងសមុទ្រប្រវែង ៣៤៤៤គីឡូម៉ែត្រការ៉េ។ ប្រទេសវៀតណាមមានផ្ទៃដីភ្នំចំនួន ៤០% និងផ្ទៃដីព្រៃឈើចំនួន ៤២%។ រដ្ឋធានីហាណូយ។

## ប្រជាជន

ក្នុងឆ្នាំ២០១៦ ប្រជាជនវៀតណាមមានចំនួន ៩២ ៧០០ ០០០ ជាប្រទេសដែលមាន ចំនួនប្រជាជនច្រើនលំដាប់ទី១៤ ក្នុងពិភពលោក។ ដង់ស៊ីតេ២៧៦,០៣ ក្នុងមួយគីឡូមែត្រ ការ៉េ។ ភាសាផ្លូវការវៀតណាម។

ជនជាតិវៀតណាម ៨៦.២% មានជនជាតិភាគតិចចំនួន៥៣។ អ្នកមិនកាន់សាសនា ចំនួន៧៣,២%, សាសនាព្រះពុទ្ធ១២,២%, គ្រឹះសាសនាចំនួន៨,៣%, ៤,៨ Caodaism 4.8% , Hoahaoism 1.4%, និង 0.1% ផ្សេងទៀត។

## របបនយោបាយ

សាធារណរដ្ឋសង្គមនិយមវៀតណាម។ ជាប្រទេសដែលដឹកនាំដោយគណបក្សកុំមុនីសមួយគត់។ ស្ថាប័នរដ្ឋសំខាន់មានបី គឺស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងតុលាការ។

ស្ថាប័ននីតិបញ្ញត្តិ មានសភាជាតិតែមួយគត់។ សមាជិកសភាមាន៤៩៨នាក់។ គ្រប់គ្រងដោយប្រធានមួយរូប គ្រប់គ្រងទាំងស្ថាប័ននីតិប្រតិបត្តិ និងតុលាការ តាមរយៈគ្រប់រដ្ឋមន្ត្រីទាំងអស់ត្រូវបានតែងតាំងចេញពីសមាជិកសភាជាតិ។

ស្ថាប័ននីតិប្រតិបត្តិ៖ ប្រធានាធិបតីវៀតណាមជាប្រមុខរដ្ឋ និងជាអគ្គមេបញ្ជាការយោធា បំពេញតួនាទីជាប្រធានឧត្តមក្រុមប្រឹក្សាការពារ និងសន្តិសុខជាតិ។ នាយករដ្ឋមន្ត្រីប្រទេសវៀតណាមជាប្រមុខ រដ្ឋាភិបាល គ្រប់គ្រងក្រុមប្រឹក្សារដ្ឋមន្ត្រីរួមមានឧបនាយករដ្ឋមន្ត្រីបីរូប និងរដ្ឋមន្ត្រី២៦ក្រសួង និងគណកម្មាធិការ។

ស្ថាប័នតុលាការ៖ តុលាការកំពូលប្រជាជនវៀតណាម ដឹកនាំដោយប្រធានតុលាការកំពូលមួយរូប ជាតុលាការឧទ្ធរខ្ពស់ជាងគេបំផុតរបស់ប្រទេស។ ក្រៅពីនោះនៅមានតុលាការជាន់ទាបខេត្ត និងតុលាការស្រុកមួយចំនួនទៀត។ នៅមានតុលាការយោធាសម្រាប់កាត់ក្តីបញ្ហាពាក់ព័ន្ធនឹងសន្តិសុខជាតិ។ ប្រទេសវៀតណាមនៅមានរក្សាទុកទោសប្រហារជីវិតនៅឡើយ។ គ្រាន់តែនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤ មានមនុស្សប្រហែល៧០០នាក់ត្រូវបានកាត់ទោសប្រហារជីវិត។

## សេដ្ឋកិច្ច

| GDP (nominal) | 2017 estimate |
|---|---|
| Total | $215.829 billion[5] (47th) |
| Per capita | $2,305[5] (129th) |

ប្រទេសវៀតណាមបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី១១ ខែមករា ឆ្នាំ ២០០៧។ ដៃគូពាណិជ្ជកម្មរបស់ប្រទេសវៀតណាមរួមមានប្រទេសចិន ជប៉ុន អូស្រ្តាលី បណ្តាប្រទេសអាស៊ាន សហរដ្ឋអាមេរិក និងបណ្តាប្រទេសអឺរ៉ុបខាងលិច។

វៀតណាមនាំចេញនិងនាំចូលយ៉ាងសន្ធឹកសន្ធាប់នូវទូរស័ព្ទ និងគ្រឿងបន្លាស់។ ប្រេងឆៅក៏ជាទំនិញនាំចេញលំដាប់ខ្ពស់ផងដែរ។ ចំណែកឯដែកជាទំនិញនាំចូលជាប់លំដាប់ខ្ពស់ផងដែ។ ប្រទេសវៀតណាមដែលនាំចេញទំនិញទៅសហរដ្ឋអាមេរិកច្រើនជាងគេ។ ផ្ទុយទៅវិញប្រទេសចិននាំទំនិញចូលវៀតណាមច្រើនជាងគេ។

វៀតណាមបានធ្វើការកែទម្រង់សេដ្ឋកិច្ចជាសេដ្ឋកិច្ចទីផ្សារចាប់តាំងពីឆ្នាំ១៩៨៦ គឺនៅក្នុងមហាសន្និបាតជាតិលើកទី៦

## បញ្ហាសំខាន់ៗ

ជិត៤០ឆ្នាំកន្លងមកហើយដែលវៀតណាមខាងជើងនិងវៀតណាមខាងត្បូង បានបង្រួបបង្រួមគ្នាទៅជាប្រទេសតែមួយដែលដឹកនាំដោយគណបក្សកុម្មុយនិស្ត។ ទោះបីជាបាននិងកំពុងបន្តធ្វើសេរីកម្មសេដ្ឋកិច្ចតាំងពីឆ្នាំ១៩៨៦មកក្តី ក៏វៀតណាមដែលយកតម្រាប់តាមប្រទេសចិន នៅតែជាប្រទេសកាន់អំណាចផ្តាច់ការក្នុងពេលបច្ចុប្បន្ន។

ក្រោយបន្ទាប់ពីទីក្រុងសៃហ្គុង(Saigon) បានធ្លាក់នៅខែមេសាឆ្នាំ១៩៧៥ វៀតណាមខាងជើង និងវៀតណាមខាងត្បូងត្រូវបានបង្រួបបង្រួមគ្នាទៅជាប្រទេសតែមួយវិញដែលក្លាយជារបបកុម្មុយនិស្តផ្តាច់ការក្រោមឈ្មោះថាសាធារណរដ្ឋសង្គមនិយមវៀតណាម។

ឥឡូវនេះ ជិត៤០ឆ្នាំក្រោយមក ជាផ្លូវការទីក្រុងហាណូយ(Hanoi)ចាត់ទុករបបនយោបាយនៃប្រទេសខ្លួនថាជា "លទ្ធិប្រជាធិបតេយ្យ ដឹកនាំដោយគណបក្សតែមួយ" នោះ គឺគណបក្សកុម្មុយនិស្តវៀតណាម។ រដ្ឋាភិបាល ពន្យល់ថា ខ្លួនកំពុងប្រឹងប្រែងធ្វើឲ្យលទ្ធិប្រជាធិបតេយ្យ រីកចំរើនសន្សឹមៗទៅមុខដោយសន្តិវិធី។

នៅក្នុងន័យនេះ អាជ្ញាធរអះអាងថា នៅពេលបោះឆ្នោតសភាម្តងៗ តែងតែមានតំណាងរាស្ត្រមួយចំនួន ដែលមិនមែនចេញមកពីជួរគណបក្សកុម្មុយនិស្ត។ ជាក់ស្តែង វាមានអ៊ីចឹងមែនបេក្ខជនមិនមែនកុម្មុយនិស្តក្នុងពេលបោះឆ្នោតឆ្នាំ២០០៧ក៏ដូចក្នុងពេលបោះឆ្នោតឆ្នាំ២០១១ដែរ។

ក៏ប៉ុន្តែ ការពិតទាំងស្រុង វាមិនដូចមាត់រដ្ឋាភិបាលថានោះឡើយ។ អ្នកដែលមិនមែនកុម្មុយនិស្តអាចឈរឈ្មោះបោះឆ្នោតបាន លុះត្រាតែអ្នកនោះជាបេក្ខជនឯកឯង គ្មានអង្គការនយោបាយ សង្គមឬសាសនានៅពីក្រោយ។ យ៉ាប់ជាងនេះទៅទៀត បេក្ខភាពនៃបណ្តាជនឯករាជ្យទាំងអស់នោះ ត្រូវឆ្លងកាត់មុខអាជ្ញាធរមូលដ្ឋាន រួចហើយមុខអាជ្ញាធរថ្នាក់ជាតិ។ ជាទូទៅ បេក្ខភាពច្រើនសន្ធឹកសន្ធាប់ណាស់ត្រូវបានច្រានចោលក្រោមលេសថាជាការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ។

ក្រោមលេសថាជាការគំរាមកំហែងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរវៀតណាម ចាប់សកម្មជនប្រជាធិបតេយ្យ និងសកម្មជនសិទ្ធិមនុស្សញាត់បញ្ចូលគុក ធ្វើទុក្ខបុកម្នេញទៅលើជនជាតិភាគតិចទៅលើប្រមុខពុទ្ធសាសនា និងប្រមុខគ្រិស្តសាសនា។ មិនត្រឹមតែគ្មានសេរីភាពសាសនាប៉ុណ្ណោះទេ សូម្បីតែសេរីភាពសារ ព័ត៌មានក៏គ្មានដែរ។ ជាក់ស្តែង នៅក្នុងរបាយការណ៍ឆ្នាំ២០០៨របស់ខ្លួន អង្គការអ្នកសារព័ត៌មានគ្មាន

ព្រំដែន បានសរសេរជាអាទិ៍ថា "នគរបាលនយោបាយ នៅវៀតណាម បានចាត់វិធានការប្រឆាំងនឹងការបោះពុម្ពផ្សាយផ្សេងៗរបស់ពួកអ្នកជំទាស់។ អ្នកកាសែតម្នាក់ និងពួកអ្នកសរសេរអត្ថបទប្រឆាំងនឹងរដ្ឋាភិបាលតាមអ៊ីនធឺណែត ចំនួនជាង១០នាក់ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ ហើយអ្នកកាសែតបារាំងម្នាក់ធ្វើការឲ្យវិទ្យុប្រឆាំងមួយត្រូវបានចាប់ខ្លួនក្នុងបទភេរវកម្ម។"

និយាយរួម ប្រព័ន្ធនយោបាយនៃប្រទេសវៀតណាមមានមូលដ្ឋាននៅលើអំណាចនៃបក្សកុម្មុយនិស្ត។ គឺគណៈកម្មាធិការមជ្ឈិមនិងការិយាល័យនយោបាយនៃបក្សជាអ្នកអនុម័តរាល់សេចក្តីសម្រេចចិត្តសំខាន់ៗ។ បក្សកុម្មុយនិស្តវៀតណាមមានវត្តមាននៅគ្រប់ជាន់ថ្នាក់និងគ្រប់ទីកន្លែង ពីរដ្ឋបាលជាតិនិងមូលដ្ឋាន ពីកងទ័ពនិងនគរបាលរហូតទៅដល់សាលារៀននិងសហគ្រាសរដ្ឋឬឯកជន។

ផ្ទុយទៅវិញ នៅលើវិស័យសេដ្ឋកិច្ច វៀតណាមយកតម្រាប់តាមចិនដោយបានបោះបង់ចោលសេដ្ឋកិច្ចផែនការបែរទៅរកសេដ្ឋកិច្ចទីផ្សារនិងបើកចំហប្រទេសដើម្បីទទួលវិនិយោគបរទេស។

ថ្នាក់ដឹកនាំវៀតណាម បានផ្តើមធ្វើសេរីកម្មសេដ្ឋកិច្ចនៅឆ្នាំ១៩៨៦។ កាលនោះ ទីក្រុងហាណូយបានអនុម័តច្បាប់មួយចំនួន បានអនុញ្ញាតឲ្យមានវិនិយោគបរទេសជាលើកទីមួយបង្អស់។ គឺជាការផ្តើមឡើងនៃនយោបាយdoi moi ដែលគេអាចបកប្រែថាជា កំណែទម្រង់ ឬការផ្លាស់ប្តូរឲ្យបានប្រសើរឡើងស្រដៀងគ្នានឹងពាក្យPerestroïkaនៅសហភាពសូវៀតសម័យលោកGorbatchev។

ក្រោយមកទៀត នៅឆ្នាំ១៩៩១ ថ្នាក់ដឹកនាំវៀតណាម បានផ្តើមធ្វើសេរីកម្មនៅលើវិស័យកសិកម្ម។ ដីធ្លីលែងជាកម្មសិទ្ធិរបស់សមូហភាព។ រដ្ឋាភិបាលទទួលស្គាល់វិស័យឯកជននិងធ្វើកំណែទម្រង់ក្រុមហ៊ុនរដ្ឋ។ នយោបាយ doi moi បាននាំមកយ៉ាងលឿនរហ័សនូវលទ្ធផលល្អហួសការស្មាន និងគួរឲ្យភ្ញាក់ផ្អើលជាទីបំផុត។ នៅចុងទសវត្សរ៍ទី៩០ វៀតណាមដែលជាប្រទេសក្រគ្មានអង្ករប្រេកឆ្នាំង បានក្លាយជាប្រទេសលក់អង្ករចេញទៅក្រៅលំដាប់ថ្នាក់លេខមួយ នៅក្នុងពិភពលោក។ នៅឆ្នាំ១៩៩៥ វៀតណាមក្លាយជាសមាជិកនៃអាស៊ាន មានទំនាក់ទំនងទូតឡើងវិញជាមួយសហរដ្ឋអាមេរិក ដែលបានសម្រេចឈប់ដាក់ទណ្ឌកម្មសេដ្ឋកិច្ចទៅលើប្រទេសអតីតសត្រូវមួយនេះរបស់ខ្លួននៅឆ្នាំ១៩៩៤។

ជាការពិតណាស់ដែលថា សេរីកម្មសេដ្ឋកិច្ចនៅវៀតណាម មិនបាននាំមកទន្ទឹមគ្នានូវប្រជាធិបតេយ្យូបនីយកម្មនៃប្រទេស។ ក៏ប៉ុន្តែក្រុមអ្នកសង្កេតការណ៍ អះអាងថាសព្វថ្ងៃនៅផ្ទៃក្នុងគណបក្សកុម្មុយនិស្តវៀតណាមមានការតស៊ូមតិយ៉ាងផុសផុល ជុំវិញប្រធានរឿងពីរ។ ប្រធានរឿងទីមួយគឺការចាំបាច់ក្នុងការបង្កើតឲ្យមានអង្គការមួយចំនួនដែលមិនអាស្រ័យនឹងបក្សកុម្មុយនិស្ត ដូចយ៉ាងអង្គការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយជាដើម។

គោលដៅ គឺធ្វើយ៉ាងណាដើម្បីឲ្យមានបណ្តើរៗ ស្ថាប័នឯករាជ្យដែលអាចទប់កម្លាំងខ្លាំងជ្រុលរបស់គណបក្សកុម្មុយនិស្ត ពីព្រោះពិភពលោកដែលផ្លាស់ប្តូរ ទាមទារឲ្យមានការផ្លាស់ប្តូរដែរ នៅក្នុងប្រទេសវៀតណាម។

ប្រធានរឿងទីពីរនៃការតស៊ូមតិនៅក្នុងផ្ទៃក្នុងបក្សកុម្មុយនិស្តវៀតណាមសព្វថ្ងៃគឺការរៀបចំឲ្យមានតុល្យភាពល្អ រវាងចរន្តពួកកុម្មុយនិស្តខាងត្បូង និងចរន្តពួកកុម្មុយនិស្តខាងជើង។ គួរបញ្ជាក់ថា នៅឆ្នាំ១៩៧៥ ក្រោយពេលដែលទីក្រុងសៃហ្គុងបានធ្លាក់ ពួកកុម្មុយនិស្តដែលបានបង្កប់ខ្លួននៅវៀតណាមខាងត្បូងបាក់កម្លាំងទន់ខ្សោយខ្លាំង។ មូលហេតុទីមួយគឺបណ្តាលមកពី ក្នុងចន្លោះឆ្នាំ១៩៦៨ និងឆ្នាំ១៩៧៥ ពួកកុម្មុយនិស្តបង្កប់ខ្លួន នៅវៀតណាមខាងត្បូង បានស្លាប់អស់ច្រើន។ ឯមូលហេតុទីពីរ គឺបណ្តាលមកពីការ

បង្រួបបង្រួមយ៉ាងលឿនរហ័ស វៀតណាមខាងត្បូងនិងវៀតណាមខាងជើងទៅជាប្រទេសតែមួយនិងការលាតសន្ធឹងរបៀបគ្រប់គ្រងប្រទេសតាមបែបកុម្មុយនីស្ត ពីខាងជើងមកខាងត្បូង ធ្វើឲ្យចរន្តពួកកុម្មុយនិស្តខាងជើង មានឥទ្ធិពលខ្លាំងជាងចរន្តពួកកុម្មុយនិស្តខាងត្បូង។

ក៏ប៉ុន្តែ នៅដើមសតវត្សរ៍ទី២១នេះ សេដ្ឋកិច្ចមានតម្លៃជាងមនោគមវិជ្ជា បានន័យថាតំបន់ប៉ែកខាងត្បូង ជាពិសេសទីក្រុងសៃហ្គុងដែលជាក្បាលម៉ាស៊ីនសេដ្ឋកិច្ច កំពុងស្គាល់ការអភិវឌ្ឍន៍លឿនជាងតំបន់ប៉ែកខាងជើងជាហេតុធ្វើឲ្យចរន្តពួកកុម្មុយនិស្តខាងត្បូងមានទឹកមាត់ប្រៃឡើងវិញ។

លើសពីនេះទៅទៀត ប្រជាជនវៀតណាមនៅបរទេស កូនចៅរបស់ជនភៀសខ្លួនBoat people ដែលបានរៀនសូត្រនៅអាមេរិកឬនៅអឺរ៉ុប ត្រឡប់ចូលមកក្នុងមាតុប្រទេសវិញ ជាពិសេសមករស់នៅទីក្រុងសៃហ្គុង និងរកស៊ីមានបាន ក្លាយជាតួអង្គសេដ្ឋកិច្ចសំខាន់ៗ ដែលពីអំណើះតទៅ គណបក្សកុម្មុយនិស្តវៀតណាមត្រូវតែយកចិត្តទុកដាក់៕

**សំណួរត្រិះរិះ**

១. តើប្រទេសវៀតណាមមានឈ្មោះផ្លូវការអ្វី?

២. តើប្រទេសវៀតណាមមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?

៣. តើប្រទេសវៀតណាមមានប្រជាជនប៉ុន្មានលាននាក់?

៤. តើប្រទេសវៀតណាមមានរបបនយោបាយយ៉ាងដូចម្តេច?

៥. តើវិស័យសេដ្ឋកិច្ច វៀតណាមមានប្រភពចំណូលពីវិស័យអ្វីខ្លះ?

៦. តើដៃគូពាណិជ្ជកម្មសំខាន់របស់ វៀតណាមមានប្រទេសណាខ្លះ?

៧. តើប្រទេសវៀតណាមមានបញ្ហាអ្វីខ្លះ?

**៣. ប្រទេសឥណ្ឌូនេស៊ី**





**ឈ្មោះផ្លូវការ៖** សាធារណរដ្ឋឥណ្ឌូនេស៊ី

**ផ្ទៃដី៖** ១ ៩០៤ ៥៦៩គីឡូម៉ែត្រការ៉េ

**ថ្ងៃឯករាជ្យជាតិ** ១៧ ខែសីហា ឆ្នាំ១៩៤៥ ពីប្រទេសហូឡង់

**ទង់ជាតិ៖**

- ពណ៌ក្រហម តំណាងឱ្យសេចក្តីក្លាហាន។
- ពណ៌ស តំណាងឱ្យចិត្តវិញ្ញាណ។

## ទីតាំងភូមិសាស្ត្រ



ប្រទេសជាអធិបតេយ្យមួយ និងជាប្រទេសមួយស្ថិតលើទ្វីបពីរ ប៉ុន្តែមួយភាគធំស្ថិតក្នុងតំបន់អាស៊ី អាគ្នេយ៍និងផ្នែកខ្លះទៀតនៅលើទ្វីបអូសេអានី។ ប្រទេសនេះស្ថិតនៅចន្លោះមហាសមុទ្រឥណ្ឌានិងមហាសមុទ្រប៉ាស៊ីភិច។ ប្រទេសឥណ្ឌូនេស៊ីផ្សំឡើងដោយកោះចំនួន១៧ ០០០ មានផ្ទៃដីចំនួន១ ៩០៤ ៥៦៩ គីឡូម៉ែត្រការ៉េ ជាប្រទេសដែលមានផ្ទៃដីធំជាប់លំដាប់ថ្នាក់ទី១៤ និងជាប់លំដាប់ទី៧បើគិតទាំងផ្ទៃទឹក(៤,៨៥%)និងផ្ទៃដី។ ប្រទេសឥណ្ឌូនេស៊ីមានព្រំប្រទល់ជាប់ប្រទេសញ៉ូប៉ាពូគីណេ ទីម័រខាងកើត ខាងកើតប្រទេសម៉ាឡេស៊ី ជាប់ប្រទេសសិង្ហបូរី វៀតណាម ហ្វីលីពីន អូស្រាលី ប៉ាឡូ និងឥណ្ឌា។

ប្រទេសឥណ្ឌូនេស៊ីមាន៣៤ខេត្ត។ ទីក្រុងធំជាងគេគឺទីក្រុងចាក្រាតា។

## ប្រជាជន

ប្រទេសឥណ្ឌូនេស៊ីមានប្រជាជនចំនួន២៦៣,៥១លាននាក់ ក្នុងឆ្នាំ២០១៧ និងមានដង់ស៊ីតេ១២៤,៦៦នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។ ជាប្រទេសដែលមានប្រជាជនច្រើនលំដាប់ទី៤លើពិភពលោក។ ប្រទេសឥណ្ឌូនេស៊ីមានអ្នកកាន់សាសនាឥស្លាមចំនួន៨៧,២% សាសនាគ្រឹះចំនួន៩,៩% ហ៊ីនឌូ១,៧% ព្រះពុទ្ធ០,៧% ខុងជឺនិងផ្សេងៗទៀតចំនួន០,២%។ ជាប្រទេសដែលមានអ្នកកាន់សាសនាឥស្លាមច្រើនជាងគេលើពិភពលោក។ ភាសាជាផ្លូវការគឺ ភាសាឥណ្ឌូនេស៊ី។ ក្រៅពីនោះមានភាសាជ្វា ម៉ាឡេ គ្រាមភាសា អង់គ្លេស និងភាសាផ្សេងៗទៀតចំនួន៧០០ភាសា។

## របបនយោបាយ

ប្រធានាធិបតីឥណ្ឌូនេស៊ីជាប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធជាតិ។ ជានាយកនៃអភិបាលកិច្ចក្នុងស្រុង ការរៀបចំគោលនយោបាយ និងកិច្ចការបរទេស។ ប្រធានធិបតីតែងតាំងក្រុមប្រឹក្សារដ្ឋមន្ត្រីដោយមិនឆ្លងកាត់ការបោះឆ្នោតសភា។ នៅឆ្នាំ២០០៤ ប្រជាជនបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតីដោយផ្ទាល់។ ប្រធានាធិបតីមានអណត្តិ៥ឆ្នាំ និងឈរឈ្មោះបានតែពីរអណត្តិប៉ុណ្ណោះ។

ប្រទេសឥណ្ឌូនេស៊ី មានស្ថាប័នតំណាងរបស់ជាតិ គឺសភាប្រឹក្សាប្រជាជន។ សភាមានតួនាទីសំខាន់គឺគាំទ្រនិងធ្វើវិសោធនកម្មធម្មនុញ្ញ សម្ពោធប្រធានាធិបតី និងជាក្រុមប្រឹក្សាបង្កើតគោលនយោបាយដឹកនាំប្រទេស។ សភាមានអំណាចចោទប្រកាន់ប្រធានាធិបតី។ សភាមានពីរ គឺក្រុមប្រឹក្សាតំណាងប្រជាជនមានសមាជិកចំនួនចំនួន៥៦០នាក់ និងក្រុមប្រឹក្សាតំណាងតំបន់មានសមាជិក១៣២នាក់។ ក្រុមប្រឹក្សាតំណាងប្រជាជនជាអ្នកអនុម័តច្បាប់ និងត្រួតពិនិត្យស្ថាប័ននីតិប្រតិបត្តិ មានអណត្តិ៥ឆ្នាំ ដោយបោះឆ្នោតតំណាងសមាមាត្រ។ ក្រុមប្រឹក្សាតំណាងតំបន់ជាសភាថ្មីមួយសម្រាប់ធ្វើការគ្រប់គ្រងបញ្ហាតំបន់។

ប្រទេសឥណ្ឌូនេស៊ីមានតុលាការរដ្ឋ តុលាការឧទ្ធរណ៍ និងតុលាការកំពូល។ ក្រៅពីនោះនៅមានតុលាការពាណិជ្ជកម្ម តុលាការរដ្ឋបាលរដ្ឋ តុលាការធម្មនុញ្ញ និងតុលាការសាសនា។

## សេដ្ឋកិច្ច

សេដ្ឋកិច្ចឥណ្ឌូនេស៊ីជាសេដ្ឋកិច្ចលាយបញ្ចូលគ្នារវាងផ្នែកឯកជន និងរដ្ឋ។ ជាប្រទេសមានសេដ្ឋកិច្ចនាំមុខគេនៅអាស៊ីអាគ្នេយ៍។ ជាប្រទេសសមាជិកG20។ ប្រទេសឥណ្ឌូនេស៊ីមានGPD US$1.020 trillion និងមានចំណូល៣៨៩៥ដុល្លារសម្រាប់ម្នាក់ក្នុងមួយឆ្នាំ(២០១៧)។

សេវាកម្មជាចំណូលសំខាន់ជាងគេនៃសេដ្ឋកិច្ចប្រទេសមានចំនួន៤៣,៣%នៃ(GPD 2016)។ វិស័យផលិតកម្មឧស្សាហកម្មមានចំនួន៤២,៩% និងវិស័យកសិកម្មមានចំនួន១៣,៧% ផលិតផលសំខាន់របស់ប្រទេសមានស្រូវ ដូងប្រេង តែ កាហ្វេ កាការ៉ូ រុក្ខជាតិឱសថ និងគ្រឿងទេស។

ប្រទេសឥណ្ឌូនេស៊ីមានធនធានធម្មជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ដូចជា ប្រេងកាត ឧស្ម័នធម្មជាតិ សំណប៉ាហាំង ទងដែង និងមាស។ ដៃគូពាណិជ្ជកម្មសំខាន់របស់ប្រទេសឥណ្ឌូនេស៊ីរួមមានជប៉ុន សហរដ្ឋអាមេរិក ចិន សិង្ហបូរី ម៉ាឡេស៊ី និងអូស្ត្រាលី។

ប្រទេសឥណ្ឌូនេស៊ីផលិតផលនាំចេញមានធ្យូងអនាម័យ ដូងប្រេង ឧស្ម័នធម្មជាតិ ប្រេងកាតចៅនិងកៅស៊ូ។ ទីផ្សារនាំចេញរបស់ឥណ្ឌូនេស៊ីសំខាន់រួមមានជប៉ុនទី១ ចិនទី២ សហរដ្ឋអាមេរិកទី៣ សិង្ហបូរីទី៤ និងឥណ្ឌា។ ទីផ្សារនាំចូលរបស់ឥណ្ឌូនេស៊ីរួមមានចិនទី១ សិង្ហបូរីទី២ ជប៉ុនទី៣ កូរ៉េខាងត្បូងទី៤ ម៉ាឡេស៊ីទី៥។

**បញ្ហាសំខាន់ៗ**

ឥណ្ឌូណេស៊ីដែលមានប្រជាជនរហូតដល់ជាង២៦០លាននាក់ ជាប្រទេសអ៊ីស្លាមធំជាងគេបង្អស់នៅក្នុងពិភពលោក។ ក៏ប៉ុន្តែ អ៊ីស្លាមនៅឥណ្ឌូណេស៊ីជាអ៊ីស្លាមស្លូតបូតប្រកបដោយត្រាប្រណី ពីព្រោះជាអ៊ីស្លាមមួយដែលមានប្រភពចេញមកពីប្រទេសឥណ្ឌាពីសតវត្សរ៍ទី១៣ដល់សតវត្សរ៍ទី១៤ តាមរយៈពួកឈ្មួញ មិនមែនតាមរយៈសង្គ្រាមសាសនាDjihadទេ។ ម្ល៉ោះហើយ គេមិនអាចប្រដូចជនជាតិឥណ្ឌូណេស៊ីអ៊ីស្លាមទៅនឹងប្រជាជនអ្នកកាន់សាសនាអ៊ីស្លាមនៅក្នុងពិភពអារ៉ាប់បានទេ។ ឧទាហរណ៍ជាក់ស្តែងនារីឥណ្ឌូណេស៊ីមិនសូវពាក់ទេស្បៃគ្រប់មុខ។

យ៉ាងណាមិញ អ៊ីស្លាមដាច់ខាតនិយមឬអ៊ីស្លាមជ្រុលនិយមឥណ្ឌូណេស៊ីបានផ្តើមកកើតឡើងនៅចុងទសវត្សរ៍ទី៩០ ជាពិសេសនៅលើកោះMoluques ជាទីដែលពីឆ្នាំ១៩៩៩ដល់ឆ្នាំ២០០២ សហគមន៍អ៊ីស្លាម និងសហគមន៍អ្នកកាន់គ្រិស្តសាសនាបានកាប់សម្លាប់គ្នាយ៉ាងសាហាវព្រៃផ្សៃជាទីបំផុត។ ពីពេលនោះមកស្រមោលនៃភេរវកម្មអ៊ីស្លាមជ្រុលនិយមបានចាប់ផ្តើមលេចត្រដែតឡើងនៅលើទឹកដីឥណ្ឌូណេស៊ី។

មហាភេរវកម្មថ្ងៃទី១១កញ្ញាឆ្នាំ២០០១នៅសហរដ្ឋអាមេរិកគឺជាព្រឹត្តិការណ៍មួយសំខាន់ដែលបានធ្វើឲ្យចលនាអ៊ីស្លាមជ្រុលនិយមនៅឥណ្ឌូណេស៊ីរីកធំនិងមានឥទ្ធិពលខ្លាំងក្លាឡើង។ ពីព្រោះចំពោះពួកសកម្មជនអ៊ីស្លាមជ្រុលនិយមនៅឥណ្ឌូណេស៊ីទាំងនេះ មហាភេរវកម្មនៅអាមេរិកថ្ងៃទី១១កញ្ញាឆ្នាំ២០០១គឺជាការផ្តើមឡើងនៃសង្គ្រាមរវាងអរិយធម៌នៃអ៊ីស្លាមនិងអរិយធម៌នៃគ្រិស្តសាសនា។

អ៊ីចឹងហើយបានជាប៉ុន្មានថ្ងៃប៉ុណ្ណោះក្រោយព្រឹត្តិការណ៍ថ្ងៃទី១១កញ្ញាឆ្នាំ២០០១ ចរន្តអ៊ីស្លាមរឹងរូសជាងគេនៅឥណ្ឌូណេស៊ីបានអំពាវនាវឲ្យអ្នកកាន់សាសនាអ៊ីស្លាមទាំងអស់នៅក្នុងពិភពលោកពួតដៃគ្នាក្នុងនាមព្រះអាឡា(Allah)ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តរបស់អាមេរិក។ គឺនៅក្នុងបរិបទនេះហើយដែលជាងមួយឆ្នាំក្រោយមក ប្រទេសឥណ្ឌូណេស៊ីបានក្លាយជាផ្ទាំងស៊ីបនៃពួកភេរវជន។ ឧទាហរណ៍ជាក់ស្តែងគឺភេរវកម្មនៅបាលី(Bali)ថ្ងៃទី១២តុលាឆ្នាំ២០០២ ភេរវកម្មដែលបានបណ្តាលឲ្យមាន

ស្លាប់២០២នាក់ភាគច្រើនជាអ្នកទេសចរបស្ចិមលោក។

ឧទាហរណ៍ជាក់ស្តែងផ្សេងៗទៀត គឺរួមមានភេរវកម្មទៅលើសណ្ឋាគារMarriot ក្នុងរដ្ឋធានីយ៉ាការតា (Jakarta) ឆ្នាំ២០០៣ ភេរវកម្មទៅលើស្ថានទូតអូស្ត្រាលីនៅយ៉ាការតាឆ្នាំ២០០៤ និងភេរវកម្មជាថ្មីទៅលើសណ្ឋាគារMarriottនិងទៅលើសណ្ឋាគារRitz-Carltonនៅយ៉ាការតាឆ្នាំ២០០៩។

តើពួកភេរវជនអ៊ីស្លាមជ្រុលនិយមនៅឥណ្ឌូណេស៊ីចេញមកពីណា?

នៅខែតុលាឆ្នាំ២០០៨ ភេរវជនមួយក្រុមដែលជាអ្នកបានបង្កភេរវកម្មនៅបាលីត្រូវបាន តុលាការកាត់ទោសប្រហារជីវិត។ ពួកវាជាសមាជិកនៃអង្គការJemaah Islamiyah ដែលគេចាត់ទុកថាជាសាខារបស់អង្គការភេរវកម្មអន្តរជាតិអាល់កៃដា(Al-Qaïda)នៅអាស៊ីអាគ្នេយ៍។

មេកើយរបស់Jemaah Islamiyah ជាជនជាតិម៉ាឡេស៊ីឬឥណ្ឌូណេស៊ី។ គឺពួកJemaah Islamiyah នេះឯងដែលជាអ្នកបានបង្កភេរវកម្មប្រឆាំងនឹងព្រះវិហាគ្រិស្តសាសនានៅលើកោះMoluques ក្នុងខែធ្នូឆ្នាំ ២០០០ ហើយគឺនៅលើកោះMoluquesនេះតែម្តងដែលពួកអ៊ីស្លាមជ្រុលនិយមបានទទួលការបង្ហាត់ហ្វឹកហ្វឺននិងការបង្ខំស្មារតីឲ្យក្លាយទៅជាភេរវជនមិនចេះខ្លាចស្លាប់។

Jemaah Islamiyah មានមហិច្ឆតាបង្កើតរដ្ឋអ៊ីស្លាមដ៏ធំមួយដែលគ្របយកឥណ្ឌូណេស៊ី ម៉ាឡេស៊ី សិង្ហបុរី និងតំបន់អ៊ីស្លាមនៃប្រទេសហ្វីលីពីននិងនៃប្រទេសថៃ។ ម្ល៉ោះហើយបានជាគេចាប់ផ្តើមនិយាយថា ភេរវកម្មដែលកើតឡើងឥតឈប់ឈរនៅខាងត្បូងប្រទេសថៃសព្វថ្ងៃអាចជាស្នាដៃរបស់ពួកJemaah Islamiyah។

រហូតមកទល់សព្វថ្ងៃ សហរដ្ឋអាមេរិកបាននិងកំពុងបន្តធ្វើសហប្រតិបត្តិការជាមួយឥណ្ឌូណេស៊ីដើម្បីកំទេចអង្គការJemaah Islamiyah។ សហប្រតិបត្តិការរវាងទីក្រុងវ៉ាស៊ីនតោននិងទីក្រុងយ៉ាកាតាបានធ្វើឲ្យអង្គការភេរវកម្មតំបន់មួយនេះបាក់កម្លាំង និងបាត់បង់ឥទ្ធិពលមិនតិចទេ។ ជាក់ស្តែង តាំងពីឆ្នាំ២០០៩មកអស់មានទៀតហើយភេរវកម្មដែលមានលក្ខណៈសាហាវយង់ឃ្នងនៅឥណ្ឌូណេស៊ី។

ទន្ទឹមនេះ សហរដ្ឋអាមេរិកបានទាំងលើកឡើងម្តងជាពីរដង ពីការបង្កើតមជ្ឈមណ្ឌលប្រឆាំងភេរវកម្មប្រចាំតំបន់មួយនៅលើទឹកដីឥណ្ឌូណេស៊ីទៀតផង។ តែឥណ្ឌូណេស៊ីមិនដែលព្រមទេ ពីព្រោះបារម្ភខ្លាចថាបើធ្វើដូចនេះប្រទេសខ្លួនអាចនឹងក្លាយជាសមរភូមិនៃសង្គ្រាមសាសនាDjihad៕

ប្រជាជនឥណ្ឌូណេស៊ីមានចំនួនប្រមាណជាង២៦០លាននាក់ មានជនជាតិភាគតិចចំនួនជាង ៥០០ សហគមន៍ និងនិយាយ២០០ភាសាខុសៗគ្នា។ តែល្អម្យ៉ាង ល្អត្រង់ថា ៨៨%នៃប្រជាជនទាំងស្រុងកាន់សាសនាអ៊ីស្លាមដូចគ្នា។ យ៉ាងណាក៏ដោយ ប្រទេសឥណ្ឌូណេស៊ីមិនអាចគេចផុតពីការបែកហ្បួរគ្នាបានទេ ដោយហេតុតែមានការទាមទារអត្តសញ្ញាណនិងការទាមទារផ្តាច់ទឹកដីដែលបានផ្តើមកើតឡើង តាំងពីឆ្នាំ ១៩៤៥មកម្ល៉េះ។ កាលណោះ ក្រោយពេលដែលជប៉ុនបានចាញ់សង្គ្រាមលោកលើកទីពីរ និងបានដកទ័ពចេញពីអាស៊ីអាគ្នេយ៍ហើយ លោកសូការណូ (Soekarno) បានឆ្លៀតប្រកាសឯករាជ្យនៃប្រទេសឥណ្ឌូណេស៊ី។

ក៏ប៉ុន្តែ ហូឡង់(Hollande) ដែលជាប្រទេសអាណានិគមអ្នកគ្រប់គ្រងឥណ្ឌូណេស៊ី បានប្រឆាំងនឹងទង្វើបែបនេះរបស់លោកសូការណូ ហើយស្រាប់តែបានទៅបំផុសបំផុលជនជាតិភាគតិចដែលរស់នៅតាមបណ្តាខេត្តខណ្ឌនានា ដូចជានៅលើកោះMoluques ឬនៅលើកោះCélèbes ជាដើម ឱ្យងើបបះបោរទាមទារស្វ័យភាព។ មិនតែប៉ុណ្ណោះ កងទ័ពហូឡង់ថែមទាំងបានឆ្លៀតវាយប្រហារទៅលើកងកម្លាំងឥណ្ឌូណេស៊ីនៅ

ខែកក្កដាឆ្នាំ១៩៤៧និងនៅខែធ្នូឆ្នាំ១៩៤៨ទៀតផង។

គេត្រូវរង់ចាំរហូតដល់ខែធ្នូឆ្នាំ១៩៤៩ ទើបឃើញប្រទេសហូឡង់ ដែលត្រូវបានសហរដ្ឋអាមេរិកដាក់សម្ពាធ យល់ព្រមទទួលស្គាល់ឯករាជ្យរបស់ឥណ្ឌូណេស៊ី។ តាំងពីពេលនោះមក ឥណ្ឌូណេស៊ីក៏ក្លាយជាសហព័ន្ធរួមមួយដែលមានរដ្ឋទាំងអស់ចំនួន១៦។

រីឯដែនដីទីម័រខាងកើតវិញ បន្តឋិតនៅក្រោមអាណានិគមរបស់ប្រទេសព័រទុយហ្កាល់(Portugal)តទៅទៀត។ ដូចគ្នាអ៊ីចឹងដែរ ដែនដីនូវែលហ្គីណេ(Nouvelle-Guinée)ខាងលិចបន្តឋិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសហូឡង់តទៅទៀត។

យ៉ាងណាក៏ដោយ ការទាមទារអត្តសញ្ញាណនិងការទាមទារផ្ដាច់ទឹកដីមិនបានរលាយបាត់បង់ទៅវិញឡើយ។ នៅខែមេសាឆ្នាំ១៩៥០ កោះMoluquesបានប្រកាសឯករាជ្យ ជាហេតុបានជំរុញលោកសូការណូឲ្យសម្រេចប្រកាសទុកជាមោឃៈ លក្ខន្តិកសហពន្ធន៍រួមនៃប្រទេសឥណ្ឌូណេស៊ី ហើយបានប្រកាសបង្កើតសាធារណរដ្ឋរួមមួយដាក់ជំនួសវិញនៅខែសីហាឆ្នាំ១៩៥០។

ពេញមួយទសវត្សរ៍ទី៥០ លោកសូការណូបានខ្នះខ្នែងពង្រឹងនិងពង្រីកប្រទេស តាមរយៈការប្រើធម៌ក្ដៅ។ ឧទាហរណ៍ជាក់ស្ដែង នៅខាងក្នុងប្រទេស លោកសូការណូបានប្រើទ័ពបង្ក្រាបចលនាផ្ដាច់ទឹកដីនិយមនៅប៉ែកខាងជើងនៃកោះCélèbes នៅឆ្នាំ១៩៥។ នៅខាងក្រៅប្រទេសវិញ លោកសូការណូបានប្រឹងប្រែងនិយាយលើកតម្កើងគោលគំនិតស្ដីពីការបង្កើតមហាប្រទេសមួយដែលត្រូវច្របាច់បញ្ចូលគ្នាឥណ្ឌូណេស៊ី នូវែលហ្គីណេខាងលិចនិងដែនដីប៉ែកខាងជើងនៃកោះBornéo។ ក្នុងន័យនេះ នៅខែមីនាឆ្នាំ១៩៦២ កងទ័ពជាតិ ឥណ្ឌូណេស៊ីបានចូលកាន់កាប់ដែនដីនូវែលហ្គីណេខាងលិច។

ជម្លោះនេះបានជំរុញអង្គការសហប្រជាជាតិឱ្យធ្វើអន្តរាគមន៍។ អង្គការសហប្រជាជាតិបានគ្រប់គ្រងនូវែលហ្គីណេខាងលិចអស់រយៈពេល៨ខែ រួចហើយបានប្រគល់ដែនដីនេះទៅឲ្យ ឥណ្ឌូណេស៊ី នៅខែឧសភាឆ្នាំ១៩៦៣។ កាលណោះ អ.ស.ហបានតម្រូវឱ្យទីក្រុងហ្សាការតារៀបចំបោះឆ្នោតប្រជាមតិមួយនៅលើទឹកដីនូវែលហ្គីណេខាងលិចនេះឱ្យបានមុនឆ្នាំ១៩៦៩ ដើម្បីសួរយោបល់របស់ពលរដ្ឋនៅទីនោះថា តើចង់បានឯករាជ្យឬចង់បន្តឋិតនៅក្រោមការគ្រប់គ្រងរបស់ឥណ្ឌូណេស៊ី។ តែសម្រេចសម្រួចទៅ លោកសូការណូមិនដែលបានរៀបចំធ្វើប្រជាមតិនោះសោះឡើយ។

គឺនៅក្នុងបរិបទបែបនេះហើយ ដែលនៅក្នុងឆ្នាំ១៩៦៥ ប្រជាជនប៉ាពូនៅនូវែលហ្គីណេខាងលិចបានបង្កើតអង្គការមួយឡើង នោះគឺអង្គការដើម្បីឯករាជ្យនៃប៉ាពូអាស៊ីដែលបានចាប់អាវុធចេញមុខប្រឆាំងនឹងទីក្រុងហ្សាការតា។ ទន្ទឹមនេះ ក្នុងចន្លោះឆ្នាំ១៩៦៣-១៩៦៥ ឥណ្ឌូណេស៊ីរបស់លោកសូការណូត្រូវប្រឈមមុខនឹងម៉ាឡេស៊ី ពីព្រោះប្រទេសទាំងពីរដណ្ដើមគ្នាចង់បានតំបន់ប៉ែកខាងជើងនៃកោះBornéo។នៅទីបំផុត ដែនដីប៉ែកខាងជើងនៃកោះBornéoនេះបានក្លាយជាខេត្តមួយរបស់សហពន្ធន៍រួមម៉ាឡេស៊ី។

នៅឆ្នាំ១៩៦៩ លោកស៊ូហារតូ(Suharto)ដែលបានក្លាយជាប្រធានាធិបតីឥណ្ឌូណេស៊ីនៅឆ្នាំ១៩៦៨ជំនួសលោកសូការណូ បានសម្រេចកែឈ្មោះដែនដីនូវែលហ្គីណេខាងលិចមកជាអ៊ីរីយ៉ាន់ ហ្សាយ៉ា(Irian Jaya)ដែលពីអំណើះតទៅ ជាខេត្តមួយផ្ដាច់មុខរបស់ឥណ្ឌូណេស៊ី។ រីឯតំបន់ប៉ែកខាងកើតនៃកោះនេះវិញទទួលបានឯករាជ្យនៅឆ្នាំ១៩៧៥ ក្រោមឈ្មោះថា រដ្ឋប៉ាពូអាស៊ី-នូវែលហ្គីណេ (Papouasie

Nouvelle-Guinée)។

ក្រោយមកទៀត នៅខែវិច្ឆិកាឆ្នាំ១៩៧៥ប្រទេសព័រទុយហ្គាល់បានសម្រេចលះបង់ចោលអាណានិគមទាំងអស់របស់ខ្លួន ជាហេតុបានជំរុញឲ្យទីម័រខាងកើតប្រកាសឯករាជ្យ។ មួយខែក្រោយមកតែប៉ុណ្ណោះ លោកស៊ូហារតូបានបញ្ជូនកងទ័ពទៅកាន់កាប់ទីម័រខាងកើតហើយបានប្រកាសចាត់ទុកដែនដីនេះថាជាខេត្តមួយរបស់ឥណ្ឌូណេស៊ី។

និយាយរួម គឺការសម្រេចចិត្តរបស់លោកសូការណូក្នុងការផ្លាស់ប្តូរលក្ខន្តិកនៃប្រទេសពីសហពន្ធន័រួមមកជាសាធារណរដ្ឋរួមនៅឆ្នាំ១៩៥០តែម្តង ដែលបានបង្កឱ្យមានការទាមទារផ្តាច់ទឹកដីកាន់តែខ្លាំងឡើងពីសំណាក់ពូជសាសន៍ផ្សេងៗនៅក្នុងប្រទេសឥណ្ឌូណេស៊ី។ សហពន្ធន័រួមគោរពអត្តសញ្ញាណនិងស្វ័យភាពតិចឬច្រើនរបស់ពូជសាសន៍នីមួយ។ ផ្ទុយទៅវិញ សាធារណរដ្ឋរួមប្រើអំណាចផ្តាច់ការ បង្ខំឱ្យទាំងអស់គ្នាដែលជាពូជសាសន៍មិនដូចគ្នា ដែលនិយាយភាសាមិនដូចគ្នា និងដែលកាន់សាសនាមិនដូចគ្នា ទទួលស្គាល់អំណាចរបស់ទីក្រុងហ្សាការតា។

មិនតែប៉ុណ្ណោះ ចាប់ពីឆ្នាំ១៩៥០ទៅ រដ្ឋាភិបាលឥណ្ឌូណេស៊ីថែមទាំងបានជម្លៀសប្រជាជនចេញទាំងបង្ខំពីតំបន់សម្បូណ៌មនុស្សនៅ ទៅដាក់នៅក្នុងតំបន់មិនសូវមានមនុស្សនៅ។ គោលដៅនៃទង្វើបែបនេះគឺនយោបាយ ពីព្រោះរដ្ឋអំណាចទីក្រុងហ្សាការតា ចង់ធ្វើឱ្យពូជសាសន៍ដែលជាអ្នកទាមទារឯករាជ្យក្លាយជាជនជាតិភាគតិចនៅលើទឹកដីនៃដូនតារបស់ពួកគេ។ ជាឧទាហរណ៍ជាក់ស្តែង រដ្ឋអំណាចបានបញ្ជូនប្រជាជនពីហ្សាវ៉ា(Java) ទៅកាន់នូវែលហ្គីណេខាងលិច ដើម្បីធ្វើយ៉ាងណាឲ្យជនជាតិប៉ាពូនៅទីនោះក្លាយជាជនជាតិភាគតិច។ ដូចគ្នាអ៊ីចឹងដែរ ប្រជាជនអ្នកកាន់សាសនាអ៊ីស្លាមត្រូវបានដឹកបញ្ជូនទៅកាន់ប៉ែកខាងត្បូងនៃកោះ Moluques ដើម្បីធ្វើឲ្យអ្នកកាន់គ្រិស្តសាសនានៅទីនោះមានចំនួនតិចជាងអ្នកកាន់សាសនាអ៊ីស្លាម។

នៅដើមសតវត្សរ៍ទី២១ ចលនាផ្តាច់ទឹកដីនិយមដែលស្ថិតនៅក្រោមការគាបសង្កត់អស់ជាច្រើនសិបឆ្នាំ បានងើបក្បាលបះបោរជាថ្មីឡើងវិញ។ មូលហេតុគឺមកពីរបបផ្តាច់ការរបស់លោកស៊ូហារតូដែលកាន់អំណាចតាំងពីឆ្នាំ១៩៦៨មកបានរលំរលាយនៅខែឧសភាឆ្នាំ ១៩៩៨ និងមកពីប្រទេសឥណ្ឌូណេស៊ីបាននិងកំពុងបន្តបោះជំហានបណ្តើរៗទៅរកលទ្ធិប្រជាធិបតេយ្យ។ គឺនៅក្នុងបរិបទថ្មីបែបនេះហើយដែលរដ្ឋអំណាចហ្សាការតាបានបង្ខំចិត្តទទួលស្គាល់ជាលើកទីមួយបង្អស់ឯករាជ្យរបស់ទីម័រខាងកើតនៅខែតុលាឆ្នាំ១៩៩៩៕

ឯករាជ្យទីម័រខាងកើតដែលត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី២០ឧសភាឆ្នាំ២០០២ បានផ្តល់ក្តីសង្ឃឹមមិនតិចឡើយដល់ខេត្តផ្សេងៗទៀតនៃប្រទេសឥណ្ឌូណេស៊ី ខេត្តដែលតាំងពីដើមមកមិនដែលទទួលស្គាល់ឡើយរដ្ឋអំណាចរបស់ទីក្រុងហ្សាការតា។ ខេត្តAceh គឺជាឧទាហរណ៍មួយជាក់ស្តែង។

Aceh ឋិតនៅប៉ែកចុងខាងជើងនៃកោះSumatra។ តាំងពីដើមដំបូងមក ប្រជាជនAcehបានបដិសេធមិនទទួលឡើយការត្រួតត្រារបស់ប្រទេសហូឡង់និងក្រោយមកទៀតបានច្រានចោលដូចគ្នាអំណាចរបស់ទីក្រុងហ្សាការតា។ អ៊ីចឹងហើយ បានជានៅឆ្នាំ១៩៥៣ ខេត្តនេះទាមទារផ្តាច់ទឹកដីនិយមមួយនេះ បានសាកល្បងប្រកាសជាលើកទីមួយបង្អស់ឯករាជ្យរបស់ខ្លួន។ ប៉ុន្តែ រដ្ឋអំណាចឥណ្ឌូណេស៊ីមិនព្រមឲ្យត្រឹមតែស្វ័យភាពបន្តិចបន្តួចនៅលើវិស័យសាសនានិងវប្បធម៌ប៉ុណ្ណោះ។

ដោយហេតុតែមិនសុខចិត្ត ទើបនៅឆ្នាំ១៩៧៦ពួកអ្នកទាមទារឯករាជ្យបានបង្កើតចលនាAcehសេរី

មួយ ហៅកាត់ថាGAM។ ក៏ប៉ុន្តែរហូតដល់ចុងទសវត្សរ៍ទី៩០ ចលនាGAMនេះ មិនដែលងើបក្បាលរួចឡើយ តែងតែត្រូវបានកងទ័ពឥណ្ឌូណេស៊ីវាយបង្ក្រាប។ ការប្រយុទ្ធគ្នារវាងភាគីទាំងពីរបានបណ្ដាលឲ្យមានអ្នកស្លាប់៤ពាន់នាក់ពីឆ្នាំ១៩៨០ដល់ឆ្នាំ១៩៩៩។

នៅឆ្នាំ១៩៩៩ ចលនាGAM ចាប់ផ្ដើមមានថាមពលឡើងវិញដោយសារតែមូលហេតុពីរ។ ទីមួយ គឺមកអំពីរបបផ្ដាច់ការរបស់ស៊ូហារតូ(Suharto)បានរលំរលាយនៅឆ្នាំ១៩៩៨ និងទីពីរ គឺមកអំពីទីក្រុងហ្សាការតាបានបង្ខំចិត្តទទួលស្គាល់ជាលើកទីមួយបង្អស់ឯករាជ្យរបស់ទីម័រខាងកើត ដែលជាហេតុធ្វើឲ្យចលនាGamចង់បានឯករាជ្យដែរ។

យ៉ាងណាក៏ដោយ រដ្ឋាភិបាលថ្មីនៃឥណ្ឌូណេស៊ីប្រជាធិបតេយ្យក្រោយសករាជស៊ូហារតូបន្តសង្កត់សង្កិនមិនឲ្យចលនាGAMទាមទារផ្ដាច់ទឹកដី។ ឧទាហរណ៍ជាក់ស្ដែង នៅឆ្នាំ២០០៣រដ្ឋាភិបាលទីក្រុងហ្សាការតា បានប្រកាសដាក់ខេត្តAcehក្រោមច្បាប់អាជ្ញាសឹក ហើយបានដាក់ពង្រាយទាហាន៤ម៉ឺននាក់នៅក្នុងខេត្តទាំងមូល។ ក៏ប៉ុន្តែ កងកម្លាំងរបស់GAMនៅតែបន្តសកម្មភាពទ័ពព្រៃបានតទៅទៀត ដោយសារតែពួកគេប្រព្រឹត្តរបរធក់ប្លន់តាមសមុទ្រ នៅម្ដុំដែសមុទ្រMalacca និងដោយសារតែមានការគាំទ្រពីសំណាក់ប្រជាជន។ លើកណាក៏ដោយ ប្រជាជននៅក្នុងខេត្តAceh តែងតែធ្វើបាតុកម្មប្រឆាំងនឹងអាជ្ញាធរឥណ្ឌូណេស៊ីក្រោយបន្ទាប់ពីមានការវាយប្រហារម្ដងៗទៅលើចលនាGAM។

នៅទីបំផុត គឺគ្រោះមហន្តរាយធម្មជាតិទេតើដែលបានតម្រូវឲ្យទីក្រុងហ្សាកាតានិងចលនាAcehសេរី GAM ត្រូវរ៉ូវគ្នា។ នៅថ្ងៃទី២៦ធ្នូឆ្នាំ២០០៤ រលកយក្សស៊ូណាមី(tsunami) បានធ្វើឲ្យខ្ទេចខ្ទីអស់រលីងខេត្តមួយចំនួននៅតាមមាត់សមុទ្រនៃបណ្ដាប្រទេសចំនួន១៣ ក្នុងនោះខេត្តAceh នៃប្រទេសឥណ្ឌូណេស៊ីបានទទួលរងខ្លាំងជាងគេ។ នៅក្នុងខេត្តតែមួយនេះ មានអ្នកស្លាប់រហូតដល់ទៅ១៦៨០០០នាក់។ ដោយសារតែមហន្តរាយធម្មជាតិដ៏ធំធេងនេះ ពិភពលោកបានចាប់អារម្មណ៍ខ្លាំងមែនទែនទៅលើអធិករណ៍រវាងទីក្រុងហ្សាការតានិងចលនាAcehសេរី អធិករណ៍ដែលរហូតមកដល់ថ្ងៃដ៏សោកសង្វេគនោះ មតិអន្តរជាតិមិនដែលសូវបានរវីរវល់។

ក្រោយរលកយក្សស៊ូណាមី នៅម្ខាងកងទ័ពឥណ្ឌូណេស៊ីមិនអាចបន្តធ្វើការវាយលុកទៅលើខេត្តមួយដែលខ្ទេចខ្ទីគ្មានសល់អ្វីទៀតទេ និងដែលអង្គការមនុស្សធម៌ជាច្រើនបានចូលមកជួយយកអាសាប្រជាជន។ នៅម្ខាងទៀត ចលនាGAMបានបាត់បង់អស់រលីងសកម្មជន ទីជម្រក និងរចនាសម្ព័ន្ធ។ នៅក្នុងបរិបទបែបនេះ នៅខែកុម្ភៈឆ្នាំ២០០៥ ក្រោមការគាបសង្កត់របស់សហគមន៍អន្តរជាតិ ចលនាAcehសេរីនិងរដ្ឋាភិបាលឥណ្ឌូនេស៊ីបានយល់ព្រមឈប់បាញ់គ្នា ហើយក្រោយមកទៀតបានផ្ដើមកិច្ចចរចានៅប្រទេសហ្វាំងឡង់ (Finlande)។ ក៏ប៉ុន្តែ គេត្រូវរង់ចាំរហូតដល់ខែសីហាឆ្នាំ២០០៥ ទើបឃើញភាគីទាំងពីរសុខចិត្តចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយស្ដីពីស្វ័យភាពធំទូលំទូលាយនៃខេត្តAceh។

នៅតំបន់Irian Jayaវិញ ក៏ដូចគ្នាអ៊ីចឹងដែរ ប្រជាជនទាមទារឯករាជ្យឬក៏ស្វ័យភាពទូលំទូលាយ។ នៅឆ្នាំ២០០១ Irian Jaya ដែលបានទទួលអំណាចខ្លះពីទីក្រុងហ្សាកាតាបានប្រកាសដូរឈ្មោះជាប៉ាពូអាស៊ីខាងលិច។ ក៏ប៉ុន្តែ ក្រោយពីមានឃាតកម្មទៅលើប្រមុខចលនាទាមទារឯករាជ្យនិយមTheys Eluay នៅខែវិច្ឆិកា

រួចមក សុបិនចង់បានឯករាជ្យរបស់ប្រជាជនប៉ាពូអាស៊ីខាងលិចបានរលាយទៅវិញដូចអំបិលត្រូវទឹក។ សព្វថ្ងៃនេះ ការទាមទារឯករាជ្យនៅក្នុងខេត្តនេះ ជាកង្វល់មួយដ៏ធំរបស់រដ្ឋអំណាចនៅហ្សាកាតា៕

**សំណួររំលឹក៖**

១. តើប្រទេសឥណ្ឌូនេស៊ីមានឈ្មោះផ្លូវការអ្វី?
២. តើប្រទេសឥណ្ឌូនេស៊ីមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?
៣. តើប្រទេសឥណ្ឌូនេស៊ីមានប្រជាជនប៉ុន្មានលាននាក់?
៤. តើប្រទេសឥណ្ឌូនេស៊ីមានរបបនយោបាយយ៉ាងដូចម្តេច?
៥. តើប្រធានាធិបតីឥណ្ឌូនេស៊ីមានអាណត្តិប៉ុន្មានឆ្នាំ?
៦. តើវិស័យសេដ្ឋកិច្ចឥណ្ឌូនេស៊ី មានប្រភពចំណូលពីវិស័យអ្វីខ្លះ?
៧. តើដៃគូពាណិជ្ជកម្មសំខាន់របស់ប្រទេសឥណ្ឌូនេស៊ីមានប្រទេសណាខ្លះ?
៨. តើប្រទេសឥណ្ឌូនេស៊ីមានបញ្ហាអ្វីខ្លះ?

## ៤. សហព័ន្ធម៉ាឡេស៊ី





ទង់ជាតិរបស់ប្រទេសម៉ាឡេស៊ីមានន័យថា ទង់ជាតិនៃកិត្តិយសដែលមានទទឹងមួយភាគពីរនៃបណ្តោយ។ ផ្ទៃទង់ឆ្លាសគ្នាដោយពណ៌សនិង ក្រហម មានឆ្នូតចំនួន១៤ឆ្នូត ដែលតំណាងឱ្យការស្មើភាពគ្នានៃរដ្ឋទាំង១៣និងទីក្រុងកូឡាឡាំពួរ។ ផ្នែកជ្រុង មុំខាងឆ្វេងមានព្រះចន្ទចំណិតនិងផ្កាយពណ៌លឿងមានកាំរស្មីចំនួន១៤ ស្ថិតនៅក្នុងផ្ទៃរាងចតុកោណពណ៌ ខៀវ។

- ផ្កាយដែលមានកាំរស្មីចំនួន១៤ តំណាងឱ្យការឯកភាពនៃរដ្ឋទាំង១៤។
- រូបព្រះចន្ទមួយចំណិត តំណាងឱ្យអត្តសញ្ញាណនៃសាសនាឥស្លាម។
- ផ្ទៃពណ៌ខៀវ តំណាងឱ្យការសាមគ្គីគ្នារបស់ប្រជាជននៅក្នុងប្រទេស។
- ពណ៌លឿងរបស់ផ្កាយ តំណាងឱ្យព្រះមហាក្សត្រជាប្រមុខនៃអ្នកដឹកនាំប្រទេស។

**ទីតាំងភូមិសាស្ត្រ**



ប្រទេសម៉ាឡេស៊ីមានផ្ទៃដីទំហំ៣២៩៦១៣គីឡូម៉ែត្រការេ ជាប្រទេសមានផ្ទៃដីធំជាងគេទី៦៦។ ប៉ែកខាងលិចមានព្រំប្រទល់ជាប់នឹងប្រទេសថៃ ខាងកើតជាប់នឹងប្រទេសឥណ្ឌូនេស៊ី និងព្រុយនេ និងប៉ែកខាងត្បូងជាប់នឹងប្រទេសសឹង្ហបុរី។ ប្រទេសនេះក៏មានព្រំដែនទឹកជាប់ជាមួយប្រទេសវៀតណាម ហ្វីលីពីនផងដែរ។

ប្រទេសម៉ាឡេស៊ីចែកជាពីរផ្នែក ដោយសមុទ្រចិនខាងត្បូង គឺឧបទ្វីបម៉ាឡាកា និងកោះបូនេអូ។

**ប្រជាជន**



| | |
|---|---|
| 2017 estimate | 31,533,000[4] (44th) |
| 2010 census | 28,334,135[5] |
| Density | 92/km² (238.3/sq mi) (116th) |

ជនជាតិម៉ាឡេ៥០,១%, ចិន២២,៦% ជនជាតិដើម១១,៨% ឥណ្ឌា៦,៧% និងផ្សេងៗទៀត៨,៨% ។ អ្នកកាន់សាសនាឥស្លាម៦១,៣% ព្រះពុទ្ធ១៩,៨% គ្រឹស្ត៩,២% ហិណ្ឌូ៦,២% និងសាសនាផ្សេងៗទៀត ៣,៤%។

**របបនយោបាយ**

ទម្រង់រដ្ឋាភិបាលរាជានិយមអាស្រ័យធម្មនុញ្ញសហព័ន្ធ។ ប្រមុខរដ្ឋ គឺប្រមុខសហព័ន្ធជាន់ខ្ពស់ប្រមុខរដ្ឋាភិបាល គឺនាយករដ្ឋមន្ត្រី។ ស្ថាប័ននីតិបញ្ញត្តិ មានសភាពីរគឺ សភា និងព្រឹទ្ធសភាសភាតំណាងរាស្ត្រមានសមាជិក២២២រូប ព្រឹទ្ធសភាមានសមាជិក៧០រូប មានអាណត្តិ៥ឆ្នាំ

ប្រទេសម៉ាឡេស៊ីប្រទេសសហព័ន្ធរាជានិយមបោះឆ្នោតអាស្រ័យរដ្ឋធម្មនុញ្ញ។ មហាក្សត្រត្រូវបានគេបោះឆ្នោតជ្រើសរើសមានអាណត្តិប្រាំឆ្នាំ ដោយខ្សែលោហិតមហាក្សត្រគ្រប់គ្រង៩រដ្ឋនៃម៉ាឡេ និងអភិបាលរដ្ឋបួនទៀតមិនចូលរួមបោះឆ្នោតជ្រើសរើសនោះទេ។ តាមលក្ខណៈយល់ព្រមគ្នាមិនផ្លូវការតំណែងផ្លាស់ប្តូរគ្នាម្តងម្នាក់វិលជុំ។

អំណាចស្ថាប័ននីតិបញ្ញត្តិត្រូវបានបែងចែកជាពីរ គឺស្ថាប័ននីតិបញ្ញត្តិសហព័ន្ធ និងរដ្ឋ។ សភាសហព័ន្ធមានពីរ គឺសភា និងព្រឹទ្ធសភា។ សភាមានសមាជិក២២២រូប មានអាណត្តិប្រាំឆ្នាំ និងព្រឹទ្ធសភាចំនួន៧០រូប ក្នុងនោះ ២៦រូបបោះឆ្នោតជ្រើសរើសដោយសភានៃរដ្ឋទាំង១៣ នៅសល់៤៤រូបទៀតតែងតាំងដោយព្រះមហាក្សត្រ តាមការស្នើសុំពីនាយករដ្ឋមន្ត្រី។

នៅតាមរដ្ឋនីមួយៗមានសភាតែមួយ។ រដ្ឋបាលរដ្ឋនីមួយដឹកនាំដោយប្រធានរដ្ឋមន្ត្រី អ្នកដែលជាសមាជិកសភាពីគណៈបក្សមតិភាគច្រើន។ សម្រាប់រដ្ឋដែលដឹកនាំដោយត្រកូលមហាក្សត្រវិញ ជាប្រធានរដ្ឋមន្ត្រីត្រូវ តែងតាំងដោយមានសំណើសុំពីនាយករដ្ឋមន្ត្រី។

អំណាចស្ថាប័ននីតិប្រតិបត្តិស្ថិតក្នុងគណៈរដ្ឋមន្ត្រីដឹកនាំដោយនាយករដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីត្រូវតែជាសមាជិកសភា មានការយល់ព្រមពីព្រះមហាក្សត្រ និងដឹកនាំគណៈបក្សសម្លេងភាគច្រើននៅសភា។ សមាជិកគណៈរដ្ឋមន្ត្រីជ្រើសរើសចេញពីសភាទាំងពីរ។ នាយករដ្ឋមន្ត្រីជាអ្នកដឹកនាំគណៈរដ្ឋមន្ត្រី និងរដ្ឋាភិបាល។

តុលាការកំពុលគឺតុលាការសហព័ន្ធ អមដោយតុលាការឧទ្ធរ និងតុលាការជាន់ខ្ពស់ពីរទៀត។ មួយសម្រាប់ ឧបទ្វីបម៉ាឡេស៊ី និងមួយទៀតសម្រាប់ម៉ាឡេស៊ីខាងកើត។ ម៉ាឡេស៊ីមានតុលាការពិសេសសម្រាប់

ធ្វើ សវនាការប្រឆាំងព្រះរាជា។ មានទោសប្រហារជីវិតសម្រាប់បទឧក្រិដ្ឋធ្ងន់ធ្ងរដូចជា ឃាតកម្ម ភេរវកម្ម គ្រឿងញៀន និងចាប់ជំរិត។ ការស្រឡាញ់ភេទដូចគ្នា គឺជាអំពើខុសច្បាប់។

## ការបែងចែកតំបន់នយោបាយ

ប្រទេសម៉ាឡេស៊ី គឺរដ្ឋសហព័ន្ធមួយដែលមាន១៣រដ្ឋ និងដែនដីសហព័ន្ធបីទៀត។ រដ្ឋនិងដែនដីទាំងនេះ បែកជាពីរតំបន់។ នៅក្នុងតំបន់ឧបទ្វីបម៉ាឡេស៊ីមាន១១រដ្ឋនិងដែនដីសហព័ន្ធពីរ។ នៅម៉ាឡេស៊ីខាងកើតមាន ពីររដ្ឋនិងដែនដីសហព័ន្ធមួយ។ រដ្ឋនីមួយៗចែកទៅជាស្រុក ហើយស្រុកចែកទៅជាmukim។ នៅសាបាស និងសារាវ៉ាក់ ស្រុកចងគ្នាជាក្រុមបង្កើតទៅជាតំបន់។

ការគ្រប់គ្រងរដ្ឋគឺមានការបែងចែករវាងរដ្ឋសហព័ន្ធ និងរដ្ឋបាលរដ្ឋនីមួយៗ ដែលមានអំណាចខុសគ្នា។ រដ្ឋាភិបាលសហព័ន្ធគ្រប់គ្រងដោយផ្ទាល់ទៅលើដែនដីសហព័ន្ធ។ រដ្ឋបាលថ្នាក់ក្រោមគ្រប់គ្រងដោយរដ្ឋអំណាចមូលដ្ឋានដោយរាប់បញ្ចូលទាំងក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សារាជធានី។ ម៉ាឡេស៊ីមាន១៤៨រដ្ឋអំណាចមូលដ្ឋាន ១១ក្រុមប្រឹក្សាក្រុង ៣៣ក្រុមប្រឹក្សារាជធានី និង៩៧ក្រុមប្រឹក្សាស្រុក។

រដ្ឋទាំង១៣របស់ម៉ាឡេស៊ី ដោយផ្អែកលើប្រវត្តិសាស្ត្រនៃរាជាណាចក្រម៉ាឡាយូ រដ្ឋ៩ក្នុងចំណោម ១១ នៅតែ គ្រប់គ្រងដោយគ្រួសាររាជវង្ស។ ព្រះមហាក្សត្របោះឆ្នោតជ្រើសរើសចេញពីក្សត្រគ្រប់គ្រងរដ្ឋទាំង ៩នោះ មានអាណត្តិ៥ឆ្នាំ។ ព្រះមហាក្សត្រតែងតាំងអភិបាលរដ្ឋមានអាណត្តិ៤ឆ្នាំដោយមិនគ្រងរាជ្យ បន្ទាប់ពីពិគ្រោះ យោបល់ជាមួយប្រមុខរដ្ឋមន្ត្រី។ នៅក្នុងរដ្ឋនីមួយៗមានសភាមួយ និងបង្កើតផ្ទាល់ខ្លួន។ រដ្ឋសហព័ន្ធអន្តរាគមន៍នៅក្នុងរដ្ឋខណៈដែលរដ្ឋខ្វះការអភិវឌ្ឍ និងមានជម្លោះប្រេងរវាងរាជវង្សគ្រប់គ្រងរដ្ឋ។

## សេដ្ឋកិច្ច

| GDP (nominal) | 2015 estimate |
|---|---|
| Total | $344.848 billion[6] (35th) |
| Per capita | $10,756[6] (65th) |

ម៉ាឡេស៊ីជាប្រទេសសេដ្ឋកិច្ចសេរី និងជាប្រទេសសេដ្ឋកិច្ចទីផ្សារឧស្សាហកម្មថ្មី។ កំណើនសេដ្ឋកិច្ចប្រចាំ ឆ្នាំ៦,៥%ចាប់តាំងពី១៩៥៧ រហូតដល់ឆ្នាំ២០០៥។ នៅក្នុងឆ្នាំ២០១៥ សេដ្ឋកិច្ចម៉ាឡេស៊ីមានកំណើនចំនួន៦%។ នៅក្នុងឆ្នាំ១៩៩១ អតីតនាយករដ្ឋមន្ត្រីម៉ាឡេស៊ី មាហាជា មូហាមេដ បានបង្កើតទស្សនវិស័យឆ្នាំ ២០២០ ធ្វើប្រទេសម៉ាឡេស៊ីឱ្យក្លាយជាប្រទេសដែលផ្គត់ផ្គង់ឧស្សាហកម្មដោយខ្លួនឯងបាន។

នៅក្នុងអំឡុងឆ្នាំ១៩៧០ សេដ្ឋកិច្ចម៉ាឡេស៊ីពឹងផ្អែកជាសំខាន់ទៅលើវិស័យអាជីវកម្មរ៉ែ និងកសិកម្ម បានប្រែ ឱ្យទៅជាប្រទេសមានសេដ្ឋកិច្ចពឹងផ្អែកលើចំរុះវិស័យវិញ។ ចាប់តាំងពីអំឡុងទសវត្ស១៩៨០ វិស័យឧស្សាហកម្មមានការវិនិយោគខ្ពស់ ដែលបាននាំឱ្យសេដ្ឋកិច្ចប្រទេសកើនឡើង។

ជំនួញអន្តរជាតិ ការសម្របសម្រួលផ្លូវកប៉ាល់តាមច្រកម៉ាឡាកា និងផលិតផលឧស្សាហកម្ម គឺជាកត្តាសំខាន់នៃសេដ្ឋកិច្ចម៉ាឡេស៊ី។ ម៉ាឡេស៊ីជាប្រទេសនាំចេញធនធានធម្មជាតិ និងកសិកម្ម។ បេងកាតផៅ គឺជាវិស័យក្នុងការនាំចេញ។ ប្រទេសម៉ាឡេស៊ីប្រទេសផលិតសំណាបាហាំង ជ័រកៅស៊ូ និងដូចប្រេងច្រើនជាងគេនៅលើលោក។ ផលិតផលឧស្សាហកម្មជះឥទ្ធិពលខ្លាំងទៅសេដ្ឋកិច្ចប្រទេសម៉ាឡេស៊ី។

នៅក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យមានភាពចំរុះក្នុងវិស័យសេដ្ឋកិច្ច និងកាត់បន្ថយទៅលើការពឹងពាក់តែទៅលើការនាំចេញទំនិញ។ រដ្ឋាភិបាលបានធ្វើការជំរុញវិស័យបន្ថែមទៀតលើវិស័យទេសចរណ៍។ ជាលទ្ធផលវិស័យទេសចរណ៍ជាប្រភពចំណូលទី៣នៃសេដ្ឋកិច្ចជាតិ។

## បញ្ហាសំខាន់ៗ

តាំងពីបានទទួលឯករាជ្យពីអង់គ្លេសនៅឆ្នាំ១៩៥៧មក ម៉ាឡេស៊ីបានបង្កើតប្រព័ន្ធ នយោបាយមួយដែលថ្នាក់ដឹកនាំជាបន្តបន្ទាប់នៃប្រទេសអះអាងថា មានមូលដ្ឋាននៅលើConsensus។ មានន័យថា មហិច្ឆតារបស់រដ្ឋអំណាច គឺបង្រួបបង្រួមបណ្តាសហគមន៍និងជាតិសាសន៍ផ្សេងៗនៅក្នុងប្រទេស ដាក់ក្រោមដំបូលនៃចលនានយោបាយចម្រុះតែមួយគត់ នោះគឺBarisan Nationalប្រែថា រណសិរ្សជាតិ។ រណសិរ្សជាតិចង់ទាក់ទាញជាពិសេសសហគមន៍សំខាន់ៗទាំងបីនៃប្រទេស ពោលគឺសហគមន៍ម៉ាឡេ៦០%នៃចំនួនប្រជាជនទាំងស្រុង សហគមន៍ចិន២៥% និងសហគមន៍ឥណ្ឌា៨%។

នៅក្នុងចលនានយោបាយចម្រុះBarisan Nasionalឬរណសិរ្សជាតិនេះ គណបក្សអង្គការឯកភាពជាតិម៉ាឡេ(UMNO)មានឥទ្ធិពលខ្លាំងជាងគេ ពីព្រោះគណបក្សនេះត្រូវបានគាំទ្រដោយសហគមន៍ម៉ាឡេអ្នកកាន់សាសនាអ៊ីស្លាមដែលមានចំនួនច្រើនលើសលុបនៅក្នុង ប្រទេស។ ម្ល៉ោះហើយ គេអាចនិយាយថា តាំងពីឆ្នាំ១៩៥៧មក ប្រទេសម៉ាឡេស៊ីឋិតនៅក្រោមការគ្រប់គ្រងផ្តាច់មុខរបស់គណបក្សអង្គការឯកភាពជាតិម៉ាឡេUMNOនេះតែម្តង។

តាមការពិតនិងនៅលើសាច់ការណ៍ជាក់ស្តែង គ្មានឡើយការបង្រួបបង្រួមគ្នារវាងសហគមន៍នានានៅក្នុងប្រទេសម៉ាឡេស៊ី មានតែការដើរខ្សែលើជាដរាបពីសំណាក់សហគមន៍ម៉ាឡេដែលមានចំនួនច្រើនលើសលប់ទៅលើបណ្តាសហគមន៍នានាដទៃ។ ការរើសអើងនិងនយោបាយលើកស្ទួយតែជនជាតិម៉ាឡេបែបនេះ ថែមទាំងបានបង្កឲ្យមានការប្រយុទ្ធគ្នាជាច្រើនលើកច្រើនសា រវាងសហគមន៍ចិននិងសហគមន៍ម៉ាឡេ និងបាតុកម្មពីសំណាក់ជនជាតិចិនប្រឆាំងនឹងរដ្ឋាភិបាលនៅដើមទសវត្សន៍ទី៧០ទៀតផង។

ការមានប្រៀបផ្តាច់មុខតែឯកឯង អស់រយៈពេលជាងកន្លះសតវត្សរ៍នៃគណបក្សអង្គការឯកភាពជាតិ(UMNO)នៅលើឆាកនយោបាយម៉ាឡេស៊ី បានធ្វើឲ្យរដ្ឋាភិបាលជាបន្តបន្ទាប់គ្នា វេខ្លួនបន្តិចម្តងៗទៅរកអំណាចផ្តាច់ការ។ ជាក់ស្តែងជាងគេ គឺរដ្ឋាភិបាលរបស់ម៉ាហាធីរ(Mahathir) ដែលបានគ្រប់គ្រងប្រទេសពីឆ្នាំ១៩៨១ដល់ឆ្នាំ២០០៣។

នៅក្នុងទសវត្សរ៍ទី៩០ ម៉ាហាធីរបានទាំងតាំងខ្លួនជាអ្នកការពារគោលការណ៍អាស៊ី ឬអ្វីដែលគេហៅថា**អាស៊ីនិយម** និយាយបែបផ្សេងម៉ាហាធីរបានចេញមុខការពារអំណាចផ្តាច់ការភ្លើស្វាង ដើម្បីប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យបែបបស្ចិមលោក។ នៅក្នុងន័យនេះ ម៉ាហាធីរបានប្រើប្រាស់កងទ័ពនិងកងនគរបាល ដើម្បីក្តាប់និងត្រួតត្រាប្រជារាស្ត្រ ដើម្បីពង្រឹងអំណាចរបស់ខ្លួន និងដើម្បីវាយបង្ក្រាបពួកប្រឆាំង។ ឧទាហរណ៍ជាក់ស្តែង គឺការវាយបង្ក្រាបទៅលើបាតុកម្មនៅឆ្នាំ១៩៨៦របស់ពួកមេធាវី ដែលបានទាមទារឲ្យមានការគោរពសិទ្ធិមនុស្ស។ ឧទាហរណ៍ជាក់ស្តែងមួយទៀត គឺការចាប់ខ្លួនអន់វ៉ារ អ៊ីប្រាហ៊ីម(Anwar Ibrahim)ដាក់គុកនៅឆ្នាំ១៩៩៨ អន់វ៉ារ អ៊ីប្រាហ៊ីមដែលជាបុរសខ្លាំងទី២ ជាឧបនាយករដ្ឋមន្ត្រី និងដែលតាមការគ្រោងទៅនឹងត្រូវឡើងស្នងតំណែងនាយករដ្ឋមន្ត្រីពីម៉ាហាធីរទៀតផង។

ពិតមែនតែជាអ្នកកាន់អំណាចផ្ដាច់ការ ម៉ាហាធីរបានកាត់បន្ថយមិនតិចទេភាពក្រីក្រ បានលើកកំពស់ជីវភាពរបស់ប្រជាជនដោយសារតែការលក់ទំនិញចេញទៅក្រៅប្រទេស និងដោយសារតែឧស្សាហកម្មខ្លាំងក្លាដែលបានធ្វើឲ្យកំណើនសេដ្ឋកិច្ចនៃប្រទេសម៉ាឡេស៊ី ឡើងទៅដល់៦%ជាមធ្យមភាគ តាំងពីទសវត្សរ៍ទី៨០ ហូតដល់ឆ្នាំ២០០៨។ ហើយនៅឆ្នាំ២០១២កន្លងទៅនេះ កំណើនសេដ្ឋកិច្ចរបស់ម៉ាឡេស៊ីបានកើនទៅដល់ ៥,៦% ទោះបីជាពិភពលោកត្រូវប្រឈមមុខនឹងវិបត្តិសកលក៏ដោយ។ មុននឹងចាកចេញពីអំណាចនៅខែតុលាឆ្នាំ២០០៣ ម៉ាហាធីរបានជម្រុញអាប់ឌុល្លា អាម៉ាដ បាដាវី (Abdullah Ahmad Badawi) ឲ្យក្លាយជាអ្នកដឹកនាំនៃបក្សអង្គការឯកភាពជាតិម៉ាឡេUNMO ដែលជាឈ្នាន់ជាន់ឡើងទៅធ្វើជានាយករដ្ឋមន្ត្រី។ មួយឆ្នាំក្រោយមក គឺនៅថ្ងៃទី២១មីនាឆ្នាំ២០០៤ ការបោះឆ្នោតបានអនុញ្ញាតឲ្យបាដាវីបន្តជាផ្លូវការតំណែងជានាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី។

ក៏ប៉ុន្តែ តាំងពីឆ្នាំ២០០៧មក លក្ខណៈផ្ដាច់ការនៃរបបនយោបាយម៉ាឡេ បាននិងកំពុងបន្តស្បើយទៅវិញបន្តិចម្ដងៗ គឺហាក់បីដូចជាប្រទេសអាស៊ីអាគ្នេយ៍មួយនេះផ្ដើមឈានជើងចេញពីប្រព័ន្ធអំណាចគណបក្សតែមួយទៅរកប្រព័ន្ធនយោបាយពហុបក្ស។ មានមូលហេតុច្រើនយ៉ាង ដែលអាចពន្យល់ការផ្លាស់ប្ដូរស៊ីជម្រៅបែបនេះ។ ម្យ៉ាង គឺការដោះលែងអន់វ៉ារ អ៊ីប្រាហ៊ីម ឲ្យចេញពីពន្ធនាគារ នៅខែកញ្ញាឆ្នាំ២០០៤ ការដោះលែងដែលបានបើកលទ្ធភាពឲ្យអតីតឧបនាយករដ្ឋមន្ត្រីរូបនេះ ចាប់ផ្ដើមចេញមុខធ្វើជាមេដឹកនាំនៃគណបក្សប្រឆាំង។ ម្យ៉ាងទៀត គឺអសមត្ថភាពរបស់បាដាវី ក្នុងការដឹកនាំគណបក្សអង្គការឯកភាពជាតិម៉ាឡេ និងក្នុងការដឹកនាំរដ្ឋាភិបាល។ អ៊ីចឹងហើយ បានជានៅខែវិច្ឆិកាឆ្នាំ២០០៧ បណ្ដាជនជាង៣០០០០០នាក់បានចុះធ្វើបាតុកម្ម នៅតាមដងផ្លូវនៃទីក្រុងKuala Lumpour។ គឺជាចលនាបាតុកម្មធំជាងគេមួយមិនដែលមានឡើយ នៅប្រទេសម៉ាឡេស៊ី នារយៈពេលជិត២០ឆ្នាំចុងក្រោយនេះ។ នៅខែឧសភាឆ្នាំ២០០៨ មានមហាបាតុកម្មមួយទៀតកើតឡើង នៅក្នុងរដ្ឋធានី។ បណ្ដាបាតុករប្រឆាំងនឹងប្រេងសាំងឡើងថ្លៃ ប្រឆាំងនឹងអសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការប្រយុទ្ធទប់ទល់នឹងអំពើពុករលួយ និងក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធបោះឆ្នោត។ គឺនៅក្នុងបរិបទបែបនេះហើយ ដែលបក្សជំទាស់បានរួបរួមគ្នាជាធ្លុងមួយ ដើម្បីតទល់នឹងគណបក្សអង្គការឯកភាពជាតិម៉ាឡេUNMO នៅពេលបោះឆ្នោតខែមីនាឆ្នាំ២០០៨ ការបោះឆ្នោតដែលបានធ្វើឲ្យអាសនៈ នៅក្នុងរដ្ឋសភារបស់បក្សប្រឆាំងកើនចំនួនពី១៨ទៅ៨២។

ការបោះឆ្នោតខែមីនាឆ្នាំ២០០៨នៅម៉ាឡេស៊ី គឺជារលកយក្សស៊ូណាមីនយោបាយមួយ សម្រាប់គណបក្សអង្គការឯកភាពជាតិម៉ាឡេ ពីព្រោះជាលើកទីមួយបង្អស់គណបក្សមួយនេះដែលកាន់អំណាចផ្ដាច់មុខតែឯកឯងនៅក្នុងប្រទេសតាំងពីឆ្នាំ១៩៥៧មក ទទួលមិនបានអាសនៈចំនួន២ភាគ៣នៅក្នុងរដ្ឋសភានិងអស់មានអំណាចកែប្រែរដ្ឋធម្មនុញ្ញបានស្រេចតែអំពើចិត្តទៀតហើយ។

គឺការផ្លាស់ប្ដូរស៊ីជម្រៅនៅលើឆាកនយោបាយម៉ាឡេស៊ីបែបនេះហើយ ដែលបានជម្រុញឲ្យលោកបាដាវីលះបង់ចោលតំណែងប្រធានបក្សអង្គការឯកភាពជាតិម៉ាឡេនៅខែមីនាឆ្នាំ២០០៨។ នៅថ្ងៃទី២៦មីនាឆ្នាំ២០០៨ បណ្ដាប្រតិភូទាំង២ ៥០០នាក់របស់បក្សក៏បានបោះឆ្នោតតែងតាំងណាហ្ស៊ីប ទុន រ៉ាហ្សាក (Najib Tun Razak) ជាប្រធាន។ ហើយនៅថ្ងៃទី៣មេសាឆ្នាំ២០០៨ដដែលនោះ ណាហ្ស៊ីប ទុន រ៉ាហ្សាក បានក្លាយជាស្វ័យប្រវត្តិ ទៅជានាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី។ តាំងពីពេលនោះមក ណាហ្ស៊ីប ទុន រ៉ាហ្សាក ត្រូវ

ប្រឈមមុខនឹងមេដឹកនាំគណបក្សប្រឆាំងអន់វ៉ារ អ៊ីប្រាហ៊ីម។កាប្រឈមមុខដាក់គ្នាខ្លាំងរវាងណាហ្ស៊ីប ទុន រ៉ាហ្សាកនិងអន់វ៉ារ អ៊ីប្រាហ៊ីម រវាងគណបក្សកាន់អំណាចនិងគណបក្សប្រឆាំងបានប្រព្រឹត្តទៅ នាពេលបោះឆ្នោតខែឧសភាឆ្នាំ២០១៣។ ទោះបីជានៅទីបំផុតជ័យជំនះបានទៅបក្សកាន់អំណាចដូចពេលបោះឆ្នោតមុនៗក៏ដោយ តែលទ្ធផលនៃសម្លេងឆ្នោតបានបង្ហាញនូវការប្រែប្រួលស៊ីជម្រៅនៃទិដ្ឋភាពនយោបាយម៉ាឡេស៊ី និងការផ្លាស់ប្តូរស៊ីជម្រៅនៃចិត្តគំនិតរបស់ប្រជាពលរដ្ឋម៉ាឡេស៊ី។ ពីអំណើះតទៅ សង្គមម៉ាឡេស៊ីត្រូវបានពុះចែកជាពីរសើងស្មើគ្នា៖ នៅម្ខាងអ្នកគាំទ្របក្សប្រឆាំង និងនៅម្ខាងទៀតអ្នកគាំទ្របក្សកាន់អំណាច។ មិនមែនមាននៅម្ខាងជនជាតិម៉ាឡេ និងនៅម្ខាងទៀតអ្នកមានដើមកំណើតជាជាតិសាសន៍ចិន ឥណ្ឌា ឬជាជាតិសាសន៍ដទៃផ្សេង ដូចពេលមុនៗទៀតហើយ។ ពីអំណើះតទៅនៅម៉ាឡេស៊ី អ្នកបោះឆ្នោតឱ្យគណបក្សប្រឆាំងជាយុវជន ជាអ្នករស់នៅទីក្រុង រីឯអ្នកគាំទ្របក្សកាន់អំណាច ជាមនុស្សចាស់ ជាអ្នករស់នៅជនបទ។ ពួកយុវជនទាំងនេះដែលក្នុងខណៈនេះតំណាង១ភាគ៥នៃអ្នកមានសិទ្ធិបោះឆ្នោត និងដែលជាអ្នកនិយមលេងFacebook អាចនឹងធ្វើឱ្យក្រឡាប់ចាក់ឆាកនយោបាយម៉ាឡេស៊ី នាពេលឆាប់ៗខាងមុខ ដោយនឹងអាចបណ្តាលឱ្យគណបក្សកាន់អំណាចតាំងពីឆ្នាំ១៩៥៧មកម្លេះចាញ់ឆ្នោត។

**សំណួរត្រិះរិះ**

១. តើប្រទេសម៉ាឡេស៊ីមានឈ្មោះផ្លូវការអ្វី?

២. តើប្រទេសម៉ាឡេស៊ីមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?

៣. តើប្រទេសម៉ាឡេស៊ីមានប្រជាជនប៉ុន្មានលាននាក់?

៤. តើប្រទេសម៉ាឡេស៊ីមានរបបនយោបាយយ៉ាងដូចម្តេច?

៥. តើនាយករដ្ឋម៉ាឡេស៊ីមានអាណត្តិប៉ុន្មានឆ្នាំ?

៦. តើវិស័យសេដ្ឋកិច្ច ម៉ាឡេស៊ីមានប្រភពចំណូលពីវិស័យអ្វីខ្លះ?

៧. តើដៃគូពាណិជ្ជកម្មសំខាន់របស់ប្រទេសម៉ាឡេស៊ីមានប្រទេសណាខ្លះ?

៨. តើប្រទេសម៉ាឡេស៊ីមានបញ្ហាអ្វីខ្លះ?

## ៥. ប្រទេសប្រ៊ុយណេ





**ឈ្មោះប្រទេស៖** ណេការ៉ា ប្រ៊ុយណេ ដារូសាឡឹម

**ផ្ទៃដី៖** ៥.៧៦៥ គីឡូម៉ែត្រការ៉េ

**រាជធានី៖** បង់ដាសេរីបេហ្គាវ៉ាន់

**រូបិយវត្ថុ៖** ដុល្លារប្រ៊ុយណេ

**ភាសាផ្លូវការ៖** ភាសាម៉ាឡាយូ

**ថ្ងៃបុណ្យឯករាជ្យជាតិ៖** ថ្ងៃទី១ ខែមករា ឆ្នាំ១៩៨៤ (ពីចក្រភពអង់គ្លេស)

ទង់ជាតិបច្ចុប្បន្នរបស់ប្រទេសប៊ុយណេត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ១៩៥៩ ដែលពណ៌ លឿងតំណាងឱ្យរាជវង្ស ពណ៌ខ្មៅនិងពណ៌សតំណាងឱ្យគណៈរដ្ឋមន្ត្រី។ នៅចំកណ្តាលគឺរូបត្រាផែនដី

ប្រកបដោយនិមិត្តសញ្ញា៥យ៉ាងគឺ ទង់ ឆត្រ ស្លាបសត្វបក្សីចំនួន៤ ដៃសងខាង និងរូបព្រះច័ន្ទមួយចំណិត ដែលមានអត្ថន័យដូចតទៅះ

- រូបទង់ និងឆត្រតំណាងឱ្យសម្តេចព្រះរាជាធិបតីជាមេដឹកនាំខ្ពស់បំផុតរបស់ប្រទេស។
- ស្លាបសត្វចំនួន៤ តំណាងឱ្យការការពារយុត្តិធម៌ សេចក្តីស្ងប់សុខ ភាពរីកចម្រើន និងសន្តិសុខរបស់ជាតិ។
- រូបដៃទាំងពីរតំណាងឱ្យតួនាទីរបស់រដ្ឋាភិបាល គឺការលើកកម្ពស់ភាពមានបាន ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍឱ្យបានរីកចម្រើនរុងរឿងជានិរន្តន៍តទៅ។
- រូបព្រះចន្ទមួយចំណិតតំណាងឱ្យសាសនាឥស្លាមជាសាសនារបស់រដ្ឋ មានអក្សរអារ៉ាប់នៅក្នុងរូបព្រះចន្ទ ដែលមានន័យថាជាការគោរពតាមមាគ៌ារបស់ព្រះជាម្ចាស់ជានិច្ច។ នៅផ្នែកខាងក្រោមជារូបផ្ទាំងក្រណាត់ដែលមានសរសេរថា ប្រ៊ុយណេ ជាដែនដីសន្តិភាព។

## ភូមិសាស្ត្រ



កោះបូនេអូ ជាកោះដែលមានទំហំធំលំដាប់ទី៣ នៅក្នុងពិភពលោក ជាកន្លែងទីបរិស្ថានវិទ្យាអេកូឡូស៊ី និងជាប្រភពកំណើតសត្វជាច្រើនប្រភេទដូចជាសត្វអក ឬសត្វឥន្ទ្រីសសមុទ្រចំពុះពណ៌ស។

ប្រទេសប្រ៊ុយណេស្ថិតនៅទិសខាងកើតឆៀងខាងជើងនៃកោះបូនេអូ ដែលមានដែនដីចែកចេញជាពីរផ្នែក




ដោយមានរដ្ឋសារ៉ាវ៉ាក់របស់ម៉ាឡេស៊ី ខណ្ឌត្រង់ចន្លោះកណ្តាល ខាងកើត ខាងលិច និងខាងត្បូងប្រទេសប្រ៊ុយណេជាប់នឹងប្រទេសម៉ាឡេស៊ី ខាងជើងជាប់នឹងសមុទ្រចិនខាងត្បូង។

## ប្រជាជន

ប្រជាជនមានចំនួន៤១៧២០០ ក្នុងខែកក្កដា ឆ្នាំ២០១៥។ ក្នុងឆ្នាំ២០០៤ ជនជាតិផ្សេងៗរស់នៅប្រទេសប្រុយនេរួមមានៈ ម៉ាឡេ៦៦,៣% ចិន១១,២% ជនជាតិដើមភាគតិចបូនេអូ៣,៤% ឥណ្ឌា២,៣% និងផ្សេងៗទៀតមាន១៦,៨%។

សាសនាះ ឥស្លាម៦៤% សាសនាជនជាតិដើមភាគតិច១១% ព្រះពុទ្ធ៩% គ្រិស្ត៨% និងសាសនាដទៃទៀត

## របបនយោបាយ

របបរាជានិយមមានព្រះមហាក្សត្រជាប្រមុខ។ ប្រទេសប្រ៊ុយណេគ្រប់គ្រងដោយរបបរាជានិយម ដែលមានសម្តេចរាជាធិបតីទ្រង់ជាប្រមុខ ជានាយករដ្ឋមន្ត្រី ជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជារដ្ឋមន្ត្រី

ក្រសួងហិរញ្ញវត្ថុ។ គណៈរដ្ឋមន្ត្រីប្រទេសប្រ៊ុយណេចែកចេញជា១២ផ្នែកសំខាន់ៗ ដោយមន្ត្រីរាជការតំណែងធំត្រូវបានតែងតាំងដោយសម្តេចរាជាធិបតី ព្រមទាំងមានខ្សែរាជវង្សកាន់តំណែង នៅបណ្តាក្រសួងផងដែរ។

ប្រទេសប្រ៊ុយណេបែងចែកជាពីរផ្នែក ដោយមានរដ្ឋសារ៉ាវ៉ាក់នៃប្រទេសម៉ាឡេស៊ី នៅត្រង់ចន្លោះកណ្តាល។ ប្រ៊ុយណេបែងចែកតំបន់គ្រប់គ្រងជាបួនខេត្តគឺ បេឡៃ ប្រ៊ុយណេមូអារ៉ា ទូតុង និងតេមប៊ូរ៉ុង។

## សេដ្ឋកិច្ច និងធនធានធម្មជាតិ

| GDP (nominal) | 2015 estimate |
| --- | --- |
| Total | $13.002 billion[6] (111th) |
| Per capita | $30,933[6] (25th) |

សេដ្ឋកិច្ចរបស់ប្រទេសប្រ៊ុយណេជាសេដ្ឋកិច្ចបែបទីផ្សារសេរី នៅក្រោមការគ្រប់គ្រងរបស់រដ្ឋមានទំនិញនាំចេញសំខាន់ គឺប្រេង និងឧស្ម័នធម្មជាតិ។ ប្រ៊ុយណេជាប្រទេសផលិតប្រេងដែលមានទ្រង់ទ្រាយធំលំដាប់ទី៤ នៅតំបន់អាស៊ីអាគ្នេយ៍ បន្ទាប់ពីឥណ្ឌូចិន វៀតណាម និងម៉ាឡេស៊ី និងផលិតឧស្ម័នធម្មជាតិបានច្រើនលំដាប់ទី៤ នៅក្នុងពិភពលោក។ បើទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលប្រ៊ុយណេបានយល់ឃើញថា គួរកាត់បន្ថយការពឹងផ្អែកទៅលើការនាំចេញប្រេង ទើបត្រូវផ្តោតសំខាន់ទៅលើការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍ផងដែរ។

ជនជាតិប្រ៊ុយណេនិយមធ្វើជាមន្ត្រីរាជការ ទើបកម្លាំងពលករដែលធ្វើការក្នុងវិស័យឧស្សាហកម្មសំណង់ភាគច្រើនជាកម្លាំងពលករបរទេស ដែលមកពីប្រទេសជិតខាង។

ក្រោយពីការរកឃើញអណ្តូងប្រេងនៅទីក្រុងស៊ីរៀ នៅក្នុងឆ្នាំ១៩៣២ ប្រ៊ុយណេផលិតប្រេង និងនាំចេញជាច្រើន និងក្លាយជាចំណូលដ៏សំខាន់របស់ប្រទេស។

**ឧស្សាហកម្មសំខាន់៖** ចម្រាញ់ប្រេង និងសំណង់។

**ធនធានធម្មជាតិសំខាន់៖** ប្រេង ឧស្ម័នធម្មជាតិ ឈើម៉ៃសាក់។

**ប្រទេសដៃគូពាណិជ្ជកម្មសំខាន់៖** អង់គ្លេស សហរដ្ឋអាមេរិក សិង្ហបុរី និងម៉ាឡេស៊ី។

**ទំនិញនាំចេញ៖** ប្រេងឆៅ ឧស្ម័នធម្មជាតិ ពីគ្រឿងលៀម និងសម្លៀកបំពាក់។

**ទំនិញនាំចូល៖** គ្រឿងចក្រនិងឧបករណ៍ដឹកជញ្ជូន ផលិតផលឧស្សាហកម្ម អាហារ គីមី។ ប្រទេសនេះមិនអនុញ្ញាតឱ្យនាំចូល ហ្វ៊ីន ផាវ វ៉ាក់សាំងពីប្រទេសតៃវ៉ាន់ អាវុធ និងគ្រាប់កាំភ្លើង ដោយហេតុផលផ្នែកសុខភាព និងសីលធម៌។

## បញ្ហាសំខាន់ៗ

ជារាជានិយមផ្តាច់ការ ព្រុយណេមិនដែលស្គាល់អស្ថិរភាពនយោបាយម្តងណាឡើយ នារយៈពេលជាង៤០ឆ្នាំកន្លងមកនេះ។ មិនតែប៉ុណ្ណោះ ទាំងថ្នាក់ដឹកនាំទាំងប្រជាពលរដ្ឋ ដូចជាស្ពឹក មិនសូវខ្វល់ខ្វាយពីអនាគតកាល ដោយហេតុតែរាជាណាចក្រដ៏តូចមួយនេះរស់ក្នុងភាពរុងរឿង សម្បូរប្រាក់ចាយ ប្រាក់ដែលបានមកពីការលក់ប្រេងកាតនិងឧស្ម័នធម្មជាតិ។ ក៏ប៉ុន្តែអនាគតនៃប្រទេសព្រុយណេ មិនច្បាស់ជាមានភាពត្រចះត្រចង់ទេ។

ព្រុយណេជារាជាណាចក្រដ៏តូចមួយ នៅប៉ែកខាងជើងនៃកោះប័រនេអូ(Bornéo) បានទទួលឯករាជ្យពីប្រទេសអង់គ្លេសនៅឆ្នាំ១៩៨៤ និងឋិតនៅក្រោមការគ្រប់គ្រងជាង៤០ឆ្នាំកន្លងមកហើយ របស់ស៊ុលតង់អាស្សាណាល បូលក្វា(Hassanal Bolkiah) ដែលជាក្សត្រផង ជានាយករដ្ឋមន្ត្រី ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងជារដ្ឋមន្ត្រីក្រសួងការពារជាតិផង។

ផលិតផលដុលក្នុងស្រុករបស់ប្រជាជនព្រុយណេម្នាក់ៗ កើនរហូតដល់ទៅដល់ជិត៤០០០០ដុល្លារក្នុងមួយឆ្នាំ ពោលគឺមានកម្រិតខ្ពស់ជាងគេបង្អស់នៅទូទាំងភូមិភាគអាស៊ីអាគ្នេយ៍។ នេះគឺដោយសារតែព្រុយណេមានប្រជាជនតិច គឺប្រមាណជា៤០ ០០០០នាក់ប៉ុណ្ណោះ និងដោយសារតែទឹកដីព្រុយណេ សម្បូរទៅដោយប្រេងកាតនិងឧស្ម័នធម្មជាតិដែលនាំមកនូវ៩០%នៃប្រាក់ចំណូលប្រចាំឆ្នាំរបស់រដ្ឋ។

ម្ល៉ោះហើយប្រជាជនព្រុយណេ រស់នៅក្នុងភាពរុងរឿង និងក្នុងភាពសុខដុមរមនា ពុំចាំបាច់បង់ពន្ធដារទេ ប្រើប្រាស់ឥណទានគ្មានការប្រាក់សម្រាប់ទិញឡានជិះ ចាក់សាំងដែលមានតម្លៃថោកមែនទែន ទៅរៀន និងព្យាបាលជម្ងឺដោយមិនចាំបាច់បង់ប្រាក់។

គឺនៅក្នុងបរិបទបែបនេះហើយ ដែលស៊ុលតង់អាស្សាណាល បូលក្វាអាចគ្រប់គ្រងប្រទេសបានជាងបួនទសវត្សរ៍កន្លងមកហើយ ដោយគ្មានបក្សជំទាស់ គ្មានសេរីភាពសារព័ត៌មានហើយក៏គ្មានដៃរអ្នកទោសនយោបាយ។ តាំងពីបានឯករាជ្យនៅឆ្នាំ១៩៨៤មក សមាសភាពរបស់រដ្ឋាភិបាលត្រូវបានរុះរើតែម្តងគត់ គឺនៅខែឧសភាឆ្នាំ២០០៥។ កាលណោះ បុត្ររបស់ស៊ុលតង់អាស្សាណាល បូលក្វា បានទទួលតំណែងជា"ឧត្តមរដ្ឋមន្ត្រី"មានឋានៈលំដាប់ទី២នៅក្នុងជួររដ្ឋាភិបាល។

ក៏ប៉ុន្តែប្រជាជនព្រុយណេ មិនអាចបន្តរស់អ៊ីចឹង ក្នុងភាពសម្បូរសប្បាយយូរលង់តទៅមុខបានទេ ពីព្រោះនៅយ៉ាងយូរ២០ឆ្នាំទៀតខាងមុខនេះ អណ្តូងប្រេងកាតទាំងប៉ុន្មាននឹងត្រូវរីងស្ងួត រីឯឧស្ម័នធម្មជាតិវិញក៏នឹងត្រូវអស់រលីងនៅ៣០ឆ្នាំទៀតខាងមុខនេះដែរ។

ដើម្បីត្រៀមខ្លួនប្រឈមមុខនឹងទស្សនវិស័យនៃការអស់ប្រេងកាតនិងអស់ឧស្ម័នធម្មជាតិនេះ ការិយាល័យរបស់ស៊ុលតង់ដែលជាស្ថាប័នក្តាប់អំណាចសឹងទាំងស្រុង បានផ្សព្វផ្សាយជាសាធារណៈ នៅខែមករាឆ្នាំ២០០៨ ផែនការមួយដែលគេប្រសិទ្ធិនាមឲ្យថា «ចក្ខុនិមិត្តសម្រាប់ព្រុយណេ នៅឆ្នាំ២០៣៥»

ផែនការនេះគ្រោងបង្កើត នៅគ្រប់ទីកន្លែងក្នុងប្រទេសសកម្មភាពសេដ្ឋកិច្ចថ្មី ដែលមិនទាក់ទងសោះឡើយទៅនឹងវិស័យថាមពល រួមមានជាអាទិ៍ បច្ចេកវិជ្ជាខាងព័ត៌មានវិទ្យា និងធនាគារ។ ទន្ទឹមនេះ ស៊ុលតង់អាស្សាណាល បូលក្វា ក៏គ្រោងបង្កើនគុណភាពនៃប្រព័ន្ធអប់រំជាតិដែរ ដោយចង់ពង្រីកចំណេះដឹងរបស់អនាគតប្រជាជនសកម្ម ឲ្យចេះបង្កើតនិងដឹកនាំក្រុមហ៊ុនខ្នាតតូចនិងខ្នាតមធ្យម។ ក្រៅពីនេះ ផែនការ«ចក្ខុនិមិត្តសម្រាប់ ឆ្នាំ២០៣៥» ក៏គ្រោងថានឹងលើកស្ទួយវិស័យឧស្សាហកម្មទេសចរណ៍ ឧស្សាហកម្មផលិត Aluminium និងឧស្សាហកម្មផលិតMéthanol ។ល។និង។ល។ ការិយាល័យរបស់ស៊ុលតង់ អាស្សាណាល បូលក្វា ថែមទាំងបានទាំងអះអាងថា ផែនការនេះនឹងធ្វើឲ្យព្រុយណេ អាចចូលទៅក្នុងក្រុមបណ្តាប្រទេសអ្នកមានជាងគេទាំង១០ នៅក្នុងពិភពលោក នៅឆ្នាំ២០៣៥ទៀតផង។ យ៉ាងណាក៏មានតែគំនិតមិនគ្រប់គ្រាន់ទេ ត្រូវចេះអនុវត្តវាថែមទៀត។ ហើយការអនុវត្តន៍ជាក់ស្តែងនឹងច្បាស់ជាប្រទះនឹងបញ្ហាមួយចំនួនសែនស្មុគ

ស្មាញ។ បញ្ហាទីមួយ គឺរចនាសម្ព័ន្ធនៃសេដ្ឋកិច្ចព្រុយណេបច្ចុប្បន្ន រចនាសម្ព័ន្ធសេដ្ឋកិច្ចដែលស្លឹកគ្មានថាមភាព និងគ្មានប្រសិទ្ធិភាព។

ដោយហេតុតែព្រុយណេជាប្រទេសមានស្តុកស្តម្ភ រស់ដោយកម្រៃបានមកពីប្រេងកាតនិង ឧស្ម័ន ៧៥% នៃប្រជាជនសកម្មរបស់ប្រទេសនេះ ជាមន្ត្រីរាជការមិនសូវហ៊ានសរហួនក្នុងការងារ។ មិនតែប៉ុណ្ណោះ រាល់សំណុំរឿងនយោបាយ សេដ្ឋកិច្ចនិងយោធា និងសូម្បីតែការចំណាយរបស់រដ្ឋដែលមានកម្រិតលើសពី២ ៥០០០ដុល្លារឡើងទៅ ត្រូវតែឆ្លងកាត់តាមស៊ុលតង់អាស្សាណាល បូលក្វា ទាំងអស់ ជាហេតុធ្វើឲ្យអភិក្រមនៃសេចក្តីសម្រេចចិត្តប្រើពេលវែងឆ្ងាយនិងអូសបន្លាយយូរ។

ម្ល៉ោះហើយ ដើម្បីប្រឈមមុខនឹងអនាគតកាល ដែលមិនច្បាស់ជាមានភាពត្រចះត្រចង់ ដូចពេលនេះទេ ថ្នាក់ដឹកនាំព្រុយណេ និយាយឲ្យចំស៊ុលតង់ អាស្សាណាល បូលក្វា ត្រូវតែចេះបណ្តុះបណ្តាលពីឥឡូវទៅឲ្យហើយគំនិតផ្តួចផ្តើមនៅក្នុងស្មារតីរបស់ប្រជាជន និងជាពិសេសចេះចែករំលែកអំណាច ពីការិយាល័យរបស់ស៊ុលតង់ទៅឲ្យស្ថាប័ននេះ ឬស្ថាប័ននោះកាន់កាប់ខ្លះ៕

**សំណួរត្រិះរិះ**

១. តើប្រទេសប្រ៊ុយណេមានឈ្មោះផ្លូវការអ្វី?
២. តើប្រទេសប្រ៊ុយណេមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?
៣. តើប្រទេសប្រ៊ុយណេមានប្រជាជនប៉ុន្មានលាននាក់?
៤. តើប្រទេសប្រ៊ុយណេមានរបបនយោបាយយ៉ាងដូចម្តេច?
៥. តើប្រធានាធិបតីប្រ៊ុយណេមានអាណត្តិប៉ុន្មានឆ្នាំ?
៦. តើវិស័យសេដ្ឋកិច្ចប្រ៊ុយណេ មានប្រភពចំណូលពីវិស័យអ្វីខ្លះ?
៧. តើប្រទេសប្រ៊ុយណេមានបញ្ហាអ្វីខ្លះ?

## ៦. ប្រទេសសិង្ហបុរី






**ឈ្មោះប្រទេស៖** សាធារណរដ្ឋសិង្ហបុរី
**ផ្ទៃដីសរុប៖** ៧១៩.១គីឡូម៉ែត្រការ៉េ
**រាជធានី៖** សិង្ហកាពួរ
**រូបិយវត្ថុ៖** ដុល្លារសិង្ហបុរី

ទង់ជាតិសិង្ហបុរីបែងចែកជាពីរឆ្នូតរាងទ្រវែង ដោយមានផ្នែកខាងលើពណ៌ក្រហម និងផ្នែកខាងក្រោមមានពណ៌ ផ្នែកមុំខាងឆ្វេងមានរូបព្រះចន្ទមួយចំណិត និងមានរូបផ្កាយចំនួន៥ដួង នៅរៀងគ្នាជារង្វង់។

- ពណ៌ក្រហម តំណាងឱ្យសាមគ្គីភាពនិងភាពស្មើគ្នា។
- ពណ៌ស តំណាងឱ្យអំពើល្អ និងបរិសុទ្ធ។
- រូបព្រះច័ន្ទមួយចំណិតតំណាងឱភាពរីកចម្រើននៃជាតិ

- ផ្កាយចំនួន៥ដួង តំណាងឱ្យប្រជាធិបតេយ្យ សន្តិភាព ភាពរីកចម្រើន ភាពយុត្តិធម៌ និងសេចក្តីស្មើភាពគ្នា។

**ថ្ងៃឯករាជ្យជាតិ៖** ថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៦៥(ពីសហព័ន្ធម៉ាឡេស៊ី)

**ភាសាជាតិ៖** ភាសាចិនកុកងឺ អង់គ្លេស ម៉ាឡាយូ តាមីល និងភាសាផ្សេងៗទៀត ភាសាផ្លូវការ៖ ចិនកុកងឺ អង់គ្លេស ម៉ាឡាយូ និងតាមីល។ ចូលជាសមាជិកអាស៊ាន៖ ០៨ សីហា ១៩៦៧

## ទីតាំងភូមិសាស្ត្រ



សិង្ហបុរីគឺជាប្រទេសស្ថិតនៅលើកោះ ដែលជាចំណុចកណ្តាលនៃភូមិភាគអាស៊ីអាគ្នេយ៍ នៅត្រង់ប្រទេសម៉ាឡេស៊ី និងប្រទេសឥណ្ឌូនេស៊ីប្រជុំទៅដោយកោះតូចធំជាច្រើន គឺកោះតូចៗចំនួន៦៣ និងកោះធំៗចំនួន៣ គឺកោះភូឡៅតេកុង កោះភូឡៅអ៊ូប៊ិន និងកោះសេនតូសហ្សា។

## ប្រជាជន




តាមការប៉ាន់ស្មាន នៅឆ្នាំ២០១៦ ប្រជាជនសិង្ហបុរីមានចំនួន៥.៦០៧.៣០០នាក់។ ជនជាតិដែលរស់នៅក្នុងប្រទេសសិង្ហបុរីរួមមាន៖ ចិន៧៤,១% ម៉ាឡេ១៣,៤% ឥណ្ឌា៩,២% និងផ្សេងៗទៀត៣,៣%។

សាសនា៖ ព្រះពុទ្ធសាសនា៤២.៥% សាសនាឥស្លាម១៤.៩% សាសនាតៅ៨.៥% សាសនាហិណ្ឌូ៤% សាសនាគ្រិស្តនិកាយកាតូលិក៤.៨% សាសនាគ្រិស្តនិកាយផ្សេងៗទៀត៩.៨% គ្មានសាសនា១៤.៨% និងសាសនាផ្សេងទៀត០.៧%។

## នយោបាយ និងស្ថិរភាព

របបគ្រប់គ្រង៖ របបសាធារណរដ្ឋបែបរដ្ឋសភាមានប្រធានាធិបតីជាប្រមុខ

ប្រទេសសិង្ហបុរីគ្រប់គ្រងដោយរបបសាធារណរដ្ឋបែបរដ្ឋសភា មានប្រធានាធិបតីជាប្រមុខដឹកនាំរដ្ឋាភិបាលដែលតែងតាំងដោយប្រធានាធិបតី។

ប្រធានាធិបតីរបស់ប្រទេសសិង្ហបុរីបច្ចុប្បន្នគឺ លោកជូនីតាន់ យែងយ៉ាំ ជាប្រធានាធិបតីទីប្រាំពីរ ចំណែកនាយករដ្ឋមន្ត្រីគឺលោក លីស៊ាន ឡុង ជាកូនប្រុសច្បងរបស់លោក លីក្វាន់យូ អតីតនាយករដ្ឋមន្ត្រីនៃប្រទេសសិង្ហបុរី។

សិង្ហបុរីបែងចែកតំបន់គ្រប់គ្រងជាប្រាំភូមិភាគ គឺភាគកណ្តាលចែកជា១១ខណ្ឌតូចៗ ជាមជ្ឈមណ្ឌលនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ភាគខាងកើតចែកជា៦ខណ្ឌ ជាទីតាំងនៃព្រលានយន្តហោះអន្តរជាតិសិង្ហបុរីភាគខាងលិចបែងចែកជា១២ខណ្ឌ ជាតំបន់ផ្ទុកទឹកដ៏ធំបំផុតរបស់ប្រទេសសិង្ហបុរី ភាគខាងជើងមាន៨ខណ្ឌ ទីនោះក៏ជាកន្លែងផ្ទុកទឹកសម្រាប់ប្រើប្រាស់ដូចភាគខាងលិចដែរ ឯភាគខាងជើងជាទីតាំងរបស់កងទ័ព។

## សេដ្ឋកិច្ចនិងធនធានធម្មជាតិ

| GDP (nominal) | 2017[3] estimate |
|---|---|
| Total | $311.282 billion (41st) |
| Per capita | $55,252 (10th) |

សិង្ហបុរីជាប្រទេសតូចពុំសូវសម្បូរធនធានធម្មជាតិប៉ុន្មាននោះទេ ហេតុដូច្នេះហើយប្រាក់ចំណូលសំខាន់គឺ បានមកពីពន្ធលើផលចំណូលរបស់ក្រុមហ៊ុនឯកជនផ្សេងៗ ឬមជ្ឈមណ្ឌលពាណិជ្ជកម្ម ដោយជ្រើសរើសរកប្រភេទទំនិញដែលអ្នកប្រើប្រាស់ត្រូវការមកពីកន្លែងផ្សេងៗជាច្រើនមកលក់ក្នុងតម្លៃថោកសមរម្យ។ ប្រាក់ចំណូលសំខាន់មួយទៀតរបស់ប្រទេសសិង្ហបុរីគឺតាមរយៈវិស័យទេសចរណ៍។

ទំនិញឧស្សាហកម្ម ឧស្សាហកម្មទេសចរណ៍

**ប្រទេសជាដៃគូពាណិជ្ជកម្ម**សំខាន់ សហភាពអឺរ៉ុប ចិន សហរដ្ឋអាមេរិក ហុងកុង ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ជប៉ុន តៃវ៉ាន់ កូរ៉េខាងត្បូង និងថៃ។

**ទំនិញនាំចេញ** ជាការនាំចេញបន្តទំនិញផ្សេងៗដូចជា ពីគ្រឿងលៀម (ប្រេងកាតមិនទាន់ចម្រាញ់) ម្ហូបអាហារ ភេសជ្ជៈ ផលិតផលគីមី។

**ទំនិញនាំចូល** ម្ហូបអាហារ និងភេសជ្ជៈ យន្តហោះ ឧបករណ៍អេឡិចត្រូនិច វិទ្យុ ទូរទស្សន៍ និងឧបករណ៍អគ្គិសសនីផ្សេងៗទៀតជាច្រើន។

## បញ្ហាសំខាន់ៗ

យ៉ាងណាមិញ រដ្ឋដ៏តូចមួយនេះ កាន់អំណាចផ្តាច់ការ តែជាអំណាចផ្តាច់ការមួយភ្លឺស្វាង ឲ្យតម្លៃទៅលើយុត្តិធម៌សង្គម សន្តិសុខ ភាពថ្លៃថ្នូរនិងសុភមង្គលរបស់ប្រជាពលរដ្ឋ។

នៅអាស៊ី សិង្ហបុរីជាប្រទេសគំរូមួយ គំរូនៃវឌ្ឍនភាពសេដ្ឋកិច្ច និងគំរូនៃសន្តិសុខ។ ក៏ប៉ុន្តែចំពោះបស្ចិមលោក រដ្ឋដ៏តូចមួយនេះកាន់អំណាចផ្តាច់ការ មិនគោរពសិទ្ធិមនុស្ស មានឈ្មោះជាលទ្ធិប្រជាធិបតេយ្យតែនៅលើក្រដាស។

តាមពិតទៅ តាំងពីឆ្នាំ១៩៦៥មក ឆ្នាំដែលសិង្ហបុរីផ្តាច់ខ្លួនចេញពីសហព័ន្ធរួមម៉ាឡេស៊ី លទ្ធិប្រជាធិបតេយ្យ និងសេរីកម្មនយោបាយ មិនដែលជាអាទិភាពចម្បងរបស់រដ្ឋាភិបាលឡើយ។ សម្រាប់ លី គាន់យូ (Lee Kuan Yew) ដែលជាបិតានៃវឌ្ឍនភាពសិង្ហបុរី និងជានាយករដ្ឋមន្ត្រីពីឆ្នាំ១៩៥៩ដល់ឆ្នាំ១៩៩០ អ្វីដែលសំខាន់ គឺការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សណ្តាប់ធ្នាប់សាធារណៈ។ នៅក្នុងន័យនេះ លី គាន់យូ បានបង្កើតនិងពង្រឹងម៉ាស៊ីនសន្តិសុខមួយ ដើម្បីកាត់បន្ថយទាល់តែអស់រលីង ឥទ្ធិពលនៃពួកប្រឆាំង និងដើម្បីធ្វើឲ្យគណបក្សរបស់លោក គឺបក្សសកម្មភាពប្រជាជន មានអំណាចខ្លាំងផ្តាច់មុខតែឯង នៅលើឆាកនយោបាយនៃប្រទេស។

តាំងពីឆ្នាំ១៩៥៩មក បក្សសកម្មភាពប្រជាជនឈ្នះឆ្នោតរហូត ហើយកាន់កាប់អាសនៈទាំងស្រុងនៅក្នុងសភាពីឆ្នាំ១៩៦៥ដល់ឆ្នាំ១៩៨១។ ដើម្បីឈ្នះឆ្នោត និងដើម្បីក្តាប់អំណាចទាំងស្រុងបាន រដ្ឋាភិបាលរបស់ លី គាន់យូ ប្រើស្នៀតនយោបាយបីយ៉ាង។ ម្យ៉ាងគឺការពុះចែកមណ្ឌលបោះឆ្នោតឡើងវិញ ដើម្បីរំសាយដែនអំណាចរបស់បក្សប្រឆាំង។ ម្យ៉ាងទៀត គឺការប្រើប្រាស់ធនធាននិងស្ថាប័នរដ្ឋ សម្រាប់ប្រយោជន៍នៃគណបក្ស។ ម្យ៉ាងចុងក្រោយបង្អស់ គឺការប្តឹងផ្តល់ឡើងតុលាការ ប្រឆាំងនឹងពួកអ្នកជំទាស់ ក្នុងបទបង្ខូចកេរ្តិ៍ឈ្មោះ។

លើសពីនេះទៅទៀត រដ្ឋាភិបាលរបស់ លី គាន់យូ ក៏ប្រើច្បាប់ ដើម្បីបិទមាត់អ្នកជំទាស់ដែរ នោះគឺច្បាប់ស្តីពីសន្តិសុខផ្ទៃក្នុង។ ច្បាប់នេះអនុញ្ញាតដោយមិនចាំបាច់កាត់ទោស ឱ្យឃុំខ្លួនជនណាក៏ដោយដែលជាប់សង្ស័យថាបង្កវិទ្ធង្សនា និងសកម្មភាពកុម្មុយនិស្ត។ ជាក់ស្តែង នៅមុនពេលបោះឆ្នោតឆ្នាំ១៩៦៨ លី គាន់យូ បានប្រើច្បាប់សន្តិសុខផ្ទៃក្នុងនេះ ដើម្បីរុញច្រានអ្នកដឹកនាំបក្សប្រឆាំងពីនាក់ចេញពីសង្វៀននយោបាយ។ មែនទែនទៅ ច្បាប់នេះ មិនមែនសំដៅ ទៅលើតែអ្នកនយោបាយប៉ុណ្ណោះទេ។ វាក៏ជាសម្ពាធមួយដ៏មានប្រសិទ្ធិភាព ដាក់ទៅលើអ្នកកាសែត អ្នកជំនួញ ឬជនណាក៏ដោយដែលហ៊ានរិះគន់រដ្ឋាភិបាល។

ទោះជាយ៉ាងណាក៏ដោយ មានគណបក្សនយោបាយរហូតទៅដល់ជាង៤០ នៅសិង្ហបុរី។ ក៏ប៉ុន្តែ តាំងពីឆ្នាំ១៩៦៥មក គ្មានបក្សណាមួយ អាចយកឈ្នះឬសង្ឃឹមយកឈ្នះបក្ស សកម្មភាពប្រជាជនរបស់ លី គាន់យូ ឡើយ។ មូលហេតុ គឺមកពីរដ្ឋាភិបាល លី គាន់យូ ក្នុងអតីតកាល និងរដ្ឋាភិបាលនៃកូនប្រុសរបស់គាត់ លី សៀនឡុង (Lee Hsien Long) ក្នុងបច្ចុប្បន្នកាល ក្តាប់សឹងទាំងស្រុង មធ្យោបាយឃោសនាមហាជន។ ទូរទស្សន៍ វិទ្យុ និងកាសែត សុទ្ធសឹងជាកម្មសិទ្ធិរបស់នាយករដ្ឋមន្ត្រី របស់រដ្ឋមន្ត្រី និងរបស់ញាតិមិត្តសណ្តានរបស់អ្នកដឹកនាំប្រទេស។

ម្ល៉ោះហើយ ការនិយាយរិះគន់រដ្ឋាភិបាល អាចចេញមកពីសារពត៌មានបរទេសមួយគត់។ ដូចនេះ រដ្ឋាភិបាលសិង្ហបុរី ធ្វើទុក្ខបុកម្នេញសារពត៌មានបរទេសមិនស្វាងឡើយ។ រដ្ឋសិង្ហបុរីប្តឹងផ្តល់ឡើងតុលាការប្រឆាំងនឹងកាសែតឬទស្សនាវដ្តីបរទេសណាដែលហ៊ានរិះគន់ខ្លួន។ ជាក់ស្តែង សារពត៌មាន Time, Asian Wall Street Journal, Asiaweek, ឬក៏ Far Eastern Economic Review សុទ្ធតែធ្លាប់បានប្រឈមមុខនឹងតុលាការសិង្ហបុរី។ មិនតែប៉ុណ្ណោះ ដើម្បីត្រួតពិនិត្យអត្ថបទនៃអ្នកកាសែតបរទេសទាំងនេះបាន និងដើម្បីស្រួលធ្វើការគាបសង្កត់ រដ្ឋាភិបាលសិង្ហបុរី ទាមទារឲ្យមធ្យោបាយឃោសនាមហាជនបរទេស ដាក់ប្រចាំនៅលើទឹកដីសិង្ហបុរី តំណាងឬអ្នកឆ្លើយឆ្លងពត៌មានម្នាក់យ៉ាងតិច និងដាក់លុយ២០ម៉ឺនដុល្លារប្រចាំទុក នៅក្នុងធនាគារសិង្ហបុរី។ ធ្វើដូចនេះ រដ្ឋាភិបាលសិង្ហបុរីអាចដកហូតយកប្រាក់សងជម្ងឺចិត្តភ្លាមៗ នៅក្រោយការប្តឹងផ្តល់ឈ្នះសារពត៌មានបរទេសទាំងអស់នេះម្តងៗ។

ដោយឡែក ពេលបោះឆ្នោតម្តងៗ រដ្ឋាភិបាលទិញសំឡេងឆ្នោតដោយប្រយោល បានន័យថា រដ្ឋាភិបាលចែកចាយអំណោយឲ្យប្រជាពលរដ្ឋ។ ឧទាហរណ៍នៅឆ្នាំ២០០១ អាជ្ញាធរបានចែកភាគហ៊ុនទីផ្សារហាងឆេងឲ្យដល់ប្រជាពលរដ្ឋ ដែលបាននាំគ្នាទៅដកយកលុយអំណោយនេះ ពីធនាគារ មួយថ្ងៃមុនថ្ងៃបោះឆ្នោត។ លើសពីនេះទៅទៀត គ្មានទេស្ថាប័នឯករាជ្យដើម្បីចាត់ចែងនិងត្រួតពិនិត្យមើលការបោះឆ្នោត។គឺរដ្ឋាភិបាលជាអ្នកចាត់ចែងទាំងអស់។

ម្យ៉ាងវិញទៀត នៅពីក្រោយរដ្ឋាភិបាលដែលប្រសូតចេញពីការបោះឆ្នោតនេះ គឺក្រុមគ្រួសារ លី គាន់យូ តែម្តងដែលជាអ្នកក្តាប់អំណាច។ លី គាន់យូ ដែលជាផ្លូវការបានបោះបង់ចោលមុខតំណែងនាយករដ្ឋមន្ត្រីតាំងពីឆ្នាំ១៩៩០នៅបន្តទាញខ្សែបង្ហៀររដ្ឋាភិបាលតទៅទៀត។ លី សៀនឡុង កូនប្រុសគាត់វិញ ជាបច្ចុប្បន្ននាយករដ្ឋមន្ត្រី។ សមាជិកខ្លះនៃក្រុមគ្រួសាររបស់ លី គាន់យូ ជាប្រធានអគ្គនាយកនៃក្រុមហ៊ុនរដ្ឋធំៗមួយចំនួន ដូចជាក្រុមហ៊ុន Singapour Telecom ជាដើម។

និយាយរួម នៅលើក្រដាស សិង្ហបុរីជាលទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដោយយកគំរូតាមលទ្ធិប្រជាធិបតេយ្យនៃប្រទេសអង់គ្លេស។ ក៏ប៉ុន្តែ ការពិតជាក់ស្តែង រដ្ឋដ៏តូចតែមហារុងរឿងមួយនេះកាន់អំណាចផ្តាច់ការសោះ។

សួរថា ទោះជាគ្មានសេរីភាពនយោបាយ និងគ្មានសិទ្ធិបុគ្គលទូលំទូលាយ តើប្រជាជនសិង្ហបុរី មានសុភមង្គលដែរឬទេ? គេត្រូវដឹងថា ប្រជាពលរដ្ឋសិង្ហបុរីមានកំរិតជីវភាពខ្ពស់សឹងគ្រាន់បើជាងប្រជាជនបស្ចិមលោកទៅទៀត។ សិង្ហបុរីឲ្យតម្លៃទៅលើយុត្តិធម៌សង្គម ត្រូវបានគេទទួលស្គាល់ថា ជាប្រទេសស្អាតស្អំគ្មានអំពើពុករលួយ ជាប្រទេសប្រកបដោយសន្តិសុខខ្ពស់។ ម្ល៉ោះហើយ កម្រមានណាស់អ្នកដែលចង់ចាកចេញពីសិង្ហបុរី ដើម្បីទៅរស់នៅប្រទេសផ្សេង៕

## របបនយោបាយនៃប្រទេសសិង្ហបុរី( ទី៥៧)

សិង្ហបុរី ជាប្រទេសមួយមហារុងរឿង រុងរឿងជាងគេបង្អស់នៅអាស៊ីអាគ្នេយ៍ និងរុងរឿង ជាងបណ្តាប្រទេសបស្ចិមលោកខ្លះទៅទៀត។ យ៉ាងណាមិញ រដ្ឋដ៏តូចមួយនេះកាន់អំណាចផ្តាច់ការ តែជាអំណាចផ្តាច់ការមួយភ្លឺស្វាង ឲ្យតម្លៃទៅលើយុត្តិធម៌សង្គម សន្តិសុខ ភាពថ្លៃថ្នូរនិងសុភមង្គលរបស់ប្រជាពលរដ្ឋ។

នៅអាស៊ី សិង្ហបុរីជាប្រទេសគំរូមួយ គំរូនៃវឌ្ឍនភាពសេដ្ឋកិច្ច និងគំរូនៃសន្តិសុខ។ ក៏ប៉ុន្តែចំពោះបស្ចិមលោក រដ្ឋដ៏តូចមួយនេះកាន់អំណាចផ្តាច់ការ មិនគោរពសិទ្ធិមនុស្ស មានឈ្មោះជាលទ្ធិប្រជាធិបតេយ្យតែនៅលើក្រដាស។

តាមពិតទៅ តាំងពីឆ្នាំ១៩៦៥មក ឆ្នាំដែលសិង្ហបុរីផ្តាច់ខ្លួនចេញពីសហពន្ធន៍ម៉ាឡេស៊ី លទ្ធិប្រជាធិបតេយ្យ និងសេរីកម្មនយោបាយ មិនដែលជាអាទិភាពចម្បងរបស់រដ្ឋាភិបាលឡើយ។ សម្រាប់លី គាន់យូ (Lee Kuan Yew) ដែលជាបិតានៃវឌ្ឍនភាពសិង្ហបុរី និងជានាយករដ្ឋមន្ត្រីពីឆ្នាំ១៩៥៩ដល់ឆ្នាំ១៩៩១ អ្វីដែលសំខាន់ គឺការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សណ្តាប់ធ្នាប់សាធារណៈ។ នៅក្នុងន័យនេះ លី គាន់យូបានបង្កើតនិងពង្រឹងម៉ាស៊ីនសន្តិសុខមួយ ដើម្បីកាត់បន្ថយទាល់តែអស់រលីង ឥទ្ធិពលនៃពួកប្រឆាំង និងដើម្បីធ្វើឲ្យគណបក្សរបស់លោក គឺបក្សសកម្មភាពប្រជាជន(People's Action Party) មានអំណាចខ្លាំងផ្តាច់មុខតែឯងនៅលើឆាកនយោបាយនៃប្រទេស។

តាំងពីឆ្នាំ១៩៥៩មក បក្សសកម្មភាពប្រជាជនឈ្នះឆ្នោតរហូត ហើយថែមទាំងបានកាន់កាប់អាសនៈទាំងស្រុងនៅក្នុងសភាពីឆ្នាំ១៩៦៥ដល់ឆ្នាំ១៩៨១ទៀតផង។ ដើម្បីឈ្នះឆ្នោត និងដើម្បីក្តាប់អំណាចទាំងស្រុងបាន រដ្ឋាភិបាលរបស់លី គាន់យូ ប្រើយុទ្ធសាស្ត្រនយោបាយបីយ៉ាង។ ម្យ៉ាងគឺការពុះចែកមណ្ឌលបោះឆ្នោតឡើងវិញ ដើម្បីរំសាយដែនអំណាចរបស់បក្សប្រឆាំង។ ម្យ៉ាងទៀត គឺការប្រើប្រាស់ធនធាននិងស្ថាប័នរដ្ឋសម្រាប់ប្រយោជន៍នៃគណបក្ស។ ម្យ៉ាងចុងក្រោយបង្អស់ គឺការប្តឹងផ្តល់ឡើងតុលាការ ប្រឆាំងនឹងពួកអ្នកជំទាស់ក្នុងបទបង្ខូចកេរ្តិ៍ឈ្មោះ។

លើសពីនេះទៅទៀត រដ្ឋាភិបាលសិង្ហបុរី ក៏ប្រើច្បាប់ ដើម្បីបិទមាត់អ្នកជំទាស់ដែរ នោះគឺច្បាប់ស្តីពីសន្តិសុខផ្ទៃក្នុង។ ច្បាប់នេះអនុញ្ញាត ដោយមិនចាំបាច់កាត់ទោស ឱ្យឃុំខ្លួនជនណាក៏ដោយដែលជាប់សង្ស័យថាបង្កវិទ្ធង្សនា និងសកម្មភាពកុម្មុយនិស្ត។ ជាក់ស្តែង នៅមុនពេលបោះឆ្នោតឆ្នាំ១៩៦៨ លី គាន់យូបានប្រើច្បាប់សន្តិសុខផ្ទៃក្នុងនេះ ដើម្បីរុញច្រានអ្នកដឹកនាំបក្សប្រឆាំងពីនាក់ចេញពីសង្វៀននយោបាយ។

មែនទែនទៅ ច្បាប់នេះ មិនមែនសំដៅ ទៅលើតែអ្នកនយោបាយប៉ុណ្ណោះទេ។ វាក៏ជាសម្ពាធមួយដ៏មានប្រសិទ្ធិភាព ដាក់ទៅលើអ្នកកាសែត អ្នកជំនួញ ឬជនណាក៏ដោយ ដែលហ៊ានរិះគន់ក្រុមគ្រួសាររបស់ លី គាន់យូ និងប្រព័ន្ធនយោបាយជាសារវន្តរបស់ប្រទេស។

ទោះជាយ៉ាងណាក៏ដោយ មានគណបក្សនយោបាយប្រឆាំងជាច្រើន និងការបោះឆ្នោតជាបន្តបន្ទាប់បួនឬប្រាំឆ្នាំម្តង នៅសិង្ហបុរី។ ក៏ប៉ុន្តែ តាំងពីឆ្នាំ១៩៦៥មក គ្មានបក្សណាមួយ អាចយកឈ្នះឬសង្ឃឹមយកឈ្នះបក្សសកម្មភាពប្រជាជនរបស់ លី គាន់យូបានឡើយ។ មូលហេតុ គឺមកពីរដ្ឋាភិបាលលី គាន់យូ ក្នុងអតីតកាល និងរដ្ឋាភិបាលនៃកូនប្រុសរបស់គាត់ គឺលី សៀនឡុង( Lee Hsien Long ) ក្នុងបច្ចុប្បន្នកាល បំបិទមាត់គណបក្សប្រឆាំងនិងធ្វើទុក្ខបុកម្នេញបណ្តាមេគណបក្សប្រឆាំង។ មិនតែប៉ុណ្ណោះ រដ្ឋអំណាចក្តាប់សឹងទាំងស្រុង មធ្យោបាយឃោសនាមហាជន។ ទូរទស្សន៍ វិទ្យុ និងកាសែត សុទ្ធសឹងជាកម្មសិទ្ធិរបស់នាយករដ្ឋមន្ត្រីរបស់រដ្ឋមន្ត្រី និងរបស់ញាតិមិត្តសន្តានរបស់អ្នកដឹកនាំប្រទេស។

ម្ល៉ោះហើយ ការនិយាយរិះគន់រដ្ឋាភិបាល អាចចេញមកពីសារពត៌មានបរទេសមួយគត់។ ដូចនេះរដ្ឋាភិបាលសិង្ហបុរី ធ្វើទុក្ខបុកម្នេញសារពត៌មានបរទេសឡើយ។ រដ្ឋសិង្ហបុរីប្តឹងផ្តល់ឡើងតុលាការ ប្រឆាំងនឹងកាសែតឬទស្សនាវដ្តីបរទេសណាដែលហ៊ានរិះគន់ខ្លួន ហ៊ានរិះគន់ក្រុមគ្រួសាររបស់លី គាន់យូនិងប្រព័ន្ធនយោបាយជាសារវន្តរបស់ប្រទេស។

ជាក់ស្តែង សារពត៌មាន Time, Asian Wall Street Journal, Asiaweek, ឬក៏ Far Eastern Economic Review សុទ្ធតែធ្លាប់បានប្រឈមមុខនឹងតុលាការសិង្ហបុរី។ មិនតែប៉ុណ្ណោះ ដើម្បីត្រួតពិនិត្យអត្ថបទនៃអ្នកកាសែតបរទេសទាំងនេះបាន និងដើម្បីស្រួលធ្វើការគាបសង្កត់ រដ្ឋាភិបាលសិង្ហបុរី ទាមទារឲ្យមធ្យោបាយឃោសនាមហាជនបរទេស ដាក់ប្រចាំនៅលើទឹកដីសិង្ហបុរី តំណាងឬអ្នកឆ្លើយឆ្លងពត៌មានម្នាក់យ៉ាងតិច និងដាក់លុយច្រើនម៉ឺនដុល្លារប្រចាំទុក នៅក្នុងធនាគារសិង្ហបុរី។ ធ្វើដូចនេះ រដ្ឋាភិបាលសិង្ហបុរីអាចដកហូតយកប្រាក់សងជម្ងឺចិត្តភ្លាមៗ នៅក្រោយការប្តឹងផ្តល់ឈ្នះសារពត៌មានបរទេសទាំងអស់នេះម្តងៗ។

ដោយឡែក ឱ្យតែដល់ពេលបោះឆ្នោតម្តងៗ រដ្ឋាភិបាលទិញសំឡេងឆ្នោតដោយប្រយោល បានន័យថា នៅមុនពេលបោះឆ្នោតម្តងៗ រដ្ឋាភិបាលដ៏ធូធារនៃប្រទេសអាស៊ីមួយនេះតែងតែចាត់វិធានការសេដ្ឋកិច្ចផ្សេងៗ ដើម្បីបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។ លើសពីនេះទៅទៀត គ្មានទេស្ថាប័នឯករាជ្យដើម្បីចាត់ចែងនិងត្រួតពិនិត្យមើលការបោះឆ្នោត។ គឺរដ្ឋាភិបាលជាអ្នកចាត់ចែងទាំងអស់។

នៅពីក្រោយរដ្ឋាភិបាលដែលប្រសូតចេញពីការបោះឆ្នោតម្តងៗ គឺក្រុមគ្រួសារលី គាន់យូតែម្តងដែលជាអ្នកក្តាប់អំណាច។ លី គាន់យូដែលជាផ្លូវការបានបោះបង់ចោលមុខតំណែងនាយករដ្ឋមន្ត្រីតាំងពីឆ្នាំ១៩៩១ និងដែលមានអាយុ៨៩ឆ្នាំទៅហើយនៅបន្តមានឥទ្ធិពលខ្លាំងក្លាទៅលើរដ្ឋាភិបាលតទៅទៀត ក្នុងឋានៈជាSenior Minister និងក្រោយមកទៀតជា Minister Mentor រហូតដល់ឆ្នាំ២០១១។ បានន័យថា យោបល់និងការណែនាំរបស់លី គាន់យូជាការមួយចាំបាច់ សម្រាប់រដ្ឋមន្ត្រីនីមួយៗ។ មិនតែប៉ុណ្ណោះ បណ្តាគណបក្សប្រឆាំងគោរពខ្លាំងណាស់ បិតានៃវឌ្ឍនភាពសិង្ហបុរីរូបនេះ។

រីឯ លី សៀនឡុង កូនប្រុសរបស់លី គាន់យូវិញ ជាបច្ចុប្បន្ននាយករដ្ឋមន្ត្រី។ ដូចគ្នាអ៊ីចឹងដែរ សមាជិកខ្លះនៃក្រុមគ្រួសាររបស់លី គាន់យូ ដឹកនាំក្រុមហ៊ុនរដ្ឋធំៗមួយចំនួន និងមានតួនាទីសំខាន់ៗនៅក្នុងសង្គម

សិង្ហបុរី។

និយាយរួម នៅលើក្រដាស សិង្ហបុរីជាលទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដោយយកគំរូតាមលទ្ធិប្រជាធិបតេយ្យនៃប្រទេសអង់គ្លេស។ ក៏ប៉ុន្តែ ការពិតជាក់ស្តែង រដ្ឋអាស៊ីដ៏តូចមួយនេះ កាន់អំណាចផ្តាច់ការសោះ។ ប៉ុន្តែ រដ្ឋាភិបាលផ្តាច់ការសិង្ហបុរី នៅតែមានប្រជាប្រិយភាពខ្ពស់ ទោះជាបានក្តាប់អំណាចជាង៥០ឆ្នាំកន្លងមកហើយក្តី។ នេះមិនមែនជាការមួយចៃដន្យឡើយ។ ប្រជាប្រិយភាពរបស់រដ្ឋអំណាចអាស៊ីដ៏មហារុងរឿងមួយនេះ មានមូលដ្ឋាននៅលើកត្តាពីរសំខាន់ៗ។

ទីមួយ គឺភាពទៀងត្រង់ បានន័យថា រដ្ឋាភិបាលសិង្ហបុរីជាប្រទេសស្អាតស្អំគ្មានអំពើពុករលួយ និងផ្តល់តម្លៃខ្ពស់ទៅលើយុត្តិធម៌សង្គម។ រីឯកត្តាទីពីរវិញ គឺប្រសិទ្ធភាពសេដ្ឋកិច្ច។

ដោយសារតែចក្ខុនិមិត្តនិងសកម្មភាពនយោបាយរបស់ លី គាន់យូ ក្នុងរយៈពេលជាង៥០ឆ្នាំកន្លងទៅនេះ សិង្ហបុរីបានក្លាយទៅជានាគសេដ្ឋកិច្ចមួយដែលពិភពលោកច្រណែនឬកោតសរសើរ។ ជ័យជំនះដ៏ធំធេងនេះ ដែលបានមកពីអ្វីដែលគេហៅថា ការអភិវឌ្ឍន៍សេដ្ឋកិច្ចបែបផ្តាច់ការ គឺជាលទ្ធផលនៃការបណ្តុះបណ្តាលធនធានមនុស្ស អស់រយៈពេលជាច្រើនទសវត្សរ៍ ក្នុងគោលដៅស្រូបយកចំណេះដឹងនិងចំណេះធ្វើពីបស្ចិមលោក។ សព្វថ្ងៃនេះ សេដ្ឋកិច្ចរបស់សិង្ហបុរីមានមូលដ្ឋាននៅលើឧស្សាហកម្មបច្ចេកវិជ្ជាឈានមុខ ដែលត្រូវបានសាងសង់ឡើង ដោយសារមូលធននិងបទពិសោធន៍របស់ក្រុមហ៊ុនបរទេស អ៊ឺរ៉ុប អាមេរិក ឬជប៉ុន។

ម្ល៉ោះហើយ សួរថា ទោះជាគ្មានសេរីភាពនយោបាយ និងគ្មានសិទ្ធិបុគ្គលទូលំទូលាយ តើប្រជាជនសិង្ហបុរីមានសុភមង្គលដែរឬទេ? គេត្រូវដឹងថា ប្រជាពលរដ្ឋសិង្ហបុរីមានកំរិតជីវភាពខ្ពស់សឹងគ្រាន់បើជាងប្រជាជនបស្ចិមលោកទៅទៀត។ សិង្ហបុរីឲ្យតម្លៃទៅលើយុត្តិធម៌សង្គម ត្រូវបានគេទទួលស្គាល់ថា ជាប្រទេសស្អាតស្អំគ្មានអំពើពុករលួយ ជាប្រទេសប្រកបដោយសន្តិសុខខ្ពស់។ ម្ល៉ោះហើយ កម្រមានណាស់អ្នកដែលចង់ចាកចេញពីសិង្ហបុរី ដើម្បីទៅរស់នៅប្រទេសផ្សេង៕

## សំណួរត្រិះរិះ

១. តើប្រទេសសិង្ហបុរីមានឈ្មោះផ្លូវការអ្វី?
២. តើប្រទេសសិង្ហបុរីមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?
៣. តើប្រទេសសិង្ហបុរីមានប្រជាជនប៉ុន្មានលាននាក់?
៤. តើប្រទេសសិង្ហបុរីមានរបបនយោបាយយ៉ាងដូចម្តេច?
៥. តើវិស័យសេដ្ឋកិច្ចសិង្ហបុរី មានប្រភពចំណូលពីវិស័យអ្វីខ្លះ?
៦. តើប្រទេសសិង្ហបុរីមានបញ្ហាអ្វីខ្លះ?

## ៧. ប្រទេសថៃ





**ឈ្មោះប្រទេស៖** ព្រះរាជាណាចក្រថៃ
**ផ្ទៃដី៖** ៥១៣១២០គីឡូម៉ែត្រការ៉េ
**រាជធានី៖** បាងកក
**ភាសាផ្លូវការ៖** ថៃ
**រូបិយវត្ថុថៃ៖** បាត
**ចូលជាសមាជិកអាស៊ាន៖** ០៨ សីហា ១៩៦៧
**ថ្ងៃឯករាជ្យជាតិ៖** ១២៣៨ មិនដែលស្ថិតនៅក្រោមអាណានិគមប្រទេសណាឡើយ

ទង់មានឈ្មោះថាត្រៃរង្គ មាន៣ពណ៌គឺ

- ពណ៌ក្រហម តំណាងឱ្យជាតិ និងសាមគ្គីភាពរបស់ជនរួមជាតិ
- ពណ៌ស តំណាងឱ្យសាសនាជាមាគ៌ាអប់រំទូន្មានចិត្តឱ្យបរិសុទ្ធ
- ពណ៌ខៀវ តំណាងឱ្យព្រះមហាក្សត្រជាប្រមុខរដ្ឋរបស់ប្រទេសជាតិ

### ទីតាំងភូមិសាស្ត្រ

ដែនដីប្រទេសថៃមានលក្ខណៈស្រដៀងគ្នានឹងពូថៅ ស្ថិតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ត្រង់ចន្លោះឧបទ្វីបឥណ្ឌូចិន និងឧបទ្វីបម៉ាឡាយូ។ ខាងកើតជាប់នឹងប្រទេសឡាវ និងកម្ពុជា ខាងលិចជាប់នឹងប្រទេស មីយ៉ាន់ម៉ា និងសមុទ្រអាន់ដាម៉ាន់ ខាងជើងជាប់ប្រទេសមីយ៉ាន់ម៉ា និងឡាវ ខាងត្បូងជាប់ប្រទេសម៉ាឡេស៊ី និងឈូងសមុទ្រថៃ។




### ប្រជាជន

តាមការប៉ាន់ប្រមាណក្នុងឆ្នាំ២០១៥ ចំនួនប្រជាជនសរុបមាន៖ ៦៧ ៩៥៩ ០០០ នាក់។ ជំរឿនឆ្នាំ២០១០ ប្រជាជនសរុបមានចំនួន៦៤ ៧៨៥ ៩០៩នាក់។ ជនជាតិដែលរស់ប្រទេសថៃរួមមានៈជនជាតិថៃកណ្តាល៣៤,១% ខុនអ៊ីសាន២៤,៩ ខុនមាំង៩,៩% ថៃភាគខាងត្បូង៧,៥% ចិន១៤% ឥស្លាម៥,៥% ជនជាតិផ្សេងៗទៀតមានម៉ាឡេ មន ខ្មែរ និងជនជាតិដើម១២%។

សាសនា៖ ព្រះពុទ្ធសាសនា៩៣,២% សាសនាឥស្លាម៥,៥% សាសនាគ្រិស្ត០,៩% ហិនឌូ០,១% គ្មានសាសនា០,៣%។

### របបនយោបាយ

របបការគ្រប់គ្រង៖ លទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានព្រះមហាក្សត្រជាប្រមុខ។ ប្រទេសថៃគ្រប់គ្រងតាមបែបរាជានិយមជារៀងរហូតមក បើទោះបីជាផ្លាស់ប្តូរពីរបបរាជានិយមមកជារបបរាជាលទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនៅក្នុងឆ្នាំ១៩៣២ក៏ដោយ ក៏នៅតែមានស្ថាប័នព្រះមហាក្សត្រទ្រង់ជាម្លប់ដ៏ត្រជាក់ និងជាប្រមុខនៃប្រជានុរាស្ត្រដែរ។

ការគ្រប់គ្រងប្រទេសចែកជាស្ថាប័ននីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ។ ស្ថាប័ននីតិប្រតិបត្តិគឺគណៈរដ្ឋមន្ត្រី ស្ថាប័ននីតិបញ្ញត្តិគឺសភាដែលចែកចេញជារដ្ឋសភា និងព្រឹទ្ធសភា ចំណែកស្ថាប័នតុលាការ គឺតុលាការដើម្បីភាពយុត្តិធម៌។

ការបែងចែកតំបន់នយោបាយ៖ ប្រទេសថៃមាន៧៦ខេ មាន៥តំបន់ និងមានតំបន់គ្រប់គ្រងពិសេសពីរ គឺទីក្រុងបាងកក និងប៉ាតាយា។ នៅក្នុងឆ្នាំ២០០៦ ប្រទេសថៃមាន៨៧៧ស្រុក និង៥០ខណ្ឌក្នុងទីក្រុងបាងកក។

## សេដ្ឋកិច្ច

| GDP (nominal) | 2016 estimate |
|---|---|
| Total | $409.724 billion[10] |
| Per capita | $5,938[10] |

សេដ្ឋកិច្ចរបស់ប្រទេសថៃគឺជាសេដ្ឋកិច្ចបែបទីផ្សារសេរី ដែលរីកលូតលាស់តាមរយៈវិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យឧស្សាហកម្មនាំចេញយានយន្ត និងគ្រឿងអេឡិចត្រូនិច។ កាលពីអតីត សេដ្ឋកិច្ចរបស់ប្រទេសថៃមានការរីកលូតលាស់ជាខ្លាំង ស្ទើរតែជាលំដាប់កូនខ្លាទី៥នៃតំបន់អាស៊ីទៅហើយ ប៉ុន្តែដោយសារវិបត្តិហិរញ្ញវត្ថុក្នុងឆ្នាំ១៩៩៧ ធ្វើឱ្យសេដ្ឋកិច្ចរបស់ថៃមានការធ្លាក់ចុះ ទោះបីជាបានងើបឡើងវិញក្នុងរយៈពេលក្រោយមកក៏ដោយ ប៉ុន្តែដោយសារភាពជាប់គាំងនយោបាយផ្ទៃក្នុង ព្រមទាំងគ្រោះធម្មជាតិដែលជាឧបសគ្គសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**ឧស្សាហកម្មសំខាន់** ផលិតយានយន្ត គ្រឿងអេឡិចត្រូនិច វាយនភណ្ឌ ម្ហូបអាហារ និងទេសចរណ៍។

**ផលិតផលកសិកម្មសំខាន់** អង្ករ កាស៊ូ ពោត ដូង សណ្តែកសៀង។

**ធនធានធម្មជាតិ** សំណប៉ាហាំង ទង់ដែង ឧស្ម័នធម្មជាតិ ព្រៃឈើ ម្នាងសិលា។

**ប្រទេសដៃគូពាណិជ្ជកម្ម** ប្រទេសចិន ជប៉ុន សហរដ្ឋអាមេរិក ម៉ាឡេស៊ី និងសិង្ហបុរី។

**ទំនិញនាំចេញ** កុំព្យូទ័រ ឧបករណ៍ និងគ្រឿងបន្លាស់អេឡិចត្រូនិច គ្រឿងអលង្កា រតនវត្ថុ និងរថយន្ត។

**ទំនិញនាំចូល** ប្រេងឆៅ គ្រឿងចក្រ គ្រឿងបន្លាស់ ឧបករណ៍អគ្គិសនី និងដែក។

## បញ្ហាសំខាន់ៗ

### ទ័ពព្រៃអ៊ីស្លាមជ្រុលនិយមនៅប្រទេសថៃ(ទី៥)

តាំងពីឆ្នាំ២០០៤មក ភេរវកម្មនិងឃាតកម្មកើតឡើងសឹងមិនលស់ថ្ងៃ នៅតំបន់ប៉ែកខាងត្បូងនៃប្រទេសថៃ។ មកទល់ឥឡូវ គេនៅមិនទាន់ស្គាល់ឈ្មោះអង្គការភេរវកម្មដែលបង្កហិង្សានិងមូលហេតុពិតប្រាកដនៃអំពើសាហាវយង់ឃ្នងទាំងនេះទេ។ ម្ល៉ោះហើយបានជារដ្ឋាភិបាលថៃនិងសហរដ្ឋអាមេរិកព្រួយបារម្ភខ្លាំងឡើងៗ។

ថៃជាប្រទេសកាន់ព្រះពុទ្ធសាសនា ក៏ប៉ុន្តែមានខេត្តចំនួនបីដែលប្រជាជនភាគច្រើន ជាអ្នកកាន់សាសនាអ៊ីស្លាម គឺណារ៉ាធីវ៉ាត(Narathiwat) ប៉ាត់តានី(Pattani) និងយ៉ាឡា(Yala)។ តាំងពីឆ្នាំ២០០៤មក ខេត្តទាំងបីនេះដែលឋិតនៅប៉ែកខាងត្បូងនៃប្រទេស ជួបប្រទះនឹងអំពើហិង្សាបង្កឡើងដោយពួកអ៊ីស្លាមជ្រុលនិយម។ ដើមដំបូងបង្អស់ នៅខែមករាឆ្នាំ២០០៤ពួកគេបានវាយប្រហារទៅលើបន្ទាយទាហាន និងប៉ុស្តិ៍

ប៉ូលិសនៅណារ៉ាធីវ៉ាត។ ជាការឆ្លើយតបវិញ រដ្ឋាភិបាលទីក្រុងបាងកកដែលកាលណោះដឹកនាំដោយលោកថាក់ស៊ីន(Thaksin) បានប្រកាសដាក់តំបន់ប៉ែកខាងត្បូងនៅក្រោមច្បាប់អាជ្ញាសឹក។

ក្រោយមកទៀត នៅខែមេសាឆ្នាំ២០០៤ដដែលនោះ ពួកអ៊ីស្លាមជ្រុលនិយមជាច្រើនរយនាក់ អ្នកខ្លះប្រដាប់ដោយកាំភ្លើង អ្នកខ្លះទៀតប្រដាប់ដោយខ្មៅរកាំបិតនិងពូថៅ បានវាយប្រហារជាថ្មីទៅលើបន្ទាយទាហាន និងស្នងការដ្ឋានប៉ូលិស។ នៅក្នុងការប្រយុទ្ធគ្នានោះ ពួកអ៊ីស្លាមជ្រុលនិយមជាងមួយរយនាក់បានបាត់បង់ជីវិត។ ពេលនោះហើយ គឺជាពេលចាប់ផ្ដើមឡើងនៃសកម្មភាពទ័ពព្រៃដែលមានបន្តមកទល់សព្វថ្ងៃ។

រហូតមកដល់ថ្ងៃនេះ គេនៅតែរកមិនឃើញឡើយមូលហេតុពិតប្រាកដ ដែលបានជំរុញឲ្យប្រជាជនថៃអ៊ីស្លាមងើបបះបោរប្រឆាំងនឹងអាជ្ញាធរថៃនៅដើមឆ្នាំ២០០៤នោះ។ ក្រុមអ្នកសង្កេតការណ៍ខ្លះអះអាងថា អ្នកដែលបានបង្កហេតុមុនគេគឺទាហានថៃ មិនមែនពួកថៃអ៊ីស្លាមដូចគេថានោះទេ។ ពួកក្រុមអ្នកសង្កេតការណ៍ទាំងនោះពន្យល់ថា អំពើហិង្សាបានកើតឡើងតែប៉ុន្មានសប្ដាហ៍ប៉ុណ្ណោះ ក្រោយពីលោកនាយករដ្ឋមន្ត្រីថាក់ស៊ីនបានដកតួនាទីគ្រប់គ្រងសន្តិសុខខេត្តណារ៉ាធីវ៉ាត ប៉ាត់តានី និងយ៉ាឡាពីដៃកងទ័ព និងបានប្រគល់សមត្ថកិច្ចនេះទៅឲ្យប៉ូលិសក្ដាប់វិញ។ យោងទៅតាមក្រុមអ្នកសង្កេតការណ៍ដដែលទាំងនោះ សេចក្ដីសម្រេចចិត្តបែបនេះរបស់លោកថាក់ស៊ីន បានធ្វើឲ្យពួកនាយទាហានថៃខ្លះបាត់បង់កន្លែងខ្លាញ់ និងបាត់បង់កម្រៃដែលបានមកពីសកម្មភាពមិនស្របច្បាប់ ដូចជាពេស្យាចារនិងការរត់ពន្ធគ្រឿងញៀនជាដើម ហើយបានជំរុញឲ្យពួកនាយទាហានថៃទាំងនោះបង្កហេតុ បញ្ឆេះកំហឹងរបស់ពួកថៃអ៊ីស្លាមដែលរស់នៅក្នុងខេត្តប៉ែកខាងត្បូងទាំងបី។

ក្រុមអ្នកសង្កេតការណ៍ខ្លះទៀតយល់ឃើញថាអង្គការភេរវកម្ម*Jamaah Islamiyah* បានចូលទៅអុជអាលឲ្យប្រជាជនថៃអ៊ីស្លាមបះបោរទាមទារឯករាជ្យ និងផ្ដាច់ដែនដីប៉ែកខាងត្បូងនៃប្រទេសថៃចេញពីការត្រួតត្រារបស់ទីក្រុងបាងកក។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងដែនដីប៉ែកខាងត្បូងប្រទេសថៃដែលជាប់ព្រំប្រទល់ជាមួយប្រទេសម៉ាឡេស៊ី តែងតែមានអំពើហិង្សាកើតឡើងយូរៗម្ដងតាំងពីឆ្នាំ១៩០៩មកម្ល៉េះ។ ក៏ប៉ុន្តែ អំពើហិង្សានៅទីនោះមិនដែលមានលក្ខណៈធំធេងនិងបន្តយូរអង្វែង ដូចពេលនេះទេ។ គួរគូសបញ្ជាក់ថា តាំងពីឆ្នាំ២០០៤មកទល់ឥឡូវ សកម្មភាពទ័ពព្រៃរបស់ពួកអ៊ីស្លាមជ្រុលនិយមនៅប្រទេសថៃ បានបណ្ដាលឲ្យមានអ្នកស្លាប់ប្រមាណ៤ ៨០០នាក់ហើយ។

តាំងពីឆ្នាំ២០០៥មក ពួកថៃអ៊ីស្លាមជ្រុលនិយមបានប្ដូរយុទ្ធសាស្ត្រ មិនសូវសម្លាប់តំណាងអាជ្ញាធរប៉ូលិសឬទាហានដូចមុនទៀតទេ តែវាយប្រហារទៅលើលោកសង្ឃ គ្រូបង្រៀនឬពុទ្ធបរិស័ទវិញម្ដង។ ម្យ៉ាងទៀត អ្វីដែលធ្វើឲ្យរដ្ឋាភិបាលថៃបារម្ភ គឺអំពើហិង្សាអាចនឹងរាលដាលចេញពីខេត្តអ៊ីស្លាមទាំងបីចូលទៅដល់តំបន់ផ្សេងៗ និងចូលទៅដល់ទីក្រុងបាងកកតែម្ដង។ ឧទាហរណ៍ជាក់ស្ដែង នៅខែមករាឆ្នាំ២០០៧ ភេរវកម្មបំផ្ទុះគ្រាប់បែកប្រាំបីកន្លែងសឹងផ្ទួនៗគ្នា ត្រូវបានបង្កឡើងនៅកណ្ដាលទីក្រុងបាងកកទៀតផង។ កាលណោះក្រុមនាយទាហានដែលបានធ្វើរដ្ឋប្រហារទម្លាក់លោកថាក់ស៊ីនបានចោទថា បក្សពួករបស់លោកថាក់ស៊ីនជាអ្នកនៅពីក្រោយភេរវកម្មទាំងអស់នោះ។

ក៏ប៉ុន្តែកាលណោះ ក្រុមអ្នកសង្កេតការណ៍ខ្លះបាននិយាយថា ភេរវកម្មនៅទីក្រុងបាងកកទាំងអស់នោះអាចជាស្នាដៃរបស់ពួកថៃអ៊ីស្លាមជ្រុលនិយម ដែលចាប់ពីពេលនេះទៅមានបណ្ដាញធំនិងមាំជាងមុន

ហូតដល់មានលទ្ធភាពចូលមកបង្កភេរវកម្មក្នុងកណ្តាលរាជធានីថៃតែម្តង។

មកទល់ឥឡូវ គេនៅតែពិបាកវិភាគណាស់ទៅលើបាតុភាពទំពព្រៃអ៊ីស្លាមជ្រុលនិយមនៅប៉ែកខាងត្បូងនៃប្រទេសថៃ ពីព្រោះ គេមិនដែលស្គាល់ឈ្មោះក្រុមភេរវជនឬអង្គការភេរវកម្ម ដែលបាននិងកំពុងបង្កអំពើហិង្សានៅទីនោះទេ។ តាមមើលទៅ គោលដៅរបស់ពួកថៃអ៊ីស្លាមជ្រុលនិយមគឺពង្រីកបញ្ហា ឲ្យមានលក្ខណៈជាបញ្ហាតំបន់ឬអន្តរជាតិ និងបង្ខំឲ្យរដ្ឋាភិបាលថៃប្រើអំពើហិង្សាឆ្លើយតបទៅនឹងអំពើហិង្សារបស់ពួកគេវិញ ធ្វើយ៉ាងណាដើម្បីឲ្យតំបន់ប៉ែកខាងត្បូងនៃប្រទេសថៃក្លាយជាសមរភូមិមួយថ្មីនៃសង្គ្រាមសាសនាDjihad។

សហរដ្ឋអាមេរិកក៏កំពុងបារម្ភខ្លាំងណាស់ដែរ បារម្ភខ្លាចខេត្តអ៊ីស្លាមទាំងបីនៅខាងត្បូងប្រទេសថៃក្លាយជាទីកន្លែងមួយថ្មីនៃDjihadអន្តរជាតិ ក្លាយជាទីកន្លែងថ្មីនៃជំរំបង្ហាត់ហ្វឹកហ្វឺនរបស់ពួកភេរវជនអ៊ីស្លាមជ្រុលនិយមអន្តរជាតិ។ កាលពីប៉ុន្មានឆ្នាំមុន ទីក្រុងវ៉ាស៊ីនតោនថែមទាំងបានស្នើម្តងហើយម្តងទៀតឲ្យប្រទេសថៃយល់ព្រមទទួលកងទ័ពអាមេរិកាំងនៅលើទឹកដីខ្លួន។ តែរដ្ឋាភិបាលថៃមិនព្រម ខ្លាចក្រែងវត្តមានទាហានអាមេរិកាំងទាក់ទាញពួកភេរវជនអ៊ីស្លាមជ្រុលនិយមអន្តរជាតិឲ្យចូលមកក្នុងទឹកដីថៃច្រើនឡើងៗ។

ត្រង់ចំណុចនេះ នៅពាក់កណ្តាលខែមករាឆ្នាំ២០១២នេះ ប៉ុន្មានថ្ងៃប៉ុណ្ណោះក្រោយពីស្ថានទូតអាមេរិកាំងនៅថៃ បានទាញសញ្ញាអាសន្នប្រកាសប្រាប់ថា ភេរវជនមកពីប្រទេសក្រៅត្រៀមវាយប្រហារទៅលើពួកទេសចរបរទេសនៅបាងកក អាជ្ញាធរថៃបានចាប់ខ្លួនជនជាតិលីបង់ម្នាក់។ សម្រាប់ទីក្រុងបាងកក ជនជាតិលីបង់រូបនោះជាសកម្មជនរបស់Hezbollah ដែលជាសត្រូវរបស់អ៊ីស្រាអែលនិងរបស់សហរដ្ឋអាមេរិក។

ម្ល៉ោះហើយមិនយូរមិនឆាប់ ថៃអាចនឹងក្លាយជាផ្ទាំងស៊ីបរបស់ពួកភេរវជនអ៊ីស្លាមជ្រុលនិយមអន្តរជាតិ ពីព្រោះម្យ៉ាង ប៉ែកខាងត្បូងនៃប្រទេសនេះជាសម្បុកនៃពួកថៃអ៊ីស្លាមជ្រុលនិយមអស់រយៈពេលប្រាំបីឆ្នាំកន្លងមកហើយ។ ពីព្រោះម្យ៉ាងទៀត ប្រទេសនេះជាសម្ព័ន្ធមិត្តចាក់ទឹកមិនលិចរបស់សហរដ្ឋអាមេរិក។ និងពីព្រោះម្យ៉ាងចុងក្រោយ ថៃជាប្រទេសពេញនិយមរបស់ពួកទេសចរលោកខាងលិចដែលពួកភេរវជនអ៊ីស្លាមនិយមជ្រុលស្អប់ខ្ពើម៕

## ប្រទេសថៃ៖ យោធា ព្រះមហាក្សត្រ និងលទ្ធិប្រជាធិបតេយ្យ (ទី១៥)

នៅលើក្រដាស ថៃជាប្រទេសប្រជាធិបតេយ្យ តាំងពីឆ្នាំ១៩៣៣ មកម៉្លេះ។ ក៏ប៉ុន្តែ នៅលើសាច់ការជាក់ស្តែងវិញ ប្រទេសនេះតែងតែឋិតនៅក្រោមការដឹកនាំរបស់យោធា។ ទោះជាបានប្រសូតចេញពីការបោះឆ្នោតក៏ដោយ គ្រប់រដ្ឋាភិបាលស៊ីវិលសុទ្ធតែឋិតនៅក្រោមការគំរាមកំហែងធ្វើរដ្ឋប្រហារពីសំណាក់យោធានិងសុទ្ធតែឋិតនៅក្រោមឥទ្ធិពលដ៏ខ្លាំងជ្រុលរបស់ព្រះបរមរាជវាំង។ រាប់ទាំងរដ្ឋប្រហារថ្ងៃទី១៩កញ្ញាឆ្នាំ២០០៦ ដែលបានទម្លាក់លោកថាក់ ស៊ីន(Thaksin)ចេញពីតំណែងនាយករដ្ឋមន្ត្រី ប្រទេសថៃបានស្គាល់រដ្ឋប្រហារយោធាទាំងអស់ចំនួន១៩លើក តាំងពីឆ្នាំ១៩៣២មក។ នេះស្តែងឲ្យឃើញថា យោធាដើរតួនាទីធំសម្បើមណាស់ នៅក្នុងជីវិតនយោបាយនៃប្រទេសថៃ។

មែនទែនទៅ អន្តរាគមន៍យោធាដ៏ញឹកញាប់បែបនេះដែលតាមធម្មតាគ្មានការបង្ហូរឈាមឡើយ មិនមែនជារឿងចៃដន្យទេ។ ម្យ៉ាង យោធាជាអ្នកដែលបានផ្តួលរំលំរបបរាជានិយមផ្តាច់ការនៅឆ្នាំ១៩៣២ និងជាអ្នកដែលបានបង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ នៅថ្ងៃទី២៤មិថុនាឆ្នាំ១៩៣៣។ ម្យ៉ាងទៀត ពេញ

មួយសតវត្សរ៍ទី២០ យោធាដែលមិនចាំបាច់គិតគូរពីរឿងការពារជាតិ ដ្បិតប្រទេសថៃមិនដែលឆ្លងកាត់សង្គ្រាម បានងាកមករវីរវល់តែពីរឿងផ្ទៃក្នុងនៃប្រទេស។

អ៊ីចឹងហើយ បានជាមកទល់សព្វថ្ងៃ យោធាថៃតាំងខ្លួនជាកម្លាំងមួយម្ចាស់ការ មិនស្តាប់បញ្ជាអ្នកនយោបាយ ផ្តល់សិទ្ធិធំដល់ខ្លួនឯង ដើម្បីគាបសង្កត់ឬរំលំរដ្ឋាភិបាល។ អ៊ីចឹងហើយដែរ បានជានាយករដ្ឋមន្ត្រីថៃជាច្រើនរូប សុទ្ធសឹងជានាយទាហានឬជាអតីតនាយទាហាន ដូចយ៉ាងលោកភីប៊ុន(Phibun) លោកសារីត(Sarit) លោកថានំ(Thanom) ឬក៏កន្លងទៅថ្មីៗនេះ លោកសុងធី(Sonthi)។

លើកណាក៏ដូចលើកណា ក្រុមនាយទាហានដែលបានធ្វើរដ្ឋប្រហារ តែងតែអះអាងថា គឺដើម្បីការពារផលប្រយោជន៍ជាតិ។ ឧទាហរណ៍ ទាក់ទិននឹងរដ្ឋប្រហារឆ្នាំ១៩៤៧ ឧត្តមសេនីយ៍ភីប៊ុនបាននិយាយអះអាងថា គឺដើម្បីការពារភាពថ្លៃថ្នូរនៃរបបរាជានិយម ប្រឆាំងនឹងរដ្ឋាភិបាលមួយដែលទន់ជ្រាយពេក នៅចំពោះមុខបស្ចិមលោក។ ពាក់ព័ន្ធនឹងរដ្ឋប្រហារឆ្នាំ១៩៧១វិញ ក្រុមឧត្តមសេនីយ៍បានពន្យល់ថា គឺដើម្បីការពារប្រទេសទប់ទល់នឹងឥទ្ធិពលកុម្មុយនិស្តដែលចេញមកពីតំបន់បណ្តោយព្រំដែនជាមួយប្រទេសម៉ាឡេស៊ី។ ហើយស្តីពីរដ្ឋប្រហារឆ្នាំ២០០៦វិញ ក្រុមឧត្តមសេនីយ៍បានថ្លែងថា គឺដើម្បីរក្សាស្ថិរភាពនៃប្រទេស។

ទោះបីជាមិនចេញមុខខ្លាំង ឥទ្ធិពលរបស់ព្រះមហាក្សត្រថៃធំលើសអំណាចរបស់ពួកយោធាទៅទៀត។ បើសិនជាគ្មានការគាំទ្រពីព្រះចៅភូមីពុល(Phumibol) និងពីព្រះបរមរាជវាំងទេ រដ្ឋប្រហារយោធាបន្តបន្ទាប់គ្នាតាំងពីឆ្នាំ១៩៥០មក ប្រហែលជាមិនអាចទទួលជោគជ័យងាយៗ អ៊ីចឹងបានទេ។ ជាក់ស្តែង នៅឆ្នាំ១៩៨១ រដ្ឋប្រហារប្រឆាំងនឹងឧត្តមសេនីយ៍ព្រេម(Prem) ដែលគ្មានការគាំទ្រពីសំណាក់ព្រះចៅភូមីពុល បានទទួលបរាជ័យស្មោះ។

ដោយឡែក យោធា រដ្ឋាភិបាល និងរាស្ត្រថៃ ទទួលស្គាល់តួនាទីជាចាំបាច់របស់ព្រះមហាក្សត្រ ក្នុងការដោះស្រាយវិបត្តិធ្ងន់ធ្ងរនិងក្នុងការផ្សះផ្សាជាតិ ទោះបីជាតួនាទីនោះ មិនបានចែងនៅក្នុងរដ្ឋធម្មនុញ្ញក៏ដោយ។ នៅឆ្នាំ១៩៧៣ ក្រោយពីរដ្ឋាភិបាលបានវាយបង្ក្រាបក្នុងថ្លុកឈាមចលនានិស្សិត ឧត្តមសេនីយ៍ថានំត្រូវបង្ខំចិត្តលាលែងចេញពីមុខតំណែងនាយករដ្ឋមន្ត្រី និងត្រូវបង្ខំចិត្តនិរទេសទៅរស់នៅក្រៅប្រទេស តាមសំណូមពររបស់ព្រះចៅភូមីពុល។

លើសពីនេះទៅទៀត ព្រះមហាក្សត្រថៃមានសិទ្ធិប្រើអំណាចវេតូ(Veto) ដោយមិនឡាយព្រះហស្តលេខាប្រកាសឲ្យប្រើប្រាស់ច្បាប់ណាដែលព្រះអង្គមិនឯកភាព។ ហើយជាទូទៅ សភាតែងតែបោះបង់ចោលជាស្ថាពរ ច្បាប់ដែលត្រូវបានជំទាស់ដោយព្រះមហាក្សត្រ។

នៅក្នុងបរិបទបែបនេះ គេអាចអះអាងបានថា លទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនៅប្រទេសថៃនារយៈពេល៨០ឆ្នាំចុងក្រោយនេះមានដំណើររប៉ាក់របើក។ មូលហេតុទីមួយ គឺបណ្តាលមកពីឥទ្ធិពលធំធេងពេករបស់ព្រះមហាក្សត្រ ធំធេងហួសសេចក្តីចែងរបស់រដ្ឋធម្មនុញ្ញ។

មូលហេតុទីពីរ គឺបណ្តាលមកពីរដ្ឋប្រហារយោធាមិនចេះឈប់ឈរ ដែលមិនអាចធ្វើឲ្យលទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនៃប្រទេស រីកធំនិងរឹងមាំបាន។ នារយៈពេល៨០ ឆ្នាំចុងក្រោយនេះ ក្រោយរដ្ឋប្រហារម្តងៗ យោធាថៃតែងតែឡើងកាន់កាប់អំណាចមួយឆ្នាំឬពីរឆ្នាំមុននឹងប្រគល់អំណាចទៅឲ្យ

ស៊ីវិលវិញ ហើយមិនតែប៉ុណ្ណោះ រដ្ឋាភិបាលស៊ីវិលទាំងនោះគ្រប់គ្រងប្រទេស ក្រោមការឃ្លាំមើលរបស់យោធាទៅទៀត។

ឯមូលហេតុចុងក្រោយនៃលទ្ធិប្រជាធិបតេយ្យរប៉ាក់របើុកនៅប្រទេសថៃ គឺបណ្តាលមកពីអស្ថិរភាពខ្លាំងនៃរដ្ឋាភិបាលនីមួយៗ។ កម្រមានណាស់រដ្ឋាភិបាលមួយដែលអាចដឹកនាំប្រទេសមួយអាណត្តិពេញ ពីព្រោះសុទ្ធសឹងជារដ្ឋាភិបាលចម្រុះដែលត្រូវតែរលំបះជើង ពេលមានការបាក់បែកប្រេះឆា នៅក្នុងជួរថ្នាក់ដឹកនាំប្រទេសម្តងៗ។

ដោយឡែក ភាពតានតឹងនិងអស្ថិរភាពនយោបាយនៅក្នុងប្រទេសតាំងពីឆ្នាំ២០០៦មក គឺជាការគំរាមកំហែងថ្មីដល់លទ្ធិប្រជាធិបតេយ្យថៃ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៧ ដែលគេចាត់ទុកថាមានលក្ខណៈប្រជាធិបតេយ្យជាងគេ ត្រូវបានបោះបង់ចោល។ រីឯលោកថាក់ស៊ីន ដែលបានឈ្នះឆ្នោតនៅឆ្នាំ២០០១និងនៅឆ្នាំ២០០៥ ក៏ដូចបក្សពួករបស់លោកនៅក្នុងជួរគណបក្សអំណាចប្រជាជនដែលបានឈ្នះឆ្នោតនៅឆ្នាំ២០០៧ ត្រូវគេរាំងមិនឲ្យដឹកនាំប្រទេសបាន។ ជាក់ស្តែង នៅឆ្នាំ២០០៨ រដ្ឋាភិបាលរបស់លោកសាម៉ាក់(Samak) ត្រូវបានរំលំដោយពួកអាវលឿងដែលបានកាន់កាប់ទីស្នាក់ការរបស់រដ្ឋាភិបាលនៅខែសីហា និងអាកាសយានដ្ឋាននៅទីក្រុងបាងកកនៅខែធ្នូ។ ក្រោយមកទៀត រដ្ឋាភិបាលលោកសុមឆៃ(Somchai) ដែលជាប្អូនថ្លៃរបស់លោកថាក់ស៊ីន ក៏បានដួលរលំដូចគ្នា ក្រោយពីតុលាការបានសម្រេចចិត្តរំលាយចោលគណបក្សរបស់លោក គឺបក្សអំណាចប្រជាជន។

បន្ទាប់មកទៀត លោកអាភីស៊ីត(Abhisit) ដែលជាសត្រូវរបស់លោកថាក់ស៊ីន និងដែលបានដឹកនាំប្រទេសរហូតដល់ការបោះឆ្នោតខែកក្កដាឆ្នាំ២០១១ បានឋិតនៅក្រោមការអុកឡុករបស់ពួកអាវក្រហមវិញម្តង។ ពួកអាវក្រហមដែលស្និទ្ធនឹងលោកថាក់ស៊ីនបានធ្វើបាតុកម្មធំនៅឆ្នាំ២០១០នៅកណ្តាលទីក្រុងបាងកក រហូតដល់បានជំរុញឱ្យមានការវាយបង្ក្រាបពីសំណាក់កងទ័ព។ កាលណោះ អន្តរាគមន៍របស់យោធាបានបណ្តាលឱ្យមានស្លាប់៩១នាក់ និងរបួស១ ៩០០នាក់។

ក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ ប្រទេសថៃបានវិលមកឋិតនៅក្រោមការគ្រប់គ្រងរបស់បក្សពួកលោកថាក់ស៊ីនវិញម្តង។ គណបក្សភឿថៃដែលដឹកនាំដោយប្អូនស្រីរបស់លោកថាក់ស៊ីន គឺលោកស្រី យីនឡាក់(Yingluck) បានឈ្នះឆ្នោតនៅខែកក្កដាឆ្នាំ២០១១ ហើយលោកស្រីយីនឡាក់បានក្លាយជានាយករដ្ឋមន្ត្រីដឹកនាំរដ្ឋាភិបាលចម្រុះមួយដែលចូលរួមដោយគណបក្សចំនួនប្រាំ។

យ៉ាងណាក៏ដោយ លោកស្រីនាយករដ្ឋមន្ត្រីត្រូវប្រឈមមុខនឹងបញ្ហាជាអាទិភាពជាច្រើន។ ម្យ៉ាង គឺបញ្ហាសេដ្ឋកិច្ចជាពិសេសក្រោយគ្រោះទឹកជំនន់ដ៏កាចមួយមិនដែលមានកាលពីឆ្នាំទៅមិញ។ ម្យ៉ាងទៀត គឺការផ្សះផ្សាជាតិ រវាងអ្នកមាននិងអ្នកក្រ រវាងអ្នកទីក្រុងនិងអ្នកស្រុកស្រែចម្ការ រវាងពួកអាវលឿងនិងពួកអាវក្រហម រវាងពួកអ្នកស្អប់និងអ្នកស្រឡាញ់ថាក់ស៊ីន៕

## សំណួរត្រិះរិះ

១. តើប្រទេសថៃមានឈ្មោះផ្លូវការអ្វី?

២. តើប្រទេសថៃមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?

៣. តើប្រទេសថៃមានប្រជាជនប៉ុន្មានលាននាក់?
៤. តើប្រទេសថៃមានរបបនយោបាយយ៉ាងដូចម្តេច?
៥. តើវិស័យសេដ្ឋកិច្ច ថៃមានប្រភពចំណូលពីវិស័យអ្វីខ្លះ?
៦. តើប្រទេសថៃមានបញ្ហាអ្វីខ្លះ?

## ៨. ប្រទេសមីយ៉ាន់ម៉ា





**ឈ្មោះប្រទេស៖** សហភាពមីយ៉ាន់ម៉ា នៅឆ្នាំ២០១០ ឈ្មោះរបស់ប្រទេសបានប្តូរទៅជាសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

**ក្រឡាផ្ទៃ៖** ៦៧៦ ៥៧៨ គីឡូម៉ែត្រការ៉េ



**រដ្ឋធានី៖** ណៃពីតូរ **រូបិយវត្ថុ៖** ខ្យាត

**ភាសាជាតិ៖** មីយ៉ាន់ម៉ា (ភូមា) ភាសាផ្លូវការ៖ មីយ៉ាន់ម៉ា (ភូមា)

**ថ្ងៃចូលជាសមាជិកអាស៊ាន៖** ២៣ កក្កដា១៩៩៧

**ថ្ងៃឯករាជ្យជាតិ៖** ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៤៨ (ពីចក្រភពអង់គ្លេស)

**ទង់ជាតិ៖**

- ពណ៌លឿង តំណាងឱ្យភាពជាធ្លុងមួយ សេចក្តីសុខ និងសាមគ្គីភាព
- ពណ៌បៃតង តំណាងឱ្យភាពសម្បូរហូរហៀរ ការអភិវឌ្ឍ និងសន្តិភាព
- ពណ៌ក្រហម តំណាងឱ្យភាពក្លាហាន និងភាពដាច់ខាត
- រូបផ្កាយពណ៌សចំកណ្តាល តំណាងឱ្យភាពបរិសុទ្ធ ភាពស្មោះត្រង់ ការមានមេត្តា និងមានថាមពល។

ទង់ជាតិចាស់របស់មីយ៉ាន់ម៉ា មានផ្ទៃពណ៌ក្រហម និងជ្រុងខាងឆ្វេងផ្នែកខាងលើមានពណ៌ខៀវ មានរូបកងចក្រ កួរស្រូវ ផ្កាយពណ៌សចំនួន១៤ព័ទ្ធជុំវិញ ដែលតំណាងឱ្យការរស់នៅរួមគ្នា៧រដ្ឋ ៧ភូមិភាគ និងជានិមិត្តសញ្ញាបង្ហាញឱ្យឃើញពីការមានសិទ្ធិស្មើគ្នានៅក្នុងសហភាព។




### ទីតាំងភូមិសាស្ត្រ

ប្រទេសមីយ៉ាន់ម៉ា ស្ថិតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងឧបទ្វីបឥណ្ឌូចិន ខាងជើងជាប់នឹងប្រទេសចិន ខាងកើតជាប់ឆៀងខាងត្បូងជាប់នឹងឡាវ និងថៃ ខាងលិចជាប់នឹងឥណ្ឌា និងបង់ក្លាដេស ខាងត្បូងជាប់នឹងសមុទ្រអាន់ដាម៉ាន់ និងឈូងសមុទ្របេងហ្គាល។

### ប្រជាជន

យោងតាមជំរឿនឆ្នាំ២០១៤ ចំនួនប្រជាជនសរុបមានៈ ៥១ ៤៨៦ ២៥៣ នាក់។ ជនជាតិដែលរស់នៅប្រទេសភូមារួមមានៈ ភូមា៦៨% សាន៩% ការេន៧% រ៉ាឃីន៤% មន២% និងផ្សេងៗទៀតមាន១០%។ សាសនាៈ ពុទ្ធសាសនា៨៩% គ្រិស្តសាសនា៥% សាសនាឥស្លាម៤% សាសនាដទៃទៀត៤%។

**របបនយោបាយ**

របបគ្រប់គ្រងៈ រដ្ឋសភាដែលសមាជិកសភាបានមកពីការបោះឆ្នោត និងមានប្រធានាធិបតីជាប្រមុខ។

ក្រោយពីរៀបចំការបោះឆ្នោតទូទាំងប្រទេសកាលពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១០ ប្រទេសមីយ៉ាន់ម៉ាបានផ្លាស់ប្តូររបបគ្រប់គ្រងពីរបបផ្តាច់ការយោធាមកជារបបប្រជាធិបតេយ្យ ដោយមានប្រធានាធិបតីជាប្រមុខរបស់ប្រទេស និងជាប្រមុខរដ្ឋាភិបាល កាន់តំណែង៥ឆ្នាំក្នុងមួយអណត្តិ។

លោក ធេនសេន ជាប្រធានាធិបតី ដែលធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីទី១១ អំឡុងឆ្នាំ២០០៧-២០១១ និងជាប្រធានាធិបតីដំបូងគេរបស់មីយ៉ាន់ម៉ា ដែលមិនមែនជាទាហាន។

ភូមាបានរៀបចំការបោះឆ្នោតជាតិនៅថ្ងៃទី៨ ខែវិច្ឆកា ឆ្នាំ២០១៥។ ជាការបោះឆ្នោតប្រកួតប្រជែងដោយចំហជាលើកដំបូងចាប់តាំងពីឆ្នាំ១៩៩០មក។ ជាលទ្ធផលគណបក្សសម្ព័ន្ធជាតិដើម្បីប្រជាធិបតេយ្យទទួលបានអសនៈភាគច្រើនដាច់ខាត នៅក្នុងសភាជាតិទាំងពីរ ដែលមានចំនួនគ្រប់គ្រាន់សម្រាប់តែងតាំងបេក្ខជនប្រធានាធិបតី។ ប៉ុន្តែប្រធានគណបក្សលោកស្រីអង់ សាន ស៊ូឈី ត្រូវរដ្ឋធម្មនុញ្ញរាំងមិនឱ្យធ្វើជាប្រធានាធិបតីបាន។

សភាថ្មីត្រូវបានកោះប្រជុំនាថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ ហើយនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ លោក ហ្ទីន ខ្យ៉ (Htin Kyaw) ត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធានធិបតីដែលមិនមែនជាយោធា ចាប់តាំងពីរដ្ឋប្រហារយោធាឆ្នាំ១៩៦២មក។ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦ បានទទួលតំណែងជាទីប្រក្សារដ្ឋ ជាតំណែងបង្កើតថ្មី ដែលមានឋានៈប្រហាក់ប្រហែលនឹងនាយករដ្ឋមន្ត្រី។

រដ្ឋធម្មនុញ្ញប្រទេសភូមាបានធ្វើសេចក្តីព្រាងដោយអ្នកគ្រប់គ្រងយោធា ក្នុងខែកញ្ញា ឆ្នាំ២០០៨។ ប្រទេសត្រូវបានគ្រប់គ្រងដោយប្រព័ន្ធសភា ដែលមានស្ថាប័ននីតិបញ្ញត្តិពីរ(ដោយមានប្រធានាធិបតីមួយរូបទទួលខុសត្រូវចំពោះចំពោះស្ថាប័ននីតិបញ្ញត្តិ) សមាជិកស្ថាប័ននីតិបញ្ញត្តិមួយផ្នែកចាត់តាំងចេញពីយោធា និងសមាជិកដទៃទៀតចេញពីការបោះឆ្នោតជាតិ។

ស្ថាប័នបញ្ញត្តិមានសភាពីរ។ ព្រឹទ្ធសភា(សភាជាតិ)មានសមាជិក២២៤អសនៈ និងសភា(សភាតំណាង)មានសមាជិក៤៤០អសនៈ។ សមាជិកព្រឹទ្ធសភាចំនួន២២៤រូប ក្នុងនោះមាន១៦៨រូបចេញពីការបោះឆ្នោត និង៥៦រូបចាត់តាំងចេញពីកងកម្លាំងប្រដាប់អាវុធភូមា។ សភាមានសមាជិក៤៤០រូប ក្នុងនោះ៣៣០រូបចេញពីការបោះឆ្នោតជាតិ និង១១០រូបចេញពីចាត់តាំងកងកម្លាំងប្រដាប់អាវុធ។

| ល.រ | រដ្ឋ/តំបន់ | ស្រុក | ទីប្រជុំជន | ទីក្រុង | Wards | ចង្កោមភូមិ | ភូមិ |
|---|---|---|---|---|---|---|---|
| 1 | រដ្ឋកាឈីន | 4 | 18 | 20 | 116 | 606 | 2630 |
| 2 | រដ្ឋកាយ៉ាស់ | 2 | 7 | 7 | 29 | 79 | 624 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 3 | រដ្ឋកាឈីន | 3 | 7 | 10 | 46 | 376 | 2092 |
| 4 | រដ្ឋឈីន | 2 | 9 | 9 | 29 | 475 | 1355 |
| 5 | តំបន់សាហ្គាំង | 8 | 37 | 37 | 171 | 1769 | 6095 |
| 6 | តំបន់តានីនថារីយី | 3 | 10 | 10 | 63 | 265 | 1255 |
| 7 | តំបន់បាហ្គូ | 4 | 28 | 33 | 246 | 1424 | 6498 |
| 8 | តំបន់ម៉ាក់វេ | 5 | 25 | 26 | 160 | 1543 | 4774 |
| 9 | តំបន់ម៉ាន់ដាឡៃ | 7 | 31 | 29 | 259 | 1611 | 5472 |
| 10 | រដ្ឋមន | 2 | 10 | 11 | 69 | 381 | 1199 |
| 11 | រដ្ឋរ៉ាឃីន | 4 | 17 | 17 | 120 | 1041 | 3871 |
| 12 | តំបន់យ៉ាងហ្គុន | 4 | 45 | 20 | 685 | 634 | 2119 |
| 13 | រដ្ឋសាន | 11 | 54 | 54 | 336 | 1626 | 15513 |
| 14 | តំបន់អាយេយាវ៉ាឌី | 6 | 26 | 29 | 219 | 1912 | 11651 |
| | សរុប | **63** | **324** | **312** | **2548** | **13742** | **65148** |

ប្រទេសមីយ៉ាន់ម៉ាចែកចេញជា៧រដ្ឋ សម្រាប់ប្រជាជនដែលជាជនជាតិភាគតិច និង៧តំបន់សម្រាប់ប្រជាជនដែលមានសាច់សារលោហិតជាជនជាតិមីយ៉ាន់ម៉ា។

## សេដ្ឋកិច្ច

| GDP (nominal) | 2017 estimate |
|---|---|
| Total | 72.368 billion[3] (72nd) |
| Per capita | $1,374[3] (150th) |

អត្រានៃកំណើនសេដ្ឋកិច្ចរបស់មីយ៉ាន់ម៉ា មានសេដ្ឋកិច្ចកើនឡើងយ៉ាងឆាប់រហ័ស៦,៥% ក្នុង១ឆ្នាំ ក្នុងអំឡុងពេល៣-៤ឆ្នាំខាងមុខទៀត ព្រោះបរទេសមកបណ្តាក់ទុនកាន់តែច្រើនឡើង ដោយសារតែមានការកាត់បន្ថយនូវការធ្វើពហិការមីយ៉ាន់ម៉ាកាលពីឆ្នាំ២០១៣។

រចនាសម្ព័ន្ធខាងសេដ្ឋកិច្ចរបស់មីយ៉ាន់ម៉ាមាន៣ផ្នែកគឺ កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ផ្នែកកសិកម្មមានភាគច្រើនបំផុត បន្ទាប់មកផ្នែកកសិកម្មមានភាគច្រើនបំផុត បន្ទាប់មកផ្នែកសេវាកម្ម និងផ្នែកឧស្សាហកម្ម។

**ទំនិញឧស្សាហកម្មសំខាន់ៗ** វាយនភណ្ឌ សម្លៀកបំពាក់ ឧស្ម័នធម្មជាតិ ឈើកែច្នៃ និងផលិតផលធ្វើពីឈើ។

**កសិកម្មសំខាន់** អង្ករ ពោត សណ្តែក លូ អំពៅ។

**ធនធានសំខាន់** ឧស្ម័នធម្មជាតិ ឈើម៉ៃសាក់ រ៉ែ រតនវត្ថុ កៅស៊ូ។
**ប្រទេសជាដៃពាណិជ្ជកម្មសំខាន់ៗ** ចិន ថៃ ឥណ្ឌា ជប៉ុន សិង្ហបុរី។
**ទំនិញនាំចេញ** ឧស្ម័នធម្មជាតិ ឈើសាច់រឹង សម្លៀកបំពាក់ រ៉ែ រតនវត្ថុ កៅស៊ូ សណ្ដែក ម្ហូបសមុទ្រ។
**ទំនិញនាំចូល** គ្រឿងម៉ាស៊ីន ប្រេងឆៅ ដែក លោហៈ និងផលិតផលធ្វើពីលោហៈ។

**បញ្ហាសំខាន់ៗ**

**ទ័ពព្រៃនៃជនជាតិភាគតិចនៅភូមា(ធី៤២)**

តាំងពីឆ្នាំ១៩៤៨មកម្ល៉េះ កងទ័ពភូមាវាយបង្ក្រាបឥតត្រាប្រណីទៅលើពួកជនជាតិភាគតិចដែលទាមទារផ្ដាច់ដែនដីរបស់ពួកគេចេញពីការត្រួតត្រារបស់រដ្ឋាភិបាល។ ប៉ុន្តែ ប៉ុន្មានខែចុងក្រោយនេះ(២០១៣) របបថ្មីនៅទីក្រុងណៃពីដ៏(Naypidav) ដែលជារដ្ឋាភិបាលស៊ីវិលទីមួយបង្អស់នៅក្នុងប្រវត្តិសាស្ត្រភូមា បានផ្ដើមបើកការចរចាជាមួយពួកជនជាតិភាគតិច។ តើអ្វីទៅឫសគល់នៃសង្គ្រាមទ័ពព្រៃនៅភូមា?

ជនជាតិភាគតិចនៅប្រទេសភូមាមានមិនតិចជាង១៣០សហគមន៍ទេ ដូចជាពួកShan ពួកKaren និងពួកKachin។ល។និង។ល។ ពួកគេនិយាយភាសាជាង១០ខុសៗគ្នា។ ជាទូទៅ ពួកគេកាន់ព្រះពុទ្ធសាសនា តែក៏មានដែរអ្នកកាន់សាសនាអ៊ីស្លាម ដូចជាពួកRohingya ដែលរស់នៅតាមបណ្ដោយព្រំដែនជាមួយប្រទេសបង់ក្លាដែស និងអ្នកកាន់គ្រិស្តសាសនា ដូចជាពួកKaren និងពួកKachinជាដើម។ បើនិយាយពីចំនួនវិញ ពួកជនជាតិភាគតិចទាំងនោះតំណាងមួយភាគបីនៃប្រជាជនទាំងជាង៥២លាននាក់នៃប្រទេស ពោលគឺប្រមាណជាង១៧លាននាក់។

នៅឆ្នាំ១៩៤៧ ឧត្តមសេនីយ៍អុង សាន់ដែលប្រជាជាតិភូមាទាំងមូលចាត់ទុកជាបិតានៃឯករាជ្យ បានយល់ព្រមប្រគល់ស្វ័យភាពរដ្ឋបាលដ៏ធំទូលំទូលាយនៅក្នុងក្របខណ្ឌនៃប្រទេសសហពន្ធ័មួយទៅឱ្យជនជាតិភាគតិច តាមរយៈកិច្ចព្រមព្រៀងមួយ ឈ្មោះកិច្ចព្រមព្រៀងPanglong ចុះថ្ងៃទី១២កុម្ភៈឆ្នាំ១៩៤៧។

ក៏ប៉ុន្តែ នៅឆ្នាំ១៩៤៧ដដែលនោះ ស្រាប់តែវីរបុរសជាតិអុង សាន់ត្រូវបានគេធ្វើឃាត។ ក្រោយមកក្រុមឧត្តមសេនីយ៍ដែលបានឡើងមកក្ដាប់អំណាចរដ្ឋបានសម្រេចចិត្តមិនអនុវត្តកិច្ចព្រមព្រៀងPanglongទៅវិញ។ អ៊ីចឹងហើយបានជានៅឆ្នាំ១៩៤៨ ពោលគឺក្រោយពីភូមាបានទទួលឯករាជ្យពីប្រទេសអង់គ្លេសជាផ្លូវការហើយ ពួកជនជាតិភាគតិចសំខាន់ៗ រួមមានជាអាទិ៍ពួកKaren ពួកShan និងពួកKachin បានចាប់អាវុធប្រយុទ្ធនឹងរដ្ឋាភិបាលទីក្រុងរ៉ង់ហ្គូន (Rangoon)។ គោលដៅ គឺផ្ដាច់រដ្ឋរបស់ពួកគេនៅតាមបណ្ដោយព្រំដែនជាមួយប្រទេសចិនឬនៅតាមបណ្ដោយព្រំដែនជាមួយប្រទេសថៃចេញពីការត្រួតត្រារបស់រដ្ឋអំណាចភូមា។ ឧទាហរណ៍ជាក់ស្ដែង ពួកKachinបានបង្កើតទ័ពព្រៃឈ្មោះកងកម្លាំងដើម្បីឯករាជ្យKachin រីឯពួកKarenវិញបានបង្កើតចលនាសហភាពជាតិKaren និងបានផ្ដើមសង្គ្រាមទ័ពព្រៃប្រឆាំងនឹងរដ្ឋាភិបាលនៅរ៉ង់ហ្គូន សង្គ្រាមទ័ពព្រៃដែលមានបន្តរហូតមកទល់សព្វថ្ងៃនេះ។

នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍និងនៅក្នុងពិភពលោកសព្វថ្ងៃ ពួកKaren ជាទ័ពព្រៃចាស់ជាងគេបង្អស់ដែលទាមទារផ្ដាច់ផ្ទៃដីប្រមាណប្រាំមួយរយគីឡូម៉ែត្រក្រឡានៅជាប់នឹងព្រំដែនថៃ ចេញពីការត្រួតត្រារបស់ប្រទេសភូមា។ តំបន់នោះ ជាភាសាKarenមានឈ្មោះថា Kawthoolei ប្រែថាប្រទេសសម្បូណ៌ផ្កា។

ហូតមកទល់ពេលថ្មីៗនេះ រដ្ឋាភិបាលភូមាដែលប្រើមធ្យោបាយវាយបង្ក្រាបយ៉ាងសាហាវព្រៃផ្សៃជាទី

បំផុត នៅតែយកជ័យជំនះទៅលើកងទ័ពសហភាពជាតិKarenមិនបាន បានត្រឹមរុញច្រានទ័ពព្រៃនេះ និងប្រជាជនKaren ចូលកាន់តែជ្រៅទៅក្នុងព្រៃនិងចូលទៅក្នុងទឹកដីថៃ ជាទីដែលពួកគេរស់នៅយ៉ាងវេទនាតាមជំរំនានា។

មានទទ្សឹករណ៍ពីរដែលអាចពន្យល់ការប្រឹងប្រែងតស៊ូស្លាប់រស់របស់ពួកទ័ពព្រៃKaren។ ទីមួយ ពួកKarens គ្មានជម្រើសអ្វីផ្សេងក្រៅពីប្រយុទ្ធស្លាប់រស់ ពីព្រោះរហូតមកទល់ពេលថ្មីៗនេះ របបសឹកភូមាគ្មានបំណងចង់ចរចាជាមួយពួកជនជាតិភាគតិចឡើយ ហើយបានអនុវត្តនយោបាយមួយដែលគេអាចវាយតម្លៃថាជាអំពើប្រល័យពូជសាសន៍។ កងទ័ពភូមាតែងតែបានដុតបំផ្លាញគ្មានសល់ភូមិស្រុកនិងស្រូវអង្ករបស់ពួកKaren បានកាប់សម្លាប់បុរសនិងរំលោភស្ត្រី។ ទីពីរ ពួកKaren ដែលមានគ្នាប្រមាណប្រាំពីរលាននាក់ជាជាតិសាសន៍មួយស្រេចទៅហើយ ទោះជាគ្មានប្រទេសនិងគ្មានស្ថាប័នគ្រប់គ្រងមាំមួនក៏ដោយ ពីព្រោះពួកគេមានប្រវត្តិសាស្ត្រ ភាសា និងវប្បធម៌ច្បាស់លាស់ ខុសពីជនជាតិភាគតិចដទៃផ្សេងនៅភូមា ដូចជាពួកShan ជាដើម។

មិនតែប៉ុណ្ណោះ ប្រទេសថៃដែលបានគាំទ្រពួកទ័ពព្រៃKaren អស់ជាច្រើនឆ្នាំ បានបែរមកត្រូវរ៉ូវជាមួយរបបភូមាវិញ ពីព្រោះថៃក៏ដូចភូមាដែរជាសមាជិករបស់អាស៊ាន ហើយពីព្រោះថៃឥឡូវ ត្រូវការប្រយោជន៍សេដ្ឋកិច្ច ចៀសមិនរួចពីរកស៊ីជាមួយប្រទេសភូមា។ និយាយបែបផ្សេង រដ្ឋាភិបាលទីក្រុងបាងកកលែងត្រូវការពួកទ័ពព្រៃKaren ដើម្បីបង្កើតឲ្យមានតំបន់ទ្រនាប់មួយនៅចន្លោះប្រទេសខ្លួននិងប្រទេសភូមាទៀតហើយ តែត្រូវការអភិវឌ្ឍតំបន់បណ្តោយព្រំដែនដោយទាក់ទងផ្ទាល់ជាមួយរបបភូមា។ គឺនៅក្នុងក្របខ័ណ្ឌនៃប្រយោជន៍សេដ្ឋកិច្ចនេះហើយ ដែលនៅឆ្នាំ២០០៥ ភូមានិងថៃបានយល់ព្រមព្រៀងគ្នាថា នឹងសាងសង់ទំនប់វារីអគ្គិសនីចំនួនបួន នៅលើទន្លេSalouen។.......................

ក្រៅពីប្រយោជន៍សេដ្ឋកិច្ចដែលបានមកពីទំនប់វារីអគ្គិសនីទាំងបួន ភូមាមានគោលដៅនយោបាយមួយច្បាស់ នោះគឺពន្លិចទៅក្នុងទឹកស្រុកភូមិកំណើត លំនៅដ្ឋាននិងដំណាំដាំដុះរបស់ពួកKaren។ ពេលណាទំនប់ទាំងបួននេះត្រូវសាងសង់រួចរាល់ហើយ នោះទឹកទន្លេSalouen នឹងជន់ឡើងពីរយម៉ែត្រយ៉ាងតិច ដែលជាហេតុនឹងបណ្តាលឲ្យតំបន់ពួកKarenលិចលង់អស់គ្មានសល់។ នៅពេលនោះ មិនត្រឹមតែទ័ពព្រៃKaren ប៉ុណ្ណោះទេដែលនឹងត្រូវវិនាសសាបសូន្យ ពូជសាសន៍Karen ទាំងមូលនឹងអាចរលត់បាត់បង់។ យ៉ាងណាក៏ដោយ តាំងពីខែវិច្ឆិកាឆ្នាំ២០១១មក របបថ្មីភូមាដែលដឹកនាំដោយលោកប្រធានាធិបតី ធេន សេន (Thein Sein) ចង់បញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃជាមួយពួកជនជាតិភាគតិច។ រដ្ឋអំណាចស៊ីវិលនៅរដ្ឋធានីថ្មីណៃពីដ៏(Naypidav) ដែលកំពុងបោះជំហានទៅរកលទ្ធិប្រជាធិបតេយ្យផ្តើមចរចាជាមួយពួកជនជាតិភាគតិច ហើយសម្រេចបានកិច្ចឈប់បាញ់គ្នាជាមួយពួកជនជាតិភាគតិចខ្លះ ដូចយ៉ាងជាមួយពួកShanនៅចុងឆ្នាំ២០១១ និងជាមួយពួកKaren នៅដើមឆ្នាំ២០១២។ មិនតែប៉ុណ្ណោះ លោកធេន សេន ក៏បានបញ្ជាឱ្យកងទ័ពឈប់វាយប្រហារទៅលើពួកKachinទៀតផង។

ប៉ុន្តែទន្ទឹមនេះ តាំងពីខែមិថុនាឆ្នាំ២០១២មក ពួកRohingyaដែលជាអ្នកកាន់សាសនាអ៊ីស្លាម នៅក្នុងរដ្ឋArakanនិងដែលគ្មានកងកម្លាំងប្រដាប់អាវុធដូចពួកKaren ពួកShan ឬពួកKachinត្រូវប្រឈមមុខជាថ្មីនឹងការកាប់សម្លាប់ពីសំណាក់អ្នកកាន់ព្រះពុទ្ធសាសនា។ ការកាប់សម្លាប់ទៅលើពួកRohingya ប្រព្រឹត្តទៅ

ដោយមានការគាំទ្រពីកងទ័ពនិងពីរដ្ឋអំណាចភូមាទៀតផង។

យ៉ាងណាក៏ដោយ ដោះស្រាយបញ្ហាជនជាតិភាគតិច មិនមែនជារឿងងាយស្រួលទេ ពីព្រោះរដ្ឋាភិបាលភូមាមិនអាចបណ្តោយឲ្យដែនដីទាំងអម្បាលម៉ានរបស់ពួកជនជាតិភាគតិច របូតចេញពីការគ្រប់គ្រងរបស់ខ្លួនបានឡើយ។ ទន្ទឹមនេះ ទីក្រុងណៃពីដ៏ក៏ដឹងច្បាស់ដែរថា សន្តិភាពនឹងមិនអាចកើតឡើងបានទេ បើសិនជានៅតែគ្មានទេនោះ ស្វ័យភាពធំទូលំទូលាយសម្រាប់ពួកជនជាតិភាគតិច៕

**របបនយោបាយភូមា**(**ទី១៣**)

រហូតមកដល់ចុងឆ្នាំ២០១១កន្លងទៅនេះ អំណាចរដ្ឋនៃប្រទេសភូមាឋិតនៅក្នុងដៃរបស់ក្រុមនាយទាហាន។

ផ្ទុយទៅវិញ ជិតមួយឆ្នាំចុងក្រោយនេះ រដ្ឋអំណាចភូមាដឹកនាំដោយប្រធានាធិបតីស៊ីវិលទីមួយ បាន និងកំពុងបន្តធ្វើកំណែទម្រង់នយោបាយ។ គោលដៅគឺបើកចំហប្រទេស ទាក់ទងឡើងវិញជាមួយបស្ចិមលោក បញ្ចុះបញ្ចូលឱ្យលោកខាងលិចលើកទណ្ឌកម្មចេញ និងអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេស។

ពីឆ្នាំ១៩៦២រហូតដល់ចុងឆ្នាំ២០១១ អំណាចរដ្ឋនៃប្រទេសភូមាឋិតនៅក្នុងកណ្តាប់ដៃរបស់ក្រុមនាយទាហាន។ ហើយក្នុងអំឡុងពេលជាងប្រាំទសវត្សរ៍ ភូមាដែលបានដូរឈ្មោះជាមីយ៉ាន់ម៉ា(Myanma) បានអនុវត្តអំណាចផ្តាច់ការបែបរបបសឹក បានបិទព្រំដែនសឹងជិតស្លុង និងមានទំនាក់ទំនងតិចតួចបំផុតជាមួយពិភពលោក។

មិនមែនជារឿងមួយចៃដន្យទេ ដែលអំណាចត្រូវបានកាន់កាប់ដោយក្រុមនាយទាហាន ពីព្រោះពីឆ្នាំ១៩៤៨ ឆ្នាំដែលភូមាទទួលបានឯករាជ្យ រហូតដល់ឆ្នាំ១៩៦២ រដ្ឋាភិបាលស៊ីវិល ចេះតែទៅពឹងពាក់កងទ័ពឥតឈប់ឈរ។ ជាក់ស្តែងនៅឆ្នាំ១៩៤៨ នាយករដ្ឋមន្ត្រី អ៊ូ នូ(U Nu) បានពឹងពាក់ឧត្តម សេនីយ៍ នេ វីន(Ne Win) ឲ្យបង្ក្រាបពួកជនជាតិភាគតិចការ៉េន (Karens) ដែលងើបបះបោរទាមទារឯករាជ្យ។ ក្រោយមកទៀតនៅឆ្នាំ១៩៥៨ អ៊ូ នូបានទៅ ពឹងពាក់ឧត្តមសេនីយ៍ នេ វីន ជាថ្មី លើកនេះ ឲ្យបង្ក្រាបពួកកុម្មុយនិស្តវិញម្តង។ នៅទីបំផុត នៅខែមីនាឆ្នាំ១៩៦២ ឧត្តមសេនីយ៍ នេ វីន បានធ្វើរដ្ឋប្រហារទម្លាក់អ៊ូ នូ ហើយបានក្រសោបយកអំណាចទាំងស្រុងមកក្តាប់។

គេត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៨៨ ទើបឃើញប្រជាជនស៊ីវិលងើបបះបោរ ធ្វើបាតុកម្មប្រឆាំង នឹងរបបសឹករបស់នេ វីន។ កាលនោះ នៅចំពោះមុខមហាបាតុកម្មមួយរបស់គណបក្សប្រឆាំង គឺបក្សសម្ព័ន្ធជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ ដឹកនាំដោយលោកស្រីអុង សាន់ស៊ូជី (Aung San Suu Kyi) ឧត្តមសេនីយ៍នេ វីន បានបង្ខំចិត្តលាលែងចេញពីតំណែង។ ក៏ប៉ុន្តែ កងទ័ពដែលនៅតែមិនព្រមបោះបង់ចោលអំណាច បានចាប់ពួកមេដឹកនាំបក្សជំទាស់ដាក់គុក បានចាប់លោកស្រីអុង សាន់ស៊ូជី ឃុំខ្លួនក្នុងគេហដ្ឋានលោកស្រីនិងបានបង្កើតស្ថាប័នរដ្ឋាភិបាលមួយ ដែលគេប្រសិទ្ធនាមឲ្យថា គណៈកម្មាធិការរដ្ឋដើម្បីរៀបចំច្បាប់និងសណ្តាប់ធ្នាប់ឡើងវិញ ហៅកាត់ថាSLORC។

ស្ថាប័ន SLORC នេះដែលនៅឆ្នាំ១៩៩៧ ត្រូវបានដូរឈ្មោះទៅជា ក្រុមប្រឹក្សារដ្ឋដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍ (SPDC) គឺជាសសរគ្រឹះនៃរបបផ្តាច់ការភូមា។ សមាជិកនៃក្រុមប្រឹក្សារដ្ឋនេះសុទ្ធសឹងជានាយទាហាន មានមេបញ្ជាការយោធភូមិភាគ១២នាក់និងនាយទាហានជាន់ខ្ពស់៧នាក់។ គឺក្រុមនាយទាហាននេះ

ហើយ ដែលជាអ្នកតែងតាំងនាយករដ្ឋមន្ត្រី កំណត់មនោគមវិជ្ជានិងបន្ទាត់នយោបាយធំៗនៃរបបសឹកភូមា។

នៅខែមិថុនាឆ្នាំ១៩៨៩ ក្រុមនាយទាហាន បានសម្រេចប្តូរឈ្មោះភូមា ទៅជាមីយ៉ាន់ម៉ា (Myanmar)។ មីយ៉ាន់ម៉ា ដែលមានន័យថា «**ពូជសាសន៍ដែលកើតមុនគេនៅក្នុងលោកិយ**»ជាពាក្យមួយម៉ាត់ប្រកបទៅលក្ខណៈជាតិនិយម។ រហូតដល់ចុងឆ្នាំ២០១១ ក្រៅពីមូលដ្ឋានជាតិនិយម មនោគមវិជ្ជារបស់ក្រុមនាយទាហានភូមាឈរនៅលើការប្រឆាំងនឹង ប្រជាធិបតេយ្យូបនីយកម្ម និងការប្រឆាំងនឹងបស្ចិមលោក។

ការប្រឆាំងនឹងប្រជាធិបតេយ្យូបនីយកម្មបានជំរុញរបបសឹកឱ្យក្តាប់យ៉ាងតឹងរ៉ឹង មធ្យោបាយឃោសនាមហាជន ដូចជាទូរទស្សន៍ វិទ្យុ និងសារពត៌មាន និងខ្ទប់មាត់បក្សជំទាស់។ នៅក្នុងន័យនេះ របបសឹកបានបន្តចាប់អ្នកប្រឆាំងដាក់គុក និងបានវាយបង្ក្រាបក្នុងថ្លុកឈាមរាល់ចលនាបះបោរ ដូចយ៉ាង ការវាយបង្ក្រាបគ្មានត្រាប្រណី ទៅលើបាតុកម្មលោកសង្ឃនិងនិស្សិត នៅឆ្នាំ២០០៧។

ដោយឡែក មិនមែនចៃដន្យទេ ដែលរបបសឹកភូមាប្រឆាំងនឹងបស្ចិមលោក ពីព្រោះអស់រយៈពេលជាច្រើនទសវត្សរ៍ សហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុបបានដាក់សម្ពាធគ្រប់បែបយ៉ាង ទៅលើភូមា បានបង្ខំឲ្យក្រុមនាយទាហានធ្វើប្រជាធិបតេយ្យូបនីយកម្មនៅក្នុងប្រទេស និងដោះលែងអ្នកទោសនយោបាយ ជាពិសេសលោកស្រីប្រមុខបក្សជំទាស់អ៊ុងសាន់ស៊ូជីដែលនៅឆ្នាំ១៩៩១ បានក្លាយជាជ័យលាភីរង្វាន់ណូបែល(Nobel) ផ្នែកសន្តិភាព។

ទោះជាយ៉ាងណាក៏ដោយ រហូតមកទល់ពេលថ្មីៗនេះ ការគាបសង្កត់របស់បស្ចិមលោកទៅលើរបបសឹក គ្មានប្រសិទ្ធិភាពទាល់តែសោះ ពីព្រោះរបបផ្តាច់ការភូមាមិនដែលត្រូវការលោកខាងលិចទេ។ សូម្បីតែនៅខែឧសភាឆ្នាំ២០០៨ ក្រោយពេលដែលខ្យល់ព្យុះកំបុតត្បូងNarguis បានសម្លាប់ប្រជាជនភូមាអស់ជាងមួយសែននាក់ ក៏របបសឹកមិនបានយល់ព្រមទទួលជំនួយពីបស្ចិមលោកដែរ បានយល់ព្រមទទួលតែជំនួយពីបណ្តាប្រទេសអាស៊ី។

ការពិត របបសឹកភូមាអាងយ៉ាង ពីព្រោះមានប្រទេសចិនជួយនិងមានប្រទេសរុស្ស៊ី ព្រមទាំងបណ្តាប្រទេសអាស៊ានរកស៊ីជាមួយ។ ជាក់ស្តែង មកទល់ពេលនេះ វិនិយោគរបស់ប្រទេសចិន រុស្ស៊ី វៀតណាម ថៃ និងសិង្ហបុរីនៅប្រទេសភូមា កើនរហូតដល់ទៅរាប់ពាន់លានដុល្លារ។ប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រោមការណែនាំរបស់ប្រទេសចិន និងដោយហេតុតែមានការទិតៀនកាន់តែខ្លាំងពីសំណាក់សមាជិកអាស៊ានខ្លះ របបសឹកភូមាបានផ្តើមបោះជំហានទៅរកអ្វី ដែលខ្លួនប្រសិទ្ធនាមឲ្យថា លទ្ធិប្រជាធិបតេយ្យនៅក្នុងក្របខណ្ឌនៃវិន័យ។

នៅក្នុងន័យនេះ រដ្ឋធម្មនុញ្ញថ្មីមួយ ត្រូវបានអនុម័តឡើង តាមរយៈការបោះឆ្នោតប្រជាមតិ កាលពីចុងឆ្នាំ ២០០៨។ គោលដៅចុងក្រោយ តាមរយៈរដ្ឋធម្មនុញ្ញថ្មីនេះ គឺបង្កើតរបបនយោបាយប្រធានាធិបតីស៊ីវិលមួយ។

នៅខែវិច្ឆិកាឆ្នាំ២០១១ រដ្ឋអំណាចភូមាបានរៀបចំបោះឆ្នោត បានរំលាយចោលរបបសឹក បានដោះឯកសណ្ឋានយោធាចោល បានបង្កើតរដ្ឋាភិបាលស៊ីវិលមួយ និងបានដោះលែងលោកស្រីអ៊ុង សាន់ស៊ូជីឱ្យមានសេរីភាពវិញ។ លោកស្រីប្រមុខបក្សប្រឆាំងនិងឥស្សរជនជាច្រើននាក់នៃបក្សជំទាស់ថែមទាំងបានក្លាយជាអ្នកតំណាងរាស្ត្រទៀតផង តាមរយៈការបោះឆ្នោតសភាមួយភាគនៅខែមេសាឆ្នាំ២០១២។

សព្វថ្ងៃនេះ ភូមាបាននិងកំពុងបន្តកំណែទម្រង់នយោបាយតទៅទៀត។ ទន្ទឹមនេះ បស្ចិមលោកបានបន្ធូរសម្ពាធទៅលើប្រទេសភូមានិងបានបង្កើនកិច្ចចរចាជាមួយរបបថ្មីរបស់លោកប្រធានាធិបតីស៊ីវិលទីមួយ ធេន សេន(Thein Sein)។

មានមូលហេតុមួយធំដែលអាចពន្យល់ការវិវឌ្ឍន៍ទៅដ៏ល្អប្រសើរ មិនធ្លាប់ដែលមានបែបនេះរបស់ប្រទេសភូមា នោះគឺនៅទីបំផុតពួកក្រុមនាយទាហានមានឆន្ទៈនយោបាយក្នុងការបើកចំហប្រទេស។ បើកចំហប្រទេសដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ដ្បិតការបិទទ្វារជិតស្លុងនិងការមិនទាក់ទងរកស៊ីជាមួយបស្ចិមលោក ធ្វើឱ្យភូមាស្គាល់ភាពយឺតយ៉ាវគ្រប់វិស័យបើប្រៀបធៀបទៅនឹងបណ្តាប្រទេសដទៃក្នុងតំបន់។

យ៉ាងណាក៏ដោយ សហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុបនៅមិនទាន់ព្រមលើកទណ្ឌកម្មចេញទាំងស្រុងទេ តែកោតសរសើរនិងលើកទឹកចិត្តរបបថ្មីឲ្យបន្តកំណែទម្រង់នយោបាយ។ បស្ចិមលោកនៅបារម្ភ បារម្ភខ្លាចចាញ់បោករដ្ឋអំណាចភូមា ពីព្រោះគេដឹងថា នៅពីក្រោយលោកប្រធានាធិបតីស៊ីវិលធេន សេន នៅបន្តមានស្រមោលរបស់ក្រុមនាយទាហានដែលចង់រក្សាអំណាចរបស់ពួកគេឲ្យនៅឋិតថេរយូរអង្វែងតទៅទៀត៕

**សំណួរត្រិះរិះ**

១. តើប្រទេសមីយ៉ាន់ម៉ាមានឈ្មោះផ្លូវការអ្វី?
២. តើប្រទេសមីយ៉ាន់ម៉ាមានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?
៣. តើប្រទេសមីយ៉ាន់ម៉ាមានប្រជាជនប៉ុន្មានលាននាក់?
៤. តើប្រទេសមីយ៉ាន់ម៉ាមានរបបនយោបាយយ៉ាងដូចម្តេច?
៥. តើប្រធានាធិបតីមីយ៉ាន់ម៉ាមានអាណត្តិប៉ុន្មានឆ្នាំ?
៦. តើវិស័យសេដ្ឋកិច្ច មីយ៉ាន់ម៉ាមានប្រភពចំណូលពីវិស័យអ្វីខ្លះ?
៧. តើដៃគូពាណិជ្ជកម្មសំខាន់របស់ប្រទេសមីយ៉ាន់ម៉ាមានប្រទេសណាខ្លះ?
៨. តើប្រទេសមីយ៉ាន់ម៉ាមានបញ្ហាអ្វីខ្លះ?

## ៩. ហ្វីលីពីន/ភីលីពីន

សាធារណរដ្ឋហ្វីលីពីន។ រដ្ឋធានី ម៉ានីល






- ផ្ទៃពណ៌ខៀវ តំណាងឱ្យការស្នេហាជាតិ យុត្តិធម៌ និង សន្តិភាព។
- ផ្ទៃពណ៌ក្រហម តំណាងឱ្យសេចក្តីក្លាហាន កម្លាំង ញើសឈាមដែលពលី ដើម្បីឯករាជ្យ។
- រាងត្រីកោណពណ៌ស តំណាងឱ្យសេចក្តីស្មើភាពគ្នានិងសមាគមកាទីពូណាន់ ជាសមាគមសម្ងាត់ដែល ធ្លាប់បានតស៊ូប្រឆាំងការគ្រប់គ្រងរបស់ចក្រពត្តិអេស្បាញ។

- រូបព្រះអាទិត្យ តំណាងឱ្យឯករាជ្យភាព កាំរស្មីចំនួន៨តំណាងឱ្យខេត្តទាំង៨ ដែលបានរំដោះពីអំណាចអេស្បាញដំបូងគេ មានខេត្តបាតាងកាស់ ប៊ូឡាខាន់ កាវីតេ ឡាគូណា ម៉ានីឡា នួយវ៉ាអេឃីយ៉ា ប៉ាំប៉ុងកា និងខេត្តតាលីក។
- ផ្កាយចំនួន៣ នៅក្នុងរង្វង់ត្រីកោណ តំណាងឱ្យតំបន់គ្រប់គ្រងសំខាន់ៗនៃប្រទេស គឺលូសូន មិនដាណាវ និងវីសាយ៉ាន់។

## ទីតាំងភូមិសាស្ត្រ



ប្រទេសភីលីពីនជាប្រជុំកោះរួមមានកោះប្រហែល ៧៦៤១កោះ។

ផ្ទៃដីសរុប៣០០ ០០០គីឡូម៉ែត្រការេ ដោយរាប់បញ្ចូលទាំងផ្ទៃទឹក។ ក្នុងនោះផ្ទៃទឹកលើផ្ទៃដីមានចំនួន០,៦១% និងផ្ទៃដី ២៩៨,១៧០គីឡូម៉ែត្រការេ។ សមុទ្រចិនខាងត្បូងស្ថិតនៅ ភាគខាងលិច សមុទ្រសេលេបេសស្ថិតនៅភាគខាងត្បូង។ កោះបូនេអូស្ថិតនៅភាគនិរតី និងតៃវ៉ាន់ស្ថិតនៅភាគខាងជើង។ ខាងកើតជាប់មហាសមុទ្រប៉ាស៊ីភិច។

## ប្រជាជន

| | |
|---|---|
| 2015 census | 100,981,437 (12th) |
| Density | 336.60/km²(871.8/sq mi) (43rd) |

ប្រជាជនជាតិដែលរស់នៅប្រទេសហ្វីលីពីន រួមមានៈ វីសាយាន៣៣,៨% តាហ្គាឡក់២៧,៧% អ៊ីឡូកាណូ៩,៨% ប៊ីកូឡានូ៦,៨% ម៉ូរ៉ូ៥,១% កាបាំប៉ាន់ហ្គា៣,១% អ៊ីហ្វូរ៉ត់១,៧% ប៉ាន់ហ្គាស៊ីណិនស៍ ១,៤% ចិន១,២% សាំបូអាន់ហ្គេញ៉ូ១,១% និងផ្សេងៗទៀត៦,៨%។ ប្រជាជនហ្វីលីពីន៩២%កាន់គ្រីស្ត សាសនា៥,៥៧%ឥស្លាម និង២,៤៣%ផ្សេងៗទៀត។

## របបនយោបាយ

ហ្វីលីពីនជាប្រទេសប្រជាធិបតេយ្យដឹកនាំដោយប្រធានាធិបតី។ ប្រទេសនេះ ជារដ្ឋរួមតែមួយលើកលែងតែ តំបន់មូស្លីមមិនដាណាវដែលជាតំបន់ស្វ័យត្ត។

តួនាទីប្រធានាធិបតីជាប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធ។ ប្រធានាធិបតីជ្រើសរើស តាមរយៈការបោះឆ្នោត ដោយមានប្រជាប្រិយភាពសម្រាប់តែមួយអាណត្តិរយៈពេល៦ឆ្នាំ។ គាត់ជាអ្នកតែងតាំងនិងជាប្រធានគណៈរដ្ឋមន្ត្រី។

ប្រទេសហ្វីលីពីនមានសភាពីរ គឺសភា និងព្រឹទ្ធសភា។ សមាជិកព្រឹទ្ធសភាជ្រើសរើសតាមរយៈការបោះឆ្នោត មានអាណត្តិ៦ឆ្នាំ។ សមាជិកព្រឹទ្ធសភាត្រូវបានគេជ្រើសរើស នៅពេលដែលមានការបោះឆ្នោតជ្រើសរើសសភាតំណាងស្រុក និងតំណាងតំបន់។ សមាជិកសភាជ្រើសរើសតាមរយៈការបោះឆ្នោតមានអាណត្តិ៣ឆ្នាំ។

អំណាចតុលាការស្ថិតនៅលើតុលាការជាន់ខ្ពស់ រួមមានប្រធានមួយរូប និងជាប្រធានសមាគមតុលាការចំនួន១៤ ដែលត្រូវបានតែងតាំងដោយប្រធានាធិបតី ដោយមានការអនុម័ត ដោយក្រុមប្រឹក្សាតុលាការ និងក្រុមប្រឹក្សាគណៈមេធាវី។

ប្រទេសហ្វីលីពីនចែកជាបីក្រុមកោះ គឺលូស៊ូន វីសាយាស់ និងមិនដាណាវ។ បែងចែកជា១៨តំបន់ ៨១ខេត្ត ១៤៥ទីក្រុង រដ្ឋធានី១៤៨៩ និង៤២០៣៦បារាំងហ្គៃ។

## សេដ្ឋកិច្ច

| **GDP** (nominal) | 2017 estimate |
|---|---|
| Total | $348.593 billion[7] |
| Per capita | $3,280[7] |

សេដ្ឋកិច្ចប្រទេសហ្វីលីពីន ជាប់លំដាប់ទី៣៦នៅលើពិភពលោក តាមរយៈការប៉ាន់ប្រមាណពីផលិតផលក្នុងស្រុកចំនួន៣១១,៦៨៧ពាន់លានដុល្លារ។ ផលិតផលនាំចេញរួមមានផលិតផលសឺមីខនដាក់ទ័រនិងអគ្គីសនី បរិក្ខារដឹកជញ្ជូន សំលៀកបំពាក់ ផលិតផលទង់ដែង ប្រេងកាតតៅ ប្រេងដូង និងផ្លែឈើ។

ប្រទេសនាំចេញសំខាន់ៗរួមមានសហរដ្ឋអាមេរិក ជប៉ុន ចិន សិង្ហបុរី កូរ៉េខាងត្បូង នីឌ័រឡែនដ៍ ហុងកុង អាឡឺម៉ង់ តៃវ៉ាន់ និងថៃ។

ជាប្រទេសឧស្សាហកម្មថ្មី សេដ្ឋកិច្ចហ្វីលីពីនបានកំពុងនឹងផ្លាស់ប្តូរពីការពឹងផ្អែកលើវិស័យកសិកម្មទៅជាប្រទេសសេដ្ឋកិច្ចពឹងផ្អែកលើវិស័យសេវាកម្មនិងផលិតកម្មឧស្សាហកម្ម។ កម្លាំងពលកម្មមានប្រហែល ៤០,៨១៣លាននាក់។ វិស័យកសិកម្មមានកម្លាំងពលកម្មចំនួន៣០% ផ្តល់ចំណូលបាន១៤%នៃGDP, វិស័យឧស្សាហកម្មផ្តល់ការងារចំនួន១៤% និងផ្តល់ចំណូលបាន៣០%នៃGDP ចំណែកវិស័យសេវាកម្មផ្តល់ការងារបានចំនួន៤៧%នៃកម្លាំងពលកម្ម និងផ្តល់ចំណូលបាន៥៦%នៃGDP។ បច្ចុប្បន្នប្រទេសហ្វីលីពីនមានប្រជាជន៤៥%នៃប្រជាជនមានចំណូលតិចជា២ដុល្លារក្នុងមួយថ្ងៃ។

## បញ្ហាសំខាន់ៗ

អស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមកហើយ ដែលហ្វីលីពីនត្រូវប្រឈមមុខនឹងពួកទ័ពព្រៃអ៊ីស្លាមផ្តាច់ទឹកដីនិយមនៅប៉ែកខាងត្បូងនៃប្រទេស ដូចជានៅកោះMindanao, Sulu BasilanនិងJolo ជាដើម។ ពួកអ្នកកាន់សាសនាអ៊ីស្លាមនៅទីនោះបានផ្តើមគុំកួនទីក្រុងម៉ានីល ចាប់ពីទសវត្សរ៍ទី៥០មក ពោលគឺតាំងពីរដ្ឋាភិបាលបានផ្តើមបញ្ជូនអ្នកកាន់គ្រិស្តសាសនា ទៅតាំងលំនៅដ្ឋាននៅលើកោះMindanao។ ពីព្រោះតាំងពីពេលនោះមក ជម្លោះសាសនាបានកើតឡើង ជាពិសេសនៅក្នុងទសវត្សរ៍ទី៧០ នៅពេលដែលអ្នកកាន់សាសនាអ៊ីស្លាម និងអ្នកកាន់គ្រិស្តសាសនាបានផ្តើមកាប់សម្លាប់គ្នាយ៉ាងសាហាវព្រៃផ្សៃជាទីបំផុត។

គឺនៅក្នុងបរិបទដ៏តានតឹងបែបនេះហើយ ដែលចលនាអ៊ីស្លាមផ្តាច់ទឹកដីនិយមចំនួនពីរបានកកើតឡើង។ មួយឈ្មោះរណសិរ្សម៉ូរ៉ូរំដោះជាតិ និងមួយទៀតឈ្មោះរណសិរ្សម៉ូរ៉ូរំដោះអ៊ីស្លាម។ រណសិរ្សទាំងពីរទាមទារចង់បានរដ្ឋឯករាជ្យមួយសម្រាប់អ្នកកាន់សាសនាអ៊ីស្លាម រដ្ឋអ៊ីស្លាមឯករាជ្យមួយដែលគ្របយកកោះ Mindanao Sulu Basilan និង Jolo។ ដើម្បីសម្រេចមហិច្ឆតារបស់ខ្លួន ចលនាប្រដាប់អាវុធទាំងពីរនេះធ្វើសង្គ្រាមទ័ពព្រៃប្រព្រឹត្តឃាតកម្មនិងបង្កភេរវកម្ម។

រីឯរដ្ឋាភិបាលហ្វីលីពីនវិញ ជួនកាលអនុវត្តនយោបាយវាយបង្ក្រាប និងជួនកាលទៀតនយោបាយលួង

លោមពួកអ្នកផ្តាច់ទឹកដីនិយម រហូតដល់ទទួលបានជោគជ័យមួយធំនៅឆ្នាំ១៩៧៦។ កាលណោះ កិច្ចព្រមព្រៀងមួយរវាងទីក្រុងម៉ានីលនិងរណសិរ្សទាំងពីរនៃចលនាទាមទារឯករាជ្យ បានបង្កើតឲ្យមានតំបន់ស្វយ័តមួយនៅប៉ែកខាងលិចនៃកោះMindanao ជាទីដែលអ្នកកាន់គ្រិស្តសាសនាមានចំនួនច្រើនជាងអ្នកកាន់សាសនាអ៊ីស្លាម។ អ៊ីចឹងហើយបានជាពីរឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៨ រណសិរ្សម៉ូរ៉ូរំដោះជាតិនិងរណសិរ្សម៉ូរ៉ូរំដោះអ៊ីស្លាមដែលយល់ដឹងថាបានចាញ់បោករដ្ឋាភិបាល សម្រេចចិត្តចាប់អាវុធធ្វើការតស៊ូជាថ្មីឡើងវិញ។ សង្គ្រាមទ័ពព្រៃដែលផ្តើមឡើងវិញ បានទាំងបណ្តាលឲ្យចំនួនជនភៀសសឹកកើនរហូតដល់ទៅ៥០០ ០០០នាក់ទៀតផងនៅក្នុងទសវត្សរ៍ទី៨០។

នៅដើមទសវត្សរ៍ទី៩០ រដ្ឋាភិបាលទីក្រុងម៉ានីលសុខចិត្តចរចាជាថ្មីឡើងវិញជាមួយពួកទ័ពព្រៃ។ នៅទីបំផុត ការចរចាដែលបានប្រព្រឹត្តទៅអស់ជាច្រើនឆ្នាំ នាំមកនូវជោគជ័យដ៏ធំធេងសម្រាប់រដ្ឋអំណាច។ កាលណោះ គឺនៅឆ្នាំ១៩៩៧ រណសិរ្សម៉ូរ៉ូរំដោះជាតិបានយល់ព្រមដាក់អាវុធ និងបានទទួលពីរដ្ឋាភិបាលហ្វីលីពីនស្វ័យភាពសម្រាប់កោះMindanao។ ផ្ទុយទៅវិញ រណសិរ្សម៉ូរ៉ូរំដោះអ៊ីស្លាមបានសម្រេចចិត្តបន្តសង្គ្រាមទ័ពព្រៃ ដើម្បីបង្កើតរដ្ឋអ៊ីស្លាមឯករាជ្យមួយឲ្យទាល់តែបាន។

យ៉ាងណាក៏ដោយ ពីចុងទសវត្សរ៍ទី៩០ រហូតដល់ប៉ុន្មានឆ្នាំចុងក្រោយនេះ ពួកទ័ពព្រៃដែលបានធ្វើឲ្យរដ្ឋាភិបាលហ្វីលីពីនល្វឹងមុខខ្លាំងជាងគេ គឺពួកAbu Sayyaf។ គឺសុទ្ធសឹងជាពួកអ៊ីស្លាមជ្រុលនិយមផុតលេខដែលបានផ្តាច់ខ្លួនចេញពីរណសិរ្សម៉ូរ៉ូរំដោះអ៊ីស្លាម។ ពួកAbu Sayyaf ផ្តើមមានឈ្មោះល្បីល្បាញពេញពិភពលោកនៅឆ្នាំ២០០០ ដោយហេតុតែកាលណោះពួកជ្រុលនិយមទាំងនេះបានចាប់ជនជាតិស្បែកសជាច្រើននាក់ធ្វើជាចំណាប់ខ្មាំង។ ប៉ុន្តែ នៅឆ្នាំ២០០៦ នៅក្នុងសង្គ្រាមប្រឆាំងភេរវកម្មអន្តរជាតិ កងទ័ពអាមេរិកាំងនិងកងទ័ពហ្វីលីពីនបានពួតដៃគ្នាវាយសំពងយ៉ាងដំណំទៅលើពួកAbu Sayyaf ដែលសហរដ្ឋអាមេរិកសង្ស័យថាមានទំនាក់ទំនងជាមួយបណ្តាញភេរវកម្មអន្តរជាតិអាល់កៃដា។

សព្វថ្ងៃនេះ ពួកAbu Sayyaf មិនសូវមានឥទ្ធិពលខ្លាំងដូចមុនទេ តែនៅបន្តចាប់ជនជាតិបរទេសធ្វើជាចំណាប់ខ្មាំង ដើម្បីទុកសម្រាប់លោះយកលុយ។ តាំងពីឆ្នាំ២០១១មក ពួកទ័ពព្រៃនេះបានចាប់ខ្លួនជនជាតិអាស៊ីជាពិសេស។ ក៏ប៉ុន្តែកន្លងទៅថ្មីៗនេះ ជនជាតិអឺរ៉ុបពីរនាក់បានបាត់ខ្លួន អាចឋិតនៅក្នុងកណ្តាប់ដៃរបស់ពួកAbu Sayyaf។ ដូច្នេះ សព្វថ្ងៃនេះ មាននៅសល់តែទ័ពព្រៃប្រមាណ១២ ០០០នាក់របស់រណសិរ្សម៉ូរ៉ូរំដោះអ៊ីស្លាមប៉ុណ្ណោះ ដែលបន្តប្រឆាំងខ្លាំងនឹងរដ្ឋាភិបាលហ្វីលីពីន។ ពួកទាំងនេះឈប់ទាមទារចង់បានរដ្ឋអ៊ីស្លាមឯករាជ្យទៀតហើយ ចង់បានស្វ័យភាពសម្រាប់តំបន់ប៉ែកខាងត្បូងទាំងមូល។ កាលពីខែសីហាឆ្នាំ២០១១កន្លងទៅនេះ ប្រធានាធិបតីBonigno Aquino ដែលសន្យាថានឹងបិទបញ្ចប់ជាស្ថាពរទំព័រទ័ពព្រៃនៃប្រទេសបានជួបចរចាជាមួយមេដឹកនាំនៃរណសិរ្សម៉ូរ៉ូរំដោះអ៊ីស្លាម។ ប៉ុន្តែ ស្រាប់តែពីរខែក្រោយមក យន្តហោះចម្បាំងហ្វីលីពីនបានវាយប្រហារទៅលើពួកទ័ពព្រៃម៉ូរ៉ូជាលើកទីមួយបង្អស់តាំងពីឆ្នាំ២០០៨មក។

ប្រតិបត្តិការយោធានោះដែលបានបណ្តាលឲ្យមានស្លាប់រាប់សិបនាក់នៅខាងពួកទ័ពព្រៃនិងដែលបានបណ្តាលឲ្យមានជនភៀសសឹកចំនួនជាង១០ ០០០នាក់អាចធ្វើឲ្យកិច្ចចរចាសន្តិភាពដ៏កម្រមួយស្លាប់តាយហោងកណ្តាលផ្លូវ៕

តាំងពីរបបផ្តាច់ការរបស់ម៉ាកូស(Marcos)បានដួលរលំនៅឆ្នាំ១៩៨៦ រហូតមកទល់សព្វថ្ងៃ ប្រធានាធិបតីហ្វីល្លីពីនបន្តបន្ទាប់គ្នា បាននិងកំពុងបន្តខ្នះខ្នែងបោសសំអាតកាកសំណល់នៃរបបចាស់ និងពង្រឹងប្រព័ន្ធប្រជាធិបតេយ្យនៃប្រទេស។ ក៏ប៉ុន្តែ លទ្ធិប្រជាធិបតេយ្យហ្វីល្លីពីន នៅតែមានលក្ខណៈផុយស្រួយមែនទែន។

លទ្ធិប្រជាធិបតេយ្យហ្វីល្លីពីន បានលេចចេញជាពន្លកឡើង នៅខែកុម្ភៈឆ្នាំ១៩៨៦។ កាលនោះ សហរដ្ឋអាមេរិក ក្រោមអាណត្តិប្រធានាធិបតីរបស់រីហ្កាន(Reagan) បានបង្ខំឲ្យ ម៉ាកូសដែលជាអ្នកកាន់អំណាចផ្តាច់ការជុះស្លែ រៀបចំបោះឆ្នោតដោយសេរី។ ជោគជ័យស្រាប់តែបានទៅលោកស្រីកូរី អាគីណូ(Cory Aquino) ភរិយាមេម៉ាយរបស់មេដឹកនាំគណបក្សប្រឆាំង លោកបេនីញ៉ូ អាគីណូ(Benigno Aquino) លោកបេនីញ៉ូ អាគីណូដែលត្រូវបានគេធ្វើឃាត នៅឆ្នាំ១៩៨៣។

ក៏ប៉ុន្តែ ម៉ាកូសមិនព្រមចុះចេញពីអំណាច ជាហេតុបាន បង្កឲ្យមានមហាបាតុកម្មដែលគេប្រសិទ្ធនាមឲ្យថា បដិវត្តន៍សីលធម៌។ នៅទីបំផុត ម៉ាកូស បានបង្ខំចិត្តនិរទេសទៅស្រុកក្រៅ ក្រោយពីត្រូវបានវិហារកាតូលិក កងទ័ព សហរដ្ឋអាមេរិកឈប់គាំទ្រនិងបោះបង់ចោល។

តាំងពីពេលនោះមក លទ្ធិប្រជាធិបតេយ្យបានក្លាយជាការពិតនៅហ្វីល្លីពីន ស្តែងចេញតាមរយៈការអនុម័តរដ្ឋធម្មនុញ្ញមួយនៅឆ្នាំ១៩៨៧ និងតាមរយៈការផ្លាស់ប្តូរប្រធានាធិបតីបន្តបន្ទាប់គ្នា៖ មានលោកស្រីកូរី អាគីណូ ពីឆ្នាំ១៩៨៦ដល់ឆ្នាំ១៩៩២ លោក ហ្វីឌែល រ៉ាមូស (Fidel Ramos) ពីឆ្នាំ១៩៩២ដល់ឆ្នាំ១៩៩៨ លោកអេស្ត្រាដា(Estrada) ពីឆ្នាំ១៩៩៨ដល់ឆ្នាំ២០០១ លោកស្រី អារ៉ូយ៉ូ(Aroyo) និងលោកបេនីញ៉ូណូយណូយ អាគីណូ(Benigno Noynoy Aquino) ពីឆ្នាំ២០១០ មកទល់សព្វថ្ងៃ។

យ៉ាងណាមិញ លទ្ធិប្រជាធិបតេយ្យហ្វីល្លីពីនផុយស្រួយមែនទែន។ មូលហេតុមានច្រើនយ៉ាង។ មូលហេតុទីមួយ គឺបណ្តាលមកពីអំណាចមួយភាគធំបានធ្លាក់ទៅក្នុងកណ្តាប់ដៃ របស់ពួកអ្នកមានជាងគេបង្អស់មួយក្រុមនិងរបស់ក្រុមគ្រួសារពួកគេ ជាភាសាបារាំង គេហៅថា Oligarchie។ បានន័យថា ត្រកូលគ្រួសារអស់ទាំងនេះមិនធ្លាក់ខ្លួនក្រ និងនៅតែបន្ត មានអំណាចធំ តរហូតមកទល់សព្វថ្ងៃ ទោះបីជាម៉ាកូសនិងបក្សពួករបស់ម៉ាកូស ឈប់គ្រប់គ្រងប្រទេសហ្វីល្លីពីន ជាងម្ភៃប្លាយឆ្នាំកន្លងមកហើយក៏ដោយ។ ត្រកូលគ្រួសារអស់ទាំងនេះ បន្តមានទំនាក់ទំនងជាមួយថ្នាក់ដឹកនាំនយោបាយ បន្តគាបសង្កត់ និងអូសទាញរដ្ឋាភិបាលហ្វីល្លីពីនបន្តបន្ទាប់គ្នា ឲ្យអនុវត្តនយោបាយណា ដែលអាចជួយបង្កើនផលប្រយោជន៍របស់ពួកគេតទៅទៀត។

មូលហេតុទីពីរនៃលទ្ធិប្រជាធិតេយ្យផុយស្រួយនៅហ្វីល្លីពីន គឺបណ្តាលមកពីថ្នាក់ដឹកនាំនៃប្រទេស និងក្រុមគ្រួសាររបស់ថ្នាក់ដឹកនាំ ចាត់ទុកសម្បត្តិសាធារណៈខ្លះ ថាជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ ជាភាសាបារាំង គេហៅថា Patrimonialisme។

វត្តមាននៃបាតុភាព Oligarchie និងបាតុភាពPatrimonialisme នៅក្នុងប្រព័ន្ធនយោបាយហ្វីល្លីពីន បង្កឲ្យមានអំពើពុករលួយ និងជួនកាលអស្ថិរភាពនយោបាយទៀតផង។ ពីព្រោះវាធ្វើឲ្យរដ្ឋអំណាចទន់ជ្រាយ និងជម្រុញឲ្យមន្ត្រីរដ្ឋការដែលមិនអព្យាក្រឹតទាល់តែសោះ អត់គោរពច្បាប់ ហើយមិនអនុវត្តច្បាប់ ពេលត្រូវប្រឈមមុខនឹងអ្នកមានឬអ្នកមានអំណាចម្តងៗ។

គឺបាតុភាពOligarchie និងបាតុភាពPatrimonialismeនេះហើយ ដែលបានបង្កឲ្យមានអំពើពុក

រលួយ និងនៅទីបំផុតបានបណ្តាលឲ្យលោកអេស្ត្រាដាដួលរលំពីតំណែងប្រធានាធិបតី នៅឆ្នាំ២០០១។

អេស្ត្រាដាជាតួឯកកុនម្នាក់ ដែលបានជាប់ឆ្នោតជាប្រធានាធិបតី នៅឆ្នាំ១៩៩៨ ដោយសារតែល្បីឈ្មោះខ្លាំង។ ក៏ប៉ុន្តែ បន្តិចម្តងៗ អេស្ត្រាដាដែលត្រូវរ៉ូវគ្នាជាមួយត្រកូលគ្រួសារអ្នក មានស្តុកស្តម្ភខ្លះតាំងពីជំនាន់ម៉ារកូសមក បានទទួលប្រាក់សំណូកពីពួកអ្នកទាំងនោះ ហើយដើម្បីសងគុណពួកគេវិញ បានប្រើអំណាចជួយពួកគេឲ្យរកស៊ីកាន់តែមានបាន។

នៅក្នុងចំណោមពួកអ្នកមានដែលបានស៊ុមគ្រលំជាមួយរដ្ឋអំណាចអេស្ត្រាដា រួមមានជាអាទិ៍ Lucio TAN។ តាមរយៈអភិក្រមនៃឯកជនភាវូបនីយកម្មមិនស្របច្បាប់មួយ Lucio TAN បានទិញភាគហ៊ុននៃធនាគារPhilippine National Bank បានរហូតដល់ទៅ៤៦% ហើយដោយសារតែអន្តរាគមន៍របស់ប្រធានាធិបតីអេស្ត្រាដា Lucio TAN បានពង្រឹងយ៉ាង មាំល្អ ឥទ្ធិពលរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាលនៃធនាគារទៀតផង។

អ៊ីចឹងហើយ បានជាបន្តិចម្តងៗ អ្នកនយោបាយឆ្វេងនិយមដែលជាចន្ទល់មួយដ៏សំខាន់របស់អេស្ត្រាដាបានបែរខ្នងដាក់គាត់ ឈប់គាំទ្រគាត់ ជាពិសេសក្រោយពីសភាហ្វីលីពីន បានចាប់ផ្តើមតុបតែងនីតិក្រមដើម្បីទំលាក់គាត់ចេញពីតំណែងប្រធានាធិបតី។ នៅឆ្នាំ២០០១ អេស្ត្រាដាបានបង្ខំចិត្តលាលែងចេញពីតំណែងនិងប្រគល់អំណាចទៅឲ្យលោកស្រីអារ៉ូយ៉ូដែលជាអនុប្រធានាធិបតី កាន់កាប់វិញម្តង។

ចំណុចខ្សោយមួយទៀតនៃលទ្ធិប្រជាធិបតេយ្យហ្វីលីពីន គឺការប៉ុនប៉ងធ្វើរដ្ឋប្រហារមិនស្ងាងពីសំណាក់កងទ័ព។ ឧទាហរណ៍ជាក់ស្តែង នៅក្រោមអាណត្តិប្រធានាធិបតីរបស់កូរី អាគីណូ ពីឆ្នាំ១៩៨៦ដល់ឆ្នាំ១៩៩២ មានច្រើនណាស់ការប៉ុនប៉ងធ្វើរដ្ឋប្រហារ ក្នុងនោះមានរដ្ឋប្រហារចំនួនពីរដែលរិះតែទទួលជោគជ័យ។

ក្រោយមកទៀត ក៏ដូចគ្នាអ៊ីចឹងដែរ លោកស្រីប្រធានាធិបតីអារ៉ូយ៉ូ ក៏ត្រូវប្រឈមមុខមិនស្ងាង នឹងការប៉ុនប៉ងធ្វើរដ្ឋប្រហារដែរ។ នៅខែកុម្ភៈឆ្នាំ២០០៦ អារ៉ូយ៉ូបានសម្រេចចិត្តប្រកាសដាក់ប្រទេសទាំងមូលក្នុងភាពអាសន្ន ដើម្បីទប់ស្កាត់កុំឲ្យ« រដ្ឋប្រហាររបស់ពួកសកម្មជនឆ្វេងនិយមនិងរបស់ពួកយោធាផ្សងព្រេងនិយម» កើតឡើងទាន់។ ក៏ប៉ុន្តែ ពួកអ្នកប្រឆាំងបាននាំគ្នាចោទថាអារ៉ូយ៉ូ បានធ្វើដូចនេះ ក្នុងគោលដៅពង្រឹងអំណាចរបស់លោកស្រីតែប៉ុណ្ណោះ។

តាំងពីឆ្នាំ២០១០មក ណូយណូយ អាគីណូ កូនប្រុសរបស់លោកស្រីអតីតប្រធានាធិបតីកូរី អាគីណូជាអ្នកដឹកនាំប្រទេសហ្វីលីពីន។ តាមមើលទៅ ណូយណូយអាគីណូ ក៏មិនសូវខុសពីប្រធានាធិបតីមុនៗដែរ នឹងប្រហែលជាគេចមិនផុតឡើយពីបាតុភាពបក្សពួកនិយម និងគ្រួសារនិយម។ មូលហេតុ គឺមកអំពីនៅហ្វីលីពីនអំណាចនយោបាយ ក៏ដូចអំណាចសេដ្ឋកិច្ច សុទ្ធតែឋិតនៅក្នុងកណ្តាប់ដៃរបស់គ្រួសារអ្នកមាននិងអ្នកមានឈ្មោះល្បីល្បាញមួយក្រុមដដែលជាដដែល ទោះបីជាប្រទេសនេះបានឆ្លងចេញផុតពីសករាជអំណាចផ្តាច់ការរបស់ម៉ារកូស តាំងពីឆ្នាំ១៩៨៦ក៏ដោយ៕

## សំណួរត្រិះរិះ

១. តើប្រទេសហ្វីលីពីន មានឈ្មោះផ្លូវការអ្វី?

២. តើប្រទេសហ្វីលីពីន មានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?

៣. តើប្រទេសហ្វីលីពីន មានប្រជាជនប៉ុន្មានលាននាក់?
៤. តើប្រទេសហ្វីលីពីន មានរបបនយោបាយយ៉ាងដូចម្តេច?
៥. តើប្រធានាធិបតីហ្វីលីពីន មានអាណត្តិប៉ុន្មានឆ្នាំ?
៦. តើវិស័យសេដ្ឋកិច្ចហ្វីលីពីន មានប្រភពចំណូលពីវិស័យអ្វីខ្លះ?
៧. តើដៃគូពាណិជ្ជកម្មសំខាន់របស់ប្រទេសហ្វីលីពីន មានប្រទេសណាខ្លះ?
៨. តើប្រទេសហ្វីលីពីន មានបញ្ហាអ្វីខ្លះ?

## ១០. ប្រទេសឡាវ





**ឈ្មោះប្រទេស៖**សាធារណរដ្ឋប្រជាធិបតេយ្យប្រជាជនឡាវ
**ក្រឡាផ្ទៃ៖** ២៣៦ ៨០០ គីឡូម៉ែត្រការ៉េ
**រាជធានី៖** វៀងចន្ទ
**ភាសាជាតិ៖** ឡាវ ភាសាផ្លូវការ៖ ឡាវ**ថ្ងៃដែលចូលជាសមាជិកអាសស៊ាន៖** ២៣ កក្កដា ១៩៩៧
**ថ្ងៃឯករាជ្យ:** ១៩ ខែកក្កដា ឆ្នាំ១៩៤៨ ពីបារាំង
**ទង់ជាតិ៖**




- រង្វង់មូលដែលនៅចំកណ្តាល តំណាងឱ្យដួងចន្ទដែលបញ្ចេញពន្លឺនៅពីទន្លេមេគង្គ
- ផ្នែកផ្ទៃពណ៌ខៀវ តំណាងឱ្យភាពមានបាន និងភាពសំបូរហូរហៀររបស់ប្រទេស
- ពណ៌ក្រហម តំណាងឱ្យប្រជាជនដែលបានស្លាប់នៅក្នុងសង្គ្រាម ដើម្បីសេរីភាព

### ទីតាំងភូមិសាស្ត្រ



ប្រទេសឡាវគឺជាប្រទេសដែលគ្មានផ្លូវទៅកាន់សមុទ្រទេ ភាគច្រើនគឺជាតំបន់ភ្នំខ្ពស់ៗ ហើយក៏មិនមានវាលទំនាបសម្រាប់ធ្វើកសិកម្មច្រើនដែរ។

ព្រំប្រទល់ខាងជើងជាប់នឹងប្រទេសចិន ខាងត្បូងជាប់នឹងប្រទេសថៃ និងប្រទេសកម្ពុជា ខាងកើតជាប់នឹងប្រទេសថៃ និងប្រទេសមីយ៉ាន់ម៉ា។

### ប្រជាជន

យោងតាមជំរឿនឆ្នាំ២០១៥ ចំនួនប្រជាជនសរុបមាន៖ ៦ ៤៩២ ២២៨នាក់។ ជនជាតិដែលរស់នៅប្រទេសឡាវ( ឆ្នាំ២០០៥ )រួមមាន៖ ជនជាតិឡាវ៥៥% ខ្មុ១១% ម៉ុង៨% និងផ្សេងៗទៀតចំនួន២៦%។ សាសនាព្រះពុទ្ធ។

**របបនយោបាយ**

របបគ្រប់គ្រង៖ របបសង្គមនិយមមានប្រធានាធិបតីជាអ្នកដឹកនាំ

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាជនឡាវគ្រប់គ្រងដោយរបបសង្គមនិយម ដោយគណបក្សប្រជាជនបដិវត្តឡាវ តាំងពីឆ្នាំ១៩៧៥ មានប្រមុខប្រទេស និងនាយករដ្ឋមន្ត្រីជាអ្នកដឹកនាំ។ លោកប្រធានាធិបតី ប៊ុនញ៉ាំង វ៉ូរ៉ាចិត គាត់ជាអគ្គលេខាបក្សប្រជាជនបដិវត្តឡាវ។

ប្រមុខរដ្ឋាភិបាល គឺជានាយករដ្ឋមន្ត្រី ជាសមាជិកការិយាល័យនយោបាយបក្សកុំម្មុយនីសឡាវ។ គោលនយោបាយរដ្ឋាភិបាលសម្រេចដោយបក្ស ដែលមានសមាជិកការិយាល័យនយោបាយចំនួន១១រូបនៃគណបក្សប្រជាជនបដិវត្តឡាវ និងសមាជិកគណកម្មាធិការមជ្ឈមបក្សប្រជាជនបដិវត្ត៦១រូប។ ការសម្រេចចិត្តសំខាន់ៗត្រូវបានវេតូដោយក្រុមប្រឹក្សារដ្ឋមន្ត្រី។ សាធារណរដ្ឋសង្គមនិយមវៀតណាមនៅតែមានឥទ្ធិពលការិយាល័យនយោបាយឡាវ បក្សកុំម្មុយនីយ និងយោធា។

នៅឆ្នាំ១៩៩១ ប្រទេសឡាវបានអនុម័តរដ្ឋធម្មនុញ្ញថ្មី និងបានរក្សាតួនាទីដឹកនាំដោយគណបក្សប្រជាជនបដិវត្តឡាវដដែល។ នៅឆ្នាំ១៩៩២ ការបោះឆ្នោតត្រូវបានធ្វើឡើងសម្រាប់៨៥អសនៈសភាជាតិថ្មី គ្រប់គ្រងដោយរដ្ឋាភិបាលបក្សកុំម្មុនីយតែមួយ បោះឆ្នោតជាសម្ងាត់មានអាណត្តិ៥ឆ្នាំ។ នៅការបោះឆ្នោតឆ្នាំ២០១១ សមាជិកសភាកើនដល់១៣២រូប។

ប្រទេសឡាវចែកចេញជា១៨ខេត្ត និងទីក្រុងមួយគឺ វៀងចន្ទ។ ខេត្តបែងចែកទៅជាស្រុក និងភូមិ។ នយោបាយរបស់ប្រទេសឡាវមានស្ថិរភាពជាខ្លាំង ដែលជាបច្ច័យដ៏សំខាន់មួយដែលអូសទាញឱ្យជនបរទេសចូលទៅបណ្តាក់ទុន។

**សេដ្ឋកិច្ច**

| GDP (nominal) | 2017 estimate |
|---|---|
| Total | $14.971 billion[4] |
| Per capita | $2,051[4] |

ប្រទេសឡាវជាប្រទេសដែលមានធនធានធម្មជាតិជាច្រើន ដូច្នេះហើយទើបសេដ្ឋកិច្ចរបស់ប្រទេសឡាវត្រូវពឹងទៅលើការនាំចេញធនធានធម្មជាតិជាគោល ព្រោះកម្លាំងពលករនៅក្នុងប្រទេសថោក និងនយោបាយមានស្ថិរភាព ដែលធ្វើឱ្យប្រទេសជាច្រើនចាប់អារម្មណ៍ទៅបណ្តាក់ទុន។

**ទំនិញឧស្សាហកម្មសំខាន់** វាយនភណ្ឌ រ៉ែ ត្បូងថ្ម វារីអគ្គីសនី

**ទំនិញកសិកម្មសំខាន់** ឈើ ឈើកែច្នៃ

**ធនធានសំខាន់** ព្រៃឈើ សំណប៉ាហាំង ម្នាងសិលា ត្បូងថ្ម ដែក សំណ ស័ង្កសី មាស

**ប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់** ថៃ វៀតណាម ចិន ជប៉ុន សហរដ្ឋអាមេរិក សហភាពអឺរ៉ុប

ទំនិញនាំចេញ វារីអគ្គិសនី រ៉ែ ត្បូងថ្ម ឈើកែច្នៃ សម្លៀកបំពាក់

**ទំនិញនាំចូល** គ្រឿងឧបភោគបរិភោគ ប្រេង និងហ្គាសសម្រាប់ដាំស្ល យានជំនិះ ឧបករណ៍អគ្គិសនី។

**បញ្ហាសំខាន់ៗ**

**ឡាវ ៖ ពីកុម្មុយនិស្តរណបវៀតណាម មកជាអំណាចបក្សតែមួយក្រោមឥទ្ធិពលចិន?(ទី២៣)**

ជាប្រទេសកុម្មុយនិស្តតាំងពីឆ្នាំ១៩៧៥មក ប្រទេសឡាវបានចាប់ផ្តើមលះបង់ចោលសេដ្ឋកិច្ចផែនការ នៅឆ្នាំ១៩៨៦ ដើម្បីបែរទៅរកសេដ្ឋកិច្ចទីផ្សារវិញ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលឡាវក៏បានផ្តើមងាក ចេញពីមនោគមវិជ្ជាMarx-Lénineនិយម បានបង្កើនទំនាក់ទំនងសេដ្ឋកិច្ចជាមួយប្រទេសចិននិងថៃ និងបាន រើបម្រះម្តងបន្តិចៗចេញពីឥទ្ធិពលនយោបាយ ផ្តាច់មុខរបស់វៀតណាម។

ក្រោយពីបានធ្លាក់ទៅនៅក្រោមការកាន់កាប់របស់ចលនាប៉ាថេតឡាវនៅឆ្នាំ១៩៧៥មក ប្រទេស ឡាវ បានអនុម័តយករបបកុម្មុយនិស្តផ្តាច់ការនិងសេដ្ឋកិច្ចផែនការ។ នៅក្នុងសម័យសង្គ្រាមត្រជាក់និងនៅ ក្នុងបរិបទនៃការប្រជែងឥទ្ធិពលគ្នារវាងសហភាពសូវៀត និងចិន ឡាវកុម្មុយនិស្ត បានក្លាយទៅជាប្រទេស រណបរបស់វៀតណាមដែលបានជ្រើសយកសហភាពសូវៀតធ្វើជារៀមច្បង ដើម្បីប្រឆាំងនឹងចិន។ នៅក្នុង ន័យនេះថ្នាក់ដឹកនាំទីក្រុងវៀងចន្ទន៍(Vientiane) បានអនុញ្ញាតឲ្យវៀតណាមដាក់ទ័ពប្រមាណពី៤០ ០០០ ទៅ៥០ ០០០នាក់នៅលើទឹកដីខ្លួនពីឆ្នាំ១៩៧៥រហូតដល់ពាក់កណ្តាលទសវត្សរ៍ទី៨០។

តាំងពីឆ្នាំ១៩៨៦មក ប្រទេសឡាវដែលយកគំរូតាមវៀតណាម បាននិងកំពុងបន្តធ្វើកំណែទម្រង់ ដោយលះបង់ចោលបណ្តើរៗសេដ្ឋកិច្ចផែនការហើយងាកមករកសេដ្ឋកិច្ចទីផ្សារវិញ។ ប៉ុន្តែទន្ទឹមនេះ ថ្នាក់ ដឹកនាំបន្តអនុវត្តរបបនយោបាយផ្តាច់ការ ដែលគ្រប់គ្រងដោយគណបក្សតែមួយគត់ នោះគឺបក្សបដិវត្តន៍ ប៉ា ថេតឡាវ(PRPL)។ ជាក់ស្តែង តំណាងរាស្ត្រទាំងអស់លើកលែងតែ៤នាក់ចេញ សុទ្ធតែជាសមាជិករបស់ បក្សកុម្មុយនិស្ត។ អ្វីៗក៏បិតនៅក្នុងកណ្តាប់ដៃបក្សដែលលាតសន្ធឹងឥទ្ធិពលរបស់ខ្លួនចូលទៅដល់គ្រប់កៀន កោះនៃសង្គម តាមរយៈអង្គការផ្សេងៗ រួមមានជាអាទិ៍រណសិរ្សកសាងជាតិ សហព័ន្ធសហជីព សហភាពយុវវ័យ បដិវត្តន៍និងសហភាពនារីបដិវត្តន៍។

រក្សាការសម្ងាត់ នេះហើយគឺជាគោលការណ៍របស់សមាជិកទាំង១១ រូបនៃការិយាល័យនយោបាយ បក្សដែលជាអ្នកត្រួតត្រាប្រទេស។ គ្មានឡើយស្រមោលឬវត្តមានរបស់អ្នក ប្រឆាំងនៅលើឆាកនយោបាយ ហើយក៏គ្មានដែរសិទ្ធិសេរីភាពសំខាន់ៗដូចជាសេរីភាពសារព័ត៌មានជាដើម។

យ៉ាងណាក៏ដោយ ប្រទេសឡាវមានកំណើនសេដ្ឋកិច្ចខ្ពស់ល្អ នារយៈពេលជាង១០ឆ្នាំចុងក្រោយនេះ គឺប្រមាណ៦ឬ៧% ដោយសារតែគម្រោងធំៗមួយចំនួន នៅលើវិស័យវារី អគ្គិសនី រ៉ែ ដឹកជញ្ជូននិងទេសចរ ណ៍។ ក៏ប៉ុន្តែឡាវនៅតែជាប្រទេសដែលក្រីក្រជាងគេបង្អស់មួយនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍។ ជាទូទៅ អភិវឌ្ឍន៍មានលក្ខណៈយឺតយ៉ាវ ដោយហេតុតែកង្វះហេដ្ឋារចនាសម្ព័ន្ធ និងកង្វះធនធានមនុស្ស។

ប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសឡាវហាក់បីដូចជាបាននិងកំពុងបន្តរើបម្រះខ្លួនចេញពីមនោគមវិជ្ជា កុម្មុយនិស្ត។ ឧទាហរណ៍ជាក់ស្តែង លោកប៊ូអាសូន ប៊ូផាវ៉ាន់(Bouasone Bouphavanh)ដែលជានាយករដ្ឋ មន្ត្រីពីឆ្នាំ២០០៦ដល់ឆ្នាំ២០១០ បានប្រកាសដោយឥតលាក់លៀមថា លែងត្រូវការទៀតហើយទ្រឹស្តីរបស់ Marx-Léninនិងថាប្រទេសឡាវត្រូវតែអនុវត្តមនោគមវិជ្ជាថ្មី ដែលសមស្របទៅតាមកាលៈទេសៈនៃសត វត្សរ៍ទី២១ នោះគឺមនោគមវិជ្ជា«សាច់ការនិយម»។ រីឯលោកនាយករដ្ឋមន្ត្រីបច្ចុប្បន្ន គឺលោកថុងស៊ីនថំម៉ាវុន (Thongsing Thammavong) ក៏មានទស្សនៈដូចគ្នាអ៊ីចឹងដែរ។

ក្នុងគ្រាបច្ចុប្បន្ន នៅលើសាច់ការជាក់ស្តែង មនោគមវិជ្ជាកុម្មុយនិស្ត គ្មានប្រយោជន៍អ្វីផ្សេង សម្រាប់ បក្សបដិវត្តន៍ប៉ាថេតឡាវ ក្រៅតែពីអនុញ្ញាតឲ្យអាជ្ញាធរគ្រប់គ្រងរដ្ឋបាល ដាក់គំនាបទៅលើមន្ត្រីរដ្ឋការឲ្យ

គោរពវិន័យនិងទៅលើប្រជាជនឲ្យកោតខ្លាចរដ្ឋាភិបាលតែប៉ុណ្ណោះ។

លើសពីនេះទៅទៀត កម្មាភិបាលជំនាន់ថ្មីនៃបក្សកុម្មុយនិស្តឡាវយល់ឃើញថា អ្វីដែលសំខាន់ក្នុងសម័យឥឡូវ គឺសេដ្ឋកិច្ច មិនមែនមនោគមវិជ្ជាទៀតទេ។ ពួកគេចង់បើកដៃកាន់តែធំទទួលសេដ្ឋកិច្ចទីផ្សារ បើកចំហទ្វារនៃប្រទេសទទួលអង្គការអន្តរជាតិនានា និងបើកសិទ្ធិឲ្យឡាវនិងឡាវអាចជជែកពិភាក្សាគ្នាដោយសេរី។

ការប្រាថ្នាចង់ឲ្យសង្គមផ្លាស់ប្តូរបែបនេះមិនមែនចៃដន្យឡើយ។ សេដ្ឋកិច្ចទីផ្សារបាននិងកំពុងបន្តជួយរំដោះប្រទេសឡាវឲ្យរួចផុតពីឥទ្ធិពលផ្តាច់មុខរបស់វៀតណាម ដែលត្រូវប្រជែងដើងគ្នានឹងចិន ថៃ ព្រមទាំងបស្ចិមប្រទេសមួយចំនួន។ នៅក្នុងចំណោមប្រទេសទាំង៣៧ដែលដាក់ទុនរកស៊ីនៅប្រទេសឡាវសព្វថ្ងៃ វៀតណាមជាប់លំដាប់ថ្នាក់លេខ៣តែប៉ុណ្ណោះនៅក្រោយថៃនិងចិន។

ការប្រជែងដើងគ្នារវាងចិននិងវៀតណាមក្នុងការទាក់ទងរកស៊ីជាមួយប្រទេសឡាវ បាននិង កំពុងបន្តបំផុសឱ្យមាននូវសំណួរមួយចំនួនជុំវិញឥទ្ធិពលនយោបាយរបស់ទីក្រុងហាណូយ ទៅលើទីក្រុងវៀងចន្ទន៍។ តើបក្សបដិវត្តន៍ប៉ាថេតឡាវនៅតែឋិតក្រោមបង្គាប់របស់ទីក្រុងហាណូយដូចពីមុនទៀតដែរឬទេ ?តើតាមរយៈយុទ្ធសាស្ត្រនៃអំណាចស្រទន់«Soft Power» ចិនកំពុងបង្កើនឥទ្ធិពលនយោបាយរបស់ខ្លួនទៅលើប្រទេសឡាវដែរឬទេ ?

យ៉ាងណាក៏ដោយ គេកត់សម្គាល់ឃើញថា វគ្គបណ្តុះបណ្តាលនយោបាយដែលបក្សកុម្មុយនិស្តឡាវរៀបចំឡើងប្រាំខែម្តងសម្រាប់មន្ត្រីរដ្ឋការ និងដែលពីដើមតែងតែបានប្រព្រឹត្តទៅនៅទីក្រុងហាណូយ ឥឡូវនេះត្រូវលើកទៅធ្វើនៅប្រទេសចិនវិញ នៅទីក្រុងKunming ក្នុងខេត្តYunnan ជាប់នឹងព្រំដែនខាងជើងនៃប្រទេសឡាវ៕

**ជំនួបកំពូលអាស៊ាន៖ អង្គការក្រៅរដ្ឋាភិបាលប្តឹងពីការបាត់ខ្លួនសកម្មជនសិទ្ធិមនុស្សឡាវ សម្បត្តិ សំផុន(ទី៦០)**

នៅថ្ងៃសុក្រ និងថ្ងៃសៅរ៍នេះ (១៣ ១៤ ខែធ្នូ ឆ្នាំ២០១៣) ប្រមុខដឹកនាំនៃបណ្តាប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅថាអាស៊ាននោះ បានជួបជុំគ្នា នៅក្រុងតូក្យូ ដើម្បីពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងសន្តិសុខ។ ឆ្លៀតក្នុងឱកាសជំនួបកំពូលអាស៊ាននេះ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានទាក់ទាញចំណាប់អារម្មណ៍របស់មេដឹកនាំប្រទេសអាស៊ាន អោយយកចិត្តទុកដាក់លើបញ្ហាសិទ្ធិមនុស្ស នៅក្នុងបណ្តាប្រទេសសមាជិកអាស៊ាន។

ពិសេសករណីសកម្មជនសិទ្ធិមនុស្ស សម្បត្តិ សំផុន នៅប្រទេសឡាវ ដែលបានបាត់ខ្លួនមួយឆ្នាំមកហើយនោះ។ នៅថ្ងៃសុក្រម្សិលមិញ និងថ្ងៃសៅរ៍ចុងសប្តាហ៍នេះ នៅក្រុងតូក្យូ ប្រទេសជប៉ុន ប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍បានជួបពិភាក្សាគ្នាពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងសន្តិសុខ។ ឆ្លៀតក្នុងឱកាសនេះ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានទាក់ទាញចំណាប់អារម្មណ៍មេដឹកនាំប្រទេសអាស៊ាន អោយយកចិត្តទុកដាក់លើបញ្ហាសិទ្ធិមនុស្ស នៅក្នុងបណ្តាប្រទេសសមាជិកអាស៊ាននានាពិសេសករណីរបស់សកម្មជនសិទ្ធិមនុស្ស សម្បត្តិ សំផុន នៅប្រទេសឡាវ ដែលបានបាត់ខ្លួនមួយឆ្នាំមកហើយនោះ។

លិខិតមួយទាក់ទងនឹងប្រធានបទសិទ្ធិមនុស្សគួរអោយព្រួយបារម្ភ ត្រូវបានដាក់ទៅនាយករដ្ឋមន្ត្រីជប៉ុន ស៊ីនហ្សូ អាបេ ដែលជាម្ចាស់ផ្ទះរៀបចំជំនួបកំពូលអាស៊ាន រយៈពេលថ្ងៃនេះ។ គួររំលឹកថា លោកសម្បត្តិ សំផុន ជាសកម្មជនសិទ្ធិមនុស្សក្នុងសង្គមស៊ីវិលឡាវ។ លោកធ្លាប់បានធ្វើសកម្មភាពជួយជនក្រីក្រ កសិករ

ក្នុងប្រទេសឡាវ។ គេបានឃើញលោក សម្បត្តិ សំផុន ចុងក្រោយបង្អស់ នៅថ្ងៃ១៥ធ្នូ ឆ្នាំ២០១២ នៅមុខស្នងការប៉ូលិសទីក្រុងវៀងចន្ទ។ ក្នុងរូបភាពវីដេអូ គេបានឃើញលោក ត្រូវបានគេចាប់ខ្លួន ហើយគេក៏ឃើញមានវត្តមានប៉ូលិសច្រើនរូប នៅក្នុងរូបភាពវីដេអូផងដែរ។ ប៉ុន្តែរដ្ឋាភិបាលឡាវបានបដិសេធ ថាខ្លួនមិនមែនជាដើមចមនៃការបាត់ខ្លួនរបស់សកម្មជនសិទ្ធិមនុស្សនេះឡើយ។

សំរាប់លោកស្រី ហ្សឺណឺវីយ៉េវ ហ្គារីហ្គូស ជាប្រធានអង្គការ Amnesty International France ករណីលោក សម្បត្តិ សំផុន សបង្ហាញពីការរំលោភសិទ្ធិមនុស្សនៅឡាវ និងការខ្វះសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់។ អង្គការ Amnesty International France គិតថា រដ្ឋាភិបាលឡាវមានការទទួលខុសត្រូវផ្ទាល់ចំពោះវិធានការស្វែងរករូបលោក សម្បត្តិ សំផុន ហើយត្រូវធ្វើការស៊ើបអង្កេតដើម្បីចាប់ខ្លួនជនល្មើសនានាដែលបានចាប់លោកទៅ៕

**សំណួរត្រិះរិះ**

១. តើប្រទេសឡាវ មានឈ្មោះផ្លូវការអ្វី?
២. តើប្រទេសឡាវ មានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?
៣. តើប្រទេសឡាវ មានប្រជាជនប៉ុន្មានលាននាក់?
៤. តើប្រទេសឡាវ មានរបបនយោបាយយ៉ាងដូចម្ដេច?
៥. តើប្រធានាធិបតីឡាវ មានអាណត្តិប៉ុន្មានឆ្នាំ?
៦. តើវិស័យសេដ្ឋកិច្ចឡាវ មានប្រភពចំណូលពីវិស័យអ្វីខ្លះ?
៧. តើដៃគូពាណិជ្ជកម្មសំខាន់របស់ប្រទេសឡាវ មានប្រទេសណាខ្លះ?
៨. តើប្រទេសឡាវ មានបញ្ហាអ្វីខ្លះ?

# មេរៀនទី៤៖ សេដ្ឋកិច្ចអាស៊ាន

អាស៊ានដែលជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍បានក្លាយជាប្លុកសេដ្ឋកិច្ចដ៏សំខាន់មួយនៅលើឆាកពិភពលោក ជាមួយនឹងចំនួនប្រជាជនសរុបជាង៦០០លាននាក់ និងផលិតផលក្នុងស្រុកសរុបនៃពាន់ពាន់លានដុល្លារ វាជាតំបន់ដែលពោរពេញដោយសក្តានុពល។ អាស៊ានកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងពាណិជ្ជកម្ម និងការវិនិយោគពិភពលោក។ ទីតាំងយុទ្ធសាស្ត្រ និងការកើនឡើងនៃវណ្ណៈកណ្តាលធ្វើឱ្យវាក្លាយជាទីផ្សារដ៏ទាក់ទាញសម្រាប់អាជីវកម្មបរទេស។ ជាងនេះទៅទៀត កិច្ចខិតខំប្រឹងប្រែងធ្វើសមាហរណកម្មរបស់អាស៊ានកំពុងរួមចំណែកដល់ការបង្កើតប្លុកសេដ្ឋកិច្ចកាន់តែធំ និងរួបរួមកាន់តែច្រើន។

## ១. ទំហំសេដ្ឋកិច្ចអាស៊ាន

អាស៊ានមានផ្ទៃដីចំនួន៤,៤៦លានគីឡូម៉ែត្រការ៉េ ស្មើនឹង៣%នៃផ្ទៃដីពិភពលោកសរុប។ អាស៊ានមានប្រជាជនសរុបប្រហែលចំនួន៦៨៥លាននាក់(wolfram, 2023) ស្មើនឹង៨,៨%នៃប្រជាជនសរុប។ ផ្ទៃសមុទ្រមានទំហំធំជាងបីដងនៃផ្ទៃដី។ នៅក្នុងឆ្នាំ២០១០សេដ្ឋកិច្ចអាស៊ានកើនដល់ចំនួន១,៨ពាន់ពាន់លានដុល្លារ(Trillion) ជាប់លំដាប់ថ្នាក់ទី៩នៃសេដ្ឋកិច្ចពិភពលោក ស្ថិតនៅពីក្រោយសហរដ្ឋអាមេរិច ចិន ជប៉ុន អាឡឺម៉ង់ បារាំង ប្រេស៊ីល ចក្រភពអង់គ្លេស និងអ៊ីតាលី។

**លក្ខណៈសំខាន់ៗនៃសេដ្ឋកិច្ចអាស៊ាន**

- សេដ្ឋកិច្ចចម្រុះ៖ សេដ្ឋកិច្ចបណ្តាប្រទេសអាស៊ានស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៍ផ្សេងៗ ចាប់ពីសិង្ហបុរី ដែលជាមជ្ឈមណ្ឌលហិរញ្ញវត្ថុពិភពលោក រហូតដល់ប្រទេសកម្ពុជា និងឡាវ ដែលកំពុងអភិវឌ្ឍ។ ភាពចម្រុះនេះផ្តល់ទាំងបញ្ហាប្រឈម និងឱកាស។
- កំណើនយ៉ាងឆាប់រហ័ស៖ ប្រទេសអាស៊ានជាច្រើនបានជួបប្រទះនឹងកំណើនសេដ្ឋកិច្ចដ៏រឹងមាំក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ដែលជំរុញដោយកត្តាមួយចំនួនដូចជាចំនួនប្រជាជនវ័យក្មេង និងកំពុងកើនឡើង ឧស្សាហកម្មផ្តោតលើការនាំចេញ និងការវិនិយោគពីបរទេស។
- កិច្ចខិតខំប្រឹងប្រែងសមាហរណកម្ម៖ សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC: The ASEAN Economic Community) មានគោលបំណងបង្កើតទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ ដែលសម្រួលដល់លំហូរដោយសេរីនៃទំនិញ សេវាកម្ម ការវិនិយោគ ដើមទុន និងកម្លាំងពលកម្មជំនាញនៅក្នុងតំបន់។
- ទីតាំងយុទ្ធសាស្ត្រ៖ ទីតាំងភូមិសាស្ត្ររបស់អាស៊ាន ជាតំបន់ទំនាក់ទំនងដ៏សំខាន់រវាងអាស៊ីបូព៌ា អាស៊ីខាងត្បូង និងអូសេអានី ដោយផ្តល់នូវអត្ថប្រយោជន៍ជាយុទ្ធសាស្ត្រសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ។
- បញ្ហាប្រឈម៖ ទោះបីជាមានភាពខ្លាំងក៏ដោយ ក៏អាស៊ានប្រឈមមុខនឹងបញ្ហាដូចជា គម្លាតហេដ្ឋារចនាសម្ព័ន្ធ វិសមភាពប្រាក់ចំណូល និងតម្រូវការសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

កម្លាំងជំរុញកំណើនសេដ្ឋកិច្ចអាស៊ានរួមមានវិស័យ ឧស្សាហកម្មតម្រង់ទិសផលិតកម្ម និងនាំចេញ៖ ប្រទេសដូចជាវៀតណាម ថៃ និងម៉ាឡេស៊ី បានក្លាយជាមជ្ឈមណ្ឌលផលិតកម្មដ៏សំខាន់ ផលិតគ្រឿងអេឡិច

គ្រឿងបន្លាស់រថយន្ត និងវាយនភណ្ឌសម្រាប់ទីផ្សារពិភពលោក។ វិស័យសេវាកម្ម៖ វិស័យសេវាកម្ម រួមមានទេសចរណ៍ ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យា កំពុងរីកដុះដាលយ៉ាងឆាប់រហ័សនៅក្នុងប្រទេសអាស៊ានជាច្រើន។ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖ ការវិនិយោគលើការដឹកជញ្ជូន ថាមពល និងទូរគមនាគមន៍កំពុងធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ និងគាំទ្រដល់កំណើនសេដ្ឋកិច្ច។ សេដ្ឋកិច្ចឌីជីថល៖ អាស៊ានកំពុងទទួលយកបច្ចេកវិទ្យាឌីជីថល ជាមួយនឹង e-commerce និង fintech លេចចេញជាកត្តាជំរុញដ៏សំខាន់នៃការច្នៃប្រឌិត និងការបង្កើតការងារ។

បញ្ជីពីផលិតផលក្នុងស្រុកសរុបរបស់បណ្តាប្រទេសអាស៊ាន ( List of ASEAN countries GDP )

**ការប៉ាន់ប្រមាណរបស់មូលនិធិរូបីយប័ណ្ណអន្តរជាតិ ក្នុងខែមេសា ឆ្នាំ២០១៧**

| ចំណាត់ថ្នាក់ | ប្រទេស | ចំនួនប្រជាជនគិតជាលាននាក់ | ផលិតផលក្នុងស្រុកសរុបគិតជាលានដុល្លារ | ផលិតផលក្នុងស្រុកគិតជាចំណូលម្នាក់ |
|---|---|---|---|---|
| 1 | ឥណ្ឌូនេស៊ី | 261.989 | 1,020,515 | 3,895 |
| 2 | ថៃ | 69.095 | 432,898 | 6,265 |
| 3 | ហ្វីលីពីន | 106.279 | 328,593 | 3,102 |
| 4 | ម៉ាឡេស៊ី | 32.199 | 309,860 | 9,623 |
| 5 | សិង្ហបុរី | 5.675 | 291,860 | 51,431 |
| 6 | វៀតណាម | 93.607 | 215,829 | 2,305 |
| 7 | មីយ៉ាន់ម៉ា | 52.645 | 72,368 | 1,374 |
| 8 | កម្ពុជា | 16.013 | 20,953 | 1,308 |
| 9 | ឡាវ | 7.299 | 14,971 | 2,051 |
| 10 | ប្រុយណេ | 0.429 | 12,326 | 28,740 |

## ២. ដៃគូពាណិជ្ជកម្មអាស៊ាន

ទីតាំងភូមិសាស្ត្រយុទ្ធសាស្ត្ររបស់អាស៊ានបានធ្វើឱ្យតំបន់នេះក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់។ កំណើនសេដ្ឋកិច្ច និងកិច្ចខិតខំប្រឹងប្រែងធ្វើសមាហរណកម្មរបស់ខ្លួនបានទាក់ទាញដៃគូពាណិជ្ជកម្មជាច្រើន៖

- **ចិន៖** ដៃគូពាណិជ្ជកម្មដ៏ធំបំផុតរបស់អាស៊ាន ជាមួយនឹងទំហំពាណិជ្ជកម្មកើនឡើងគួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។
- **សហរដ្ឋអាមេរិក៖** ជាដៃគូពាណិជ្ជកម្មដ៏យូរអង្វែង និងសំខាន់ ដោយផ្តោតលើបច្ចេកវិទ្យា និងសេវាកម្ម។
- **ប្រទេសជប៉ុន៖** ជាវិនិយោគិន និងដៃគូពាណិជ្ជកម្មដ៏សំខាន់ ជាពិសេសក្នុងវិស័យផលិតកម្ម ឧស្សាហកម្ម និងបច្ចេកវិទ្យា។

- **សហភាពអឺរ៉ុប៖** ជាទីផ្សារដ៏សំខាន់សម្រាប់ការនាំចេញរបស់អាស៊ាន ដោយផ្តោតលើទំនិញកសិកម្ម និងផលិតឧស្សាហកម្ម។
- **ប្រទេសឥណ្ឌា៖** ក្លាយជាដៃគូពាណិជ្ជកម្មដ៏សំខាន់ ជាមួយនឹងទំនាក់ទំនងសេដ្ឋកិច្ចដែលកំពុងរីកចម្រើន។

## កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងភាពជាដៃគូសេដ្ឋកិច្ច

អាស៊ានបានអនុវត្តយ៉ាងសកម្មនូវសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ច តាមរយៈកិច្ចព្រមព្រៀងផ្សេងៗរួមមាន៖

- តំបន់ពាណិជ្ជកម្មសេរីអាស៊ាន(AFTA)កិច្ចព្រមព្រៀងនេះមានគោលបំណងលុបបំបាត់ពន្ធលើផលិតផលភាគច្រើនក្នុងចំណោមរដ្ឋសមាជិកអាស៊ាន។
- ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់(RCEP)កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដ៏ធំបំផុតរបស់ពិភពលោក ដែលពាក់ព័ន្ធនឹងអាស៊ាន និងដៃគូពាណិជ្ជកម្មរបស់ខ្លួន រួមមានប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង អូស្ត្រាលី នូវែលសេឡង់ និងប្រទេសដទៃទៀត។
- ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក(TPP)ខណៈពេលដែលសហរដ្ឋអាមេរិកដកខ្លួនចេញ ប្រទេសចំនួន ១១ ដែលនៅសេសសល់ រួមទាំងសមាជិកអាស៊ានមួយចំនួន បានបង្កើតកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និងរីកចម្រើនសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP)។

កិច្ចព្រមព្រៀងទាំងនេះបានរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចរបស់អាស៊ាន និងការធ្វើសមាហរណកម្មរបស់ខ្លួនទៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ពិភពលោក។

បញ្ជីពីផលិតផលក្នុងស្រុកសរុបរបស់បណ្តាប្រទេសអាស៊ាន(List of ASEAN countries GDP)

**ការប៉ាន់ប្រមាណរបស់មូលនិធិរូបិយប័ណ្ណអន្តរជាតិ នៅឆ្នាំ២០២០**

| ចំណាត់ថ្នាក់ | ប្រទេស | ចំនួនប្រជាជន គិតជាលាននាក់ | ផលិតផលក្នុងស្រុកសរុប គិតជាលានដុល្លារ | ផលិតផលក្នុងស្រុក គិតជាចំណូលម្នាក់ |
|---|---|---|---|---|
| | សហរដ្ឋអាម៉េរិក | 338.448 | 23,760,331 | 70,203 |
| | ចិន | 1,432.260 | 17,706,631 | 12,362 |
| | ជប៉ុន | 123.832 | 5,368,188 | 43,350 |
| | ឥណ្ឌា | 1,416.159 | 3,935,267 | 2,778 |
| | កូរ៉េខាងត្បូង | 52.509 | 1,829,011 | 34,832 |
| | អាស៊ាន | | | |
| 1 | ឥណ្ឌូនេស៊ី | 279.048 | 1,615,556 | 5,789 |
| 2 | ហ្វីលីពីន | 117.341 | 579,297 | 4,936 |

| ចំណាត់ថ្នាក់ | ប្រទេស | ចំនួនប្រជាជន គិតជាលាននាក់ | ផលិតផលក្នុងស្រុកសរុប គិតជាលានដុល្លារ | ផលិតផលក្នុងស្រុក គិតជាចំណូលម្នាក់ |
|---|---|---|---|---|
| 3 | ថៃ | 69.345 | 519,050 | 7,485 |
| 4 | ម៉ាឡេស៊ី | 35.030 | 488,959 | 13,958 |
| 5 | សិង្ហាបុរី | 5.933 | 340,848 | 57,451 |
| 6 | វៀតណាម | 97.934 | 314,193 | 3,208 |
| 7 | មីយ៉ាន់ម៉ា | 54.360 | 120,217 | 2,211 |
| 8 | កម្ពុជា | 17.250 | 31,570 | 1,830 |
| 9 | ឡាវ | 8.019 | 23,123 | 2,883 |
| 10 | ប្រុយណេ | 0.456 | 16,451 | 36,109 |

**សំណួរត្រិះរិះ**

១. តើផលិតផលក្នុងស្រុកសរុបរបស់តំបន់អាស៊ានមានចំនួនប៉ុន្មាន?

២. តើលក្ខណៈសំខាន់ៗរបស់សេដ្ឋកិច្ចអាស៊ានមានអ្វីខ្លះ?

៣. ចូរបង្ហាញពីដៃគូពាណិជ្ជកម្មសំខាន់របស់អាស៊ាន។

## ពីអាស៊ាន១០ប្រទេស ទៅកាន់អាស៊ានបូក៣



បណ្ដាប្រទេសអាស៊ីអាគ្នេយ៍ទាំង១០ ក្រោមដំបូលតែមួយរបស់អាស៊ាន@RFI

នៅដើមទសវត្សរ៍ទី៨០ គេឃើញបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ចាកចេញបណ្ដើរៗពីភាពប្រេះឆា ដើម្បីបោះពួយទៅរកទីដៅនៃឯកភាពក្រោមដំបូលតែមួយនៃអង្គការតំបន់ អាស៊ាន។ ហើយនៅដើមទសវត្សរ៍ទី៩០

បណ្តាប្រទេសអាស៊ីអាគ្នេយ៍ផ្តើមចាកចេញបណ្តើរៗពីភាពប្រេះឆា ដើម្បីបោះជំហានទៅរកទិសដៅនៃឯកភាព។ នេះក៏ដោយសារតែសង្គ្រាមត្រជាក់ត្រូវបានចប់ ដ្បិតសហភាពសូវៀតបានរលំរលាយនៅថ្ងៃទី២៦ ធ្នូ ឆ្នាំ ១៩៩១។

តាមពិត នៅចុងទសវត្សរ៍ទី៨០ មហាអំណាចបស្ចិមលោក ចិន និងសហភាពសូវៀត ដែលកាលណោះកំពុងត្រជះខ្យល់ បានត្រូវរ៉ូវគ្នាបញ្ចប់វិបត្តិនៅកម្ពុជា រហូតដល់បានសម្រេចនៅទីបំផុត តាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣តុលាឆ្នាំ១៩៩១។

ចាប់ពីពេលនោះមក អាស៊ានដែលបានទទួលយកប្រទេសព្រុយណេជាសមាជិកទី៦របស់ខ្លួននៅឆ្នាំ ១៩៨៥ ក៏ផ្តើមចរចាក្នុងគោលដៅប្រមូលយកវៀតណាម ឡាវ កម្ពុជានិងភូមាមកដាក់នៅក្រោមដំបូលតែមួយនៃអង្គការតំបន់នេះ។ អាស៊ានទទួលយកវៀតណាមនៅឆ្នាំ១៩៩៥ បន្ទាប់មក ឡាវ និង ភូមា នៅឆ្នាំ ១៩៩៧ និងនៅចុងបញ្ចប់ គឺ កម្ពុជានៅឆ្នាំ១៩៩៩។

និយាយរួម ចាប់ពីទសវត្សរ៍ទី៩០ទៅ បណ្តាប្រទេសអាស៊ីអាគ្នេយ៍លែងប្រេះឆា លែងលាបពណ៌នយោបាយឬមនោគមវិជ្ជាដាក់គ្នា លែងចាត់ទុកគ្នាជាសត្រូវទៀតហើយ។ អ្វីដែលចាំបាច់ គឺការអភិវឌ្ឍន៍សេដ្ឋកិច្ច។

កាលសម័យនោះ នៅពេលដែលអាស៊ានបានផ្តើមបើកទ្វារទទួលយកបណ្តាប្រទេសអាស៊ីអាគ្នេយ៍ដទៃដែលជាអតីតសត្រូវ មានសំណួរជាច្រើនចោទឡើង ជាអាទិ៍ តើសមាជិកដែលស្អប់លទ្ធិកុម្មុយនិស្ត ដូចជា ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ថៃនិងហ្វីលីពីន អាចនឹងធ្វើការជាមួយវៀតណាមនិងឡាវកុម្មុយនិស្តបានដែរឬទេ?

តាមពិត ជាទូទៅ នៅជំនាន់នោះ បណ្តាសមាជិកអាស៊ាន សុទ្ធតែជាអ្នកកាន់អំណាចផ្តាច់ការ ដូចជា សិង្ហបុរី ភូមា វៀតណាម ឡាវ និងឥណ្ឌូណេស៊ី។ ដោយឡែក ខុសផ្ទុយពីសហភាពអឺរ៉ុប អាស៊ានមិនដាក់លក្ខខណ្ឌតម្រូវឱ្យប្រទេសសមាជិកគោរពសិទ្ធិមនុស្សនិងគោលការណ៍ប្រជាធិបតេយ្យអ្វីទេ។ មិនតែប៉ុណ្ណោះ ថ្នាក់ដឹកនាំនៃបណ្តាសមាជិកខ្លះ ដូចជា លី គាន់យូ (Lee Kuan Yew) នៅសិង្ហបុរី និង ម៉ាហាធារ ម៉ូហាម៉ាឌ (Mahathir Mohamad) នៅម៉ាឡេស៊ីជាដើម មិនព្រមទទួលឡើយគោលការណ៍ប្រជាធិបតេយ្យបែបបស្ចិមលោកឡើយ។

ពួកគេនាំគ្នាអះអាងថាមិនត្រូវអនុវត្តឡើយ ឬក៏មិនត្រូវអនុវត្តម៉ត់ចត់ហួសហេតុពេកទេលិទ្ធិប្រជាធិបតេយ្យបែបបស្ចិមលោក ដ្បិតសង្គមអាស៊ីមានប្រពៃណីនិងវប្បធម៌របស់គេដាច់ដោយឡែក ដែលខុសគ្នាស្រឡះពីប្រពៃណីនិងវប្បធម៌បស្ចិមលោក។ សម្រាប់ លី គាន់យូ និង ម៉ាហាធារ ម៉ូហាម៉ាឌ បស្ចិមលោកឲ្យតម្លៃខ្លាំងណាស់ទៅលើបុគ្គល សេរីភាព និងសមធម៌ ចំណែកពិភពអាស៊ីវិញឲ្យតម្លៃខ្លាំងជាងគេទៅលើគ្រួសារ សង្គម វិន័យ សណ្តាប់ធ្នាប់ អំណាច និងការងារ។

យ៉ាងណាក៏ដោយ នៅចុងទសវត្សរ៍ទី៩០ បណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងដប់ បានបិទបញ្ចប់សករាជនៃការប្រេះឆាច្រើនទសវត្សរ៍ និងបានឯកភាពគ្នាជ្រកក្រោមដំបូលអង្គការតែមួយ ព្រមទាំងបានចាប់ដៃគ្នាកសាងសន្តិភាពដើម្បីពង្រឹងសហប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុងតំបន់។

ដូច្នេះ គោលដៅចំបងមួយដែលជាគោលការណ៍ត្រូវទៅដល់នៅដំណាច់ឆ្នាំ២០១៥ខាងមុខ គឺប្រែក្លាយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ទៅជាសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ តាមរយៈការធ្វើសមាហរណ៍

កម្មទាំងស្រុងមួយ។ និយាយបែបផ្សេង ដូចនៅក្នុងសហភាពអឺរ៉ុបអ៊ីចឹង នៅក្នុងលំហដែនដីនៃអាស៊ានទាំងមូល នឹងត្រូវមានដោយសេរីចរាចរណ៍ទំនិញ មូលធន និងប្រជាជន។

នៅក្នុងទសវត្សរ៍ទី៩០ដដែលនោះ សង្គ្រាមត្រជាក់ដែលបានរលត់បាត់ទៅក៏បានបិទបញ្ចប់ការប្រជែងឥទ្ធិពលគ្នារវាងសហរដ្ឋអាមេរិក ចិននិងរុស្ស៊ីនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែរ។ ក៏ប៉ុន្តែ ទន្ទឹមនោះ ស្រាប់តែចិននិងជប៉ុន មួយជាមហាយក្សនយោបាយដែលកំពុងក្លាយជាមហាយក្សសេដ្ឋកិច្ច និងមួយទៀតជាមហាយក្សសេដ្ឋកិច្ចតែមានសហរដ្ឋអាមេរិកជាបង្អែកនយោបាយនិងយោធា ផ្ដើមប្រជែងជើងគ្នានៅអាស៊ីប៉ាស៊ីហ្វិកជាទូទៅ និងនៅអាស៊ីអាគ្នេយ៍ជាច់ដោយឡែក។

ជាក់ស្ដែង នៅខែមករាឆ្នាំ១៩៩៧ នាយករដ្ឋមន្ត្រីជប៉ុនសម័យនោះ គឺលោក Ryutaro Hashimoto បានស្នើឱ្យមានជាប្រចាំ ជំនួបកំពូលមួយឆ្នាំម្ដងរវាងអាស៊ាននិងជប៉ុន។ ប៉ុន្តែ ថ្នាក់ដឹកនាំនៃបណ្ដាសមាជិកអាស៊ានដែលយល់ដឹងពីបាតុភាពភូមិសាស្ត្រនយោបាយថ្មីនៅអាស៊ី រារែក កិកកុកមិនព្រមទទួលសំណើរបស់ជប៉ុន ដ្បិតបារម្ភខ្លាចចិនអាក់អន់ស្រពន់ចិត្ត។ នៅទីបំផុត អាស៊ានក៏សម្រេចចិត្តទាក់ទងជប៉ុនផង ចិនផង និងថែមទាំងកូរ៉េខាងត្បូងមួយទៀត ដើម្បីបង្កើតឡើងនូវអ្វីដែលសព្វថ្ងៃនេះគេហៅថាអាស៊ានបូក៣។

តាមការពិត អាស៊ានបូក៣ ត្រូវបានបង្កើតឡើងជាផ្លូវការ មួយឆ្នាំក្រោយមក។ គឺនាឱកាសជំនួបកំពូលនៅហាណូយប្រទេសវៀតណាម ក្នុងខែធ្នូឆ្នាំ១៩៩៨។ នេះមិនមែនចៃដន្យទេ ពីព្រោះនៅឆ្នាំ១៩៩៨នោះ វិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរមួយដែលគេប្រសិទ្ធិនាមថាជាវិបត្តិអាស៊ី បានញាំញីខ្លាំងទ្វីបអាស៊ី ជាពិសេសអាស៊ីអាគ្នេយ៍។ មិនតែប៉ុណ្ណោះ នៅក្នុងឆ្នាំ១៩៩៨ដដែលនោះ បណ្ដាប្រទេសមួយចំនួននៅក្នុងតំបន់ជួបប្រទះនឹងការប្រែប្រួលនយោបាយ។ របបផ្ដាច់ការរបស់ Suharto នៅឥណ្ឌូណេស៊ីបានដួលរលំនៅម៉ាឡេស៊ីវិញ នាយករដ្ឋមន្ត្រី Mahathir បានដកឧបនាយករដ្ឋមន្ត្រី Anwar Ibrahim ដែលក្លាយជាគូប្រជែងចេញពីតំណែង។

ចំណែកនៅកូរ៉េខាងត្បូង លោក Kim Dae Jung បានជាប់ឆ្នោតជាប្រធានាធិបតីថ្មី។ ផ្ទុយទៅវិញ នៅជប៉ុនលោក Ryutaro Hashimoto បានបង្ខំចិត្តលាលែងចេញពីតំណែង ដោយហេតុតែវិបត្តិសេដ្ឋកិច្ច និងនយោបាយ។ គឺព្រឹត្តការណ៍ទាំងអស់នេះហើយ ដែលបានជំរុញឱ្យបង្កើតជំនួបកំពូលអាស៊ានបូក៣ ជាផ្លូវការនៅឆ្នាំ១៩៩៨ ដើម្បីឱ្យថ្នាក់ដឹកនាំអាស៊ីអាចផ្លោះប្ដូរយោបល់គ្នា និងអាចជជែកគ្នាដើម្បីរកដំណោះស្រាយបញ្ហាសេដ្ឋកិច្ច នយោបាយ និងសន្តិសុខ នៅលើវេទិកាតំបន់រួមគ្នាមួយ៕

**សំណួរត្រិះរិះ**

១. តើប្រទេសណាខ្លះដែលប្រកាន់របបសាធារណរដ្ឋ? រាជានិយម? កុំម្មុយនីស? និងរាជានិយមផ្ដាច់ការ?

២. តើប្រទេសណាខ្លះដែលមានសេដ្ឋកិច្ចពឹងផ្អែកលើវិស័យឧស្សាហកម្មផង នាំប្រេងចេញផង និងទេសចរណ៍ផង?

៣. តើប្រទេសណាខ្លះជាប្រទេសឧស្សាកម្ម នៅអាស៊ីអាគ្នេយ៍?

## មេរៀនទី៥៖ ទំនាក់ទំនងអាស៊ាន និងបណ្តាប្រទេសមហាអំណាចក្នុងពិភពលោក

### ១. ជំនួបកំពូលអាស៊ានបូក៣ ទៅជំនួបកំពូលអាស៊ីបូព៌ា



ជំនួបកំពូលអាស៊ីបូព៌ាលើកទី៧នៅភ្នំពេញខែវិច្ឆិកាឆ្នាំ២០១២RFI

ទោះបីជាអាស៊ានបូក៣ គឺបូកចិនជប៉ុននិងកូរ៉េខាងត្បូងត្រូវបានបង្កើតនៅឆ្នាំ១៩៩៨រួចហើយក្តី ក៏ចិននិងជប៉ុននៅបន្តប្រជែងជើងគ្នា លើកនេះនៅលើវេទិកាអាស៊ានតែម្តង។ ដូច្នេះហើយ បានជាសមាជិកអាស៊ានខ្លះរួមមានជាអាទិ៍សិង្ហបុរីនិងឥណ្ឌូណេស៊ីជាដើមផ្តើមបារម្ភ បារម្ភពីឥទ្ធិពលខ្លាំងហួសហេតុរបស់ចិននៅក្នុងជំនួបកំពូលអាស៊ានបូក៣។ បន្តិចម្តងៗ សិង្ហបុរីនិងឥណ្ឌូណេស៊ីជំរុញនិងគាំទ្រដោយជប៉ុន ចង់ឃើញអាស៊ានបើកទ្វារទទួលដៃគូដទៃផ្សេងដូចជាឥណ្ឌាដែលជាមហាអំណាចអាស៊ីខាងត្បូងជាដើម។

ទន្ទឹមនេះ ចិនចង់ឱ្យមានជំនួបកំពូលអន្តររដ្ឋាភិបាលមួយរវាងតែអាស៊ាននិងបណ្តាប្រទេសអាស៊ីសុទ្ធសាធ។ រីឯជប៉ុនវិញចង់ឱ្យមានការចូលរួមពីសំណាក់ប្រទេសផ្សេងដែលមិនមែនជាអាស៊ី ដូចជាអូស្ត្រាលី នូវែលសេឡង់ និងអាមេរិកទៀតផង។ គោលដៅ គឺរក្សាតុល្យភាពនៅអាស៊ីអាគ្នេយ៍និងនៅលើវេទិកាអាស៊ានកុំឲ្យចិនមានប្រៀបខ្លាំងពេក។

នៅទីបំផុត ការចរចានិងការប្រទាញប្រទង់គ្នាខ្លះផងនៅលើវេទិកាជំនួបកំពូលអាស៊ានបូក៣ បានផ្តល់ចេញជាលទ្ធផលដូចអ្វីដែលជប៉ុនប្រាថ្នាចង់បាន លទ្ធផលដែលស្តែងចេញតាមរយៈជំនួបកំពូលអាស៊ីបូព៌ាលើកទីមួយបង្អស់ នៅខែធ្នូឆ្នាំ២០០៥នៅប្រទេសម៉ាឡេស៊ី។ ចូលរួមក្នុងជំនួបកំពូលអាស៊ីបូព៌ាលើកទីមួយបង្អស់នោះ មានសមាជិកអាស៊ានទាំង១០ ចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី និងនូវែលសេឡង់។

សេចក្តីថ្លែងការណ៍រួម ដែលគេហៅថាសេចក្តីថ្លែងការណ៍Kuala Lumpurថ្ងៃទី១៤ធ្នូឆ្នាំ២០០៥ មានបីចំណុចសំខាន់ៗ។ ទីមួយ បណ្តាប្រទេសហត្ថលេខីទាំង១៦ ប្តេជ្ញាចិត្តធ្វើឱ្យជំនួបកំពូលអន្តររដ្ឋាភិបាលអាស៊ីបូព៌ានេះក្លាយជាទីសន្ទនានៃបញ្ហាយុទ្ធសាស្ត្រ សន្តិសុខ នយោបាយ និងសេដ្ឋកិច្ច។ ទីពីរ ជំនួបកំពូលអន្តររដ្ឋាភិបាល

អាស៊ីបូព៌ាជាបន្តបន្ទាប់ នឹងត្រូវប្រព្រឹត្តទៅរៀងរាល់ឆ្នាំនៅក្នុងជំនួបកំពូលអាស៊ាននៃតែម្តង ហើយនឹងត្រូវរៀបចំដឹកនាំដោយប្រទេសប្រធានផ្លាស់វេនរបស់អាស៊ាន។ ទីបី ជំនួបកំពូលអាស៊ីបូព៌ាត្រូវតែជួយពង្រឹងការកសាងអាស៊ាននិងត្រូវតែជួយជំរុញការធ្វើសមាហរណកម្មនៃតំបន់អាស៊ីបូព៌ាទាំងមូល។

តើសមាហរណកម្មនៃតំបន់អាស៊ីបូព៌ាទាំងមូលមានន័យថាជាការបង្កើតឡើងនូវសហគមន៍អាស៊ីបូព៌ាមួយដែរឬទេនៅទីបំផុត?

ជាច្រើនឆ្នាំកន្លងមកហើយ ថ្នាក់ដឹកនាំនៃជំនួបកំពូលអាស៊ីបូព៌ាបានជជែកពិភាក្សាគ្នាយ៉ាងសកម្មអំពីលទ្ធភាពនៃការបង្កើតឡើងនូវសហគមន៍អាស៊ីបូព៌ាមួយ ដោយយកគំរូតាមសហភាពអឺរ៉ុប។ ក៏ប៉ុន្តែពីមួយឆ្នាំទៅមួយឆ្នាំ គោលគំនិតដ៏ល្អមួយនេះ ដូចជានៅទ័លច្រកមួយកន្លែង មិនទៅមុខទាល់តែសោះ ដោយហេតុតែប្រយោជន៍ខ្វែងគ្នាខ្លាំងរវាងបណ្តាប្រទេសអាស៊ីធំៗ ជាពិសេសរវាងចិននិងជប៉ុន និងប្រយោជន៍ខ្វែងគ្នាខ្លាំងរវាងបណ្តាប្រទេសសមាជិកអាស៊ាន។

នៅក្នុងស្មារតីរបស់ជប៉ុន សហគមន៍នេះដែលត្រូវយកគំរូតាមសហភាពអឺរ៉ុប គួរតែច្របាច់បញ្ចូលគ្នាសមាជិកអាស៊ានទាំងដប់ ជប៉ុន ចិន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី និងនូវែលហ្សេឡង់ ឲ្យនៅក្រោមដំបូលតែមួយ ដំបូលសេដ្ឋកិច្ចជាបឋម និងក្រោយមកទៀតនយោបាយ។ ហើយបើធ្វើទៅបាន ជប៉ុនក៏ចង់បន្ថែមទាំងសហរដ្ឋអាមេរិកមួយទៀតដែរនៅចុងក្រោយបង្អស់។

អ្វីដែលធ្វើឱ្យការបង្កើតសហគមន៍អាស៊ីបូព៌ារឹងរឹតតែមានលក្ខណៈស្មុគស្មាញ គឺសូម្បីតែប្រទេសអូស្ត្រាលី ក៏មានគំនិតមួយដែរ នោះគឺសមាហរណកម្មមួយដ៏ធំទូលំទូលាយ ដែលនឹងគ្របដាក់ក្រោមដំបូលតែមួយ បណ្តាប្រទេសអាស៊ីនិងបណ្តាប្រទេសប៉ាស៊ីហ្វិក ជាពិសេសសហរដ្ឋអាមេរិកតែម្តង ដោយមិនកំណត់ជាមុន និងមិនកំណត់តទៅអានាគតចំនួនប្រទេសសមាជិកទេ។

ក៏ប៉ុន្តែមកទល់ពេលនេះ ចិនមិនព្រម។ បើបង្កើតសហគមន៍អាស៊ីបូព៌ា ចិនចង់ប្រមូលយកតែបណ្តាប្រទេសអាស៊ីសុទ្ធសាធ ហើយមិនចង់ឱ្យមានឥណ្ឌាទៅទៀត។ មូលហេតុ គឺមកពីចិនបារម្ភក្រែងតទៅថ្ងៃមុខអូស្ត្រាលីដែលស្និទ្ធនឹងសហរដ្ឋអាមេរិក មានលទ្ធភាពលួចបើកបង្អួចឲ្យឥទ្ធិពលអាមេរិកាំងហូរចូលមកក្នុងអនាគតសហគមន៍អាស៊ីបូព៌ាបាន។

ម្ល៉ោះហើយ សម្រេចសម្រួចទៅ ក្នុងខណៈនេះ ជំនួបកំពូលអាស៊ីបូព៌ានៅតែជាជំនួបកំពូលអាស៊ីបូព៌ាដែលជាកិច្ចប្រជុំអន្តររដ្ឋាភិបាល។ មិនទាន់អាចមានទៅកើតទេសហគមន៍អាស៊ីបូព៌ាស្អីគេនេះ ឬសហគមន៍អាស៊ីប៉ាស៊ីហ្វិកស្អីគេនោះ។

ដោយឡែក ប៉ុន្មានឆ្នាំចុងក្រោយនេះ ជំនួបកំពូលអាស៊ានបាននិងកំពុងបន្តក្លាយទៅជាវេទិកានៃការប្រឈមមុខដាក់គ្នាយ៉ាងមោះមុតរវាងបណ្តាប្រទេសសមាជិកអាស៊ាន រវាងសមាជិកអាស៊ានមួយចំនួននិងចិន និងរវាងមហាអំណាចធំៗដែលបានចូលមកកៀកជិតបណ្តាប្រទេសអាស៊ីអាគ្នេយ៍ តាមរយៈជំនួបកំពូលអាស៊ីបូព៌ា។ មានមូលហេតុធំៗពីរយ៉ាងដែលជាប្រភពនៃការប្រឈមមុខដាក់គ្នានេះ។ ម្យ៉ាង គឺមកពីមហិច្ឆតាស្រេកឃ្លានទឹកដីកាន់តែធំរបស់ចិន នៅក្នុងតំបន់ ជាពិសេសនៅក្នុងសមុទ្រចិនខាងត្បូង។ ម្យ៉ាងទៀត គឺមកពីសហរដ្ឋអាមេរិកបានក្លាយជាសមាជិកនៃជំនួបកំពូលអាស៊ីបូព៌ានៅឆ្នាំ២០១១។

## ២. ទំនាក់ទំនងអាស៊ាន និងឥណ្ឌា




ជំនួបកំពូលលើកទី១០រវាងអាស៊ាននិងឥណ្ឌា នៅភ្នំពេញខែវិច្ឆិកាឆ្នាំ២០១២@RFI

ក៏ដូចជាទំនាក់ទំនងរវាងអាស៊ាននិងចិនឬក៏រវាងអាស៊ាននិងជប៉ុនដែរ ទំនាក់ទំនងរវាងអាស៊ាននិងឥណ្ឌាបានរីកលូតលាស់ខ្លាំង ចាប់ពីដើមទសវត្សរ៍ទី៩០មកតែប៉ុណ្ណោះ។ គំនិតផ្តួចផ្តើមនៃការខិតចូលជិតគ្នារវាងភាគីទាំងពីរ ចេញមកជាបឋមពីខាងភាគីឥណ្ឌា។

ក្រោយពីសង្គ្រាមត្រជាក់បានរលត់រលាយបាត់ទៅ និងនៅពេលដែលចិនកំពុងលាតសន្ធឹងឥទ្ធិពលរបស់ខ្លួនចូលមកក្នុងតំបន់សមុទ្រឥណ្ឌា ស្រាប់តែឥណ្ឌាមានគំនិតចង់ពង្រឹងវត្តមានរបស់ខ្លួននៅភូមិភាគអាស៊ីអាគ្នេយ៍។ នៅក្នុងន័យនេះ ចាប់ពីដើមទសវត្សរ៍ទី៩០មក ទីក្រុងNew Delhi បាននិងកំពុងបន្តអនុវត្តនូវអ្វីដែលគេប្រសិទ្ធនាមឱ្យថា Look East Policy ឬនយោបាយសំដៅទៅទិសខាងកើត។ មែនទែនទៅ *នយោបាយសំដៅទៅទិសខាងកើតនេះ*វាឆ្លើយតបទៅនឹងមហិច្ឆតារបស់ឥណ្ឌាតាំងពីប្រទេសមួយនេះដណ្តើមឯករាជ្យបានពីអង់គ្លេសមកវិញនៅឆ្នាំ១៩៤៧ម្ល៉េះ។ មហិច្ឆតានោះ គឺការចង់ក្លាយជាមហាអំណាចមួយ ពីព្រោះនៅសម័យបូរាណកាល ឥណ្ឌាមិនមែនក្តាប់បានត្រឹមតែតំបន់អាស៊ីខាងត្បូងប៉ុណ្ណោះទេ តែបានទាំងលាតសន្ធឹងដោយសន្តិវិធីឥទ្ធិពលរបស់ខ្លួនចូលទៅដល់ភូមិភាគអាស៊ីអាគ្នេយ៍ទៀតផង ដូចមាននៅសល់ វប្បធម៌ឥណ្ឌា តរហូតមកទល់សព្វថ្ងៃនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន ជាឧទាហរណ៍ជាក់ស្តែងស្រាប់។

នៅក្នុងក្របខ័ណ្ឌនៃនយោបាយសំដៅទៅទិសខាងកើតនេះ ឥណ្ឌាចែចូវអាស៊ាន ក្លាយជាដៃគូរបស់អាស៊ាននៅឆ្នាំ១៩៩៥ ចូលរួមក្នុងForumតំបន់របស់អាស៊ាន(ARF) តាំងពីឆ្នាំ២០០៦ មានវត្តមាននៅក្នុងជំនួបកំពូលអាស៊ាននិងបណ្តាប្រទេសពាក់ព័ន្ធ តាំងពីឆ្នាំ២០០២ និងមានវត្តមាននៅក្នុងជំនួបកំពូលអាស៊ីបូព៌ាតាំងពីឆ្នាំ២០០។ មិនតែប៉ុណ្ណោះនាវានៃកងទ័ពជើងទឹករបស់ឥណ្ឌាធ្វើចរាចរណ៍និងល្បាតនៅក្នុង

សមុទ្រចិនខាងត្បូងទៀតផង។

ដូចគ្នាអ៊ីចឹងដែរ ឥណ្ឌាពង្រឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយអាស៊ាន ជាហេតុធ្វើឱ្យទំហំនៃការផ្លោះប្តូរពាណិជ្ជកម្មរវាងភាគីទាំងពីរកើនឡើងលឿន៖ ១៣ពាន់លានដុល្លារនៅឆ្នាំ២០០៥ ៥៤ពាន់លានដុល្លារនៅឆ្នាំ២០១០ និងជាង៧០ពាន់លានដុល្លារនៅឆ្នាំ២០១២។ មិនតែប៉ុណ្ណោះ នៅឆ្នាំ២០០៩ អាស៊ាននិងឥណ្ឌាបានចុះកិច្ចព្រមព្រៀងបង្កើតតំបន់ផ្លោះប្តូរពាណិជ្ជកម្មដោយសេរីមួយ ហើយតាមការគ្រោងទុក ការផ្លោះប្តូរជាក់ស្តែងដោយសេរីបែបនេះរវាងឥណ្ឌានិងអាស៊ានទាំងមូលនឹងត្រូវប្រព្រឹត្តទៅនៅឆ្នាំ២០១៦។ គឺនៅក្នុងក្របខ័ណ្ឌនៃនយោបាយសំដៅទៅទិសខាងកើតនេះដូចគ្នា ដែលនៅក្រោយគ្រោះរលកយក្សTsunami ឆ្នាំ២០០៤ ឥណ្ឌាបានផ្តល់ប្រាក់៥០ម៉ឺនដុល្លារទៅឱ្យថៃ និងបានបញ្ជូននាវាមួយគ្រឿងប្រដាប់ទៅដោយមន្ទីរពេទ្យទៅកាន់តំបន់Aceh នៃប្រទេសឥណ្ឌូណេស៊ី។ ជំនួយទាំងនេះ ពិតមែនតែមានទំហំតិចតួចស្តួចស្តើង តែវាជាសញ្ញាបង្ហាញនូវមហិច្ឆតារបស់ឥណ្ឌាក្នុងការលាតសន្ធឹងឥទ្ធិពលរបស់ខ្លួនចូលមកក្នុងភូមិភាគអាស៊ីអាគ្នេយ៍។

ទន្ទឹមគ្នានឹងការខិតជិតទៅរកអាស៊ានទាំងមូល ឥណ្ឌាក៏មានទំនាក់ទំនងដាច់ដោយឡែក ជាមួយសមាជិកអាស៊ានមួយក្រុមដែរ នៅក្នុងក្របខ័ណ្ឌនៃអ្វីដែលគេហៅថា កិច្ចសហប្រតិបត្តិការMekong-Gange។ គឺជាគំនិតផ្តួចផ្តើមមួយដែលបានកកើតឡើងនៅឆ្នាំ២០០០ និងដែលប្រមូលផ្តុំជាក់នៅជុំវិញឥណ្ឌា បណ្តាប្រទេសអាស៊ីអាគ្នេយ៍ចំនួន៥ ភូមា ថៃ កម្ពុជា ឡាវ និងវៀតណាម ដើម្បីធ្វើសហប្រតិបត្តិការរវាងគ្នានៅលើវិស័យវប្បធម៌ អប់រំ ទេសចរណ៍ និងដឹកជញ្ជូន។ ជាទូទៅនយោបាយសំដៅទៅទិសខាងកើតរបស់ឥណ្ឌាត្រូវបានអាស៊ានទទួលស្វាគមន៍។ អាស៊ានយល់ថា ខ្លួនមិនអាចមើលរំលងឥណ្ឌាបានទេ ពីព្រោះឥណ្ឌាជាមហាអំណាចអាស៊ីខាងត្បូងដែលមានអាវុធនុយក្លេអ៊ែរ និងជាមហាទីផ្សារមួយដែលមានប្រជាជនរហូតដល់ទៅជាង១ ២០០លាននាក់។ និយាយរួម ឥណ្ឌាជាមហាយក្សអាស៊ីមួយសមល្មមនឹងដើរតួនាទីជានគរបាលរក្សាសន្តិសុខនៅក្នុងតំបន់និងមានមាឌធំសមល្មមនឹងអាចធ្វើឱ្យមហាយក្សចិនកោតខ្លាច។

អ៊ីចឹងហើយ បានជាថ្នាក់ដឹកនាំអាស៊ីអាគ្នេយ៍ភាគច្រើនមើលឃើញថា ការពង្រឹងទំនាក់ទំនងជាមួយឥណ្ឌាអាចជួយកាត់បន្ថយឥទ្ធិពលរបស់ចិន អាចជួយរក្សាលំនឹងភូមិសាស្ត្រនយោបាយនៅក្នុងតំបន់និងនៅទីបំផុត អាចជួយអាស៊ានកុំឱ្យពឹងពាក់ចិនខ្លាំងជ្រុលពេក នៅលើវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច ទូតនិងនយោបាយ។ គឺនៅក្នុងបរិបទនេះហើយ ដែលនៅឆ្នាំ២០០៤ អាស៊ាននិងឥណ្ឌាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយស្តីពី«*ភាពជាដៃគូ ដើម្បីសន្តិភាពនិងវឌ្ឍនភាពរួម*»។ បើយោងទៅតាមក្រុមអ្នកសង្កេតការណ៍ កិច្ចព្រមព្រៀងជាមួយឥណ្ឌាមួយនេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូយុទ្ធសាស្ត្រដែលអាស៊ាននិងចិនបានចុះហត្ថលេខានៅឆ្នាំ២០០៣។ ម្ល៉ោះហើយវាជាសញ្ញាបង្ហាញថាថ្នាក់ដឹកនាំអាស៊ានយកឥណ្ឌាមកទប់កុំឱ្យជញ្ជីងភូមិសាស្ត្រនយោបាយរបស់អាស៊ីអាគ្នេយ៍ផ្អៀងទៅខាងចិនខ្លាំងពេក។

ដោយឡែក គួរកត់សម្គាល់ថា តាំងពីដើមទសវត្សរ៍ទី៩០មក អាស៊ានឱបរឹតឥណ្ឌាដោយគ្មានការភិតភ័យ ដ្បិតជាទូទៅថ្នាក់ដឹកនាំអាស៊ីអាគ្នេយ៍សឹងទាំងស្រុងចាត់ទុកឥណ្ឌាថាជាមហាអំណាចដ៏ស្លូតមួយដែលកាន់លទ្ធិប្រជាធិបតេយ្យនិងដែលអនុវត្តអំណាចស្រទន់ *Soft Power*។ នៅក្នុងបរិបទប្រកបដោយអំណោយផលល្អបែបនេះ និងដោយសារមានការជួយជំរុញពីសហរដ្ឋអាមេរិកទៀតផង ឥណ្ឌាច្បាស់ជានឹងបន្តពង្រឹងទំនាក់ទំនងជាមួយអាស៊ាននៅគ្រប់វិស័យ តទៅថ្ងៃមុខ។ ប៉ុន្តែ *នយោបាយសំដៅទៅអាស៊ីអាគ្នេយ៍* របស់

ឥណ្ឌានឹងច្បាស់ជាមានកម្រិតនិងខ្វះសន្ទុះក្លៀវក្លា ដោយហេតុតែនៅក្នុងភូមិភាគនេះ មានឥទ្ធិពលខ្លាំងជ្រុលពេកទៅហើយរបស់មហាយក្សចិន ជាអាទិ៍នៅភូមា កម្ពុជា និងឡាវ៕

## ៣. ទំនាក់ទំនងអាស៊ាន និងជប៉ុនៈ ដៃគូចាំបាច់




ទំនាក់ទំនងអាស៊ាន-ជប៉ុន នាឪកាសជំនួបកំពូលអាស៊ាន-ជប៉ុនខែធ្នូឆ្នាំ២០១៣។RFI

ពីពេលចប់សង្គ្រាមលោកលើកទីពីររហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៧០ នយោបាយតំបន់របស់ជប៉ុនផ្តោតទៅលើតែតំបន់ប៉ាស៊ីហ្វិកមួយគត់។ ដើមដំបូង គឺជាសហប្រតិបត្តិការផ្តាច់មុខជាមួយសហរដ្ឋអាមេរិក និងក្រោយមកទៀត ពីឆ្នាំ១៩៦៥ដល់ឆ្នាំ១៩៧៧ ក្រៅតែពី ជាមួយអាមេរិក ជប៉ុនមានសហប្រតិបត្តិការពាណិជ្ជកម្មជាមួយកាណាដា អូស្ត្រាលី និងនូវែលហ្សេឡង់។

គេត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៧៧ ទើបឃើញជប៉ុន កាលណោះក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រីTakeo Fukuda សម្រេចចិត្តពង្រីកនយោបាយការបរទេសតំបន់របស់ខ្លួនចូលទៅដល់អាស៊ីអាគ្នេយ៍។ កាលណោះ ក្នុងឆ្នាំ១៩៧៧ តាមរយៈសុន្ទរកថាមួយនៅទីក្រុងManille ប្រទេសហ្វីលីពីន លោក Takeo Fukuda បានថ្លែងថា «*ប្រទេសជប៉ុនត្រូវតែរៀបទំនាក់ទំនងមិត្តភាពនិងសហប្រតិបត្តិការមាំមួនជាមួយបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ដើម្បីជួយឱ្យតំបន់មួយនេះស្គាល់ការអភិវឌ្ឍន៍ សន្តិសុខនិងភាពរុងរឿង*»។ ចាប់ពីពេលនោះមក អាស៊ានត្រូវបានថ្នាក់ដឹកនាំជប៉ុនដាក់បញ្ចូលជាផ្លូវការទៅក្នុងនយោបាយការបរទេសរបស់ខ្លួន។ ចូរកុំភ្លេចថា ពីឆ្នាំ១៩៦៧ ឆ្នាំដែលអាស៊ានបានចាប់កំណើតឡើងរហូតដល់ឆ្នាំ១៩៧៧ ជប៉ុនមិនដែលឱ្យតម្លៃសោះឡើយដល់អង្គការតំបន់មួយនេះ។ មូលហេតុ គឺមកពីនៅដើមដំបូង អាស៊ានដែលត្រូវបានបង្កើតឡើង ជាពិសេសដើម្បីខ្ទប់ឥទ្ធិពលកុម្មុយនិស្តនៅអាស៊ីអាគ្នេយ៍ មិនបានទទួលការគាំទ្រពីសំណាក់សហរដ្ឋអាមេរិកភ្លាមៗទេ។ ពីព្រោះកាលណោះអាមេរិកចង់ឱ្យអាស៊ានចូលជាបក្សសម្ព័ន្ធរបស់ខ្លួន ដូចតៃវ៉ាន់ឬក៏ជប៉ុនអ៊ីចឹងដែរ ប៉ុន្តែអាស៊ានមិនព្រមដ្បិតចង់បង្ហាញថាខ្លួនប្រកាន់ជំហរ អព្យាក្រឹតនៅក្នុងសង្គ្រាមត្រជាក់រវាងសហរដ្ឋ អាមេរិកនិងសហភាពសូវៀត។

ម្ល៉ោះហើយបានជាជប៉ុនដែលជាសម្ព័ន្ធមិត្តចាក់ទឹកមិនលិចរបស់អាមេរិក ត្រូវតែប្រកាន់ជំហរដូច អាមេ រិកដែរ មិនខ្វីរវល់អាស៊ានដែលកាលសម័យនោះ ជាអង្គការមួយតូចច្រម៉ក់គ្មានទម្ងន់ភូមិសាស្ត្រ នយោបាយអ្វីសោះនៅលើឆាកតំបន់។

ទន្ទឹមនេះ នៅក្នុងអំឡុងពេលដដែលនោះ គឺពីចន្លោះឆ្នាំ១៩៦៧និងឆ្នាំ១៩៧៧ នៅលើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មវិញ ផលិតផលmade in Japan បានហូរចូលយ៉ាងគគុកគគាក់ទៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍។ បាតុភាពនេះបានបណ្តាលឱ្យថ្នាក់ដឹកនាំនៃប្រទេសសមាជិកអាស៊ានខ្លះត្អូញត្អែរនិងខ្លះទៀតខឹងប្រឡោតតោតតូងផង ដ្បិតផលិតផលនាំចូលមកពីជប៉ុន បានធ្វើឱ្យរោងចក្រនិងសិប្បកម្មក្នុងស្រុកបះជើងខាតឡុងចុង។

ទោះជាយ៉ាងណាក៏ដោយ គេត្រូវរង់ចាំរហូតដល់ចប់សង្គ្រាមត្រជាក់នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ទើបឃើញទំនាក់ទំនងទូទៅទាំងទូត ទាំងនយោបាយនិងទាំងសេដ្ឋកិច្ចរវាងអាស៊ាននិងជប៉ុនមានលក្ខណៈមាំមួន និងស្និទ្ធស្នាលល្អប្រសើរឡើងជាលំដាប់។ សព្វថ្ងៃនេះ ការផ្លាស់ប្តូរពាណិជ្ជកម្មរវាងជប៉ុននិងទ្វីបអាស៊ីទាំងមូលកើនរហូតដល់ទៅ៦០%នៃការផ្លាស់ប្តូរពាណិជ្ជកម្មសរុបរវាងជប៉ុននិងពិភពលោកហើយ នៅក្នុងតួលេខ៦០% នេះមួយភាគធំជាការផ្លាស់ប្តូររវាងជប៉ុននិងភូមិភាគអាស៊ីអាគ្នេយ៍។ ទំនាក់ទំនងសេដ្ឋកិច្ចនិងពាណិជ្ជកម្មល្អប្រសើរឡើងជាលំដាប់រវាងភាគីទាំងពីរក៏បានស្តែងឡើងដែរ តាមរយៈការចូលជាធរមាននៅឆ្នាំ២០០៨នៃកិច្ចព្រមព្រៀងទាំងស្រុងស្តីពីភាពជាដៃគូសេដ្ឋកិច្ចរវាងអាស៊ាននិងជប៉ុន។

នៅទីបំផុត តើហេតុអ្វីបានជាជប៉ុនបានសម្រេចចិត្តខិតចូលកៀកអាស៊ាន? មូលហេតុធំជាងគេ គឺមកពីជប៉ុនកត់សម្គាល់ឃើញថា តាំងពីសង្គ្រាមត្រជាក់បានរលត់រលាយទៅ ចិនបាននិងកំពុងបន្តលាតសន្ធឹងឥទ្ធិពលរបស់ខ្លួនទៅលើអាស៊ីប៉ាស៊ីហ្វិកនិយាយជាទូទៅ និងទៅលើភូមិភាគអាស៊ីអាគ្នេយ៍និយាយដោយឡែក។

គឺនៅក្នុងបរិបទបែបនេះហើយដែលតាមរយៈគំនិតផ្តួចផ្តើមរបស់ជប៉ុន ហ្វូរ៉ូម(Forum)តំបន់អាស៊ាន (ARF) សម្រាប់ជជែកវែកញែកពីបញ្ហានយោបាយនិងសន្តិសុខ ត្រូវបានបង្កើតឡើងនៅដើមទសវត្សរ៍ឆ្នាំ១៩៩០និងជំនួបកំពូលអាស៊ានបូក៣ត្រូវបានបង្កើតឡើងជាផ្លូវការនៅឆ្នាំ១៩៩៨។

ក្នុងគោលដៅសម្រួលធ្វើឱ្យទំនាក់ទំនងរឹងរឹតតែស្និទ្ធស្នាល នាជំនួបកំពូលអាស៊ាននៅខែមេសាឆ្នាំ ២០០៥ លោកនាយករដ្ឋមន្ត្រីជប៉ុនសម័យនោះគឺលោកKoizumi បានសម្តែងការសោកស្តាយជាផ្លូវការនិងជាលើកទីមួយបង្អស់ ចំពោះអំពើហិង្សាដែលកងទ័ពជប៉ុនបានប្រព្រឹត្តិទៅលើបណ្តាប្រជាជាតិនៃភូមិភាគអាស៊ីអាគ្នេយ៍ កាលសម័យសង្គ្រាមលោកទីពីរ។

ក្រោយមកទៀត ក្នុងអំឡុងពេលជាច្រើនឆ្នាំ នៅពេលមុនមានជំនួបកំពូលបណ្តាប្រទេសមហាអំណាចឧស្សាហកម្មG8ម្តងៗ នាយករដ្ឋមន្ត្រីជប៉ុនជាបន្តបន្ទាប់តែងតែធ្វើទស្សនកិច្ចមួយជុំអាស៊ាន។ ធ្វើបែបនេះ ជប៉ុនចង់បង្ហាញថាខ្លួនយកចិត្តទុកដាក់ទៅលើមតិរបស់ថ្នាក់ដឹកអាស៊ាន និងចង់បង្ហាញថាខ្លួនអាចនាំនាំមតិអស់ទាំងនេះយកទៅជជែកជាមួយក្រុមបណ្តាប្រទេសអ្នកមានស្តុកស្តមជាងគេនៅក្នុងពិភពលោក ជំនួសមុខឱ្យអាស៊ាន។

នៅខាងថ្នាក់ដឹកនាំអាស៊ានវិញ ពួកគេលែងភិតភ័យ លែងភ័យខ្លាចជប៉ុន ដូចនៅក្នុងអតីតកាលសម័យសង្គ្រាមលោកលើកទី២ទៀតហើយ។ ផ្ទុយទៅវិញ ពួកគេចាត់ទុកជប៉ុនជាដៃគូយុទ្ធសាស្ត្រមួយដ៏

សំខាន់និងចាំបាច់បំផុត ដើម្បីរក្សារលំនឹងភូមិសាស្ត្រនយោបាយធ្វើយ៉ាងណាកុំឱ្យមហាយក្សចិនមានប្រៀបខ្លាំងពេកនៅក្នុងទ្វីបអាស៊ីជាទូទៅ និងនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ជាពិសេស។

តទៅថ្ងៃមុខ ដោយហេតុតែមហិច្ឆតាកាន់តែធំរបស់ចិនទៅលើសមុទ្រចិនខាងកើតនិងទៅលើសមុទ្រចិនខាងត្បូង អាស៊ាននិងជប៉ុនទំនងជាអាចនឹងខិតកៀកគ្នាកាន់តែជិត មិនមែនក្នុងគោលដៅទប់ទល់បែបយោធាជាមួយនឹងចិនទេ តែក្នុងគោលដៅធ្វើឱ្យច្បាប់មានប្រៀបជាងកម្លាំងបាយ។ ជាក់ស្តែង នាឱកាសជំនួបកំពូលអាស៊ាន-ជប៉ុនកាលពីខែធ្នូឆ្នាំ២០១៣កន្លងទៅនេះ លោកនាយករដ្ឋមន្ត្រីជប៉ុន Shinzo Abe បានប្រកាសថា *«ជាមួយអាស៊ាន ជប៉ុនចង់កសាងអនាគតរបស់អាស៊ីជាទីដែលដាច់ខាត ច្បាប់នឹងត្រូវតែឈ្នះអានុភាព»*៕

## ៤. ទំនាក់ទំនងអាស៊ាននិងចិនៈ ទំនាក់ទំនងបន្តប់នៅដោយការមិនទុកចិត្ត




នៅអតីតកាល ជាពិសេសនៅចន្លោះទសវត្សរ៍ទី៦០និងទសវត្សរ៍ទី៧០ បណ្តាប្រទេសអាស៊ីអាគ្នេយ៍តែងតែចាត់ទុកចិនថាជាគ្រោះថ្នាក់មួយធំ។ កាលជំនាន់នោះ ចិនជាគ្រោះថ្នាក់កុម្មុយនិស្តសម្រាប់ឥណ្ឌូណេស៊ី ថៃ ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន ឬភូមា។ ប្រទេសទាំងនេះខ្លាចចិនខ្លាំង និងព្រួយបារម្ភខ្លាំងជាពិសេសនៅឆ្នាំ១៩៧៥ នាពេលដែលឥណ្ឌូចិនទាំងមូលក្លាយជាកុម្មុយនិស្ត។ ក្រោយមកទៀត នៅឆ្នាំ១៩៧៩ បណ្តាប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើននាំគ្នាចាត់ទុកចិនថា ជាគ្រោះថ្នាក់យោធា ពីព្រោះពេលនោះ កងទ័ពចិនបានវាយប្រហារទៅលើប្រទេសវៀតណាមដែលហ៊ានវាយរំលំរបបខ្មែរក្រហម និងហ៊ានចូលកាន់កាប់ប្រទេសកម្ពុជា។

ផ្ទុយទៅវិញ សព្វថ្ងៃនេះ ជាទូទៅបណ្តាប្រទេសសមាជិកទាំង១០របស់អាស៊ានមានទំនាក់ទំនងល្អជាមួយចិន ល្អជាងកាលសម័យសង្គ្រាមត្រជាក់។ មិនតែប៉ុណ្ណោះ អាស៊ានថែមទាំងគាំទ្រចិន និងទទួលស្គាល់គោលការណ៍ប្រទេសចិនតែមួយទៀតផង នៅលើឆាកអន្តរជាតិ។ នៅក្នុងបរិបទនេះ តាំងពីដើមទសវត្សរ៍ទី៩០មក ចិនបាននិងកំពុងបន្តរុញកូនអុករបស់គេបន្តិចម្តងៗចូលមកក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដោយសារតែការទូតសេដ្ឋកិច្ចវប្បធម៌ និងនយោបាយដ៏ប៉ិនប្រសប។ ចិនប្រើអំណាចស្រទន់ The soft power និងអនុវត្តនយោបាយ «ឈ្នះៈឈ្នះ»ក្នុងគោលដៅពង្រីកឥទ្ធិពល និងលាងសម្អាតកេរ្តិ៍ឈ្មោះរបស់ខ្លួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ជាងពីរទសវត្សរ៍ចុងក្រោយនេះ ជាទូទៅ អាស៊ានកក់ក្តៅក្នុងចិត្តជាងកាលសម័យសង្គ្រាមត្រជាក់ ពីព្រោះថ្នាក់ដឹកនាំចិនឲ្យតម្លៃទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចជាងឥទ្ធិពលមនោគមវិជ្ជា ហើយពីព្រោះសុន្ទរកថារបស់ថ្នាក់ដឹកនាំចិនសំដៅចង់បានតែសន្តិភាពនិងស្ថិរភាពនៅក្នុងប្រទេសចិន និងនៅតំបន់ជុំវិញប្រទេសចិន ។ នៅក្នុងន័យនេះ នៅឆ្នាំ២០០៤ លោក វេន យ៉ាបៅ (Wen Jiabao) ដែលជានាយករដ្ឋមន្ត្រីចិនជំនាន់នោះ បានប្រដូចប្រទេសចិនទៅនឹងសត្វដំរីដ៏ស្លូតមួយដែលគ្មានបំណងអាក្រក់ចង់បៀតបៀនអាស៊ានឡើយ។

តាមរយៈនយោបាយអំណាចស្រទន់ ចិនក៏កំពុងពង្រីកឥទ្ធិពលវប្បធម៌របស់ខ្លួនទៅលើភូមិភាគអាស៊ីអាគ្នេយ៍ដែរ។ ខ្សែភាពយន្តចិន សិល្បៈធ្វើម្ហូបអាហារចិន និងផលិតផលឧបភោគបរិភោគ made in China កំពុងជួយធ្វើឲ្យកេរ្តិ៍ឈ្មោះរបស់ចិន ល្បីសុះសាយពេញទូទាំងតំបន់អាស៊ីអាគ្នេយ៍។

នៅលើវិស័យសេដ្ឋកិច្ចវិញ ចិនខ្នះខ្នែងអនុវត្តនយោបាយ«ឈ្នះ-ឈ្នះ»នៅចំពោះមុខអាស៊ាន។ ជាក់ស្តែង ក្រោយពីមានវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ១៩៩៧-១៩៩៨ អាស៊ានបូកបីក៏បានចុះហត្ថលេខាទទួលកិច្ចព្រមព្រៀងសហប្រតិបត្តិការរូបិយវត្ថុមួយ ដែលគ្រោងឲ្យមានការខ្ចីរូបិយប័ណ្ណគ្នាទៅវិញទៅមករវាងបណ្តាប្រទេសហត្ថលេខី ពេលណាអស្ថិរភាពខ្លាំងកើតឡើងម្តងៗនៅលើទីផ្សារហិរញ្ញវត្ថុ។ វិបត្តិហិរញ្ញវត្ថុអាស៊ីនៅឆ្នាំ១៩៩៧ ក៏ជាឱកាសមួយសម្រាប់ឲ្យចិនបង្ហាញនូវសាមគ្គីភាពរបស់គេចំពោះអាស៊ានដែរ។ កាលនោះ ចិនមិនព្រមបញ្ចុះខ្លាំងពេកទេតម្លៃប្រាក់យ៉ន់(Yuan)របស់ខ្លួន ពីព្រោះចិនចង់ជួយអូសទាញអាស៊ានឲ្យចេញផុតពីវិបត្តិ។

សព្វថ្ងៃ ចិនបាននិងកំពុងបន្តទិញយ៉ាងសន្ធឹកសន្ធាប់ផលិតផលរបស់អាស៊ាន ជាហេតុធ្វើឲ្យភូមិភាគអាស៊ីអាគ្នេយ៍ស្គាល់កំណើនសេដ្ឋកិច្ចខ្លាំង ជាពិសេសតាំងពីឆ្នាំ២០០២មក។ ម្យ៉ាងវិញទៀត អាស៊ានក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែរស្តីពីការផ្លោះប្តូរពាណិជ្ជកម្មដោយសេរីជាមួយចិន។ ដោយឡែកសហគមន៍ចិននៅអាស៊ីអាគ្នេយ៍ក៏ជួយទាញចិននិងអាស៊ានឲ្យខិតចូលជិតគ្នាដែរ។ នៅអតីតកាល ជនជាតិចិននៅអាស៊ីអាគ្នេយ៍ស្អប់របបចិនកុម្មុយនិស្ត។ ផ្ទុយទៅវិញ សព្វថ្ងៃ កូនចៅចិននៅក្នុងតំបន់មានមោទនភាពចំពោះឥទ្ធិពលខ្លាំងក្លានៃប្រទេសដូនតាពួកគេហើយមិនរារែកឡើយក្នុងការទាក់ទងរកស៊ីជាមួយចិនកុម្មុយនិស្ត។

ក៏ប៉ុន្តែ ទោះបីជាទំនាក់ទំនងរវាងចិននិងអាស៊ានមានលក្ខណៈកាន់តែប្រសើរពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយ ក៏តាំងពីដើមដំបូងមកថ្នាក់ដឹកអាស៊ានតែងតែប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍មួយច្បាស់ នោះគឺធ្វើយ៉ាងណាកុំឲ្យអាស៊ីអាគ្នេយ៍ឋិតនៅក្រោមឥទ្ធិពលផ្តាច់មុខរបស់ចិនបាន។

ការពិត សព្វថ្ងៃទំនាក់ទំនងរវាងចិននិងអាស៊ានមានលក្ខណៈកាន់តែល្អ ល្អណាស់បើប្រៀបទៅនឹងសម័យសង្គ្រាមត្រជាក់។ ចិននិងអាស៊ានមានទំនាក់ទំនងសេដ្ឋកិច្ចកាន់តែប្រសើរឡើង ជាក់ស្តែងតាមរយៈការចូលជាធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងភាគីទាំងពីរនៅខែមករាឆ្នាំ២០១០ ទោះជាវាមានសុពលភាពទៅលើតែឥណ្ឌូនេស៊ី ថៃ សិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន និងព្រុយណេសិនក៏ដោយ។ តែ ចង់ឬមិនចង់ នៅឆ្នាំ២០១៥ នៅពេលណាដែលប្រទេសអាស៊ាន៤ទៀត គឺវៀតណាម កម្ពុជា ឡាវនិងភូមានឹងត្រូវចូលក្នុងតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ានហើយ នៅពេលនោះ ចិននឹងច្បាស់ជាក្លាយទៅជាដៃគូពាណិជ្ជកម្មធំបំផុតរបស់អាស៊ាន គឺធំជាងជប៉ុន និងសហភាពអឺរ៉ុបទៅទៀត។ ជាការពិតណាស់ដែលថា ថ្នាក់ដឹកនាំទីក្រុងប៉េកាំងបាននិងកំពុងបន្តខ្នះខ្នែងពន្យល់ប្រាប់អាស៊ានថា ចិនគ្មានបំណងអាក្រក់ចង់បៀតបៀនបណ្តាប្រទេសអាស៊ីអាគ្នេយ៍ទេ ហើយថាចង់ធ្វើជាដៃគូគំរូមួយរបស់អាស៊ាន។ ក៏ប៉ុន្តែ ថ្នាក់ដឹកនាំអាស៊ានមិនដែលទុកចិត្តមហាយក្ស

ចិនទាំងស្រុងឡើយ ហើយតែងតែប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍មួយច្បាស់ នោះគឺធ្វើយ៉ាងណាកុំឲ្យអាស៊ីអាគ្នេយ៍ឋិតនៅក្រោមឥទ្ធិពលផ្តាច់មុខរបស់ចិនបាន។ អ៊ីចឹងហើយបានជាតាំងពីឆ្នាំ១៩៩៨មកនៅក្រោយជំនួបកំពូលអាស៊ានម្តងៗ តែងតែមានរៀបចំឡើងនូវអ្វីដែលគេហៅថា ជំនួបកំពូលអាស៊ានបូក៣ គឺបូកចិន ជប៉ុន និងកូរ៉េ ខាងត្បូង។ មិនតែប៉ុណ្ណោះ រៀងរាល់ឆ្នាំនៅពេលបិទបញ្ចប់ជំនួបកំពូលអាស៊ានហើយ ក៏តែងតែមានរៀបចំឡើងដែរនូវអ្វីដែលគេហៅថាជំនួបកំពូលអាស៊ីបូព៌ារវាងប្រទេសអាស៊ានទាំង១០ និងចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី នូវែលសេឡង់ សហរដ្ឋអាមេរិកព្រមទាំងរុស្ស៊ី។ ការដែលអាស៊ាននៅតែមិនទាន់ទុកចិត្តចិនកុម្មុយនិស្តមួយរយភាគរយ គឺមិនមែនចៃដន្យឡើយ។ ចូរកុំភ្លេចថា គោលដៅសំខាន់ជាងគេមួយនៃការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ឡើងនៅឆ្នាំ១៩៦៧ គឺការបង្រួបបង្រួមគ្នាជាខែលមួយដើម្បីទប់ទល់នឹងគ្រោះថ្នាក់កុម្មុយនិស្ត។

ដោយឡែក ក្នុងបច្ចុប្បន្នកាលនេះ នៅម្ខាងថ្នាក់ដឹកនាំចិនថ្លែងថា ចង់បានតែសន្តិភាពនិងស្ថិរភាពនៅក្នុងតំបន់។ ក៏ប៉ុន្តែ នៅម្ខាងទៀត កាយវិការរបស់ទីក្រុងប៉េកាំងមិនទាន់ស្តែងឲ្យឃើញច្បាស់នៅឡើយទេថា ចិនជាមហាប្រទេសដែលនិយមអំណាចស្រទន់The soft power។ ជាក់ស្តែង មហិច្ឆតារបស់ទីក្រុងប៉េកាំងនៅក្នុងតំបន់សមុទ្រចិនខាងត្បូងនៅតែបន្តបណ្តាលឲ្យភាពតានតឹងកើតឡើងជារឿយៗ។ ភាពតានតឹងចេះតែបន្តកើតឡើងរវាងចិននិងជប៉ុន រវាងចិននិងបណ្តាប្រទេសអាស៊ានមួយចំនួន ជាអាទិ៍ជាមួយវៀតណាម ហ្វីលីពីន ម៉ាឡេស៊ី និងព្រុយណេ។ គឺនៅក្នុងបរិបទតានតឹងបែបនេះហើយដែលអាស៊ានបានបើកដៃទទួលសហរដ្ឋអាមេរិក តាមរយៈជំនួបកំពូលអាស៊ាន-អាមេរិក តាំងពីឆ្នាំ២០០៩មក។

ការខិតចូលជិតគ្នារវាងសហរដ្ឋអាមេរិកនិងអាស៊ាន មិនយូរមិនឆាប់ វានឹងអាចធ្វើឲ្យល្អក់កករទំនាក់ទំនងរវាងចិននិងអាស៊ាន ពីព្រោះ នេះជាការបើកលទ្ធភាពឲ្យអាមេរិកបង្កើនវត្តមាន និងទម្ងន់របស់ខ្លួន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលចិនចាត់ទុកថាជាដែនអំណាចរបស់ខ្លួន។ សហរដ្ឋអាមេរិកច្បាស់ជានឹងឆ្លៀតពន្យល់ដល់បណ្តាប្រមុខដឹកនាំអាស៊ាន នូវតួនាទីដ៏ចាំបាច់របស់ខ្លួន ក្នុងតំបន់អាស៊ីអាគ្នេយ៍ ឧទាហរណ៍ នៅក្នុងដំណោះស្រាយនៃជម្លោះទីប្រជុំកោះParacel និងSprately ជាដើម។ ត្រង់នេះ នៅខែកញ្ញាឆ្នាំ២០១០ នាពេលដែលជំនួបកំពូលអាស៊ាន-អាមេរិក កំពុងតែប្រព្រឹត្តិទៅនៅញូយ៉ក ស្រាប់តែក្រសួងការបរទេសចិនចេញសេចក្តីថ្លែងការណ៍ព្រមានថា ចិនជំទាស់មិនឲ្យប្រែក្លាយបញ្ហាទីប្រជុំកោះParacel និងSprately ទៅជាបញ្ហាអន្តរជាតិទេ បានន័យថា ទីក្រុងប៉េកាំងចង់ដោះស្រាយជម្លោះទីប្រជុំកោះទាំងពីរនេះ ជាឧភតោភាគី គឺថាជាមួយភាគីជម្លោះនីមួយៗដាច់ពីគ្នា។

មិនតែប៉ុណ្ណោះ មិនយូរមិនឆាប់ វត្តមានរបស់អាមេរិកនៅក្នុងវេទិកាអាស៊ាន ក៏នឹងអាចបណ្តាលឲ្យមានការបាក់បែកគ្នារវាងប្រទេសអាស៊ានដែលមានទំនោរទៅរកអាមេរិក និងប្រទេសអាស៊ានដែលមានទំនោរទៅរកចិន។ ដោយហេតុតែការវិវឌ្ឍន៍ទៅនៃប្រវត្តិសាស្ត្រនៅក្នុងអាស៊ាន មានរួចស្រេចទៅហើយ ប្រទេសដែលស្និទ្ធនឹងអាមេរិកនិងប្រទេសដែលស្និទ្ធនឹងចិន។

## ៥. ទំនាក់ទំនងអាស៊ាន និងសហរដ្ឋអាមេរិក




ជំនួបកំពូលអាមេរិក-អាស៊ានលើកទី៣ នៅប្រទេសឥណ្ឌូណេស៊ី។RFI

មហិច្ឆតារបស់សហរដ្ឋអាមេរិកមកលើភូមិភាគអាស៊ីអាគ្នេយ៍មានជាយូរយារណាស់មកហើយ។ ចូរកុំភ្លេចថា អាមេរិកក្រសោបយកហ្វីលីពីនមកធ្វើជាអាណានិគមរបស់ខ្លួន នៅឆ្នាំ១៨៩៨។ ប៉ុន្តែយ៉ាងណាក៏ដោយ ក៏អាមេរិកផ្តើមយកចិត្តទុកដាក់ខ្លាំងទៅលើតំបន់អាស៊ីអាគ្នេយ៍ ក្រោយពេលដែលសង្គ្រាមត្រជាក់បានផ្ទុះឡើងនៅឆ្នាំ១៩៤៧ និងជាពិសេសក្រោយពេលដែលចិនបានក្លាយជាកុម្មុយនិស្តនៅឆ្នាំ១៩៤៩។

នៅក្នុងបរិបទនៃសង្គ្រាមត្រជាក់រវាងលោកសេរីដឹកមុខដោយអាមេរិក និងពិភពកុម្មុយនិស្តនាំមុខដោយសហភាពសូវៀត អាមេរិកផ្តើមលូកដៃចូលជ្រៀមកដល់ភូមិភាគអាស៊ីអាគ្នេយ៍នៅពាក់កណ្តាលទសវត្សរ៍ទី៥០ តាមរយៈសង្គ្រាមនៅឥណ្ឌូចិន។ កាលណោះ ក្រោយបរាជ័យរបស់កងទ័ពបារាំងនៅDien Bien Phu ឆ្នាំ១៩៥៤ អាមេរិកចេញមុខការពារកុំឱ្យវៀតណាមខាងត្បូងធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់វៀតណាមខាងជើងកុម្មុយនិស្ត។ ការប្តេជ្ញាចិត្តបែបនេះរបស់អាមេរិកធ្វើឱ្យសង្គ្រាមវៀតណាមផ្ទុះឡើងនៅឆ្នាំ១៩៦៤ សង្គ្រាមដែលប៉ុន្មានឆ្នាំក្រោយមកបានដរនិងរីករាលដាលទៅដល់កម្ពុជានិងឡាវ។

ទន្ទឹមនេះ អាមរិកបែរជាមិនគាំទ្រសោះឡើយ ការបង្កើតអាស៊ានឡើងនៅឆ្នាំ១៩៦៧ ដោយបណ្តាប្រទេសសម្ព័ន្ធមិត្រទាំង៥របស់ខ្លួន គឺថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី និងហ្វីលីពីន ទោះបីជាកាលណោះអាស៊ានត្រូវបានបង្កើតឡើង ដើម្បីប្រយុទ្ធទប់ទល់នឹងគ្រោះថ្នាក់កុម្មុយនិស្តក៏ដោយ។ មានមូលហេតុពីរយ៉ាងដែលអាចបំភ្លឺឥរិយាបថបែបនេះរបស់អាមេរិកកាលសម័យនោះ។ ម្យ៉ាងទៀត គឺមកពីបណ្តាប្រទេសស្ថាបនិកអាស៊ានទាំង៥ មិនព្រមប្រកាសគាំទ្រអាមេរិកជាផ្លូវការ នៅក្នុងសង្គ្រាមត្រជាក់ជាមួយសហភាពសូវៀត។ ម្យ៉ាងទៀត គឺមកពីកាលណោះ អាស៊ានត្រូវបានចិនចាត់ទុកថាជាអង្គការតំបន់មួយដែលប្រឆាំងនឹងខ្លួន ជួនចំពេលមួយដែលអាមេរិកកំពុងត្រូវការចិន និងចាប់ផ្តើមត្រូវរ៉ូវគ្នាជាមួយនឹងចិន ដើម្បីប្រឈមមុខនឹងសហភាពសូវៀត។

ប៉ុន្តែ ក្រោយមកទៀត ដោយហេតុតែការគាបសង្កត់របស់មតិអន្តរជាតិ និងដោយហេតុតែភាពសាហាវយង់ឃ្នងនៃសង្គ្រាម អាមេរិកត្រូវបង្ខំចិត្តដកទ័ពចេញពីឥណ្ឌូចិន ហើយបណ្តោយឱ្យវៀតណាមខាងត្បូង កម្ពុជានិងឡាវក្លាយជាកុម្មុយនិស្ត នៅឆ្នាំ១៩៧៥។ ចាប់ពីពេលនោះមក អាមេរិកផ្តើមកាត់បន្ថយទម្ងន់យុទ្ធសាស្ត្រនិងយោធារបស់ខ្លួននៅអាស៊ីនិយាយជាទូទៅ និងនៅអាស៊ីអាគ្នេយ៍និយាយដាច់ដោយឡែក។ ជាក់ស្តែងនៅពេលដែលវៀតណាមរណបសូវៀតចូលរំលំរបបខ្មែរក្រហមរណបចិននិងកាន់កាប់កម្ពុជានៅឆ្នាំ១៩៧៩ អាមេរិកឈរឱបដៃមើល មិនព្រមធ្វើអ្វីក្រៅពីចូលដៃជាមួយចិន ដើម្បីជួយពីចម្ងាយ ជួយផ្តល់អាវុធឱ្យខ្មែរក្រហមធ្វើសង្គ្រាមប្រឆាំងនឹងរបបហេង សំរិនរណបវៀតណាម។

គេត្រូវរង់ចាំរហូតដល់ដើមទសវត្សរ៍ឆ្នាំ២០០០ ទើបឃើញអាមេរិកវិលបណ្តើរៗមកកាន់អាស៊ីអាគ្នេយ៍វិញ។ ក៏ប៉ុន្តែ គឺជាការត្រឡប់មកវិញដោយប្រយោល តាមរយៈសង្គ្រាមប្រឆាំងភេរវកម្មអន្តជាតិរបស់លោកប្រធានាធិបតីអាមេរិកាំង ប៊ូស(Bush)។

កាលនោះ ក្រោយមហាភេរវកម្មថ្ងៃទី១១កញ្ញាឆ្នាំ២០០១នៅសហរដ្ឋអាមេរិក រដ្ឋការលោក ប៊ូស ចាត់ទុកអាស៊ីអាគ្នេយ៍ថាជាសមរភូមិសំខាន់ទីពីរនៃសង្គ្រាមប្រឆាំងភេរវកម្មអន្តរជាតិរបស់ខ្លួន ដ្បិតអាស៊ីអាគ្នេយ៍ជាទីដែលសម្បូណ៌អ្នកកាន់សាសនាអ៊ីស្លាមរស់នៅ។ ក្នុងគោលដៅប្រឆាំងនឹងពួកភេរវជនអ៊ីស្លាមជ្រុលនិយមនៅក្នុងតំបន់ អាមេរិក របស់លោក ប៊ូស បានផ្តើមពង្រឹងឡើងវិញសហប្រតិបត្តិការយោធាជាមួយសម្ព័ន្ធមិត្តអាស៊ីអាគ្នេយ៍របស់ខ្លួន រួមមានឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ។ មិនតែប៉ុណ្ណោះ អាមេរិកក៏បានផ្តើមប្រឹងប្រែងខិតទៅរកវៀតណាមដែរ ក្នុងគោលបំណងទប់ស្កាត់ឥទ្ធិពលរបស់ចិននៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍។

តាំងពីឆ្នាំ២០០៩មក សហរដ្ឋអាមេរិកក្រោមការដឹកនាំរបស់លោកអូបាម៉ា(Obama) បាននិងកំពុងបន្តពង្រឹងវត្តមានអាមេរិកាំង នៅអាស៊ីប៉ាស៊ីហ្វិក។ មានមូលហេតុបីសំខាន់ៗដែលអាចពន្យល់បំភ្លឺមហិច្ឆតាអាមេរិកាំង នៅអាស៊ីប៉ាស៊ីហ្វិកដ៏ធំល្វឹងល្វើយនេះ។ ទីមួយ គឺមូលហេតុប្រវត្តិសាស្ត្រ ដែលបានតម្រូវឲ្យសហរដ្ឋអាមេរិកដើរតួនាទីជាមហាអំណាចនៅក្នុងតំបន់នេះ តាំងពីចុងសតវត្សរ៍ទី១៩មកម្ល៉េះ។ ទីពីរ គឺមូលហេតុនយោបាយ បានន័យថាមានប្រទេសមួយចំនួន ដូចជាជប៉ុន កូរ៉េខាងត្បូង សិង្ហបូរីនិងអូស្ត្រាលីជាដើម ចង់បានវត្តមានអាមេរិកាំងនៅក្នុងតំបន់ដើម្បីបន្តរក្សាសន្តិសុខនិងលំនឹងភូមិសាស្ត្រនយោបាយ នៅចំពោះមុខការលេចត្រដែតឡើងនៃប្រទេសចិន។ រីឯមូលហេតុទីបីវិញ ដែលជំរុញសហរដ្ឋអាមេរិកឱ្យពង្រឹងវត្តមានរបស់ខ្លួននៅអាស៊ីប៉ាស៊ីហ្វិក គឺប្រយោជន៍ពាណិជ្ជកម្ម និងសេដ្ឋកិច្ច ដ្បិតតំបន់នេះកំពុងស្គាល់កំណើនសេដ្ឋកិច្ចខ្លាំងជាងគេបង្អស់ នៅក្នុងលោកសព្វថ្ងៃ។ គឺនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រថ្មីនៅចំពោះមុខអាស៊ីនេះហើយដែលរដ្ឋការលោក អូបាម៉ា កំពុងសើរើមើលឡើងវិញនយោបាយការបរទេសរបស់រដ្ឋការលោក ប៊ូស នៅអាស៊ីអាគ្នេយ៍។ រដ្ឋការលោក ប៊ូស បានឲ្យតម្លៃទៅលើតែសង្គ្រាមប្រឆាំងភេរវកម្មនៅក្នុងតំបន់នេះ និងទៅលើសហប្រតិបត្តិការឧភតោភាគីជាមួយសមាជិកអាស៊ាននីមួយៗដាច់ដោយឡែក។

ផ្ទុយទៅវិញ អ្វីដែលលោកអូបាម៉ាចាប់អារម្មណ៍ខ្លាំង គឺមិនមែនករណីប្រទេសនីមួយៗនៅអាស៊ីអាគ្នេយ៍ទេ តែគឺអាស៊ានទាំងមូលតែម្តង។ ជាក់ស្តែង តាំងពីឆ្នាំ២០០៩មក ជំនួបកំពូលអាស៊ាន-អាមេរិកត្រូវបានរៀបចំឡើងរៀងរាល់ឆ្នាំ។

ទន្ទឹមនេះ ក្នុងពេលមួយដែលចិនបង្ហាញកាន់តែច្បាស់នូវមហិច្ឆតាស្រេកឃ្លានទឹកដីរបស់ខ្លួនជាអាទិ៍នៅក្នុងសមុទ្រចិនខាងត្បូង បណ្តាសមាជិកអាស៊ានមួយចំនួនធំទទួលស្វាគមន៍ការមកដល់របស់សហរដ្ឋអាមេរិក។ ជាទូទៅ ពួកគេមើលឃើញថា ការពង្រឹងទំនាក់ទំនងជាមួយអាមេរិកអាចជួយកាត់បន្ថយឥទ្ធិពលរបស់ចិន អាចជួយរក្សាលំនឹងភូមិសាស្ត្រនយោបាយនៅក្នុងតំបន់និង នៅទីបំផុត អាចជួយអាស៊ានកុំឱ្យពឹងពាក់ចិនខ្លាំងជ្រុលពេក នៅលើវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច ទូតនិងនយោបាយ។ ដោយឡែក សមាជិកអាស៊ានដែលមានទំនាស់ទឹកដីជាមួយចិននៅសមុទ្រចិនខាងត្បូង រួមមានវៀតណាមនិងហ្វីលីពីនជាដើម ចាត់ទុកអាមេរិកជាបង្អែកនយោបាយឬយោធាផងក៏មិនដឹង ដើម្បីប្រឈមមុខនឹងចិន។ យ៉ាងណាក៏ដោយ បញ្ហានៅក្នុងសមុទ្រចិនខាងត្បូងរវាងបណ្តាប្រទេសសមាជិកអាស៊ាន និងចិន ជាឱកាសមួយដ៏ល្អសម្រាប់ទីក្រុងវ៉ាស៊ីនតោន ក្នុងការលូកដៃចូលមកក្នុងភូមិភាគអាស៊ីអាគ្នេយ៍និយាយដោយឡែក និងចូលមកក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកនិយាយជាទូទៅ៕

## ៦. ទំនាក់ទំនងអាស៊ាន និងសហភាពអឺរ៉ុបៈ នៅតែស្វែងរកគ្នាមិនទាន់ឃើញ



អាស៊ាន និង សហភាពអឺរ៉ុប

ហូតមកដល់ឆ្នាំ២០០០-២០០១ អាស៊ានមិនដែលត្រូវបានសហភាពអឺរ៉ុបយកចិត្តទុកដាក់ខ្លាំងឡើយ។ នយោបាយការបរទេសរួមរបស់ទីក្រុង Bruxelles បានឲ្យតម្លៃជាពិសេសទៅលើតែបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅទ្វីបអាហ្វ្រិក នៅតំបន់ការ៉ាអ៊ីប(Caraïbes) និងនៅតំបន់ប៉ាស៊ីហ្វិក(Pacifique)។ ឯនៅអាស៊ីវិញ សហភាពអឺរ៉ុបបានត្រឹមតែពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ជាមួយប្រទេសធំៗឬជាមួយប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ ដូចជាចិនឥណ្ឌានិងកូរ៉េខាងត្បូងតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ នារយៈពេលជាងដប់ឆ្នាំចុងក្រោយនេះ នៅក្នុងពេលមួយដែលការផ្លោះប្តូរពាណិជ្ជកម្មរវាងអឺរ៉ុបនិងអាស៊ីចេះតែកើនឡើងជាលំដាប់ ស្រាប់តែអាស៊ានក្លាយដោយស្វ័យប្រវត្តជាដៃគូសេដ្ឋកិច្ចមួយដ៏ធំរបស់សហភាពអឺរ៉ុប។ សព្វថ្ងៃនេះអឺរ៉ុបជាទីផ្សារសំខាន់លំដាប់ថ្នាក់ទីពីរ សំរាប់ផលិតផលរបស់អាស៊ាន នៅក្រោយសហរដ្ឋអាមេរិកដែលជាទីផ្សារធំទីមួយ ហើយអឺរ៉ុបជាដៃគូពាណិជ្ជកម្មទីបីរបស់អាស៊ាន បន្ទាប់ពីអាមេរិកនិងជប៉ុន។

នៅឆ្នាំ២០០០-២០០១ ទីក្រុងBruxelles ផ្តើមភ្ញាក់ខ្លួន ហើយផ្តើមយល់ដឹងពីសក្តានុពលសេដ្ឋកិច្ចរបស់អាស៊ាន ដោយហេតុតែឱនភាពហូតទៅដល់ជាងបីម៉ឺនលានដុល្លារនៃជញ្ជីងពាណិជ្ជកម្មរបស់អឺរ៉ុបនៅចំពោះមុខអាស៊ាន បានន័យថាបណ្តាប្រទេសសមាជិកសហភាពអឺរ៉ុបទិញទំនិញពីបណ្តាសមាជិកអាស៊ានច្រើនជាងលក់ទំនិញទៅឲ្យបណ្តាប្រទេសទាំងនេះ។ ដូច្នេះ ចាប់តាំងពីពេលនោះមក ទីក្រុងBruxellesបានផ្លាស់ប្តូរនយោបាយ ក្នុងគោលដៅពង្រឹងវត្តមានរបស់អឺរ៉ុបនៅអាស៊ីអាគ្នេយ៍។ នៅក្នុងន័យនេះ គណៈកម្មការអឺរ៉ុបបាននិងកំពុងបន្តជំរុញឲ្យក្រុមហ៊ុនអឺរ៉ុប ទៅដាក់ទុនរកស៊ី នៅក្នុងបណ្តាប្រទេសសមាជិកអាស៊ាន។ នៅក្នុងន័យដូចគ្នានេះដែរ សហភាពអឺរ៉ុបបានចុះហត្ថលេខាទទួលយកសន្ធិសញ្ញាស្តីពីមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ហៅកាត់ថាTAC ហើយសហភាពអឺរ៉ុបក៏កំពុងបន្តចរចាជាមួយអាស៊ាន ដើម្បីបង្កើតតំបន់ផ្លោះប្តូរពាណិជ្ជកម្មដោយសេរីមួយដែរ។

យ៉ាងណាក៏ដោយ មកទល់សព្វថ្ងៃ សហភាពអឺរ៉ុបនិងអាស៊ាន ដូចជានៅតែមិនទាន់ព្រមឲ្យតម្លៃខ្ពស់ដល់ភាពជាដៃគូនេះរបស់ពួកគេនៅឡើយ។ ជាក់ស្តែង កិច្ចប្រជុំពីរឆ្នាំម្តងរវាងប្លុកទាំងពីរ នៅតែប្រព្រឹត្តទៅត្រឹមថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេសនៅឡើយ មិនទាន់មានទេជំនួបកំពូល រវាងបណ្តាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលរបស់សហភាពអឺរ៉ុប និងរបស់អាស៊ាន។ ពិបាកយល់ជាងនេះទៅទៀត គឺរដ្ឋមន្ត្រីការបរទេសប្រទេសអឺរ៉ុបខ្លះមិនទាំងទៅចូលរួមក្នុងកិច្ចប្រជុំនេះទៅទៀត ច្រើនតែបញ្ជូនរដ្ឋលេខាធិការទៅជំនួសខ្លួនទៅវិញ យ៉ាងណាមិញ សហភាពអឺរ៉ុបនិងអាស៊ានដូចជាមិនសូវស៊ីចង្វាក់គ្នា។ ជាទូទៅ អឺរ៉ុបមានឥរិយាបថរឹងរូស ឧទាហរណ៍នៅចំពោះមុខការរំលោភសិទ្ធិមនុស្សរហូតមកទល់ពេលថ្មីៗនេះនៅប្រទេសភូមា។ ចំណែកអាស៊ានវិញ មិនសូវចង់ជ្រៀតជ្រែកទេក្នុងបញ្ហាផ្ទៃក្នុងនៃប្រទេសណាមួយ ចូលចិត្តសាច់ការ និងគិតតែពីប្រយោជន៍សេដ្ឋកិច្ច។

មែនទែនទៅ មានច្រើនណាស់ចំណុចរួមរវាងសហភាពអឺរ៉ុបនិងអាស៊ាន ចំណុចរួមដែលអាចជួយឱ្យប្លុកទាំងពីរខិតចូលជិតគ្នា។ មានជាបឋមប្រវត្តិសាស្ត្ររួមគ្នា ប្រវត្តិសាស្ត្រដែលទាក់ទងទៅនឹងសម័យអាណានិគមនិយម ពីព្រោះចូរកុំភ្លេចថាបារាំង អង់គ្លេស អេស្ប៉ាញ ព័រទុយហ្គ័ល ឬក៏ហុល្លង់ សុទ្ធសឹងជាប្រទេសដែលបានកាន់កាប់ប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនធំអស់រយៈពេលជាច្រើនសិបឆ្នាំ។ ដោយឡែក សហភាពអឺរ៉ុបជាគំរូសមាហរណ៍កម្មតំបន់មួយសំរាប់អាស៊ាន អាស៊ានដែលចង់ប្រែក្លាយឱ្យដូចសហភាពអឺរ៉ុបយ៉ាងយូរនៅឆ្នាំ២០២០។ ម្យ៉ាងទៀត ការពង្រឹងភាពជាដៃគូរវាងតំបន់ទាំងពីរនឹងនាំមកនូវអត្ថប្រយោជន៍ធំ។ អត្ថប្រយោជន៍សំរាប់សហភាពអឺរ៉ុប គឺបទពិសោធនៅក្នុងទំនាក់ទំនងរវាងអង្គការតំបន់មួយនិងអង្គការតំបន់មួយទៀត។ ចំណែកអត្ថប្រយោជន៍សំរាប់អាស៊ានវិញ គឺអឺរ៉ុបអាចជួយធ្វើឲ្យមានតុល្យភាពភូមិសាស្ត្រនយោបាយមួយល្អនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលឋិតនៅក្រោមឥទ្ធិពលខ្លាំងពេករបស់ប្រទេសចិននិងរបស់សហរដ្ឋអាមេរិក

**សេចក្តីសន្និដ្ឋានទៅលើភូមិសាស្ត្រនយោបាយអាស៊ីអាគ្នេយ៍**

និយាយរួម អាស៊ីអាគ្នេយ៍បានឈានជើងចេញរួចពីភាពប្រេះឆារ និងដើរមកដល់គោលដៅឯកភាពក្រោមដំបូលតែមួយរបស់អាស៊ាន នៅទីបំផុត។ ប៉ុន្តែ នេះមិនមែនបានន័យថា ភូមិភាគអាស៊ីអាគ្នេយ៍នឹងច្បាស់ជាមានអនាគតភ្លឺស្វាងនោះទេ។




បណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងដប់ក្រោមដំបូលអាស៊ានតែមួយនៅទីបំផុត។RFI

នៅក្នុងទសវត្សរ៍ទី៥០ សេដ្ឋវិទូមួយចំនួនបានអះអាងថា អាស៊ីអាគ្នេយ៍នឹងមិនអាចឈានជើងចេញរួចពីភាពក្រីក្របានទេ។ ៦០ឆ្នាំក្រោយមក ភូមិភាគមួយនេះកំពុងស្គាល់សន្ទុះសេដ្ឋកិច្ចខ្លាំងក្លា ប្រមូលផ្តុំទៅដោយនាគសេដ្ឋកិច្ចដូចជាសិង្ហបុរី និងពួកខ្លាសេដ្ឋកិច្ច រួមមានជាអាទិ៍ ម៉ាឡេស៊ី ថៃ ហ្វីលីពីន ឥណ្ឌូណេស៊ី ព្រមទាំងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាវៀតណាម ភូមា កម្ពុជា និងឡាវ។

ប៉ុន្តែ គេគួរទទួលស្គាល់ថា អាស៊ីអាគ្នេយ៍សម័យចន្លោះទសវត្សរ៍ទី៥០និងចុងទសវត្សរ៍ទី៨០ គឺពិតជាតំបន់មួយដែលមិនអំណោយផលសោះឡើយសម្រាប់ការអភិវឌ្ឍន៍ ដ្បិតវាជាសមរភូមិក្តៅគគុកជាងគេមួយនៃសង្គ្រាមត្រជាក់ ដូចមានសង្គ្រាមនៅឥណ្ឌូចិនក្នុងទសវត្សរ៍ទី៦០ ៧០និង៨០ ជាឧទាហរណ៍ជាក់ស្តែងស្រាប់។ គឺនៅក្នុងបរិបទបាក់បែកប្រេះឆារគ្នាខ្លាំងក្នុងទសវត្សរ៍ទី៦០នោះហើយដែលសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថាអាស៊ានត្រូវបានបង្កើតឡើង។ តាមការពិតអាស៊ានត្រូវបានបង្កើតឡើងដោយគ្មានការគាំទ្របន្តិចសោះឡើយពីសំណាក់អង្គការសហប្រជាជាតិនិងពីសំណាក់មហាអំណាចដែលកាលសម័យនោះកំពុងជាប់ដៃកកូរកកាយឥណ្ឌូចិន និងកំពុងប្រជែងឥទ្ធិពលមនោគមវិជ្ជារវាងគ្នា នៅអាស៊ីអាគ្នេយ៍ទាំងមូល។

សរុបមក គ្មានអ្នកណាមានជំនឿទៅលើអនាគតអាស៊ានទេ កាលសម័យនោះ។ ម្យ៉ាងគឺមកពីបណ្តាប្រទេសស្ថាបនិក ថៃ ម៉ាឡេស៊ី សិង្ហបុរី ហ្វីលីពីន និងឥណ្ឌូណេស៊ីកាលណោះ សុទ្ធតែមានជម្លោះទឹកដីនឹងគ្នា។ ម្យ៉ាងទៀត កុំថាឡើយកាលសម័យទសវត្សរ៍ទី៦០ សូម្បីតែសព្វថ្ងៃហ្នឹង ក៏បណ្តាប្រទេសអាស៊ីអាគ្នេយ៍នៅតែមានលក្ខណៈខុសគ្នាច្រើននិងដូចគ្នាតិច ប្រើភាសាខុសៗគ្នា មានសាសនា វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីមិនដូចគ្នា។ ភាពមិនដូចគ្នាក៏មានដែរ នៅលើវិស័យរបបនយោបាយ និងកម្រិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយនេះមិនទាន់និយាយដល់លក្ខណៈភូមិសាស្ត្រផង។ អាស៊ីអាគ្នេយ៍មិនមែនជាទ្វីប មិនមែនជាឧបទ្វីប តែជាភូមិភាគនៃពិភពពីរខុសគ្នាពិភពឥណ្ឌូចិនដែលជាដីគោក និងពិភពម៉ាឡេដែលជាដីកោះ។ តែយ៉ាងណា

ក៏ដោយ បន្តិចម្តងៗ និងជាពិសេស ក្រោយពីសង្គ្រាមត្រជាក់បានរលត់រលាយបាត់នៅដើមទសវត្សរ៍ទី៩០ អាស៊ានដ៏តូចច្រម៉ក់និងដែលគ្មានអ្នកណាឱ្យតម្លៃចាប់ផ្តើមរីកធំ មានទឹកមាត់ប្រៃ រហូតដល់ក្លាយជាអង្គការតំបន់មួយដែលគ្មានមហាអំណាចណាមួយអាចមើលរំលងបានទេក្នុងគ្រានេះ ដូចមានជំនួបកំពូលប្រចាំឆ្នាំដ៏អធិកអធមរបស់អង្គការមួយនេះបូករួមនិងជំនួបកំពូលពាក់ព័ន្ធដទៃផ្សេងជាឧទាហរណ៍ជាក់ស្តែងស្រាប់។

ប៉ុន្តែ ទន្ទឹមនេះ នៅពេលដែលបណ្តាប្រទេសអាស៊ីអាគ្នេយ៍បានចាកចេញរួចពីភាពប្រេះឆានិងបានបង្រួបបង្រួមគ្នាដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ចក្រោមដំបូលតែមួយរបស់អាស៊ាន ស្រាប់តែអង្គការតំបន់មួយនេះហាក់ដូចជាដើរមកដល់របត់មួយប្រកបទៅដោយគ្រោះថ្នាក់ ដោយហេតុតែត្រូវប្រឈមមុខនឹងបញ្ហាស្មុគស្មាញមួយចំនួន។ ក្នុងចំណោមបញ្ហាទាំងនោះ មានជាពិសេសទំនាស់នៃការដណ្តើមគ្នាក្តោបក្តាប់ទីប្រជុំកោះ Paracel និងSpratly នៅក្នុងសមុទ្រចិនខាងត្បូងរវាងបណ្តាប្រទេសអាស៊ានមួយក្រុម និងរវាងបណ្តាប្រទេសអាស៊ានទាំងនេះនិងមហាយក្សចិន។ ត្រង់នេះ មហិច្ឆតាកាន់តែធំនិងការស្រេកឃ្លានទឹកដីកាន់តែច្បាស់របស់ចិននៅក្នុងសមុទ្រចិនខាងត្បូងបាននិងកំពុងបន្តបណ្តាលឱ្យភាពតានតឹងកើតឡើងជារឿយៗ នៅក្នុងជំនួបកំពូលអាស៊ាន និងនៅក្នុងជំនួបកំពូលអាស៊ីបូព៌ា។ ការមើលមុខគ្នាមិនចំ កើតឡើងជាពិសេស រវាងចិន វៀតណាម និងហ្វីលីពីន។ ធ្ងន់ធ្ងរជាងនេះទៅទៀត គឺស្ថានភាពទូទៅនៅអាស៊ីអាគ្នេយ៍សព្វថ្ងៃ។ ពិតមែនតែសង្គ្រាមត្រជាក់បានរលត់រលាយបាត់ទៅអស់រយៈពេលជាង២០ឆ្នាំកន្លងមកហើយក្តី ក៏ចម្បាំងត្រជាក់មួយហាក់ដូចជាកំពុងផ្តើមកើតឡើងសារជាថ្មីនៅក្នុងភូមិភាគនេះ រវាងសហរដ្ឋអាមេរិកនិងចិន។

បញ្ហានៅក្នុងសមុទ្រចិនខាងត្បូងរវាងបណ្តាប្រទេសសមាជិកអាស៊ាននិងចិន ជាឱកាសមួយដ៏ល្អសម្រាប់ទីក្រុងវ៉ាស៊ីនតោន ក្នុងការលូកដៃចូលមកក្នុងអាស៊ីអាគ្នេយ៍។ គឺនៅក្នុងបរិបទបែបនេះហើយដែលតាំងពីឆ្នាំ២០០៩មក អាមេរិកនិងអាស៊ានបានបើកដៃរកគ្នា តាមរយៈជំនួបកំពូលអាស៊ាន-អាមេរិកមួយឆ្នាំម្តង តាំងពីឆ្នាំ២០០៩មក ហើយនៅឆ្នាំ២០១១ អាមេរិកក៏ដូចរុស្ស៊ីដែរបានក្លាយជាសមាជិកផ្លូវការនៃជំនួបកំពូលអាស៊ីបូព៌ា។

ដោយឡែក ពីពេលនេះតទៅ បណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំង១០ត្រូវប្រឈមមុខនឹងបញ្ហាស្មុគស្មាញដែលហូរចេញពីអភិក្រមនៃការធ្វើឱ្យសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍អាស៊ានក្លាយជាសហគមន៍សេដ្ឋកិច្ចអាស៊ាន នាដំណាច់ឆ្នាំ២០១៥ខាងមុខ។ បានន័យថា វាគឺជាការធ្វើសមាហរណកម្មទាំងស្រុងមួយ ដែលមិនត្រឹមតែមានចរាចរណ៍ទំនិញដោយសេរីប៉ុណ្ណោះទេ តែក៏នឹងត្រូវមានដែរចរាចរណ៍មូលធននិងចរាចរណ៍ប្រជាជនដោយសេរីនៅក្នុងលំហដែនដីនៃអាស៊ានទាំងមូល។

ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននាពេលខាងមុខនេះ មិនមែនជាការងាយស្រួលទេ ប៉ុន្តែជាគោលដៅមួយចាំបាច់។ ពីព្រោះ ពេលចេញជារូបរាង និងពេលមានដំណើរការរលូនល្អហើយ នៅពេលនោះអាស៊ីអាគ្នេយ៍ នឹងក្លាយជាមហាអំណាចសេដ្ឋកិច្ចទី៩នៅក្នុងពិភពលោក ក្លាយទៅជាទីផ្សារមួយដ៏ធំដែលមានប្រជាជនរហូតដល់ទៅជិត៦០០លាននាក់។ ប៉ុន្តែ ដើម្បីសម្រេចបានជោគជ័យនៃការធ្វើសមាហរណកម្មទាំងស្រុង វាទាល់តែពលរដ្ឋ ថ្នាក់ដឹកនាំនិងអ្នកនយោបាយជាទូទៅនៃប្រទេសសមាជិកអាស៊ាននីមួយៗ ចេះសម្លឹងមើលឆ្ងាយ ឆ្ងាយហួសពីព្រំដែនរបស់ប្រទេសខ្លួន និងឆ្ងាយហួសពីចក្ខុនិមិត្តជាតិនិយមឬជាតិនិយមជ្រុល ដើម្បីឱបក្រសោបយកព្រំដែននិងផលប្រយោជន៍តំបន់។

## សំណួរត្រិះរិះ

១. តើមូលហេតុអ្វីបានជាអាស៊ានទាំង១០ប្រទេសរួមគ្នា បង្កើតជាសមាគមមួយបាន ?
២. តើមូលហេតុអ្វីដែលបណ្ដាលឱ្យមានជំនួបកំពូលអាស៊ានបូកបី ?
៣. តើមូលហេតុអ្វីដែលនាំឱ្យកើតមានជំនួបកំពូលអាស៊ីបូព៌ា ?
៤. តើជំនួបកំពូលអាស៊ីបូព៌ាទទួលបានលទ្ធផលអ្វីខ្លះ ?
៥. តើអាស៊ីបូព៌ាអាចប្រក្លាយទៅជាសហគមន៍អាស៊ីបូព៌ាបានដែរ ឬទេ ?
៦. តើមូលហេតុអ្វីដែលនាំឱ្យកើតមានទំនាក់ទំនងអាស៊ាននិងឥណ្ឌា ?
៧. តើទំនាក់ទំនងអាស៊ានឥណ្ឌាផ្តល់ផលប្រយោជន៍ដល់ភាគីទាំងពីអ្វីខ្លះ ?
៨. តើមូលហេតុអ្វីដែលនាំឱ្យកើតមានទំនាក់ទំនងអាស៊ាននិងជប៉ុន ?
៩. តើទំនាក់ទំនងអាស៊ានជប៉ុនផ្តល់ផលប្រយោជន៍ដល់ភាគីទាំងពីអ្វីខ្លះ ?
១០. តើមូលហេតុអ្វីដែលនាំឱ្យកើតមានទំនាក់ទំនងអាស៊ាននិងចិន ?
១១. តើទំនាក់ទំនងអាស៊ានចិនផ្តល់ផលប្រយោជន៍ដល់ភាគីទាំងពីអ្វីខ្លះ ?
១២. តើមូលហេតុអ្វីដែលនាំឱ្យកើតមានទំនាក់ទំនងអាស៊ាននិងអាមេរិក ?
១៣. តើទំនាក់ទំនងអាស៊ានអាមេរិចផ្តល់ផលប្រយោជន៍ដល់ភាគីទាំងពីអ្វីខ្លះ ?

## ឯកសារយោង


1. Ministry of Foreign Affairs and International Cooperation(2024). ASEAN Charter. Retrieve from: https://mfaic.gov.kh/Page/2021-04-01-ASEAN-Charter-
2. អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា(២០១២). ធម្មនុញ្ញអាស៊ាន. នាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ. ភ្នំពេញ។
3. Wolfram Alpha(2024). Cambodia. Retrieve from: https://www.wolframalpha.com/input?i2d=true&i=Cambodia
4. Wolfram Alpha(2024). Laos. Retrieve from: https://www.wolframalpha.com/input?i2d=true&i=Laos
5. Wolfram Alpha(2024). Vietnam. Retrieve from: https://www.wolframalpha.com/input?i2d=true&i=Vietnam
6. Wolfram Alpha(2024). Thailand. Retrieve from: https://www.wolframalpha.com/input?i2d=true&i=Thai
7. Wolfram Alpha(2024). Myanmar. Retrieve from: https://www.wolframalpha.com/input?i2d=true&i=Myamar

8. Wolfram Alpha(2024). Philippines. Retrieve from: https://www.wolframalpha.com/input?i2d=true&i=philippines
9. Wolfram Alpha(2024). Brunei. Retrieve from: https://www.wolframalpha.com/input?i2d=true&i=Brunei
10. Wolfram Alpha(2024). Singapore. Retrieve from: https://www.wolframalpha.com/input?i2d=true&i=Singapore
11. Wolfram Alpha(2024). Malaya. Retrieve from: https://www.wolframalpha.com/input?i2d=true&i=Mylaysia
12. Wolfram Alpha(2024). Indonesia. Retrieve from: https://www.wolframalpha.com/input?i2d=true&i=Indonesia
13. Wikipedia(2024). Cambodia. Retrieve from: https://en.wikipedia.org/wiki/Cambodia
14. Wikipedia(2024). Laos. Retrieve from: https://en.wikipedia.org/wiki/Laos
15. Wikipedia(2024). Vietnam. Retrieve from: https://en.wikipedia.org/wiki/Vietnam
16. Wikipedia(2024). Thai. Retrieve from: https://en.wikipedia.org/wiki/Thai
17. Wikipedia(2024). Malaysia. Retrieve from: https://en.wikipedia.org/wiki/Malaysia
18. Wikipedia(2024). Myanmar. Retrieve from: https://en.wikipedia.org/wiki/Myanmar
19. Wikipedia(2024). Philippines. Retrieve from: https://en.wikipedia.org/wiki/ Philippines
20. Wikipedia(2024). Indonesia. Retrieve from: https://en.wikipedia.org/wiki/Indonesia
21. Wikipedia(2024). Brunei. Retrieve from: https://en.wikipedia.org/wiki/Brunei
22. Wikipedia(2024). Singapore. Retrieve from: https://en.wikipedia.org/wiki/Brunei. Singapore
23. តាន់ ហ្សង់-ហ្វ្រង់ស័រ(20/01/2014). អាស៊ាន១០ប្រទេស ទៅកាន់អាស៊ានបូក៣. RFI. ភ្នំពេញ
24. តាន់ ហ្សង់-ហ្វ្រង់ស័រ(05/02/2014). អាស៊ាននិងឥណ្ឌា. RFI. ភ្នំពេញ
25. តាន់ ហ្សង់-ហ្វ្រង់ស័រ(17/02/2014). ទំនាក់ទំនងជប៉ុន និងអាស៊ាន. RFI. ភ្នំពេញ
26. តាន់ ហ្សង់-ហ្វ្រង់ស័រ(24/02/2014). អាស៊ាន និងចិន. RFI. ភ្នំពេញ
27. តាន់ ហ្សង់-ហ្វ្រង់ស័រ(10/03/2014). សហរដ្ឋអាមេរិក និងអាស៊ាន. RFI. ភ្នំពេញ
28. តាន់ ហ្សង់-ហ្វ្រង់ស័រ(17/03/2014). អាស៊ាននិងសហភាពអឺរ៉ុប. RFI. ភ្នំពេញ

# ជំពូកទី៦៖ ភូមិវិទ្យាទេសចរណ៍ និងអេកូ-ទេសចរណ៍
# មេរៀនទី១៖ សញ្ញាណទូទៅនៃភូមិវិទ្យា ទេសចរណ៍

## ១. លក្ខណៈទូទៅនៃទេសចរណ៍

### ១.១. បញ្ញត្តិផ្សេងៗនៃទេសចរណ៍

តាមពិត ទេសចរណ៍មានន័យទូលំទូលាយណាស់ ទៅតាមការយល់ឃើញរបស់មនុស្សម្នាក់ៗនិងតាមកាលសម័យនីមួយៗ។ បច្ចុប្បន្ននេះមានការអោយនិយមន័យ **ទេសចរណ៍** ផ្សេងៗពីគ្នាថា ទេសចរណ៍ គឺជាការ ដើរលេង កំសាន្ត តាមរយៈដំណើរថ្មើជើង ឬតាមរយៈយានជំនិះណាមួយ ហើយត្រូវវិលត្រលប់មកកាន់ទីកន្លែង ដែលខ្លួនបានចាកចេញដំណើរវិញ បន្ទាប់ពីខ្លួនបានបញ្ចប់នូវសកម្មភាពនេះ។ ខ្លះទៀត បានកំណត់និយមន័យថា ទេសចរណ៍គឺជាការធ្វើដំណើរ ឬជាចលនារបស់ប្រជាពលរដ្ឋ ដែលមិនជាប់ទាក់ទងទៅនឹងការផ្លាស់ប្តូរទីកន្លែងរស់នៅនិងការងារ។ បានសេចក្តីថាការធ្វើដំណើរក្នុងគោលបំណង សំរាក លំហែកាយ និងអារម្មណ៏។ ទាំងនេះបង្ហាញឱ្យឃើញថា ទេសចរណ៍កើតឡើងពីការធ្វើដំណើរ ហើយការធ្វើដំណើរនេះ បាននាំឱ្យមានការកើតឡើងនូវសកម្មភាពថ្មីមួយគឺ ការស្នាក់នៅ ការទទួលទាន និងការសំរាក។ បើតាមអង្គការទេសចរណ៍ពិភពលោក (World Tourism Organization) បានកំណត់ន័យថា **ទេសចរណ៍** គឺជាការធ្វើដំណើររបស់មនុស្សម្នាក់ ឬមួយក្រុម ដែលបានចាកចេញពីលំនៅដ្ឋានជាអចិន្ត្រៃយ៍ សំដៅទៅទីកន្លែងណាមួយ ក្នុងគោលបំណងផ្សេងៗ បន្ទាប់មកត្រូវវិលត្រឡប់មកកាន់ទីកន្លែងដើមវិញ ក្នុងរយៈពេលចាប់ពី ២៤ ម៉ោងឡើងទៅ ប៉ុន្តែតិចជាង១ឆ្នាំក្នុងគោលបំណងធ្វើជំនួញ សកម្មភាពកីឡា សំរាក លំហែកំសាន្ត ជួបជុំគ្រួសារ ញាតិមិត្ត ឬចូលរួមក្នុងព្រឹត្តិការណ៍អ្វីមួយ តែមិនមែនក្នុងគោលបំណងតាំងទីលំនៅនោះទេ។

**ការធ្វើដំណើរ** គឺជាការចាកចេញពីកន្លែងដែលយើងរស់នៅសព្វថ្ងៃទៅកាន់កន្លែងផ្សេងៗទៀតក្នុងគោលបំណងច្រើនយ៉ាង ហើយត្រឡប់មកកន្លែងដើមវិញ ក្នុងរយៈពេលតិចជាង២៤ម៉ោង។

ភាពខុសគ្នានៃទេសចរណ៍ និងការធ្វើដំណើរ គឺគ្រាន់តែជាការបែងចែកមួយដោយជាក់លាក់ទៅលើស្ថានភាពនៃសេដ្ឋកិច្ច ដែលទាក់ទងទៅនឹងការចំណាយរបស់បុគ្គលម្នាក់ៗ ដែលបានធ្វើដំណើរកំសាន្ត ជាពិសេសគឺមានលក្ខណៈជាអន្តរជាតិ។

### ១.២. ប្រវត្តិទេសចរណ៍

#### ក. កត្តាជំរុញក្នុងការធ្វើដំណើរទេសចរណ៍

ការធ្វើដំណើរបែបទំនើប និងទេសចរណ៍ចាប់ផ្តើមនៅក្នុងសតវត្សទី១៩ ដែលនៅក្នុងពេលនោះមានការអភិវឌ្ឍផ្លូវដែក ផ្លូវថ្នល់ និងនាវាដឹកអ្នកដំណើរ។ ការធ្វើដំណើរជាលក្ខណៈអន្តរជាតិបានចាប់ផ្តើម នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ដោយសារការរីកចម្រើនប្រភេទយន្តហោះពាណិជ្ជកម្ម។ ការធ្វើដំណើរបែបទំនើបត្រូវបានជំរុញតាមរយៈកត្តាជាច្រើនដូចជា ៖

- **សេវាកម្មដឹកជញ្ជូន** កន្លែងស្នាក់នៅ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត កាន់តែមានភាពទំនើប និងប្រកបដោយផាសុកភាពដល់អ្នកទេសចរណ៍ ក្នុងការធ្វើដំណើរ។

- **ពាណិជ្ជកម្មអន្តរជាតិ** បានជំរុញឱ្យមានអាជីវកម្មកាន់តែច្រើន ហើយកាន់តែរីកចំរើនពីមួយថ្ងៃទៅមួយថ្ងៃដោយឆ្លងកាន់ពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត។
- **វិស្សមកាលប្រចាំឆ្នាំរបស់ពួកគេកាន់តែយូរ** ទើបជំរុញឱ្យគេអាចធ្វើដំណើរបានជាញឹកញាប់។
- **មនុស្សចង់ចាកចេញពីការងារដដែលៗ ដើម្បីផ្លាស់ប្តូរបរិយាកាស** និងទទួលអ្វីដែលថ្មីហើយប្លែកពីការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។
- **កំកាន់ជីវភាពរស់នៅ**របស់ពួកគេ អាចបង្កលក្ខណៈងាយស្រួលដល់ពួកគេក្នុងការធ្វើដំណើរទៅកាន់ទិសដៅផ្សេងៗ។
- **ចង់ស្វែងយល់អំពី**ប្រវត្តិសាស្ត្រ វប្បធម៌ វប្បធម៌ និងចំណេះដឹងថ្មីៗបន្ថែមទៀតក្នុងការរស់នៅ។

## ខ. ដំណាក់កាលរីកចម្រើននៃវិស័យទេសចរណ៍

ប្រវត្តិនៃការរីកចម្រើន និងការលូតលាស់នៃវិស័យទេសចរណ៍ ជាប់ទាក់ទងយ៉ាងជិតស្និទទៅនឹងការរីកចម្រើនមធ្យោបាយនានានៃវិស័យគមនាគមន៍ដូចមានខាងក្រោម ៖

- ដំណាក់កាលនៃការកកើតរថភ្លើង
- ដំណាក់កាលនៃការកកើតរថយន្ត
- ដំណាក់កាលនៃការធ្វើដំណើរកំសាន្តតាមនាវាធំៗ
- ដំណាក់កាលនៃការកកើតឡើងនៃយន្តហោះដឹកអ្នកដំណើរ
- ដំណាក់កាលនៃការកើតឡើងនៃសេវាកម្មសារអេឡិចត្រូនិច ដែលបានព័ត៌មានលឿនបំផុតដល់វិស័យគមនាគមន៍។
- ការកើនឡើងនូវមធ្យោបាយនានាលើវិស័យគមនាគមន៍បានធ្វើឱ្យការធ្វើដំណើរមានការផ្លាស់ប្តូរយ៉ាងខ្លាំងបំផុតទាំងសុវត្ថិភាព ផាសុកភាព និងកាត់បន្ថយនូវការចំណាយពេលវេលា ក៏ដូចជាការកាត់បន្ថយនូវការចំណាយលុយកាក់ច្រើនផងដែរ។ ជាមួយនឹងការកើតឡើងនូវមធ្យោបាយធ្វើដំណើរថ្មីៗ ទេសចរណ៍ និងបដិសណ្ឋារកិច្ចបានចាប់កំណើតលេចចេញជារូបរាងច្បាស់លាស់តាំងពីពេលនោះមក។
- នៅឆ្នាំ ១៨១៥ ជនជាតិអង់គ្លេសឈ្មោះ David Galinyany ជាអ្នករៀបចំ និងចាត់ចែងដំណើរទស្សនកិច្ចជាលើកដំបូង ដែលចេញដំណើរពីប្រទេសអង់គ្លេសទៅប្រទេសបារាំង។
- នៅឆ្នាំ ១៨២២ លោក Robert Sart បានប្រកាសខ្លួនឯងជាភ្នាក់ងារទេសចរណ៍ដំបូងបង្អស់នៅទីក្រុង Bristol ប្រទេសអង់គ្លេស។ គាត់ចាប់ទទួលអ្នកធ្វើដំណើរតាមសមុទ្រដោយកប៉ាល់ប្រើដោយចំហាយទឹកនៅកាន់តំបន់ផ្សេងៗនឹងទៅទីក្រុង Dublin ប្រទេសអៀរឡង់។
- នៅឆ្នាំ ១៨២៩ K.Baedeker ជាជនជាតិអាល្លឺម៉ង់បានបង្កើតជាលើកដំបូងនូវទស្សនាវដ្តីសម្រាប់ការធ្វើដំណើរដោយបានទទួលការនិយមចូលចិត្តយ៉ាងខ្លាំងពីអ្នកធ្វើដំណើរនៅអឺរ៉ុប។
- នៅឆ្នាំ១៨៣០ មានការសម្ពោធដាក់ឱ្យប្រើប្រាស់នូវខ្សែរថភ្លើង១ខ្សែជាលើកដំបូងនៅក្នុងពិភពលោក គឺនៅក្នុងចក្រភពអង់គ្លេស។ ខ្សែរថភ្លើងនេះ ធ្វើចរាចរណ៍ពីទីក្រុង Manchester ទៅកាន់ទីក្រុង Liverpool ដែលជាបុព្វហេតុដ៏ចម្បងធ្វើឱ្យមានការប្រែប្រួលយ៉ាងខ្លាំងនូវការធ្វើដំណើរ។

- នៅឆ្នាំ១៨៥០ សហរដ្ឋអាមេរិក បានសម្ពោធឱ្យប្រើប្រាស់រថភ្លើង១ខ្សែប្រើប្រាស់រថភ្លើង ១ខ្សែ ប្រវែង ១៥០០០គម។
- នៅឆ្នាំ១៨៥១ លោក Thomas Cook ជាជនជាតិអង់គ្លេសបានចាត់ចែងប្រមូលជនជាតិមកពីគ្រប់ខេត្តនៅទូទាំងប្រទេស ដើម្បីទៅចូលរួមពិធីតាំងពិពណ៌ ជាលក្ខណៈអន្តរជាតិនៅទីក្រុងប៉ារីស។ ព្រឹត្តិការណ៍នេះត្រូវបានគេទទួលស្គាល់លោក តូម៉ាស់គុក ថាជាអ្នកបង្កើតទេសចរណ៍ទំនើប និងមនុស្សទី១ ដែលយល់ដឹងពីខ្លឹមសារ និងផងប្រយោជន៍នៃការរៀបចំចាត់ចែងធ្វើ ទេសចរណ៍នៅអំឡុងទស្សវត្សរ៍ទី២០។ សព្វថ្ងៃនេះ ក្រុមហ៊ុន Thomas Cook បានធ្វើជាម្ចាស់លើក្រុមហ៊ុន Tour Agency ចំនួន១២០០០ ក្នុងស្ទើរគ្រប់ប្រទេសនៅលើពិភពលោកហើយបានបំរើភ្ញៀវទេសចរដល់ទៅ ២០លាននាក់ ជារៀងរាល់ឆ្នាំ។

វិស័យទេសចរណ៍បានចាប់កំណើតតាំងពីពេលនោះមក ហើយបានធ្វើឱ្យប្រជាជន ជាច្រើនទទួលស្គាល់នូវសារៈសំខាន់ ដែលជាហេតុធ្វើឱ្យពួកចង់ដឹង ចង់ឃើញ និងចង់ធ្វើ។ ក្នុងដំណាក់កាលជាមួយគ្នានេះដែរ វាបានលេចចេញឡើងនូវការតាំងទីលំនៅយ៉ាងច្រើនកុះករ នៅក្នុងទីក្រុងធំៗមានប្រជាជនរាប់លាននាក់រស់នៅ (ដែលជាបុព្វហេតុដំបូង ធ្វើឱ្យប្រជាជននៅតាមជនបទមានចំណូលចិត្តធ្វើដំណើរចូលទីក្រុង)។

ការរីកដុះដាល និងការរីកចំរើននៃវិស័យទេសចរណ៍ក្នុងសម័យថ្មី គឺអាស្រ័យដោយការរីកចម្រើនយ៉ាងខ្លាំងនៃសេវាកម្មទូរគមនាគមន៍ សេវាដឹកជញ្ជូនសេវាបំរើផ្នែកម្ហូបអាហារ ស្នាក់នៅ និងការរីកចម្រើននូវកំណើនជីវភាពរបស់ប្រជាជន។ ការរីកចម្រើនទាំងនេះ បានធ្វើឱ្យសេវាកម្មដឹកជញ្ជូនកាន់តែមានភាពសុក្រឹត្យ ប្រកបដោយសុវត្ថិភាព ល្បឿនកាន់តែលឿន ព្រមទាំងតំលៃថោកជាងមុន។

វិស័យទេសចរណ៍ត្រូវបានពិភពលោកទទួលស្គាល់ថា ជាឧស្សាហកម្មគ្មានផ្សែង ហើយអាចរកចំណូលបានយ៉ាងច្រើនដល់សង្គមជាតិ។ ការរីកចម្រើនវិស័យទេសចរណ៍បានបង្កើតការងារយ៉ាងច្រើនដល់ប្រជាពលរដ្ឋក្នុងសហគមន៍ តាមរយៈនៃការបំរើលើសេវាកម្មផ្សេងៗ និងការបង្កើនចង្វាក់ផលិតកម្មលើគ្រប់វិស័យ ដើម្បីផ្គត់ផ្គង់តម្រូវការភ្ញៀវទេសចរណ៍។

ទន្ទឹមនឹងគុណសម្បត្តិដ៏ប្រសើរនេះ ឧស្សាហកម្មទេសចរណ៍ ក៏ត្រូវបានចាត់ចូលក្នុងចំណោមនៃប្រភេទឧស្សាហកម្មផុយស្រួយ។ ការផ្គត់ផ្គង់ការហូបចុក នូវភ្ញៀវទេសចរយ៉ាងច្រើនដោយពុំមានការរៀបចំតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវអាចនឹងនាំមកនូវគុណវិបត្តិដល់ប្រជាជនក្នុងសហគមន៍ ដូចជាការឆ្លងនូវវប្បធម៌ ការបំពុលបរិស្ថានសហគមន៍ ក៏អាចធ្វើឱ្យបាត់បង់ផលប្រយោជន៍ប្រជាជនក្នុងសហគមន៍ផងដែរ ប្រសិនបើគេពុំបានប្រើប្រាស់ផលិតផល និងពលកម្មក្នុងស្រុកជាអាទិភាពនោះទេ។ ម្យ៉ាងទៀតក៏អាចមានទំនាស់ជាច្រើនរវាងប្រជាជនក្នុងសហគមន៍ និងភ្ញៀវទេសចរ ពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ តាមរយៈនៃការហូបអាហារនូវវប្បធម៌ពាលា ទំនៀមទំលាប់ប្រពៃណីបរទេសដែលប្រជាជនក្នុងស្រុកពុំអាចទទួលយកបាន។ ករណីខ្លះទៀត ភ្ញៀវទេសចរ បានចាត់ទុកខ្លួនគេជាមនុស្សប្រសើរ ប្រកាន់នូវភាពរើសអើងបានវាយតម្លៃទាប ចំពោះប្រជាជនក្នុងសហគមន៍។

### ១.៣. អ្នកណាជាទេសចរ?

នៅក្នុងវិស័យទេសចរណ៍ អ្នកដែលទទួលប្រើប្រាស់សេវាកម្មមានតែមួយគឺទេសចរ។ ទេសចរ ជាអ្នកទទួល និងប្រើប្រាស់ផលិតផលទេសចរណ៍ (កម្មវិធីដំណើរកម្សាន្ត ទស្សនកិច្ច សេវាកម្ម និងទំនិញ) ខុសគ្នាពីផ្សារទំនិញ និងផ្សារហិរញ្ញវត្ថុ ដែលផលិតផលត្រូវស្វែងរកអ្នកទិញ ឬអតិថិជន នៅលើទីផ្សារទេសចរណ៍ អ្នកប្រើប្រាស់ជាអ្នកស្វែងរក ផលិតផល និងសេវាកម្ម ដោយខ្លួនឯង។ ផលិតផលទេសចរណ៍ ត្រូវបានគេផ្តល់ ឬវាយតម្លៃ ក្នុងរយៈពេលប្រតិបត្តិ និងដំណើរការទទួលប្រើប្រាស់ប៉ុណ្ណោះ។

ការស្រាវជ្រាវ បានបង្ហាញថាការកំណត់និយមន័យទេសចរច្បាស់លាស់លុះត្រាតែពិនិត្យទៅលើជាតុផ្សំរបស់វា ៖

- **ទេសចរ ៖** ជាអ្នកប្រើប្រាស់ផលិតផលទេសចរណ៍ (សេវាកម្ម ទំនិញ និងការងារ)។ ទេសចរកើតមានឡើងដោយសារមានតម្រូវការលើការសំរាក លំហែ ធ្វើដំណើរ... បើគ្មានទេសចរ ក៏គ្មានទេសចរណ៍ដែរ
- **ទេសចរ ៖** ជាអ្នកដែលស្នាក់នៅយប់ក្រៅពីកន្លែងរស់នៅរបស់ខ្លួនតែមិនលើសពី៣៦៥ថ្ងៃ អ្នកដែលមកដល់ហើយស្នាក់នៅលើសពី៣៦៥ថ្ងៃជាបន្តបន្ទាប់គេមិនចាត់ចូលជាអ្នកទេសចរទេ។
- ទេសចរ ៖ ត្រូវបានគេកំណត់ទៅតាមគោលបំណងដំណើរ និងវ័យ។
    - ៣-១២ឆ្នាំ កូនក្មេង
    - ១៤-១៦ឆ្នាំ សិស្ស
    - ១៥-២៥ឆ្នាំ យុវវ័យ
    - ១៨-២៥ឆ្នាំ និស្សិត
    - ២៨-៤៤ឆ្នាំ មនុស្សពេញវ័យ
    - ៤៥-៦៤ឆ្នាំ មនុស្សវ័យជរា (មនុស្សចាស់ចូលនិវត្តន៍)

## ២. ភាពខុសគ្នានៃការធ្វើដំណើរ និងទេសចរណ៍

សកម្មភាពទេសចរណ៍ ខុសប្លែកពីសកម្មភាពការធ្វើដំណើរ ដោយសកម្មភាពនៃការធ្វើដំណើររបស់មហាជនតែក្នុងរយៈពេលខ្លីមួយ គឺមិនតិចជាង២៤ម៉ោង។ កត្តាទាំងនេះត្រូវបានបង្ហាញពីទស្សនវិស័យមួយចំនួនគឺ ៖

- ទេសចរណ៍ ចាំបាច់ស្ថិតក្នុងប្រភេទដំណើរដែលបានមកដល់ តែមានការស្នាក់នៅយប់
- ទេសចរណ៍ មិនចំណាយពេលវេលាយូរលើសពីមួយឆ្នាំនោះទេ
- ទេសចរណ៍ ជាចលនាបំលាស់ទីពីទីដៅមួយទៅកាន់ទីមួយផ្សេងទៀត
- ទេសចរណ៍ធ្វើឡើង នៅពេលទំនេរ ក្រៅពីការងារ និងមានមធ្យោបាយគ្រប់គ្រាន់ដើម្បីធ្វើដំណើរ
- ទេសចរណ៍ ជាសកម្មភាពដំណើរភ្ជាប់ជាមួយបំណងស្វែងយល់ ទស្សនា និងកំសាន្ត។

ការបង្ហាញខាងលើនាំឱ្យមានការអះអាងជាក់លាក់ថា អ្នកធ្វើដំណើរទាំងឡាយពុំមានត្រូវចាត់ បញ្ចូលថាជា **ទេសចរ** ទាំងអស់នោះឡើយ។ អ្នកដំណើរទាំងឡាយដែលពុំអាចចាត់ទុក ឬបញ្ចូលក្នុងស្ថិតិទេសចរ (ទេសចរជាតិ ឬទេសចរអន្តរជាតិ) មាន ៖

- អ្នកធ្វើដំណើរដើម្បីស្វែងរកទីលំនៅ និងធ្វើដំណើរស្វែងរកការងារ និងស្វែងរកប្រាក់ចំណូលប្រចាំខែ ដើម្បីបំពេញតម្រូវការក្នុងគ្រួសារ។
- បុគ្គលម្នាក់ៗធ្វើដំណើរទៅតំបន់ផ្សេងៗក្នុងប្រទេស ដើម្បីបំពេញការងារប្រចាំថ្ងៃឱ្យអង្គភាពរបស់ខ្លួន។
- បុគ្គលម្នាក់ៗធ្វើដំណើរពីតំបន់មួយ ទៅតំបន់មួយក្នុងគោលដៅ ធ្វើការសិក្សាស្រាវជ្រាវនូវអ្វីដែលថ្មី ប្លែក ដើម្បីយកមកធ្វើការបង្ហាញ
- ពលទាហាន និងគ្រួសាររបស់គេចេញបំរើកាតព្វកិច្ចតំបន់ណាមួយក្នុងប្រទេស
- អ្នកដំណើរឆ្លងកាត់ ( Transistor ) និងជនភៀសខ្លួន
- អ្នកដំណើរតាមនាវា រថយន្ត ឬ រថភ្លើង ដោយទទួលដំណោកក្នុងមធ្យោបាយដែលបានធ្វើដំណើរទាំងនោះ។
- អ្នកបើកបរទាំងឡាយដែលទទួលដំណោកក្នុងរថយន្តរបស់ខ្លួន និងក្នុងតំបន់មកដល់។

## ៣. ប្រភេទទេសចរណ៍

ទេសចរណ៍ត្រូវបានគេបែងចែកជាប្រភេទច្រើនផ្សេងៗគ្នាដូចជា ៖

- ប្រភេទគិតទៅតាមទ្រង់ទ្រាយ
- ប្រភេទគិតទៅតាមគោលបំណង
- ប្រភេទគិតទៅតាមមធ្យោបាយធ្វើដំណើរ
- និងប្រភេទគិតទៅតាមលទ្ធភាពចំណាយ

### ៣.១. ប្រភេទទេសចរណ៍គិតទៅតាមទ្រង់ទ្រាយ

យោងទៅតាមការបែងចែក និងការប្រើប្រាស់ទីតាំងភូមិសាស្ត្រ គេបែងចែកជាទ្រង់ទ្រាយ៤សំខាន់ៗ ៖

- ទេសចរណ៍ក្នុងប្រទេស (Domestic Tourism ) ជាប្រភេទទេសចរណ៍ដែលធ្វើដំណើរកំសាន្តទៅកន្លែងណាមួយ នៅក្នុងប្រទេសកំណើតរបស់ខ្លួន។
- ទេសចរណ៍អន្តរជាតិ (International Tourism) ជាការធ្វើដំណើររបស់ម្ចាស់ស្រុកទៅកំសាន្តនៅកន្លែងណាមួយ ដែលមិនមែនស្ថិតនៅក្នុងប្រទេសរបស់ខ្លួន។ ប្រភេទទេសចរណ៍នេះត្រូវគេចែកជា២គឺ ទេសចរណ៍បរទេស និងទេសចរណ៍ក្រៅប្រទេស។
- ទេសចរណ៍ជាតិ (National Tourism) ជាចង្កោមសកម្មភាពការងារ ដែលបំរើឱ្យវិស័យទេសចរណ៍ក្នុងស្រុក។
- ទេសចរណ៍សង្គម (Social Tourism) ជាទេសចរណ៍ដែលបង្កើតឡើងដោយរដ្ឋាភិបាល សហគមន៍ ស្ថាប័នផ្សេងៗ សម្រាប់បង្កជាលទ្ធភាពដល់ស្រទាប់មហាជន សិស្ស និស្សិត មន្ត្រីរាជការ អ្នកចូលនិវត្តន៍ យុវវ័យ ជនពិការ និងប្រជាពលរដ្ឋជាដើម។

### ៣.២. ប្រភេទទេសចរណ៍គិតទៅតាមគោលបំណង

ប្រភេទទេសចរណ៍គិតទៅតាមគោលបំណង និងតម្រូវការលើការធ្វើដំណើរ ត្រូវបានបែងចែកជា ៦ ប្រភេទផ្សេងៗគ្នា ៖

#### ក. ទេសចរណ៍ស្វែងយល់ ទស្សនា និងសកម្មភាពកំសាន្ត

ទេសចរណ៍ប្រភេទនេះមានទិដ្ឋភាពប្លែកៗទាក់ទងជាមួយវប្បធម៌ អរិយធម៌ និងធម្មជាតិដែលរួមមាន ៖

- កំសាន្តលំហែអារម្មណ៍ជាមួយនឹងភាពយន្ត មហោស្រព ការតាំងពិពណ៌។
- ការបរបាញ់សត្វ ការនេសាទ គូរគំនូរ ការសិក្សាស្រាវជ្រាវ វប្បធម៌ និងប្រវត្តិសាស្ត្រ ជនជាតិដើមភាគតិច ដើមកំណើត (វប្បធម៌ សាសនា ភាសា និងអរិយធម៌)។
- ងូតទឹក កំសាន្ត សម្រាកតាមតំបន់ឆ្នេរ លំហែកាយ ធ្វើការផ្លាស់ប្តូរបរិយាកាស
- បន្ធូរអារម្មណ៍ ស្វែងយល់ពីវប្បធម៌ ប្រវត្តិសាស្ត្រ ប្រពៃណី។
- ទស្សនាប្រាសាទបុរាណ ជីវិតរាត្រី និងសាកល្បងអាហារ។
- ការសិក្សាអំពីធម្មជាតិ សត្វព្រៃ បក្សាបក្សី តំបន់ការពារ ផ្សេងៗ។ល។

#### ខ. ទេសចរណ៍សុខភាព និងការព្យាបាល

ទេសចរណ៍ប្រភេទនេះ គឺតម្រូវទៅតាមអាកាសធាតុ តំបន់សមុទ្រ តំបន់កីឡា រមណីយដ្ឋាន ការព្យាបាលជំងឺ និងថែរក្សាសុខភាព ថ្នាំបុរាណ ដើម្បីពង្រឹងសុខភាព ស្តារកំលាំងកាយ-ចិត្ត និងបន្ធូរភាពតានឹងអារម្មណ៍។

#### គ. ទេសចរណ៍កីឡា

ជាបំណងទេសចរណ៍ ដែលកំណត់បានដោយសារការធ្វើដំណើរជាទេសចរណ៍ ដើម្បីហាត់កីឡា ដើម្បីចូលរួមប្រកួត និងទស្សនាការលេងកីឡា ការប្រកួតប្រជែងកីឡាដូចជា បាល់ទាត់ តេនីស បាល់បោះ ប្រដាល់ ឡើងភ្នំ ហែលទឹក។ល។

#### ឃ. ទេសចរណ៍អាជីវកម្ម

ជាប្រភេទទេសចរណ៍ ដែលធ្វើដំណើរក្នុងគោលបំណង កំណត់ បញ្ជាក់ និងបង្កើតទំនាក់ ទំនងសម្រាប់ការងារអាជីវកម្ម ជាមួយអ្នកមានលទ្ធភាពជាដៃគូ និងចូលរួមក្នុងពិធីធំៗដូចជា សិក្ខាសាលា ការប្រជុំតូចធំ សន្និបាត សន្និសីទ ពិធីតាំងពិព័រណ៍...។ល។ ទេសចរណ៍អាជីវកម្ម ធ្វើឡើងដោយការស្វែងយល់ និងសិក្សាអំពីលក្ខន្តិកៈ សម្រាប់ធ្វើការងារអាជីវកម្ម និងត្រៀមទិញទំនិញ សម្រាប់យកទៅធ្វើពាណិជ្ជកម្ម។ល។

#### ង. ទេសចរណ៍សួរសុខទុក្ខញាតិមិត្ត

ជាប្រភេទទេសចរណ៍ ដែលធ្វើដំណើរទៅសួរសុខទុក្ខបងប្អូនដែលបានបែកគ្នាក្នុងរយៈពេលយូរ និងមកជួបជុំជាមួយមនុស្សដែលជាទីស្រលាញ់ពេញចិត្តរបស់យើងឡើងវិញ ទិញវត្ថុអនុស្សាវរីយ៍ និងជំនួន។ល។

#### ច. ទេសចរណ៍ឆ្លងភេទ

ជាប្រភេទទេសចរណ៍ ដែលទេសចរភាគច្រើនបានចំណាយពេលវេលា ដោយឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយ ពីប្រទេសមួយទៅប្រទេសមួយ ក្នុងការគោលបំណងស្វែងរកការកំសាន្តកាយ និង ស្វែងរកសេចក្តីសុខ តាមរយៈការរួមភេទ។ ប៉ុន្តែ ទេសចរណ៍ប្រភេទនេះ មិនមានគ្រប់ទីកន្លែងនោះទេពីព្រោះប្រទេសមួយ

ចំនួនមិនអនុញ្ញាតឱ្យមានទេសចរណ៍ប្រភេទនោះឡើយ ដោយសារតែវាទាក់ទងទៅនឹងប្រពៃណីទំនៀមទំលាប់របស់ពួកគេ។

### ៣.៣. ប្រភេទទេសចរណ៍គិតទៅតាមមធ្យោបាយធ្វើដំណើរ

យោងតាមមធ្យោបាយធ្វើដំណើរ និងដំណើរទស្សនិច្ចត្រូវបានគេបែងចែកជា ២ គឺ ៖

- ទេសចរ ដែលប្រើប្រាស់មធ្យោបាយធ្វើដំណើរដោយខ្លួនឯង
- ទេសចរ ដែលប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់ការីទេសចរណ៍ ដែលការធ្វើដំណើរនេះដែរត្រូវបានគេបែងចែកទៅតាមមធ្យោបាយធ្វើដំណើរមួយចំនួនដូចជា ៖
  - ទេសចរណ៍ធ្វើដំណើរដោយប្រើប្រាស់មធ្យោបាយផ្លូវគោកគឺ ៖
    - ផ្លូវថ្នល់ ៖ មានដូចជា រថយន្ត ទោចក្រយាន្ត ថ្មើរជើង សត្វពាហនៈ...។
    - ផ្លូវដែក ៖ រថភ្លើង មេត្រូ អូតូរ៉ៃ...។
  - ទេសចរណ៍ធ្វើដំណើរដោយប្រើប្រាស់មធ្យោបាយផ្លូវអាកាស គឺការប្រើប្រាស់យន្តហោះគ្រប់ប្រភេទបាល់ឡុង...។
  - ទេសចរណ៍ធ្វើដំណើរដោយប្រើប្រាស់មធ្យោបាយផ្លូវទឹក គឺការប្រើប្រាស់នាវាគ្រប់ប្រភេទតាមផ្លូវទឹកសាប និងទឹកប្រៃ។

### ៣.៤. ប្រភេទទេសចរណ៍គិតទៅតាមលទ្ធភាពចំណាយ

ប្រភេទទេសចរណ៍គិតទៅលទ្ធភាពចំណាយ និងគោលការណ៍តម្លៃផលិតទេសចរណ៍ ទេសចរណ៍ប្រភេទនេះត្រូវបានបែងចែកដូចជា ៖

- ទេសចរណ៍ចំណាយខ្ពស់ដោយមានតម្រូវការទៅលើផលិតផល និងសេវាកម្ម ដែលមានគុណភាពខ្ពស់។
- ទេសចរណ៍ចំណាយមធ្យមដោយមានតម្រូវការទៅលើផលិតផល និងសេវាកម្មដែលមានគុណភាពមធ្យម។
- ទេសចរណ៍ធម្មតាដែលមិនសូវមានលទ្ធភាពចំណាយ មិនសូវមានតម្រូវការអ្វីធំដុំទៅលើផលិតផលទេសចរណ៍ និងសេវាកម្មទេសចរណ៍ឡើយ។

## ៤. ហេតុផលនៃការមានភូមិវិទ្យាទេសចរណ៍

### ៤.១. ហេតុអ្វីបានជាមនុស្សធ្វើដំណើរទេសចរណ៍?

គ្រប់ស្រទាប់មហាជន សម្រាប់សំណួរខាងលើនេះប្រាកដជាមានចំលើយផ្សេងៗ និងខុសៗគ្នាទៅតាមមជ្ឈដ្ឋានដែលគេរស់នៅឫសគល់នៃវប្បធម៌។ ការធ្វើដំណើររបស់ពួកអ្នកទេសចរមានមូលហេតុច្រើនបែបច្រើនយ៉ាងណាស់ ក្នុងចំណោមនោះមានហេតុផលសំខាន់ៗមួយចំនួនរួមមានដូចតទៅ ៖

▪ ផ្លាស់ប្តូរបរិយាកាស ៖ អ្នកទេសចរទាំងឡាយតែងតែចង់ផ្លាស់ប្តូរ នូវបរិយាកាសរស់នៅរបស់ពួកគេពីព្រោះនៅលើភពផែនដីរបស់យើងព្រះអាទិត្យមិនបានផ្តល់នូវថាមពលកំដៅអោយបានស្មើៗគ្នានោះទេ មានន័យថានៅគ្រប់ទីកន្លែងទាំងអស់នៅលើផែនដីមានសីតុណ្ហភាពមិនស្មើគ្នានោះឡើយ។ តំបន់ណាដែលស្ថិតនៅក្បែរតំបន់អេក្វាទ័រ ឬនៅចំតំបន់អេក្វទ័រ កន្លែងនោះបានទទួលកម្តៅគ្រប់គ្រាន់ ហើយមានសីតុណ្ហភាពក្តៅ

ស្រួល។ តំបន់ណា ដែលនៅឆ្ងាយពីតំបន់អេក្វាទ័រ តំបន់នោះមិនបានទទួលនូវកម្តៅគ្រប់គ្រាន់ ជាហេតុធ្វើឱ្យសីតុណ្ហភាពនៅតំបន់នោះត្រជាក់ ដូចនេះជាហេតុធ្វើឱ្យពួកគេតែងតែធ្វើដំណើរកម្សាន្តទៅកាន់តំបន់ ដែលមានសីតុណ្ហភាពខុសប្លែកពីតំបន់ដែលគេរស់នៅ។

ឧទាហរណ៍ ៖ ដូចជាប្រទេសស្វីស ប្រទេសបារាំង ប្រទេសហ្វាំងឡង់ និងប្រទេសកាណាដា ជាដើម ប្រជាពលរដ្ឋរបស់ពួកគេចូលចិត្តធ្វើដំណើរមកកាន់ប្រទេស ដែលមានសីតុណ្ហភាពក្តៅ ពីព្រោះគេយល់ថាធ្វើដូចនេះនឹងមានសុខភាពល្អណាស់។

▪ ការស្វែងយល់អំពីវប្បធម៌ផ្សេងៗ ៖ មនុស្សតែងតែមានការងឿងឆ្ងល់ ចង់ដឹង ចង់យល់អំពី វប្បធម៌ និងរមណីយដ្ឋានប្រវត្តសាស្ត្ររបស់ប្រទេសផ្សេងៗនៅលើពិភពលោក ដូចនេះ មនុស្សតែងតែធ្វើដំណើរទៅឆ្ងាយៗ ដើម្បីចង់ឃើញអំពីវប្បធម៌ និងទីកន្លែងរមណីយដ្ឋានប្រវត្តិសាស្ត្រទាំងនោះដោយផ្ទាល់តែម្តង។

▪ ការចូលរួមមើលកីឡា លេងកីឡា និងការផ្សងព្រេង ៖ មនុស្សច្រើនឡើងៗបានធ្វើដំណើរ ដើម្បីបានចូលរួមលេងកីឡា និងមើលកីឡាជាការលំហែកម្សាន្ត។ ឧទាហារណ៍ដូចជា ការលេងជិះស្គីលើទឹកកក ការជិះទូកលើសមុទ្រ ការស្ទូចត្រី និងការចូលរួមទស្សនាការប្រកួតកីឡាអូឡាំពិក កីឡាប្រចាំអាស៊ី កីឡាពានរង្វាន់ពិភពលោកជាដើម។ ម្យ៉ាងទៀត មានអ្នកខ្លះទៀតចូលចិត្តធ្វើដំណើរផ្សងព្រេងដូចជា ការឡើងភ្នំអេវើរេស ឡើងភ្នំអង់ ការធ្វើដំណើរកាត់មហាសមុទ្រទឹកកកអាកទិចជាដើម។

▪ទស្សនាទេសភាពធម្មជាតិ ៖ មនុស្សភាគច្រើនចូលចិត្តធ្វើដំណើរកំសាន្តទៅតាមតំបន់ ដែលមានទេសភាពធម្មជាតិនានាដូចជា ឧទ្យានជាតិ ព្រៃព្រឹក្សា ដែលជាជំរកសត្វព្រៃ ភ្នំ ទន្លេ ទឹកជ្រោះឆ្នេរសមុទ្រ ពីព្រោះតំបន់ទាំងនោះមានទេសភាពស្រស់ត្រកាល ជាពិសេសតំបន់នេះមានសត្វព្រៃដែលជាកន្លែងទាក់ទាញបំផុតសម្រាប់ពួកគេ។

▪ ស្វែងយល់ពីអ្វីដែលប្លែក ៖ អ្នកទេសចរទាំងឡាយតែងតែចង់មើល ចង់ឃើញនូវអ្វីៗ ដែលប្លែកទំនើបៗ ដូចនេះ ពួកគេតែងតែធ្វើដំណើរទៅតំបន់ទាំងនោះ ដើម្បីទស្សនា។ ឧទាហរណ៍ដូចជា អាគារភ្លោះ និងផ្សារទំនើបនៅប្រទេសម៉ាឡេស៊ីជាដើម...។

▪ ការស្វែងយល់ពីទំនាក់ទំនងមនុស្ស ៖ មនុស្សរស់នៅក្នុងសង្គមតែងតែមានទំនាក់ទំនង រវាងគ្នានឹងគ្នា។ ដូច្នេះមនុស្សតែងតែចំណាយពេលវេលាដើម្បីទៅសួរសុខទុក្ខគ្នាទៅវិញទៅមកដូចជា ទៅសួរសុខទុក្ខញាត្តិមិត្ត ឬបងប្អូនរបស់ពួកគេដែលរស់នៅទីឆ្ងាយៗ ។

▪ ការចូលរួមក្នុងពិធីសាសនាផ្សេងៗ ៖ មានអ្នកទេសចរជាច្រើនទៀតបានចំណាយពេលវេលារបស់ពួកគេ ដើម្បីទៅចូលរួមក្នុងពិធីបុណ្យតាមបែបសាសនាផ្សេងៗ។ គេមានកន្លែងមួយ ដែលគេហៅថា Pilgrims ក្នុងនោះ Mecca ទំនងជាពិធីបុណ្យសាសនាធំជាងគេ ដែលពួកមូស្លីមតែងតែប្រារព្ធម្តង ក្នុងមួយជីវិតរបស់ពួកគេ ជាពិសេសពិធីបុណ្យ Ramadan ដែលគេតែងតែប្រារព្ធធ្វើឡើងក្នុងមួយឆ្នាំម្តងនៅតាមបណ្តាប្រទេសមជ្ឈឹមបូព៌ា។ រីឯសាសនាផ្សេងៗទៀត ក៏មានជំរុំរបស់ពួកគេផ្ទាល់ដែរដូចជា គ្រីសបរិស័ទ្ធចូលចិត្តធ្វើដំណើរទៅកាន់ប្រទេសអ៊ីស្រាអែល ដែលជាទីកន្លែងប្រភពដើមនៃសាសនាគ្រិស្ទ រីឯព្រះពុទ្ធសាសនាក៏មានទីកន្លែងសំខាន់ៗ សម្រាប់ពួកគេដែរជាពិសេសប្រទេសឥណ្ឌា និងប្រទេសនេប៉ាល់ ដែលជាទីកន្លែងកំណើតរបស់សាសនាព្រះពុទ្ធ និងព្រហ្មញ្ញសាសនា ។

### ៤.២. ហេតុអ្វីបានជាមាន ភូមិវិទ្យា ទេសចរណ៍?

ដូចដែលយើងបានដឹងរួមមកហើយថា ទេសចរណ៍ គឺជាការផ្លាស់ប្តូរទីកន្លែងមួយទៅកាន់កន្លែងមួយផ្សេងទៀត ដើម្បីធ្វើដំណើរកំសាន្ត ចូលរួមសិក្ខាសាលា ការធ្វើជំនួញ កីឡាជាដើម។ រហូតមកទល់ពេលនេះ ទេសចរណ៍ ជាផ្នែកមួយយ៉ាងសំខាន់ដូចជាផ្នែកផ្សេងៗទៀតដែរ ក្នុងវិស័យសេដ្ឋកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម គមនាគមន៍ ហើយជានិច្ចកាលជាប់ពាក់ព័ន្ធជាមួយការសម្រាកលំហែកាយ មើលទេសភាពព្រៃព្រឹក្សា សមុទ្រ ភ្នំ ព្រៃឈើ សត្វព្រៃ ភូមិស្រុក វប្បធម៌ ប្រពៃណី ជនជាតិភាគតិច និងជាប់ពាក់ព័ន្ធជាមួយនឹងការស្នាក់នៅ ដែលសកម្មភាពទាំងនេះបានក្លាយជាបាតុភូតសាកលនៅលើពិភពលោក។

ចាប់ពីសតវត្សរ៍ទី២០មក មនុស្សបានធ្វើដំណើរទេសចរណ៍ទាំងក្រុមៗ ដោយសារមានការរីកចម្រើនផ្នែកផ្សព្វផ្សាយពាណិជ្ជកម្ម អំពីទីកន្លែងនានា តាមរយៈវិទ្យុ ទូរទស្សន៍ វីដេអូ ទស្សនាវដ្តី កាសែត ប៉ាណូផ្សាយពាណិជ្ជកម្ម ការតាំងពីពណ៌ ផែនទី តាមប្រព័ន្ធអ៊ីនធឺណែត និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ...។

ក្រោយពីសង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់ ទេសចរបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើទេសភាពធម្មជាតិ ដូចជានៅអាព្រិចមានទេសភាព និងសត្វព្រៃចំឡែកៗ និងនៅតាមឆ្នេរសមុទ្រ មេឌីទែរ៉ានេ តំបន់ដែលទេសចរយកចិត្តទុកដាក់ជាងគេ គឺទេសភាពព្រៃភ្នំ សមុទ្រ ទេសភាពតំបន់ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម។ ដោយសារតែផ្នែកទេសចរណ៍មានជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងទេសភាពធម្មជាតិ និងទិដ្ឋភាពសង្គម ទើបបានជាវិស័យទេសចរណ៍ជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងភូមិវិទ្យា ដែលជាមុខវិជ្ជាមួយសិក្សាអំពីទេសភាពផែនដី ទិដ្ឋភាពរបស់សង្គម និង បាតុភូតផ្សេងៗទៀតដែលកើតមាននៅលើផែនដី។

## ៥. កត្តាដែលមានឥទ្ធិពលដល់ការអភិវឌ្ឍវិស័យទេសចរណ៍

កត្តាដែលមានឥទ្ធិពលលើការអភិវឌ្ឍវិស័យទេសចរណ៍ គឺមានកត្តាជាច្រើនដែលជះឥទ្ធិពលទៅលើការរីកដុះដាល និងការអភិវឌ្ឍវិស័យទេសចរណ៍ ដែលរួមមាន ៖

- បច្ចេកវិទ្យា (មធ្យោបាយទំនាក់ទំនង និងការប្រាស្រ័យទាក់ទង...។ល។
- ច្បាប់ (ការកំណត់ និងផ្តល់សិទ្ធសេរីភាព)
- សេដ្ឋកិច្ច និងសង្គមកិច្ច (មហាជន ប្រាក់ចំណូល មុខជំនាញ)
- សម្បត្តិធម្មជាតិ (តំបន់ទេសភាពព្រៃព្រឹក្សា សត្វព្រៃ អាកាសធាតុល្អ ភ្នំ)
- ធនធានវប្បធម៌ និងប្រវត្តិសាស្ត្រ (ប្រាង្គប្រាសាទ សំណង់បុរាណ វត្តអារាម...)
- ប្រជាសាស្ត្រ (កំណើនពលរដ្ឋ សមាជិកគ្រួសារ)
- ធនធានមនុស្ស (សក្តានុពលភាព កំកាន់វប្បធម៌និងការបណ្តុះបណ្តាល ការសិក្សា)
- ទីផ្សារទេសចរណ៍ ការរីកដុះដាលនៃតម្រូវការ សំណើរទិញ-លក់ និងការផ្គត់ផ្គង់
- ហិរញ្ញវត្ថុ (លទ្ធភាពវិនិយោគទុន)
- វប្បធម៌សង្គម (បរិយាកាសសង្គម និងអាកប្បកិរិយាសង្គម)
- បរិស្ថានធម្មជាតិ (ស្ថានភាពបរិស្ថាន ការបំពុល ឬការខូចខាត...)
- នយោបាយ (ការរៀបចំនយោបាយទេសចរណ៍ និងនយោបាយគ្រប់គ្រងទេសចរណ៍)

ទន្ទឹមគ្នានេះដែរ មានកត្តាជាច្រើនដែលបង្អាក់ដល់ការរីកដុះដាលនៃវិស័យទេសចរណ៍ ដែលរួមមាន វិបត្តិសេដ្ឋកិច្ច វិបត្តិនយោបាយ សង្គ្រាមស៊ីវិល ជម្លោះសាសនា កំណើនតម្លៃលើវត្ថុប្រើប្រាស់ ភាពគ្មានការងារធ្វើរបស់ប្រជាពលរដ្ឋ អសន្តិសុខក្នុងសង្គម អតិផរណានៃទឹកប្រាក់ បញ្ហាបរិស្ថាន ការដែលទីភ្នាក់ងារទេសចរណ៍មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ការបណ្ដឹង និងការរឹតបន្តឹងលើទិដ្ឋាការ គយ អន្តោប្រវេសន៍ ។ល។

កត្តាទាំងអស់ខាងលើ បានជះឥទ្ធិពលមិនល្អដល់ដំណើរការអភិវឌ្ឍវិស័យទេសចរណ៍ ព្រមទាំងធ្វើឱ្យសេដ្ឋកិច្ចជាតិមានដំណើរការមិនល្អដោយសារទេសចរណ៍ធ្លាក់ចុះ និងដុនដាប រីឯតម្លៃសេវាកម្ម និងផលិតផលទេសចរណ៍មានកម្រិតខ្ពស់ សេវាកម្មសណ្ឋាគារធ្លាក់ចុះ បរិមាណភ្ញៀវទេសចរធ្លាក់ចុះ មានបញ្ហាក្នុងសង្គម និងមនុស្សជាតិ ដោយសារភាពអាប់អួរ គ្មានប្រាក់ចំណូល កាត់បន្ថយការចាយវាយ ។

## ៦. លក្ខណៈពិសេសនៃវិស័យទេសចរណ៍

ទេសចរណ៍ជាវិស័យសេវាកម្មដែលមានលក្ខណៈកាន់តែប្លែកពីផលិតផលនៃទំនិញ និងសម្ភារៈដទៃទៀត។ លក្ខណៈពិសេសរបស់វិស័យសេវាកម្មទេសចរណ៍រួមមាន ៖

- មិនបានឃើញ ឬសាកល្បងមុន និងត្រូវបានគេប្រើប្រាស់នៅកន្លែងដែលផលិត
- ទេសចរណ៍ និងប្រជាពលរដ្ឋក្នុងតំបន់មានទំនាក់ទំនងស្អិតរមួតនឹងគ្នា
- មិនអាចផ្លាស់ប្ដូរទីតាំងផលិតបាន និងមិនអាចត្រូវរក្សាសម្រាប់ថ្ងៃក្រោយ ។

ដោយសារទេសចរណ៍មានលក្ខណៈពិសេសបែបនេះហើយ ទើបអ្នកដែលគ្រប់គ្រង និងអ្នកដែលប្រតិបត្តការងារនេះត្រូវតែយកចិត្តទុកដាក់ដូចជា ៖

- គ្រប់គ្រងលើគុណភាពផលិតផល និងសេវាកម្ម។
- រៀបចំផលិតផលទេសចរណ៍ តាមរយៈការទាក់ទាញអារម្មណ៍ និងទឹកចិត្តរបស់ភ្ញៀវទេសចរ (ធនធានធម្មជាតិ បេតិកភណ្ឌ អាកាសធាតុ ព្រៃព្រឹក្សា ឆ្នេរសមុទ្រ...)។
- បង្កភាពងាយស្រួលសម្រាប់ការស្នាក់នៅ ទទួលទានអាហារ ទស្សនាកំសាន្ត សេវាដឹកជញ្ជូន។
- ផលិតផលទេសចរណ៍អាចនឹងបាត់បង់ដោយសារការមិនយកមកប្រើប្រាស់ បាត់បង់ចំណូល និងខាតបង់ទាំងស្រុង។
- ការផ្ដុកចំនួនភ្ញៀវទេសចរលើសចំណុះក្នុងទីកន្លែងកម្សាន្តសប្បាយ ទីតាំងប្រវត្តិសាស្ត្រ ប្រាសាទបុរាណ អាចនឹងធ្វើឱ្យខូចខាតបរិស្ថាន កាត់បន្ថយបរិយាកាសរីករាយ ដោយសារភាពអ៊ូអរលើសកម្រិត។
- ការពង្រីកទីតាំងទេសចរណ៍ត្រូវពិចារណាលើបញ្ហាដីធ្លី ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ ដើម្បីចៀសវាងការប្រណាំងប្រជែង និងជម្លោ។
- ទេសចរណ៍អាចនឹងមានការខាតបង់ដែលបណ្ដាលមកពីតម្រូវការមានការប្រែប្រួលទៅតាមរដូវ។

## ៧. ផលិតផលទេសចរណ៍

### ៧.១. ផលិតផលទេសចរណ៍ជាអ្វី?

ជាតុផ្សំសំខាន់ៗ នៃផលិតផលទេសចរណ៍មានដូចជា ផលិតផលរូបិយ ផលិតផលអរូបិយ ខ្សែទស្សនកិច្ច សេវាកម្មទេសចរណ៍ និងទំនិញទេសចរណ៍ ។

- **ផលិតផលរូបិយ** គឺធនធានដែលមានស្រាប់ និងមិនអាចបង្កើតបាន (ធម្មជាតិ វប្បធម៌ ឬ ប្រវត្តិសាស្ត្រ) ហេដ្ឋារចនាសម្ព័ន្ធ មូលដ្ឋានសេវាកម្មទេសចរណ៍ ធនធានកែច្នៃ និងបង្កើតឡើង។
- **ផលិតផលអរូបិយ** គឺបរិយាកាសតំបន់ អាកប្បកិរិយាម្ចាស់ស្រុក ការជឿជាក់មកលើតំបន់ទេសចរណ៍។
- **ខ្សែទស្សនកិច្ច** គឺកញ្ចប់សេវាកម្មដែលផ្សំដោយសេវាកម្មដឹកជញ្ជូន និងការស្នាក់នៅ សេវាកម្មអាហារ និងទស្សនកិច្ច សេវាកម្មបកប្រែ និងមគ្គុទេសក៏។ល។
- **សេវាកម្មទេសចរណ៍** គឺសេវាកម្មដឹកជញ្ជូន និងការស្នាក់នៅ សេវាកម្មអាហារ និងទស្សនកិច្ច សេវាកម្មបកប្រែ មគ្គុទេសក៍ និងសេវាកម្មដទៃទៀត។
- **ទំនិញទេសចរណ៍** គឺជាវត្ថុអនុស្សាវរីយ៍ គ្រឿងចម្លាក់ (មាស ប្រាក់ ស្ពាន់ ឈើ ថ្ម...) វេជនវត្ថុ (សូត្រ ហូល ផាមួង...) កេតនវត្ថុ (គ្រឿងអលង្ការ ត្បូង មាស...) និងសម្ភារៈ សម្រាប់ធ្វើទេសចរណ៍។

### ក.ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ ដោយរាប់បញ្ចូលនូវបណ្ដាញផ្លូវថ្នល់ អាកាសយានដ្ឋាន ការផ្គត់ផ្គង់ទឹក អគ្គិសនី អនាម័យបរិស្ថាន ប្រព័ន្ធបង្ហូរទឹក និងលូ...។ល។

អធិរចនាសម្ព័ន្ធគិតបញ្ចូលនូវសណ្ឋាគារ ទីកន្លែងស្នាក់នៅ ភោជនីយដ្ឋាន និងបណ្ដាសេវាកម្មទេសចរណ៍ទាំងឡាយ។ ទីតាំងដែលមានកន្លែងឬ មណ្ឌលកម្សាន្ត ទាំងផ្នែកធម្មជាតិ និងវប្បធម៌មានអាកាសធាតុល្អប្រពៃ ចាំបាច់ត្រូវមានតម្រូវការបន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធ និងអធិរចនាសម្ព័ន្ធ។

### ខ.ធនធានដែលគេបង្កើត និងកែច្នៃ

ធនធានដែលគេបង្កើត និងកែច្នៃរួមមានឧទ្យាន តំបន់ទេសភាព ជម្រកសត្វព្រៃ រមណីយដ្ឋានទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធបដិសណ្ឋារកិច្ច។ សម្រាប់មណ្ឌលទេសចរណ៍ គេបែងចែកដូចជា ៖




### គ.បរិយាកាសក្នុងតំបន់

បរិយាកាសក្នុងតំបន់ ជាការពិចារណាពីតំបន់ដែលត្រូវជ្រើសរើស សម្រាប់ជុំរុញសកម្មភាពទេសចរណ៍ដោយផ្អែកលើលក្ខណៈសម្បត្តិ ផ្នែកភូមិសាស្ត្រដូចជាអាកាសធាតុ បណ្ដាជួរឆ្នេរសមុទ្រ សភាពខ្ពស់ទាបនៃទឹកដី...។ ដូចនៅប្រទេសនានាដែរ ភាពក្រីក្រគឺជាបញ្ហាចោទដល់ការអភិវឌ្ឍ វិស័យទេសចរ

ណ៍។ ភាពក្រីក្រមានលក្ខណៈច្រើនសណ្ឋានដូចជា ប្រាក់ចំណូលទាប សុខភាពអន់ខ្សោយ ខ្វះខាតការសិក្សាអប់រំ ស្ថានភាពអាហាររូបត្ថម្ភ លក្ខខណ្ឌរស់នៅពុំមានអនាម័យ ទ្រព្យសម្បត្តិតិចតួច លទ្ធភាពស្វែងរកការងារធ្វើមានកម្រិត។ កត្តាទាំងនេះនឹងនៅមានកត្តាផ្សេងៗទៀតដែលធ្វើឱ្យបរិយាកាសក្នុងតំបន់មិនប្រក្រតី។

**ឃ.កិច្ចស្វាគមន៍ និង សកម្មភាពបុគ្គលិក**

ការទទួលស្វាគមន៍ភ្ញៀវ គឺជាការចាប់ផ្ដើមរវាងប្រជាជនដែលជាម្ចាស់ស្រុក និងភ្ញៀវទេសចរ ក្នុងការទំនាក់ទំនងគ្នា។ សណ្ឋាគារ និងភោជនីយដ្ឋាន ដែលមានដំណើរការល្អ វាអាស្រ័យទៅលើ សកម្មភាពរបស់បុគ្គលិកផងដែរ ដោយចេះនិយាយរាក់ទាក់ និងអូសទាញឱ្យទេសចរទិញផលិតផលរបស់ក្រុមហ៊ុន និងមានស្មារតីរឹងប៉ឹង ក្នុងពេលបំពេញការងារ។

ការសម្ដែងចេញនូវការស្វាគមន៍ រួសរាយរាក់ទាក់ដល់ភ្ញៀវទេសចរ យើងនឹងទទួលបានមកវិញនូវផលចំណេញយូរអង្វែង តាមរយៈភ្ញៀវទេសចរដែលចូលមកទស្សនាកំសាន្ត មកក្នុងលក្ខណៈការទូត និងកិច្ចប្រជុំផ្សេងៗ។

**ង.សន្តិសុខ និងសុវត្ថិភាពក្នុងតំបន់ទេសចរណ៍**

សន្តិសុខ និងសុវត្ថិភាពជាបញ្ហាមួយដែលត្រូវបានពង្រឹងនៅមានបញ្ហាជាច្រើនអាចកើតជារឿយៗដូចនេះ យើងត្រូវមានវិធានការណ៍មួយចំនួន ដើម្បីទប់ស្កាត់នូវរាល់អំពើអសន្តិសុខ ទាំងឡាយ ដើម្បីសុវត្ថិភាពដល់ភ្ញៀវទេសចរ ។

**ច.អនាម័យ និងបរិស្ថានក្នុងតំបន់ទេសចរណ៍**

អនាម័យ និងបរិស្ថាន ក៏ជាកត្តាចាំបាច់ផងដែរ សម្រាប់តំបន់ទេសចរណ៍ និងនៅតាមតំបន់រមណីយដ្ឋាននានា។ បញ្ហាធំ គឺនៅតាមទីក្រុង ទីប្រជុំជន ការខ្វះអនាម័យ ការចោលសំរាម ពាសវាលពាសកាល និងការចាក់សំរាមតាមដងផ្លូវដោយពុំមានការគ្រប់គ្រងបានល្អ ធ្វើឱ្យមានផលប៉ះពាល់ដល់សុខភាព ខូចគុណភាពទឹក ប៉ះពាល់ដល់បរិស្ថានធម្មជាតិ និងជាពិសេស ប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃ។

**ឆ.ភាពជឿជាក់មកលើតំបន់ទេសចរណ៍**

តំបន់ទេសចរណ៍ ជាទីកន្លែងដែលប្រមូលផ្ដុំដោយសកម្មភាពជាច្រើន ហើយលើសពីនេះទៅទៀតជាតំបន់ដែលទទួលការចាប់អារម្មណ៍ពីសំណាក់ភ្ញៀវជាតិ និងអន្តរជាតិ ដែលធ្វើដំណើរមកដើម្បីសម្រាកលំហែសិក្សាស្រាវជ្រាវ។ល។ ការឈានជើងចូលដល់តំបន់ទេសចរណ៍ ទេសចរតែងមានអារម្មណ៍កក់ក្ដៅ និងជឿជាក់អំពីគុណភាព សេវាកម្ម ផលិតផលទេសចរណ៍ តម្លៃសន្តិសុខ គេត្រូវតែទទួលបាននូវភាពរីករាយ និងការរំពឹងថា តើការចំណាយស្របទៅ នឹងអ្វីដែលគេទទួលបាននោះដែរឬយ៉ាងណា? កាលណាការទទួលស្វាគមន៍ ហេដ្ឋារចនាសម្ព័ន្ធ មានការរៀបចំបានល្អ សេវាកម្មគ្រប់គ្រាន់ បរិយាកាសសង្គមល្អ និងសកម្មភាពបុគ្គលិកល្អ និងធានានូវសុវត្ថិភាព ការចាប់អារម្មណ៍ និងការជឿទុកចិត្តរបស់ភ្ញៀវមានកម្រិតខ្ពស់ ចំនួនទេសចរនឹងមានការកើនឡើងជាលំដាប់។

**៧.២.ទីផ្សារការធ្វើដំណើរ និងទេសចរណ៍**

ទីផ្សារការធ្វើដំណើរ និងទេសចរណ៍ ជាទីកន្លែងដែលមានការដោះដូរ ទិញ-លក់នូវផលិតផលទេសចរណ៍ ហើយការដោះដូរផលិតផលទេសចរណ៍ត្រូវបានគេធ្វើឡើងនៅកន្លែងផ្សេងៗគ្នា នៅ សណ្ឋាគារ

ឬផ្ទះសំណាក់របស់ភ្នាក់ងារទេសចរណ៍ ការដោះដូរដោយគ្មានការចូលរួមដោយផ្ទាល់ពីសំណាក់អ្នកលក់ និងអ្នកទិញ។ ឧទាហរណ៍ ៖ ទិញសំបុត្រយន្តហោះ តាមរយៈអ៊ីម៉ែល អ៊ិនធឺណេត ឬ តាមរយៈទូរស័ព្ទ។ល។ ជាការពិត យើងដឹងរាល់គ្នាថា ផលិតផលត្រូវបានគេបង្កើតឡើង ដើម្បីលក់ ហើយកន្លែងដែលផលិតផលទាំងនោះត្រូវបានលក់គឺទីផ្សារ។ ទីផ្សារត្រូវបានគេកំណត់ន័យឱ្យដូចខាងក្រោម ៖

- ទីផ្សារ ៖ ជាទីកន្លែងដែលស្តែងចេញនូវការប្រព្រឹត្តិឡើង ដើម្បីលក់នូវផលិតផល។
- ទីផ្សារ ៖ ជាកន្លែងធ្វើអាជីវកម្មដែលឆ្លុះបញ្ចាំងឱ្យអាជីវករ ឬក្រុមហ៊ុនយល់ដឹងឱ្យពិតប្រាកដអំពីតម្រូវការសង្គម ដើម្បីត្រៀមរៀបចំលក្ខណៈផ្គត់ផ្គង់។
- ទីផ្សារ ៖ ជាក្រុមអតិថិជនដែលមានកម្លាំងទិញ និងមានតម្រូវការមិនទាន់បំពេញ យើងត្រូវមានការយកចិត្តទុកដាក់លើកត្តា ៣ ទៀត គឺអតិថិជនជាបុគ្គល ឬក្រុមហ៊ុន អតិថិជន ត្រូវមានកម្លាំងទិញ (តម្រូវការផ្សារភ្ជាប់នឹងថវិការ) អតិថិជនដែលតម្រូវការមិនទាន់បានបំពេញ (តម្រូវការជំរុញឱ្យគេទិញផលិតផល) ។

ទេសចរណ៍ជាផ្នែកមួយនៃទីផ្សារសេវាកម្ម និងទំនិញ ដែលគេកំណត់វាទៅតាមតម្រូវការ និងការផ្គត់ផ្គង់ផលិតផលសេវាកម្មទេសចរណ៍។ តម្រូវការទេសចរណ៍ជាទីផ្សារទេសចរណ៍នៅក្នុង និងក្រៅប្រទេស ការស្នើរផ្គត់ផ្គង់ទេសចរណ៍មានជាសេវាកម្មដែលបម្រើឱ្យទេសចរណ៍(ការដឹកជញ្ជូនធនធាន ដែលទាក់ទាញទេសចរណ៍ សេវាកម្ម និងទីតាំងកម្សាន្ត ព្យាបាល ទីតាំងសម្រាប់ទស្សនា សេវាកម្ម ស្នាក់នៅ អាហារ និងភេសជ្ជៈ។ល។

## ៨. តម្រូវការលើការធ្វើដំណើរ និងទេសចរណ៍

ជាទូទៅបុគ្គលទាំងឡាយមុននឹងចាកចេញពីលំនៅស្ថានរបស់ពួកគេ ទៅកាន់តំបន់ណាមួយជាលក្ខណៈទេសចរណ៍ ដើម្បីសម្រាកកម្សាន្ត និងបំពេញគោលបំណងណាមួយផ្សេង ទៀតលុះត្រាតែគេ ដឹងជាមុនថានៅក្នុងរយៈពេលដែលគេធ្វើដំណើរនេះ គេនឹងទទួលបាននូវផលប្រយោជន៍អ្វី ដែលគេបានគ្រោងទុកជាមុន ។

ដើម្បីឱ្យការធ្វើដំណើរប្រព្រឹត្តិទៅបានជោគជ័យដូចការចង់បាន តំបន់គោលដៅទេសចរណ៍ចាំបាច់ត្រូវមានភាពទាក់ទាញនៃបណ្តាសេវាកម្មដែលក្រុមហ៊ុនទេសចរណ៍ និងការរៀបចំល្អ ដែលអាចបំពេញតម្រូវការរបស់អ្នកទេសចរបាន។ ការយល់ដឹងបានច្បាស់លាស់ពីតម្រូវការលើការធ្វើដំណើរ និង ទេសចរណ៍ជាកត្តាកំណត់មួយ សម្រាប់ការឈានចូលដល់ការទទួលជោគជ័យ នៅក្នុងការប្រតិបត្តិខ្សែទស្សនកិច្ច និងការធ្វើដំណើរ។

### ៨.១. តម្រូវការមុនពេលធ្វើដំណើរ

ជាទូទៅ មុនពេលធ្វើដំណើរមនុស្សតែងតែមានតម្រូវការជាចាំបាច់ទៅលើព័ត៌មាន ការទិញ ការកក់ ជាមុននូវមធ្យោបាយធ្វើដំណើរ និងការស្នាក់នៅព្រមទាំងការរៀបចំខ្លួនផងដែរ សម្រាប់ការត្រៀមចេញដំណើរ។

- តម្រូវការទៅលើព័ត៌មាន ៖ ទាក់ទងទៅនឹងទីតាំងភូមិសាស្ត្រ ស្ថានភាពនយោបាយ បរិស្ថាន សង្គម និងការផ្តល់ទិដ្ឋាការ ។
- តម្រូវទៅលើការកក់ឬទិញ ៖ ការកក់ ទិញសេវាស្នាក់នៅ អាហារ និងភេសជ្ជៈ កក់សំបុត្រមធ្យោបាយធ្វើដំណើរ ការកក់ ទិញខ្សែទស្សនកិច្ច។

- តម្រូវការរៀបចំខ្លួនធ្វើដំណើរ ៖ ពេលវេលា ថវិកា លិខិតឆ្លងដែន ទិដ្ឋាការ ...។

### ៨.២. តម្រូវការកំឡុងពេលធ្វើដំណើរ

តម្រូវការក្នុងរយៈពេលធ្វើដំណើរ សំដៅទៅលើសេចក្តីត្រូវការចាំបាច់ ដោយខានមិនបាននូវសេវាកម្មដឹកជញ្ជូន និងតម្រូវការលើសេវាកម្មផ្សេងៗទៀត នៅក្នុងមធ្យោបាយដឹកជញ្ជូន ដែលសម្រួលដល់ការធ្វើដំណើរ ដើម្បីបំពេញតម្រូវការលើសេវាក្នុងការដឹកជញ្ជូនទេសចរក្នុងការធ្វើដំណើរទៅកាន់តំបន់គោលដៅទេសចរណ៍ ផលិតផលវិស័យគមនាគមន៍ និងដឹកជញ្ជូនត្រូវបានបង្កើតឡើង ដោយបែងចែកជា ៤ ប្រភេទផ្សេងៗគ្នា ៖

- តម្រូវការដឹកជញ្ជូនក្នុងរយៈចំងាយឆ្ងាយ ៖ សំដៅលើការដឹកជញ្ជូនទេសចរ ពីប្រទេសដែលគេរស់នៅមកប្រទេសគោលដៅ ដោយប្រើប្រាស់រាល់មធ្យបាយដែលអំណោយ ផលទៅតាមតម្រូវការ និងលទ្ធភាពរបស់ពួកគេ។
- តម្រូវការដឹកជញ្ជូននៅពេលមកដល់តំបន់គោលដៅ ៖ ការដឹកជញ្ជូនពីចំណតរថយន្ត យន្តហោះ ស្ថានីយរថភ្លើង និងកំពង់ផែឆ្ពោះទៅកាន់សណ្ឋាគារ និងត្រលប់ទៅវិញនៅពេលបញ្ចប់សកម្មភាពទេសចរណ៍។
- តម្រូវការដឹកជញ្ជូននៅក្នុងតំបន់ទេសចរណ៍ ៖ ជាតម្រូវការដឹកជញ្ជូនទេសចរពីតំបន់មួយទៅកាន់តំបន់មួយទៀតក្នុងតំបន់ ដែលស្ថិតនៅក្នុងគោលដៅទេសចរណ៍ ដើម្បីបំពេញបំណងលើការធ្វើដំណើរកម្សាន្ត។
- តម្រូវការដឹកជញ្ជូនក្នុងខ្សែទស្សនកិច្ច ៖ ការដឹកជញ្ជូនទេសចរណ៍ត្រូវធ្វើឡើងនៅក្នុងរង្វង់ នៃការទស្សនាកម្សាន្តក្នុងតំបន់ទេសចរណ៍ ដែលមានកំណត់នៅក្នុងកម្មវិធីទេសចរណ៍។

### ៨.៣. តម្រូវការលើការស្នាក់នៅ និងអាហារ

- តម្រូវលើការស្នាក់នៅ ៖ ទេសចរមិនត្រូវបានផ្តាច់ចេញពីការស្នាក់នៅឡើយ ព្រោះគេត្រូវស្ថិតនៅក្នុងតំបន់ទេសចរណ៍យ៉ាងតិច ២៤ ម៉ោង។
- តម្រូវការលើអាហារ ៖ តម្រូវការទេសចរលើផ្នែកអាហារ អាចគិតទៅតាមរសជាតិ អនាម័យ ក៏ដូចជាភោជនីយដ្ឋាន ដោយផ្អែកទៅលើលក្ខណៈ នៃការបម្រើសេវាកម្មរបស់បុគ្គលិក ការផ្តល់សេវារហ័ស គុណភាពល្អ នៃការផ្តល់សេវាឆាប់រហ័ស រួមជាមួយនឹងតម្លៃមួយដ៏សមរម្យអាចទទួលយកបាន។

### ៨.៤. តម្រូវការក្នុងតំបន់ទេសចរណ៍

- តម្រូវការលើសកម្មភាពក្នុងតំបន់ទេសចរណ៍ ៖ ទេសចរដែលមកដល់ទោះជាក្នុងគោលបំណងបែបណាក៏ដោយ ក៏មានសកម្មភាពប្រហាក់ប្រហែលគ្នា ដើម្បីការស្នាក់នៅរបស់ពួកគេទទួលបាននូវបទពិសោធន៍ និងការទទួលបាននូវភាពសប្បាយរីករាយ និងបន្សល់ទុកនូវអារម្មណ៍ល្អ។ តម្រូវការលើផ្នែកសកម្មភាពទាក់ទងជាមួយនឹងការបង្កើនការយល់ដឹងលើផ្នែកស្មាតី វប្បធម៌ និងការកម្សាន្តសប្បាយ។ សកម្មភាពទាំងអស់នោះ អាចមានកន្លែងកម្សាន្តនានា ដែលបង្កនូវភាពទាក់ទាញ (ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ព្រៃលិចទឹក តំបន់ឧទ្យានជាតិ សារមន្ទីរ តន្ត្រី ពិធីបុណ្យប្រពៃណី។

- តម្រូវការចាំបាច់ដទៃ៖ តម្រូវការទាំងនោះមានដូចជា សេវាសុខាភិបាល និងថែទាំ ទូរគមនាគមន៍ និងប្រៃសនីយ៍ ទឹកស្អាត អគ្គិសនី ការគ្រប់គ្រងបរិស្ថាន សន្តិសុខ សុវត្ថិភាពក្នុងការស្នាក់នៅ និងតម្រូវការធានាគារ និងកន្លែងប្តូរប្រាក់។

## ៨.៥. តម្រូវការលើការទិញវត្ថុអនុស្សាវរីយ៍ និងរក្សាចំណាប់អារម្មណ៍

ទេសចរគ្រប់រូបនៅពេលធ្វើដំណើរកំសាន្តនៅក្នុងតំបន់ណាមួយ ប្រទេសណាមួយ តែងតែចង់បាននូវរបស់របរដែលជាវត្ថុអនុស្សាវរីយ៍ពីតំបន់ទាំងនោះ មិនថាការទិញវត្ថុអនុស្សាវរីយ៍ទេ ការថតរូប ក៏មានសារៈសំខាន់ផងដែរ។

- ការថតរូប ៖ ជាតម្រូវការមួយផ្នែករបស់ទេសចរណ៍ ក្នុងការផ្តិតយករូបភាពប្លែកៗ និង ទេសភាពដ៏ស្រស់ត្រកាលនៃតំបន់ទេសចរណ៍ ឬព្រឹត្តិការណ៍ផ្សេងៗ ដើម្បីរម្លឹកអនុស្សាវរីយ៍ទាំងឡាយដែលបានកន្លងផុតទៅ។
- ការរក្សានូវចំណាប់អារម្មណ៍ ៖ ដើម្បីទាក់ទាញដល់ទឹកចិត្តទេសចរ ក្នុងការវិលត្រលប់មកទស្សនាកម្សាន្តម្តងទៀត នោះគ្រប់ប្រទេស ឬតំបន់គោលដៅទេសចរណ៍ទាំងអស់ត្រូវចេះរៀបចំបង្កើនសេវាកម្មផលិតផលថ្មីៗ អភិវឌ្ឍផលិតផលឱ្យមានគុណភាព ធានាបាននូវស្តង់ដា និងការតម្រូវការ តាមការចង់បានរបស់ទេសចរ។ ការរក្សាចំណាប់អារម្មណ៍នេះ ត្រូវយកចិត្តទុកដាក់ទៅលើការបម្រើដែលមានលក្ខណៈពិសេសជាច្រើនដូចជា ៖
- បដិសណ្ឋារកិច្ច ៖ វាអាចបញ្ជាក់នូវកិត្យានុភាព ភាពជឿជាក់ និងការផ្តល់ភាពកក់ក្តៅ ទំនុកចិត្តសម្រាប់ភ្ញៀវ។
- ភាពស្រស់ស្អាតនៃធម្មជាតិ ៖ ធម្មជាតិជាកត្តាមួយ ដែលទាក់ទាញទេសចរយ៉ាងខ្លាំងដូចជាបរិស្ថានព្រៃភ្នំ ទឹកជ្រោះ និងលក្ខណៈពិសេសផ្សេងៗទៀតដែលធ្វើឱ្យទេសចរជាប់ចិត្តជិតអារម្មណ៍មិនចង់ឃ្លាតឆ្ងាយ ហើយចង់ត្រឡប់មកម្តងទៀតក្នុងពេលឆាប់ៗ។
- ការផ្តល់សេវាកម្ម ៖ ត្រូវធ្វើយ៉ាងណាឱ្យភ្ញៀវមានចំណាប់អារម្មណ៍ ប្រសិនបើមានការពេញចិត្តពីសំណាក់ភ្ញៀវ គេនឹងត្រលប់មកម្តងទៀត។
- ស្តង់ដាសេវាកម្មដែលផ្គត់ផ្គង់ក្នុងខ្សែទស្សនកិច្ច ៖ ការរៀបចំក្នុងខ្សែទស្សនកិច្ចឱ្យមានស្តង់ដាជាប្រការចាំបាច់ក្នុងការធ្វើឱ្យអ្នកប្រើប្រាស់បន្សល់នូវការចាប់អារម្មណ៍ល្អៗ អាចជួយផ្សព្វផ្សាយបន្តដើម្បីនាំទេសចរផ្សេងទៀតមកបន្ថែមនៅពេលក្រោយ។

**សំណួរត្រិះរិះ**

១. ចូរឱ្យនិយមន័យទេសចរណ៍ និងការធ្វើដំណើរ។

២. តើគេចែកទេសចរណ៍ជាប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូររៀបរាប់។

៣. មូលហេតុអ្វីបានជាគេធ្វើដំណើរទេសចរណ៍?

៤. តើកត្តាអ្វីខ្លះជះឥទ្ធិពលលើការអភិវឌ្ឍវិស័យទេសចរណ៍?

៥. តើលក្ខណៈពិសេសវិស័យទេសចរណ៍មានអ្វីខ្លះ? ចូរបញ្ជាក់។

៦. តើផលិតផលទេសចរណ៍ជាអ្វី? តើផលិតផលទេសចរណ៍មានអ្វីខ្លះ? ចូររៀបរាប់។

៧. តើអ្វីជាទីផ្សារការធ្វើដំណើរ និងទេសចរណ៍?

៨. តើមុខងារ និងជាតុផ្សំនៃទីផ្សារទេសចរណ៍មានអ្វីខ្លះ?

៩. តើតម្រូវការលើការធ្វើដំណើរ និងទេសចរណ៍មានអ្វីខ្លះ? ចូរបញ្ជាក់។

# មេរៀនទី២៖ កម្មវត្ថុ រដ្ឋបាល មុខងារ និងឥទ្ធិពលវិស័យទេសចរណ៍

## ១. ច្បាប់រដ្ឋបាលទេសចរណ៍

### ១.១. លិខិតឆ្លងដែន

អ្នកដំណើរដែលធ្វើដំណើរទៅបរទេស ពោលគឺឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយទៀត ត្រូវទាមទារឱ្យមាននូវលិខិតឆ្លងដែនសម្គាល់ខ្លួនមួយបែប ដែលគេត្រូវបង្ហាញសមត្ថកិច្ចដែលមានភារៈឆែកឆេរនៅច្រកចេញ-ចូល នៃប្រទេសរបស់ខ្លួន និងច្រកចេញ-ចូល នៃប្រទេសដែលធ្វើដំណើរទៅ ឬ ឆ្លងកាត់ លិខិតនោះគេឱ្យឈ្មោះថា លិខិតឆ្លងដែន។

លិខិតឆ្លងដែន គឺជាកូនសៀវភៅតូចមួយដែលនៅក្នុងនោះរួមមាន ព័ត៌មានដែលទាក់ទងទៅនឹងខ្លួនរបស់មនុស្សម្នាក់ៗនៅក្នុងនោះរួមមាន ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ សញ្ជាតិ ទីកន្លែងរស់នៅបច្ចុប្បន្ន មុខរបរ កម្ពស់ រូបថត (ថតភ្លាម) ថ្ងៃឆ្នាំផ្ដល់ឱ្យ និងសុពលភាព ព្រមទាំងហត្ថលេខាសាមីខ្លួន។ លិខិតឆ្លងដែន ត្រូវប្រគល់ឱ្យពលរដ្ឋគ្រប់រូប មិនថាក្មេង ឬ មនុស្សចាស់។

លិខិតឆ្លងដែនជាទូទៅមាន៣ប្រភេទគឺ ៖

- លិខិតឆ្លងដែនធម្មតា
- លិខិតឆ្លងដែនផ្លូវការ
- លិខិតឆ្លងដែនការទូត សម្រាប់អង្គទូត ឬ មន្ត្រីជាន់ខ្ពស់ (រដ្ឋមន្ត្រី)

#### ក. លិខិតឆ្លងដែនធម្មតា

លិខិតឆ្លងដែនធម្មតា គឺជាប្រភេទលិខិតឆ្លងដែន សម្រាប់ប្រជាពលរដ្ឋសាមញ្ញ សិស្ស និស្សិត មន្ត្រីរាជការ ហើយក៏ជាប្រភេទលិខិតឆ្លងដែន ដែលមនុស្សទូទៅត្រូវតែមានមិនថា រាស្ត្រសាមញ្ញ មន្ត្រីរាជការ មន្ត្រីអង្គទូត មន្ត្រីជាន់ខ្ពស់ ប្រើដើម្បីការធ្វើដំណើរទៅកាន់បរទេសក្នុងគោលបំណងផ្ទាល់ខ្លួន ដំណើរកំសាន្ត ព្យាបាលជំងឺ សួរសុខទុក្ខញាតិមិត្ត ធ្វើជំនួញ ឬប្រកបអាជីវកម្មនៅបរទេស។

#### ខ. លិខិតឆ្លងដែនផ្លូវការ

លិខិតឆ្លងដែនផ្លូវការ គឺជាប្រភេទលិខិតឆ្លងដែន សម្រាប់មន្ត្រីរាជការ សម្រាប់មន្ត្រីដែលមានឋានៈតួនាទីចាប់ពីប្រធាននាយដ្ឋាន ដែលចេញទៅបរទេស ក្នុងដំណើរបំពេញបេសកម្មផ្លូវការរបស់រដ្ឋ។ សូមបញ្ជាក់ថា លិខិតឆ្លងដែនផ្លូវការអាចប្រើប្រាស់បាននៅពេលមន្ត្រីដែលបំពេញបេសកម្មផ្លូវការរបស់រដ្ឋទៅបរទេស ដោយមានលិខិតបំពេញបេសកម្មភ្ជាប់ជាមួយ ហើយមិនអាចយកទៅប្រើប្រាស់ដើម្បីដំណើរទៅបរទេសក្នុងគោលបំណងផ្ទាល់ខ្លួនបានទេ។

#### គ. លិខិតឆ្លងដែនសម្រាប់អង្គទូត ឬ មន្ត្រីជាន់ខ្ពស់

លិខិតឆ្លងដែនការទូត ជាប្រភេទលិខិតឆ្លងដែន សម្រាប់អង្គទូត ឬមន្ត្រីជាន់ខ្ពស់ (រដ្ឋមន្ត្រី) ដែលចេញទៅបរទេស ក្នុងដំណើរបំពេញបេសកម្មផ្លូវការរបស់រដ្ឋ ហើយមិនអាចយកទៅប្រើប្រាស់ដើម្បីដំណើរទៅបរទេសក្នុងគោលបំណងផ្ទាល់ខ្លួនបានទេ។

**១.២. ទិដ្ឋាការ**

គ្រប់ប្រទេសទាំងអស់នៅលើពិភពលោក ការចូលទៅក្នុងប្រទេសរបស់គេត្រូវតែស្នើសុំនូវការអនុញ្ញាតជាចាំបាច់ពីស្ថានទូតដែលប្រចាំនៅក្នុងប្រទេសរបស់ខ្លួន ឬប្រទេសជិតខាង (ប្រសិនបើប្រទេសដែលយើងរស់នៅមិនមានស្ថានទូតដែលប្រចាំ)។ ក្នុងករណីប្រទេសជាប់ព្រំដែន ដែលមានចុះកិច្ចសន្យា ឬកិច្ចព្រមព្រាងឆ្លងព្រំដែនរវាងប្រទេសនិងប្រទេស អាចអនុញ្ញាតិសុំទិដ្ឋាការនៅតាមព្រំដែនបាន ប៉ុន្តែរយៈពេលខ្លី (មួយ ឬពីរសប្តាហ៍)។ លិខិតអនុញ្ញាតដែលបោះជាប់នឹងលិខិតឆ្លងដែនដោយស្ថានទូត ឬស្ថានតំណាងប្រទេសមួយ ហៅថា ទិដ្ឋាការ។

**ក. ប្រភេទទិដ្ឋាការ** ទិដ្ឋាការ ឬលិខិតអនុញ្ញាត ដែលបោះជាប់នឹងលិខិតឆ្លងដែនដោយស្ថានទូត ឬ ស្ថានតំណាងមាន២ប្រភេទគឺ ៖

- ទិដ្ឋាការសុំស្នាក់នៅ
- ទិដ្ឋាការសុំឆ្លងកាត់

ទិដ្ឋាការទាំង ២ ប្រភេទអាចសុំចេញចូលបានម្តង ឬអាចសុំបានច្រើនដង អាស្រ័យទៅតាមប្រភេទនៃគោលបំណងរបស់អ្នកសុំ។

**ខ. ទិដ្ឋាការសុំស្នាក់នៅ**

ទិដ្ឋាការសុំស្នាក់នៅ ដែលរយៈពេល ៣ខែ/ដង ហើយអាចបន្តរហូតដល់រយៈពេលយូរបំផុតពេញ ១ ឆ្នាំ យោងទៅតាមការចាំបាច់ក្នុងការសុំពន្យាពេលស្នាក់នៅ និងស្ថានភាពជាក់ស្តែងដូចជា មានជំងឺជាទម្ងន់ គ្រោះថ្នាក់ភ្លាមៗ សម្រាលកូនមុនកំណត់ អាកាសធាតុមិនអំណោយផល ឬសង្គ្រាម។ល ។

**គ. ទិដ្ឋាការសុំឆ្លងកាត់**

ទិដ្ឋាការសុំឆ្លងកាត់ មានរយៈពេលយូរបំផុតត្រឹម ៤៨ ម៉ោង ហើយក៏អាចសុំពន្យាពេលស្នាក់នៅ និងទៅតាមស្ថានភាពជាក់ស្តែងដូចជា មានជំងឺជាទម្ងន់ គ្រោះថ្នាក់ភ្លាមៗ សម្រាលកូនមុនកំណត់ អាកាសធាតុមិនអំណោយផល ឬសង្គ្រាម...។ល។

**១.៣. ច្រកចេញ-ចូល**

នៅតាមព្រំដែននៃប្រទេសជិតខាង ដែលអាចធ្វើគមនាគមន៍ ទៅមកបានតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសតែងតែមានប៉ុស្តិ៍ត្រួតពិនិត្យ។ ប៉ុស្តិ៍ត្រួតពិនិត្យនោះហៅថា ច្រកព្រំដែន ដែលត្រួតពិនិត្យ ដោយប៉ូលីស និងភ្នាក់ងារគយប្រចាំព្រំដែន ដើម្បីពិនិត្យលើលិខិតឆ្លងដែន ទិដ្ឋការ និងប្រភេទទំនិញដែលអ្នកដំណើរឬអ្នកទេសចរយកជាប់តាមខ្លួន។

**១.៤. គយ**

នៅច្រកចេញ-ចូល នៃព្រំដែនអន្តរជាតិ នៃប្រទេសនីមួយៗតែងតែមានទីស្នាក់ការគយ សម្រាប់ត្រួតពិនិត្យមើលឥវ៉ាន់ ដើម្បីឱ្យម្ចាស់ឥវ៉ាន់ទាំងនោះបង់ពន្ធនូវរាល់ទំនិញដែលលើសចំណុះ។ ដោយឡែកចំពោះទេសចរ ដែលចេញចូលប្រទេសនីមួយៗ អាចនាំយកទំនិញនៅបរទេសមកប្រទេសរបស់ខ្លួន ឬយកទំនិញប្រទេសរបស់ខ្លួទៅបរទេសដោយរួចពន្ធបាន តែក្នុងកម្រិតនៃបរិមាណណាមួយ ឬប្រភេទទំនិញណាមួយប៉ុណ្ណោះ មិនទូទៅនោះទេ។

**ក. បេសកកម្ម និងចក្ខុវិស័យ**

បេសកកម្មចម្បងរបស់ទីចាត់ការគយ និងរដ្ឋាករគឺ ៖

- ធានាប្រសិទ្ធភាពខ្ពស់ក្នុងការប្រមូលពន្ធ-អាករ និងកម្រៃផ្សេងៗជូនរដ្ឋ
- ទប់ស្កាត់ និងបង្ក្រាបនូវអំពើគេចពន្ធគ្រប់រូបភាព ដើម្បីសម្រួលដល់កិច្ចការពាណិជ្ជកម្មអន្តរជាតិ
- ប្រែក្លាយអង្គភាពទីចាត់ការគយ និងរដ្ឋាករ ទៅជាស្ថាប័នផ្តល់សេវាលក្ខណៈស្តង់ដា សម្រាប់អាជីវករ និងអបិតិជន។
- កសាងធនធានមនុស្សដែលប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌ខ្ពស់

**ខ. ការកំណត់តម្លៃគិតពន្ធគយ**

ការកំណត់តម្លៃគិតពន្ធគយ ឬវាយតម្លៃពន្ធគយជាការងារមួយដែលសំខាន់ ហើយស្មុគ្រស្មាញ ដែលត្រូវធ្វើការកែលម្អជាប្រចាំ ដើម្បីឱ្យមានការកំណត់តម្លៃឯកភាព និងគោលបំណងឱ្យមានតម្លាភាពក្នុងការកំណត់តម្លៃពន្ធ ទីចាត់ការគយ និងរដ្ឋាករបានរៀបចំឱ្យមានតារាងទំនិញសំខាន់ៗ សម្រាប់ជាការយោង ជាពិសេសក្រោយពេលដែលយន្តការអធិការកិច្ចទំនិញមុនពេលផ្ទុកត្រូវបានបញ្ឈប់។ តារាងនេះត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានព័ត៌មានជាក់ស្តែងស្តីពីតម្លៃទំនិញនៅលើទីផ្សារក្នុង ស្រុក ក្រៅស្រុក និងជាពិសេសទិន្នន័យ របាយការណ៍ជាក់ស្តែងរបស់ក្រុមហ៊ុន ព្រមទាំងកត្តាជាក់ស្តែង មួយចំនួននៅកម្ពុជាផងដែរ។

**គ. កិច្ចការអន្តរជាតិ**

ជាបទពិសោធន៍របស់ប្រទេសនានាក្នុងសកលលោកបានបង្ហាញថា រដ្ឋបាលពន្ធគយ និងរដ្ឋាករមានតួនាទីយ៉ាងសំខាន់ ក្នុងការសម្រេចសម្រួលពាណិជ្ជកម្មអន្តរជាតិ។ ដូច្នេះហើយ សហប្រតិបត្តិការ អន្តរជាតិផ្នែកកិច្ចការគយ និងរដ្ឋាករជាការងារមួយសំខាន់ចំពោះមុខ។

**១.៥. ពន្ធក្រៅប្រទេស**

នៅកន្លែងខ្លះដូចជានៅកំពង់ផែអន្តរជាតិ អាកាសយានដ្ឋានអន្តរជាតិ ច្រកចេញ-ចូលអន្តរជាតិ តែងតែមានហាងទំនិញរួចពន្ធ ដែលអតិថិជនក្រោយពីទិញទំនិញនោះរួចហើយ ត្រូវតែចាកចេញពីប្រទេសនោះ ហើយយកទៅប្រើប្រាស់នៅប្រទេសរបស់ខ្លួន។

**១.៦. សម្បទាពន្ធសម្រាប់ទេសចរណ៍**

តាមសន្និសញ្ញាទីក្រុង ញ៉ូវយ៉ក នៅឆ្នាំ ១៩៥៤ បានចែងថា បណ្តាប្រទេសជាសមាជិកទាំងឡាយត្រូវបង្កលក្ខណៈងាយស្រួលដល់ទេសចរ ដែលចេញចូលប្រទេសនោះ ក្នុងអនុញ្ញាតិឱ្យនាំចូលមកនូវសម្ភារៈ ឬទំនិញ ឬសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ដោយរួចពន្ធ។ ចំពោះបណ្តាទេសចរ ដែលអនុញ្ញាតិឱ្យនាំចូលមកនូវសម្ភារៈ ឬទំនិញ ឬសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ដោយរួចពន្ធទាំងនោះបានតែម្តងម្កាលនោះទេមិនមែន ១សប្តាហ៍ ឬជារៀងរាល់ខែនោះឡើយ។ ក្នុងករណីទេសចរចេញ-ចូល រាល់ថ្ងៃ រាល់សប្តាហ៍ ឬជារៀងរាល់ខែ ដោយនាំយករបស់ដដែល នោះនឹងត្រូវទទួលការចាប់បង្ខំឱ្យបង់ពន្ធជាក់ជាមិនខាន។

## ២. មុខងារ និងធាតុផ្សំនៃទីផ្សារទេសចរណ៍

### ២.១. មុខងារនៃទីផ្សារទេសចរណ៍

- តម្រូវឱ្យប្រើប្រាស់ ឬទិញផលិតផលក្នុងតម្លៃដើម និងតម្លៃដែលអ្នកទិញអាចទទួលទិញបានក្នុងតម្លៃមួយដែលសមរម្យ
- រៀបចំចាត់ចែងធ្វើឱ្យផលិតផលទេសចរណ៍បានដល់អ្នកទិញ (អ្នកប្រើប្រាស់)
- បំពេញឱ្យមានឡើងវិញនូវសម្ភារៈជាមូលដ្ឋានសម្រាប់សកម្មភាពការងារ។

នៅក្នុងដំណើរការនៃការបំពេញ**មុខងារទី១** ទីផ្សារទេសចរណ៍បានបង្កឱ្យមាននូវចលនាតម្លៃដែលបង្ហាញពីការដោះដូរ និងទិញ-លក់ ផលិតផលទេសចរណ៍។ បញ្ចប់ការដោះដូរ បញ្ជាក់បានថាបញ្ចប់សកម្មភាពនៃទំនាក់ទំនង មួយរវាងទំនិញ-ទឹកប្រាក់ ដែលតម្រូវឱ្យទិញ ផលិតផលទេសចរណ៍ក្នុងតម្លៃណាមួយ ។

**មុខងារទី២** សំដៅជំរុញផលិតផលទៅដល់អតិថិជន (អ្នកទិញ) តាមរយៈការបង្កើតបណ្តាញសម្រាប់ចែកចាយលក់និងធ្វើឱ្យទេសចរបានស្គាល់អំពីផលិតផលដែលទីភ្នាក់ងារស្នើលក់។ ទេសចរបានចំណាយប្រាក់របស់ខ្លួនមកទិញ-ដូរ និងផលិតផលទេសចរណ៍ ដើម្បីបំពេញតម្រូវការរបស់ខ្លួន តាមរយៈភ្នាក់ងារទេសចរណ៍ដែលជាអ្នករៀបចំលក់ និងជាអ្នកដែលប្រមូលភ្ញៀវ។

**មុខងារទី៣** តម្រូវអោយមានការសន្សំ និងចេះបែងចែកប្រាក់ចំណូលដែលបានមកពីការដោះដូរ ទិញលក់ ផលិតផលទេសចរណ៍ក្នុងទីផ្សារ។ ការសន្សំត្រូវបានបែងចែកដើម្បីជំរុញ និងរៀបចំផលិតបន្ត ឬពង្រីកទីផ្សារជារួម។

### ២.២. ធាតុផ្សំនៃទីផ្សារទេសចរណ៍

ជាតុផ្សំទីផ្សារទេសចរណ៍មានបួន ៖ តម្រូវការទេសចរណ៍ ការផ្គត់ផ្គង់ទេសចរណ៍ តម្លៃផលិតផលទេសចរណ៍ និងការប្រកួតប្រជែងលក់ផលិតផលទេសចរណ៍។

នៅក្នុងទីផ្សារទេសចរណ៍កត្តាចម្បងគឺទំនាក់ទំនងជាប្រចាំរវាងតម្រូវការលើផលិតផលទេសចរណ៍ដែលទេសចរចង់បាន និងស្នើរផ្គត់ផ្គង់ផលិតផលទេសចរណ៍ដែល ដាក់ឡើងដោយទីភ្នាក់ងារទេសចរណ៍។

- តម្រូវការទេសចរណ៍ ៖ ជាទ្រង់ទ្រាយមួយនៃតម្រូវការរបស់អតិថិជនលើផលិតផលទេសចរណ៍ដែលតម្រូវការនេះអាចសម្រេចទៅបានប្រសិនបើពួកគេមានមធ្យោបាយ (ប្រាក់គ្រប់គ្រាន់) សម្រាប់ទិញផលិតផល។
- ការផ្គត់ផ្គង់ទេសចរណ៍ ៖ ជាបរិមាណដ៏ច្រើននៃខ្សែទស្សនកិច្ច កម្មវិធីកម្សាន្ត សេវាកម្ម និងទំនិញទេសចរណ៍ ដែលរៀបចំឡើងសម្រាប់លក់ និងផ្គត់ផ្គង់នៅក្នុងទីផ្សារ។ ការផ្គត់ផ្គង់ទេសចរណ៍ជាផ្នែកមួយដ៏សំខាន់នៃជាតុទាំងបួនរបស់ទីផ្សារទេសចរណ៍។ ចំណុចពិសេសរបស់វា គឺស្ថិតនៅលើអ្នកផលិតសេវាកម្ម អ្នកផលិតផលិតផល ការរីកដុះដាល ឬរីកចម្រើននៃឧស្សាហកម្មទេសចរណ៍ និងទំហំធនធានទេសចរណ៍ ដែលប្រើប្រាស់ក្នុងចង្កោម ផលិតផល (ធនធានធម្មជាតិ វប្បធម៌ អរិយធម៌ ប្រវត្តសាស្រ្ត ធនធាន កែច្នៃ ឧទ្យានជាតិ...)។

- តម្លៃផលិតផលទេសចរណ៍ ៖ ជារង្វាស់ដែលកំណត់សមស្របទៅតាមតម្រូវការ និងការស្នើផ្តត់ផ្គង់ ផលិតផលដែលមាននៅក្នុងទីផ្សារទេសចរណ៍។
- ការប្រកួតប្រជែង ៖ ការប្រជែងគ្នារវាងប្រតិបត្តិករអាជីវកម្មទេសចរណ៍នៅក្នុងទីផ្សារដើម្បី ឈរជើងដណ្តើមអតិថិជន និងកាន់កាប់ទីផ្សារ សម្រាប់លក់ផលិតផល។ បន្ថែមទៅលើនេះការប្រកួតប្រជែងទីផ្សារទេសចរណ៍ត្រូវបានគេធ្វើសំដៅលើតម្លៃផលិតផលទេសចរណ៍ តម្រូវការ និងការផ្គត់ផ្គង់ផលិតផលទេសចរណ៍។

## ៣. ឥទ្ធិពលទេសចរណ៍ទៅលើវិស័យផ្សេងៗ

ទេសចរណ៍ ជាវិស័យមួយក្នុងចំណោមវិស័យអាទិភាពនៃសេដ្ឋកិច្ចជាតិ ហើយដែលប្រទេសជាច្រើនក្នុងពិភពលោកយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍ។ ប្រទេសមួយចំនួននៅលើពិភពលោកកំពុងតែទទួលជោគជ័យយ៉ាងខ្លាំង ក្នុងការជម្រុញឱ្យសេដ្ឋកិច្ចមានការរីកលូតលាស់ តាមរយៈផលប្រយោជន៍នៃវិស័យទេសចរណ៍ វិភាគទានទេសចរណ៍ទៅលើសេដ្ឋកិច្ចមាន ២ ប្រភេទផ្ទុយគ្នា គឺវិជ្ជមាន និង អវិជ្ជមាន ហើយផ្នែកទាំង ២ នេះមានឥទ្ធិពលទៅវិញទៅមក។

### ៣.១. ឥទ្ធិពលទេសចរណ៍ទៅលើវិស័យសេដ្ឋកិច្ច

#### ក. ចំណូលរូបិយប័ណ្ណ

ទេសចរណ៍ ក៏ជាវិស័យដ៏សំខាន់បំផុតនៃប្រភពដែលទទួលបានរូបិយវត្ថុបរទេស។ ដើម្បីសម្រេចបាននូវចំណូលរូបិយប័ណ្ណ ចាំបាច់ត្រូវតែបន្ថយទំនិញនាំចូល និងសេវាកម្មទាំងឡាយដែលប្រើប្រាស់ក្នុងវិស័យទេសចរណ៍ ព្រមទាំងការជ្រាបចេញដទៃៗទៀត នៃវិស័យនេះ។ ការជ្រាបចេញ នៃរូបិយប័ណ្ណមានដូចជា ៖

- ទំនិញដែលនាំចូលដទៃទៀតដូចជា ភេជ្ជៈ ចំណីអាហារ ការផ្គត់ផ្គង់សណ្ឋាគារ។
- ការផ្ទេរទៅក្រៅប្រទេសនូវប្រាក់ចំណេញពីសេវាកម្ម តាមរយៈការវិនិយោគតាមសណ្ឋាគារ ក្រុមហ៊ុនរៀបចំកម្មវិធីដំណើរកំសាន្ត និងក្រុមហ៊ុនទេសចរណ៍។
- ការផ្ទេរចេញនូវប្រាក់ខែ ដែលបង់ទៅឱ្យអ្នកធ្វើការនៅក្រៅប្រទេស ក្នុងវិស័យទេសចរណ៍។
- ការរួមចំណែកចំពោះផលិតផលក្នុងស្រុកសរុប( **GDP**) ទេសចរណ៍បានចូលរួមយ៉ាងសកម្ម ក្នុងការគណនា ដោយផ្អែកទៅលើ **GDP** ដែលជះឥទ្ធិពលដោយសារវិស័យទេសចរណ៍។
- ការរួមចំណែកនៅក្នុងចំណូលរបស់រដ្ឋាភិបាល ចំណូលរបស់រដ្ឋាភិបាលពីវិស័យទេចរណ៍ គឺជាសក្តានុពលភាពដ៏សំខាន់មួយ។ ការបង់ពន្ធដោយទេសចរត្រូវបានប្រមូលដោយរដ្ឋាភិបាលរួមមានតម្លៃទិដ្ឋាការ ពន្ធគយ នាំចូលត្រូវបានប្រមូលមកពីមុខទំនិញទាំងឡាយដែលនាំចូលសម្រាប់បំរើទេសចរណ៍ដូចជា ប្រភេទភេសជ្ជៈជាដើម។ ពន្ធអាជ្ញាប័ណ្ណត្រូវបានប្រមូលពីសណ្ឋាគារ ក្រុមហ៊ុនទេសចរណ៍ និងក្រុមហ៊ុនផ្តល់សេវាដទៃទៀត។

#### ខ. ចំណូលសរុបនៃវិស័យទេសចរណ៍

ជាទូទៅចំណូលសរុបដែលបានមកពីវិស័យទេសចរណ៍ ត្រូវបានគណនាដោយផ្អែកទៅលើបរិមាណទឹកប្រាក់ដែលអ្នកទេសចរចំណាយនៅក្នុងប្រទេស ឬតំបន់ទេសចរណ៍។ តាមការប៉ាន់ស្មានលើការចំណាយរបស់ទេសចរនៅក្នុងប្រទេសដែលពួកគេបានមកដល់ គឺចំណាយទៅលើការស្នាក់នៅ ការដឹកជញ្ជូនអាហារ

និងសេវាកម្មផ្សេងៗ ចំណាយលើការទស្សនា ចំណាយលើខ្សែទស្សកិច្ច ចំណាយលើទំនិញទេសចរណ៍ និងការកែកំសាន្ត ផ្សេងៗ...។ បញ្ហាមួយទៀតដែលត្រូវតែគិតគូរផងដែរអំពីការហូរទឹកប្រាក់ទៅបរទេសវិញតាមរយៈការទិញទំនិញផ្សេងៗ ដើម្បីបំពេញសេវាកម្មទេសចរណ៍ដូចជា ភេសជ្ជៈ ចំណីអាហារ សម្ភារៈបច្ចេកទេស យានយន្ត ប្រេងឥន្ធនៈ អាជីវករ ជាជនបរទេស...។

**គ. ចំណូលពីបរទេសដល់រដ្ឋាភិបាល**

ជាទូទៅ ចំណូលរដ្ឋាភិបាលដែលបានមកពីវិស័យទេសចរណ៍ទទួលបាន តាមរយៈការសុំទិដ្ឋាការចូលក្នុងប្រទេស ពន្ធលើការចេញអាជ្ញាប័ណ្ណអាជីវកម្មទេសចរណ៍ ពន្ធលើការនាំចូលទំនិញទេសចរណ៍ ការសហប្រតិបត្តិការខ្សែទស្សនកិច្ច ពន្ធលើប្រាក់ចំណេញ តម្លៃចូលទស្សនាតំបន់ទេសចរណ៍ ពន្ធលើព្រលានយន្តហោះ ពន្ធលើការសុំចុះចតឯកជន និងពន្ធលើការប្រើប្រាស់ដីធ្លីសម្រាប់វិស័យទេសចរណ៍។

**ឃ. ផ្តល់ការងារជូនប្រជាពលរដ្ឋ និង សេដ្ឋកិច្ចតំបន់**

វិស័យទេសចរណ៍ផ្តល់ជាផលប្រយោជន៍ដល់ប្រជាជនដោយប្រយោល និងដោយផ្ទាល់ទាំងប្រជាជនរស់ក្នុងសហគមន៍ និងនៅតំបន់ជិតខាងសហគមន៍ដូចជា មន្ត្រីបំរើការក្នុងក្រសួងទេសចរណ៍ បុគ្គលិកបម្រើការក្នុងក្រុមហ៊ុនទេសចរណ៍ បុគ្គលិកក្នុងអាហារដ្ឋាន តំបន់ទេសចរណ៍ កន្លែងកំសាន្ត ការងារដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ការធ្វើដំណើរ ផលិតផលកសិកម្ម (ផ្គត់ផ្គង់អាហារ) ឧស្សាហកម្ម និងសិប្បកម្ម (ទំនិញទេសចរណ៍) និងជីវភាពក្នុងសហគមន៍។ ការផ្សារភ្ជាប់ជាមួយវិស័យសេដ្ឋកិច្ចដទៃទៀត ការភ្ជាប់ទេសចរណ៍ជាមួយវិស័យដទៃទៀតកាន់តែខ្លាំងក្លាឡើយនាពេលបច្ចុប្បន្ននេះ។

**៣.២. ឥទ្ធិពលទេសចរណ៍ទៅលើវិស័យបរិស្ថាន**

វិស័យទេសចរណ៍អាចទទួលបានផលប៉ះពាល់ដល់បរិស្ថានទាំងផលវិជ្ជមាន និងអវិជ្ជមានអាស្រ័យទៅលើការអភិវឌ្ឍធ្វើទៅតាមផែនការ និងគ្រប់គ្រងបានឬទេ? នៅក្នុងទម្រង់ដ៏ល្អបំផុត វិស័យ ទេសចរណ៍អាចផ្តល់នៅការរកប្រាក់ចំនូលដែលត្រូវបង់សម្រាប់ថែរក្សាឧទ្យានជាតិ ជម្រកសត្វព្រៃ និងតំបន់ការពារដទៃទៀត ព្រមទាំងទេសភាពជាលក្ខណៈធម្មជាតិក្នុងប្រទេសកម្ពុជា ដោយសារធនធានទាំងនោះ គឺជាការទាក់ទាញភ្ញៀវទេសចរ។ បញ្ហាបរិស្ថានរួមចេញពីការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងពេលបច្ចុប្បន្ន រួមមានលទ្ធភាពនៃការបំពុលបរិយាកាស ផ្ទៃដី ក្នុងទឹក និងក្រោមដី ដែលបង្កឱ្យប្រព័ន្ធលូទឹកស្អុយមិនល្អពីតំបន់ ឬរមណីយដ្ឋានទេសចរណ៍ សណ្ឋារគារដែលមិនបានរៀបចំប្រព័ន្ធលូទឹកសម្អុយបានត្រឹមត្រូវ និងរមណីយដ្ឋានទេសចរណ៍ដទៃទៀតដែលមិនបានទាក់ទាញបន្ថែមទៅលើទេសភាព ព្រមទាំងបញ្ចៀសនៃការប្រើប្រាស់ដីធ្លីជាពិសេសបញ្ចៀសសណ្ឋាគារដែលមានទីតាំងមិនសមស្រប និងមានកម្រិតកំណត់នៃកន្លែងចតរថយន្តដែលបានអភិវឌ្ឍសម្រាប់សណ្ឋាគារនោះ។

**ក. ផលវិជ្ជមាន**

ដើម្បីចូលរួមចំណែកថែរក្សាការពារ បរិស្ថានធម្មជាតិ ថែរក្សាបរិស្ថានសង្គម ថែរក្សា បរិស្ថានវប្បធម៌ បង្កើនការយល់ដឹងពីបរិស្ថានដល់សហគមន៍ ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងកាកសំណល់ អប់រំប្រជាជនក្នុងសហគមន៍ ស្តីអំពីអនាម័យបរិស្ថានក្នុងលំនៅស្ថាន ក៏ដូចជាក្នុងសហគមន៍អាចជៀសផុតពីជំងឺឆ្លងផ្សេងៗ។

**ខ. ផលអវិជ្ជមាន**

ការបំពុលទឹក ដី អាកាស ដោយប្រព័ន្ធបង្ហូរទឹកសម្អុយ និងកាកសំណល់ ផ្សេងៗ ការប្រើប្រាស់ទីតាំងមិនបានសមស្រប ដោយគ្មានទីតាំងល្អ និងចំណតរថយន្តគ្រប់គ្រាន់ ការចោលសំរាមពាសវាលពាសកាល គ្មានបង្គន់អនាម័យគ្រប់គ្រាន់ ខូចខាតសោភ័ណភាពតំបន់ទេសចរណ៍ សំណង់អាណាធិបតេយ្យតាមតំបន់រមណីយដ្ឋាន ការកាប់បំផ្លាញព្រៃឈើ បំផ្លាញជម្រកសត្វព្រៃ ការបាត់បង់សត្វព្រៃ ការធ្វើអាជីវកម្ម និងការុកកានព្រៃធ្វើចម្ការព្រៃដុត...។

**៣.៣. ឥទ្ធិពលទេសចរណ៍ទៅលើសង្គម**

ជារឿយៗ អាកប្បកិរិយារបស់ពលរដ្ឋម្ចាស់ប្រទេស គឺជាកត្តាសំខាន់សំរាប់ទាក់ទាញទេសចរទៅកំសាន្តលេងទេសចរជាច្រើនចាប់អារម្មណ៍ នឹងបទពិសោធន៍វប្បធម៌ណាដែលមានលក្ខណៈពីឥរិយាបថរបស់ពួកគេ។ វប្បធម៌របស់ពលរដ្ឋម្ចាស់ប្រទេសខុសគ្នាទៅតាមទម្រង់ជាច្រើន ប៉ុន្តែភាគច្រើនគេចែកចេញជាពីរផ្នែកគឺ ៖

- ទំនៀមទម្លាប់ដែលកើតឡើងដោយពលរដ្ឋម្ចាស់ប្រទេស
- ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋម្ចាស់ប្រទេស ព្រមទាំងប្រវត្តិសាស្ត្រ និងសាសនារបស់គេ

វិស័យទេសចរណ៍បានបង្កើនចំណាប់អារម្មណ៍ទៅលើផ្នែកសង្គមវប្បធម៌ ដែលជាកត្តាជួយថែរសិល្បៈ និងជាអាជីពប្រពៃណីឆ្លុះបញ្ចាំងពីជីវិតរបស់ពលរដ្ឋម្ចាស់ប្រទេសដែលបានបាត់បង់បាត់ទាំងស្រុង។ ពិសេសជាងនេះទៅទៀត វិស័យទេសចរណ៍បានបង្កើតឱ្យមានតម្រូវការផ្នែកវត្ថុអនុស្សាវរីយ៍របស់ពលរដ្ឋម្ចាស់ស្រុក ហើយតម្រូវការទាំងនោះបានធ្វើឱ្យពួកគាត់បានផលិតសម្ភារៈផ្សេងៗដូចជាចម្លាក់ធ្វើអំពីថ្ម ចម្លាក់ធ្វើអំពីឈើ ឬឈើតំណាងឱ្យវប្បធម៌របស់ពួកគេជាដើម។

**ក. ផលវិជ្ជមាន**

បង្កើនការងារកាន់តែច្រើនដល់ប្រជាជនទូទៅ ប្រើប្រាស់ចំណូលពីទេសចរ ស្រមាប់ប្រយោជន៍សង្គមរួម ប្រជាជនមានជំនាញផ្ទាល់ខ្លួន ដោយបង្កើតជាភូមិមួយផលិតផលមួយ សម្រាប់ផ្សព្វផ្សាយ អំពីអ្វីដែលពួកគេមាន និងចេះបង្កើតធ្វើឱ្យមានកំណើនកម្រិតជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ ធ្វើឱ្យសង្គមមានស្ថិរភាព និងសុវត្ថិភាព។

**ខ. ផលអវិជ្ជមាន**

ការរីករាលដាលនៃជំងឺឆ្លងមួយចំនួនដូចជា ជំងឺអេដស៍ ជំងឺកាមរោគ ការប្រើប្រាស់ គ្រឿងញៀន ពេស្យាចារ្យ ការហូរចូលនូវ ជនអន្តោប្រវេសន៍ខុសច្បាប់ ទំនាស់រវាងម្ចាស់ស្រុកជាមួយទេសចរ ប្រជាពលរដ្ឋម្ចាស់ស្រុក ទទួលការមើលងាយពីសំណាក់ទេសចរ...។

**៣.៤. ឥទ្ធិពលទេសចរណ៍ទៅលើវិស័យវប្បធម៌**

វិស័យទេសចរណ៍បានបង្កើនចំណាប់អារម្មណ៍ទៅលើផ្នែកវប្បធម៌ ដែលជាកត្តាជួយថែរសិល្បៈ និងជាអាជីពប្រពៃណីឆ្លុះបញ្ចាំងពីជីវិត របស់ពលរដ្ឋម្ចាស់ប្រទេសដែលបានបាត់បង់បាត់ទាំងស្រុង។ ពិសេសជាងនេះទៅទៀតវិស័យទេសចរណ៍បានបង្កើតឱ្យមានតម្រូវការផ្នែកវត្ថុអនុស្សាវរីយ៍របស់ពលរដ្ឋម្ចាស់ស្រុក ហើយតម្រូវការទាំងនោះបានធ្វើឱ្យពួកគាត់បានផលិតសម្ភារៈផ្សេងៗដូចជា ចម្លាក់ធ្វើអំពីថ្ម ចម្លាក់ធ្វើអំពីឈើ ឬឈើតំណាងឱ្យវប្បធម៌របស់ពួកគេជាដើម។

### ក. ផលវិជ្ជមាន

ការអភិរក្សប្រពៃណីទំនៀមទម្លាប់ សាសនា របាំ ល្ខោន សម្រាប់ទាក់ទាញភ្ញៀវទេសចរ មានការលើតម្កើង និងកែលម្អមូលដ្ឋានវប្បធម៌ សារៈមន្ទីរ សម្រាប់ប្រើប្រាស់ក្នុងវិស័យទេសចរណ៍ លើកទឹកចិត្តឱ្យប្រជាជនកាន់តែមានមោទនភាព និងកាន់តែស្រលាញ់ទៅលើវប្បធម៌ប្រពៃណីរបស់ខ្លួន ផ្ដល់ឱកាសសម្រាប់ការផ្លាស់ប្ដូរបទពិសោធន៍គ្នាអំពីវប្បធម៌រវាងភ្ញៀវទេសចរ និងម្ចាស់ស្រុក។

### ខ. ផលវិជ្ជមាន

ធ្វើឱ្យប៉ះពាល់ភាពសមរម្យដល់ម្ចាស់ស្រុក នៅពេលដែលបរិមាណភ្ញៀវទេសចរកើនឡើងឆាប់រហ័ស ភាពសឹករិចរិលនៃតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រ និងវត្ថុបុរាណសំខាន់ៗ ការយល់ច្រឡំ និងការវិវាទរវាងម្ចាស់នឹងទេសចរ ដោយសារភាសា ទំនៀមទម្លាប់ ប្រពៃណីខុសគ្នា ការទទួលយកវប្បធម៌របស់ទេសចរ តាមរយៈសកម្មភាពផ្សេងៗ យុវជនងាយនឹងទទួលយកនូវវប្បធម៌ប្លែកៗ ដែលប្រាកចាកនូវវប្បធម៌ប្រពៃណីរបស់ជាតិខ្លួន។

## ៤. កម្មវត្ថុទេសចរណ៍

### ៤.១. លទ្ធភាពនៃការទទួលទេសចរណ៍

បើយើងនិយាយអំពីលទ្ធភាពនៃការទទួលទេសចរណ៍ យើងពុំអាចលើកយកតែតំបន់ទេសចរណ៍មួយចំណុចមកនិយាយបានទេ នៅមានកត្តាជាច្រើនទៀតដែលទាក់ទងទៅនឹងការទទួលទេសចរណ៍ដូចជា ៖

- ការស្នាក់នៅរបស់ភ្ញៀវ ( សណ្ឋាគារ ម៉ូតែល ផ្ទះសំណាក់...។ល។
- ការផ្គត់ផ្គង់ការហូបអាហារ (ភោជនីយដ្ឋានគ្រប់ប្រភេទ  ហាងលក់គ្រឿង ភេសជ្ជៈ បៀរហ្គាឌែន ឬ អាហារដ្ឋានតូចៗ...)
- កន្លែងកម្សាន្តសម្រាប់ពេលរាត្រី សុវត្ថិភាពគមនាគមន៍
- មានតំបន់វប្បធម៌ ប្រវត្តិសាស្ត្រ និងសម្បត្តិធម្មជាតិ
- តំបន់ទេសចរណ៍កែច្នៃដូចជា សួនសត្វ កាស៊ីណូ តំបន់កសិដ្ឋាន ជលវប្បដ្ឋាន សួនឧទ្យានផ្សេងៗ...។
- មានធនធានមនុស្ស និងអ្នកជំនាញគ្រប់គ្រាន់ មានសៀវភៅណែនាំភ្ញៀវ។

### ក. អំណោយផលពីធនធានធម្មជាតិ

ប្រទេសដែលទទួលទេសចរណ៍មានសក្ដានុពល ជាប្រទេសដែលអាចទាក់ទាញ ទេសចរណ៍ ពោលគឺជាប្រទេសដែលសំបូរទៅដោយអំណោយផលធម្មជាតិយ៉ាងសម្បូរបែបបដូចជា អាកាសធាតុ ទីតាំងភូមិសាស្ត្រ ដែលជាកត្តាទាក់ទាញដល់ការស្នាក់នៅរបស់ទេសចរ ប្រកបដោយផាសុកភាព។

### ខ. ការទាក់ទាញពីកេរដំណែល និងតំបន់ប្រវត្តិសាស្ត្រ

គេអាចប្រទះឃើញការទាក់ទាញកេដំណែលវប្បធម៌ នៅក្នុងទម្រង់ផ្សេងៗគ្នាទាំងទំហំ និងទីតាំងនៅលើពិភពលោក។ ចំពោះការទាក់ទាញទាំងនេះមានច្រើនប្រភេទណាស់ ដែលអាចរាប់បានតាំងពីសហគមន៍តូចមួយរហូតដល់អច្ឆរិយវត្ថុលើពិភពលោក ប៉ុន្តែតំបន់ទាក់ទាញនេះមិនអាចនិយាយត្រឹមតែសារមន្ទីរ បូជនីយដ្ឋានប្រវត្តិសាស្ត្រ ឬសម្បត្តិបុរាណវិទ្យាប៉ុណ្ណោះទេ តែគេក៏អាចរាប់បញ្ចូលនូវ សម្បត្តិធនធានធម្មជាតិដ៏អស្ចារ្យផ្សេងៗទៀតដូចជា សួនបណ្ដុះរុក្ខជាតិ ផ្សោតទឹកសាប ជលវប្បដ្ឋាន និងសួនឧទ្យានជាតិជាដើម។

### ៤.២. តំបន់ទេសចរណ៍

តំបន់ទេសចរណ៍ ជាតំបន់រមណីយដ្ឋានដែលជាកន្លែង អំណោយផលពីធម្មជាតិល្អ ស្ប៉ា (Spa) ជាកន្លែងដែលមានទឹកក្តៅផុសធម្មជាតិ ឬស្ប៉ា(Spa) ក៏ជាកន្លែងកែច្នៃ នៅតំបន់ដែលគ្មានទឹកក្តៅធម្មជាតិផុស ភាគច្រើនជាប្រភេទទេសចរមនុស្សចាស់ ដើម្បីព្យាបាលជំងឺ។ ទីក្រុងបុរាណ និងទីក្រុងប្រវត្តិសាស្ត្រក៏ជាកន្លែងដែលទេសចរចូលចិត្តស្រាវជ្រាវ និងស្វែងយល់នៃប្រវត្តិនៃការកកើតរបស់ទីកន្លែងនោះផងដែរ។ ឧទ្យានជាតិជាតំបន់ ដែលអាចទាក់ទាញទេសចរដោយមានទាំងសត្វព្រៃ និងព្រៃឈើ។ ភាពរីកចម្រើនផ្នែកសេដ្ឋកិច្ច និងស្នាដៃកសាងស្ថាបត្យកម្ម នៃអគារទំនើបៗទាន់សម័យ និងភាពទាន់សម័យនៃជីវភាពរស់នៅសម្បូរបែប ក៏ជាការទាក់ទាញទេសចរ ទៅដើម្បីស្វែងយល់អំពីជីវិតពិតនៅតាមតំបន់នីមួយៗ ដែលមានឥរិយាបថក្នុងការរស់នៅប្រពៃណីទំនៀមទម្លាប់ វប្បធម៌ សាសនា មានមិនដូចគ្នាទេនៅលើពិភពលោកយើងនេះ។

#### ក. តំបន់កែច្នៃ សួនសត្វ

បើយើងបរិយាយអំពីសួនសត្វ គឺជាតំបន់ទេសចរណ៍កែច្នៃ មួយប្រភេទដែលអាចទាក់ទាញទេសចរមកពីគ្រប់ទិសទី ដើម្បីមកទស្សនា និងសិក្សាស្វែងយល់។ សួនសត្វត្រូវបានគេបែងចែកទៅតាមលក្ខណៈនីមួយៗរបស់វាគឺ ៖

- **សួនសត្វ** (Zoos) ជាការប្រមូលផ្តុំនូវសត្វទាំងឡាយ មកដាក់មួយកន្លែង សម្រាប់ធ្វើការទាក់ទាញមនុស្សឱ្យមកទស្សនា។ សួនសត្វមានទំហំខុសៗគ្នា សួនសត្វមួយចំនួនបើកដំណើរការមិនត្រឹមតែក្នុងគោលបំណងសម្រាប់រកកម្រៃនោះទេ តែក៏ថែរក្សានូវប្រភេទសត្វដែលកម្រកុំឱ្យផុតពូជ។
- **សួនសត្វ** (Safari Park) មានលក្ខណៈល្អប្រសើរជាងសួនសត្វ ប្រភេទព្រោះថាសត្វទាំងអស់ត្រូវបានគេថែរក្សានៅក្នុងទីកន្លែង បើកចំហរមួយដែលគ្មានរបងព័ទ្ធជុំវិញ ប៉ុន្តែត្រូវបានគេផ្សាំងឱ្យនៅតែក្នុងតំបន់របស់វាមិនអាចមានចេតនាចង់ទៅកន្លែងផ្សេងទៀតឡើយ។ តែវាទាមទារនូវការ ចំណាយថវិកាច្រើន សម្រាប់បណ្តុះបណ្តាលបុគ្គលិក។
- **សួនសត្វ** (Game Preserve) សួនសត្វប្រភេទនេះ ជាទូទៅជាសួនឧទ្យានជាតិតែម្តងដែលគេអភិរក្សសត្វព្រៃ និងព្រៃដើម្បីជៀសវាងពីការកាប់បំផ្លាញដោយមនុស្ស។

#### ខ. ជលវប្បដ្ឋាន

ទោះបីជលវប្បដ្ឋានទទួលនូវប្រជាប្រិយភាព ត្រឹមតែពាក់កណ្តាលនៃការទស្សនាសួនសត្វក្តី បច្ចុប្បន្នកំពុងតែមានការរីកចម្រើនទាំងទំហំ និងការចូលរួមទស្សនា។ ជលវប្បដ្ឋានមួយចំនួនមិនមែនបើកដំណើរការរកកម្រៃនោះទេ តែគេថែមទាំងទទួលបានការគាំទ្រព្រមទាំងគ្រប់គ្រងដោយមូលនិធិ ដើម្បីថែរក្សា និងការពារជីវិតសត្វក្នុងទឹក។ ដូចជាការអភិរក្សជលវប្បដ្ឋាន នៅខេត្តក្រចេះ ស្ទឹងត្រែង ដើម្បីការពារផ្សោតទឹកសាប ដែលជាប្រភេទសត្វកម្រ។

#### គ. កត្តាធនធានមនុស្ស

អំណោយផលធនធានធម្មជាតិសម្បូរបែបយ៉ាងណាក៏ដោយ ប្រសិនបើយើងជាម្ចាស់ប្រទេសមិនចេះយកមកប្រើប្រាស់ផងនោះ យើងនៅតែពុំអាចអភិវឌ្ឍវិស័យទេសចរណ៍ឱ្យរីកចម្រើនបានដែរ ដើម្បីយក

ធនធានធម្មជាតិទាំងនោះមកប្រើបាន គឺទាមទារនូវអ្នកមានជំនាញច្បាស់លាស់ និងមានសមត្ថភាពខាងវិស័យទេសចរណ៍ ចេះចាត់ចែង រៀបចំទទួលភ្ញៀវ បំពេញបំណងធ្វើឱ្យអ្នកទេសចរពេញចិត្តជាប់ចិត្តហើយមានបំណងត្រលប់មកវិញម្តងទៀត។

**ឃ. ការទាក់ទាញ**

តំបន់ដែលមានលទ្ធភាពទាក់ទាញទេសចរ បានច្រើនជាងគេ គឺតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ និងតំបន់ទេសចរណ៍ធម្មជាតិ។ ការទាក់ទាញទេសចរ អាស្រ័យទៅលើកត្តាជាច្រើនដូចជាការផ្សព្វផ្សាយតាមរយៈមធ្យោបាយផ្សេងៗ ទោះបីជាតាមរយៈជាសមូហភាពសង្គមជាលក្ខណៈបុគ្គល តាមរយៈបណ្តាញសង្គម វិនិយោគទុន ការទស្សនកិច្ចផ្លូវការ ទស្សនកិច្ចសិក្សាក៏ដោយ យើងត្រូវប្រើប្រាស់ឱ្យអស់លទ្ធភាពតាមដែលអាចធ្វើទៅបាន។

**ង. ហេដ្ឋារចនាសម្ព័ន្ធ**

ជាលក្ខខណ្ឌសេដ្ឋកិច្ចដែលមានអំពើផ្ទាល់ទៅលើលទ្ធភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍។ ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសមិនរីកចម្រើន ទោះបីជាធម្មជាតិអំណោយផលយ៉ាងណាក៏ដោយ ក៏គ្មានលទ្ធភាពស្រូបយកទេសចរបានតាមបំណងដែរ។ ទេសចរ ត្រូវការផ្លូវគមនាគមន៍ដែលងាយស្រួល តម្លៃថោកសមរម្យ មានការប្រដែងនៅលើសេវាកម្មនៃការបម្រើ និងលើតម្លៃ។

**ច. ផ្ទះសំណាក់ទេសចរណ៍**

ការស្នាក់នៅរបស់ទេសចរ ប្រែប្រួលទៅតាមកម្រិតជីវភាពរបស់ភ្ញៀវ តាមស្ថានភាពនៃទីកន្លែង ហើយតម្លៃនៃការលក់បន្ទប់ក៏មានការប្រែប្រួលពេញមួយឆ្នាំផងដែរ អាស្រ័យទៅតាមរដូវកាលនៃទេសចរណ៍។ ផ្ទះសំណាក់ទេសចរណ៍មានច្រើនប្រភេទដូចជា សណ្ឋាគារ ម៉ូតែល បឹងកាឡូ ផ្ទះសំណាក់។ល។

**ឆ. ភោជនីយដ្ឋាន**

ក្នុងឧស្សាហកម្មអាហារមានហាងជាច្រើនប្រភេទ សម្រាប់ផ្តល់អាហារទាំងនោះដល់ភ្ញៀវ បច្ចុប្បន្នមានហាងជាច្រើនរង់ចាំទទួលស្វាគមន៍ភ្ញៀវដូចជា ភោជនីយដ្ឋាន ភោជនីយដ្ឋានក្នុងសណ្ឋាគារ ដែលបម្រើដោយខ្លួនឯង និងអាហារដ្ឋាន ។

៨ បុគ្គលិកបម្រើសេវាកម្ម

មគ្គុទេសក៍ជាអ្នកទទួលខុសត្រូវ ក្នុងការដឹកនាំភ្ញៀវក្នុងដំណើរកម្សាន្ត ក្នុងតំបន់ទេសចរណ៍។ មគ្គុទេសក៍ទាមទារនូវជំនាញពិតប្រាកដ ជាពិសេសភាសាបរទេស ចំណេះដឹងប្រវត្តិសាស្ត្រ វប្បធម៌ច្បាស់លាស់ ព្រមទាំងចេះអត់ធ្មត់ និងម្មត់ចត់ទៀតផង។ អ្នកជូនដំណើរទេសចរត្រូវបានក្រុមហ៊ុនទេសចរណ៍បញ្ជូនមកដើម្បីជួយមើលការខុសត្រូវ និងមើលបម្រើទេសចរដូចជាកន្លែងស្នាក់នៅ ការញ៉ាំអាហារ រកកន្លែងកម្សាន្ត និងការពារសុវត្ថិភាពទេសចរ។

**ឋ. សេវាកម្មមធ្យោបាយដឹកជញ្ជូន**

នៅក្នុងវិស័យទេសចរណ៍ ការផ្លាស់ផ្លូរពីទីកន្លែងមួយទៅទីកន្លែងមួយអាស្រ័យទៅលើមធ្យោបាយដឹកជញ្ជូន។ ការដឹកជញ្ជូនទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ធ្វើឱ្យងាយស្រួលក្នុងការប្រើប្រាស់ពេលវេលាជាក់លាក់ សន្សំពេលវេលា សន្សំលុយកាក់ និងសេវាកម្មរហ័សទាន់ចិត្ត។

**សំណួរត្រិះរិះ**

១. ចូរបង្ហាញអំពីមុខងារនៃវិស័យទេសចរណ៍។

២. តើវិស័យទេសចរណ៍មានជាតុផ្សំអ្វីខ្លះ? ចូររៀបរាប់។

៣. ចូរបរិយាយអំពីកត្តាផ្សេងៗ ដែលជះឥទ្ធិពលលើការអភិវឌ្ឍវិស័យទេសចរណ៍?

៤. ដើម្បីធ្វើដំណើរកំសាន្តនៅបរទេសដោយស្របច្បាប់ តើទេសចរត្រូវមានឯកសារអ្វីខ្លះ?

៥. តើលិខិតឆ្លងដែនជាអ្វី? មានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូររៀបរាប់។

៦. តើទិដ្ឋាការជាអ្វី? មានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូររៀបរាប់។

៧. ហេតុអ្វីចាំបាច់មានភ្នាក់ងារគយនៅប្រចាំតាមព្រំដែន ឬព្រំប្រទល់ប្រទេសនីមួយៗ?

៨. ដូចម្តេចដែលហៅថាទំនិញរួចពន្ធ? តើទេសចរត្រូវទទួលបានសម្បទាពន្ធអ្វីខ្លះ?

៩. តើអ្វីខ្លះជាលទ្ធភាពក្នុងតំបន់ទេសចរណ៍ ដែលត្រូវរៀបចំដើម្បីការមកដល់របស់ទេសចរ?

១០.តើគេចែកសួនសត្វជាប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរបញ្ជាក់។

១១.តើត្រូវមានមធ្យោបាយអ្វីខ្លះ ដើម្បីរក្សាចំណាប់អារម្មណ៍ពេលធ្វើសកម្មភាពទេសចរណ៍?

# មេរៀនទី៣៖ សញ្ញាណទូទៅនៃអេកូ-ទេសចរណ៍ និងប្រព័ន្ធតំបន់ការពារធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជានៃអេកូ-ទេសចរណ៍

## ១.សញ្ញាណទូទៅនៃអេកូ-ទេសចរណ៍

### ១.១. អ្វីទៅជាអេកូ-ទេសចរណ៍?

ពាក្យថា អេកូទេសចរណ៍ Eco-Tourism ត្រូវបានបង្កើតឡើងដោយពាក្យពីគឺ ៖

១- Ecology បានមកពីពាក្យ អេកូឡូស៊ី មានន័យថា បរិស្ថានវិទ្យា។

២- Tourism មានន័យថាទេចរណ៍។

ជាទូទៅពាក្យថា អេកូទេសចរណ៍ Eco-Tourism មានន័យថា ទេសចរណ៍បរិស្ថាន ឬក៏យើងអាចហៅបានថា ជាប្រភេទទេសចរណ៍ ដែលផ្តោតការយកចិត្តទុកដាក់លើការថែរក្សា ការពារ និងមានទំនាក់ទំនងនឹងការអភិវឌ្ឍធនធានធម្មជាតិ និងវប្បធម៌មូលដ្ឋាន សហគមន៍ នៅតាមតំបន់ទេសចរណ៍នោះ។

### ក.ការកំណត់និយមន័យអេកូ-ទេសចរណ៍

ពាក្យថា អេកូ-ទេសចរណ៍ (Eco-Tourism) គឺជាទស្សនាទានថ្មីមួយនៅក្នុងវិស័យ ទេសចរណ៍ ហើយវាត្រូវបានគេយល់ច្រឡំ និងមានការប្រើប្រាស់ខុស ចាប់តាំងពីពាក្យ នេះត្រូវបានគេដឹងឮ ជាលើកដំបូងក្នុងទស្សវត្សរ៍ឆ្នាំ ១៩៨០ មកម្លេះ។ មនុស្សមួយចំនួនបានឆ្លៀតយកពាក្យថា អេកូ-ទេសចរណ៍នេះ ប្រើប្រាស់ដើម្បីទាក់ទាញអ្នកធ្វើដំណើរឱ្យទៅកាន់តំបន់អ្វីមួយ ដែលមានការ ថែរក្សា និងតំបន់ការពារធម្មជាតិតែតាមពិត គឺជាកម្មវិធីទេសចរណ៍ធម្មជាតិសាមញ្ញ ហើយអាចបណ្តាលឱ្យមានផលប៉ះពាល់ អវិជ្ជមានទៅលើបរិស្ថាន និងសង្គម។ ការកំណត់និយមន័យទៅលើពាក្យថា អេកូទេសចរណ៍បានកើតឡើងចាប់តាំងពីឆ្នាំ ១៩៨៧ មកម្លេះ។ តាមរយៈការសិក្សាយើង ឃើញថា មានការកំណត់និយមន័យយ៉ាងច្រើនជាបន្តបន្ទាប់ ដែលទាក់ទងទៅនឹងអេកូទេចរណ៍នេះ តែនិយមន័យដែលគេទទួលស្គាល់ជាទូទៅ និងមានអត្ថន័យ ត្រឹមត្រូវ គឺជានិយមន័យ ដែលបង្កើតឡើងដោយសមាគមអេកូ-ទេសចរណ៍អន្តរជាតិក្នុងឆ្នាំ១៩៩០។ ខាងក្រោមនេះ គឺជានិយមន័យអេកូ-ទេសចរណ៍មួយចំនួនដែលបានកំណត់ជាបន្តបន្ទាប់ដូចជា ៖

- **អេកូ-ទេសចរណ៍** គឺជាដំណើរកំសាន្ត ដោយមានការទំនួលខុសត្រូវលើបរិស្ថាន ហើយការកំសាន្តនោះមិនបានធ្វើឱ្យមានការប៉ះពាល់ដល់ធម្មជាតិ ពោលគឺជាដំណើរកំសាន្តក្នុងគោលបំណងសប្បាយរីករាយ និងឱ្យតម្លៃលើធម្មជាតិព្រមទាំងជំរុញនូវការអភិរក្ស ផលប៉ះពាល់អវិជ្ជមាន និងការផ្តល់ឱ្យប្រជាពលរដ្ឋមូលដ្ឋានទទួលបាន អត្ថប្រយោជន៍សេដ្ឋកិច្ច ពីធម្មជាតិនោះ។
- **អេកូ-ទេសចរណ៍** គឺជាការធ្វើដំណើរកំសាន្តទៅតំបន់ធម្មជាតិ ក្នុងនោះទេសចរ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដោយជួយអភិរក្សបរិស្ថាន និងចូលរួមធ្វើឱ្យសុខមាលភាពសហគមន៍មូលដ្ឋានប្រសើរឡើង។
- **អេកូ-ទេសចរណ៍** គឺជាទេសចរណ៍អាស្រ័យធម្មជាតិ ហើយទេសចរណ៍ប្រភេទ នេះត្រូវមានការទាក់ទងនឹងការអប់រំ ការបកស្រាយអំពីបរិស្ថានធម្មជាតិ និងការរៀបចំគ្រប់គ្រងអេកូ-ទេចរណ៍នេះប្រកបដោយចីរភាព។

- **អេកូ-ទេសចរណ៍** គឺជាដំណើរកំសាន្ត ដែលមានទំនួលខុសត្រូវខ្ពស់ និងជំរុញការអភិរក្សធម្មជាតិ និងធ្វើយ៉ាងណាឱ្យមាននិរន្តរភាពនូវការរស់នៅជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

ដោយផ្អែកលើនិយមន័យផ្សេងៗជាច្រើនខាងលើ និងយោងតាម TES បានកំណត់ អេកូ- ទេសចរណ៍ ដោយយោងទៅលើមូលដ្ឋានសំខាន់ៗ ៧ ចំណុចដូចជា ៖

- ត្រូវចៀសវាងឱ្យបាននូវផលអវិជ្ជមាន ដែលអាចនឹងបំផ្លាញនូវលក្ខណៈដើមនៃធនធានធម្មជាតិ ឬវប្បធម៌នៅតំបន់ទេចរណ៍។
- ភ្នាក់ងារទេសចរណ៍ ត្រូវធានាឱ្យបាននូវការពន្យល់បកស្រាយយ៉ាងច្បាស់លាស់ស្តីអំពីប្រព័ន្ធអេកូឡូស៊ីធនធានធម្មជាតិ និងមរតកវប្បធម៌ដល់ភ្ញៀវទាំងឡាយ ដែលបានទៅដល់តំបន់ទេសចរណ៍ ពីព្រោះយើងដឹងហើយថា អេកូ-ទេសចរណ៍ គឺជាប្រភេទទេសចរណ៍អប់រំ និងស្រាវជ្រាវវិទ្យាសាស្ត្រ។
- ការបែងចែកផលប្រយោជន៍ឱ្យមានសមភាព ដល់ប្រជាជននៅក្នុងសហគមន៍ និងជនអន្តោគ្រាម ពីព្រោះថាអ្នកទាំងនេះហើយគឺជាម្ចាស់នៃធនធានទាំងឡាយ ផលប្រយោជន៍ទាំងនោះរួមបញ្ចូលទាំងការចូលរួមក្នុងសកម្មភាពទេសចរណ៍ និងការធ្វើផែនការអភិវឌ្ឍសហគមន៍។
- ផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចដល់ប្រជាជនសហគមន៍ និងផ្តល់ការងារអភិរក្សដល់ពួកគេ។
- ទេសចរណ៍ប្រភេទនេះ មិនអនុញ្ញាតឱ្យមានរៀបចំជាក្រុមធំបានឡើយ ហើយក៏មិនអនុញ្ញាតឱ្យមានចំនួនអ្នកទស្សនាច្រើនពេកក្នុងពេលតែមួយបានដែរ។ ម្យ៉ាងទៀត ត្រូវធានាការអភិវឌ្ឍទេសចរណ៍មិនបានប៉ះពាល់ដល់បរិស្ថាន ជាពិសេសនោះ ត្រូវតែគិតគូរដល់ការបង្កើតសមត្ថភាពដើម្បីគ្រប់គ្រងបរិស្ថានធម្មជាតិ និងសង្គម។
- ត្រូវប្រើប្រាស់ធនធានក្នុងសហគមន៍ឱ្យអស់លទ្ធភាពជាពិសេសកម្លាំងពលកម្ម
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធត្រូវគិតគូរអំពីការបំពុលបរិស្ថាន ការរំខានផលការរីកលូតលាស់នៃរុក្ខជាតិ និងសត្វតាមរយៈសំឡេង កាកសំណល់ និងផ្សែងពុល...។

រួមសេចក្តីមក អេកូ-ទេសចរណ៍ គឺជាទស្សនវិស័យមួយដែលមានការរីកចម្រើន អំពីតម្រូវការដើម្បីធ្វើតាមគោលដៅមួយនៃការអភិរក្សធនធានធម្មជាតិ ដោយមានការទទួលស្គាល់ជាទូទៅ និង មានលក្ខណៈត្រឹមត្រូវពីសំណាក់មហាជនដែលរស់នៅក្នុងតំបន់នីមួយៗ។ ជាមួយគ្នានេះដែរ អេកូ-ទេសចរណ៍មានកាតព្វកិច្ចការពារតំបន់ធម្មជាតិ ដើម្បីបម្រើដល់ការកំសាន្ត នូវទេស្សនីយភាពធម្មជាតិ និងវប្បធម៌សង្គម ព្រមទាំងដើម្បីការអប់រំស្តីអំពីអត្ថប្រយោជន៍របស់សហគមន៍ ចូលរួមអភិរក្សហើយធនធានធម្មជាតិ ធនធានវប្បធម៌ ជនជាតិ និងប្រព័ន្ធអេកូឡូស៊ី។

**អេកូ-ទេសចរណ៍** គឺជាដំណើរកំសាន្ត ដែលមានការទំនួលខុសត្រូវ លើបរិស្ថានហើយការ កំសាន្តនោះមិនបានធ្វើឱ្យមានការប៉ះពាល់ដល់ធម្មជាតិ ពោលគឺជាដំណើរកំសាន្តក្នុង គោលបំណងសប្បាយរីករាយ និងឱ្យតម្លៃលើធម្មជាតិព្រមទាំងជំរុញនូវការអភិរក្សផលប៉ះពាល់អវិជ្ជមាន និងការផ្តល់ឱ្យប្រជាពលរដ្ឋមូលដ្ឋានទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចពីធម្មជាតិនោះ។

**អេកូ-ទេសចរណ៍** គឺជាការធ្វើដំណើរកំសាន្តទៅតំបន់ធម្មជាតិក្នុងនោះទេសចរត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយជួយអភិរក្សបរិស្ថាន និងចូលរួមធ្វើឱ្យសុខមាលភាពសហគមន៍ ឬមូលដ្ឋានប្រសើរឡើង។

**អេកូ-ទេសចរណ៍** គឺជាទេសចរណ៍អាស្រ័យធម្មជាតិ ហើយទេសចរណ៍ប្រភេទនេះ ត្រូវមានការទាក់ទងជាមួយនឹងការអប់រំ ការបកស្រាយអំពីបរិស្ថានធម្មជាតិ និងការរៀបចំគ្រប់គ្រងអេកូ-ទេចរណ៍នេះប្រកបដោយចីរភាព។

**អេកូ-ទេសចរណ៍** គឺជាដំណើរកំសាន្តដែលមានទំនួលខុសត្រូវខ្ពស់ និងជំរុញការអភិរក្សធម្មជាតិ និងធ្វើយ៉ាងណាឱ្យមាននិរន្តរភាព នូវការរស់នៅជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

**ខ.សមាហរណកម្ម ការអភិវឌ្ឍ និងការអភិរក្សអេកូទេសចរណ៍**

កាលនៅមិនទាន់មានប្រភេទអេកូ-ទេសចរណ៍ គេសង្កេតឃើញមានប្រទេសជាច្រើនបានប្រើប្រាស់ធនធានធម្មជាតិ សម្រាប់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិរបស់ខ្លួនដូចជា ការកាប់ឆ្ការព្រៃ ការចិញ្ចឹមសត្វតាមទីវាល ការជីកយករ៉ែ និងការធ្វើកសិកម្មជាដើម ...។

អេកូ-ទេសចរណ៍ Eco-Tourism ក៏ត្រូវការមានការអភិវឌ្ឍខ្លួនឯងដែរ ថ្វីត្បិតតែជាទេសចរណ៍ម្យ៉ាងដែលត្រូវការធនធានធម្មជាតិ និងវប្បធម៌ ក៏ជាប្រភពទាក់ទាញភ្ញៀវទេសចរដែរ។ ការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធ ដោយរួមបញ្ចូលទាំងមធ្យោបាយធ្វើដំណើរ កន្លែងស្នាក់នៅ និងសកម្មភាពផ្សេងៗ ទៀតសម្រាប់អ្នកទេចរ ដែលគេមិនសូវខ្វល់ខ្វាយអំពីកន្លែស្នាក់នៅជាប្រភេទសណ្ឋាគារធំៗ ភោជនីយដ្ឋានធំៗ និងទំនើបនោះឡើយ គឺគេចង់បានបែបធម្មជាតិ ដែលស្រស់បំព្រង។

ការផ្តល់កន្លែងស្នាក់នៅដែលមានផលប៉ះពាល់ដល់បរិស្ថានតិចតួចបំផុតដូចជា ផ្ទះសំណាក់ ក្នុងភូមិធម្មតា ឬបន្ទប់គេងដែលស្ថិតនៅក្នុងផ្ទះប្រជាជន Home Stay សុទ្ធសឹងតែជាតម្រូវការ និង ការចង់បានរបស់ភ្ញៀវប្រភេទអេកូ-ទេសចរណ៍។

វិស័យទេសចរណ៍ ជាអាវុធមុខពីរ ជាមួយនឹងការធ្វើផែនការត្រឹមត្រូវ និងមានការរីកចម្រើនក្នុងល្បឿនយឺតៗ ដូចនេះ អេកូ-ទេសចរណ៍មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចប៉ុណ្ណោះទេ ថែមទាំងអាចធ្វើការអភិរក្សប្រភពធនធានទាំងឡាយបានទៀតផង។

ទេសចរណ៍ជាប្រភេទឧស្សាហកម្មដែលងាយប្រែប្រួល ព្រោះវាពឹងផ្អែកទាំងស្រុងលើឥទ្ធិពលមិនប្រាកដប្រជាមួយដូចជា អាកាសធាតុ ឬអស្ថិរភាពនយោបាយជាដើម។

**១.២. អត្ថប្រយោជន៍អេកូទេសចរណ៍**

កាលពីពុំទាន់មានអេកូ-ទេសចរណ៍ គេសង្កេតឃើញមានប្រទេសជាច្រើនបានប្រើប្រាស់ធនធានធម្មជាតិ សម្រាប់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិរបស់ខ្លួន។ ការកាប់ឆ្ការព្រៃ ការចិញ្ចឹមសត្វលើទីវាល ការជីករុករករ៉ែ និងការធ្វើកសិកម្មជាដើម ដែលជាដើមហេតុនៃការប្រើប្រាស់ប្រភព ដើមនៃធន ជានធម្មជាតិ។

អេកូ-ទេសចរណ៍ ក៏ត្រូវការឱ្យមានការអភិវឌ្ឍលើខ្លួនវាដែរ ថ្វីត្បិតតែវាជាប្រភេទទេសចរណ៍ម៉្យាងដែលត្រូវការធនធានធម្មជាតិ និងវប្បធម៌ជាប្រភពទាក់ទាញទេសចរក៏ដោយ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដោយរួមបញ្ចូលទាំងមធ្យោបាយធ្វើដំណើរ កន្លែងស្នាក់នៅ និងសកម្មភាពផ្សេងៗទៀតសម្រាប់ទេសចរ។ ការផ្តល់កន្លែង ស្នាក់ នៅដែលមានផលប៉ះពាល់តិចតួចទៅលើបរិស្ថានដូចជា ផ្ទះសំណាក់ធម្មតា ឬបន្ទប់គេងដែលស្ថិតក្នុងផ្ទះអ្នកភូមិសុទ្ធសឹងតែជាតម្រូវការ និងការចង់បានរបស់ភ្ញៀវប្រភេទអេកូ-ទេសចរណ៍នេះ។

ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ដែលបានមកពីវិស័យទេសចរណ៍ គួរតែត្រូវបានបែងចែកដោយសមធម៌ទៅដល់ដៃប្រជាជនដែលរស់នៅក្បែរតំបន់ការពារនោះ រដ្ឋាភិបាល និងទីភ្នាក់ងារទេសចរណ៍ផ្សេងៗទៀត តាមរយៈប្រាក់ចំណូល អេកូ-ទេសចរណ៍ ពិតជាបានចូលរួមចំណែក ក្នុងការលើកកម្ពស់តំហែទាំសុខភាព និងការអប់រំទៅដល់ប្រជាជន ក្នុងមូលដ្ឋានព្រមទាំងផ្តល់ ការងារជាច្រើននៅក្នុងសហគមន៍ និងក្នុងមូលដ្ឋានព្រមទាំងផ្តល់ការងារ ជាច្រើននៅក្នុងឧស្សាហកម្មទេសចរណ៍។

វិស័យទេសចរណ៍ជាកាំបិតមុខពីរ ជាមួយនឹងការធ្វើផែនការត្រឹមត្រូវ និងមានការរីកចម្រើនក្នុងល្បឿនយឺតៗ ដូចនេះអេកូទេសចរណ៍មិនត្រឹមតែអាចផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ក្នុងតំបន់ប៉ុណ្ណោះទេ ថែមទាំងអាចធ្វើការអភិរក្សប្រភពធនធានទាំងឡាយបានទៀតផង ទោះបីជាយ៉ាងណាក៏ដោយ ការរីកចម្រើនយឺតៗ និងការអភិវឌ្ឍដែលមានផលប៉ះពាល់អប្បរមា មិនប្រាកដជាផ្តល់លទ្ធផលដូច្នោះដែរ។ ទេសចរណ៍ ជាប្រភេទឧស្សាហកម្មដែលងាយប្រែប្រួលពីព្រោះវាពឹងផ្អែកទាំងស្រុងទៅលើឥទ្ធិពលមិនប្រាកដប្រជាដូចជា អាកាសធាតុ ឬស្ថិរភាពនយោបាយជាដើម។ ដូច្នេះ ការអភិវឌ្ឍតំបន់មួយឱ្យទៅជាតំបន់ទេសចរណ៍អាចប្រឈមមុខទៅនឹងបញ្ហាទ្វេរគ្រោះថ្នាក់ផ្សេងៗទៀតដូចជា ផែនការទេសចរណ៍នោះពុំបានទាក់ទាញភ្ញៀវចូលមកទស្សនាឱ្យបានគ្រប់គ្រាន់ ឬការចូលមករបស់ភ្ញៀវមានចំនួនច្រើនលឿនពេក ដែលពុំអាចតម្រូវការរបស់ពួកគេទាន់ពេលវេលា។

ការអភិវឌ្ឍអេកូ-ទេសចរណ៍ចាំបាច់ជាការអភិវឌ្ឍ ដែលប្រកបដោយនិរន្តភាពចំពោះធនធានធម្មជាតិដែលស្ថិតនៅក្នុងតំបន់ការពារ ដើម្បីជំនួសការប្រព្រឹត្តពីមុនដូចជាការកាប់បំផ្លាញព្រៃឈើជាដើម។ កម្មវិធីអភិវឌ្ឍអេកូ-ទេសចរណ៍បានជួយការកាត់បន្ថយតម្រូវការរបស់ប្រជាជនក្នុងសហគមន៍ ដែលតែងតែទាក់ទាញយកផលប្រយោជន៍ពីការប្រើប្រាស់ធនធានធម្មជាតិ។

## ១.៣. ឥទ្ធិពលអេកូ-ទេសចរណ៍ទៅលើវិស័យផ្សេងៗ

### ក.ឥទ្ធិពលអេកូ-ទេសចរណ៍ទៅលើវិស័យសេដ្ឋកិច្ច

ការនាំមកនូវរូបិយប័ណ្ណចូលទៅក្នុងតំបន់ការពារ ជាកង្វល់របស់អ្នកអភិរក្ស។ មូលនិធិ ដែលអាចរកបានរបស់រដ្ឋាភិបាល សម្រាប់តំបន់ការពារជាទូទៅកំពុងមានការថមថយ ហើយតំបន់ធម្មជាតិសំខាន់ៗមួយចំនួននឹងមិនអាចបន្តមានជីវិត ដោយគ្មានប្រភពចំណូលថ្មីនោះឡើយ ទេសចរណ៍ផ្តល់ ឱកាសបង្កើនប្រាក់ចំណូលនៅក្នុងយុទ្ធសាស្ត្រដូចជា តម្លៃចូលទស្សនា ការប្រើប្រាស់សេវាកម្ម និង ផ្នែកផ្សេងៗទៀត ម្យ៉ាងវិញទៀតក៏មានប្រភេទការងារផ្សេងៗទៀត ដែលកើតមានដោយប្រយោល តាមរយៈវិស័យទេសចរណ៍ក្នុងករណីខ្លះ ប្រជាជនក្នុងសហគមន៍អាចជាបេក្ខភាពដ៏សមស្របបំផុតសម្រាប់ការងារមគ្គុទេសក៍ទេសចរណ៍ដោយសារពួកគេមានការយល់ដឹងបានច្បាស់លាស់ អំពីទីតាំងភូមិសាស្ត្រ និង បរិយាកាសមូលដ្ឋានរបស់ខ្លួន។

ភ្ញៀវទេសចរ ដែលមកទស្សនាកំសាន្ត បានជំរុញឱ្យសេដ្ឋកិច្ចមានភាពរីកលូតលាស់ នៅក្នុងកម្រិតមូលដ្ឋានកម្រិតតំបន់ និងកម្រិតជាតិប្រសិនបើភ្ញៀវទេសចរនាំមកនូវការងារដល់ប្រជាជននៅកម្រិតមូលដ្ឋាននោះបន្ទាប់មកពួកគេនឹងមានប្រាក់បន្ថែមទៀត សម្រាប់ការចំណាយ នៅក្នុងមូលដ្ឋាន ហើយសកម្មភាពសេដ្ឋកិច្ច នៅក្នុងតំបន់នឹងកើនឡើងជាបន្តបន្ទាប់ពីមួយថ្ងៃទៅមួយថ្ងៃ។

នៅពេលដែលសហគមន៍ មានចំណែកនៅក្នុងការអភិវឌ្ឍអេកូ-ទេសចរណ៍ មានន័យថាប្រភពចំណូលថ្មីអាចត្រូវបានបង្កើនឡើងសម្រាប់សហគមន៍គឺ ជាការបង្កើតឱកាសចំណូលដែលសហគមន៍ទទួលបានគឺ អាចកាត់បន្ថយការពឹងអាស្រ័យទៅលើសកម្មភាពដែលផ្តល់ផលអវិជ្ជមានផ្សេងៗទៀតបានដូចជាការកាប់ព្រៃឈើ ការជួញដូរសត្វព្រៃ។ ការលក់ដូរសត្វព្រៃ និង ផ្នែកផ្សេងទៀតដូចជា ព្រៃឈើ ជាមធ្យោបាយមួយដ៏គាប់ប្រសើរដែលមានពីមុន។ ការលក់ឈើប្រណិតៗនៅតំបន់ត្រូពិចក៏បាន នាំមកនូវប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ផងដែរ។ តម្រូវការចំពោះផលិតផលទាំងនេះ ដែលចេះតែកើន ឡើងឥតឈប់ឈរបានជំរុញឱ្យមានការធ្លាក់ចុះនូវពូជសត្វមួយចំនួន ហើយគ្រោះថ្នាក់ជាងនេះទៅទៀត គឺមានពូជសត្វខ្លះកំពុងតែប្រឈមមុខទៅនឹងការផុតពូជ ដូច្នេះវាមានសារៈសំខាន់ក្នុងការស្វែងរកដំណោះស្រាយ ដើម្បីរារាំងសកម្មភាពទាំងអស់នេះ។

ជាក់ស្តែងនៅក្នុងការលើកយកឧទាហរណ៍មកបញ្ជាក់ ៖ គម្រោងអភិរក្សសត្វស្វាភ្នំដែលធំជាងគេនៅអាព្រិច Mountain Gorilla Project ការចាប់ផ្តើមឡើងដោយមានអ្នកទស្សនមិនលស់ ៥០នាក់ ហើយប្រាក់ចំណូលទទួលបានមានមិនដល់ ២ ពាន់ដុល្លារផងនោះ... ស្រាប់តែរយៈពេល ១០ ឆ្នាំក្រោយមកមានភ្ញៀវទេសចរជាមធ្យម ៥០០០នាក់/ប្រចាំឆ្នាំ ដើម្បីទស្សនា Mountain Gorilla Project។ ទេសចរបានចំណាយប្រាក់ជាងជិត២០០ដុល្លារ/ម្នាក់ ដូច្នេះ ឧទ្យាននេះអាចរកប្រាក់ចំណូលជាប្រចាំឆ្នាំបានជិត ១ លានដុល្លារ។ បន្ថែមពីលើនេះទៅទៀត គេបានប៉ាន់ប្រមាណថា អ្នកទេសចរទាំងនោះបានចំណាយប្រាក់ ៦០០លានដុល្លារបន្ថែមទៀតដែលប្រហែលជា ៣ លានដុល្លារជាប្រចាំឆ្នាំ ចំណូលប៉ាន់ស្មានដែលបានមកពីប្រភពទាំងឡាយដែលទាក់ទងទៅនឹងវិស័យទេចរណ៍ជាសរុបមានពី ៦ ទៅ៨ លានដុល្លារ/ឆ្នាំ។

### ខ.ឥទ្ធិពលអេកូ-ទេសចរណ៍ទៅលើសង្គម

ឥរិយាបថនៃការរស់នៅជនជាតិដើម ជារឿយៗជាប្រភពនៃការទាក់ទាញភ្ញៀវអេកូ-ទេចរណ៍មួយផងដែរ ក្នុងមូលហេតុនេះហើយបានជាអេកូ-ទេសចរណ៍ជាប្រភេទឧស្សាហកម្មមួយ ដែលទាមទារ ឱ្យមានការអភិរក្សវប្បធម៌ជនជាតិដើម។ ជំនាញវិជ្ជាជីវៈ ដែលជាទំនៀមទម្លាប់ដូចជា ការសាងសង់គេហដ្ឋាន សិល្បៈនិងហត្ថកម្មជាដើម គឺមានសារៈប្រយោជន៍ ក្នុងការអភិវឌ្ឍផលិតផលទេចរណ៍ អ្នករបាំ និងតន្ត្រីករអាចសម្តែងឱ្យទេសចរទស្សនា រីឯរបស់របរធ្វើពីដៃក៏គេលក់ទៅឱ្យភ្ញៀវទេសចរបានផងដែរ។

នៅប៉ាពួគីណេថ្មី (Papua New Guinea) ក្នុងឆ្នាំ១៩៩០ Bates បានបញ្ជាក់ថា ឱកាសការងារនៅផ្ទះ ភ្ញៀវទេចរ ដែលទស្សនាតំបន់ដាច់ស្រយាល សម្រាប់យុវជនហ៊ូលី ជាហេតុផលឱ្យពួក គេរស់នៅក្នុងតំបន់កុលសម្ព័ន្ធ ដែលជាទំនៀមទម្លាប់របស់ខ្លួនជាជាងការធ្វើដំណើរចូលទៅក្នុងទីក្រុង ដើម្បីស្វែងរកការងារធ្វើ។ ការអប់រំទៅដល់យុវជនឱ្យស្គាល់ពីទំនៀមទម្លាប់វប្បធម៌របស់ខ្លួន ក៏ជាផ្នែកមួយក្នុងការជំរុញឱ្យមានការអភិរក្សព្រមទាំងជាប្រភពនាំមកនូវចំណូលផងដែរ។

### គ.ឥទ្ធិពលអេកូ-ទេសចរណ៍ទៅលើវិស័យវប្បធម៌

ឥទ្ធិពលសង្គម-វប្បធម៌មានអន្តរទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងប្រជាជនក្នុងសហគមន៍ដោយផ្ទាល់ និងដោយប្រយោលផងដែរ ជារឿយៗប្រជាជននៅក្នុងសហគមន៍តែងតែទទួលឥទ្ធិពលនូវវប្បធម៌

ចំណូលថ្មី។ អ្នកទេសចរតែងនាំមកនូវទំនៀមទម្លាប់ថ្មីៗ ដែលអាចនឹងធ្វើឱ្យទំនៀមទម្លាប់ដើមរបស់ពួកគេមានការផ្លាស់ប្តូរ។ អេកូ-ទេសចរណ៍ត្រូវតែថែរក្សា និងអភិរក្សវប្បធម៌ឱ្យបានល្អប្រសើរ។

វប្ប-ធម៌រួមមាន ៖

- សិប្បកម្មតម្បាញ (ហូល ផាមួង សូត្រ ក្រម៉ា កន្ទេល...)
- សិប្បកម្មចម្លាក់ (ថ្ម ឈើ ស្បែកសត្វ ប្រាក់ មាស...)
- សំណង់អគារ បេតិកភណ្ឌជាតិ អគារអាណានិគម
- សិល្បៈ តន្ត្រី និងរបាំ ( ប្រពៃណី ឬ បុរាណ និងសម័យទំនើប)
- ទំនៀមទម្លាប់ក្នុងការរស់នៅរបស់ពួកអន្តោគ្រាម។

**ឃ.ឥទ្ធិពលអេកូ-ទេសចរណ៍ទៅលើវិស័យបរិស្ថាន**

វិស័យទេសចរណ៍ និងបរិស្ថានមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតជាមួយគ្នា។ វិស័យទេសចរណ៍ពឹងផ្អែកទៅលើបរិស្ថាន ក្នុងគោលបំណងច្រើនប្រភេទនៃលក្ខណៈទាក់ទាញទេសចរជាពិសេស។ ប្រសិនបើមានការអភិវឌ្ឍវិស័យទេសចរណ៍ វាអាចនឹងផ្តល់នូវផលប៉ះពាល់ជាច្រើនទៅលើបរិស្ថាន ដោយផ្តល់ទាំងផលវិជ្ជមាន និងអវិជ្ជមានផង។

**ផលវិជ្ជមាន**

ប្រសិនបើយើងបានរៀបចំផែនការអភិវឌ្ឍ និងគ្រប់គ្រងបានល្អនោះ វិស័យទេសចរណ៍អាចបង្កើតនូវផលប្រយោជន៍ជាច្រើនទៅលើបរិស្ថាន ដែលក្នុងនោះរួមមាន ៖

- ជួយថែរក្សា និងទទួលខុសត្រូវលើតំបន់ធម្មជាតិជាសំខាន់ ( ឧទ្យានជាតិ និងតំបន់បម្រុងទុក) និងសត្វដែលរស់នៅក្នុងតំបន់នោះ ដោយគិតទាំងបរិស្ថានសមុទ្រ ពីព្រោះទីកន្លែងនោះជាកន្លែងដែលទាក់ទាញបំផុតសម្រាប់ទេសចរ។
- ថែរក្សា និងទទួលខុសត្រូវលើរមណីយដ្ឋានបុរាណវិទ្យា តំបន់ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណនានា ដែលជាទីទាក់ទាញដល់បណ្តាទេសចរទាំងឡាយ ទោះបីជាតំបន់នោះជាតំបន់ប្រវត្តិសាស្ត្រនៅក្នុងទីក្រុងក៏ដោយ ក៏ត្រូវតែថែរក្សា និងអភិវឌ្ឍសម្រាប់វិស័យទេសចរណ៍ដែរ។
- ជំរុញធ្វើឱ្យមានគុណភាពផ្នែកបរិស្ថាននៅក្នុងតំបន់នោះបានល្អប្រសើរ ពីព្រោះទេសចរចូលចិត្តកន្លែងដែលមានបរិយាកាសស្រស់ស្រាយ និងមិនមានការបំពុល មានអនាម័យ និង ស្អាតស្រស់បំព្រង។
- បង្កើនការយល់ដឹងលើបញ្ហាបរិស្ថានជាមូលដ្ឋាន ជាពិសេសពួកយុវជន ត្រូវសង្កេតមើលលើផលប្រយោជន៍នៃវិស័យទេសចរណ៍។

**ផលអវិជ្ជមាន**

- ការបញ្ចេញផ្សែងពុលពីរោងចក្រផ្សែងយានយន្ត និងការហុយធូលីពីការដ្ឋានសំណង់នានា នាំឱ្យមានភាពអាប់អួរបរិយាកាសសង្គម។
- សំរាម ដោយសារទេសចរមានចំនួនច្រើនហួសហេតុនាំឱ្យមានកំនើនសំរាមកើនលើសលប់ ជាពិសេសនៅតាមតំបន់រមណីយដ្ឋាននានា សណ្ឋាគា ផ្ទះសំណាក់ និងភោជនីយដ្ឋាន។

- កង្វក់ទឹក តំបន់ទេសចរណ៍ដែលស្ថិតនៅតាមឆ្នេរសមុទ្រ បឹង ទន្លេ ជ្រោះ តែងតែទទួលរងនូវបញ្ហាកង្វក់ទឹកនៅផ្នែកខាងលើ និងផ្នែកខាងក្រោម ដែលបណ្តាលមកពីការអភិវឌ្ឍប្រព័ន្ធលូបង្ហូរកាកសំណល់មិនបានត្រឹមត្រូវ និងការធ្វើឱ្យមានកង្វក់ដោយសារអ្នកទេសចរ។ ទឹកស្អុយត្រូវបានគេបង្ហូរចេញពីភោជនីយដ្ឋាន សណ្ឋាគារ ឬផ្ទះសំណាក់ចូលទៅក្នុងប្រភពទឹក សមុទ្រ ឬទន្លេទាំងនេះបានធ្វើឱ្យមានបញ្ហាកង្វក់ទឹកកើតឡើង ហើយជះឥទ្ធិពលលើបរិស្ថានយ៉ាងធ្ងន់ធ្ងរ។
- កង្វក់ខ្យល់តែងតែកើតមាននៅតាមតំបន់ទេសចរណ៍នានា ដោយជៀសពុំរួច ជាពិសេសតំបន់ដែលមានរថយន្តចូលទៅដល់ និងតំបន់ដែលជិតនោះទីកន្លែងកំសាន្ត។ កង្វក់ខ្យល់នាំឱ្យមានកើតនូវបាតុភូតគឺមី៣ ប្រភេទ គឺការប្រែប្រួលអាកាសធាតុ កំណើនឧស្ម័នផ្ទះកញ្ចក់ និងភ្លៀងអាស៊ីត ដែលពិភពលោកកំពុងតែយកចិត្តទុកដាក់បំផុត។
- ការរំខានសត្វទាំងឡាយនឹងត្រូវបានបន្លាច ដោយសារការលើសំឡេងនៃទេសចរ ក្នុងតំបន់ ហើយវាក៏រត់ចេញពីទីនោះ ទាំងនេះគឺជាបញ្ហាមួយធំណាស់ជាពិសេសមានទេសចរមួយចំនួនចូលចិត្តប្រើប្រាស់ម៉ូតូធំៗ ដែលមានសំឡេងខ្លាំងៗ បើកឆ្លងកាត់សួនឧទ្យាន នឹងបឹងនានាដែរ ព្រមទាំងមានការបើកយានយន្តធំៗ សម្រាប់បំរើឱ្យការដឹកភ្ញៀវកំសាន្ត ដែលមានសំឡេងខ្លាំងៗ មានការសាងសង់ សំណង់អាគារ ក្នុងតំបន់ទេសចរណ៍ពេលនោះបក្សី សត្វព្រៃទាំងឡាយតែងតែរងនូវការរំខានក្នុងការបន្តពូជ។
- ការខូចខាតដល់ជួរផ្កាថ្មដូចជា ការសាងសង់សំណង់អគារទេសចរណ៍នៅតាមតំបន់មាត់សមុទ្រអាចធ្វើឱ្យខូចខាតពីព្រោះថា ទឹកនិងក្លាយទៅជាកខ្វក់ដោយកករ និងសំរាមដែលមនុស្សពង្រាយដោយហេតុថាផ្កាថ្មវាត្រូវការទឹកស្អាត ដើម្បីដុះលូតលាស់ហេតុនេះ ហើយទើបវាត្រូវទទួលរងនូវការខូចខាត ម្យ៉ាងទៀតទេសចរខ្លះដែលចូលទៅកំសាន្តនៅតាមតំបន់មាត់សមុទ្រ ជាញឹកញាប់ពួកគេតែងតែបេះបោចផ្កាថ្ម ដែលហេតុនាំឱ្យខូចខាត ឬបាត់បង់។
- តម្រូវការធនធានទេសចរមានតម្រូវការធនធានជាច្រើនជាងមនុស្សនៅក្នុងតំបន់ទៅទៀត គឺគេត្រូវការប្រើប្រាស់ប្រេងឥន្ទនៈសម្រាប់ធ្វើដំណើរ និងសម្រាប់ចម្អិនអាហារ។ គេត្រូវការភ្លើងអគ្គីសនីដើម្បីបំភ្លឺ និងត្រូវការម៉ាស៊ីនត្រជាក់ថែមទៀត គេត្រូវការមុខម្ហូប ដែលពិបាករក ហើយដែលភាគច្រើនមានតែនៅក្នុងតំបន់តែប៉ុណ្ណោះ។ កត្តាទាំងនេះ វាបានធ្វើឱ្យក្លាយទៅជាសម្ពាធមួយដែលរុញផ្ទប់ទោះលើបរិស្ថាននៅក្នុងតំបន់ទេសចរណ៍ទាំងនោះ។
- ការសឹករេចរិល និងការប្រេះបែក ក្រុមទេសចរដែលមានចំនួនច្រើនសុទ្ធតែធ្វើឱ្យមានការសឹកដាច់រេចរិលដល់តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រ ប្រាសាទបុរាណនានា។

ឧទាហរណ៍ ៖ ប្រសិនបើមានមនុស្សច្រើនពេក ដើម្បីទស្សនាជុំវិញតំបន់ប្រវត្តិសាស្ត្រ ពួកគេអាចបណ្តាលឱ្យមានការសឹកដាច់ក្បាច់ ចម្លាក់ ផ្ទាំងថ្ម ហើយត្រូវបានខូចខាតដោយសារមនុស្សជាច្រើនបានប៉ះ ឬកកិតទៅលើវាទេសចរខ្លះបានលួចយកក្បាច់ចម្លាក់តូចៗ និងរូបបដិមាករទាំងឡាយ។

**វិធានការណ៍ការពារផលប៉ះពាល់ដល់បរិស្ថាន**

ដើម្បីការពារ និងទប់ទល់នូវឥទ្ធិពលរបស់វិស័យទេសចរណ៍ទៅលើបរិស្ថានដែលបណ្តាលមកពីការអភិវឌ្ឍវិស័យទេសចរណ៍មិនបានត្រឹមត្រូវនោះរួមមាន ៖

- រៀបចំកន្លែងចាក់កាកសំណល់ផ្សេងៗ តំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹក សម្រាប់ប្រើប្រាស់ ថាមពលអគ្គីសនីលូទឹក និងប្រព័ន្ធបង្ហូរទឹកសម្អុយនៅតំបន់ទេសចរណ៍ ទាំងនោះឱ្យបានត្រឹមត្រូវ។អត្ថប្រយោជន៍ផ្សេងៗនៃអេកូ-ទេសចរណ៍មានដូចជា ៖
- សហគមន៍នឹងទទួលបាននូវមូលនិធិរួម និងសកម្មភាពសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រផ្តល់ដល់ការអភិរក្សជីវចម្រុះ។
- ប្រជាជនក្នុងសហគមន៍នឹងទទួលបានសិទ្ធអំណាចក្នុងការគ្រប់គ្រងធនធានរបស់គេ។
- ប្រជាជនក្នុងសហគមន៍នឹងទទួលបានផលកម្រៃយ៉ាងច្រើនពីសកម្មភាពទេសចរណ៍ដូចជាសេវាស្នាក់នៅ ម្ហូបអាហារ ការសាងសង់ ការលក់ផលិតផលកសិកម្ម សកម្មភាពដឹកជញ្ជូន។ល។

## ១.៤. ទស្សនវិស័យនៃអេកូ-ទេសចរណ៍

ទស្សនវិស័យនៃអេកូ-ទេសចរណ៍ គឺការអភិវឌ្ឍអេកូទេសចរណ៍ប្រកបដោយចីរភាព ការអភិវឌ្ឍដោយចីរភាពអាចដំណើរការទៅបាន ទាមទារមានការចូលរួមពីគ្រប់ផ្នែកនៃអ្នកដែលពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍផ្សេងៗទៀត ដូចជាអង្គការទេសចរណ៍ពិភពលោក អង្គការក្នុងតំបន់ រាជរដ្ឋាភិបាល ផ្នែកឯកជន និងសហគមន៍មូលដ្ឋាន។ គេមានវិធីសាស្ត្រជាច្រើន ដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ឱ្យមានចីរភាព ប៉ុន្តែនៅក្នុងនេះយើងលើកយក ៥ ចំណុចដែលចាត់ទុកថាជាបញ្ហាចម្បងមកធ្វើការពិភាក្សា ៖

- ចូលរួមដើម្បីអភិវឌ្ឍសហគមន៍មូលដ្ឋាន
- ប្រើប្រាស់កម្លាំងមូលដ្ឋានផ្គត់ផ្គង់ទំនិញ និងសេវាកម្ម
- បែងចែកផលប្រយោជន៍ឱ្យសមស្រប
- អភិរក្សធនធាន ដែលមិនអាចកើតឡើងវិញបាន
- ផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន

### ក.ការចូលរួមដើម្បីអភិវឌ្ឍសហគមន៍

ប្រជាជនក្នុងសហគមន៍ត្រូវតែថែទាំ ត្រួតពិនិត្យ រាល់ដំណើរការអភិវឌ្ឍវិស័យទេសចរណ៍ ដោយផ្តើមចេញពីការទាក់ទងជិតស្និតក្នុងការបង្កើតឡើងនូវចក្ខុវិស័យទេសចរណ៍ សហគមន៍ការបញ្ជាក់អះអាងពីប្រភពធនធានដែលត្រូវបានថែរក្សា និងធ្វើឱ្យមានទេសចរណ៍។ ជាមួយគ្នានេះដែរចាំបាច់ត្រូវឱ្យប្រជាជនសហគមន៍ចូលរួមនូវរាល់សកម្មភាព កិច្ចការប្រតិបត្តិ និងការធ្វើផែនការជាយុទ្ធសាស្ត្រ ក៏ដូចជាប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ សេវាកម្ម និងសម្ភារៈមូលដ្ឋានផ្សេងៗ។

មានន័យថា ដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ឱ្យមានចីរភាពបានលុះត្រាមានការចូលរួមមកពីសហគមន៍មូលដ្ឋាន ព្រោះពួកគេជាម្ចាស់ធនធាន គេស្គាល់ទីតាំងភូមិសាស្ត្រច្បាស់លាស់ងាយស្រួលក្នុងការកាត់បន្ថយផលអវិជ្ជមានផ្សេងៗ។

### ខ.ការប្រើប្រាស់កម្លាំងមូលដ្ឋានផ្គត់ផ្គង់ទំនិញ និងសេវាកម្ម

ការអភិវឌ្ឍវិស័យទេសចរណ៍ ត្រូវផ្តល់មកនូវការប្រើប្រាស់កម្លាំងពលកម្មក្នុងសហគមន៍ ការផ្តល់ការងារពេញលេញ ដែលយល់ឃើញថាជាផ្នែកទាំងមូលនៃការអភិវឌ្ឍវិស័យនីមួយៗនៅក្នុងកម្រិតតំបន់។ នៅក្នុងដំណើរការធនាការប្រើប្រាស់កម្លាំងពលកម្មប្រកបដោយគុណ ភាពនោះគឺជាការធានាថា វាជាលទ្ធភាពមួយដ៏ល្អប្រសើរបំផុត ដែលអាចអនុវត្តន៍ទៅបានដូចជា ការដឹកជញ្ជូន ផ្ទះស្នាក់នៅ ម្ហូបអាហារមគ្គុទេសក៍... ត្រូវរៀបចំដោយមនុស្សក្នុងសហគមន៍។

ផ្តល់ការអប់រំ និងហ្វឹកហាត់ជំនាញ ឬវិជ្ជាជីវៈ សម្រាប់សហគមន៍ និងជំនាញហិរញ្ញវត្ថុ សម្រាប់ អាជីវកម្ម ជាចំណុចស្នូលនៃគោលការអភិវឌ្ឍសហគមន៍មូលដ្ឋាន។

### គ.ការបែងចែកផលប្រយោជន៍ឱ្យបានសមស្រប

ការបែងចែកផលប្រយោជន៍ ឱ្យសមស្របផ្អែកលើមូលដ្ឋានទូទៅនៃប្រាក់ចំណេញពីវិស័យទេសចរណ៍ ត្រូវតែកើតឡើងទៅតាមគោលដៅ។ ការប្រទាក់គ្នាក្នុងតំបន់ ការចូលរួមរបស់ប្រជាជនក្នុងសហគមន៍នៅក្នុងដំណើរការអភិវឌ្ឍ និងប្រតិបត្តិការប្រកពធនធាន និងសេវាកម្មទេសចរណ៍នឹងជួយឱ្យជានាបាននូវភាពស្មើគ្នា ក្នុងការបែងចែកផលចំណេញទៅតាមការ ចំណាយចូលរួម ឬធនធានដែលកើតឡើងក្នុងការបែងចែកផលចំណេញទៅតាមការចូលរួម ឬធនធានដែលកើតឡើងក្នុងកំឡុងពេលប្រតិបត្តិការរវាងម្ចាស់ស្រុកទេសចរ និងអ្នកផ្គត់ផ្គង់សេវាកម្មផ្សេងៗ ទៀត។ ការបែងចែកផលប្រយោជន៍នេះ តម្រូវឱ្យមានភាពចុះសម្រុងគ្នារវាងសេចក្តីត្រូវការរបស់អ្នកទេសចរ ទីកន្លែង និងសហគមន៍មូលដ្ឋាន ពោលគឺត្រូវកែសម្រួលតាមរយៈការគាំទ្រសហគមន៍ ដ៏ទូលាយជាមួយនឹងតុល្យភាពសមរម្យចំពោះ សេដ្ឋកិច្ចសង្គម វប្បធម៌ និងគោលដៅនៃការអភិវឌ្ឍធនធានមនុស្ស រួមជាមួយការទទួលស្គាល់អត្ថប្រយោជន៍ សហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងឧស្សាហកម្មទេសចរណ៍។

### ឃ.អភិរក្សធនធានដែលមិនកើតឡើងវិញ

ការអភិវឌ្ឍអេកូ-ទេសចរណ៍ប្រកបដោយនិរន្តរភាព អាចនាំមកនូវសមធម៌ទៅតាមអន្តរជំនាន់។ សមធម៌ដោយមានការបែងចែកកម្រៃ និងប្រាក់ចំណេញនៃដំណើរការអភិវឌ្ឍអេកូ-ទេសចរណ៍ត្រូវតែ អនុវត្តន៍ក្នុងចំណោមមនុស្សបច្ចុប្បន្ន និងមនុស្សជំនាន់ក្រោយៗទៀត។ អភិវឌ្ឍអេកូ-ទេសចរណ៍ប្រកបដោយចីរភាពត្រូវតែគេចចេញពីការប្រើប្រាស់ប្រកពធនធាន ដែលមិនកើតឡើងវិញ។ ព្រំដែនផែនការរយៈពេលវែងតម្រូវឱ្យមានការស្វែងយល់ និងយល់ព្រមតាមរយៈស្ថាប័ន និងគោលដៅអភិវឌ្ឍអេកូ-ទេសចរណ៍ ក្នុងការធានាថាមិនត្រូវបានប្រើប្រាស់សម្រាប់រយៈពេលខ្លី និងក្រោមត្រូវបំភ្លេចចោលព្រមទាំងធ្វើការផ្លាស់ប្តូរទៅទីកន្លែងផ្សេងទៀត។ ព្រំដែននៃការផែនការវែងនឹងជំរុញលើកទឹកចិត្តដល់ការប្រើប្រាស់យុទ្ធសាស្ត្រសកម្មនិយម និងការធានាដល់គោលដៅនិរន្តរភាពការបង្កើតឱ្យមានការប្រទាក់ក្រឡាគ្នា។

### ង.ផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន

ផែនការអភិវឌ្ឍត្រូវដើរតាមគម្រូមួយដែលបានបង្ហាញពីភាពរីកចម្រើន តាមលក្ខណៈប្រពៃណីដោយផ្តល់ឱកាសជាចម្បងដល់ការប្រើប្រាស់កម្លាំងពលកម្មសហគមន៍ ដោយទាញប្រភពចំណូល និង ធ្វើឱ្យមានភាពប្រសើរឡើងនៃសុខុមាលភាពតំបន់។ ជាមួយគ្នានេះដែរ ការអភិវឌ្ឍត្រូវធានាបានថាអាចថែរក្សាបាន

សមស្របនូវតម្លៃដើមរបស់បរិស្ថានធម្មជាតិ និងវប្បធម៌។ ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យ សម្បត្តិសាធារណៈដូចជា ប្រភពទឹក បរិយាកាស និងដីធ្លីត្រូវធានាបានថា មិនមានការបំពានដល់កម្មសិទ្ធសហគមន៍។

រាល់ការធ្វើ និងប្រតិបត្តិការផែនការត្រូវតែផ្តល់ឱកាសដល់ប្រជាជនក្នុងមូលដ្ឋាន បានចូលរួម និងប្រាប់អំពីហេតុផល ថាហេតុអ្វីបានជាត្រូវចូលរួម ការចូលរួមរបស់ប្រជាជនក្នុងសង្គមពីព្រោះ ៖

- ពួកគេស្គាល់ច្បាស់នូវទីតាំងភូមិសាស្ត្រ
- មានលំនាំជីវិត ផ្សារភ្ជាប់ជាមួយនឹងធម្មជាតិតាំងពីយូរមកហើយ
- ធនធានទាំងឡាយនៅក្នុងតំបន់ជាប្រភពជីវិតរបស់ពួកគេ
- មានតែពួកគេប៉ុណ្ណោះ ដែលបានស្គាល់ច្បាស់ពីលំនាំនៃការរីកលូតលាស់របស់ធម្មជាតិទាំងនោះ។

ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ក្រុមការងារ អ្នកអភិរក្ស ក៏ត្រូវគិតផងដែរថាការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈដល់សហគមន៍។

## ១.៥. គោលនយោបាយជាតិលើការអភិវឌ្ឍអេកូ-ទេសចរណ៍

វិស័យទេសចរណ៍ប្រទេសណាមួយមិនអាចរីកចម្រើនទៅបាន ដោយគ្មានការត្រួតពិនិត្យច្បាស់លាស់នោះទេ វាត្រូវតែបានអភិវឌ្ឍតាមគោលនយោបាយជាតិ ក្នុងទិសដៅអភិវឌ្ឍប្រទេសជាតិ។ គោលនយោបាយទេសចរណ៍កំណត់នូវគោលការណ៍ណែនាំ សម្រាប់គាំទ្រដំណើរការនៃការរៀបចំផែនការ និងការគ្រប់គ្រង។

គោលនយោបាយ និងផែនការទេសចរណ៍ កម្រិតជាតិអាចកំណត់ដូចខាងក្រោម ៖

- អភិវឌ្ឍទេសចរណ៍ ដើម្បីឱ្យមានតុល្យភាព និងប្រកបដោយនិរន្តរភាពជាមួយគោលដៅសេដ្ឋកិច្ច និងសង្គមរបស់ប្រទេស ដោយអនុលោមតាមបណ្តាអាទិភាពរបស់ជាតិដែលបានកំណត់ជាពិសេស គឺការបង្កើតអាជីព បង្កើតចំណូលពីការផ្លាស់ប្តូររូបិយបណ្ណ័និង ជំរុញការអភិវឌ្ឍក្នុងតំបន់។
- លើកទឹកចិត្តសហគ្រិនក្នុងមូលដ្ឋាន ដោយបង្កើនការផ្សារភ្ជាប់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចផ្នែកដទៃទៀត។
- នៅពេលជាមួយគ្នានេះដែរ ការស្វែងរកការវិនិយោគបរទេស ដែលជាវិភាគទានដល់ផែនការអភិវឌ្ឍទេសចរណ៍សម្របទៅតាមបញ្ញាត្តិ និងការគ្រប់គ្រងដែលបានរៀបចំឡើង។
- ប្រើប្រាស់ទេសចរណ៍ក្នុងការរក្សាភាពមានតែមួយគត់នៃកេរដំណែលប្រវត្តិសាស្ត្រ និងវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ព្រមទាំងជីវភាពរស់នៅរបស់ពលរដ្ឋ។
- អភិវឌ្ឍទេសចរណ៍ ដើម្បីជួយរក្សា និងការពារបរិស្ថានធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់តំបន់ និងរមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ ក៏ដូចជាធម្មជាតិ។
- អនុញ្ញាតិឱ្យប្រជាពលរដ្ឋ និងទេសចរមានសិទ្ធិប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ សម្បទា សេវា និងកន្លែងកំសាន្ត។ មធ្យោបាយនេះ ធានាឱ្យការអភិវឌ្ឍវិស័យទេសចរណ៍ត្រូវការធ្វើវិភាគជូនប្រជាពលរដ្ឋមូលដ្ឋាន ព្រមទាំងទេសចរនូវតម្រូវការរបស់គេ។
- រក្សាសមាសធាតុ នៃផលិតផលទេសចរណ៍ឱ្យមានតុល្យភាពទាំងគុណភាព និងបរិមាណ។
- អភិវឌ្ឍបណ្តាយុទ្ធសាស្ត្រ ដើម្បីទាក់ទាញបរិមាណ និងប្រភេទទេសចរដែលមានលទ្ធភាពអាចធ្វើវិភាគទានក្នុងការប្រមូលថវិកាដល់ជាតិ។

- ជំរុញការអភិវឌ្ឍលើកម្មវិធី និងសម្បទាបណ្តុះបណ្តាលសមស្រប ដើម្បីជំរុញឱ្យមានការងាយស្រួលក្នុងការស្វែងរកអាជីព និងសម្រេចលើបរិមាណ គុណភាពដែលចង់បាន។
- សម្របសម្រួលបណ្តាភ្នាក់ងារទាំងអស់ ទាំងផ្នែកសារធារណៈឯកជនអង្គការដែលមានផលប្រយោជន៍ដែលពាក់ព័ន្ធទៅនឹងវិស័យទេសចរណ៍។
- រក្សាផ្តល់ព័ត៌មានជូនសាធារណៈជនជាទូទៅអំពីកំណើនវិស័យទេសចរណ៍ ដោយពន្យល់ប្រាប់ពីការអភិវឌ្ឍ និងវិភាគទានរបស់គេទៅលើសេដ្ឋកិច្ច និងសង្គម។
- ពន្យល់ជូនសាធារណៈជនទូទៅផងដែរ តើគេអាចជួយនឹងគាំទ្រការអភិវឌ្ឍលើវិស័យទេសចរណ៍ទាំងបណ្តាអន្តរជាតិ និងក្នុងមូលដ្ឋានយ៉ាងដូចម្តេច?

## ២. អេកូ-ទេសចរណ៍កម្ពុជា

លក្ខខណ្ឌភូមិសាស្ត្រនៃប្រទេសកម្ពុជា បានបង្កើតឡើងនូវទេសភាពប្លែកៗរួមជាមួយនឹងធនធានធម្មជាតិយ៉ាងសម្បូរបែប ម្យ៉ាងវិញទៀត ឆ្លងតាមលក្ខខណ្ឌប្រវត្តិសាស្ត្រ ប្រទេសកម្ពុជាត្រូវបានគេទទួលស្គាល់ថា ជាទឹកដីដែលពោរពេញទៅដោយភោគទ្រព្យនៃ កំណប់ធនធានធម្មជាតិ ដែលគេហៅថាជ្រោយសុវណ្ណភូមិ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម នាយកដ្ឋានគង្ហាររុក្ខា និងប្រមាញ់បានបង្កើតតំបន់ការពារធម្មជាតិដែលមានឈ្មោះថា ព្រៃបម្រុងទុករបស់រដ្ឋ ដោយចែកជា ២ ផ្នែកគឺ ព្រៃបម្រុងទុកសម្រាប់សត្វព្រៃ និងព្រៃបម្រុងទុកសម្រាប់កសិកម្ម ប៉ុន្តែក្រោយឆ្នាំ១៩៧០ ព្រៃបម្រុងទុក និងតំបន់ការពារទាំងនោះត្រូវ  អសកម្ម។ ក្រោយពីប្រសូតឡើងនៃរាជរដ្ឋាភិបាលថ្មីមួយ បន្ទាប់ពីការបោះឆ្នោតជាសាកលដោយសេរី និងយុត្តិធម៌នាឆ្នាំ១៩៩៣ ព្រះករុណាព្រះបាទនរោត្តមសីហនុ បានសព្វព្រះរាជហឫទ័យឡាយព្រះហស្តលេខាលើព្រះរាជក្រិត្យស្តីអំពីកិច្ចការពារតំបន់ធម្មជាតិនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។ តំបន់ការពារធម្មជាតិទាំងអស់មាន ២៣ តំបន់ដែលត្រូវបានបែងចែកតាមលក្ខណៈពិសេសដោយឡែកគឺ តំបន់ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព និងតំបន់ប្រើប្រាស់ច្រើនយ៉ាង ដែលស្ថិតនៅតាមចំណុចសំខាន់ៗនៃស្ថានភាពភូមិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ប្រភេទទាំង ៤ នៃតំបន់ការពារធម្មជាតិទាំងនេះឆ្លុះបញ្ចាំងនូវលក្ខណៈពិសេសនៃប្រព័ន្ធអេកូឡូស៊ី និង គោលដៅគ្រប់គ្រងខុសៗគ្នា សម្រាប់តំបន់ទាំងនោះ ហើយតំបន់ទាំងនោះក៏ត្រូវបានឆ្លើយតបទៅនឹង  ចំណាត់ថ្នាក់របស់ IUCN [(3)] ។

បន្ថែមពីលើនេះ កាលពីខែធ្នូ ឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងបរិស្ថានជាប្រមុខបានសម្រេចបើកបង្កើតឱ្យមានតំបន់ការពារធម្មជាតិមួយទៀតឈ្មោះថា តំបន់ការពារមណ្ឌលគីរី។

### ២.១. គោលនយោបាយសម្រាប់វិស័យ អេកូ-ទេសចរណ៍

គោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះវិស័យទេសចរណ៍ គឺជុំរិញការអភិវឌ្ឍវិស័យ ទេសចរណ៍ ដោយផ្អែកទៅលើធនធានធម្មជាតិ និងមរតកវប្បធម៌។ រដ្ឋាភិបាលបានលើកស្ទួយដល់អ្នកវិនិយោគទុនឯកជន និងសារធារណៈ សំដៅកសាងហេដ្ឋរចនាសម្ព័ន្ធទេសចរណ៍ និងបានខិតខំថែរក្សាសន្តិសុខ និងស្ថិរភាពនយោបាយ ដើម្បីឱ្យវិស័យទេសចរណ៍ក្លាយជាប្រភពចំណូលសំខាន់នៃសេដ្ឋកិច្ចជាតិ ការងារទេសចរណ៍ត្រូវផ្សារភ្ជាប់នឹងការថែរក្សាមរតកវប្បធម៌ (ខាងសម្ភារៈ និងវប្បធម៌ស្មារតី) របស់ជាតិ និងការពារបរិស្ថានធម្មជាតិ។ ក្រសួងទេសចរណ៍នៅកម្ពុជា គឺពឹងផ្អែកលើមូលដ្ឋានធនធានធម្មជាតិ និងកេរដំណែលវប្បធម៌នេះទាំងស្រុង។

ប្រទេសកម្ពុជាសម្បូរទៅដោយកេរមរតកវប្បធម៌ និងសម្បត្តិធម្មជាតិច្រើនអនេក ដោយយោងទៅតាមទីតាំងភូមិសាស្ត្រមានលក្ខណៈអំណោយផលយ៉ាងប្រសើរ សម្រាប់ការអភិវឌ្ឍផ្នែកអេកូ-ទេសចរណ៍ ដែលតំបន់ការពារទេសភាពប្រណីតៗរួមមាន ទឹកធ្លាក់ ដែនជម្រកសត្វព្រៃ ទីជម្រកមច្ឆជាតិ ទីជម្រកសត្វស្លាប បឹងធម្មជាតិ កោះ ឆ្នេរសមុទ្រ ធនធានបាតសមុទ្រ វប្បធម៌ អរិយធម៌ប្លែកៗរបស់ជនជាតិភាគតិចធនធានទាំងនោះ គឺជាទុនមួយយ៉ាងសំខាន់បំផុត ហើយវាជាមូលដ្ឋានក្នុងការអភិវឌ្ឍអេកូ-ទេសចរណ៍នាពេលអនាគត។ ដើម្បីឱ្យមានការរីកចម្រើន និងឈានឆ្ពោះទៅរកនិរន្តភាពនៃវិស័យអេកូ-ទេសចរណ៍ត្រូវកំណត់នូវគោលនយោបាយមួយចំនួន ដែលមានការពាក់ព័ន្ធរួមគ្នាទៅនឹងសកម្មភាពអភិវឌ្ឍដែលក្នុងនោះបានបែងចែកជា៣ដំណាក់កាលសំខាន់ៗ។

**ដំណាក់កាលទី១**

- បង្កើនការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ភ្ញៀវទេសចរអន្តរជាតិអំពីទេសចរណ៍បរិស្ថាន ដើម្បីទាញយករូបិយប័ណ្ណឱ្យបានច្រើន។
- ត្រូវមានគម្រោងផែនការថវិកាចំណាយទៅលើការរៀបចំកែលម្អចំពោះកេរដំណែលវប្បធម៌ ធនធានធម្មជាតិ និងបរិស្ថានផងដែរ។
- អភិវឌ្ឍផលិតផល និងសេវាកម្មទេសចរណ៍ឱ្យបានត្រឹមត្រូវទៅតាមបទដ្ឋាន។
- ផ្តល់នូវវិធានការការពារសុវត្ថិភាព ទាំងអាយុជីវិត ទាំងទ្រព្យសម្បត្តិ ក្នុងការធានារ៉ាប់រងឱ្យឈានទៅដល់គោលដៅដំណើរកំសាន្តរបស់ពួកគេ។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីបំផុសប្រជាពលរដ្ឋយល់ដឹងពីសារៈសំខាន់នៃការ អភិវឌ្ឍវិស័យទេសចរណ៍។
- ពង្រឹងផ្នែកឧស្សាហកម្មទេសចរណ៍ឱ្យមានភាពរឹងមាំ។
- ត្រូវមានការចូលរួមចំណែករបស់ប្រជាជនក្នុងសហគមន៍ និងមហាជនទូទៅនូវរាល់សកម្មភាពអភិវឌ្ឍនានានៃអេកូ-ទេសចរណ៍។

**ដំណាក់កាលទី២**

រាល់ការចំណាយលើការកែលម្អ អភិវឌ្ឍវិស័យទេសចរណ៍នៅតំបន់ការពារធម្មជាតិ គឺធ្វើយ៉ាងណាដើម្បីបង្កើនចំណូលដល់ប្រជាពលរដ្ឋ ដែលរស់នៅផ្ទាល់ក្នុងតំបន់អភិវឌ្ឍនោះ។

**ដំណាក់កាលទី៣**

ការអភិរក្ស និងការកែលម្អនូវកេរដំណែលវប្បធម៌ ធនធានធម្មជាតិ និងបរិស្ថាន ជាពិសេសត្រូវរក្សានូវអត្តសញ្ញាណជាតិ ឬរបស់សហគមន៍ ដែលមានស្រាប់នៅទីនោះ។

### ២.២. ជម្រើសជាយុទ្ធសាស្ត្រនៃអេកូ-ទេសចរណ៍

ប្រទេសកម្ពុជា គួរតែស្វែងយល់ការងារមួយចំនួនដែលពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រ ដើម្បីឱ្យសមស្របទៅនឹងក្រិត្យក្រមនៃការអភិវឌ្ឍរបស់វា។

**ក.ការកំណត់រមណីយដ្ឋានទេសចរណ៍**

ការកំណត់រមណីដ្ឋានទេសចរណ៍ ដោយផ្អែកលើគោលការណ៍ទេសចរណ៍ ធ្វើយ៉ាងណាត្រូវជានាចីរភាពដំណើរការអនុវត្តជាមួយគ្នានេះដែរ យើងក៏ត្រូវគិតដល់ឧស្សាហកម្មទេសចរណ៍ផងដែរ។

**ខ.ការបែងចែកតំបន់អេកូ-ទេសចរណ៍**

ការបែងចែកតំបន់អេកូ-ទេសចរណ៍ វិធានការណ៍នេះធានាថាភាគច្រើននៃទេសចរធ្វើទស្សនកិច្ចដូចជាទិសដៅសម្រាប់ការលំហែកំសាន្ត ជាតំបន់រមណីយដ្ឋានធម្មជាតិ ហើយត្រូវកំណត់ផងដែរថា បរិមាណទេសចរក្នុងតំបន់ ឬសហគមន៍ និងផ្តល់សេវាកម្មបែបអេកូ-ទេសចរណ៍។

**គ.អេកូ-ទេសចរណ៍ក្នុងតំបន់**

អេកូ-ទេសចរណ៍ក្នុងតំបន់ ធានាថារាជរដ្ឋាភិបាលនឹងបន្តដើម្បីទាញយកចំណូលពីរមណីយដ្ឋានធម្មជាតិ ប៉ុន្តែសារប្រយោជន៍ដែលហូរចូលពីអេកូ-ទេសចរណ៍គួរតែផ្តល់នូវផលចំណេញភាគខ្លះដល់សហគមន៍មូលដ្ឋាន តាមគុណភាពព្រមជាមួយការផ្តល់កញ្ចប់ថវិកាដល់កិច្ចការពារបរិស្ថាន។

**ឃ.ការយល់ដឹងពីអេកូ-ទេសចរណ៍**

ការយល់ដឹងពីអេកូ-ទេសចរណ៍ ៖ នៅក្នុងវិធានការនេះរដ្ឋក៏ត្រូវធានាថា ចំណេះដឹងស្តីពីផ្នែក អេកូ-ទេសចរណ៍ត្រូវបានផ្សព្វផ្សាយ។

**២.៣. ការរៀបចំអភិវឌ្ឍអេកូ-ទេសចរណ៍**

ដើម្បីរៀបចំអភិវឌ្ឍអេកូ-ទេសចរណ៍ឱ្យមានចីរភាព យើងគួរតែរៀបចំផែនការប្រើប្រាស់ដី និងផែនការគ្រប់គ្រងបរិស្ថានឱ្យបានគង់វង្ស។

**ក.ការរៀបចំផែនការប្រើប្រាស់ដី (សម្រាប់សាងសង់អគារ)**

ការរៀបចំផែនការប្រើប្រាស់ដី ៖ គឺសំដៅទៅលើដង់ស៊ីតេអគារប្រភេទណាដែលត្រូវកំណត់ឱ្យសាងសង់បាននៅដីដែលបានគ្រោងនឹងសាងសង់ ហើយត្រូវគិតគូរពីកម្ពស់អគារ ទីធ្លា សម្រាប់ចតយានយន្តគ្រប់ប្រភេទ ព្រមទាំងទីធ្លាសួនសាធារណៈជាដើម។

**ខ.ច្បាប់គ្រប់គ្រងបរិស្ថាន**

**ច្បាប់គ្រប់គ្រងបរិស្ថាន ច្បាប់គឺជាបញ្ញាត្តិដែលចាប់បង្ខំមនុស្សឱ្យគោរព និងអនុវត្តន៍តាម។ គ្រប់ច្បាប់ទាំងអស់មានចរិតចាប់បង្ខំ ដោយគ្មានការសម្របសម្រួលឡើយ ជាមួយគ្នានេះដែរ ច្បាប់គឺជាម៉ែត្រវាស់នូវកម្រិតខុសឆ្គងរបស់បុគ្គល ឬអ្នកប្រព្រឹត្តិល្មើស។**

នៅប្រទេសជឿនលឿនច្បាប់បរិស្ថាន ជាឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុត សម្រាប់ធានាកិច្ចអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីឱ្យច្បាប់បរិស្ថានមានប្រសិទ្ធភាព ទាំងអ្នកធ្វើច្បាប់ ទាំងអ្នកអនុវត្តច្បាប់ត្រូវតែគោរពច្បាប់ ប្រសិនបើជនណាមួយមិនគោរពតាមនឹងផ្តន្ទាទោសនៅទង្វើរបស់ខ្លួន ប៉ុន្តែក៏គួរបញ្ជាក់ផងដែរថា ច្បាប់ត្រូវតែធ្វើការផ្សព្វផ្សាយជាសាធារណៈ មុនពេលយកទៅអនុវត្ត។

**២.៤. កាលានុវត្តភាព និងការគម្រាមកំហែង**

**ក. កាលានុវត្តភាពជាសក្តានុពលនៃអេកូ-ទេសចរណ៍**

ទេសចរណ៍បានផ្តល់ទាំងឱកាស និងការគំរាមកំហែងទៅដល់តំបន់ការពារ។ អេកូ-ទេសចរណ៍ មាន

តួនាទីបង្កើនឱកាស និងកាត់បន្ថយការគម្រាមកំហែង។ ប្រសិនបើឱកាសត្រូវបានបញ្ជាក់យ៉ាងច្បាស់ នោះមានន័យថាអេកូ-ទេសចរណ៍ ប្រាកដជានឹងនាំមកនូវផលប្រយោជន៍ ប្រសិនបើមានការគំរាមកំហែង មិនអាចបញ្ចៀសបាននោះ វានឹងក្លាយទៅជាការចំណាយមួយ។ គ្មានផលប្រយោជន៍ណាមួយដែលនឹងកើតឡើងដោយស្វ័យប្រវត្តិជាប់មកជាមួយនឹងអេកូ-ទេសចរណ៍នោះឡើយ ភាពជោគជ័យ គឺអាស្រ័យការធ្វើផែនការ និងការគ្រប់គ្រងបានល្អ។ គម្រោងអេកូ-ទេសចរណ៍ ដែលត្រូវបានអនុវត្តន៍មានភាពទន់ខ្សោយ និងគ្មានផែនការច្បាស់លាស់អាចទៅជាគម្រោងទេសចរណ៍ ដែលងាយនឹងទទួលរងនូវផលប៉ះពាល់អវិជ្ជមាន។

**អេកូ-ទេសចរណ៍ជាកាលានុវត្តភាពមួយ**

( Eco- Tourism as an Opportunity )




## ខ.ភាលានុវត្តភាពជាសក្តានុពលនៃអេកូ-ទេសចរណ៍

- **ការបង្កើតចំណូល** ៖ ការនាំយកមកនូវរូបិយប័ណ្ណចូលទៅក្នុងតំបន់ការពារ ជាកង្វល់របស់អ្នកអភិរក្ស មូលនិធិដែលអាចរកបានរបស់រដ្ឋាភិបាល សម្រាប់តំបន់ការពារ ជាទូទៅកំពុងមានការថយចុះ ហើយតំបន់ការពារធម្មជាតិសំខាន់ៗមួយចំនួននឹងមិនអាចបន្តមានជីវិត ដោយគ្មានប្រភពចំណូលថ្មីនោះឡើយ។ អេកូ-ទេសចរណ៍ផ្តល់ទាំងឱកាស និងប្រាក់ចំណូលនៅក្នុងវិធីសាស្ត្រដូចជាលក់សំបុត្រចូលទស្សនា តម្លៃឈ្នួលប្រើប្រាស់ សម្បទានផ្នែកឯកជន និងប្រទានកម្ម ។
- **អនិកម្មភាព** ការងារថ្មីៗត្រូវបានបង្កើតឡើងនៅតំបន់ការពារ តាមរយៈវិស័យទេសចរណ៍តំបន់ការពារអាចផ្តល់ជាឱកាសដូចជា មគ្គុទេសក៏ទេសចរណ៍ ឆ្មាំអ្នកសិក្សាស្រាវជ្រាវ ឬអ្នកចាត់ការដើម្បីបំពេញតម្រូវការរបស់អេកូ-ទេសចរណ៍។ ក្នុងសហគមន៍ប្រជាជនអាចជាអ្នកបើកបរ មគ្គុទេសក៏ទេសចរណ៍ ម្ចាស់ផ្ទះសំណាក់ សិប្បករ ឬពួកគេអាចចូលបម្រើការងារតាមក្រុមហ៊ុនឯកជននានា ដែលទាក់ទងទៅនឹងវិស័យទេសចរណ៍។

- **យុត្តិកម្មតំបន់ការពារ** ៖ ដើម្បីជាសក្តានុពលក្នុងការទាក់ទាញភ្ញៀវទេសចរ គឺស្ថិតនៅលើមន្ត្រីរដ្ឋាភិបាល និងប្រជាជនក្នុងសហគមន៍ទ្រទ្រង់ដល់តំបន់ការពារ។ សម្រាប់មន្ត្រីរដ្ឋាភិបាល ការប្រកាសអំពីតំបន់គួរទទួលបានការការពារ និងផ្តល់ហិរញ្ញវត្ថុដើម្បីថែរក្សាតំបន់ទាំងនោះ ប៉ុន្តែមន្ត្រីទាំងនោះជារឿយៗតែងតែប្រឈមមុខទៅនឹងផលប្រយោជន៍ប្រជែងមួយចំនួន ចំពោះការធ្វើសេចក្តីសម្រេចចិត្តអំពីរបៀបក្នុងការប្រើប្រាស់ដី និងការប្រើប្រាស់ធនធានផ្សេងទៀត។
- **សេដ្ឋកិច្ចខ្លាំង** ៖ ទេសចរ ចូលមកទស្សនាតំបន់ការពារធម្មជាតិ បានជំរុញឱ្យសេដ្ឋកិច្ចមានភាពរីកលូតលាស់នៅក្នុងកម្រិតមូលដ្ឋាន កម្រិតតំបន់ និងកម្រិតជាតិ។ ប្រសិនបើភ្ញៀវទេសចរនាំមកនូវការងារដល់ប្រជាជននៅកម្រិតមូលដ្ឋាន នោះពួកគេនឹងមានប្រាក់ចំណូលបន្ថែមទៀតសម្រាប់ការចំណាយក្នុងមូលដ្ឋាន ហើយសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់នឹងកើនឡើងជាបន្តបន្ទាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ គំរូនេះមានដូចគ្នា គឺអាចកើតមានឡើងនៅក្នុងកម្រិតតំបន់ និងកម្រិតជាតិ។
- **ការអប់រំខាងបរិស្ថាន** ៖ ការអប់រំខាងបរិស្ថានមានទិសដៅផ្តល់ការអប់រំ ដើម្បីយល់ដឹងអំពីបរិស្ថាន និងមនសិការស្រឡាញ់បរិស្ថាន។ ការអប់រំខាងបរិស្ថាននេះ គឺសំដៅទៅលើមនុស្ស ២ ក្រុម គឺមនុស្សក្នុងសហគមន៍ និងទេសចរជាទូទៅទេសចរ ដែលបានធ្វើដំណើរមកក្នុងតំបន់ធម្មជាតិត្រូវបានចាត់ទុកថាជាសនវករល្អបំផុតសម្រាប់ការអប់រំ ដោយសារពួកគេមានចំណាប់អារម្មណ៍ទៅលើធម្មជាតិ សោភ័ណភាព ចង់ដឹង ចង់ស្តាប់ បន្ថែមអំពីបញ្ហាផ្សេងៗ ដែលពួកគេពុំដែលបានជួបពីមុនមកដូចជាឧបសគ្គក្នុងការអភិរក្សតំបន់ការពារ។
- **មូលវិចារណ៍ និងមោទនភាព** ៖ (Appreciation and Pride) គឺជាផលប្រយោជន៍អរូបិយ ដែលមានតិចជាងចំណុចផ្សេងៗ ដែលត្រូវបានបកស្រាយ ប៉ុន្តែវាអាចនាំទៅរកសកម្មភាពរូបិយ វាជារឿងសាមញ្ញ សម្រាប់មនុស្សដែលមិនធ្វើមូលវិចារណ៍ពេញលេញដល់បរិយាកាសជុំវិញ និងមិនទទួលយកនូវអ្វីៗដែលពួកគេមានសម្រាប់ជាអនុប្រទាន។

### គ. វិសាលភាពនៃឱកាស និងការគំរាមកំហែងនៃអេកូ-ទេសចរណ៍

វិសាលភាពទាំងមូលនៃឱកាស និងការគំរាមកំហែងរបស់អេកូ-ទេសចរណ៍នឹងមិនអនុវត្ត ចំពោះរាល់តំបន់ការពារនោះឡើយ។ ឧទាហរណ៍៖ ក្នុងតំបន់ការពារមួយដែលទាក់ទាញភ្ញៀវក្នុងស្រុក ជាចម្បង នោះឱកាសក្នុងការបង្កើតការដោះដូររូបិយប័ណ្ណនឹងមានកម្រិត ប៉ុន្តែឱកាសល្អអាចមានក្នុងការបង្កើននូវការយល់ដឹងអំពីការអភិរក្សនៅក្នុងស្រុក។ ការបំផ្លាញបរិស្ថាននឹងមានការផ្លាស់ប្តូរ អាស្រ័យទៅលើភាពមិនមាំទាំនៃធនធានធម្មជាតិ និងប្រភេទសកម្មភាពនានា ដែលត្រូវបានអនុញ្ញាត។ កាលៈទេសៈរបស់តំបន់ការពារនីមួយៗបង្កើតបានជាការកំណត់មួយ ជាពិសេសឱកាស និងការគំរាមកំហែង។

## ៣. ប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជា

### ៣.១. ការកំណត់តំបន់ការពារធម្មជាតិ

ព្រះរាជាណាចក្រកម្ពុជា ជាទឹកដីអច្ឆរិយៈ និងជាទឹកដីដ៏ពិសិដ្ឋ ដែលបានបន្សល់ទុកនូវ ធនធានវប្បធម៌យ៉ាងល្អប្រពៃ និងសម្បត្តិធម្មជាតិល្អប្រណីត។ ខឿនវប្បធម៌ ដែលជាអត្តសញ្ញាណ ជាតិខ្មែរមិនអាចជនណា ឬបរទេសណាបំបាត់ប្រវត្តិសាស្ត្រ ឬបដិសេធមិនស្គាល់បានឡើយ។ ធនធានធម្មជាតិសម្បូរបែប ក៏ទាមទារ

ឱ្យមានការប្រើប្រាស់ប្រកបដោយនិរន្តភាពដែរ ទើបយើងអាចយកផលយូរអង្វែង។ បើយោងតាម IUCN តំបន់ការពារធម្មជាតិ គឺជា**តំបន់ដែលគេបានកំណត់ថាជាកន្លែង**ពិសេស ដើម្បីធ្វើការការពារ និងទស្សនាសប្បាយជាមួយនឹងមរតកវប្បធម៌ ឬធម្មជាតិក្នុងបំណងរក្សា ជីវចម្រុះ និងបង្កើនសេវាកម្មទ្រទ្រង់ជីវិតតាមបែបអេកូឡូស៊ី។ បើតាមការសិក្សាស្រាវជ្រាវ តំបន់ការពារ ធម្មជាតិជាផ្លូវការមានប្រមាណជាង ៧០០០ កន្លែង ហេតុផលដែលចាត់ទុកតំបន់ទាំងនោះថា ជាតំបន់អេកូទេសចរណ៍ ពីព្រោះតំបន់ទាំងនោះផ្តល់នូវការជានាយ៉ាងពិសេសក្នុងការរក្សានូវភាពទាក់ទាញរបស់ខ្លួនយូរអង្វែង។ បន្ទាប់ពីឡាយព្រះហស្ថលេខាលើព្រះរាជក្រិត្យ ស្តីអំពីកិច្ចការពារតំបន់ការពារធម្មជាតិនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ តំបន់ការពារធម្មជាតិត្រូវបានបែងចែកជា ២៣ តំបន់ ដែលការបែងចែកនោះចែកទៅតាលក្ខណៈដោយឡែក ទៅតាមចំណាត់ថ្នាក់របស់ IUCN។

### ក.ការកំណត់ដោយព្រះរាជក្រិត

ព្រះរាជក្រឹត្យស្តីពីការការពារតំបន់ធម្មជាតិឆ្នាំ១៩៩៣ បានទទួលស្គាល់តំបន់ការពារចំនួន ២៣ កន្លែង ព្រះរាជក្រឹត្យនេះបានបែងចែកតំបន់ការពារចេញជាបួនប្រភេទគឺ តំបន់ឧទ្យានជាតិ តំបន់ជម្រកសត្វព្រៃ តំបន់ការពារទេសភាព និងតំបន់ប្រើប្រាស់ច្រើនយ៉ាង ដោយយោងតាមលក្ខណៈ គោលបំណងនៃការការពារ និងការអភិរក្សទៅលើតំបន់ការពារនីមួយៗ។ មកទល់ពេលនេះ តំបន់ការពារទាំងនេះ បានគ្របដណ្តប់ប្រមាណ ១៨ ភាគរយលើផ្ទៃដីប្រទេសកម្ពុជាទាំងមូល។

### ខ.ការកំណត់ដោយអនុក្រិត ឬអនុសញ្ញា

តំបន់ឧទ្យានជាតិបង្កើតថ្មីបន្ថែមចំនួន ៥ ដែលបង្កើតឡើងដោយអនុក្រិតនៅឆ្នាំ២០១៦ មានដូចជាឧទ្យានជាតិវ៉ីនសៃ-សៀមប៉ាងដែលស្ថិតក្នុងខេត្តស្ទឹងត្រែង និងរតនគីរី ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាលដែលស្ថិតក្នុងខេត្តកោះកុង ពោធិ៍សាត់ និងកំពង់ស្ពឺ ឧទ្យានជាតិអូរយ៉ាដាវ ដែលស្ថិតក្នុងខេត្តរតនគីរី ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូងដែលស្ថិតក្នុងខេត្តកោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និងព្រះសីហនុ ឧទ្យានជាតិកោះរុងដែលស្ថិតក្នុងខេត្តព្រះសីហនុ។

តំបន់រ៉ាំសា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៩ បន្ទាប់ពីប្រទេសកម្ពុជាបានក្លាយជាសមាជិកនៃអនុសញ្ញាការពារដីសើម ដែលមានសារៈសំខាន់ជាអន្តរជាតិ ឬអនុសញ្ញារ៉ាំសា។

ក្រោមក្របខណ្ឌគតិយុត្តិអន្តរជាតិនេះ តំបន់រ៉ាំសាដែលជាប្រភេទថ្មី ក្នុងចំណោមប្រភេទតំបន់ការពារធម្មជាតិនឹងក្លាយជាតំបន់ដែលត្រូវបានការពារខ្ពស់ជាងគេ ក្នុងលំដាប់អន្តរជាតិនៅក្នុងប្រទេសកម្ពុជា។

## ៣.២. ការធ្វើចំណាត់ថ្នាក់តំបន់ការពារធម្មជាតិ

ក្នុងឆ្នាំ២០០៨ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានបន្ថែមប្រភេទថ្មីចំនួន ៣ ចូលទៅក្នុងតំបន់ការពារធម្មជាតិ ដែលនាំឱ្យតួលេខសរុបនៃប្រភេទតំបន់ការពារធម្មជាតិកើនឡើងដល់ ៨។ ទោះបីជា លក្ខណៈ និងគោលបំណងនៃការការពារតំបន់ធម្មជាតិ ក្នុងប្រភេទនីមួយៗត្រូវបានកំណត់ដោយច្បាប់ គោលការណ៍នៃការគ្រប់គ្រងតំបន់ទាំង ៤ អាចនឹងប្រើប្រាស់ចំពោះតំបន់ការពារទាំងនេះផងដែរក្នុងករណីចាំបាច់។

ក្រោមក្របខណ្ឌគតិយុត្តិ និងរដ្ឋបាលថ្មីនៃច្បាប់ឆ្នាំ២០០៨ តំបន់ការពារធម្មជាតិនៅកម្ពុជាត្រូវបានបែងចែក និងគ្រប់គ្រងដោយវិធានដូចតទៅ ៖

- **តំបន់ឧទ្យានជាតិ ៖** ជាតំបន់ត្រូវបានទុកបម្រុង សម្រាប់ធម្មជាតិ ទេសភាព និងត្រូវបានការពារ សម្រាប់គោលបំណងផ្សេងៗរួមមាន ការកំសាន្ត ការអប់រំ និងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ។
- **តំបន់ដែនជម្រកសត្វព្រៃ** ៖ តំបន់ការពារ និងអភិរក្សសត្វព្រៃ។
- **តំបន់ការពារទេសភាព** ៖ ជាតំបន់ដែលត្រូវបានរក្សាទុក ជាកន្លែងទស្សនាទេសភាព សម្រាប់ជាការកំសាន្ត និងទេសចរណ៍។
- **តំបន់ប្រើប្រាស់ច្រើនយ៉ាង** ៖ ជាតំបន់មានភាពចាំបាច់ សម្រាប់ស្ថេរភាពធនធានទឹក ព្រៃឈើ សត្វព្រៃ និងនេសាទ ហើយក៏បម្រើសម្រាប់ការកំសាន្ត និងការអភិរក្សធម្មជាតិ ដើម្បីជានាការអភិវឌ្ឍសេដ្ឋកិច្ច។
- **តំបន់ស្នូលនៃបបនីយជីវមណ្ឌល** ៖ តំបន់អភិរក្សជីវចម្រុះ និងគាំទ្រសកម្មភាពអភិវឌ្ឍប្រកបដោយនិរន្តរភាព។ តំបន់នេះ មានទីតាំងស្ថិតនៅខេត្តបាត់ដំបង និងខេត្តកំពង់ធំ ការបង្កើតតំបន់បបនីយជីវមណ្ឌលបឹងទន្លេសាប ជាចំណែកពិសេសនៅក្នុងច្បាប់នេះ ដែលស្តែងពីសារៈសំខាន់របស់បឹងនេះមកកាន់ប្រទេសកម្ពុជា។
- **តំបន់បេតិកភណ្ឌធម្មជាតិ** ៖ តំបន់ធម្មជាតិ ឬពាក់កណ្តាលធម្មជាតិ ដែលមានគុណតម្លៃ សម្រាប់ប្រព័ន្ធអេកូឡូស៊ី ឬ សោភ័ណភាព ឬវប្បធម៌។
- **តំបន់ឧទ្យានជាតិស**មុទ្រ ៖ តំបន់ឆ្នេរសមុទ្ររួមមានរុក្ខជាតិ សត្វព្រៃ និងមច្ឆជាតិមានគុណតម្លៃប្រវត្តិសាស្ត្រ និងវប្បធម៌។
- **តំបន់រ៉ាំសា** ៖ តំបន់ដែលត្រូវបានទទួលស្គាល់អំពីសារៈសំខាន់នៃដីសើម មានបរិស្ថានជុំវិញដែលភាគច្រើនសំដៅលើសត្វព្រៃ ជម្រករបស់វា និងប្រព័ន្ធអេកូឡូស៊ី។ ការប៉ាន់ស្មានថា មានផ្ទៃដីប្រមាណសាមសិបភាគរយរបស់កម្ពុជាជាដីសើម និងមានតំបន់ជាច្រើនទៀតដែលត្រូវបានរំពឹងថានឹងស្ថិតក្រោមការការពារដោយអនុសញ្ញាតំបន់រ៉ាំសានាពេលអនាគត។
- **ព្រំប្រទល់តំបន់ការពារ** ៖ តំបន់ការពារធម្មជាតិ។

### ក.តំបន់ឧទ្យានជាតិ

**ឧទ្យានជាតិ** គឺជាតំបន់ដែលកំណត់ដោយព្រះរាជក្រិត្យទុក សម្រាប់ការពារដែនធម្មជាតិ និងទស្សនីយភាព ដើម្បីបម្រើឱ្យវិទ្យាសាស្ត្រអប់រំ និងទេសចរណ៍។ ក្រៅពីឧទ្យានជាតិ កម្ពុជានៅមានតំបន់អភិរក្សធម្មជាតិផ្សេងៗ ដែលអាចត្រូវបានប្រើប្រាស់ក្នុងគោលដៅផ្សេងទៀត ដែលមិនប៉ះពាល់ដល់បរិស្ថានតំបន់នោះ។

ក្រសួងបរិស្ថានបានឱ្យដឹងថា គិតត្រឹមឆ្នាំ២០១៦ ឧទ្យានជាតិចំនួន១២តំបន់ ត្រូវបានបង្កើតឡើងដោយក្នុងនោះឧទ្យានជាតិចំនួន៧ បានបង្កើតឡើងដោយព្រះរាជក្រឹត្យ និងទីតាំងចំនួន ៥ តំបន់ទៀតត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ។ បើតាមក្រសួងបរិស្ថាន ឧទ្យានជាតិទាំង ១២ តំបន់នេះ បានគ្រប់ដណ្តប់លើផ្ទៃដីសរុប ១.៧២០.២៦៩,៣៥ ហិកតា ដែលស្មើនឹង ៩,៥ ភាគរយ នៃផ្ទៃដីប្រទេសស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ កោះកុង កំពត ពោធិ៍សាត់ សៀមរាប រតនគិរី ព្រះសីហនុ និងខេត្តស្ទឹងត្រែង

+ តំបន់ឧទ្យានជាតិទាំងនោះរួមមាន ៖

១. ព្រះសុរាម្រិត-កុសមៈ ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ ព្រះសីហនុ និងកោះកុង ហើយមានផ្ទៃក្រឡា ៣៥.២៣២ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០

២. ព្រះមុនីវង្ស "បូកគោ"ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពត ព្រះសីហនុ និងកំពង់ស្ពឺ ហើយមានផ្ទៃដី ១៥៤.៤៥៨ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ ។

៣. កែប ស្ថិតក្នុងភូមិសាស្ត្រខេត្តកែប ហើយមានផ្ទៃដី ១.១៥២ ហិកតា ចេញដោយអនុក្រឹត្យថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៣ ។

៤. ព្រះសីហនុ (រាម) ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ ហើយមានផ្ទៃដី ១៥.០០០ ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ។

៥. បុទុមសាគរ ស្ថិតក្នុងខេត្តកោះកុង ហើយមានផ្ទៃដី ១៧១.២៥០ ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ។

៦. ព្រះជ័យវរ្ម័ន-នរោត្តម (ភ្នំគូលែន) ស្ថិតក្នុងខេត្តសៀមរាប ហើយមានផ្ទៃដីប្រមាណ ៣៧.៥០០ ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ។

៧. វីរៈជ័យ ស្ថិតក្នុងខេត្តរតនគិរី និងស្ទឹងត្រែង ហើយមានផ្ទៃដី ៣៣២.៥០០ ហិកតា ចេញដោយព្រះរាជក្រឹត្យ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ។

៨. វ៉ុនសៃ-សៀមប៉ាង ស្ថិតក្នុងខេត្តស្ទឹង និងរតនគីរី ហើយមានផ្ទៃដី ៥៧. ៤៦៩ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ។

៩. ជួរភ្នំក្រវាញកណ្តាល ស្ថិតក្នុងខេត្តកោះកុង ពោធិ៍សាត់ និងកំពង់ស្ពឺ ហើយមានផ្ទៃដី៤០១.៣១៣ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ។

១០. អូរយ៉ាដាវ ស្ថិតក្នុងខេត្តរតនគិរី ហើយមានផ្ទៃដីប្រមាណ ១០១. ៣៤៨ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ។

១១. ជួរភ្នំក្រវាញខាងត្បូង ស្ថិតក្នុងខេត្តកោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និងព្រះសីហនុ មានផ្ទៃដី៤១០. ៣៩២ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ។

១២. កោះរ៉ុង ស្ថិតក្នុងខេត្តព្រះសីហនុ ហើយមានផ្ទៃដីប្រមាណ ២.៦៥៥, ៣៥ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ។

តំបន់ឧទ្យានជាតិ គឺសំដៅដល់តំបន់ធម្មជាតិក្នុងដែនដីគោក ឬ ដែនទឹកដែលត្រូវបានកំណត់ដើម្បីការពារខាងផ្នែកប្រព័ន្ធអេកូឡូស៊ីមួយ ឬច្រើនរបស់តំបន់ ដែលបានកំណត់សម្រាប់ជាប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់ ។ ជាពិសេសកម្រិតដល់ការប្រើប្រាស់ដែលអាចធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញដល់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារតួនាទីរបស់តំបន់នោះ ជាមួយនឹងគោលបំណងនៃការកំណត់តំបន់ និងការផ្តល់មូលដ្ឋានសម្រាប់ការកំសាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿដែលគ្រប់សកម្មភាពទាំងនេះ ដោយពុំបង្កការគម្រាមកំហែងដល់បរិស្ថានធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋានឡើយនេះបើតាមក្រសួងបរិស្ថាន។

- **ឧទ្យានជាតិគីរីរម្យ**

**ឧទ្យានជាតិព្រះសុរាម្រិតកុសុមៈគីរីរម្យ** ដែលគ្រប់គ្នាស្គាល់ថាជា ឧទ្យានជាតិគិរីរម្យ (Kirirom National Park) ជាឧទ្យានជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅចំងាយ ១១២ គ.ម ពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ ៤ ទៅកាន់ក្រុងព្រះសីហនុ។ ឧទ្យានជាតិគិរីរម្យស្ថិតនៅក្នុង ភូមិជំរំផុត ឃុំគិរីរម្យ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ឧទ្យានជាតិគីរីរម្យលាតសន្ធឹងលើផ្ទៃដីដែលមានព្រៃ ឈើប្រមាណ ៨ ម៉ឺនហិកតា។ ភ្នំគិរីរម្យមានកំពស់ ៧០០ ម៉ែត្រ។ ដោយគ្របដណ្តប់លើផ្ទៃដីប្រមាណ ៨.៤០១ ហិកតា និងស្ថិតនៅលើខ្ពង់រាបដែលមានរយៈកម្ពស់ចាប់ពី ៣០០ ទៅ ១០០០ ម៉ែត្រ ពីលើនីវ៉ូទឹកសមុទ្រ។ រមណីយដ្ឋានគិរីរម្យ គឺជាតំបន់ឧទ្យានធម្មជាតិដ៏ធំ ដែលស្ថិតនៅជិតរាជធានីភ្នំពេញជាងគេ ហើយតាំងនៅទិសខាងត្បូងឆៀងខាងលិច (និរតីទិស) នៃរាជធានីប្រទេសកម្ពុជា។ ពីក្រុងភ្នំពេញគេអាចធ្វើដំណើរទៅទស្សនាតំបន់គិរីរម្យបានយ៉ាងងាយស្រួល តាមរយៈផ្លូវជាតិលេខ ៤ ដូចទៅកាន់ក្រុងព្រះសីហនុដែរ ប៉ុន្តែដល់បង្គោលគីឡូម៉ែត្រលេខ ៨៧ ត្រង់មុំផ្លូវបំបែកត្រែងត្រយឹង គេនឹងឃើញមានផ្លូវបំបែកខាងស្តាំដៃមួយឆ្ពោះទៅកាន់តំបន់គិរីរម្យ ដែលមានចម្ងាយផ្លូវ ២៧ គ.ម ក្នុងរយៈចម្ងាយផ្លូវ ១០ គ.ម ដំបូង គឺជាផ្លូវរាបស្មើ និង ១៧ គ.ម បន្ទាប់ទៀត គឺជាផ្លូវឡើងខ្ពង់រាប និងភ្នំ។ រមណីយដ្ឋាននេះ មានចម្ងាយពីរាជធានីភ្នំពេញ ១១៤ គ.ម និង ១៤៧ គ.ម ពីក្រុងព្រះសីហនុ ឬមានចម្ងាយ ៤៤ គ.ម ពីទីរួមខេត្តកំពង់ស្ពឺ។

ព្រៃធម្មជាតិនៅតំបន់គិរីរម្យ រួមមានប្រភេទព្រៃស្រល់សុទ្ធភាគច្រើន និងព្រៃឈើតំបន់ត្រូពិកជាច្រើនប្រភេទទៀត។ ព្រៃស្រល់ធម្មជាតិ គឺជាចំណុចពិសេសរបស់រមណីយដ្ឋាននេះ ហើយក៏ជាព្រៃស្រល់បម្រុងទុកធំជាងគេបំផុតនៅប្រទេសកម្ពុជាផងដែរ  គេបែងចែកព្រៃនៅតំបន់នោះ ជាប្រភេទព្រៃស្រល់ចំរុះ ឬព្រៃ Dipterocarpaceas និងព្រៃជាំស្លឹកធំ Gallery Forest ដុះនៅតាមមាត់អូរជ្រោះ ស្ទឹង និងព្រៃមួយប្រភេទទៀត គឺជាស្រោងសើម Moist dense dipterocarp forest ដែលសម្បូរទៅដោយជីវសាស្ត្រចម្រុះនៅទីនោះផងដែរ។ គួររំលឹកថា ពីមុនទសវត្សរ៍ឆ្នាំ១៩៩០ តំបន់គិរីរម្យទាំងមូលមានផ្ទៃដីរហូតដល់ ៨១.៧២០ ហិកតា ហើយដើម្បីឆ្លើយតបទៅនឹងការវិចវិល្ជរួមតូច ដោយការកាប់បំផ្លាញនៃធនធានធម្មជាតិព្រៃឈើនៅទូទាំងប្រទេស ដែលបានកើតមានចំពោះឧទ្យានជាតិ និងដែនជម្រកសត្វព្រៃដ៏សំខាន់នេះ និងក៏ដូចជាការទប់ស្កាត់នូវរាល់វិនាសកម្មព្រៃឈើក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចុះបញ្ជីរមណីយដ្ឋានគិរីរម្យជា "ឧទ្យានជាតិព្រះសុរាម្រិត" ដែលមានផ្ទៃដី ៣៥០០០ ហិកតា តាមព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។ ហើយឧទ្យានជាតិនេះបានបើកសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩៥ រហូតមកដល់បច្ចុប្បន្ននេះ។ ចំពោះបញ្ហាសន្តិសុខ និងសុវត្ថិភាពនៃតំបន់ឧទ្យានជាតិគិរីរម្យទាំងមូល គឺមានលក្ខណៈល្អប្រសើរណាស់ ដែលមានអំណោយផលដល់ការអភិវឌ្ឍខាងវិស័យទេសចរណ៍ សម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលទៅទស្សនាកម្សាន្តសប្បាយបានគ្រប់រដូវកាល។ នៅក្នុងតំបន់ឧទ្យានជាតិគិរីរម្យបច្ចុប្បន្ន មានតំបន់ទេសចរណ៍សំខាន់ៗ សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនា និងលេងកម្សាន្តសប្បាយជាច្រើន ក្នុងនោះមានរមណីយដ្ឋានទឹកជ្រោះភ្នំ ដំណាក់ចាស់ ដំណាក់ថ្មី តំបន់ស្រះស្រង់ តំបន់ទឹកធ្លាក់ ជ្រោះអូរតាហ៊ុយ តំបន់ចម្ការតែ ភ្នំថ្មដា និងតំបន់ល្អាងភ្នំ។

ឧទ្យានជាតិនេះ ត្រូវបានបង្កើតឡើងនៅក្នុងនៅឆ្នាំ១៩៤០ ដោយនាយកដ្ឋានគង្គា រុក្ខប្រមាញ់ ហើយបានធ្វើផ្លូវជាលើកដំបូងចូលទៅដល់ទីខ្ពង់រាបគិរីរម្យ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៤៤ សម្តេចព្រះនរោត្តម សីហនុ បានយាងធ្វើព្រះរាជទស្សនកិច្ចតំបន់នោះជាលើកដំបូងតាមរយៈដំរី ព្រះអង្គក៏បានសព្វព្រះរាជហឫទ័យចំពោះទេសភាពដ៏ល្អប្រណីតនៃតំបន់នេះ។ ព្រះអង្គបានព្រះរាជតម្រិះថា « ព្រៃស្រល់បែបនេះ មានតែនៅក្នុងប្រទេសបារាំងប៉ុណ្ណោះ មិននឹកស្មានថា ព្រៃស្រស់នេះមាននៅក្នុងប្រទេសកម្ពុជា ឡើយ។ នៅពេលនោះព្រះអង្គរាជានុញ្ញាតឱ្យអ្នកជំនាញបច្ចេកទេសសិក្សា និងកំណត់ឈ្មោះតំបន់នេះថា «ខ្ពង់រាបគិរីរម្យ» ព្រះរាជក្រមលេខ ១២៩ លរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៤៤។ នៅក្នុងឆ្នាំនោះ មានអ្នកវិទ្យាសាស្ត្រក៏ដូចជាក្រុមភូមិសាស្ត្រ បសុព្យាបាល និងក្រុមភូមិសាស្ត្រ បានចូលទៅធ្វើការសិក្សាស្រាវជ្រាវពីស្ថានភាពភូមិសាស្ត្រ ស្ថានភាពដី ស្ថានភាពជីវសាស្ត្រនៅតំបន់គិរីរម្យជាច្រើនក្រុមជាបន្ត បន្ទាប់។ នៅក្នុងឆ្នាំ១៩៤៤ នោះដែរ នាយកដ្ឋានគង្គា និងរុក្ខាប្រមាញ់បានកំណត់តំបន់គិរីរម្យថា «ជាព្រៃបម្រុងទុកសម្រាប់ផ្តល់ផលទៅថ្ងៃអនាគត»។ ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៤៥ សម្តេចព្រះ នរោត្តម សីហនុ បានយាងធ្វើព្រះរាជទស្សនកិច្ច និងគង់ប្រថាប់នៅព្រះរាជសំណាក់ ដែលរៀបចំសាងសង់ឡើងដោយនាយកដ្ឋានគង្គា និងរុក្ខាប្រមាញ់នៅអូរខ្សាច់ស។

នៅក្នុងឆ្នាំ១៩៤៩ នាយកដ្ឋានគង្គា និងរុក្ខាប្រមាញ់ បានដំណើរការសាងសង់ផ្លូវ និងស្ពាននានាទៅទូទាំងតំបន់គិរីរម្យ សម្រាប់បម្រើឱ្យវិស័យទេសចរណ៍។ នៅចុងឆ្នាំ១៩៤៩ តំបន់គិរីរម្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរឥស្សរៈ។ ការគ្រប់គ្រងរបស់ខ្មែរឥស្សរៈរយៈពេល១ឆ្នាំ ស្ពានជាច្រើន នៅក្នុងតំបន់គីរីរម្យត្រូវបានដុតបំផ្លាញដោយជនប្រដាប់អាវុធ ហើយនៅពេលនោះភ្នាក់ងាររុក្ខានៃនាយកដ្ឋានគង្គា និងរុក្ខាប្រមាញ់ បានសម្រេចចិត្តបញ្ឈប់សកម្មភាពគ្រប់គ្រងតំបន់គិរីរម្យ ប៉ុន្តែពួកគេបានវិលត្រឡប់ចូលមកគ្រប់គ្រងតំបន់នេះវិញនៅដើមឆ្នាំ១៩៥៤។ បន្ទាប់ពីសន្និសីទអន្តរជាតិនៃទីក្រុងហ្សឺណែវ នៃប្រទេសស្វីស ខែវិច្ឆិកា ឆ្នាំ ១៩៥៤ ដែលបារាំងបានប្រគល់ឯករាជ្យភាពពេញបរិបូរណ៍ជូនប្រទេសកម្ពុជា ទើបនាយកដ្ឋានគង្គា និងរុក្ខាប្រមាញ់ បានចាបផ្តើមដំណើរការការងារ និងសកម្មភាពគ្រប់គ្រងព្រៃឈើរបស់ខ្លួនឡើងវិញ ក្នុងតំបន់គិរីរម្យដោយយោងទៅតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៥០។ នៅឆ្នាំ១៩៦២ តំបន់គិរីរម្យ ត្រូវបានកសាងឡើងជាក្រុងទេសចរណ៍មានឈ្មោះថា "ក្រុងដូឡុង" ឬហៅថា "បុរីដូឡុង"។ មូលហេតុដែលក្រុងនេះត្រូវបានកំណត់ឈ្មោះថា ក្រុងដូឡុង ព្រោះសម្តេចចក្រី ញឹក ជូឡុង នៅពេលនោះ គឺជាសកម្មជនម្នាក់ដ៏សំខាន់ក្នុងការរួមវិភាគទាន និងចលនាប្រជាជន ដើម្បីស្ថាបនាទីក្រុងទេសចរណ៍ដ៏ប្រណីតនេះឡើង។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ក្រៅពីរាជធានីភ្នំពេញ និងក្រុងព្រះសីហនុ ឬក្រុងកំពង់សោមរដ្ឋាភិបាលសម័យនោះបានបង្កើតជាក្រុងថ្មីៗមួយចំនួនទៀតដូចជា ក្រុងអង្គរ ក្រុងកែប ក្រុងបូកគោ ក្រុងប៉ៃលិន និងក្រុងបុរីជូឡុងនេះឯង។

ជីវចម្រុះដែលសម្បូរជាងគេបំផុតនៅទឹកដីខេត្តកំពង់ស្ពឺ គឺភ្នំឱរ៉ាល់ និងតំបន់ឧទ្យានជាតិគីរីរម្យ ហើយតំបន់សម្បូរលំដាប់បន្ទាប់ គឺតំបន់រដ្ឋបាលព្រៃឈើ។ អេកូឡូស៊ីព្រៃឈើ គឺជាផ្នែកមួយដ៏សំខាន់នៃមូលដ្ឋានធនធានធម្មជាតិ សម្រាប់ពិភពលោកទាំងមូល។ តាមរយៈអេកូឡូស៊ីព្រៃឈើនៅលើពិភពលោកនេះ វាបានជះឥទ្ធិពលជាខ្លាំងទៅលើកត្តាមួយចំនួនលើពិភពលោកដូចជា ការទទួលបានទឹកភ្លៀង សីតុណ្ហភាព សំណើមដី

និងកត្តាជាច្រើនមួយចំនួនទៀត។ ព្រៃឈើនៅឧទ្យានជាតិគីរីរម្យ គឺត្រូវបានគេបែងចែកជាពីរតំបន់គឺ ព្រៃស្រល់ចម្រុះ និងតំបន់ព្រៃឈើដែលមានស្លឹកធំនៅតាមបណ្ដោយមាត់ទឹកដូចជា អូរ ជ្រោះ បឹងជាដើម។

ព្រៃស្រល់ចម្រុះច្រើនមានដុះនៅលើទឹកដីឧទ្យានជាតិគីរីរម្យ ដែលមានរយៈកម្ពស់ចាប់ពី ៣០ម៉ែត្រទៅដល់ ៥០ ម៉ែត្រ ភាគច្រើនដុះនៅតាមបណ្ដោយចង្កេះភ្នំ និងនៅតាមខ្ពង់រាបរបស់វា។ ក្នុងព្រៃប្រភេទនេះគេចែកចេញជាពីរស្រទាប់ ដែលស្រទាប់ទីមួយជាស្រទាប់រុក្ខជាតិខ្ពស់បំផុត គឺពួកដំណុះរុក្ខជាតិស្រល់។ ចំណែកឯស្រទាប់ទីពីរវិញ គឺជាស្រទាប់ថ្នាក់ទាបដែលមានប្រភេទរុក្ខជាតិជាច្រើនដុះនៅលាយឡំគ្នាជាមួយដើមស្រល់មានដូចជា ក្លូ ប្រម៉ាស ខ្លៀវ ធ្នង់ ត្បែង ត្រាច សុក្រំ នុបពិសី ត្រង់ ផ្ដុង កណ្ដាល គ្រើល ពពលធ្លក និងកំពូលបាយជាដើម។

- **ឧទ្យានជាតិវីរៈជ័យ**

ឧទ្យានជាតិវីរៈជ័យ មានទីតាំងនៅភាគឦសានប្រទេសកម្ពុជា លាតសន្ធឹងគ្របដណ្ដប់ខេត្តរតនគិរីនិងស្ទឹងត្រែង ។ ឧទ្យាននេះ មានព្រំប្រទល់ជាប់ប្រទេសឡាវ និងវៀតណាម ហើយមានផ្ទៃក្រឡា ៣.៣២៥ គីឡូម៉ែត្រក្រឡា និងស្ថិតនៅភាគនិរតី នៃប្រជុំជួរភ្នំអាណ្ណាម ដែលលាតសន្ធឹងចេញពីប្រទេសវៀតណាម និងស្ថិតនៅជាយវាលព្រៃជម្រុះស្លឹកឥណ្ឌូចិនកណ្ដាល។ ឧទ្យានជាតិវិរៈជ័យ ចាត់ទុកជាដែនជម្រកមួយ សម្រាប់ពពួកថនិកសត្វធំៗរបស់ប្រទេសកម្ពុជាមានដូចជា ខ្ទីង ទន្សោង ក្របីព្រៃ ដំរី ខ្លាដំបង ខ្លារខិនជាដើម។ លក្ខណៈជីវសាស្ត្រឧទ្យានជាតិវីរៈជ័យ មានសារៈសំខាន់ដល់ការងារ អភិរក្សអន្តរជាតិ ។ ឧទ្យានជាតិនេះ ជាដែនជម្រកព្រៃឈើសើមរយៈកម្ពស់មធ្យមប្រមាណជាង ៧៥ភាគរយនៃផ្ទៃប្រទេស។ ភាគច្រើននៃតំបន់ភូមិភាគឦសានប្រទេសកម្ពុជា គ្របដណ្ដប់ដោយព្រៃជម្រុះស្លឹក និងព្រៃពាក់កណ្ដាលស្រោង។ ព្រៃឈើឧទ្យានជាតិវីរៈជ័យភាគច្រើន ជាប្រភេទព្រៃពាក់កណ្ដាលស្រោង និងព្រៃស្រោងបៃតងជានិច្ច ទិដ្ឋភាពចម្រុះរបស់ឧទ្យានជាតិនេះ ក៏បង្កប់ផងដែរនូវតំបន់ទំនាបលិចទឹក វាលស្មៅ ព្រៃឫស្សី ព្រៃចម្រុះជ្រុះស្លឹក និងព្រៃជ្រុះស្លឹកសុទ្ធ ។ ឧទ្យានជាតិនេះ អាចជាដែនជម្រកព្រៃឈើនៅសល់ចុងក្រោយគេបំផុត ដែលមានរុក្ខជាតិប្រចាំតំបន់ចាំបាច់ត្រូវការពារ។ មានទន្លេធំៗពីរ គឺទន្លេសេសាននៅភាគខាងត្បូង និងទន្លេសេកុង នៅភាគខាងលិចជាប់នឹងឧទ្យានជាតិ។ ទន្លេធំៗទាំងពីរ និងស្ទឹងធំៗមួយចំនួនទៀត ដែលមាននៅក្នុងឧទ្យានជាតិ គឺជាប្រភពអាងទឹកដ៏សំខាន់របស់តំបន់នេះ ហើយវាក៏បានទ្រទ្រង់ដល់ធម្មជាតិ និងសត្វទឹកនានាមួយចំនួនធំ ដែលខ្លះជាប្រភេទប្រចាំតំបន់។

- **ឧទ្យានជាតិកែប**

**ឧទ្យានជាតិកែប** មានទីតាំងស្ថិតនៅក្នុងដែនដីនៃខេត្តកែប ដែលមានចម្ងាយប្រមាណ ២៥គីឡូម៉ែត្រពីទីក្រុងកំពត ហើយមានចម្ងាយ ១៧៣ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ឧទ្យានជាតិនេះមានផ្ទៃដី ៥.០០០ ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹងផ្លូវជាតិលេខ ១៦ ខាងត្បូងជាប់នឹងឆ្នេរសមុទ្រ ខាងកើត និងខាងលិចជាប់នឹងផ្លូវជាតិលេខ ១៦២ ។ បុរីកែបមានព្រំប្រទល់ប្រមាណ ១៥ គីឡូម៉ែត្រក្រៅពីផ្លូវគោក ផ្លូវសមុទ្រក៏ជាមធ្យោបាយគមនាគមន៍ដ៏សំខាន់ សម្រាប់សហគមន៍ក្នុងតំបន់ផងដែរ។ ច្រើនជាងនេះទៅទៀត វាផ្ដល់នូវធនធាន សមុទ្រដ៏ច្រើនដល់ប្រជាជនក្នុងតំបន់ដូចជា ត្រី ក្ដាម បង្គា មឹក លៀស ខ្យង ងាវ។ល។ ទិដ្ឋភាពដ៏ស្រស់ត្រកាលនៃឆ្នេរខ្សាច់នៃតំបន់ឧទ្យានជាតិកែប គឺជួយទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យនៅ

ស្នាក់កម្សាន្តតំបន់នោះផងដែរ ផ្នែកមួយចំនួននៃមាត់សមុទ្រនៅភាគខាងកើត និងខាងលិចនៃតំបន់នេះ ព្រៃកោងកាងលាតសន្ធឹងពីទំនាបទឹកប្រៃរហូតដល់មាត់សមុទ្រ ហើយព្រៃកោងកាងខាងលើនេះផ្តល់ជាថ្នាលបណ្តុះពូជ និងជាទីសម្បុកពងកូនដល់ពពួកត្រី ក្តាម ខ្យង ល្មូន និងគ្រប់សត្វសមុទ្រ។ ក្រៅពីនោះ ក៏ជាតំបន់តូចធំធ្លាប់មានប្រវត្តិថាជាតំបន់ជម្រកធម្មជាតិដ៏សំខាន់ សម្រាប់សត្វព្រៃដូចជា ចតុប្បាទ បក្សាបក្សីសម្បូរបែបប្រកបដោយជីវសាស្ត្រចម្រុះ និងសោភ័ណភាពទេសភាពស្រស់បំព្រង។

ដើម្បីរាំងនឹងការដែលចេះតែមិនឈប់ឈរនូវការកាប់បំផ្លាញព្រៃឈើ បំផ្លាញជម្រកធម្មជាតិ និងជីវសាស្ត្រចម្រុះនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រូវបានសម្រេច និងប្រកាសដាក់ជាឧទ្យានជាតិដោយព្រះរាជក្រឹត ដែលឡាយព្រះហស្ថដោយព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ។

- **ឧទ្យានជាតិបូកគោ**

ឧទ្យានជាតិបូកគោ មានផ្ទៃដី ១៤០ ០០០ ហិកតា ស្ថិតនៅក្នុងខេត្តកំពត។ លក្ខណៈពិសេសនៃឧទ្យាននេះ គឺស្ថិតនៅលើរយៈកម្ពស់ ១ ០៧៦ ម៉ែត្រ ដែលមានធាតុអាកាសត្រជាក់ហើមជានិច្ច ហើយនៅរដូវវស្សាភ្ញៀវទេសចរអាចមើលឃើញរូបភាពពពកពិត ដែលហោះហើរអណ្តែតជុំវិញខ្លួន។ នៅលើកំពូលភ្នំ បើយើងសម្លឹងមើលទៅទិសខាងលិច យើងអាចមើលឃើញទស្សនីយភាពដ៏ស្អាតនៃក្រុងព្រះ-សីហនុ ហើយបើយើងសម្លឹងមើលខាងកើតវិញ យើងយើងអាចមើលឃើញទិដ្ឋភាពទីរួមខេត្តកំពត និងទស្សនីយភាពក្រុងកែប។

ចំណែកឯនៅភូមិសាស្ត្រពពកវិលមានទឹកធ្លាក់បីជំណាក់ ដែលជាកន្លែងសម្រាកលម្ហែមិនអាចបំភ្លេចបាន។ សណ្ឋានដីនៅលើភ្នំបូកគោ ជាដីមមោកតំបន់ខ្ពស់ សម្បូរប្រភេទរុក្ខជាតិស្រល់ ធមធា ព្រមទាំងមានថនិកសត្វធំៗរួមមាន ខ្លាដំបង ដំរីខ្លាឃ្មុំ និងខ្លាឃ្មុំខ្មៅនៅអាស៊ី។

- **ឧទ្យានជាតិព្រះសីហនុរាម**

ឧទ្យានជាតិព្រះសីហនុរាមមានផ្ទៃដី ២១០០០ហិកតា ស្ថិតនៅក្នុងខេត្តព្រះសីហនុហើយលក្ខណៈពិសេសនៃឧទ្យាននេះ សម្បូរព្រៃស្រោងដុះឡើងវិញនៅដីទំនាប ព្រមទាំងព្រៃកោងកាង Mangrove Forest ដុះតាមព្រែកទឹកសាប និងតាមតំបន់ឆ្នេរសមុទ្រ។

ភ្ញៀវទេសចរអាចធ្វើដំណើរកំសាន្ត ឬទៅស្រាវជ្រាវតាមមធ្យោបាយពីរយ៉ាង គឺអាចតាមផ្លូវគោកដោយប្រើរថយន្តគ្រប់ប្រភេទ ជិះមើលទេសភាពឆ្នេរសមុទ្រ មើលទេសភាពចម្ការដូង និងអាចឆ្លងទៅលេងកោះតាកៀវតាមអូប័រ។ ចំណែកឯការធ្វើដំណើរតាមផ្លូវទឹកវិញ គឺចាប់ផ្តើមចេញដំណើរតាមព្រែកទឹកសាបដោយទូក ឬកាណូតរបស់ឧទ្យាននុរក្ស មើលទេសភាពព្រៃកោងកាង និងឆ្នេរខ្សាច់ដ៏ស្អាតគ្មានពីរនៃកោះសំប៉ូច (កោះរាជបុត្រ)។

- **ឧទ្យានជាតិបុទុមសាគរ**

ឧទ្យានជាតិបុទុមសាគរ មានផ្ទៃដី ១៧១ ២៥០ ហិកតា ស្ថិតនៅក្នុងខេត្តកោះកុង។ លក្ខណៈពិសេសនៃឧទ្យាននេះ គឺសម្បូរព្រៃស្រោងទំនាបធំៗ ស្ថិតនៅសភាពល្អនៅឡើយ ព្រៃកោងកាង និង Dacrydium Podcarpus ព្រៃនៅវាលភក់តំបន់ឆ្នេកម្ពុជា ។

- **ឧទ្យានជាតិជ័យវរ្ម័ននរោត្តម (ភ្នំគូលែន)**

ឧទ្យានជាតិជ័យវរ្ម័ន នរោត្តម (ភ្នំគូលែន) មានផ្ទៃដី ៣៧ ៥០០ ហិចតា ស្ថិតនៅខេត្តសៀមរាប

ហើយលក្ខណៈពិសេសរបស់តំបន់ឧទ្យានជាតិនេះ គឺជាតំបន់ស្ថិតនៅអាងរងទឹកភ្លៀងរបស់ស្ទឹងសៀមរាប។ ឧទ្យានជាតិនេះបម្រើឱ្យវិស័យទេសចរណ៍ធម្មជាតិ និងទេសចរណ៍វប្បធម៌ផង ពីព្រោះនៅតំបន់នេះ អតីតជាទីក្រុងរបស់ព្រះមហាក្សត្រជ័យវរ្ម័នទី២ ដែលបានបន្សល់ទុកនៅមរតកបុរាណវត្ថុជាច្រើន។

- **ឧទ្យានជាតិកោះរ៉ុង**

ឧទ្យានជាតិកោះរ៉ុង កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានចេញអនុក្រឹត្យសម្រេចបង្កើតឱ្យមានជាឧទ្យានជាតិសមុទ្រកោះរ៉ុង ដោយបានដាក់ទីតាំង ឬតំបន់មួយចំនួននាខេត្តព្រះសីហនុ និងកោះកុងរួមមានកោះរ៉ុង កោះរ៉ុងសន្លឹម កោះកូន កោះតូច កោះតាទៀម កោះម្នាស់ក្រៅ កោះម្នាស់ក្នុង និងសមុទ្រជុំវិញ ដែលមានផ្ទៃដីសរុបទាំងអស់ជាង ៥ ម៉ឺន ២ ពាន់ហិកតា (៥២ ៤៤៨) ឱ្យក្លាយទៅជាឧទ្យានជាតិសមុទ្រកោះរ៉ុង។ នៅក្នុងនោះមានផ្ទៃដីលើគោកមានទំហំជាង ៥ ពាន់ហិចតា (៥ ៣១១) និងផ្ទៃទឹកសមុទ្រមានទំហំជាង ៤៧ ១៣៧ ហិកតា។ ខ្លឹមសារនៅក្នុងអនុក្រឹត្យនេះ គឺមានគោលដៅធានាថែរក្សា និងការពារសោភ័ណភាពព្រៃឈើធម្មជាតិ វប្បធម៌ ប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះលើកោះ និងបរិវេណសមុទ្រជុំវិញ ដែលផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយចីរភាព ការរក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជន ក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការថែរក្សាការការពារ និងការអភិរក្សជីវចម្រុះ និងធនធានធម្មជាតិក្នុងតំបន់

- **ឧទ្យានជាតិ វីរៈសៃ សៀមប៉ាង**

ឧទ្យានជាតិ វីរៈសៃ-សៀមប៉ាង ស្ថិតក្នុងខេត្តស្ទឹងត្រែង និងខេត្តរតនគីរី ហើយមានផ្ទៃដីសរុប ៥៧ ៤៦៩ ហិចតា ចេញដោយអនុក្រឹត្យ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។

- **ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល**

ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ស្ថិតក្នុងខេត្តកោះកុង ពោធិ៍សាត់ និងកំពង់ស្ពឺ មានផ្ទៃដី៤០១ ៣១៣ ហិចតា ចេញដោយអនុក្រឹត្យ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។

- **ឧទ្យានជាតិអូរយ៉ាដាវ**

ឧទ្យានជាតិអូរយ៉ាដាវ ស្ថិតក្នុងខេត្តរតនគីរី ហើយមានផ្ទៃដី ១០១ ៣៤៨ ហិចតា ចេញដោយអនុក្រឹត្យ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។

- **ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង**

ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ស្ថិតក្នុងខេត្តកោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និងព្រះសីហនុ ហើយមានផ្ទៃដី ៤១០ ៣៩២ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។

### ខ. តំបន់ដែនជម្រកសត្វព្រៃ

តំបន់ដែនជម្រកសត្វព្រៃ ជាតំបន់ធម្មជាតិដែលប្រភេទសត្វ និងរុក្ខជាតិមានសារៈសំខាន់ជាលក្ខណៈជាតិ ឬលក្ខណៈរូបសាស្ត្រ ទាមទារនូវអន្តរាគមន៍ ពិសេសភាពស្ថិតស្ថិររបស់វា។ ដែនជម្រកសត្វព្រៃ IUCN បានចាត់លំដាប់ថ្នាក់លេខ១ ដើម្បីទុកជាតំបន់បម្រុងតែធម្មជាតិ និងជាតំបន់ហាមប៉ះ ពាល់មានដូចជាតំបន់

ការពារធម្មជាតិជាពិសេស សម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ ឬតំបន់ការពារហោមប៉ះពាល់។ ដែនជម្រកសត្វព្រៃនៃព្រះរាជាណាចក្រកម្ពុជាមាន ១០ កន្លែងគឺ ៖

- **ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់**

ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ មានផ្ទៃដីសរុប ២៥៣ ៧៥០ ហិចតា ស្ថិតនៅក្នុងខេត្តកោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។ លក្ខណៈពិសេសនៃតំបន់នេះ គឺមានភ្នំខ្ពស់ៗ និងព្រមទាំងមានរុក្ខជាតិប្លែកៗជាច្រើន គឺចាប់ពីព្រៃប្រភេទដើមឈើទាល និងប្រភេទដើមស្រល់ ធមធារ ជាព្រៃស្ងួត រហូតដល់ព្រៃស្រោងដែលមានកម្ពស់មធ្យម។ ចំពោះផ្នែកដែលខ្ពស់ នៃតំបន់នេះមិនទាន់មានការបកស្រាយតាមផ្នែករុក្ខសាស្ត្រនៅឡើយទេ។ ថនិកសត្វធំៗនៅតំបន់នេះមាន ខ្លាដំបង ទន្សោង ខ្ទីង និងរមាំង ដែលជាប្រភេទកំពុងរងគ្រោះថ្នាក់ និងការគំរាមកំហែង។

- **ដែនជម្រកសត្វព្រៃពាមក្រសោប**

ដែនជម្រកសត្វព្រៃពាមក្រសោបមានផ្ទៃដី ២៣ ៧៥០ ហិចតា ស្ថិតនៅក្នុងខេត្តកោះកុង ហើយលក្ខណៈពិសេសនៃតំបន់នេះ គឺសម្បូរព្រៃកោងកាងដែលមានសារៈសំខាន់បំផុតសម្រាប់ប្រទេសកម្ពុជា និងប្រហែលជាព្រៃដែលធំជាងគេបំផុតនៅឈូងសមុទ្រថៃ [៦]។

- **ដែនជម្រកសត្វព្រៃរនាមដូនសំ**

ដែនជម្រកសត្វព្រៃរនាមដូនសំ មានផ្ទៃដីសរុបទាំងអស់ ១៧៨ ៥០០ ហិកតា ស្ថិតនៅក្នុងខេត្តបាត់ដំបង និងបន្ទាយមានជ័យ។ តំបន់នេះ ជាតំបន់ព្រៃស្រោង និងពាក់កណ្តាលព្រៃស្រោងនៅលើដីទំនាប។ ចំពោះស្ថានភាពផ្សេងៗ គេមិនទាន់ដឹងច្បាស់នៅឡើយអំពីស្ថានភាពនៅក្នុងព្រៃតំបន់នេះទេ។

- **ដែនជម្រកសត្វព្រៃគូលេន-ព្រហ្មទេព**

ដែនជម្រកសត្វព្រៃគូលេន-ព្រហ្មទេព មានផ្ទៃដីសរុប ៤០២ ៥០០ ហិកតា ស្ថិតនៅក្នុងខេត្តសៀមរាប និងព្រះវិហារ។ ដែនជម្រកសត្វព្រៃនេះ ជាតំបន់ធំជាងគេបំផុត ក្នុងចំណោមប្រព័ន្ធតំបន់ការពារធម្មជាតិ ហើយដែលមានបំណងទុកសម្រាប់**ការពារគោព្រៃ**។

ជម្រកសំខាន់ៗរួមមាន៖

- វាលព្រៃប្រភេទដើមឈើទាលនៅដីទំនាប (មានប្រវត្តិមានដង់ស៊ីតេគោព្រៃខ្ពស់)
- ព្រៃស្រោង និងពាក់កណ្តាលព្រៃស្រោង
- វាលភក់ដ៏ធំបំផុតនៅប៉ែកឦសានរបស់ប្រទេសកម្ពុជា

- **ដែនជម្រកសត្វព្រៃបឹងពែរ**

ដែនជម្រកសត្វព្រៃបឹងពែរមានផ្ទៃដីសរុប ២៤២ ៥០០ ហិកតា ស្ថិតនៅខេត្តកំពង់ធំ សៀមរាប និងព្រះវិហារ ជាដែនជម្រកសត្វព្រៃពីមុនតាមរបាយការណ៍ក្រសួងបរិស្ថានបានឱ្យដឹងថា ដែនជម្រកសត្វព្រៃនេះមានពពួកពពួកក្តាន់ រមាំងជាច្រើន ព្រមទាំងមានបក្សីជាច្រើន បានកើតជាកូនជាចៅប្រហែលជាមានដំរីមួយចំនួនធ្វើអន្តោប្រវេសន៍ដែរ ហើយម្យ៉ាងទៀតតំបន់នេះក៏មានបុរាណវត្ថុសំខាន់ៗមួយចំនួនផងដែរ។

- **ដែនជម្រកសត្វព្រៃលំផាត់**

ដែនជម្រកសត្វព្រៃលំផាត់ មានផ្ទៃដីសរុប ២៥០ ០០០ ហិកតា ស្ថិតនៅក្នុងទឹកដីនៃខេត្តរតនគីរី

និងខេត្តមណ្ឌលគីរី។ កាលពីមុនសង្គ្រាមក្នុងតំបន់នេះ ត្រូវបានស្នើរឡើងជាតំបន់បម្រុងសម្រាប់គោព្រៃ ព្រំដែនកាលពីដើមត្រូវបានពង្រីកសម្រាប់បញ្ចូលប្រភេទរុក្ខជាតិបន្ថែមទៀត។ តំបន់នេះភាគច្រើនសម្បូរព្រៃស្រោង ដែលដុះនៅលើដីបាសាល់ វាលស្មៅស្ថិតនៅចន្លោះព្រៃរបោះ ព្រៃរបោះចម្រុះ ព្រៃពាក់កណ្ដាលស្រោង ជម្រកតាមទន្លេ និងតំបន់ដីសើមតូចៗ។ គេសង្កេតឃើញមាន ទន្សោង ឆ្កែព្រៃអាស៊ី និងមានដំរីអន្តោប្រវេសន៍មកកន្លែងនេះមួយរយៈពេលជារៀងរាល់ឆ្នាំ ហើយតំបន់នេះក៏ជាតំបន់បន្តពូជរបស់សត្វក្រៀលផងដែរ។

- **ដែនជម្រកសត្វព្រៃភ្នំព្រេច**

ដែនជម្រកសត្វព្រៃភ្នំព្រេច មានផ្ទៃដី ២២២ ៥០០ ហិកតា ស្ថិតនៅក្នុងទឹកដីនៃខេត្តមណ្ឌលគីរី និងខេត្តក្រចេះ។ ដែនជម្រកសត្វព្រៃនេះ ស្រដៀងគ្នាទៅនឹងដែនជម្រកសត្វព្រៃនៅលំផាត់ដែរ ភាគច្រើនជាព្រៃស្រោងដុះលើដីបាសាល់ វាលស្មៅនៅចន្លោះព្រៃវាល និងព្រៃរបោះ ព្រៃរបោះចម្រុះ ព្រៃស្រោង និងពាក់កណ្ដាលព្រៃស្រោង ជម្រកទន្លេ និងតំបន់ដីសើមតូចៗ។ គេប្រទះឃើញមានផងដែរ ដូចជា ទន្សោង ឆ្កែព្រៃអាស៊ី និងមានដំរីអន្តោប្រវេសន៍មកកន្លែងនេះមួយរយៈពេលជារៀងរាល់ឆ្នាំ ហើយតំបន់នេះក៏ជាតំបន់បន្តពូជរបស់សត្វក្រៀលផងដែរ។

- **ដែនជម្រកសត្វព្រៃភ្នំណាមលៀរ**

ដែនជម្រកសត្វព្រៃភ្នំណាមលៀរ មានផ្ទៃដីសរុប ៤៧ ៥០០ ហិកតា ស្ថិតនៅក្នុងទឹកដីនៃខេត្តមណ្ឌលគីរី ភាគច្រើនជាព្រៃស្រោង ដែលជាជម្រកខ្លាដំបង ដំរី អាញ្ចើកិតមី និងក្ងោក។

- **ដែនជម្រកសត្វព្រៃស្នួល**

ដែនជម្រកសត្វព្រៃស្នួល មានផ្ទៃដីសរុប ៧៤ ០០០ ហិកតា ស្ថិតនៅក្នុងខេត្តក្រចេះ តំបន់នេះជាតំបន់ព្រៃបម្រុងទុក ភាគច្រើនជាព្រៃស្រោងដែលមានឈើហ៊ុបធំៗ នៅលើតំបន់ខ្ពង់រាប។

- **ដែនជម្រកសត្វព្រៃភ្នំសំកុះ**

ដែនជម្រកសត្វព្រៃភ្នំសំកុះ មានផ្ទៃដី ៣៣៣ ៧៥០ហិកតា ស្ថិតនៅក្នុងខេត្តកោះកុង និង ពោធិ៍សាត់។ លក្ខណៈពិសេសនៃតំបន់នេះ គឺជាតំបន់ដែលរយៈកម្ពស់ខ្ពស់ៗ និងមានប្រភេទព្រៃឈើប្លែកៗនៅលើពិភពលោកជាច្រើន ថែមទាំងមានថនិកសត្វធំៗជាច្រើនដូចជា ខ្លាដំបង ទន្សោង ខ្ទីង និងរមាំង ដែលជាប្រភេទកំពុងរងគ្រោះថ្នាក់ និងទទួលការគំរាមកំហែង។

**គ.តំបន់ការពារទេសភាព**

តំបន់ការពារធម្មជាតិ និងពាក់កណ្ដាលធម្មជាតិដែលមានសារៈសំខាន់ជាលក្ខណៈជាតិ និងត្រូវបានរក្សាសម្រាប់បង្កើតរមណីដ្ឋាន និងកន្លែងទេសចរណ៍។ តំបន់ទាំងនេះត្រូវបាន IUCN ចាត់លំដាប់ថ្នាក់ទី ៥ ដោយរួមមានតំបន់ការពារទេសភាពសមុទ្រ និងដីគោក (តំបន់ធម្មជាតិគ្រប់គ្រងជាពិសេសសម្រាប់អភិរក្សរមណីដ្ឋានទេសភាពដីនិងសមុទ្រ)។ ក្រសួងបរិស្ថានបានឱ្យដឹងថា កាលពីថ្ងៃទី១៧ ខែតុលាថា កម្ពុជាមានតំបន់ការពារទេសភាពចំនួន៨ ក្នុងនោះ ៣ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ និង ៥ បង្កើតឡើងដោយអនុក្រឹត្យ ដែលមានទីតាំងស្ថិតនៅក្នុងខេត្តសៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ កំពត កំពង់ធំ តាកែវ និងព្រះ សីហនុ។ តំបន់ការពារទេសភាពសំដៅតំបន់ដែនដីគោក និងឬដែនទឹក ដែលតំបន់នោះទទួលរងអន្តរអំពើរបស់មនុស្សទៅលើធម្មជាតិ ដោយបង្កើតបានជាតំបន់ដែលមានលក្ខណៈប្លែកខាងផ្នែក

សោភ័ណភាណធម្មជាតិ ឬកែច្នៃអេកូឡូស៊ី ឬវប្បធម៌ និងជាទូទៅសម្បូរដោយជីវចម្រុះ។ **តំបន់ការពារទេសភាពទាំង ៨ រួមមាន ៖**

- **តំបន់ការពារទេសភាពអង្គរ**

តំបន់ការពារទេសភាពអង្គរ មានផ្ទៃដីសរុប ១០៨០០ហិចតា ស្ថិតនៅក្នុងខេត្តសៀមរាប តំបន់ការពារទេសភាពអង្គរជាតំបន់មួយសំខាន់ជាងគេ ក្នុងចំណោមតំបន់ការពារធម្មជាតិទាំង ២៣កន្លែងនៅប្រទេសកម្ពុជា ព្រោះតែសារៈសំខាន់ក្នុងការអភិរក្សជីវចម្រុះ និងបុរាណវត្ថុ។ តំបន់នេះ ជារាជធានីមួយនៃព្រះរាជាណាចក្រអង្គរ ក្នុងសម័យកាលមហានគររុងរឿង(សតវត្សរ៍ទី ៩-១៥) ហើយក៏ជាតំបន់ដែលបានបញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅខែធ្នូ ឆ្នាំ១៩៩២ ដោយគេឱ្យតម្លៃទៅលើវប្បធម៌ សិល្បៈ និងស្ថាបត្យកម្មគ្មានពីរនៅលើលោក។ លក្ខណៈពិសេសនៃតំបន់ការពារទេសភាពអង្គររួមមាន សំណង់ស្ថាបត្យកម្ម តែមួយគ្មានពីរតំបន់ប្រាសាទបុរាណធំៗលម្អទៅដោយក្បាច់រចនាដ៏ប្រណីត និងមានប្រព័ន្ធជារាសាស្ត្រស៊ុំញ៉ាំ ព្រែកជីក និងអាងស្តុកទឹក សម្រាប់ស្រោចស្រពនៅក្នុងវិស័យកសិកម្ម និងផ្គត់ផ្គង់ទឹកនៅក្នុងរាជធានីបុរាណមួយនេះ។ តំបន់អង្គរវត្តត្រូវបានគេចាត់ទុក និងទទួលស្គាល់ថាជា តំបន់ទេសភាពប្រណីតមានតែមួយគត់នៅអាស៊ីអាគ្នេយ៍។

- **តំបន់ការពារទេសភាពបន្ទាយឆ្មារ**

តំបន់ការពារទេសភាពបន្ទាយឆ្មារ មានផ្ទៃដីសរុប ៨១ ២០០ ហិកតា ស្ថិតនៅក្នុងទឹកដី នៃខេត្តបន្ទាយមានជ័យ។ តំបន់នេះ ត្រូវបានចាត់បញ្ចូលជាតំបន់ការពារទេសភាព ដោយសារតែជាកន្លែងវប្បធម៌ និងបុរាណវិទ្យារបស់វារួមទាំងប្រាសាទ (ប្រាសាទបន្ទាយឆ្មារ) ដ៏សំខាន់មួយផងដែរ។

- **តំបន់ការពារទេសភាពព្រះវិហារ**

តំបន់ការពារទេសភាពព្រះវិហារ មានផ្ទៃដីសរុប ៥ ០០០ ហិកតា ស្ថិតនៅក្នុងទឹកដី នៃខេត្តព្រះវិហារ។ តំបន់នេះត្រូវបានបញ្ចូលជាតំបន់ការពារទេសភាព និងបេតិកភណ្ឌពិភពលោក ដោយសារតែជាកន្លែងវប្បធម៌ និងបុរាណវិទ្យា រួមផ្សំជាមួយនឹងប្រាសាទបុរាណផងដែរ (ប្រាសាទព្រះវិហារ)ដ៏សំខាន់ផងដែរ។

- **តំបន់ការពារទេសភាពអន្លង់ព្រីង**

តំបន់ការពារទេសភាពអន្លង់ព្រីង ដែលមានក្រឡាផ្ទៃសរុប ២១៧ ហិកតា ត្រូវបានទទួលស្គាល់ជាតំបន់នៃបណ្តាញផ្លូវហោះហើររបស់សត្វស្លាបអាស៊ីខាងកើត-អូស្ត្រាលី ដោយលេខាធិការដ្ឋាន កិច្ចសហប្រតិបត្តិការអន្តរជាតិនៃភាពជាដៃគូផ្លូវហោះហើរសត្វស្លាបអាស៊ីខាងកើត-អូស្ត្រាលី។ ផ្លូវហោះហើររបស់សត្វស្លាប គឺជាពាក្យដែលប្រើសម្រាប់បង្ហាញពីតំបន់ភូមិសាស្ត្រមួយ ដែលសត្វស្លាបទេសន្តប្រវេសន៍ជាច្រើនធ្វើការបម្លាស់ទីពីជម្រកពងកូនទៅទីសំចត និងទីតាំងស្វែងរកចំណីក្នុងរដូវកាលជាក់លាក់មួយជាប្រចាំឆ្នាំរបស់ពួកវា។ បច្ចុប្បន្ន នៅលើពិភពលោកមានផ្លូវហោះហើរចំនួនប្រាំបួន ហើយប្រទេសកម្ពុជាមានទីតាំងស្ថិតនៅក្នុងផ្លូវហោះហើរអាស៊ីខាងកើត-អូស្ត្រាលី និងបានចូលជាសមាជិកនៃកិច្ចសហប្រតិបត្តិការអន្តរជាតិនៃភាពជាដៃគូរផ្លូវហោះហើរសត្វស្លាបអាស៊ីខាងកើត-អូស្ត្រាលីចាប់តាំងពីឆ្នាំ ២០០៧ ដែលមានក្រសួងបរិស្ថានជាសេនាធិការ។

តំបន់ការពារទេសភាពអន្លង់ព្រីងបានផ្តល់ជាទីជម្រក និងប្រភពចំណីដ៏សំខាន់សម្រាប់សត្វស្លាបទេសន្តរប្រវេសន៍ជាច្រើនប្រភេទ ពិសេសសត្វក្រៀល សត្វខ្វែកសមុទ្រស្លាបធ្មូតស ទាព្រៃក្បាល ធ្មូតស។ល។ ជាទូទៅ ពួកវាមកដល់តំបន់ដីសើមនេះ ក្នុងកំឡុងខែធ្នូ ដើម្បីរកចំណីហើយនៅដើមខែឧសភា សត្វស្លាបទេសន្តប្រវេសន៍ទាំងនោះធ្វើការផ្លាស់ទីទៅកាន់ទីតាំងពងកូនដើម្បីបន្តពូជ។

- **តំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប**

តំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាបស្ថិតក្នុងខេត្តកំពង់ធំ និងសៀមរាប ដែលមានផ្ទៃក្រឡា ៣១ ១៥៩ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។

- **តំបន់ការពារទេសភាពបឹងព្រែកល្ពៅ**

តំបន់ការពារទេសភាព បឹងព្រែកល្ពៅ ស្ថិតក្នុងខេត្តតាកែវដែលមានផ្ទៃក្រឡា ៨ ៣០៥ ហិកតា ចេញដោយអនុក្រឹត្យ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៧។

- **តំបន់ការពារទេសភាពអាងត្រពាំងថ្ម**

តំបន់ការពារទេសភាពអាងត្រពាំងថ្ម ស្ថិតក្នុងខេត្តបន្ទាយមានជ័យ មានផ្ទៃក្រឡា ១២ ៦៥០ ហិកតា ចេញដោយអនុក្រឹត្យថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០។

- **តំបន់ការពារទេសភាពបឹងព្រែកទប់**

តំបន់ការពារទេសភាពបឹងព្រែកទប់ ស្ថិតក្នុងខេត្តព្រះសីហនុ ដែលមានផ្ទៃក្រឡា ១ ៦៣០ ហិកតា ចេញដោយអនុក្រឹត្យថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦។

**ឃ.តំបន់ប្រើប្រាស់ច្រើនយ៉ាង**

ក្រសួងបរិស្ថានបានបញ្ជាក់ថា តំបន់ប្រើប្រាស់ច្រើនយ៉ាង សំដៅដល់តំបន់ក្នុងដែនដីគោក និងឬដែនទឹក ដែលក្នុងនោះមានសម្បូរដោយប្រព័ន្ធធម្មជាតិ ដែលពុំទាន់រងការបំផ្លិចបំផ្លាញ និងតម្រូវឱ្យមានសកម្មភាពគ្រប់គ្រង ដើម្បីធានាការការពារ ការថែទាំធនធានជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី សម្រាប់ពេលយូរអង្វែង។ ទន្ទឹមនឹងនេះដែរ អាចផ្តល់ផលិតផល និងសេវាកម្មធម្មជាតិ សម្រាប់ការប្រើប្រាស់តាមតម្រូវការរបស់សហគមន៍។ ការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងមានគោលបំណង ដើម្បីធានាឱ្យមានការថែទាំទីជម្រកសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី សារព័ន្ធមជ្ឈដ្ឋានធម្មជាតិ ព្រមទាំងធានាឱ្យមានការបំពេញលក្ខខណ្ឌចាំបាច់ សម្រាប់ប្រភេទណាមួយនៃសត្វព្រៃ រុក្ខជាតិ និងជីវចម្រុះ រក្សាលំនឹងបរិស្ថានការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ ការបង្កើតតំបន់នេះ ក៏បានផ្តល់ផលិតផល និងសេវាកម្មធម្មជាតិ សម្រាប់ការប្រើប្រាស់ដោយនិរន្តរភាពលើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាអ្នកពាក់ព័ន្ធក្នុងការថែរក្សា ការពារអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព បង្កើនតួនាទីប្រព័ន្ធអេកូឡូស៊ីតំបន់ការពារធម្មជាតិ សម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់។ ក្រសួងបរិស្ថានបង្ហាញថា គិតចាប់ពីឆ្នាំ១៩៩៣ ដល់ខែ មិថុនា ឆ្នាំ២០១៨ កម្ពុជា មានតំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន ៨ តំបន់ហើយ។ តំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន ៣ តំបន់ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ទីតាំងចំនួន ២ តំបន់ទៀត ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យក្នុងឆ្នាំ២០១៦ ទីតាំងចំនួន២តំបន់ទៀតត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ

ក្នុង ឆ្នាំ២០១៧ និងទីតាំងចំនួន ១ តំបន់ទៀតក្នុងឆ្នាំ២០១៨។ តំបន់ប្រើប្រាស់ច្រើនយ៉ាងសរុបមាន ៨តំបន់ គ្របដណ្តប់នៅលើផ្ទៃដីសរុបចំនួន ៤១២ ៧៩៦ ហិកតា ស្ថិតនៅក្នុងខេត្តសៀមរាប កោះកុង បាត់ដំបង កំពង់ធំ កំពង់ឆ្នាំង ប៉ៃលិន ពោធិ៍សាត់ ត្បូងឃ្មុំ ខេត្តព្រះសីហនុ ខេត្តក្រចេះ និងខេត្តរតនគីរី។ តំបន់ប្រើប្រាស់ច្រើនយ៉ាង ៨ រួមមាន ៖

- **តំបន់ប្រើប្រាស់ច្រើនយ៉ាង ដងពែង**

តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង មានផ្ទៃដី ២៧ ៧០០ ហិកតា ស្ថិតនៅក្នុងទឹកដីនៃខេត្តកោះកុង។ ជាប្រភេទតំបន់ដីសើមនៅតាមតំបន់ទំនាបឆ្នេរសមុទ្រ ដោយភាគច្រើនជាព្រៃកោងកាង និងព្រៃជាំទឹក ប៉ុន្តែមានព្រៃស្រោងខ្លះៗដែរ។ កត្តាកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

- **តំបន់ប្រើប្រាស់ច្រើនយ៉ាង សំឡូត**

តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត មានផ្ទៃដីសរុប ៦០ ០០០ ហិកតា ស្ថិតនៅក្នុងទឹកដីនៃខេត្តបាត់ដំបង។ តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូតជាតំបន់ព្រៃស្រោង ហើយទទួលរងនូវការបំផ្លិចបំផ្លាញដោយសារការដាក់មីន បណ្តាលឱ្យមានការហូរច្រោះ និងបង្កើនកំណល្បាប់នៅក្នុងទន្លេដែលហូរចូលបឹងទន្លេសាប។ កំណត់ដោយអនុក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

- **តំបន់ប្រើប្រាស់ច្រើនយ៉ាង ទន្លេសាប**

តំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាប មានផ្ទៃដីសរុប ៣១៦ ២៥០ ហិកតា ស្ថិតនៅក្នុងទឹកដីនៃខេត្តកំពង់ឆ្នាំង កំពង់ធំ សៀមរាប បាត់ដំបង និងពោធិ៍សាត់។ តំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាបជាតំបន់បម្រុងសម្រាប់មច្ឆវិទ្យាក្នុងកំឡុងដ៏វែង មានសារៈសំខាន់ផ្នែកជីវសាស្រ្ត វារីសាស្ត្រ វប្បធម៌ និង សេដ្ឋកិច្ច។ កំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

- **តំបន់ប្រើប្រាស់ច្រើនយ៉ាង ពញាក្រែក**

ពញាក្រែក ស្ថិតនៅទីតាំងខេត្តត្បូងឃ្មុំ ដែលមានផ្ទៃក្រឡា ១៩៩ ហិកតា បានកំណត់ដោយអនុក្រឹត្យ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។

- **តំបន់ប្រើប្រាស់ច្រើនយ៉ាង ព្រែកទឹកសាបក្បាលឆាយ**

ព្រែកទឹកសាបក្បាលឆាយស្ថិតនៅក្នុងខេត្តព្រះសីហនុ មានផ្ទៃក្រឡា ៥ ៥២០ ហិកតា កំណត់ដោយអនុក្រឹត្យ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៦។

- **តំបន់ប្រើប្រាស់ច្រើនយ៉ាង ភ្នំនាងកង្រី-ភ្នំទូកមាស**

ភ្នំនាងកង្រី-ភ្នំទូកមាស ស្ថិតក្នុងខេត្តកំពង់ឆ្នាំង មានផ្ទៃក្រឡា ៥ ០៦៣ ហិកតា កំណត់ដោយអនុក្រឹត្យ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧។

- **តំបន់ប្រើប្រាស់ច្រើនយ៉ាង សសរស្តម្ភសត្វតោ**

សសរស្តម្ភសត្វតោ ស្ថិតក្នុងខេត្តក្រចេះ មានផ្ទៃក្រឡា ៨៣៩ ហិកតា កំណត់ដោយអនុក្រឹត្យ ចុះថ្ងៃទី ២៨ វិច្ឆិកា ឆ្នាំ២០១៧។

- **តំបន់ប្រើប្រាស់ច្រើនយ៉ាង បឹងយក្ខឡោម**

បឹងយក្ខឡោម ស្ថិតក្នុងខេត្តរតនគិរី ដែលមានផ្ទៃដីសរុបចំនួន ២២៥ ហិកតា កំណត់ដោយអនុក្រឹត្យ

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨។

**ខ.តំបន់រ៉ាំសា**

តំបន់រ៉ាំសា ជាកិច្ចការពារជាច់ដោយឡែក ត្រូវបានធ្វើឡើងក្នុង ខែមិថុនា ឆ្នាំ១៩៩៩ នៅពេលដែលតំបន់ដីសើមចំនួន៣កន្លែងត្រូវបានកំណត់ជា "តំបន់រ៉ាំសា" ក្រោមអនុសញ្ញារ៉ាំសាសន្ធិសញ្ញាអន្តរដ្ឋាភិបាលមួយនេះ ទទួលស្គាល់ពីសារៈសំខាន់ផ្នែកអេកូឡូស៊ី នៃតំបន់ដីសើមសំខាន់ៗ និងតម្រូវការសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព។ តំបន់ដីសើមទាំងស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាបនៃក្រសួងបរិស្ថាន។

មកដល់បច្ចុប្បន្ននេះ មានតំបន់រ៉ាំសាចំនួន៥ (គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨) មានដូចជា ៖

- តំបន់រ៉ាំសាស្ថិតនៅក្នុងខេត្តស្ទឹងត្រែង លាតសន្ធឹងតាមទន្លេមេគង្គប្រវែង ៣៧ គីឡូម៉ែត្រ និងមានផ្ទៃដីប្រមាណ ១៤ ៦០០ ហិកតា។
- តំបន់រ៉ាំសារបឹងឆ្មា ប្រព័ន្ធទន្លេ និងតំបន់លិចទឹក មានទំហំ ២៨ ០០០ ហិកតា ស្ថិតក្នុងខេត្តកំពង់ធំ និងសៀមរាប (មួយផ្នែកនៃតំបន់ប្រើប្រាស់ច្រើនយ៉ាង)។
- តំបន់រ៉ាំសា កោះកាពិ និងប្រជុំកូនកោះ មានទំហំ ១២ ០០០ ហិកតា ស្ថិតក្នុងខេត្តកោះកុង (មួយផ្នែកនៃដែនជម្រកសត្វព្រៃ)។
- តំបន់រ៉ាំសាព្រែកទាល់ ជម្រកពងកូនសត្វស្លាបទឹក ដែលមានទំហំ ២១ ៣៤២ ហិកតា ស្ថិតនៅក្នុងខេត្តបាត់ដំបង ជាជម្រកសត្វស្លាបពងកូនធំជាងគេ នៅតំបន់អាស៊ីអាគ្នេយ៍ត្រូវបានប្រកាសជាតំបន់រ៉ាំសា នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥។
- តំបន់រ៉ាំសាស្ទឹងសែន ស្ថិតតាមបណ្ដោយភាគនិរតីនៃបឹងទន្លេសាប ភាគច្រើនជាព្រៃលិចទឹកដ៏ល្អត្រូវបានទទួលស្គាល់ជាតំបន់រ៉ាំសានៅថ្ងៃទី០៥ នៅខែវិច្ឆិកា ឆ្នាំ២០១៨។

**ច. ព្រំប្រទល់តំបន់ការពារ**

ព្រំប្រទល់តំបន់ការពារតំបន់ការពារធម្មជាតិ ត្រូវបានកំណត់ព្រំដែនជា ៤ តំបន់រួមមាន ៖

- **តំបន់ស្នូល** ៖ តំបន់ដែលមានតម្លៃអភិរក្សខ្ពស់ និងមានអម្បូរសត្វ និងរុក្ខជាតិងាយរងគ្រោះដោយការគំរាមកំហែង ក៏ដូចជាមានបរិស្ថានជីវចម្រុះងាយរងគ្រោះ។ ការចូលទៅកាន់តំបន់ស្នូលនេះត្រូវបានហាមឃាត់ និងមានការលើកលែងតែចំពោះមន្ត្រីរដ្ឋបាលអភិរក្ស និងការពារធម្មជាតិ និងអ្នកស្រាវជ្រាវតែប៉ុណ្ណោះ។ មន្ត្រីរដ្ឋបាលទទួលបន្ទុកអភិរក្ស និងការពារធម្មជាតិអាចផ្ដល់សិទ្ធិចូលទៅកាន់តំបន់នេះដល់មន្ត្រី និងអ្នកស្រាវជ្រាវដោយមានការអនុញ្ញាតិពីក្រសួងបរិស្ថានជាមុន។ មានករណីលើកលែងចំពោះមន្ត្រីទទួលបន្ទុកសន្តិសុខ និងការពារជាតិដែលមានសិទ្ធិអនុញ្ញាតក្នុងការចូលទៅកាន់តំបន់នេះ។ រាល់ការប្រើប្រាស់ធនធាតិធម្មជាតិក្នុងតំបន់ស្នូលត្រូវបានហាមឃាត់ជាកំហិត។ សកម្មភាពកសិកម្មត្រូវបានហាមឃាត់ផងដែរ។
- **តំបន់អភិរក្ស** ៖ ជាតំបន់ដែលមានតម្លៃអភិរក្សខ្ពស់រួមមាន ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ទេសភាពធម្មជាតិដែលមានទីតាំងស្ថិតនៅក្បែរតំបន់ស្នូល។ ការចូលទៅកាន់តំបន់នេះត្រូវមានការអនុញ្ញាតពីរដ្ឋបាលអភិរក្ស និងការពារធម្មជាតិជាមុន។ សហគមន៍ខ្នាតតូច

ដែលប្រើអនុផលព្រៃឈើ ដើម្បីទ្រទ្រង់ដល់ជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋានត្រូវបានអនុញ្ញាតឱ្យចូលទៅកាន់តំបន់នេះ ក្រោមការត្រួតពិនិត្យយ៉ាងតឹងតែង និងក្រោមលក្ខខណ្ឌមិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរទៅលើជីវចម្រុះនៅក្នុងតំបន់នោះ។ ការចូលទៅកាន់តំបន់នេះ ទាមទារការអនុញ្ញាតពីរដ្ឋបាលអភិរក្ស និងការពារធម្មជាតិ និងមានករណីលើកលែងចំពោះមន្ត្រីទទួលបន្ទុកសន្តិសុខនិងការពារជាតិ។ រាល់ការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះត្រូវបានហាមឃាត់ផងដែរ។ សកម្មភាពកសិកម្មត្រូវបានហាមឃាត់ផងដែរ។

- **តំបន់ប្រើប្រាស់**ដោយ**ចីរភាព** ៖ ជាតំបន់ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ចំពោះការអភិវឌ្ឍ និងការគ្រប់គ្រងសេដ្ឋកិច្ចជាតិ និងការអភិរក្សតំបន់ការពារ។ ដោយឡែកពីតំបន់ស្នូល និងតំបន់អភិរក្ស តំបន់នេះ អនុញ្ញាតឱ្យមានការសាងសង់ផ្សេងៗ ក្រោមការកំហិត និងការអនុញ្ញាតពីក្រសួងបរិស្ថាន។ រដ្ឋាភិបាលអាចនឹងអនុញ្ញាតឱ្យរដ្ឋបាលមូលដ្ឋាន ឬសហគមន៍ធ្វើការអភិវឌ្ឍ និងវិនិយោគនៅក្នុងតំបន់នេះ ដោយផ្អែកតាមលក្ខខណ្ឌកំណត់ដោយក្រសួងបរិស្ថាន។ ការប្រើប្រាស់ធនធានធម្មជាតិអាចត្រូវបានអនុញ្ញាត ប្រសិនបើតំបន់នេះត្រូវបានប្រើប្រាស់ជាតំបន់ការពារសហគមន៍។ ក្រសួងបរិស្ថានអាចបែងចែកផ្នែកមួយចំនួននៃតំបន់នេះទៅកាន់សហគមន៍ ក្នុងនាមជាតំបន់ការពាររបស់សហគមន៍។
- **តំបន់សហគមន៍** ៖ គឺជាតំបន់បម្រុងទុក ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម សម្រាប់សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច។ តំបន់នេះរួមមាន ដីប្រជាពលរដ្ឋ វាលស្រែ វាលចម្ការ និងតំបន់សម្រាប់ធ្វើកសិកម្ម ប័ណ្ណកម្មសិទ្ធិដីធ្លីទាមទារឱ្យមានការអនុញ្ញាតពីក្រសួងបរិស្ថាន។

ត្រឹមចុងខែឧសភាឆ្នាំ២០១៦ មានតំបន់ការពារធម្មជាតិចំនួន ៥៣ កន្លែង ដែលត្រូវបានដាក់បញ្ចូលទៅក្នុងប្រភេទទាំងប្រាំ សូមចូលមកកាន់ទិន្នន័យតំបន់ការពារធម្មជាតិ។ ទោះបីជាតំបន់ការពារធម្មជាតិមួយចំនួនត្រូវបានដាក់បញ្ចូលទៅក្នុងប្រភេទតែមួយក៏ដោយ កម្រិតនៃការការពារ និងអភិរក្សទៅលើតំបន់ទាំងនេះមានសភាពខុសៗគ្នា ទៅតាមករណីនីមួយៗ ដែលនេះទាមទារឱ្យមាននិយមន័យច្បាស់លាស់ទៅលើប្រភេទ និងការកំណត់ព្រំដែនតំបន់នៃតំបន់ការពារនីមួយៗក្នុងការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព។

## ៣.៣. លំនឹងជីវចម្រុះ និង ការបាត់បង់ជីវៈចម្រុះ

សណ្ឋានដី និងរបបជលសាស្ត្រប្លែកៗរបស់ប្រទេសកម្ពុជា ផ្តល់អំណោយផលឱ្យប្រទេសនេះមានភាពសម្បូរបែបនៃជីវចម្រុះ។ សណ្ឋានដីនៅប៉ែកខាងកើត គ្របដណ្តប់ដោយចំណោតភាគខាងលិចនៃជួរភ្នំអាណ្ណាម និងនៅចន្លោះខាងត្បូងឆៀងខាងខាងលិច គ្របដណ្តប់ដោយជួរភ្នំក្រវ៉ាញ និងភ្នំដំរី។ ផ្ទៃដីប្រទេសកម្ពុជាភាគច្រើនគ្របដណ្តប់ទៅដោយព្រៃឈើដែលមាន ៦២% [៧] នៃផ្ទៃដីសរុប។ដោយសារប្រទេសកម្ពុជាលាតសន្ធឹងក្នុងវាលទំនាប និងជ្រលងទន្លេមេគង្គ ជាហេតុធ្វើឱ្យមានដីសើមគ្របដណ្តប់ ៣០% នៃផ្ទៃដីប្រទេសដោយរួមទាំងប្រព័ន្ធទន្លេសាប និងប្រព័ន្ធទន្លេមេគង្គ ព្រមទាំងតំបន់ដីសើមដទៃទៀតនៅតំបន់ឆ្នេរមានឥទ្ធិពលយ៉ាងខ្លាំងលើប្រព័ន្ធអេកូឡូស៊ីនៃកម្ពុជា (បឹងទន្លេសាបជាបឹងទំនាបលិចទឹកសាបធំជាងគេក្នុងចំណោមបឹងទំនាបលិចទឹកនៅក្នុងពិភពលោក)។

**ក. អ្វីជាជីវចម្រុះ?**

ជីវចម្រុះ គឺអ្វីៗដែលមានជីវិត ជីវចម្រុះត្រូវបានគេឱ្យនិយមន័យច្រើនប្លែកៗគ្នា ៖

ភាពប្លែកគ្នានៅក្នុងចំណោមសារពាង្គកាយ ដែលមានជីវិតពីបណ្ដាប្រភពរួមមាននៅក្នុងចំណោម ភាវៈផ្សេងទៀតរួមទាំងនៅលើដី នៅក្នុងសមុទ្រ និងប្រព័ន្ធអេកូឡូស៊ី ក្នុងទឹកដទៃទៀត និង ភាពស្មុគស្មាញ នៃបរិស្ថាន។ ប្រការនេះ រួមមានភាពផ្សេងៗនៅក្នុងបណ្ដាប្រភេទរវាងប្រភេទ និង ប្រព័ន្ធអេកូឡូស៊ី (អនុសញ្ញាស្ដីពីជីវចម្រុះ IUCN )។

ជាការប្រែប្រួលផ្អែកលើលក្ខណៈបន្តពូជ (Genetic) នៅក្នុងកំណកំណើតគ្រប់កម្រិតពីសែន (Gene) នៅក្នុងចំនួនតែមួយនៃប្រភេទក្នុងតំបន់ ឬប្រភេទផ្សេងទៀត ដែលមានគ្រប់ឬតែមួយផ្នែកនៃសហគមន៍។

ជាភាពផ្សេងៗគ្នានៃគ្រប់ភាវៈដែលមានជីវិតនៅលើភពផែនដីគឺនៅជុំវិញខ្លួនយើង និងថែរក្សាការពារ យើង សូម្បីនៅក្នុងទីក្រុងក៏ដោយ ជីវចម្រុះនៅតែតែជាផ្នែកសំខាន់សម្រាប់ជីវិត យើងមិនអាចមើលឃើញវា ប៉ុន្តែជីវចម្រុះជួយរក្សាទឹកឱ្យស្អាតដែលយើងអាចបរិភោគបាន ខ្យល់ដែលយើងដកដង្ហើមបាន ធ្វើឱ្យដីមានជីជាតិ ដែលអាចដាំដំណាំបានសម្រាប់ជាអាហារ និងសម្អាតទឹកសមុទ្ររបស់យើង។

**ខ. ការប្រើប្រាស់ជីវចម្រុះ**

ជីវចម្រុះទ្រទ្រង់សង្គមមនុស្សយ៉ាងច្រើន តាមបែបបរិស្ថាន សេដ្ឋកិច្ច ទេសចរណ៍ វប្បធម៌ និងស្មារតី។ ប្រទេសកម្ពុជាត្រូវធ្វើម្ចាស់ចំពោះភាពប្លែកនៃអាយុជីវិតរបស់ជីវចម្រុះនេះ ដែលត្រូវបានគេយល់ដឹងយ៉ាងច្រើន ដោយផ្ទាល់ ក្នុងការប្រើប្រាស់នៃធនធានជីវចម្រុះដូចជា ផ្នែកកសិកម្ម រុក្ខកម្ម និង ជលផល។ នៅក្នុងវិស័យ កសិកម្ម សារៈសំខាន់នៃប្រព័ន្ធអេកូឡូស៊ីនានាត្រូវបានគេគួបផ្សំជាមួយប្រភេទនានា ដែលពេញនិយម សម្រាប់អាហារ ការទប់ស្កាត់ជាមួយនឹងជំងឺនានា ព្រមជាមួយនិងកត្តាចង្រៃនានា។ ជីវចម្រុះជួយដល់បញ្ហាដទៃផ្សេងទៀតជាច្រើនដូចជា កត្តាពិនិត្យពូជបង្កវិនាសកម្មធម្មជាតិនៃផលិតកម្មកសិកម្មនានា ជាពិសេសនៅក្នុងខ្សែអាហារ។

**គ. ការព្រួយបារម្ភពីការបាត់បង់ជីវចម្រុះ**

មានមូលហេតុជាច្រើន ដែលបណ្ដាលឱ្យមានការបាត់បង់ជីវចម្រុះ ដែលរួមមាន ៖

- សោភ័ណភាព ៖ រាល់ប្រភេទ និងប្រព័ន្ធអេកូឡូស៊ីបានផ្ដល់នូវភាពសម្បូរបែប និងភាពស្អាតនៃជីវិតនៅលើភពផែនដី នៅពេលណាមួយនឹងត្រូវបាត់បង់ និងប្រភេទមួយចំនួននឹងត្រូវបាត់បង់ជារៀងរហូត។
- ក្រិតក្រមធម្មជាតិ ៖ ប្រភេទខ្លះមានលក្ខណៈជាប្រភេទទោល ហើយត្រូវបានគេឱ្យតម្លៃទៅលើវាខ្ពស់ ជាមូលហេតុនៃការដណ្ដើមចង់បាន ព្រោះវាមានតម្លៃសម្រាប់អេកូឡូស៊ី និងមនុស្ស។
- សេដ្ឋកិច្ច ៖ ប្រភេទនីមួយៗគឺមានតម្លៃវិសេសវិសាលសម្រាប់ចីរភាពនៃប្រព័ន្ធអេកូឡូស៊ី ការរក្សាទុកប្រភេទទីជម្រក និងប្រព័ន្ធអេកូឡូស៊ីជាវត្ថុមួយ ដែលមានតម្លៃស្មុកស្មាញសម្រាប់តម្រូវការរបស់មនុស្សក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

- ការទ្រទ្រង់ជីវិត ៖ មនុស្សយើងអាស្រ័យទៅលើប្រភេទផ្សេងៗ សម្រាប់អាហាររបស់ពួកគេ ថ្នាំសង្កូវ និងផលិតផលផ្សេងៗ។ មនុស្សពឹងផ្អែកផងដែរលើមុខងារស្មុគស្មាញនៃប្រភេទ ចែកជាសេវាអេកូឡូស៊ីដូចជា ទឹកស្អាត សារជាតិ ដែលធ្វើឱ្យជំជាត់ រីកលូតលាស់ និងកាត់បន្ថយជាតិពុល។
- សន្តិសុខស្បៀង ៖ ភាពប្លែកៗគ្នានៃតំណពូជ គឺមានសារៈសំខាន់ក្នុងការបង្កាត់ដំណាំ និងចិញ្ចឹមសត្វតាមកសិដ្ឋាន។ អ្នកបង្កាត់ត្រូវការប្រភេទប្លែកៗ នៃដាំណាំច្រើនមុខ ក្នុងលំដាប់លំដោយបង្កាត់ប្រភេទថ្មី ដែលអាចទប់ទល់ការវិវត្តនៃបរិស្ថានធម្មជាតិ និងតម្រូវការរបស់សង្គមមនុស្ស។
- ផ្នែកអេកូឡូស៊ី ៖ ប្រភេទនីមួយៗត្រូវមានទំនាក់ទំនងបំពេញឱ្យកន្លែងគ្នាទៅវិញទៅមកពិសេសនៃប្រព័ន្ធអេកូឡូស៊ី ឬទីជម្រក។ គ្រប់ប្រភេទទាំងអស់អាស្រ័យគ្នាទៅវិញទៅមក តាមទម្រង់ស៊ាំញ៉ាំនៃប្រព័ន្ធជីវិត ការបំផ្លាញប្រភេទណាមួយនាំទៅរកការវិនាសផុតពូជ ឬបម្រែបម្រួលនៃប្រភេទ ផ្សេងៗទៀត ការផុតពូជប្រភេទ ណាមួយនៅលើផែនដីជាមូលហេតុ នាំឱ្យភាវៈមានជីវិតនៅលើផែនដីទាំងអស់នៅលើភពផែនដីខិតកាន់តែជិតទៅរកការវិនាសផុតពូជទាំងស្រុង។

## ៣.៤. សត្វ និងរុក្ខជាតិជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

គណៈរដ្ឋមន្ត្រីបានធ្វើការអនុម័តនៅព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៥ ទៅលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការជ្រើសរើសសត្វ និងរុក្ខជាតិ សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ដែលការជ្រើសរើសនេះត្រូវបានរៀបចំដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

**សត្វ និង រុក្ខជាតិ ដែលត្រូវជ្រើសរើសជានិមិត្តរូបនៃប្រទេសកម្ពុជាមាន ៧ ប្រភេទគឺ ៖**

១- ប្រភេទសត្វចតុបាទគឺ សត្វគោព្រៃ

២- ប្រភេទបក្សីគឺ សត្វត្រយ៉ង

៣- ប្រភេទឧរង្គសត្វគឺ អណ្តើកសសៃ (អណ្តើកហ្លួង)

៤- ប្រភេទមច្ឆាគឺ ត្រីគល់រាំង

៥- ប្រភេទរុក្ខជាតិគឺ ដើមត្នោត

៦- ប្រភេទផ្កាគឺ ផ្ការំដួល និង

៧- ប្រភេទផ្លែឈើគឺ ចេកពងមាន់។

### សំណួរត្រិះរិះ

១. ចូរឱ្យនិយមន័យអេកូ-ទេសចរណ៍?

២. តើអេកូ-ទេសចរណ៍អត្ថប្រយោជន៍អ្វីខ្លះ? ចូររៀបរាប់។

៣. តើអ្វីខ្លះជា ទស្សនៈវិស័យនៃអេកូ-ទេសចរណ៍?

៤. ចូរបង្ហាញពីឥទ្ធិពលនៃអេកូ-ទេសចរណ៍ទៅលើវិស័យសេដ្ឋកិច្ច។

៥. តើត្រូវមានគោលនយោបាយយ៉ាងដូចម្តេចខ្លះ ក្នុងការអភិរក្សតំបន់អេកូ-ទេសចរណ៍?

៦. តើអ្វីជាគោលនយោបាយអេកូ-ទេសចរណ៍នៅប្រទេសកម្ពុជា?

៧. តើជម្រើសជាយុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីការអភិវឌ្ឍវិស័យអេកូ-ទេសចរណ៍?

៨. តើមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងអភិរក្សតំបន់អេកូ-ទេសចរណ៍?

៩. ហេតុអ្វីបានជាចាំបាច់ត្រូវបង្កើតតំបន់ការពារធម្មជាតិ?

១០. តើតំបន់ការពារធម្មជាតិចែកចេញជាប៉ុន្មានតំបន់? អ្វីខ្លះ?

១១. តើប្រភេទសត្វ និងរុក្ខជាតិអ្វីខ្លះ ដែលត្រូវបានជ្រើសរើសជានិមិត្តរូបរបស់ព្រះរាជាណាចក្រកម្ពុជា? ហេតុអ្វី?

១២. តើមានបញ្ហាប្រឈមអ្វីខ្លះ នៅក្នុងតំបន់ការពារធម្មជាតិ?

១៣. តើត្រូវមានវិធានការអ្វីខ្លះ ដើម្បីអភិរក្សតំបន់ការពារធម្មជាតិឱ្យមាននិរន្តរភាព?

# ជំពូកទី៧ ៖ ភូមិវិទ្យា ប្រជាជន ឬប្រជាគណាន៍

## មេរៀនទី១ ៖ រំលឹកបញ្ញាត្តិទូទៅ និងកំណើនប្រជាជនពិភពលោកនៅដើមសហស្សវត្សទី៣

### ១. បញ្ញាត្តិទូទៅនៃភូមិវិទ្យាប្រជាជន

- **ទម្រង់ប្រជាជនក្មេង៖** គេគិតទៅតាម ទម្រង់ពីរ៉ាមីតអាយុ របស់ប្រជាជនក្នុងប្រទេសមួយ ឬ តំបន់ មួយ ដែលមានប្រជាជនក្មេងច្រើនជាង មនុស្សចាស់។
- **ដង់ស៊ីតេប្រជាជន ៖ ចំនួន**ប្រជាជនជាមធ្យមលើផ្ទៃដី១គីឡូម៉ែត្រការ៉េ។
- **ប្រជាជនសកម្ម៖**ប្រជាជនមានសកម្មភាពក្នុងវិស័យ៣ធំៗគឺ ឧស្សាហកម្ម កសិកម្ម និងសេវាកម្ម
- **នគរូបនីយកម្ម** ៖ ការពង្រីកទីក្រុង ឬ រៀបចំបង្កើតឲ្យក្លាយទៅជាទីក្រុង។
- **ជំណុះប្រជាជន** ៖ ប្រវត្តិនៃការតាំងទីលំនៅរបស់ប្រជាជនពីដំណាក់កាលដំបូង។
- **ពន្ធភាព** ៖ ភាពស្រដៀងគ្នា។
- **កសិកម្មយថាផល** ៖ កសិកម្មដែលមិនទទួលបានការថែទាំ ទទួលផលតិចមិនបានទៀងទាត់ មិនប្រើ ប្រាស់ បច្ចេកទេសទំនើប និង មិនប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិត។
- **សណ្តានក្រោយ** ៖ ជំនាន់ក្រោយនៃមនុស្ស។
- **ជនចំណូលស្រុក** ៖ មនុស្សដែលធ្វើការផ្លាស់ទីចូលក្នុងតំបន់ណាមួយ។
- **លទ្ធភាពបង្កកំណើត៖** គឺចំនួនកូនជាមធ្យមដែលស្ត្រីម្នាក់អាចបង្កើតបាន ក្នុងដំណាក់កាលបន្តពូជ (ពីអាយុ ១៥ - ៤៩ឆ្នាំ )។
- **អត្រាជាតិប្រមាណ** ៖ ចំនួនមនុស្សកើត ឬ ចំនួនកំណើត។
- **សម្ពាធប្រជា**សាស្ត្រ ៖ បន្ទុកដ៏ធ្ងន់ធ្ងរ នៃកំនើនប្រជាជន។
- **ទម្រង់ប្រជាជនក្មេង** ៖ គេគិតទៅតាម ទម្រង់ពីរ៉ាមីតអាយុ របស់ប្រជាជនក្នុងប្រទេសមួយ ឬ តំបន់ មួយ ដែលមានប្រជាជនក្មេងច្រើនជាង មនុស្សចាស់។
- **របាយប្រជាជន** ៖ ការតាំងទី ឬ ការរ៉ាយប៉ាយ។
- **មរណប្រមាណកុមារ** ៖ ចំនួនកុមារដែលស្លាប់ក្រោមអាយុ៥ឆ្នាំ។
- **មរណប្រមាណទារក** ៖ ចំនួនកុមារដែលស្លាប់ក្រោមអាយុ១ឆ្នាំ។
- **មរណប្រមាណ**មាតា៖ ចំនួនស្ត្រី ដែលស្លាប់ក្នុងអំឡុងពេលមានគភ៌ ស្លាប់ក្នុងពេលសម្រាលកូន និងស្លាប់ក្រោយពេលសម្រាលកូនរយៈពេល១ឆ្នាំ។
- **ចលនាបំលាស់ទីលំនៅ** ៖ សកម្មភាព ផ្លាស់ទីលំនៅ របស់ប្រជាជនពីកន្លែងដែលធ្លាប់រស់នៅទៅ កាន់កន្លែងថ្មីផ្សេងទៀត។
- **ចំណាកស្រុក** ការចេញនៃប្រជាជនពីតំបន់ណាមួយ ទៅកាន់តំបន់ដ៏ទៃទៀតក្នុងបំណងតាំងទីលំនៅថ្មី។

- **ដីសណ្ដរគជំ** ៖ តំបន់គំនដីល្បាប់ដែលបង្កើតឡើងដោយផ្លូវទឹកពេលទៅដល់សមុទ្រ។ ដីនេះលយ ចូលទៅ ក្នុង សមុទ្រ គេចាត់ទុកតំបន់នេះជាតំបន់មានតំលៃ ឬ ជាតំបន់ដែលមានសកម្មភាពសេដ្ឋកិច្ច រីកលូតលាស់ល្អ។
- **ផលិតផលជាតិសរុប** ៖ ជាផលដែលប្រជាជនរកប្រាក់ចំណូលបានជាមធ្យមក្នុងម្នាក់ ក្នុងរយៈពេល ១ឆ្នាំ គិតជាប្រាក់ដុល្លាអាមេរិច។
- **ជំរឿនប្រជាជន** ៖ ការរាប់ចំនួនប្រជាជន។
- **ជនចំណូល**ស្រុក ៖ មនុស្សដែលធ្វើការផ្លាស់ទីចូលក្នុងតំបន់ណាមួយ។
- **ឧស្សាហូបនីយកម្ម** ៖ ការរីកចម្រើនផ្នែកឧស្សាហកម្ម ទាំងឧបករណ៍ប្រើប្រាស់ និង បច្ចេកទេស ក្នុង ការផលិត។
- (NPI) ៖ ប្រទេសឧស្សាហកម្មលូតលាស់ថ្មី។
- **ជំងឺប៉េស្តខ្មៅ** ៖ ជំងឺពិសម្យ៉ាង ឆ្លងតាមសត្វកណ្ដុរ បណ្ដាលឲ្យមនុស្សស្លាប់ អស់២៥លាននាក់ នៅឆ្នាំ ១៣៤៧ - ១៣៥១ ។
- **ជំងឺអុត** ៖ ជំងឺអុតស្វាយ ជាអំរែកមរណៈរាប់សតវត្សកន្លងមក។
- **អន្តរភាពប្រជាសាស្ត្រ** ៖ គឺជាដំណើរឆ្លងកាត់ពីរបប ប្រជាសាស្ត្រមួយ ដែលមានជាតិប្រមាណ និង មរណៈ ប្រមាណ **ខ្ពស់** ទៅជារបប ប្រជាសាស្ត្រមួយទៀតដែលមាន ជាតិប្រមាណ និង មរណៈ**ទាប**។
- **ប្រទេសលោកខាងជើង** ៖ សំដៅទៅលើប្រទេសអភិវឌ្ឍ ឬ ប្រទេសអ្នកមាន។
- **ប្រទេសលោកខាងត្បូង** ៖ សំដៅទៅលើប្រទេសកំពុងអភិវឌ្ឍ ឬ ប្រទេសអ្នកក្រ។
- **នយោបាយផែនការគ្រួសារ** ៖ នយោបាយ ក្នុងការកាត់បន្ថយចំនួនកូនក្នុងគ្រួសារ ដើម្បីឲ្យមានតុល្យភាព ជាមួយនឹងប្រាក់ចំណូល ឬ សេដ្ឋកិច្ចគ្រួសារ។
- **កំណើនវិសមភាពភេទ** ៖ មានការរើសអើងភេទ តាមរយៈការចូលរួម ក្នុងសកម្មភាពផ្សេងៗ។
- **ពីរ៉ាមីតអាយុប្រជាជន** ៖ គឺជាគំនូសតាង ដោយក្រុមមនុស្សមួយក្រុម ដោយគិតតាមថ្នាក់អាយុ តាម ភេទ ក្នុង កាលវេលាកំណត់មួយ។
- **បន្ទុះទារក** ៖ ការកើតមានយ៉ាងឆាប់រហ័ស ហើយខ្លាំងក្លានៃជាតិប្រមាណ ក្រោយសង្គ្រាមលោកលើក ទី២ នៅក្នុង ប្រទេសឧស្សាហកម្ម។
- **បន្ទុះមនុស្ស** ៖ ភាពចាស់យ៉ាងឆាប់រហ័ស នៃទម្រង់ប្រជាជនក្នុងប្រទេសឧស្សាហកម្ម នៅ ជំណាច់ ស.តទី២០។
- **អន្តរភាពប្រជាសាស្ត្រទំនើប** ៖ ជារបបប្រជាសាស្ត្រមួយដែលមានជាតិប្រមាណ និងមរណៈទាប។
- **ក្រុមអាយុ** ៖ គេសំដៅពីការដាក់អាយុជាក្រុម នៅលើពីរ៉ាមីតអាយុ។

  **ឧទាហរណ៍៖** ក្រុមអាយុពី ០ - ៤ឆ្នាំ ពី ៥ - ៩ឆ្នាំ ....។
- **ភាពចំណាស់នៃប្រជាជន** ៖ គេគិតទៅតាម ទម្រង់ពីរ៉ាមីតអាយុ របស់ប្រជាជនក្នុងប្រទេសមួយ ឬ តំបន់មួយ ដែលមានប្រជាជនចាស់ច្រើនជាងក្មេង។

- **ទម្រង់ប្រជាជនក្មេង** ៖ គេគិតទៅតាម ទម្រង់ពីរ៉ាមីតអាយុ របស់ប្រជាជនក្នុងប្រទេសមួយ ឬ តំបន់ មួយ ដែលមានប្រជាជនក្មេងច្រើនជាង មនុស្សចាស់។
- ONU (Organization Nation Unit) ៖ អង្គការសហប្រជាជាតិ។
- **អន្តោប្រវេស្ត** ៖ ការចាកចេញទៅតាំងទីលំនៅប្រទេសដ៏ទៃដែលមិនមែនជាប្រទេសកំណើត។
- **ឧបទ្វីប** ៖ ដីដែលលយចូលទៅក្នុងសមុទ្រមួយផ្នែកធំ មួយផ្នែកតូចជាប់នឹងទ្វីប។
- **មេកាឡូប៉ូល** ៖ បណ្តុំ ឬ ប្រជុំទីក្រុងសំខាន់ៗ ភាគច្រើន មាននៅ ប្រទេសមហាអំនាច ។
- **មណ្ឌលឧស្សាហកម្ម** ៖ តំបន់ដែលប្រមូលផ្តុំ រោងចក្រឧស្សាហកម្ម ច្រើន។
- **មណ្ឌលបណ្តុំរ៉ែ** ៖ តំបន់ដែលសម្បូរទៅដោយរ៉ែ ច្រើនប្រភេទ។
- **សំទុះប្រជាសាស្ត្រ** ៖ ការកើនឡើងនៃ ចំនួនប្រជាជន។
- **បន្ទុះប្រជាជនក្រុង** ៖ ការកើនឡើងខ្លាំង នៃប្រជាជនក្រុង ហួសពីការស្មានទុក ។
- **អន្តរភាពទីក្រុង** ៖ របបប្រជាសាស្ត្រដែលមានការផ្លាស់ទីចូលច្រើន និងការផ្លាស់ទីចេញច្រើន។
- **បរិមណ្ឌលក្រុង** ៖ ទីក្រុងតូចៗ ឬ ទីក្រុងរណប។
- **ចំណោលស្រុកស្រែ**៖ការចាកចោលស្រុកស្រែជនបទ ដើម្បីទៅរស់នៅឬ រកការងារធ្វើនៅទីក្រុង។
- **ឧស្សាហូបនីយកម្ម** ៖ ការរីកចម្រើនខាងផ្នែកឧស្សាហកម្ម ដោយមានភាពទំនើប ទាំងសម្ភារៈ និង បច្ចេកទេស
- **សេវាមូលដ្ឋាន** ៖ រួមមានសេវាផ្សេងៗដូចជា ទឹក អគ្គិសនី អនាម័យ សុខាភិបាល ការអប់រំ...។
- **បញ្ហាក្រុង** ៖ បន្ទុះប្រជាជនក្រុង កង្វះហេដ្ឋារចនាសម្ព័ន្ធ កង្វក់បរិស្ថានក្រុង កង្វះជម្រក និង កង្វះការងារ សម្រាប់ប្រជាជនក្នុងទីក្រុង។
- **អត្រានគរូបនីយកម្ម** ៖ បង្ហាញអំពីភាគរយនៃប្រជាជនដែលរស់នៅក្នុងក្រុង របស់ប្រទេសមួយ ឬ តំបន់មួយ។
- **សំណង់អានាធិបតេយ្យ** ៖ កន្លែងដែលមានសកម្មភាពរញ៉េរញ៉ៃមានលក្ខណៈ មិនស្របច្បាប់ និង ជាកន្លែង អាចបណ្តាលឲ្យមានឧក្រិដ្ឋភាពខ្ពស់។
- **វុក្ខវិថី** ៖ វិថីដែលមានរុក្ខជាតិដុះអមសងខាងផ្លូវ។
- **សង្កាត់អ្នកក្រ** ៖ សង្កាត់ដែលប្រវត្តិសាស្ត្រនៅជិតមណ្ឌលកណ្តាល (មានសំណង់ចាស់ៗ) និង លំនៅថ្មីៗ នៃសំណង់អនាធិបតេយ្យនៅកណ្តាលក្រុង (សំណង់អានាធិបតេយ្យ)
- **វិសមភាពចំពោះសេវា** ៖ ការទទួលបាន សេវាមិនស្មើគ្នារវាង សង្កាត់អ្នកមាន និងសង្កាត់អ្នកក្រ។
- **ជំនោរប្រជាសាស្ត្រ** ៖ ការរុញច្រាន លំហក្រុងទៅកាន់តែឆ្ងាយ និង បង្កើនតម្រូវការអ្នកក្រទីក្រុង ដល់ទៅជប់ដង។
- **ការបំពុលខ្យល់** ៖ កង្វក់បរិយាកាស ដែលបណ្តាលមកពីការ សាយភាយនៃភាគល្អិតរឹង ដំណក់តូចៗនៃ អង្គធាតុរាវ និង ឧស្ម័ន ដែលពុល ឬ មានជាតុវិទ្យុសកម្មចូលទៅក្នុងបរិយាកាសធ្វើឲ្យមានផល ប៉ះពាល់ដល់ សុខភាព មនុស្ស និង ជីវិតនៅលើផែនដី។
- **អក្ខរកម្ម** ៖ទង្វើ ឬសកម្មភាពដែលធ្វើឲ្យមនុស្សចេះអក្សរ (ចេះទាំងអាន និង ចេះសរសេរ)។

- **អត្រាអក្ខរកម្ម** ៖ជាភាគរយនៃប្រជាជនចេះអាន និងចេះសរសេរ ធៀបជាមួយនឹងប្រជាជនសរុបអាយុ៧ឆ្នាំឡើង។
- **យេនឌ័រ** ៖ ការចូលរួមក្នុងសកម្មភាពអ្វីមួយដែលក្នុងនោះរួមមាន ទាំងបុរស និងស្ត្រី។
- **ប្រព័ន្ធអប់រំចំណេះទូទៅនៅកម្ពុជា** ៖ មានរយៈពេល១២ឆ្នាំ ចែកជា៣ភូមិសិក្សា។
- **អត្រាភេទ** ៖ ចំនួនបុរស និង ធៀបនឹងចំនួនស្ត្រី១០០នាក់។
- **សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស** HDI (Human Development Index)ដោយគិតទៅលើសន្ទស្សន៍ធំ១៣គឺ សន្ទស្សន៍នៃសង្ឃឹមរស់ពីកំណើត សន្ទស្សន៍ នៃការសិក្សាអប់រំ និង សន្ទស្សន៍នៃផលិតផលក្នុងស្រុកសម្រាប់មនុស្សម្នាក់ (GDP)។
- **សេវាកម្ម** ៖ ការបំរើ ឬ ការផ្តល់ជូន ប៉ុន្តែមិនមែនជាសម្ភារៈ។
- **សេវាសង្គម** ៖ សកម្មភាពបំពេញតម្រូវការសង្គម ដោយមិនបានផលិតជាសម្ភារៈប្រើប្រាស់។
- **អាជ្ញាប័ណ្ណ** ៖ ប័ណ្ណដែលផ្តល់សិទ្ធិឱ្យក្នុងការធ្វើអ្វី ឬ ផលិតអ្វីមួយ។
- ADB (Asia Development Bank) ៖ ធនាគារអភិវឌ្ឍន៍អាស៊ី។
- **សម្បទាខាងអំណាន** ៖ ការដែលអាចអានបានត្រឹមត្រូវល្អ។
- **ការបន្ទោបង់ពាសវាលពាសកាល** ៖ ការបន្ទោបង់លើដី ក្នុងព្រៃ ក្នុងគុម្ពោតព្រៃ ក្នុងប្រភពទឹកនៅទីវាល ឬ ការបោះចោលលាមកមនុស្សពាសវាលពាសកាល។
- **ថាមពលអគ្គិសនី** ៖ ប្រភេទថាមពលដែលប្រើប្រាស់ផូស៊ីលឥន្ទនៈ។
- **ថាមពលវារីអគ្គិសនី** ៖ ប្រភេទថាមពលដែលបានមកពីទឹក។
- **ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី** ៖ គឺការប្រព័ន្ធសកម្មភាពផលិត និង ចែកចាយត្រូវជានារ៉ាប់រងដោយសហគ្រាស ហើយមានការប្រកួតប្រជែងគ្នា។
- **ផលិតផលក្នុងស្រុកសរុប** ៖ ប្រាក់ចំណូលបានជាមធ្យម ដែលមនុស្សម្នាក់ក្នុងប្រទេសណាមួយរក បាន ក្នុងរយៈពេល១ឆ្នាំ គិតជាប្រាក់ដុល្លាអាមេរិច។
- » **សម្ពាធប្រជាសាស្ត្រ** ៖ ការកើនឡើងនៃចំនួនប្រជាជន ឬ កំនើនប្រជាជនច្រើន ដែលធ្វើឲ្យមានសម្ពាធ ទៅលើ វិស័យផ្សេងៗទៀត។
- **សន្ទស្សន៍នៃភាពក្រីក្រ** ៖ គឺជាឯកតាប្រើសម្រាប់សម្គាល់ កម្រិតជីវភាពរបស់ប្រជាជននៅតំបន់ណាមួយដោយ មើលទៅលើប្រាក់ចំណូលជាសរុបជាមធ្យម ដែលមនុស្សម្នាក់រកបានក្នុងរយៈពេល១ថ្ងៃ ធៀបនឹងទឹកប្រាក់២ដុល្លារអាមេរិក។
- **ចលនាប្រជាជន** ៖ មាន២គឺ
  - ការចេញ៖ មាន២គឺ ការផ្លាស់ទីចេញ និង ស្លាប់
  - ការចូល៖មាន២គឺ ការផ្លាស់ទីចូល និង កំណើត
- **ការផ្លាស់ទី**
  - ចំណូលស្រុក ឬ ការផ្លាស់ទីចូល
  - ចំណាកស្រុក ឬ ការផ្លាស់ទីចេញ

- **អន្តោប្រវេសន្ត៖** ការផ្លាស់ទីចេញទៅនៅប្រទេសផ្សេង ដែលមិនមែនជាប្រទេសកំណើត។ អន្តោប្រវេសន្តស្របច្បាប់ និងអន្តោប្រវេសន្តខុសច្បាប់។
- **អត្រាភេទ** ៖ ចំនួនភេទប្រុស ធៀបនឹងចំនួនភេទស្រី១០០នាក់។
- **ទម្រង់តាមភេទ និង តាមអាយុ** ៖ មានភេទស្រី និង ភេទប្រុស និង ទម្រង់តាមអាយុ (អាយុ និង ក្រុមអាយុ) គេឃើញទិន្នន័យនៅក្នុង **ពីរ៉ាមីតអាយុ** ។
- **ពីរ៉ាមីតអាយុ៖** មាន៣ទម្រង់គឺ ពីរ៉ាមីតអាយុដែលមានទម្រង់ប្រជាជន **ក្មេង** (ចំនួនប្រជាជនក្មេងច្រើនជាងចាស់) មាននៅប្រទេសកំពុងអភិវឌ្ឍន៍ ឬ ប្រទេសក្រីក្រ។
- **ជំរឿន៖** ការរាប់ចំនួន។
- **ជាតិពន្ធុ៖** ប្រវត្តិ នៃការតាំងទីលំនៅរបស់ជាតិសាសន៍ណាមួយ នៅតំបន់ណាមួយ។
- **អាយុ ៖** អាយុ១ឆ្នាំ មានចំនួន៥០ អាយុ២ឆ្នាំមានចំនួន៤០ ...។ អាយុមាន២ប្រភេទគឺ៖
  - អាយុពិតប្រាកដ ៖ អាយុរបស់បុគ្គលម្នាក់គិតពីថ្ងៃកើត រហូតដល់ថ្ងៃដែលគេសាកសួរ។
  - អាយុពេញលេញ ៖ អាយុរបស់បុគ្គលម្នាក់ដែលគិតពីថ្ងៃកើត រហូតដល់ថ្ងៃខួបកំណើតចុងក្រោយ។
- **អត្រានុកូលដ្ឋាន** ៖ បញ្ជីរួមមាន៖ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព សំបុត្រលែងលះ។
- **សំបុត្រកំណើត** ៖ គឺសំបុត្រដែល គិតពីទារកកើត រហូតរយៈពេល១ខែ។
- **សំបុត្របញ្ជាក់កំណើត** ៖ គឺសំបុត្រដែលបញ្ជាក់កំណើតមនុស្ស ដែលទៅចុះឈ្មោះ លើសពីថ្ងៃដែលបានកើត រយៈពេល១ខែ (ដោយមានសាក្សី២នាក់)។
- **សេចក្ដីចម្លងសំបុត្រកំណើត** ៖ ការចម្លងសំបុត្រកំណើត ដោយមានបញ្ជាក់ពី អាជ្ញាធរ ស្រុក ឬ ខណ្ឌ ក្នុងការទទួលស្គាល់។
- **សំបុត្រមរណភាព៖** គឺសំបុត្រដែលគេធ្វើនៅពេលដែលមានសមាជិកគ្រួសារ ណាម្នាក់ស្លាប់
- **សំបុត្រអាពាហ៍ពិពាហ៍៖** គឺសំបុត្រដែលគេចុះនៅពេលពេលគូរស្វាមីភរិយាដែលរៀបអាពាហ៍ពិពាហ៍រួចយ៉ាងហោចណាស់រយៈពេល១ខែ។

## ២. ប្រវត្តិកំណើនប្រជាជន

ក្រោយពេលដែលមានកំណើនយឺត និងទៀងទាត់អស់ជាច្រើនពាន់ឆ្នាំមក ភពផែនដីមានបន្ទុះប្រជាសាស្ត្រ ចាប់ពី២សតវត្ស កន្លងមកថ្មីៗនេះ។

### ២.១. ប្រវត្តិកំណើនប្រជាជនមុនឆ្នាំ១៦៥០

- តាំងពីដើមកំណើតមនុស្សរហូតដល់ពាក់កណ្ដាលសតវត្សទី១៧ប្រជាជនពិភពលោកមានកំណើនយឺតបំផុត។
- ប្រជាជនកើនពី២៥០លាននាក់ ក្នុងឆ្នាំ២២០០០មុន គ.ស ដល់ ៥០០លាន នាក់នៅឆ្នាំ១៦៥០។
- អត្រាកំណើនមធ្យមមានប្រហែល 0.0៥%។
- មរណប្រមាណខ្ពស់គឺកុមារអាយុក្រោម១ឆ្នាំ និង សង្ឃឹមរស់មានមិនលើសពី៣០ឆ្នាំ ។

- ពីសតវត្ស ទី១១ដល់ទី១៣មាន ការសម្លាប់រង្គាលពីជំងឺ ប៉េស្តខ្មៅ (ជំងឺពិសម្បាំងឆ្លងតាមកណ្តុរ) បណ្តាលឱ្យមនុស្សស្លាប់អស់ ២៥លាននាក់ កាត់បន្ថយមនុស្សអស់ចំនួន១/៤។

### ២.២. ប្រវត្តិកំណើនប្រជាជនពីឆ្នាំ ១៦៥០ ដល់ឆ្នាំ ១៩៥០

ក្នុងរយៈពេល ៣០០ឆ្នាំនេះ ប្រជាជនពិភពលោកកើនពី ៥០០លានទៅ ២៥០០លាននាក់។ កំណើនមធ្យមមាន០.៥% ស្មើងប់ដង កាលពីមុនឆ្នាំ១៦៥០។ កំណើននេះបានមកពីតំហយចុះដាប់លាប់នៃអត្រាមរណប្រមាណ ចាប់តាំងពីពាក់កណ្តាលទីពីរនៃសតវត្សទី១៨ ធ្វើឱ្យមានកំណើនប្រជាជនយ៉ាងរហ័ស។

ចាប់តាំងពីសតវត្សទី១៨មក បដិវត្តន៍កសិកម្ម អាចផ្តល់នូវចំណីអាហារ ដ៏ល្អប្រសើរ និងបានបញ្ចប់គ្រោះទុរ្ភិក្ស ពីក្នុងប្រទេសនោះ ការរីកចម្រើនផ្នែកវិជ្ជាពេទ្យ និង អនាម័យបានធ្វើឲ្យមរណប្រមាណថយចុះនៅសតវត្សទី១៩ ការប្រើប្រាស់ទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកក្នុងក្រុង ការសិក្សាអប់រំពីភាពស្អាត និង ការចាក់វ៉ាក់សាំង បានរីកសាយ ពិសេសការ ប្រយុទ្ធប្រឆាំងជំងឺអុត ដ៏កាចសាហាវ ជាអំរែកមរណៈរាប់សតវត្សកន្លងមក នៅគ្រប់ទីកន្លែង អត្រាជាតិប្រមាណ មានកម្រិត ខ្ពស់ ប្រជាជនកើនជាមធ្យមក្នុងអត្រាពី១ ទៅ ១.៥%។

### ២.៣. ប្រវត្តិកំណើនប្រជាជនពីឆ្នាំ ១៩៥០ មក

នៅសតវត្សទី២០ កំណើនប្រជាជននៅតែខ្លាំងក្លាដោយសារតំហយចុះយ៉ាងរហ័សនៃមរណប្រមាណ ប្រជាជនពិភពលោក មានចំនួន៣ពាន់លាននាក់នៅឆ្នាំ១៩៦០ មាន៤.៤៣៥ពាន់លាន (១៩៨០) ៥.២៦៤ ពាន់លាន (១៩៩០) និង ៦.៥ ពាន់លាន (២០០៦)។ កំណើនដ៏ខ្លាំងក្លានេះមានតែនៅក្នុងប្រទេសកំពុងអភិវឌ្ឍនៃទ្វីបអាស៊ី អាព្រិក និងអាមេរិកឡាទីន។ មរណប្រមាណនៅក្នុងប្រទេសលោកខាងត្បូង បានថយចុះយ៉ាងសម្បើមដោយសារវឌ្ឍនភាពសេវាកម្មសុខាភិបាល កសិកម្ម និងជំនួយស្បៀង។

## ៣. អន្តរភាពប្រជាសាស្ត្រ

អន្តរភាពប្រជាសាស្ត្រ គឺជាដំណើរឆ្លងកាត់ពីរបបប្រជាសាស្ត្រមួយ ដែលមានជាតិប្រមាណនិង មរណប្រមាណ ខ្ពស់ទៅ របបប្រជាសាស្ត្រមួយទៀត ដែលមានជាតិប្រមាណ និង មរណប្រមាណទាប។

### ៣.១. របបប្រជាសាស្ត្រប្រពៃណី

- នៅមុនអន្តរភាពប្រជាសាស្ត្រ អត្រាកំណើនធម្មជាតិមានកម្រិតទាបណាស់ ព្រោះជាតិប្រមាណ និង មរណប្រមាណខ្ពស់ដូចគ្នា។
- ជាតិប្រមាណខ្ពស់ ព្រោះនៅជំនាន់នោះគេមិនបានយល់ដឹងសោះឡើយថា អ្វីទៅជាផែនការគ្រួសារនោះ ហើយគូរ ស្រករក៏ បង្កើតកូនដោយចៃដន្យ មិនមែនតាមក្តីប្រាថ្នាឡើយ។
- អ្នកជំនាន់នោះរស់នៅតាមបែបធម្មជាតិ ក្រោមការញាំញីនៃជំងឺរាតត្បាតគ្មានថ្នាំសង្កូវត្រឹមត្រូវសម្រាប់ការ ព្យាបាល ពោល គឺវេជ្ជសាស្ត្រមានកម្រិតទាប។

### ៣.២. អន្តរភាពប្រជាសាស្ត្រវគ្គទី១

- គេឃើញមានកំណើនធម្មជាតិខ្ពស់ ព្រោះជាតិប្រមាណខ្ពស់ តែមរណប្រមាណស្រុតចុះ ជាតិប្រមាណនៅតែខ្ពស់ ព្រោះលទ្ធភាពបង្កកំណើតមានកម្រិតខ្ពស់ (៦ទៅ៨នាក់ សម្រាប់ស្ត្រីម្នាក់)
- មរណប្រមាណចាប់ផ្តើមថយចុះ ពិសេសមរណភាពកុមារ ព្រោះកិច្ចការពារផ្នែកវេជ្ជសាស្ត្រមានភាពប្រសើរ ស្របគ្នានឹងអនាម័យផងដែរ។

### ៣.៣. អន្តរភាពប្រជាសាស្ត្រវគ្គទី២

- គេសង្កេតជាតិប្រមាណថយចុះ ស្របគ្នានឹងមរណប្រមាណនៅតែទាប ដែលជាហេតុនាំឲ្យកំណើនធម្មជាតិនៃ ប្រជាជនចាប់ផ្តើមមានល្បឿនយឺត ជាតិប្រមាណស្រុតចុះយ៉ាងរហ័ស។
- អាស្រ័យមូលហេតុច្រើនយ៉ាង តម្លៃជីវភាពកើនឡើង ការចូលរួមកាន់តែច្រើនក្នុងកិច្ចការសង្គម និងការងារផលិតកម្មរបស់នារីវេជ្ជសាស្ត្រកាន់តែជឿនលឿនខ្លាំង ចំណីអាហារកាន់តែប្រសើរឡើង។

### ៣.៤. អន្តរភាពប្រជាសាស្ត្រទំនើប

- អន្តរភាពប្រជាសាស្ត្រត្រូវបានបញ្ចប់ នៅពេលដែលចំនួនប្រជាជនមានលំនឹងលទ្ធភាពបង្កកំណើតរបស់ស្ត្រីចុះទាប (២នាក់ ឬទាបជាងនេះ)
- មរណប្រមាណ លែងបន្តថយចុះទៀត តែជួនកាលអាចកើនឡើងផងដែរ ព្រោះសមាមាត្រមនុស្ស ចាស់ កាន់តែធំ (ភាពចំណាស់នៃទម្រង់ប្រជាជន)។

## ៤. ពិភពលោកមួយបែងចែក ទៅតាមប្រជាសាស្ត្រ

សព្វថ្ងៃស្ថានភាពប្រជាសាស្ត្រប្រទេសអភិវឌ្ឍមានលក្ខណៈផ្ទុយគ្នា។ ប្រទេសលោកខាងជើងបានចេញផុតពីអន្តរភាពប្រជាសាស្ត្រហើយ រីឯប្រទេសលោកខាងត្បូង ភាគច្រើនស្ថិតនៅក្នុងវគ្គទី២នៃអន្តរភាពប្រជាសាស្ត្រ ក្នុងពេលដែលប្រទេសខ្លះ ទៀត ទើបតែ បញ្ចប់វគ្គទី១ប៉ុណ្ណោះ។ នៅប្រទេសអភិវឌ្ឍ លទ្ធភាពបង្កកំណើត របស់ស្ត្រី មានកម្រិតទាប (តិចជាង២នាក់) ដោយសារគូស្រករ មានការយល់ដឹងច្បាស់ពីលក្ខខណ្ឌជីវភាព និង ស្ម័គ្រចិត្តយកកូនតិច។ នៅទ្វីបអឺរ៉ុបដ៏ចំណាស់នេះ ជំនាន់មនុស្ស លែងកើតមានទៀតហើយ។ ស្ថានភាពនៅក្នុងប្រទេស អភិវឌ្ឍមានប្លែកៗគ្នា រដ្ឋមួយចំនួនជា ចិន កូរ៉េខាងត្បូង តៃវ៉ាន់ សឹង្ហបុរី ថៃ បានបញ្ចប់ អន្តរភាពប្រជាសាស្ត្រខ្លួនហើយ ដោយសារនយោបាយផែនការគ្រួសារដ៏មានប្រសិទ្ធភាព។

## ៥. កំណើនប្រជាជន និងភាពក្រីក្រ

ដំណើរការវិវត្តឆ្ពោះទៅរកអន្តរភាពប្រជាសាស្ត្រ របស់ប្រទេសកំពុងអភិវឌ្ឍ ពុំគ្រាន់តែបណ្តាលឲ្យមានកំណើន ប្រជាជន យ៉ាងឆាប់រហ័សប៉ុណ្ណោះទេ ថែមទាំងនាំមកនូវបម្រែបម្រួលទម្រង់ប្រជាជនតាមភេទ និង តាមអាយុ (ពីរ៉ា មីត អាយុប្រជាជន) និង ទម្រង់គ្រួសារយ៉ាងខ្លាំងក្លាទៀតផង បាតុភូតទាំងពីរនេះជះឥទ្ធិពលវិជ្ជមានឬ អវិជ្ជមាន ទៅលើភាពក្រីក្រ អាស្រ័យនិងភាពជឿនលឿន នៅក្នុងអន្តរភាពប្រជាសាស្ត្រ។

### ៥.១. ពេលដំបូងនៃអន្តរភាពប្រជាសាស្ត្រ

ក្នុងដំណាក់កាលនេះ ពីរ៉ាមីតអាយុប្រជាជនបានបង្ហាញច្បាស់លាស់ណាស់ថា ប្រជាជនមានទម្រង់ក្មេង ពោល គឺចំនួន កុមារមានច្រើនជាងមនុស្សពេញវ័យ ហើយផលវិបាកគឺ៖

- ប្រាក់សន្សំ មានកម្រិតទាប (មេគ្រួសារត្រូវចំណាយលុយយ៉ាងច្រើន សម្រាប់ចិញ្ចឹមគ្រួសារដ៏ធំ និង មិនអាចសន្សំលុយកាក់បានឡើយ)
- សុខភាព និង ការសិក្សាអប់រំមានកម្រិតទាប (ខ្វះថវិការ ព្យាបាលជំងឺ និងការរៀនសូត្ររបស់កូនចៅ)
- កំណើនសម្ពាធលើបម្រើបម្រាស់ធនធានធម្មជាតិ (កំណើនតម្រូវការអុស ធ្យូង ឈើ សំណង់នានា នាំឱ្យបាត់ បង់ព្រៃឈើជាដើម)

- កំណើវិសមភាពភេទ (កំណើនការងារផ្ទះរបស់ស្ត្រីមេផ្ទះ និងកូនស្រីដែលជាប់រវល់ជួយកិច្ចការផ្ទះ ខកខានមិនបានទៅសាលារៀន)។

### ៥.២. ដំណាក់កាលទី២នៃអន្តរភាពប្រជាសាស្ត្រ

ដំណើរឆ្ពោះទៅរកលំនឹងប្រជាសាស្ត្រ ជាពិសេសរវាងកុមារនិង មនុស្សពេញវ័យ ទំហំគ្រួសារឆ្ពោះទៅរកភាពរួមតូច បន្ទុកគ្រួសារតិច ជីវភាពគ្រួសារអាចល្អប្រសើរឡើង សុខភាព និង ការសិក្សា អប់រំ ត្រូវបានកែលំអ ផលិតភាពការងារ និង ផលទុនអាចត្រូវបានលើកកម្ពស់ ភាពក្រីក្រ អាច ត្រូវបានកាត់បន្ថយ។ រដ្ឋអាចសម្រេចបាននូវការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ចំណែកនៅអាព្រិកក្បែរសាហារ៉ា លទ្ធភាពបង្កកំណើតរបស់ស្ត្រីនៅមានកម្រិតខ្ពស់នៅឡើយ ៥.២នាក់ /ស្ត្រីម្នាក់)នៅក្នុងប្រទេសតែមួយ លទ្ធភាពបង្កកំណើតក៏ខុសគ្នាដែរទៅតាមក្រុមសង្គម ។

### ៥.៣. ការមានកូនច្រើនជាគុណប្រយោជន៍សម្រាប់គ្រួសារក្រីក្រដែរឬទេ?

គ្រួសារក្រីក្រយល់ថា ការមានកូនច្រើនផ្តល់ប្រយោជន៍យ៉ាងច្រើនដូចជា៖

- កូនៗអាចជួយឪពុកម្តាយ ពេលគាត់មានវ័យចាស់
- កូនៗដែលមិនទាន់ទៅសាលា ចាប់បំពេញការងារ(អាយុ៥ឆ្នាំ)និងរកលុយបានបន្តិចបន្តួចសម្រាប់ជួយសម្រាលជីវភាពគ្រួសារ
- កូនស្រី អាចជួយសម្រាលការងារផ្ទះរបស់អ្នកម្តាយ

ចំពោះគ្រួសារទាំងនោះការមានកូនច្រើនអាចបន្តរស់បានប៉ុន្តែលទ្ធភាពនៃការអប់រំ និងសន្សំប្រាក់ដែលជាមធ្យោបាយ សំខាន់ ក្នុងការទប់ស្កាត់ភាពក្រីក្រមានតិចតួចណាស់។ ការសិក្សាអប់រំ អាចជួយកាត់បន្ថយអត្រាមរណៈ ដូចជាការសិក្សា យល់ដឹងអំពីវិធីទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ជាពិសេសជំងឺអេដស ដែលនាំមកនូវ ផលវិបាក យ៉ាងច្រើនដូចជា៖

- មានទុក្ខព្រួយជាប្រចាំ ដោយឃើញកូនស្លាប់មុនខ្លួន
- ការលំបាកដោយបាត់បង់ការជួយឧបត្ថម្ភពីកូន ពេលខ្លួនជរា
- មានបន្ទុកការងារបន្ថែមលើកិច្ចការ ដែលកូនរបស់ពួកគេធ្លាប់បំពេញ
- មានបន្ទុកចិញ្ចឹមបីបាច់រក្សារចៅតូចៗ ដែលកំព្រា។

## ៦. របាយប្រជាជនពិភពលោក

ប្រទេសលោកខាងជើង បានឈានចូលសម័យប្រជាសាស្ត្រទំនើបហើយ ចំណែកប្រទេសលោកខាងត្បូងមួយចំនួនទើបតែបានឆ្លងផុតអន្តរភាពប្រជាសាស្ត្រ មួយចំនួនធំស្ថិតក្នុងវគ្គទី២ នៃអន្តរភាពក្នុងពេលដែលមួយចំនួនទៀតទើបនឹងឆ្លងវគ្គទី១នៅឡើយ។

### ៦.១. ការប៉ានស្មានចំនួនប្រជាជនតាមតំបន់ធំៗ

តើអ្នកប្រជាសាស្ត្រ ធ្វើការប៉ាន់ស្មានចំនួនប្រជាជនពិភពលោកដោយរបៀបណា? ចំណោលប្រជាសាស្ត្រប្រព្រឹត្តិ ទៅដោយផ្អែកលើរូបមន្តគណិតសាស្ត្រ និង ប្រើប្រាស់អត្រាកំណើនណាមួយជាគោល លើសពីនេះគេអាចគណនា រយៈពេល កើនទ្វេរនៃចំនួនប្រជាជនក្នុងប្រទេសណាមួយ តំបន់មួយ ឬ ក្នុងពិភពលោកទាំងមូល។ ប្រជាជនពិភពលោក កើនឡើងឥតឈប់ឈរ មិនអាចទប់ទល់បានឡើយ ភពផែនដីមានមនុស្សរស់

នៅចំនួន៥លាននាក់កាលពី ៦០០០ ឬ៧០០០ឆ្នាំមុន។ នៅដើមសម័យយើងនេះមានមនុស្ស១០០០លាននាក់/ឆ្នាំ១៨០០ ៣០០០លាននាក់/ឆ្នាំ១៩៦០ និង៦.៥៣ន់លាននាក់/២០០៦។ ចំនួននេះនឹងកើនឡើងជាង៨០០០លាននៅឆ្នាំ២០២៥។

សំទុះថេរនៃអត្រាកំណើនប្រជាសាស្ត្រ បង្កើតមានលំនាំកំណើនមួយគួរឱ្យកង្វល់។ តាមពិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍសព្វថ្ងៃ **ជំនាន់មនុស្ស** កំពុងធ្វើដំណពូជស្ថិតក្នុង**ក្រុមអាយុ**មួយ ដែលមានចំនួនច្រើនជាងកាលពីជំនាន់ឪពុកម្តាយរបស់ពួកគេ។ គេត្រូវរងចាំប៉ុន្មានឆ្នាំទៀតពេលកូនៗ របស់ពួកគេគ្រប់អាយុរៀបការ ទើបគេអាចសង្កេតឃើញតំហយចុះដាក់លាក់មួយនៃកំណើន។ នៅទីបញ្ចប់ផ្នែកមួយនៃពិភពលោក (ពិសេសមួយភាគធំនៃទ្វីបអាព្រិក និងមជ្ឈឹមបូព៌ា) មិនដែលស្គាល់អ្វី ដែលហៅថាកម្រិតកំណើតនៅឡើយ ហើយគេត្រូវរងចាំជាបន្តទៀត ដើម្បីធ្វើឱ្យមានមរណប្រមាណថយចុះនៅ ក្នុងចំណោមប្រទេសមួយចំនួននៃប្រទេសលោកខាងត្បូងមួយចំនួន។ ភាពចំណាស់នៃប្រជាជនជាផលវិបាកបានមកពីតំហយចុះនៃលទ្ធភាពបង្កកំណើតរបស់ស្ត្រីនៅក្នុងប្រទេសអភិវឌ្ឍ គេមានក្តីបារម្ភពីឥទ្ធិពលនៃភាពចំណាស់ប្រជាជនលើសលប់មួយនៅក្នុងប្រទេសអភិវឌ្ឍ គេត្រូវរងបន្ទុកដ៏ធ្ងន់នៃទម្រង់ប្រជាជនក្មេង(ចំនួនកុមារមានច្រើនជាងមនុស្សពេញវ័យ) ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍនឹងស្គាល់ភាពចំណាស់ នៃប្រជាជនបានឆាប់រហ័សនៅពេលមរណៈប្រមាណមានតំហយចុះយ៉ាងខ្លាំងតែប៉ុណ្ណោះ។

### ៦.២. ប្រទេសដែលមានប្រជាជនច្រើនជាងគេ

ក្នុងរយៈពេលមិនយូរប៉ុន្មានខាងមុខនេះ សង្វាក់កំណើនខុសគ្នា ធ្វើឲ្យផលធៀបរវាងតំបន់ប្រជាជនធំៗ មានការប្រែប្រួលក្នុងមួយឆ្នាំៗ ប្រជាជនពិភពលោកកើនបានចំនួន៨៥លាននាក់ ដែលក្នុងចំនួននេះ ទ្វីបអឺរ៉ុប ស្រូបយកតែ១.៧% អាមេរិកខាងជើងបាន២.២% អាស៊ី៦៥% ទ្វីបអាព្រិក២០% និង អាមេរិកឡាទីន ១១%។ នៅប៉ុន្មានទសវត្សរ៍ខាងមុខនេះ ប្រជាជននៃប្រទេសអភិវឌ្ឍនឹងថយចុះយ៉ាងរហ័ស ពិសេសនៅទ្វីបអឺរ៉ុប រីឯនៅទ្វីបអាព្រិកវិញនឹងត្រូវរងនូវទម្ងន់ប្រជាសាស្ត្រ ដែលកើនឡើងយ៉ាងសម្បើម បន្ទាប់មកគឺអាមេរិកឡាទីន ចំណែកឯទ្វីបអាស៊ីវិញចំនួនប្រជាជននឹងស្ថិតនៅថេរ។ ដូចគ្នានេះ ដែរ ចំណាត់ថ្នាក់រដ្ឋតាមចំនួនប្រជាជននឹង ត្រូវប្រែប្រួល នៅឆ្នាំ២០២៥ ចំនួនប្រជាជនចិន និង ឥណ្ឌាមួយផ្នែក ជាមួយ សហរដ្ឋអាមេរិកមួយផ្នែកទៀត នឹងបង្ហាញឲ្យឃើញពីគម្លាតរវាងគ្នាយ៉ាងច្បាស់ ប្រទេសនីសេរីយ៉ា និង មានប្រជាជនច្រើនជាងសហរដ្ឋអាមេរិក ប្រទេសប្រេស៊ីល ប៉ាគីស្ថាន និងបង់ក្លាដែស នឹងមានប្រជាជនប្រហាក់ប្រហែលសហរដ្ឋអាមេរិក សព្វថ្ងៃ ប្រទេសបារាំងនឹងមានប្រជាជនត្រឹមតែពាក់កណ្តាលប្រជាជន អេចូពី និង តិចជាងប្រទេសអេស៊ីប សាអៀ តង់សានី កេនីញ៉ា ដែលសព្វថ្ងៃនេះខ្លួនមានច្រើនជាង។

### ៦.៣. ភាពវិបត្តប្រជាសាស្ត្រ

នៅឆ្នាំ២០៥០ ប្រជាជនពិភពលោកនឹងមានប្រហែល ៩៣ន់លាននាក់ ខុសគ្នាពីចំនួន ១៥៣ន់នាក់ ដែលគេ បាន ផ្សព្វផ្សាយកាលពី៥០ឆ្នាំមុន។ តំហយល្បឿននៃកំណើនប្រជាជន ជាប់ទាក់ទងទៅនឹងកម្រិតទាប នៃលទ្ធភាពបង្កកំណើត របស់ស្ត្រី។ សន្ទស្សន៍មធ្យមនៃលទ្ធភាពបង្កកំណើតក្នុងពិភពលោក នឹងត្រូវស្ថិតនៅក្រោមបន្ទាត់នៃតំណជំនាន់មនុស្ស (១.៨នាក់ ទល់នឹងស្ត្រី ២.១សម្រាប់ស្ត្រីម្នាក់) ជានិច្ចកាលប្រទេសជាច្រើន នៅអាព្រិក និង មជ្ឈឹមបូព៌ាមានសន្ទស្សន៍មធ្យមលើសពី៤នាក់ អាស្រ័យហេតុនេះ ទ្វីបអាព្រិកនឹង

មានប្រជាជន កើនឡើងជិតពីរដង គឺដល់ទៅ១.៥៣ពាន់លាននាក់ពី ឥឡូវនេះទៅដល់ឆ្នាំ២០៥០ មែនហើយ នយោបាយកូន ទោល បានធ្វើឲ្យអត្រាជាតិប្រមាណរបស់ចិនចុះមកត្រឹមតែ ១.៣% គេអាចប្រៀបបានទៅនឹងប្រទេសបារាំង ១.២% តែភាគច្រើននៃប្រជាជនចិននៅតែក្មេង (ទម្រង់ប្រជាជនក្មេង)។

### ៦.៤. ប្រជាជននឹងមាន៩ពាន់លាននាក់នៅឆ្នាំ២០៥០

កពផែនដីនឹងមានប្រជាជនរស់នៅចំនួនប្រហែល៩ពាន់លាននាក់នៅឆ្នាំ២០៥០ ទល់នឹង ៦.៥ ពាន់លាននាក់ នៅពេលបច្ចុប្បន្ន។ ជានិច្ចកាលនិន្នាការទូទៅ គឺការកាត់បន្ថយល្បឿនកំណើនប្រជាសាស្ត្រធៀបទៅនឹងកំណើនកាលពី២០ ទៅ៥០ឆ្នាំមុនដែលជួយគាំទ្រឲ្យមានស្ថិរភាពប្រជាសាស្ត្រពិភពលោកយ៉ាងយឺតៗមួយៗ។

នៅក្នុងប្រទេសឧស្សាហកម្ម លើកលែងតែសហរដ្ឋអាមេរិកចេញ ការមកដល់នៃអន្តោប្រវេស្តន៍បណ្តាលឱ្យមានកំណើនប្រជាសាស្ត្រមួយ តែមិនបង្កើតឲ្យមានជំនាន់មនុស្សថ្មីសោះឡើយ។ ក្នុងលក្ខខណ្ឌទាំងនេះ ប្រជាជនលោកខាងជើង ដែលសព្វថ្ងៃ មានចំនួន១.២ពាន់លាននាក់ និងមិនត្រូវកើនទៀតទេ រហូតដល់ ២០៥០។ អង្គការសហប្រជាជាតិ ប៉ាន់ស្មានថានឹងមានតំហយប្រជាសាស្ត្រនៅប្រទេសអាល្លឺម៉ង់ អ៊ីតាលី រុស្សី និងនៅប្រទេសដ៏ទៃទៀត ដែលបែកចេញ ពីសហភាព សូវៀត ផ្ទុយទៅវិញប្រជាជនប្រទេសក្រីក្រនឹងកើនឡើងពីឥឡូវទៅដល់ឆ្នាំ២០៥០ ពី៥.៣ពាន់លាននាក់ ទៅ៧.៨ពាន់លាន នេះជាសំទុះប្រជាសាស្ត្រដែលពន្យល់ដោយអង្គការសហប្រជាជាតិ។

កពផែនដីមានមនុស្សរស់នៅមិនស្មើគ្នាទេ តំបន់ខ្លះមានមនុស្សរស់នៅកុះករ តំបន់ខ្លះជាវាលរហោស្ថាន តំបន់ខ្លះ មានមនុស្សរស់នៅជាមធ្យម និងតំបន់ខ្លះទៀតមនុស្សរស់នៅតិចតួច សូម្បីតែនៅក្នុងប្រទេសមួយក៏មានរបាយប្រជាជនមិនស្មើគ្នាដែរ។

**ប្រទេស២៥ដែលមានប្រជាជនច្រើនជាងគេលើពិភពលោក (គិតជាលាននាក់)**

| ល.រ | ឈ្មោះប្រទេស | ១៩៥០ | ល.រ | ឈ្មោះប្រទេស | ១៩៩៤ | ល.រ | ឈ្មោះប្រទេស | ២០៥០ |
|---|---|---|---|---|---|---|---|---|
| ១ | ចិន | ៥៥៤ | ១ | ចិន | ១១៩២ | ១ | ចិន | ១៣១៥ |
| ២ | ឥណ្ឌា | ៣៥០ | ២ | ឥណ្ឌា | ៩១១ | ២ | ឥណ្ឌា | ១១០៣ |
| ៣ | សហភាពសូវៀត | ១៨០ | ៣ | ស.រ.អាមេរិក | ២៦០ | ៣ | ស.រ.អាមេរិក | ២៩៨ |
| ៤ | ស.រ.អាមេរិក | ១៥២ | ៤ | ឥណ្ឌូនេស៊ី | ២០០ | ៤ | ឥណ្ឌូនេស៊ី | ២២២ |
| ៥ | ជប៉ុន | ៨៤ | ៥ | ប្រេស៊ីល | ១៥៥ | ៥ | ប្រេស៊ីល | ១៨៦ |
| ៦ | ឥណ្ឌូនេស៊ី | ៨០ | ៦ | រុស្សី | ១៥០ | ៦ | ប៉ាគីស្ថាន | ១៥៨ |
| ៧ | ប្រេស៊ីល | ៥៣ | ៧ | ប៉ាគីស្ថាន | ១២៦ | ៧ | រុស្សី | ១៤៣ |
| ៨ | អង់គ្លេស | ៥១ | ៨ | ជប៉ុន | ១២៥ | ៨ | បេងក្លាដេស | ១៤២ |
| ៩ | អាល្លឺម៉ង់ខាងលិច | ៥០ | ៩ | បេងក្លាដេស | ១១៧ | ៩ | នីសេរីយ៉ា | ១៣១ |
| ១០ | អ៊ីតាលី | ៤៧ | ១០ | នីសេរីយ៉ា | ៩៨ | ១០ | ជប៉ុន | ១២៨ |
| ១១ | បារាំង | ៤២ | ១១ | ម៉ិចស៊ិចកូ | ៩២ | ១១ | ម៉ិចស៊ិចកូ | ១០៧ |
| ១២ | បេងក្លាដេស | ៤២ | ១២ | អាល្លឺម៉ង់ | ៨១ | ១២ | វៀតណាម | ៨៧ |
| ១៣ | ប៉ាគីស្ថាន | ៤០ | ១៣ | វៀតណាម | ៧៣ | ១៣ | ភីលីពីន | ៨៣ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៤ | នីសេរីយ៉ា | ៣៣ | ១៤ | ភីលីពីន | ៦៩ | ១៤ | អាល្លឺម៉ង់ | ៨២ |
| ១៥ | វៀតណាម | ២៨ | ១៥ | តួគី | ៦២ | ១៥ | អេចូពី | ៧៧ |
| ១៦ | អេស្ប៉ាញ | ២៨ | ១៦ | អ៊ីរ៉ង់ | ៦១ | ១៦ | អេស៊ីប | ៧៤ |
| ១៧ | ម៉ិចស៊ិចកូ | ២៧ | ១៧ | ថៃ | ៦០ | ១៧ | តួគី | ៧៣ |
| ១៨ | ប៉ូឡូញ | ២៥ | ១៨ | អេស៊ីប | ៥៩ | ១៨ | អ៊ីរ៉ង់ | ៦៩ |
| ១៩ | ភីលីពីន | ២១ | ១៩ | អ៊ីតាលី | ៥៨ | ១៩ | ថៃ | ៦៤ |
| ២០ | តួគី | ២១ | ២០ | អង់គ្លេស | ៥៨ | ២០ | បារាំង | ៦០ |
| ២១ | ថៃ | ២០ | ២១ | បារាំង | ៥៨ | ២១ | រាជាណាចក្ររួម | ៥៩ |
| ២២ | កូរ៉េខាងត្បូង | ២០ | ២២ | អេចូពី | ៥៥ | ២២ | អ៊ីតាលី | ៥៨ |
| ២៣ | អេស៊ីប | ២០ | ២៣ | អ៊ុយក្រែន | ៥១ | ២៣ | កុងកោ | ៥៧ |
| ២៤ | អាល្លឺម៉ង់ខាងកើត | ១៨ | ២៤ | កូរ៉េខាងត្បូង | ៤៥ | ២៤ | មីយ៉ាន់ម៉ា | ៥០ |
| ២៥ | មីយ៉ាន់ម៉ា | ១៨ | ២៥ | មីយ៉ាន់ម៉ា | ៤៥ | ២៥ | កូរ៉េខាងត្បូង | ៤៧ |

**ស្ថានភាពប្រជាជនក្នុងប្រទេសអភិវឌ្ឍ និង ប្រទេសកំពុងអភិវឌ្ឍន៍**




## ៧. ការលំបាកក្នុងការវាស់វិសមភាពនៃការអភិវឌ្ឍ

ការអភិវឌ្ឍគឺជា សមត្ថភាពនៃសង្គមមួយក្នុងការបំពេញតម្រូវការចាំបាច់របស់ប្រជាជនខ្លួន និង អាចឲ្យគេទទួល បាននូវផាសុកភាព សុខភាព ភាពសម្បូរសប្បាយ គេមិនត្រូវច្រឡំថា វាជាកំណើនសេដ្ឋកិច្ចធម្មតា ដែលអាចបំពេញតម្រូវ ការមនុស្សមួយក្រុមតូចនោះទេ ប្រទេសខ្លះអាចធានារ៉ាប់រងនូវភាពសល់ផលជូនប្រជាជនខ្លួនបាន ប្រទេសខ្លះទៀតមិនអាចរ៉ាប់រងនូវតម្រូវការរស់នៅរបស់ប្រជាជនបានឡើយ។

### ៧.១. ផាសុកភាព និង ទុរគ៌តភាព

តម្រូវការទី១របស់មនុស្សគឺការមានចំណីអាហារគ្រប់គ្រាន់ ប្រកបដោយគុណភាព និង ប្លែកៗគេត្រូវ

ការនូវថាមពលពី ២២០០-២៥០០ កាល់ឡូរី/ថ្ងៃ សម្រាប់មនុស្សម្នាក់ទៅតាមអាកាសធាតុ អាយុ និង សកម្មភាព ព្រមទាំង ប្រូតេអ៊ីនបានមកពីសត្វ ៥០ក្រាម ដោយមិនគិតពីវីតាមីន និង សារធាតុខនិជ (កាល់ស្យូម អ៊ីយ៉ូត សូដ្យូម) ផ្សេងៗទៀត។ តម្រូវការនេះមិនអាចកើតមាននៅគ្រប់ទីកន្លែងទេ ជាទូទៅប្រជាជននៃប្រទេសអភិវឌ្ឍខ្លាំងបំផុត មានរបបហូបចុ កគ្រប់គ្រាន់ និង លើសពីគ្រប់គ្រាន់ ទៅទៀត ទន្ទឹមនឹងប្រទេសអឺរ៉ុបខាងកើត និងប្រទេសខ្លះនៃតំបន់មេឌីរ៉ានេនៅខ្វះខាតជាតិប្រូតេអ៊ីនតិចតួចនៅក្នុងប្រទេសមួយចំនួនផ្សេងទៀត( ពិសេស នៅអាមេរិកឡាទីន នៅតំបន់ម៉ាក្រិបនៅមជ្ឈឹមបូព៌ា) មនុស្សម្នាក់ ទទួលបានកាឡូរីជាបង្គួរ តែខ្វះខាតជាតិ ប្រូតេអ៊ីនច្រើន នៅកន្លែងដ៏ទៃទៀត របបអាហារគិតជាកាឡូរីមានមិនគ្រប់គ្រាន់ ជួនកាលខ្វះខាតខ្លាំង (តិចជាង ២០០០កាល់ឡូរី) និង មានជាតិប្រូតេអ៊ីនកម្រិតទាប (តិចជាង ២០ក្រាម)។ គេប៉ាន់ស្មាន ថាមានមនុស្សប្រហែល ៤៥០លាននាក់ (ដែល ២/៣នៅអាស៊ីខាងត្បូង និង ១/៥ នៅទ្វីបអាព្រិច ) ទទួលរងនូវ ការហូប ចុកខ្វះខាត។ ជាញឹកញាប់ពួកគេតែងទទួលការហូបចុកមិនគ្រប់គ្រាន់ ដែលជាហេតុនាំមកនូវជំងឺកង្វះជីវជាតិ (ជំងឺក្រិស ខ្សោយ អស់កម្លាំង អន់ភ្នែក) ផ្ទុយទៅវិញ ទុរ្ភិក្សច្រើនកើតមានតែនៅក្នុងប្រទេសដែលធាប់ឆេះដោយ ចម្បាំង ក្នុងស្រុក ឬ ចម្បាំងពីខាងក្រៅ។ សមត្ថភាពចំពោះការរស់រាន និងមរណភាពក៏ពិបាក និងបង្កើតឲ្យមានផង ដែរនៅក្នុងលោក នៅ សៀរ៉ាលេអូន សង្ឃឹមរស់មានត្រឹម៤២ឆ្នាំ ចំណែកនៅប្រទេសចិនមាន៧០ឆ្នាំ និង នៅប្រទេសបារាំងមាន៧៧ឆ្នាំ អត្រា មរណភាពកុមារ ជាមធ្យមនៅប្រទេសលោកខាងលិចមាន ៤ដងទាបជាង នៅអាព្រិក និងអាស៊ី។ នៅអឺរ៉ុបខាងលិចអត្រានេះធ្លាក់មកនៅទាបជាង១% រីឯនៅប្រទេសម៉ាលីមានលើសពី១៦.៥%។ ចំពោះក្របខណ្ឌវេជ្ជសាស្ត្រ និងការចំណាយ ទៅលើសេវាសុខាភិបាលមានភាពខុសគ្នា ខ្លាំងរវាងប្រទេសនីមួយៗ នៅប្រទេសលោកខាងលិច ជាមធ្យមគ្រូពេទ្យម្នាក់ ទទួលបន្ទុកព្យាបាលមនុស្ស ៧០០នាក់ ប៉ុន្តែនៅប្រទេសភាគច្រើននៃទ្វីបអាព្រិច និង អាស៊ី ទទួលបន្ទុក ព្យាបាលមនុស្ស ២៧០០០នាក់ នៅអាព្រិច នៅពេលប្រជាជននៃប្រទេសអភិវឌ្ឍ (អាមេរិកខាងជើង អឺរ៉ុប រុស៊ី អូស្ត្រាលី) ចំណាយពី ២០០ទៅ៧០០ដុល្លា/ឆ្នាំ សម្រាប់ការព្យាបាលដោយឡែក ប្រទេសកំពុងអភិវឌ្ឍវិញអាចចំណាយបាន ត្រឹមតែ តិចជាង ៥ដុល្លារប៉ុណ្ណោះ។ នៅទីនេះគេនិយាយពីការប្រើប្រាស់ពេទ្យក្នុងកម្រិតខ្ពស់ហួស ចំណែកនៅទីនោះ គេកំពុងតែខ្វះខាត ថ្នាំសង្កូវសំខាន់ៗទៅវិញ ភាពងាយស្រួលក្នុងការទទួលនូវកម្រិតវប្បធម៌មានមិនដូចគ្នា ទេក្នុងពិភពលោក មែនហើយការខិត ខំប្រឹងប្រែងផ្នែកអក្ខរកម្មបានប្រព្រឹត្តទៅនៅក្នុងប្រទេសជាច្រើន តែអត្រាអនក្ខរភាពប្រែប្រួលពី២ ទៅ៨២% នៅក្នុងប្រទេស ជឿនលឿនបំផុត ជាទូទៅអត្រានេះមានមិនលើសពី ៥% ទេអាមេរិចឡាទីនមាន១៦% អាស៊ី៣៦% អាព្រិចក្បែរសាហារ៉ា ៥០% (ឃើតយ៉ាងណាស់)។ ប្រទេសរីក ចម្រើនបំផុត បោះផ្សាយបានជិត ៣/៤ នៃសៀវភៅ និងសារព័ត៌មាន ក្នុងពិភពលោក ភាពទន់ខ្សោយ នៃការអភិវឌ្ឍ អាចវាយតម្លៃតាមរយៈសូចនាករសង្គម និងសេដ្ឋកិច្ចផ្សេងៗ ទៀតជាច្រើនដូចជាកំណើនប្រជាសាស្ត្រ មួយខ្ពស់នៅឡើយនៅក្នុងប្រទេសក្រីក្របំផុតការវាយតម្លៃទាបចំពោះស្ត្រីភេទ ភាពទន់ខ្សោយនៃវណ្ណៈមធ្យម និង ផលិតភាពទាបនៃការងារនៅទីជនបទ សមត្ថភាពទាបផ្នែកបច្ចេកវិទ្យា ភាពចំណុះគ្នានៃសេដ្ឋកិច្ច ហិរញ្ញវត្ថុ ដោយមិនត្រូវបំភ្លេចចោលពីការមិនគោរពសិទ្ធមនុស្ស និង សេរីភាពគ្រឹះនៅក្នុងប្រទេសមួយចំនួនផងទេ។



**ផាសុកភាព និងទុរគតភាពនៃប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ**

## ៧.២. បញ្ញាត្តិនានានៃតតិយលោក លោកខាងជើង និងលោកខាងត្បូង

នៅសម័យក្រោយសង្គ្រាមលោកលើកទី៣ ប៉ុណ្ណោះដែលគេបាននាំគ្នាចាប់អារម្មណ៍ទៅលើទំហំនៃវិសមភាពសេដ្ឋកិច្ចរវាងប្រទេសរីកចម្រើនខ្ពស់ និង ប្រទេសដ៏ទៃទៀតដែលរីកចម្រើនតិចតួច ឬក៏ទេ។ នៅឆ្នាំ១៩៤៩ លោកប្រធានា ធិបតីអាមេរិកទ្រូម៉ាន់ បានប្រកាសដំណឹង អំពីផែនការជំនួយដល់ប្រទេសទាំងនោះដែលលោកហៅថា ប្រទេសកំពុងអភិវឌ្ឍ។ នៅឆ្នាំ១៩៥២ អ្នកប្រជាសាស្ត្របារាំងម្នាក់ឈ្មោះ អាប្រិតសូវី បានបង្កើតបញ្ញត្តិថ្មី តតិយ លោក យោងតាមពាក្យតតិយរដ្ឋ ដែលគេប្រើសំដៅជនក្រីក្ររងការមើលងាយមើលថោកកាលពីមុនបដិវត្តន៍បារាំងឆ្នាំ ១៧៨៩។ នៅឆ្នាំ ១៩៥៥ កិច្ចប្រជុំអាស៊ី-អាព្រិក នៅទីក្រុងបានឌុង (ឥណ្ឌូនេស៊ី) បានធ្វើឲ្យគេចាប់អារម្មណ៍ទៅលើឯកភាពរបស់ប្រទេសតតិយលោក ទាំងនោះ។ នៅពេលនោះគេបង្កើតលក្ខណៈវិនិច្ឆ័យទៅលើពាក្យមិនទាន់អភិវឌ្ឍ(ប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គម និងវប្បធម៌)។ គេបានកំណត់ន័យនៃពាក្យ មិនទាន់អភិវឌ្ឍ ថាជាភាពខុសគ្នារវាងកំណើនយឺតនៃធនធានសម្ភារៈ និង កំណើន តម្រូវការរបស់ប្រជាជន។ នៅឆ្នាំ១៩៥៧ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ (OECD) បានប្រើកន្សោមពាក្យ ដែលមានលក្ខណៈសុទិដ្ឋិនិយម ជាងគឺ ប្រទេសកំពុងស្ថិតនៅក្នុងមាគ៌ាអភិវឌ្ឍន៍ ក្រោយមកបានសម្រួលត្រឹមប្រទេសកំពុងអភិវឌ្ឍ។ ការបង្ហាញភាពផ្ទុយគ្នារវាងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍមានលក្ខណៈសម្គាល់ច្បាស់លាស់ដូចជា ភាពមានបានគឺមានអ្វីៗទាំងអស់ ការរស់នៅល្អប្រសើរ ការព្យាបាលជំងឺមានកម្រិតជំនាញខ្ពស់ កាសិក្សាអប់រំប្រកបដោយគុណភាព និងភាពសម្បូរោងចក្រឧស្សាហកម្មខ្លាំង។ ប្រទេសអភិវឌ្ឍរួមមាន អាមេរិចខាងជើង សហភាពអឺរ៉ុប រុស្ស៊ី អូស្ត្រាលី ជប៉ុន និងញូហ្សេលែន។ ចំណែកប្រទេសអាហ្សង់ទីន និងអាព្រិកខាងត្បូងកាន់តែរត់មកប្រកៀកហើយនោះ ត្រូវគេចាត់ទុកថាជាប្រទេសកំពុងអភិវឌ្ឍនៅឡើយ ដោយហេតុថា ប្រទេសអភិវឌ្ឍទាំងអស់ស្ទើរតែស្ថិតនៅអឌ្ឍគោលខាងជើង និងខ្លះទៀតនៅអឌ្ឍគោលខាងត្បូង គេក៏ប្រកាន់យកទម្លាប់បែងចែកពិភពលោកជា លោកខាងជើងអភិវឌ្ឍ និងលោកខាងត្បូងកំពុងអភិវឌ្ឍ ឬក៏ជាមជ្ឈមណ្ឌល មួយនិងមួយទៀតជាបរិមណ្ឌល។

## ៧.៣. វិសមភាពវាស់តាម GDP ឬ HDI

ជាទូទៅកម្រិតវិសមភាពត្រូវបានគេវាស់វែង តាមផលិតផលជាតិសរុប(GNP) ឬតាមផលិតផលក្នុងស្រុកសរុប(GDP)សម្រាប់មនុស្សម្នាក់មានន័យថាតាមតម្លៃនៃរបស់ទ្រព្យ និងសេវាដែលប្រជាជនក្នុងប្រទេស

មួយទទួលបានក្នុងឆ្នាំណាមួយ តាមរយៈនេះ គេសង្កេតឃើញមានគម្លាតជីវភាពរវាងមនុស្សលើភពផែនដី។ ប្រជាជនអេចូពី រស់នៅមាន ទឹកប្រាក់ ៨២៣ដុល្លារ/ឆ្នាំ ក្នុងពេលដែលសហរដ្ឋអាមេរិចមានដល់ទៅ ៤១ ៣៩៩ដុល្លារ/ឆ្នាំ និង ប្រជាជនលុចសំបូរ ដល់ទៅ ៦៩ ៨០០ដុល្លារ/ឆ្នាំ នៅឆ្នាំ២០០៣ ប៉ុន្តែការប្រើផលិតផលជាតិសរុប(GNP) ឬតាមផលិតផល ក្នុងស្រុកសរុប(GDP) សម្រាប់មនុស្សម្នាក់មិនគ្រប់គ្រាន់ទេដើម្បីវាស់កម្រិតនៃការភិវឌ្ឍ ព្រោះថាវាគ្រាន់តែជាមធ្យមភាពគដែលអាច លាក់កំបាំងវិសមភាពផ្ទៃក្នុងយ៉ាងធំធេង ម្យ៉ាងទៀតប្រាក់ដុល្លារ ដែលជារូបិយវត្ថុគំរូមានការប្រែប្រួលខ្លាំង ហើយតម្លៃពិត របស់វាមិនដូចគ្នានៅគ្រប់ទីកន្លែងនោះទេ។ ឧទាហរណ៍៖ បើគេមានប្រាក់ ៤០០០ដុល្លារនៅញូយ៉ក គេហាក់ដូចជាខ្វះអ្វីៗសព្វបែបយ៉ាង បើនៅប៉ុបេរិញ គេហាក់ដូចជាមានបាវបម្រើ៥នាក់នៅក្នុងផ្ទះអញ្ចឹងនេះគេមិនទាន់គិតពីសេដ្ឋកិច្ចលួចលាក់ នៅក្នុងប្រទេសអភិវឌ្ឍខ្លះដូចជាប្រទេស អ៊ីតាលីឬក៏ សេដ្ឋកិច្ចមិនសមស្រប និងផលិតកម្មស្វ័យប្រើប្រាស់ដែលកើតមាន ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍផងទេ។ ស្ថិតិមួយចំនួនខិតខំវាយតម្លៃ លើលទ្ធភាពទិញដូរពិតប្រាកដរបស់ប្រជាជន តាមរយៈនេះ គេញែកប្រទេសជាក្រុមដូចតទៅ៖

- ប្រទេសដែលមានណាស់ប្រមូលផ្តុំ១៥% នៃប្រជាជនពិភពលោកមានប្រទេសឧស្សាហកម្មធំៗ (សហរដ្ឋអាមេរិក កាណាដា អឺរ៉ុបខាងជើង៣យ័ព្យ ជប៉ុន អូស្ត្រាលី និង ញូហ្សេឡែន) ប្រទេសអ្នកនាំចេញប្រេងកាត ដែលមានប្រជាជនតិចដូចជា អារ៉ាប៊ីសាអ៊ូឌីត ឬ ប្រទេសឧស្សាហកម្មថ្មីនៃអាស៊ី (សឹង្ហបុរី ហុងកុង តៃវ៉ាន់ កូរ៉េខាងត្បូង)។

**ប្រទេស២០ដែលមាន HDIខ្ពស់ និង ទាបឆ្នាំ២០១១**

| ប្រទេស២០ដែលមាន HDI ខ្ពស់ជាងគេ | | | ប្រទេស២០ដែលមាន HDI ទាបជាងគេ | | |
|---|---|---|---|---|---|
| ល.រ | ឈ្មោះប្រទេស | HDI | ល.រ | ឈ្មោះប្រទេស | HDI |
| ១ | ណរវែស | ០.៩៦៣ | ១៥៦ | គីនេ | ០.៤៦៦ |
| ២ | អ៊ីស្លង់ | ០.៩៥៦ | ១៥៧ | សេនេកាល់ | ០.៤៥៨ |
| ៣ | អូស្ត្រាលី | ០.៩៥៤ | ១៥៨ | រ្វ៉ាន់ដា | ០.៤៥០ |
| ៤ | ស៊ុយអ៊ែត | ០.៩៤៩ | ១៥៩ | អង់កូឡា | ០.៤៤៥ |
| ៥ | កាណាដា | ០.៩៤៩ | ១៦០ | បេណាំង | ០.៤៣១ |
| ៦ | លុចសំបួ | ០.៩៤៩ | ១៦១ | កូតអ៊ីវ័រ | ០.៤២០ |
| ៧ | ស្វ៊ីស | ០.៩៤៧ | ១៦២ | តង់សានី | ០.៤១៨ |
| ៨ | អៀឡង់ | ០.៩៤៦ | ១៦៣ | ម៉ាឡាវី | ០.៤០៤ |
| ៩ | ប៊ែលស៊ិច | ០.៩៤៥ | ១៦៤ | សំប៊ី | ០.៣៩៤ |
| ១០ | សហរដ្ឋអាមេរិក | ០.៩៤៤ | ១៦៥ | កុងហ្គោ | ០.៣៨៥ |
| ១១ | ជប៉ុន | ០.៩៤៣ | ១៦៦ | ម៉ូសំប៊ិច | ០.៣៧៩ |
| ១២ | ហូឡង់ | ០.៩៤៣ | ១៦៧ | ប៊ូរុនឌី | ០.៣៧៨ |
| ១៣ | ដាណឺម៉ាក | ០.៩៤១ | ១៦៨ | អេចូពី | ០.៣៦៧ |
| ១៤ | ផាំងឡង់ | ០.៩៤១ | ១៦៩ | អាព្រិចកណ្តាល | ០.៣៥៥ |

| | | | | | |
|---|---|---|---|---|---|
| ១៥ | រាជាណាចក្ររួម | ០.៩៣៩ | ១៧០ | គីនេប៊ីសាវ | ០.៣៤៨ |
| ១៦ | បារាំង | ០.៩៣៨ | ១៧១ | ឆាត | ០.៣៤១ |
| ១៧ | អូទ្រីស | ០.៩៣៦ | ១៧២ | ម៉ាលី | ០.៣៣៣ |
| ១៨ | ញូហ្សេលែន | ០.៩៣៣ | ១៧៣ | បៀគីណាផាសូ | ០.៣៣០ |
| ១៩ | អាឡឺម៉ង់ | ០.៩៣០ | ១៧៤ | សៀរ៉ាលេអូន | ០.២៩៨ |
| ២០ | អេស្ប៉ាញ | ០.៩២៨ | ១៧៥ | នីស៊េរីយ៉ា | ០.២៨១ |

- ប្រទេសដែលមានជាបង្គួរប្រមូលផ្តុំចំនួ២០% នៃប្រជាជនពិភពលោក មានប្រទេសអឺរ៉ុបមួយចំនួនដែលអនុវត្ត របប សេដ្ឋកិច្ចទីផ្សារ (ព័រទុយហ្គាល់ ក្រិក) រដ្ឋមួយចំនួនធំនៃអតីតសហភាពសូវៀត និង ប្រទេសអឺរ៉ុបខាងកើត ក៏ដូចជាមួយភាគ ធំនៃអាមេរិចឡាទីន។
- ប្រទេសក្រីក្រ ឬ ក្រណាស់ នៅទ្វីបអាព្រិក និង អាស៊ី ប្រមូលផ្តុំចំនួន ២/៣ នៃប្រជាជនពិភពលោក និងបង្កើត បានត្រឹមតែ ២០% នៃផលទុនពិភពលោកប៉ុណ្ណោះ។ ក្រក្នុងចំណោមក្រ ប្រទេសមិនសូវជឿនលឿនក្នុងពិភពលោកទាំងនោះ បង្កើតបានជាខ្សែក្រវ៉ាត់ទុរគ៌ក នៅភាគខាងត្បូងសាហារ៉ា មានប្រជាជនប្រមាណ៤៩៥.៦លាននាក់ (២០០៨) មានផល ទុនសរុបតែពាក់កណ្តាលផលទុនប្រទេស បែលស៊ិចមួយប៉ុណ្ណោះ។ ប្រទេសខ្លះនៃប្រទេសកំពុងអភិវឌ្ឍដូចជាហៃទី ម៉ាដាកាស្កា ស៊ូដង់ និង ជាទូទៅអាព្រិចខាងត្បូងសាហារ៉ា ស្ថិតនៅនឹងថ្កល់ក្នុងភាពមិនសូវជឿនលឿនរីកចម្រើន អាស្រ័យហេតុ នេះទើបគេអាចនិយាយបានពីចត្វាលោកឬ លោកទីបួន សំដៅលើក្រុមប្រទេសក្រីក្របំផុតនៃលោកកំពុងអភិវឌ្ឍ។ នៅឆ្នាំ១៩៩០កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP = United Nations for Development Program) បានបង្កើតសូចនាករថ្មីមួយទៀតសម្រាប់វាស់កម្រិតនៃការអភិវឌ្ឍន៍របស់មនុស្ស (HDI = Human Development Index) ដោយរួមបញ្ចូលសន្ទស្សន៍ជាច្រើនដូចជាសង្ឃឹមរស់ពីកំណើត អក្ខរភាពមនុស្សពេញវ័យ មុខរបរផលិតកម្មនិង សេវាកម្មនានា របស់ប្រជាជន និង ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ។ HDI អាចវាស់វែងកម្រិតនៃ ការអភិវឌ្ឍពិត ប្រាកដ របស់ប្រទេសនីមួយៗបានត្រឹមត្រូវជាង។

## ៨. ពិភពលោកមួយមានការអភិវឌ្ឍមិនស្មើគ្នា

ពិភពលោកមួយអភិវឌ្ឍមិនស្មើគ្នា នាំឱ្យមានការបែងចែកពិភពលោកជា២គឺ លោកខាងជើង និងលោកខាងត្បូង។ មនុស្សមានលក្ខណៈពហុភាពទៅតាមវប្បធម៌ ប្រព័ន្ធនយោបាយ បែបផែនផលិតកម្ម បណ្តូរ និង បម្រើបម្រាស់គ្រឿងសម្ភារៈ។ របាយសកម្មភាព ធនធាន ក៏ដូចជាភ័ព្វសំណាងក្នុងការរស់រាន មានភាពមិនស្មើគ្នាទេក្នុងពិភពលោកកន្លែងខ្លះ គេមានលើសលប់នូវអ្វីៗទាំងអស់ ចំណែកឯកន្លែងខ្លះទៀត គេខ្វះខាតនូវអ្វីដែលចាំបាច់។ ប៉ុន្តែភាពផ្ទុយគ្នារវាងប្រទេសមាន និងប្រទេសក្រីក្រ អ្នកគ្រប់សង្កត់គេ និង អ្នកដែលត្រូវគេគ្របសង្កាត់ រវាងលោកខាងជើង និង លោកខាងជើង មិនបានបង្ហាញឲ្យឃើញនូវលក្ខណៈមួយជាទីគាប់ចិត្តនាពេលបច្ចុប្បន្ននេះឡើយ។

# ពិភពលោកមួយភិវឌ្ឍមិនស្មើគ្នា



## ៨.១. ការរៀបចំឡើងវិញនូវប្រព័ន្ធពិភពលោក

ប្រព័ន្ធពិភពលោកអាចចែកចេញជាពីរប្លុកគឺ លោកខាងត្បូង និង លោកខាងជើង។ លោកខាងត្បូងរួមមាន ប្រទេសអាព្រិក អាស៊ី (លើកលែងប្រទេសខ្លះនៃអាស៊ីបូព៌ា សំខាន់បំផុតគឺជប៉ុន និងប្រទេសនាំចេញប្រេងកាតខ្លះ នៃមជ្ឈឹមបូព៌ា) មួយភាគធំនៃអាមេរិចឡាទីន ប្រជាជាតិខ្លះនៃអូសេអានី ប្រទេសមួយចំនួននៃអឺរ៉ុបខាងកើត មានប្រជាជន សរុបចំនួន៣/៤ នៃប្រជាជនពិភពលោក។ លោកខាងជើងរួមមាន សហរដ្ឋអាមេរិក និងកាណាដា មួយភាគធំនៃទ្វីបអឺរ៉ុប អូស្ត្រាលី និងញូសេឡេន និង ប្រទេសខ្លះនៃអាស៊ីបូព៌ា។ លោកខាងត្បូងជាពាក្យប្រើសម្រាប់ សម្គាល់ក្រុម ប្រទេស ដែលមានការអភិវឌ្ឍកម្រិតទាបទុរគតខ្លាំង។ ចំណែក លោកខាងជើងរួមមានប្រទេស ប្រទេសឧស្សាហកម្ម ប្រទេស អ្នកមាន និយាយរួមគឺជាក្រុមប្រទេសដែលប្រជាជនភាគច្រើនរស់នៅដោយសម្បូរសប្បាយ។ ប្លុកទាំងពីរដែលបង្ហាញ ពីភាពផ្ទុយ គ្នារវាងប្រទេសអ្នកមាន និង ប្រទេសអ្នកក្រមិនមានលក្ខណៈស្ថិតស្ថេរទេ ជាការពិត ប្រទេសខ្លះមានការរីក ចម្រើន អវិឌ្ឍមាន។ ផ្ទុយទៅវិញ មានប្រទេសខ្លះបានឆ្លងផុតពីលោកខាងត្បូងចូលទៅក្នុងផ្ទៃនៃលោកខាងជើង ដូចជា ករណី ប្រទេសឧស្សាហកម្មថ្មីជាពិសេស នាគទាំង៤នៃអាស៊ី មានដូចជា កូរ៉េខាងត្បូង តៃវ៉ាន់ ហុងកុង និង សឹង្ហបុរី។

## ៨.២. ប្រទេសលោកខាងជើង

ក្រុមប្រទេសទាំងនេះ កំពុងស្ថិតក្នុងការរៀបចំឡើងវិញយ៉ាងស៊ីជម្រៅ ហាក់ដូចជាបង្ហាញឲ្យឃើញថាពុំមែនជា លំហមួយទទួលបានការរីកចម្រើនស្មើសាច់នោះទេ។ ការបែកបាក់នៃសហភាពសូវៀត និងការទទួលបានឯករាជ្យ របស់បណ្ដាប្រទេសអតីតសង្គមនិយមអឺរ៉ុបខាងកើត បានបង្ហាញឲ្យឃើញថា មានការវាយតម្លៃខ្ពស់ហួសលើស កម្រិតនៃការអភិវឌ្ឍរបស់រដ្ឋទាំងនោះ ហើយបាននាំមកនូវ ឱនភាពសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ផលទុនសម្រាប់មនុស្ស ម្នាក់ៗរបស់ ប្រទេសនោះមានកម្រិតទាបជាងប្រទេសជាច្រើននៅអាមេរិចឡាទីនរដ្ឋខ្លះដូចជា ប៉ូឡូញ ឬ រ៉ូម៉ានី អាចរាប់បញ្ចូលទៅក្នុងក្រុមប្រទេសអភិវឌ្ឍ។ កាលពីសម័យអតីតសហភាពសូវៀត(១៩៨៨) ផលិតផលជាតិសរុប សម្រាប់មនុស្សម្នាក់គឺ GDP=៧៤០០ដុល្លារអាមេរិក។ ប៉ុន្តែនៅឆ្នាំ ១៩៩១ប្រទេសរុស៊ីទទួលបានត្រឹម១៦៥០ដុល្លារ ហើយរដ្ឋទាំងឡាយនៃអាស៊ីកណ្ដាល និងតំបន់កូកាស ពី ៦០០ទៅ ១១០០ដុល្លារ តិចជាងប្រទេសប្រេស៊ីល និង អាព្រិចខាងត្បូងច្រើនណាស់ (២ ៨០០ដុល្លារ) ឬ ម៉ិចស៊ិក (៣០០០ដុល្លារ)។ នៅក្នុងប្រទេសអតីតសង្គមនិយមអឺរ៉ុបខាងកើត កសិកម្មប្រើប្រាស់កម្លាំងពលកម្ម

យ៉ាងតិចក៏ ២០% នៃប្រជាជននៅឡើយ។ ចំណែកនៅអឺរ៉ុបខាងលិច និងសហរដ្ឋអាមេរិក ប្រើអស់តិចជាង ១០%។ តារាងខាងក្រោមនេះបង្ហាញពីផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំគិតជាដុល្លារសហរដ្ឋអាមេរិក របស់បណ្ដាប្រទេសបណ្ដាប្រទេសអាស៊ីកណ្ដាល និងតំបន់កូកាសនៅឆ្នាំ២០០២ និង ២០០៥។

### ៨.៣. ប្រទេសលោកខាងត្បូង

គម្លាតផលទុនរវាងក្រុមប្រទេសទាំងនេះ មានធំធេងនៅឡើយគម្លាតនេះមានពី១ទៅ១៥ឬ ៣០ រវាងប្រទេសដូចជា ម៉ិចស៊ិក (៣០១០ដុល្លារ/ម្នាក់) និងប្រទេសមួយចំនួន១៥នៃក្រុមប្រទេសដែលមានការអភិវឌ្ឍតិច ដោយទទួលបានតិចជាង ២០០ដុល្លារក្នុងឆ្នាំ១៩៩១ (ប្រទេសអេចូពី តង់សានី ១២០ដុល្លារ ម៉ូសំប៊ិច ៨៥ដុល្លារ)។

ទម្រង់សេដ្ឋកិច្ចប្រទេសលោកខាងត្បូង មានលក្ខណៈប្លែកៗគ្នាដូចជានៅប្រទេសលោកខាងជើងដែរ ប្រទេសប្រេងកាតខ្លះ បានឆ្លៀតយកចំណេញពីការតម្លើងថ្លៃប្រេងជាបន្តបន្ទាប់ សម្រាប់កសាងផ្លូវថ្នល់ កំពង់ផែ អគារសាធារណៈ សាកលវិទ្យាល័យ សម្រាប់បណ្ដាក់ទុននៅប្រទេសលោកខាងលិចក្នុងវិស័យសណ្ឋាគារ អគារ រថយន្ត ឬ សម្រាប់អភិវឌ្ឍឧស្សាហកម្ម និងកសិកម្មរបស់ខ្លួន ទោះបីមានការធ្លាក់ចុះថ្មីៗនៃតម្លៃប្រេងដែលនាំមកនូវផលប៉ះពាល់យ៉ាងខ្លាំងក៏ដោយ ក៏ប្រទេសអាល់សេរី វេនេស៊ុយអេឡា ឧទាហរណ៍ អាចសម្រេចបាន សព្វថ្ងៃនេះជាង ១/៣ នៃផលិតផលក្នុងស្រុកសរុបលើផ្នែកឧស្សាហកម្ម។ ប្រទេសដ៏ទៃទៀតដែលពឹងផ្អែកលើសារៈសំខាន់នៃទីផ្សារក្នុងស្រុកលើតម្លៃថោក និងភាពប៉ិនប្រសប់នៃពលករ ឬលើភោគទ្រព្យជាតិ បានក្លាយទៅជាប្រទេសពាក់កណ្ដាលឧស្សាហកម្ម (ប្រទេសប្រេស៊ីល ម៉ិចស៊ិក ឥណ្ឌា អាហ្សង់ទីន)។

**ប្រទេស១០ក្រីក្របំផុតក្នុងពិភពលោក ឆ្នាំ២០១១**

| ល.រ | ឈ្មោះប្រទេស | ឈ្មោះទីក្រុង | ផលិតផលជាតិសរុប GDP ($) |
|---|---|---|---|
| ១ | សាធារណរដ្ឋ កុងហ្គោ | Kinshasa | ៣៤៨ |
| ២ | លីបេរីយ៉ា | Monrovia | ៤៥៦ |
| ៣ | ហ្ស៊ីមបាវ៉េ | Harare | ៤៨៧ |
| ៤ | ប៊ូរុនឌី Burundi | Bujumbura | ៦១៥ |
| ៥ | អេរីត្រា Eritrea | Asmara | ៧៣៥ |
| ៦ | សាធារណរដ្ឋអាព្រិកកណ្ដាល | Bangui | ៧៦៨ |
| ៧ | នីហ្សេ Niger | Niamey | ៧៧១ |
| ៨ | សេរ៉ាឡេអុន Sierra Leone | Freetown | ៨៤៩ |
| ៩ | ម៉ាឡាវី Malawi | Lilongwe | ៨៦០ |
| ១០ | តូហ្គោ Togo | Lome | ៨៩៩ |

## សំណួរត្រិះរិះ

១. តើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មានទម្រង់ប្រជាជនយ៉ាងដូចម្តេច? ចូរពន្យល់។
២. ចូរប្រៀបធៀបអត្រាមរណប្រមាណមាតានៃប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសអភិវឌ្ឍន៍ ។
៣. ចូរនិយាយពីសារៈសំខាន់នៃអត្រានុកូលដ្ឋាន។
៤. នៅក្នុងអន្តរភាពប្រជាសាស្ត្រ តើដំណាក់កាលប្រជាសាស្ត្រណាដែលត្រូវបានបញ្ចប់? ហេតុអ្វី?
៥. ចូរប្រៀបធៀបអាយុកាលសង្ឃឹមរស់ប្រជាជននៅប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍។

# មេរៀនទី២ ៖ ប្រជាជន និងការអភិវឌ្ឍនៅកម្ពុជា

## ១. ទម្រង់ប្រជាសាស្ត្រនៃកម្ពុជា

សម្រាប់ពាក្យថា **អភិវឌ្ឍន៍** មានន័យថា លទ្ធភាពអាចរស់នៅបានយូរអង្វែង ប្រកបដោយ សុខភាពល្អ ទទួលបានការអប់រំ និងលទ្ធភាពទទួលបានធនធានចាំបាច់ សម្រាប់ការរស់នៅសមរម្យ។ ដើមឡើយគេកំណត់ពាក្យ អភិវឌ្ឍន៍ សំដៅទៅលើវិសមភាពសេដ្ឋកិច្ចតែមួយមុខប៉ុណ្ណោះ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាច្រើនយកមកធ្វើជាមូលដ្ឋានគិត ក្នុងមានផលិតផលក្នុងស្រុកសរុប និង ផលិតផលជាតិសរុបជាដើម។ ប៉ុន្តែពាក្យថា អភិវឌ្ឍន៍ បែបសេដ្ឋកិច្ចនិយមនេះត្រូវគេជំទាស់ជាច្រើន ហើយលើកយកវង្វាស់វិសមភាពថ្មីៗថែមទៀត សម្រាប់ធ្វើជាមូលដ្ឋាននៃការគិតលើការអភិវឌ្ឍប្រជាជននៃនីមួយៗ។

ចាប់ពីឆ្នាំ១៩៩០មក កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP)បានបង្កើត **សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស** (HDI = Human Development Index ឬ IDH= Index du development Human)ដោយគិតលើសន្ទស្សន៍ធំៗ៣គឺ សង្ឃឹមរស់ពីកំណើត អក្ខរភាពមនុស្សពេញវ័យ និង ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់។

ចាប់ពីឆ្នាំ១៩៩៧ មក កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ បានរៀបចំឡើងនូវសន្ទស្ស ន៍មួយថ្មីទៀតសម្រាប់បំភ្លឺជ្រុងម្ខាងទៀតនៃការអភិវឌ្ឍន៍មនុស្សគឺ **សន្ទស្សន៍ភាពក្រីក្រ**។ មានភាពខុសគ្នាខ្លាំងរវាងសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស នៃបណ្តាប្រទេសក្នុងពិភពលោក ក្នុងកម្រិតទាបបំផុត០.២៧៣(សៀរ៉ាឡេអូន) ខ្ពស់បំផុត ០.៩៥៦ (ន័រវេស)។ ក្នុងឆ្នាំ ២០០៦ ប្រទេសកម្ពុជាមានសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ០.៥៧៥ ជាប់ចំណាត់ថ្នាក់ទី១១៦លើ១៧៧ ក្នុងចំណោមប្រទេសជាសមាជិកអង្គការសហប្រជាជាតិ (នៅឆ្នាំ ១៩៩៧ ជាប់ចំណាត់ថ្នាក់ ១៤០ លើ ១៥៣)។

សុខភាពប្រជាជនគឺជា ផ្នែកមួយនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស និង កត្តាគន្លឹះនៃការអភិវឌ្ឍមនុស្ស។ ភាពល្អប្រសើរនៃសុខភាពក៏ដូចជាជីវិត អាចវាស់បានទៅតាមរបបម្ហូបអាហារដែលជាកត្តាសំខាន់សម្រាប់សុខមាលភាពមនុស្សលោក។ បច្ចុប្បន្ននៅកម្ពុជា ការប្រើប្រាស់សេវាសង្គម និង សេវាមូលដ្ឋាន នៅមានកម្រិតនៅឡើយ។

### ១.១. ទម្រង់ប្រជាសាស្ត្រ

ទម្រង់ប្រជាសាស្ត្រកម្ពុជារួមមាន ដង់ស៊ីតេប្រជាជន អត្រាភេទ ទម្រង់តាមភេទនិងអាយុ ប្រជាជនទីប្រជុំជន ប្រជាជនជនបទ ប្រជាជនសកម្មនិងក្រុមទន់ខ្សោយ។ ទម្រង់ប្រជាសាស្ត្រនេះ តែងតែប្រែប្រួលខុសៗគ្នាតាមសម័យកាលនីមួយៗ អាស្រ័យទៅតាមបម្រែបម្រួលនៃស្ថានភាពសង្គម សេដ្ឋកិច្ច នយោបាយ កម្រិតអភិវឌ្ឍន៍ផ្នែកវេជ្ជសាស្ត្រ និងវប្បធម៌របស់ប្រទេស។

### ១.២. ដង់ស៊ីតេនិងលទ្ធភាពបន្តកំណើតនៃប្រជាជនកម្ពុជា

យោងតាមការធ្វើជំរឿងរបស់ក្រសួងផែនការចាប់ពីម៉ោង 00:00នាទីថ្ងៃទី 3 ដល់ថ្ងៃទី13ខែមិនាឆ្នាំ ២០០៨ ប្រជាជនកម្ពុជាមានចំនួនសរុប 13 395 682នាក់ ក្នុងនោះប្រុសមានចំនួន 6 516 054 នាក់ និងស្រីចំនួន 6 879 628 នាក់(51.36%) ហើយអត្រាកំណើនប្រជាជនប្រចាំឆ្នាំមាន 1.54%។ ទិន្នន័យខាងលើ

នេះ បង្ហាញឱ្យឃើញពីកំណើនប្រជាជនកម្ពុជាគួរឲ្យកត់សំគាល់ បើធៀបទៅនឹងលទ្ធផលជំរឿនឆ្នាំ 1998 ប្រជាជនកម្ពុជាមានចំនួនសរុប 11 437 656 នាក់។ ជំរឿនឆ្នាំ 1962 ដែលជាជំរឿនចុងក្រោយនាសម័យសង្គមរាស្ត្រនិយម ប្រជាជនកម្ពុជាមានចំនួន 5 751 000នាក់។ ជំរឿនឆ្នាំ 1931 មានចំនួន 2 803 000នាក់ និងឆ្នាំ 1921 មានចំនួន 2 402 585នាក់។ របាយប្រជាជននៅតាមតំបន់ធំៗទាំងបួន ក៏ដូចតាមបណ្តាលខេត្តទាំង 23 និងរាជធានីដែរ គឺមិនស្មើគ្នាទេ។

- **តំបន់វាលរាប** មានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម ស្វាយរៀង ព្រៃវែង និង តាកែវ ប្រមូលផ្តុំប្រជាជនចំនួន 6 547 953 នាក់ស្មើនឹង 48.88%។
- **តំបន់ទន្លេសាប** មានខេត្តកំពង់ធំ សៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង បន្ទាយមានជ័យ ឧត្តរមានជ័យ និងប៉ៃលិន ប្រមូលផ្តុំប្រជាជនចំនួន 4 356 705នាក់ស្មើនឹង 32.53%។
- **តំបន់ឆ្នេរសមុទ្រ** មានខេត្តព្រះសីហនុ កំពត កែប និង កោះកុង ប្រមូលឧផ្តុំប្រជាជនចំនួន 960 480 នាក់ ស្មើនឹង 7.17%។
- **តំបន់ខ្ពង់រាបនិងតំបន់ភ្នំ** មានខេត្តកំពង់ស្ពឺ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ និង ព្រះវិហារ ប្រមូលផ្តុំប្រជាជនចំនួន 1 530 544នាក់ស្មើនឹង 11.43%.

តំបន់វាលរាបនិងតំបន់ទន្លេសាប មានប្រជាជនរស់នៅកុះករជាងតំបន់ឆ្នេរសមុទ្រនិងតំបន់ខ្ពង់រាបនិងភ្នំ ដោយសារតំបន់នេះ មានលក្ខខណ្ឌប្រសើរដល់ការរស់នៅ ប៉ុន្តែបើធៀបនឹងឆ្នាំ 1998 ឃើញថាអត្រាភាគរយមានការថយចុះបន្តិតនៅតំបន់ទន្លេសាបមានការកើនឡើងបន្តិច។ រីឯតំបន់ភ្នំនិងខ្ពង់រាប ចំនួនប្រជាជនកើនឡើងពី 10.39% នៅឆ្នាំ 1998 ទៅ 11.43% នៅឆ្នាំ 2008។

កំពង់ចាម ជាខេត្តដែលមានប្រជាជនរស់នៅច្រើនជាងគេគឺមានចំនួន 1 679 992នាក់។ បន្ទាប់មកគឺរាជធានីភ្នំពេញ ដែលមានប្រជាជនរស់នៅចំនួន 1 327 615នាក់(កាលពីឆ្នាំ 1998 ចំណាត់ ថ្នាក់ទី3 បន្ទាប់ពីកំពង់ចាម និងកណ្តាល)។ ឯខេត្តកណ្តាលដែលកាលពីឆ្នាំ 1998 មានចំណាត់ថ្នាក់លេខ 2 ខាងចំនួនប្រជាជនបានប្តូរមកចំណាត់ថ្នាក់លេខ 3 វិញ ក្នុងចំនួនប្រជាជន 1 265 280នាក់។ ឯខេត្តដែលមានប្រជាជនរស់នៅតិចជាងគេ គឺខេត្តកែប (35 753នាក់) និង បន្ទាប់មកគឺខេត្តមណ្ឌលគិរី និងខេត្តប៉ៃលិន ដែលកាលពីឆ្នាំ1998 ជាក្រុងប៉ៃលិន ក្រុងកែប និង ខេត្តមណ្ឌលគិរី។

ដង់ស៊ីតេប្រជាជន គឺជាចំនួនប្រជាជនក្នុងផ្ទៃដីមួយគីឡូម៉ែត្រការេ។ ប្រសិនបើប្រជាជនកើនក្នុងអំឡុងពេលមួយ តែទំហំផ្ទៃដីនៅដដែល នោះដង់ស៊ីតេប្រជាជននឹងកើនជាសមាមាត្រ។ ដង់ស៊ីតេប្រជាជនកម្ពុជាបានកើនពី 64នាក់/$km^2$ នៅឆ្នាំ 1998 ទៅ 75នាក់/$km^2$ នៅឆ្នាំ2008 (មិនគិតផ្ទៃបឹងទន្លេសាប 3000 $km^2$) គឺកើនឡើងចំនួន 11នាក់/$km^2$ តែក្នុងរយៈពេលមួយទសវត្សរ៍ប៉ុណ្ណោះ។ ចំនួននេះតិចជាងនៅតំបន់អាស៊ីអាគ្នេយ៍ ដែលមាន 126នាក់/$km^2$ ។ សិង្ហបុរី ជាប្រទេសដែលមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍ 7 053នាក់/$km^2$ បន្ទាប់មកគឺប្រទេសហ្វីលីពីន 320នាក់/$km^2$ វៀតណាម 260នាក់/$km^2$ និងថៃ 127នាក់/$km^2$ ។ ប្រទេសឡាវមានដង់ស៊ីតេត្រឹមតែ 28នាក់/$km^2$ ប៉ុណ្ណោះ គឺទាបជាងដង់ស៊ីតេប្រជាជនកម្ពុជាជិតបីដង។

តាមបណ្តាខេត្ត ដង់ស៊ីតេប្រជាជនប្រែប្រួលពីកម្រិតទាប 4នាក់/$km^2$ ក្នុងខេត្តមណ្ឌលគិរី ទៅ 4 516 នាក់/$km^2$ នៅរាជធានីភ្នំពេញ។ ខេត្តកណ្តាលនៅតែរក្សាលំដាប់ទីមួយក្នុងចំណោមខេត្តទាំង 23 ខាងដង់ស៊ីតេប្រជាជន 355នាក់/$km^2$ ។ បន្ទាប់មកគឺខេត្តតាកែវ 237នាក់/$km^2$ និងខេត្តព្រៃវែង 194នាក់/$km^2$ ។ ដង់ស៊ីតេនេះ ក៏មានការប្រែប្រួលរវាងពីស្រុកមួយទៅស្រុកមួយទៀតដែរទោះបីជានៅក្នុងខេត្តជាមួយគ្នាក៏ដោយ។ ខេត្តចំនួនពីរដែលមានដង់ស៊ីតេប្រជាជនថេរក្នុងរយៈពេលមួយទសវត្សរ៍នេះ គឺខេត្តព្រៃវែង( 194នាក់/$km^2$ ) និងកោះកុង( 12នាក់/$km^2$ )។

តំបន់ទំនាបកណ្តាលមានដង់ស៊ីតេប្រជាជន261នាក់/$km^2$លើសពីឆ្នាំ 1998 ដែលមានត្រឹមតែ 235 នាក់/$km^2$ បន្ទាប់មក គឺតំបន់ទន្លេសាប 64នាក់/$km^2$ និងតំបន់ឆ្នេរសមុទ្រ 56នាក់/$km^2$ ។ តំបន់ខ្ពង់រាបនិងភ្នំមានដង់ស៊ីតេប្រជាជនត្រឹមតែ 22នាក់/$km^2$ ប៉ុណ្ណោះ។

### ១.៣. កម្រិតលទ្ធភាពបង្កកំណើត

**អត្រាលទ្ធភាពបង្កកំណើត** គឺជាចំនួនកូនមធ្យមដែលស្ត្រីម្នាក់អាចបង្កើតបាននៅដំណាក់បន្តពូជ( 15-44ឆ្នាំ) តាមការធ្វើជំរឿនក្នុងឆ្នាំ2008 អត្រាលទ្ធភាពបង្កកំណើតបានថយចុះពីចំនួនកូនគិតជាមធ្យម ដែលស្ត្រីម្នាក់មាន 5.2 នាក់នៅឆ្នាំ 1998 មកនៅត្រឹម 3.1នាក់( ចន្លោះពី 2.7នាក់ទៅ 3.4នាក់)។ ថ្វីត្បិតតែអត្រានេះថយចុះជាងពីឆ្នាំ 1998 ដែលមាន5.2 នាក់ ក៏ដោយ តែបើធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់ អត្រានេះនៅតែមានកម្រិតខ្ពស់ជាងគេនៅឡើយ។ អត្រាលទ្ធភាពបង្កកំណើតរបស់ ស្ត្រីប្រែប្រួលទៅតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ច ទំនៀមទំលាប់ និងកម្រិតវប្បធម៌របស់ស្ត្រី ។ ស្ត្រីដែលមិនបានចូលរៀន មានកូនច្រើនជាងស្ត្រីដែលបានរៀនបញ្ចប់កម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ហើយស្ត្រីដែលបានរៀនចប់កម្រិតមធ្យមសិក្សាទុតិយភូមិនិងខ្ពស់ជាងនេះ លទ្ធភាពបង្កកំណើតក៏ថយចុះជាងនេះដែរ។ លទ្ធភាពបង្កកំណើតរបស់ស្ត្រីនៅទីប្រជុំជននៅចន្លោះពី 1.8 ទៅ 2.4 ជាមធ្យម 2.1 មានកម្រិតទាបជាងលទ្ធភាពបង្កកំណើតរបស់ស្ត្រីនៅជនបទដែលមានចន្លោះពី 2.9 ទៅ 3.6 និងជាមធ្យម 3.3នាក់។ **លទ្ធភាពបង្កកំណើតរបស់ស្ត្រី** គឺជាកត្តាកំណត់នៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI)។ ប្រសិនបើប្រទេសមួយ មានសន្ទស្សន៍អភីវឌ្ឍន៍មនុស្សទាប(បញ្ហាចូលរៀនមានកម្រិត អាហារូបត្ថម្ភមិនគ្រប់គ្រាន់ សុខភាពមិនទាន់ល្អ) នោះលទ្ធភាពបង្កកំណើតស្ត្រីមានកម្រិតខ្ពស់។ ផ្ទុយទៅវិញបើប្រទេសមួយមានសន្ទស្សន៍អភិវឌ្ឍន៍កម្រិតខ្ពស់ (អត្រាចូលរៀនខ្ពស់ អាហារូបត្ថម្ភគ្រប់គ្រាន់ សុខភាពប្រជាជនល្អប្រសើរ និងមានអាយុវែង) នោះលទ្ធភាពបង្កកំណើតរបស់ស្ត្រីមានកម្រិតទាបវិញ។ **អត្រាភេទ** គឺជាចំនួនមនុស្សប្រុសធៀបនឹងមនុស្សស្រី 100នាក់ ដែលមានសារៈសំខាន់សម្រាប់ជារង្វាស់សាមញ្ញនៃសមាសភាពភេទ។ អត្រាភេទប្រែប្រួលទៅតាមស្ថានភាពសង្គម តាមភូមិសាស្ត្រ តាមអាយុ និងចលនាបំលាស់លំនៅរបស់ប្រជាជន។ **ប្រជាជនសកម្មលើវិស័យសេដ្ឋកិច្ច** គឺបុរស និងស្ត្រីដែលធ្វើការងារលើវិស័យការងារទាំងបីគឺ កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ នៅកម្ពុជា ប្រជាជនដែលធ្វើការងារក្នុងវិស័យកសិកម្មភាគច្រើន ជាស្ត្រីនិងមាននិន្នាការថយចុះនៅទសវត្សរ៍ចុងក្រោយនេះ។ ឯវិស័យឧស្សាហកម្ម ចំនួនប្រជាជនធ្វើការងារមានចំនួនកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ គឺស្ត្រីមានចំនួនច្រើនជាងបុរស។ ចំពោះវិស័យសេវាកម្មក៏មានចំនួនកើនឡើងផងដែរ ឯចំនួនស្ត្រីវិញថ្វីត្បិតមានចំនួនតិចជាងបុរសក៏ដោយ តែបើធៀបទៅនឹងឆ្នាំ1998 មានសំទុះកើនឡើងខ្លាំងជាងបុរស។ **អត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច** គឺជាភាគ

រយនៃប្រជាជនសកម្មធៀបនឹងប្រជាជនសរុបចាប់ពីអាយុ7ឆ្នាំឡើងទៅ។ នៅកម្ពុជា មនុស្សចូលរួមសកម្មភាពសេដ្ឋកិច្ច(ប្រជាជនសកម្ម) សរុបមានចំនួន 7 053 398នាក់ ក្នុងនោះស្ត្រីមានចំនួន 3 608 345នាក់ត្រូវជា 51.16%។អត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅថ្នាក់ជាតិសម្រាប់មនុស្សអាយុ7ឆ្នាំឡើង (អន្តរជាតិគិត 15-64ឆ្នាំ)បានកើនឡើងក្នុងទសវត្សរ៍ឆ្នាំ 1998-2008 ចាប់ពី55.5%ទៅ 61.7%សម្រាប់មនុស្សទាំងពីរភេទ ចាប់ពី 56.5% ទៅ 62.5% សម្រាប់មនុស្សប្រុស និងចាប់ពី 54.6% ទៅ 60.9% សម្រាប់ស្ត្រី។

## ២. វិសមតាពនៃការប្រើប្រាស់សេវានៅកម្ពុជា

សុខភាពប្រជាជន គឺជាផ្នែកមួយនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស និងជាកត្តាគន្លឹះនៃការអភិវឌ្ឍន៍មនុស្ស។ ភាពល្អប្រសើរនៃសុខភាពក៏ដូចជាជីវិត អាចរស់វែងបានទៅតាមរបប អាហារ ដែល ជាកត្តាសំខាន់សម្រាប់សុខុមាលភាពមនុស្សលោក។ បច្ចុប្បន្ននៅប្រទេសកម្ពុជា ជំងឺឆ្លងត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងពិសេសជំងឺគ្រុនចាញ់ជំងឺអេដស៍ដែលមានរីករាលកាន់តែច្រើនឡើងៗ។ បញ្ហាបន្ទាប់ដែលកំពុងចោទនៅកម្ពុជាដែរនោះគឺកង្វះអាហាររូបត្ថម្ភរបស់កុមារ។ កង្វះអាហារនេះជាកត្តានាំឱ្យមនុស្សមួយចំនួនក្នុងសង្គមងាយទទួលគ្រោះថ្នាក់ដោយជំងឺផ្សេងៗ។

បច្ចុប្បន្នកំណើននៃជំងឺគ្រុនចាញ់ ផ្សារភ្ជាប់ទៅនិងចលនាបំលាស់លំនៅរបស់ប្រជាជន ពិសេសបំលាស់លំនៅពីជនបទទៅជនបទក្នុងបំណងធ្វើអាជីវកម្ម រ៉ែត្បូង មាស កាប់អុស ធ្វើចម្ការជាដើម ។ ខេត្តដែលមានប្រជាជនស្លាប់ច្រើនជាងគេដោយជំងឺគ្រុនចាញ់មាន ខេត្តបាត់ដំបង សៀមរាប ពោធិ៍សាត់ កំពង់ធំ ក្រចេះ និងកំពង់ចាម។

## ៣. អាយុសង្ឃឹមរស់នៃប្រជាជនកម្ពុជា

### ៣.១. អាយុសង្ឃឹមរស់

អាយុសង្ឃឹមរស់គឺជារយៈពេលនៃអាយុរបស់ប្រជាជននៅក្នុងប្រទេសមួយ ឬតំបន់មួយ ដែលរាប់ពីពេលកើតរហូតដល់ថ្ងៃស្លាប់។ ប្រទេសមួយដែលមានអាយុសង្ឃឹមរស់របស់ប្រជាជន ខ្ពស់ យើង អាចវាយតម្លៃបានថា ប្រទេសនោះជាប្រទេសរីកចម្រើន (ប្រទេសអភិវឌ្ឍ) ជាពិសេស ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវិទ្យាសាស្ត្រ ជាក់ស្តែងដូចជាប្រទេសជប៉ុន (៨១ឆ្នាំ) បារាំង (៧៩ឆ្នាំ) ស្វីស (៨០ឆ្នាំ)។ រីឯប្រទេសមានសេដ្ឋកិច្ចទន់ខ្សោយ ឬក៏ប្រទេសកំពុងអភិវឌ្ឍ អាយុសង្ឃឹមរស់ របស់ប្រជាជន មានកម្រិតទាប ជាក់ស្តែងដូចជាប្រទេសអេត្យូពី (៥៦ឆ្នាំ) ម៉ាលី (៤៧ឆ្នាំ) កម្ពុជា (៥៦ឆ្នាំ)។ អាយុសង្ឃឹមរស់ ដែលយើងមើលឃើញនៅក្នុងពិភពលោកទាំងមូលមានភាពប្រែប្រួល នៅក្នុងប្រទេសនោះទាំងតាមតំបន់ និងទៅតាមភេទនីមួយៗ។ ស្ត្រីភាគច្រើននៅគ្រប់ប្រទេសទាំងអស់តែងមានអាយុសង្ឃឹមរស់វែងជាងបុរស សូមមើលទៅលើតារាងខាងក្រោម៖

**អាយុកាលសង្ឃឹមរស់របស់ប្រជាជននៅ**
**ប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍ (ឆ្នាំ ២០០២)**

| ប្រទេស | អាយុកាលមធ្យម | អាយុតាមភេទ | |
|---|---|---|---|
| | | ស្ត្រី | បុរស |
| **ប្រទេសអភិវឌ្ឍ** | | | |
| ជប៉ុន | ៨១ | ៨៥ | ៧៨ |

| | | | |
|---|---|---|---|
| បារាំង | ៧៩ | ៨៣ | ៧៦ |
| សហរដ្ឋអាមេរិក | ៧៧ | ៨០ | ៧៤ |
| **ប្រទេសកំពុងអភិវឌ្ឍ** | | | |
| កម្ពុជា | ៥៦ | ៥៨ | ៥៤ |
| អេត្យូពី | ៥២ | ៥៣ | ៥១ |
| ម៉ាលី | ៤៧ | ៤៨ | ៤៦ |

**ប្រភព:** ឯកសារភូមិវិទ្យា អភិវឌ្ឍសម្រាប់ប្រើក្នុងដេប៉ាតឺម៉ង់ភូមិវិទ្យា

នៅកម្ពុជា អាយុកាលមធ្យមសង្ឃឹមរស់របស់ប្រជាជន៥៦ឆ្នាំ ក្នុងនោះស្ត្រី៥៨ឆ្នាំ បុរស៥៤ឆ្នាំ នេះបង្ហាញថាអាយុសង្ឃឹមរស់ប្រជាជនតាមភេទ ស្ត្រីមានអាយុខ្ពស់ជាងបុរស។ ក្រៅពីការបង្ហាញ អាយុប្រជាជនតាមភេទខុសគ្នា ក៏នៅមានភាពខុសគ្នានៅតាមតំបន់នីមួយៗដែរពីអាយុសង្ឃឹមរស់នេះ។ តំបន់ទីក្រុង(ប្រជុំជន) ប្រជាជនមានអាយុសង្ឃឹមរស់ខ្ពស់ជាងនៅជនបទ(ខេត្ត)នានា។ ភាពខុសគ្នានេះអាស្រ័យទៅលើវិស័យសង្គមកិច្ច សេដ្ឋកិច្ចរបស់ទីតាំងនីមួយៗ។ ជំរឿនរបស់ប្រជាជន ទូទៅនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៨ នៅក្នុងរបាយការណ៍ទី៦ វិភាគនៃលទ្ធផលជំរឿន ធ្វើផែនការណ៍ប្រជាជនក្នុងឆ្នាំ ២០០១-២០២១ ដែលមានរយៈពេល២០ឆ្នាំបានបង្ហាញថាអាយុសង្ឃឹមរស់របស់ប្រជាជននៅក្នុងទីក្រុង(ប្រជុំជន) សម្រាប់ស្ត្រី ៦៥ឆ្នាំ រីឯបុរស៦១.១ឆ្នាំ ចំណែកឯនៅជនបទ អាយុសង្ឃឹមរស់របស់ស្ត្រី ៦០.៨ឆ្នាំ បុរស៥៦ឆ្នាំ (២០០១-២០០៦)។ បើធ្វើការប្រៀបធៀប លទ្ធផលក្នុងឆ្នាំ១៩៩៨ ដែលជំរឿនចាប់ផ្តើមបង្ហាញទិន្នន័យនេះ អាយុសង្ឃឹមរស់របស់ប្រជាជនកម្ពុជាមានការកើនឡើង។

## ៣.២. កត្តាដែលមានឥទ្ធិពលលើ អាយុសង្ឃឹមរស់របស់ប្រជាជនកម្ពុជា

ដោយសារប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ ទើបអាយុសង្ឃឹមរស់របស់ប្រជាជនមានកម្រិតទាបនៅឡើយក្នុង នោះប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ មានអាយុសង្ឃឹមរស់ខ្ពស់ជាងយើង។ សង្គ្រាមបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាធ្លាក់ស្ទើរដល់ចំណុចសូន្យ(១៩៧០-១៩៧៩)។ ថវិការបស់ប្រទេស សម្រាប់ការអភិវឌ្ឍមួយចំនួនជាជំនួយឥតសំណង និងមានសំណងពីបរទេស។ លុះដល់ឆ្នាំ១៩៩៩ ទើបប្រទេសយើងបានជួបសន្តិភាពពេញបរិបូរណ៍ ហើយគម្រោងអភិវឌ្ឍមួយ ចំនួនងាកទៅរកតំបន់ជនបទដាច់ស្រយាល។ ទោះបីជាប្រទេសយើងប្រកាន់ ខ្ជាប់នូវគោលការណ៍អភិវឌ្ឍប្រទេសឡើងវិញ ក៏ការរីកចម្រើនមិនទាន់បានប្រសើរនៅឡើយ ជាពិសេសមានបញ្ហាចោទខ្លាំងទៅលើអាយុសង្ឃឹមរស់របស់ប្រជាជន ដែលមានកម្រិតទាបនៅឡើយ។ កត្តាសេដ្ឋកិច្ច និងសង្គមកិច្ច ដែលអាចបង្ហាញឱ្យឃើញនូវបញ្ហាទាំងឡាយ ដែលធ្វើឱ្យអាយុសង្ឃឹមរស់របស់ប្រជាជនទាប។

### ក.សេដ្ឋកិច្ច

- **កម្រិតជីវភាពរបស់ប្រជាជន**

គេប៉ាន់ស្មានថា ផលិតផលស្បៀងអាហារសរុប ក្នុងមនុស្សម្នាក់នៅកម្ពុជា មានកម្រិតប្រហែលជា២៦០ដុល្លារ/ឆ្នាំ(២០០០) គឺប្រហែលជា ៣០%ទាបជាងខ្សែបន្ទាត់នៃភាពក្រីក្រ (ចំណូលក្នុងមនុស្សម្នាក់ ១ដុល្លា/ថ្ងៃ ឬ៣៦៥ដុល្លាឆ្នាំ គឺជាបន្ទាត់តាមនិយមន័យរបស់ធានាគារពិភពលោក)។ តាមតួលេខរបស់

រាជរដ្ឋាភិបាល អត្រាក្រីក្រធៀបនឹងប្រជាជនសរុប បានថយចុះបន្តិចគឺពី ៣៩% (១៩៩៤) មកត្រឹម ៣៦% (១៩៩៩)។ ប៉ុន្តែដោយចំនួនប្រជាជនសរុបកើនឡើងយ៉ាងលឿនក្នុងរយៈពេលនេះ ចំនួនអ្នកក្រីក្រនៅកម្ពុជា បានកើនឡើងប្រហែលជាកន្លះលាននាក់ គឺពី៣.៨លាននាក់ (១៩៩៤) ទៅដល់៤.៣លាននាក់(១៩៩៩)។ លើសពីនេះទៅទៀតការធ្វើអង្កេតពីសេដ្ឋកិច្ច សង្គមកិច្ច និងការ វាយតម្លៃភាពក្រីក្រ ដែលរដ្ឋាភិបាលបានធ្វើជាបន្តបន្ទាប់ បានបង្ហាញឱ្យឃើញថា អត្រាភាពក្រីក្រនៅតាមជនបទមានកម្រិតខ្ពស់ជាងតំបន់ទីប្រជុំជន។

- **ប្រាក់ចំណូលគ្រួសារ**

ប្រាក់ចំណូលគ្រួសារកម្ពុជានៅមានកម្រិតទាបខ្លាំងណាស់ ជាពិសេសនៅក្នុងតំបន់ជនបទ។ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចនានាបានបង្ហាញថា ប្រាក់ចំណូលរបស់ប្រជាជនកម្ពុជា បានកើនឡើងក្នុងចន្លោះឆ្នាំ ១៩៩៤-១៩៩៩។ នៅទីក្រុងភ្នំពេញ គ្រួសារជាមធ្យមអាចរកប្រាក់ ចំណូលបាន ២៩២ ដុល្លាក្នុង១ខែ ក្នុងឆ្នាំ១៩៩៩ (កើន២១៤ដុល្លាឆ្នាំ១៩៩៤) ប៉ុន្តែនៅជនបទ ចំណូលប្រចាំខែបានត្រឹមតែ ៨២ដុល្លា ក្នុងឆ្នាំ ១៩៩៩ (កើន៥២ដុល្លា ក្នុងឆ្នាំ១៩៩៤)។ លើសពីនេះទៅទៀតតាមរបាយការណ៍ ប្រាក់ចំណូល**ឆ្នាំ១៩៩៩** នៅតាមតំបន់ជនបទមានប្រជាជនមិនដល់៥%ទេ ដែលមាន**ប្រាក់ចំណូល លើសពី១ដុល្លា ក្នុង១ថ្ងៃ**។ ប៉ុន្តែប្រជាជននៅភ្នំពេញប្រហែលជា៧០% មានចំណូលលើសពីបន្ទាត់ នៃភាពក្រីក្ររបស់ធានាគារពិភពលោក។ គម្លាតជាមធ្យម រវាងប្រាក់ចំណូលនៅក្រុងភ្នំពេញ និងប្រាក់ ចំណូលនៅតាមជនបទបានថយចុះបន្តិចក្នុងឆ្នាំ ១៩៩៩។ ក្នុងឆ្នាំ១៩៩៩ គ្រួសារនានានៅក្រុងភ្នំពេញ រកចំណូលបានជាមធ្យម ៣.៦ដង លើសពីគ្រួសារនៅជនបទ ឯកាលពីឆ្នាំ១៩៩៤ បានលើសដល់ ទៅ៤ដង។ ផ្អែកលើគណនេយ្យជាតិ គេបានប៉ាន់ថា ប្រាក់ចំណូលមធ្យមក្នុង១គ្រួសារ (មានសមាជិក៥នាក់) គណនាឡើងគ្រប់វិជ្ជាជីវៈ គឺមានទំហំប្រហែល ១០០ ដុល្លាក្នុង១ខែ ក្នុងឆ្នាំ២០០០ ដែលជា ការថយចុះ បើប្រៀបធៀបនឹងប្រាក់ចំណូលក្នុងឆ្នាំ១៩៩៦(១១៤ ដុល្លា) តែវាបានកើនឡើងបើប្រៀប ធៀបនឹងប្រាក់ចំណូលក្នុងឆ្នាំ១៩៩៣ (៨០ដុល្លា)។ ការប្រយុទ្ធគ្នាក្នុងខែកក្កដា ១៩៩៧ និងវិបត្តិហិរញ្ញវត្ថុនៅអាស៊ី គឺជាមូលហេតុចំបងនៃការថយចុះប្រាក់ចំណូលក្នុងរយៈពេល ៤ឆ្នាំចុងក្រោយ។ អង្កេតប្រចាំត្រីមាស ដែលក្រុមអ្នកស្រាវជ្រាវនៃវិទ្យាស្ថានបណ្តុះបណ្តាលស្រាវជ្រាវនិងអភិវឌ្ឍបានធ្វើ ជាទៀងទាត់ក្នុងផ្សារធំៗទាំង៥នៅក្រុងភ្នំពេញ បានបញ្ជាក់គាំទ្រនិន្នាការនេះ និងបានបង្ហាញថាចំណាយប្រើប្រាស់ក្នុងឆ្នាំ១៩៩៩ បានងើបឡើងវិញបន្តិចធៀបនឹងឆ្នាំ១៩៩៨ ប៉ុន្តែនៅក្នុងកម្រិតចំណាយមុនខែកក្កដា ១៩៩៧ដដែល។ កំណើនបន្តិចនេះអាចឆ្លុះបញ្ចាំងពីការកែលំអរ គួរឱ្យកត់សម្គាល់ស្ថេរភាពនយោបាយ និងបរិស្ថានធ្វើអាជីវកម្មល្អជាងមុន។ ប៉ុន្តែការប្រើប្រាស់តាមខេត្តនានា នៅតែខ្សោយដដែល គឺវាឆ្លុះបញ្ចាំងពីតម្រូវការទាបរបស់កសិករទាំងឡាយ ដែលមានសមត្ថភាពរកប្រាក់ចំណូលខ្សោយ។ លើសពីនេះទៀតការងើបឡើងនៃសេដ្ឋកិច្ចយឺតៗនៅតាមជនបទ ក៏បានរួម ចំណែកដល់ការចំណាយកម្រិតទាប នៅតាមខេត្តដែរ។ មួយចំណែកទៀត ការអង្កេតពលករ ងាយរង គ្រោះក្នុងក្រុងភ្នំពេញ បានបង្ហាញថាក្នុងឆ្នាំ២០០០ ពលករប្រភេទនេះនៅតែរកប្រាក់ចំណូល បានជាង កម្រិតមុន ខែកក្កដា ១៩៩៧នៅឡើយ។

ភាគច្រើនការងារបុរសមានចំនួនច្រើនជាងស្ត្រីគឺស្ថិតក្នុងការងារកសិកម្ម មានការនេសាទ រុក្ខាប្រមាញ់ ថាមពលទឹក ហ្គាស រ៉ែ សំណង់ រដ្ឋាភិបាល សាធារណៈ ការការពារ អប់រំ សុខាភិបាល ការងារសង្គមឧស្សាហកម្ម។ ប្រភេទការងារនេះ ត្រូវរកកម្លាំងបុរសជាចាំបាច់ទាំង កម្លាំងកាយ និង បញ្ញា ព្រោះបុរសមានកម្លាំងរឹងមាំ

ដែលអាចទ្រាំទ្រការងារធ្ងន់ៗទាំងនោះបាន។ ចំពោះស្ត្រីវិញ មានសកម្មភាពចូលរួមច្រើនក្នុងការងារផលិតកម្ម ពាណិជ្ជកម្ម លក់ដុំ និងលក់រាយ សណ្ឋាគារ ភោជនីយដ្ឋាន ហិរញ្ញវត្ថុ លក់ ដូរអចលនទ្រព្យ និងសកម្មភាព អាជីវកម្មផ្សេងៗ។ ការងារទាំងនេះ ជាប្រភេទ ការងារមធ្យម ស្រាល ដែលប្រើប្រាស់បញ្ញាស្មារតី និងរូប សម្ផស្ស ហើយស្ត្រីមានភាពសក្តិសមបំផុត។ ការងារដែលបុរសធ្វើភាគច្រើន ប្រឈមមុខនឹងគ្រោះថ្នាក់បំផុត ដែលធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយ ស្មារតី និងបណ្តាលឱ្យសុខភាពទ្រុឌទ្រោមចុះខ្សោយ ងាយទទួលរងនូវ ការឃាយីពីជំងឺផ្សេងៗ ដែលអាចធ្វើឱ្យបុរសមានអាយុសង្ឃឹមរស់ទាបជាងស្ត្រី។

## សំណួរត្រិះរិះ

១. ហេតុអ្វីបានជាអាយុសង្ឃឹមរស់របស់ស្ត្រីខ្ពស់ជាងបុរស?

២. ចូរប្រៀបធៀបអាយុសង្ឃឹមរស់រវាងប្រជាជនប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍ ។

# ជំពូកទី៨៖ សមុទ្រ និងមហាសមុទ្រ
## មេរៀនទី១៖ សមុទ្រ និង មហាសមុទ្រ

បើយើងមើលពីលំហខាងក្រៅ ផែនដី គឺជាភពដ៏ស្រស់ស្អាតដែលពោរពេញទៅដោយសមុទ្រពណ៌ខៀវព្រៃពណ៌បៃតង វាលលំហពណ៌ក្រហម និងពពកពណ៌ស ហើយជាដុំសិលារឹងដែលមានការប្រែប្រួលផ្ទៃលើនិងបរិយាកា ដោយឆ្លងកាត់អស់ រយៈពេលរាប់រយលានឆ្នាំ។

ផែនដី ជាភពទី៣ក្នុងប្រព័ន្ធព្រះអាទិត្យ មានសារៈសំខាន់ណាស់សម្រាប់យើងទាំងអស់គ្នា និង ជាភពដ៏ល្អពិសេសបំផុត។ ទេសភាពរបស់ភពផែនដីមានលក្ខណៈដោយឡែកពីគ្នាហើយប្រហែល៧០%នៃផែនដីគ្របដណ្តប់ទៅដោយសមុទ្រ និង មហាសមុទ្រ។ ភពផែនដីជាភពតែមួយគត់ដែលមានភាវៈរស់មាន ជីវិតរស់នៅ ទោះជាយ៉ាងណាក៏ដោយលក្ខណៈពិសេសបច្ចុប្បន្នរបស់ផែនដី មិនដូចទៅនឹងផែនដីដែលកកើតដំបូងនោះឡើយ។ បច្ចុប្បន្ន មានភស្តុតាងជាច្រើនបានបង្ហាញថាភពផែនដីបានកើតឡើងតាំងពី៤៦០០លានឆ្នាំមុន។ សព្វថ្ងៃ គេប្រទះឃើញសិលាដែលចាស់បំផុតនៅលើផែនដី គឺជាប្រភេទសិលាក្រានីតនៅភាគខាងលិចឆៀងខាងជើងប្រទេសកាណាដា។ ធរណីវិទូបានប៉ាន់ស្មានថា សិលាចាប់កំណើតមានអាយុប្រហែល៤០០៣លានឆ្នាំមុន ការប៉ាន់ស្មានអាយុកាលដោយផ្អែកលើការវិភាគនៃវិទ្យុសកម្ម។

### ១. កំណកំណើតភពផែនដី

អ្នកវិទ្យាសាស្ត្រ បានសិក្សាយ៉ាងយកចិត្តទុកដាក់អំពីអាចម៍ផ្កាយ ដើម្បីដឹងពីប្រវត្តិភពផែនដី និង ភពនានាក្នុងប្រព័ន្ធព្រះអាទិត្យ។ សព្វថ្ងៃ អ្នកដឹងទេថាអាចម៍ផ្កាយនៅតែបន្តធ្លាក់ជាហូរហែរ ប៉ុន្តែវាមិនបង្កឱ្យមានគ្រោះមហន្តរាយអ្វីឡើយ។ ពួកអ្នកវិទ្យាសាស្ត្របានប្រមូលអាចម៍ផ្កាយជាច្រើន ដើម្បីស្រាវជ្រាវពីអាយុកាលរបស់វា។ អ្នកដឹងទេថា ហេតុអ្វីបានជាអាចម៍ផ្កាយមានសារៈសំខាន់ចំពោះការដឹងពីប្រវត្តភពផែនដី? ដោយសារអាចម៍ផ្កាយ ភាគច្រើនកើតឡើងក្នុងលក្ខណៈដូចគ្នានៃភពផ្សេងៗនិងភពផែនដី នៅពេលប្រព័ន្ធព្រះអាទិត្យកើតឡើងដំបូង។ អ្នកវិទ្យាសាស្ត្រគិតថា ផែនដីកើតឡើងពីដុំធូលី សិលា និង ទឹកកកក្នុងលំហ។ ទំនាញផែនដីបានទាញដុំទាំងនោះឱ្យមកផ្តុំនៅជាមួយខ្លួនវា ដើម្បីឱ្យមានទំហំកាន់តែធំ និងហាប់ណែនមានកម្លាំងទំនាញកាន់តែខ្លាំង ហើយទាញអង្គផ្សេងៗទៀតឱ្យធ្លាក់មករកវា ហើយការប៉ះទង្គិចកាន់តែខ្លាំង និងចលនាកាន់តែលឿន។ ចលនារបស់ផែនដីមានល្បឿនលឿន ហើយដោយសារមានការប៉ះទង្គិចជាមួយវត្ថុផ្សេងទៀតក្នុងលំហ ធ្វើឱ្យកើនកម្រៅរហូតដល់រលាយទៅជាម៉ាក់ម៉ា។ សីតុណ្ហភាពនៅលើភពផែនដីកាលពីដំបូង ធ្វើឱ្យដែកដែលជារូបជាតុធ្ងន់សម្បូរជាងគេអាចរលាយបាន កម្លាំងទំនាញ បានទាញដែកដែលរលាយឱ្យធ្លាក់ទៅកាន់ផ្នែកខាងក្នុងបង្អស់របស់ផែនដី ហើយរូបធាតុដែលរលាយដែលស្រាលជាងអណ្តែតមកកាន់ស្រទាប់ខាងក្រៅ នៅទីបំផុតផែនដីបានកកើតឡើងជា៣ស្រទាប់ ដោយផ្នែកខាងក្នុងបង្អស់គឺជាស្នូលដែលហាប់ណែនមាន ដែក និងនីកែលនៅជុំវិញស្នូលគឺជាស្រទាប់សិលាដ៏ក្រាស់។

មានសភាពរាវហើយខាប់ហៅថា ម៉ង់តូ និងស្រទាប់ក្រៅគេបំផុត គឺជាសំបកផែនដីដែលមានរូបធាតុរឹងហើយស្រាល បានចុះត្រជាក់ហៅថា សំបកផែនដី។ សិលាមិនកើតក្នុងពេលដំណាលគ្នានឹងផែនដីឡើយ

ដូច្នេះផែនដីកើតឡើងដំបូង គ្របដណ្តប់ដោយ ម៉ាក់ម៉ា ហើយវត្ថុដែលធ្ងន់លិចទៅផ្នែកកណ្តាលបង្កើតបាន ជាស្នូលដែករឹង និង ផ្នែកខាងក្រៅចុះត្រជាក់បង្កើតបានជាសំបកផែនដី។

សម្មតិកម្មរបស់អ្នកវិទ្យាសាស្ត្រគឺផែនដី ភពដ៏ទៃទៀត និងព្រះអាទិត្យកើតឡើងក្នុងពេលដំណាលគ្នា ជាមួយនឹងអាចម៍ផ្កាយដែលមានអាយុកាលប្រហែល៤៦០០លានឆ្នាំមុនមកម្លេះ។ ការសន្និដ្ឋាននេះគឺផ្អែកលើ ការប្រមូលសិលាជាច្រើនដែលកើតពីអាចម៍ផ្កាយតាំងពី៤៦០០លានឆ្នាំមុន មកដល់ ៤៥០០លានឆ្នាំមុន។

តាមរយៈប្រវត្តិដ៏យូរលង់របស់ភពផែនដីដី ផ្ទៃរបស់វាធ្លាប់បានពើងឡើង ស្រុតចុះ ពត់ពែន និងបាក់ បែក ដូច្នេះផែនដីពេលបច្ចុប្បន្នខុសពីផែនដីកាលពីរាប់រយលានឆ្នាំមុន។ បន្ទុះភ្នំភ្លើងបានធ្វើឱ្យមនុស្សឆ្ងល់ថា មានអ្វីខ្លះស្ថិតនៅក្នុងផែនដី ធរណីវិទូចង់ឆ្លើយសំណួរនេះ ប៉ុន្តែពួកគេមិនអាចជីករូងចូលទៅកាន់ផ្ចិតផែនដី បានឡើយ។ អណ្តូងរ៉ែដែលជ្រៅជាងគេនៅលើពិភពលោក គឺអណ្តូងរ៉ែមាសស្ថិតនៅអាព្រិចខាងត្បូងមាន ជម្រៅ ៣៨០០ម៉ែត្រ នៅមានជម្រៅ ១៦០០ដង នៃអណ្តូងរ៉ែមាសនេះ ទើបអាចដល់ផ្ចិតផែនដី។

## ១.១. បរិយាកាសអតីតកាលនិងបច្ចុប្បន្នកាល

### ក. បរិយាកាសអតីតកាល

ទំនាញរបស់ផែនដីបានទាញយកឧស្ម័ន២ប្រភេទ ដើម្បីបង្កើតបរិយាកាសដំបូងរបស់ខ្លួន មានដូចជា ឧស្ម័នមេតាន និងអាម៉ូញ៉ាក់ក្នុងដំណើរវិលជុំវិញព្រះអាទិត្យ។ ក្រោយមក កាំរស្មីព្រះអាទិត្យបានបំបែកភាគ ល្អិតនៃសមាសធាតុបរិយាកាសដំបូងឱ្យចាកចេញផុតទៅ មូលហេតុនៃការចាកចេញនៃឧស្ម័នទាំងពីរគឺបណ្តាល មកពីផែនដីមានម៉ាសតូច និង ទំនាញខ្សោយ។ បន្ទាប់ពីការបាត់បង់បរិយាកាសដំបូង បរិយាកាសបន្ទាប់ក៏ ចាប់ផ្តើមកើតឡើងកាលពីប្រហែល៣០០០លានឆ្នាំមុន។ ទំនាក់ទំនងបរិយាកាសបន្ទាប់ជាមួយនឹងបន្ទុះភ្នំភ្លើង ដែលបានបញ្ចេញឧស្ម័នដ៏ច្រើនដូចជា កាបូនឌីអុកស៊ីត អាសូត និងចំហាយទឹក។ យោងតាមការពិនិត្យ អ្នកវិទ្យាសាស្ត្របានចាត់ទុកថាបរិយាកាសបន្ទាប់ មានឧស្ម័នស្រដៀងគ្នានឹងបរិយាកាសបច្ចុប្បន្នដែរ។ ដូច្នេះ បន្ទុះភ្នំភ្លើងបានបន្ថែមឧស្ម័នជាច្រើនទៅក្នុងបរិយាកាស ដុំធូលី និង ទឹកកកក្នុងលំហនៃផ្កាយដុះកន្ទុយធ្វើដំណើរ ជុំវិញព្រះអាទិត្យ។ ដុំទឹកកកក្នុងលំហនៅក្នុងផ្កាយដុះកន្ទុយ មានទឹក កាបូនឌីអុកស៊ីត និងកំណកឧស្ម័ន។

### ខ.បរិយាកាសបច្ចុប្បន្ន

បរិយាកាសបច្ចុប្បន្នមានសមាសធាតុផ្សំដូចជា អាសូតប្រហែល៧៨% អុកស៊ីសែន២១% និង ១% ឧស្ម័នផ្សេងៗដ៏ទៃទៀត ដូចជាឧស្ម័នកាបូនិច ចំហាយទឹក អាកុង ណេអុង សេណុង គ្រីបតុង អេល្យូម មេតាន អ៊ីដ្រូសែន អូសូន ក្នុងនោះក៏មានកាបូនឌីអុកស៊ីត ០.០៣% ផងដែរ។ កាលពីកំណាកំណើតភពផែនដីដំបូង សកម្មភាពភ្នំភ្លើងបានបញ្ចេញនូវបរិមាណឧស្ម័នដ៏ច្រើន ប្រហែលមកពីពន្លឺព្រះអាទិត្យបណ្តាលឱ្យអាម៉ូញ៉ាក់ និងចំហាយទឹកខ្លះក្នុងបរិយាកាសប្រែក្លាយទៅជា អាសូត អ៊ីដ្រូសែន និងអុកស៊ីសែនបន្តិចបន្តួច។ អ៊ីដ្រូសែន ភាគច្រើនបានភាយទៅក្នុងលំហបន្តិចម្តងៗដោយសារកំលាំងទំនាញផែនដីមិនអាចចាប់ឧស្ម័នស្រាលនេះបាន។ ប្រហែលជា២០០៧លានឆ្នាំមុន ជីវិតរុក្ខជាតិប្លង់តុង ស៊ីស្យាណូបាក់តេរី បានលេចឡើង។ ជីវិតទាំងពីរនេះ បានប្រើប្រាស់ឧស្ម័នកាបូនិចដើម្បី ផលិតអាហារ និងចាប់ផ្តើមផលិតឧស្ម័នអុកស៊ីសែន តាមរយៈការធ្វើរស្មីសំយោគទៅក្នុងបរិយាកាសយ៉ាងយឺតៗ បន្តិចម្តងៗកាន់តែកើនឡើងរហូតដល់កម្រិតបច្ចុប្បន្ន។ អុកស៊ីសែន ខ្លះបង្កើតបានជាអូសូន ម៉ូលេគុលអូសូន១កើតឡើងពីអាតូមអុកស៊ីសែន៣ភ្ជាប់គ្នាបានប្រមូលផ្តុំគ្នាជាស្រទាប់

ក្នុងបរិយាកាសជាន់ខ្ពស់។ អូសូនក្នុងបរិយាកាសស្ទើរតែ ទាំងអស់គឺស្ថិតនៅក្នុងមណ្ឌលអាកាសស្ងប់។ នៅពេល អូសូនស្រូបយកថាមពលពីព្រះអាទិត្យ ថាមពលបាន បំលែងទៅជាកម្ដៅហើយធ្វើឱ្យខ្យល់ក្ដៅ ។

**ស្រទាប់អូសូនមានអត្ថប្រយោជន៍** ជួយការពារជីវិតភាវៈទាំងអស់នៅលើផែនដី និងទប់ស្កាត់រលកកាំរស្មីស្វាយអ៊ុលត្រាដែលបញ្ចេញពីព្រះអាទិត្យ គឺជួយកាត់បន្ថយការបញ្ចេញថាមពលរបស់វាមកត្រឹមផ្ទៃលើទឹកសមុទ្រប៉ុណ្ណោះ។ ដូច្នេះភាវៈរស់ស្វ័យជីព បានធ្វើរស្មីសំយោគ ដើម្បីឱ្យពួកវាអាចរស់នៅផ្ទៃលើនៃសមុទ្របាន និងប្រើថាមពលកាំរស្មីព្រះអាទិត្យក្នុងការធ្វើឱ្យលូតលាស់ ព្រមទាំងបង្កើនការផលិតអុកស៊ីសែនយ៉ាងច្រើនក្នុងបរិយាកាស តាំងពីកកើតបរិយាកាសទី២ មកដល់ស័កប៉ាលេអូសូអ៊ិច ដែលមានបរិមាណអុកស៊ីសែនឡើងដល់ ១/១០ ស្មើនឹង ១០% នៃបរិយាកាសបច្ចុប្បន្ន។ នៅចុងស័កប៉ាលេអូសូអ៊ិច បរិមាណឧស្ម័នអុកស៊ីសែនឈានឡើងដល់កម្រិតស្មើនឹងបរិមាណឧស្ម័នអុកស៊ីសែនសព្វថ្ងៃ។ ក្រោយមក កាបូនឌីអុកស៊ីតក្នុបរិយាកាសបានថយចុះនៅពេលភាវៈមានជីវិតធ្វើរស្មីសំយោគដើម្បីបង្កើនការផលិតអុកស៊ីសែននៅក្នុងបរិយាកាសបច្ចុប្បន្ន។

កាបូនឌីអុកស៊ីតមិនបានបាត់បង់ពីបរិយាកាសផែនដីឡើយ ប៉ុន្តែវាបានបាត់បង់ក្នុងបរិយាកាស។ នៅពេលដែលផែនដីចុះត្រជាក់ចំហាយទឹកចាប់ផ្ដើមក្លាយជាកំណកអាកាស រួចបង្កើតបានជាភ្លៀង។ ទឹកភ្លៀងប្រមូលផ្ដុំជាច្រើនបង្កើតបានជាសមុទ្រ ទឹកភ្លៀងបានរំលាយសិលានៅផ្ទៃផែនដីផងដែរ។ ដោយសារបរិយាកាសមានផ្ទុកកាបូនឌីអុកស៊ីត ដូច្នេះសារធាតុកាបូនឌីអុកស៊ីតដែលមាននៅក្នុងទឹកភ្លៀងក៏ហូរចូលក្នុងសមុទ្រ។ ដោយឆ្លងកាត់រយៈពេលយូរ កាបូនឌីអុកស៊ីត ប្រែក្លាយទៅជាថ្មកំបោរ ដែលមានទម្រង់ដូចកាល់ស្យូមកាបូណាត កាបូនខ្លះបានក្លាយទៅជាផូស៊ីលឥន្ធនៈ។ សព្វថ្ងៃ នៅពេលអ្នកប្រើផូស៊ីលឥន្ធនៈ កាបូនដែលផ្ទុកក្នុងប្រេងក្នុងកំឡុងរយៈពេលយូរនោះ បានប្រែក្លាយទៅជាកាបូនម្ដងទៀតក្នុងបរិយាកាសបច្ចុប្បន្ន។

**គ.កំណកំណើតមហាសមុទ្រ និងសមុទ្រ**

នៅពេលដែលបរិយាកាសផែនដីកំពុងមានការវិវត្តន៍ ស្របពេលផែនដីបានចុះត្រជាក់ល្មមធ្វើឱ្យទឹកកកកើតឡើង នៅរវាងប្រហែល ២០០០ ទៅ ៣៥០០លានឆ្នាំមុន ចំហាយទឹកបានចាប់ផ្ដើមកជាកំណកអាកាស ហើយធ្លាក់មកផែនដីក្នុងទម្រង់ជាទឹកភ្លៀង ហើយបង្កើតបានជាសមុទ្រ និង មហាសមុទ្រ។ ទឹកសមុទ្របានស្រូបយកបរិមាណឧស្ម័នកាបូនិចយ៉ាងច្រើនពីបរិយាកាស។ មកដល់១៥០០លានឆ្នាំមុន សមាសភាពគីមីរបស់បរិយាកាសមានលក្ខណៈស្រដៀងគ្នានឹងសមាសភាពបរិយាកាសបច្ចុប្បន្ន។

## ២. វដ្តទឹក និងទឹកលើផែនដី

ទឹកនៅលើភពផែនដីកកើតឡើងវិញដោយធម្មជាតិតាមរយៈវដ្តទឹក។ វដ្តទឹកគឺជាចលនាឥតឈប់ឈរនៃទឹកពីប្រភពទឹកដូចជា បឹង ទន្លេ ស្ទឹង អូរ សមុទ្រ មហាសមុទ្រ ទឹកលើដី និង ប្រភពទឹកក្នុងដីទៅក្នុងមណ្ឌលអាកាសតាមរយៈរំហួតចំហាយទឹកបង្កើតបានជាកំណកអាកាស រួចក៏ធ្លាក់ត្រឡប់ប្រភពដើមវិញ។ វដ្តទឹកមាន៣ដំណាក់កាល គឺ រំហួត កំណក និងកំណកអាកាស។

### ២.១. វដ្តទឹក

**ក. ដំណាក់កាលរំហួត**

ដំណើររំហួតនៃទឹកគឺទឹកការប្រែក្លាយទៅជាឧស្ម័នហៅថា ចំហាយទឹក។ ទឹកហូរចេញពីប្រភពទន្លេ បឹង មហាសមុទ្រ សមុទ្រ... ។ រុក្ខជាតិក៏មានតួនាទីក្នុងដំណើរការរំហួតនេះផងដែរ ព្រោះវាបានទាញយកទឹកពីក្នុង

ដីតាមរយៈឫស ហើយបញ្ចេញមកវិញតាមរយៈស្លឹកក្នុងទម្រង់ជាចំហាយទឹកចូលទៅក្នុងមណ្ឌលបរិយាកាស។

**ខ. ដំណើរការកំណក**

ចរន្តខ្យល់ក្តៅបាននាំយកចំហាយទឹកស្ទុះឡើងលើដល់រយៈកម្ពស់ខ្ពស់ដែលមានសីតុណ្ហភាពត្រជាក់ ហើយខ្យល់ត្រជាក់ពុំអាចផ្ទុកចំហាយទឹកបានច្រើនដូចខ្យល់ក្តៅ ជាលទ្ធផលចំហាយទឹកចុះត្រជាក ក៏ប្តូរទៅជាដំណក់ទឹកដែលជាកំណកបានប្រមូលផ្តុំគ្នាជុំវិញភាគល្អិតនៃធូលីតូចៗ ឬផ្សេងដែលមានតួនាទីស្នូល ហើយបង្កើតបានជាពពកនៅក្នុងមណ្ឌលបរិយាកាស។

**គ. ដំណើរការកំណកអាកាស**

នៅពេលដែលចំហាយទឹក កកជាកំណកកាន់តែច្រើន មាឌតំណក់ទឹកនៅក្នុងពពកក៏កាន់តែរីកធំហើយ ចរន្តខ្យល់បានធ្វើឱ្យពពកផ្លាស់ទី នៅដំណាក់កាលចុងក្រោយ តំណក់ទឹកដែលជាកំណកធ្ងន់ក៏ធ្លាក់មកលើភពផែនដីវិញក្នុងទម្រង់ជាកំណកអាកាសដែលក្នុងនោះរួមមាន ក្រោមទម្រង់ជាភ្លៀង ជាភ្លៀងព្រិល ជាព្រិល និង ទឹកកកសំឡី ហើយភាគច្រើនធ្លាក់ចូលទៅក្នុងមហាសមុទ្រ និងសមុទ្រហើយកំណកអាកាសមួយចំនួនត្រូវស្រូបចូលទៅក្នុងដី ក្លាយទៅជាទឹកក្នុងដី។

**២.២. របាយទឹកលើភពផែនដី**

សាគរវិទូបានប៉ានស្មានថា មហាសមុទ្រ និង សមុទ្រមានវិសាលភាពធំធេងណាស់ ស្មើនឹង៧០% រីឯផ្ទៃដីវិញមានត្រឹមតែ៣០%ប៉ុណ្ណោះ។ ភាគច្រើនទឹកលើផ្ទៃដីជាទឹកប្រៃ ស្ថិតនៅក្នុងមហាសមុទ្រ និងសមុទ្រ មានរហូតដល់៩៧%ហើយទឹកសាបមានតែ៣% ក្នុងនោះ៣/៤ ជាផ្ទាំងទឹកកកដ៏ធំដែលនៅជិតប៉ូលខាងជើង និង ប៉ូល ខាងត្បូង និង ១/៤នៃទឹកសាបប៉ុន្តែជាទឹកក្នុងដី។

រវាងអឌ្ឍគោលទាំងពីររបាយផ្ទៃដី និងមហាសមុទ្រមិនស្មើគ្នាទេ។ នៅអឌ្ឍគោលខាងជើង ផ្ទៃទឹកសមុទ្រមាន៦២% ផ្ទៃដីមាន៣៨% ចំណែកនៅអឌ្ឍគោលខាងត្បូង ផ្ទៃទឹកសមុទ្រមាន៨៤% រីឯផ្ទៃដី មាន១៦%។

**ក. ទឹកមហាសមុទ្រ**

មហាសមុទ្រ ជាទឹកប្រៃយ៉ាងសំបើមបានគ្របដណ្តប់ផ្ទៃយ៉ាងធំធេងនៃផែនដី។ ទឹកសមុទ្រទាំងអស់ចែកជាសមុទ្រ និងមហាសមុទ្រ។ មហាសមុទ្រទាំងអស់មាន៤គឺ មហាសមុទ្រប៉ាស៊ីភិច មហាសមុទ្រអាត្លង់ទិច មហាសមុទ្រឥណ្ឌា និងមហាសមុទ្រទឹកកកអាកទិច។ សមុទ្រសំខាន់ៗមាន សមុទ្រមេឌីទែរ៉ានេ សមុទ្រចិន សមុទ្រឧត្តរ សមុទ្រការ៉ាអ៊ីប សមុទ្រម៉ង់ សមុទ្រក្រហម សមុទ្របាល់ទិច...។ ភាគច្រើននៃទឹកសាបលើភពផែនដីគឺស្ថិតនៅក្រោមទម្រង់ជាផ្ទាំងទឹកកកដ៏ក្រាស់ ដែលគ្របដណ្តប់លើផ្ទៃទ្វីបអង់តាកទិច ជិតប៉ូលខាងត្បូង និងតំបន់គ្រីនលែន ជិតប៉ូលខាងជើង។ ដុំ និងផ្ទាំងទឹកកកធំៗដែលអណ្តែតភាគច្រើនតែងតែប្រេះបែកចេញពីផ្ទាំងទឹកកក ហើយអណ្តែតនិងរលាយយឺតៗរួចហូរឆ្ពោះទៅតំបន់ទឹកដែលក្តៅ។

**ខ. ទឹកសាប**

ទឹកសាបដែលគេរកឃើញនៅក្នុងទន្លេ បឹង ស្ទឹង អូរ ជាប្រភពដ៏សំខាន់សម្រាប់មនុស្ស សត្វ និង រុក្ខជាតិ ប៉ុន្តែវាមានតិចតួចបំផុតប្រើប្រៀបធៀបទៅនឹងទឹកសាបលើភពផែនដីយើងនេះ។ ទឹកក្រោមដីជាទឹកដែលជ្រាប ឬ ហូរចូលទៅបំពេញក្រហែង ប្រហោង និង ស្រទាប់សិលា។ នៅពេលដែលមានភ្លៀង ឬព្រិលធ្លាក់ ទឹកខ្លះបានជ្រាបចូលទៅក្នុងដី ទឹកនេះក៏ហូរឆ្លងកាត់ផ្នែកចំហរវាងភាគល្អិត និងសិលាហើយទីបំផុតទឹកក៏បាន

ទៅដល់ស្រទាប់សិលាដែលមិនអាចឆ្លងកាត់បានតទៅទៀត។ ទឹកក្រោមដីមានបរិមាណច្រើនជាងទឹកបឹង ទន្លេ ស្ទឹង អូរ នៅលើភពផែនដីយើងច្រើនណាស់។

### ៣. របាយមហាសមុទ្រលើពិភពលោក

មហាសមុទ្រ ជាបឹងទឹកប្រៃដែលមានតួនាទីយ៉ាងច្រើននៅក្នុងការតម្រូវការបរិស្ថានរបស់ផែនដី ហើយក៏ជាសមាសភាពផ្សំយ៉ាងសំខាន់នៃមណ្ឌលទឹកផងដែរ។ មហាសមុទ្រ ជាធនធានសំខាន់មួយក្នុងចំណោមធនធានដ៏ទៃជាច្រើនរបស់ពិភពលោកយើង រំហួតទឹកមហាសមុទ្រជាប្រភពច្រើនបំផុតនៃកំណកអាកាស ហើយសីតុណ្ហភាពមហាសមុទ្រក៏កំណត់នូវគម្រូធាតុអាកាស និង ខ្យល់បក់ផងដែរ។ ជីវិតបានកើតឡើងក្នុងមហាសមុទ្រ ប្រហែលជាង ៣០០០លានឆ្នាំមុន មុនពេលដែលមានលេចឡើងនូវជីវិតសត្វ និង រុក្ខជាតិ នៅលើដី។ មហាសមុទ្រគឺជាជម្រកនៃប្រភេទភាវៈរស់ជាច្រើននៅគ្រប់ស្រទាប់ទឹកទាំងអស់។ សាគរវិទូបានប៉ានស្មានថា មហាសមុទ្រ និង សមុទ្រមាននវិសាលភាពធំធេងណាស់ ស្មើនឹង៧០% រីឯផ្ទៃដីវិញមានត្រឹមតែ៣០% ប៉ុណ្ណោះ។ ទឹកសមុទ្រទាំងអស់ចែកជាសមុទ្រ និងមហាសមុទ្រ។ មហាសមុទ្រ ទាំងអស់មាន៤គឺ មហាសមុទ្រប៉ាស៊ីភិច មហាសមុទ្រអាត្លង់ទិក មហា សមុទ្រឥណ្ឌា និងមហាសមុទ្រទឹកកកអាកទិក។

ប្រហែលជា៤៥០០លានឆ្នាំមុន ផែនដីមានសណ្ឋានខុសពីបច្ចុប្បន្ន គឺពុំមានមហាសមុទ្រ និងសមុទ្រទេ ភ្នំ ភ្លើងបានព្រួសកំអែ ផេះ និងឧស្ម័នពាសពេញភពទាំងមូល នៅពេលនោះភពមានសីតុណ្ហភាពក្តៅជាងបច្ចុប្បន្នខ្លាំងណាស់។ ឧស្ម័នភ្នំភ្លើង គួបផ្សំនឹងឧស្ម័នផ្សេងៗនិងចំហាយទឹកបានចាប់ផ្តើមបង្កើតបរិយាកាសផែនដីដំបូងនៅខណៈពេលបរិយាកាសបានវិវត្តន៍ ផែនដីបានចុះត្រជាក់ ប្រហែលជា៤០០០លានឆ្នាំមុន ផែនដីចុះត្រជាក់ល្មម ដែលធ្វើឱ្យចំហាយទឹកក្លាយទៅជាកំណក ហើយធ្លាក់ជាភ្លៀងមកផែនដី។ ទឹកភ្លៀងចាប់ផ្តើមចាក់បំពេញតំបន់ទាបៗ និងកំហូងនៃផ្ទៃរបស់ផែនដី ហើយមហាសមុទ្រដំបូងក៏កើតឡើង។ មហាសមុទ្របានផ្លាស់ប្តូរជាច្រើន ទៅតាមប្រវត្តិភពផែនដី។

#### ៣.១. របាយមហាសមុទ្រ

មហាសមុទ្រទាំងអស់មាន៤គឺ មហាសមុទ្រប៉ាស៊ីភិចធំជាងគេ មហាសមុទ្រអាត្លង់ទិក មហាសមុទ្រឥណ្ឌា និង មហាសមុទ្រទឹកកកអាកទិចមានទំហំតូចជាងគេ។ មហាសមុទ្រទាំងអស់ថ្វីត្បិតតែមានទីតាំងផ្សេងៗពីគ្នាក៏ដោយ ក៏គ្មានមហាសមុទ្រណាមួយនៅដាច់ឡែកពីគេឡើយ ចរន្តទឹកសមុទ្រអាចចុះឡើងពីមហាសមុទ្រមួយ ទៅមហាសមុទ្រមួយទៀត។

#### ក. មហាសមុទ្រប៉ាស៊ីភិច

ជាមហាសមុទ្រធំជាងគេ មានផ្ទៃទូលាយ មានទីតាំងស្ថិតនៅចន្លោះទ្វីបអាស៊ី ទ្វីបអាព្រិច និងទ្វីបអូស្ត្រាលី។ អេក្វាទ័រ បានបែងចែកមហាសមុទ្រនេះជា២គឺមហាសមុទ្រប៉ាស៊ីភិចខាងជើង និងមហាសមុទ្រប៉ាស៊ីភិចខាងត្បូង។ ស្នាមភ្លោះ **ម៉ារីយ៉ាន** នៅមហាសមុទ្រប៉ាស៊ីភិចខាងជើងឈៀងខាងលិចជាចំណុចជ្រៅបំផុត នៅក្នុងពិភពលោក ដែលមានជម្រៅរហូតដល់ ១០៨៨១ម៉ែត្រ។ មហាសមុទ្រប៉ាស៊ីភិចមានផ្ទៃសរុប ១៨០លាន គ.ម$^{២}$ ទទឹងត្រង់អេក្វាទ័រ ១៧០០គ.ម និង ជម្រៅជាមធ្យម ៣៩៤០ម៉ែត្រ។

#### ខ. មហាសមុទ្រអាត្លង់ទិក

មហាសមុទ្រប៉ាស៊ីភិច ជាមហាសមុទ្រធំលំដាប់លេខ២ក្នុងលោក មានរាងទ្រវែងជាអក្សរទេ មានទីតាំង

ស្ថិតនៅចន្លោះទ្វីបអឺរ៉ុប ទ្វីបអាព្រិក និងទ្វីបអាមេរិក លាតសន្ធឹងពីជើងទៅត្បូង។ មហាសមុទ្រអាត្លង់ទិចមានផ្ទៃ ១០៦លានគ.ម² និងជម្រៅមធ្យមប្រហាក់ប្រហែលមហាសមុទ្រប៉ាស៊ីភិចដែរ។ អេក្វាទ័រ បានបែងចែកមហាសមុទ្រនេះជា២គឺមហាសមុទ្រអាត្លង់ទិចខាងជើង និងមហាសមុទ្រអាត្លង់ទិចខាងត្បូង។

### គ. មហាសមុទ្រឥណ្ឌា

មហាសមុទ្រឥណ្ឌា ជាមហាសមុទ្រធំលំដាប់ទី៣ គ្របដណ្តប់ប្រហែល២០%នៃទឹកនៅលើផ្ទៃផែនដី មានទីតាំងស្ថិតនៅខាងត្បូងទ្វីបអាស៊ីក្នុងអឌ្ឍគោលខាងត្បូង ចន្លោះទ្វីបអាស៊ី ទ្វីបអាព្រិច និងទ្វីបអូស្ត្រាលី មហាសមុទ្រឥណ្ឌាមានផ្ទៃសរុប៧៥លានគ.ម² និង ជម្រៅជាមធ្យម ៣៩០០ម៉ែត្រ។

### ឃ. មហាសមុទ្រទឹកកកអាកទិក

មហាសមុទ្រទឹកកកអាកទិច ជាមហាសមុទ្រតូចជាងគេបំផុត ហើយជម្រៅក៏រាក់ជាងគេដែរ លាតសន្ធឹង លើប៉ូលខាងជើង មហាសមុទ្រនេះមានទីតាំងស្ថិតនៅជាយខាងជើងទ្វីបអឺរ៉ាស៊ី និង ទ្វីបអាមេរិក ហើយជាប់បន្ត ពីមហាសមុទ្រ មហាសមុទ្រអាត្លង់ទិច និង មហាសមុទ្រប៉ាស៊ីភិចខាងជើង ភាគច្រើនផ្ទៃ របស់វាគ្របដណ្តប់ដោយទឹកកកជាអចិន្ត្រៃយ៍ មហាសមុទ្រទឹកកកអាកទិចមានផ្ទៃសរុប១៣លានគ.ម²។

## ៤. សណ្ឋានដីបាតសមុទ្រ

ដើម្បីដឹងពីសណ្ឋានដីបាតសមុទ្រ សាគរវិទូព្យាយាមបង្កើតផែនដីបាតសមុទ្រ ដោយវិធីផ្សេងៗដោយជនជាតិបារាំង និងអង់គ្លេសក្នុងការស្រាវជ្រាវរុករកក្នុងមហាសាគរ។ នៅឆ្នាំ១៨៧២ នាវាសាឡង់ស៊ែ របស់អង់គ្លេសផ្ទុកឧបករណ៍សាមញ្ញមួយចំនួនស្ថិតនៅលើសមុទ្រអស់រយៈពេលចំនួន៣ឆ្នាំ៦ខែ។ ឧបករណ៍សាមញ្ញក្នុងការសិក្សាស្រាវជ្រាវបាតសមុទ្រគឺ បើខ្សែលួសទង់ដែង ដើម្បីស្ទង់ជម្រៅបាតសមុទ្រ ប្រើសំណាញ់ចងភ្ជាប់ខ្សែ ពួរដើម្បីប្រមូលយករុក្ខជាតិបាតសមុទ្រ ប្រើសីតុណ្ហមាត្រ(ទែម៉ូម៉ែត្រ) ដើម្បីកត់ត្រាសីតុណ្ហភាពគម្រូទឹកតាមជម្រៅ។ ប៉ុន្តែចាប់ពីស.តទី១៩មក ការសិក្សាបានដុះដាលជ្រាលជ្រៅជាងមុន ដោយតាមវិធីទំនើបជាងមុនផង។ គេបានបង្កើតនាវាមុជទឹក ដែលអាចចុះជ្រៅជាង៤០០០ម អ្នកវិទ្យាសាស្ត្រពិនិត្យផ្ទាល់សណ្ឋានដីបាតសមុទ្រដោយប្រើឧបករណ៍បញ្ចាំងពន្លឺ។ បច្ចុប្បន្ន គេស្ទង់បាតសមុទ្រដោយប្រើឧបករណ៍ទំនើបគឺប្រើសូរសំលេងពិសេស សូរអ៊ុលត្រា និងប្រើតារាវណប ការប្រមូលទិន្នន័យព័ត៌មានពីតារាវណបស៊ីសេតឆ្នាំ១៩៧៨ និងតារាវណបផ្សេងៗទៀតបាន ផ្តល់រូបភាពពេញលេញពីសណ្ឋានដីបាតសមុទ្រ។ ក្រោយពីសិក្សាស្រាវជ្រាវបានសព្វគ្រប់ ទើបគេដឹងថា សណ្ឋានដីបាតសមុទ្រមិនមានអ្វីខុសប្លែកខ្លាំងពីសណ្ឋានដីនៅលើទ្វីបនោះទេ។ គេប្រទះឃើញវាលទំនាប ខ្ពង់រាប ភ្នំ ប្រជុំភ្នំ ជួរភ្នំ ជ្រោះជ្រៅ ជ្រលងទន្លេ ភ្នំភ្លើងរស់ ភ្នំភ្លើងងាប់ បាតុភូតរញ្ជួយដី ... ព្រមជាមួយនេះរុក្ខជាតិមានដុំផងដែរ។ ជាទូទៅគេអាចចែកសណ្ឋានដីបាតសមុទ្រជា២ផ្នែកធំៗគឺ ជាយទ្វីប និង អាងសមុទ្រ។

### ៤.១. ជាយទ្វីប

គេសន្មត់ថាជាយទ្វីបគឺជាតំបន់មាត់សមុទ្រដែលចុះទៅដល់បាតជម្រៅ២០០ម គេប្រដូចជាយទ្វីបទៅនឹងខ្ពង់រាបលើទ្វីប។ ជាយទ្វីបទាំងអស់ពុំមានទំហំដូចជាគ្នាទេជាយទ្វីបខ្លះតូចចង្អៀតដូចជាជាយទ្វីបនៅតាមបណ្តោយ ដងភ្នំអង់នៃប្រទេសស៊ីលីជាដើម។ ជាយទ្វីបខ្លះធំទូលាយ គឺជាយទ្វីបបារាំង អង់គ្លេស និងតំបន់ស៊ីបេរី...។ល។តំបន់ជាយទ្វីបច្រើនតែមានចំណោតទេរសន្សឹមៗចូលឆ្ងាយទៅក្នុងសមុទ្រ ប៉ុន្តែនៅខាង

ចុងប្រហែលក្នុងជម្រៅ២០០ម មានតែមមួយចោតហៅថា ច្រាំងជាយទ្វីប នៅលើជាយទ្វីបសម្បូរទៅដោយកូនភ្នំ ដែលកូនភ្នំខ្លះ លេចផុតពីផ្ទៃទឹក គេឱ្យឈ្មោះថា កោះសមុទ្រ។ នៅប្រទេសកម្ពុជាកោះទាំងឡាយដូចជា កោះទន្សាយ កោះកុងកោះរ៉ុង .... គឺជាកូនភ្នំដែលដែលស្ថិតនៅលើជាយទ្វីបប្រទេស ឬ ខ្ពង់រាបបាតសមុទ្រយើង។ ក្រៅពីកូនភ្នំ គេប្រទះឃើញចាប់ពីជម្រៅ៩០ម ទៅមានកាញ៉ុងបាតសមុទ្រយ៉ាងច្រើន នៅលើជាយទ្វីបជ្រលងជ្រៅៗ។ កាញ៉ុងបាតសមុទ្រ នេះជាជ្រលងទន្លេដែលជីកដោយខ្សែទឹកជំនាន់ដើម ហើយដែលបានលិចចូលទៅក្នុងបាតសមុទ្រ ក្រោយពីការខូចទ្រង់ទ្រាយនៃសំបកផែនដី។ ការសិក្សាអំពីតំបន់ជាយទ្វីបផ្តល់ផលប្រយោជន៍សំខាន់ណាស់ព្រោះថា៖

- តំបន់នេះអាចមានកំណប់រ៉ែដែលបន្តពីទ្វីបជិតខាង ពិសេសរ៉ែប្រេងកាត ឧស្ម័ន និងរ៉ែសំណប៉ាហាំង។ នៅជាយទ្វីបកម្ពុជាបានរកឃើញកំណប់ប្រេងកាតដ៏ធំមួយដែលមានប្រវែងប្រហែល៤៣៥ គ.ម តាមបណ្តោយជាយទ្វីបរហូតដល់ឆ្នេរនៃខេត្តកោះកុង។
- តំបន់ជាយទ្វីប ជាតំបន់នេសាទពិសេស ប្រើឧបករណ៍ទំនើបៗដូចជា នាវាអួនឡាក់ លាយឡំជាមួយការនេសាទធុនតូច ឬ នេសាទប្រពៃណី។

### ៤.២. តំបន់អាងសមុទ្រ

អាងសមុទ្រជាផ្នែកសំខាន់នៃសណ្ឋានដីបាតសមុទ្រ អាងនេះមានទំហំធំទូលាយ (៨០%នៃបាតសមុទ្រ) និង មានជម្រៅពី ២០០០ម ទៅ ៦០០០ម នៅផ្នែកកណ្តាលនៃអាងសមុទ្រមានជួរភ្នំដ៏វែងជាងគេហៅថា ទ្រនុង ដូចជាទ្រនុងអាត្លង់ទិចជាដើម។ ទ្រនុងអាត្លង់ទិចជាជួរភ្នំមួយដ៏វែង លាតសន្ធឹងពីសមុទ្រប្រទេសណរវេស ឆ្ពោះទៅមហាសមុទ្រអាត្លង់ទិចខាងត្បូងដោយឆ្លងកាត់តាមកោះភ្នំភ្លើងនៃប្រទេសអ៊ីស្លង់ និងកោះអាស៊ រ ជួរភ្នំនេះបន្តឆ្លងចូលទៅក្នុងមហាសមុទ្រប៉ាស៊ីភិចប៉ែកខាងត្បូងកាត់តាមចន្លោះ ទ្វីបអូស្ត្រាលី និង ទ្វីបអង់តាកទិច។ តាមការសិក្សាស្រាវជ្រាវបានរកឃើញថា ជួរភ្នំបាតសមុទ្រទាំងអស់ មានប្រវែងសរុប ៦០០០០ គម ឆ្លងកាត់គ្រប់មហាសមុទ្រ នៅតាមសងខាងតាមបណ្តោយជួរភ្នំឬ ទ្រនុងមានអន្លង់សមុទ្រប្រៀបបាន នឹងជ្រោះជ្រៅដែលមានច្រាំងចោតខ្លាំងពុះកាត់បាតសមុទ្រ អន្លង់សមុទ្រដែលជ្រៅជាងគេបំផុតក្នុងមហាសមុទ្រ មិនមែនស្ថិតនៅកណ្តាល មហាសមុទ្រឡើយ ផ្ទុយទៅវិញអន្លង់ជ្រៅៗ នេះគេបានរកឃើញ នៅជិតទ្វីបតាមជាយនៃបាតមហាសមុទ្រប៉ាស៊ីភិច គឺរណ្តៅកោះម៉ារីយ៉ាន មានជម្រៅ១០៨៨១ម៉ែត្រ ស្ថិតនៅក្បែរប្រទេសហ្វីលីពីន។

នៅតំបន់អាងមហាសមុទ្រនេះគេសង្កេតឃើញមាន ភ្នំភ្លើងចម្លែកៗ ភ្នំភ្លើងងាប់ ភ្នំភ្លើងរស់ នៅពេលមាន បាតុភូតភ្នំភ្លើង ឬ រញ្ជួយដី ឬ បំណាក់ស្រុត កើតឡើងនៅបាតមហាសមុទ្រម្តងៗ គេប្រទះឃើញមានមហាសមុទ្រមានរលកធំៗ អាចមានកម្ពស់រហូតដល់៣៥ម៉ែត្រ វាបានបំផ្លាញអ្វីៗជាច្រើន កាលណាវាប៉ះឆ្នេររលកធំៗទាំងនោះហៅថា ស៊ុយណាមិ ។ តំបន់ក្បែរត្រូពិចក្បែរទ្វីប កោះភ្នំភ្លើងខ្លះសម្បូរទៅដោយកោះផ្កាថ្មដុះព័ទ្ធ ជុំវិញគេហៅថា ផ្កាថ្មប៉ះប្រះទឹក ។ ផ្កាថ្មប៉ះប្រះទឹកមាននៅតំបន់ត្រូពិចដូចជា នៅមហាសមុទ្រប៉ាស៊ីភិចខាងត្បូង និងសមុទ្រការ៉ាអ៊ីប ព្រោះផ្កាថ្មត្រូវការពន្លឺព្រះអាទិត្យ និងជម្រៅទឹករាក់ជាង៥៥ម៉ែត្រ។

## ៥. ទឹកសមុទ្រ និងមហាសមុទ្រ

បរិមាណទឹកសមុទ្រមានប្រមាណ១៣៤៧គ.ម$^{៣}$ ជាទូទៅទឹកសមុទ្រមានរសជាតិប្រៃ។

### ៥.១. ជាតិប្រៃនៃទឹកសមុទ្រ

សមុទ្រជាឃ្លាំងអំបិលខនិជរលាយនៃពិភពលោក ក្នុងទឹកសមុទ្រ១គ.ម$^{៣}$ មានអំបិលខនិជរលាយចំនួន៣៩តោនជាមធ្យម។ រសជាតិប្រៃបណ្តាលមកពីសារជាតុអំបិលច្រើនយ៉ាងដែលរលាយក្នុងក្នុងសមុទ្រ។ សូដ្យូមក្លរួ មានច្រើនជាងគេបង្អស់ក្នុងទឹកសមុទ្រ ទឹក១លីត្រ មានអំបិល១៥ក្រាមជាមធ្យម នៅក្នុងទឹកគេរកឃើញអង្គធាតុទោលចំនួនប្រមាណ៥០ ក្នុងចំណោមអង្គធាតុទោលដែលគេស្គាល់ទាំងអស់ ប៉ុន្តែអំបិលខនិជប្រាំមុខមានភាគលើសគេគឺ សូដ្យូមក្លរួ (អំបិលសំខាន់ជាងគេមានចំនួន៧៧.៨% នៃចំនួនអំបិលទាំងអស់) ម៉ាញ៉េស្យូមក្លរួ ម៉ាញ៉េស្យូមស៊ុលផាត កាលស្យូមស៊ុលផាត ប៉ូតាស្យូមស៊ុលផាត។ ក្រៅពីអំបិលទាំងប្រាំមុខនេះ មានអំបិលអ៊ីយ៉ូត អំបិលដែក អំបិលប្រាក់ អំបិលទង់ដែង អំបិលរ៉ាដ្យូម... ដែលមានចំនួនទាំងអស់០.៥% ។ អំបិលដែលរលាយក្នុងទឹកសមុទ្រ បានមកពីប្រភពផ្សេងៗគឺ៖

**ប្រភពមកពីទ្វីប ៖** ផលនៃរបេចមេកានិច និង គីមី នៅលើទ្វីបត្រូវបានផ្លូវទឹកតូចធំទាំងអស់នាំមកចាក់នៅក្នុងសមុទ្រ ធ្វើឱ្យសមុទ្រមានរសជាតិប្រៃ។

**ប្រភពមកពីសមុទ្រ និង មហាសមុទ្រ ៖** ក្នុងភ្នំភ្លើងផ្ទុះ ផ្សែងភ្នំភ្លើងនិងអង្គធាតុផ្សេងៗទៀតរលាយក្នុងសមុទ្រ ម្យ៉ាងវិញទៀតរបេចមេកានិច និង របេចគីមីលើសិលាបាតសមុទ្រ ព្រមទាំងសត្វសមុទ្រដូចជា ងៀវ គ្រំលៀស ក៏ជាមូលហេតុសំខាន់ដែរ។

អំបិលមានប្រយោជន៍ចាំបាច់ណាស់សម្រាប់អាហារមនុស្ស និង សត្វ ហើយក្នុងពេលបច្ចុប្បន្ននេះអំបិលជារូបធាតុដើមមួយ ជាទំនិញមួយសម្រាប់រោងចក្រឧស្សាហកម្មគីមីដែលកាន់តែអភិវឌ្ឍ។

### ៥.២. ដង់ស៊ីតេទឹកសមុទ្រ

ដោយសារភាគអំបិលដ៏សំខាន់ដែលមាននៅក្នុងទឹក ធ្វើឱ្យទឹកសមុទ្រមានដង់ស៊ីតេខ្ពស់ជាងទឹកសាប។ ហេតុនេះទឹកសមុទ្រជួយទ្រអ្នកហែលជាងទឹកសាប ហើយនាវាក៏ពុំសូវកប់ជ្រៅក្នុងទឹកដែរ *ឧទាហរណ៍* នៅលើផ្ទៃទឹកនៃសមុទ្រ ក្ស័យ ដែលមានដង់ស៊ីតេខ្ពស់បំផុត អ្នកទេសចរ អាចផ្តេកខ្លួនដោយមិនព្រួយពីលិចខ្លួនទៅក្នុងជម្រៅសមុទ្រឡើយ។ ម្យ៉ាងទៀតដង់ស៊ីតេ មានកម្រិតកាន់តែខ្ពស់កាលណាសីតុណ្ហភាពកាន់តែចុះទាប ដូច្នេះជាទូទៅដង់ស៊ីតេកើនឡើង ពីអេក្វាទ័រទៅប៉ូល ក្នុងផ្ទៃទឹកផ្នែកខាងក្រោម ដង់ស៊ីតេកើនឡើង កាលណាជម្រៅកាន់តែជ្រៅ ព្រោះសីតុណ្ហភាពកាន់តែចុះទាប ហើយសម្ពាធកាន់តែកើនឡើងខ្លាំង។ ហេតុដូច្នេះវត្ថុណាក៏ដោយដើម្បីឱ្យលិចជ្រៅទៅក្នុងទឹកសមុទ្របានលុះត្រាតែមានដង់ស៊ីតេធំជាង១.១ (ម៉ាសមាឌរបស់វត្ថុអ្វីមួយ)។

### ៥.៣. សីតុណ្ហភាពទឹកសមុទ្រ

ព្រះអាទិត្យជាប្រភពផ្តល់កម្តៅឱ្យមហាសមុទ្រ ហើយមហាសមុទ្រមានមុខងាររក្សាកម្តៅទុកផងនិងរំភាយកម្តៅផង។ ផ្ទៃលើមហាសមុទ្រទទួលកម្តៅព្រះអាទិត្យបានច្រើនជាងគេ ចលនាទឹកសមុទ្រដូចជារលក និង ចរន្តទឹកបានបញ្ជូនកម្តៅចុះទៅក្រោមបានជម្រៅពី ១០០គ.ម ទៅ ៤០០គ.ម ប៉ុណ្ណោះ។

សីតុណ្ហភាពផ្ទៃលើអាចប្រែប្រួលពី២៦អង្សាសេ នៅតំបន់ត្រូពិច ទៅ -១.៤អង្សាសេ នៅតំបន់ប៉ូល ជាទូទៅសីតុណ្ហភាពចុះជាលំដាប់ពីអេក្វាទ័រ ទៅ ប៉ូល។ នៅត្រង់រយៈទទឹងដូចគ្នា សីតុណ្ហភាពប្រែប្រួលទីតាមរដូវក្នុងឆ្នាំនីមួយៗ ចំណែកសីតុណ្ហភាពក្នុងជម្រៅសមុទ្រវិញ មិនសូវខុសគ្នាខ្លាំងពេកទេគឺ៖

- ពីផ្ទៃលើដល់ជម្រៅ ១០០ម សីតុណ្ហភាពចុះរហ័សណាស់
- ពី១០០ម ដល់ ៣០០០ម សីតុណ្ហភាពចុះមិនសូវលឿន
- ជម្រៅ ៣០០០ម ទៅសីតុណ្ហភាពទៅនឹងដដែលពី ០អង្សាសេទៅ២អង្សាសេក្រោមសូន្យ។

សីតុណ្ហភាពទឹកមហាសមុទ្រថយចុះ នៅពេលដែលជម្រៅទឹកកើនឡើង ទោះបីជាយ៉ាងណាក៏ដោយករណីនេះមិនកើនឡើងពីផ្ទៃលើមហាសមុទ្រទៅបាតរបស់វាទេ ទឹកនៅក្នុងមហាសមុទ្រអាចបែងចែកជា៣ស្រទាប់ដោយយោងទៅលើសីតុណ្ហភាពនៅទឹកផ្នែកខាងលើក្តៅជាងសីតុណ្ហភាពមធ្យមនៃទឹកមហាសមុទ្រ។

- **តំបន់ផ្ទៃលើ** ( Surface Zone ) តំបន់ផ្ទៃលើជាស្រទាប់ខាងលើបង្អស់នៃទឹកមហាសមុទ្រមានសីតុណ្ហភាពក្តៅ ហើយមានជំម្រៅប្រហែល ៣០០ម៉ែត្រ ពន្លឺព្រះអាទិត្យ កម្តៅផ្ទៃទឹកខាងលើដល់ទៅជម្រៅប្រហែល ១០០ម៉ែត្រ ចរន្តផ្ទៃទឹកខាងលើធ្វើឱ្យទឹកក្តៅ និង ត្រជាក់នៅខាងក្រោមលាយគ្នា។
- **តំបន់សីតុណ្ហភាពធ្លាក់ចុះខ្លាំង** ( Thermocline ) គឺជាស្រទាប់ទឹកដែលបន្តពីជម្រៅ៣០០ម៉ែត្រទៅដល់ជម្រៅ ប្រហែល៧០០ម៉ែត្រ នៅចន្លោះជម្រៅក្នុងតំបន់នេះ នៅពេលជម្រៅទឹកសមុទ្រកើនឡើង សីតុណ្ហភាព ទឹកធ្លាក់ចុះលឿនជាងតំបន់ពីរផ្សេងទៀត។
- **តំបន់ជ្រៅ** (Deep Zone) គឺគិតចាប់ពីបាតក្រោមនៃតំបន់សីតុណ្ហភាពធ្លាក់ចុះខ្លាំងរហូតដល់បាតសមុទ្រ សីតុណ្ហភាពជាមធ្យមនៅក្នុងតំបន់នេះគឺ ២ $^{0}$C ។

ការសិក្សាពីសីតុណ្ហភាពទឹកសមុទ្រផ្តល់អត្ថប្រយោជន៍ច្រើនៈ

- ការស្គាល់របាយ និង បម្រែបម្រួល សីតុណ្ហភាពទឹកសមុទ្រមានតម្លៃ ពិសេសសម្រាប់អ្នកនេសាទ គឺអាចឱ្យអ្នកនេសាទ តាមដានហ្វូងត្រី និង ដឹងទីកន្លែងរដូវល្អសម្រាប់នេសាទ។
- ចន្លោះសីតុណ្ហភាពដែលខុសគ្នារវាងទឹកផ្នែកលើ និងទឹកផ្នែកក្រោមអាចផ្តល់ជាប្រភពថាមពល។ ចំពោះបញ្ហានេះ អ្នកប្រាជ្ញលើសកលលោកកំពុងយកចិត្តទុកដាក់ស្រាវជ្រាវ និង ទាញយកផល។

## ៥.៤. កំណកទឹកសមុទ្រ

នៅក្នុងទឹកសមុទ្រផ្នែកខាងលើ ចំណុចកំណកនៅត្រឹមតែ -២អង្សាសេ ជាមធ្យម ប៉ុន្តែជួនកាលចុះរហូតដល់ -៣.៥អង្សាសេ ក៏មាន។ ទឹកសមុទ្រកកដំបូងជាបន្ទះមូលតូចៗហៅថា ផ្កាទឹកកក បន្ទាប់មកបន្ទះតូចៗនេះភ្ជាប់គ្នាបង្កើតបានជាផ្ទាំងទឹកកកធំរយគីឡូម៉ែត្រ។ នៅក្នុងមហាសមុទ្រមានផ្ទាំងទឹកកកប្រៃដែលអណ្តែតលើផ្ទៃសមុទ្រហៅថា បង់គីស ក្រៅពីនេះនៅមានផ្ទាំងទឹកកកសាបដែលជាច់ធ្លាក់ពីផែនទឹកកកទ្វីបនៃតំបន់ប៉ូល ហៅថា អាយស៊្បែរ។

## ៥.៥. តំបន់មហាសមុទ្រ

យោងទៅលើជម្រៅទឹកមហាសមុទ្រ មហាសមុទ្រក៏ត្រូវបានបែងចែកទៅជាតំបន់អេកូឡូស៊ី ផ្អែកទៅលើកន្លែងខុសៗគ្នានៃប្រភេទបង់តួសរស់នៅ តំបន់ទាំងនោះត្រូវបានចែងចែកជាក្រុមទៅជាបរិស្ថានមហាសមុទ្រសំខាន់ពីរគឺៈ

- មជ្ឈដ្ឋានបង់ទិច ជាមជ្ឈដ្ឋានបាតក្រោមនៃមហាសមុទ្រ និង សារពាង្គកាយទាំងអស់ដែលរស់នៅក្នុង ឬ នៅនឹងបាតមហាសមុទ្រ។

- មជ្ឈដ្ឋានប៉េឡាសិក ៖ ជាមាឌទាំងមូលរបស់ទឹកនៅក្នុងមហាសមុទ្រ រួមទាំងសារពាង្គកាយសមុទ្រ ដែលរស់នៅពីលើបាតសមុទ្រ។

**គ. ជីវិតក្នុងមហាសមុទ្រ**

ជីវិតក្នុងមហាសមុទ្រ ចែកចេញជាបីក្រុមសំខាន់គឺ ប្លង់តុង ណិកតុង និង បង់តូស។ គេចាត់សារពាង្គកាយសមុទ្រចូលទៅក្នុងក្រុមមួយនៃក្រុមទាំងបីនេះ ដោយយោងទៅលើទីកន្លែងដែលពួកវារស់នៅនិងរបៀបផ្លាស់ទី។

- **ប្លង់តុង**៖ គឺជាសារពាង្គកាយដែលអណ្តែត ឬ ក្បែរផ្ទៃលើមហាសមុទ្រ។ ប្លង់តុងភាគច្រើនមិនអាចមើលឃើញដោយភ្នែកទទេបានឡើយ ប្លង់តុង ត្រូវបានចបែងចែកទៅជា២ក្រុមបន្ថែមទៀតគឺប្លង់តុងទាំងឡាយដូចរុក្ខជាតិ ហៅថា ប្លង់តុងរុក្ខជាតិ ហើយប្លង់តុងដូចសត្វ ហៅថា ប្លង់តុងសត្វ។
- **ណិកតុង**៖ គឺជាសារពាង្គកាយ ដែលហែលដោយសេរីនៅក្នុងមហាសមុទ្រ ប្រភេទណិកតុងរួមបញ្ចូលទាំងពួកថនិកសត្វដូចជា ត្រីបាឡែន ត្រីដូហ្វីន និង តោសមុទ្រ ក៏ដូចជាប្រភេទត្រីច្រើនប្រភេទទៀតដែរ ណិកតុងគឺសម្បូរបំផុតនៅផ្ទៃទឹកខាងលើ។
- **បង់តូស**៖គឺជាសារពាង្គកាយដែលរស់នៅលើ ឬ នៅក្នុងបាតមហាសមុទ្រ ពួកវារស់នៅក្នុងភក់ខ្សាច់ និង ថ្ម។ បង់តូស មានច្រើនប្រភេទដូចជា ក្តាម ផ្កាយសមុទ្រ ឈ្លើង ផ្កាថ្ម អេប៉ុង សារាយសមុទ្រ និងលៀស...។ល។

**ខ. ធនធានមហាសមុទ្រ**

មហាសមុទ្រ ផ្តល់ធនធានមិនចេះរីងស្ងួត ប្រសិនបើយើងទាញយកផលពីវាឱ្យបានសមស្រប ដូចជា អាហារ វត្ថុធាតុដើម ថាមពល និងទឹកហើយមានធនធាន ដែលមិនទាន់រកឃើញជាច្រើនទៀតនៅក្នុងមហាសមុទ្រ។ បច្ចុប្បន្ន អត្រាប្រជាជនមានការកើនឡើង តម្រូវការធនធានក៏កើនឡើងដែរ ក្នុងខណៈពេលដែលលទ្ធភាពរបស់វាកំពុង តែថយចុះ។

- **ធនធានមានជីវិត** ៖ មនុស្សបានប្រមូលរុក្ខជាតិ និង សត្វសមុទ្រជាច្រើន សម្រាប់ធ្វើជាអាហារអស់ រយៈពេលរាប់ពាន់ឆ្នាំមកហើយ ភាវៈរស់ទាំងអស់នោះរួមមានបង្គា ខ្យង ក្តាម គ្រំជំពុះទា និង ប្រភេទ សារាយ សមុទ្រជាច្រើនទៀត...។ ***ឧទាហរណ៍៖*** ស៊ូស៊ី គឺជាមុខម្ហូបមួយមុខរបស់ប្រទេសជប៉ុន ត្រូវបានរុំទៅដោយស្មៅសមុទ្រដែលសម្បូរដោយប្រូតេអ៊ីន។
- **ធនធានគ្មានជីវិត**៖ មនុស្សប្រមូលធនធានគ្មានជីវិតជាច្រើនប្រភេទពីមហាសមុទ្រ ធនធានទាំងនេះ ផ្តល់នូវវត្ថុធាតុដើមជាច្រើនប្រភេទដូចជា ទឹករ៉ែ និង ថាមពល...។

ប្រេង និងឧស្ម័នធម្មជាតិ ត្រូវបានរកឃើញនៅក្នុងស្រទាប់មិនជ្រាបទឹក បំណិតទឹកសាបគឺជាដំណើរការរំហួតទឹកសមុទ្រ ដូច្នេះ ទឹកនិងអំបិលញែកចេញពីគ្នា ដំណើរការនេះមានតម្លៃថ្លៃណាស់ ប្រទេសអារ៉ាប៊ីសាអ៊ូឌីត ដែលស្ថិតនៅក្នុងតំបន់វាលខ្សាច់ភាគកណ្តាលនៃអាស៊ីខាងកើត មានរោងចក្របំណិតទឹកសាបមួយដែលធំជាងគេនៅលើពិភពលោក។ ស្ពាមកំពត រ៉ែនៅបាតមហាសមុទ្រមានដូចជា ម៉ង់កាណែស ដែកទង់ដែង នីកែល កូបាល និង ផូស្វាត។ ជំនោរ និង លំនាច បានផ្តល់ថាមពលដល់តំបន់ខ្លះនៅលើពិភពលោក ហើយថ្មីៗនេះ អ្នកស្រាវជ្រាវកំពុងនិងបានប្រើប្រាស់កម្មវិធីកុំព្យូទ័រ ធ្វើការវិភាគទៅលើថាមពលរលកបន្ថែមទៀត។

## សំណួរត្រិះរិះ

១. ចូរនិយាយពីកំណាក់កំណើតភពផែនដី?

២. តើបរិយាកាសបច្ចុប្បន្ននិងអតីតកាលខុសគ្នាដូចម្តេច? ចូរពន្យល់។

៣. ចូរនិយាយពីវដ្តទឹកនៅលើភពផែនដី ។

៤. ហេតុអ្វីបានជាទឹកទន្លេសាប ទឹកសមុទ្រប្រៃ?

៥. ចូរនិយាយពីលក្ខណៈខុសគ្នារវាងសមុទ្រនិងមហាសមុទ្រ?

# មេរៀនទី២ ៖ សមុទ្រ ជាធនធានធម្មជាតិ

## ១. ការនេសាទ និងបច្ចេកទេសនេសាទ

សមុទ្រ និង មហាសមុទ្រ ផ្តល់អាហារមួយចំនួនសម្រាប់មនុស្ស ជាតិនៅលើភពផែនដី។ អាហារដ៏សំខាន់នោះគឺជាត្រីដែលបានមកពីការនេសាទជាពិសេសនេសាទទឹកប្រៃ។

នេសាទជាបច្ចេកទេសទី១ ក្នុងចំណោមបច្ចេកវិទ្យាសម្រាប់ដោះស្រាយបញ្ហាចិញ្ចឹមជីវិត នៅសម័យបុរេប្រវត្តិ មនុស្សចេះនេសាទត្រី ដោយប្រើឧបករណ៍សាមញ្ញងាយៗ ព្រោះត្រីងាយរកបានជាងការបបាញ់ ហើយពុំសូវមានគ្រោះថ្នាក់ សព្វថ្ងៃគេនៅបន្តប្រើឧបករណ៍នេសាទប្រពៃណីខ្លះៗ ក៏ការនេសាទបានប្រមូលផ្តុំបច្ចេកទេសទំនើបៗសម្រាប់រាវរកត្រី ចាប់ត្រី ដូចជា ឧបករណ៍រ៉ាដា នាវា-រោងចក្រ សូរសំលេងអ៊ុលត្រា...ដែលអាចចាប់ត្រីផង អាចរក្សាទុកត្រីបានច្រើនសប្តាហ៍នៅលើលំហសមុទ្រ ជួនកាលកែច្នៃនៅក្នុងលំហសមុទ្របានថែមទៀត។

### ១.១. ការនេសាទ

#### ក. កន្លែងនេសាទ

មជ្ឈមណ្ឌលនេសាទធំៗនៅក្នុងពិភពលោក ពាក់ព័ន្ធជាមួយកត្តាធម្មជាតិ និង កត្តាសេដ្ឋកិច្ច។

- **កត្តាធម្មជាតិ** ៖ តាំងពីយូរយារណាស់មកហើយ មនុស្សស្គាល់ជម្រក និង របៀបរស់នៅរបស់ត្រីយ៉ាងច្បាស់លាស់ នៅក្នុងទឹកសមុទ្រមានរុក្ខជាតិរាប់ម៉ឺនប្រភេទហៅថា ប្លង់តុង ដែលអណ្តែតទូទាំងសមុទ្រ ប្លង់តុងទាំងនេះសម្បូរច្រើនជាងគេនៅតំបន់ប៉ូលខាងជើង ប៉ូលខាងត្បូង និងនៅតាមជាយទ្វីប ប្រភេទប្លង់តុង ជាចំណីអាហារសំខាន់របស់ត្រី និង សត្វសមុទ្រផ្សេងៗទៀត។ ប្លង់តុងមាន២ប្រភេទគឺ ប្លង់តុងសត្វ និង ប្លង់តុងរុក្ខជាតិ ហើយយើងមិនអាចមើលឃើញដោយភ្នែកទទេបានឡើយ វាមានចំនួនដល់ទៅ២/៣ នៃរុក្ខជាតិលើពិភពលោក។ ទីណាមានប្លង់តុង ទីនោះមានត្រីរស់នៅកុះករ ម្យ៉ាងទៀតត្រីចូលចិត្ត តំបន់ខ្សែទឹកចម្រុះដែលសីតុណ្ហភាព និង ជាតិប្រៃខុសៗគ្នា ដូចជាកន្លែងជួបគ្នារវាងខ្សែទឹកត្រជាក់ និង ខ្សែទឹកត្រជាក់ និង ខ្សែទឹកក្តៅត្រូពិច មានជំនួបខ្សែទឹកឡាប្រាដ័រ និង គុលស្ទ្រីមនៅជីថ្មី ជំនួបខ្សែទឹកអូយ៉ាស៊ីវ៉ូ នៅជប៉ុនខាងកើត ជំនួបខ្សែទឹកក្តៅរាក់ៗ និង ខ្សែទឹកត្រជាក់ជ្រៅៗ នៅតាមឆ្នេរខាងលិចអាហ្វ្រិច អាមេរិកជាដើម។ កន្លែងខាងលើនេះល្បីឈ្មោះថាជាកន្លែងនេសាទដ៏ប្រសើរបំផុតនៅលើពិភព ក្រៅពីតំបន់ជំនួបខ្សែទឹកក្តៅ និង ខ្សែទឹកត្រជាក់ តំបន់ជាយទ្វីបក៏ល្បីឈ្មោះថា តំបន់នេសាទសំខាន់ដែរ តំបន់ជាយទ្វីបជម្រៅទឹករាក់ ពន្លឺអាចមានគ្រប់គ្រាន់សម្រាប់ការលូតលាស់របស់រុក្ខជាតិ និងប្លង់តុង។ ប្លង់តុង ជាក្រុមសត្វ និង រុក្ខជាតិ បណ្តែតខ្លួនក្នុងផ្ទៃទឹកក្លាយជាចំណីហូរហៀរសម្រាប់ត្រី និង សត្វសមុទ្រ។
- **កត្តាសេដ្ឋកិច្ច** ៖ គ្រាន់តែភាពសម្បូរត្រីមិនអាចធ្វើឱ្យនេសាទសកម្មទេ លុះត្រាតែគេអាចលក់ត្រីបានផងទើបនេសាទក្លាយជានេសាទសកម្ម។ ដូចនេះតំបន់នេសាទសកម្មជាងគេក្នុងពិភពលោកត្រូវតែស្ថិតនៅជិតមណ្ឌលដែលមានមនុស្សច្រើន តាមមាត់ឆ្នេរដូចជានៅឆ្នេរអឺរ៉ុបប៉ែកពាយ័ព្យព្រោះមធ្យោបាយដឹកនិងរក្សាទុកបានយូរកាន់តែទំនើបឡើងៗ ជាហេតុនាំឱ្យគេបង្កើតទីផ្សារត្រីបានច្រើនកន្លែង ហើយឆ្ងាយៗពីតំបន់នេសាទទៀតផង។

កត្តាធម្មជាតិ កត្តាសេដ្ឋកិច្ច បង្កើតឱ្យមានមជ្ឈមណ្ឌលនេសាទធំៗក្នុងពិភពលោកដូចជា៖

- មជ្ឈមណ្ឌលនេសាទអឺរ៉ុបខាងលិច ធ្វើសកម្មភាពចាប់ពីប្រទេសណ័រវែសខាងត្បូង រហូតដល់ប្រទេសអេស្ប៉ាញ។
- មជ្ឈមណ្ឌលនេសាទអាស៊ីខាងកើត៖ធ្វើសកម្មភាពពីកាំឆាត់កាដល់កម្រងកោះប៉ាស៊ីភិចខាងលិច។

មជ្ឈមណ្ឌលនេសាទទាំងពីរខាងលើនេះ មានលក្ខណៈធម្មជាតិល្អៗជាច្រើនព្រោះជាតំបន់ជាយទ្វីបធំទូលាយ កន្លែងជំនួបខ្សែទឹកសមុទ្រ មជ្ឈដ្ឋានប្រជាជនច្រើន តំបន់ចម្រុះនេសាទប្រពៃណី និង នេសាទឧស្សាហកម្មទំនើប។ ក្រុមហ៊ុនធំៗរបស់សហគ្រាសនេសាទនៃប្រទេសឧស្សាហកម្មលូតលាស់ដូចជា ប្រទេសបារាំង អង់គ្លេស ជប៉ុន រុស្ស៊ី បង្កើតកំពង់ផែនេសាទធំៗនៅលើទ្វីប និងមាននាវារោងចក្រធំៗ ទំនើបៗរាតត្បាតដែនសមុទ្រអន្តរជាតិនៃពិភពលោកទាំងមូល។ មជ្ឈដ្ឋានទាំងពីរនេះផ្តល់១៦% នៃប្រូតេអ៊ីនសត្វជាអាហារសម្រាប់មនុស្សជាតិនៃពិភពលោកយើងនេះ។ ថ្មីៗនេះប្រទេសចិនក៏បានរួមចំណែកនៅក្នុងឧស្សាហកម្មក្នុងលំហសមុទ្រជាមួយនឹងនាវាទំនើបៗផងដែរ។ សព្វថ្ងៃផលិតផលត្រីដែលចាប់បានពីសមុទ្រ និងមហាសមុទ្រនៅលើពិភពលោក ស្ថិតនៅទ្រឹងជុំវិញ៨៤លានតោន/ឆ្នាំ ដែលនៅក្នុងនោះប្រទេសចិនតែឯងរ៉ាប់រងបាន១/៥ទៅហើយ។ ចាប់ពីប្រទេសចិនចូលរួមចំណែកក្នុងវិស័យនេសាទក្នុងដែនអន្តរជាតិមកភូមិសាស្ត្រចាប់ត្រីបានប្រែប្រួល។ តំបន់ប៉ាស៊ីភិចស្ថិតនៅឆ្ងាយខ្លាំងពីតំបន់អាត្លង់ទិច និង ឥណ្ឌា ប៉ាស៊ីភិច ៦០% អាត្លង់ទិច៣០% ឥណ្ឌា១០%។

### ១.២. ការវិវត្តន៍បច្ចេកទេសនេសាទ

គេបានដឹងថាមនុស្សចេះបរិភោគត្រីតាំងពីសម័យបុរេប្រវត្តិមកម្លេះ អ្នកបុរាណវត្ថុវិទ្យាបានជីកកកាយរកឃើញនៅតាមឆ្នេរ តាមទំនាប ខ្ពង់រាបនូវសំណល់កម្ទេចកម្ទីម្ហូប អាហាររបស់មនុស្សសម័យបុរេប្រវត្តិ ដូច្នេះនៅគ្រប់អរិយធម៌សម័យបុរាណមនុស្សសុទ្ធសឹងចេះនេសាទ។ ឧបករណ៍នេសាទដែលគេបានឃើញដូចជាផ្លែសន្ទូចជាដើម ខ្លះធ្វើពីឆ្អឹងខ្លះធ្វើពីលោហៈ.... មានជំនឿថា ប្រាកដជាមានឧបករណ៍ផ្សេងៗដែលធ្វើពីឈើ ឬ ឬស្សីដែលត្រូវបានពុកផុយអស់។ ប៉ុន្តែការសង្កេតនិងសិក្សាអាចនាំឱ្យយើងដឹងថាឧបករណ៍នេសាទសាមញ្ញបច្ចុប្បន្នមួយចំនួនដែលប្រជននេសាទប្រពៃណីកំពុងប្រើប្រាស់ដូចជា លប សៃយ៉ុន ទ្រូ មងសរសៃរុក្ខជាតិ... ពិតជាមានមូលដ្ឋានពីបុរាណមិនខាន ។

គេសង្កេតឃើញថា នេសាទមានមុខងារសំខាន់ណាស់ក្នុងចំណីអាហារ(នៅប្រទេសជប៉ុន មនុស្សម្នាក់បរិភោគត្រីលើសពី 50 kg ក្នុង 1ឆ្នាំ) ។ តម្រូវការទីផ្សារកាន់តែខ្លាំងនូវផលិតផលត្រីជាចំណី អាហារសម្រាប់មនុស្សដែលកាន់តែកើនឡើងឥតឈប់ឈរ ទាមទារឱ្យខិតខំស្រាវជ្រាវរកមធ្យោបាយ ថ្មីៗទៀត ដើម្បីចាប់ត្រីឱ្យបានកាន់តែច្រើន ។ យ៉ាងណាមិញសំណាញ់ មង អួន... ធ្វើអំពីសរសៃ រុក្ខជាតិ ត្រូវបានជំនួសដោយសំណាញ់ មង អួន ធ្វើអំពីសរសៃអំបោះសំយោគជាប់មាំហើយផលិត បានច្រើនជាង ។ ម្យ៉ាងទៀតពួក កប៉ាល់ កាណូតតូចៗដែលមិនហ៊ានចេញទៅឆ្ងាយពីឆ្នេរនោះ ត្រូវបានជំនួសដោយនាវាសមុទ្រធំៗមានបន្ទប់សម្រាប់កម្មករ បន្ទប់ទឹកកកសម្រាប់រក្សាគុណភាពត្រី ។ បច្ចុប្បន្ននេះគេប្រើ "នាវា-រោងចក្រធំៗផ្ទុកកម្មករនេសាទ ឧបករណ៍នេសាទដោយធ្វើការនេសាទផង រក្សាត្រីក្នុងបន្ទប់ត្រជាក់ផង នាវាប្រភេទនេះអាចនៅក្នុងលំហសមុទ្របានច្រើនសប្តាហ៍ដោយ មិនចាំបាច់ចូលមកកំពង់ផែនៅលើទ្វីប នាវាខ្លះជាប់ដោយអួនឡាក់ដែលមានទទឹង10m ខ្សែផ្លែសន្ទូចធំៗដែលមានប្រវែងរហូតដល់1600m។ ខ្លះទៀតមានសំណាញ់ធំៗធ្វើអំពី

អំបោះសំយោគ ដែលពុំងាយខូចមានប្រវែង1000m កម្ពស់ពី40m ទៅ 60m ។ នាវាទាំងនេះសុទ្ធសឹងបំពាក់ទៅដោយប្រដាប់ប្រដា ប្រដាប់ស្ទង់ប្រើសំឡេងអ៊ុលត្រាដែលអាចប្រាប់ជម្រកត្រីនិងហ្វូងត្រី។ ក្នុងពេលថ្មីៗនេះ គេបានបង្កើតឧបករណ៍ពិសេសម្យ៉ាងទៀត ដោយប្រើរលកសំឡេងអ៊ីតហៅត្រី ធ្វើឱ្យហ្វូងត្រីទាំងឡាយនាំគ្នាមកចូលក្នុងស៊ងដោយងាយៗ។ ចំណែកកំពង់ផែនេសាទវិញក៏ត្រូវបានពង្រីកដោយសារ ចំណុះរបស់នាវា និងដោយសារឧស្សាហូបនីយកម្មនេសាទ ។

### ១.៣. របៀបនេសាទ

បើគិតទៅតាមបច្ចេកទេសនេសាទ គេអាចចែកនេសាទជា 2 ប្រភេទគឺ នេសាទធុនតូចនិង នេសាទធុនធំ។

#### ក. បច្ចេកនេសាទធុនតូច

ជានេសាទប្រពៃណីដែលប្រព្រឹត្តទៅតាមមាត់ឆ្នេរ ។ នេសាទនេះប្រើមនុស្សច្រើន ពួកតូចៗ ក៏ច្រើន ឯពួកទាំងនេះកម្រចេញនេសាទដោយដេកផ្លូវណាស់ ។ ឧបករណ៍នេសាទច្រើនជាឧបករណ៍សាមញ្ញមានសន្ទូច មង ទ្រូង អួនឡាក់តូចៗ ។ ចំណែកឯទិន្នផលមិនទៀងទាត់ឡើយ ហើយពុំសូវ ខ្ពស់ផងបើគិតទៅតាមចំនួនអ្នកនេសាទច្រើននិងទូកនេសាទ ។ ផលិតផលត្រីដែលចាប់បានគេយកមក លក់នៅតាមកំពង់ផែដែលគេសំចតទូក ។ 95% នៃអ្នកនេសាទពិភពលោករស់នៅក្នុងប្រទេសក្រីក្រ ហើយប្រកបរបរនេសាទប្រពៃណី ចំពោះប្រទេសអ្នកមានធំៗ នេសាទប្រពៃណីកាន់តែថយបន្តិចម្ដងៗ ប្រទេសទាំងនោះគេប្រើរបៀបទំនើបៗសម្រាប់នេសាទតាមឆ្នេរ ។

#### ខ. បច្ចេកនេសាទធុនធំ

ជានេសាទឧស្សាហកម្មដែលប្រព្រឹត្តទៅ ភាគច្រើនក្នុងលំហកណ្ដាលសមុទ្រ ក្នុងដែន សមុទ្រអន្តរជាតិនៃមហាសមុទ្រ ។ ក្នុងការធ្វើ នេសាទគេប្រើនាវាធំៗដែលអាចចេញទៅ នេសាទឆ្ងាយៗបាន ហើយដែលប្រដាប់ដោយ មធ្យោបាយទំនើបៗ។ វាទាំងនេះជាកម្មសិទ្ធិ របស់សហគ្រាសធុនធំឬធុនកណ្ដាល ព្រោះគេត្រូវការទុននេសាទបែបនេះ។ គេប្រើអួនឡាក់ធំៗសម្រាប់អូសដល់បាតមហាសមុទ្រ ប្រើកប៉ាល់សមុទ្រ សម្រាប់ផ្គត់ផ្គង់សម្ភារៈផ្សេងៗដល់ នាវា-រោងចក្រដែលទទួលបន្ទប់ រក្សាត្រីក្នុងបន្ទប់ត្រជាក់និងធ្វើផលិតអាហារកំប៉ុងជាម្សៅត្រីជាដើម ។ ប្រទេសដែលបាននាំមុខគេក្នុងវិស័យនេសាទធុនធំដូចជាប្រទេសរុស្ស៊ី សហរដ្ឋអាមេរិក ប៉េរូ ស៊ីលី ដែលសម្រេចបាន 2/3 នៃផលិតកម្មត្រីនៃពិភពលោក ប្រទេសខាងលើនេះ ក្រៅពីមានកំពង់ផែនេសាទទំនើបៗ នៅមានសាខាលក់ផលិតផលសមុទ្រនៅ តាមនានាទៀត ។ បច្ចុប្បន្ននេះ នេសាទធុនធំប្រមូលផ្ដុំនាវានេសាទរហូតដល់3.5លានគ្រឿងរាតត្បាតពាសពេញផ្ទៃមហាសមុទ្រ ធ្វើឱ្យមហាសមុទ្រមាន "ជំងឺនេសាទហួសហេតុ ។

### ២. អាជីវកម្មធនធានរ៉ែក្នុងសមុទ្រ

ក្រៅពីធនធានរ៉ែដែលមានក្នុងទឹក ដីបាតសមុទ្រក៏អាចមានកំណប់រ៉ែមិនតិចដែរ ។ ដូចយើងបានដឹងហើយថា ផ្ទៃដីបាតសមុទ្រមានវិសាលភាពធំធេងណាស់ស្មើនិង 70% នៃផ្ទៃដីទាំងមូល ។ ទោះបីជាសណ្ឋានដីបាតសមុទ្រ ឬសណ្ឋានដីទ្វីបក៏ដោយ ទាំងអស់នេះជាលទ្ធផលដែលកើតឡើងដោយ ចលនាតិចតួនិចឆ្លងកាត់ការវិវត្តនៃប្រវត្តិធរណីកាលជាមួយគ្នា ។ ដូចនេះគេអាចសន្និដ្ឋានបានថា ដី បាតសមុទ្រពិតជាមានកំណប់រ៉ែសំខាន់គ្រប់បែបយ៉ាង ដូចដែលគេបានរកឃើញនៅលើទ្វីបដែរ ។ ចំណែកឯរ៉ែ ដែលគេកំពុងយកចិត្ត

ទុកដាក់ខ្លាំងជាងគេក្នុងបាតសមុទ្រនោះគឺរ៉ែប្រេងកាត កន្លែងយកប្រេងកាតនៅជាយទ្វីប (សមុទ្រខាងត្បូង)។

## ២.១. រ៉ែប្រេងកាត

តំបន់ជាយទ្វីបជាតំបន់បន្តពីកំណាប់រ៉ែនៃទ្វីបជិតខាង។ តំបន់ជាយទ្វីប បានក្លាយជាមុខសញ្ញាសំខាន់ទីពីរបន្ទាប់ពីរ៉ែប្រេងកាតនៅលើទ្វីប។ តំបន់ជាយទ្វីប ដីទ្វីបដែលលយចូលទៅក្នុងផ្ទៃសមុទ្រ រហូតដល់ជម្រៅ 200m ។ អាជីវកម្មរ៉ែប្រេងកាតនៅទីនេះមានលក្ខណៈល្អប្រសើរជាងតំបន់អាង សមុទ្រដែលមានជម្រៅជ្រៅជាង។ តំបន់ជាយទ្វីបមានជម្រៅទឹករាក់ ស្ងប់ជាងលំហសមុទ្រហើយនៅជិតឆ្នេរងាយស្រួលផ្គត់ផ្គង់ផង។ តំបន់ជាយទ្វីបដែលធំទូលាយជាងគេគឺជាយទ្វីបបារាំងនិងអង់គ្លេសដែលមានទំហំស្មើនឹងសមុទ្រម៉ង់ និងសមុទ្រឧត្តរ ។ ជាយទ្វីបដ៏ធំមួយទៀតគឺជាយទ្វីបនៃស៊ីបេរី ។ បច្ចុប្បន្ននេះ ការរុករកនិងអាជីវកម្មប្រេងកាតនៅសមុទ្រឧត្តរ បានទទួលផលល្អប្រសើរមិនចាញ់កំណាប់រ៉ែនៅលើទ្វីប ឡើយ។ សព្វថ្ងៃនេះ ក្រុមហ៊ុនប្រេងកាតធំៗកំពុងចុះកិច្ចសន្យា ធ្វើការរុករកនិងធ្វើអាជីវកម្មប្រេងកាត តាមបណ្ដាជាយទ្វីបនៃប្រទេសក្រីក្រមួយចំនួនក្នុងពិភពលោក ។ ជាយទ្វីបនៅប្រទេសកម្ពុជាក៏មានក្រុម ហ៊ុនអន្តរជាតិកំពុងចុះឈ្មោះរដេញថ្លៃធ្វើអាជីវកម្មដែរ។ ដូចជាក្រុមហ៊ុនប្រេងអាមេរិក ឆេវ៉ុន Chevron) កំពុងរុករកប្រេងកម្ពុជានឹងចាប់ផ្ដើមផលិតប្រេងនៅឆ្នាំ 2011 ខាងមុខនេះ។

## ២.២. ធនធានរ៉ែដទៃទៀត

នៅក្នុងទឹកសមុទ្រគេបានរកឃើញអង្គធាតុទោលចំនួនប្រមាណ ក្នុងចំណោមអង្គធាតុទាំងនេះដែលគេស្គាល់ទាំងអស់។ ប៉ុន្តែអំបិលដែលមានភាគលើសគេក៏ សូដ្យូមស៊ុលផាត មាញ៉េស្យូមស៊ុលផាត កាល់ស្យូមស៊ុលផាត និងប៉ូតាស្យូមស៊ុលផាត។ ជាមួយគ្នានេះគេបានដឹងថា ទឹកសមុទ្រទាំងអស់ពួកមាសរហូតដល់ទៅ ១០ពាន់លានតោនឯណោះ។ សព្វថ្ងៃ គេបានធ្វើអាជីវកម្មរ៉ែអំបិលសម្រាប់ធ្វើជាអាហារ ។ ក្រៅពីប្រើប្រាស់ក្នុងអាហារ អំបិលកំពុងក្លាយជារូបធាតុដើមសម្រាប់ឧស្សាហកម្មគីមី ដែលកំពុងលូតលាស់។ ក្នុងរោងចក្រគីមីខ្លះ បានចម្រាញ់យកផូស្វាត ពីទឹកសមុទ្រដើម្បីធ្វើជាជីសម្រាប់កសិកម្មទៀតផង ។

ការរុករកពីក្រោមដីបាតសមុទ្រ មិនមែនជាការងាយស្រួលឡើយ ព្រោះវាទាមទារឱ្យប្រើបច្ចេកទេសថ្មីៗនិងចំណាយទុនច្រើនទើបអាចធ្វើបាន។ នៅលើទ្វីបឬជាយទ្វីប ដរាបណាមនុស្សនៅតែអាចរករ៉ែយកមកប្រើប្រាស់ គេពិតជាពុំយកចិត្តទុកដាក់ទៅលើកំណាប់រ៉ែដែលអាចមាននៅបាតសមុទ្រជ្រៅៗឡើយ។ ការពិត តំបន់នេះមានផ្ទៃធំទូលាយណាស់ ហើយពិតជាមានកំណាប់រ៉ែសំខាន់ៗមិនតិចទេ ។ យើងអាចនិយាយបានថា បាតសមុទ្រជ្រៅៗជា "កំណាប់រ៉ែបម្រុង" ចុងក្រោយរបស់ភពផែនដី មុននឹងអ្នកភពផែនដីឈានទៅធ្វើអាជីវកម្មរ៉ែនៅភពផ្សេងៗដែលនៅជិតផែនដីយើងជាងគេ។ បើទោះបីជួបការលំបាកយ៉ាងណាក៏ដោយ ក៏គេបានសាកល្បងជីកយករ៉ែសំណប៉ាហាំងនៅតាមឆ្នេរខាងកើតកោះស៊ូម៉ាត្រា ។ នៅក្នុង សមុទ្រជ្រៅមុខដីសណ្ដទន្លេមីស៊ីស៊ីពី និងទីក្រុងបាគូ គេជីកយកបានប្រេងកាត ។ ការស្រាវជ្រាវបានឱ្យដឹងថា នៅបាតសមុទ្រមានលោហៈមានតម្លៃជា ច្រើនដូចជា គីកែល គូបាល់ ស្ពាន់ជាដើម។ ចាប់ពីឆ្នាំ ចាប់ពីឆ្នាំ1982មក គេបានកំណត់ថា ធនធានបាតសមុទ្រ ក្នុងដែនទឹកអន្តរជាតិទាំងអស់ជាសម្បត្តិបេតិកភណ្ឌរួមរបស់មនុស្សជាតិនៅលើភពផែនដី ។

## ៣. សកម្មភាពតំបន់ឆ្នេរសមុទ្រ

សព្វថ្ងៃ តំបន់ឆ្នេរកំពុងក្លាយជាតំបន់ទាក់ទាញយ៉ាងខ្លាំងនៃសកម្មភាពសេដ្ឋកិច្ច ។ ក្រៅពីសកម្មភាព

នៃសាទ ថ្ងៃ តំបន់ខ្មែរកំពុងទៀតដែលអ្នកវិនិយោគទុនលើពិភពលោកកំពុងយកចិត្តទុកដាក់ គ ឧស្សាហកម្ម និងទេសចរណ៍ ។

## ៣.១. តំបន់ឧស្សាហកម្ម

ប្រទេសដែលគេបានសម្លឹងទៅឃើញថា បានយកទំនាបឆ្នេរធ្វើជាមូលដ្ឋានសំខាន់របស់ ឧស្សាហកម្ម ខ្លួននោះ៖ គឺប្រទេសជប៉ុន ។

### ក. ប្រទេសជប៉ុន

ប្រទេសជប៉ុនជាកម្រងកោនចំនួន 1042 ដែលនៅក្នុងនោះមានការធំៗចំនួនបួន គឺហុងស្ស៊ូ ហុកកៃដូ គ្យូស៊ូ និងស៊ីគុកូ។ ប្រទេសជប៉ុនមានផ្ទៃដីសរុប 377 829 km² ក្នុងនោះ 16% ជាទំនាបឆ្នេរ ។ ប្រទេសជប៉ុនមានប្រជាជនចំនួន 128.085 លាននាក់(2005)។ 80% នៃប្រជាជនជប៉ុនរស់នៅ តាមទំនាបឆ្នេរ ដែលលាតសន្ធឹងតាមឆ្នេរប៉ាស៊ីហ្វិកប្រវែង 1200 km ពីក្រុងតូក្យូមកគីតាគ្យូស៊ូ ជាតំបន់ដែលមានប្រជាជនរស់នៅកុះករខ្លាំង និងជាតំបន់ឧស្សាហកម្មនៃប្រទេសជប៉ុន។ តំបន់នេះផ្តល់ 85% នៃផលទុនក្នុងស្រុករបស់ជប៉ុន ។

ឧស្សាហកម្មផ្អែកលើកំពង់ផែសមុទ្រ ប្រទេសជប៉ុន ជាប្រទេសតែមួយគត់ដែលបានកសាងឧស្សាហកម្មដ៏ធំមួយដោយគ្មានធនធានធម្មជាតិនៅលើដែនដីរបស់ខ្លួន(រូបធាតុដើមនិងថាមពល)។ ប្រការនេះហើយដែលប្រទេសជប៉ុនត្រូវស្ថិតនៅក្នុងស្ថានភាពបង្ខំចិត្តបើកចំហសេដ្ឋកិច្ចយ៉ាងទូលំទូលាយទៅរកក្រៅប្រទេស (សម័យមុីអុីយិ)។ ដូចនេះ ប្រទេសជប៉ុនត្រូវនាំចូលទាំងស្រុង ដូចជា រូបធាតុដើម (រ៉ែដែក រ៉ែបុកស៊ីត រ៉ែម៉ង់កាណែស....)។ ដើម្បីឱ្យឧស្សាហកម្មរបស់ខ្លួនដំណើរការបាន ជប៉ុនត្រូវបង្ខំចិត្តនាំចូលអុីដ្រូកាបួដែលមានបរិមាណដ៏សន្ធឹកសន្ធាប់គឺជាង250លានតោនក្នុងមួយឆ្នាំៗ ក្នុងនោះ60% មកពីមជ្ឈិមបូព៌ា ។

ដែលគេនិយមសាងសង់រោងចក្រឧស្សាហ កម្មធំៗនៅក្បែររូបធាតុដើម បង្កើតបានជាទីក្រុងរ៉ែ ប្រទេសជប៉ុនសម្លឹងឃើញទំនាបឆ្នេរនិងកំពង់ផែ សមុទ្រជាមូលដ្ឋានសំខាន់និងជាដង្ហើមស្លាប់រស់សម្រាប់ឧស្សាហកម្មរបស់ខ្លួន ព្រោះនថា" ដើម្បីរស់ជប៉ុន ត្រូវនាំចេញនាំចូល" ។ ដូចនេះទាំងឧស្សាហកម្មធុនធ្ងន់ ទាំងឧស្សាហកម្មធុនស្រាលគ្រប់ប្រភេទ មិន អាចនៅឆ្ងាយពីតំបន់ឆ្នេរបានឡើយ ព្រោះវាត្រូវការចាំបាច់នូវរូបធាតុដើមនិងថាមពលនាំចូល ។ ការតាំងទីនៃឧស្សាហកម្មជប៉ុននៅតំបន់ឆ្នេរ វាអាចជាបញ្ហាដាច់ណាត់ពីកត្តាក្រៅថ្នាក់ជាតិនិង មហាពហុជាតិមិនមែនជាកត្តាក្នុងស្រុកតែឯកឯងទេ ។

នៅក្នុងសម័យ "កំណើនសេដ្ឋកិច្ចខ្ពស់" (La Haute Croissance) ពាក្យថា កុំប៊ីណា (Combinat) មានន័យថា តំបន់ឧស្សាហកម្មទំនាបឆ្នេរ ដែលបានសាងសង់នៅលើដីចាក់បំពេញលើផ្ទៃទឹកមុខឆ្នេរ(ប៉ុលឌែរ)។ កុំប៊ីណាជប៉ុន គឺជាពហុឧស្សាហកម្មមួយដែលរដ្ឋនិងសហគ្រាសឯកជនធំៗសហការគ្នាយ៉ាងស្អិតរមួតបំផុត។ ក្នុងបរិបទសេដ្ឋកិច្ច រោងចក្រឧស្សាហកម្មធំៗទំនើបបំផុតនេះ៖ ប្រើទុនចម្រុះ៖ រដ្ឋនិងឯកជនដ៏សន្ធឹកសន្ធាប់ ដើម្បីកែច្នៃប្លែងភាពរូបធាតុដើមមួយមុខ ឬច្រើនមុខដូចជា រោងចក្រ ដែកថែប រោងចក្រគីមីប្រេងកាត ។ នៅក្បែរកុំប៊ីណាទាំងនេះ គេបានបង្កើតឧស្សាហកម្មធុនស្រាល យ៉ាងច្រើនគ្រប់ប្រភេទទៀតនៅតាមបណ្តោយឆ្នេរ ដែលមានទីក្រុងធំៗប្រជាជនរស់នៅកុនករបំផុត ក្នុងពិភពលោក ។ គេបានសាងសង់កំពង់ផែធំៗទំនើបបំផុត ដែលជាកម្មសិទ្ធិឯកជនសម្រាប់រ៉ាប់រងគ្រប់ការងារទាំងអស់។

**ខ. ប្រទេសឧស្សាហកម្មលូតលាស់ខ្លាំង**

តំបន់ឆ្នេរទទួលយកសកម្មភាពថ្មីៗថែមទៀតក្នុងវិស័យសេដ្ឋកិច្ច ដូចជានៅអឺរ៉ុបបានចេញពីទីក្រុងរ៉ែមកឆ្នេរសមុទ្រវិញ លោហកម្មសហរដ្ឋអាមេរិក ព្រោះនៅទីនោះគេបានរូបធាតុដើមមានតម្លៃថោក ម្យ៉ាងទៀតសន្តិសុខផ្លូវសមុទ្រអន្តរជាតិមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សេដ្ឋកិច្ចពិភពលោក។ ឯក្រោយខ្នងនៃសមុទ្រក្លាយជាយុទ្ធសាស្ត្រសម្រាប់ដឹកជញ្ជូនពិសេសអ៊ីដ្រូកាបួ ។ ក្នុងក្របខ័ណ្ឌសកលភាវូបនីយកម្មសេដ្ឋកិច្ចសំខាន់ណាស់ ផ្លូវសមុទ្រមិនត្រូវបានរាំងទេ ។ សកលភាវូបនីយកម្មសេដ្ឋកិច្ចបានពង្រឹង យ៉ាងខ្លាំងក្លាឧស្សាហកម្មកំពង់ផែ។ ក្នុងបំណងបន្ថយតម្លៃផលិតកម្ម គេបានបង្កើតតំបន់ឧស្សាហកម្មកំពង់ផែ(ZIP) ដើម្បីទទួលរូបធាតុដើម ហើយប្លែងភាពនៅនឹងកន្លែងសម្រាប់នាំចេញ។ បើទីកន្លែងចង្អៀតគេចាក់ដីបំពេញក្នុងសមុទ្រ ដើម្បីឆ្លើយតបតាមតម្រូវការ។ តំបន់ឧស្សាហកម្មកំពង់ផែនេះ កើតមាននៅគ្រប់កន្លែងកំពង់ផែ សមុទ្រក្នុងប្រទេសជប៉ុន សហរដ្ឋអាមេរិក អឺរ៉ុប និងចិន។ សកម្មភាពឧស្សាហកម្មកំពង់ផែ មានច្រើនណាស់ពីឧស្សាហកម្មធុនធ្ងន់ច្រើនជាងគេ គឺរោងចក្រដែកថែបលើទឹកមាននៅ កាវ៉ាសាគី (តូក្យូ) នៅផុសស្មែ នៅ ដង់គែក។ ឧស្សាហកម្មគីមី និងគីមីប្រេងកាត ក៏លាតសន្ធឹងលើជាយទ្វីបដូចជានៅផុសស្មែ ឡាវ៉ឺរ៉ា នៅអង់វែ នៅសិង្ហបុរី នៅឈូងសមុទ្រជប៉ុន(សមុទ្រខាងកើត) នៅកាលវ៉េស្តុន និងករពុសគ្រីស នៅសហរដ្ឋអាមេរិក សំណង់មេកានិក (រថយន្ត សំណង់នាវា) មាននៅភូមិភាគខាងត្បូងប្រទេសកូរេ នៅអ៊ុលសាន និងនៅក្នុងសមុទ្រជប៉ុន ។

**៣.២. តំបន់ទេសចរណ៍**

**ក. ឆ្នេរជាតំបន់ទាក់ទាញទេសចរ**

សព្វថ្ងៃនេះ តំបន់ទេសចរណ៍ឆ្នេរកំពុងពេញនិយមខ្លាំងក្នុងចំណោមសង្គមមនុស្ស ដែលចូលចិត្តដើរកំសាន្ត និងលំហែកាយនាមាត់សមុទ្រ។ អ្នកទេសចរភាគច្រើនចូលចិត្ត និងស្រលាញ់តំបន់ឆ្នេរ ព្រោះនៅទីនោះធម្មជាតិបានបង្កើតទេសភាពពិសេសម្យ៉ាងដែលពួកអង់គ្លេសាក់សុងប្រសិទ្ធនាមថា "4S" (sca សមុទ្រ sunព្រះអាទិត្យ sand ខ្សាច់ surf រលក)។ កត្តាខាងលើនេះជំរុញឱ្យមានការ រៀបចំតំបន់ទេសចរណ៍ដែលសម្បូរពន្លឺព្រះអាទិត្យ និងសមុទ្រក្តៅនៃអាងមេឌីទែរ៉ានេ នៅរដ្ឋផ្លរីត និងនៅកោះទាំងឡាយនៃតំបន់ត្រូពិច។

ទេសចរណ៍លើឆ្នេរមានកំណើតតាំងពីសតវត្សទី19ម្ល៉េះ គ្រាន់តែមានតិចតួចតាមឆ្នេរអាស៊ី នៃប្រទេសបារាំង(1834)នៅប្រទេសអេស្ប៉ាញ នៅភាគខាងត្បូងនៃប្រទេសអង់គ្លេស។ កាលនោះមាន តែអ្នកមាននិងអភិជនទេដែលមានសំណាងបានទៅកំសាន្តនៅទីនោះ។ ប៉ុន្តែចាប់ពីក្រោយសង្គ្រាមលោកលើកទី 2មក ស្ថានភាពសង្គមសេដ្ឋកិច្ចមានលក្ខណៈល្អប្រសើរ(ប្រាក់បៀវត្សខ្ពស់ ឈប់សម្រាក មានប្រាក់បៀវត្ស) ផ្នែកហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរីកលូតលាស់ ទើបភាពអ៊ូអរនៃតំបន់ឆ្នេរចាប់កម្រើកឡើងជាមួយនិងនានាភាពផ្នែកបដិសណ្ឋារកិច្ចដូចជា សណ្ឋាគារ ផ្ទះសំណាក់។ល។

ទេសចរណ៍ឆ្នេរបង្កើតវិសមភាពធនធានរវាង ប្រទេសអ្នកមាននិងប្រទេសក្រ ប្រទេសលោកខាងត្បូងមានភ័ព្វសំណាងបានរៀបចំទេសចរណ៍ប្រភេទនេះបានច្រើន ដោយបានទុនវិនិយោគពីក្រុមហ៊ុនពហុជាតិទេសចរណ៍មកពីប្រទេសអ្នកមានដូចនៅ សមុទ្រការ៉ាអ៊ីប ឬអាហ្វ្រិកនិរតី។ ប្រទេសទាំងនេះបានទាក់ទាញភ្ញៀវទេសចរយ៉ាងច្រើន អ្នកមាននិងទទួលបានប្រាក់ចំណូលសន្ទឹកសន្ធាប់។ លុះទាប់ពីទសវត្សរ៍ឆ្នាំ (1950-1960) វិស័យទេសចរណ៍នេះយ៉ាងខ្លាំងក្លា មានសហគ្រាសសាធារណៈ ឬឯកជនបុគ្គល ។

ចាប់ពីពេលនោះមកលំហទេសចរណ៍ឆ្នេរធំៗខ្នាតពិភពលោកត្រូវបានបង្កើតឡើង សមុទ្រមេឌីទែរ៉ាណេ ជាទីប្រសព្វនៃកត្តាអនុគ្រោះដូចជា ព្រះអាទិត្យ ខ្សាច់ និងកោះទាំងឡាយ(អឺរ៉ុប) ។

**ខ. តំបន់ធំៗនៃទេសចរណ៍ឆ្នេរក្នុងពិភពលោក**

គេប៉ាន់ស្មានថា មានអ្នកទេសចរចំនួន 2000 លាននាក់នៅក្នុងពិភពលោក ។ ជិត 460 លានន ត្រូវបានទាក់ទាញ ដោយតំបន់ទេសចរណ៍ឆ្នេរធំចម្បងពីរ គឺសមុទ្រមេឌីទែរ៉ាណេអឺរ៉ុបនិងសមុទ្រព្យ ខែរ៉ាណេអាមេរិក (ឈូងសមុទ្រម៉ិកស៊ិកនិងសមុទ្រការ៉ាអ៊ីប) ។ គេអាចបញ្ចូលផងដែរនូវឆ្នេរ ចាំស៊ីហ្វិកនៃអាមេរិកខាងជើង កោះហាវ៉ៃ និងកោះប៉ូលីណេស៊ី ឆ្នេរនៃអាត្លង់ទិកខាងជើង ។

**១.សមុទ្រមេឌីទែរ៉ាណេអឺរ៉ុប**

ជាតំបន់ឆ្នេរខ្សាច់ធំជាងគេនៅទ្វីបអឺរ៉ុប ដោយរាប់បញ្ចូលកោះទាំងឡាយក្នុងសមុទ្រជាយផង (ក្នុងសមុទ្រអាទ្រីយ៉ាទឹក សមុទ្រអេសេ សមុទ្រខ្មៅ) ។ ទឹកសមុទ្រក្តៅឧណ្ហៗ រស្សោនរដូវក្តៅនិងស្ងួត ទេសភាពច្រើនពណ៌គួបផ្សំជាមួយតំបន់ប្រវត្តិសាស្ត្រនិងសិល្បៈផងនោះ បានទទួលស្រូបយកភ្ញៀវ ទេសចរយ៉ាងហូរហៀរលើឆ្នេរ។ ប្រទេសអេស្ប៉ាញ(លើសពី50លាននាក់ទេសចរបរទេស) និងប្រទេសអ៊ីតាលីជាមួយប្រទេសបារាំងផងដែរជាយក្សធំៗទាំងបីនៃប្រទេសទេសចរនៅមេឌីទែរ៉ាណេ រត់មុខប្រទេសក្រិកនិងអតីតយូហ្គោស្លាវី ។

**២.សមុទ្រមេឌីទែរ៉ាណេអាមេរិក**

ជាស្ថានសួគ៌លោកីយថ្មីមួយទៀតនៃទេសចរណ៍ឆ្នេរដែលមាន 3S (Sun Sea Sand) ជាលម្អ ។ បន្ថែមលើនេះទៀត មានកម្តៅថ្ងៃ និងភាពស្ងួតនៃហេមន្តរដូវ និងភ្លៀងរលឹមស្រិចៗឯនេះបន្តិចឯណោះបន្តិច។ ភាគខាងជើងនៃឧបទ្វីបផ្លរីត ដែលជាគូប្រជែង និងរដ្ឋកាលីផរនី(ជាប់ចំណាត់ថ្នាក់លេខ១ក្នុងសហរដ្ឋ) ស្រូបបានទេសចរ30លាននាក់ក្នុងមួយឆ្នាំ "គឺជារដ្ឋព្រះអាទិត្យ" ជាមួយនឹងឆ្នេរខ្សាច់ប្រវែង13500km ព្រមទាំងមានឧទ្យានធម្មជាតិ សណ្ឋាគារ រាប់ពាន់និងជាង5000ម៉ូតែល។

ឯចំណែកឆ្នេរម៉ិកស៊ិកវិញ សន្ទះដីឆ្នេរកង់គូនត្រូវបានរៀបចំជាតំបន់ទេសចរណ៍ចាប់ពីឆ្នាំ1970 ដែលស្ថិតនៅចន្លោះសមុទ្រការ៉ាអ៊ីបនិងកោះបឹងផ្កាថ្ម។ ទាំងអង់ទីតូចទាំងអង់ទីធំដែលសម្បូរទៅដោយស្ថានីយ៍តូចៗជាច្រើន និងកំពង់ផែសំចតនាវាចម្បាំងក្រិក បារាំង អ៊ីតាលី អាមេរិក ដែលឆ្លងចុះឆ្លងឡើងក្នុងសមុទ្រការ៉ាអ៊ីប បង្កើតបានទេសភាពប្លែកៗទាក់ទាញភ្នែកអ្នកទេសចរ ។

**គ. តំបន់ផ្សេងៗទៀត**

នៅឆ្នេរនៃប្រទេសលោកខាងត្បូង ដែលមានឈ្មោះល្បីៗនៅអាស៊ី(ស្រីលង្កា ថៃ ហ្វីលីពីន) នៅអាហ្វ្រិក (សេណេហ្គាល់ កេនញ៉ា តង់សានី) ឬមហាសមុទ្រឥណ្ឌា (កោះសេសែល កោះម៉ូរីស) ដែលនៅទីនោះតម្លៃស្នាក់នៅមធ្យម គួបផ្សំនិងតម្លៃសំបុត្រយន្តហោះថោក (ការប្រកួតវិស័យទេសចរណ៍)ទេសចរបាននាំមកនូវរូបិយប័ណ្ណយ៉ាងច្រើន និងបង្កើតការងារសម្រាប់ប្រទេសទាំងនោះ។ ប៉ុន្តែក៏អាចមានលទ្ធផលអវិជ្ជមានចំពោះសង្គមផងដែរ គឺបញ្ហាគ្រឿងញៀន និងការជួញដូរផ្លូវភេទ ពិសេសនៅអាស៊ីខាងត្បូង ។

**៤. បញ្ហាសមុទ្រ**

សមុទ្រនិងមហាសមុទ្រជាប្រភពដ៏មហាសាលនៃធនធានធម្មជាតិផ្នែកជីវសាស្ត្រ និងផ្នែករ៉ែ ដែលសម្បូរហូរហៀរ។ សព្វថ្ងៃប្រភេទខាងលើកំពុងរងនូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរពីសកម្មភាពរបស់មនុស្សនិងបាតុភូត

ធម្មជាតិមួយចំនួន។ បញ្ហាដែលពិភពលោកកំពុងព្រួយបារម្ភខ្លាំងនោះគឺការ ធ្វើអាជីវកម្មនេសាទហួសហេតុលើសមុទ្រ និងមហាសមុទ្រដែលជាបេតិកភណ្ឌរួមរបស់មនុស្សជាតិ។

## ៤.១. គ្រោះថ្នាក់បណ្តាលមកពីការនេសាទហួសហេតុ

ក្នុងពេលថ្មីៗនេះ របាយការណ៍អង្គការចំណីអាហារ និងកសិកម្ម (FAO) របស់អង្គការសហប្រជាជាតិបានឱ្យដឹងថា70% នៃសន្និធិត្រីពិភពលោកកំពុងចុះខ្សោយឬឈានដល់កម្រិតខ្សោយ ។ គួរឱ្យកត់សម្គាល់ផងដែរថា ប្រភេទត្រីដែលតែងតែបានទិន្នផលខ្ពស់ត្រូវបានគេធ្វើអាជីវកម្មហួសហេតុខ្លាំង ជាងគេ ប្រការនេះអាចឈានទៅរកការបាត់បង់ប្រភេទពូជល្អៗមិនខាន ។ ម្យ៉ាងទៀតក្នុងចំណោម កន្លែងនេសាទចំនួន១៧ លើពិភពលោកមាន៩កន្លែងត្រូវស្រុតចុះយ៉ាងខ្លាំងដឹងចំនួន៤កន្លែងទៀត ត្រូវបានចាត់ទុកថាលែងមានតម្លៃសេដ្ឋកិច្ច។ ជាច្រើនឆ្នាំកន្លងមកនេះសហគមន៍អ្នកនេសាទពិភព លោកបានស្រែកប្រកាសភាពអាសន្នពីបញ្ហានេះ ។ ពួកគេធ្លាប់មានជីវភាពធូរធារក៏ព្រោះតែតំបន់នេសាទរបស់គេ ប៉ុន្តែបច្ចុប្បន្ននេះប្រាក់ចំណូលរបស់គេចុះថយយ៉ាងខ្លាំងគួរឱ្យបារម្ភដោយសារកត្តា ជាច្រើនដែលជាមូលហេតុ ។

### ក. សកម្មភាពមនុស្ស

តម្រូវការចំណីអាហារកាន់តែកើនសម្រាប់មនុស្ស ដោយសាររបកគំហើញនៃពួកបុរាណវត្ថុវិទ្យាគេបានដឹងថា មនុស្សចេះបរិភោគត្រីតាំងពីសម័យបុរេប្រវត្តិ។ ក្នុងសំណល់កម្ទេចកម្ទីម្ហូប អាហារជំនាន់ដើមដែលបុរាណវត្ថុវិទូបានរកឃើញនៅឆ្នេរប្រទេសស្កង់ឌីណាវ ប្រទេសដទៃទៀតនៅ អឺរ៉ុបមានប្រទេសបារាំងអ៊ីតាលីជាដើម និងនៅប្រទេសប្រេស៊ីល គុយបា សហរដ្ឋអាមេរិក ផ្នែកខាងកើតមានសំបកក្តាម បង្កងសមុទ្រ (ឆ្អឹងត្រី ហារ៉ង់ ត្រីតុង ត្រីម៉ង់) សំបកខ្ចៅខ្យង ។ នៅគ្រប់អរិយធម៌ បុរាណមនុស្សសុទ្ធសឹងចេះនេសាទ ចេះបរិភោគត្រី ចេះបរិភោគគ្រឿងផ្សំពីត្រី ដូចជាទឹកត្រី រ៉ូម៉ាំង ហៅថា ការ៉ុម (Garum) ។ នៅអឺរ៉ុបក្នុងមជ្ឈិមសម័យគេដឹងថាការបរិភោគត្រីមានច្រើនឡើងជាងសម័យមុនៗ។ នៅចុងមជ្ឈិមសម័យនិងសម័យទំនើបការបរិភោគត្រីកាន់តែកើនឡើងថែមទៀត។ មកដល់សព្វថ្ងៃនេះចំនួនមនុស្សកាន់តែកើនឡើងជាលំដាប់ តម្រូវការត្រីជាអាហារក៏កាន់តែខ្ពស់ឡើងដែរ ។ នៅប្រទេសជប៉ុន ប្រជាជនម្នាក់បរិភោគត្រី 50kg ក្នុងមួយឆ្នាំ។ ជនជាតិជប៉ុននិយមចូលចិត្ត ត្រីជាអាហារ 40% នៃប្រូតេអ៊ីនសត្វបានមកពីផលផលសមុទ្រ ។

តម្រូវការចំណីសត្វ ៖ ត្រីមិនត្រឹមតែជាអាហារសម្រាប់មនុស្សទេ សហគ្រាសឧស្សាហកម្មធំៗ បានតម្រង់ទិសទៅរកផលិតកម្មចំណីសត្វថែមទៀត។ ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងពិភពលោក គេសង្កេតឃើញផលិតកម្មត្រីចាប់ពីឆ្នាំ 1950 មក មានសន្ទុះយ៉ាងខ្លាំង 26 លានតោន (1955) ទៅ 98លានតោន (1994) ពីឆ្នាំ 1950 ដល់ 1970កំណើនខ្លាំង។ ចាប់ពីឆ្នាំ1970 មកយឺតៗវិញរហូតដល់ឆ្នាំ 1990 នៅទ្រឹង ហើយបច្ចុប្បន្ននេះ ផលិតកម្មត្រីស្ថិតនៅជុំវិញ៨៤លានតោន ការនៅទ្រឹងយូរឆ្នាំនេះបញ្ជាក់ឱ្យដឹងថា សមុទ្រកើតជំងឺធ្ងន់ធ្ងរបណ្តាលពីការ នេសាទហួសហេតុ ។

តម្រូវការពង្រីកសមត្ថភាពចាប់ត្រី៖ កងនាវានេសាទពិភពលោក (ទាំងនាវាតូចទាំងនាវាធំ) បានកើនឡើងពី 585 000 នាវានៅឆ្នាំ1970 ទៅ 1.2 លាននាវានៅឆ្នាំ 1990 ។ បច្ចុប្បន្ននេះមាននាវាចំនួន 3.5លាន។ ជាមួយគ្នានិងឧបករណ៍ចាប់ត្រីទំនើបនិងនាវា-រោងចក្រធំៗរបស់ប្រទេសអ្នកមានគេបាន ដណ្តើមគ្នាចាប់ត្រីក្នុងដែនសមុទ្រអន្តរជាតិបង្កើតបានជាទំនាស់ដែលអាចក្លាយទៅជាសង្គ្រាមដូចជា សង្គ្រាមត្រីមរុយ រវាង

អង់គ្លេសនិងប្រទេសអ៊ីស្លង់ ការបិទផ្លូវនាវាចរណ៍រវាងប្រទេសបារាំងនិង ប្រទេសអេស្ប៉ាញ និង សង្គ្រាមត្រីតួបូ (Turbot) រវាងប្រទេសអេស្ប៉ាញនិងប្រទេសកាណាដាជាដើម ។ តំបន់នេសាទសំខាន់ៗដែលបានក្លាយជាការវិវាទរវាងប្រទេសនេសាទធំៗមានដូចជា៖

- **តំបន់អាត្លង់ទិកនិរតី** ៖ ច្បាប់ប្រទេសកាណាដាហាមឃាត់នាវានេសាទ បរទេសទាំងអស់មិនឱ្យចូលនេសាទក្នុងដែនសមុទ្រ អន្តរជាតិនៅជិតប្រទេសខ្លួនដោយយកលេសថា ចុះខ្សោយសន្និធិត្រី ។
- **តំបន់អាត្លង់ទិកភាគឦសាន** ៖ ប្រទេសអេស្ប៉ាញ បារាំង អង់គ្លេស ប្រឈម មុខដាក់គ្នាយ៉ាងតឹងតែងបំផុតពីវិធីនេសាទ ប្រទេស អេស្ប៉ាញនេសាទបែបប្រពៃណី( ប្រើដងសន្ទូច...) រីឯប្រទេសបារាំងនិងអង់គ្លេសប្រើមងដែលគ្រោះថ្នាក់ ដល់ឋានប្រព័ន្ធ ។
- **តំបន់ប្រទេសហុងឌូរ៉ាស់** ៖ បញ្ហាប្រទេសនេសាទតាមឆ្នេរប្រឆាំងនឹង ការកាប់ព្រៃកោងកាងដើម្បីចិញ្ចឹមបង្គារបស់ប្រទេស ហុងឌូរ៉ាស់ ។
- **តំបន់ប្រទេសម៉ារ៉ុក៖** សហភាពអឺរ៉ុបនិងប្រទេសម៉ារ៉ុក ប្រឈមមុខដាក់គ្នាពីបញ្ហាការចាប់ត្រីនៅត្រឹមតែ 50%។
- **តំបន់សេណេហ្គាល់៖** អ្នកនេសាទប្រទេសសេណេហ្គាល់ប្រឆាំងនឹងសហភាពអឺរ៉ុបដែលបានប្រើនាវានេសាទ និងឧបករណ៍ទំនើបៗដែលនាំឱ្យឧបករណ៍នេសាទប្រទេសសេណេហ្គាល់លែងមានប្រសិទ្ធភាពចាប់ត្រី ។
- **តំបន់គូរីល៖** តំបន់នេះសម្បូរក្តាមណាស់ ជាកន្លែងប្រឈមមុខដាក់គ្នារវាងកងរក្សាព្រំដែនរុស្ស៊ីនិងជប៉ុន ។ ការចុះអន់ថយនៃធនធានត្រីមិនមែនមកតែពីការនេសាទទេ គឺមកពីសកម្មភាពប្រយោលដូចជា ការបំពុលទឹកសមុទ្រវាជាបញ្ហាធ្ងន់ធ្ងរមួយទៀតដែលបំផ្លាញជីវិតសត្វសមុទ្រ ។

សមុទ្រនិងមហាសមុទ្រត្រូវបានបំពុលរាល់ថ្ងៃ ៖ នៅពេលសារធាតុពុលជ្រាបចូលទៅក្នុងទន្លេ ស្ទឹងនោះ វាអាចនាំយកទឹកពុលទៅកាន់សមុទ្រធ្វើឱ្យទឹកសមុទ្ររងនូវជាតិពុលដែរ ។ យ៉ាងហោចណាស់មានចំនួន 80% នៃសារធាតុពុលសមុទ្រដែលបានមកពីទ្វីប។ ក្រៅពីនេះសារធាតុពុលផ្សេងៗ ទទួលរងសកម្មភាពដោយផ្ទាល់នៅក្នុងមហាសមុទ្រតែម្តង ។ សារធាតុចូលទាំងនោះគ្រោះថ្នាក់ខ្លាំងណាស់ ព្រោះវាបំផ្លាញឋានប្រព័ន្ធសមុទ្រ ក្រៅពីសកម្មភាពមនុស្ស ជាតុភូតធម្មជាតិក៏បានចូលរួមកាត់បន្ថយបរិមាណត្រីដែរ ។

**ខ. បាតុភូតធម្មជាតិ (បាតុភូតអែលនីញ៉ូ)**

តាមធម្មតាខ្សែទឹកត្រជាក់ពីតំបន់ប៉ូលអង់តាកទិចដែលជាខ្សែទឹកជ្រៅមកដល់ឆ្នេរប្រទេសស៊ីលីត្រូវងើបឡើងលើ។ ខ្សែទឹកត្រជាក់នេះបាននាំមកជាមួយនូវប្លង់តុង ចំណីគ្រប់ប្រភេទនិងកូនត្រី(អង់ស្វា)ដ៏សន្ធឹកសន្ធាប់ទៀតផង ។ ហេតុនេះហើយបានជានៅតាមឆ្នេរសមុទ្រប្រទេសស៊ីលី ពេរ៉ូ អេក្វាទ័រ ក្លាយជាតំបន់នេសាទដ៏ល្បីល្បាញក្នុងតំបន់ប៉ាស៊ីហ្វិកខាងត្បូង។ វត្តមានអែលនីញ៉ូក្នុងតំបន់រាំងខ្សែទឹកត្រជាក់មិនឱ្យងើបឡើងបាន ជាហេតុនាំឱ្យមច្ឆជាតិនិង សត្វសមុទ្រផ្សេងៗខ្វះចំណីអាហារ ។ បរិមាណត្រីថយចុះការនេសាទក៏មិនបានទទួលផលល្អ ។ បាតុភូតនេះតែងកើតមានជាញឹកញយរៀងរាល់ 3 ទៅ 4 ឆ្នាំម្តង ។ ផ្ទុយទៅវិញ មនុស្សនិងបាតុភូធម្មជាតិដូចបានរៀបរាប់ខាងលើ ជាតួអង្គសំខាន់ពីរដែលបង្កការវិនាសធនធានជលផលសមុទ្រ។ ជារឿយៗគេសង្កេតឃើញថាបាតុភូតធម្មជាតិតែងកើតមានយូរៗម្តង។ ផ្ទុយ ទៅវិញមនុស្សទេដែល

បានបំផ្លាញជាប្រចាំតាមរយៈ "ការចាប់ត្រីដោយខ្វះវិចារណញ្ញាណនិង បំពុលទឹកសមុទ្រដោយខ្វះមនសិការ។ សកម្មភាពខ្វះការទទួលខុសត្រូវបែបនេះបាននាំមកនូវផលអាក្រក់ មានជា អាទិ៍ដូចតទៅៈ

- ប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកលើការនេសាទទទួលផលប៉ះពាល់ខ្លាំងជាងគេ គឺកម្មករនេសាទ កម្មកររោងចក្របាត់បង់ការងារ បាត់បង់ប្រាក់ចំណូល។
- សហគ្រាសនេសាទ សហគ្រាសឧស្សាហកម្មអាហារសម្រាប់មនុស្សនិងសត្វត្រូវផ្អាកសកម្មភាព ខ្ចុំឈប់ដំណើរការ ។
- ប្រជានេសាទនៃប្រទេសក្រីក្រដែលមានចំនួន ១០% នៃអ្នកនេសាទពិភពលោកត្រូវប្រឈមមុខនិងការបាត់បង់ចំណូល ។

ក្រៅពីនេះពិភពលោកទាំងមូលត្រូវប្រឈមនឹងបញ្ហាកង្វះអាហារ ទុរភិក្ស ការបរិភោគមិន គ្រាប់គ្រាន់ ជំងឺអាសន្នរោគ...។ បើពុំមានវិធានការទាន់ពេលវេលាទេ ពិភពលោកទាំងមូលត្រូវបាត់បង់សន្តិវិត្រីសម្រាប់ជាអាហារចាំបាច់ ហើយជាមួយគ្នានេះលទ្ធភាពនៃការស្តារត្រីឡើងវិញក៏ត្រូវខកខានដែរ។

វិធានការណ៍សំខាន់ៗ មានដូចជាៈ

- ប្រភេទមួយចំនួនទាមទារបង្កើតច្បាប់អន្តរជាតិ កំណត់ដែនសមុទ្រ និងអន្តរជាតិ តាមរយៈច្បាប់នេះ៣៦% នៃបាតសមុទ្រត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់ប្រទេសនីមួយៗ។
- អង្គការមួយចំនួនរបស់អង្គការសហប្រជាជាតិ (អ.ស.ប)បានបង្កើតកម្មវិធីអភិរក្ស ពូជត្រីនឹងសត្វសមុទ្រប្រភេទខ្លួនដែលខិតទុកជូតត្រីបាឡែន ភេ អណ្តើក) ហើយនឹងលើកទឹកចិត្តឱ្យមានការចិញ្ចឹមជលផលតាមឆ្នេរ ជួយសម្រាលដល់ការចាប់ត្រីធម្មជាតិ។ ប្រទេសជប៉ុន ឈានមុខគេក្នុងវិស័យកសិកម្មជលផលប្រភេទនេះ។
- ដែនសមុទ្រអន្តរជាតិ ត្រូវតែដាក់ជាសម្បត្តិរួមរបស់ អ.ស.ប. ហើយផលនេសាទគួរត្រូវបានជាប្រយោជន៍រួមរបស់មនុស្សទាំងអស់គ្នានៅលើផែនដី។ រវាងប្រទេសក្រីក្រប្រកបរបរនេសាទធុនតូចជាមួយឧបករណ៍ប៉ះពាល់តិចតួចដល់បរិស្ថាន នេសាទសម្រាប់តែជាអាហារប្រចាំថ្ងៃ ហើយក៏ក្នុងចិញ្ចឹមប្រជានេសាទចំនួន២០លាននាក់ជាមួយគ្រួសារមួយផ្នែក និងមួយផ្នែកទៀត ប្រទេសពួកមានប្រើប្រាស់ទុនវិនិយោគដ៏សន្ធឹកសន្ធាប់ ប្រើប្រាស់ឧបករណ៍ទំនើបៗ នេសាទប្រើសម្រាប់រោងចក្រឧស្សាហកម្មអាហារមនុស្សនិងសត្វ តើមួយណាគួររក្សាទុកមួយណាត្រូវកាត់បន្ថយ។ សហគមន៍នេសាទពិភពលោកជាអ្នកផ្តល់ចម្លើយសមរម្យ ។

## ៤.២. គ្រោះថ្នាក់បណ្តាលមកពីកង្វក់បរិស្ថាន

សកម្មភាពមនុស្ស នៅតែជាមូលហេតុចម្បងដែលនាំឱ្យសមុទ្រជួបបញ្ហា "កង្វក់បរិស្ថាន" ។

### ក. លើឆ្នេរ

តំបន់មាត់សមុទ្របានក្លាយជាតំបន់ទាក់ទាញខ្លាំងជាងគេនៅពេលបច្ចុប្បន្ន ព្រោះតែតំបន់នេះ សម្បូរទៅដោយលក្ខណៈអនុគ្រោះច្រើនគឺៈ

- ជាប់សមុទ្រនិងមហាសមុទ្រជាប្រភពធនធានធម្មជាតិ
- ងាយស្រួលក្នុងទំនាក់ទំនងពិភពលោក

- អាកាសធាតុល្អប្រសើរសម្រាប់រស់នៅ ។

ភាពអនុគ្រោះទាំងនេះហើយ ដែលនាំឱ្យអ្នកវិនិយោគទុនទាំងឧស្សាហករ ពាណិជ្ជ ទេសចរ ផ្តោតចិត្តទុកដាក់ខ្លាំងមកលើតំបន់នេះ ។ ប្រភពនៃការបំពុលតំបន់ឆ្នេរមានដូចខាងក្រោម៖

បណ្តុំរោងចក្រឧស្សាហកម្ម ៖ បច្ចុប្បន្ននេះដោយមានការលើកទឹកចិត្តពីអ្នកនយោបាយ "សកលភាវូបនីយកម្មសេដ្ឋកិច្ច" រោងចក្រកំពង់ផែកើតព្រោងព្រាតដូចផ្សិតនៅតាមបណ្តោយឆ្នេរទាំង ប្រទេសអ្នកមានទាំងប្រទេសអ្នកក្រ ។ រោងចក្រប្រភេទនេះអាចឆ្លើយតបគ្រប់តម្រូវការរបស់ពិភពលោក ព្រោះតែទីតាំងពិសេសរបស់ខ្លួនមាន កំពង់ប្រេងកាត ឧស្ម័ន ឬ គ្រាប់ធញ្ញជាតិ ឈើ...។ រោងចក្រកំពង់ផែទាំងនេះលាតសន្ធឹងតាមឆ្នេរចង្អៀតកែច្នៃផលិតផលនាំចូល (គីមីប្រេងកាត ដែក ថែប) និងផលិតសម្រាប់នាំចេញ (វាយនភ័ណ្ឌ រថយន្ត ឧបករណ៍អេឡិចត្រូនិច) ។ កំពង់ផែទាំងអស់ នោះត្រូវបានតភ្ជាប់ជាមួយផ្លូវថ្នល់ ផ្លូវដែក ហើយខ្លះភ្ជាប់ជាមួយអាកាសយានដ្ឋានអន្តរជាតិដូចជា កំពង់ផែហុងកុងជាដើម ។ ប្រសិនបើតំបន់ឆ្នេរចង្អៀតខ្វះទីតាំងសាងសង់ គេអាចពង្រាបថ្ម ឬចាក់ បំពេញផ្ទៃសមុទ្រ (អាកាសយានដ្ឋានកាន់សៃ Kansai នៅប្រទេសជប៉ុន) ។

បណ្តុំប្រជាជនរស់នៅកុះករ ៖ នគរូបនីយកម្មត្រូវដើរទន្ទឹមគ្នានឹងការអភិវឌ្ឍសេដ្ឋកិច្ច។ សំណង់លំនៅស្ថាន មន្ទីរពេទ្យ សាលារៀន និងសំណង់ផ្សេងទៀតត្រូវបង្កើតឡើងសម្រាប់បំពេញ តម្រូវការរបស់មនុស្សដែលកាន់តែមកច្រើនឡើងៗឥតឈប់ឈរ ។ គេបានរកឃើញថា ក្នុងចំនួន ប្រជាជនសកលលោកទាំង 6.5 ពាន់លាននាក់មានចំនួនជាង 60% ទៅហើយដែលរស់នៅតាមឆ្នេរជាទី ដីចង្អៀតនេះ។ ម្យ៉ាងទៀតគេបានដឹងថា មានទីប្រជុំជនក្រុងចំនួន16 ដែលមានប្រជាជនលើសពី 10 លាននាក់ ។

តំបន់ឆ្នេរជាតំបន់កសិកម្មអតិផល ៖ បើទោះបីផ្ទៃដីតូចចង្អៀតក៏ដោយ ក៏កសិកម្មអភិផល ប្រព្រឹត្តទៅយ៉ាងសកម្មបំផុតនៅទីនេះ៖ ។ គេបានទប់សមុទ្រហើយបង្ហូត ដើម្បីយកដីធ្វើកសិកម្មអភិផល (បារាំង អ៊ីតាលី ជប៉ុន ចិន កូរ៉េ...) ដីដែលគេដណ្តើមបាននេះ គេរៀបចំឱ្យទៅជាទេសភាពកសិកម្ម ដែលមានទ្រង់ទ្រាយជាធរណីមាត្រ។ កសិកម្មប្រភេទនេះមិនអាចចៀសផុតពីប្រើ ជីគីមីនិងថ្នាំសម្លាប់សត្វល្អិតឡើយ ។

សកម្មភាពទេសចរណ៍ ៖ រៀងរាល់ថ្ងៃ ទេសចររាប់លាននាក់កំពុងដើរកំសាន្តស្នាក់នៅតំបន់ឆ្នេរ ។ ដើម្បីឆ្លើយតបនឹងកំណើនទេសចរគេបានរៀបចំឱ្យមានសណ្ឋាគារប្រណីត កន្លែងកំសាន្ត អគារតូចធំ កប៉ាល់កំសាន្ត កំពង់ផែទេសចរណ៍។ ដើម្បីទប់ទល់នឹងកំណើនទេសចរដ៏ច្រើនលើសលប់ ប្រទេសខ្លះបានកម្រិតទីតាំងសំណង់ទេសចរណ៍ ទីតាំងចរាចរណ៍ ការពារមជ្ឈដ្ឋានដែលងាយខូចខាត (លំនាច ផ្នូកខ្សាច់អ្នកទេសចរស្រឡាញ់ឆ្នេរដ៏ច្រើនសន្ធឹកសន្ធាប់ បានមកលេងកំសាន្តឆ្នេរ ក្នុងតំបន់ត្រូពិកចាប់ពីប្រទេសថៃដល់ម៉ិចស៊ិក និងនៅលើកោះមួយចំនួនក្នុងមហាសមុទ្រប៉ាស៊ីភិច និង មហាសមុទ្រឥណ្ឌា ។

យោងលើប្រភពដូចបានពោលខាងលើ ក្នុងកាកសំណល់ឧស្សាហកម្ម សំណល់លំនៅស្ថាន ។ សំណល់ច្រើនឬតិច ។ គេអាចចែកសារជាតុបំពុលជា 3 ផ្នែកគឺ និងសារជាតុពុលក្នុង សារជាតុពុលក្នុងកាកសំណល់កសិកម្ម គួរកត់សម្គាល់ថាកម្រិតជាតិពុលទាបឬខ្ពស់វាទាក់ទងទៅនឹងបរិមាណ។

- **កាកសំណល់ឧស្សាហកម្ម**

គ្រឿងម៉ាស៊ីនគ្រប់បែបយ៉ាងដែលប្រើឥន្ទនៈផូស៊ីល បញ្ចេញផ្សែងទៅក្នុងអាកាសធ្វើឱ្យពុល ។ សារជាតុពុលទាំងនោះ៖រួមផ្សំជាមួយភ្លៀង បង្កើតបានជាភ្លៀងអាស៊ីតធ្លាក់ស្រោចស្រព ហើយហូរចាក់ទៅក្នុងសមុទ្រធ្វើឱ្យ

ទឹកបាត់បង់តុល្យភាពគីមីសម្លាប់ទាំងរុក្ខជាតិ សត្វលើគោក សត្វសមុទ្រ ។ ចំពោះមនុស្សវិញអាកាសជាតុពុលធ្វើឱ្យមានភាពតឹងតែងក្នុងអារម្មណ៍និងជំងឺប្រជា ដកដង្ហើម ។ ចំពោះសំណល់រឹងរបស់រោងចក្រវិញ ថ្វីត្បិតតែគេបានរក្សាទុកក្នុងកន្លែងដ៏មានសុវ ភាពក៏ដោយក៏នៅតែជ្រាបឬលេចចេញនូវសារធាតុគ្រោះថ្នាក់បានដូចជាបារ៉ែតកាត់មីញ៉ូមជាដើម សំណល់មួយចំនួនត្រូវបានគេកែច្នៃឡើងវិញ ។

សំណល់ខ្លះទៀត បើទោះបីមានការហាមប្រាម ដោយ ក៏គេនៅតែលួចយកទៅទម្លាក់ក្នុងសមុទ្រ គេបានបង្កើតកិច្ចព្រមព្រៀងអន្តរជាតិជាច្រើន ដោយហាមប្រាមមិនឱ្យទម្លាក់កាកសំណល់គ្រោះថ្នាក់ទៅក្នុងសមុទ្រ ។ ប៉ុន្តែគេពុំសូវបានទទួលផល ល្អប៉ុន្មានទេ ព្រោះខ្វះមធ្យោបាយសម្រាប់ឃ្លាំមើល ។ អង្គការក្រៅរដ្ឋាភិបាល "គ្រីនភីស" (Green Peace) តែងពុំអាចឃ្លាំមើលសមុទ្រនិងមហាសមុទ្របានឡើយ ។ក្រៅពីនេះឆ្នេរត្រូវបានបំពុលដោយប្រេងកាតដែលលេចចេញពីនាវាដឹកប្រេងធំៗរងគ្រោះថ្នាក់ ខ្យល់ព្យុះ ឬការដាច់បំពង់បង្ហូរប្រេងធ្វើឱ្យឋានប្រព័ន្ធខូចខាតបំផ្លាញទាំងសត្វសមុទ្រទាំងរុក្ខជាតិសមុទ្រ ។ ករណីមួយទៀតដែលគួរឱ្យបារម្ភគឺការសង់រោងចក្រអគ្គិសនីនុយក្លេអ៊ែររបស់ប្រទេសអ្នកមាន ។ គេនិយមសង់នៅលើឆ្នេរ ព្រោះគេត្រូវការទឹកសម្រាប់ធ្វើឱ្យត្រជាក់ម៉ាស៊ីនរេអាក់ទ័រ (Réacteur) ។ ក្នុង ករណីគ្រោះថ្នាក់ជាយថាហេតុវិទ្យុសកម្មនឹងបំពុលទាំងអាកាស ទាំងទឹកក្នុងតំបន់ ។

- **កាកសំណល់កសិកម្ម**

កាកសំណល់គីមីដែលបានមកពីកសិកម្មមានសារធាតុនីត្រាតនិងសារធាតុដែលប្រើប្រាស់សម្រាប់សម្លាប់សត្វល្អិត គេបានប្រទះឃើញមាននៅក្នុងទឹកក្បែរឆ្នេរ ។ សារធាតុពុលទាំងនេះធ្វើឱ្យ ត្រីខ្វះខ្យល់ដកដង្ហើម ។

- **កាកសំណល់លំនៅស្ថាន**

ភាគច្រើនជាសំណល់ដែលអាចបំបែកជាតុជីវៈ គេយកទៅធ្វើជាជីកំប៉ុស ។ មួយផ្នែកទៀតគេ កែច្នៃឡើងវិញ ។ សំណល់ប្រភេទនេះមិនសូវប៉ះពាល់ខ្លាំងដល់បរិស្ថានទេ លើកលែងតែសំណល់វេជ្ជ សាស្ត្រដែលគ្រោះថ្នាក់ដល់សុខភាពមនុស្ស ។

**ខ. លំហសមុទ្រ**

តំបន់ដែលរងនូវការបំពុលខ្លាំងជាងគេគឺ ឆ្នេរសមុទ្រជាយទ្វីបដូចជា សមុទ្រឧត្តរ សមុទ្របាល់ទិច សមុទ្រមេឌីទែរ៉ាណេ បន្ទាប់គឺឆ្នេរមហាសមុទ្រធំៗ ព្រោះនៅទីនោះសកម្មភាពមនុស្សមានជាមមាញឹក ។ លំហសមុទ្រធំល្វឹងល្វើយហើយនៅឆ្ងាយពីសកម្មភាពមនុស្ស ត្រូវបានបំពុលក្នុងកម្រិតទាប។ អ្នកវិទ្យាសាស្ត្រអង់គ្លេសដែលបានតាមដាន pH ក្នុងទឹកសមុទ្រជ្រៅជាប្រចាំបានបញ្ជាក់ថា ទឹកសមុទ្រជ្រៅកើនជាតិអាស៊ីតគួរឱ្យបារម្ភដែរ។ តើគួរទុកចិត្តថា មហាអំណាចឧស្សាហកម្មធំៗដែលមាន មធ្យោបាយគ្រប់គ្រាន់មិនបានរំលោភមហាសមុទ្រ ដោយលួចទម្លាក់កាកសំណល់ឧស្សាហកម្មគ្រោះថ្នាក់ឬទេ? ដើម្បីបេតិកភណ្ឌពិភពលោកមួយឋិតថេរចីរកាលយូរអង្វែងសម្រាប់មនុស្សជាតិ "អភិវឌ្ឍគប្បីដើរទន្ទឹមគ្នានឹងអភិរក្ស ។

**សំណួរត្រិះរិះ**

១. ហេតុអ្វីបានជាការនេសាទត្រូវតែគោរពទៅតាមបច្ចេកទេសនេសាទ? ចូរពន្យល់។
២. តើផលអាក្រក់នៃបរិស្ថានសមុទ្របណ្ដាលឲ្យមានគ្រោះថ្នាក់អ្វីខ្លះ?